# ព្រះ
# ត្រៃបិដក

## ប្រែរួមនឹង
## ព្រះអដ្ឋកថា

## ភាគ៣៣

បាលីប្រែ ៥២

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

# និង

# បរមត្ថជោតិកា អដ្ឋកថា

## សេចក្តីប្រែជាភាសាខ្មែរ

# ខុទ្ទកនិកាយ

# ខុទ្ទកបាឋ ធម្មបទគាថា ឧទាន

# បឋមភាគ

# ៣៣

# បាលីប្រែ ៥២



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ភាគទី ៣៣

# សុត្តន្តបិដក ខុទ្ទកនិកាយ

## ធម្មបទគាថា ចិត្តវគ្គទី ៣

[ ១៣ ] អ្នកប្រាជ្ញ តែងធ្វើចិត្តដែលញាប់ញ័រ ឃ្លេងឃ្លោង រក្សាបានដោយកម្រ ហាមឃាត់បានដោយលំបាក ឲ្យជាចិត្តត្រង់បាន ដូចអ្នកធ្វើព្រួញពត់ព្រួញឲ្យត្រង់ ។ ចិត្តនេះដែលបុគ្គលលើកឡើងចាកអាល័យ គឺកាមគុណ ៥ បោះទៅក្នុងវិបស្សនាកម្មដ្ឋាន ដើម្បីលះបង់នូវវដ្តៈ ជាទីនៅនៃមារ រមែងញាប់ញ័រ ។ ដូចត្រីដែលគេលើកឡើងចាកទីនៅ គឺទឹក បោះទៅលើគោក ដូច្នោះឯង ។

ការទូន្មានចិត្ត ដែលសង្កត់សង្កិន បានដោយលំបាក ជាធម្មជាតរហ័ស មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្ដីប្រាថ្នា ក្នុងអារម្មណ៍ណាមួយ រមែងជាគុណញុំាងប្រយោជន៍ឲ្យសម្រេច ( ព្រោះថា ) ចិត្តដែលហ្វឹកហ្វឺនបានហើយ រមែងនាំមកនូវសេចក្ដីសុខ ។

អ្នកមានប្រាជ្ញា គួររក្សាចិត្តដែលឃើញដោយកម្រក្រៃពេក ដែលល្អិតពេកណាស់ មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្ដីប្រាថ្នា ក្នុងអារម្មណ៍ណាមួយ ( ព្រោះថា ) ចិត្តដែលគេរក្សាបានហើយ រមែងនាំមកនូវសេចក្ដីសុខ ។

អ្នកទាំងឡាយណា នឹងសង្រួមចិត្តដែលទៅឆ្ងាយ ជាចិត្តត្រាច់ទៅតែឯង មិនមានសរីរៈ មានគុហា គឺមហាភូតរូប ៤ ជាទីអាស្រ័យនៅ អ្នកទាំងនោះឯង រមែងរួចចាកចំណងនៃមារ ។

ប្រាជ្ញា រមែងមិនបរិបូណ៌ដល់បុគ្គលដែលមានចិត្តមិនខ្ជាប់ខ្ជួន មិនដឹងច្បាស់នូវព្រះសទ្ធម្ម មានសេចក្តីជ្រះថ្លាអណ្តែតទៅ ។ ភ័យ រមែងមិនមានដល់បុគ្គលអ្នកមានចិត្តមិនទទឹកដោយរាគៈ មានចិត្តដែលទោសខ្ទាំងខ្ទប់មិនបាន មានបុណ្យ និងបាបលះចោលហើយ ភ្ញាក់រឭកជានិច្ច ។ បុគ្គលគប្បីដឹងច្បាស់នូវកាយនេះថា ដូចជាឆ្នាំង គប្បីបិទនូវចិត្តនេះ ឲ្យដូចជាបិទទ្វារនគរ ដើម្បីច្បាំងនូវមារដោយអាវុធ គឺបញ្ញា គប្បីរក្សាទុកនូវធម៌ ដែលខ្លួនឈ្នះហើយ មិនគប្បីជាអ្នកជំអក់នៅ ( ក្នុងធម៌នោះ ) ឡើយ ។

ឱហ្ន៎ មិនយូរប៉ុន្មានទេតើ កាយនេះ មានវិញ្ញាណទៅប្រាស គេយកទៅចោលផុតហើយ មុខជានឹងដេកស្តូកស្តឹងលើផែនដី ដូចជាអង្កត់ឧសរកប្រយោជន៍គ្មាន ។

ចោរក្រឡេកឃើញចោរផងគ្នា ឬក៏បុគ្គលមានពៀរ ក្រឡេកឃើញបុគ្គលមានពៀរផងគ្នា គប្បីធ្វើនូវសេចក្តីវិនាសណាមួយ ដល់គ្នា ចិត្តដែលបុគ្គលតាំងទុកខុសហើយ រមែងធ្វើបុគ្គលនោះ ឲ្យអាក្រក់ក្រៃលែងជាងសេចក្តីវិនាសនោះទៅទៀត ។

មាតា បិតា មិនគប្បីធ្វើហេតុនោះបាន ឬជនទាំងឡាយដទៃជាញាតិ មិនគប្បីធ្វើនូវហេតុនោះបាន ចំណែកខាងចិត្ត ដែលបុគ្គលតាំងទុកត្រូវហើយ រមែងធ្វើបុគ្គលនោះ ឲ្យប្រសើរជាងហេតុនោះបាន ។

**ចិត្តវគ្គទី ៣ ចប់**

# អដ្ឋកថា

# ចិត្តវគ្គទី ៣

## រឿងមេឃិយត្ថេរ

### លំនាំដើម

ព្រះសាស្តា កាលគង់នៅត្រង់ភ្នំឈ្មោះចាលិកា ទ្រង់ប្រារព្ធដល់ព្រះមេឃិយៈ ត្រាស់ធម្មទេសនានេះថា **ផន្ទនំ ចបលំ ចិត្តំ** ជាដើម ។

មេឃិយសូត្រ[១] ទាំងអស់ បណ្ឌិតគប្បីសម្តែងឲ្យពិស្តារ ដើម្បីឲ្យរឿងនៃព្រះមេឃិយត្ថេរនោះជាក់ច្បាស់ ព្រះសាស្តាត្រាស់ហៅព្រះមេឃិយត្ថេរ ដែលមិនអាចប្រកបសេចក្តីព្យាយាមក្នុងអម្ពវ័ននោះបាន ព្រោះភាពដែលលោកត្រូវវិតក្ក ៣ គ្របសង្កត់ហើយ ត្រាស់ថា ម្នាលមេឃិយៈ អ្នកលះបង់តថាគតដែលអង្វរហើយថា ម្នាលមេឃិយៈ តថាគតនៅម្នាក់ឯង ចូរអ្នកបង្អង់សិនទម្រាំភិក្ខុដទៃរូបខ្លះប្រាកដ ដូច្នេះ ទុកតថាគតនៅតែឯង ហើយទៅ ឈ្មោះថាធ្វើកម្មដ៏ធ្ងន់ ។ ឈ្មោះថា ភិក្ខុមិនគួរជាធម្មជាតស្ទុះទៅរហ័ស ការញុំាងចិត្តនោះឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួន រមែងគួរ ដូច្នេះហើយ ទើបទ្រង់ភាសិតព្រះគាថា ២ ព្រះគាថានេះថា

---

១- បិ. ៥៣ ទំ. ១៩២ ។

**ផន្ទនំ ចបលំ ចិត្តំ ទុរក្ខំ ទុន្និវារយំ**
**ឧជុំ ករោតិ មេធាវី ឧសុការោវ តេជនំ ។**
**វារិជោវ ថលេ ខិត្តោ ឱកមោកតឧព្ភតោ**
**បរិផន្ទតិទំ ចិត្តំ មារធេយ្យំ បហាតវេ ។**

*អ្នកប្រាជ្ញតែងធ្វើចិត្តដែលញាប់ញ័រ ឃ្លេងឃ្លោង រក្សាបានដោយកម្រ ហាមឃាត់បានដោយលំបាក ឲ្យជាចិត្តត្រង់បាន ដូចអ្នកធ្វើព្រួញ ពត់ព្រួញឲ្យត្រង់ ។ ចិត្តនេះ ដែលបុគ្គលលើកឡើងចាកអាល័យពីកាមគុណ ៥ បោះទៅក្នុងវិបស្សនាកម្មដ្ឋាន ដើម្បីលះបង់នូវវដ្តៈ ជាទីនៅនៃមារ រមែងញាប់ញ័រ ដូចត្រីដែលគេលើកឡើង ចាកទីនៅ គឺទឹក បោះទៅលើគោក ដូច្នោះឯង ។*

## សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ បទថា* **ផន្ទនំ** *គឺអន្ទះអន្ទែងនៅក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើម ។*

*បទថា* **ចបលំ** *សេចក្តីថា មិនតាំងនៅក្នុងអារម្មណ៍មួយបាន ដូចទារកក្នុងស្រុក មិនស្ងៀមនៅដោយឥរិយាបថមួយដូច្នោះ ទើបឈ្មោះថាញាប់ញ័រ ។*

*បទថា* **ចិត្តំ** *បានដល់ វិញ្ញាណ ។ វិញ្ញាណនោះ ព្រះដ៏មានព្រះភាគត្រាស់ហៅថា ចិត្ត ព្រោះជាធម្មជាតវិចិត្រដោយភូមិ វត្ថុ អារម្មណ៍ និងវិថីចិត្ត មានកិរិយាចិត្តជាដើម ។*

*បទថា* **ទុរក្ខំ** *សេចក្តីថា ឈ្មោះថា ដែលបុគ្គលរក្សាបានដោយលំបាក*

ព្រោះតាំងទុកបានលំបាកក្នុងអារម្មណ៍ ដែលជាទីសប្បាយមួយនោះឯង ដូចគោដែលធ្លាប់ទំពាស៊ីស្រូវក្នុងស្រែ ដែលដេរដាសទៅដោយសម្ទួង ដូច្នោះ ។

បទថា **ទុន្និវារយំ** សេចក្តីថា ឈ្មោះថាដែលបុគ្គលហាមបានលំបាក ព្រោះជាធម្មជាតដែលរក្សាបានលំបាក ដើម្បីនឹងហាម គឺរាំងចិត្តដែលទៅកាន់វិសភាគារម្មណ៍ ។

ពីរបទថា **ឧសុការោវ តេជនំ** សេចក្តីថា ជាងព្រួញនាំយកកំណាត់ឈើមួយមកអំពីព្រៃហើយ ធ្វើមិនឲ្យមានសម្បក ហើយលាបដោយទឹកបាយនិងប្រេង រោលត្រង់អំបែងរងើកភ្លើង ពត់ត្រង់ប្រគាបឈើ ធ្វើឲ្យបាត់វៀច គឺឲ្យត្រង់ ឲ្យជារបស់គួរបាញ់រោមទ្រាយបាន កាលធ្វើហើយ ទើបសំដែងសិប្បៈដល់ព្រះរាជា និងរាជមហាមាត្យ រមែងបានសក្ការៈ និងការរាប់អានដ៏ច្រើន យ៉ាងណា បុរសអ្នកមានប្រាជ្ញា គឺបុរសឈ្លាស បានដល់ បុគ្គលដឹងច្បាស់ ក៏ដូច្នោះដូចគ្នា គឺធ្វើចិត្តនេះដែលមានសភាពញាប់ញ័រជាដើម ឲ្យអស់សម្បក គឺឲ្យប្រាសចាកកិលេសដែលគ្រោតគ្រាត ដោយអំណាចធុតង្គនិងការនៅក្នុងព្រៃ ហើយលាបដោយជ័រ គឺសទ្ធា រោលដោយការព្យាយាមដែលប្រព្រឹត្តទៅតាមផ្លូវកាយ និងតាមចិត្ត ពត់ត្រង់ប្រគាប គឺសមថៈ និងវិបស្សនា ធ្វើឲ្យត្រង់ គឺមិនឲ្យវៀច បានដល់ ឲ្យអស់ព្យសន៍ កាលធ្វើហើយពិចារណាសង្ខារទាំងឡាយ ទម្លាយបង់នូវគំនរអវិជ្ជាធំបានហើយ ធ្វើគុណវិសេសនេះ គឺវិជ្ជា ៣ អភិញ្ញា ៦ លោកុត្តរធម៌ ៩ ឲ្យនៅក្នុងកណ្តាប់ដៃនោះឯង រមែងបានជាទក្ខិណេយ្យបុគ្គលដ៏កំពូល ។

បទថា **វារិជោវ** ប្រែថា ដូចត្រី ។ ពីរបទថា **ថលេ ខិត្តោ** បានដល់ ដែលព្រានសន្ទូចបោះទៅលើគោកដោយដៃ ជើង ឬដោយគ្រឿងដាក់ មានសំណាញ់ជាដើម ណាមួយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបាទព្រះគាថាថា **ឱកមោកតឧព្ភតោ** ដូចតទៅនេះ ទឹក ឈ្មោះថា **ឱក** ក្នុងពាក្យនេះថា **ឱកបុណ្ណេហិ ចីវរេហិ កិលន្ត-រូបា យេន សាវត្ថី** ភិក្ខុអ្នកក្រុងបាឋា ក៏មានចីវរទាំងឡាយទទឹកជោក បានសេចក្ដីលំបាកកាយ នាំគ្នាដើរសំដៅទៅកាន់ក្រុងសាវត្ថី ។ អាល័យ ឈ្មោះថា **ឱក** ដូចក្នុងពាក្យនេះថា **ឱកំ បហាយ អនិកេតសារី** ព្រះតថាគតលះបង់នូវផ្ទះ ( អាល័យ ) ជាអ្នកមិនមានការអន្ទោលទៅរកកន្លែងស្នាក់ ( អារម្មណ៍ទាំង ៦ ) ។ ពាក្យទាំងពីរ ក៏រមែងបានក្នុងបាទព្រះគាថានេះ ។ ក្នុងបទថា **ឱកមោកតោ** នេះ មានអត្ថដូច្នេះ ចាកលំនៅ គឺទឹក ចាកអាល័យ ពោល គឺទឹក ។ បទថា **ឧព្ភតោ** ប្រែថា ដែលព្រានសន្ទូចលើកឡើងហើយ ។

បាទព្រះគាថាថា **បរិផន្ទតិទំ ចិត្តំ** សេចក្ដីថា ចិត្តនេះ គឺដែលត្រេកអរហើយ ក្នុងអាល័យ គឺកាមគុណ ៥ ដែលព្រះយោគាវចរលើកឡើងហើយចាកអាល័យ គឺកាមគុណ ៥ នោះ បោះទៅក្នុងវិបស្សនាកម្មដ្ឋាន ពោលដោយការព្យាយាម ដែលប្រព្រឹត្តទៅតាមផ្លូវកាយ និងចិត្ត ដើម្បីលះវដ្ដៈពោល គឺអន្ទាក់មារ រមែងអន្ទះអន្ទែង គឺរមែងមិនអាចតាំងនៅក្នុងវិបស្សនា-កម្មដ្ឋាននោះបានដូចត្រីនោះ កាលព្រានសន្ទូចលើកឡើងអំពីអាល័យ គឺទឹក

ហើយបោះទៅលើគោក កាលមិនបានទឹករមែងអន្ទះអន្ទែង ដូច្នោះ ។ កាលបើដូច្នេះ បុគ្គលអ្នកមានបញ្ញា មិនដាក់ធុរៈ រមែងធ្វើចិត្តនោះឲ្យត្រង់ គឺឲ្យគួរដល់ការងារ ដោយន័យដែលពោលហើយនោះឯង ។

ម្យ៉ាងទៀត ចិត្តនេះ កាលលះអន្ទាក់មារ គឺកិលេសវដ្តមិនបាន តាំងនៅ រមែងអន្ទះអន្ទែងដូចត្រី ដូច្នោះ ព្រោះដូច្នោះ ព្រះយោគាវចរ គួរលះអន្ទាក់មារ គឺគួរលះអន្ទាក់មារ ពោល គឺកិលេសវដ្ត ដែលជាហេតុអន្ទះអន្ទែងនៃចិត្តនោះ ដូច្នេះឯង ។

ក្នុងកាលចប់គាថា ព្រះមេឃិយត្ថេរបានតាំងនៅក្នុងសោតាបត្តិផល ជនដ៏ច្រើន ក៏បានជាអរិយបុគ្គល មានសោតាបន្នបុគ្គលជាដើមដូច្នេះឯង ។៚

**រឿង ព្រះមេឃិយត្ថេរ ចប់**

# រឿង អញ្ញតរភិក្ខុ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអញ្ញតរភិក្ខុ ១ អង្គ ត្រាស់ព្រះធម្មទេសនានេះថា **ទុន្និគ្គហស្ស លហុនោ** ជាដើម ។

បានឮថា មានស្រុកមួយឈ្មោះមាតិកគ្រាម ក្បែរជើងភ្នំក្នុងដែនរបស់ព្រះបាទកោសល ។ ថ្ងៃមួយ ភិក្ខុប្រមាណ ៦០ រូប ទូលអាពធនា សូមព្រះមានព្រះភាគត្រាស់ប្រាប់កម្មដ្ឋាន អំពីភាពជាព្រះអរហន្ត ក្នុងសម្នាក់នៃព្រះ

សាស្តាហើយ ទៅកាន់ស្រុកនោះ ចូលទៅដើម្បីបិណ្ឌបាត ។ លំដាប់នោះ ម្ចាស់របស់ស្រុកនោះ ឈ្មោះថាមាតិកៈ ជាមាតារបស់ជាម្ចាស់ស្រុកនោះ ឃើញភិក្ខុទាំងនោះហើយ និមន្តឲ្យគង់ក្នុងផ្ទះ អង្គាសដោយបបរ និងកត្តមាន រសដ៏ប្រសើរផ្សេងៗ សួរថា លោកម្ចាស់ទាំងឡាយ បំណងនឹងទៅក្នុងទីណា ភិក្ខុទាំងនោះប្រាប់ថា មហាឧបាសិកា ពួកអាត្មាបំណងនឹងទៅតាមផាសុក នាងដឹងថា ភិក្ខុទាំងឡាយប្រហែលជាស្វែងរកទីកន្លែងសម្រាប់ចាំវស្សា ទើប ក្រាបចុះទៀបបាទា ហើយពោលថា បើលោកម្ចាស់ទាំងឡាយនៅក្នុងទីនេះ ៣ ខែសោត ខ្ញុំនឹងទទួលសរណៈ ៣ សីល ៥ នឹងធ្វើឧបោសថកម្ម ។ ភិក្ខុ ទាំងឡាយប្រឹក្សាគ្នាថា យើងទាំងឡាយ កាលអាស្រ័យឧបាសិកានេះ មិន មានសេចក្តីលំបាកដោយភិក្ខា អាចធ្វើការរលាស់ចេញចាកភពបាន ដូច្នេះ ហើយទើបទទួលពាក្យ នាងបានជម្រះវិហារដែលជាលំនៅ ប្រគេនដល់ភិក្ខុ ទាំងនោះ ។

ភិក្ខុទាំងនោះ កាលនៅក្នុងទីនោះ ថ្ងៃមួយ បានប្រជុំគ្នាហើយ ដាស់តឿន គ្នានិងគ្នាថា អាវុសោ ពួកយើងមិនគួរប្រព្រឹត្តដោយសេចក្តីប្រមាទ ព្រោះមហា នរក ៨ រណ្តៅ មានទ្វារបើករង់ចាំពួកយើង ដូចផ្ទះរបស់ខ្លួននោះឯង ឯពួក យើងបានរៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះពុទ្ធ ដែលទ្រង់គង់ព្រះជន្មនៅឡើយ ហើយទើបមក ធម្មតាព្រះពុទ្ធទាំងឡាយ បុគ្គលណាម្នាក់ដែលជាអ្នកអួតអាង សូម្បីត្រាច់ទៅតាមស្នាមព្រះបាទ ក៏មិនអាចឲ្យទ្រង់ប្រោសប្រាណបាន តែ បុគ្គលដែលមានអធ្យាស្រ័យជាប្រក្រតីប៉ុណ្ណោះ អាចឲ្យទ្រង់ប្រោសប្រាណ

បាន អ្នកទាំងឡាយ ចូរជាបុគ្គលមិនប្រមាទចុះ ។ ពួកយើងមិនគួរឈរ មិនគួរអង្គុយ ក្នុងទីមួយកន្លែងពីររូប តែក្នុងកាលទំនុកបម្រុងព្រះថេរៈក្នុងពេលល្ងាច និងកាលដែលជាភិក្ខាចារក្នុងពេលព្រឹកប៉ុណ្ណោះ សឹមពួកយើងជួបជុំគ្នា តែក្នុងកាលដ៏សេស នឹងមិននៅរួមគ្នាពីររូប ម្យ៉ាងទៀត កាលភិក្ខុមិនមានផាសុក គឺមានជំងឺ វាយជួងក្នុងកណ្ដាលវិហារហើយ សឹមពួកយើងមកតាមសញ្ញានៃជួង ធ្វើថ្នាំឲ្យដល់ភិក្ខុនោះ ។

កាលភិក្ខុទាំងនោះ ធ្វើកតិកាគ្នាយ៉ាងនេះ ថ្ងៃមួយ ឧបាសិកានោះឲ្យបុគ្គលកាន់ភេសជ្ជៈទាំងឡាយ មានសប្បិ និងទឹកអំពៅជាដើម ដែលជនទាំងឡាយមានទាសៈ និងកម្មករជាដើម ចោមរោមដើរទៅកាន់វិហារនោះ ក្នុងពេលល្ងាច មិនឃើញភិក្ខុទាំងឡាយក្នុងវិហារហើយ ទើបសួរពួកបុរសថា លោកម្ចាស់ទាំងឡាយទៅក្នុងទីណាអស់ហ្ន៎ កាលពួកជនទាំងនោះប្រាប់ថា លោកម្ចាស់ទាំងឡាយ ជាអ្នកអង្គុយក្នុងទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃរៀងៗ ខ្លួនប៉ុណ្ណោះ ទើបពោលតទៅថា ខ្ញុំធ្វើដូចម្ដេចហ្ន៎ ទើបអាចជួបលោកម្ចាស់ទាំងនោះបាន ។

លំដាប់នោះ មនុស្សទាំងឡាយដែលដឹងកតិកាវត្តរបស់ភិក្ខុសង្ឃ ទើបប្រាប់ឧបាសិកានោះថា បពិត្រអ្នកម្ដាយ លោកម្ចាស់ទាំងឡាយនឹងប្រជុំគ្នាក្នុងកាលបុគ្គលមកវាយជួង ទើបនាងឲ្យវាយជួង ភិក្ខុទាំងឡាយបានឮសំឡេងជួងហើយ ចេញអំពីលំនៅរៀងៗ ខ្លួន ដោយសម្គាល់ថាភិក្ខុរូបខ្លះ នឹងមិនមានផាសុក ទើបប្រជុំគ្នាត្រង់កណ្ដាលវិហារ ភិក្ខុឈ្មោះថា និមន្តដោយផ្លូវជាមួយ

គ្នាពីររូបមិនមាន ។

ឧបាសិកាឃើញភិក្ខុមួយរូបៗ ប៉ុណ្ណោះ ដើរមកអំពីទីកន្លែងនីមួយៗ ទើបគិតថា ប្រហែលលោកម្ចាស់ដែលជាកូនរបស់អញ ធ្វើនូវការឈ្លោះទាស់ទែងនូវគ្នានិងគ្នា ដូច្នេះហើយ ថ្វាយបង្គំភិក្ខុសង្ឃពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់ទាំងឡាយបានធ្វើនូវការឈ្លោះគ្នាឬ ភិក្ខុទាំងឡាយពោលថា មហាឧបាសិកា ពួកអាត្មាមិនបានធ្វើការឈ្លោះទាស់ទែងគ្នាឡើយ ។ ឧបាសិកាពោលថា បពិត្រលោកម្ចាស់ បើលោកម្ចាស់ទាំងឡាយមិនមានការវិវាទគ្នាសោត បើដូច្នោះ ហេតុអ្វី ទើបមិននិមន្តមកដូចកាលមកកាន់ផ្ទះរបស់ខ្ញុំ មកដោយរួមគ្នាទាំងអស់ តែពេលនេះ បែរជាមកមួយអង្គៗ អំពីទីមួយកន្លែងៗ ។ ភិក្ខុទាំងឡាយពោលថា មហាឧបាសិកា ពួកអាត្មាអង្គុយធ្វើសមណធម៌ ក្នុងទីមួយកន្លែងរៀងៗ ខ្លួន ។ ឧបាសិកាពោលថា លោកម្ចាស់ទាំងឡាយ ឈ្មោះថាសមណធម៌នោះ គឺអ្វី ភិក្ខុទាំងឡាយពោលថា មហាឧបាសិកា ពួកអាត្មាស្វាធ្យាយអាការ ៣២ ផ្តើមតាំងនូវការអស់ទៅ សូន្យទៅក្នុងអត្តភាព ។ ឧបាសិកាពោលថា បពិត្រលោកម្ចាស់ ការស្វាធ្យាយអាការ ៣២ និងការផ្តើមតាំងនូវការអស់ទៅ សូន្យទៅក្នុងអត្តភាព រមែងសមគួរដល់លោកម្ចាស់ទាំងឡាយប៉ុណ្ណោះឬ ឬអាចសមគួរដល់យើងខ្ញុំដែរ ។ ភិក្ខុទាំងឡាយពោលថា មហាឧបាសិកា ធម៌នេះ ព្រះដ៏មានព្រះភាគ ទ្រង់មិនបានហាមដល់បុគ្គលណាម្នាក់ឡើយ ។ ឧបាសិកាពោលថា បើដូច្នោះ សូមលោកម្ចាស់ទាំងឡាយឲ្យអាការ ៣២ នឹងសូមប្រាប់ការផ្តើមចម្រើននូវការអស់ទៅ និងសូន្យទៅក្នុង

អត្តភាពដល់ខ្ញុំផងចុះ ។ ភិក្ខុទាំងឡាយពោលថា មហាឧបាសិកា បើយ៉ាង នោះ ចូរនាងរៀនយកចុះ ហើយឲ្យរៀនយកទាំងអស់ ។

ចាប់តាំងអំពីនោះ ឧបាសិកានោះក៏បានធ្វើការស្វាធ្យាយនូវអាការ ៣២ និងផ្ដើមនូវការអស់ទៅ សូន្យទៅក្នុងខ្លួន បានសម្រេចមគ្គ ៣ ផល ៣ មុន ភិក្ខុទាំងនោះឯង បដិសម្ភិទា ៤ និងលោកិយអភិញ្ញា បានមកដល់ឧបាសិកា នោះដោយមគ្គនោះឯង ។ នាងចេញអំពីសុខដែលកើតអំពីមគ្គ និងផលហើយ សម្លឹងមើលដោយទិព្វចក្ខុ ពិចារណាថា កាលណាហ្ន៎ ទើបលោកម្ចាស់ជា កូនរបស់អញសម្រេចធម៌នេះ ។ ហើយអាវជ្ជនៈតទៅថា លោកម្ចាស់ទាំង-ឡាយនេះនៅមានរាគៈ នៅមានទោសៈ នៅមានមោហៈ លោកម្ចាស់ទាំង នោះមិនមានគុណធម៌ត្រឹមតែឈាន និងវិបស្សនាឡើយ ឧបនិស្ស័យនៃ អរហត្តរបស់លោកម្ចាស់ ដែលជាកូនរបស់អញមានឬហ្ន៎ ឃើញថា មាន ដូច្នេះហើយ ទើបអាវជ្ជនៈថា សេនាសនៈដែលជាសប្បាយមានឬ មិនមានហ្ន៎ ឃើញសេនាសនៈជាទីសប្បាយហើយ ទើបពិចារណាថា លោកម្ចាស់ទាំង-ឡាយរបស់អញ មិនទាន់បានបុគ្គលជាទីសប្បាយឬ ក៏ឃើញបុគ្គលជាទី សប្បាយហើយទើបពិចារណាទៀតថា លោកម្ចាស់ទាំងឡាយ មិនបានអាហារ ជាទីសប្បាយឬ ក៏បានឃើញថា អាហារដែលជាទីសប្បាយ មិនមានដល់ពួក លោក ។ ចាប់តាំងអំពីនោះមក ក៏រៀបចំបបរដែលមានបែបផ្សេងៗ និង របស់ទំពាជាច្រើនប្រការ និងភោជនមានរសដ៏លើសផ្សេងៗ ហើយនិមន្តភិក្ខុ ទាំងឡាយឲ្យគង់ហើយ ទើបប្រគេនទឹកទក្ខិណោទកហើយ ប្រគេនដោយ

ពាក្យថា បពិត្រលោកម្ចាស់ លោកម្ចាស់ទាំងឡាយពេញចិត្តវត្ថុណាមួយ សូមកាន់យកវត្ថុនោះៗ ឆាន់ចុះ ។

ភិក្ខុទាំងនោះទទួលយកវត្ថុទាំងឡាយ មានបបរជាដើមហើយ ក៏បរិភោគតាមគាប់ចិត្ត ។ កាលភិក្ខុទាំងនោះ បានអាហារជាទីសប្បាយ ចិត្តក៏ជាធម្មជាតមានអារម្មណ៍មួយ ។ ពួកលោកមានចិត្តចុះស៊ប់ ចម្រើនវិបស្សនាក្នុងកាលមិនយូរ ក៏បានសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ ហើយគិតថា គួរអរគុណមហាឧបាសិកា ជាទីពឹងរបស់ពួកយើង បើពួកយើងមិនបានអាហារ ដែលជាទីសប្បាយហើយសោត ការសម្រេចមគ្គ និងផល ក៏គង់មិនមានដល់ពួកយើង ឥឡូវនេះ ពួកយើងនៅចាំវស្សាបវារណាហើយនឹងទៅកាន់សម្នាក់របស់ព្រះសាស្តា ។

ភិក្ខុទាំងឡាយលាមហាឧបាសិកាថា ពួកអាត្មានឹងគាល់ព្រះសាស្តា មហាឧបាសិកាពោលថា សាធុ លោកម្ចាស់ ហើយជូនដំណើរភិក្ខុទាំងនោះពោលពាក្យដែលជាទីស្រឡាញ់ដ៏ច្រើនថា សូមលោកម្ចាស់ទាំងឡាយ មកសួរសុខទុក្ខខ្ញុំទៀត ដូច្នេះជាដើម ហើយទើបត្រឡប់ ។

ចំណែកភិក្ខុទាំងនោះឯង កាលដល់នគរសាវត្ថីហើយ ថ្វាយបង្គំព្រះសាស្តាហើយ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង កាលព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកល្មមអត់ធន់បានដែរឬ ពួកអ្នកល្មមញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបានដែរឬ ម្យ៉ាងទៀត ពួកអ្នកមិនលំបាកដោយបិណ្ឌបាតទេឬ ទើបក្រាបទូលថា បពិត្រព្រះអង្គ ពួកខ្ញុំព្រះអង្គល្មមអត់ធន់បាន ល្មម

ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបាន ម្យ៉ាងទៀត ពួកខ្ញុំព្រះអង្គមិនលំបាកដោយបិណ្ឌបាតឡើយ ព្រោះឧបាសិកាម្នាក់ ឈ្មោះមាតិកមាតាជ្រាបវារចិត្តរបស់ពួកខ្ញុំព្រះអង្គ ។ កាលពួកខ្ញុំព្រះអង្គគិតថា ធ្វើម្តេចហ្ន៎ មហាឧបាសិកាគប្បីចាត់ចែងអាហារឈ្មោះនេះ ដើម្បីពួកយើង នាងក៏ចាត់ចែងអាហារប្រគេនតាមដែលពួកខ្ញុំព្រះអង្គគិតហើយ ដូច្នេះហើយ ក៏ពោលសរសើរគុណរបស់មហា-ឧបាសិកានោះ ។

ភិក្ខុមួយរូប ស្តាប់ពាក្យសរសើរគុណរបស់មហាឧបាសិកានោះហើយ ជាអ្នកប្រាថ្នានឹងទៅក្នុងទីនោះ រៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះសាស្តាហើយ ទូលលាព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងទៅកាន់ស្រុកនោះ ហើយចេញអំពីវត្តជេតពន ដល់ស្រុកនោះដោយលំដាប់ ក្នុងថ្ងៃដែលខ្លួនចូលទៅកាន់វិហារ គិតថា បានឮថា ឧបាសិកានេះរមែងដឹងដល់ហេតុដែលបុគ្គលដទៃគិតហើយ ឯអាត្មាអញហត់នឿយហើយ ក្នុងការដើរផ្លូវ មិនអាចបោសវិហារបាន ធ្វើម្តេចហ្ន៎ ឧបាសិកានេះ គប្បីបញ្ជូនមនុស្សអ្នកជម្រះវិហារ មកដើម្បីយើង ។

ឧបាសិកាអង្គុយក្នុងផ្ទះនោះឯង ជ្រាបសេចក្តីនោះហើយ ទើបបញ្ជូនមនុស្សទៅដោយពាក្យថា ចូរអ្នកទៅជម្រះវិហារហើយសឹមមក ចំណែកភិក្ខុក្រៅអំពីនេះចង់ផឹកទឹក គិតថា ធ្វើម្តេចហ្ន៎ឧបាសិកានេះគប្បីធ្វើទឹកផឹក លាយដោយស្ករផែន បញ្ជូនមកឲ្យដល់អញ ឧបាសិកាក៏បានបញ្ជូនទឹកនោះមកឲ្យ ។ លោកគិតទៀតថា ចូរឧបាសិកាបញ្ជូនបបរ ដែលមានរសប្រណីត និងសម្

ឧត្តរិភង្គ មកដើម្បីអញក្នុងថ្ងៃស្អែកនេះ អំពីព្រលឹមចុះ ។ ឧបាសិកាបាន ធ្វើយ៉ាងនោះ ។

ភិក្ខុឆាន់បបរហើយគិតថា ធ្វើម្ដេចហ្ន៎ ឧបាសិកាគប្បីបញ្ជូនរបស់ទំពា បែបនេះមកដើម្បីអញ ។ ឧបាសិកាក៏បានបញ្ជូនខាទនីយនោះទៅហើយ លោក គិតថា ឧបាសិកានេះបញ្ជូនវត្ថុដែលអញគិតហើយគ្រប់ៗ វត្ថុមក អញចង់ជួប ឧបាសិកានោះ ធ្វើម្ដេចហ្ន៎ នាងគប្បីឲ្យមនុស្សកាន់ភោជន មានរសផ្សេងៗ ដើម្បីអញ មកដោយខ្លួនឯង ។ ឧបាសិកាគិតថា ភិក្ខុជាកូនរបស់អញបំណង នឹងឃើញអញ ទន្ទឹងការទៅរបស់អញ ដូច្នេះហើយ ទើបឲ្យមនុស្សកាន់ភោជន ទៅកាន់វិហារហើយ បានប្រគេនដល់ភិក្ខុនោះ ។ ភិក្ខុនោះ ធ្វើភត្តកិច្ចហើយ សួរថា មហាឧបាសិកា នាងឬ ឈ្មោះមាតិកមាតា ឧបាសិកាពោលថា ត្រូវ ហើយលោកម្ចាស់ ។ ភិក្ខុនោះពោលថា ឧបាសិកា នាងជ្រាបចិត្តរបស់អ្នក ដទៃឬ ឧបាសិកាពោលថា លោកម្ចាស់សួរខ្ញុំធ្វើអ្វី ភិក្ខុនោះពោលថា នាង បានធ្វើវត្ថុគ្រប់យ៉ាងដែលអាត្មាគិតហើយ ព្រោះដូច្នោះ ទើបអាត្មាសួរនាង ។ ឧបាសិកាពោលថា បពិត្រលោកម្ចាស់ ភិក្ខុដែលដឹងចិត្តរបស់អ្នកដទៃ ក៏មាន ច្រើន ភិក្ខុនោះពោលថា អាត្មាមិនបានសួរដល់អ្នកដទៃ សួរចំពោះឧបាសិកា ប៉ុណ្ណោះ ។

តែទោះជាយ៉ាងនោះ ឧបាសិកាក៏មិនបានប្រាប់ត្រង់ៗ ថា ខ្ញុំដឹងចិត្តរបស់ អ្នកដទៃ ប្រែខ្វៀជាពោលថា បពិត្រអយ្យបុត្រ ធម្មតាមនុស្សទាំងឡាយ ដែលដឹងចិត្តរបស់អ្នកដទៃ រមែងធ្វើយ៉ាងនោះបាន ។

ភិក្ខុនោះគិតថា កម្មនេះធ្ងន់ហ្ន៎ ធម្មតាបុថុជ្ជនរមែងគិតដល់អារម្មណ៍ដែលស្អាតខ្លះ មិនស្អាតខ្លះ បើអាត្មានឹងគិតដល់វត្ថុដែលមិនសមគួរហើយសោត ឧបាសិកានេះ ក៏គប្បីញាំងអាត្មាឲ្យដល់ប្រការប្លែក ដូចចាប់ចោរត្រង់ផ្នួងសក់មួយអន្ទើដោយកស្តុតាង ដូច្នោះ ។ អាត្មាគួរគេចទៅអំពីទីនេះ ហើយពោលថា ឧបាសិកា អាត្មានឹងលាទៅ ឧបាសិកាពោលថា លោកម្ចាស់នឹងទៅទីណា ភិក្ខុនោះពោលថា នឹងទៅកាន់សម្នាក់ព្រះសាស្តា ឧបាសិកាពោលថា សូមលោកម្ចាស់នៅក្នុងទីនេះសិនចុះ ភិក្ខុនោះពោលថា អាត្មាមិននៅទេ នឹងត្រូវទៅដោយពិតប្រាកដ ហើយបានដើរចេញអំពីទីនោះ ទៅកាន់សម្នាក់របស់ព្រះសាស្តា ។

លំដាប់នោះ ព្រះសាស្តាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ អ្នកនៅក្នុងទីនោះមិនបានឬ ភិក្ខុនោះពោលថា បពិត្រព្រះអង្គ យ៉ាងនោះឯង ខ្ញុំព្រះអង្គមិនអាចនៅទីនោះបាន ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ ព្រោះហេតុអ្វី ភិក្ខុនោះពោលថា បពិត្រព្រះអង្គ ព្រោះឧបាសិកានោះ ដឹងដល់រឿងដែលអ្នកដទៃគិតហើយគ្រប់ប្រការ ខ្ញុំព្រះអង្គគិតថា ធម្មតាបុថុជ្ជន រមែងគិតអារម្មណ៍ដែលស្អាតខ្លះ មិនស្អាតខ្លះ បើអាត្មាគិតដល់វត្ថុខ្លះ ដែលមិនសមគួរហើយសោត ឧបាសិកានោះក៏នឹងញាំងអាត្មា ឲ្យដល់នូវប្រការដែលប្លែក ដូចចាប់ចោរត្រង់ផ្នួងសក់ មួយអន្ទើដោយកស្តុតាង ដូច្នោះ ដូច្នេះហើយ ទើបមក ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ អ្នកគួរនៅក្នុងទីនោះឯង ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមិនអាច ខ្ញុំព្រះអង្គនឹងនៅទីនោះ មិនបាន ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុបើយ៉ាងនោះ ចូរអ្នករក្សាវត្ថុមួយប៉ុណ្ណោះ

បានឬទេ ភិក្ខុនោះពោលថា បពិត្រព្រះអង្គ តើរក្សាអ្វី ព្រះសាស្តាត្រាស់ថា ចូរអ្នករក្សាចិត្តរបស់អ្នកនោះឯង ធម្មតាចិត្តនេះ បុគ្គលរក្សាបានលំបាក អ្នកចូរសង្កត់ចិត្តរបស់អ្នកឲ្យបាន កុំគិតដល់អារម្មណ៍ណាមួយដទៃឡើយ ធម្មតាចិត្តបុគ្គលសង្កត់បានលំបាក ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

**ទុន្និគ្គហស្ស លហុនោ　　យត្ថ កាមនិបាតិនោ**
**ចិត្តស្ស ទមថោ សាធុ　　ចិត្តំ ទន្តំ សុខាវហំ ។**

*ការទូន្មានចិត្ត ដែលសង្កត់សង្កិនបានដោយលំបាក ជាធម្មជាតរហ័ស មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្តីប្រាថ្នា ក្នុងអារម្មណ៍ណាមួយ រមែងជាគុណញុំាងប្រយោជន៍ឲ្យសម្រេច ( ព្រោះថាចិត្ត ) ដែលហ្វឹកហ្វឺនបានហើយ រមែងនាំមកនូវសេចក្តីសុខ ។*

## សេចក្តីអធិប្បាយ

បណ្ឌិតគប្បីជ្រាបវិគ្គហៈក្នុងព្រះគាថានោះដូចតទៅនេះថា ធម្មតាចិត្តនេះ បុគ្គលសង្កត់សង្កិនបានលំបាក ព្រោះហេតុនោះ ទើបឈ្មោះថា **ទុន្និគ្គហំ។**

ចិត្តនេះ រមែងកើត និងរលត់រហ័ស ព្រោះហេតុនោះ ទើបឈ្មោះថា **លហុ** នូវចិត្តដែលសង្កត់បានលំបាក ដែលកើត និងរលត់រហ័សនោះ ។

បាទព្រះគាថាថា **យត្ថ កាមនិបាតិនោ** សេចក្តីថា រមែងធ្លាក់ទៅក្នុងអារម្មណ៍ឯណានីមួយនោះឯង ។ ពិតហើយ ចិត្តនេះ រមែងមិនស្គាល់ឋានៈដែលខ្លួនគួរបាន ឬឋានៈដែលមិនគួរបាន ឋានៈដែលគួរ ឬឋានៈដែលមិនគួរ រមែងមិនពិចារណាមើលជាតិ មិនពិចារណាមើលគោត្រ មិនពិចារណាមើល

វ័យ រមែងធ្លាក់ទៅក្នុងអារម្មណ៍ ដែលខ្លួនប្រាថ្នាតែម្យ៉ាង ។ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ចិត្តនេះ ធ្លាក់ទៅក្នុងអារម្មណ៍ តាមសេចក្តីប្រាថ្នា ។

ការទូន្មានចិត្តបែបនេះជាការល្អ គឺភាពនៃចិត្តដែលបុគ្គលទូន្មានដោយអរិយមគ្គ ៤ បានដល់ភាពនៃចិត្ត ដែលបុគ្គលធ្វើហើយដោយប្រការដែលចិត្តអស់ព្យសន៍បាន ជាការល្អ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះថាចិត្តនេះ ដែលបុគ្គលទូន្មានហើយ រមែងជាហេតុនាំសុខមកឲ្យ គឺចិត្តដែលបុគ្គលហ្វឹកហាត់ហើយ បានដល់ ធ្វើឲ្យអស់ព្យសន៍ រមែងនាំមកនូវសេចក្តីសុខ ដែលកើតអំពីមគ្គផល និងសុខ គឺព្រះនិព្វាន ដែលជាបរមត្ថ ។

ក្នុងកាលចប់ទេសនា បរិស័ទដែលមកប្រជុំគ្នាច្រើន បានជាអរិយបុគ្គលមានព្រះសោតាបន្នជាដើម ទេសនាសម្រេចប្រយោជន៍ដល់មហាជនហើយ ។

ព្រះសាស្តា កាលប្រទានឱវាទនេះដល់ភិក្ខុនោះហើយ ទើបទ្រង់បញ្ជូនទៅដោយព្រះតម្រាស់ថា ទៅចុះភិក្ខុ អ្នកកុំគិតវត្ថុណាមួយដទៃ ចូរនៅក្នុងទីនោះឯង ។ ភិក្ខុនោះ បានព្រះឱវាទអំពីសម្នាក់របស់ព្រះសាស្តាហើយ ទើបទៅក្នុងទីនោះ មិនគិតអ្វីមួយដែលនាំឲ្យគិតខាងក្រៅឡើយ ។

ចំណែកមហាឧបាសិកា កាលប្រមើលមើលដោយទិព្វចក្ខុ ក៏ឃើញព្រះថេរៈហើយ កំណត់ដោយញាណរបស់ខ្លួននោះឯងថា ឥឡូវនេះ ភិក្ខុដែលជាបុត្ររបស់អញ បានអាចារ្យឲ្យឱវាទហើយ ទើបត្រឡប់មកទៀត ហើយបានចាត់ចែងអាហារដែលជាទីសប្បាយដល់ព្រះថេរៈនោះ ។

ព្រះថេរៈនោះបានភោជនជាទីសប្បាយហើយ ក្នុងពេល ២-៣ ថ្ងៃប៉ុណ្ណោះ ក៏បានសម្រេចអរហត្ត សម្រាកសម្រាន្តនៅដោយសេចក្តីសុខ ដែលកើតអំពីមគ្គ និងផល គិតថា គួរពេញចិត្តហ្ន៎ មហាឧបាសិកាបានជាទីពឹងរបស់អញហើយ អញអាស្រ័យមហាឧបាសិកានេះ ទើបដល់នូវការស្រុះចេញអំពីភពបាន ហើយពិចារណាថា មហាឧបាសិកានេះ បានជាទីពឹងរបស់អញ ក្នុងអត្តភាពនេះប៉ុណ្ណោះឬហ្ន៎ កាលអញអន្ទោលទៅក្នុងសង្សារ មហាឧបាសិកានេះ ធ្លាប់ជាទីពឹងក្នុងអត្តភាពដទៃៗ ឬទេ ហើយទើបរឭកជាតិថយក្រោយទៅ ៩៩ អត្តភាព ។ សូម្បីមហាឧបាសិកានោះ ក៏បានជាបាទបរិចារិការបស់ព្រះថេរៈនោះក្នុងអត្តភាពទី ៩៩ ជាអ្នកមានចិត្តប្រតិព័ទ្ធក្នុងបុរសដទៃ ទើបឲ្យសម្លាប់ព្រះថេរៈនោះ ឲ្យដាច់ចាកជីវិត ។

ព្រះថេរៈ កាលឃើញទោសរបស់មហាឧបាសិកានោះត្រឹមប៉ុណ្ណោះហើយ ទើបគិតថា គួរសង្វេគហ្ន៎ មហាឧបាសិកានេះ បានធ្វើកម្មធ្ងន់មកហើយ ។

ចំណែកមហាឧបាសិកាអង្គុយក្នុងផ្ទះនោះឯង ពិចារណាបណ្តើរថា កិច្ចនៃបព្វជិតរបស់ភិក្ខុជាបុត្រអញ ដល់ទីបំផុតហើយឬនៅហ្ន៎ ក៏បានដឹងថា ព្រះថេរៈនោះ សម្រេចអរហត្តហើយ ទើបពិចារណាក្រៃលែងឡើងទៅ ក៏ជ្រាបថា ភិក្ខុជាបុត្ររបស់អញសម្រេចអរហត្តហើយ ទើបគិតថា គួរត្រេកអរពិតហ្ន៎ ឧបាសិកានេះបានជាទីពឹងរបស់អញយ៉ាងសំខាន់ ដូច្នេះហើយ ពិចារណាតទៅទៀតថា សម្បីក្នុងកាលកន្លងទៅហើយ ឧបាសិកានេះធ្លាប់ជាទីពឹងរបស់អញឬហ្ន៎ ក៏រឭកជាតិទៅរហូត ៩៩ អត្តភាព តែអញបានស្ម័គ្រស្មន់ជាមួយ

ប្រុសដទៃ ផ្តាច់ជីវិតព្រះថេរៈក្នុងអត្តភាពទី ៩៩ ព្រះថេរៈនេះឯងឃើញទោស មានប្រមាណប៉ុណ្ណោះរបស់អញហើយ គិតថា គួរសង្វេគ ឧបាសិកាបានធ្វើកម្មធ្ងន់ហើយ នាងពិចារណាតទៅទៀតថា អាត្មាអញកាលអន្ទោលទៅក្នុងសង្សារវដ្ត អញមិនបានធ្លាប់ធ្វើឧបការៈដល់ភិក្ខុ ដែលជាបុត្រសោះឬហ្ន៎ បានរឭកដល់អត្តភាពទី ១០០ ដែលក្រៃលែងជាង ៩៩ អត្តភាពនោះ ក៏ជ្រាបថា ក្នុងអត្តភាពទី ១០០ អញជាបាទបរិចារិកានៃព្រះថេរៈនោះ បានឲ្យជីវិតទានក្នុងទីដែលប្រហារជីវិតមួយកន្លែង ។ គួរត្រេកអរ អញធ្វើឧបការៈច្រើនដល់ភិក្ខុដែលជាបុត្ររបស់អញ អង្គុយក្នុងផ្ទះនោះឯងពោលថា សូមលោកម្ចាស់ពិចារណាមើលឲ្យពិសេសក្រៃលែងឡើង ។

ព្រះថេរៈនោះ បានស្តាប់សំឡេងរបស់ឧបាសិកានោះ ដោយសោតធាតុដែលជាទិព្វហើយ រឭកដល់អត្តភាពទី ១០០ ឲ្យវិសេសឡើងហើយ ឃើញភាពដែលឧបាសិកានោះ បានឲ្យជីវិតដល់ខ្លួនក្នុងអត្តភាពនោះ ទើបគិតថា គួរត្រេកអរហ្ន៎ ឧបាសិកានេះធ្លាប់ធ្វើឧបការៈដល់អញ ដូច្នេះហើយ មានចិត្តត្រេកអរ ពោលបញ្ហាក្នុងមគ្គ ៤ ផល ៤ ដល់ឧបាសិកាក្នុងទីនោះឯង បានបរិនិព្វានហើយ ដោយអនុបាទិសេសនិព្វានធាតុ ។

**រឿង អញ្ញតរភិក្ខុ ចប់**

# រឿង ឧក្កណ្ឋិតភិក្ខុ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធភិក្ខុដែលអផ្សុកមួយអង្គ ត្រាស់ធម្មទេសនានេះថា **សុទុទ្ទសំ** ជាដើម ។

បានឮមកថា កាលព្រះសាស្តាប្រថាប់នៅក្នុងក្រុងសាវត្ថី សេដ្ឋីបុត្រម្នាក់ចូលទៅរកព្រះថេរៈ ដែលជាជីតុនរបស់ខ្លួនសាកសួរថា បពិត្រលោកម្ចាស់ ខ្ញុំប្រាថ្នានឹងផុតចាកទុក្ខ សូមលោកម្ចាស់ប្រាប់អាការ សម្រាប់ផុតចាកទុក្ខដល់ខ្ញុំ ។ ព្រះថេរៈពោលថា សាធុអាវុសោ បើអ្នកប្រាថ្នានឹងផុតចាកទុក្ខសោត ចូរអ្នកថ្វាយសលាកភត្ត បក្ខិកភត្ត ថ្វាយវស្សាវាសិកភត្ត ថ្វាយបច្ច័យទាំងឡាយមានចីវរជាដើម ចែករំលែកទ្រព្យសម្បត្តិរបស់ខ្លួនឲ្យជា ៣ ចំណែក ប្រកបការងារដោយទ្រព្យ ១ ចំណែក ចិញ្ចឹមបុត្រ និងភរិយាដោយទ្រព្យ ១ ចំណែក ថ្វាយទ្រព្យ ១ ចំណែកក្នុងព្រះពុទ្ធសាសនា ។ សេដ្ឋីបុត្រទទួលថា សាធុ លោកម្ចាស់ ហើយធ្វើកិច្ចគ្រប់យ៉ាងតាមលំដាប់នៃកិច្ចដែលព្រះថេរៈប្រាប់ហើយ សាកសួរព្រះថេរៈទៀតថា ខ្ញុំនឹងធ្វើបុណ្យអ្វីដទៃដែលក្រៃលែងឡើងជាងនេះទៀតឬ ព្រះថេរៈឆ្លើយថា អាវុសោ ចូរអ្នកទទួលត្រៃសរណៈ និងសីល ៥ ។ គាត់បានទទួលត្រៃសរណៈ និងសីល ៥ ទាំងនោះហើយ ទើបសាកសួរដល់បុញ្ញកម្ម ដែលក្រៃលែងឡើងជាងនោះ ។ ព្រះថេរៈក៏ទូន្មានថា បើដូច្នោះ ចូរអ្នកទទួលសីល ១០ សេដ្ឋីបុត្រពោលថា សាធុ លោកម្ចាស់ ហើយក៏ទទួលសីល ១០ ព្រោះគាត់ធ្វើបុញ្ញកម្មយ៉ាងនោះតាមលំដាប់

ទើបគាត់មានឈ្មោះថា អនុបុព្វសេដ្ឋីបុត្រ ។ គាត់សាកសួរទៀតថា បុណ្យដែលខ្ញុំគប្បីធ្វើឲ្យក្រៃលែងឡើងទៅជាងនេះ នៅមានឬ លោកម្ចាស់ កាលព្រះថេរៈពោលថា បើយ៉ាងនោះ ចូរអ្នកបួស ទើបចេញបួសហើយ ។ ភិក្ខុអ្នកទ្រទ្រង់ព្រះអភិធម្មមួយរូប បានជាអាចារ្យរបស់លោក ភិក្ខុទ្រទ្រង់វិន័យមួយរូប ជាព្រះឧបជ្ឈាយ៍ ។ ក្នុងវេលាដែលភិក្ខុនោះ បានឧបសម្បទាហើយមកកាន់សម្នាក់របស់ខ្លួន អាចារ្យពោលបញ្ហាក្នុងព្រះអភិធម្មថា ឈ្មោះថាក្នុងព្រះពុទ្ធសាសនា ភិក្ខុធ្វើកិច្ចនេះ ទើបគួរ ធ្វើកិច្ចនេះ មិនគួរ ។

ចំណែកព្រះឧបជ្ឈាយ៍ ក៏ពោលបញ្ហាក្នុងព្រះវិន័យ ក្នុងកាលដែលភិក្ខុនោះមកកាន់សម្នាក់របស់ខ្លួនថា ឈ្មោះថា ក្នុងព្រះពុទ្ធសាសនា ភិក្ខុធ្វើវត្ថុនេះ គួរ វត្ថុនេះ មិនគួរ វត្ថុនេះ សម វត្ថុនេះ មិនសម ។

លោកគិតថា ឱកម្មនេះធុនប៉្ញុំ អញប្រាថ្នានឹងផុតចាកទុក្ខ ទើបបួស តែក្នុងព្រះពុទ្ធសាសនានេះ ស្ថានជាទីលាដៃរបស់អញមិនប្រាកដ អញតាំងនៅក្នុងផ្ទះ ក៏អាចផុតទុក្ខក្នុងវដ្ដៈបាន អញគួរជាគ្រហស្ថល្អជាង ។ តាំងអំពីនោះលោកក៏អផ្សុក អស់សេចក្ដីត្រេកអរ មិនធ្វើការស្វាធ្យាយក្នុងអាការ ៣២ មិនរៀនឧទ្ទេស ស្គាំងស្គម ស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ ត្រូវសេចក្ដីខ្ជិលច្រអូសគ្របសង្កត់ ដេរដាសហើយដោយកមរមាស់ ។

គ្រានោះ ពួកភិក្ខុកំលោះ និងសាមណេរសួរលោកថា អាវុសោ ហេតុអ្វី ទើបលោកឈរសំកុក ក្នុងទីដែលឈរហើយ អង្គុយសំកុក ក្នុងទីដែលអង្គុយហើយ ត្រូវរោគស្គមលឿងគ្របសង្កត់ ស្គាំងស្គមស្លេកស្លាំង មានខ្លួន

រវាមដោយសរសៃ ត្រូវសេចក្តីខ្ពិលច្រអូសគ្របសង្កត់ ដេរដាសហើយដោយកមរមាស់ លោកធ្វើកម្មអ្វី ភិក្ខុនោះពោលថា អាវុសោ ខ្ញុំជាមនុស្សអផ្សុក ភិក្ខុកំលោះ និងសាមណេរសួរថា ព្រោះហេតុអ្វី ។

ភិក្ខុនោះ ប្រាប់ព្រឹត្តិការណ៍នោះហើយ ភិក្ខុកំលោះ និងសាមណេរទាំងនោះ ប្រាប់ដល់អាចារ្យ និងឧបជ្ឈាយ៍របស់លោកហើយ ។ អាចារ្យ និងឧបជ្ឈាយ៍ បាននាំគ្នាទៅកាន់សម្នាក់ព្រះសាស្តា ។

ព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកមកធ្វើអ្វី អាចារ្យ និងឧបជ្ឈាយ៍ទូលថា បពិត្រព្រះអង្គ ភិក្ខុរូបនេះអផ្សុកក្នុងសាសនារបស់ព្រះអង្គ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ យ៉ាងនោះឬ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គ យ៉ាងនោះឯង ព្រះសាស្តាត្រាស់ថា ព្រោះហេតុអ្វី ភិក្ខុនោះពោលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រោះខ្ញុំព្រះអង្គប្រាថ្នានឹងផុតចាកទុក្ខ ទើបបានបួស អាចារ្យរបស់ខ្ញុំព្រះអង្គពោលអភិធម្មកថា ឧបជ្ឈាយ៍ពោលវិនយ-កថា ខ្ញុំព្រះអង្គបានធ្វើទូវការសន្និដ្ឋានថា ក្នុងព្រះពុទ្ធសាសនានេះ ស្ថានជាទីលាដៃរបស់អញមិនមានឡើយ អញជាគ្រហស្ថក៏អាចផុតទុក្ខបាន អញនឹងជាគ្រហស្ថ ដូច្នេះ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ បើអ្នកអាចរក្សារបស់ម្យ៉ាងប៉ុណ្ណោះបាន កិច្ច គឺការរក្សារបស់ទាំងឡាយដ៏សេស រមែងមិនមាន ។ ភិក្ខុនោះពោលថា បពិត្រព្រះអង្គ របស់នោះជាអ្វី ព្រះសាស្តាត្រាស់ថា អ្នកអាចរក្សាចំពោះចិត្តរបស់អ្នកបានឬទេ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គ អាចរក្សាបាន ។

ព្រះសាស្តាប្រទានឱវាទថា បើដូច្នោះ ចូរអ្នករក្សាចំពោះចិត្តរបស់ខ្លួន អ្នកនឹងផុតចាកទុក្ខបាន ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

**សុទុទ្ទសំ សុនិបុណំ យត្ថ កាមនិបាតិនំ**
**ចិត្តំ រក្ខេថ មេធាវី ចិត្តំ គុត្តំ សុខាវហំ ។**

អ្នកមានប្រាជ្ញា គួររក្សាចិត្ត ដែលឃើញដោយកម្រក្រៃពេក ដែលល្អិតពេកណាស់ មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្តីប្រាថ្នា ក្នុងអារម្មណ៍ណាមួយ ( ព្រោះថា ) ចិត្តដែលគេរក្សាបានហើយ រមែងនាំមកនូវសេចក្តីសុខ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សុទុទ្ទសំ** បានដល់ លំបាកនឹងឃើញបានដោយល្អ ។ បទថា **សុនិបុណំ** បានដល់ ល្អិតក្រៃលែង ។

បាទព្រះគាថាថា **យត្ថ កាមនិបាតិនំ** សេចក្តីថា ច្រើនដោយការមិនពិចារណាមើលឋានៈទាំងឡាយ មានជាតិជាដើម ធ្លាក់ទៅក្នុងអារម្មណ៍ណាមួយ ក្នុងឋានៈដែលគប្បីបាន ឬមិនគប្បីបាន សមគួរ ឬមិនសមគួរ ។

បាទព្រះគាថាថា **ចិត្តំ រក្ខេថ មេធាវី** សេចក្តីថា បុគ្គលអន្ធពាលមានបញ្ញាថោកថយ ឈ្មោះថាអាចរក្សាចិត្តរបស់ខ្លួនបាន មិនមាន ។ បុគ្គលនោះជាអ្នកប្រព្រឹត្តទៅក្នុងអំណាចចិត្ត រមែងដល់នូវសេចក្តីវិនាសអន្តរធាន រីបុគ្គលអ្នកមានបញ្ញា គឺជាបណ្ឌិតអាចរក្សាចិត្តបាន ។ ព្រោះហេតុនោះ ចូរអ្នកគ្រប់គ្រងរក្សាចិត្តឲ្យបាន ព្រោះថា ចិត្តដែលរក្សាបាន ជាហេតុនាំសុខមកឲ្យ

គឺរមែងនាំមកនូវសេចក្តីសុខ ដែលកើតអំពីមគ្គផល និងនិព្វាន ដូច្នេះ ។

ក្នុងវេលាចប់ទេសនា ភិក្ខុនោះសម្រេចសោតបត្តិផលហើយ ជនដទៃជាច្រើន បានជាអរិយបុគ្គល មានព្រះសោតាបន្នជាដើម ទេសនាបានសម្រេចជាប្រយោជន៍ដល់មហាជន ដូច្នេះឯង ។៚

**រឿង ឧក្កណ្ឋិតភិក្ខុ ចប់**

# រឿង ក្មួយរបស់ព្រះសង្ឃរក្ខិតត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុឈ្មោះសង្ឃ-រក្ខិតៈ ត្រាស់ព្រះធម្មទេសនានេះថា **ទូរង្គមំ ឯកចរំ** ជាដើម ។

បានឮមកថា កុលបុត្រម្នាក់ក្នុងក្រុងសាវត្ថី ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយចេញបួស បានឧបសម្បទាហើយ មានឈ្មោះសង្ឃរក្ខិតត្ថេរ ក្នុងកាល ២-៣ ថ្ងៃប៉ុណ្ណោះ ក៏សម្រេចអរហត្តផល ។ ប្អូនប្រុសរបស់លោកបានកូនហើយ ក៏បានតាំងឈ្មោះរបស់ព្រះថេរៈដល់បុត្រនោះ ។ កុមារនោះមានឈ្មោះថា ភាគិនេយ្យសង្ឃរក្ខិតៈ ចម្រើនវ័យហើយ បានបំពេញបព្វជ្ជាឧបសម្បទា ក្នុងសម្នាក់របស់ព្រះថេរៈ ចូលទៅចាំវស្សាក្នុងវត្តជិតស្រុកណាមួយ បានសំពត់វស្សាវាសិកសាដកពីរផ្ទាំង បណ្តោយ ៧ ហត្ថមួយផ្ទាំង ៨ ហត្ថមួយផ្ទាំង កំណត់ថា សំពត់វែង ៨ ហត្ថ នឹងជារបស់ព្រះឧបជ្ឈាយ៍

របស់អញ សំពត់ ៧ ហត្ថ នឹងជារបស់អញ ចេញវស្សាហើយ បំណងនឹង សួរសុខទុក្ខព្រះឧបជ្ឈាយ៍ ដើរមកបណ្តើរ ត្រាច់បិណ្ឌបាតក្នុងរវាងផ្លូវ លុះ មកដល់ហើយ កាលព្រះថេរៈមិនទាន់ត្រឡប់មកកាន់វិហារនោះឯង ក៏ចូល ទៅកាន់វិហារ ហើយបោសទីសម្រាកពេលថ្ងៃរបស់ព្រះថេរៈ រៀបចំទឹកលាង ជើង ក្រាលអាសនៈ ហើយអង្គុយមើលផ្លូវព្រះថេរៈ កាលជ្រាបកាលដែល ព្រះថេរៈមកដល់ហើយ ធ្វើការទទួលបាត្រ និងចីវរ អារាធនាព្រះថេរៈឲ្យគង់ ដោយពាក្យថា សូមលោកម្ចាស់និមន្តគង់ចុះ កាន់ផ្ចិតស្លឹកត្នោតបក់ហើយ ប្រគេនទឹកឆាន់ លាងជើងទាំងពីរហើយ នាំសំពត់សាដកនោះមកដាក់ទៀប បាទា ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ប្រើប្រាស់សំពត់សាដក នេះ ហើយបានឈរបក់ ។

លំដាប់នោះ ព្រះថេរៈពោលនឹងលោកថា សង្ឃរក្ខិតៈ ចីវររបស់ខ្ញុំ បរិបូណ៌ហើយ អ្នកនោះឯងចូរប្រើប្រាស់ចុះ ។

ព្រះសង្ឃរក្ខិតៈពោលថា បពិត្រលោកម្ចាស់ សំពត់នេះខ្ញុំកំណត់ដើម្បី លោកម្ចាស់តាំងអំពីកាលដែលខ្ញុំបានហើយ សូមលោកម្ចាស់ប្រើប្រាស់ចុះ ។ ព្រះថេរៈពោលថា ណ្ហើយចុះ សង្ឃរក្ខិតៈ ចីវររបស់ខ្ញុំបរិបូណ៌ អ្នកនុ៎ះឯង ចូរប្រើប្រាស់ចុះ ។

ព្រះសង្ឃរក្ខិតៈពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់កុំធ្វើ យ៉ាងនេះឡើយ ព្រោះកាលលោកម្ចាស់ប្រើប្រាស់សំពត់សាដកនេះ ផល ច្រើននឹងមានដល់ខ្ញុំ ។

កាលនោះ លុះព្រះសង្ឃរក្ខិតៈនោះពោលអង្វរហើយអង្វរទៀត ព្រះថេរៈក៏នៅតែមិនប្រាថ្នាសំពត់សាដកផ្ទាំងនោះ ។ លោកឈរបក់បណ្ដើរ គិតបណ្ដើរថា ក្នុងកាលជាគ្រហស្ថ អញជាក្មួយរបស់ព្រះថេរៈ ក្នុងកាលបួសហើយ អញក៏ជាសទ្ធិវិហារិក កាលបើដូច្នោះ ព្រះឧបជ្ឈាយ៍មិនបំណងប្រើប្រាស់រួមជាមួយអញ បើព្រះឧបជ្ឈាយ៍នេះមិនរួមប្រើប្រាស់ជាមួយអញ អញនឹងត្រូវការអ្វីដោយភាពជាសមណៈ អញនឹងទៅជាគ្រហស្ថវិញ ។

ខណៈនោះ លោកគិតឃើញថា ការគ្រប់គ្រងផ្ទះ តាំងខ្លួនបានលំបាក អញនឹងលក់សំពត់សាដកប្រវែង ៨ ហត្ថ ហើយទិញមេពពែមួយ ធម្មតាមេពពែរមែងកើតកូនឆាប់ អញនឹងលក់កូនពពែដែលកើតហើយ ធ្វើជាដើមទុន កាលប្រមូលទុនបានច្រើនហើយ នឹងនាំស្រីម្នាក់មកជាភរិយា នាងនឹងកើតបានកូនម្នាក់ កាលបើដូច្នោះ អញនឹងដាក់ឈ្មោះលោកអ៊ំរបស់អញដល់កូននោះ ហើយឲ្យអង្គុយក្នុងយានតូច នាំបុត្រ និងភរិយារបស់អញមកថ្វាយបង្គំលោកអ៊ំ កាលធ្វើដំណើរមក នឹងពោលជាមួយភរិយារបស់អញ ក្នុងរវាងផ្លូវថា នាងចូរឲ្យកូនដល់ខ្ញុំមុន យើងនឹងនាំកូននោះទៅ នាងនឹងពោលថា អ្នកត្រូវការអ្វីដោយបុត្រ អ្នកចូរមក ចូរបរយានតូចនេះទៅ ហើយទទួលយកបុត្រទៅ តាំងចិត្តថា អញនឹងនាំកូននោះទៅ កាលមិនអាចពទៅបាន ក៏ទុកបោលត្រង់ស្នាមកង់រទេះ កាលបើដូច្នេះ អញនឹងសង្កត់ក្បាលរបស់នាងលំដាប់នោះ អញនឹងនិយាយនឹងនាងថា នាងមិនបានឲ្យកូនរបស់ខ្ញុំដល់ខ្ញុំ នាងមិនអាចពកូននោះទៅបាន កូននោះរមែងឈ្មោះថានាងធ្វើឲ្យវិនាសហើយ

នឹងយកជង់ជន្ទញវាយខ្លួន ។

ព្រះថេរៈក្មួយប្រុសនោះ គិតយ៉ាងនោះបណ្តើរ ឈរបក់បណ្តើរ ក៏យក ផ្ចិតជាន់ត្នោត វាយព្រះសិសៈព្រះថេរៈហើយ ។

ព្រះថេរៈពិចារណាថា ព្រោះហេតុអ្វីហ្ន៎ ទើបត្រូវសង្ឃរក្ខិតៈវាយក្បាល ជ្រាបរឿងដែលក្មួយប្រុសនោះគិតហើយទាំងអស់ ទើបពោលថា សង្ឃរក្ខិតៈ អ្នកមិនអាចឲ្យប្រហារមាតុគ្រាម ក្នុងរឿងនេះ ព្រះថេរៈចាស់មានទោសអ្វី ។

លោកគិតថា អញវិនាសហើយ បានឮថា ព្រះឧបជ្ឈាយ៍ដឹងរឿងអញ គិតហើយ អញត្រូវការអ្វីដោយភាពជាសមណៈ ដូច្នេះហើយ បោះផ្ចិត ស្លឹកត្នោត ប្រារព្ធដើម្បីគេចទៅ ។

លំដាប់នោះ ភិក្ខុកំលោះ និងសាមណេរទាំងឡាយដេញតាមចាប់ភិក្ខុ នោះ នាំមកកាន់សម្នាក់ព្រះសាស្តា ។ ព្រះសាស្តាទតឃើញភិក្ខុនោះហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកមកធ្វើអ្វី ពួកអ្នកបានភិក្ខុមួយរូបឬ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះអង្គ យ៉ាងនោះឯង ពួកខ្ញុំព្រះអង្គនាំភិក្ខុកំលោះ រូបនេះ ដែលអផ្សុកហើយលបគេចទៅ មកកាន់សម្នាក់របស់ព្រះអង្គ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ បានឮថា អ្នកធ្វើយ៉ាងនោះឬ សង្ឃ-រក្ខិតៈភិក្ខុពោលថា បពិត្រព្រះអង្គ យ៉ាងនោះឯង ព្រះសាស្តាត្រាស់ថា ម្នាល ភិក្ខុ អ្នកធ្វើកម្មធ្ងន់យ៉ាងនោះ ដើម្បីអ្វី អ្នកជាបុត្រព្រះពុទ្ធមួយអង្គ ប្រារព្ធ សេចក្តីព្យាយាម បួសក្នុងសាសនារបស់ព្រះពុទ្ធ ដូចតថាគតមិនមែនឬ មិន អាចឲ្យគេហៅខ្លួនថា ជាព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី ឬ

ព្រះអរហន្ត បានធ្វើកម្មធ្ងន់យ៉ាងនោះដើម្បីអ្វី ព្រះសង្ឃរក្ខិតៈពោលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គអផ្សុក ។ ព្រះសាស្ដាត្រាស់ថា ព្រោះហេតុអ្វី ទើបអ្នកអផ្សុក ព្រះសង្ឃរក្ខិតៈនោះ ក្រាបទូលរឿងនោះដល់ព្រះសាស្ដា ចាប់តាំងអំពីថ្ងៃដែលខ្លួនឲ្យសំពត់វស្សាវាសិកសាដក រហូតដល់យកផ្ចិតស្លឹកត្នោតវាយព្រះថេរៈ ហើយក្រាបទូលថា បពិត្រព្រះអង្គ ព្រោះហេតុនេះ ទើបខ្ញុំព្រះអង្គលបគេចទៅ ។

លំដាប់នោះ ព្រះសាស្ដាត្រាស់នឹងលោកថា មកចុះភិក្ខុ អ្នកកុំគិតថ្វីឡើយ ធម្មតាចិត្តនេះ មានកិច្ចទទួលអារម្មណ៍ សូម្បីមាននៅក្នុងទីឆ្ងាយ គួរភិក្ខុព្យាយាមដើម្បីជាប្រយោជន៍ដល់ការផុតចាកគ្រឿងចង គឺរាគៈ ទោសៈ មោហៈ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**ទូរង្គមំ ឯកចរំ អសរីរំ គុហាសយំ**
**យេ ចិត្តំ សញ្ញមេស្សន្តិ មោក្ខន្តិ មារពន្ធនា ។**

អ្នកទាំងឡាយណា នឹងសង្រួមចិត្តដែលទៅឆ្ងាយ ជាចិត្តត្រាច់ទៅតែឯង មិនមានសរីរៈ មានគុហា គឺមហាភូតរូប ៤ ជាទីអាស្រ័យនៅ អ្នកទាំងនោះឯង រមែងរួចចាកចំណងនៃមារ ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **ទូរង្គមំ** ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅ ឈ្មោះថា ការទៅ និងការមករបស់ចិត្ត ដោយចំណែកនៃទិស មានទិសបូព៌

ជាដើម សូម្បីប្រមាណប៉ុនសរសៃពីងពាង មិនមាន ចិត្តនោះ រមែងទទួលអារម្មណ៍ដែលមាននៅក្នុងទីឆ្ងាយ ព្រោះដូច្នោះ ទើបឈ្មោះថា **ទូរង្គមំ** ។

ម្យ៉ាងទៀត ចិត្ត ៧-៨ ដួង ឈ្មោះថា អាចកើតឡើងរួមជាបាច់ដោយការរួមគ្នាក្នុងខណៈមួយ មិនមាន ។ ក្នុងកាលដែលកើតឡើង ចិត្តកើតឡើងមួយដួងៗ កាលចិត្តដួងនោះរលត់ហើយ ចិត្តដួងថ្មីក៏កើតឡើងមួយដួងទៀត ព្រោះហេតុនោះ ទើបឈ្មោះថា **ឯកចរំ** ។

សរីរសណ្ឋានក្តី ប្រភេទនៃពណ៌ មានពណ៌ខៀវជាដើមក្តី របស់ចិត្តមិនមាន ព្រោះហេតុនោះ ទើបឈ្មោះថា **អសរីរំ** ។

គុហា គឺមហាភូតរូប ៤ ឈ្មោះថា គុហា ។ ចិត្តដែលអាស្រ័យហទយរូបប្រព្រឹត្តទៅ ព្រោះហេតុនោះ ទើបឈ្មោះថា **គុហាសយំ** ។

ពីរបទថា **យេ ចិត្តំ** សេចក្តីថា ជនពួកណាមួយ ទោះជាបុរសក្តីស្ត្រីក្តី ជាគ្រហស្ថក្តី បព្វជិតក្តី កាលមិនឲ្យកិលេសដែលមិនទាន់កើត ឲ្យកើតឡើង លះកិលេសដែលកើតឡើងហើយ ព្រោះការរាយមាយនៃសតិ ឈ្មោះថា នឹងសង្រួមចិត្ត គឺនឹងធ្វើចិត្តឲ្យស្ងប់ បានដល់ មិនឲ្យរាយមាយ ។

បាទព្រះគាថាថា **មោក្ខន្តិ មារពន្ធនា** សេចក្តីថា ជនពួកនោះ ឈ្មោះថា ផុតចាកវដ្តៈ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលរាប់ថាជាចំណងនៃមារ ព្រោះមិនមានគ្រឿងចង គឺកិលេស ។

ក្នុងកាលចប់ទេសនា ព្រះភាគិនេយ្យសង្ឃរក្ខិតត្ថេរ សម្រេចសោតាបត្តិផលហើយ ។ ជនដទៃជាច្រើន បានជាអរិយបុគ្គល មានសោតាបន្នជាដើមហើយ ។ ទេសនាបានសម្រេចប្រយោជន៍ដល់មហាជនដូច្នេះឯង ៕

**រឿង ក្មួយរបស់ព្រះសង្ឃរក្ខិតត្ថេរ ចប់**

# រឿង ព្រះចិត្តហត្ថត្ថេរ

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះថេរៈឈ្មោះចិត្តហត្ថៈ ត្រាស់ព្រះធម្មទេសនានេះថា **អនវដ្ឋិតចិត្តស្ស** ជាដើម ។

បានឮថា កុលបុត្រអ្នកនគរសាវត្ថីម្នាក់ស្វែងរកគោដែលបាត់ទៅ ទើបចូលទៅក្នុងព្រៃ ជួបគោក្នុងពេលថ្ងៃត្រង់ លែងចូលហ្វូងគោហើយ គិតថា អញនឹងបានវត្ថុត្រឹមតែអាហារ ក្នុងសម្នាក់របស់ភិក្ខុទាំងឡាយដោយពិត ត្រូវសេចក្ដីស្រេកឃ្លានគ្របសង្កត់ហើយ ទើបចូលទៅកាន់វិហារដល់សម្នាក់របស់ភិក្ខុទាំងឡាយ ថ្វាយបង្គំហើយ បានឈរក្នុងចំណែកម្ខាង ។ ក្នុងសម័យនោះឯង ភត្តដែលសល់អំពីភិក្ខុទាំងឡាយធាន់ មាននៅក្នុងថាសសម្រាប់ដាក់ភត្តដែលជារបស់សល់ ភិក្ខុទាំងនោះឃើញគាត់ត្រូវសេចក្ដីឃ្លានគ្របសង្កត់ហើយ ទើបពោលថា សូមអ្នកកាន់យកភត្តបរិភោគចុះ ។ ឈ្មោះថា ក្នុងសម័យពុទ្ធកាល សម្ល និងម្ហូបច្រើន រមែងកើតឡើង ។ គាត់ទទួល

កត្តល្អមញ៉ាំងអត្តភាពអំពីថាសនោះ បរិភោគហើយ ផឹកទឹក លាងដៃ ថ្វាយបង្គំភិក្ខុទាំងឡាយហើយ សួរថា បពិត្រលោកម្ចាស់ ថ្ងៃនេះ លោកម្ចាស់ទាំងឡាយបានទៅកាន់ទីនិមន្តហើយឬ ភិក្ខុទាំងឡាយឆ្លើយថា ឧបាសក ថ្ងៃមិនមាន ភិក្ខុទាំងឡាយ រមែងបានកត្តាហាររឿយៗ ដោយទំនងនេះឯង ។

បុរសនោះគិតថា ពួកយើងក្រោកឡើងហើយ កាលក្រោកឡើងហើយ ធ្វើការងាររឿយៗ អស់យប់ និងថ្ងៃ ក៏គង់មិនបានកត្តដែលឆ្ងាញ់យ៉ាងនេះបានឮថា ភិក្ខុទាំងនេះ ឆាន់រឿយៗ អញនឹងត្រូវការអ្វីដោយភាពជាគ្រហស្ថ អញនឹងបួសជាភិក្ខុ ដូច្នេះហើយ ទើបចូលទៅរកភិក្ខុទាំងឡាយ សូមបព្វជ្ជាហើយ ។ លំដាប់នោះ ពួកភិក្ខុពោលនឹងបុរសនោះថា ឧបាសក ជាការល្អហើយ ឲ្យបុរសនោះបព្វជ្ជាហើយ ។ បុរសនោះបានឧបសម្បទាហើយ ធ្វើវត្តនឹងបដិវត្ត ដែលជាឧបការៈដល់ភិក្ខុទាំងពួង ។ លោកមានសរីរៈធាត់ដោយកាលកន្លងទៅ ២-៣ ថ្ងៃ ព្រោះលាភ និងសក្ការៈកើតឡើងដល់ព្រះពុទ្ធទាំងឡាយ ។

បន្ទាប់អំពីនោះ ភិក្ខុនោះគិតថា អញនឹងត្រូវការអ្វីដោយការត្រាច់ទៅដើម្បីភិក្ខាចិញ្ចឹមជីវិត អញនឹងជាគ្រហស្ថ ។ លោកសឹកចូលកាន់ផ្ទះហើយ ។ កាលកុលបុត្រដែលសឹកថ្មីនោះ ធ្វើការងារនៅក្នុងផ្ទះបាន ២-៣ ថ្ងៃប៉ុណ្ណោះ សរីរៈក៏ស្គម ។ បន្ទាប់អំពីនោះ គាត់គិតថា ប្រយោជន៍អ្វីរបស់អញដោយសេចក្ដីទុក្ខនេះ អញនឹងជាសមណៈ ដូច្នេះហើយ ក៏ត្រឡប់មកបួសជាថ្មី ។ លោកសម្រាកសម្រាន្តនៅបានប៉ុន្មានថ្ងៃ ក៏អផ្សុកឡើងហើយសឹក តែលោក

ជាអ្នកមានឧបការៈដល់ពួកភិក្ខុក្នុងកាលបួសដោយ ២-៣ ថ្ងៃប៉ុណ្ណោះ លោកក៏នឿយណាយទៀត ទើបគិតថា ប្រយោជន៍អ្វីរបស់អញដោយភាពជាគ្រហស្ថ អញនឹងបួស ទើបទៅថ្វាយបង្គំភិក្ខុទាំងឡាយ សូមបព្វជ្ជាហើយ ។ គ្រានោះ ភិក្ខុទាំងឡាយឲ្យបុរសនោះបព្វជ្ជាទៀតហើយ ដោយអំណាចនៃឧបការៈ ភិក្ខុនោះបួសហើយសឹកយ៉ាងនេះអស់វារៈ ៦ ដង ។ ភិក្ខុទាំងឡាយគិតថា ភិក្ខុនេះប្រព្រឹត្តទៅក្នុងអំណាចនៃចិត្តត្រាច់ទៅ ទើបប្រគេនព្រះនាមដល់លោកថា ចិត្តហត្ថត្ថេរ ។

កាលចិត្តហត្ថៈនោះទៅមកៗ យ៉ាងនេះឯង ភរិយាមានគភ៌ហើយ ។ ក្នុងវារៈទី ៧ គាត់លីនង្គ័លអំពីព្រៃទៅផ្ទះ ទុកដាក់គ្រឿងប្រើប្រាស់ហើយ ចូលបន្ទប់ដោយបំណងថា នឹងដេរសំពត់កាសាវៈរបស់ខ្លួន ក្នុងខណៈនោះ ភរិយារបស់គាត់កំពុងដេកលក់ សំពត់ដែលនាងស្លៀករលុង ទឹកមាត់ក៏ហូរចេញអំពីមាត់ ច្រមុះក៏ស្រមុក គ្រូកៗ ហាមាត់សង្កៀតធ្មេញ ប្រាកដដល់គាត់ដូចសរីរៈដែលហើមប៉ោង គាត់គិតថា សរីរៈនេះមិនទៀង ជាទុក្ខ អញបួសអស់កាលប៉ុណ្ណោះហើយ អាស្រ័យសរីរៈនេះ ទើបមិនអាចតាំងនៅក្នុងភិក្ខុភាវៈបានដូច្នេះហើយ ក៏យកសំពត់កាសាវៈរុំពោះបណ្តើរ ចេញចាកផ្ទះបណ្តើរ ។ គ្រានោះ ម្តាយក្មេករបស់គាត់ ឈរត្រង់ផ្ទះជាប់គ្នា ឃើញគាត់កំពុងដើរទៅដោយអាការយ៉ាងនោះ សង្ស័យថា បុរសនេះត្រឡប់ទៅទៀតហើយ គេមកអំពីព្រៃអម្បាញ់មិញនេះឯង រុំសំពត់កាសាវៈត្រង់ពោះ ចេញដើរបែរមុខទៅកាន់វិហារ កើតហេតុអ្វីអេះ ទើបចូលទៅកាន់ផ្ទះ ឃើញកូនស្រីដេកលក់ ដឹង

ថា បុរសនេះ ឃើញកូនស្រីរបស់អញនេះ មានសេចក្ដីរំខាន បានចេញទៅហើយ ទើបដាស់កូនស្រីពោលថា នាងអាក្រក់ ជួជាតិ ចូរក្រោកឡើង ប្ដីរបស់ឯងឃើញឯងកំពុងដេកលក់ មានសេចក្ដីរំខាន ទៅបាត់ហើយ តាំងអំពីនេះ ឯងនឹងមិនមានរូបគេ កូនស្រីពោលថា បពិត្រអ្នកម៉ែ ទៅក៏ទៅចុះ គាត់នឹងទៅខាងណា ២-៣ ថ្ងៃទៀតប៉ុណ្ណោះ ក៏នឹងមកវិញ ។

នាយចិត្តហត្ថៈនោះទន្ទេញទៅថា មិនទៀង ជាទុក្ខ កំពុងដើរទៅ សម្រេចសោតាបត្តិផលហើយ ចូលទៅថ្វាយបង្គំភិក្ខុទាំងឡាយហើយ ក៏សូមបព្វជ្ជា ។ ភិក្ខុទាំងឡាយពោលថា ពួកយើងមិនអាចឲ្យអ្នកបព្វជ្ជាបាន ភាពជាសមណៈរបស់អ្នកនឹងមានអំពីណា ក្បាលរបស់អ្នកដូចគ្នានឹងថ្មសំលៀងកាំបិត បុរសនោះពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទាំងឡាយអនុគ្រោះឲ្យខ្ញុំបួសក្នុងគ្រានេះម្ដងទៀតចុះ ទើបភិក្ខុទាំងនោះឲ្យបួសហើយ ដោយអំណាចនៃឧបការៈ ។

បាន ២-៣ ថ្ងៃប៉ុណ្ណោះ លោកក៏សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា ភិក្ខុទាំងនោះពោលនឹងលោកថា ចិត្តហត្ថៈ លោកដឹងសម័យដែលលោកនឹងទៅដោយពិត ហេតុអ្វីក្នុងពេលនេះទើបលោកឃឹតយូរទៅវិញ លោកពោលថា ខ្ញុំទៅហើយក្នុងកាលដែលមានការជាប់ជំពាក់ទេ ការជាប់ជំពាក់នោះខ្ញុំកាត់បានហើយ ។ បន្ដទៅ ខ្ញុំនឹងមិនទៅជាធម្មតា ។ ពួកភិក្ខុនាំគ្នាទៅកាន់សម្នាក់ព្រះសាស្ដា ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនោះត្រូវពួកខ្ញុំព្រះអង្គពោលយ៉ាងនេះ ពោលយ៉ាងនេះ លោកព្យាករអរហត្ត លោកពោល

ពាក្យមិនពិត ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយយ៉ាងនោះឯង បុត្ររបស់តថាគតបានធ្វើការទៅ និងការមក ក្នុងវេលាមិនស្គាល់ព្រះសទ្ធម្ម ក្នុងវេលាដែលខ្លួននៅមានចិត្តមិនមាំទាំ ឥឡូវនេះ បុត្ររបស់តថាគតនោះ លះបុណ្យ និងបាបបានហើយ ត្រាស់គាថាពីរថា

**អនវដ្ឋិតចិត្តស្ស សទ្ធម្មំ អវិជានតោ**
**បរិប្លវប្បសាទស្ស បញ្ញា ន បរិបូរតិ ។**
**អនវស្សុតចិត្តស្ស អនន្វាហតចេតសោ**
**បុញ្ញបាបប្បហីនស្ស នត្ថិ ជាគរតោ ភយំ ។**

ប្រាជ្ញា រមែងមិនបរិបូណ៌ដល់បុគ្គល ដែលមានចិត្តមិនខ្ជាប់ខ្ជួន មិនដឹងច្បាស់នូវព្រះសទ្ធម្ម មានសេចក្តីជ្រះថ្លាអណ្តែតទៅ ។ ភ័យ រមែងមិនមានដល់បុគ្គល ដែលមានចិត្តមិនទទឹកដោយរាគៈ មានចិត្តដែលទោសខ្ទាំងខ្ទប់មិនបាន មានបុណ្យ និងបាបលះចោលហើយ ភ្ញាក់រឭកជានិច្ច ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អនវដ្ឋិតចិត្តស្ស** ព្រះសាស្តាទ្រង់សម្តែងអត្ថថា ឈ្មោះថា ចិត្តនេះ របស់បុគ្គលណា មិនមានពិតប្រាកដ ឬមាំទាំ បុគ្គលណា មិនតាំងនៅក្នុងការៈណា ដូចគ្នានឹងត្រឡាចដែលដាក់លើខ្នងសេះ ដូចគ្នានឹងបង្គោលដែលបោះក្នុងគំនរអង្កាម ដូចគ្នានឹងផ្កាកុម្ភ ដាក់លើក្បាលតម្លែក ជួនកាល ជាសាវកៈ គឺអ្នកបម្រើ ជួនកាល ជាអាជីវក ជួនកាល

ជានិគ្រន្ថ ជួនកាល ជាតាបស ។ បុគ្គលបែបនេះ ឈ្មោះថា មានចិត្តមិនតាំងមាំ បញ្ញាដែលជាកាមាវចរក្តី ជារូបាវចរជាដើមក្តី រមែងមិនបរិបូណ៌ដល់បុគ្គលនោះ ដែលមានចិត្តមិនមាំទាំ មិនដឹងព្រះសទ្ធម្មនេះ មានពោធិ-បក្ខិយធម៌ ៣៧ ឈ្មោះថា មានសេចក្តីជ្រះថ្លាអណ្តែតអណ្តូង ព្រោះជាអ្នកមានសទ្ធាតិច ឬព្រោះជាអ្នកមានសទ្ធាញាប់ញ័រ កាលបញ្ញាជាកាមាវចរមិនបរិបូណ៌ បញ្ញាដែលជារូបាវចរ អរូបាវចរ និងលោកុត្តរ នឹងបរិបូណ៌បានអំពីណា ។

បទថា **អនវស្សុតចិត្តស្ស** បានដល់ ជាបុគ្គលមានចិត្តត្រូវរាគៈមិនទទឹកហើយ ។

ក្នុងបទថា **អនន្វាហតចេតសោ** ព្រះដ៏មានព្រះភាគត្រាស់ការដែលចិត្តត្រូវទោសៈប៉ះខ្ទប់ហើយ ក្នុងអាគតដ្ឋានថា មានចិត្តត្រូវទោសៈប៉ះខ្ទប់ដូចសរសេរទៀន ។

តែក្នុងបទថា **អនន្វាហតចេតសោ** នេះ បណ្ឌិតគប្បីជ្រាបអត្ថថា បុគ្គលមានចិត្តដែលទោសៈមិនប៉ះខ្ទប់ ។

បទថា **បុញ្ញបាបបហីនស្ស** សេចក្តីថា ជាអ្នកលះបុណ្យ និងបាបបានដោយមគ្គទី ៤ គឺបុគ្គលអស់អាសវៈហើយ ។

បាទព្រះគាថាថា **នត្ថិ ជាគរតោ ភយំ** សេចក្តីថា ការមិនមានភ័យដូចព្រះដ៏មានព្រះភាគត្រាស់សម្រាប់បុគ្គលដែលអស់អាសវៈ ភ្ញាក់រឭកនោះឯង បុគ្គលដែលអស់អាសវៈនោះ ឈ្មោះថា ភ្ញាក់ហើយ ព្រោះប្រកបដោយ

ធម៌ ជាហេតុភ្ញាក់រឭកទាំងឡាយ មានសទ្ធាជាដើម ។ ព្រោះដូច្នេះ លោកភ្ញាក់ក្តី មិនភ្ញាក់ក្តី ភ័យ គឺកិលេស ឈ្មោះថា មិនមាន ព្រោះកិលេសទាំងឡាយ មិនមានការវិលត្រឡប់មក ។ ពិតណាស់ កិលេសទាំងឡាយ ឈ្មោះថា មិនជាប់តាមលោក ព្រោះកិលេសទាំងឡាយ ដែលលោកលះបានហើយ ដោយមគ្គនោះៗ មិនមានការចូលទៅរកលោកទៀតឡើយ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា កិលេសពួកណាដែលព្រះអរិយបុគ្គលលះបានហើយ ដោយសោតាបត្តិមគ្គ មិនមករក គឺមិនត្រឡប់មកកាន់កិលេសទាំងនោះទៀត កិលេសពួកណាដែលអរិយបុគ្គលលះបានហើយ ដោយសកទាគាមិមគ្គ អនាគាមិមគ្គ និងអរហត្តមគ្គ លោកមិនមករក គឺមិនត្រឡប់មកកាន់កិលេសទាំងនោះទៀត ដូច្នេះ ។

ទេសនាមានប្រយោជន៍ មានផលដល់មហាជនហើយ ។

ថ្ងៃមួយ ភិក្ខុទាំងឡាយសន្ទនាគ្នាថា អាវុសោទាំងឡាយ ឈ្មោះថាកិលេសទាំងនេះគ្រោតគ្រាតពេក កុលបុត្រដែលដល់ព្រមដោយឧបនិស្ស័យនៃអរហត្តបែបនេះ គង់ត្រូវកិលេសឲ្យសៅហ្មងបាន ត្រូវត្រឡប់ទៅជាគ្រហស្ថ អស់ ៧ ដង បួស ៧ ដង ។ ព្រះសាស្តាទ្រង់ស្តាប់បវត្តិកថារបស់ភិក្ខុនោះ ទើបយាងទៅកាន់ធម្មសភា ដោយការទៅដោយសមគួរដល់ខណៈនោះ ប្រថាប់លើពុទ្ធាសនៈហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកប្រជុំដោយពាក្យសម្តីដូចម្តេចហ្ន៎ កាលពួកភិក្ខុក្រាបទូលថា ដោយរឿងឈ្មោះនេះ ហើយទើបត្រាស់ថា កាលពួកភិក្ខុក្រាបទូលថា ដោយរឿងឈ្មោះនេះហើយ

ទើបត្រាស់ថា យ៉ាងនោះឯងភិក្ខុទាំងឡាយ ឈ្មោះថា កិលេសទាំងឡាយ ជាសភាវៈគ្រោតគ្រាត បើកិលេសទាំងនេះមានរូបរាង ដែលបុគ្គលណាម្នាក់គប្បីអាចទុកដាក់បានក្នុងទីមួយកន្លែង ចក្រវាឡនឹងចង្អៀត ព្រហ្មលោកក៏ទាបឱកាសរបស់កិលេសទាំងនោះ មិនគប្បីមានកន្លែងដាក់ឡើយ ។ កិលេសទាំងនេះ រមែងធ្វើបុរសអាជានេយ្យ ដែលដល់ព្រមដោយបញ្ញាដូចតថាគត ឲ្យសៅហ្មងបាន នឹងពោលថ្វីក្នុងជនដ៏សេស ។ មែនពិត តថាគតធ្លាប់អាស្រ័យថ្កៅ និងស្លួយត្រឹមកន្លះនាឡិ និងចបរិលមួយ បួសសឹកហើយអស់ ៦ ដង ។

ភិក្ខុទាំងនោះក្រាបទូលសួរថា បពិត្រព្រះអង្គ រឿងនោះកើតឡើងក្នុងកាលណា ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកនឹងស្តាប់ឬ ភិក្ខុទាំងនោះក្រាបទូលថា ករុណា ព្រះអង្គ ព្រះសាស្តាត្រាស់ថា បើដូច្នោះ ចូរពួកអ្នកស្តាប់ ដូច្នេះហើយ ទ្រង់នាំអតីតនិទានមកត្រាស់ថា

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជ្យសម្បត្តិក្នុងក្រុងពារាណសី បុរសម្នាក់ឈ្មោះកុទ្ទាលបណ្ឌិត បួសជាអ្នកបួសខាងក្រៅ នៅក្នុងព្រៃហិមពាន្ត ៨ ខែ កាលទឹកដីសើមជោកជាំក្នុងសម័យដែលភ្លៀងធ្លាក់ខ្លាំង គិតថា ក្នុងផ្ទះរបស់អញនៅមានគ្រាប់ថ្កៅ និងគ្រាប់ស្លួយប្រមាណកន្លះនាឡិ និងចបរិលមួយ ពូជ គឺថ្កៅ និងស្លួយកុំបីវិនាសឡើយ ទើបសឹក យកចបជម្រះដីមួយកន្លែង សាបព្រោះពូជនោះ រាំងរបងក្នុងកាលដែលគ្រាប់ពូជចាស់ ក៏ប្រមូលបេះពូជទុកប្រមាណមួយនាឡិ បរិភោគពូជដ៏សេស លោកគិតថា ឥឡូវនេះប្រយោជន៍អ្វីដោយផ្ទះរបស់អញ អញនឹងបួស ៨ ខែ ទើបចេញបួសហើយ ។

លោកអាស្រ័យគ្រាប់ថ្លៅ និងគ្រាប់ស្លួយប្រមាណមួយនាឡិ និងចបរិល ក៏សឹកទៅជាគ្រហស្ថអស់ ៧ ដង បួស ៧ ដង ដោយទំនងនេះឯង តែក្នុងគ្រាទី ៧ គិតថា អញអាស្រ័យចបរិលនេះ មកជាគ្រហស្ថហើយបួស អស់ ៧ ដង អញនឹងបោលវាក្នុងទីណាមួយកន្លែង លោកទៅកាន់ច្រាំងស្ទឹងគង្គា ហើយគិតថា កាលអញឃើញទីធ្លាក់គង់ត្រូវចុះរាវយកវិញ អញនឹងបោលវា ដោយអាការដែលអញមិនឃើញទីដែលវាធ្លាក់ ទើបយកសំពត់ចាស់ខ្ចប់ពូជប្រមាណមួយនាឡិ ហើយចងសំពត់ចាស់ត្រង់បន្ទុះចប ចាប់ចបត្រង់ចុងដងឈរត្រង់ច្រាំងស្ទឹង បិទភ្នែកគ្រវីលើក្បាល ៣ ដង គ្រវែងបោលទៅក្នុងស្ទឹងគង្គា បែរមើលទៅមិនឃើញទីធ្លាក់ បានបន្លឺសំឡេងថា អញឈ្នះហើយ អញឈ្នះហើយ អស់វារៈ ២ ដង ។ ខណៈនោះ ព្រះបាទក្រុងពារាណសី ទ្រង់បង្ក្រាបបច្ចន្តជនបទឲ្យរាបទាប ហើយយាងមក ឲ្យបោះព្រះពន្លាក្បែរឆ្នេរស្ទឹង ស្តេចចុះកាន់ស្ទឹង ដើម្បីស្រង់ ទ្រង់បានឮសំឡេងនោះ ។ ធម្មតាសំឡេងថា អញឈ្នះហើយ អញឈ្នះហើយ រមែងមិនពេញព្រះហឫទ័យរបស់ព្រះរាជាទាំងឡាយ ទើបទ្រង់យាងទៅកាន់សម្នាក់របស់កុទ្ទាលបណ្ឌិតនោះ ត្រាស់សួរថា យើងធ្វើការបង្ក្រាបអមិត្តមកអម្បាញ់មិញនេះ ដោយគិតថា យើងឈ្នះ ចំណែកអ្នក ស្រែកថា អញឈ្នះហើយ អញឈ្នះហើយ សេចក្តីនេះដូចម្តេច ទើបកុទ្ទាលបណ្ឌិតទូលថា ព្រះអង្គទ្រង់ឈ្នះពួកចោរខាងក្រៅ ការឈ្នះដែលទ្រង់ឈ្នះហើយ រមែងត្រឡប់ជាមិនឈ្នះទៀតបានពិត ចំណែកចោរ គឺលោភៈ ដែលមាននៅខាងក្នុងដែលទូលបង្គំឈ្នះហើយ ចោរ

គឺសេចក្តីលោភនោះ នឹងមិនត្រឡប់ឈ្នះទូលបង្គំទៀត ឈ្នះចោរ គឺលោភៈនោះតែម្យ៉ាង ទើបល្អ ដូច្នេះហើយ ទើបពោលគាថានេះថា

សេចក្តីឈ្នះណា ត្រឡប់ចាញ់វិញបាន សេចក្តីឈ្នះនោះ មិន
ឈ្មោះថា ឈ្នះប្រពៃទេ សេចក្តីឈ្នះណា មិនត្រឡប់ចាញ់វិញ
បាន សេចក្តីឈ្នះនោះ ទើបឈ្មោះថា ឈ្នះប្រពៃមែនពិត ។

ក្នុងខណៈនោះឯង លោកសម្លឹងមើលស្ទឹងគង្គា ញុំាងកសិណ មានទឹកជាអារម្មណ៍ឲ្យកើតឡើង សម្រេចគុណវិសេសហើយ អង្គុយពត់ភ្នែនក្នុងអាកាស ។ ព្រះរាជាទ្រង់ស្តាប់ធម្មកថារបស់មហាបុរស ថ្វាយបង្គំហើយ ទ្រង់សូមបួស ទ្រង់បួសមួយអន្លើដោយពួកពល មានបរិស័ទប្រមាណ ១ យោជន៍ សូម្បីក្សត្រសាមន្តរាជដទៃ ទ្រង់ស្តាប់កាលដែលព្រះបាទក្រុងពារាណសីនោះបួសហើយ យាងមកដោយបំណងថា អញនឹងកាន់យករាជសម្បត្តិរបស់ស្តេចក្រុងពារាណសីនោះ ទ្រង់ឃើញព្រះនគរដែលមាំទាំយ៉ាងនោះទទេ ទើបត្រិះរិះថា ព្រះរាជាកាលទ្រង់បោះបង់នគរបែបនេះបួស ទ្រង់នឹងមិនបួសក្នុងឋានៈដែលថោកថយ សូម្បីអញបួសក៏គួរ ដូច្នេះហើយ ទ្រង់យាងទៅទីនោះ ចូលទៅរកមហាបុរស ទ្រង់សូមបួស មួយអន្លើដោយបរិស័ទហើយ ។ ព្រះរាជា ៧ អង្គ ទ្រង់បួសដោយទំនងដូចគ្នានេះ ។ អាស្រមក៏ផ្សាយទៅដល់ ៧ យោជន៍ ។ ព្រះរាជា ៧ អង្គ ទ្រង់ចោលភោគៈទាំងឡាយ នាំជនមានប្រមាណប៉ុណ្ណោះបួសហើយ ។ មហាបុរសនៅប្រព្រឹត្តព្រហ្មចរិយៈ ជាអ្នកចូលដល់ព្រហ្មលោកហើយ ។

ព្រះសាស្តាកាលទ្រង់នាំធម្មទេសនានេះមកហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កុទ្ទាលបណ្ឌិតក្នុងកាលនោះ បានជាតថាគត ឈ្មោះថា កិលេសទាំងនេះ ជាសភាវៈគ្រោតគ្រាតយ៉ាងនោះ ។

**រឿង ព្រះចិត្តហត្ថត្ថេរ ចប់**

# រឿង ភិក្ខុប្រារព្ធវិបស្សនា

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធពួកភិក្ខុដែលប្រារព្ធវិបស្សនា ត្រាស់ធម្មទេសនានេះថា **កុម្ភូបមំ** ជាដើម ។

បានឮថា ភិក្ខុ ៥០០ រូប ក្នុងក្រុងសាវត្ថី រៀនកម្មដ្ឋានអំពីភាពជាព្រះអរហន្ត ក្នុងសម្នាក់ព្រះសាស្តាហើយ គិតថា អញនឹងធ្វើសមណធម៌ ទៅអស់ចម្ងាយផ្លូវប្រមាណមួយរយយោជន៍ បានដល់តំបន់ធំមួយ លំដាប់នោះពួកមនុស្សឃើញភិក្ខុទាំងនោះ ទើបនិមន្តឲ្យគង់លើអាសនៈដែលគេបានរៀបចំអង្គាសដោយកត្តាហារទាំងឡាយ មានបបរដ៏ប្រណីតជាដើមហើយ សួរថា លោកម្ចាស់ទាំងឡាយនឹងទៅណា កាលភិក្ខុទាំងនោះពោលថា ពួកអាត្មានឹងទៅតាមផាសុក ទើបនិមន្តថា សូមនិមន្តលោកម្ចាស់ទាំងឡាយ នៅក្នុងទីនេះអស់កាល ៣ ខែចុះ ពួកខ្ញុំនឹងតាំងនៅក្នុសរណៈ នឹងរក្សាសីល ក្នុងសម្នាក់លោកម្ចាស់ទាំងឡាយ ។ ជ្រាបការនិមន្តរបស់ភិក្ខុទាំងនោះហើយ ទើបសួរ

ថា ក្នុងទីមិនឆ្ងាយ មានជនព្រៃជាច្រើន និមន្តលោកម្ចាស់ស្នាក់នៅត្រង់ជនព្រៃនោះចុះ ដូច្នេះហើយ បញ្ជូនទៅ ។ ភិក្ខុទាំងនោះទៅកាន់ជនព្រៃនោះហើយ ។

ពួកទេវតាដែលអាស្រ័យនៅក្នុងជនព្រៃនោះគិតថា លោកម្ចាស់ទាំង-ឡាយមានសីល មកដល់ជនព្រៃនេះដោយលំដាប់ហើយ បើលោកម្ចាស់ទាំងឡាយស្នាក់នៅក្នុងទីនេះ ការដែលពួកយើងនាំបុត្រ និងកាតាឡើងដើមឈើមិនគួរឡើយ ទើបអង្គុយលើផែនដីគិតថា លោកម្ចាស់ទាំងឡាយនៅក្នុងទីនេះមួយយប់ក្នុងថ្ងៃនេះ ស្អែកនេះនឹងទៅពិត ។ ចំណែកពួកភិក្ខុ ត្រាច់ទៅបិណ្ឌបាតក្នុងស្រុក ក្នុងថ្ងៃស្អែកឡើងហើយ ក៏ត្រឡប់មកកាន់ជនព្រៃនោះឯង ។ ពួកទេវតាគិតថា បុគ្គលណាម្នាក់នឹងនិមន្តភិក្ខុសង្ឃឲ្យឆាន់ក្នុងថ្ងៃស្អែកនេះ ព្រោះដូច្នោះ ទើបត្រឡប់មក ។ ថ្ងៃនេះ មិនទៅ ស្អែកនេះ ប្រហែលជាទៅពិត ដូច្នេះហើយ ក៏នាំគ្នាស្នាក់នៅត្រង់ផែនដីនោះឯង ប្រមាណកន្លះខែដោយឧបាយនេះ ។ បន្ទាប់អំពីនោះមក ពួកទេវតាគិតថា លោកម្ចាស់ទាំង-ឡាយ ប្រហែលជានៅក្នុងទីនេះឯងអស់កាល ៣ ខែនេះ កាលលោកម្ចាស់ទាំងឡាយនៅក្នុងទីនេះ ពួកយើងឡើងអង្គុយលើដើមឈើក៏មិនគួរ នឹងត្រូវនាំកូន និងចៅអង្គុយលើផែនដីអស់ ៣ ខែ ក៏ជាទុក្ខរបស់ពួកយើង ពួកយើងនឹងធ្វើដូចម្តេចឲ្យភិក្ខុទាំងនេះគេចទៅបាន ។ ទេវតាទាំងនោះ ក៏ផ្តើមសម្តែងសរីរៈខ្មោចឥតក្បាល និងឲ្យឮសំឡេងអមនុស្ស ក្នុងទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃ និងក្នុងទីបំផុតនៃទីចង្រ្កមនោះៗ រោគទាំងឡាយមានក្អកកណ្តាសជាដើម កើតដល់ពួកភិក្ខុហើយ ភិក្ខុទាំងនោះសួរគ្នានិងគ្នាថា

អាវុសោ ពោគអ្វីចាក់ដោតលោក ពោគអ្វីចាក់ដោតលោកម្ចាស់ ពោលថា ពោគកណ្ដាសចាក់ដោតខ្ញុំ ពោគក្អកចាក់ដោតខ្ញុំ ដូច្នេះហើយ ពោលថា អាវុសោ ថ្ងៃនេះ ខ្ញុំបានឃើញខ្មោចកំបុតក្បាលក្នុងទីបំផុតនៃទីចង្រ្កម ខ្ញុំបាន ឃើញខ្មោចក្នុងទីសម្រាកពេលយប់ ខ្ញុំបានឮសំឡេងអមនុស្សក្នុងទីសម្រាក ពេលថ្ងៃ ទីនេះ ជាទីដែលគួរវៀរ ក្នុងទីនេះ ការមិនផាសុកមានដល់ពួកយើង ពួកយើងនឹងទៅកាន់សម្នាក់របស់ព្រះសាស្ដា ។ ភិក្ខុទាំងនោះ ចេញទៅកាន់ សម្នាក់របស់ព្រះសាស្ដាដោយលំដាប់ ថ្វាយបង្គំហើយ អង្គុយក្នុងទីសមគួរ នាចំណែកម្ខាង ។

លំដាប់នោះ ព្រះសាស្ដាត្រាស់នឹងភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកមិនអាចនៅក្នុងទីនោះឬ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ យ៉ាងនោះឯង ព្រោះអារម្មណ៍ដែលគួរខ្លាចបែបនេះ ប្រាកដដល់ខ្ញុំព្រះអង្គ ទាំងឡាយ ដែលស្នាក់នៅក្នុងទីនោះ ព្រោះហេតុនោះ ទើបមានការមិនផាសុក បែបនេះ ។ ដោយហេតុនោះ ទើបខ្ញុំព្រះអង្គទាំងឡាយគិតថា ទីនេះ ជាទី ដែលគួរវៀរ ចោលទីនោះ មកកាន់សម្នាក់របស់ព្រះអង្គហើយ ព្រះសាស្ដា ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកទៅក្នុងទីនោះឯងសមគួរ ភិក្ខុក្រាប ទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមិនអាចទេ ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុ ទាំងឡាយ ពួកអ្នកមិនយកអាវុធទៅ ឥឡូវនេះ ពួកអ្នក ចូរយកអាវុធទៅ ចុះ ។ ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ កាន់យកអាវុធប្រភេទណា ទៅ ព្រះសាស្ដាត្រាស់ថា តថាគតនឹងឲ្យអាវុធដល់ពួកអ្នក ចូរពួកអ្នកកាន់

យកអាវុធដែលតថាគតឲ្យទៅ ដូច្នេះហើយ ត្រាស់មេត្តសូត្រទាំងមូលថា

កិច្ចណា ( ដែលព្រះអរិយៈ ) បានត្រាស់ដឹងនូវបទដ៏ស្ងប់រម្ងាប់ គឺព្រះនិព្វាន ( បានធ្វើហើយ ) កិច្ចនោះ កុលបុត្តអ្នកឈ្លាសក្នុងប្រយោជន៍គួរធ្វើ ( កុលបុត្តនោះ ) ជាអ្នកអាចហ៊ានផង ត្រង់ដោយកាយ និងវាចាផង ត្រង់ល្អដោយចិត្តផង គេប្រដៅងាយផង មានសុភាពទន់ភ្លន់ផង មិនមានមានះដ៏ក្រៃលែងផង ដូច្នេះជាដើម ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកគប្បីស្វាធ្យាយមេត្តសូត្រនេះ ចាប់តាំងអំពីដងព្រៃខាងក្រៅវិហារ ចូលទៅខាងក្នុងវិហារ ដូច្នេះហើយ ទ្រង់បញ្ជូនទៅហើយ ។ ភិក្ខុទាំងនោះថ្វាយបង្គំព្រះសាស្តា ចេញទៅដល់ដងព្រៃនោះដោយលំដាប់ នាំគ្នាស្វាធ្យាយជាក្រុមខាងក្រៅវិហារ ចូលទៅកាន់ដងព្រៃហើយ ។

ពួកទេវតាក្នុងដងព្រៃទាំងអស់ ក៏ប្រែត្រឡប់បាននូវមេត្តាចិត្ត ធ្វើការទទួលភិក្ខុទាំងនោះ សួរដោយអើពើដល់ការទទួលបាត្រចីវរ ។ សួរដោយអើពើដល់ការគក់ប្របាច់រាងកាយ ធ្វើការរក្សាយ៉ាងមានរបៀបក្នុងទីនោះដល់ពួកលោក ទេវតាបានជាអ្នកអង្គុយស្ងប់ ដូចចក្រដែលឈប់វិល ។ ឈ្មោះថា សំឡេងនៃអមនុស្ស ឈប់មានហើយក្នុងទីណាមួយ ចិត្តរបស់ភិក្ខុទាំងនោះ មានអារម្មណ៍មួយ ពួកលោកអង្គុយក្នុងទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃ ញ៉ាំងចិត្តឲ្យឈមចុះក្នុងវិបស្សនា តាំងនូវសេចក្តីព្យាយាមអស់នូវការអន្តរាយក្នុងខ្លួន គិតថា ឈ្មោះថា អត្តភាពនេះ ដូចគ្នានឹងភាជន៍ដីព្រោះអត្ថថា ត្រូវបែក មិនមាំទាំ ដូច្នេះ ចម្រើនវិបស្សនាហើយ ។

ព្រះសម្មាសម្ពុទ្ធ ប្រថាប់គង់ក្នុងព្រះគន្ធកុដិនោះឯង ទ្រង់ជ្រាបថាភិក្ខុទាំងនោះផ្តើមវិបស្សនាហើយ ទើបទ្រង់ហៅភិក្ខុទាំងនោះត្រាស់ថា ម្នាលភិក្ខុទាំងឡាយយ៉ាងនោះឯង ឈ្មោះថា អត្តភាពនេះ ដូចគ្នានឹងភាជន៍ដីដោយពិត ព្រោះអត្ថថា ត្រូវបែក មិនមាំទាំ ដូច្នេះហើយ ទ្រង់ផ្សាយព្រះឱភាសទៅ សូម្បីប្រថាប់នៅក្នុងទីមួយរយយោជន៍ ក៏ហាក់ដូចប្រថាប់គង់ក្នុងទីចំពោះមុខរបស់ភិក្ខុទាំងនោះ ទ្រង់ផ្សាយព្រះឆព្វណ្ណរង្សី មានព្រះរូបប្រាកដ ត្រាស់ព្រះគាថានេះថា

**កុម្ភូបមំ កាយមិមំ វិទិត្វា នគរូបមំ ចិត្តមិទំ ឋបេត្វា**
**យោធេថ មារំ បញ្ញាវុធេន ជិតញ្ច រក្ខេ អនិវេសនោ សិយា ។**

បុគ្គលគប្បីដឹងច្បាស់នូវកាយនេះថា ដូចជាឆ្នាំង គប្បីបិទនូវចិត្តនេះ ឲ្យដូចជាបិទទ្វារនគរ គប្បីច្បាំងនូវមារដោយអាវុធ គឺបញ្ញា គប្បីរក្សាទុកនូវធម៌ ដែលខ្ជួនឈ្នះហើយ មិនគប្បីជាអ្នកជំអក់នៅ ( ក្នុងធម៌នោះ ) ឡើយ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **នគរូបមំ** សេចក្តីថា ស្គាល់នូវកាយនេះ គឺដែលរាប់ថាប្រជុំនៃអាការ មានសក់ជាដើម ឈ្មោះថា ប្រៀបដូចឆ្នាំង គឺដូចភាជន៍ដី ព្រោះអត្ថថា មិនមានកម្លាំង និងខ្សោយកម្លាំង ព្រោះអត្ថថា ប្រព្រឹត្តទៅម្តងម្កាល ដោយភាពជាកាយមិនស្ថិតស្ថេរ ។

បាទព្រះគាថាថា **នគរូបមំ ចិត្តមិទំ ឋបេត្វា** ជាដើម សេចក្តីថា ធម្មតា

នគរមានគូទឹកជ្រៅ ព័ទ្ធដោយកំពែង ប្រកបដោយទ្វារ និងប៉ម ឈ្មោះថា មាំទាំ ខាងក្រៅ ដល់ព្រមដោយផ្លូវបែកជា ៤ មានផ្សារក្នុងចន្លោះ ឈ្មោះថា រៀបចំល្អខាងក្នុង ពួកចោរខាងក្រៅមកកាន់នគរនោះ ដោយគិតថា អញនឹងប្លន់ ក៏មិនអាចចូលទៅបាន រមែងហាក់ដូចជាប៉ះនូវភ្នំ ខ្ចាតត្រឡប់ទៅយ៉ាងណា កុលបុត្រដែលជាបណ្ឌិតក៏ដូច្នោះដូចគ្នា រក្សាវិបស្សនាចិត្តរបស់ខ្លួនធ្វើឲ្យមាំទាំ គឺឲ្យដូចគ្នានឹងនគរ ហាមកិលេសដែលមគ្គនោះៗ គប្បីសម្លាប់ដោយអាវុធគឺបញ្ញា ដែលសម្រេចហើយដោយវិបស្សនា និងសម្រេចហើយដោយអរិយមគ្គ ឈ្មោះថា គប្បីច្បាំង គឺគប្បីប្រហារកិលេសមារនោះ ដូចអ្នកចម្បាំងឈរក្នុងនគរ ច្បាំងពួកចោរដោយអាវុធ មានប្រការផ្សេងៗ មានអាវុធដែលមានមុខតែម្ខាង ដូច្នោះ ។

ពីរបទថា **ជិតញ្ច រក្ខេ** សេចក្តីថា កុលបុត្រកាលត្រូវសេពអាវាសជាទីសប្បាយ ឧតុជាទីសប្បាយ បុគ្គលជាទីសប្បាយ និងការស្តាប់ធម៌ជាហេតុសប្បាយជាដើម ចូលសមាបត្តិក្នុងចន្លោះៗ ចេញអំពីសមាបត្តិនោះ ពិចារណាសង្ខារទាំងឡាយដោយចិត្តបរិសុទ្ធ ឈ្មោះថា គប្បីរក្សាធម៌ ដែលឈ្នះហើយ គឺវិបស្សនាយ៉ាងទន់ ដែលខ្លួនឲ្យកើតឡើងហើយ ។

ពីរបទថា **អនិវេសនោ សិយា** បានដល់ គប្បីជាអ្នកមិនមានអាល័យ អធិប្បាយថា ឧបមាដូចអ្នកចម្បាំងធ្វើជម្រកជាទីសម្រាកនៃពល ក្នុងបទេសដែលប្រឈមមុខនៃសង្គ្រាម ច្បាំងជាមួយពួកអមិត្ត ជាអ្នកឃ្លាន ឬស្រេកហើយ កាលក្រោះធូរ ឬកាលអាវុធភ្ជាត់ធ្លាក់ ក៏ចូលទៅកាន់ជម្រកជាទីសម្រាក

របស់ពួកពល សម្រាកបរិភោគ ផឹក ចងនូវក្រោះ ចាប់អាវុធហើយ ចេញច្បាំងទៀត ញាំញីសេនានៃបរបក្ស ឈ្នះបច្ចាមិត្តដែលមិនទាន់បានឈ្នះ រក្សាជ័យជម្នះដែលឈ្នះហើយ បើអ្នកចម្បាំងនោះ កាលសម្រាកយ៉ាងនោះ ក្នុងជម្រកដែលជាទីសម្រាកនៃពល ត្រេកអរក្នុងជម្រកនោះ គប្បីស្នាក់នៅ ក៏គប្បីធ្វើរាជសម្បត្តិ ឲ្យប្រព្រឹត្តទៅក្នុងកណ្ដាប់ដៃរបស់សត្រូវយ៉ាងណា ភិក្ខុនោះក៏ដូច្នោះដូចគ្នា ព្យាយាមចូលសមាបត្តិ ចេញអំពីសមាបត្តិនោះ ពិចារណាសង្ខារទាំងឡាយ ដោយចិត្តដ៏បរិសុទ្ធ រមែងអាចរក្សាវិបស្សនាយ៉ាងទន់ ដែលបានចំពោះហើយ រមែងឈ្នះកិលេសមារដោយការបានចំពោះនូវមគ្គដ៏ប្រសើរ តែបើភិក្ខុនោះ ពេញចិត្តក្នុងសមាបត្តិតែម្យ៉ាង មិនព្យាយាមពិចារណាសង្ខារទាំងឡាយដោយចិត្តដ៏បរិសុទ្ធទេ មិនអាចធ្វើនូវការចាក់ធ្លុះមគ្គ និងផលបានឡើយ ព្រោះហេតុនោះ ភិក្ខុកាលរក្សាធម៌ដែលគួររក្សា គប្បីជាអ្នកមិនជាប់នៅ គឺគប្បីធ្វើសមាបត្តិឲ្យជាទីសម្រាកហើយ មិនជាប់នៅ បានដល់ មិនគប្បីធ្វើអាល័យក្នុងសមាបត្តិនោះ ។ ព្រះសាស្ដាត្រាស់ថា អ្នកទាំងឡាយ ចូរធ្វើយ៉ាងនោះ ។ ព្រះសាស្ដាទ្រង់សម្ដែងធម៌ដល់ភិក្ខុទាំងឡាយនោះ ដោយប្រការដូច្នេះ ។

ក្នុងពេលចប់ធម្មទេសនា ភិក្ខុ ៥០០ រូប អង្គុយក្នុងទីអង្គុយនោះ សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ សរសើរផង ថ្វាយបង្គំព្រះសរីរៈ ដ៏ប្រកបដោយវណ្ណៈដូចមាសរបស់ព្រះតថាគតផង និមន្តមកហើយ ដូច្នេះឯង ។

# រឿង បូតិគត្តិស្សត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធព្រះថេរៈឈ្មោះបូតិគត្តិស្សត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **អចិរំ វតយំ កាយោ** ជាដើម ។

បានឮថា កុលបុត្រអ្នកក្រុងសាវត្ថីមួយរូប ស្តាប់ធម្មកថាក្នុងសម្នាក់របស់ព្រះសាស្តា ថ្វាយជីវិតក្នុងព្រះសាសនា បានបព្វជ្ជាឧបសម្បទាហើយបានឈ្មោះថា ព្រះតិស្សត្ថេរ ។ កាលកន្លងទៅ រោគកើតឡើងក្នុងសរីរៈរបស់លោក ពកទាំងឡាយ ប្រមាណប៉ុនគ្រាប់ស្ពៃផ្កាផុសឡើង ពកនោះធំឡើងតាមលំដាប់ ប្រមាណប៉ុនគ្រាប់សណ្តែកបាយ ប្រមាណប៉ុនគ្រាប់សណ្តែកខ្មៅប្រមាណប៉ុនគ្រាប់ក្រជៅ ប្រមាណប៉ុនផ្លែកន្ទួតព្រៃ ប្រមាណប៉ុនផ្លែព្នៅ បែកហើយ ។ សរីរៈទាំងនោះ បានជាប្រហោងតូចធំ ឈ្មោះរបស់លោកកើតឡើងហើយថា ព្រះបូតិគត្តិស្សត្ថេរ គឺព្រះតិស្សត្ថេរមានកាយស្អុយ ។ បន្ទាប់មក ក្នុងកាលជាចំណែកដទៃ ឆ្អឹងរបស់លោកបែកហើយ លោកបានជាបុគ្គល ដែលបុគ្គលណាមួយបដិបត្តិ គឺបម្រើមិនបាន ។ សំពត់ស្បៀក និងសំពត់ដណ្តប់ ប្រឡាក់ដោយខ្ទុះ និងឈាម បានដូចជាទំពុម្ព ។ ពួកភិក្ខុមានសទ្ធិវិហារិកជាដើម មិនអាចបដិបត្តិបាន លះបង់លោកហើយ លោកជាបុគ្គលមិនមានទីពឹង សឹងហើយ ។

ធម្មតាព្រះសម្ពុទ្ធទាំងឡាយ ទ្រង់មិនលះបង់ កាលប្រមើលមើលសត្វលោក អស់ពីរវារៈ គឺក្នុងពេលទៀបភ្លឺ កាលទ្រង់ប្រមើលមើលលោក ទ្រង់

ប្រមើលតាំងអំពីកណ្តាប់នៃចក្រវាល ធ្វើព្រះញាណឲ្យបែរមុខចំពោះព្រះគន្ធ-កុដិ កាលទ្រង់ប្រមើលក្នុងពេលល្ងាច ទ្រង់ប្រមើលចាប់ពីព្រះគន្ធកុដិ ធ្វើព្រះញាណឲ្យបែរមុខចំពោះទីខាងក្រៅ ។ ក្នុងសម័យនោះ ព្រះបូតិគត្តិស្សត្ថេរប្រាកដហើយខាងក្នុងសំណាញ់ គឺព្រះញាណរបស់ព្រះដ៏មានព្រះភាគ ។ ព្រះសាស្តាទ្រង់ឃើញឧបនិស្ស័យនៃអរហត្តរបស់ព្រះតិស្សភិក្ខុ ទ្រង់ត្រិះរិះថា ភិក្ខុនេះត្រូវពួកសទ្ធិវិហារិកជាដើមលះបង់ហើយ ឥឡូវនេះ ភិក្ខុនេះ វៀរតថាគតចេញ មិនមានទីពឹងដទៃឡើយ ដូច្នេះហើយ ទើបទ្រង់យាងចេញអំពីព្រះគន្ធកុដិ ដូចយាងចារិកក្នុងវិហារ ទ្រង់ទៅកាន់រោងភ្លើង ទ្រង់លាងឆ្នាំងដាក់ទឹក លើកដាក់លើជើងក្រាន កាលទ្រង់រង់ចាំឲ្យទឹកក្តៅ បានប្រថាប់ឈរក្នុងរោងភ្លើងនោះឯង ទ្រង់ដឹងកាលដែលទឹកក្តៅហើយ យាងទៅចាប់ចុងគ្រែដែលតិស្សភិក្ខុសិង ។ ក្នុងកាលនោះ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះអង្គសូមទ្រង់យាងទៅ បពិត្រព្រះអង្គ ពួកខ្ញុំព្រះអង្គនឹងលើកឯង ហើយលើកគ្រែ នាំទៅកាន់រោងភ្លើង ។ ព្រះសាស្តាទ្រង់ឲ្យនាំស្នូកមក ទ្រង់ចាក់ទឹកក្តៅហើយ ទ្រង់ប្រាប់ភិក្ខុនោះឲ្យដោះយកសំពត់ដណ្តប់របស់លោក ឲ្យញីដោយទឹកក្តៅ ហើយឲ្យហាលថ្ងៃ ។ លំដាប់នោះ ព្រះសាស្តាប្រថាប់ឈរក្នុងទីជិតលោក ទ្រង់ស្រោចសរីរៈនោះឲ្យសើមដោយទឹកក្តៅ ហើយជូតសរីរៈរបស់លោក ឲ្យលោកងូតហើយ ។ ក្នុងទីបំផុតនៃការងូតរបស់លោក សំពត់ដណ្តប់នោះស្ងួតហើយ ។ ពេលនោះ ព្រះសាស្តាទ្រង់គ្រាហ៍លោកឲ្យស្លៀកសំពត់ដណ្តប់នោះ ទ្រង់ឲ្យបោកសំពត់កាសាវៈដែលលោកស្លៀកដោយទឹក ហើយ

ឲ្យហាលថ្ងៃ ។ ពេលនោះ កាលទឹកត្រង់កាយរបស់លោកស្ងួត សំពត់ស្បៀក នោះក៏ស្ងួត ។ លោកស្បៀកសំពត់កាសាវៈមួយផ្ទាំង ដណ្ដប់សំពត់កាសាវៈ មួយផ្ទាំង ជាអ្នកមានសរីរៈស្រាល មានអារម្មណ៍ជាឯកគ្គតា សិងលើគ្រែ ហើយ ។ ព្រះសាស្ដាប្រថាប់ឈរក្នុងទីខាងលើសីសៈរបស់លោក ត្រាស់ថា ម្នាលភិក្ខុ កាយរបស់អ្នកនេះមានវិញ្ញាណទៅប្រាសហើយ មិនមានឧបការៈ នឹងដេកលើផែនដីដូចអង្កត់ឧស ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**អចិរំ វតយំ កាយោ បឋវឹ អធិសេស្សតិ**

**ឆុទ្ធោ អបេតវិញ្ញាណោ និរត្ថំវ កលិង្គរំ ។**

ឱហ្ន៎ មិនយូរប៉ុន្មានទេតើ កាយនេះ មានវិញ្ញាណទៅ

ប្រាស គេយកទៅចោលផុតហើយ មុខជានឹងដេកស្ដូក

ស្ដឹងលើផែនដី ដូចជាអង្កត់ឧសរកប្រយោជន៍គ្មាន ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **អចិរំ វត** ជាដើម សេចក្ដីថា ភិក្ខុ ក្នុង កាលមិនយូរឡើយ កាយនេះ នឹងដេកសង្កត់លើផែនដី គឺដេកខាងលើនៃ ផែនដី ដែលសត្វដេកហើយ ដោយការដេកប្រក្រតីនេះ ។

ដោយបទថា **ឆុទ្ធោ** ព្រះសាស្ដាទ្រង់សម្ដែងអត្ថថា កាយនេះនឹងជារបស់ ឈ្មោះថា ទទេ ព្រោះការមានវិញ្ញាណទៅប្រាស ត្រូវបោះចោលហើយដេក ។ សេចក្ដីនេះ ដូចអ្វី ដូចអង្កត់ឧសមិនមានប្រយោជន៍ អធិប្បាយថា ដូចអង្កត់ ឧសដែលមិនមានឧបការៈ មិនមានប្រយោជន៍ ។ មែនពិត ពួកមនុស្សដែល

មានសេចក្តីត្រូវការដោយទព្វសម្ភារៈ ចូលកាន់ព្រៃហើយ កាប់ឈើត្រង់ដោយសណ្ឋាននៃឈើត្រង់ ឈើវៀចដោយសណ្ឋាននៃឈើវៀច កាន់យកជាទព្វ-សម្ភារៈ តែកាប់ឈើជាប្រហោង ឈើពុក ឈើមិនមានខ្លឹម ឈើពកតូចធំដ៏សេស បោលក្នុងព្រៃនោះឯង មនុស្សពួកដទៃ ដែលត្រូវការដោយទព្វ-សម្ភារៈ មកហើយ ឈ្មោះថា បំណងកាន់យកចម្រៀកឈើដែលត្រូវបោលនោះ មិនមាន មនុស្សទាំងនោះសម្លឹងមើលឈើនោះហើយ កាន់យកឈើដែលមានឧបការៈដល់ខ្លួនប៉ុណ្ណោះ ឈើក្រៅអំពីនេះ ជាឈើសន្ធត់ផែនដីតែម្យ៉ាង ។ ឈើនោះ គប្បីជាឈើមិនមានបុគ្គលណាម្នាក់ អាចធ្វើជាជើងរោងគ្រែ ឬជ្រញ់ទ្រាប់ជើង ឬថា ធ្វើជាតាំងបន្ទះក្តារដោយឧបាយនោះៗ បានបណ្តាអាការ ៣២ ក្នុងអត្តភាពនេះ មួយចំណែក ឈ្មោះថា ចូលដល់នូវភាពជារបស់ដែលគប្បីកាន់យកបាន ដោយអំណាចនៃឧបករណ៍វត្ថុ មានទ្រនល់គ្រែជាដើម ឬដោយមុខ មានឧបការៈដទៃ មិនមាន កាយនេះ មានវិញ្ញាណទៅប្រាសហើយ ក្នុងថ្ងៃបន្តិចបន្តួចប៉ុណ្ណោះ ក៏នឹងដេកលើផែនដី ដូចអង្កត់ឧស មិនមានប្រយោជន៍ដូច្នោះ ដូច្នេះឯង ។

ក្នុងកាលចប់ទេសនា ព្រះបូតិគត្តិស្សត្ថេរសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាហើយ មហាជនក៏បានជាព្រះអរិយបុគ្គល មានសោតបន្នជាដើម ។ ចំណែកព្រះថេរៈសម្រេចអរហត្តហើយ បរិនិព្វាន ។ ព្រះសាស្តាឲ្យធ្វើសរីរ-កិច្ចរបស់លោក ទ្រង់ទុកអដ្ឋិធាតុហើយ ឲ្យធ្វើចេតិយបញ្ចុះ ។

ពួកភិក្ខុក្រាបទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គ ព្រះបូតិគត្តិស្សត្ថេរ

កើតក្នុងទីណា ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បរិនិព្វានហើយ ពួកភិក្ខុពោលថា បពិត្រព្រះអង្គ កាយរបស់ភិក្ខុដែលដល់ព្រមដោយឧបនិស្ស័យនៃអរហត្តបែបនោះ កើតជាកាយស្អុយ ព្រោះហេតុដូចម្តេច ឆ្អឹងទាំងឡាយបែកហើយ ព្រោះហេតុដូចម្តេច អ្វីជាហេតុដល់នូវភាពជាឧបនិស្ស័យនៃអរហត្តរបស់លោក ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ផលទាំងអស់នេះ កើតហើយដល់តិស្សៈនោះ ក៏ព្រោះកម្មដែលខ្លួនធ្វើ ។ ភិក្ខុទាំងនោះសួរថា បពិត្រព្រះអង្គ តើកម្មដែលលោកធ្វើនោះដូចម្តេច ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ចូរពួកអ្នកស្តាប់ ដូច្នេះហើយ ទ្រង់នាំអតីតនិទានមក ត្រាស់ដូចតទៅនេះ

តិស្សភិក្ខុនេះ ជាព្រានបក្សី ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធ ព្រះនាមកស្សបៈ សម្លាប់បក្សីជាច្រើន ទំនុកបម្រុងឥស្សរជន លក់បក្សីដ៏សេស អំពីបក្សីដែលឲ្យដល់ឥស្សរជនទាំងនោះ ។ គិតថា សត្វដែលសល់អំពីលក់ បើអញសម្លាប់រក្សាទុក ក៏នឹងស្អុយខូច ទើបកាច់ឆ្អឹងស្នែង និងឆ្អឹងស្លាបរបស់បក្សីទាំងនោះ ធ្វើឲ្យហើរមិនបាន ហើយគរទុក ។ គាត់លក់បក្សីទាំងនោះក្នុងថ្ងៃស្អែក ក្នុងកាលដែលបានបក្សីច្រើន ក៏ឲ្យអាំងដើម្បីជាប្រយោជន៍ដល់ខ្លួន ។ ថ្ងៃមួយ កាលភោជនមានរសរបស់គាត់ឆ្អិនហើយ ព្រះខីណាស្រពមួយអង្គ ត្រាច់ទៅបិណ្ឌបាត បានឈរត្រង់ទ្វារផ្ទះរបស់គាត់ គាត់ឃើញព្រះថេរៈហើយ ញុំាងចិត្តឲ្យជ្រះថ្លា គិតថា សត្វមានជីវិតជាច្រើន ត្រូវអញសម្លាប់ឲ្យស្លាប់ លោកម្ចាស់ឈរត្រង់ទ្វារផ្ទះរបស់អញ ភោជនដែលមានរសក៏មានព្រមក្នុងផ្ទះ អញ

នឹងប្រគេនបិណ្ឌបាតដល់លោក ។ ដូច្នេះហើយ ទើបទទួលបាត្ររបស់ព្រះទីណាស្រេពនោះ ដាក់ភោជនដែលមានរសនោះ ឲ្យពេញក្នុងបាត្រហើយ ប្រគេនបិណ្ឌបាតដែលមានរស ហើយថ្វាយបង្គំព្រះថេរៈដោយបញ្ចង្គប្រតិស្ឋាន ពោលថា បពិត្រលោកម្ចាស់ ខ្ញុំគប្បីដល់ទីបំផុតនៃធម៌ដែលលោកម្ចាស់ឃើញចុះ ។ ព្រះថេរៈធ្វើអនុមោទនាថា ចូរសម្រេចយ៉ាងនោះចុះ ។

ម្នាលភិក្ខុទាំងឡាយ ផលទាំងអស់នោះសម្រេចដល់តិស្សៈ ដោយអំណាចនៃកម្មដែលតិស្សៈធ្វើហើយក្នុងកាលនោះឯង កាយរបស់តិស្សកើតរោគស្អុយរលួយ ហើយឆ្អឹងទាំងឡាយបែក ក៏ដោយផលនៃការវាយឆ្អឹងបក្សីទាំងឡាយ តិស្សៈសម្រេចអរហត្ត ក៏ដោយផលនៃការថ្វាយបិណ្ឌបាតដែលមានរសដល់ព្រះទីណាស្រេពដូច្នេះឯង ។៚

**រឿង ព្រះបូតិគត្តតិស្សត្ថេរ ចប់**

# រឿង នន្ទគោបាលកៈ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងកោសលជនបទ ទ្រង់ប្រារព្ធនាយគោបាលកៈ ឈ្មោះនន្ទៈ ត្រាស់ព្រះធម្មទេសនានេះថា **ទិសោ ទិសំ** ជាដើម ។

បានឮមកថា នាយគោបាលកៈឈ្មោះនន្ទៈ ក្នុងក្រុងសាវត្ថី ជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានសម្បត្តិច្រើន រក្សាហ្វូងគោរបស់គហបតីឈ្មោះ

អនាថបិណ្ឌិក ។ បានឮថា នាយនន្ទគោបាលកៈនោះ លបគេចអំពីរាជភ័យ ព្រោះភាពជាអ្នកចិញ្ចឹមគោ ដូចជជិលឈ្មោះកេណិយៈ លបគេចនូវការបៀតបៀននៃព្រះរាជាដោយភេទបព្វជិត រក្សាកំណប់ទ្រព្យរបស់ខ្លួន ។ គាត់កាន់យកបញ្ចគោរស អស់កាលដ៏សមគួរដល់កាល មកកាន់សម្នាក់របស់អនាថ-បិណ្ឌកសេដ្ឋី ជួបព្រះសាស្ដាស្ដាប់ធម៌ហើយ ទូលអារាធនាព្រះសាស្ដាដើម្បីឲ្យទ្រង់យាងមកកាន់លំនៅរបស់ខ្លួន ។

ព្រះសាស្ដា ទ្រង់រង់ចាំភាពចាស់ក្លានៃញាណរបស់បុរសនោះ ទ្រង់មិនយាងទៅឡើយ កាលទ្រង់ជ្រាបភាពដែលគាត់មានបញ្ញាចាស់ក្លាហើយ ថ្ងៃមួយទ្រង់មានមហាភិក្ខុសង្ឃចោមរោមហើយ យាងចារិកទៅ ទ្រង់គេចអំពីផ្លូវប្រថាប់គង់ហើយត្រង់គល់ឈើមួយកន្លែង ដែលជិតលំនៅរបស់នន្ទគោបាលកៈនោះ ។

នាយនន្ទៈចូលទៅកាន់សម្នាក់របស់ព្រះសាស្ដា ថ្វាយបង្គំ ធ្វើបដិសណ្ឋារៈនិមន្តព្រះសាស្ដាហើយ បានថ្វាយបញ្ចគោរសទាន ដ៏ប្រណីតដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ ព្រះសាស្ដាទ្រង់ធ្វើអនុមោទនាស្រេចហើយ ត្រាស់អនុបុព្វីកថា មានទានកថាជាដើម ក្នុងកាលចប់កថា នាយគោបាលកៈឈ្មោះនន្ទៈ តាំងនៅក្នុងសោតាបត្តិផល ទទួលបាត្ររបស់ព្រះសាស្ដាតាមជូនដំណើរព្រះសាស្ដាទៅ កាលព្រះសាស្ដាប្រាប់ឲ្យត្រឡប់ ដោយព្រះតម្រាស់ថា ឧបាសក អ្នកចូរឈប់ចុះ ថ្វាយបង្គំព្រះសាស្ដាត្រឡប់ហើយ ។ លំដាប់នោះ នាយព្រានម្នាក់បានបាញ់គាត់ស្លាប់ហើយ ។

ពួកភិក្ខុមកឯក្រោយឃើញហើយ ទើបទៅក្រាបទូលព្រះសាស្តាថា បពិត្រព្រះអង្គ នាយនន្ទគោបាលកៈថ្វាយមហាទាន តាមជូនដំណើរទ្រង់ហើយត្រឡប់ទៅ ត្រូវនាយព្រានសម្លាប់បង់ហើយ ក៏ព្រោះភាពដែលព្រះអង្គយាងមកក្នុងទីនេះ បើព្រះអង្គមិនយាងមកហើយសោត ការស្លាប់នឹងមិនមានដល់គាត់ឡើយ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលតថាគតមកក្តី មិនបានមកក្តី ឈ្មោះថា ឧបាយជាគ្រឿងផុតចាកការស្លាប់របស់នាយនន្ទៈនោះ សូម្បីទៅកាន់ទិសធំ ៤ ទិសតូច ៤ មិនមាន ដ្បិតថា ចិត្តប៉ុណ្ណោះដែលតម្កល់ខុសហើយ ដែលប្រព្រឹត្តទៅខាងក្នុងសត្វទាំងនេះ រមែងធ្វើសេចក្តីវិនាសដែលពួកចោរ ឬពួកមនុស្សដែលចងពៀរធ្វើមិនបានដូច្នេះ ត្រាស់ព្រះគាថានេះថា

**ទិសោ ទិសំ យន្តំ កយិរា វេរី វា បន វេរិនំ**
**មិច្ឆាបណិហិតំ ចិត្តំ បាបិយោ នំ តតោករេ ។**

ចោរក្រឡេកឃើញចោរផងគ្នា ឬក៏បុគ្គលមានពៀរ ក្រឡេកឃើញបុគ្គលមានពៀរផងគ្នា គប្បីធ្វើនូវសេចក្តីវិនាសណាមួយដល់គ្នា ចិត្តដែលបុគ្គលតាំងទុកខុសហើយ រមែងធ្វើបុគ្គលនោះឲ្យអាក្រក់ក្រៃលែង ជាងសេចក្តីវិនាសនោះទៅទៀត ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **ទិសោ ទិសំ** ប្រែថា ចោរឃើញចោរ ។ សព្ទថា **ទិស្វា** ជាព្រះបាលីដ៏សេស គឺបណ្ឌិតគប្បីបន្ថែមចូល ។ ពីរបទថា **យន្តំ កយិរា** សេចក្តីថា គប្បីធ្វើនូវសេចក្តីវិនាសនោះដល់ចោរ ឬបុគ្គលចង

ពៀរនោះ ។ សូម្បីក្នុងបទទី ២ ក៏មានន័យដូចគ្នា ។

ព្រះដ៏មានព្រះភាគ បានត្រាស់ជាពាក្យអធិប្បាយដូច្នេះថា ចោរ ជាអ្នកប្រទូស្តចំពោះមិត្តណាម្នាក់ កាលខុសក្នុងបុត្រ ភរិយា ស្រែ ចម្ការ គោ និងក្របីជាដើមរបស់ចោរណាម្នាក់ ចោរខុសចំពោះចោរណា ឃើញចោរនោះដែលខុសក្នុងខ្លួនយ៉ាងនោះឯង ឬថាបុគ្គលចងពៀរ ឃើញបុគ្គលដែលចងពៀរទុកដោយហេតុណាមួយយ៉ាងនោះឯង ដែលឈ្មោះថាអ្នកចងពៀរ ។ ដែលឈ្មោះថាគប្បីធ្វើសេចក្តីវិនាសឯណាដល់ចោរ ឬបុគ្គលចងពៀរនោះ គឺគប្បីបៀតបៀនបុត្រ និងភរិយារបស់ចោរ ឬអ្នកចងពៀរនោះ គប្បីធ្វើវត្ថុផ្សេងៗមានស្រែជាដើមរបស់ចោរ ឬរបស់បុគ្គលចងពៀរនោះឲ្យវិនាស ឬគប្បីផ្តាច់ជីវិតចោរ ឬបុគ្គលចងពៀរនោះ ព្រោះភាពដែលខ្លួនជាអ្នកកាចសាហាវ ឬព្រោះភាពដែលខ្លួនជាបុគ្គលឃោរឃៅ ចិត្ត ឈ្មោះថា តម្កល់ខុស ព្រោះភាពជាចិត្តតម្កល់ខុសក្នុងអកុសលកម្មបថ ១០ គប្បីធ្វើឲ្យបុគ្គលនោះអាក្រក់ជោកទាបក្រៃលែងជាងការវិនាសនោះ គឺធ្វើបុរសនោះឲ្យជាអ្នកលាមកជាងហេតុនោះទៅទៀត ។ ពិតហើយ ចោរក្តី បុគ្គលចងពៀរក្តី មានប្រការដូចពោលហើយ គប្បីញុំាងទុក្ខឲ្យកើត ឬគប្បីធ្វើនូវការអស់ទៅនៃជីវិតដល់ចោរ ឬដល់បុគ្គលចងពៀរបានក្នុងអត្តភាពនេះប៉ុណ្ណោះ ។ ចំណែកចិត្តនេះ ដែលបានតម្កល់ក្នុងអកុសលកម្មបថទាំងឡាយ រមែងញុំាងបុគ្គលឲ្យដល់នូវសេចក្តីវិនាសក្នុងទិដ្ឋធម៌ខ្លះ បន្សាត់ទៅក្នុងអបាយ ៤ រមែងមិនឲ្យងើបក្បាលឡើងបានក្នុងពាន់អត្តភាពខ្លះ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ទេសនាមានប្រយោជន៍ដល់មហាជនហើយ ។

កម្មដែលឧបាសកបានធ្វើក្នុងរវាងកព្ពូកភិក្ខុមិនបានទូលសួរ ព្រោះហេតុដូច្នោះ ទើបកម្មនោះ ព្រះសាស្តាមិនបានត្រាស់ប្រាប់ ដូច្នេះឯង ៚

**រឿង ឆត្តគោថាលកៈ ចប់**

# រឿង សោរេយ្យត្ថេរ

## លំនាំដើម

ព្រះសាស្តាញ៉ាំងព្រះធម្មទេសនានេះថា **ន តំ មាតា បិតា កយិរា** ជាដើម ដែលតាំងឡើងក្នុងសោរេយ្យនគរ ឲ្យចប់ក្នុងនគរសាវត្ថី ។

ព្រះសាស្តា កាលគង់នៅក្នុងក្រុងសាវត្ថី កូនប្រុសរបស់សោរេយ្យសេដ្ឋីក្នុងសោរេយ្យនគរ អង្គុយលើយានតូច ដែលមានសេចក្តីសុខជាមួយសម្លាញ់ម្នាក់ ចេញទៅអំពីនគរ ដើម្បីប្រយោជន៍នឹងងូតទឹក ដោយបរិវារដ៏ច្រើន ។ ខណៈនោះ ព្រះមហាកច្ចាយនត្ថេរ មានបំណងនឹងចូលទៅកាន់សោរេយ្យនគរដើម្បីបិណ្ឌបាត ដណ្តប់សំពត់សង្ឃាដីខាងក្រៅព្រះនគរ ។ សរីរៈរបស់ព្រះថេរៈមានពណ៌ដូចមាស កូនប្រុសរបស់សោរេយ្យសេដ្ឋីឃើញលោកហើយទើបគិតថា ស្អាតពិតហ្ន៎ ព្រះថេរៈរូបនេះ គួរជាភរិយារបស់អញ ឬពណ៌នៃសរីរៈរបស់ភរិយាអញ គប្បីដូចជាពណ៌នៃសរីរៈរបស់ព្រះថេរៈនោះ ។ ក្នុង

ខណៈគ្រាន់តែចិត្តគិតហើយប៉ុណ្ណោះ ភេទប្រុសរបស់សេដ្ឋីបុត្រនោះក៏វិនាស ទៅ ភេទស្រីបានប្រាកដហើយ ។ គាត់មានការខ្មាសអៀន ទើបចុះអំពីរទេះ គេចទៅ បុគ្គលអ្នកជិតស្និទ្ធ ចំណាំនូវកូនប្រុសរបស់សេដ្ឋីនោះមិនបាន ទើប ពោលថា អ្វីនុ៎ះ អ្វីនុ៎ះ សូម្បីនាងក៏ដើរទៅកាន់ផ្លូវ ដែលទៅកាន់ក្រុង តក្កសិលា ។

ចំណែកសម្មាញ់របស់នាង សូម្បីដើររកខាងនោះ និងខាងនេះក៏មិនជួប ជនទាំងពួងងូតស្រេចហើយ បានត្រឡប់ទៅកាន់ផ្ទះ ។ កាលជនទាំងឡាយ ពោលថា សេដ្ឋីបុត្រទៅណា ជនដែលទៅជាមួយឆ្លើយថា ពួកខ្ញុំស្មានថាគាត់ ងូតទឹកត្រឡប់មកហើយ ។ ខណៈនោះ មាតា និងបិតារបស់សេដ្ឋីបុត្រ គយ គន់មើលក្នុងទីនោះៗ កាលមិនឃើញ ទើបទ្រហោយំរៀបរាប់ បានថ្វាយភត្ត ដើម្បីអ្នកស្លាប់ ដោយសម្គាល់ថា កូនប្រុសរបស់ខ្លួនស្លាប់ហើយ ។

នាងឃើញពួករទេះទៅកាន់ក្រុងតក្កសិលា ទើបដើរតាមក្រោយយានតូច ទៅ ។ ខណៈនោះ ពួកមនុស្សឃើញនាងហើយពោលថា នាងដើរតាមក្រោយ យានតូចរបស់ពួកយើងធ្វើអ្វី ពួកយើងមិនស្គាល់នាងថា នាងជាកូនស្រីរបស់ អ្នកណា នាងពោលថា នែអ្នក ពួកអ្នកបររទេះតូចពួកអ្នកទៅចុះ ខ្ញុំនឹងដើរ ទៅ កាលដើរទៅហត់នឿយខ្លាំង បានដោះចិញ្ចៀនសម្រាប់ពាក់ត្រង់ម្រាមដៃ ឲ្យហើយ ធ្វើឱកាសក្នុងយានតូចមួយកន្លែងដើម្បីខ្លួន ។

ពួកមនុស្សគិតថា ភរិយារបស់សេដ្ឋីបុត្រនៃពួកយើង ក្នុងក្រុងតក្កសិលា មិនទាន់មាន យើងទាំងឡាយនឹងប្រាប់ដល់លោក បណ្ណាការធំនឹងមានដល់ពួក

យើង ។ ពួកជនទាំងនោះទៅហើយ សួរថា បពិត្រលោកម្ចាស់ ឥត្ថីកែវខ្ញុំបាននាំមកហើយដើម្បីលោកម្ចាស់ កូនប្រុសរបស់សេដ្ឋីនោះបានស្តាប់ហើយ ឲ្យហៅនាងមក ឃើញនាងសមនឹងវ័យរបស់ខ្លួន មានរូបស្អាតគួរពេញចិត្ត មានសេចក្តីស្រឡាញ់កើតឡើង ទើបបានឲ្យធ្វើជាកិរិយាក្នុងផ្ទះរបស់ខ្លួន ។

មែនពិត ពួកបុរស ឈ្មោះថា មិនធ្លាប់ក្លាយភេទជាស្រី ឬពួកស្រីមិនធ្លាប់ក្លាយភេទជាប្រុស មិនមាន ។ ព្រោះថា ពួកបុរសប្រព្រឹត្តកន្លងក្នុងកិរិយាទាំងឡាយរបស់ជនដទៃ ធ្វើកាលកិរិយាហើយ ឆេះក្នុងនរកអស់សែនឆ្នាំជាច្រើន កាលត្រឡប់មកកាន់ជាតិជាមនុស្ស រមែងដល់នូវភាវៈជាស្រីអស់រយអត្តភាព សូម្បីព្រះអានន្ទត្ថេរ ដែលជាអរិយសាវក មានបារមីបំពេញមកហើយរាប់សែនកប្ប អន្ទោលទៅក្នុងសង្សារ ក្នុងអត្តភាពមួយ បានកើតក្នុងត្រកូលជាងមាសធ្វើបរទារកម្ម ឆេះក្នុងនរកហើយ ដោយផលកម្មដ៏សេសបានត្រឡប់មកជាស្រីបាទបរិចារិកានៃបុរសអស់ ១៤ អត្តភាព ដល់នូវការដកពូជ គឺត្រូវគេក្រៀវអស់ ៧ អត្តភាព ។ ចំណែកស្រីទាំងឡាយ ធ្វើបុណ្យទាំងឡាយមានទានជាដើម នឿយណាយក្នុងភាពជាស្ត្រី ក៏តាំងចិត្តថា បុណ្យរបស់ខ្ញុំនេះចូរប្រព្រឹត្តទៅ ដើម្បីត្រឡប់បានជាអត្តភាពជាបុរស ធ្វើកាលកិរិយាហើយរមែងត្រឡប់បានអត្តភាពជាបុរស ។ ពួកស្រីដែលមានប្តីដូចទេវតា ត្រឡប់បានអត្តភាពជាបុរស ដោយអំណាចនៃការប្រតិបត្តិក្នុងស្វាមីដូចគ្នា ។ ចំណែកកូនសេដ្ឋីនេះ ញុំាងចិត្តឲ្យកើតឡើងក្នុងព្រះថេរៈដោយមិនមែនឧបាយ ក៏ត្រឡប់ បានភាវៈជាស្រី ក្នុងអត្តភាពនេះ មួយរំពេច ។

គភ៌បានតាំងក្នុងផ្ទៃរបស់នាង ព្រោះអាស្រ័យការនៅរួមជាមួយបុរស កូនសេដ្ឋីក្នុងនគរតក្កសិលា ។ ដោយកាលកន្លងទៅ ១០ ខែ នាងបានបុត្រ ក្នុងកាលដែលបុត្ររបស់នាងដើរបាន ក៏បានបុត្រមួយទៀត ដោយអាការយ៉ាង នេះ ទើបបុត្ររបស់នាងមាន ៤ នាក់ គឺបុត្រដែលនៅក្នុងផ្ទៃ ២ នាក់ បុត្រ ដែលកើតព្រោះអាស្រ័យខ្លួនកាលនៅជាបុរស ក្នុងសោរេយ្យនគរ ២ នាក់ ។

ក្នុងកាលនោះ កូនប្រុសសេដ្ឋីដែលជាសម្លាញ់របស់នាង ចេញអំពី សោរេយ្យនគរ ទៅកាន់ក្រុងតក្កសិលាដោយរទេះ ៥០០ អង្គុយលើយានតូច ដែលមានសេចក្តីសុខ ចូលទៅកាន់ព្រះនគរ ។ ខណៈនោះ នាងបើកបង្អួច លើប្រាសាទជាន់លើ ឈរមើលវាំងផ្លូវ ឃើញសម្លាញ់នោះ ចាំបានយ៉ាង ច្បាស់ ទើបបញ្ជូនស្រីបម្រើ ឲ្យទៅអញ្ជើញសេដ្ឋីបុត្រនោះមកហើយ ឲ្យអង្គុយ លើទីដែលមានតម្លៃច្រើន បានធ្វើសក្ការៈ និងសេចក្តីរាប់អានយ៉ាងធំ ។ គ្រា នោះ សម្លាញ់នោះពោលនឹងនាងថា នែនាង ក្នុងកាលមុនអំពីនេះ ខ្ញុំមិនធ្លាប់ ឃើញនាង ។ កាលបើដូច្នេះ ហេតុអ្វី ទើបបានជានាងធ្វើសក្ការៈដ៏ធំដល់ខ្ញុំ នាងស្គាល់ខ្ញុំឬ នាងពោលថា ខ្ញុំស្គាល់ អ្នកជាអ្នកស្រុកសោរេយ្យនគរ មិនមែនឬ សេដ្ឋីបុត្រពោលថា នែនាង ពិតមែនហើយ ។

នាងបានសួរដល់សេចក្តីសុខសប្បាយ របស់មាតាបិតា របស់ភរិយា មួយអន្លើដោយកូនប្រុសទាំង ២ សម្លាញ់ក្រៅអំពីនេះឆ្លើយថា អើនាង ជន ទាំងនោះសុខសប្បាយ ហើយសួរថា នែនាង នាងស្គាល់ជនទាំងនោះឬ នាង ពោលថា អើអ្នក ខ្ញុំស្គាល់ កូនប្រុសរបស់លោកទាំងនោះមានម្នាក់ តើគាត់

ទៅណា សេដ្ឋីបុត្រពោលថា នែនាង នាងកុំសួរដល់គេឡើយ ខ្ញុំនិងគេ ថ្ងៃមួយ បានអង្គុយក្នុងយានតូចយ៉ាងមានសេចក្តីសុខ ចេញទៅដើម្បីងូតទឹក មិនជ្រាបទីទៅរបស់គេឡើយ កាលក្រឡេកមើលខាងនោះ ខាងនេះក៏មិនឃើញ ទើបប្រាប់ដល់ឪពុកម្តាយរបស់គេ ឪពុកម្តាយទាំងពីររបស់គេ បានទ្រហោយំរៀបរាប់ ធ្វើកិច្ចដែលគួរធ្វើដល់បុគ្គលដែលស្លាប់ទៅហើយ ។ នាងពោលថា នែអ្នក ខ្ញុំ គឺសេដ្ឋីបុត្រនោះឯង សម្លាញ់នោះពោលថា នែនាង ចូរចៀសចេញទៅ នាងពោលអ្វី សម្លាញ់របស់ខ្ញុំស្អាតដូចជាកូនទេវតា គេជាប្រុស នាងពោលថា ណ្ហើយចុះអ្នក ខ្ញុំ គឺសេដ្ឋីបុត្រនោះ ។

ខណៈនោះ ទើបសម្លាញ់នោះសួរនាងថា រឿងនេះដូចម្តេច នាងពោលថា ថ្ងៃនោះ អ្នកឃើញព្រះមហាកច្ចាយនត្ថេរដែរឬទេ សម្លាញ់នោះពោលថា ខ្ញុំឃើញ នាងពោលថា ខ្ញុំឃើញព្រះមហាកច្ចាយនៈហើយ បានគិតថា ស្អាតពិតហ្ន៎ ព្រះថេរៈរូបនេះ គួរជាភរិយារបស់អញ ឬថា ពណ៌នៃសរីរៈរបស់ភរិយាអញ គប្បីដូចពណ៌នៃសរីរៈរបស់ព្រះថេរៈនោះ ក្នុងខណៈខ្ញុំគិតហើយនោះឯង ភេទប្រុសបានអន្តរធានទៅ ភេទស្រីបានប្រាកដឡើង កាលបើដូច្នេះ ខ្ញុំមិនអាចប្រាប់ដល់អ្នកណាបាន ដោយការខ្មាស ទើបគេចទៅអំពីទីនោះ មកក្នុងទីនេះ សម្លាញ់នោះពោលថា ឱហ្ន៎ អ្នកធ្វើកម្មធ្ងន់ហើយ ហេតុអ្វីទើបអ្នកមិនដល់ខ្ញុំ អើ អ្នកបានឲ្យព្រះថេរៈអត់ទោសហើយឬ នាងពោលថា មិនទាន់ឲ្យលោកអត់ទោសឡើយ អ្នកដឹងឬ ព្រះថេរៈនៅក្នុងទីណា សម្លាញ់នោះពោលថា អាស្រ័យនគរនេះឯង នាងពោលថា បើលោកត្រាច់បិណ្ឌបាត

គប្បីមកក្នុងទីនេះសោត ខ្ញុំគប្បីប្រគេនភិក្ខាហារដល់ព្រះថេរះរបស់ខ្ញុំ សម្លាញ់នោះពោលថា បើដូច្នោះ សូមនាងប្រញាប់ធ្វើសក្ការៈ ខ្ញុំនឹងញុំាងលោកម្ចាស់ឲ្យអត់ទោសឲ្យ ។

សេដ្ឋីបុត្រទៅកាន់លំនៅព្រះថេរៈ ថ្វាយបង្គំហើយ អង្គុយក្នុងទីសមគួរ នាចំណែកម្ខាង និមន្តថា បពិត្រលោកម្ចាស់ ស្អែកនេះសូមនិមន្តលោកម្ចាស់ទទួលភិក្ខារបស់ខ្ញុំ ព្រះថេរៈពោលថា នែសេដ្ឋីបុត្រ ក្រែងអ្នកជាភ្ញៀវមិនមែនឬ សេដ្ឋីបុត្រពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់កុំសួរភាពដែលខ្ញុំជាភ្ញៀវឡើយ ស្អែកនេះ សូមនិមន្តលោកម្ចាស់ទទួលភិក្ខារបស់ខ្ញុំចុះ ។

ព្រះថេរៈទទួលនិមន្តហើយ ។ សក្ការៈជាច្រើន គេបានត្រៀមរៀបចំក្នុងផ្ទះដើម្បីព្រះថេរៈ ។ ស្អែកឡើង ព្រះថេរៈបានទៅកាន់ទ្វារផ្ទះ ។ ខណៈនោះ សេដ្ឋីបុត្រនិមន្តលោកឲ្យគង់ហើយ អង្គាសដោយអាហារដ៏ប្រណីត នាំស្រីនោះមកហើយ ឲ្យក្រាបចុះទៀបបាទារបស់ព្រះថេរៈ ពិតថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់អត់ទោសដល់ស្រី ជាសម្លាញ់របស់ខ្ញុំផង ព្រះថេរៈពោលថា តើមានរឿងអ្វី សេដ្ឋីបុត្រពោលថា បពិត្រលោកម្ចាស់ ក្នុងកាលមុន បុគ្គលនេះជាសម្លាញ់ ជាទីស្រឡាញ់របស់ខ្ញុំ ជួបលោកម្ចាស់ហើយ បានគិតយ៉ាងនេះ យ៉ាងនេះ កាលបើដូច្នោះ ភេទប្រុសរបស់គេក៏អន្តរធានទៅ ភេទស្រីបានប្រាកដហើយ សូមលោកម្ចាស់អត់ទោសចុះ ។

ព្រះថេរៈពោលថា បើយ៉ាងនោះ ចូរអ្នកក្រោកឡើង អាត្មាអត់ទោសឲ្យដល់អ្នក ។ គ្រាន់តែព្រះថេរៈហាមាត់ថា អាត្មាអត់ទោសប៉ុណ្ណោះ ភេទ

ស្រីបានវិនាសទៅ ភេទប្រុសបានប្រាកដហើយ កាលភេទប្រុសបានត្រឡប់ប្រាកដឡើងប៉ុណ្ណោះ សេដ្ឋីបុត្រក្នុងក្រុងតក្កសិលាបានពោលនឹងសេដ្ឋីបុត្រនោះថា សម្លាញ់អ្នករួមទុក្ខ កូនពីរនាក់នេះ ជាកូនរបស់យើងទាំងពីរពិត ព្រោះជាអ្នកនៅក្នុងផ្ទៃរបស់អ្នក និងព្រោះជាអ្នកអាស្រ័យខ្ញុំកើត យើងទាំងពីរនឹងនៅក្នុងនគរនេះឯង អ្នកកុំក្រវល់ក្រវាយឡើយ ។

សោរេយ្យសេដ្ឋីបុត្រពោលថា អ្នករួមទុក្ខ ខ្ញុំដល់នូវអាការចម្លែក គឺកាលពីដើម ខ្ញុំជាបុរស ហើយដល់នូវភាពជាស្រី ហើយត្រឡប់ជាប្រុសបានទៀត ដោយអត្តភាពមួយប៉ុណ្ណោះ កាលមុនបុត្រពីរនាក់អាស្រ័យខ្ញុំកើតឡើង ឥឡូវនេះ បុត្រពីរនាក់ ប្រសូតចេញអំពីផ្ទៃខ្ញុំ អ្នកកុំសម្គាល់ថា ខ្ញុំនោះដល់នូវអាការចម្លែកដោយអត្តភាពមួយ នឹងមិននៅក្នុងផ្ទះតទៅទៀត ខ្ញុំនឹងបួសក្នុងសម្នាក់នៃលោកម្ចាស់របស់យើង កុមារពីរនាក់នេះ ចូរជាភារៈរបស់អ្នក អ្នកកុំបោះបង់ក្មេងទាំងពីរនេះ ដូច្នេះហើយ ថើបកូនទាំងពីរ អង្អែលខ្នងហើយប្រគល់ដល់ឪពុក ចេញទៅបួសក្នុងសម្នាក់ព្រះថេរៈ ចំណែកព្រះថេរៈឲ្យលោកបព្វជ្ជាឧបសម្បទាស្រេចហើយ នាំត្រាច់ចារិកទៅ បានដល់ក្រុងសាវត្ថីដោយលំដាប់ ។ ឈ្មោះរបស់លោកបានប្រាកដថា សោរេយ្យត្ថេរ ។

អ្នកជនបទដឹងរឿងនោះហើយ នាំគ្នាភ្ញាក់ផ្អើល ចូលទៅសួរថា បានឮថា រឿងនេះពិតយ៉ាងនោះឬ សោរេយ្យត្ថេរពោលថា អាវុសោ រឿងនេះពិតហើយ ។ អ្នកជនបទពោលថា បពិត្រលោកម្ចាស់ ហេតុនេះមានពិតឬ បានឮថា កូនពីរនាក់កើតក្នុងផ្ទៃរបស់លោកម្ចាស់ កូនពីរនាក់អាស្រ័យលោកម្ចាស់

កើត បណ្ដាកូនពីរពួកនោះ លោកម្ចាស់មានសេចក្ដីស្រឡាញ់ច្រើនក្នុងកូនពួកណា សោរេយ្យត្ថេរពោលថា អាវុសោ អាត្មាស្រឡាញ់កូនដែលនៅក្នុងផ្ទៃ ។

ជនដែលមកហើយ ក៏សួរយ៉ាងនោះឯងរឿយៗ ទៅ ។ ព្រះថេរៈប្រាប់ហើយដូចមុនថា មានសេចក្ដីស្រឡាញ់ក្នុងកូនដែលនៅក្នុងផ្ទៃនោះឯងច្រើន ។ កាលលោកមានសេចក្ដីរំខាន ទើបអង្គុយមួយអង្គឯង ។ លោកចូលដល់ភាពជាបុគ្គលម្នាក់ឯងប៉ុណ្ណោះ ផ្ដើមចម្រើនទូវការអស់ទៅ និងសូន្យទៅ ក្នុងអត្តភាព សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយហើយ ។

បន្ទាប់មក ពួកជនដែលមកហើយសួរលោកថា បពិត្រលោកម្ចាស់ បានឮថា ហេតុឈ្មោះនេះមានហើយពិតឬ ព្រះសោរេយ្យៈពោលថា អើអាវុសោ ពិតហើយ ពួកជនពោលថា លោកម្ចាស់មានសេចក្ដីស្នេហាច្រើនក្នុងកូនពួកណា ព្រះសោរេយ្យៈពោលថា ឈ្មោះថា ការស្រឡាញ់ក្នុងកូនណាម្នាក់របស់អាត្មា មិនមាន ។

ភិក្ខុទាំងឡាយក្រាបទូលព្រះសាស្ដាថា បពិត្រព្រះអង្គ ភិក្ខុរូបនេះពោលអ្វីមិនពិត ក្នុងថ្ងៃមុនៗ ពោលថា មានសេចក្ដីស្នេហាក្នុងកូនដែលនៅក្នុងផ្ទៃច្រើនជាង ឥឡូវនេះ ពោលថា ការស្រឡាញ់ក្នុងកូនណាម្នាក់របស់អាត្មាមិនមាន រមែងព្យាករអរហត្តផល ។

ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុត្ររបស់តថាគតមិនមែនព្យាករអរហត្តផលទេ ព្រោះថា តាំងអំពីកាលដែលបុត្ររបស់តថាគតឃើញមគ្គទស្សនៈដោយចិត្តដែលតាំងទុកដោយប្រពៃហើយ សេចក្ដីស្នេហាក្នុងបុត្រ

ណាម្នាក់ មិនកើតឡើយ ចិត្តប៉ុណ្ណោះដែលប្រព្រឹត្តទៅខាងក្នុងរបស់សត្វទាំង នេះ រមែងឲ្យសម្បត្តិដែលមាតាបិតាមិនអាចធ្វើឲ្យបាន ដូច្នេះហើយ ទើប ត្រាស់ព្រះគាថានេះថា

**ន តំ មាតា បិតា កយិរា អញ្ញេ វាបិ ច ញាតកា**
**សម្មាបណិហិតំ ចិត្តំ សេយ្យសោ នំ តតោ ករេ ។**

មាតាបិតា មិនគប្បីធ្វើហេតុនោះបាន ឬជនទាំងឡាយដទៃជា ញាតិ មិនគប្បីធ្វើនូវហេតុនោះបាន ចំណែកខាងចិត្តដែល បុគ្គលតាំងទុកត្រូវហើយ រមែងធ្វើបុគ្គលនោះ ឲ្យប្រសើរជាង ហេតុនោះបាន ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ន តំ** សេចក្តីថា មាតាបិតា និងញាតិដទៃ មិនធ្វើហេតុនោះបានឡើយ ។

បទថា **សម្មាបណិហិតំ** គឺឈ្មោះថាតាំងទុកប្រពៃហើយ ព្រោះភាពជា ធម្មជាតតាំងទុកប្រពៃក្នុងកុសលកម្មបថ ១០ ។

បាទព្រះគាថាថា **សេយ្យសោ នំ តតោ ករេ** សេចក្តីថា គប្បីធ្វើ គឺរមែងធ្វើបុគ្គលឲ្យប្រសើរជាង គឺក្រៃលែងជាង បានដល់ ឲ្យឧត្តមជាង ហេតុនោះ ។

ពិតណាស់ មាតាបិតាកាលនឹងឲ្យទ្រព្យដល់បុត្រទាំងឡាយ រមែងអាច ឲ្យទ្រព្យសម្រាប់មិនចាំបាច់ធ្វើការងារ ហើយចិញ្ចឹមជីវិតដោយសប្បាយ ក្នុង

អត្តភាពមួយប៉ុណ្ណោះ សូម្បីមាតាបិតារបស់នាងវិសាខា មានទ្រព្យច្រើន មានភោគៈច្រើន បានឲ្យទ្រព្យសម្រាប់ចិញ្ចឹមជីវិតដោយសប្បាយដល់នាង ក្នុងអត្តភាពមួយប៉ុណ្ណោះ ចម្ងតាមាតាបិតាដែលអាចឲ្យសិរី គឺភាពជាស្តេចចក្រពត្តិក្នុងទ្វីបទាំង ៤ រមែងមិនមានដល់កូនទាំងឡាយ នឹងពោលទៅថ្វីដល់ទិព្វសម្បត្តិ ឬបឋមជ្ឈានសម្បត្តិជាដើមនោះ ក្នុងការឲ្យលោកុត្តរសម្បត្តិ មិនចាំបាច់ពោលដល់ឡើយ ។ តែចិត្តតម្កល់ដោយប្រពៃហើយ អាចឲ្យសម្បត្តិទាំងអស់បាន ព្រោះដូច្នោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា **សេយ្យសោ នំ តតោ ករេ ។**

ក្នុងកាលចប់ទេសនា មហាជនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ ទេសនាបានជាប្រយោជន៍ដល់មហាជនដូច្នេះឯង ៕

**រឿងព្រះសោរេយ្យត្ថេរ ចប់**

**ចិត្តវគ្គទី ៣ ចប់**

# សុត្តន្តបិដក

## ធម្មបទគាថា បុប្ផវគ្គទី ៤

[ ១៤ ] អ្នកណានឹងដឹងច្បាស់នូវផែនដី គឺអត្តភាពនេះ និងយមលោក គឺអបាយភូមិ ៤ និងមនុស្សលោកនេះ ព្រមទាំងទេវលោកបាន អ្នកណានឹងជ្រើសរើសនូវចំណែកនៃធម៌ ដែលព្រះតថាគតសម្ដែងប្រពៃហើយ ដូចមាលាការដែលឈ្លាសវៃ ជ្រើសរើសនូវផ្កា ដូច្នោះឯង ។

ព្រះសេក្ខបុគ្គលនឹងដឹងច្បាស់នូវផែនដី គឺអត្តភាពនេះ និងយមលោក គឺអបាយភូមិ ៤ និងមនុស្សលោកនេះ ព្រមទាំងទេវលោកបាន ព្រះសេក្ខ-បុគ្គល នឹងជ្រើសរើសនូវចំណែកនៃធម៌ ដែលព្រះតថាគតសម្ដែងប្រពៃហើយ ដូចមាលាការដែលឈ្លាសវៃ ជ្រើសរើសនូវផ្កា ដូច្នោះ ។

ភិក្ខុ កាលដឹងច្បាស់នូវកាយនេះថា ដូចជាដុំពពុះទឹក ដឹងច្បាស់នូវកាយនេះថា មានសភាពដូចព្រេញថ្ងៃ គប្បីកាត់នូវផ្កាជាប្រធាននៃមារ គឺវដ្តៈ ៣ ទៅកាន់ស្ថានជាទីមិនឃើញនៃមច្ចុរាជ ។

មច្ចុ គឺសេចក្ដីស្លាប់ តែងកៀរយកទៅនូវនរជន អ្នកមានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗ កំពុងជ្រើសរើសនូវផ្កា គឺកាមគុណ ៥ នោះឯង ដូចទឹកជំនន់ធំ ដែលកួចយកអ្នកស្រុកកំពុងដេកលក់ទៅ ដូច្នោះឯង ។

អ្នកធ្វើទីបំផុត គឺមរណៈ តែងក្រុងសត្វ ដែលមានចិត្តជាប់ជំពាក់ ក្នុងអារម្មណ៍ផ្សេងៗ កំពុងជ្រើសរើសនូវផ្កា គឺកាមគុណ ៥ មិនឆ្អែតឆ្អន់ក្នុងកាមទាំងឡាយនោះឯង ឲ្យនៅក្នុងអំណាចរបស់ខ្លួន ។

ភមរជាតិ មិនធ្វើផ្កាឈើ ដែលមានពណ៌ និងក្លិនឲ្យវិនាសទេ ក្រេប យកតែរសហើរទៅ យ៉ាងណាមិញ អ្នកប្រាជ្ញ គប្បីត្រាច់ទៅក្នុងស្រុក ក៏ យ៉ាងនោះឯង ។

ពាក្យចាក់ដោតទាំងឡាយរបស់ជនដទៃ បុគ្គលមិនគួរធ្វើទុកក្នុងចិត្តទេ កិច្ចដែលធ្វើហើយ នឹងមិនទាន់ធ្វើហើយរបស់ជនដទៃ ( ដែលមិនមែនជាមុខ ការរបស់ខ្លួន ) បុគ្គលមិនគួរពិនិត្យមើលទេ បុគ្គលគួរពិនិត្យពិចារណា តែ កិច្ចការទាំងឡាយដែលធ្វើហើយ និងមិនទាន់ធ្វើហើយ របស់ខ្លួនតែម្យ៉ាង ។

ផ្កាឈើមានទ្រង់ទ្រាយល្អ មានពណ៌ ( ល្អ ) តែគ្មានក្លិន ( ប្រអូប ) ( រមែងមិនក្រអូបដល់អ្នកដែលទ្រទ្រង់ ) ដូចម្ដេចមិញ វាចាជាសុភាសិត រមែងគ្មានផលដល់អ្នកដែលមិនធ្វើតាមដូច្នោះ ផ្កាឈើដែលមានទ្រង់ទ្រាយល្អ មានពណ៌ មានក្លិន ( រមែងក្រអូបដល់អ្នកដែលទ្រទ្រង់ ) ដូចម្ដេចមិញ វាចា ជាសុភាសិត រមែងមានផលដល់អ្នកដែលធ្វើតាមដោយគោរព ដូច្នោះឯង ។

មាលាការ បេះធ្វើសំណុំនៃកម្រងផ្កាអំពីគំនរនៃផ្កា ( ផ្សេងៗ គ្នា ) ឲ្យ ច្រើនបាន យ៉ាងណាមិញ កុសលដែលសត្វកើតមកហើយ គួរធ្វើឲ្យច្រើន យ៉ាងនោះ ។

ក្លិនផ្កាឈើ ផ្សាយទៅច្រាសខ្យល់មិនបាន ក្លិនខ្លឹមចន្ទន៍ក្តី ក្លិនខ្លឹម ក្រស្នាក្តី ក្លិនផ្កាម្លិះរួតក្តី ក៏ផ្សាយទៅច្រាសខ្យល់មិនបាន ចំណែកក្លិនរបស់ សប្បុរសទាំងឡាយ រមែងផ្សាយទៅច្រាសខ្យល់បាន ព្រោះសប្បុរស រមែង ផ្សាយទៅបានគ្រប់ទិស ។ ក្លិននៃសីល ជាគុណជាតិប្រសើរបំផុតជាងគន្ធជាតិ

ទាំងនេះ គឺខ្លឹមចន្ទន៍ ខ្លឹមក្រស្នា ផ្កាឧប្បល ផ្កាម្លិះលា ។

ក្លិនក្រស្នា និងក្លិនចន្ទន៍ណា ក្លិននេះ ក្រអូបមានប្រមាណតិចទេ ចំណែកក្លិននៃបុគ្គលមានសីលទាំងឡាយណា ក្លិននោះ ទើបក្រអូបលើស លុបផ្សាយទៅក្នុងទេវលោក និងមនុស្សលោកបាន ។

មារាធិរាជ ( ទុកជាខំស្វែងរក ) ក៏មិនជួបនូវផ្លូវ របស់លោកអ្នក មានសីលបរិបូណ៌ អ្នកនៅដោយសេចក្ដីមិនប្រមាទ អ្នករួចស្រឡះ ( ចាក ធម៌ជាគ្រឿងសៅហ្មង ) ព្រោះដឹងច្បាស់តាមហេតុ ។

ផ្កាឈូក ទុកជាកើតក្នុងគំនរសំរាម ដែលគេចាក់ចោលក្បែរផ្លូវធំនោះ ក៏គង់មានក្លិនក្រអូប ជាទីរីករាយនៃចិត្តបាន ដូចម្ដេចមិញ បណ្ដាជន ដែល ដូចជាគំនរសំរាម សាវករបស់ព្រះសម្មាសម្ពុទ្ធ រមែងរុងរឿងកន្លងផុតបុថុជ្ជន ទាំងឡាយ ដែលល្ងិតល្ងង់ ដោយប្រាជ្ញា ( របស់ខ្លួន ) ដូច្នោះឯង ។

**បុប្ផវគ្គទី ៤ ចប់**

# អដ្ឋកថា
# ធម្មបទដ្ឋកថា ខុទ្ទកនិកាយ គាថាធម្មបទ

## បុប្ផវគ្គ
## រឿង ភិក្ខុ ៥០០ ដែលខ្វល់ខ្វាយក្នុងបឋវីកថា
### លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធភិក្ខុ ៥០០ រូប ដែលខ្វល់ខ្វាយក្នុងបឋវីកថា ត្រាស់ធម្មទេសនានេះថា **កោ ឥមំ បឋវឹ វិជេស្សតិ** ជាដើម ។

បានឮមកថា ភិក្ខុទាំងនោះត្រាច់ចារិកទៅក្នុងជនបទ ជាមួយព្រះសាស្ដា មកដល់វត្តជេតពនហើយ អង្គុយនៅក្នុងរោងឆាន់ក្នុងពេលល្ងាច និយាយដល់រឿងផែនដី ក្នុងទីដែលខ្លួនទៅហើយថា ក្នុងទីដែលទៅក្នុងស្រុកឈ្មោះនោះ អំពីស្រុកនោះ ដីរាបស្មើ មិនរាបស្មើ មានភក់ច្រើន មានគ្រោះច្រើន មានដីខ្មៅ មានដីក្រហម ។

ព្រះសាស្ដាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងផែនដីក្នុងទីដែលខ្ញុំព្រះអង្គទៅហើយ ដូច្នេះហើយ

ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នុ៎ះ ឈ្មោះថា ផែនដីខាងក្រៅ ការដែលពួកអ្នកធ្វើបរិកម្មក្នុងផែនដីខាងក្នុង ទើបគួរ ដូច្នេះហើយ ទ្រង់បានភាសិត ២ គាថានេះថា

**កោ ឥមំ បឋវឹ វិជេស្សតិ យមលោកញ្ច ឥមំ សទេវកំ**
**កោ ធម្មបទំ សុទេសិតំ កុសលោ បុប្ផមិវ បចេស្សតិ ។**
**សេក្ខោ បឋវឹ វិជេស្សតិ យមលោកញ្ច ឥមំ សទេវកំ**
**សេក្ខោ ធម្មបទំ សុទេសិតំ កុសលោ បុប្ផមិវ បចេស្សតិ ។**

អ្នកណា នឹងដឹងច្បាស់នូវផែនដី គឺអត្តភាពនេះ និងយមលោក គឺអបាយភូមិ ៤ និងមនុស្សលោកនេះ ព្រមទាំងទេវលោកបាន អ្នកណានឹងជ្រើសរើសនូវចំណែកនៃធម៌ ដែលព្រះតថាគតសម្តែងប្រពៃហើយ ដូចមាលាការដែលឈ្លាសវៃ ជ្រើសរើសនូវផ្កា ដូច្នោះឯង ។ ព្រះសេក្ខបុគ្គលនឹងដឹងច្បាស់នូវផែនដី គឺអត្តភាពនេះ និងយមលោក គឺអបាយភូមិ ៤ និងមនុស្សលោកនេះ ព្រមទាំងទេវលោកបាន ព្រះសេក្ខបុគ្គលនឹងជ្រើសរើសនូវចំណែកនៃធម៌ ដែលព្រះតថាគតសម្តែងប្រពៃហើយ ដូចមាលាការដែលឈ្លាសវៃ ជ្រើសរើសនូវផ្កា ដូច្នោះ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **កោ ឥមំ** សេចក្តីថា បុគ្គលណានឹងដឹងច្បាស់នូវផែនដីនេះ ពោល គឺអត្តភាព ។

បទថា **វិជេស្សតិ** សេចក្ដីថា នឹងដឹងច្បាស់ គឺចាក់ធ្លុះ បានដល់ ធ្វើឲ្យជាក់ច្បាស់ដោយញាណរបស់ខ្លួន ។

បទថា **យមលោកញ្ច** បានដល់ អបាយលោក ៤ យ៉ាងផង ។

ពីរបទថា **ឥមំ សទេវកំ** សេចក្ដីថា អ្នកណានឹងដឹងច្បាស់ គឺនឹងជ្រាបច្បាស់ បានដល់ចាក់ធ្លុះ ធ្វើឲ្យជាក់ច្បាស់នូវមនុស្សលោកនេះផង មួយអន្លើដោយទេវលោកផង ព្រះសាស្ដារមែងត្រាស់សួរដូច្នេះ ។

បាទព្រះគាថាថា **កោ ធម្មបទំ សុទេសិតំ** សេចក្ដីថា បុគ្គលណានឹងជ្រើសរើស បានដល់ពិចារណាឃើញ ចាក់ធ្លុះ ធ្វើឲ្យជាក់ច្បាស់នូវបទធម៌ពោល គឺពោធិបក្ខិយធម៌ ៣៧ ដែលឈ្មោះថាតថាគតសម្ដែងល្អហើយ ព្រោះភាពជាធម៌ដែលតថាគតពោលហើយតាមសេចក្ដីពិត ដូចនាយមាលាការអ្នកឈ្លាសជ្រើសរើសនូវផ្កា ដូច្នោះ ។

បទថា **សេក្ខោ** ជាដើម សេចក្ដីថា ព្រះអរិយបុគ្គល ៧ ពួក តាំងអំពីលោកដែលតាំងនៅក្នុងសោតាបត្តិមគ្គ រហូតដល់លោកដែលតាំងនៅក្នុងអរហត្តមគ្គ ឈ្មោះថា ព្រះសេក្ខៈ ព្រោះនៅសិក្សាសិក្ខាទាំង ៣ នេះ គឺអធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា ប្រាទបេញនូវឆន្ទរាគៈ ចាកអត្តភាពនោះដោយអរហត្តមគ្គ ឈ្មោះថា ដឹងច្បាស់ គឺនឹងជ្រាបច្បាស់ បានដល់ ចាក់ធ្លុះ ធ្វើឲ្យជាក់ច្បាស់នូវផែនដី ពោល គឺអត្តភាពនេះ ។

បទថា **យមលោកញ្ច** ជាដើម សេចក្ដីថា ព្រះសេក្ខៈនោះឯង នឹងដឹងច្បាស់ គឺនឹងជ្រាបច្បាស់ បានដល់ចាក់ធ្លុះ ធ្វើឲ្យជាក់ច្បាស់នូវយមលោក មាន

ប្រការដែលពោលហើយយ៉ាងនោះ និងមនុស្សលោកនេះ ព្រមទាំងទេវលោកទាំងឡាយ ឈ្មោះថា ព្រមទាំងទេវលោក ។ លោកអ្នកដែលនៅសិក្សា ៧ ពួកនោះឯង ឈ្មោះថា សេក្ខៈ អធិប្បាយថា នាយមាលាការអ្នកឈ្លាស ចូលទៅកាន់សួនផ្កាហើយ រើរផ្កាដែលខ្ចី និងក្រពុំ ផ្កាដែលត្រូវសត្វចោះ ផ្កាក្រៀម និងផ្កាដែលមិនល្អចេញហើយ ជ្រើសយកចំពោះតែផ្កាដែលល្អដែលកើតល្អហើយ យ៉ាងណា ព្រះសេក្ខៈនឹងជ្រើសរើស គឺចម្រាញ់ បានដល់ ពិចារណាឃើញ ចាក់ធ្លុះ ធ្វើឲ្យជាក់ច្បាស់នូវបទនៃពោធិបក្ខិយធម៌នេះ ដែលតថាគតពោលល្អហើយ គឺសម្តែងល្អហើយ ដូច្នេះនោះឯង ។

ព្រះសាស្តា ទ្រង់ឆ្លើយបញ្ហាឯងនោះឯង ។ ក្នុងវេលាចប់ទេសនា ភិក្ខុ ៥០០ រូប សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយហើយ ។ ទេសនាមានប្រយោជន៍ដល់បរិស័ទ ដែលប្រជុំគ្នាដូច្នេះឯង ៕

**រឿង ភិក្ខុ ៥០០ ដែលខ្វល់ខ្វាយក្នុងបឋវីកថា ចប់**

# រឿង ព្រះថេរៈចម្រើនមរីចិកម្មដ្ឋាន

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធភិក្ខុមួយអង្គដែលចម្រើនមរីចិកម្មដ្ឋាន ត្រាស់ព្រះធម្មទេសនានេះថា **ផេណូបមំ** ជាដើម ។

បានឮមកថា ព្រះថេរៈនោះរៀនកម្មដ្ឋាន ក្នុងសម្នាក់ព្រះសាស្តាហើយ

គិតថា អញនឹងធ្វើសមណធម៌ ដូច្នេះហើយ ចូលទៅកាន់ព្រៃ ព្យាយាមហើយព្យាយាមទៀត ក៏មិនអាចសម្រេចអរហត្តបាន ទើបត្រឡប់មកកាន់សម្នាក់ព្រះសាស្ដា ដោយតាំងចិត្តថា នឹងទូលអារាធនាឲ្យទ្រង់ត្រាស់ប្រាប់ព្រះកម្មដ្ឋានឲ្យវិសេស ។ ឃើញថ្ងៃបណ្ដើរកូនក្នុងរវាងផ្លូវ ចម្រើនមរីចិកម្មដ្ឋានថា កម្ដៅថ្ងៃនេះ តាំងឡើងហើយក្នុងរដូវក្ដៅ រមែងប្រាកដដល់បុគ្គលទាំងឡាយ ដែលឈរក្នុងទីឆ្ងាយ ដូចមានរូបរាង តែមិនប្រាកដដល់បុគ្គលដែលមកកាន់ទីជិតយ៉ាងណា អត្តភាពនេះក៏មានការប្រៀបធៀបយ៉ាងនោះ ព្រោះអត្ថថា កើតឡើងនិងសូន្យទៅ និមន្តមកហើយ ហត់នឿយក្នុងរវាងផ្លូវ ស្រង់ទឹកក្នុងស្ទឹងអចិរវតីគង់ត្រង់ម្ចប់ឈើក្បែរឆ្នេរស្ទឹង ដែលមានក្រខ្សែហូរខ្លួលខ្លាញ់មួយកន្លែង ឃើញពពុះទឹកធំ តាំងឡើងដោយកម្លាំងនៃទឹកប៉ះខ្ទប់គ្នាហើយបែកទៅ បានកាន់យកជាអារម្មណ៍ថា សូម្បីអត្តភាពនេះក៏មានរូបរាងយ៉ាងនោះដូចគ្នា ព្រោះអត្ថថាកើតឡើងហើយក៏បែកទៅ ។

ព្រះសាស្ដា គង់នៅត្រង់ព្រះគន្ធកុដិនោះឯង ទតឃើញព្រះថេរៈនោះហើយ ទើបត្រាស់ថា ម្នាលភិក្ខុ យ៉ាងនោះឯង អត្តភាពនេះ មានរូបយ៉ាងនោះឯង មានការកើតឡើង និងបែកធ្លាយទៅជាសភាវៈពិត ដូចដុំពពុះទឹក និងថ្ងៃបណ្ដើរកូន ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**ផេណូបមំ កាយមិមំ វិទិត្វា មរីចិធម្មំ អភិសម្ពុធានោ**
**ឆេត្វាន មារស្ស បបុប្ផកានិ អទស្សនំ មច្ចុរាជស្ស គច្ឆេ ។**

ភិក្ខុកាលដឹងច្បាស់នូវកាយនេះថា ដូចជាដុំពពុះទឹក ដឹងច្បាស់នូវ

*កាយនេះថា មានសភាពដូចព្រេញថ្ងៃ គប្បីកាត់នូវផ្កាជាប្រធាន នៃមារ គឺវដ្តៈ ៣ ទៅកាន់ស្ថានជាទីដែលមិនឃើញនៃមច្ចុរាជ ។*

# សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ បទថា* **ផេណូបមំ** *សេចក្តីថា ដឹងច្បាស់នូវកាយនេះ គឺដែលរាប់ថា ជាទីប្រជុំនៃកោដ្ឋាសផ្សេងៗ មានសក់ជាដើម ។ ប្រៀបដូចដុំពពុះទឹក ព្រោះអត្ថថា មិនមានកម្លាំង មានកម្លាំងថោកថយ មិនតាំងនៅយូរ និងជារបស់មួយជួរខណៈ ។*

*បទថា* **មរីចិធម្មំ** *ជាដើម សេចក្តីថា ដឹងច្បាស់ គឺដឹង បានដល់ ជ្រាបថា សូម្បីកាយនេះ ឈ្មោះថា មានថ្ងៃបណ្តើរកូនជាសភាវៈ ព្រោះអត្ថថា ប្រព្រឹត្តទៅមួយជួរខណៈ និងប្រាកដតិចតួច ដូចថ្ងៃបណ្តើរកូន ឃើញហាក់ដូចមានរូបរាង និងជាហេតុចូលដល់ភាពជារបស់ដែលគួរកាន់យកបាន ដល់បុគ្គលទាំងឡាយ ដែលឈរនៅក្នុងទីឆ្ងាយ តែកាលបុគ្គលចូលទៅជិត រមែងប្រាកដជារបស់ទទេ ចូលដល់នូវភាពជារបស់កាន់យកមិនបាន ដូច្នោះ ។*

*ពីរបទថា* **មារស្ស បបុប្ផកានិ** *ជាដើម សេចក្តីថា ភិក្ខុដែលជាព្រះខីណាស្រព កាត់នូវវដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ពោល គឺកម្រងផ្ការបស់មារចេញបានដោយអរិយមគ្គហើយ គប្បីបានដល់នូវទីដែលមិនឃើញ គឺដែលមិនឃើញ គឺដែលមិនជាវិស័យនៃមច្ចុរាជ បានដល់ អមតមហានិព្វាន ។*

*ក្នុងកាលចប់គាថា ព្រះថេរៈសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយហើយ សរសើរ ថ្វាយបង្គំព្រះសរីរៈរបស់ព្រះសាស្តា ដែលមាន*

ពណ៌ដូចមាស មកហើយ ដូច្នេះឯង ។l៙ঙ

## រឿង ព្រះថេរៈចម្រើនមរីចិកម្មដ្ឋាន ចប់

# រឿង ព្រះបាទវិឌូឌភៈ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងនគរសាវត្ថី ទ្រង់ប្រារព្ធព្រះបាទវិឌូឌភៈ មួយអន្លើដោយបរិស័ទ ដែលត្រូវទឹកជំនន់កួចឲ្យសោយទិវង្គតហើយ ត្រាស់ព្រះធម្មទេសនានេះថា **បុប្ផានិ ហេវ បចិនន្តំ** ជាដើម ។ អនុបព្វីកថាក្នុងរឿងនោះ មានដូចតទៅនេះ

កុមារ ៣ អង្គ គឺព្រះរាជឱរសរបស់ព្រះបាទមហាកោសល ក្នុងនគរសាវត្ថី ព្រះនាមបសេនទិកុមារ ១ កុមាររបស់ស្តេចលិច្ឆវី ក្នុងនគរវេសាលី ព្រះនាមមហាលិ ១ ឱរសរបស់ព្រះបាទមល្ល: ក្នុងនគរកុសិនារា ព្រះនាមពន្ធុល: ១ យាងទៅនគរតក្កសិលា ដើម្បីរៀនសិប្បៈក្នុងសម្នាក់អាចារ្យទិសាបាមោក្ខ មកជួបគ្នាត្រង់សាលាក្រៅព្រះនគរ ក៏សួរដល់ហេតុដែលមកត្រកូល និងព្រះនាមនៃគ្នានិងគ្នាហើយ ក៏ធ្វើជាសម្លាញ់នឹងគ្នា រួមគ្នាចូលទៅរកអាចារ្យ មិនយូរប៉ុន្មានក៏រៀនសិប្បៈសម្រេច ទើបថ្វាយបង្គំលាអាចារ្យព្រមគ្នា យាងចេញអំពីនគរតក្កសិលា បានទៅលំនៅរៀងៗ ខ្លួន ។

បណ្ដាកុមារទាំង ៣ អង្គនោះ បសេនទិកុមារ ទ្រង់សម្ដែងសិប្បៈថ្វាយ

ព្រះជនក ព្រះជនកទ្រង់ជ្រះថ្លាហើយ ទើបអភិសេកក្នុងរាជសម្បត្តិ ។

មហាលិកុមារ ដើម្បីសម្តែងសិប្បៈ ដល់ស្តេចលិច្ឆវីទាំងឡាយ ទ្រង់សម្តែងដោយភាពឧស្សាហ៍ខ្លាំង ព្រះនេត្រក៏បែកទៅហើយ ។ ស្តេចលិច្ឆវីប្រឹក្សាគ្នាថា ឱហ្ន៎ អាចារ្យរបស់ពួកយើងដល់នូវការខូចភ្នែកហើយ ពួកយើងមិនបោះបង់លោក នឹងទំនុកបម្រុងលោក ដូច្នេះហើយ ទើបបានថ្វាយទ្វារមួយដែលជកសួយបានមួយថ្ងៃ ១ សែន ដល់មហាលិកុមារនោះ ។ ទ្រង់អាស្រ័យទ្វារនោះ ឲ្យឱរសរបស់ស្តេចលិច្ឆវី ៥០០ អង្គ សិក្សាសិប្បៈហើយ ។

ចំណែកពន្ធុលកុមារ កាលពួកត្រកូលមល្លរាជពោលថា សូមពន្ធុលកុមារ កាប់ឫស្សីទាំងនេះ ដូច្នេះហើយ បានលោតឡើងទៅកាន់អាកាសកម្ពស់ ៨០ ហត្ថ យកដាវកាប់បាច់ឫស្សី ៦០ ដើម ដែលពួកស្តេចមល្លៈយកឫស្សី ៦០ ដើម ញាត់ដែកត្រង់កណ្តាលហើយ ឲ្យលើកឡើងតម្កល់ជាប់ហើយ ពន្ធុលកុមារនោះ បានឮសំឡេងក្រឹកខ្លាំង របស់ដែកក្នុងបាច់ឫស្សីចុងក្រោយ ទើបសួរថា នេះអ្វី បានឮថា គេយកដែកញាត់ក្នុងឫស្សីគ្រប់បាច់ហើយ ទើបបោះដាវចោល ស្រែកយំពោលថា ញាតិ និងមិត្តរបស់អញ មានប្រមាណប៉ុណ្ណេះ សូម្បីតែម្នាក់ដែលជាអ្នកស្រឡាញ់ក្នុងអញ មិនបានប្រាប់ហេតុនេះដល់អញ បើអញដឹងសោត គប្បីកាប់មិនឲ្យឮសំឡេងខ្លាំងដូច្នេះឡើយ ហើយទូលដល់ព្រះជនក និងព្រះជននីថា ទូលបង្គំនឹងសម្លាប់ស្តេចមល្លៈទាំងអស់នេះ ហើយគ្រងរាជសម្បត្តិ កាលព្រះជនក និងព្រះជននីឃាត់ហើយដោយប្រការផ្សេងៗ ជាដើមថា នែកូន នេះជារាជបវេណី កូនមិនគប្បីធ្វើ

យ៉ាងនោះ ទើបទូលថា បើដូច្នោះ ខ្ញុំនឹងទៅកាន់សម្នាក់សម្លាញ់របស់ខ្ញុំដូច្នេះ បានទៅកាន់ក្រុងសាវត្ថីហើយ ។

ព្រះបាទបសេនទិកោសល ទ្រង់ជ្រាបការយាងមករបស់ពន្ធុលៈនោះ ទ្រង់ទទួលយាងឲ្យចូលព្រះនគរដោយសក្ការៈធំហើយ ទ្រង់តាំងទុកក្នុងតំណែងសេនាបតី ។ ពន្ធុលសេនាបតីនោះ ឲ្យយាងព្រះជនក និងព្រះជននីមកអាស្រ័យ នៅក្នុងក្រុងសាវត្ថីនោះឯង ។

សម័យថ្ងៃមួយ ព្រះរាជាទ្រង់ប្រថាប់ឈរលើប្រាសាទជាន់លើ ទតទៅកាន់វាំងផ្លូវ ឃើញភិក្ខុច្រើនពាន់រូប និមន្តទៅដើម្បីធ្វើភត្តកិច្ច ក្នុងគេហដ្ឋានជនទាំងនេះ គឺអនាថបិណ្ឌិកសេដ្ឋី ចូឡអនាថបិណ្ឌិកសេដ្ឋី នាងវិសាខា នាងសុប្បវាសា ទើបត្រាស់សួរថា លោកម្ចាស់ទាំងឡាយនិមន្តទៅណា ពួករាជ-បុរសក្រាបទូលថា បពិត្រព្រះសម្មតិទេព ភិក្ខុពីរពាន់រូបទៅដើម្បីប្រយោជន៍ដល់ភត្តទាំងឡាយ មាននិច្ចភត្ត សាលាកភត្ត និងគិលានភត្តជាដើម ក្នុងគេហដ្ឋានរបស់អនាថបិណ្ឌិកសេដ្ឋីរាល់ៗ ថ្ងៃ ។ ភិក្ខុ ៥០០ រូប ទៅគេហដ្ឋានរបស់ចូឡអនាថបិណ្ឌិកសេដ្ឋីជានិច្ច របស់នាងវិសាខា និងនាងសុប្បវាសាក៏ដូចគ្នា ដូច្នេះហើយ ទ្រង់ព្រះបំណងនឹងទំនុកបម្រុងភិក្ខុសង្ឃ ដោយព្រះអង្គឯងខ្លះ ទើបយាងទៅកាន់វិហារ ទ្រង់និមន្តព្រះសាស្ដា មួយអន្លើដោយភិក្ខុ ១ ពាន់រូប ថ្វាយទានដោយព្រះហស្តអស់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ ថ្វាយបង្គំព្រះសាស្ដាហើយ ទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ទទួលភិក្ខារបស់ខ្ញុំព្រះអង្គ មួយអន្លើដោយភិក្ខុ ៥០០ រូប ជានិច្ចចុះ ។

ព្រះសាស្ដាត្រាស់ថា បពិត្រមហារាជ ធម្មតាព្រះពុទ្ធទាំងឡាយ រមែង មិនទទួលកិច្ចប្រចាំក្នុងទីមួយកន្លែង មហាជនដ៏ច្រើនរមែងទន្ទឹងចំពោះការមក របស់ព្រះពុទ្ធទាំងឡាយ ។

ព្រះរាជាត្រាស់ថា បើដូច្នោះ សូមទ្រង់បញ្ជូនភិក្ខុមួយរូបមកជាប្រចាំចុះ ព្រះសាស្ដា ទ្រង់បានធ្វើឲ្យជាភារៈរបស់ព្រះអានន្ទត្ថេរ ។

ព្រះរាជាមិនចាត់ចែងនាទីថា កាលភិក្ខុសង្ឃមកហើយ ជនទាំងនេះ ទទួលបាត្រ ហើយចូរអង្គាស ទ្រង់អង្គាសដោយព្រះអង្គឯងប៉ុណ្ណោះអស់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៨ ទ្រង់ក៏ភ្លេច ទ្រង់ធ្វើឲ្យយឺតយូរហើយ ។

ធម្មតាក្នុងរាជត្រកូល ជនទាំងឡាយ ដែលព្រះរាជាទ្រង់មិនបានបញ្ជា ហើយ រមែងមិនបានក្រាលអាសនៈទាំងឡាយ និមន្តពួកភិក្ខុឲ្យគង់ហើយអង្គាស ពួកភិក្ខុក៏គិតគ្នាថា យើងមិនអាចឈប់បង្អង់ក្នុងទីនេះបាន នាំគ្នាចៀសចេញ ទៅច្រើនរូប ។ សូម្បីក្នុងថ្ងៃទីពីរ ព្រះរាជាក៏ទ្រង់ភ្លេចហើយ សូម្បីក្នុងថ្ងៃទីពីរ ភិក្ខុជាច្រើនក៏នាំគ្នាចៀសចេញទៅ ។ ក្នុងថ្ងៃទីបី ព្រះរាជាក៏ទ្រង់ភ្លេច ក្នុង កាលនោះ វៀរព្រះអានន្ទត្ថេរមួយអង្គប៉ុណ្ណោះ ពួកភិក្ខុដ៏សេស នាំគ្នាចៀស ចេញទៅ ។

ធម្មតាអ្នកមានបុណ្យទាំងឡាយ ជាអ្នកប្រព្រឹត្តទៅក្នុងអំណាចនៃហេតុ ទើបរក្សាការជ្រះថ្លាឲ្យត្រកូលទាំងឡាយបាន ។ សាវករបស់ព្រះតថាគតទាំង អស់ ដែលដល់នូវឋានន្តរ តាំងអំពីជនទាំង ៨ នោះ បានដល់ អគ្គសាវកពីរ រូប គឺព្រះសារីបុត្តត្ថេរ ព្រះមហាមោគ្គល្លានត្ថេរ អគ្គសាវិកាពីររូប គឺនាង

ខេមា នាងឧប្បលវណ្ណា បណ្តាឧបាសកទាំងឡាយ ឧបាសកដែលជាអគ្គសាវក ពីរនាក់ គឺចិត្តគហបតី ហត្ថកឧបាសកអ្នកក្រុងអាឡវី បណ្តាឧបាសិកាទាំងឡាយ ឧបាសិកាដែលជាអគ្គសាវិកាពីរនាក់ គឺម្តាយរបស់នន្ទមាណពឈ្មោះវេឡុកណ្ឋកី នាងខុជ្ជុត្តរា សុទ្ធសឹងតែជាអ្នកមានបុណ្យច្រើន សម្បូរដោយអភិនីហារ ព្រោះជាអ្នកបំពេញបារមី ១០ ដោយឯកទេស ។

សូម្បីព្រះអានន្ទត្ថេរ មានបារមីបំពេញហើយអស់សែនកប្ប សម្បូរដោយអភិនីហារ មានបុណ្យច្រើន កាលនឹងរក្សាសេចក្តីជ្រះថ្លារបស់ត្រកូល ទើបបានឈប់បង្អង់ ព្រោះភាពដែលខ្លួនប្រព្រឹត្តទៅក្នុងអំណាចនៃហេតុ ពួករាជបុរសនិមន្តលោកមួយអង្គប៉ុណ្ណោះ ឲ្យគង់ហើយអង្គាស ។ ព្រះរាជាមកក្នុងកាលដែលពួកភិក្ខុទៅហើយ ទតឃើញខាទនីយៈ និងភោជនីយៈតាំងនៅយ៉ាងនោះឯង ទើបត្រាស់សួរថា លោកម្ចាស់ទាំងឡាយមិនបាននិមន្តមកឬ ទ្រង់បានឮថា ព្រះអានន្ទត្ថេរនិមន្តមកមួយរូបប៉ុណ្ណោះ ទ្រង់ពិរោធភិក្ខុទាំងឡាយថា លោកម្ចាស់ទាំងឡាយ បានធ្វើការកាត់ផ្តាច់ចំពោះអញ មានប្រមាណប៉ុណ្ណោះពិត ទើបយាងទៅកាន់សម្នាក់ព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គរៀបចំភិក្ខាដើម្បីភិក្ខុ ៥០០ បានឮថា ព្រះអានន្ទត្ថេរមួយរូបប៉ុណ្ណោះនិមន្តមក ភិក្ខាដែលខ្ញុំព្រះអង្គរៀបចំហើយ តាំងនៅយ៉ាងនោះឯង ភិក្ខុ ៥០០ រូប មិនធ្វើការសម្គាល់ក្នុងព្រះរាជវាំងរបស់ខ្ញុំព្រះអង្គឡើយ នឹងមានហេតុអ្វី ។

ព្រះសាស្តា មិនត្រាស់ទោសរបស់ពួកភិក្ខុ ត្រាស់ថា បពិត្រមហារាជ សាវករបស់តថាគត មិនមានការស្និទ្ធស្នាលជាមួយព្រះអង្គ ព្រោះហេតុនោះ

ភិក្ខុទាំងឡាយនឹងមិនទៅហើយ ដើម្បីទ្រង់ប្រកាសហេតុនៃការមិនចូលទៅ និងហេតុនៃការចូលទៅកាន់ត្រកូលទាំងឡាយ ត្រាស់ហៅភិក្ខុទាំងឡាយមកហើយ ត្រាស់សូត្រនេះថា

ម្នាលភិក្ខុទាំងឡាយ ត្រកូលប្រកបដោយអង្គ ៩ ដែលភិក្ខុមិនទាន់ចូលទៅ ក៏មិនគួរចូលទៅ បើភិក្ខុចូលជ្រុលទៅហើយ ក៏មិនគួរអង្គុយ ។ ត្រកូលប្រកបដោយអង្គ ៩ តើដូចម្តេចខ្លះ ។ គឺគេមិនក្រោកទទួលដោយសេចក្តីពេញចិត្ត ១ មិនថ្វាយបង្គំដោយសេចក្តីពេញចិត្ត ១ មិនឲ្យអាសនៈដោយសេចក្តីពេញចិត្ត ១ លាក់របស់ដែលមាន ១ របស់មានច្រើនឲ្យតិច ១ មានរបស់ដែលថ្លៃថ្លាឲ្យរបស់សៅហ្មង ១ ឲ្យដោយមិនគោរព មិនឲ្យដោយគោរព ១ មិនចូលទៅអង្គុយជិតដើម្បីស្តាប់ធម៌ដោយគោរព ១ មិនត្រេកអរនឹងភាសិតរបស់ភិក្ខុនោះ ១ ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលប្រកបដោយអង្គ ៩ នេះឯង ដែលភិក្ខុមិនធ្លាប់ចូលទៅ ក៏មិនគួរចូលទៅ ឬចូលជ្រុលទៅហើយ ក៏មិនគួរអង្គុយ ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលប្រកបដោយអង្គ ៩ ដែលភិក្ខុមិនទាន់ចូលទៅ ក៏គួរចូលទៅបាន ឬចូលទៅហើយក៏គួរអង្គុយបាន ។ ត្រកូលប្រកបដោយអង្គ ៩ តើដូចម្តេចខ្លះ ។ គឺគេក្រោកទទួលដោយសេចក្តីពេញចិត្ត ១ ថ្វាយបង្គំដោយសេចក្តីពេញចិត្ត ១ ឲ្យអាសនៈដោយសេចក្តីពេញចិត្ត ១ មិនលាក់របស់ដែលមាន ១ របស់ដែលមានច្រើនឲ្យច្រើន ១ របស់ដែលថ្លៃថ្លាឲ្យរបស់ថ្លៃថ្លា ១ ឲ្យដោយគោរព មិនឲ្យដោយមិនគោរព ១ ចូលទៅអង្គុយជិតដើម្បីស្តាប់ធម៌ ១ ត្រេកអរនឹងភាសិតរបស់ភិក្ខុនោះ ១ ។

ម្នាលភិក្ខុទាំងឡាយ ត្រកូលប្រកបដោយអង្គ ៩ នេះឯង ដែលភិក្ខុមិនទាន់ចូលទៅ ក៏គួរចូលទៅបាន ឬចូលទៅហើយ ក៏គួរអង្គុយបាន ។

ដូច្នេះហើយ ទើបត្រាស់ថា មហាបពិត្រ ភិក្ខុសាវ័ករបស់តថាគត កាលមិនបានទូវការស្និទ្ធស្នាល អំពីសម្នាក់របស់ព្រះអង្គ នឹងមិនទៅដោយប្រការយ៉ាងនេះឯង ។ ពិតហើយ បុរាណបណ្ឌិតទាំងឡាយ សូម្បីគេទំនុកបម្រុងដោយសេចក្តីគោរពក្នុងទីដែលមិនស្និទ្ធស្នាល ដល់នូវទុក្ខវេទនាទៀតនឹងស្លាប់ ក៏បានទៅកាន់ទីរបស់អ្នកស្និទ្ធស្នាលដូចគ្នា កាលព្រះរាជាទូលសួរថា បពិត្រព្រះអង្គ តើក្នុងកាលណា ទ្រង់ក៏នាំអតីតនិទានមកសម្តែងដូចតទៅ

ក្នុងអតីតកាល ស្តេចព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះរាជាព្រះនាមកេសវៈ ទ្រង់លះរាជសម្បត្តិបួសជាឥសី ។ បុរស ៥០០ នាក់ ចេញបួសតាមព្រះរាជានោះ បានព្រះនាមថាកេសវតាបស ។ ម្យ៉ាងទៀត នាយកប្បកសាមាលារបស់ព្រះអង្គ បានបួសតាមជាអន្តេវាសិក ឈ្មោះកប្បកៈ ។ កេសវតាបស និងបរិស័ទ នៅក្នុងហិមវន្តប្បទេសអស់ ៨ ខែ ក្នុងរដូវភ្លៀងកាលត្រូវការសេពរសប្រៃ និងជូរ ទៅដល់ក្រុងពារាណសីហើយ ចូលទៅកាន់នគរដើម្បីភិក្ខា លំដាប់នោះ ព្រះរាជាទតឃើញតាបសនោះ ទ្រង់ជ្រះថ្លា ទ្រង់ទទួលបដិញ្ញាដើម្បីប្រយោជន៍ ដល់ការនៅក្នុងសម្នាក់របស់ព្រះអង្គអស់ ៤ ខែ និមន្តឲ្យស្នាក់នៅក្នុងព្រះរាជឧទ្យាន ទ្រង់យាងទៅកាន់ទីបម្រើតាបសនោះទាំងល្ងាច ទាំងព្រឹក ពួកតាបសដ៏សេស ស្នាក់នៅ ២-៣ ថ្ងៃ រំខានដោយសំឡេងអឺងកងផ្សេងៗ មានសំឡេងដំរីជាដើម ទើបពោលថា លោកអាចារ្យ

ពួកខ្ញុំរំខានចិត្តនឹងទៅ គេសួរៈពោលថា នែបា អ្នកនឹងទៅណា អន្តេវាសិក ប្រាប់ថា បពិត្រលោកអាចារ្យ ទៅកាន់ព្រៃហិមវន្តប្បទេស គេសួរៈពោលថា ក្នុងថ្ងៃដែលពួកយើងមកនោះឯង ស្តេចផែនដីទ្រង់ទទួលបេ្ដជ្ញាដើម្បីប្រយោជន៍ ដល់ការនៅក្នុងទីនេះ អស់ ៤ ខែ ពួកអ្នកនឹងទៅបានដូចម្តេច ។

អន្តេវាសិកពោលថា លោកអាចារ្យមិនប្រាប់ពួកខ្ញុំជាមុន ទើបថ្វាយបេ្ដជ្ញា ។ ពួកខ្ញុំមិនអាចនៅក្នុងទីនេះបាន នឹងនៅក្នុងទីល្មមស្តាប់ការប្រព្រឹត្តទៅរបស់ លោកអាចារ្យបាន ដែលមិនឆ្ងាយអំពីទីនេះដូច្នេះ នាំគ្នាថ្វាយបង្គំអាចារ្យហើយ ចៀសចេញទៅ ។ អាចារ្យនៅជាមួយអន្តេវាសិក ឈ្មោះកប្បកៈប៉ុណ្ណោះ ។

ព្រះរាជាយាងមកកាន់ទីបម្រើត្រាស់សួរថា លោកម្ចាស់ទាំងឡាយ និមន្តទៅណា គេសរតាបសទូលថា បពិត្រមហារាជ ពួកតាបសទាំងនោះ ប្រាប់ថា ពួកខ្ញុំរំខានចិត្ត ដូច្នេះហើយ ក៏ទៅកាន់ហិមវន្តប្បទេស ។

ក្នុងកាលតមកមិនយូរ សូម្បីកប្បកតាបសក៏រំខានហើយ សូម្បីត្រូវអាចារ្យ ឃាត់រឿយៗ ក៏ពោលថា ខ្ញុំមិនអាចនៅក្នុងទីនេះបានទេ ដូច្នេះហើយក៏ទៅ ។ តែកប្បកតាបសនោះ មិនទៅកាន់សម្នាក់របស់ពួកតាបសក្រៅអំពីនេះ រង់ចាំស្តាប់ដំណឹងរបស់អាចារ្យក្នុងទីក្បែរៗ នោះ ។

ក្នុងកាលតមក កាលអាចារ្យគិតដល់ពួកអន្តេវាសិក រោគក្នុងពោះក៏កើត ឡើង ព្រះរាជាទ្រង់បញ្ជាឲ្យពេទ្យព្យាបាល រោគក៏មិនស្ងប់បាន ទើបតាបស ទូលថា បពិត្រមហារាជ ទ្រង់បំណងឲ្យរោគរបស់អាត្មាភាពស្ងប់ឬ ព្រះរាជា ត្រាស់ថា បពិត្រលោកម្ចាស់ បើខ្ញុំអាច ក៏គប្បីធ្វើសេចក្តីផាសុកដល់លោក

ម្ចាស់ឥឡូវនេះឯង តាបសពោលថា បពិត្រមហារាជ បើទ្រង់ប្រាថ្នាសេចក្តីសុខ ដល់អាត្មាសោត សូមបញ្ជូនអាត្មាទៅកាន់សម្នាក់អន្តេវាសិកទាំងឡាយចុះ ។

ព្រះរាជាត្រាស់ថា សាធុ លោកម្ចាស់ ហើយឲ្យតាបសនោះសិងលើគ្រែតូច ទ្រង់បញ្ជូនអមាត្យទៅ ៤ នាក់ មាននារទអមាត្យជាប្រធាន ហើយត្រាស់ថា ពួកអ្នកចូរជ្រាបដំណឹងរបស់លោកម្ចាស់ហើយ គប្បីបញ្ជូនដំណឹងដល់យើង ។

កប្បកអន្តេវាសិកជ្រាបថា អាចារ្យមក ក៏ធ្វើនូវការទទួល កាលអាចារ្យពោលថា ជនក្រៅអំពីនេះទៅកាន់ទីណា ទើបប្រាប់ថា បានឮថា នៅក្នុងទីឈ្មោះនោះ ។

អន្តេវាសិកទាំងនោះជ្រាបថាអាចារ្យមកហើយ ក៏មកប្រជុំគ្នាក្នុងទីនោះឯង ប្រគេនទឹកក្តៅហើយ ថ្វាយផលាផលដល់អាចារ្យ រោគស្ងប់ហើយក្នុងខណៈនោះឯង ។ តាបសនោះមានពណ៌ដូចមាសក្នុងកាល ២-៣ ថ្ងៃប៉ុណ្ណោះ លំដាប់នោះ នារទអមាត្យសួរថា

កេសវតាបស មានព្រះភាគ ( របស់យើងខ្ញុំ ) នេះ លះបង់ព្រះបាទពារាណសី ជាធំជាងមនុស្ស អ្នកឲ្យសម្រេចសេចក្តីប្រាថ្នាទាំងពួង ហើយត្រេកអរសប្បាយក្នុងអាស្រម របស់កូនសិស្សឈ្មោះកប្បកៈ តើដោយឧបាយដូចម្តេច ។

កេសវតាបសនិយាយថា ម្នាលអមាត្យ រសទាំងឡាយដ៏ឆ្ងាញ់ គួររីករាយក៏មាន ដើមឈើទាំងឡាយ ជាទីរីករាយចិត្តក៏មាន ពាក្យជាសុភាសិត

ទាំងឡាយរបស់កប្បកៈ តែងធ្វើឲ្យអាត្មាត្រេកអរបាន ។

នាងទាមាត្យ ពោលថា លោកម្ចាស់ ឆាន់ចង្ហាន់ស្រូវសាលី ដែលលាយដោយសាច់ដ៏ស្អាត ហេតុដូចម្តេច បានជាស្រងែ និងស្មៅគែលលកដែលមិនមានរសប្រៃសោះ ធ្វើឲ្យលោកម្ចាស់ត្រេកអរបាន ។

កេសវតាបសនិយាយតបថា បុគ្គលមានសេចក្តីស្និទ្ធស្នាល បរិភោគភោជន ទោះបីឆ្ងាញ់ក្តី មិនឆ្ងាញ់ក្តី តិចក្តី ច្រើនក្តី ក្នុងកន្លែងណា ភោជន ( ណាមួយដែលបុគ្គលបរិភោគហើយ ក្នុងទីកន្លែងនោះជាភោជនប្រសើរ ) ព្រោះរស មានសេចក្តីស្និទ្ធស្នាលជាយ៉ាងក្រៃលែង ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់សមោធានជាតក ត្រាស់ថា ព្រះរាជាក្នុងកាលនោះ បានជាមោគ្គល្លាន នាងទអមាត្យបានជាសារីបុត្ត អន្តេវាសិកឈ្មោះកប្បកៈបានជាអានន្ទ កេសវតាបស គឺតថាគតនេះឯង ដូច្នេះហើយ ត្រាស់ថា មហាបពិត្រ បណ្ឌិតក្នុងកាលមុនដល់នូវវេទនាស្ទើរនឹងស្លាប់ បានទៅកាន់ទីដែលមានការស្និទ្ធស្នាលហើយ សាវកទាំងឡាយរបស់តថាគត ប្រហែលជាមិនបាននូវការស្និទ្ធស្នាល ក្នុងសម្នាក់របស់ទ្រង់ ។

ព្រះរាជាទ្រង់ព្រះតម្រិះថា អាត្មាអញគួរធ្វើនូវការស្និទ្ធស្នាលជាមួយភិក្ខុសង្ឃ អញនឹងធ្វើម្តេចហ្ន៎ ដូច្នេះហើយ ទ្រង់ព្រះតម្រិះទៀតថា គួរធ្វើព្រះធីតានៃព្រះញាតិរបស់ព្រះសម្មាសម្ពុទ្ធ ទុកក្នុងព្រះរាជមន្ទីរ កាលបើដូច្នេះ ពួកភិក្ខុកំលោះ និងពួកសាមណេរ ក៏នឹងស្និទ្ធស្នាលហើយមកកាន់សម្នាក់របស់

អញជានិច្ច ដោយគិតថា ព្រះរាជាជាព្រះញាតិរបស់ព្រះសម្មាសម្ពុទ្ធ ដូច្នេះ ទ្រង់ព្រះរាជសាសន៍ទៅសម្នាក់ស្ដេចសក្យៈទាំងឡាយថា ស្ដេចសក្យៈទាំង-ឡាយ ចូរប្រទានព្រះរាជធីតាមួយអង្គដល់ខ្ញុំ ហើយបញ្ជាទូតទាំងឡាយថា ពួកអ្នកគប្បីសួរថា ជាធីតានៃសក្យៈអង្គណា ហើយសឹមមក ។

ពួកទូតទៅហើយ ទូលសូមរាជធីតាមួយអង្គនឹងសក្យៈទាំងឡាយ ស្ដេចសក្យៈទាំងនោះប្រជុំគ្នាហើយ ទ្រង់ព្រះតម្រិះថា ព្រះរាជាជាបរបក្ខ បើពួកយើងមិនឲ្យសោត ទ្រង់នឹងធ្វើឲ្យពួកយើងវិនាស ឯត្រកូលទ្រង់ មិនស្មើនឹងយើងឡើយ ពួកយើងគួរធ្វើដូចម្ដេចល្អ ស្ដេចមហានាមត្រាស់ថា កូនរបស់ខ្ញុំឈ្មោះវាសភខត្តិយា កើតក្នុងផ្ទៃទាសី ដល់នូវភាពជាអ្នកមានរូបស្អាតមាន ពួកយើងនឹងឲ្យនាងនោះ ដូច្នេះហើយ ទើបប្រាប់ពួកទូតថា ប្រពៃណាស់ ពួកយើងនឹងថ្វាយព្រះរាជកញ្ញាដល់ព្រះរាជា ពួកទូតពោលថា ជាព្រះរាជ-ធីតារបស់សក្យៈអង្គណា ស្ដេចសក្យៈពោលថា ជាធីតារបស់មហានាមសក្យរាជ ដែលជាព្រះឱរសរបស់ម្ចាស់ពូនៃព្រះសម្មាសម្ពុទ្ធ ឈ្មោះវាសភ-ខត្តិយា ទូតទាំងនោះទៅក្រាបទូលដល់ព្រះរាជារបស់ខ្លួន ព្រះរាជាត្រាស់ថា បើយ៉ាងនោះក៏ប្រពៃ ពួកអ្នកចូរនាំមកចុះ ធម្មតាពួកក្សត្រមានកលមាយាច្រើន គប្បីបញ្ជូនកូនស្រីរបស់ទាសីមកក៏ថាបាន ពួកអ្នកចូរនាំធីតា ដែលសោយភោជនជាមួយព្រះបិតាមក ដូច្នេះហើយ ទ្រង់បញ្ជូនទូតទាំងឡាយទៅ ។

ពួកគេទៅហើយក្រាបទូលថា បពិត្រព្រះអង្គ ព្រះរាជាទ្រង់ប្រាថ្នាព្រះធីតាដែលសោយរួមជាមួយព្រះអង្គ ស្ដេចមហានាមត្រាស់ថា នែបា បាន ទើប

ឲ្យតាក់តែងនាងក្នុងពេលសោយរបស់ព្រះអង្គ ត្រាស់ឲ្យហៅនាងមក សម្ដែងអាការ ហាក់ដូចសោយរួមគ្នាជាមួយនាងហើយ ប្រគល់ដល់ទូតទាំងឡាយ ។ ពួកគេនាំនាងទៅកាន់ក្រុងសាវត្ថីហើយ ក្រាបទូលរឿងនោះដល់ព្រះរាជា ។

ព្រះរាជាទ្រង់ពេញព្រះហឫទ័យ តាំងនាងឲ្យជាធំជាងស្រី ៥០០ អភិសេកក្នុងតំណែងអគ្គមហេសី ក្នុងកាលមិនយូរ នាងក៏ប្រសូតព្រះឱរស មានពណ៌ដូចមាស ។ សម័យតមក ក្នុងថ្ងៃថ្វាយព្រះនាមព្រះឱរសនោះ ព្រះរាជាទ្រង់បញ្ជូនព្រះរាជសាសន៍ទៅកាន់សម្នាក់ព្រះអយ្យិកាថា ព្រះនាងវាសភខត្តិយាធីតានៃសក្យរាជ ប្រសូតព្រះឱរសហើយ ទ្រង់ថ្វាយព្រះនាមកុមារនោះដូចម្ដេច ។

ចំណែកអមាត្យ ត្រចៀកថ្ងន់ ទទួលព្រះរាជសាសន៍នោះទៅហើយ ។ អមាត្យទៅហើយ ក៏ក្រាបទូលដល់ព្រះអយ្យិការបស់ព្រះរាជា ។

ព្រះអយ្យិកានោះ ទ្រង់ស្ដាប់រឿងនោះហើយត្រាស់ថា ព្រះនាងវាសភខត្តិយា មិនប្រសូតព្រះឱរស ក៏បានគ្រប់គ្រងជនទាំងអស់ ឥឡូវនេះ នាងនឹងជាទីប្រោសប្រាណក្រៃលែងរបស់ព្រះរាជា ។

អមាត្យត្រចៀកថ្ងន់ ស្ដាប់ពាក្យថា វល្លភា មិនសូវច្បាស់ យល់ថា វិឌូឌភៈ កាលចូលគាល់ព្រះរាជាហើយ ក៏ក្រាបទូលថា បពិត្រមហារាជ សូមទ្រង់ថ្វាយព្រះនាមព្រះរាជកុមារថា វិឌូឌភៈចុះ ព្រះរាជាទ្រង់ព្រះតម្រិះថា ពាក្យថា វិឌូឌភៈ ជាឈ្មោះប្រចាំត្រកូលរបស់អញ ទើបបានថ្វាយព្រះនាមថា វិឌូឌភៈ ។

សម័យតមក ព្រះរាជាបានប្រទានតំណែងសេនាបតី ដល់វិឌូឌភកុមារនោះ ក្នុងកាលដែលទ្រង់ពេញកំលោះនោះឯង ដោយតាំងព្រះហឫទ័យថា នឹងធ្វើឲ្យជាទីប្រោសប្រាណរបស់ព្រះសាស្តា ។

វិឌូឌភៈនោះ ទ្រង់ចម្រើនដោយគ្រឿងទំនុកបម្រុងសម្រាប់កុមារ ក្នុងកាលមានព្រះជន្ម ៧ ឆ្នាំ ទ្រង់ឃើញរបស់លេងផ្សេងៗ មានរូបដំរី និងរូបសេះជាដើមរបស់កុមារដទៃ ដែលបុគ្គលនាំមកអំពីត្រកូលជីដូន ទើបសួរព្រះមាតាថា បពិត្រមាតា បុគ្គលដទៃៗ គេនាំបណ្ណាការមកអំពីត្រកូលជីដូនដើម្បីពួកកុមារ ញាតិណាមួយរមែងមិនបញ្ជូនបណ្ណាការណាមួយមកដើម្បីខ្ញុំសោះ មាតាមិនមានព្រះជនក ព្រះជននីឬ ។

បន្ទាប់អំពីនោះ ទើបព្រះមាតាលួងលោមឱរសនោះថា នែបា ស្តេចសក្យៈ ជាជីដូនរបស់អ្នក មានតែនៅឆ្ងាយ ហេតុនោះ ទើបពួកលោកមិនបានបញ្ជូនគ្រឿងបណ្ណាការណាមួយមកដើម្បីអ្នក ។

ក្នុងកាលមានព្រះជន្មវស្សា ១៦ ទើបព្រះរាជកុមារទូលព្រះមាតាទៀតថា បពិត្រមាតា ខ្ញុំប្រាថ្នានឹងសួរសុខទុក្ខត្រកូលរបស់ព្រះអយ្យិកា សូម្បីត្រូវព្រះមាតាឃាត់ថា នែកូន អ្នកកុំទៅឡើយ កូននឹងទៅធ្វើអ្វីក្នុងទីនោះ ព្រះរាជ-កុមារក៏អង្វររឿយៗ ទៅ ។ ពេលនោះ ព្រះមាតារបស់ព្រះរាជកុមារ ក៏ទ្រង់យល់ព្រមថា បើយ៉ាងនោះ ទៅក៏ទៅចុះ ។

ព្រះរាជកុមារក្រាបទូលព្រះរាជបិតាហើយយាងទៅ មួយអន្លើដោយបរិវារដ៏ច្រើន ។ ព្រះនាងវាសភខត្តិយា ទ្រង់បញ្ជូនដំណឹងទៅមុនថា ខ្ញុំម្ចាស់

នៅក្នុងទីនេះសុខសប្បាយជាទេ ព្រះញាតិទាំងឡាយ កុំសម្តែងទោសណាមួយ របស់ព្រះស្វាមីដល់កុមារនោះឡើយ ។

ស្តេចសក្យៈទ្រង់ជ្រាបថាវិឌូឌភកុមារយាងមក ទ្រង់ប្រឹក្សាថា ពួកយើងមិនអាចថ្វាយបង្គំវិឌូឌភៈបាន ទើបបញ្ជូនព្រះរាជកុមារទាំងឡាយដែលក្មេងៗជាងវិឌូឌភៈនេះទៅកាន់ជនបទហើយ កាលវិឌូឌភកុមារនោះយាងដល់កបិលវត្ថុបុរី ក៏ប្រជុំគ្នាក្នុងរាជមន្ទីរ វិឌូឌភកុមារបានយាងទៅគង់នៅក្នុងទីនោះ ។

លំដាប់នោះ ពួកសក្យៈពោលនឹងព្រះរាជកុមារនោះថា នែបា នេះជាតារបស់បា នេះជាអ៊ំ វិឌូឌភកុមារនោះត្រាច់ថ្វាយបង្គំសក្យៈទាំងអស់ មិនបានឃើញសក្យៈសូម្បីមួយអង្គដែលថ្វាយបង្គំខ្លួន ទើបទូលសួរថា ហេតុអ្វីហ្ន៎ ទើបមិនមានស្តេចសក្យៈទាំងឡាយថ្វាយបង្គំខ្ញុំខ្លះ ។

ពួកស្តេចសក្យៈត្រាស់ថា នែបា កុមារដែលជាប្អូនរបស់បា យាងទៅជនបទអស់ហើយ ទ្រង់ធ្វើសក្ការៈធំដល់ព្រះកុមារនោះ ។ ព្រះអង្គក៏គង់នៅអស់ ២-៣ ថ្ងៃ ក៏យាងចេញអំពីព្រះនគរដោយបរិវារច្រើន ។

លំដាប់នោះ ទាសីម្នាក់ស្រែកជេរថា នេះជាបន្ទះក្តារដែលកូននាងទាសីឈ្មោះវាសភខត្តិយាអង្គុយ ដូច្នេះហើយ លាងបន្ទះក្តារដែលព្រះរាជកុមារនោះអង្គុយក្នុងរាជមន្ទីរ ដោយទឹកលាយដោយទឹកដោះ ។ មហាតលិកម្នាក់ភ្លេចអាវុធរបស់ខ្លួន ត្រឡប់ទៅយកអាវុធនោះ បានឮសំឡេងជេរវិឌូឌភកុមារទើបសួរទោសនោះ ជ្រាបថា នាងវាសភខត្តិយា កើតក្នុងផ្ទៃរបស់ទាសីមហានាមសក្យៈ ទើបប្រាប់ដល់ពួកពល មានការគោឡាហលធំថា បានឮថា

ព្រះនាងវាសភខត្តិយាជាកូនស្រីរបស់ទាសី ។

ព្រះបាទវិឌូឌភៈស្តាប់ពាក្យនោះ បានតាំងព្រះហឫទ័យថា ស្តេចសក្យៈទាំងនោះ លាងបន្ទះក្តារដែលអញអង្គុយ ដោយទឹកលាយដោយទឹកដោះសិនចុះ តែក្នុងកាលដែលអញតាំងនៅក្នុងរាជសម្បត្តិហើយ អញនឹងយកឈាមបំពង់ករបស់ស្តេចសក្យៈទាំងនោះ លាងបន្ទះក្តារដែលអញអង្គុយ កាលទ្រង់យាងដល់ក្រុងសាវត្ថី ពួកអមាត្យក៏ក្រាបទូលរឿងនោះដល់ព្រះរាជា ។

ព្រះរាជាទ្រង់ពិរោធស្តេចសក្យៈថា បានឲ្យធីតានាងទាសីដល់អញ ទើបទ្រង់បញ្ជាដកគ្រឿងបរិហារ ដែលទ្រង់ព្រះរាជប្រទានដល់ព្រះនាងវាសភខត្តិយា និងព្រះឱរស ឲ្យព្រះរាជទានត្រឹមតែវត្ថុដែលជាទាសៈ និងទាសីគប្បីបានប៉ុណ្ណោះ ។

ក្នុងកាលតមក ២-៣ ថ្ងៃ ព្រះសាស្តាទ្រង់យាងទៅកាន់ព្រះរាជនិវេសន៍ប្រថាប់គង់ហើយ ។ ព្រះរាជាយាងមកថ្វាយបង្គំហើយទូលថា បពិត្រព្រះអង្គដ៏ចម្រើន បានឮថា ព្រះញាតិរបស់ព្រះអង្គប្រទានធីតានៃទាសីដល់ខ្ញុំព្រះអង្គ ព្រោះដូច្នោះ ទើបខ្ញុំព្រះអង្គដកគ្រឿងបរិហាររបស់នាងវាសភខត្តិយានោះ ព្រមទាំងបុត្រ ឲ្យត្រឹមតែរបស់ដែលទាសៈ និងទាសីគួរបានប៉ុណ្ណោះ ។

ព្រះសាស្តាត្រាស់ថា មហាបពិត្រ ស្តេចសក្យៈទាំងឡាយធ្វើកម្មមិនសមគួរ ធម្មតាកាលឲ្យ ក៏គួរឲ្យធីតាដែលមានជាតិស្មើគ្នា មហាបពិត្រ តថាគតទូលព្រះអង្គថា នាងវាសភខត្តិយាជាធីតារបស់ខត្តិយរាជ បានអភិសេកក្នុងព្រះរាជមន្ទីររបស់ខត្តិយរាជ ចំណែកវិឌូឌភកុមារ ក៏ទ្រង់អាស្រ័យខត្តិយរាជ

នោះឯងប្រសូតហើយ ធម្មតាគោត្រខាងមាតា នឹងមានប្រយោជន៍អ្វី គោត្រខាងបិតាប៉ុណ្ណោះជាសំខាន់ ដូច្នេះហើយ ត្រាស់ថា បុរាណបណ្ឌិតទាំងឡាយបានព្រះរាជទានតំណែងអគ្គមហេសីដល់ស្រីកម្សត់ ឈ្មោះកដ្ឋហារិកា គឺស្រីរកឧស និងព្រះរាជកុមារដែលកើតក្នុងផ្ទៃរបស់ស្រីនោះ ក៏ដល់នូវភាពជាព្រះរាជា ក្នុងនគរពារាណសី ទំហំ ១២ យោជន៍ ទ្រង់ព្រះនាមថា កដ្ឋវាហនៈ ហើយត្រាស់កដ្ឋហារិយជាតក ។

ព្រះរាជាទ្រង់ស្តាប់ព្រះធម្មកថា ទ្រង់ត្រេកអរថា បានឮថា គោត្រខាងបិតាប៉ុណ្ណោះជាសំខាន់ ទើបទ្រង់បញ្ជាឲ្យព្រះរាជទានគ្រឿងបរិហារអំពីមុននោះ ដល់មាតា និងបុត្រ ។

ភរិយារបស់ពន្ធុលសេនាបតី ឈ្មោះមល្លិកា ជាធីតារបស់ស្តេចមល្លៈក្នុងកុសិនារានគរ មិនមានបុត្រអស់កាលយូរ ។ តមក ពន្ធុលសេនាបតីបញ្ជូននាងទៅថា ចូរនាងទៅកាន់ផ្ទះនៃត្រកូលរបស់ខ្លួនចុះ នាងគិតថា អញនឹងគាល់ព្រះសាស្តាហើយសឹមទៅ ទើបចូលទៅកាន់វត្តជេតពន ឈរថ្វាយបង្គំព្រះដ៏មានព្រះភាគ ។ កាលព្រះសាស្តាត្រាស់សួរថា នាងនឹងទៅក្នុងទីណា ក៏ក្រាបទូលថា បពិត្រព្រះអង្គ ស្វាមីបញ្ជូនខ្ញុំម្ចាស់ទៅកាន់ផ្ទះនៃត្រកូល ព្រះសាស្តាត្រាស់ថា ព្រោះហេតុអ្វី នាងពោលថា ព្រោះខ្ញុំម្ចាស់ជាស្រីអារមិនមានបុត្រ ព្រះសាស្តាត្រាស់ថា បើយ៉ាងនោះ កិច្ច គឺការទៅមិនមាន ចូរនាងត្រឡប់ចុះ ។ នាងសប្បាយចិត្ត ថ្វាយបង្គំព្រះសាស្តាត្រឡប់ទៅកាន់និវេសន៍ កាលប្តីសួរថា ត្រឡប់មកធ្វើអ្វី ឆ្លើយថា ព្រះទសពលឲ្យខ្ញុំត្រឡប់

ពន្ធុលៈគិតថា ព្រះសាស្ដាទ្រង់ឃើញហេតុឆ្ងាយ នឹងជាហេតុនេះទើបទទួល ។ មិនយូរប៉ុន្មាន នាងក៏មានគភ៌ កើតនូវការចាញ់ផ្ទៃ ប្រាប់ថា ការចាញ់ផ្ទៃកើតហើយដល់ខ្ញុំ ពន្ធុលៈពោលថា នាងចាញ់ផ្ទៃដូចម្ដេច នាងពោលថា ខ្ញុំប្រាថ្នានឹងចុះងូត ហើយផឹកទឹកដែលគួរផឹកក្នុងស្រះបោក្ខរណី ដែលជាមង្គលក្នុងការងារអភិសេកនៃគណៈរាជត្រកូលក្នុងនគរវេសាលី ។ ពន្ធុលៈពោលថា សាធុ ហើយកាន់ធ្នូ ដែលបុគ្គលគប្បីយឹតដោយកម្លាំងរបស់បុរស ១ ពាន់ បីនាងឡើងរថ ចេញអំពីក្រុងសាវត្ថី បររថចូលទៅកាន់ក្រុងវេសាលី ដោយទ្វារដែលស្ដេចលិច្ឆវី ឲ្យដល់មហាលិលិច្ឆវី ។

លំនៅអាស្រ័យរបស់ស្ដេចលិច្ឆវី ឈ្មោះមហាលិ មាននៅក្បែរទ្វារនោះឯង គ្រាន់តែបានឮសំឡេងប៉ះនឹងធរណីទ្វារក៏ដឹងថា សំឡេងរថរបស់ពន្ធុលៈ ពោលថា ថ្ងៃនេះ ភ័យនឹងកើតដល់ស្ដេចលិច្ឆវី ។

ការរក្សាស្រះបោក្ខរណីតឹងរ៉ឹង ទាំងខាងក្នុង និងខាងក្រៅ ខាងលើសន្ធឹងដោយសំណាញ់ដែក សូម្បីតែបក្សី ក៏មិនមានឱកាស ។

ចំណែកពន្ធុលសេនាបតីចុះអំពីរថ វាយពួកមនុស្សអ្នកយាមដោយផ្ដៅឲ្យគេចទៅ ហើយកាត់សំណាញ់ដែកឲ្យករិយាចុះងូតហើយ សូម្បីខ្លួនឯងក៏ងូតខាងក្នុងស្រះបោក្ខរណីហើយ បីនាងឡើងរថ ចេញអំពីព្រះនគរបរទៅដោយផ្លូវដែលមកហើយនោះឯង ។

ពួកក្មាក់ងារអ្នករក្សា ទូលរឿងដល់ស្ដេចលិច្ឆវី ស្ដេចលិច្ឆវីពិរោធ ទ្រង់ឡើងរថ ៥០០ គ្រឿង បរចេញទៅដោយចេតនាថា នឹងចាប់ខ្លួនពន្ធុលមល្លៈ

បានប្រាប់រឿងនោះដល់មហាលិ ។

ស្តេចមហាលិត្រាស់ថា ពួកអ្នកកុំយាងទៅ ពន្ធុលៈនោះនឹងសម្លាប់អ្នកទាំងអស់ សូម្បីស្តេចលិច្ឆវីក៏នៅតែត្រាស់ថា ពួកយើងនឹងទៅឲ្យបាន ។ ស្តេចមហាលិត្រាស់ថា បើដូច្នោះ ពួកទ្រង់ឃើញកង់រថលិចចុះក្នុងផែនដីដល់ដុំហើយ គប្បីយាងត្រឡប់ បើមិនត្រឡប់អំពីនោះ នឹងបានឮសំឡេងដូចអសនីបាត គឺរន្ទះនៅខាងមុខ គប្បីត្រឡប់អំពីទីនោះ បើមិនត្រឡប់អំពីនោះ កាលណាឃើញប្រហោងក្នុងចន្ទោលរថរបស់ពួកអ្នក គប្បីត្រឡប់អំពីទីនោះ កុំទៅខាងមុខដាច់ខាត ។

ស្តេចលិច្ឆវីទាំងនោះ មិនត្រឡប់តាមពាក្យរបស់មហាលិ នាំគ្នាដេញតាមពន្ធុលៈទៅ នាងមល្លិកាឃើញហើយពោលថា នែអ្នក រថទាំងឡាយរមែងប្រាកដ ពន្ធុលៈពោលថា បើដូច្នោះ ក្នុងកាលណារថប្រាកដជួរតែមួយ នាងគប្បីប្រាប់ខ្ញុំ ។

ក្នុងកាលរថទាំងឡាយប្រាកដហាក់ដូចតែមួយ ទើបនាងប្រាប់ថា នែអ្នក ចន្ទោលរថប្រាកដតែមួយហើយ ពន្ធុលៈពោលថា បើដូច្នោះ ចូរនាងចាប់ខ្សែទាំងនេះ ហើយឲ្យខ្សែដល់នាង ឈរត្រង់កណ្តាលរថ ទាញធ្នូឡើង កង់រថលិចចុះក្នុងផែនដីដល់ដុំ ស្តេចលិច្ឆវីទ្រង់ឃើញទីនោះហើយ ក៏នៅតែទៅ ពន្ធុលៈទៅបានបន្តិច ក៏លែងខ្សែធ្នូ សំឡេងធ្នូនោះលាន់ហាក់បីដូចអសនីបាត ស្តេចលិច្ឆវីទាំងនោះ ក៏មិនត្រឡប់អំពីទីនោះ នៅតែដេញតាមទៅនោះឯង ។

ពន្ធុលៈឈរលើរថនោះឯង បាញ់ព្រួញមួយទៅ ព្រួញនោះធ្វើចន្ទោល

រថ ៥០០ ឲ្យធ្លុះហើយ ទម្លុះព្រះរាជា ៥០០ ក្នុងទីដែលចងក្រោះ ហើយលិច ចុះទៅក្នុងផែនដី ។

ស្តេចលិច្ឆវីទាំងនោះ មិនដឹងថា ខ្លួនត្រូវសរទម្លុះហើយ ត្រាស់ថា រ៉ៃយ ឈប់សិន រ៉ៃយ ឈប់សិន នៅតែដេញតាមនោះឯង ។ ពន្ធុលសេនាបតី បញ្ឈប់រថហើយ ពោលថា ពួកអ្នកជាមនុស្សស្លាប់ ឈ្មោះថា ការច្បាំង របស់ខ្ញុំជាមួយមនុស្សស្លាប់ទាំងឡាយ មិនមាន ស្តេចលិច្ឆវីពោលថា ឈ្មោះ ថា មនុស្សស្លាប់មិនមែនមានសភាពដូចយើង ពន្ធុលៈពោលថា បើដូច្នោះ ចូរពួកអ្នកស្រាយក្រោះរបស់មនុស្ស ដែលនៅក្រោយគេបង្អស់មើលចុះ ។ ពួកស្តេចលិច្ឆវីទាំងនោះឲ្យស្រាយហើយ ស្តេចលិច្ឆវីអង្គនោះ ក៏ដួលចុះអស់ ជីវិត ក្នុងខណៈស្រាយក្រោះចេញហើយនោះឯង ។ ខណៈនោះ ទើបពន្ធុលៈ ពោលនឹងស្តេចលិច្ឆវីទាំងនោះថា ពួកអ្នកទាំងអស់ក៏ដូចគ្នា យាងទៅផ្ទះរៀងៗ ខ្លួនហើយ សឹមរៀបចំវត្ថុដែលគួររៀបចំ ប្រៀនប្រដៅប្រពន្ធកូន ហើយសឹម ស្រាយក្រោះចេញ ។ ស្តេចលិច្ឆវីទាំងនោះ ធ្វើយ៉ាងនោះគ្រប់ៗ អង្គ ក៏អស់ ជីវិតហើយ ។

ចំណែកពន្ធុលៈនាំនាងមល្លិកាមកកាន់ក្រុងសាវត្ថី នាងប្រសូតបុត្រភ្លោះ ដល់ទៅ ១៦ ដង ។ សូម្បីកូនរបស់នាងទាំងអស់ បានជាអ្នកក្លៀវក្លា ដល់ ព្រមដោយកម្លាំង សុទ្ធសឹងសម្រេចសិប្បៈទាំងអស់ ។ កូនទីមួយៗ មាន បុរសមួយពាន់ជាបរិវារ ។ លានព្រះរាជវាំងពេញទៅដោយកូនទាំងនោះឯង ដែលទៅរាជនិវេសន៍ជាមួយបិតា ។

ថ្ងៃមួយ ពួកមនុស្សចាញ់ក្ដីកោងក្នុងការវិនិច្ឆ័យ ឃើញពន្ធុលៈកំពុងដើរមក ក៏ទ្រហោយំ ប្រាប់ការធ្វើក្ដីកោងរបស់ពួកអមាត្យអ្នកវិនិច្ឆ័យ ដល់ពន្ធុលៈនោះ ។ ពន្ធុលៈទៅកាន់រោងវិនិច្ឆ័យនោះហើយ បានធ្វើបុគ្គលជាម្ចាស់របស់នោះឯង ឲ្យជាម្ចាស់របស់ មហាជនឲ្យសាធុការប្រព្រឹត្តទៅដោយសំឡេងខ្លាំងអឺងកង ។

ព្រះរាជាទ្រង់ស្ដាប់សំឡេងនោះត្រាស់សួរថា នេះសំឡេងអ្វី កាលទ្រង់ជ្រាបរឿងនោះហើយ ទ្រង់សោមនស្ស ឲ្យដកពួកអមាត្យទាំងអស់នោះ ទ្រង់ប្រគល់ការវិនិច្ឆ័យដល់ពន្ធុលៈប៉ុណ្ណោះ ។ តាំងអំពីនោះមក ពន្ធុលៈក៏វិនិច្ឆ័យដោយត្រឹមត្រូវ ។ ចាប់តាំងអំពីថ្ងៃនោះមក ពួកអមាត្យអ្នកវិនិច្ឆ័យជំនាន់ចាស់មិនបានថ្លៃឈ្នួល រកចំណូលបានតិច ញុះញង់ក្នុងរាជត្រកូលថា ពន្ធុលៈប្រាថ្នាជាព្រះរាជា ។

ព្រះរាជាទ្រង់ជឿពាក្យរបស់អមាត្យទាំងនោះ មិនអាចសង្កត់ព្រះហឫទ័យបាន ទ្រង់ព្រះតម្រិះថា បើពន្ធុលៈត្រូវសម្លាប់ក្នុងទីនេះឯង ការនិន្ទាក៏នឹងកើតឡើងដល់អញ ទ្រង់បញ្ជាឲ្យបុរសដែលតែងតាំង វាយដណ្ដើមបច្ចន្តនគរ ហើយត្រាស់ឲ្យហៅពន្ធុលៈមក ទ្រង់បញ្ជូនទៅដោយព្រះតម្រាស់ថា បានឮថា ជនបទជាយដែនចោរបះបោរឡើង អ្នក ព្រមទាំងបុត្រ ចូរទៅចាប់ចោរមក ហើយទ្រង់បញ្ជូននាយទាហានដែលជាធំ ដែលមានសមត្ថភាពពួកដទៃទៅជាមួយពន្ធុលៈសេនាបតីនោះ ដោយព្រះតម្រាស់ថា ពួកអ្នកចូរកាត់ក្បាលពន្ធុលសេនាបតី ព្រមទាំងកូន ៣២ នាក់ ក្នុងទីនោះ ហើយនាំមក ។

កាលពន្ធុលៈនោះដល់ជនបទជាយដែន ពួកចោរដែលព្រះរាជាទ្រង់រៀបចំពោលថា បានឮថា លោកសេនាបតីមកហើយ នាំគ្នាគេចអស់ទៅ ។

ពន្ធុលសេនាបតីនោះ ញុំាំងបទេសនោះឲ្យស្ងប់ស្ងាប់ហើយ ក៏ត្រឡប់មក ។ លំដាប់នោះ ទាហានទាំងនោះក៏កាត់ក្បាលពន្ធុលសេនាបតី មួយអន្លើដោយកូនទាំងអស់ ក្នុងទីជិតព្រះនគរ ។

ថ្ងៃនោះ នាងមល្លិកាទេវី និមន្តអគ្គសាវកទាំងពីរ មួយអន្លើដោយភិក្ខុ ៥០០ ។ ក្នុងពេលព្រឹក ពួកមនុស្សបាននាំសំបុត្រមកឲ្យនាង ដែលមានសេចក្ដីថា ចោរកាត់ក្បាលប្ដី ព្រមទាំងកូនរបស់នាង នាងដឹងរឿងនោះហើយមិនប្រាប់ដល់បុគ្គលណាម្នាក់ បត់សំបុត្រដាក់ក្នុងថ្នក់សំពត់ អង្គាសភិក្ខុសង្ឃរឿយៗ ទៅ ។

ខណៈនោះ អ្នកបម្រើរបស់នាង ប្រគេនភត្តដល់ភិក្ខុហើយ នាំថាសសប្បិមក ធ្វើថាសបែកត្រង់ចំពោះមុខព្រះថេរៈ ព្រះធម្មសេនាបតីពោលថា របស់មានការបែកធ្លាយជាធម្មតា ក៏បែកទៅហើយ បុគ្គលណាម្នាក់មិនគួរគិត ។

នាងមល្លិកានោះ នាំយកសំបុត្រចេញអំពីថ្នក់ ប្រាប់ព្រះថេរៈថា គេនាំសំបុត្រនេះមកដល់ខ្ញុំ ដែលមានសេចក្ដីថា ពួកចោរកាត់ក្បាលឪពុក ព្រមទាំងកូន ៣២ នាក់ ខ្ញុំស្ដាប់រឿងនេះហើយក៏មិនគិត គ្រាន់តែថាសសប្បិបែក ខ្ញុំនឹងគិតដូចម្ដេច ។ ព្រះធម្មសេនាបតីពោលពាក្យជាដើមថា

ជីវិតរបស់សត្វទាំងឡាយ ក្នុងលោកនេះ មិនមាននិមិត្ត បុគ្គលណាមួយក៏កំណត់មិនបាន ខ្វះខាតផង មានប្រមាណតិចផង ជីវិត

នោះ ប្រកបដោយទុក្ខ ។

សម្តែងធម៌ស្រេចហើយ ក្រោកអំពីអាសនៈ បានទៅវិហារហើយ ។ ចំណែកនាងមល្លិកា បានហៅកូនប្រសាទាំង ៣២ នាក់ មកហើយ ប្រៀនប្រដៅថា ប្តីរបស់ពួកនាងមិនមានការខុស បានទទួលផលកម្មពីជាតិមុនរបស់ខ្លួន អ្នកទាំងឡាយកុំសោយសោក កុំបរិទេវនាការ កុំធ្វើការចងចិត្តអាក់អន់លើព្រះរាជា ។

ចារបុរសរបស់ព្រះរាជា ស្តាប់ពាក្យនោះហើយ ក្រាបទូលកាពដែលជនទាំងនោះ មិនមានទោសចំពោះព្រះរាជា ព្រះរាជាទ្រង់ដល់នូវការសង្វេគ យាងទៅកាន់និវេសន៍នាងមល្លិកានោះ ឲ្យនាងមល្លិកា និងកូនប្រសារបស់នាងអត់ទោសហើយ បានព្រះរាជទានពរដល់នាងមល្លិកា នាងក្រាបទូលថា ពរព្រះអង្គខ្ញុំម្ចាស់គ្រាន់តែទទួលទៅចុះ ។ កាលព្រះរាជាយាងទៅហើយ ថ្វាយកត្តដើម្បីអ្នកស្លាប់ ងូតទឹកហើយ ចូលគាល់ព្រះរាជាទូលថា បពិត្រព្រះអង្គ ទ្រង់ប្រទានពរដល់ខ្ញុំម្ចាស់ហើយ ម្យ៉ាងទៀត ខ្ញុំម្ចាស់មិនត្រូវការដោយរបស់ដទៃ សូមទ្រង់អនុញ្ញាតឲ្យកូនប្រសា ៣២ នាក់របស់ខ្ញុំម្ចាស់ និងខ្លួនខ្ញុំម្ចាស់ត្រឡប់ទៅកាន់ផ្ទះនៃត្រកូលចុះ ។

ព្រះរាជាទ្រង់ទទួលហើយ ។ នាងមល្លិកាបញ្ជូនកូនប្រសា ៣២ នាក់ទៅកាន់ត្រកូល រៀងៗ ខ្លួន ដោយខ្លួនឯង ចំណែកនាងបានទៅកាន់ផ្ទះនៃត្រកូលរបស់ខ្លួនក្នុងកុសិនារានគរ ។

ចំណែកព្រះរាជាបានព្រះរាជទានតំណែងសេនាបតី ដល់ទីឃការាយនៈ

ដែលត្រូវជាក្មួយរបស់ពន្ធុលសេនាបតី ។

ទីឃការាយនៈនោះ គ្រាច់ស្វែងរកទោសរបស់ព្រះរាជាដោយគិតថា អំ របស់អញត្រូវព្រះរាជាអង្គនេះឲ្យស្លាប់ហើយ ។ បានឮថា ចាប់តាំងអំពីពន្ធុលៈ មិនមានកំហុសត្រូវសម្លាប់ហើយ ព្រះរាជាទ្រង់មានវិប្បដិសារៈ មិនបានទទួល នូវការសប្បាយព្រះហឫទ័យ មិនបានសោយសុខក្នុងរាជសម្បត្តិឡើយ ។

គ្រានោះ ព្រះសាស្តា ទ្រង់អាស្រ័យនិគមឈ្មោះមេទលុបៈ របស់ពួក ស្តេចសក្យៈគង់នៅ ព្រះរាជាយាងទៅទីនោះហើយ ទ្រង់ឲ្យបោះព្រះពន្លាក្នុងទី មិនឆ្ងាយអំពីអារាម ហើយយាងទៅវិហារដោយបរិវារច្រើន ដោយទ្រង់ព្រះ តម្រិះថា នឹងថ្វាយបង្គំព្រះដ៏មានព្រះភាគ ព្រះរាជទានគ្រឿងរាជកកុធភណ្ឌទាំង ៥ ដល់ទីឃការាយនៈហើយ ទ្រង់យាងមួយព្រះអង្គឯងប៉ុណ្ណោះ ចូលកាន់ ព្រះគន្ធកុដិ ។ គប្បីជ្រាបរឿងទាំងអស់ ដោយទំនងនៃធម្មចេតិយសូត្រ កាល ទ្រង់យាងចូលកាន់ព្រះគន្ធកុដិហើយ ទើបទីឃការាយនៈកាន់យកគ្រឿងរាជ-កកុធភណ្ឌទាំងនោះ ធ្វើវិឌូឌភៈឲ្យជាព្រះរាជា បន្សល់នូវសេះមួយ និងស្រី បម្រើម្នាក់ ហើយបានត្រឡប់ទៅកាន់ក្រុងសាវត្ថី ។

ព្រះរាជាត្រាស់បិយកថាជាមួយព្រះសាស្តាហើយ ទ្រង់យាងចេញ ទ្រង់ មិនឃើញសេនា ទើបត្រាស់សួរស្រីនោះ ទ្រង់ស្តាប់រឿងនោះហើយ ទ្រង់ព្រះ តម្រិះថា អញនឹងនាំក្មួយរបស់អញទៅចាប់វិឌូឌភៈ ដូច្នេះហើយ យាងទៅកាន់ ក្រុងរាជគ្រឹះ ដល់ព្រះនគរ កាលព្រះនគរត្រូវគេបិទហើយក្នុងវេលាវិកាល ផ្ទំ ហើយក្នុងសាលាមួយកន្លែង ទ្រង់នឿយព្រះកាយពល ព្រោះខ្យល់ និងកម្តៅ

ថ្ងៃ បានសោយទិវង្គតក្នុងទីនោះឯង ក្នុងកណ្ដាលរាត្រី ។ កាលរាត្រីអស់ហើយ មហាជនបានឮសំឡេងស្រីនោះយំសោកថា បពិត្រព្រះសម្មតិទេព ជាធំនៃអ្នកកោសល ទ្រង់មិនមានទីពឹងហើយ ទើបក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាទ្រង់ទទួល ឲ្យធ្វើសរីរកិច្ចរបស់ម្ចាស់អាំដោយសក្ការៈដ៏ធំ ។

ព្រះបាទវិឌូឌភៈបានរាជសម្បត្តិហើយ ទ្រង់រឭកដល់ពៀរនោះ ទ្រង់ព្រះតម្រិះថា អញនឹងញ៉ាំងស្ដេចសក្យៈទាំងអស់ឲ្យស្លាប់ ដូច្នេះហើយ ទើបយាងចេញទៅដោយសេនាធំ ។ ក្នុងថ្ងៃនោះ ព្រះសាស្ដាទ្រង់ប្រមើលមើលលោកក្នុងពេលទៀបភ្លឺ ទ្រង់ឃើញការវិនាសនៃពួកញាតិហើយ ទ្រង់ព្រះតម្រិះថា តថាគតគួរធ្វើញាតិសង្គហៈ ក្នុងវេលាព្រឹកទ្រង់ត្រាច់ទៅដើម្បីបិណ្ឌបាត ត្រឡប់អំពីបិណ្ឌបាតហើយ ទ្រង់សម្រេចសីហសេយ្យាក្នុងព្រះគន្ធកុដិ ក្នុងពេលល្ងាចទ្រង់យាងទៅតាមអាកាស ប្រថាប់ត្រង់គល់ឈើដែលមិនមានម្លប់ ជិតក្រុងកបិលពស្ដុ ។ បន្ទាប់អំពីនោះទៅ មានដើមជ្រៃធំ មានម្លប់ត្រឈឹងត្រឈៃមួយដើម នៅក្នុងរជ្ជសីមារបស់ព្រះបាទវិឌូឌភៈ ។ ព្រះបាទវិឌូឌភៈ ទតឃើញព្រះសាស្ដា ទើបយាងចូលទៅគាល់ ថ្វាយបង្គំហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុអ្វី ទើបទ្រង់ប្រថាប់គង់ហើយ ត្រង់គល់ឈើដែលមានម្លប់សើងរើងនេះ ក្នុងវេលាក្ដៅបែបនេះ សូមទ្រង់ប្រថាប់គង់ត្រង់គល់ជ្រៃ ដែលមានម្លប់ត្រជាក់ល្អនេះចុះ ។ កាលព្រះសាស្ដាត្រាស់ឆ្លើយថា មហាបពិត្រ ណ្ហើយចុះ ឈ្មោះថា ម្លប់របស់ពួកញាតិ ជារបស់ត្រជាក់ ទើបព្រះរាជាទ្រង់ព្រះតម្រិះថា ព្រះសាស្ដាទ្រង់យាងមកដើម្បីបំណាងរក្សាពួកញាតិ

ទើបថ្វាយបង្គំព្រះសាស្តា យាងត្រឡប់ចូលកាន់ក្រុងសាវត្ថីនោះឯង ។ សូម្បីព្រះសាស្តាក៏ទ្រង់ហោះទៅកាន់វត្តជេតពនដូចគ្នា ។ ព្រះរាជាទ្រង់រឭកដល់ទោសស្តេចសក្យៈ យាងចេញទៅហើយក្នុងលើកទី ២ ទតឃើញព្រះសាស្តាក្នុងទីនោះឯង ក៏យាងត្រឡប់ទៀត ។ ទ្រង់យាងទៅក្នុងលើកទី ៣ ទតឃើញព្រះសាស្តាក្នុងទីនោះឯង ក៏យាងត្រឡប់ ។ តែកាលព្រះបាទវិឌូឌភៈនោះយាងចេញទៅក្នុងគ្រាទី ៤ ព្រះសាស្តា ទ្រង់ពិចារណាឃើញបុព្វកម្មរបស់សក្យៈទាំងឡាយ ទ្រង់ជ្រាបភាពដែលកម្មលាមក គឺការបាចថ្នាំពុលក្នុងស្ទឹងរបស់ស្តេចសក្យៈទាំងនោះ ជាកម្មដែលបុគ្គលណាម្នាក់ មិនអាចឃាត់បានមិនបានយាងចេញទៅក្នុងលើកទី ៤ ព្រះបាទវិឌូឌភៈយាងចេញទៅហើយដោយពលធំ ដោយត្រិះរិះថា អញនឹងសម្លាប់ស្តេចសក្យៈ ។

ព្រះញាតិទាំងឡាយរបស់ព្រះសម្មាសម្ពុទ្ធ ជាអ្នកមិនសម្លាប់សត្វ សូម្បីស្លាប់ ក៏មិនផ្តាច់ជីវិតរបស់សត្វដទៃ ។

សក្យៈទាំងនោះគិតថា ពួកយើងហ្វឹកហាត់ដៃហើយ មានគ្រឿងចង់សឹកដែលធ្វើហើយ ជាអ្នកមានថ្វីដៃច្រើន តែពួកយើងមិនអាចសម្លាប់សត្វដទៃឲ្យឃ្លាតចាកជីវិតបាន ពួកយើងនឹងសម្តែងកម្មរបស់ខ្លួនឲ្យគេចទៅ ។ស្តេចសក្យៈទាំងនោះទ្រង់មានគ្រឿងក្រោះដែលធ្វើហើយ ទើបយាងចេញធ្វើការប្រយុទ្ធ ។ ព្រួញដែលស្តេចសក្យៈទាំងនោះបាញ់ទៅ ទៅតាមចន្លោះៗ ពួកបុរសរបស់ព្រះបាទវិឌូឌភៈ ចេញទៅតាមប្រហោងខែល និងប្រឡោះត្រចៀកជាដើម ព្រះបាទវិឌូឌភៈទតឃើញ ទើបត្រាស់ថា អ្នកទាំងឡាយ ស្តេចសក្យៈត្រាស់ថា ពួក

យើងជាអ្នកមិនសម្លាប់សត្វមិនមែនឬ កាលបើដូច្នេះ ហេតុអ្វី ទើបពួកស្តេចសក្យៈបាញ់បុរសរបស់ពួកយើងឲ្យវិនាស ។ លំដាប់នោះ បុរសម្នាក់ក្រាបទូលព្រះបាទវិឌូឌភៈនោះថា បពិត្រព្រះអង្គ ព្រះអង្គទ្រង់ពិនិត្យមើលហើយឬ ព្រះបាទវិឌូឌភៈត្រាស់ថា ពួកស្តេចសក្យៈញុំាងបុរសរបស់យើងឲ្យវិនាស ។ ពួកបុរសពោលថា បុរសណាម្នាក់របស់ព្រះអង្គ ឈ្មោះថា ស្លាប់ហើយមិនមាន សូមទ្រង់ឲ្យរាប់បុរសទាំងនោះចុះ ។

ព្រះបាទវិឌូឌភៈកាលបញ្ជាឲ្យរាប់ ទ្រង់មិនឃើញបាត់ត្រឹមតែម្នាក់ ។ ទ្រង់យាងត្រឡប់អំពីទីនោះហើយត្រាស់ថា នែអ្នក បុគ្គលណាម្នាក់ប្រាប់ថា ពួកយើងជាស្តេចសក្យៈ អ្នកទាំងឡាយ ចូរសម្លាប់អ្នកទាំងអស់នោះ តែចូរឲ្យជីវិតដល់បុគ្គលដែលឈរនៅក្នុងសម្នាក់របស់សក្យមហានាម ដែលជាអយ្យកោរបស់យើង ។

ស្តេចសក្យៈទាំងឡាយ មិនបានឃើញគ្រឿងដែលខ្លួនគប្បីកាន់យក ពួកខ្លះរែកស្មៅ ពួកខ្លះ ឈរកាន់ដើមបបុស ។ ត្រូវសួរថា ពួកអ្នកជាស្តេចសក្យៈ ឬមិនមែន ព្រោះសក្យៈទាំងនោះសូម្បីស្លាប់ ក៏មិនពោលពាក្យកុហក ពួកដែលរែកស្មៅពោលថា មិនមែនសក្យៈ គឺស្មៅ ពួកដែលឈរកាន់ដើមបបុស ពោលថា មិនមែនសក្យៈ គឺបបុស ស្តេចសក្យៈទាំងនោះឯង សក្យៈណាដែលឈរនៅក្នុងសម្នាក់របស់ស្តេចមហានាម បានរួចជីវិតហើយ ។

បណ្តាស្តេចសក្យៈទាំងនោះ ស្តេចសក្យៈដែលរែកស្មៅ ឈ្មោះថា សក្យៈស្មៅ ពួកដែលឈរកាន់ដើមបបុស ឈ្មោះថា សក្យៈបបុស ។

ព្រះបាទវិឌូឌភៈ បញ្ជាឲ្យសម្លាប់សក្យៈដ៏សេសទាំងឡាយ មិនទុកសូម្បីទារកដែលនៅបៅដោះ ញ៉ាំងស្ទឹង គឺឈាមឲ្យហូរទៅ ហើយបញ្ជាឲ្យលាងបន្ទះក្តារអង្គុយ ដោយឈាមក្នុងបំពង់កស្តេចសក្យៈទាំងនោះ ។

សក្យវង្ស ដែលព្រះបាទវិឌូឌភៈចូលទៅកាត់ គឺផ្តាច់វង្សហើយ ដោយអាការយ៉ាងនេះ ។ ព្រះបាទវិឌូឌភៈនោះ បញ្ជាឲ្យចាប់ស្តេចសក្យមហានាមយាងត្រឡប់ហើយ ក្នុងពេលសោយអាហារព្រឹក ទ្រង់ព្រះតម្រិះថា អញនឹងសោយអាហារព្រឹក ដូច្នេះហើយ ទ្រង់ឈប់ក្នុងទីមួយកន្លែង កាលភោជនដែលបុគ្គលនាំចូលទៅហើយ ត្រាស់ឲ្យហៅព្រះអយ្យកោមក ដោយព្រះតម្រាស់ថា នឹងសោយរួមគ្នា ។

តែក្សត្រទាំងឡាយ ទោះបីលះបង់ជីវិត ក៏មិនព្រមសោយរួមជាមួយកូននាងទាសី ព្រោះដូច្នោះ ស្តេចមហានាមទតឃើញស្រះមួយ ទើបត្រាស់ថា ខ្ញុំមានរាងកាយស្មោកគ្រោក ខ្ញុំនឹងងូតទឹក ។ ព្រះបាទវិឌូឌភៈត្រាស់ថា ប្រពៃណាស់ ព្រះអយ្យកោ សូមទ្រង់ស្រង់ចុះ ព្រះបាទមហានាមទ្រង់ព្រះតម្រិះថា វិឌូឌភៈនេះ ទោះបីសម្លាប់អញ ក៏អញមិនបរិភោគរួម ការស្លាប់ឯងរបស់អញប៉ុណ្ណោះប្រសើរជាង ដូច្នេះហើយ ទើបទ្រង់រំសាយសក់ យកមេជើងស៊កចូលទៅក្នុងសក់ ចងឲ្យជាកំណួចត្រង់ចុង ប្រមៀលចុះទៅក្នុងទឹក ។

ចំណែកតេជះ នៃគុណរបស់ស្តេចមហានាមនោះ នាគពិភពក៏សម្តែងអាការក្តៅ ស្តេចនាគពិចារណាថា រឿងអ្វីហ្ន៎ ហើយទើបមកកាន់សម្នាក់របស់ស្តេចមហានាមនោះ ឲ្យស្តេចមហានាមប្រថាប់លើពពារ ហើយយាងទៅកាន់

នាគពិភព ។ ព្រះបាទមហានាមនោះឯង នៅក្នុងភពនាគនោះអស់ ១២ ឆ្នាំ ។

ចំណែកព្រះបាទវិឌូឌភៈ ប្រថាប់គង់រង់ចាំដោយព្រះតម្រិះថា ព្រះអយ្យកោរបស់អញនឹងមកក្នុងឥឡូវនេះ កាលព្រះបាទមហានាមទ្រង់យឺតយូរ ទើបបញ្ជាឲ្យមើលក្នុងស្រះ ពិនិត្យមើលរវាងបុរសដោយពន្លឺប្រទីប មិនឃើញហើយក៏ចៀសចេញទៅ ដោយទ្រង់ព្រះតម្រិះថា ព្រះអយ្យកោយាងទៅហើយ ។

ព្រះបាទវិឌូឌភៈយាងដល់ស្ទឹងអចិរវតីក្នុងពេលរាត្រី បញ្ជាឲ្យបោះព្រះពន្លាហើយ ។ បុគ្គលពួកខ្លះដេកហើយត្រង់ឆ្នេរខ្សាច់ខាងក្នុងស្ទឹង ពួកខ្លះដេកលើគោកខាងក្រៅ ។ បណ្តាជនដែលដេកហើយខាងក្នុង ជនដែលមានបាបកម្មមិនបានធ្វើហើយក្នុងកាលមុនមាន ។ បណ្តាជនដែលដេកហើយខាងលើ ដែលមានបាបកម្មបានធ្វើហើយក្នុងកាលមុនមាន ស្រមោចក្អើងទាំងឡាយប្រាកដឡើងហើយ ក្នុងទីដែលមនុស្សទាំងនោះដេកហើយ ។

ជនទាំងនោះពោលថា ស្រមោចក្រហមប្រាកដឡើងហើយក្នុងទីដែលខ្ញុំដេក ស្រមោចក្រហមប្រាកដឡើងហើយក្នុងទីដែលខ្ញុំដេក ទើបក្រោកឡើង ។ ពួកជនដែលមានបាបកម្មមិនបានធ្វើ ក្រោកឡើងទៅដេកខាងលើគោក ពួកជនមានបាបកម្មបានធ្វើហើយ ចុះទៅដេកលើឆ្នេរខ្សាច់ ។

ខណៈនោះ មហាមេឃតាំងឡើង ញ៉ាំងភ្លៀងធំឲ្យធ្លាក់ហើយ ទឹកជំនន់ហូរមកញ៉ាំងព្រះបាទវិឌូឌភៈ មួយអន្លើដោយបរិស័ទឲ្យដល់សមុទ្រហើយនោះឯង ។ ជនទាំងអស់បានជាចំណីត្រី និងអណ្តើកក្នុងសមុទ្រនោះហើយ ។ មហាជនញ៉ាំងកថាឲ្យតាំងឡើងថា ការស្លាប់របស់ស្តេចសក្យៈទាំងឡាយ មិន

សមគួរសោះ ការស្លាប់នេះ គឺពួកសក្យៈដែលព្រះបាទវិឌូឌភៈវាយហើយ យ៉ាងនេះឲ្យស្លាប់ ទើបមិនសមគួរ ។

ព្រះសាស្តាស្តាប់ពាក្យនោះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការស្លាប់យ៉ាងនេះ មិនសមគួរដល់ស្តេចសក្យៈទាំងឡាយ ក្នុងអត្តភាពនេះ ក៏ពិត តែការស្លាប់ដែលពួកស្តេចសក្យៈទាំងនោះបានហើយ ក៏គួរដោយពិត ដោយអំណាចនៃកម្មលាមក ដែលបានធ្វើក្នុងកាលមុន ។

ភិក្ខុទាំងឡាយពោលថា បពិត្រព្រះអង្គ ស្តេចសក្យៈទាំងឡាយនោះ បានធ្វើកម្មអ្វីក្នុងកាលមុន ព្រះសាស្តាត្រាស់ថា ក្នុងកាលមុន ស្តេចសក្យៈនោះ រួមគ្នាជាពួក បាចថ្នាំពុលក្នុងស្ទឹង ។

ស្អែកឡើង ភិក្ខុទាំងឡាយ ញ៉ាំងកថាឲ្យតាំងឡើងក្នុងរោងធម្មសភាថា ព្រះបាទវិឌូឌភៈញ៉ាំងស្តេចសក្យៈទាំងឡាយ ប្រមាណប៉ុណ្ណេះឲ្យស្លាប់ហើយ យាងមក កាលមនោរថរបស់ខ្លួនដល់ទីបំផុតហើយនោះឯង នាំជនមាន ប្រមាណប៉ុណ្ណោះទៅ កើតជាចំណីនៃត្រី និងអណ្តើកក្នុងសមុទ្រហើយ ។

ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងនោះទូលថា ដោយកថា ឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលមនោរថរបស់សត្វទាំង នោះ មិនដល់ទីបំផុតនោះឯង មច្ចុរាជផ្តាច់ជីវិតិន្ទ្រិយហើយ ឲ្យលិចចុះក្នុង មហាសមុទ្រ គឺអបាយ ៤ ដូចជំនន់ទឹកធំកួចអ្នកស្រុកដែលដេកលក់ដូច្នោះ ដូច្នេះហើយ ទើបទ្រង់ត្រាស់គាថានេះថា

**បុប្ផានិ ហេវ បចិនន្តំ ព្យាសត្តមនសំ នរំ**
**សុត្តំ គាមំ មហោឃោវ មច្ចុ អាទាយ គច្ឆតិ ។**

*មច្ចុ គឺសេចក្ដីស្លាប់ តែងកៀរយកទៅនូវនរជន អ្នកមានចិត្តជាប់ជំពាក់ ក្នុងអារម្មណ៍ផ្សេងៗ កំពុងជ្រើសរើសនូវផ្កា គឺកាមគុណ ៥ នោះឯង ដូចទឹកជំនន់ធំ ដែលកួចយកអ្នកស្រុក កំពុងដេកលក់ទៅ ដូច្នោះឯង ។*

## សេចក្ដីអធិប្បាយ

*បណ្ដាបទទាំងនោះ បាទព្រះគាថាថា* **ព្យាសត្តមនសំ នរំ** *សេចក្ដីថា បុគ្គលមានចិត្តជាប់ជំពាក់ហើយ ក្នុងអារម្មណ៍ដែលដល់ព្រមហើយ ឬមិនទាន់ដល់ព្រម ។*

*ព្រះដ៏មានព្រះភាគ ត្រាស់ពាក្យអធិប្បាយនេះថា នាយមាលាការចូលទៅកាន់សួនផ្កា គិតថា នឹងបេះផ្កាទាំងឡាយ ហើយមិនបេះយកផ្កាអំពីក្នុងសួននោះ ប្រាថ្នាគុម្ពដទៃៗ ឈ្មោះថា បញ្ជូនចិត្តទៅក្នុងសួនផ្កាទាំងអស់ ឬគិតថា អញនឹងបេះផ្កាអំពីគុម្ពនេះ ហើយមិនបេះយកផ្កាអំពីគុម្ពនោះ បញ្ជូនចិត្តទៅក្នុងទីដទៃ ជ្រើសរើសនូវគុម្ពឈើនោះឯង ឈ្មោះថា ដល់នូវការប្រមាទ យ៉ាងណា នរៈពួកខ្លះក៏ដូច្នោះដូចគ្នា ឈមចុះក្នុងកណ្ដាលកាមគុណ ៥ ដូចគ្នានឹងសួនផ្កា បានរូបដែលគាប់ចិត្តហើយ ប្រាថ្នាក្លិន រស ផោដ្ឋព្វៈ ដែលជាទីពេញចិត្តណាមួយ ឬបានបណ្ដាអារម្មណ៍ មានសំឡេងជាដើមនោះណាមួយហើយ គង់ប្រាថ្នាអារម្មណ៍ណាមួយទៀត ឬបានរូបនោះឯងហើយ*

គន់ប្រាថ្នាអារម្មណ៍ណាមួយ ឈ្មោះថា រមែងត្រេកអរក្នុងអារម្មណ៍នោះឯង ឬបានបណ្ដាអារម្មណ៍ មានសំឡេងជាដើមណាមួយ ហើយប្រាថ្នាអារម្មណ៍ណាមួយ ឈ្មោះថា រមែងត្រេកអរក្នុងអារម្មណ៍ដែលខ្លួនបានហើយនោះ ។ ក្នុងសវិញ្ញាណកទ្រព្យ និងអវិញ្ញាណកទ្រព្យ មានគោ ក្របី ទាសី ទាសៈ ស្រែ ចម្ការ ស្រុក និគម និងជនបទជាដើម ក៏មានន័យនោះឯង ។ ក្នុងបរិវេណវិហារ និងបច្ច័យ មានបាត្រ និងចីវរជាដើម របស់បព្វជិត ក៏ន័យនោះដូចគ្នា មច្ចុ រមែងនាំនរជនដែលមានចិត្តជាប់ជំពាក់ក្នុងកាមគុណ ដែលដល់ព្រមហើយ ឬមិនទាន់ដល់ព្រមហើយ ដែលកំពុងជ្រើសរើសនូវផ្កាពោល គឺកាមគុណ ៥ យ៉ាងនេះ ដោយប្រការដូច្នេះ ។

ពីរបទថា **សុត្តំ គាមំ** សេចក្ដីថា ឈ្មោះថា ការដេកលក់ដោយអំណាច ការដេកលក់នៃទព្វសម្ភារៈទាំងឡាយ មានជញ្ជាំងផ្ទះជាដើមនៃស្រុក មិនមាន តែស្រុក ឈ្មោះថា លក់ហើយ ព្រោះប្រៀបធៀបភាពដែលសត្វទាំង-ឡាយជាអ្នកប្រមាទហើយ ហាក់ដូចជាដេកលក់ហើយ មច្ចុនាំនរជនទៅ ដូចជំនន់ទឹកធំ និងជម្រៅ ២-៣ យោជន៍ កួចអ្នកស្រុកដែលដេកលក់ហើយយ៉ាងនោះទៅដូច្នោះ គឺថា ជំនន់ទឹកធំនោះ ញុំាងអ្នកស្រុកទាំងអស់នោះ មិនឲ្យសត្វណាម្នាក់ ក្នុងបណ្ដាស្ត្រី បុរស គោ ក្របី និងមាន់ជាដើម ឲ្យសល់មួយ ឲ្យដល់មហាសមុទ្រហើយ ធ្វើឲ្យជាចំណីរបស់ត្រី និងអណ្ដើក យ៉ាងណា មច្ចុរាជ គឺសេចក្ដីស្លាប់ នាំនរៈដែលមានចិត្តជាប់ជំពាក់ហើយ ក្នុងអា-រម្មណ៍ផ្សេងៗ គឺកាត់នូវជីវិតិន្ទ្រិយរបស់នរៈនោះ ឲ្យលិចចុះក្នុងសមុទ្រ គឺ

អបាយទាំង ៤ ក៏ដូច្នេះដូចគ្នា ។ ក្នុងកាលចប់ទេសនា មហាជនបាន សម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមហើយ ទេសនា មានប្រយោជន៍ដល់មហាជនដូច្នេះឯង ៕

**រឿង ព្រះថានវិនូឌកៈ ចប់**

# រឿង នាងបតិបូជិកា

## លំនាំដើម

ព្រះមានព្រះភាគ កាលគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធស្រីឈ្មោះ បតិបូជិកា ត្រាស់ព្រះធម្មទេសនានេះថា **បុប្ផានិ ហេវ** ជាដើម ។ រឿងកើត ឡើងក្នុងតាវត្តិង្សទេវលោក ។

បានឮថា ទេវបុត្រឈ្មោះមាលាភេរី ក្នុងតាវត្តិង្សទេវលោកនោះ មាន ស្រីទេពអប្សរមួយពាន់ចោមរោមហើយ ទៅកាន់ឧទ្យាន ។ ទេពធីតា ៥០០ ឡើងកាន់ដើមឈើ ញ៉ាំងផ្កាឲ្យធ្លាក់ចុះ ទេពធីតា ៥០០ រើសយកផ្កាដែល ទេពធីតា ៥០០ នោះឲ្យធ្លាក់ហើយ ប្រដាប់ទេវបុត្រ ។ បណ្តាទេពធីតាទាំង នោះ ទេពធីតាមួយអង្គចុតិលើមែកឈើនោះឯង សរីរៈរលត់ទៅដូចអណ្តាត ប្រទីប នាងបដិសន្ធិក្នុងផ្ទះនៃត្រកូលមួយ ក្នុងក្រុងសាវត្ថី ក្នុងកាលដែលនាង កើតហើយ ជាស្រីឮកជាតិបាន រឮកថា អញជាកិរិយារបស់មាលាភេរីទេវ- បុត្រ ដល់នូវការចម្រើន ធ្វើការបូជាដោយគ្រឿងក្រអូប និងផ្កាជាដើម ប្រាថ្នា

ការកើតចំពោះក្នុងសម្នាក់ប្តី សូម្បីនាងទៅកាន់ត្រកូលដទៃ ។ ក្នុងកាលមានអាយុ ១៦ ឆ្នាំ ថ្វាយសលាកភត្ត បក្ខិកភត្ត និងវស្សាវាសិកភត្តជាដើម ហើយ រមែងពោលថា ដោយចំណែកនៃបុណ្យនេះ សូមជាបច្ច័យដើម្បីជាប្រយោជន៍ដល់ការកើតឡើងក្នុងសម្នាក់ប្តីខ្ញុំ ។

លំដាប់នោះ ភិក្ខុទាំងឡាយជ្រាបថា ស្រីនេះក្រោកឡើងស្រេចបាច់ហើយ រមែងប្រាថ្នាប្តីប៉ុណ្ណោះ ទើបដាក់ឈ្មោះថា បតិបូជិកា ។

នាងបតិបូជិកានោះ រមែងបដិបត្តិរោងឆាន់ ចូលទៅតម្កល់ទឹកឆាន់ ក្រាលអាសនៈជានិច្ច ។ មនុស្សពួកដទៃប្រាថ្នាដើម្បីថ្វាយសលាកភត្តជាដើម នាំមកប្រគល់ឲ្យដោយពាក្យថា នៃនាង ចូរនាងចាត់ចែងភត្តនេះដល់ភិក្ខុសង្ឃ នាងដើរទៅដើរមកដោយទំនងនោះ បានកុសលធម៌ ៥៦ គ្រប់ជំហាន នាងមានគភ៌ហើយ នាងក៏ប្រសូតបុត្រដោយកាលកន្លងទៅ ១០ ខែ ។ ក្នុងកាលកូននោះដើរបាន នាងក៏បានកូនដទៃៗ រួមជា ៤ នាក់ ។ ក្នុងថ្ងៃមួយ នាងថ្វាយទានធ្វើការបូជា ស្តាប់ធម៌ រក្សាសិក្ខាបទក្នុងកាលជាទីបំផុតនៃថ្ងៃ ធ្វើកាលកិរិយាដោយរោគឯណានីមួយ ដែលកើតឡើងក្នុងខណៈនោះ ហើយបដិសន្ធិក្នុងសម្នាក់ប្តីរបស់ខ្លួន ។

ចំណែកទេពធីតាក្រៅអំពីនេះ កំពុងប្រដាប់នោះឯង អស់កាលមានប្រមាណប៉ុណ្ណោះ ទេវបុត្រឃើញទេពអប្សរនោះពោលថា នាងបាត់មុខតាំងអំពីព្រឹក នាងទៅទីណា ទេពធីតាពោលថា បពិត្រអ្នក ខ្ញុំចុតិ ទេវបុត្រពោលថា នាងនិយាយអ្វី ទេពធីតាពោលថា សេចក្តីនោះយ៉ាងនេះ ទេវបុត្រ

ពោលថា នាងកើតហើយក្នុងទីណា ទេពធីតាពោលថា កើតក្នុងផ្ទះនៃត្រកូល ក្នុងក្រុងសាវត្ថី ទេវបុត្រពោលថា នាងតាំងនៅក្នុងក្រុងសាវត្ថីនោះ អស់កាលមានប្រមាណប៉ុណ្ណា ទេពធីតាពោលថា បពិត្រអ្នក ខ្ញុំកើតអំពីផ្ទៃមាតា ដោយកាលកន្លងទៅ ១០ ខែ ក្នុងកាលអាយុ ១៦ ឆ្នាំ ទៅកាន់ត្រកូលប្តី ប្រសូតបុត្រ ៤ នាក់ ធ្វើបុណ្យ មានឲ្យទានជាដើម ប្រាថ្នាដល់អ្នក មកកើតហើយក្នុងសម្នាក់របស់អ្នកវិញ ទេវបុត្រពោលថា អាយុរបស់មនុស្ស មានប្រមាណប៉ុនណា ទេពធីតាពោលថា ប្រមាណមួយរយឆ្នាំ ទេវបុត្រពោលថា ប៉ុណ្ណោះឯងឬ ទេពធីតាពោលថា ពិតហើយអ្នក ទេវបុត្រពោលថា ពួកមនុស្សកាន់យកអាយុប្រមាណប៉ុណ្ណោះ កើតហើយ ជាអ្នកប្រមាទ ដូចដេកលក់ ញុំាងកាលឲ្យកន្លងទៅឬ ឬធ្វើបុណ្យ មានទានជាដើម ទេពធីតាពោលថា អ្នកនិយាយអ្វី ពួកមនុស្សប្រមាទជានិច្ច ប្រៀបដូចអាយុរាប់អសង្ខេយ្យកើតហើយ ហាក់បីដូចជាមិនចាស់ មិនស្លាប់ ។

ការសង្វេគជាខ្លាំង បានកើតឡើងដល់មាលាភារីទេវបុត្រថា បានឮថា ពួកមនុស្សកាន់យកអាយុប្រមាណមួយរយឆ្នាំ កើតហើយ ប្រមាទ ដូចដេកលក់ កាលណាហ្ន៎ ទើបផុតចាកទុក្ខបាន ។

១០០ ឆ្នាំរបស់ពួកយើងជា ១ យប់ ១ ថ្ងៃរបស់ពួកទេវតាជាន់តាវត្តិង្ស ៣០ រាត្រីជា ១ ខែ កំណត់ដោយ ១២ ខែ ដោយខែនោះជា ១ ឆ្នាំ ១ ពាន់ឆ្នាំទិព្វដោយឆ្នាំនោះ ជាប្រមាណអាយុរបស់ទេវតាជាន់តាវត្តិង្ស ១ ពាន់ឆ្នាំទិព្វនោះ ដោយការរាប់ក្នុងមនុស្សជា ៣ កោដិ ៦ លានឆ្នាំ ។

ព្រោះដូច្នោះ ១ ថ្ងៃរបស់ទេវបុត្រនោះ ក៏មិនទាន់កន្លងទៅ ប្រៀបដូចកាលមួយសន្ទុះប៉ុណ្ណោះ ។ ឈ្មោះថា ការប្រមាទរបស់សត្វដែលមានអាយុតិចបែបនេះ មិនគួរយ៉ាងក្រៃលែង ដូច្នេះ ។

ក្នុងថ្ងៃស្អែកឡើង ពួកភិក្ខុចូលទៅកាន់ស្រុក ឃើញរោងឆាន់មិនទាន់រៀបចំអាសនៈ មិនទាន់ក្រាល ទឹកឆាន់មិនទាន់បានតម្កល់ ទើបពោលថា នាងបតិបូជិកាទៅណា អ្នកស្រុកពោលថា បពិត្រលោកម្ចាស់ យើងទាំងឡាយឃើញនាងក្នុងទីណា ម្សិលមិញនេះ កាលលោកម្ចាស់ឆាន់ហើយ ត្រឡប់ទៅ នាងស្លាប់ក្នុងពេលល្ងាច ។

ភិក្ខុបុថុជ្ជនស្តាប់ពាក្យនោះហើយ រឭកដល់ឧបការៈរបស់នាងនោះ មិនអាចទប់ទឹកភ្នែកបាន ធម្មសង្វេគកើតដល់ព្រះខីណាស្រព ភិក្ខុទាំងនោះធ្វើភត្តកិច្ចហើយ ទៅវិហារថ្វាយបង្គំព្រះសាស្តាទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ឧបាសិកាឈ្មោះបតិបូជិកា ក្រោកឡើងស្រួលបួលហើយ ធ្វើបុណ្យមានប្រការផ្សេងៗ ប្រាថ្នាដល់ប្តីប៉ុណ្ណោះ ឥឡូវនេះ នាងស្លាប់ហើយ ទៅកើតក្នុងទីណា ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នាងកើតក្នុងសម្នាក់ប្តីរបស់នាងនោះឯង ភិក្ខុទាំងឡាយពោលថា បពិត្រព្រះអង្គ ក្នុងសម្នាក់ប្តីមិនមាន ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នាងប្រាថ្នាដល់ប្តីនោះ ក៏មិនមែន មាលាភារីទេវបុត្រក្នុងតាវត្តិង្សពិភព ជាប្តីរបស់នាង នាងឃ្លាតចាកទីប្រដាប់ផ្ការបស់ប្តីនោះហើយ ទៅកើតក្នុងសម្នាក់ប្តីនោះឯងទៀត ភិក្ខុទាំងឡាយពោលថា បពិត្រព្រះអង្គ យ៉ាងនោះឬ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ

ទាំងឡាយ យ៉ាងនោះឯង ។ ភិក្ខុទាំងឡាយពោលថា គួរសង្វេគ ជីវិតរបស់សត្វទាំងឡាយ មានប្រមាណតិច នាងអង្គាសខុំព្រះអង្គក្នុងពេលព្រឹក ពេលល្ងាចស្លាប់ដោយព្យាធិដែលកើតឡើង ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ យ៉ាងនោះឯង ឈ្មោះថា ជីវិតរបស់សត្វទាំងឡាយតិច ហេតុនោះឯង មច្ចុដែលធ្វើនូវទីបំផុត ញុំាងសត្វទាំងនេះ ដែលមិនឆ្អែតដោយវត្ថុកាម និង កិលេសកាមនោះឯង ឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួនហើយ រមែងក្តួចយកសត្វដែលកន្ទក់កន្ទេញទៅ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**បុប្ផានិ ហេវ បចិនន្តំ ព្យាសត្តមនសំ នរំ**
**អតិត្តំយេវ កាមេសុ អន្តកោ កុរុតេ វសំ ។**

អ្នកធ្វើទីបំផុត គឺមរណៈ តែងក្រុងសត្វដែលមានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗ កំពុងជ្រើសរើសនូវផ្កា គឺកាម-គុណ ៥ មិនឆ្អែតឆ្អន់ក្នុងកាមទាំងឡាយនោះឯង ឲ្យនៅក្នុងអំណាចរបស់ខ្លួន ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បាទព្រះគាថា **បុប្ផានិ ហេវ បចិនន្តំ** សេចក្តីថា បុគ្គលរវល់ជ្រើសរើសនូវផ្កា គឺកាមគុណទាំងឡាយ ដែលទាក់ទងដោយអត្តភាព និងទាក់ទងដោយគ្រឿងឧបករណ៍ ដូចនាយមាលាការជ្រើសរើសនូវផ្កាច្រើនប្រភេទ ក្នុងសួនផ្កា ដូច្នោះ ។

បាទព្រះគាថាថា **ព្យាសត្តមនសំ នរំ** សេចក្តីថា បុគ្គលមានចិត្តរាយមាយ

ទៅដោយអាការផ្សេងៗ ក្នុងអារម្មណ៍ដែលមិនទាន់មកដល់ហើយ ដោយអំណាចនៃសេចក្ដីប្រាថ្នា ក្នុងអារម្មណ៍ដែលដល់ហើយ ដោយអំណាចនៃសេចក្ដីត្រេកអរ ។

បាទព្រះគាថាថា **អតិត្តំយេវ កាមេសុ** សេចក្ដីថា បុគ្គលមិនឆ្អែតក្នុងវត្ថុកាម និងកិលេសកាមទាំងឡាយនោះឯង ដោយការស្វែងរកខ្លះ ដោយការបានចំពោះខ្លះ ដោយការប្រើប្រាស់ខ្លះ ដោយការរក្សាខ្លះ ។

បាទព្រះគាថាថា **អន្តកោ កុរុតេ វសំ** សេចក្ដីថា មច្ចុដែលធ្វើនូវទីបំផុតពោល គឺមរណៈ នាំនរៈដែលកន្ទក់កន្ទេញទៅ ឲ្យដល់នូវអំណាចនៃខ្លួន ។

ក្នុងពេលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ ទេសនាមានប្រយោជន៍ដល់មហាជន ដូច្នេះឯង ៕

**រឿង នាងបតិបូជិកា ចប់**

# រឿង កោសិយសេដ្ឋី

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធសេដ្ឋីឈ្មោះកោសិយៈ ជាអ្នកមានសេចក្ដីកំណាញ់ ត្រាស់ព្រះធម្មទេសនានេះថា **យថាបិ ភមរោ បុប្ផំ** ជាដើម ។ រឿងនេះ កើតឡើងក្នុងក្រុងរាជគ្រឹះ ។

បានឮមកថា ក្នុងទីមិនឆ្ងាយអំពីក្រុងរាជគ្រឹះ មាននិគមឈ្មោះសក្ករៈ

សេដ្ឋីម្នាក់ឈ្មោះកោសិយ: មានសេចក្តីកំណាញ់ មានសម្បត្តិ ៨០ កោដិ នៅក្នុងនិគមនោះ ។ គាត់មិនឲ្យតំណក់ប្រេង សូម្បីត្រឹមមួយតំណក់ដែលជ្រលក់ ដោយចុងស្មៅដល់អ្នកដទៃ ។ ទាំងមិនបរិភោគដោយខ្លួនឯង ។ សម្បត្តិរបស់គាត់មិនមានប្រយោជន៍ដល់បិយជនទាំងឡាយ មានកូន និងប្រពន្ធជាដើម មិនមានប្រយោជន៍ដល់សមណ:និងព្រាហ្មណ៍ទាំងឡាយ នៅជារបស់មិនបានប្រើប្រាស់ តាំងនៅដូចស្រះបោក្ខរណី ដែលមានអារក្សទឹកហួងហែង ដោយប្រការដូច្នេះឯង ។

ថ្ងៃមួយ វេលាបច្ចូសសម័យ ព្រះសាស្តាយាងចេញអំពីសមាបត្តិ ដែលប្រកបដោយសេចក្តីករុណាធំ ទ្រង់ប្រមើលមើលសត្វដែលជាផៅពង្ស ដែលល្មមទូន្មានក្នុងការត្រាស់ដឹងបាន នៅក្នុងសកលលោកធាតុ ទ្រង់បានឃើញឧបនិស្ស័យសោតាបត្តិផលរបស់សេដ្ឋី ព្រមទាំងភរិយាក្នុងទីចម្ងាយ ៤៥ យោជន៍ ។ ក្នុងថ្ងៃមុនអំពីនោះ សេដ្ឋីនោះទៅកាន់ព្រះរាជមន្ទីរ ដើម្បីគាល់ព្រះរាជា ធ្វើការបម្រើព្រះរាជាហើយត្រឡប់មក ឃើញមនុស្សស្រុកក្រៅម្នាក់ត្រូវសេចក្តីឃ្លានគ្របសង្កត់ កំពុងបរិភោគនំកុម្មាស គឺនំអំបែង ឲ្យកើតសេចក្តីស្រេកឃ្លានក្នុងនំនោះ ឡើងទៅកាន់ផ្ទះរបស់ខ្លួនហើយ គិតថា បើអញប្រាប់ថា ចង់បរិភោគនំអំបែងសោត មនុស្សជាច្រើន ក៏នឹងនាំគ្នាចង់បរិភោគជាមួយអញយ៉ាងនោះ វត្ថុជាច្រើន មានល្ង អង្ករ សប្បិ ទឹកអំពៅជាដើមរបស់អញ ក៏នឹងដល់នូវការអស់ទៅ ។ អញនឹងមិនប្រាប់ដល់បុគ្គលណាម្នាក់ដូច្នេះហើយ អត់សង្កត់នូវចំណង់ត្រាច់ទៅ កាលវេលាកន្លងទៅគាត់ក៏ស្គម

លឿងជាលំដាប់ មានខ្លួនរវាមដោយសរសៃ បន្ទាប់អំពីនោះ មិនអាចអត់សង្កត់នូវចំណង់បាន ចូលបន្ទប់ហើយ ដេកឱបគ្រែ ។ គាត់សូម្បីដល់សេចក្តីទុក្ខយ៉ាងនេះ ក៏មិនប្រាប់អ្វីដល់បុគ្គលណាម្នាក់ ព្រោះខ្លាចវិនាសទ្រព្យ ។

លំដាប់នោះ ភរិយាចូលទៅរកគាត់ អង្អែលខ្នងសួរថា អ្នកមានជំងឺឬ សេដ្ឋីពោលថា ជំងឺរបស់ខ្ញុំណាមួយមិនមាន ភរិយាពោលថា ព្រះរាជាទ្រង់ពិរោធនឹងអ្នកឬ សេដ្ឋីពោលថា សូម្បីព្រះរាជាក៏មិនពិរោធនឹងខ្ញុំ ភរិយាពោលថា បើយ៉ាងនោះការមិនពេញចិត្តណាមួយ ដែលពួកកូនប្រុសកូនស្រី ឬបរិជនមានទាសកម្មករជាដើម ធ្វើដល់អ្នកមានឬ សេដ្ឋីពោលថា សូម្បីកម្មបែបនោះក៏មិនមាន ភរិយាសួរថា អ្នកមានចំណង់ក្នុងអ្វីឬ ។ ទោះបីភរិយាពោលយ៉ាងនោះ គាត់ក៏មិនពោលពាក្យណាមួយ ដេកស្ងាត់សំឡេងព្រោះខ្លាចអស់ទ្រព្យ ។ លំដាប់នោះ ភរិយាពោលនឹងគាត់ថា នែអ្នក សូមប្រាប់ចុះ អ្នកចង់បរិភោគអ្វី ។ សេដ្ឋីនោះលេបពាក្យ ឆ្លើយថា ខ្ញុំមានចំណង់ ភរិយាសួរថា តើអ្នកចង់បរិភោគអ្វី សេដ្ឋីពោលថា ខ្ញុំចង់ស៊ីនំអំបែង ភរិយាពោលថា បើដូច្នោះហេតុអ្វីមិនប្រាប់ដល់ខ្ញុំ អ្នកជាបុគ្គលក្រីក្រឬ ឥឡូវនេះ ខ្ញុំនឹងចៀននំអំបែងឲ្យដល់មនុស្សដែលនៅក្នុងសក្ករនិគមទាំងអស់ សេដ្ឋីពោលថា ប្រយោជន៍អ្វីរបស់នាង ដោយជនទាំងនោះ ពួកគេធ្វើការរបស់ខ្លួន នឹងស៊ីរបស់ខ្លួន ។ ភរិយាពោលថា បើដូច្នេះ ខ្ញុំនឹងចៀននំអំបែង ឲ្យដល់មនុស្សដែលនៅក្នុងច្រកជាមួយគ្នា សេដ្ឋីពោលថា ខ្ញុំដឹងថា នាងជាអ្នកមានទ្រព្យហើយ ភរិយាពោលថា ខ្ញុំនឹងចៀនឲ្យគ្រប់គ្រាន់ដល់មនុស្សទាំងអស់ ដែលនៅក្នុងទីជិតផ្ទះ

នេះ សេដ្ឋីពោលថា ខ្ញុំដឹងថា នាងជាអ្នកមានអធ្យាស្រ័យទូលាយហើយ កិរិយាពោលថា បើដូច្នោះ ខ្ញុំនឹងចៀនឲ្យគ្រប់គ្រាន់ត្រឹមតែកូន ប្រពន្ធរបស់អ្នកប៉ុណ្ណោះ សេដ្ឋីពោលថា ប្រយោជន៍អ្វីរបស់នាងដោយមនុស្សទាំងនោះ ។ កិរិយាពោលថា ខ្ញុំនឹងចៀនឲ្យល្មមដល់អ្នក និងខ្ញុំឬ សេដ្ឋីពោលថា នាងនឹងធ្វើ គឺបរិភោគធ្វើអ្វី កិរិយាពោលថា បើដូច្នោះ ខ្ញុំនឹងចៀនឲ្យល្មមដល់អ្នកប៉ុណ្ណោះ សេដ្ឋីពោលថា បើនាងចៀននំនេះ មនុស្សជាច្រើន រមែងមានបំណងចង់ស៊ីដែរ ចូរនាងវៀរអង្ករដែលល្អទាំងអស់ កាន់យកចុងអង្ករ ជើងក្រាន អំបែង កាន់យកទឹកដោះស្រស់ សប្បិ ទឹកឃ្មុំ និងទឹកអំពៅបន្តិចហើយឡើងទៅជាន់ខាងលើនៃប្រាសាទជាន់ទី ៧ ហើយចៀនចុះ ខ្ញុំម្នាក់ឯងប៉ុណ្ណោះនឹងអង្គុយស៊ីក្នុងទីនោះ ។

នាងទទួលពាក្យថា សាធុ ហើយឲ្យទាសីកាន់របស់ដែលគួរកាន់ ឡើងទៅកាន់ប្រាសាទ ហើយដេញទាសីទៅ ឲ្យហៅលោកសេដ្ឋីមក ។ សេដ្ឋីនោះបិទទ្វារដាក់គន្លឹះគ្រប់ទ្វារ តាំងអំពីទ្វារដំបូងមក ហើយឡើងទៅកាន់ជាន់ទី ៧ បិទទ្វារហើយអង្គុយក្នុងទីនោះ ។ ចំណែកកិរិយារបស់គាត់ បង្កាត់ភ្លើងត្រង់ជើងក្រាន លើកអំបែងដាក់ ហើយផ្តើមចៀននំ ។

គ្រានោះ ព្រះសាស្តាត្រាស់ហៅព្រះមហាមោគ្គល្លានត្ថេរមកអំពីព្រលឹមត្រាស់ថា ម្នាលមោគ្គល្លាន ក្នុងសក្ករនិគមមិនឆ្ងាយអំពីក្រុងរាជគ្រឹះ សេដ្ឋីកំណាញ់ម្នាក់ គិតថា អញនឹងបរិភោគនំអំបែង ទើបឲ្យកិរិយាចៀននំខាងលើប្រាសាទ ៧ ជាន់ ព្រោះខ្លាចអ្នកដទៃឃើញ ចូរអ្នកទៅក្នុងទីនោះ ហើយ

ទូន្មានសេដ្ឋី ធ្វើឲ្យអស់ព្យសន៍ ឲ្យប្ដីប្រពន្ធទាំងពីរកាន់នំ ទឹកដោះ សប្បិ ទឹកឃ្មុំ និងទឹកអំពៅហើយ នាំមកកាន់វត្តជេតពន ដោយកម្លាំងរបស់ខ្លួន ថ្ងៃនេះ តថាគតមួយអន្លើដោយភិក្ខុ ៥០០ រូប នឹងអង្គុយក្នុងវិហារនោះឯង ធ្វើភត្តកិច្ចដោយនំប៉ុណ្ណោះ ។

ព្រះថេរៈទទួលព្រះតម្រាស់របស់ព្រះសាស្ដាថា សាធុព្រះអង្គ ហើយទៅកាន់និគមនោះដោយកម្លាំងឫទ្ធិរំពេចនោះឯង ជាអ្នកស្លៀកដណ្ដប់រៀបរយ ឈរត្រង់មាត់បង្អួចនៃប្រាសាទនោះ ដូចរូបកែវមណីអណ្ដែតនៅលើអាកាសនោះឯង ព្រោះឃើញព្រះថេរៈនោះឯង ហឫទ័យរបស់សេដ្ឋីក៏ញាប់ញ័រ គិតថា អញមកទីនេះព្រោះខ្លាចបុគ្គលទាំងឡាយ មានសភាពយ៉ាងនេះឯង តែសមណៈនេះមកឈរត្រង់បង្អួចបាន កាលមិនឃើញគ្រឿងឧបករណ៍ ដែលខ្លួនគួរកាន់យក ក្ដៅក្រហាយធ្វើសំឡេង តៈដៈ តៈដៈ ដូចអំបិលដែលបោះក្នុងភ្លើង ទើបពោលយ៉ាងនេះថា សមណៈអ្នកឈរនៅក្នុងអាកាស នឹងបានអ្វី សូម្បីអ្នកចង្ក្រម បង្ហាញស្នាមជើងក្នុងអាកាស ដែលមិនមានស្នាម ក៏នឹងមិនបានដូចគ្នា ។ ព្រះថេរៈចង្ក្រមត្រឡប់ទៅត្រឡប់មកក្នុងទីនោះឯង សេដ្ឋីពោលថា អ្នកចង្ក្រមនឹងបានអ្វី សូម្បីអង្គុយពត់ភ្នែនក្នុងអាកាស ក៏មិនបានដូចគ្នា ទើបព្រះថេរៈអង្គុយពត់ភ្នែន ។

គ្រានោះ សេដ្ឋីពោលថា អ្នកអង្គុយក្នុងអាកាសនឹងបានអ្វី សូម្បីឈរត្រង់ធរណីបង្អួច ក៏មិនបាន ។ ព្រះថេរៈបានឈរត្រង់ធរណីបង្អួចហើយ ។ កាលនោះ សេដ្ឋីពោលថា អ្នកឈរត្រង់ធរណីបង្អួចនឹងបានអ្វី សូម្បីបង្ហុយ

ផ្សែងហើយ ក៏នឹងមិនបានដូចគ្នា ។ ព្រះថេរៈក៏បង្ហុយផ្សែង ។ ប្រាសាទទាំងមូល មានផ្សែងគ្របដណ្តប់ពាសពេញ ។ អាការនោះ ហាក់ដូចជាកាលដែលចាក់ភ្នែកទាំងពីររបស់សេដ្ឋីដោយម្ជុល សេដ្ឋីពោលថា ទោះបីអ្នកឲ្យឆេះដោយភ្លើង ក៏មិនបាន ព្រះថេរៈក៏ធ្វើជាភ្លើង ព្រោះខ្លាចភ្លើងឆេះផ្ទះ គិតថា សមណៈនេះនឹងជាអ្នកជាប់ជំពាក់យ៉ាងមាំ បើមិនបានហើយនឹងមិនចេញទៅ អញនឹងឲ្យនំមួយចម្រៀកដល់លោក ហើយពោលនឹងភរិយាថា នែនាង នាងចូរចៀននំមួយចម្រៀកតូច ឲ្យដល់សមណៈ ហើយបញ្ជូនលោកទៅចុះ ។ នាងដាក់ម្សៅក្នុងអំបែងបន្តិច តែនំហាក់ដូចជាធំ បានរីកឡើងពេញថាសតាំងនៅហើយ ។ សេដ្ឋីឃើញហេតុនោះ ពោលថា ប្រហែលជានាងដាក់ម្សៅច្រើនពេក ដូច្នេះហើយ ដួសម្សៅបន្តិចដោយចុងវែកហើយចៀនដោយខ្លួនឯង នំរីករីតតែធំជាងមុន ។ សេដ្ឋីចៀននំណាមួយ ដោយអាការយ៉ាងនោះ នំទាំងនោះក៏រីករីតតែធំនោះឯង ។ គាត់ធុញទ្រាន់ ទើបពោលនឹងភរិយាថា នែនាង ចូរនាងឲ្យនំដល់សមណៈនេះមួយបន្ទះចុះ ។ កាលនាងចាប់នំមួយអំពីល្អី នំទាំងអស់ក៏ជាប់គ្នាតែមួយ ទើបនាងពោលនឹងសេដ្ឋីថា នែអ្នក នំទាំងអស់ជាប់គ្នាតែមួយហើយ ខ្ញុំមិនអាចធ្វើឲ្យបែកគ្នាបាន សូម្បីគាត់ពោលថា ខ្ញុំនឹងធ្វើឯង ហើយក៏មិនអាចធ្វើបាន សូម្បីទាំងពីរនាក់ចាប់ត្រង់ជាយនំទាញចេញ ក៏មិនអាចបំបែកចេញពីគ្នាបានឡើយ កាលសេដ្ឋីនោះ ព្យាយាមបំបែកនំ ញើសក៏ហូរចេញអំពីសរីរៈហើយ ការឃ្លានក៏បាត់ទៅ ។ គ្រានោះគាត់ពោលនឹងភរិយាថា នែនាង ខ្ញុំមិនត្រូវការដោយនំ នាងចូរឲ្យដល់សមណៈ

ចុះ នាងលើកល្អីហើយ ចូលទៅរកព្រះថេរៈ ព្រះថេរៈសម្ដែងធម៌ដល់ជនទាំងពីរ ពោលគុណព្រះរតនត្រ័យ សម្ដែងផលទាន ដែលបុគ្គលឲ្យហើយជាដើម ឲ្យដូចព្រះចន្ទ្រក្នុងលម្ហថា ទានដែលបុគ្គលឲ្យហើយ រមែងមានផល យញ្ញដែលបុគ្គលបូជា រមែងមានផល សេដ្ឋីស្ដាប់ធម៌នោះហើយ មានចិត្តជ្រះថ្លាពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់និមន្តមកគង់ធាន់លើបល្ល័ង្កនេះចុះ ។

ព្រះថេរៈពោលថា មហាសេដ្ឋី ព្រះសម្មាសម្ពុទ្ធប្រថាប់គង់ក្នុងវិហារជាមួយភិក្ខុ ៥០០ រូប ដោយតាំងព្រះហឫទ័យថា នឹងសោយនំ បើអ្នកមានការពេញចិត្ត ចូរឲ្យភរិយាកាន់យកនំ និងវត្ថុដទៃ មានទឹកដោះជាដើម ពួកយើងនឹងទៅកាន់សម្នាក់ព្រះសាស្ដា ។ សេដ្ឋីពោលថា ឥឡូវនេះ ព្រះសាស្ដាគង់នៅក្នុងទីណា ព្រះថេរៈពោលថា គង់នៅក្នុងវត្តជេតពនមហាវិហារ ក្នុងទីបំផុតនៃទី ៤៥ យោជន៍អំពីទីនេះ ។ សេដ្ឋីពោលថា បពិត្រលោកម្ចាស់ ពួកយើងនឹងទៅអស់ចម្ងាយផ្លូវមានប្រមាណប៉ុណ្ណេះ មិនហួសកាលទៅហើយឬ ។ ព្រះថេរៈពោលថា បើលោកសេដ្ឋីពេញចិត្ត អាត្មានឹងនាំអ្នកទាំងពីរទៅដោយកម្លាំងរបស់ខ្លួន ក្បាលជណ្ដើរប្រាសាទរបស់អ្នក នឹងមានក្នុងទីរបស់ខ្លួននេះឯង តែជើងជណ្ដើរនឹងមានត្រង់ឃ្លោងទ្វារវត្តជេតពន អាត្មានឹងនាំទៅកាន់វត្តជេតពន ដោយកាលប្រហែលគ្នានឹងចុះអំពីប្រាសាទជាន់លើ ទៅកាន់ជាន់ខាងក្រោម សេដ្ឋីទទួលថា សាធុ ។ ព្រះថេរៈធ្វើក្បាលជណ្ដើរក្នុងទីនោះឯងហើយ អធិដ្ឋានថា សូមជើងជណ្ដើរមានត្រង់ខ្លោងទ្វារវត្តជេតពន ជណ្ដើរ

បានកើតហើយយ៉ាងនោះឯង ព្រះថេរៈឲ្យសេដ្ឋី និងភរិយាដល់វត្តជេតពន រហ័សដូចកាលដែលចុះអំពីប្រាសាទជាន់លើ ទៅកាន់ជាន់ក្រោម ។

ប្តីប្រពន្ធទាំងពីរនាក់នោះ ចូលគាល់ព្រះសាស្តាហើយ ក្រាបទូលកាល ។ ព្រះសាស្តាយាងចូលកាន់រោងឆាន់ហើយ ប្រថាប់គង់លើពុទ្ធាសនៈ ដែលគេក្រាលហើយ មួយអន្លើដោយភិក្ខុសង្ឃ ។ មហាសេដ្ឋីបានថ្វាយទក្ខិណោទកដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ភរិយាដាក់នំក្នុងបាត្ររបស់ព្រះតថាគតហើយ សូម្បីមហាសេដ្ឋី មួយអន្លើដោយភរិយា ក៏បរិភោគនំសមគួរដល់សេចក្តីត្រូវការ ការអស់នំមិនប្រាកដឡើយ ។ កាលគាត់ប្រគេននំដល់ភិក្ខុក្នុងវិហារទាំងមូល ឲ្យដល់អ្នកស៊ីដែលទាំងឡាយហើយ ការអស់ទៅនៃនំក៏មិនប្រាកដនោះឯង ។ ទើបគាត់ទាំងពីរ ក្រាបទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន នំមិនអស់ឡើយ ព្រះសាស្តាត្រាស់ថា បើដូច្នោះ អ្នកទាំងពីរចូរបោះបោលត្រង់ខ្លោងទ្វារវត្តជេតពន ។ ជនទាំងពីរក៏បោះបោលត្រង់ជ្រុង មិនឆ្ងាយអំពីខ្លោងទ្វារ សព្វថ្ងៃនេះ ទីនោះ ក៏នៅប្រាកដឈ្មោះថាជ្រុងនំអំបែង ។ មហាសេដ្ឋីព្រមទាំងភរិយា ចូលទៅគាល់ព្រះដ៏មានព្រះភាគ បានឈរក្នុងទីសមគួរនាចំណែកម្ខាងហើយ ។ ព្រះសាស្តាបានធ្វើអនុមោទនាហើយ ។ ក្នុងកាលចប់អនុមោទនា ប្តីប្រពន្ធទាំងពីរតាំងនៅក្នុងសោតាបត្តិផលហើយ ថ្វាយបង្គំព្រះសាស្តា ឡើងជណ្តើរត្រង់ខ្លោងទ្វារវត្តជេតពន ហើយស្ថិតនៅលើប្រាសាទរបស់ខ្លួននោះឯង ។ តាំងអំពីនោះមក សេដ្ឋីបានចំណាយទ្រព្យចំនួន ៨០ កោដិ ក្នុងព្រះពុទ្ធសាសនានោះឯង ។

ស្អែកឡើង ក្នុងវេលាល្ងាច ពួកភិក្ខុប្រជុំគ្នាក្នុងរោងធម្មសភា អង្គុយហើយ ពោលនូវគុណកថារបស់ព្រះថេរៈថា អាវុសោទាំងឡាយ អ្នកទាំងឡាយ ចូរមើលអានុភាពរបស់ព្រះមហាមោគ្គល្លាន លោកជាអ្នកមិនបៀតបៀនទាំងសទ្ធា មិនបៀតបៀនទាំងភោគៈ ទូន្មានសេដ្ឋីដែលមានសេចក្តីកំណាញ់ មួយរយៈខ្វី ធ្វើឲ្យអស់ព្យសន៍ហើយ ឲ្យកាន់នំនាំមកកាន់វត្តជេតពន ធ្វើត្រង់ព្រះភក្ត្រព្រះសាស្តាហើយ ឲ្យតាំងនៅក្នុងសោតាបត្តិផល គួរអស្ចារ្យ ព្រះថេរៈមានអានុភាពច្រើន ព្រះសាស្តាទ្រង់ស្តាប់ពាក្យរបស់ពួកភិក្ខុ ដោយព្រះសោតធាតុដែលជាទិព្វ យាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នា ដោយរឿងអ្វីហ្ន៎ ។ កាលភិក្ខុទាំងនោះក្រាបទូលថា ដោយរឿងឈ្មោះនេះ ទើបត្រាស់សរសើរព្រះថេរៈថា ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុអ្នកទូន្មាន មិនប៉ះពាល់ទាំងសទ្ធា មិនប៉ះពាល់ទាំងភោគៈ មិនឲ្យត្រកូលខូចខាត មិនបៀតបៀនត្រកូល ដូចជាឃ្មុំយកលម្អងអំពីផ្កា ចូលទៅរកត្រកូលហើយ គួរឲ្យដឹងពុទ្ធគុណ ។ មោគ្គល្លានបុត្ររបស់តថាគតក៏ដូច្នោះ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**យថាបិ ភមរោ បុប្ផំ វណ្ណគន្ធំ អហេឋយំ**
**បលេតិ រសមាទាយ ឯវំ គាមេ មុនី ចរេ ។**

ភមរជាតិ មិនធ្វើផ្កាឈើដែលមានពណ៌ និងក្លិនឲ្យវិនាស
ទេ ក្រេបយកតែរស ហើរទៅ យ៉ាងណាមិញ អ្នកប្រាជ្ញ
គប្បីត្រាច់ទៅក្នុងស្រុក ក៏យ៉ាងនោះឯង ។

# សេចក្តីអធិប្បាយ

ជាតិនៃសត្វដែលធ្វើជាតិផ្អែមណាមួយ ឈ្មោះថា ភមរៈ ក្នុងព្រះគាថានេះ ។ បទថា **បុប្ផំ** ជាដើម សេចក្តីថា ឃ្មុំកាលហើរទៅក្នុងសួនផ្កា ក៏មិនញុំាំងផ្កា ពណ៌ និងក្លិនឲ្យខូច គឺមិនឲ្យវិនាស ហើរទៅ ។

បទថា **បលេតិ** សេចក្តីថា កាលហើរទៅយ៉ាងនោះហើយ ក្រេបរសគ្រប់គ្រាន់ដល់សេចក្តីត្រូវការ ពាំយករសដទៃទៅ ដើម្បីប្រយោជន៍ដល់ការធ្វើទឹកផ្អែម ហើយហើរទៅ ។ ឃ្មុំនោះត្រាច់ចុះកាន់ព្រៃស្ងួតណាមួយ ហើយក្រេបរសដែលលាយលម្អងនោះ ទុកក្នុងប្រហោងឈើមួយកន្លែងហើយ ធ្វើទឹកផ្អែមឲ្យជាទឹកឃ្មុំដោយលំដាប់ ។ ផ្កាពណ៌ និងក្លិនរបស់ផ្កានោះ មិនខូចខាត ព្រោះការត្រាច់ទៅក្នុងសួនផ្កានៃឃ្មុំនោះជាបច្ច័យឡើយ ដែលពិត វត្ថុទាំងអស់នោះ តាំងនៅជាប្រក្រតីនោះឯង ។

បាទព្រះគាថាថា **ឯវំ គាមេ មុនី ចរេ** សេចក្តីថា ព្រះអនាគារិយមុនីមានសេក្ខៈ និងអសេក្ខៈក៏ដូច្នោះ ត្រាច់ទទួលភិក្ខាក្នុងស្រុក ដោយលំដាប់ត្រកូល ។

មែនពិត ការវិនាសសទ្ធា ឬការវិនាសភោគៈមិនមានដល់ត្រកូលទាំងឡាយ ព្រោះការត្រាច់ទៅក្នុងស្រុករបស់មុនីជាបច្ច័យឡើយ សទ្ធាក្តី ភោគៈក្តី នៅជាប្រក្រតីនោះឯង ឯព្រះសេក្ខមុនី និងអសេក្ខមុនី កាលត្រាច់ទៅយ៉ាងនោះ ចេញមកហើយ ព្រះសេក្ខមុនីក្រាលសង្ឃាដី អង្គុយក្នុងទីដែលសប្បាយដោយទឹកខាងក្រៅស្រុក ហើយពិចារណាបិណ្ឌបាត ដោយអំណាចនៃការប្រៀបធៀបដោយប្រេងបន្តក់ក្ងោរថ សំពត់រុំដំបៅ និងសាច់កូន ហើយឆាន់បិណ្ឌបាត

គេចចូលទៅកាន់ដងព្រៃបែបនោះ ពិចារណាកម្មដ្ឋាន ប្រព្រឹត្តទៅខាងក្នុងធ្វើមគ្គ ៤ និងផល ៤ ឲ្យនៅក្នុងកណ្ដាប់ដៃឲ្យបាន ចំណែកព្រះអសេក្ខមុនីប្រកបការនៅសប្បាយក្នុងទិដ្ឋធម៌រឿយៗ ។ បណ្ឌិតគប្បីជ្រាបភាពដែលមុនីនោះ គួរឃើញស្មើគ្នានឹងឃ្មុំ ដោយការធ្វើទឹកផ្អែមបែបនេះ ។ តែក្នុងទីនេះទ្រង់បំណងយកព្រះខីណាស្រព ។

ក្នុងកាលចប់ទេសនា ជនជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

ព្រះសាស្ដា កាលត្រាស់ព្រះធម្មទេសនានេះហើយ ដើម្បីប្រកាសគុណរបស់ព្រះថេរៈឲ្យក្រៃលែង ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានទូន្មានសេដ្ឋីកំណាញ់នេះ ក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន លោកក៏ទូន្មានហើយ ឲ្យដឹងការទាក់ទងគ្នានៃកម្ម និងផលរបស់កម្មដូចគ្នា ដូច្នេះហើយ កាលទ្រង់ប្រកាសសេចក្ដីនេះ ទើបនាំអតីតនិទានមកសាធក: ដោយឥល្លិសជាតកនេះថា

ជាងកោរកាត់ពោធិសត្វពោលថា

ជនទាំង ២ នាក់ខ្វក ជនទាំង ២ នាក់ក្ញង ជនទាំង ២ នាក់មានភ្នែកស្រលៀង ពកកើត ( លើក្បាល ) របស់ជនទាំង ២ នាក់ខ្ញុំព្រះអង្គមិនស្គាល់ ( អ្នកណា ) ជាឥល្លិសសេដ្ឋីទេ ។

**រឿងកោសិយសេដ្ឋី ចប់**

# រឿង បាដិកាជីវក

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធអាជីវក ឈ្មោះបាដិកៈ ត្រាស់ធម្មទេសនានេះថា **ន បរេសំ វិលោមានិ** ជាដើម ។

បានឮមកថា ស្រីមេផ្ទះក្នុងក្រុងសាវត្ថី បដិបត្តិអាជីវក ឈ្មោះបាដិកៈ តាំងនៅក្នុងឋានៈដូចកូន ។ មនុស្សក្នុងផ្ទះរបស់នាង ស្ដាប់ធម្មទេសនារបស់ព្រះសាស្ដាហើយ មកពណ៌នាគុណដោយប្រការផ្សេងៗ ជាដើមថា ព្រះធម្មទេសនារបស់ព្រះពុទ្ធទាំងឡាយ គួរអស្ចារ្យពន់ពេក ។

ស្រីមេផ្ទះនោះ ស្ដាប់ពាក្យសរសើរគុណរបស់ព្រះសម្ពុទ្ធហើយ បំណងនឹងទៅកាន់វិហារ ហើយស្ដាប់ធម៌ ទើបប្រាប់សេចក្ដីនោះដល់អាជីវក ហើយពោលថា បពិត្រលោកម្ចាស់ ខ្ញុំនឹងទៅសម្នាក់របស់ព្រះសម្ពុទ្ធ អាជីវកនោះឃាត់ថា កុំទៅឡើយ ហើយក៏ហាមនាងដែលអង្វរហើយអង្វរទៀតនោះឯង ។

នាងគិតថា លោកម្ចាស់នេះ មិនឲ្យអញទៅវិហារស្ដាប់ធម៌ អញនឹងនិមន្តព្រះសាស្ដាមក ហើយស្ដាប់ធម៌ក្នុងទីនេះឯង ដូច្នេះហើយ ក្នុងពេលល្ងាច ទើបហៅកូនប្រុសមកហើយ បញ្ជូនទៅដោយពាក្យថា ចូរឯងទៅនិមន្តព្រះសាស្ដាមក ដើម្បីសោយភត្តាហារក្នុងថ្ងៃស្អែក ។

កូនប្រុសនោះ មុននឹងទៅក៏ទៅកាន់លំនៅរបស់អាជីវកមុន ថ្វាយបង្គំអាជីវកហើយអង្គុយ ។ ពេលនោះអាជីវកសួរថា អ្នកទៅណា កូននោះពោលថា ខ្ញុំទៅនិមន្តព្រះសាស្ដាតាមពាក្យរបស់អ្នកម្ដាយ អាជីវកពោលថា កុំទៅ

កាន់សម្នាក់របស់ទ្រង់ឡើយ កូននោះពោលថា មិនបានទេលោកម្ចាស់ ខ្ញុំនឹងទៅ អាជីវកពោលថា យើងទាំងពីរនាក់ នឹងបរិភោគគ្រឿងសក្ការៈ ដែលម្ដាយរបស់ឯងធ្វើថ្វាយព្រះសាស្ដានោះ កុំទៅឡើយ កូននោះពោលថា មិនបានទេលោកម្ចាស់ ម៉ែនឹងវាយខ្ញុំ អាជីវកពោលថា បើដូច្នោះ ទៅក៏ទៅចុះ តែកាលទៅហើយ ចូរនិមន្ត តែកុំប្រាប់ថា ទ្រង់គប្បីយាងទៅផ្ទះពួកខ្ញុំព្រះអង្គក្នុងទីនោះ ក្នុងផ្លូវនោះ ក្នុងច្រកនោះ ធ្វើដូចជាឈរក្នុងទីជិត ដូចនឹងទៅដោយផ្លូវដទៃ ហើយចូរគេចមកចុះ ។

កូននោះស្ដាប់ពាក្យរបស់អាជីវកហើយ ទៅកាន់សម្នាក់ព្រះសាស្ដា និមន្តហើយ ធ្វើកិច្ចសព្វយ៉ាងដោយទំនងអាជីវកពោលហើយនោះឯង ហើយទៅកាន់សម្នាក់របស់អាជីវកនោះ ត្រូវអាជីវកសួរថា អ្នកធ្វើដូចម្ដេច ទើបប្រាប់ថា អ្វីដែលលោកម្ចាស់ប្រាប់ទាំងអស់ ខ្ញុំធ្វើហើយ ។ អាជីវកពោលថា ឯងធ្វើល្អហើយ យើងទាំងពីរនឹងបរិភោគគ្រឿងសក្ការៈ ដែលម្ដាយរបស់អ្នកធ្វើដើម្បីព្រះសាស្ដានោះ ដូច្នេះហើយ ស្អែកឡើង អាជីវកបានទៅកាន់ផ្ទះនោះអំពីព្រលឹម ពួកមនុស្សក្នុងផ្ទះនាំអាជីវកនោះ ឲ្យទៅអង្គុយត្រង់បន្ទប់ក្រោយ ពួកមនុស្សស្និទ្ធស្នាល បូកលាបផ្ទះនោះ ដោយអាចម៍គោស្រស់ រោយផ្កាដែលមានលាជជាគម្រប់ ៥ ហើយក្រាលអាសនៈ មានតម្លៃច្រើនដ៏សមគួរ ដើម្បីជាប្រយោជន៍ដល់ការប្រថាប់គង់របស់ព្រះសាស្ដា ។ ពិតហើយ ពួកមនុស្សដែលមិនស្និទ្ធស្នាលជាមួយព្រះសម្ពុទ្ធ រមែងមិនចេះក្នុងការក្រាលអាសនៈ ។

ម្យ៉ាងទៀត ឈ្មោះថា កិច្ចទាក់ទងដោយការបង្ហាញផ្លូវ រមែងមិនមាន ដល់ព្រះពុទ្ធទាំងឡាយ ព្រោះផ្លូវទាំងអស់ ជាក់ច្បាស់ដល់ព្រះពុទ្ធទាំងអស់ ហើយថា ផ្លូវនេះទៅកាន់នរក ផ្លូវនេះទៅកាន់តិរច្ឆាន ផ្លូវនេះទៅកាន់បិត្តិវិស័យ នេះទៅកាន់មនុស្សលោក នេះទៅកាន់ទេវលោក នេះទៅអមតមហានិព្វាន ក្នុងថ្ងៃដែលទ្រង់ញ៉ាំងលោកធាតុមួយម៉ឺនឲ្យញាប់ញ័រ ហើយសម្រេចសព្វញ្ញុតញ្ញាណ ត្រង់គល់ពោធិព្រឹក្សនោះឯង ។ ទើបមិនមានពាក្យដែលគួរពោលក្នុងផ្លូវនៃទឹកផ្សេងៗ មានគាមនិគមជាដើមឡើយ ព្រោះដូច្នោះ ព្រះសាស្តា ទ្រង់កាន់បាត្រ និងចីវរហើយ យាងទៅកាន់ទ្វារផ្ទះរបស់មហាឧបាសិកាអំពីព្រលឹម ។ នាងចេញអំពីផ្ទះ ថ្វាយបង្គំព្រះសាស្តា ដោយបញ្ចង្គប្បតិដ្ឋាន យាងឲ្យទ្រង់ចូលទៅខាងក្នុងផ្ទះ និមន្តឲ្យគង់លើអាសនៈ ហើយថ្វាយទក្ខិណោទក អង្គាសដោយខាទនីយៈ និងភោជនីយៈដ៏ប្រណីត ។ ឧបាសិកាបំណាងឲ្យព្រះសាស្តាដែលធ្វើភត្តកិច្ចស្រេចហើយ ទ្រង់ធ្វើអនុមោទនា ទើបទទួលបាត្រហើយ ។

ព្រះសាស្តា ទ្រង់ផ្តើមធម្មកថា សម្រាប់អនុមោទនាដោយព្រះសូរសៀងដ៏ពីរោះ ។ ឧបាសិកាស្តាប់បណ្តើរ ឲ្យសាធុការបណ្តើរថា សាធុ សាធុ ។ អាជីវកនោះ អង្គុយក្នុងបន្ទប់ក្រោយនោះឯង បានឮសំឡេងនាងឲ្យសាធុការ ហើយស្តាប់ធម៌ មិនអាចអត់ធន់បាន ទើបចេញទៅដោយគិតថា ពេលនេះ នាងមិនមែនជារបស់អញ ដូច្នេះហើយ ជេរឧបាសិកា និងព្រះសាស្តា ដោយប្រការផ្សេងៗ ថា មេកាឡកិណី ហេងជាបុគ្គលវិនាស ហេងចូរធ្វើសក្ការៈនេះ

ដល់សមណៈនេះចុះ ដូច្នេះជាដើម ហើយចៀសចេញទៅ ។

ឧបាសិកាខ្មាស ព្រោះពាក្យរបស់អាជីវកនោះ មិនអាចបញ្ជូនចិត្តដែលដល់នូវការរាយមាយទៅតាមក្រសែនៃទេសនាបាន ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងនាងថា ឧបាសិកា នាងមិនអាចធ្វើចិត្តឲ្យទៅតាមគន្លងទេសនាបានឬ ឧបាសិកាពោលថា ករុណាព្រះអង្គ ព្រោះពាក្យសម្តីរបស់អាជីវកនេះ ចិត្តរបស់ខ្ញុំព្រះអង្គ ចូលដល់នូវការរាយមាយហើយ ។

ព្រះសាស្តាត្រាស់ថា មិនគួរពួកដល់ពាក្យដែលជនមិនស្មើភាគគ្នាបែបនេះពោល ការមិនពិចារណាដល់ពាក្យបែបនេះហើយ ពិនិត្យមើលកិច្ចដែលធ្វើហើយ និងមិនទាន់បានធ្វើរបស់ខ្លួនប៉ុណ្ណោះ ទើបគួរ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**ន បរេសំ វិលោមានិ ន បរេសំ កតាកតំ**
**អត្តនោវ អវេក្ខេយ្យ កតានិ អកតានិ ច ។**

ពាក្យចាក់ដោតទាំងឡាយ របស់ជនដទៃ បុគ្គលមិនគួរធ្វើ
ទុកក្នុងចិត្តទេ កិច្ចដែលធ្វើហើយ និងមិនទាន់ធ្វើហើយ
របស់ជនដទៃ ( ដែលមិនមែនជាមុខការរបស់ខ្លួន )
បុគ្គលមិនគួរពិនិត្យមើលទេ បុគ្គលគួរពិនិត្យពិចារណាតែ
កិច្ចការទាំងឡាយ ដែលធ្វើហើយ និងមិនទាន់ធ្វើហើយ
របស់ខ្លួនតែម្យ៉ាង ។

# សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បាទព្រះគាថាថា **ន បរេសំ វិលោមានិ** សេចក្តីថា មិនគួរធ្វើពាក្យព្រើរោម គឺពាក្យគ្រោតគ្រាត បានដល់ ពាក្យដែលកាត់បង់នូវសេចក្តីស្រឡាញ់ របស់បុគ្គលពួកដទៃទុកក្នុងចិត្តឡើយ ។

បាទព្រះគាថាថា **ន បរេសំ កតាកតំ** សេចក្តីថា មិនគួរមើលកម្មដែលធ្វើហើយ និងមិនទាន់ធ្វើហើយ របស់បុគ្គលដទៃយ៉ាងនេះថា ឧបាសកនោះ មិនមានសទ្ធា មិនជ្រះថ្លា សូម្បីវត្ថុ មានបាយមួយវែកជាដើមក្នុងផ្ទះ ក៏មិនឲ្យ សលាកភត្តជាដើមក៏មិនឲ្យ ការឲ្យបច្ច័យ មានចីវរជាដើមមិនមានដល់ឧបាសកនោះ ឧបាសិកានោះក៏ដូចគ្នា មិនមានសទ្ធា មិនជ្រះថ្លា បាយមួយវែកជាដើមក្នុងផ្ទះ ក៏នាងមិនឲ្យ សលាកភត្តជាដើមក៏មិនឲ្យ ការឲ្យបច្ច័យ មានចីវរជាដើម ក៏មិនមានដល់ឧបាសិកានោះ ។ ភិក្ខុនោះក៏ដូចគ្នា មិនមានសទ្ធា មិនជ្រះថ្លា មិនញុំាងឧបជ្ឈាយវត្ត មិនធ្វើអាចរិយវត្ត មិនធ្វើអាគន្តុកវត្ត មិនធ្វើវត្តដើម្បីភិក្ខុដែលត្រៀមនឹងទៅ មិនធ្វើវត្តទ្រង់លានព្រះចេតិយ មិនធ្វើវត្តក្នុងរោងឧបោសថ មិនធ្វើវត្តត្រង់រោងឆាន់ មិនធ្វើវត្ត មានវត្តក្នុងរោងភ្លើងជាដើម ទាំងធុតង្គណាមួយក៏មិនមានដល់លោក សូម្បីត្រឹមតែការឧស្សាហ៍ ត្រឹមតែជាបុគ្គលមានភាវនាមកជាទីត្រេកអរ ក៏មិនមាន ។

បាទព្រះគាថាថា **អត្តនោ វ អវេក្ខេយ្យ** សេចក្តីថា កុលបុត្រអ្នកបួសដោយសទ្ធា កាលរឭកដល់ឱវាទនេះថា បព្វជិតគប្បីពិចារណារឿយៗ ថា យប់ថ្ងៃកន្លងទៅ អញធ្វើអ្វី ដូច្នេះហើយ គប្បីមើលកិច្ចដែលធ្វើហើយ នឹងមិនទាន់បានធ្វើរបស់ខ្លួនយ៉ាងនេះថា អញមិនអាចលើកខ្លួនឡើងកាន់ត្រៃលក្ខណ៍ គឺ

អនិច្ចំ ទុក្ខំ អនត្តា ហើយធ្វើឲ្យក្សេមចាកយោគៈឬហ្ន៎ ។

ក្នុងកាលចប់ទេសនា ឧបាសិកាតាំងនៅក្នុងសោតាបត្តិផលហើយ ទេសនាបានជាប្រយោជន៍ដល់មហាជន ដូច្នេះឯង ។៚

**រឿង ឧបាសិកាជីវក ចប់**

# រឿង ឆត្តបាណិឧបាសក

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធឆត្តបាណិឧបាសក ត្រាស់ព្រះធម្មទេសនានេះថា **យថា បិ រុចិរំ បុប្ផំ** ជាដើម ។

សេចក្តីពិស្តារថា ក្នុងក្រុងសាវត្ថី មានឧបាសកម្នាក់ ឈ្មោះឆត្តបាណិ ជាអ្នកទ្រទ្រង់ព្រះត្រៃបិដក ជាព្រះអនាគាមី ។ ឧបាសកនោះ ជាអ្នករក្សាឧបោសថអំពីព្រលឹម បានទៅកាន់ទីបម្រើព្រះសាស្តា ។ មែនពិត ឈ្មោះថាឧបោសថកម្ម មិនមានដល់ព្រះអរិយសាវក ដែលជាអនាគាមីទាំងឡាយ ដោយអំណាចនៃការសមាទានឡើយ ព្រហ្មចរិយៈ និងការបរិភោគកត្តម្តង របស់អរិយសាវកដែលជាអនាគាមីទាំងនោះ មកហើយដោយមគ្គនោះឯង ព្រោះហេតុនោះឯង ទើបព្រះដ៏មានព្រះភាគត្រាស់ថា បពិត្រមហារាជ ឃដិការស្មូនឆ្នាំង ជាអ្នកបរិភោគកត្តតែ ១ ពេល ប្រព្រឹត្តធម៌ដ៏ប្រសើរ ជាអ្នកមានសីល មានកល្យាណធម៌ ។ ដោយប្រក្រតីនោះឯង ព្រះអនាគមីទាំងឡាយ ជាអ្នក

បរិភោគកក្កុម្ភង និងមានប្រក្រតីប្រព្រឹត្តព្រហ្មចរិយៈយ៉ាងនោះ ។ ឧបាសក នោះ ក៏ជាអ្នករក្សាឧបោសថយ៉ាងនោះដូចគ្នា ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយ អង្គុយស្តាប់ធម្មកថា ។

ក្នុងសម័យនោះ ព្រះបាទបសេនទិកោសល បានយាងទៅកាន់ទីបម្រើ ព្រះសាស្តា ឧបាសកឃើញព្រះរាជាយាងមក គិតថា អញគួរក្រោកឡើងដែរ ឬទេហ្ន៎ ដូច្នេះហើយ ក៏មិនក្រោកឡើង ដោយសម្គាល់ថា អញអង្គុយក្នុង សម្នាក់របស់អគ្គរាជា ការដែលអញឃើញស្តេចបទេសរាជ ហើយក្រោកឡើង ទទួលមិនគួរ កាលអញមិនក្រោកឡើង ព្រះរាជាទ្រង់នឹងពិរោធ កាលព្រះ រាជាទ្រង់ពិរោធ អញក៏មិនក្រោកទទួល ព្រោះថា អញឃើញព្រះរាជាហើយ ក្រោកឡើង ឈ្មោះថា ជាការធ្វើសេចក្តីគោរពព្រះរាជា មិនធ្វើសេចក្តីគោរព ព្រះសាស្តា អញមិនក្រោកឡើងឡើយ ។

ធម្មតាបុរសដែលជាបណ្ឌិត ឃើញបុគ្គលដែលអង្គុយក្នុងសម្នាក់របស់ បុគ្គលដែលគួរគោរពជាង មិនក្រោកឡើង រមែងមិនក្រោធ ។ តែព្រះរាជា ឃើញឧបាសកនោះមិនក្រោកឡើង មានព្រះហឫទ័យអាក់អន់ ថ្វាយបង្គំព្រះ សាស្តាហើយ ប្រថាប់គង់ក្នុងទីសមគួរ នាចំណែកម្ខាង ។ ព្រះសាស្តា ទ្រង់ ជ្រាបភាពដែលព្រះរាជាពិរោធ ទើបត្រាស់ពណ៌នាគុណឧបាសកថា បពិត្រ មហារាជ ឆត្តបាណិឧបាសកនេះជាបណ្ឌិត មានធម៌ឃើញហើយ ទ្រទ្រង់ព្រះ ត្រៃបិដក ឈ្លាសក្នុងប្រយោជន៍ និងមិនជាប្រយោជន៍ ។ កាលព្រះរាជា ទ្រង់ស្តាប់គុណកថារបស់ឧបាសកនោះឯង ព្រះហឫទ័យក៏ទោរទន់ ។

ក្រោយមកថ្ងៃមួយ ព្រះរាជាប្រថាប់ឈរលើប្រាសាទខាងលើ ទតឃើញឆត្តបាណិឧបាសក ធ្វើភត្តកិច្ចស្រេចហើយ កាន់ឆត្រ ពាក់ស្បែកជើង ដើរតាមលានព្រះរាជវាំង ទើបត្រាស់ឲ្យរាជបុរសហៅមក ឧបាសកនោះតម្កល់ឆត្រ ដោះស្បែកជើងចេញហើយ ចូលទៅរកព្រះរាជា ថ្វាយបង្គំហើយ បានឈរនៅក្នុងទីសមគួរ នាចំណែកម្ខាង គ្រានោះ ព្រះរាជាត្រាស់នឹងឧបាសកនោះថា នែឧបាសក ហេតុអ្វី ទើបអ្នកតម្កល់ឆត្រ និងដោះស្បែកជើងចេញ ឧបាសកពោលថា ទូលបង្គំបានឮថា ទ្រង់ត្រាស់ហៅរក ទើបមកហើយ ។ ព្រះរាជាត្រាស់ថា កាលដែលខ្ញុំជាព្រះរាជា ប្រហែលជាអ្នកទើបតែដឹងក្នុងថ្ងៃនេះទេដឹង ឧបាសកពោលថា ទូលបង្គំជ្រាបកាលដែលទ្រង់ជាព្រះរាជាសព្វកាល ព្រះរាជាត្រាស់ថា បើយ៉ាងនោះ ហេតុអ្វី ក្នុងថ្ងៃមុន អ្នកអង្គុយក្នុងសម្នាក់ព្រះសាស្តា ឃើញខ្ញុំហើយ មិនក្រោកឡើងទទួល ឧបាសកពោលថា បពិត្រមហារាជ ទូលបង្គំអង្គុយក្នុងសម្នាក់របស់អគ្គរាជា បើឃើញព្រះរាជាដែលជាបទេសរាជ ហើយក្រោកឡើង ឈ្មោះថា មិនគោរពក្នុងព្រះសាស្តា ព្រោះដូច្នេះ ទើបទូលបង្គំមិនក្រោកឡើង ព្រះរាជាត្រាស់ថា ណ្ហើយចុះ អ្នក សេចក្តីនេះស្ទះទុកសិន បានឮថា អ្នកឈ្លាសក្នុងប្រយោជន៍ និងមិនមែនជាប្រយោជន៍ ដែលប្រព្រឹត្តទៅក្នុងទិដ្ឋធម៌ និងសម្បរាយភព ទ្រទ្រង់ព្រះត្រៃបិដក ចូរប្រាប់ធម៌ដល់ខ្ញុំខាងក្នុងវាំងចុះ ឧបាសកពោលថា បពិត្រព្រះសម្មតិទេព ទូលបង្គំមិនអាចទេ ព្រះរាជាត្រាស់ថា ព្រោះហេតុអ្វី ឧបាសកពោលថា ព្រោះថា ឈ្មោះថា ព្រះរាជមន្ទីរ រមែងជាទីកន្លែងដែលមានទោស

ច្រើន បពិត្រព្រះសម្មតិទេព ក្នុងព្រះរាជមន្ទីរនេះ កម្មដែលបុគ្គលប្រកប អាក្រក់ និងល្អ រមែងជាកម្មធ្ងន់ ព្រះរាជាត្រាស់ថា អ្នកកុំពោលយ៉ាងនោះ កុំធ្វើសេចក្ដីរង្កៀសថា ថ្ងៃមុន ឃើញខ្ញុំហើយ មិនក្រោកឡើង ឧបាសក ពោលថា បពិត្រព្រះសម្មតិទេព ឈ្មោះថា ទីកន្លែងដែលត្រាច់របស់ពួក គ្រហស្ថ ជាទីដែលមានទោស សូមទ្រង់និមន្តបព្វជិតមួយរូបមកហើយ ឲ្យ ត្រាស់ធម៌ចុះ ។

ព្រះរាជា ទ្រង់បញ្ជូនឆត្តបាណិឧបាសកនោះទៅដោយព្រះវាចាថា សាធុ អ្នក ចូរអ្នកទៅចុះ ដូច្នេះហើយ ទ្រង់ទៅកាន់ទីគាល់ព្រះសាស្ដា ទូលសូម នឹងព្រះសាស្ដាថា បពិត្រព្រះអង្គ នាងសម្មិកាទេវី និងនាងវាសភខត្តិយា ពោល ថា ចង់រៀនធម៌ សូមទ្រង់ មួយអន្ទើដោយភិក្ខុ ៥០០ រូប យាងទៅកាន់វាំង របស់ខ្ញុំព្រះអង្គជានិច្ច ទ្រង់សម្ដែងធម៌ដល់នាងទាំងពីរ ព្រះសាស្ដាត្រាស់ថា មហាបពិត្រ ធម្មតាព្រះពុទ្ធទាំងឡាយ ទៅក្នុងទីមួយកន្លែងជានិច្ចមិនមាន ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ បើយ៉ាងនោះ សូមទ្រង់ប្រទានភិក្ខុដទៃ ។

ព្រះសាស្ដា ទ្រង់បានប្រគល់ភារៈឲ្យដល់ព្រះអានន្ទត្ថេរ ។ ព្រះថេរៈទៅ សម្ដែងព្រះបាលីដល់ព្រះនាងទាំងនោះជានិច្ច ។ ក្នុងព្រះនាងទាំងនោះ ព្រះនាង មល្លិកាទេវីបានរៀន បានទន្ទេញ និងឲ្យព្រះថេរៈទទួលព្រះបាលីដោយគោរព ចំណែកព្រះនាងវាសភខត្តិយា មិនរៀន មិនទន្ទេញដោយគោរពនោះឯង មិន អាចឲ្យព្រះថេរៈទទួលព្រះបាលីដោយគោរពបាន ។ ថ្ងៃមួយ ព្រះសាស្ដា ត្រាស់សួរព្រះថេរៈថា ម្នាលអានន្ទ ឧបាសិកាទាំងពីរនៅរៀនធម៌ឬ ព្រះអានន្ទ

ទូលថា បពិត្រព្រះអង្គ នៅរៀន ព្រះសាស្តាត្រាស់ថា ឧបាសិកាមួយណា រៀនដោយគោរព ព្រះអានន្ទទូលថា បពិត្រព្រះអង្គ ព្រះនាងមល្លិកាទេវីរៀន ដោយគោរព ទន្ទេញដោយគោរព អាចឲ្យខ្ញុំព្រះអង្គទទួលព្រះបាលីដោយ គោរព ចំណែកធីតាដែលជាព្រះញាតិរបស់ព្រះអង្គ មិនរៀនដោយគោរព មិនទន្ទេញដោយគោរព មិនអាចឲ្យខ្ញុំព្រះអង្គ ទទួលព្រះបាលីដោយគោរព បានឡើយ ។

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់ព្រះថេរៈហើយ ត្រាស់ថា ម្នាល អានន្ទ ធម្មតាធម៌ដែលតថាគតពោលហើយ រមែងមិនមានផលដល់អ្នកមិន ស្តាប់ មិនរៀន មិនទន្ទេញ មិនសម្តែងដោយគោរព ដូចផ្កាមិនសម្បូរដោយ ពណ៌ មិនមានក្លិន ដូច្នោះ តែមានផលច្រើន មានអានិសង្សច្រើន ដល់ បុគ្គលដែលធ្វើកិច្ចទាំងឡាយ មានការស្តាប់ដោយគោរពជាដើម ដូច្នេះហើយ បានត្រាស់ព្រះគាថា ២ គាថាថា

**យថាបិ រុចិរំ បុប្ផំ វណ្ណវន្តំ អគន្ធកំ**
**ឯវំ សុភាសិតា វាចា អផលា ហោតិ អកុព្វតោ ។**
**យថាបិ រុចិរំ បុប្ផំ វណ្ណវន្តំ សគន្ធកំ**
**ឯវំ សុភាសិតា វាចា សផលា ហោតិ សុកុព្វតោ ។**

ផ្កាឈើមានទ្រង់ទ្រាយល្អ មានពណ៌ ( ល្អ ) តែគ្មានក្លិន
( ក្រអូប ) ( រមែងមិនក្រអូបដល់អ្នកដែលទ្រទ្រង់ )
ដូចម្តេចមិញ វាចាជាសុភាសិត រមែងគ្មានផលដល់អ្នក

*ដែលមិនធ្វើតាមដូច្នោះ ផ្កាឈើដែលមានទ្រង់ទ្រាយល្អ មានពណ៌ល្អ មានក្លិន ( រមែងក្រអូបដល់អ្នកដែលទ្រទ្រង់ ) ដូចម្តេចមិញ វាចាជាសុភាសិត រមែងមានផលដល់អ្នកដែលធ្វើតាមដោយគោរព ដូច្នោះឯង ។*

# សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ បទថា* **រុចិរំ** *គឺស្អាត ។ បទថា* **វណ្ណវន្តំ** *គឺបរិបូណ៌ដោយពណ៌ និងទ្រង់ទ្រាយ ។ បទថា* **អគន្ធកំ** *គឺប្រាសចាកក្លិន មានផ្កាសិរមាន់ ផ្កាកណិការ និងផ្កាជយព្រឹក្សជាដើម ជាប្រភេទ ។ បាទព្រះគាថាថា* **ឯវំ សុភាសិតា វាចា** *សេចក្តីថា ព្រះពុទ្ធវចនៈ គឺបិដក ៣ ឈ្មោះថាវាចាសុភាសិត ។ ព្រះពុទ្ធវចនៈនោះ ដូចផ្កាឈើសម្បូរដោយពណ៌ និងទ្រង់ទ្រាយ មិនមានក្លិន ។ ដូចផ្កាមិនមានក្លិន ក្លិនរមែងមិនផ្សាយ ទៅក្នុងសរីរៈបុគ្គលអ្នកទ្រទ្រង់នូវផ្កាមិនមានក្លិននោះ យ៉ាងណា សូម្បីព្រះពុទ្ធវចនៈនេះក៏ដូច្នោះ រមែងមិននាំក្លិន គឺការស្តាប់ ក្លិន គឺការទ្រទ្រង់ និងក្លិន គឺកិច្ចបដិបត្តិមកឲ្យ ឈ្មោះថា រមែងមិនមានផលដល់បុគ្គលមិនតាំងចិត្តប្រព្រឹត្តព្រះពុទ្ធវចនៈនោះដោយអើពើ ដោយកិច្ចទាំងឡាយ មានការស្តាប់ជាដើម ឈ្មោះថា ជាអ្នកមិនមានកិច្ចដែលគួរធ្វើក្នុងព្រះពុទ្ធវចនៈនោះ ព្រោះហេតុនោះ ទើបព្រះសាស្តាត្រាស់ថា វាចាសុភាសិតក៏ដូច្នោះ រមែងមិនមានផល ដល់បុគ្គលដែលមិនធ្វើ ។*

*បទថា* **សគន្ធកំ** *បានដល់ ផ្កាចម្ប៉ា និងឈូកខៀវជាដើមជាប្រភេទ ។*

បទថា **ឯវំ** ជាដើម សេចក្តីថា ក្លិនរមែងផ្សាយទៅក្នុងសរីរៈរបស់បុគ្គលដែលទ្រទ្រង់ផ្កានោះយ៉ាងណា សូម្បីវាចាសុភាសិត ពោល គឺព្រះពុទ្ធវចនៈ បានដល់ព្រះត្រៃបិដកក៏ដូច្នោះ រមែងមានផល គឺឈ្មោះថា មានផលច្រើន មានអានិសង្សច្រើន ព្រោះនាំក្លិន គឺការស្តាប់ ក្លិន គឺការទ្រទ្រង់ចាំ ក្លិន គឺកិច្ចបដិបត្តិមក ឲ្យដល់បុគ្គលអ្នកធ្វើល្អ គឺបុគ្គលដែលតាំងចិត្តធ្វើកិច្ចដែលគួរធ្វើក្នុងព្រះពុទ្ធវចនៈនោះ ដោយកិច្ចទាំងឡាយ មានការស្តាប់ជាដើម ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ ទេសនាក៏បានកើតជាប្រយោជន៍ដល់មហាជនដូច្នោះឯង ។l៚

**រឿង ឆត្តបាណិឧបាសក ចប់**

# រឿង នាងវិសាខា

## លំនាំដើម

ព្រះសាស្តា កាលទ្រង់ចូលទៅអាស្រ័យក្រុងសាវត្ថី ប្រថាប់នៅក្នុងបុព្វារាម ទ្រង់ប្រារព្ធឧបាសិកាឈ្មោះវិសាខា ត្រាស់ធម្មទេសនានេះថា **យថាបិ បុប្ផរាសិម្ហា** ជាដើម ។

បានឮមកថា នាងវិសាខាឧបាសិកានោះ កើតក្នុងផ្ទៃនាងសុមនាទេវី ករិយាធំរបស់ធនញ្ជយសេដ្ឋី ជាកូនមេណ្ឌកសេដ្ឋី ក្នុងភត្តិយនគរ ដែនអង្គៈ

ក្នុងកាលដែលនាងមានអាយុ ៧ ឆ្នាំ ព្រះសាស្តាទ្រង់ឃើញឧបនិស្ស័យសម្បត្តិ របស់សត្វ ដែលមានផៅពង្សគ្រប្បីទូន្មាន ដើម្បីការត្រាស់ដឹង មានសេលៈ-ព្រាហ្មណ៍ជាដើម មានមហាភិក្ខុសង្ឃជាបរិវារ ទ្រង់ចារិកទៅដល់នគរនោះ ។

ក្នុងសម័យនោះ មេណ្ឌកគហបតី ជាប្រធានរបស់អ្នកមានបុណ្យច្រើន ៥ នាក់ គ្រប់គ្រងតំណែងសេដ្ឋីក្នុងនគរនោះ ។ បុគ្គលមានបុណ្យច្រើន ៥ នាក់ គឺមេណ្ឌកសេដ្ឋី ១ ភរិយាធំរបស់សេដ្ឋីឈ្មោះចន្ទបទុមា ១ កូនប្រុសច្បងរបស់សេដ្ឋីឈ្មោះធនញ្ជ័យ ១ ភរិយារបស់ធនញ្ជ័យឈ្មោះសុមនាទេវី ១ អ្នកបម្រើរបស់មេណ្ឌកសេដ្ឋីឈ្មោះបុណ្ណៈ ១ ។

មិនមែនមានតែមេណ្ឌកសេដ្ឋី ១ ប៉ុណ្ណោះទេ ក្នុងដែនរបស់ព្រះបាទពិម្ពិសារ ក៏មានបុគ្គលអ្នកមានភោគៈរាប់មិនអស់ ចំនួន ៥ នាក់ គឺជោតិកៈ ១ ជដិលៈ ១ មេណ្ឌកៈ ១ បុណ្ណកៈ ១ កាកវលិយៈ ១ ។

ក្នុងជនទាំងនោះ មេណ្ឌកសេដ្ឋីបានជ្រាបភាពដែលព្រះទសពល យាងមកដល់នគររបស់ខ្លួន ទើបហៅទារិកាឈ្មោះវិសាខា ដែលជាកូនស្រីធនញ្ជ័យ-សេដ្ឋី ដែលជាកូនមកប្រាប់ថា នែនាង ជាមង្គលដល់នាងផង ដល់យើងផងនាង និងទារិកាបរិវាររបស់នាង ៥០០ ចូរឡើងរទេះសេះ ៥០០ ចោមរោមដោយទាសី ៥០០ ទៅធ្វើការទទួលព្រះទសពល នាងទទួលថា សាធុ ហើយបានធ្វើយ៉ាងនោះ ។ តែព្រោះភាពដែលនាងជាក្មេងឈ្លាស ក្នុងហេតុដែលគួរ និងមិនគួរ ទើបទៅដោយយាន ដែលល្មមយានទៅបាន ចុះអំពីយានហើយ ក៏ដើរទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយ ឈរក្នុងទីសមគួរ

នាចំណែកម្ខាង ។ កាលនោះ ព្រះសាស្តាទ្រង់សម្តែងធម៌ ដោយអំណាច បុព្វចរិយារបស់នាង ។

ក្នុងកាលចប់ទេសនា នាង មួយអន្លើដោយទាសិកា ៥០០ តាំងនៅក្នុងសោតាបត្តិផលហើយ ។ ចំណែកមេណ្ឌកសេដ្ឋី ចូលគាល់ព្រះសាស្តា ស្តាប់ធម្មកថា តាំងនៅក្នុងសោតាបត្តិផលហើយ ទើបនិមន្តដើម្បីសោយក្នុងថ្ងៃស្អែក អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយខាទនីយៈ ភោជនីយៈដ៏ប្រណីតត្រង់ផ្ទះរបស់ខ្លួន បានថ្វាយមហាទានដោយឧបាយនេះឯង រហូតកន្លះខែ ។ ព្រះសាស្តាប្រថាប់នៅក្នុងភទ្ទិយនគរ តាមសមគួរដល់ព្រះហឫទ័យហើយ ទ្រង់ចៀសចេញទៅ ។

សម័យនោះឯង ព្រះបាទពិម្ពិសារ និងព្រះបាទបសេនទិកោសល ដែលជាបងប្អូនថ្លៃនឹងគ្នា ថ្ងៃមួយ ព្រះបាទកោសលទ្រង់ព្រះតម្រិះថា បុគ្គលមានភោគៈរាប់មិនអស់ ជាអ្នកមានបុណ្យច្រើនទាំង ៥ នាក់ នៅក្នុងដែនព្រះបាទពិម្ពិសារ ឯក្នុងដែនរបស់អញ បុគ្គលមានសភាពបែបនោះ សូម្បីតែម្នាក់ក៏មិនមាន ។ កុំដូច្នោះឡើយ អញគប្បីទៅកាន់សម្នាក់របស់ព្រះបាទពិម្ពិសារ សុំអ្នកមានបុណ្យច្រើនណាម្នាក់ ។

ទ្រង់យាងទៅក្នុងនគរនោះហើយ កាលព្រះរាជា ទ្រង់ធ្វើបដិសណ្ឋារៈ ទូលសួរថា ទ្រង់យាងមកព្រោះហេតុអ្វី ទើបត្រាស់ថា ខ្ញុំមកដោយបំណងថា បុគ្គលមានភោគៈរាប់មិនអស់ មានបុណ្យច្រើនទាំង ៥ នាក់ នៅក្នុងដែនរបស់ទ្រង់ ខ្ញុំនឹងនាំយកបុគ្គលណាម្នាក់ ក្នុងបណ្តាជនទាំង ៥ នោះទៅ សូមទ្រង់

ប្រទានបុគ្គលណាម្នាក់ក្នុងជនទាំង ៥ នោះដល់ខ្ញុំចុះ ព្រះបាទពិម្ពិសារត្រាស់ថា ខ្ញុំមិនអាចឲ្យត្រកូលធំៗ ផ្លាស់ទីកន្លែងបាន ព្រះបាទបសេនទិកោសលត្រាស់ថា បើខ្ញុំមិនបាន ក៏មិនទៅ ។

ព្រះរាជា ទ្រង់ប្រឹក្សាជាមួយពួកអមាត្យហើយត្រាស់ថា ឈ្មោះថា ការបំបែកត្រកូលធំៗ មានជោតិកត្រកូលជាដើម ហាក់ដូចជាធ្វើផែនដីឲ្យកម្រើក ។ កូនរបស់មេណ្ឌកមហាសេដ្ឋី ឈ្មោះធនញ្ជយសេដ្ឋីមាន ទូលបង្គំប្រឹក្សាជាមួយគាត់ស្រេចហើយ នឹងថ្វាយចម្លើយដល់ព្រះអង្គ ដូច្នេះហើយ បញ្ជាឲ្យហៅធនញ្ជយសេដ្ឋីមកហើយត្រាស់ថា នែបា ព្រះបាទកោសលត្រាស់ថា នឹងនាំយកសេដ្ឋីមានទ្រព្យម្នាក់ទៅ ចូរអ្នកទៅជាមួយព្រះអង្គចុះ ធនញ្ជយសេដ្ឋីពោលថា បើទ្រង់បញ្ជូនទូលបង្គំទៅ ទូលបង្គំនឹងទៅ ព្រះបាទពិម្ពិសារត្រាស់ថា បើដូច្នោះ ចូរអ្នកត្រៀមទៅចុះ សេដ្ឋីនោះបានធ្វើកិច្ចដែលគួរធ្វើរបស់ខ្លួនហើយ ចំណែកព្រះរាជាទ្រង់ធ្វើសក្ការៈធំដល់សេដ្ឋីនោះ ទ្រង់បញ្ជូនព្រះបាទបសេនទីកោសល ទៅដោយព្រះតម្រាស់ថា សូមទ្រង់នាំសេដ្ឋីនោះទៅចុះ ។ ព្រះរាជានាំធនញ្ជយសេដ្ឋីនោះយាងទៅ ដោយការស្នាក់នៅមួយរាត្រីក្នុងទីទាំងពួង សម្រេចដល់ទីដែលជាផាសុកមួយកន្លែងហើយក៏ឈប់ ។

គ្រានោះ ធនញ្ជយសេដ្ឋីទូលសួរព្រះរាជាថា នេះជាដែនរបស់អ្នកណា ព្រះបាទបសេនទិកោសលត្រាស់ថា លោកសេដ្ឋី គឺរបស់យើង ធនញ្ជ័យពោលថា ក្រុងសាវត្ថី បន្ទាប់អំពីនេះទៅចម្ងាយប៉ុន្មាន ព្រះបាទបសេនទិកោ-សលត្រាស់ថា ក្នុងទីបំផុត ៧ យោជន៍ ។ ធនញ្ជយសេដ្ឋីពោលថា ខាង

ក្នុងព្រះនគរបង្អៀត បរិវារជនរបស់ទូលបង្គំមានច្រើន បើទ្រង់អនុគ្រោះ សោត ខ្ញុំព្រះអង្គគប្បីនៅក្នុងទីនេះឯង ព្រះរាជាត្រាស់ថា សាធុ ដូច្នេះហើយ បានឲ្យសាងក្រុងក្នុងទីនោះ បានព្រះរាជទានដល់សេដ្ឋីនោះហើយយាងទៅ ។ ក្រុងបានឈ្មោះថា **សាកេត** ព្រោះភាពនៃទីលំនៅក្នុងប្រទេសនោះ ដែល សេដ្ឋីចងចិត្តទុកហើយក្នុងពេលល្ងាច ។

ក្នុងក្រុងសាវត្ថី កូនរបស់មិគារសេដ្ឋី ឈ្មោះបុណ្ណវឌ្ឍនកុមារ ចម្រើន វ័យហើយ គ្រានោះ មាតាបិតាពោលនឹងបុណ្ណវឌ្ឍនៈថា នែបា ចូរបាជ្រើស រើសទារិកាម្នាក់ ក្នុងទីជាទីពេញរបស់បាចុះ ។ បុណ្ណវឌ្ឍនកុមារពោលថា កិច្ច ដោយកិរិយារបស់ខ្ញុំមិនមាន មាតាបិតាពោលថា បាកុំធ្វើយ៉ាងនេះ ធម្មតា ត្រកូលដែលមិនមានកូន តាំងនៅមិនបាន ។

កុមារត្រូវមាតាបិតានិយាយពន្យល់ហើយ ទើបពោលថា បើដូច្នោះ ខ្ញុំ កាលបានស្ត្រីប្រកបដោយលម្អ ៥ យ៉ាង នឹងធ្វើតាមពាក្យពុកម៉ែ មាតាបិតា ពោលថា ឈ្មោះថា លម្អ ៥ យ៉ាងនោះ គឺអ្វី បុណ្ណវឌ្ឍនកុមារពោលថា គឺ លម្អសក់ លម្អសាច់ លម្អឆ្អឹង លម្អស្បែក លម្អវ័យ ។ សក់របស់ស្រី ដែលមានបុណ្យច្រើន ដូចគ្នានឹងកាំនៃកន្ទុយក្ងោក ធ្លាក់រំសាយដល់ជាយ សំពត់ស្លៀកហើយ ក៏មានចុង-ងឡើងតាំងនៅ ។ នេះ ឈ្មោះថា លួសក់ បបូរមាត់ដូចគ្នានឹងផ្លែបាសទុំ ដល់ព្រមដោយពណ៌របស្មើល្អ នេះ ឈ្មោះថា លម្អសាច់ ។ ធ្មេញសរាបស្មើមិនរង្វើល ស្អាតដូចជួរនៃពេជ្រដែលគេតម្រៀប និងដូចជួរនៃសង្ខដែលគេខាត់ល្អហើយ នេះ ឈ្មោះថា លម្អឆ្អឹង ។ ពណ៌

សម្បុររបស់ស្រីខ្មៅ មិនលាបដោយគ្រឿងលាបជាដើម ក៏ខ្មៅស្មុគ្គ ប្រៀបដូចកម្រងផ្កាឧប្បលខៀវរបស់ស្រីដែលស ប្រៀបដូចកម្រងផ្កាកណិការ នេះឈ្មោះថា លម្អស្បែក ។ ស្រីដែលប្រសូតហើយ ១០ ដង ដូចប្រសូតម្តងនៅក្មេងដដែល នេះ ឈ្មោះថា លម្អវ័យ ។

គ្រានោះ មាតាបិតារបស់នាយបុណ្ណវឌ្ឍនកុមារនោះ អញ្ជើញព្រាហ្មណ៍ ១០៨ នាក់ ឲ្យមកបរិភោគហើយ សួរថា ឈ្មោះថា ស្រីដែលត្រូវដោយលក្ខណៈបញ្ចកល្យាណីមានឬ ព្រាហ្មណ៍ឆ្លើយថា មាន សេដ្ឋីពោលថា បើដូច្នោះ ជន ៨ នាក់ ចូរទៅស្វែងរកទារិកាបែបនេះ ដូច្នេះហើយ ឲ្យទ្រព្យជាច្រើន ប្រាប់ថា ក្នុងកាលពួកអ្នកត្រឡប់ យើងខ្ញុំនឹងដឹងវត្ថុដែលគួរធ្វើដល់ពួកអ្នក អ្នកទាំងឡាយ ចូរទៅស្វែងរកស្ត្រីបែបនោះចុះ ក្នុងកាលដែលអ្នកជួបហើយ គប្បីពាក់កម្រងមាសនេះ ដូច្នេះហើយ ឲ្យកម្រងផ្កាមាសដែលមានតម្លៃមួយសែន បញ្ជូនទៅហើយ ។

ព្រាហ្មណ៍ទាំងនោះ ទៅកាន់នគរធំៗ ស្វែងរក មិនឃើញស្រីដែលត្រូវដោយលក្ខណៈបញ្ចកល្យាណី ត្រឡប់មកដល់ក្រុងសាកេតដោយលំដាប់ ក្នុងថ្ងៃមានបុណ្យនក្ខត្តឫក្ស ទើបគិតគ្នាថា ការងាររបស់ពួកយើងគង់សម្រេចក្នុងថ្ងៃនេះ ។

ក្នុងនគរនោះ ឈ្មោះថា បុណ្យនក្ខត្តឫក្ស រមែងមានប្រចាំឆ្នាំ ។ ក្នុងកាលនោះ សូម្បីត្រកូលដែលមិនចេញខាងក្រៅ ក៏ចេញអំពីផ្ទះជាមួយបរិវារមានរាងកាយមិនបានបិទបាំង ទៅកាន់ស្ទឹងដោយជើងនោះឯង ក្នុងថ្ងៃនោះ

សូម្បីកូនទាំងឡាយរបស់ខត្តិយមហាសាលជាដើម ក៏ឈរក្បែរផ្លូវនោះៗ ដោយតាំងចិត្តថា ពួកយើងជួបទារិកាដែលមានត្រកូល ដែលគួរពេញចិត្ត មានជាតិស្មើគ្នាហើយ នឹងពាក់ដោយកម្រងផ្កា ។

ព្រាហ្មណ៍ទាំងនោះទៅដល់សាលាមួយ ជិតទ្វារស្ទឹងហើយ ក៏ឈរ ។ ខណៈនោះ នាងវិសាខាមានអាយុ ១៥-១៦ ឆ្នាំ ប្រដាប់ដោយគ្រឿងអាភរណៈគ្រប់យ៉ាង ដែលពួកកុមារី ៥០០ ចោមរោមហើយ គិតថា អញនឹងទៅកាន់ស្ទឹងហើយ ងូតទឹក ដល់ប្រទេសនោះហើយ ។ គ្រានោះឯង ពពកតាំងឡើង ក៏ញ៉ាំងភ្លៀងឲ្យធ្លាក់ ។ ទារិកា ៥០០ រត់រះដើរចូលកាន់សាលា ពួកព្រាហ្មណ៍ពិចារណាមើល ក៏មិនឃើញក្មេងស្រីទាំងនោះ សូម្បីត្រឹមតែម្នាក់ ដែលត្រូវដោយលក្ខណៈបញ្ចកល្យាណី ។ នាងវិសាខាចូលទៅកាន់សាលា ដោយការដើរតាមប្រក្រតីនោះឯង សំពត់ និងអាភរណៈសើមជោក ។ ពួកព្រាហ្មណ៍ឃើញលម្អ ៤ យ៉ាងរបស់នាងហើយ បំណងនឹងឃើញធ្មេញទើបពោលនឹងគ្នាថា កូនស្រីរបស់យើងជាស្រីយឺតយាវ ប្ដីរបស់ស្រីនេះប្រហែលជាមិនបាន សូម្បីត្រឹមតែចុងអង្ករ ពេលនោះ វិសាខាពោលនឹងព្រាហ្មណ៍នោះយ៉ាងនេះថា ពួកលោកថាឲ្យអ្នកណា ព្រាហ្មណ៍ពោលថា ខ្ញុំថាឲ្យនាងហ្នឹង ។

បានឮថា សំឡេងដ៏ពីរោះរបស់នាង បានបន្លឺរចេញប្រៀបដូចសំឡេងជួង លំដាប់នោះ ទើបនាងសួរព្រាហ្មណ៍ទាំងនោះ ដោយសំឡេងដ៏ពីរោះទៀតថា ព្រោះហេតុអ្វី ទើបថាឲ្យខ្ញុំ ព្រាហ្មណ៍ពោលថា ស្រីបរិវាររបស់

នាងមិនឲ្យសំពត់ និងគ្រឿងអលង្ការសើម ប្រញាប់ចូលកាន់សាលា កិច្ចសូម្បីត្រឹមតែការប្រញាប់មកកាន់ទីប្រមាណប៉ុណ្ណោះរបស់នាង មិនមាន នាងបណ្ដោយឲ្យសំពត់ និងគ្រឿងអាភរណៈសើមហើយ ព្រោះដូច្នោះ ទើបពួកយើងនាំគ្នាថា នាងវិសាខាពោលថា លោកឪពុកទាំងឡាយ ពួកលោកកុំពោលយ៉ាងនេះ ខ្ញុំរឹងមាំជាងក្មេងស្រីទាំងនោះ តែខ្ញុំកំណត់ហេតុការណ៍ហើយទើបមិនមកដោយរហ័ស ព្រាហ្មណ៍ពោលថា នែនាង តើហេតុអ្វីទៅ នាងវិសាខាពោលថា លោកឪពុកទាំងឡាយ ជន ៤ ពួករត់រមែងមិនល្អជាហេតុ ១ សូម្បីហេតុដទៃទៀត ក៏នៅមាន ព្រាហ្មណ៍ពោលថា ជន ៤ ពួក ពួកណាខ្លះ កាលរត់ មិនល្អ នាងវិសាខាពោលថា លោកឪពុកទាំងឡាយ ព្រះរាជាដែលអភិសេកហើយ ទ្រង់គ្រឿងអលង្ការហើយ ដោយអាភរណៈទាំងពួង កាលចងក្បិនរត់ទៅក្នុងលានព្រះរាជវាំង មិនល្អ តែងបាននូវការនិន្ទាដោយពិតប្រាកដថា ហេតុអ្វី ទើបព្រះរាជាអង្គនេះរត់ដូចគហបតី ទ្រង់យាងទៅសន្សឹមៗ នោះឯង ទើបល្អ ដំរីមង្គលរបស់ព្រះរាជា ដែលគាក់តែងគ្រឿងអលង្ការហើយ រត់ទៅក៏មិនល្អ លុះតែដើរទៅដោយហត្ថិលីលា ទើបល្អ ។ បព្វជិតកាលរត់ក៏មិនល្អ រមែងបាននូវការនិន្ទាតែម្យ៉ាងប៉ុណ្ណោះថា ហេតុអ្វីទើបសមណៈរូបនេះរត់ទៅដូចគ្រហស្ថ តែរមែងស្អាតដោយការដើរ ដោយអាការរបស់អ្នកស្ងប់ស្ងៀម ស្ត្រីកាលរត់ក៏មិនល្អ ត្រូវគេតិះដៀលតែម្យ៉ាងថា ហេតុអ្វី ទើបស្រីនេះរត់ដូចបុរស តែរមែងល្អដោយការដើរតាមធម្មតា នែលោកឪពុកទាំងឡាយ ជន ៤ ពួកនេះ បើរត់ទៅ មិនល្អ ។

ព្រាហ្មណ៍ពោលថា ហេតុដទៃទៀតនៅមានដូចម្ដេច នាងវិសាខាពោលថា លោកឪពុកទាំងឡាយ ធម្មតាមាតាបិតាថែរក្សាអវយវៈតូចធំ មើលថែរក្សាកូនស្រី ព្រោះថា ពួកខ្ញុំ ឈ្មោះថា ជារបស់ដែលមាតាបិតាគប្បីលក់ដូរ មាតាបិតាចិញ្ចឹមខ្ញុំមក ដើម្បីបញ្ជូនទៅកាន់ត្រកូលដទៃ បើក្នុងកាលពួកខ្ញុំរត់ទៅ ជាន់ជាយសំពត់ ឬដួលចុះត្រង់ផែនដី ដៃ ឬជើងគប្បីបាក់ ពួកខ្ញុំក៏គប្បីជាភារៈរបស់ត្រកូលនោះឯង ចំណែកគ្រឿងអលង្ការសើមហើយក៏នឹងស្ងួត ខ្ញុំកំណត់ហេតុនេះ ទើបមិនរត់ ពួកព្រាហ្មណ៍ឃើញការដល់ព្រមនៃធ្មេញ ក្នុងកាលដែលនាងនិយាយ ទើបឲ្យសាធុការដល់នាងថា សម្បត្តិបែបនេះ ពួកយើងមិនធ្លាប់ឃើញឡើយ ហើយពោលថា នៃនាង កម្រងផ្កានេះ សមគួរដល់នាងប៉ុណ្ណោះ ដូច្នេះហើយ ទើបបំពាក់កម្រងផ្កាមាសនោះឲ្យ លំដាប់នោះ ទើបនាងសួរពួកព្រាហ្មណ៍ថា លោកឪពុកទាំងឡាយ ពួកលោកមកអំពីនគរណា ព្រាហ្មណ៍ពោលថា មកអំពីនគរសាវត្ថី នាងវិសាខាពោលថា ត្រកូលសេដ្ឋីឈ្មោះអ្វី ព្រាហ្មណ៍ពោលថា ឈ្មោះមិគារសេដ្ឋី នាងវិសាខាពោលថា កូនប្រុសរបស់លោកឈ្មោះអ្វី ព្រាហ្មណ៍ពោលថា ឈ្មោះបុណ្ណវឌ្ឍនកុមារ ។

នាងវិសាខាទទួលថា ត្រកូលរបស់យើងស្មើគ្នា ដូច្នេះហើយ ទើបបញ្ជូនដំណឹងដល់បិតាថា សូមលោកឪពុកអ្នកម្ដាយ បញ្ជូនរថមកឲ្យខ្ញុំចុះ ។ ក្នុងកាលដែលមក នាងដើរមកក៏ពិត តែកាលដែលប្រដាប់ដោយកម្រងផ្កាមាសហើយ មិនបានទៅដូច្នោះ ឃើញស្រីទាំងឡាយដែលមានឥស្សរៈ រមែងទៅដោយយាន មានរថជាដើម ស្រីក្រៅអំពីនេះឡើងយានធម្មតា បាំងឆត្រ ឬ

ស្លឹកត្នោតខាងលើ កាលធត្រ ឬស្លឹកត្នោតនោះមិនមាន ក៏លើកជាយសំពត់ឡើងមកបាំងលើស្មានោះឯង ។ ចំណែកបិតារបស់នាងវិសាខានោះ បញ្ជូនរថទៅ ៥០០ គ្រឿង នាងវិសាខាឡើងរថទៅហើយ សូម្បីពួកព្រាហ្មណ៍ក៏បានទៅជាមួយគ្នា ។

ពេលនោះ លោកសេដ្ឋីសួរព្រាហ្មណ៍ទាំងនោះថា ពួកអ្នកមកអំពីណា ព្រាហ្មណ៍ពោលថា បពិត្រលោកសេដ្ឋី ខ្ញុំមកពីក្រុងសាវត្ថី សេដ្ឋីពោលថា សេដ្ឋីរបស់អ្នកឈ្មោះអ្វី ព្រាហ្មណ៍ពោលថា ឈ្មោះមិគារសេដ្ឋី សេដ្ឋីពោលថា កូនរបស់គេឈ្មោះអ្វី ព្រាហ្មណ៍ពោលថា ឈ្មោះបុណ្ណវឌ្ឍនកុមារ សេដ្ឋីពោលថា មានទ្រព្យប៉ុន្មាន ព្រាហ្មណ៍ពោលថា បពិត្រលោកសេដ្ឋី ៤០ កោដិ សេដ្ឋីស្តាប់ពាក្យហើយគិតថា ទ្រព្យប៉ុណ្ណោះ បើប្រៀបធៀបនឹងទ្រព្យរបស់ខ្ញុំស្មើគ្នានឹងមួយកាកណិក ។ តែប្រយោជន៍អ្វីដោយហេតុដទៃ ចាប់តាំងអំពីកាលដែលនាងទារិកា បានហេតុត្រឹមតែការរក្សា សេដ្ឋីនោះធ្វើសក្ការៈដល់ព្រាហ្មណ៍ទាំងនោះ ឲ្យស្នាក់នៅ ២-៣ ថ្ងៃ ហើយបញ្ជូនត្រឡប់ទៅ ។

ពួកព្រាហ្មណ៍ទៅកាន់ក្រុងសាវត្ថីហើយ ជម្រាបលោកសេដ្ឋីថា ពួកខ្ញុំបាននាងទារិកាហើយ សេដ្ឋីពោលថា កូនស្រីរបស់អ្នកណា ព្រាហ្មណ៍ពោលថា របស់ធនញ្ជយសេដ្ឋី សេដ្ឋីនោះគិតថា នាងទារិកានៃត្រកូលធំដែលយើងបានហើយ យើងគួរតែនាំនាងមកដោយរហ័ស ដូច្នេះហើយ ក្រាបទូលដល់ព្រះរាជា ដើម្បីទៅក្នុងក្រុងនោះ ។

ព្រះរាជាទ្រង់ព្រះតម្រិះថា ត្រកូលធំនោះ យើងនាំមកអំពីសម្នាក់របស់

ព្រះបាទពិម្ពិសារ ហើយឲ្យនៅអាស្រ័យក្នុងក្រុងសាកេត គួរធ្វើការលើកតម្កើងដល់ត្រកូលនោះ ដូច្នេះហើយ ត្រាស់ថា សូម្បីយើងក៏ទៅ ។ សេដ្ឋីទូលថា សាធុ ព្រះអង្គ ដូច្នេះហើយ ក៏បញ្ជូនដំណឹងទៅប្រាប់ដល់ធនញ្ជយសេដ្ឋីថា កាលខ្ញុំមក ព្រះរាជាក៏នឹងយាងមក ពលរបស់ព្រះរាជាច្រើន អ្នកនឹងអាចធ្វើកិច្ចដែលគួរធ្វើ ដល់ជនមានប្រមាណប៉ុណ្ណោះ ឬក៏មិនអាចទេ ។

សេដ្ឋីបានបញ្ជូនដំណឹងទៅថា សូម្បីព្រះរាជាទ្រង់យាងមកត្រឹម ១០ អង្គ ក៏សូមយាងមកចុះ ។ មិគារសេដ្ឋីរៀរត្រឹមតែអ្នកយាមផ្ទះ នាំជនដ៏សេសក្នុងនគរធំ ដែលមានប្រមាណប៉ុណ្ណោះទៅ ឈប់សម្រាកក្នុងរវាងផ្លូវកន្លះយោជន៍ហើយ បញ្ជូនដំណឹងទៅថា ពួកខ្ញុំមកហើយ ។

ធនញ្ជយសេដ្ឋី បញ្ជូនគ្រឿងបណ្ណាការជាច្រើនទៅ ហើយប្រឹក្សានឹងកូនស្រីថា នែនាង បានឮថា ឪពុកក្មេករបស់នាង មកជាមួយព្រះបាទកោសល យើងគួររៀបចំផ្ទះមួយណា សម្រាប់ឪពុកក្មេករបស់នាង ផ្ទះខ្លះណាសម្រាប់ព្រះរាជា ផ្ទះខ្លះណាសម្រាប់ឥស្សរជន មានឧបរាជជាដើម សេដ្ឋីធីតាអ្នកឈ្លាស មានញាណមុតស្រួចដូចកំពូលពេជ្រ តាំងសេចក្តីប្រាថ្នាអស់សែនកប្ប បរិបូណ៌ហើយដោយអភិនីហារ ប្រាប់ថា អ្នកទាំងឡាយ ចូររៀបចំផ្ទះមួយនោះ ដើម្បីឪពុកក្មេករបស់យើង ផ្ទះមួយនោះ ដើម្បីព្រះរាជា ផ្ទះមួយនោះ ដើម្បីឧបរាជជាដើម ដូច្នេះហើយ ឲ្យហៅទាសៈ និងកម្មករមកប្រាប់ថា ពួកអ្នកប៉ុណ្ណោះនាក់ ចូរធ្វើកិច្ចដែលគួរធ្វើដល់ព្រះរាជា ប៉ុណ្ណោះនាក់ ចូរធ្វើកិច្ចដែលគួរធ្វើដល់ឧបរាជជាដើម ពួកអ្នកនោះឯង ចូរមើលថែពាហនៈ មានដំរី

និងសេះជាដើម ។ សូម្បីអ្នកចងសេះជាដើមមកដល់ហើយ នឹងបានសរសើរមហោស្រព ក្នុងការងារមង្គល ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះមនុស្សពួកខ្លះ កុំបីមានពាក្យពោលថា អញទៅមង្គលនៃនាងវិសាខា មិនបានអ្វីសោះ ធ្វើតែកិច្ចមានការឃ្វាលសេះជាដើម មិនបានដើរតាមសប្បាយ ។

ក្នុងថ្ងៃនោះឯង បិតារបស់នាងវិសាខាបានហៅជាងមាស ៥០០ នាក់មកហើយ ពោលថា ពួកអ្នកចូរធ្វើគ្រឿងអលង្ការឈ្មោះមហាលតាបសាធន៍ដល់កូនស្រីរបស់ខ្ញុំ ដូច្នេះហើយ បញ្ជាឲ្យយកមាស និងប្រាក់ កែវមណីកែវមុក្តា កែវប្រពាល និងពេជ្រជាដើម ល្មមសមគ្នានឹងមាសនោះ ។

ព្រះរាជាប្រថាប់នៅ ២-៣ ថ្ងៃហើយ ទ្រង់បញ្ជូនដំណឹងទៅដល់ធនញ្ជយសេដ្ឋីថា សេដ្ឋីមិនអាចធ្វើការអង្គាសពួកយើងបានទេ ចូរសេដ្ឋីដឹងកាលទៅនៃនាងទារិកាចុះ ។

ចំណែកសេដ្ឋីនោះ បញ្ជូនដំណឹងទៅទូលព្រះរាជាថា ឥឡូវនេះ រដូវភ្លៀងមកដល់ហើយ បុគ្គលណាម្នាក់ មិនអាចត្រាច់ទៅអស់កាល ៤ ខែបានការដែលពួកពលរបស់ព្រះអង្គបានវត្ថុណាមួយសមគួរ វត្ថុទាំងអស់នោះ ជាភារៈរបស់ទូលបង្គំ ទ្រង់នឹងយាងទៅបាន ក្នុងកាលដែលទូលបង្គំបញ្ជូនទ្រង់ទៅ ។ ចាប់តាំងអំពីកាលនោះ នគរសាកេតបានជានគរ ហាក់ដូចជាមាននក្ខត្តឫក្សជានិច្ច ។

វត្ថុមានកម្រងផ្កា គ្រឿងក្រអូប និងសំពត់ជាដើម ជារបស់ដែលសេដ្ឋី

នោះរៀបចំហើយ ដល់ជនទាំងអស់ ចាប់តាំងអំពីព្រះរាជាជាដើម ។ ជនទាំងនោះគិតគ្នាថា សេដ្ឋីធ្វើសក្ការៈដល់ពួកយើងតែម្យ៉ាងអស់កាល ៣ ខែហើយដោយអាការយ៉ាងនេះ ។ ចំណែកគ្រឿងប្រដាប់ក៏មិនទាន់សម្រេច អ្នកគ្រប់គ្រងការងារមកប្រាប់ដល់សេដ្ឋីថា វត្ថុដទៃដែលឈ្មោះថាមិនមាន ក៏មិនមាន ។ តែឧសសម្រាប់ចម្អិនបបរ និងកត្តដើម្បីពួកពលមិនគ្រប់គ្រាន់ ។ សេដ្ឋីពោលថា ទៅចុះបាទាំងឡាយ ចូរពួកអ្នកជញ្ជូនយករោងដំរីចាស់ៗ ជាដើម និងផ្ទះចាស់ៗ ក្នុងនគរនេះ ដុតដាំស្ងចុះ ។

កាលដាំស្ងយ៉ាងនេះ កន្លះខែកន្លងទៅហើយ លំដាប់នោះ អ្នកគ្រប់គ្រងការងារមកប្រាប់ដល់លោកសេដ្ឋីម្តងទៀតថា ឧសមិនមាន សេដ្ឋីពោលថា បុគ្គលណាម្នាក់ មិនអាចបានឧសក្នុងពេលនេះ ចូរពួកអ្នកបើកឃ្លាំងសំពត់ទាំងឡាយ ហើយយកសំពត់សាច់គ្រោតគ្រាត មូរជាចុងជ្រលក់ប្រេងដាំស្ងចុះ ។ ជនទាំងនោះ បានធ្វើយ៉ាងនោះអស់កន្លះខែ ។ ៤ ខែកន្លងទៅហើយដោយអាការយ៉ាងនេះ ។ សូម្បីគ្រឿងប្រដាប់ក៏សម្រេចហើយ ។

ពេជ្រ ៤ នាឡិ បានដល់ការប្រកបចូលក្នុងគ្រឿងប្រដាប់នោះ កែវមុក្តា ១១ នាឡិ កែវប្រពាល ២០ នាឡិ កែវមណី ៣៣ នាឡិ គ្រឿងប្រដាប់នោះ ដល់នូវការសម្រេចដោយរតនៈទាំងនេះឯង និងរតនៈដទៃ ដោយប្រការដូច្នេះ ។ គ្រឿងប្រដាប់មិនសម្រេចដោយអំបោះ ការងារដែលធ្វើដោយអំបោះ គេធ្វើហើយដោយប្រាក់ គ្រឿងប្រដាប់នោះ ពាក់ត្រង់ក្បាលហើយ ទៅទល់គ្នានឹងខ្នងជើង ឡេវដែលគេប្រកបក្នុងទីនោះៗ ធ្វើដោយមាស អន្ទាក់

ឡៀវ ធ្វើដោយប្រាក់ ឡៀវមួយដាក់ត្រង់កណ្តាលក្បាល ឡៀវពីរដាក់ត្រង់ត្រចៀកទាំងសងខាង ឡៀវមួយដាក់ត្រង់កញ្ចឹង-ក ឡៀវពីរដាក់ត្រង់ជង្គង់ទាំងពីរ ឡៀវពីរដាក់ត្រង់កែងដៃទាំងពីរ ឡៀវពីរដាក់ត្រង់ចង្កេះទាំងសងខាង ។ ក្នុងគ្រឿងប្រដាប់នោះឯង គេធ្វើក្ងោកមួយ រោមស្លាបស្តាំ ៥០០ ធ្វើដោយមាស រោមស្លាបឆ្វេង ៥០០ ចំពុះធ្វើដោយកែវប្រពាល ភ្នែកធ្វើដោយកែវមណី ក និងកន្ទុយក៏ដូចគ្នា ឆ្អឹងទ្រនុងស្លាបធ្វើដោយប្រាក់ ជើងក៏ដូចគ្នា ក្ងោកនោះ ស្ថិតនៅត្រង់កណ្តាលក្បាលនៃនាងវិសាខា ប្រាកដហាក់បីដូចក្ងោកពេនពង់លើកំពូលភ្នំ ។ សំឡេងស្លាបមួយពាន់ ប្រព្រឹត្តទៅប្រៀបដូចទិព្វសង្គីតៈ និងប្រៀបដូចសំឡេងគឹកកង នៃតន្ត្រីប្រកបដោយអង្គ ៥ ។ ជនទាំងឡាយដែលចូលទៅកាន់ទីជិតប៉ុណ្ណោះ ទើបដឹងថា ក្ងោកនោះ មិនមែនក្ងោកពិត ។ គ្រឿងប្រដាប់មានតម្លៃ ៩ កោដិ លោកសេដ្ឋី បានឲ្យតម្លៃហត្ថកម្ម ១ សែន ។

សួរថា គ្រឿងប្រដាប់នោះ នាងវិសាខានោះបានហើយ ព្រោះផលនៃកម្មដូចម្តេច ឆ្លើយថា បានឮថា ក្នុងកាលនៃព្រះកស្សបសម្មាសម្ពុទ្ធ នាងថ្វាយចីវរសាដកដល់ភិក្ខុ ២ ម៉ឺនរូបហើយ បានប្រគេនអំបោះខ្លះ ម្ជុលខ្លះ គ្រឿងជ្រលក់ខ្លះ ដែលជារបស់ខ្លួននោះឯង នាងបានហើយនូវគ្រឿងប្រដាប់នោះព្រោះផលនៃចីវរទាននោះ ។ ចីវរទានរបស់ស្រីទាំងឡាយ រមែងដល់ទីបំផុតដោយគ្រឿងប្រដាប់ឈ្មោះមហាលតាបសាធន៍ ។ ចីវរទានរបស់បុរសទាំង-ឡាយ រមែងដល់ទីបំផុតដោយបាត្រ និងចីវរ ដែលសម្រេចហើយដោយឫទ្ធិ ។

មហាសេដ្ឋីធ្វើការត្រៀមដើម្បីកូនស្រីអស់កាល ៤ ខែយ៉ាងនោះហើយ កាលនឹងឲ្យទេយ្យធម៌ដល់កូនស្រីនោះ បានឲ្យរទេះពេញដោយកហាបណៈ ៥០០ បានឲ្យរទេះពេញដោយភាជន៍មាស ៥០០ ពេញដោយភាជន៍ប្រាក់ ៥០០ ពេញដោយភាជន៍ទង់ដែង ៥០០ ពេញដោយភាជន៍សំរឹទ្ធ ៥០០ ពេញដោយសំពត់សូត្រ ៥០០ ពេញដោយសប្បិ ៥០០ ពេញដោយប្រេង ៥០០ ពេញដោយទឹកអំពៅ ៥០០ ពេញដោយអង្ករ ៥០០ ពេញដោយស្រូវសាលី ៥០០ ពេញដោយគ្រឿងឧបករណ៍ មាននង្គ័ល និងផាល ៥០០ ។

បានឮថា ការគិតយ៉ាងនេះមានដល់មហាសេដ្ឋីនោះថា ក្នុងទីកន្លែងដែលកូនស្រីរបស់យើងទៅហើយ នាងកុំចាំបាច់បញ្ជូនមនុស្សទៅកាន់ទ្វាររបស់អ្នកដទៃថា ខ្ញុំត្រូវការដោយវត្ថុឈ្មោះនោះ ព្រោះដូច្នោះ ទើបមហាសេដ្ឋីបានឲ្យគ្រឿងឧបករណ៍គ្រប់យ៉ាង ។ មហាសេដ្ឋីបានឲ្យរថ ៥០០ អ្នកបម្រើរូបស្អាតដែលប្រដាប់ដោយគ្រឿងអលង្ការសព្វយ៉ាង លើរទេះមួយបីនាក់ៗ ។ បានឲ្យនាងបារិចារិកា ១ ពាន់ ៥០០ នាក់ ដោយប្រាប់ថា ពួកអ្នកប៉ុណ្ណោះចូរឲ្យកូនរបស់យើងងូត ប៉ុណ្ណោះចូរឲ្យបរិភោគ ប៉ុណ្ណោះជាអ្នកតែងខ្លួនត្រាច់ទៅ ។

គ្រានោះ មហាសេដ្ឋីមានការគិតយ៉ាងនេះថា អញនឹងឲ្យគោដល់កូនស្រីរបស់អញ លោកបញ្ជាបុរសថា នែអ្នក ចូរពួកអ្នកទៅបើកទ្វារក្រោលតូចហើយ ឈរវាយស្គរបីនៅក្នុងទី ៣ គាវុត ឈរក្នុងទីទាំងសងខាង ក្នុងទីប្រមាណ ១ ឧសភៈ ដោយចំណែកទទឹង បន្ទាប់អំពីនោះ ចូរកុំឲ្យមេគោទាំងឡាយទៅទីដទៃ គប្បីវាយស្គរសញ្ញា ក្នុងកាលមេគោឈប់ហើយយ៉ាង

នេះ ។ បុរសទាំងនោះ បានធ្វើយ៉ាងនោះហើយ ។ កាលមេគោចេញអំពីក្រោលបាន ១ គាវុធ ពួកគេបានវាយស្គរសញ្ញាឡើង ក្នុងវេលាមេគោទៅបានកន្លះយោជន៍ បានវាយស្គរឲ្យសញ្ញាទៀត ក្នុងពេលមេគោទៅបាន ៣ គាវុធ ពួកគេបានហាមការទៅដោយចំណែកទទឹងទៀត មេគោទាំងឡាយបានឈរប្រជ្រៀតគ្នា ក្នុងទីប្រមាណ ៣ គាវុធ ទទឹងប្រមាណ ១ ឧសភៈដោយប្រការដូច្នោះ ។

មហាសេដ្ឋី បានឲ្យបិទទ្វារក្រោលដោយពាក្យថា គោប្រមាណប៉ុណ្ណោះល្មមហើយដល់ធីតារបស់ខ្ញុំ ចូរពួកអ្នកបិទទ្វារចុះ ។ កាលគេបិទទ្វារក្រោលហើយ ព្រោះផលបុណ្យរបស់នាងវិសាខា គោដែលមានកម្លាំង និងមេគោទឹកដោះទាំងឡាយ ក៏លោតចេញទៅហើយ ។ កាលពួកមនុស្សឃាត់នោះឯង គោដែលមានកម្លាំង ៦ ម៉ឺន និងមេគោទឹកដោះ ៦ ម៉ឺន ចេញហើយ កូនគោឈ្មោលមានកម្លាំង មានចំនួនប៉ុណ្ណោះចេញទៅហើយ ពួកគោឧសភៈរបស់មេគោទឹកដោះទាំងនោះ ក៏បានជាប់តាមទៅហើយ ។

សួរថា គោទាំងឡាយទៅហើយយ៉ាងនោះ ព្រោះផលនៃកម្មអ្វី ឆ្លើយថា ព្រោះផលនៃទានដែលនាងវិសាខា បានថ្វាយហើយដល់ភិក្ខុកំលោះ និងសាមណេរដែលកំពុងឃាត់ ។

បានឮថា ក្នុងកាលព្រះកស្សបសម្មាសម្ពុទ្ធ នាងជាប្អូនពៅរបស់ធីតាទាំង ៧ របស់ព្រះបាទកិកិ ឈ្មោះនាងសង្ឃទាសី កាលថ្វាយបញ្ចគោរសទានដល់ភិក្ខុ ២ ម៉ឺនរូប កាលភិក្ខុកំលោះ និងសាមណេរបិទបាត្រឃាត់ថា ល្មមហើយ

ល្មមហើយ ក៏នៅតែប្រាប់ថា របស់នេះឆ្ងាញ់ របស់នេះគួរឆាន់ ហើយបាន ប្រគេនទៀត ។ ព្រោះផលនៃកម្មនោះ គោទាំងនោះសូម្បីឃាត់ ក៏ចេញទៅ ហើយយ៉ាងនោះ ។

ក្នុងកាលដែលសេដ្ឋីឲ្យទ្រព្យប៉ុណ្ណោះហើយ កិរិយារបស់សេដ្ឋីបានពោល ថា វត្ថុទាំងអស់ដែលអ្នករៀបចំហើយដល់កូនស្រីរបស់យើង តែអ្នកបម្រើ ប្រុសស្រីដែលធ្វើការបម្រើ អ្នកមិនទាន់បានចាត់ចែង សេចក្ដីនោះព្រោះហេតុ អ្វី សេដ្ឋីពោលថា បានជាខ្ញុំមិនចាត់ចែង ដើម្បីដឹងមនុស្សដែលមានការស្រឡាញ់ និងស្អប់ក្នុងកូនស្រីរបស់យើង ព្រោះយើងនឹងចាប់កបុគ្គលដែលមិនទៅជា មួយធីតាបញ្ជូនទៅមិនបាន តែក្នុងកាលឡើងយានទៅនោះឯង ខ្ញុំនឹងពោលថា អ្នកណាចង់ទៅជាមួយនាងវិសាខា ចូរទៅចុះ អ្នកដែលមិនចង់ទៅ កុំទៅ ។

លំដាប់នោះ សេដ្ឋីគិតថា ធីតារបស់អញនឹងទៅស្អែកនេះ អង្គុយក្នុង បន្ទប់ ឲ្យធីតាអង្គុយក្នុងទីជិតហើយ ឲ្យឱវាទថា នែនាង ធម្មតាស្រីដែលនៅ ក្នុងត្រកូលប្ដី រក្សាមារយាទនេះ និងមារយាទនេះ ទើបគួរ សូម្បីមិគារសេដ្ឋី នោះអង្គុយក្នុងបន្ទប់បន្ទាប់នោះ បានឮឱវាទរបស់ធនញ្ជយសេដ្ឋីហើយ ។

ចំណែកធនញ្ជយសេដ្ឋីនោះ ទូន្មានកូនស្រីយ៉ាងនោះហើយ ឲ្យឱវាទ ១០ ថា នែនាង ធម្មតាស្រីដែលនៅក្នុងត្រកូលប្ដី មិនគួរនាំភ្លើងខាងក្នុងចេញទៅ ខាងក្រៅ មិនគួរនាំភ្លើងខាងក្រៅចូលទៅខាងក្នុង គប្បីឲ្យដល់បុគ្គលដែលឲ្យ ប៉ុណ្ណោះ មិនគប្បីឲ្យដល់បុគ្គលដែលមិនឲ្យ គប្បីឲ្យដល់បុគ្គលដែលឲ្យផង ដែលមិនឲ្យផង គប្បីអង្គុយជាសុខ គប្បីបរិភោគជាសុខ គប្បីដេកជាសុខ

គប្បីបម្រើភ្លើង គប្បីនមស្ការទេវតាខាងក្នុង ដូច្នេះហើយ ក្នុងថ្ងៃស្អែកឡើង ហៅប្រជុំសេនាទាំងអស់ហើយ ទើបកាន់យកកុដុម្ពិកៈ ៨ នាក់ ឲ្យជាអ្នកមើលការខុសត្រូវ ក្នុងជំនុំរាជសេនាហើយពោលថា បើទោសកើតឡើងដល់កូនស្រីរបស់ខ្ញុំក្នុងទីដែលទៅហើយ ពួកអ្នកគប្បីវិនិច្ឆ័យ ដូច្នេះហើយ គាត់តែងធីតាដោយគ្រឿងអលង្ការឈ្មោះមហាលតាបសាធន៍ ដែលមានតម្លៃ ៩ កោដិ ឲ្យទ្រព្យ ៥៤ កោដិ ជាតម្លៃគ្រឿងលម្អិតសម្រាប់ងូត ឲ្យឡើងកាន់យានហើយ ឲ្យមនុស្សវាយស្គរប្រកាសក្នុងស្រុកស្មួយ ១៤ តំបន់ ដែលជារបស់ខ្លួនប៉ុនអនុរាជបុរី ជុំវិញក្រុងសាកេតថា អ្នកចង់ទៅជាមួយកូនស្រីរបស់ខ្ញុំ ក៏ចូរទៅចុះ ។

អ្នកស្រុក ១៤ តំបន់បានឮសំឡេង ទើបចេញទៅមិនមានសេសសល់បុគ្គលម្នាក់ឡើយ ដោយគិតថា មានប្រយោជន៍អ្វីដល់ពួកយើងក្នុងទីនេះ ក្នុងកាលដែលអ្នកនាងរបស់យើងទៅហើយ ។ ចំណែកធនញ្ជយសេដ្ឋី ធ្វើសក្ការៈដល់ព្រះរាជា និងមិគារសេដ្ឋីហើយ ក៏តាមជូនដំណើរធីតាជាមួយនឹងជនទាំងនោះទៅបន្តិច ។

មិគារសេដ្ឋីអង្គុយក្នុងយានតូច ទៅខាងក្រោយយានទាំងអស់ ឃើញពួកពលហើយ ទើបសួរថា ជនទាំងនោះជាអ្នកណា ពួកអ្នកបម្រើប្រាប់ថា ជាទាសី និងទាសៈរបស់កូនប្រសាលោកម្ចាស់ មិគារសេដ្ឋីពោលថា អ្នកណានឹងចិញ្ចឹមមនុស្សមានចំនួនប៉ុណ្ណោះបាន ចូរពួកអ្នកដេញវាយមនុស្សទាំងនោះឲ្យគេចទៅ ចូរទាញពួកជនដែលមិនគេចចេញអំពីទីនេះ នាងវិសាខាពោលថា

ចូរចៀសចេញទៅ កុំឃាត់គេឡើយ ពលទាំងនោះឯង នឹងឲ្យកត្តដល់ពល ។

កាលនាងពោលយ៉ាងនោះ សេដ្ឋីក៏នៅតែពោលថា នែនាង យើងមិនត្រូវការដោយជនទាំងនោះ អ្នកណានឹងចិញ្ចឹមជនទាំងនោះបាន ដូច្នេះហើយ ទើបឲ្យវាយដោយដុំថ្ម ដុំដី និងដំបងជាដើមឲ្យគេចទៅហើយ នាំពួកដ៏សេសទៅដោយគិតថា យើងល្មមដោយមនុស្សចំនួនប៉ុណ្ណេះ ។

កាលដល់ទ្វារនគរសាវត្ថី នាងវិសាខាគិតថា អញនឹងអង្គុយក្នុងយានដែលបិទចូលទៅ ឬឈរលើរថចូលទៅ ។ ពេលនោះ នាងបានសម្រេចចិត្តយ៉ាងនេះថា បើអញចូលទៅដោយយានដែលបិទ ភាពវិសេសនៃគ្រឿងប្រដាប់ឈ្មោះមហាលតាបសាធន៍ នឹងមិនប្រាកដ ឈរលើរថបង្ហាញខ្លួនដល់អ្នកនគរទាំងមូល ទៅកាន់នគរហើយ ។ អ្នកក្រុងសាវត្ថីឃើញសម្បត្តិរបស់នាងវិសាខាហើយ ទើបនិយាយគ្នាថា ស្រីនោះឈ្មោះវិសាខា សម្បត្តិបែបនេះសមគួរដល់នាងពិត ។

នាងវិសាខានោះ ចូលទៅកាន់ផ្ទះរបស់សេដ្ឋីដោយសម្បត្តិច្រើន ដោយប្រការដូច្នេះឯង ។ ក្នុងថ្ងៃដែលនាងមកដល់ អ្នកនគរទាំងមូលបានបញ្ជូនបណ្ណាការទៅតាមកម្លាំង ដោយគិតថា ធនញ្ជយសេដ្ឋីបានធ្វើសក្ការៈច្រើនសន្ធឹកសន្ធាប់ដល់ពួកយើង នាងវិសាខាបានឲ្យបណ្ណាការដែលគេបញ្ជូនមកហើយធ្វើឲ្យជាប្រយោជន៍គ្រប់យ៉ាង ក្នុងត្រកូលដទៃៗ ក្នុងនគរនោះឯង ។

នាងពោលពាក្យជាទីស្រឡាញ់ សមគួរដល់វ័យរបស់មនុស្សទាំងនោះថា អ្នកចូរឲ្យវត្ថុនេះដល់អ្នកម៉ែរបស់ខ្ញុំ ចូរឲ្យវត្ថុទាំងនេះដល់លោកឪពុករបស់

ខ្ញុំ ចូរឲ្យវត្ថុនេះដល់បងប្រុស ប្អូនប្រុសរបស់ខ្ញុំ ចូរឲ្យវត្ថុនេះដល់បងស្រីប្អូនស្រីរបស់ខ្ញុំ ដូច្នេះហើយ បញ្ជូនបណ្ណាការទៅ បានធ្វើអ្នកនគរទាំងអស់ឲ្យដូចជាពួកញាតិ ដោយប្រការដូច្នេះ ។

បន្ទាប់មក ក្នុងវេលាកណ្ដាលយប់ លាញីជាមេសេះអាជានេយ្យរបស់នាងកើតកូន នាងឲ្យពួកទាសីកាន់យកប្រទីបអុជទៅក្នុងទីនោះហើយ ញ៉ាំងលាឲ្យងូតដោយទឹកក្ដៅ ឲ្យលាបដោយប្រេង ហើយបានទៅកាន់លំនៅរបស់ខ្លួនវិញ ។

មិគារសេដ្ឋីកាលធ្វើអាវាហមង្គលរបស់បុត្រ មិនបានទឹកដល់ព្រះតថាគតដែលប្រថាប់នៅក្នុងវិហារជិតឡើយ ឯសេចក្ដីស្រឡាញ់ តាំងនៅចំពោះក្នុងពួកសមណៈអាក្រាតអស់កាលយូរ នាំឲ្យគាត់គិតថា អញនឹងធ្វើសក្ការៈដល់លោកម្ចាស់របស់អញ ដូច្នេះហើយ ថ្ងៃមួយ ឲ្យមនុស្សចម្អិនបាយាសដែលមានទឹកតិច ដាក់ក្នុងភាជន៍ថ្មីច្រើនរយសម្រាប់ ឲ្យនិមន្តពួកអចេលក៍ ៥០០ ឲ្យចូលទៅកាន់ផ្ទះហើយ ទើបបញ្ជូនដំណឹងដល់នាងវិសាខាថា កូនប្រសារបស់ខ្ញុំ ចូរមកថ្វាយបង្គំព្រះអរហន្តទាំងឡាយ ។

នាងវិសាខាអរិយសាវិកាជាសោតាបន្ន គ្រាន់តែឮពាក្យថា ព្រះអរហន្តក៏ជាអ្នកត្រេកអរ មកកាន់ទីបរិភោគនៃអចេលក៍ទាំងនោះ សម្លឹងមើលអចេលក៍ទាំងនោះហើយគិតថា បុគ្គលវៀរចាកហិរិឱត្តប្បៈបែបនេះ មិនមែនជាព្រះអរហន្តឡើយ ហេតុអ្វី ទើបលោកឪពុកឲ្យហៅខ្ញុំមក តិះដៀលសេដ្ឋីហើយក៏ទៅកាន់លំនៅរបស់ខ្លួនវិញ ។

ពួកអចេលក៍ ឃើញអាការរបស់នាងវិសាខានោះហើយ ទើបតិះដៀល សេដ្ឋីដោយសំឡេងតែមួយថា នែគហបតី លោកមិនមានស្រីដទៃទេឬ ទើបឲ្យសាវិការបស់សមណគោតម ដែលជាស្រីកាឡកិណីចូលមកក្នុងទីនេះ ចូរបណ្តេញនាងចេញអំពីផ្ទះនេះឲ្យរហ័ស ។ សេដ្ឋីគិតថា អញមិនអាចបណ្តេញចេញទៅដោយត្រឹមតែពាក្យរបស់ជនទាំងនេះប៉ុណ្ណោះ នាងជាកូនស្រីរបស់ត្រកូលធំ ដូច្នេះហើយ ទើបពោលថា លោកម្ចាស់ទាំងឡាយ ធម្មតាទារិកាដឹងខ្លះ មិនដឹងខ្លះ សូមលោកទាំងឡាយស្ងប់ស្ងៀមសិនចុះ បញ្ជូនអចេលក៍នោះទៅហើយ អង្គុយលើអាសនៈដែលមានតម្លៃច្រើន បរិភោគបាយាសដែលមានទឹកតិច ក្នុងថាសមាស ។

ក្នុងសម័យនោះ ព្រះថេរៈអ្នកសមាទានការត្រាច់បិណ្ឌបាតជាវត្តមួយអង្គកំពុងត្រាច់បិណ្ឌបាត បានចូលទៅកាន់ផ្ទះនោះហើយ នាងវិសាខាឈរបក់ផ្លិតឲ្យឪពុកក្មេក ឃើញព្រះថេរៈរូបនោះគិតថា ការប្រាប់ឪពុកក្មេកមិនគួរ ទើបបានចៀសចេញទៅឈរដោយអាការ ដែលល្មមឪពុកក្មេកនោះ ឃើញព្រះថេរៈបាន ។ តែសេដ្ឋីនោះជាបុគ្គលពាល សូម្បីឃើញព្រះថេរៈ ក៏ក្លែងធ្វើជាមិនឃើញ ឈ្ងោកមុខបរិភោគនោះឯង ។

នាងវិសាខាដឹងថា ឪពុកក្មេករបស់ខ្លួន ឃើញព្រះថេរៈក៏មិនយកចិត្តទុកដាក់ ទើបពោលថា បពិត្រលោកម្ចាស់ សូមនិមន្តទៅឯមុខចុះ ឪពុកក្មេករបស់ខ្ញុំ កំពុងបរិភោគរបស់ចាស់ សេដ្ឋីនោះអត់ធន់បាន ក្នុងកាលដែលពួកនិគ្រន្ថប្រាប់ តែក្នុងខណៈដែលនាងវិសាខាពោលថា បរិភោគរបស់ចាស់

នោះឯង ក៏ទម្លាក់ដៃពោលថា អ្នកទាំងឡាយ ចូរនាំបាយាសនេះចេញអំពីទីនេះ ចូរដេញស្រីនោះចេញអំពីផ្ទះនេះ ស្រីនេះធ្វើឲ្យយើង ឈ្មោះថាជាអ្នកស៊ីរបស់មិនស្អាត ក្នុងកាលមង្គលបែបនេះ ។

ឯទាសៈ និងកម្មករទាំងអស់ក្នុងផ្ទះនោះ សុទ្ធតែជាមនុស្សរបស់នាងវិសាខា ទើបមិនអាចចូលជិតបាន បុគ្គលណានឹងចាប់នាងត្រង់ដៃ និងជើងសូម្បីជាអ្នកអាចពោលដោយមាត់ក៏មិនមាន ។

នាងវិសាខាស្តាប់ពាក្យរបស់ឪពុកក្មេកហើយពោលថា លោកឪពុក ខ្ញុំនឹងចេញទៅដោយហេតុមានប្រមាណប៉ុណ្ណេះ លោកឪពុកមិនបាននាំខ្ញុំមក ដូចនាំនាងកុម្ភទាសី មកអំពីកំពង់ទឹក ធម្មតាកូនស្រីរបស់មាតាបិតាដែលនៅមានជីវិត នឹងមិនចេញទៅដោយហេតុមានប្រមាណប៉ុណ្ណេះ ព្រោះហេតុនោះឯងក្នុងកាលមកទីនេះ លោកឪពុករបស់ខ្ញុំបានហៅកុដុម្ពិកៈ ៨ នាក់មក ពោលថា បើទោសកើតឡើងដល់កូនស្រីរបស់ខ្ញុំ ដូច្នេះហើយ ក៏ប្រគល់ខ្ញុំទុកក្នុងដៃរបស់កុដុម្ពិកៈទាំងនោះ សូមលោកឪពុកឲ្យហៅជនទាំងនោះមកហើយ ជម្រះទោសរបស់ខ្ញុំចុះ ។

សេដ្ឋីគិតថា នាងវិសាខានេះនិយាយល្អ ទើបឲ្យហៅកុដុម្ពិកៈទាំង ៨ មកហើយប្រាប់ថា នាងទារិកានេះថាខ្ញុំ ដែលអង្គុយទទួលទានបាយាស ដែលមានទឹកតិចក្នុងថាសមាស ក្នុងវេលាមង្គលថា ជាអ្នកបរិភោគរបស់មិនស្អាត ចូរពួកលោកលើកទោសនាងវិសាខានេះឡើងហើយ ចូរអូសនាងចេញអំពីផ្ទះនេះ ។ កុដុម្ពិកៈពោលថា បានឮថា សេចក្តីនោះយ៉ាងនោះឬ នាងវិសាខាពោល

ថា ខ្ញុំមិនបានពោលយ៉ាងនោះឡើយ តែកាលព្រះថេរៈ អ្នកសមាទានបិណ្ឌ-បាតជាវត្តមួយរូប និមន្តមកឈរត្រង់ទ្វារផ្ទះ ឪពុកក្មេករបស់ខ្ញុំកំពុងទទួលទានមធុបាយាស ដែលមានទឹកតិច មិនអើពើដល់ព្រះថេរៈនោះ ខ្ញុំគិតថា ឪពុកក្មេករបស់ខ្ញុំមិនធ្វើបុណ្យក្នុងអត្តភាពនេះ បរិភោគតែបុណ្យចាស់ប៉ុណ្ណោះ ទើបពោលថា សូមនិមន្តទៅខាងមុខចុះ លោកម្ចាស់ ឪពុកក្មេករបស់ខ្ញុំកំពុងបរិភោគរបស់ចាស់ ទោសឯណាមួយរបស់ខ្ញុំ មានព្រោះហេតុនេះដែរឬទេ កុដុម្ពិកៈពោលថា លោកសេដ្ឋី ទោសព្រោះហេតុនេះមិនមាន កូនស្រីរបស់ខ្ញុំពោលប្រពៃ ហេតុអ្វី ទើបលោកខឹង សេដ្ឋីពោលថា អ្នកទាំងឡាយទោសនេះផុតក៏ផុតសិនចុះ តែថ្ងៃមួយ ក្នុងមជ្ឈិមយាម នាងវិសាខានេះ ដែលអ្នកបម្រើស្រីចោមរោមហើយ បានទៅខាងក្រោយផ្ទះ កុដុម្ពិកៈពោលថា បានឮថា សេចក្តីនេះយ៉ាងនោះឬ នាងវិសាខាពោលថា លោកឪពុកទាំងឡាយ ខ្ញុំមិនបានទៅព្រោះហេតុដទៃ កាលលាញីជាមេសេះអាជានេយ្យ កើតកូនហើយក្បែរផ្ទះនេះ ខ្ញុំគិតថា កាលដែលអង្គុយព្រងើយមិនយកជាធុរៈ មិនសមគួរ ទើបឲ្យមនុស្សកាន់ប្រទីប ហើយទៅជាមួយស្រីបម្រើ ធ្វើការបរិហារដល់មេលាដែលកើតកូនហើយ ព្រោះហេតុនេះ ខ្ញុំនឹងមានទោសដូចម្តេច កុដុម្ពិកៈពោលថា លោកសេដ្ឋី កូនស្រីរបស់ខ្ញុំធ្វើកម្ម សូម្បីពួកស្រីបម្រើ មិនគប្បីធ្វើក្នុងផ្ទះរបស់លោក លោកនៅឃើញទោសអ្វី ព្រោះហេតុនេះ សេដ្ឋីពោលថា អ្នកទាំងឡាយ ក្នុងរឿងនេះមិនមានទោសក៏ហើយចុះ តែឪពុករបស់នាងវិសាខានេះ កាលពោលប្រៀនប្រដៅក្នុងវេលាមកទីនេះ បានឲ្យឱវាទ ១០

*ប្រការ ដែលមានអាថ៌កំបាំង ខ្ញុំមិនជ្រាបសេចក្តីនៃឱវាទនោះ ចូរនាងប្រាប់សេចក្តីនៃឱវាទនោះដល់ខ្ញុំ បិតារបស់នាងបានប្រាប់ថា ភ្លើងក្នុងមិនគប្បីនាំចេញទៅខាងក្រៅ ពួកយើងអាចឬហ្ន៎ ដើម្បីមិនឲ្យភ្លើង ដល់ផ្ទះអ្នកជិតខាងទាំងពីរចំណែក ហើយនៅបាន ។*

*កុដុម្ពិកៈពោលថា សេចក្តីនេះយ៉ាងនោះឬ ។ នាងវិសាខាពោលថា លោកឪពុកទាំងឡាយ បិតារបស់ខ្ញុំមិនបានពោលសម្តៅសេចក្តីដូច្នោះឡើយ តែបានពោលបំណាំងដូច្នេះថា បើនាងឃើញទោសរបស់ម្តាយក្មេក ឪពុកក្មេក និងស្វាមីរបស់នាងហើយ កុំគប្បីពោលខាងក្រៅ គឺក្នុងផ្ទះនោះៗ ព្រោះថា ឈ្មោះថា ភ្លើង ដូចគ្នានឹងភ្លើងប្រភេទនេះ មិនមាន ។*

*សេដ្ឋីពោលថា អ្នកទាំងឡាយ សេចក្តីនោះលើកទុកសិនចុះ បិតារបស់នាងវិសាខានេះពោលថា ភ្លើងខាងក្រៅមិនគប្បីឲ្យចូលទៅខាងក្នុង ពួកយើងអាចមិនទៅនាំភ្លើងមកអំពីខាងក្រៅឬ ក្នុងកាលភ្លើងក្នុងផ្ទះរលត់ កុដុម្ពិកៈពោលថា បានឮថា សេចក្តីនេះ យ៉ាងនោះឬ នាងវិសាខាពោលថា លោកឪពុកទាំងឡាយ បិតារបស់ខ្ញុំមិនបានពោលសម្តៅសេចក្តីដូច្នោះឡើយ តែបានពោលសម្តៅសេចក្តីដូច្នេះថា បើស្រី ឬបុរសទាំងឡាយក្នុងផ្ទះជិតខាងរបស់នាង ពោលដល់ទោសរបស់ម្តាយក្មេក ឪពុកក្មេក និងស្វាមី នាងកុំនាំយកពាក្យដែលជនទាំងនោះពោលហើយ មកពោលទៀតថា ជនឈ្មោះនោះពោលលើកទោសយ៉ាងនេះរបស់អ្នកទាំងឡាយ ព្រោះឈ្មោះថា ភ្លើង ដូចគ្នានឹងភ្លើងនោះ មិនមាន ។*

នាងវិសាខាបានរួចទោសព្រោះហេតុនេះយ៉ាងនេះ ។ នាងក៏ផុតទោស ព្រោះហេតុនេះយ៉ាងណា សូម្បីក្នុងពាក្យដ៏សេស នាងក៏ផុតទោស ដូច្នោះ ។

ក្នុងឱវាទទាំងនោះ គប្បីជ្រាបអធិប្បាយដូច្នេះថា ពាក្យដែលបិតារបស់នាងទូន្មានថា នាងគួរឲ្យដល់ជនទាំងឡាយដែលឲ្យប៉ុណ្ណោះ សេដ្ឋីបំណងយកសេចក្ដីនេះថា គួរឲ្យដល់បុគ្គលដែលកាន់គ្រឿងឧបករណ៍ ដែលខ្ចីទៅហើយយកមកឲ្យវិញប៉ុណ្ណោះ ។ ពាក្យថា មិនគួរឲ្យដល់បុគ្គលដែលមិនឲ្យ សេដ្ឋីពោលសម្ដៅសេចក្ដីថា មិនគួរឲ្យដល់បុគ្គល ដែលកាន់យកគ្រឿងឧបករណ៍ ដែលខ្ចីទៅហើយមិនយកមកឲ្យវិញ ។ ពាក្យថា គួរឲ្យដល់បុគ្គលទាំងដែលឲ្យ ទាំងដែលមិនឲ្យនេះ សេដ្ឋីពោលសម្ដៅសេចក្ដីថា កាលញាតិ និងមិត្តដែលក្រីក្រមកដល់ហើយ ជនទាំងនោះអាចនឹងសងក្ដី មិនសងក្ដី ។ ឲ្យដល់ញាតិ និងមិត្តទាំងនោះឯង គួរ ។ ពាក្យថា គប្បីអង្គុយជាសុខនេះ សេដ្ឋីពោលសម្ដៅសេចក្ដីថា ការអង្គុយក្នុងទីដែលឃើញម្ដាយក្មេក ឪពុកក្មេក និងប្ដីហើយ ត្រូវក្រោកឡើង គួរ ។ ចំណែកពាក្យថា គប្បីបរិភោគជាសុខនេះ សេដ្ឋីពោលសម្ដៅសេចក្ដីថា ការមិនបរិភោគមុនម្ដាយក្មេក ឪពុកក្មេក និងប្ដី អង្គាសជនទាំងនោះ ដឹងវត្ថុដែលលោកទាំងនោះបានគ្រប់គ្នាហើយ ឬមិនទាន់បាន ខ្លួនឯងបរិភោគឯក្រោយ ទើបគួរ ។ ពាក្យថា គប្បីដេកជាសុខនេះ សេដ្ឋីពោលសម្ដៅសេចក្ដីថា មិនគប្បីចូលកាន់ដំណេកមុនម្ដាយក្មេក ឪពុកក្មេក និងប្ដី គួរធ្វើវត្តបដិបត្តិ ដែលខ្លួនគួរធ្វើដល់លោកទាំងនោះហើយ ខ្លួនឯងដេកឯក្រោយ ទើបគួរ ។ ពាក្យថា គប្បីបម្រើភ្លើងនេះ សេដ្ឋីពោលសម្ដៅ

សេចក្តីថា ការឃើញម្តាយក្មេក ឪពុកក្មេក និងប្តីឲ្យដូចជាគំនរភ្លើង និងដូចស្តេចនាគ ទើបគួរ ។ ពាក្យថា គប្បីនមស្ការទេវតាខាងក្នុងនេះ សេដ្ឋីពោលសម្តៅសេចក្តីថា ការឃើញម្តាយក្មេក ឪពុកក្មេក និងប្តី ឲ្យដូចជាទេវតា ទើបគួរ ។

សេដ្ឋីបានស្តាប់អត្ថនៃឱវាទ ១០ នេះ យ៉ាងនោះហើយ មិនឃើញពាក្យឆ្លើយ ក៏អង្គុយឱនមុខហើយ ។

គ្រានោះ កុដុម្ពិកៈទាំងឡាយសួរសេដ្ឋីនោះថា លោកសេដ្ឋី ទោសដទៃនៃធីតារបស់ខ្ញុំនៅមានឬ សេដ្ឋីពោលថា មិនមានទេ កុដុម្ពិកៈពោលថា កាលបើដូច្នោះ ហេតុអ្វី ទើបលោកបណ្តេញនាងដែលមិនមានកំហុស ចេញចាកផ្ទះ ដោយមិនមានហេតុដូច្នេះ ។

កុដុម្ពិកៈទាំងឡាយពោលយ៉ាងនោះហើយ នាងវិសាខាបានពោលថា លោកឪពុកទាំងឡាយ កាលដែលខ្ញុំមិនទៅមុនតាមពាក្យរបស់ឪពុកក្មេក មិនសមគួរឡើយ តែក្នុងកាលមក បិតារបស់ខ្ញុំបានប្រគល់ខ្ញុំក្នុងដៃរបស់លោកទាំងឡាយ ដើម្បីជម្រះទោសរបស់ខ្ញុំ កាលដែលខ្ញុំមិនមានទោស លោកទាំងឡាយជ្រាបហើយ ឥឡូវនេះ ខ្ញុំគួរទៅបាន ដូច្នេះហើយ ទើបបញ្ជាអ្នកបម្រើស្រីប្រុសទាំងឡាយថា ចូរពួកអ្នកនាំគ្នារៀបចំពាហនៈ មានយានជាដើម ។ ពេលនោះ សេដ្ឋីទាញកុដុម្ពិកៈហើយ ពោលនឹងនាងថា នែកូនឪពុកមិនដឹង ពោលទៅហើយ ចូរអត់ទោសឲ្យឪពុកចុះ នាងវិសាខាពោលថា លោកឪពុក ខ្ញុំអត់ទោស ដែលគួរអត់ឲ្យដល់លោកឪពុកបានដោយពិត

តែខ្ញុំជាកូនស្រីរបស់ត្រកូលអ្នកមានសេចក្តីជ្រះថ្លា ដែលមិនញាប់ញ័រក្នុងព្រះពុទ្ធសាសនា ពួកខ្ញុំវៀរភិក្ខុសង្ឃហើយ ជាអ្នកនៅមិនបាន បើខ្ញុំបានទំនុកបម្រុងភិក្ខុសង្ឃតាមការពេញចិត្តរបស់ខ្ញុំ ទើបខ្ញុំនៅ សេដ្ឋីពោលថា នែកូន ចូរនាងទំនុកបម្រុងសមណៈរបស់នាងតាមគាប់ចិត្តចុះ ។

នាងវិសាខាចាត់មនុស្សឲ្យទៅនិមន្តព្រះទសពល យាងឲ្យទ្រង់ចូលកាន់និវេសន៍ក្នុងថ្ងៃស្អែក ។ ចំណែកពួកសមណៈអាក្រាត បានឮថា ព្រះសាស្តាយាងទៅកាន់ផ្ទះរបស់មិគារសេដ្ឋី ទើបទៅអង្គុយព័ទ្ធផ្ទះ ។ នាងវិសាខាថ្វាយទឹកទក្ខិណោទកហើយ បញ្ជូនដំណឹងទៅថា ខ្ញុំតាក់តែងគ្រឿងសក្ការៈទាំងពួងហើយ សូមអញ្ជើញឪពុកក្មេករបស់ខ្ញុំមកអង្គាសព្រះទសពលចុះ គ្រានោះពួកអជីវកហាមមិគារសេដ្ឋីដែលចង់មកថា នែគហបតី លោកកុំទៅកាន់សម្នាក់របស់ព្រះសមណគោតមឡើយ ។ សេដ្ឋីបញ្ជូនដំណឹងទៅថា កូនស្រីរបស់ខ្ញុំចូរអង្គាសឯងចុះ ។ នាងអង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន កាលស្រេចភត្តកិច្ចហើយ បានបញ្ជូនដំណឹងទៅទៀតថា សូមអញ្ជើញឪពុកក្មេករបស់ខ្ញុំមកស្តាប់ធម្មកថាចុះ ។ ពេលនោះ ពួកអាជីវកពោលនឹងសេដ្ឋីនោះ ដែលគិតថា ឈ្មោះថា ការមិនទៅក្នុងគ្រានេះ មិនគួរយ៉ាងក្រៃលែង ហើយកំពុងទៅ ព្រោះភាពដែលខ្លួនចង់ស្តាប់ធម៌ទៀតថា បើដូច្នោះ លោកកាលស្តាប់ធម៌របស់ព្រះសមណគោតម ចូរអង្គុយស្តាប់ខាងក្រៅវាំងនន ដូច្នេះហើយ ទើបទៅមុនសេដ្ឋីនោះហើយ បាំងនូវវាំងនន សេដ្ឋីក៏ទៅអង្គុយខាងក្រៅវាំងនន ។

ព្រះសាស្តាត្រាស់ថា អ្នកអង្គុយក្រៅវាំងននក្តី ត្រង់ជញ្ជាំងផ្ទះអ្នកជិតខាង

ក្តី ជញ្ជាំងភ្នំនោះក្តី ជញ្ជាំងភ្នំចក្រវាលក្តី តថាគតឈ្មោះថាជាព្រះពុទ្ធ រមែងអាចឲ្យអ្នកបានឮសំឡេងរបស់តថាគតបាន ដូច្នេះហើយ ទ្រង់ផ្តើមអនុបុព្វីកថា ដើម្បីសម្តែងធម៌ ដូចចាប់ដើមព្រីងធំអង្រួនឲ្យញ័រ និងដូចញុំាងភ្លៀងគឺអមតធម៌ឲ្យធ្លាក់ចុះ ។

កាលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងធម៌ ជនដែលឈរខាងមុខក្តី ខាងក្រោយក្តី នៅហួសចក្រវាលមួយរយមួយពាន់ក្តី នៅក្នុងអកនិដ្ឋភពក្តី ពោលថា ព្រះសាស្តារមែងទតមើលអាត្មាអញនោះឯង ទ្រង់សម្តែងធម៌ប្រោសអញនោះឯង ។ ពិតហើយ ព្រះសាស្តាហាក់ដូចទតមើលជននោះៗ និងដូចត្រាស់ជាមួយនឹងជនទាំងនោះ ។

បានឮថា ព្រះពុទ្ធទាំងឡាយឧបមាដូចព្រះចន្ទ រមែងប្រាកដដូចប្រថាប់ឈរត្រង់ទីចំពោះមុខនៃសត្វទាំងឡាយ ដែលឈរក្នុងទីណាមួយ ដូចព្រះចន្ទអណ្តែតនៅក្នុងវេហាស៍ រមែងប្រាកដដល់ពួកសត្វថា ព្រះចន្ទនៅលើក្បាលរបស់ពួកយើង ព្រះចន្ទនៅលើក្បាលរបស់ពួកយើងដូច្នោះ ។ បានឮថា នេះជាផលនៃទានដែលព្រះពុទ្ធទាំងឡាយ ទ្រង់កាត់ក្បាលដែលប្រដាប់ហើយ ទ្រង់ខ្វេះភ្នែកដែលបន្តក់ល្អហើយ ទ្រង់ពន្លះសាច់ហទយៈហើយ ទ្រង់បរិច្ចាគឱរសដូចជាជាលី ទ្រង់បរិច្ចាគធីតាដូចជាកណ្ហាជិនា បជាបតីដូចជានាងមទ្រី ឲ្យហើយ ដើម្បីជាទាសៈរបស់អ្នកដទៃ ។

ឯមិគារសេដ្ឋី កាលព្រះសាស្តាទ្រង់ពង្រីកព្រះធម្មទេសនា អង្គុយខាងក្រៅវាំងននទនោះឯង តាំងនៅក្នុងសោតាបត្តិផល ដែលប្រដាប់ដោយន័យមួយ

ពាន់ ប្រកបដោយអចលសទ្ធា ជាបុគ្គលអស់សង្ស័យក្នុងរតនៈ ៣ លើក ជាយវាំងននឡើង យកមាត់ថ្មៅដោះកូនប្រសា តាំងនាងទុកក្នុងតំណែងជាម្តាយ ដោយពាក្យថា សូមនាងជាម្តាយរបស់ខ្ញុំតាំងអំពីថ្ងៃនេះទៅចុះ ។

ចាប់តាំងអំពីថ្ងៃនោះមក នាងវិសាខា បានឈ្មោះថា ជាមិគារមាតាហើយ ។ ខាងក្រោយបានបុត្រប្រុស ទើបបានតាំងឈ្មោះបុត្រនោះថា មិគារ ។

មហាសេដ្ឋីលែងដោះកូនប្រសាហើយ ទៅក្រាបទៀបព្រះបាទារបស់ព្រះដ៏មានព្រះភាគ ប្រេបាច់ព្រះបាទដោយដៃ ជញ្ជក់ដោយមាត់ និងប្រកាសឈ្មោះបីដងថា ខ្ញុំព្រះអង្គឈ្មោះមិគារៈដូច្នេះជាដើមហើយ ក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមិនជ្រាបអស់កាលមានប្រមាណប៉ុណ្ណេះ ទានដែលបុគ្គលឲ្យហើយក្នុងសាសនានេះមានផលច្រើន ខ្ញុំព្រះអង្គជ្រាបផលនៃទានក្នុងឥឡូវនេះក៏ព្រោះអាស្រ័យកូនប្រសាខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាអ្នកផុតហើយចាកអបាយទុក្ខទាំងពួង កូនស្រីប្រសារបស់ខ្ញុំព្រះអង្គកាលមកកាន់ផ្ទះនេះ ក៏មកហើយដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ខ្ញុំព្រះអង្គ ដូច្នេះហើយ បានពោលគាថានេះ

ខ្ញុំព្រះអង្គរមែងដឹងទូទៅ ដល់ទានដែលបុគ្គលឲ្យហើយ ក្នុង
ខេត្តដែលបុគ្គលឲ្យហើយ មានផលច្រើនក្នុងថ្ងៃនេះ កូន
ប្រសាល្អរបស់ខ្ញុំព្រះអង្គ មកកាន់ផ្ទះនេះ ដើម្បីប្រយោជន៍
ដល់ខ្ញុំព្រះអង្គហ្ន៎ ។

នាងវិសាខា ទូលនិមន្តព្រះសាស្តាដើម្បីសោយក្នុងថ្ងៃស្អែក ។ ក្នុងថ្ងៃស្អែកឡើង ម្តាយក្មេកបានសម្រេចសោតាបត្តិផលហើយ ។ ចាប់តាំងអំពី

កាលនោះ ផ្ទះនោះបានបើកទ្វារហើយ ដើម្បីព្រះសាសនា ។

លំដាប់នោះ សេដ្ឋីគិតថា កូនប្រសារបស់អញមានឧបការៈច្រើន អញនឹងធ្វើបណ្ណាការឲ្យដល់នាង ព្រោះគ្រឿងប្រដាប់របស់កូនប្រសានោះធ្ងន់ពេក មិនអាចប្រដាប់អស់កាលជានិច្ចបាន ។ អញនឹងឲ្យជាងធ្វើគ្រឿងប្រដាប់ស្រាលៗ ដល់នាង គួរដល់ការប្រដាប់គ្រប់ឥរិយាបថ ទាំងក្នុងពេលថ្ងៃ និងពេលយប់ ដូច្នេះហើយ ទើបឲ្យជាងធ្វើគ្រឿងប្រដាប់ឈ្មោះឃនមដ្ឋកៈ ដែលមានតម្លៃមួយសែន កាលគ្រឿងប្រដាប់នោះស្រេចបាច់ហើយ និមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ឲ្យឆាន់ដោយសេចក្ដីគោរពហើយ ឲ្យនាងវិសាខាងូតដោយទឹកក្រអូប ១៦ ក្អម ឲ្យឈរថ្វាយបង្គំព្រះសាស្ដាក្នុងទីចំពោះព្រះភក្ត្ររបស់ព្រះសាស្ដាហើយ ព្រះសាស្ដាទ្រង់ធ្វើអនុមោទនាហើយ យាងចូលកាន់វិហារវិញ ។

ចាប់តាំងអំពីកាលនោះ នាងវិសាខាធ្វើបុណ្យមានទានជាដើម បានពរ ៨ ប្រការអំពីសម្នាក់ព្រះសាស្ដា ប្រាកដហាក់បីដូចចន្ទលេខាក្នុងលំហ ដល់នូវការចម្រើនដោយបុត្រ និងធីតាហើយ បានឮមកថា នាងមានកូនប្រុស ១០ នាក់ មានកូនស្រី ១០ នាក់ បណ្ដាកូនទាំងនោះ កូននីមួយៗ មានកូនប្រុស ១០ នាក់ មានកូនស្រី ១០ នាក់ដែរ បណ្ដាចៅទាំងនោះ ចៅនីមួយៗ មានកូនប្រុស ១០ នាក់ មានកូនស្រី ១០ នាក់ ចំនួនមនុស្សទាំងអស់មានដល់ទៅ ៨៤២០ នាក់ ប្រព្រឹត្តទៅដោយអំណាចនៃការបន្តរបស់កូនចៅ និងចៅទួតរបស់នាងវិសាខានោះយ៉ាងនេះ ដោយប្រការដូច្នេះ ។ នាង

វិសាខាមានអាយុ ១២០ ឆ្នាំ សក់លើក្បាលមួយសរសៃដែលស្កូវ មិនមាន នាងហាក់បីដូចក្មេងស្រីអាយុប្រមាណ ១៦ ឆ្នាំជានិច្ច ។ ជនទាំងឡាយ ឃើញនាងមានកូន និងចៅជាបរិវារដើរទៅកាន់វិហារ រមែងសួរគ្នាថា ស្រី ទាំងនេះ ណាមួយជានាងវិសាខា ជនដែលឃើញនាងដើរទៅ រមែងគិតថា ឥឡូវនេះ សូមនាងដើរទៅបន្តិចចុះ អ្នកនាងរបស់ខ្ញុំដើរទៅរមែងស្អាត ។ ជន ដែលឃើញនាងឈរ អង្គុយ ដេក ក៏រមែងគិតថា ឥឡូវនេះ សូមនាងដេក បន្តិចចុះ អ្នកនាងរបស់ខ្ញុំដេកហើយ រមែងស្អាត នាងជាបុគ្គលដែលបុគ្គល ណាម្នាក់និយាយមិនបានថា ក្នុងឥរិយាបថទាំង ៤ នាងរមែងមិនស្អាត ក្នុង ឥរិយាបថឈ្មោះនោះ ដោយប្រការដូច្នោះ នាងវិសាខានោះមានកម្លាំងស្មើនឹង ដំរី ៥ ។ ព្រះរាជាទ្រង់ឮថា នាងវិសាខាទ្រទ្រង់នូវកម្លាំងស្មើនឹងដំរី ៥ ក្នុង កាលនាងទៅវិហារ ស្តាប់ធម៌ហើយត្រឡប់មក មានព្រះបំណងសាកល្បង នូវកម្លាំង ទើបឲ្យលែងដំរីទៅ ។ ដំរីនោះបួងប្រមោយ បានរត់ចូលទៅព្រេច នាងវិសាខាហើយ ។ ស្រីបរិវាររបស់នាង ៥០០ ពួកខ្លះក៏រត់គេចទៅ ពួក ខ្លះមិនលះបង់នាង កាលនាងវិសាខាសួរថា នេះជាអ្វី ទើបប្រាប់ថា បានឮ ថា ព្រះរាជាទ្រង់បំណងល្បងនូវកម្លាំងរបស់អ្នកនាង ទើបឲ្យលែងដំរី ។ នាង វិសាខាគិតថា ប្រយោជន៍អ្វីដោយការឃើញដំរីនេះហើយរត់ទៅ អញនឹង ចាប់ដំរីនោះដូចម្តេចហ្ន៎ ទើបគិតថា បើអញចាប់ដំរីនោះយ៉ាងមាំ ដំរីនោះ គប្បីវិនាស ដូច្នេះហើយ ទើបយកម្រាមដៃពីរចាប់ប្រមោយហើយច្រានទៅ ។ ដំរីមិនអាចទប់ខ្លួនបាន បានដួលចុះត្រង់លានព្រះរាជវាំងហើយ មហាជនបាន ឲ្យសាធុការ នាង មួយអន្លើដោយបរិវារ បានត្រឡប់ទៅកាន់ផ្ទះ ដោយ

សួស្តីហើយ ។

សម័យនោះឯង នាងវិសាខាមិគារមាតាមានកូនច្រើន មានចៅច្រើន មានកូនមិនមានរោគ មានចៅមិនមានរោគ សន្មតថាជាបុគ្គលយ៉ាងក្រៃលែងក្នុងក្រុងសាវត្ថី បណ្តាកូនចៅរាប់ពាន់មានចំនួនប៉ុណ្ណោះ សូម្បីតែម្នាក់ឈ្មោះថាស្លាប់ក្នុងចន្លោះមិនមានឡើយ ។ ក្នុងមហោស្រពដែលជាមង្គល អ្នកក្រុងសាវត្ថីរមែងអញ្ជើញនាងវិសាខាឲ្យបរិភោគជាមុន ។ ក្នុងថ្ងៃមហោស្រពមួយ កាលមហាជនតែងខ្លួនទៅកាន់វិហារដើម្បីស្តាប់ធម៌ សូម្បីនាងវិសាខា បរិភោគក្នុងទីដែលគេអញ្ជើញហើយ ក៏តែងគ្រឿងមហាលតាបសាធន៍ ទៅវិហារ មួយអន្លើដោយមហាជន បានដោះគ្រឿងអាភរណៈឲ្យដល់ស្រីបម្រើ ដែលព្រះធម្មសង្គាហកាចារ្យពោលសម្តៅយកពាក្យនេះថា សម័យនោះឯង ក្នុងក្រុងសាវត្ថីមានមហោស្រព មនុស្សទាំងឡាយតែងខ្លួនហើយទៅវត្ត ។ សូម្បីនាងវិសាខាមិគារមាតាក៏តែងខ្លួនទៅវិហារ ។ គ្រានោះឯង នាងវិសាខាមិគារតាមាដោះគ្រឿងប្រដាប់ ចងឲ្យជាបង្វេចត្រង់សំពត់ដណ្តប់ហើយ បានឲ្យដល់អ្នកបម្រើថា នែនាង ចូរនាងទទួលបង្វេចនេះចុះ ។

បានឮថា នាងវិសាខានោះ កាលកំពុងដើរទៅវិហារ គិតថា កាលដែលអញពាក់គ្រឿងប្រដាប់ដែលមានតម្លៃច្រើនបែបនេះនៅលើក្បាល ហើយប្រដាប់គ្រឿងអលង្ការរហូតដល់ខ្នងជើង ចូលទៅកាន់វិហារមិនគួរ ទើបដោះខ្ចប់គ្រឿងប្រដាប់នោះ ហើយបញ្ជូនឲ្យក្នុងដៃស្រីបម្រើដែលមានកម្លាំងស្មើនឹងដំរី ៥ ដែលកើតដោយបុណ្យរបស់ខ្លួនដូចគ្នា ។ ស្រីបម្រើនោះម្នាក់ប៉ុណ្ណោះ

អាចទទួលគ្រឿងប្រដាប់មហាលតាបសាធន៍នោះបាន ព្រោះហេតុនោះ ទើបនាងពោលនឹងស្រីបម្រើនោះថា នែនាង ចូរនាងទទួលគ្រឿងប្រដាប់នេះ ខ្ញុំនឹងពាក់ក្នុងកាលត្រឡប់មកអំពីសម្នាក់របស់ព្រះសាស្តា ។ នាងវិសាខាកាលឲ្យគ្រឿងប្រដាប់មហាលតាបសាធន៍នោះហើយ ទើបពាក់គ្រឿងប្រដាប់ឈ្មោះឃនមដ្ឋកៈ បានចូលទៅគាល់ព្រះសាស្តាស្តាប់ធម៌ហើយ ។ ក្នុងទីបំផុតការស្តាប់ធម៌ នាងថ្វាយបង្គំព្រះមានព្រះភាគ ក្រោកចាកអាសនៈចៀសទៅហើយ ចំណែកស្រីបម្រើរបស់នាង ភ្លេចគ្រឿងប្រដាប់នោះហើយ ។ កាលបរិស័ទស្តាប់ធម៌ចៀសចេញទៅហើយ បើបុគ្គលណាភ្លេចរបស់អ្វីមួយ ព្រះអានន្ទត្ថេររមែងរើសរបស់នោះទុកដាក់ ។ ព្រោះហេតុដូច្នេះ ក្នុងថ្ងៃនោះ លោកឃើញគ្រឿងមហាលតាបសាធន៍ហើយ ទើបទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គនាងវិសាខាភ្លេចគ្រឿងអលង្ការ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលអានន្ទចូររើសទុកក្នុងទីបំផុតនាចំណែកម្ខាងចុះ ។ ព្រះថេរៈលើកគ្រឿងប្រដាប់នោះព្យួរត្រង់ក្បាលជណ្តើរ ។

ចំណែកនាងវិសាខា ដើរទៅខាងក្នុងវិហារជាមួយនាងសុប្បិយា តាំងចិត្តថា នឹងដឹងវត្ថុដែលគួរធ្វើដល់អាគន្តុកភិក្ខុ ភិក្ខុត្រៀមធ្វើដំណើរ និងភិក្ខុមានជំងឺជាដើម ។ ដោយប្រក្រតី ភិក្ខុកំលោះ និងសាមណេរដែលត្រូវការសប្បិ ទឹកឃ្មុំ និងប្រេងជាដើម ឃើញឧបាសិកាទាំងនោះខាងក្នុងវិហារហើយរមែងកាន់យកភាជនៈ មានថាសជាដើមដើរចូលទៅរក ។ ក្នុងថ្ងៃនោះ ក៏ធ្វើហើយយ៉ាងនោះដូចគ្នា ពេលនោះ នាងសុប្បិយាឃើញភិក្ខុឈឺមួយរូប ទើប

សួរថា លោកម្ចាស់ត្រូវការអ្វី ទើបភិក្ខុឈឺរូបនោះឆ្លើយថា ត្រូវការរសនៃសាច់ នាងឆ្លើយថា បាន លោកម្ចាស់ ខ្ញុំនឹងបញ្ជូនទៅ ។ ក្នុងថ្ងៃទីពីរ កាលមិនបានសាច់ដែលជាកប្បិយៈ ទើបធ្វើកិច្ចដែលគួរធ្វើ ដោយសាច់ភ្លៅរបស់ខ្លួន ដោយការជ្រះថ្លា ក្នុងព្រះសាស្តា ក៏ត្រឡប់ជាអ្នកមានសរីរៈតាំងនៅដូចប្រក្រតីនោះឯង ចំណែកនាងវិសាខា ពិនិត្យមើលភិក្ខុកំលោះ និងសាមណេរដែលជាអ្នកឈឺហើយ ក៏ចេញទៅដោយទ្វារដទៃ ឈរត្រង់ឧបចារវិហារហើយពោលថា នែនាង ចូរនាងយកគ្រឿងប្រដាប់មក ខ្ញុំនឹងស្លៀកពាក់ ។ ក្នុងគ្រានោះ ស្រីបម្រើនោះដឹងថាខ្លួន ភ្លេចហើយចេញមក ទើបឆ្លើយថា បពិត្រអ្នកនាង ខ្ញុំភ្លេចហើយ នាងវិសាខាពោលថា បើដូច្នោះ ចូរទៅយកមក តែបើលោកម្ចាស់អានន្ទរបស់យើង រើសទុកដាក់ក្នុងទីដទៃ នាងកុំយកមកឡើយ ខ្ញុំនឹងបរិច្ចាគគ្រឿងប្រដាប់នោះប្រគេនលោកម្ចាស់នោះឯង ។ បានឮថា នាងវិសាខាដឹងថា ព្រះថេរៈតែងរើសរបស់ដែលពួកមនុស្សភ្លេច ព្រោះដូច្នោះទើបពោលយ៉ាងនោះ ។

ចំណែកព្រះថេរៈ លុះឃើញអ្នកបម្រើនោះក៏សួរថា នាងមកដើម្បីបំណងអ្វី កាលអ្នកបម្រើនោះឆ្លើយថា ខ្ញុំភ្លេចគ្រឿងប្រដាប់របស់ម្ចាស់ខ្ញុំ ទើបពោលថា អាត្មារើសទុកត្រង់ក្បាលជណ្តើរនោះ ចូរនាងយកចុះ ។ ស្រីបម្រើឆ្លើយថា បពិត្រលោកម្ចាស់ បន្ទេចកណ្តៈដែលលោកម្ចាស់យកដៃពាល់ត្រូវហើយម្ចាស់របស់ខ្ញុំប្រាប់មិនឲ្យយកទៅឡើយ ដូច្នេះហើយ ក៏មានដៃទទេត្រឡប់ទៅត្រូវនាងវិសាខាសួរថា តើមានរឿងអ្វី ទើបប្រាប់សេចក្តីនោះ ។ នាងវិសាខា

ពោលថា ខ្ញុំនឹងមិនប្រដាប់គ្រឿងដែលលោកម្ចាស់ពាល់ត្រូវឡើយ ខ្ញុំនឹងបរិច្ចាគហើយ តែលោកម្ចាស់រក្សាទុកជាការលំបាក ខ្ញុំនឹងចំណាយគ្រឿងប្រដាប់នោះហើយ នឹងបង្អោនជារបស់កប្បិយៈ នាងចូរទៅយកគ្រឿងប្រដាប់នោះមក ។ អ្នកបម្រើនោះទៅនាំយកមកហើយ ។ នាងវិសាខាមិនតែងគ្រឿងប្រដាប់នោះឲ្យហៅជាងមាសមកហើយ ឲ្យវាយតម្លៃ កាលជាងមាសទាំងនោះឆ្លើយថា មានតម្លៃ ៩ កោដិ តែសម្រាប់តម្លៃឈ្នួលដល់មួយសែន ។ ទើបដាក់គ្រឿងប្រដាប់លើយាន ហើយពោលថា បើដូច្នោះ ពួកអ្នកចូរលក់គ្រឿងប្រដាប់នោះ ។ មិនមានបុគ្គលណាអាចឲ្យទ្រព្យចំនួនប៉ុណ្ណោះទទួលបាន ព្រោះស្រីដែលសមគួរប្រដាប់គ្រឿងប្រដាប់នោះ រកបានដោយលំបាក ។ ពិតហើយស្រី ៣ នាក់ប៉ុណ្ណោះក្នុងបឋវីមណ្ឌល បាននូវគ្រឿងប្រដាប់មហាលតាបសាធន៍ គឺនាងវិសាខាមហាឧបាសិកា ១ នាងមល្លិកា ភរិយារបស់ពន្ធុលមលសេនាបតី ១ កូនស្រីរបស់សេដ្ឋីក្រុងពារាណសី ១ ព្រោះដូច្នោះ ទើបនាងវិសាខាទិញគ្រឿងប្រដាប់នោះ ខ្លួនឯងនោះឯង ឲ្យជញ្ជូនទ្រព្យ ៩ កោដិ ១ សែន ដាក់លើរទេះនាំទៅកាន់វិហារ ថ្វាយបង្គំព្រះសាស្តាហើយ ក្រាបទូលថា បពិត្រព្រះអង្គ ព្រះអានន្ទត្ថេររបស់ខ្ញុំម្ចាស់ យកដៃពាល់ត្រូវគ្រឿងប្រដាប់របស់ខ្ញុំម្ចាស់ហើយ ចាប់តាំងអំពីកាលដែលលោកពាល់ត្រូវហើយ ខ្ញុំម្ចាស់មិនអាចប្រដាប់បាន តែខ្ញុំម្ចាស់ឲ្យលក់គ្រឿងប្រដាប់នោះដោយគិតថា ចំណាយបង្អោនយកវត្ថុដែលជាកប្បិយៈមក មិនឃើញអ្នកដទៃអាចទទួលបាន ទើបឲ្យទទួលគ្រឿងប្រដាប់នោះខ្លួនឯងមកហើយ ខ្ញុំម្ចាស់នឹងបង្អោនចូលក្នុងបច្ច័យណាបណ្តា

បច្ច័យ ៤ នោះ ព្រះសាស្តាត្រាស់ថា នាងគួរធ្វើលំនៅដើម្បីសង្ឃក្បែរទ្វារទិសខាងកើតចុះ ។ នាងវិសាខាទទួលថា សមគួរព្រះអង្គ មានចិត្តរីករាយទើបយកទ្រព្យ ៩ កោដិទិញដី នាងផ្តើមសាងវិហារដោយទ្រព្យ ៩ កោដិក្រៅអំពីនេះ ។

ថ្ងៃមួយ ព្រះសាស្តាប្រមើលមើលលោកក្នុងវេលាទៀបភ្លឺ បានឃើញឧបនិស្សយសម្បត្តិរបស់សេដ្ឋីបុត្រឈ្មោះភទ្ទិយៈ ដែលចុតិអំពីទេវលោក ហើយកើតក្នុងត្រកូលសេដ្ឋីក្នុងភទ្ទិយនគរ ទ្រង់ធ្វើភត្តកិច្ចក្នុងផ្ទះរបស់អនាថ-បិណ្ឌិកសេដ្ឋីហើយ ក៏បែរព្រះភក្ត្រទៅកាន់ទិសឧត្តរ ។ តាមប្រក្រតីព្រះសាស្តាទ្រង់ទទួលភិក្ខាក្នុងផ្ទះរបស់នាងវិសាខាហើយ ក៏យាងចេញតាមទ្វារទិសទក្សិណប្រថាប់ក្នុងវត្តជេតពន ។ ទ្រង់ទទួលភិក្ខាក្នុងផ្ទះអនាថបិណ្ឌិកសេដ្ឋីហើយ ក៏យាងចេញតាមទ្វារទិសខាងកើត ប្រថាប់នៅក្នុងបុព្វារាម ។ ជនទាំងឡាយឃើញព្រះដ៏មានព្រះភាគ ទ្រង់យាងបែរព្រះភក្ត្រទៅកាន់ទ្វារទិសឧត្តរហើយ រមែងដឹងបានថា ទ្រង់យាងទៅកាន់ទីចារិក ។ ក្នុងថ្ងៃនោះ នាងវិសាខាគ្រាន់តែដឹងថា ព្រះសាស្តាទ្រង់យាងបែរព្រះភក្ត្រទៅកាន់ទ្វារទិសឧត្តរ ទើបប្រញាប់ប្រញាល់ទៅ ថ្វាយបង្គំហើយក្រាបទូលថា បពិត្រព្រះអង្គ ទ្រង់បំណងយាងទៅកាន់ទីចារិកឬ ព្រះសាស្តាត្រាស់ថា ម្នាលនាងវិសាខា យ៉ាងនោះឯង ។ នាងវិសាខាពោលថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់នឹងបរិច្ចាគទ្រព្យចំនួនប៉ុណ្ណេះសាងវិហារថ្វាយព្រះអង្គ សូមទ្រង់ត្រឡប់ចុះ ។

ព្រះសាស្តាត្រាស់ថា ម្នាលនាងវិសាខា នេះជាការទៅមិនត្រឡប់ ។

នាងវិសាខាគិតថា ព្រះមានព្រះភាគ ទ្រង់ឃើញបុគ្គលណាម្នាក់ ដែលសម្បូរដោយហេតុពិត ទើបក្រាបទូលថា បើដូច្នោះ សូមទ្រង់ត្រាស់ប្រាប់ភិក្ខុមួយរូបដែលយល់ក្នុងការងារ ដែលខ្ញុំម្ចាស់ធ្វើហើយ ឬមិនទាន់បានធ្វើត្រឡប់ហើយទ្រង់យាងចុះ ព្រះសាស្ដាត្រាស់ថា នាងគាប់ចិត្តភិក្ខុរូបណា ចូរទទួលបាត្រភិក្ខុរូបនោះចុះ ។

សូម្បីនាងជូនចិត្តក្នុងព្រះអានន្ទត្ថេរក៏ពិត តែគិតថា ព្រះមហាមោគ្គល្លានជាអ្នកមានឫទ្ធិ ការងាររបស់យើងនឹងឆាប់សម្រេច ព្រោះអាស្រ័យព្រះថេរៈនោះ ដូច្នេះហើយ ទើបទទួលបាត្ររបស់ព្រះថេរៈ ។ ព្រះថេរៈសម្លឹងព្រះសាស្ដា ព្រះសាស្ដាត្រាស់ថា ម្នាលមោគ្គល្លាន អ្នកចូរនាំបរិវារ ៥០០ ត្រឡប់ចុះ ។ លោកបានធ្វើតាមព្រះតម្រាស់នោះហើយ ។ ដោយអានុភាពរបស់លោកពួកមនុស្សទៅដើម្បីឈើ និងថ្ម រយៈផ្លូវ ៥០-៦០ យោជន៍ ក៏ជញ្ជូនយកឈើនិងថ្មមកបានភ្លាមក្នុងថ្ងៃនោះឯង សូម្បីលើកឈើ និងថ្មដាក់រទេះក៏មិនលំបាកភ្លៅរទេះក៏មិនបាក់ ក្នុងកាលមិនយូរឡើយ ពួកជនទាំងនោះ សាងប្រាសាទពីរជាន់សម្រេច ។ ប្រាសាទនោះ បានជាប្រាសាទប្រដាប់ដោយបន្ទប់មួយពាន់ គឺខាងក្រោម ៥០០ ខាងលើ ៥០០ ។ ព្រះសាស្ដាទ្រង់ចារិកទៅ អស់កាល ៩ ខែហើយ ទើបយាងត្រឡប់មកកាន់ក្រុងសាវត្ថីវិញ សូម្បីការងារក្នុងប្រាសាទរបស់នាងវិសាខា ក៏សម្រេចក្នុងរយៈពេល ៩ ខែដូចគ្នា ។ នាងឲ្យសាងកំពូលប្រាសាទចំណុះទឹកបាន ៦០ ក្អម ដោយមាសទឹក ១០ ដែលផែជាបន្ទះនោះឯង ។ នាងបានឮថា ព្រះសាស្ដាយាងមកកាន់ជេតពនមហា-

វិហារ ទើបធ្វើការទទួល នាំព្រះសាស្តាទៅកាន់វិហាររបស់ខ្លួនហើយ ទទួលប្តេជ្ញាថា បពិត្រព្រះអង្គ សូមទ្រង់នាំភិក្ខុសង្ឃប្រថាប់នៅក្នុងវិហារនេះឯងអស់កាល ៤ ខែនេះ ខ្ញុំម្ចាស់នឹងធ្វើការឆ្លងប្រាសាទ ។ ព្រះសាស្តាទ្រង់ទទួលហើយ ។

ចាប់តាំងអំពីកាលនោះ នាងវិសាខានោះរមែងថ្វាយទានដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានក្នុងវិហារនោះឯង កាលនោះ ស្រីជាសម្លាញ់ម្នាក់របស់នាង កាន់សំពត់មួយផ្ទាំងដែលមានតម្លៃមួយពាន់មកហើយពោលថា សម្លាញ់ខ្ញុំចង់ក្រាលសំពត់នេះដោយសន្មថថា ជាកម្រាលផ្ទៃក្នុងប្រាសាទរបស់នាង សូមនាងជួយប្រាប់ទីដែលគួរក្រាលដល់ខ្ញុំ ។ នាងវិសាខាពោលថា សម្លាញ់បើខ្ញុំប្រាប់ដល់នាងថា ឱកាសមិនមាន នាងក៏នឹងសម្គាល់ថាមិនប្រាថ្នាឲ្យឱកាសដល់អញ ចូរនាងពិនិត្យមើលផ្ទៃនៃប្រាសាទពីរជាន់ និងបន្ទប់មួយពាន់ រួចដឹងទីដែលគួរក្រាលខ្លួនឯងចុះ ។ ស្រីសម្លាញ់នោះ កាន់សំពត់ដែលមានតម្លៃមួយពាន់ ដើររកមើលក្នុងទីនោះៗ មិនឃើញសំពត់ដែលមានតម្លៃតិចជាងសំពត់របស់ខ្លួននោះហើយ ក៏ដល់នូវការទោមនស្សថា អញមិនបានចំណែកបុណ្យក្នុងប្រាសាទនេះ ទើបឈរយំក្នុងទីមួយកន្លែង ។ គ្រានោះ ព្រះអានន្ទឃើញស្រីនោះ ទើបសួរថា នាងយំព្រោះហេតុអ្វី នាងប្រាប់សេចក្តីនោះហើយ ។ ព្រះថេរៈពោលថា នាងកុំគិតឡើយ អាត្មានឹងប្រាប់ទីដែលត្រូវក្រាលដល់នាងហើយពោលថា ចូរនាងក្រាលត្រង់ជណ្តើរ ធ្វើជាសំពត់ជូតជើង ភិក្ខុទាំងឡាយលាងជើងហើយ ជូតជើងត្រង់សំពត់នោះមុន ទើបចូលទៅខាងក្នុង កាលបើ

ដូច្នោះ ផលជាច្រើននឹងមានដល់នាង ។ បានឮថា ទីនោះជាស្ថានដែលនាងវិសាខាមិនបានកំណត់ ។ នាងវិសាខាបានថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះសម្ពុទ្ធជាប្រធាន ខាងក្នុងវិហារអស់កាល ៤ ខែ ។ ក្នុងថ្ងៃចុងក្រោយ បានថ្វាយសំពត់សាដក ដើម្បីធ្វើចីវរដល់ភិក្ខុសង្ឃ ។ សំពត់សាដកដើម្បីធ្វើចីវរដែលភិក្ខុថ្មីក្នុងសង្ឃបានហើយ មានតម្លៃមួយពាន់ ។ នាងបានប្រគេនភេសជ្ជៈពេញបាត្រដល់ភិក្ខុគ្រប់រូប ។ ព្រោះកាលបរិច្ចាគទាន ទ្រព្យបានអស់ទៅរហូត ៩ កោដិ ។ នាងវិសាខាបរិច្ចាគទ្រព្យក្នុងព្រះពុទ្ធសាសនាទាំងអស់ ២៧ កោដិ គឺទិញដីធ្វើវិហារ ៩ កោដិ សាងវិហារ ៩ កោដិ ឆ្លងវិហារ ៩ កោដិដោយប្រការដូច្នេះ ។

ឈ្មោះថា ការបរិច្ចាគបែបនេះ រមែងមិនមានដល់ស្រីដទៃដែលតាំងនៅក្នុងភាវៈនៃស្ត្រី ដែលនៅក្នុងផ្ទះរបស់ត្រកូលមិច្ឆាទិដ្ឋិ ។

ក្នុងថ្ងៃនៃការឆ្លងវិហារស្រេច វេលារសៀល នាងវិសាខាដែលមានកូននិងចៅចោមរោមហើយ គិតថា ការប្រាថ្នាណាដែលអញតាំងទុកហើយក្នុងកាលមុន ការប្រាថ្នាទាំងអស់នោះដល់ទីបំផុតហើយ ។ ដើរប្រទក្សិណជុំវិញប្រាសាទ បន្លឺឧទានដោយសំឡេងដ៏ពីរោះ ៥ គាថាថា

> សេចក្តីត្រិះរិះរបស់ខ្ញុំថា តើកាលណា ខ្ញុំនឹងថ្វាយប្រាសាទថ្មីដែលបូកលាបដោយបាយអ និងដី ជាវិហារទាន ដូច្នេះ បរិបូណ៌ហើយ ។ សេចក្តីត្រិះរិះរបស់ខ្ញុំថា តើកាលណា ខ្ញុំនឹងបានថ្វាយគ្រែ តាំង ពូក និងខ្នើយ ជាសេនាសនភណ្ឌៈ

ដូច្នេះ បរិបូណ៌ហើយ ។ សេចក្តីត្រិះរិះរបស់ខ្ញុំថា តើកាលណា ខ្ញុំនឹងថ្វាយសលាកភត្ត ផ្សំដោយសាច់ដ៏ស្អាត ជាភោជនទាន ដូច្នេះ បរិបូណ៌ហើយ ។ សេចក្តីត្រិះរិះរបស់ខ្ញុំថា តើកាលណា ខ្ញុំនឹងថ្វាយសំពត់កាសិកពស្ត្រ សំពត់សម្បកឈើ និងសំពត់កប្បាសជាចីវរទាន ដូច្នេះ បរិបូណ៌ហើយ ។ សេចក្តីត្រិះរិះរបស់ខ្ញុំថា តើកាលណា ខ្ញុំនឹងថ្វាយសប្បិ នវនីត ទឹកឃ្មុំ ប្រេង និងទឹកអំពៅ ជាភេសជ្ជទាន ដូច្នេះ បរិបូណ៌ហើយ ។

ភិក្ខុទាំងឡាយបានឮសំឡេងរបស់នាងហើយ ក្រាបទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គ ឈ្មោះថាការច្រៀងរបស់នាងវិសាខា ពួកខ្ញុំព្រះអង្គមិនធ្លាប់ឃើញអស់កាលដ៏យូរមានប្រមាណប៉ុណ្ណេះ ។ ថ្ងៃនេះ នាង ដែលកូន និងចៅចោមរោមហើយ ច្រៀងដើរប្រទក្សិណជុំវិញប្រាសាទ ប្រមាត់របស់នាងកម្រើកឬហ្ន៎ ឬនាងខូចចរិតទៅហើយ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កូនស្រីរបស់តថាគតមិនមែនច្រៀងឡើយ តែអធ្យាស្រ័យផ្ទាល់ខ្លួនរបស់នាងពេញបរិបូណ៌ហើយ នាងត្រេកអរក្នុងចិត្តថា សេចក្តីប្រាថ្នាដែលអញតាំងទុកដល់ទីបំផុតហើយ ទើបដើរបន្លឺឧទាន ។ កាលភិក្ខុទាំងឡាយក្រាបទូលថា តើនាងតាំងសេចក្តីប្រាថ្នាតាំងពីអង្កាល់ណា ទើបព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកនឹងស្តាប់ឬ កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងស្តាប់ ទើបទ្រង់នាំអតីតនិទានមកត្រាស់ដូច្នេះថា

ម្នាលភិក្ខុទាំងឡាយ ក្នុងទីបំផុតមួយសែនកប្បអំពីកប្បនេះទៅ ព្រះពុទ្ធព្រះនាមបទុមុត្តរៈ ទ្រង់កើតឡើងហើយក្នុងលោក ព្រះអង្គមានព្រះជន្ម ១ សែនឆ្នាំ មានភិក្ខុខីណាស្រពមួយសែនជាបរិវារ ។ នគរឈ្មោះហង្សវតី ព្រះជនកជាព្រះរាជា ព្រះនាមសុនន្ទៈ ព្រះជននីជាព្រះទេវី ព្រះនាមសុជាតា ឧបាសិកាជាកំពូលឧបដ្ឋាយិការបស់ព្រះសាស្តាអង្គនោះ ទូលសូមពរ ៨ ប្រការ ហើយតាំងនៅក្នុងឋានៈដូចមាតា ទំនុកបម្រុងព្រះសាស្តាដោយបច្ច័យ រមែងទៅកាន់ទីបម្រើទាំងល្ងាច និងព្រឹក ។ ស្រីជាសម្លាញ់ម្នាក់របស់ឧបាសិកានោះ រមែងទៅវិហារជាមួយឧបាសិកានោះជានិច្ច ស្រីនោះឃើញឧបាសិកានោះចរចាជាមួយព្រះសាស្តា ដោយសេចក្តីស្និទ្ធស្នាល និងឃើញភាពជាអ្នកជិតស្និទ្ធជាមួយព្រះសាស្តា គិតថា នាងធ្វើកម្មអ្វីហ្ន៎ ទើបជាបុគ្គលស្និទ្ធស្នាលជាមួយព្រះសម្ពុទ្ធយ៉ាងនេះ ដូច្នេះហើយ ទើបទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គ ស្រីនេះជាអ្វីនឹងព្រះអង្គ ព្រះសាស្តាត្រាស់ថា នាងជាកំពូលនៃស្រីដែលជាឧបដ្ឋាយិកា ស្រីនោះពោលថា បពិត្រព្រះអង្គ នាងធ្វើកម្មអ្វី ទើបជាកំពូលនៃស្រីដែលជាឧបដ្ឋាយិកា ព្រះសាស្តាត្រាស់ថា នាងតាំងសេចក្តីប្រាថ្នាអស់មួយសែនកប្ប ។ ស្រីនោះពោលថា ឥឡូវនេះ ខ្ញុំម្ចាស់នឹងប្រាថ្នា តើអាចបានដែរឬទេ ព្រះសាស្តាត្រាស់ថា អាច ។ ស្រីនោះក្រាបទូលថា បពិត្រព្រះអង្គ បើដូច្នោះ សូមទ្រង់ និងភិក្ខុមួយសែនរូប ទទួលភិក្ខារបស់ខ្ញុំម្ចាស់ ធាន់រហូត ៧ ថ្ងៃចុះ ។ ព្រះសាស្តាទ្រង់ទទួលហើយ ។ ស្រីនោះថ្វាយទានគ្រប់ ៧ ថ្ងៃ ក្នុងថ្ងៃទីបំផុត បានថ្វាយសាដកដើម្បីធ្វើចីវរហើយ ថ្វាយបង្គំ

ព្រះសាស្តា ក្រាបចុះទៀបបាទមូល តាំងសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គ ដោយផលនៃទាននេះ ខ្ញុំម្ចាស់ប្រាថ្នាភាពជាធំ ក្នុងទេវលោកជាដើមណាមួយ ក៏មិនមែន ខ្ញុំម្ចាស់គប្បីបានពរ ៨ ប្រការ ក្នុងសម្នាក់នៃព្រះពុទ្ធ ដូចគ្នានឹងព្រះអង្គ ហើយតាំងនៅក្នុងឋានៈដូចមាតា ជាកំពូលនៃឧបាសិកាដែលអាចទំនុកបម្រុងដោយបច្ច័យ ៤ ព្រះសាស្តាទ្រង់ពិចារណាថា សេចក្តីប្រាថ្នារបស់ស្រីនេះ នឹងសម្រេចឬហ្ន៎ ទ្រង់ពិចារណាដល់អនាគតកាល ប្រមើលមើលរហូតសែនកប្បហើយ ទើបត្រាស់ថា ក្នុងទីបំផុតនៃកប្បទីមួយសែន ព្រះពុទ្ធព្រះនាមគោតម ទ្រង់នឹងកើតឡើង ។ ក្នុងកាលនោះ នាងនឹងបានជាឧបាសិកាឈ្មោះថា វិសាខា បានពរ ៨ ប្រការក្នុងសម្នាក់របស់ព្រះអង្គ ហើយតាំងនៅក្នុងឋានៈដូចមាតា ជាកំពូលនៃស្រីជាឧបដ្ឋាយិកា ដែលទំនុកបម្រុងដោយបច្ច័យ ៤ ។ សម្បត្តិនោះ នាងហាក់បីដូចបានក្នុងថ្ងៃស្អែក ។

នាងធ្វើកុសលដរាបដល់អស់អាយុហើយ ចុតិអំពីអត្តភាពនោះ កើតក្នុងទេវលោក អន្ទោលទៅក្នុងទេវលោក និងមនុស្សលោក ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធព្រះនាមកស្សបៈ កើតជាព្រះធីតាព្រះនាមសង្ឃទាសី ដែលជាបងប្អូនរបស់បណ្តាធីតា ៧ អង្គ របស់ព្រះបាទកាសីព្រះនាមកិកិ ជាអ្នកមិនបានទៅកាន់ត្រកូលដទៃ ព្រះនាងធ្វើបុណ្យមានទានជាដើម ជាមួយបងស្រីទាំងនោះអស់កាលយូរ បានធ្វើសេចក្តីប្រាថ្នាទៀបបាទមូលនៃព្រះសម្មាសម្ពុទ្ធព្រះនាមកស្សបៈថា ក្នុងអនាគតកាល ខ្ញុំម្ចាស់គប្បីបានពរ ៨ ប្រការ ក្នុងសម្នាក់នៃព្រះពុទ្ធដូចទ្រង់ ហើយតាំងនៅក្នុងឋានៈដូចមាតា ជាកំពូលឧបាសិកា

ដែលថ្វាយបច្ច័យ ៤ ។ ចាប់តាំងពីកាលនោះ នាងអន្ទោលទៅក្នុងទេវលោក និងមនុស្សលោក ក្នុងអត្តភាពនេះ កើតជាកូនស្រីរបស់ធនញ្ជយសេដ្ឋី ដែលជាកូនរបស់មេណ្ឌកសេដ្ឋី ។ បានធ្វើបុណ្យដ៏ច្រើនក្នុងសាសនារបស់តថាគត ។

ព្រះសាស្តា កាលទ្រង់សម្តែងអតីតនិទានចប់ហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធីតារបស់តថាគត មិនមែនច្រៀងដោយប្រការដូច្នេះឯង តែនាងឃើញសេចក្តីសម្រេចនៃការប្រាថ្នាដែលតាំងទុក ទើបបន្លឺឧទាន កាលទ្រង់សម្តែងធម៌ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មាលាការអ្នកឈ្លាសធ្វើគំនរផ្កាផ្សេងៗ ឲ្យជាគំនរហើយ រមែងធ្វើកម្រងផ្កា មានប្រការផ្សេងៗបាន យ៉ាងណា ចិត្តរបស់នាងវិសាខា រមែងបង្អោនទៅដើម្បីធ្វើកុសល មានប្រការផ្សេងៗ ក៏ដូច្នោះដូចគ្នា ដូច្នេះហើយ ត្រាស់គាថានេះថា

**យថាបិ បុប្ផរាសិម្ហា កយិរា មាលាគុណេ ពហូ**
**ឯវំ ជាតេន មច្ចេន កត្តព្វំ កុសលំ ពហុំ ។**

មាលាការចេះធ្វើសំណុំនៃកម្រងផ្កា អំពីគំនរនៃផ្កា ( ផ្សេងៗគ្នា ) ឲ្យច្រើនបាន យ៉ាងណាមិញ កុសលដែលសត្វកើតមកហើយ គួរធ្វើឲ្យច្រើន យ៉ាងនោះ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **បុប្ផរាសិម្ហា** បានដល់ អំពីគំនរនៃផ្កាដែលមានប្រការផ្សេងៗ ។ បទថា **កយិរា** ប្រែថា គប្បីធ្វើ ។ ពីរបទថា **មាលាគុណេ ពហូ** សេចក្តីថា នូវមាលាវិកតិច្រើនប្រភេទ ដោយប្រភេទមានផ្កា

ដែលមានទងតែម្ខាងជាដើម ។ បទថា **មច្ចេន** សេចក្តីថា សត្វដែលបាន ឈ្មោះថា **មច្ចោ** ព្រោះជាបុគ្គលដែលគប្បីស្លាប់ជាសភាវៈ គួរធ្វើកុសល មានការថ្វាយចីវរជាដើមឲ្យបានច្រើន ។ សព្ទ គឺ **បុប្ផរាសិ** ក្នុងគាថានោះ មានការសម្តែងផ្កាច្រើនជាអត្ថ ។

បើផ្កាមានតិច នាយមាលាការឈ្លាសវៃ ក៏រមែងមិនអាចធ្វើកម្រងផ្កា ឲ្យច្រើនបានឡើយ ចំណែកមាលាការដែលមិនឈ្លាស កាលផ្កា ទោះបីមាន តិចក្តី ច្រើនក្តី រមែងមិនអាចដោយពិត តែបើផ្កាមានច្រើន មាលាការដែល ឈ្លាស ឧស្សាហ៍ មុតស្រួច រមែងធ្វើពួកផ្កាឲ្យច្រើន យ៉ាងណា បើសទ្ធា របស់បុគ្គលខ្លះ មានតិច ភោគៈមានច្រើន បុគ្គលនោះ រមែងមិនអាចធ្វើកុសល ឲ្យច្រើនបានឡើយ ឯកាលសទ្ធាមានតិច ទាំងភោគៈក៏តិច បុគ្គលនោះ ក៏ រមែងមិនអាច តែកាលសទ្ធាច្រើន ភោគៈតិច បុគ្គលនោះ ក៏រមែងមិនអាច ដូចគ្នា តែបើសទ្ធាមានច្រើន ភោគៈក៏ច្រើន បុគ្គលរមែងអាចធ្វើកុសលឲ្យ ច្រើនបាន ដូច្នោះ នាងវិសាខាឧបាសិកាជាបុគ្គលបែបនោះឯង ព្រះសាស្តា ទ្រង់សម្តៅយកនាងវិសាខានោះ ទើបត្រាស់ពាក្យជាព្រះគាថាដូច្នេះថា

មាលាការបេះធ្វើសំណុំនៃកម្រងផ្កា អំពីគំនរនៃផ្កា ( ផ្សេងៗ គ្នា ) ឲ្យ ច្រើនបាន យ៉ាងណាមិញ កុសលដែលសត្វកើតមកហើយ គួរធ្វើឲ្យច្រើន យ៉ាងនោះឯង ។

មាលាការបេះធ្វើសំណុំនៃកម្រងផ្កា អំពីគំនរនៃផ្កា ( ផ្សេងៗ គ្នា ) ឲ្យ ច្រើនបាន យ៉ាងណាមិញ កុសលដែលសត្វកើតមកហើយ គួរធ្វើឲ្យបាន

ច្រើនយ៉ាងនោះ ។

ក្នុងពេលចប់ទេសនា មហាជនបានជាអរិយបុគ្គល មានសោតាបន្ន ជាដើម ទេសនាមានប្រយោជន៍ដល់មហាជនហើយ ដូច្នេះឯង ។

**រឿង ឆាតាបសាខា ចប់**

# រឿង បញ្ហារបស់ព្រះអានន្ទត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងក្រុងសាវត្ថី កាលទ្រង់ស្រាយបញ្ហា របស់ព្រះអានន្ទត្ថេរ ត្រាស់ធម្មទេសនានេះថា **ន បុប្ផគន្ធោ បដិវាតមេតិ** ជាដើម ។

បានឮមកថា ព្រះថេរៈពួនសម្ងំហើយក្នុងពេលល្ងាច គិតថា ព្រះដ៏មាន ព្រះភាគ ត្រាស់ក្លិនដ៏ឧត្តម ៣ យ៉ាង គឺក្លិនកើតអំពីឫស ក្លិនកើតអំពីខ្លឹម ក្លិនកើតអំពីផ្កា ក្លិនរបស់គន្ធជាតិទាំងនោះ ផ្សាយទៅតាមខ្យល់ប៉ុណ្ណោះ មិន ផ្សាយទៅច្រាស់ខ្យល់ឡើយ ក្លិនរបស់គន្ធជាតិណាផ្សាយទៅបានច្រាស់ខ្យល់ គន្ធជាតិនោះមានឬហ្ន៎ ។ គ្រានោះ លោកមានការគិតថា ប្រយោជន៍អ្វីរបស់ អញដោយបញ្ហាដែលវិនិច្ឆ័យដោយខ្លួនឯង អញនឹងទូលសួរព្រះសាស្តានោះ ឯងល្អជាង ចូលទៅគាល់ព្រះសាស្តាហើយ ទូលសួរ ។ ព្រោះហេតុនោះឯង ទើបព្រះធម្មសង្គាហកាចារ្យពោលថា គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូល

ទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្លិននៃគន្ធជាតិដែលផ្សាយទៅកាន់ទីបណ្តោយខ្យល់បាន ទៅច្រាស់ខ្យល់មិនបាននេះមាន ៣ យ៉ាង ។ គន្ធជាតិ ៣ យ៉ាង តើដូចម្តេច ។ គឺក្លិនឫស ១ ក្លិនខ្លឹម ១ ក្លិនផ្កា ១ ។ បពិត្រព្រះអង្គដ៏ចម្រើន ក្លិនគន្ធជាតិទាំង ៣ នេះឯង ផ្សាយទៅបានតែទីបណ្តោយ ខ្យល់ទៅច្រាសខ្យល់ មិនបានទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ក្រែងមានក្លិនគន្ធជាតិអ្វី ដែលផ្សាយទៅបណ្តោយខ្យល់ក៏បាន ផ្សាយទៅច្រាសខ្យល់ក៏បាន ផ្សាយទៅទាំងបណ្តោយខ្យល់ និងច្រាស់ខ្យល់ក៏បាន មានដែរឬទេ ។ គ្រានោះ ព្រះដ៏មានព្រះភាគ កាលទ្រង់ឆ្លើយបញ្ហាដល់ព្រះអានន្ទ ទើបត្រាស់ថា ម្នាលអានន្ទ ក្លិនគន្ធជាតិដែលផ្សាយទៅបណ្តោយខ្យល់ក៏បាន ទៅច្រាស់ខ្យល់ក៏បាន ទៅបណ្តោយខ្យល់និងច្រាស់ខ្យល់ក៏បាន មានដែរ ។

ព្រះអានន្ទទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ចុះគន្ធជាតិដែលផ្សាយទៅបណ្តោយខ្យល់ក៏បាន ច្រាស់ខ្យល់ក៏បាន ទាំងបណ្តោយខ្យល់ និងច្រាស់ខ្យល់ក៏បាន តើដូចម្តេច ។

ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ ក្នុងលោកនេះ ស្ត្រីក្តី បុរសក្តី ក្នុងស្រុក ឬនិគមណា បានដល់ព្រះពុទ្ធជាទីរឭក បានដល់ព្រះធម៌ជាទីរឭក បានដល់ព្រះសង្ឃជាទីរឭក វៀរចាកការសម្លាប់សត្វ វៀរចាកការលួចលាក់យក

វត្ថុដែលគេមិនបានឲ្យ វៀរចាកការប្រព្រឹត្តខុសក្នុងកាម វៀរចាកការនិយាយកុហក វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ជាអ្នកមានសីល មានធម៌ល្អ មានចិត្តប្រាសចាកសេចក្តីកំណាញ់ ជាមន្ទិល នៅគ្រប់គ្រងផ្ទះ ជាអ្នកមានទានបរិច្ចាគហើយ មានដៃលាងស្អាតហើយ ជាអ្នកត្រេកអរក្នុងការលះ ជាអ្នកគួរគេសូមបាន ត្រេកអរក្នុងការឲ្យនិងការចែករំលែក សមណព្រាហ្មណ៍ក្នុងទិសទាំងឡាយ រមែងសរសើរបុគ្គលនោះថា ស្ត្រីក្តី បុរសក្តី ក្នុងស្រុក ឬនិគមឈ្មោះឯណោះ ដល់ព្រះពុទ្ធជាទីរឭក ។បេ។ ត្រេកអរក្នុងការចែករំលែកទាន ។ សូម្បីពួកទេវតាក៏តែងសរសើរបុគ្គលនោះថា ស្ត្រីក្តី បុរសក្តី ក្នុងស្រុក ឬនិគមឈ្មោះឯណោះ ជាអ្នកដល់ព្រះពុទ្ធជាទីរឭក ។បេ។ គួរគេសូមបាន ត្រេកអរក្នុងការចែករំលែកទាន ។ ម្នាលអានន្ទ ក្លិននៃគន្ធជាតិនេះឯង ទើបផ្សាយទៅបណ្តោយខ្យល់ក៏បាន ច្រាសខ្យល់ក៏បាន ទាំងបណ្តោយខ្យល់ ទាំងច្រាសខ្យល់ក៏បាន ។

ដូច្នេះហើយ ទ្រង់បានភាសិតព្រះគាថាទាំងនេះថា

**ន បុប្ផគន្ធោ បដិវាតមេតិ ន ចន្ទនំ តគរមល្លិកា វា**
**សតញ្ច គន្ធោ បដិវាតមេតិ សព្វា ទិសា សប្បុរិសោ បវាយតិ ។**
**ចន្ទនំ តគរំ វាបិ ឧប្បលំ អថ វស្សិកី**
**ឯតេសំ គន្ធជាតានំ សីលគន្ធោ អនុត្តរោ ។**

ក្លិនផ្កាឈើផ្សាយទៅច្រាសខ្យល់មិនបាន ក្លិនខ្លឹមចន្ទន៍ក្តី ក្លិនខ្លឹមក្រស្នាក្តី ក្លិនផ្កាម្លិះរួតក្តី ក៏ផ្សាយទៅច្រាសខ្យល់មិនបាន ចំណែក

*ក្លិនរបស់សប្បុរសទាំងឡាយ រមែងផ្សាយទៅច្រាសខ្យល់បាន ព្រោះសប្បុរស រមែងផ្សាយទៅបានគ្រប់ទិស ។ ក្លិននៃសីល ជាគុណជាតប្រសើរបំផុត ជាងគន្ធជាតិទាំងនេះ គឺខ្លឹមចន្ទន៍ ខ្លឹមក្រស្នា ផ្កាឧប្បល ផ្កាម្លិះលា ។*

## សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ បទថា* **ន បុប្ផគន្ធោ** *សេចក្តីថា ដើមបារិច្ឆត្តកៈក្នុងកពតាវត្តិង្សដោយបណ្តោយ និងទទឹង មានប្រមាណ ១០០ យោជន៍ រស្មីផ្ការបស់ដើមបារិច្ឆត្តកៈនោះ ផ្សាយចេញទៅ ៥០ យោជន៍ ក្លិនផ្សាយទៅបាន ១០០ យោជន៍ សូម្បីក្លិននោះក៏ផ្សាយទៅបានតាមខ្យល់ប៉ុណ្ណោះ មិនអាចផ្សាយទៅច្រាសខ្យល់បានត្រឹមតែមួយធ្នាប់ឡើយ ក្លិនផ្កាបែបនេះ ផ្សាយទៅច្រាសខ្យល់មិនបាន ។ បទថា* **ចន្ទនំ** *បានដល់ ក្លិនចន្ទន៍ ។ ដោយបទថា* **តគរមល្លិកា វា** *នេះ ទ្រង់បំណាងយកក្លិនរបស់គន្ធជាតិទាំងនេះដូចគ្នា ។ ពិតហើយ ក្លិនរបស់ចន្ទន៍ក្រហមក្តី របស់ក្រស្នា និងម្លិះលាក្តី ដែលជាកំពូលនៃក្លិន កើតអំពីខ្លឹមទាំងឡាយ រមែងផ្សាយទៅបានតាមខ្យល់ប៉ុណ្ណោះ ផ្សាយទៅច្រាសខ្យល់មិនបានឡើយ ។ ពីរបទថា* **សតញ្ច គន្ធោ** *សេចក្តីថា ចំណែកក្លិនសីលរបស់សប្បុរស គឺរបស់ព្រះពុទ្ធ និងព្រះសាវកទាំងឡាយ រមែងផ្សាយទៅច្រាសខ្យល់បាន ។*

*សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះសប្បុរស រមែងផ្សាយខ្ចរខ្ចាយទៅសព្វទិស ។ អធិប្បាយថា ព្រោះសប្បុរស រមែងផ្សាយគ្របដណ្តប់ទៅ*

សព្វទិសដោយក្លិនសីល ដូច្នោះ សប្បុរសដែលបណ្ឌិតគួរពោលបានថា ក្លិនរបស់លោកផ្សាយទៅប្រាស់ខ្យល់បាន ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា **បដិវាតមេតិ ។** បទថា **វស្សិកី** បានដល់ ផ្កាម្លិះ ។

បទថា **ឯតេសំ** ជាដើម សេចក្តីថា ក្លិនសីលរបស់សប្បុរសដែលមានសីលនោះឯង ជាក្លិនដ៏កំពូលជាងក្លិននៃគន្ធជាតិ មានចន្ទន៍ក្រហមជាដើមនេះ គឺបើក្លិនដែលដូចមិនមាន បានដល់ មិនមានចំណែកប្រៀបបាន ។

ក្នុងកាលចប់ទេសនា ជនជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ ទេសនាមានប្រយោជន៍ ដល់មហាជនហើយ ដូច្នោះឯង ៕

រឿង បញ្ហារបស់ព្រះអានន្ទ ចប់

# រឿង ប្រគេនបិណ្ឌបាតដល់ព្រះមហាកស្សបត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធការប្រគេនបិណ្ឌបាតដល់ព្រះមហាកស្សបត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **អប្បមត្តោ អយំ គន្ធោ** ជាដើម ។

សេចក្តីពិស្តារថា ថ្ងៃមួយ ព្រះមហាកស្សបៈចេញអំពីនិរោធសមាបត្តិដោយកន្លងទៅ ៧ ថ្ងៃ ចេញទៅហើយដោយគិតថា នឹងត្រាច់បិណ្ឌបាតតាម

លំដាប់ប្រកក្នុងក្រុងរាជគ្រឹះ ។ ក្នុងសម័យនោះ ទេពអប្សរប្រមាណ ៥០០ មានជើងដូចជើងព្រាប ជាបាទបរិចារិការបស់សក្កទេវរាជ កើតនូវឧស្សាហ៍ថា នឹងប្រគេនបិណ្ឌបាតដល់ព្រះថេរៈ ទើបត្រៀមបិណ្ឌបាត ៥០០ សម្រាប់ ហើយកាន់មកឈរក្នុងរវាងផ្លូវពោលថា សូមលោកម្ចាស់ទទួលបិណ្ឌបាតនេះ សូមលោកម្ចាស់ ធ្វើសេចក្តីអនុគ្រោះដល់ពួកខ្ញុំចុះ ។

ព្រះថេរៈពោលថា ចូរពួកនាងទៅចុះ អាត្មានឹងធ្វើសេចក្តីអនុគ្រោះដល់ពួកអ្នកក្រ ។ ទេពអប្សរពោលថា សូមលោកម្ចាស់កុំឲ្យពួកខ្ញុំវិនាសឡើយ សូមធ្វើសេចក្តីសង្គ្រោះពួកខ្ញុំចុះ ។

ព្រះថេរៈដឹងហើយទើបហាមទៀត ហើយផ្ទាត់ម្រាមដៃប្រាប់ស្រីទេព-អប្សរទាំងឡាយ ដែលមិនប្រាថ្នានឹងចៀសចេញទៅ កំពុងនៅអង្វរថា ពួកនាងមិនស្គាល់ប្រមាណ ចូរចៀសចេញទៅ ។ ទេពអប្សរទាំងនោះឮសំឡេងម្រាមដៃរបស់ព្រះថេរៈហើយ មិនអាចនៅឈររាំងផ្លូវបាន ទើបគេចទៅកាន់ទេវលោកវិញ សក្កទេវរាជត្រាស់សួរថា ពួកនាងទៅណា មកអំពីណា ទើបទូលថា ខ្ញុំម្ចាស់នាំគ្នាទៅដោយបំណងថា នឹងប្រគេនបិណ្ឌបាតដល់ព្រះមហាកស្សបត្ថេរ ដែលចេញអំពីសមាបត្តិ សក្កទេវរាជត្រាស់ថា ពួកនាងប្រគេនហើយឬ ស្រីទេពអប្សរប្រាប់ថា ព្រះថេរៈមិនប្រាថ្នានឹងទទួល សក្ក-ទេវរាជត្រាស់ថា ព្រះថេរៈពោលដូចម្តេច ទេពអប្សរប្រាប់ថា លោកពោលថា នឹងធ្វើសេចក្តីសង្គ្រោះពួកអ្នកក្រីក្រ សក្កទេវរាជពោលថា ពួកនាងទៅដោយអាការដូចម្តេច ស្រីទេពអប្សរប្រាប់ថា ទៅដោយអាការយ៉ាងនេះឯង ។

សក្កទេវរាជត្រាស់ថា ស្រីដូចពួកនាងនឹងប្រគេនបិណ្ឌបាតដល់ព្រះថេរៈបានដូចម្ដេច បំណាងនឹងប្រគេនដោយខ្លួនឯង ទើបកាឡាខ្លួនជាមនុស្សចាស់គ្រាំគ្រាដោយអំណាចជរា មានធ្មេញបាក់ មានសក់ស្កូវ ខ្នងកោង ជាជាងតម្បាញចាស់ ទ្រង់នាំនាងសុជាតាទេពធីតា ឲ្យធ្វើជាស្រីចាស់យ៉ាងនោះដូចគ្នាហើយ ទ្រង់និម្មិតផ្លូវនៃជាងតម្បាញមួយខ្សែ ប្រថាប់សន្ទឹងកីតម្បាញ ។

ចំណែកព្រះថេរៈនិមន្តបែរមុខចូលក្រុង ដោយបំណងថានឹងធ្វើសេចក្ដីសង្គ្រោះពួកអ្នកក្រីក្រ ឃើញផ្លូវមួយខ្សែនោះ ក្រៅក្រុងនោះឯង សម្លឹងមើលក៏បានឃើញជនពីរនាក់ ។ ខណៈនោះ សក្កទេវរាជកំពុងទាញកីតម្បាញនាងសុជាតារវៃអំបោះ ។ ព្រះថេរៈគិតថា ជនពីរនាក់នេះក្នុងកាលចាស់ ក៏នៅតែធ្វើការ ក្នុងក្រុងនេះ មិនមានអ្នកក្រីក្រជាងជនទាំងពីរនេះឡើយ អាត្មាអញនឹងទទួលកត្តលួមប្រមាណមួយវែក ដែលជនទាំងពីរប្រគេនហើយ ធ្វើនូវសេចក្ដីសង្គ្រោះដល់ជនទាំងពីរនេះ ។ ព្រះថេរៈបានបែរមុខទៅត្រង់ផ្ទះរបស់ជនទាំងពីរនោះឯង ។

សក្កទេវរាជទតឃើញព្រះថេរៈនោះ ទើបត្រាស់នឹងនាងសុជាតាថា នែនាង ព្រះថេរៈជាម្ចាស់នៃយើងនិមន្តមកផ្លូវនេះ ចូរនាងអង្គុយធ្វើដូចជាមិនឃើញលោកចុះ ខ្ញុំនឹងបញ្ឆោតលោកមួយភ្លែត ហើយសឹមប្រគេនបិណ្ឌបាត ។ ព្រះថេរៈបានមកឈរត្រង់ទ្វារផ្ទះហើយ ។ ជនទាំងពីរនាក់ប្ដីប្រពន្ធនោះ ក៏ធ្វើដូចជាមិនឃើញ ធ្វើតែការងាររបស់ខ្លួនតែម្យ៉ាង រង់ចាំបន្តិចហើយ ។ គ្រានោះសក្កៈត្រាស់ថា ត្រង់ទ្វារផ្ទះហាក់ដូចជាមានព្រះថេរៈឈរមួយរូប ចូរនាងទៅ

ពិនិត្យមើលសិន ។ នាងសុជាតាឆ្លើយថា អ្នកទៅពិនិត្យមើលចុះ ។ សក្កទេវរាជចេញអំពីផ្ទះហើយ ទ្រង់ថ្វាយបង្គំព្រះថេរៈដោយបញ្ចង្គប្រតិស្ឋានហើយ យកដៃទាំងពីរប្រចត់ក្បាលជង្គង់ ហើយដកដង្ហើមធំក្រោកឡើង បន្លឺន់មួយសម្តុះត្រាស់ថា លោកម្ចាស់ជាព្រះថេរៈអង្គណាហ្ន៎ ហើយត្រាស់បន្តថា ភ្នែករបស់ខ្ញុំវាស្រវាំង ដូច្នេះហើយ ទ្រង់ដាក់ដៃបាំងត្រង់ថ្ងាស ទ្រង់សម្លឹងមើលហើយត្រាស់ថា ឱហ្ន៎ លោកម្ចាស់មហាកស្សបត្ថេររបស់ខ្ញុំ យូរៗ ទើបមកកាន់ទ្វារខ្ទមរបស់ខ្ញុំ នាងមានអ្វីក្នុងផ្ទះខ្លះដែរឬទេ នាងសុជាតាធ្វើជាទ្រមខ្វួនបន្តិចហើយបានឲ្យចម្លើយថា មានអ្នក សក្កទេវរាជត្រាស់ថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់កុំគិតថា ទានសៅហ្មង ឬប្រណីត សូមធ្វើសេចក្តីសង្គ្រោះដល់ខ្ញុំទាំងពីរចុះ ដូច្នេះហើយ ទ្រង់ក៏ទទួលបាត្រ ។ ព្រះថេរៈគិតថា ទានដែលជនពីរនាក់ប្តីប្រពន្ធនេះឲ្យហើយ ទោះជាទឹកជ្រក់ ឬកុណ្ឌកមួយក្តាប់ក៏ដោយ អាត្មាអញនឹងធ្វើសេចក្តីសង្គ្រោះដល់ជនពីរនាក់ប្តីប្រពន្ធនេះ ដូច្នេះហើយ ទើបឲ្យបាត្រទៅ ។ សក្កទេវរាជនោះចូលទៅខាងក្នុងផ្ទះហើយ ទ្រង់ដួសបាយចេញអំពីឆ្នាំងដាក់ពេញបាត្រហើយ ដាក់ក្នុងដៃព្រះថេរៈ ។ បិណ្ឌបាតនោះ មានសូបព្យញ្ជនៈច្រើន បានក្រអូបឈ្ងុយពេញក្រុងរាជគ្រឹះហើយ ។

ក្នុងកាលនោះព្រះថេរៈគិតថា បុរសនេះមានសក្តិតូច បិណ្ឌបាតមានសក្តិច្រើន ដូចគ្នានឹងភោជនរបស់សក្កទេវរាជ ជននេះជាអ្នកណាហ្ន៎ កាលនោះព្រះថេរៈជ្រាបបុរសនោះថាជាសក្កៈ ទើបពោលថា ទ្រង់ដណ្តើមសម្បត្តិអ្នកក្រីក្រ ឈ្មោះថា ធ្វើកម្មធ្ងន់ហើយ អ្នកណាក៏ដោយដែលជាអ្នកក្រីក្រ បានឲ្យ

ទានដល់អាត្មាក្នុងថ្ងៃនេះ នឹងបានតំណែងសេនាបតី ឬតំណែងសេដ្ឋី សក្កទេវរាជត្រាស់ថា អ្នកក្រីក្រជាងខ្ញុំមិនមានឡើយ ព្រះថេរៈពោលថា ទ្រង់សោយសិរីសម្បត្តិក្នុងទេវលោក ឈ្មោះថា ជាអ្នកក្រដូចម្តេច សក្កទេវរាជត្រាស់ថា លោកម្ចាស់ថាក៏ត្រូវ តែកាលព្រះពុទ្ធមិនមានកើតឡើង ខ្ញុំបានធ្វើកល្យាណកម្ម កាលព្រះពុទ្ធកើតឡើងកំពុងប្រព្រឹត្តទៅ ទេវបុត្រមានសក្តិស្មើគ្នា ៣ អង្គ គឺចូឡរថទេវបុត្រ មហារថទេវបុត្រ អនេកវណ្ណទេវបុត្រ ធ្វើកល្យាណកម្មហើយ បានកើតក្នុងទីជិតខ្ញុំ មានតេជៈច្រើនជាងខ្ញុំ កាលទេវបុត្រ ៣ អង្គនោះ នាំពួកបារិចារិកាចុះកាន់ផ្លូវ ដោយគិតថា នឹងលេងនក្ខត្តឫក្ស ខ្ញុំត្រូវគេចចូលទៅកាន់ដំណាក់ ព្រោះតេជៈចេញអំពីសរីរៈរបស់ទេវបុត្រទាំង ៣ នោះ គ្របសង្កត់សរីរៈរបស់ខ្ញុំ តេជៈអំពីសរីរៈរបស់ខ្ញុំមិនគ្របសង្កត់សរីរៈរបស់ទេវបុត្រទាំង ៣ នោះ អ្នកណាក្រជាងខ្ញុំហ្ន៎ ព្រះថេរៈពោលថា អើ បើយ៉ាងនោះ តាំងអំពីថ្ងៃនេះទៅ សូមទ្រង់កុំបោកបញ្ឆោតឲ្យទានដល់អាត្មាយ៉ាងនេះ ។ សក្កទេវរាជត្រាស់ថា បើខ្ញុំបោកបញ្ឆោតលោកម្ចាស់ថ្វាយទាន កុសលនឹងមានដល់ខ្ញុំដែរទេ ព្រះថេរៈត្រាស់ថា មាន សក្កទេវរាជត្រាស់ថា បើយ៉ាងនោះ ការធ្វើកុសលកម្ម ចាត់ជាកិច្ចរបស់ខ្ញុំចុះ ។

សក្កទេវរាជត្រាស់យ៉ាងនោះហើយ ទ្រង់ថ្វាយបង្គំព្រះថេរៈ នាំនាងសុជាតា ធ្វើប្រទក្សិណព្រះថេរៈហើយ ហោះទៅកាន់អាកាស ទ្រង់បន្លឺឧទានថា ឱទាន ដែលខ្ញុំឲ្យហើយជាទានដ៏កំពូល ខ្ញុំបានធ្វើល្អហើយក្នុងព្រះកស្សបៈ ។

ព្រោះហេតុនោះ ទើបព្រះធម្មសង្គាហកាចារ្យពោលថា សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះមហាកស្សបៈដ៏មានអាយុ នៅក្នុងបិប្ផលិ-គុហា អង្គុយដោយភ្នែនតែមួយ ចូលសមាធិណាមួយអស់ ៧ ថ្ងៃ លុះកន្លង ៧ ថ្ងៃនោះហើយ ព្រះមហាកស្សបៈដ៏មានអាយុ ក៏ចេញអំពីសមាធិនោះ ។ កាលដែលព្រះមហាកស្សបៈដ៏មានអាយុ ចេញអំពីសមាធិនោះហើយ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញចូលទៅបិណ្ឌបាតឯក្រុងរាជគ្រឹះចុះ ។ សម័យនោះឯង ពួកទេវតាចំនួន ៥០០ អង្គ ដល់នូវការខ្វល់ខ្វាយ ដើម្បីប្រគេនបិណ្ឌបាតចំពោះព្រះមហាកស្សបៈដ៏មានអាយុ ។ គ្រានោះ ព្រះមហាកស្សបៈដ៏មានអាយុ ហាមឃាត់ពួកទេវតាទាំង ៥០០ អង្គនោះហើយ ស្លៀកស្បង់ ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅបិណ្ឌបាតឯក្រុងរាជគ្រឹះ ។

សម័យនោះឯង សក្កៈជាធំជាងពួកទេវតា មានប្រាថ្នាដើម្បីប្រគេនបិណ្ឌបាត ចំពោះព្រះមហាកស្សបៈដ៏មានអាយុ បាននិម្មិតភេទខ្លួនជាជាងតម្បាញ កំពុងត្បាញនូវតម្បាញ ។ ឯអសុរកញ្ញាឈ្មោះសុជាតា ក៏ការអម្បោះឲ្យពេញខ្នារ ។ គ្រានោះ ព្រះមហាកស្សបៈដ៏មានអាយុ កំពុងត្រាច់បិណ្ឌបាតសព្វប្រេក ក្នុងក្រុងរាជគ្រឹះ បានចូលទៅកាន់លំនៅរបស់ទេវរាជឈ្មោះសក្កៈ ជាធំជាងពួកទេវតា ។ សក្កៈជាធំជាងពួកទេវតា បានឃើញព្រះមហាកស្សបៈដ៏មានអាយុ កំពុងតែនិមន្តមកអំពីចម្ងាយ លុះបានឃើញ

ហើយ ក៏ចេញអំពីផ្ទះ ទៅទទួលយកបាត្រអំពីព្រះហស្ត ចូលទៅកាន់ផ្ទះ ដួសបាយអំពីឆ្នាំង ដាក់ឲ្យពេញបាត្រ រួចប្រគេនចំពោះព្រះមហាកស្សបៈដ៏មានអាយុ ។ បិណ្ឌបាតនោះ មានសម្លច្រើនមុខ មានម្ហូបក្រៀមច្រើនមុខ ។ លំដាប់នោះ ព្រះមហាកស្សបៈដ៏មានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា សត្វនេះជាអ្វីហ្ន៎ បានជាមានឥទ្ធានុភាព មានសភាពយ៉ាងនេះ ។ លំដាប់នោះ ព្រះមហាកស្សបៈដ៏មានអាយុ មានសេចក្តីត្រិះរិះដូច្នេះទៀតថា ឱហ្ន៎ សក្កៈជាធំជាងពួកទេវតាទេតើ ។ លុះព្រះមហាកស្សបៈដ៏មានអាយុ បានដឹងច្បាស់ដូច្នេះហើយ និយាយនឹងសក្កៈជាធំជាងទេវតាថា បពិត្រកោសិយៈ ព្រះអង្គបានធ្វើអំពើនេះហើយ ក្រោយទៅ ព្រះអង្គកុំធ្វើអំពើយ៉ាងនេះទៀតឡើយ ។ បពិត្រព្រះកស្សបៈដ៏ចម្រើន យើងខ្ញុំក៏មានសេចក្តីត្រូវការដោយបុណ្យដែរ យើងខ្ញុំគួរធ្វើបុណ្យបានដែរ ។ លំដាប់នោះ សក្កៈជាធំជាងពួកទេវតា ថ្វាយបង្គំព្រះមហាកស្សបៈដ៏មានអាយុ រួចធ្វើប្រទក្សិណ ហើយហោះទៅឯអាកាស បន្លឺនូវឧទាន ក្នុងអាកាសជាទីវាលអស់វារៈ ៣ ដងថា

ឱហ្ន៎ ទានដែលអាត្មាអញបានតម្កល់ទុកល្អហើយ ក្នុងព្រះ
មហាកស្សបៈ ហៅពេញជាទានឧត្តម ឱហ្ន៎ ទានដែល
អាត្មាអញ បានតម្កល់ទុកល្អហើយ ក្នុងព្រះមហាកស្សបៈ
ហៅពេញជាទានឧត្តម ។

ព្រះមានព្រះភាគ ទ្រង់បានឮឧទានដោយទិព្វសោតធាតុដ៏បរិសុទ្ធ កន្លងបង់សោតធាតុរបស់មនុស្សធម្មតា ដែលសក្កៈជាធំជាងពួកទេវតា កំពុង

ហោះទៅកាន់វេហាស៍ ហើយបន្លឺអស់វារៈ ៣ ដង ក្នុងអាកាសជាទីវាលថា

ឱហ្ន៎ ទានដែលអាត្មាអញបានតម្កល់ទុកល្អហើយ ក្នុងព្រះមហាកស្សប ហៅពេញជាទានដ៏ឧត្តម ឱហ្ន៎ ទានដែលអាត្មាអញបានតម្កល់ទុកល្អហើយ ក្នុងព្រះមហាកស្សបៈ ហៅពេញជាទានដ៏ឧត្តម ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា

ទេវតាទាំងឡាយ រមែងស្រឡាញ់ភិក្ខុ អ្នកប្រព្រឹត្តបិណ្ឌបាតជាវត្ត អ្នកចិញ្ចឹមតែខ្លួន មិនចិញ្ចឹមបុគ្គលដទៃ ជាអ្នកនឹងធឹង ស្ងប់រម្ងាប់ មានស្មារតីគ្រប់កាល[១] ។

១- ឋ. ៥២ ទំ. ១៣៨ ។

កាលទ្រង់បន្លឺឧទាននេះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សក្កទេវរាជជាស្តេចនៃទេវតា បានយាងមកប្រគេនបិណ្ឌបាតដល់បុត្ររបស់តថាគត ព្រោះក្លិននៃសីល ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**អប្បមត្តោ អយំ គន្ធោ យ្វាយំ តគរចន្ទនី**
**យោ ច សីលវតំ គន្ធោ វាតិ ទេវេសុ ឧត្តមោ ។**

ក្លិនក្រស្នា និងក្លិនចន្ទន៍ណា ក្លិននេះក្រអូបមានប្រមាណតិចទេ ចំណែកក្លិននៃបុគ្គលមានសីលទាំងឡាយណា ទើបក្លិននោះក្រអូបលើសលប់ផ្សាយទៅក្នុងទេវលោក និងមនុស្សលោកបាន ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អប្បមត្តោ** គឺមានប្រមាណតិចតួច ។ ពីរបទថា **យោ ច សីលវតំ** សេចក្តីថា ចំណែកក្លិនសីលរបស់អ្នកមានសីលទាំងឡាយណា ក្លិនសីលនោះមិនមែនជាក្លិនតិចតួច ដូចក្លិនក្រស្នា និងក្លិនចន្ទន៍ក្រហមឡើយ គឺជាក្លិនដ៏ឧឡារ ផ្សាយទៅក្រៃលែង ដោយហេតុនោះឯង ក្លិនសីល ទើបជាក្លិនដ៏ឧត្តម គឺប្រសើរលើសលប់ ផ្សាយទៅក្នុងពួកទេវតា និងពួកមនុស្ស គឺផ្សាយទៅក្នុងពួកទេវតា និងពួកមនុស្ស បានដល់ក្រអូបទូទៅនោះឯង ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយមានសោតាបត្តិផលជាដើម ។ ទេសនាមានប្រយោជន៍ ដល់មហាជនហើយ ដូច្នេះឯង ៕៚

**រឿង ប្រគេនបិណ្ឌបាតដល់ព្រះមហាកស្សបត្ថេរ ចប់**

# រឿង ព្រះគោធិកត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលទ្រង់ចូលទៅអាស្រ័យក្រុងរាជគ្រឹះ គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធបរិនិព្វានរបស់ព្រះគោធិកត្ថេរ ត្រាស់ធម្មទេសនានេះថា **តេសំ សម្បន្នសីលានំ** ជាដើម ។

សេចក្ដីពិស្ដារថា លោកដ៏មានអាយុអង្គនោះ នៅជិតគុហាកាឡសិលា ក្បែរភ្នំឥសិគិលិ ជាអ្នកមិនប្រមាទ មានសេចក្ដីព្យាយាម មានខ្លួនបញ្ជូនទៅហើយ ពាល់ត្រូវនូវចេតោវិមុត្តិ ដែលកើតឡើងក្នុងសម័យ គឺកើតម្ដងម្កាល វិនាសចាកចេតោវិមុត្តិនោះ ដោយអំណាចអាពាធណាមួយ ដែលរើឡើង ។ លោកញ៉ាំងឈានទី ២ ខ្វះ ទី ៣ ខ្វះឲ្យកើតឡើងដល់ទៅ ៦ ដង ហើយក៏វិនាស ក្នុងគ្រាទី ៧ ឲ្យកើតឡើងហើយក៏គិតថា អញវិនាសចាកឈានដល់ទៅ ៦ ដង គតិរបស់បុគ្គលមានឈានសាបសូន្យហើយ មិនពិតប្រាកដ ពេលនេះ អញនឹងនាំសស្ត្រាមក ដូច្នេះហើយ ទើបកាន់កាំបិតសម្រាប់កោរសក់ សិងលើគ្រែតូចដើម្បីអារបំពង់កហើយ ។

មារដឹងចិត្តរបស់លោកហើយគិតថា ភិក្ខុនេះប្រាថ្នានឹងនាំសស្ត្រាមក ឯភិក្ខុទាំងឡាយកាលនាំសស្ត្រាមក រមែងជាអ្នកអស់អាល័យក្នុងជីវិត ភិក្ខុទាំងនោះផ្ដើមតាំងវិបស្សនាហើយ រមែងសម្រេចអរហត្តបាន បើអញឃាត់ភិក្ខុនោះ លោកមិនធ្វើតាមពាក្យរបស់អញ អញនឹងទូលព្រះសាស្ដាឲ្យឃាត់ ដូច្នេះហើយ ទើបចូលទៅគាល់ព្រះសាស្ដា ដោយភេទដែលអ្នកដទៃមិនស្គាល់ ក្រាបទូលថា

បពិត្រព្រះអង្គ អ្នកមានព្យាយាមធំ មានប្រាជ្ញាច្រើន
រុងរឿងដោយឫទ្ធិ និងយស កន្លងបង់នូវពៀរ និងភ័យ
គ្រប់ប្រការ ទ្រង់មានចក្ខុ ខ្ញុំព្រះអង្គសូមក្រាបថ្វាយបង្គំ
ព្រះបាទា បពិត្រព្រះអង្គ អ្នកមានព្យាយាមធំ សាវក
របស់ព្រះអង្គ ត្រូវសេចក្ដីស្លាប់គ្របសង្កត់ ប្រាថ្នាគិត

នូវសេចក្ដីស្លាប់ បពិត្រព្រះអង្គ អ្នកទ្រទ្រង់នូវអានុភាព
សូមព្រះអង្គ ឃាត់នូវសាវ័កនោះ បពិត្រព្រះមាន
ព្រះភាគ អ្នកល្បីក្នុងប្រជុំជន សាវ័ករបស់ព្រះអង្គ ជា
សេក្ខបុគ្គល មានបំណងមិនទាន់សម្រេច នៅត្រេកអរ
ក្នុងសាសនា គប្បីធ្វើមរណកាល ដូចម្ដេចបាន ។

ក្នុងខណៈនោះ ព្រះថេរៈនាំសស្ត្រាមកហើយ ។ ព្រះសាស្ដាទ្រង់ជ្រាបថា បុគ្គលនេះជាមារ ទើបត្រាស់គាថានេះថា

ពិតមែន អ្នកប្រាជ្ញទាំងឡាយ តែងធ្វើយ៉ាងនេះឯង
រមែងមិនទឹកស្ដាយនូវជីវិត គោធិកភិក្ខុ បានដកតណ្ហា
ព្រមទាំងឫស បរិនិព្វានហើយ ។

គ្រានោះឯង ព្រះដ៏មានព្រះភាគបានយាងទៅកាន់ទីដែលព្រះថេរៈនាំសស្ត្រាមក សិងហើយ មួយអន្លើដោយភិក្ខុដ៏ច្រើន ។ ខណៈនោះ មារមានចិត្តបាបគិតថា បដិសន្ធិវិញ្ញាណរបស់ព្រះគោធិកៈនេះ តាំងនៅហើយក្នុងទីណាហ្ន៎ ដូច្នេះហើយ ធ្វើជាដុំផ្សែង និងដុំពពក ស្វែងរកវិញ្ញាណរបស់ព្រះថេរៈក្នុងទិសទាំងពួង ព្រះដ៏មានព្រះភាគទ្រង់បង្ហាញភាពដែលមារនោះធ្វើជាផ្សែង និងដុំពពកនោះ ដល់ភិក្ខុទាំងឡាយហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មារមានចិត្តបាបនោះឯង ស្វែងរកវិញ្ញាណរបស់គោធិកកុលបុត្រ ដោយគិតថា វិញ្ញាណរបស់កុលបុត្រឈ្មោះគោធិកៈតាំងនៅហើយក្នុងទីណា ម្នាលភិក្ខុទាំងឡាយ គោធិកកុលបុត្រមានវិញ្ញាណមិនតាំងនៅឡើយ បរិនិព្វានហើយ មារ កាលមិនអាច

ឃើញទីតាំងនៃវិញ្ញាណរបស់ព្រះគោធិកៈនេះបាន ទើបកាឡាខ្លួនជាកុមារកាន់ពិណាមានពណ៌លឿងដូចផ្លែព្នៅ ចូលទៅគាល់ព្រះសាស្តា ទូលសួរថា

ខ្ញុំព្រះអង្គបានស្វែងរក ( វិញ្ញាណ ) របស់គោធិក-
កុលបុត្ត ក្នុងទិសខាងលើផង ខាងក្រោមផង ទិស
ទទឹងផង ទិសធំ ទិសតូចផង មិនបានជួបប្រទះសោះ
ឡើយ ចុះគោធិកៈនោះ ទៅក្នុងទីណា ។

គ្រានោះ ព្រះសាស្តា ត្រាស់នឹងមារនោះថា

គោធិកភិក្ខុ ជាអ្នកប្រាជ្ញ បរិបូណ៌ដោយប្រាជ្ញា ជាអ្នក
មានឈាន អ្នកត្រេកអរក្នុងឈានសព្វកាល ខំប្រឹង
ប្រែងទាំងថ្ងៃ ទាំងយប់ មិនគិតស្តាយជីវិត បានឈ្នះ
សេនារបស់មច្ចុ មិនមកកាន់ភពថ្មីទៀត ដកតណ្ហា
ព្រមទាំងឫស បរិនិព្វានហើយ ។

កាលព្រះសាស្តាត្រាស់យ៉ាងនោះហើយ ពិណាបានភ្លាត់ធ្លាក់អំពីក្លៀករបស់មារនោះ ជាអ្នកដែលសេចក្តីសោកគ្របសង្កត់ លំដាប់នោះ យក្ខនោះអាក់អន់ចិត្ត ក៏អន្តរធានទៅក្នុងទីនោះឯង ដោយប្រការដូច្នេះ ។

ព្រះសាស្តាត្រាស់ថា មារមានចិត្តបាប អ្នកត្រូវការអ្វីដោយទីកន្លែងដែលកុលបុត្រឈ្មោះគោធិកៈកើតហើយ ព្រោះបុគ្គលដូចអ្នករាប់រយរាប់ពាន់ ក៏មិនអាចឃើញទីដែលគោធិកៈនោះកើត ដូច្នេះហើយ បានត្រាស់ព្រះគាថានេះថា

**តេសំ សម្បន្នសីលានំ អប្បមាទវិហារិនំ**
**សម្មទញ្ញា វិមុត្តានំ មារោ មគ្គំ ន វិន្ទតិ ។**

*មារពិរាជ ( ទុកជាខំស្វែងរក ) ក៏មិនជួបនូវផ្លូវរបស់ លោកអ្នកមានសីលបរិបូណ៌ អ្នកនៅដោយសេចក្តីមិន ប្រមាទ អ្នករួចស្រឡះ ( ចាកធម៌ជាគ្រឿងសៅហ្មង ) ព្រោះដឹងច្បាស់តាមហេតុ ។*

# សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ បទថា* **តេសំ** *គឺនៃបុគ្គលដែលបរិនិព្វាន ដូច កុលបុត្រឈ្មោះគោធិកៈ មានវិញ្ញាណមិនតាំងនៅ បរិនិព្វានហើយដូច្នោះ ។*

*បទថា* **សម្បន្នសីលានំ** *គឺមានសីលបរិបូណ៌ហើយ ។ បទថា* **អប្ប-មាទវិហារិនំ** *គឺជាអ្នកនៅដោយសេចក្តីមិនប្រមាទ ពោលគឺការមិននៅប្រាស ចាកសតិ ។*

*បាទព្រះគាថាថា* **សម្មទញ្ញា វិមុត្តានំ** *សេចក្តីថា ជាអ្នករួចផុតវិសេស ហើយដោយវិមុត្តិទាំង ៥ នេះ គឺតទង្គវិមុត្តិ វិក្ខម្ភនវិមុត្តិ សមុច្ឆេទវិមុត្តិ បដិបស្សទ្ធិវិមុត្តិ និស្សរណវិមុត្តិ ព្រោះដឹងនូវហេតុ គឺដោយន័យ ដោយហេតុ ។*

*បាទព្រះគាថាថា* **មារោ មគ្គំ ន វិន្ទតិ** *សេចក្តីថា មារសូម្បីស្វែងរកឲ្យ ពេញទំហឹង រមែងមិនជួប គឺរមែងមិនបានចំពោះ បានដល់ រមែងមិនឃើញ ផ្លូវនៃព្រះវិញ្ញាណស្រពទាំងឡាយបែបនេះទៅហើយ ។*

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមហើយ ។ ទេសនាមានប្រយោជន៍ ដល់មហាជនដូច្នេះឯង ។ល។

**រឿង បរិនិព្វានរបស់ព្រះគោធិកត្ថេរ ចប់**

# រឿង គរហទិន្ន

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសាវ័ករបស់និគ្រន្ថឈ្មោះគរហទិន្ន ត្រាស់ព្រះធម្មទេសនានេះថា **យថា សង្ការធានស្មឹ** ជាដើម ។

សេចក្តីពិស្តារថា ក្នុងក្រុងសាវត្ថីមានជនពីរនាក់ ជាសម្លាញ់នឹងគ្នា គឺ សិរិគុត្ត ១ គរហទិន្ន ១ ។ ក្នុងជនពីរនាក់នោះ សិរិគុត្តជាឧបាសក គរហទិន្នជាសាវ័ករបស់និគ្រន្ថ ។ ពួកនិគ្រន្ថរមែងពោលនឹងគរហទិន្ននោះរឿយៗ យ៉ាងនេះថា ការដែលអ្នកនិយាយនឹងសិរិគុត្តសម្លាញ់របស់អ្នកថា ឯងចូលទៅរកព្រះសមណគោតមធ្វើអ្វី ឯងនឹងបានអ្វី ក្នុងសម្នាក់របស់ព្រះសមណគោតមនោះ ដូច្នេះហើយ ពោលប្រៀនប្រដៅដោយអាការដែលសិរិគុត្តចូលមករកពួកយើង ហើយនឹងឲ្យទេយ្យធម៌ដល់ពួកយើង មិនគួរឬ គហរទិន្នស្តាប់ពាក្យរបស់និគ្រន្ថទាំងនោះហើយ ក៏ព្យាយាមទៅពោលជាមួយសិរិគុត្តក្នុងទីដែលសិរិគុត្តឈរ និងអង្គុយហើយជាដើម យ៉ាងនេះថា នែសម្លាញ់ ប្រយោជន៍អ្វី

របស់អ្នកដោយព្រះសមណគោតមនោះ អ្នកទៅរកព្រះសមណគោតមនោះ នឹងបានអ្វី ការដែលអ្នកចូលទៅរកលោកម្ចាស់របស់យើងហើយ ឲ្យទានដល់លោកម្ចាស់ទាំងនោះ មិនគួរឬ សិរិគុត្តស្តាប់ពាក្យរបស់គរហទិន្ន ក៏អង្គុយស្ងៀម អស់ច្រើនថ្ងៃ សម្រាកសម្រាន្តហើយ ថ្ងៃមួយ ទើបពោលថា នែសម្លាញ់ អ្នកព្យាយាមមកពោលជាមួយខ្ញុំ ក្នុងទីដែលឈរហើយជាដើម យ៉ាងនេះថា អ្នកទៅរកព្រះសមណគោតមហើយ នឹងបានអ្វី អ្នកចូលទៅរកលោកម្ចាស់របស់យើង ថ្វាយទានដល់លោកម្ចាស់ទាំងនោះ អ្នកចូរប្រាប់ដល់ខ្ញុំសិន លោកម្ចាស់ទាំងឡាយរបស់អ្នកដឹងអ្វីខ្លះ ។

គរហទិន្នពោលថា ឱសម្លាញ់ អ្នកកុំពោលយ៉ាងនេះ ឈ្មោះថា វត្ថុដែលលោកម្ចាស់ទាំងឡាយរបស់យើងមិនដឹងមិនមាន លោកម្ចាស់ទាំងឡាយរមែងដឹងហេតុជាអតីត អនាគត និងបច្ចុប្បន្នទាំងអស់ កាយកម្ម វចីកម្ម មនោកម្មទាំងអស់ រមែងដឹងហេតុដែលគួរ និងមិនគួរទាំងអស់ ហេតុនេះនឹងមាន ហេតុនេះនឹងមិនមាន ។ សិរិគុត្តពោលថា អ្នកនិយាយថា លោកម្ចាស់របស់អ្នក រមែងដឹងដូច្នេះ មិនមែនឬ ។ គរហទិន្នពោលថា ខ្ញុំនិយាយយ៉ាងនោះឯង ។ សិរិគុត្តពោលថា បើយ៉ាងនោះ អ្នកមិនប្រាប់សេចក្តីនោះដល់ខ្ញុំអស់កាលមានប្រមាណប៉ុណ្ណេះ ឈ្មោះថា ធ្វើកម្មធ្ងន់ហើយ ថ្ងៃនេះ ខ្ញុំនឹងដឹងអានុភាពនៃញាណរបស់លោកម្ចាស់ទាំងឡាយហើយ នែសម្លាញ់ អ្នកចូរទៅចុះ ហើយនិមន្តលោកម្ចាស់ទាំងឡាយតាមពាក្យរបស់ខ្ញុំ ។

គរហទិន្ននោះ ចូលទៅកាន់សម្នាក់របស់ពួកនិគ្រន្ថ ថ្វាយបង្គំនិគ្រន្ថទាំង

នោះហើយពោលថា សិរិគុត្តសម្លាញ់របស់ខ្ញុំនិមន្តលោកម្ចាស់ឆាន់ក្នុងថ្ងៃស្អែក និគ្រន្ថពោលថា សិរិគុត្តពោលនឹងអ្នកខ្លួនឯងឬ គរហទិន្នពោលថា យ៉ាងនោះឯងលោកម្ចាស់ ។ និគ្រន្ថទាំងនោះត្រេកអរហើយពោលថា កិច្ចរបស់ពួកយើងសម្រេចហើយ ចាប់តាំងអំពីកាលដែលសិរិគុត្តជ្រះថ្លាក្នុងពួកយើងហើយ សម្បត្តិណាមួយ នឹងមានដល់ពួកយើង លំនៅរបស់សិរិគុត្តក៏ធំ ។

សិរិគុត្តនោះ ប្រើមនុស្សឲ្យជីករណ្ដៅវែងសងខាង ក្នុងរវាងផ្ទះពីរខ្នងនោះហើយ ក៏ឲ្យយកលាមកកាវដាក់រហូតពេញ ប្រើបង្គោលបោះក្នុងទីបំផុតសងខាង ខាងក្រៅរណ្ដៅ ឲ្យចងខ្សែត្រង់បង្គោលទាំងនោះ ឲ្យដាក់ជើងមុខរបស់អាសនៈទាំងឡាយលើមាត់រណ្ដៅ ជើងក្រោយត្រង់ខ្សែ សម្គាល់ថា ក្នុងកាលដែលអង្គុយហើយយ៉ាងនេះឯង ពួកនិគ្រន្ថនឹងមានក្បាលដាំចុះ ឲ្យមនុស្សក្រាលកម្រាលលើអាសនៈទាំងឡាយ ដោយអាការដែលរណ្ដៅមិនប្រាកដ ឲ្យមនុស្សលាងពាងធំៗ ហើយ ចងមាត់ដោយស្លឹកចេក និងសំពត់ចាស់ធ្វើពាងទទេនោះឯង ឲ្យលាបដោយគ្រប់បបរ គ្រប់បាយ សប្បិ ទឹកអំពៅ និងនំខាងក្រៅហើយ ឲ្យតាំងទុកខាងក្រោយផ្ទះ ។

គរហទិន្នប្រញាប់ទៅផ្ទះរបស់សិរិគុត្តនោះអំពីព្រលឹម សួរថា អ្នកចាត់ចែងសក្ការៈដើម្បីលោកម្ចាស់ទាំងឡាយហើយឬ សិរិគុត្តពោលថា អើសម្លាញ់ ខ្ញុំរៀបចំហើយ គរហទិន្នពោលថា សក្ការៈនោះនៅឯណា សិរិគុត្តពោលថា បបរនៅក្នុងពាងទាំងឡាយនោះប្រមាណប៉ុណ្ណេះ បាយក្នុងពាងប្រមាណប៉ុណ្ណេះ សប្បិ ទឹកអំពៅ នំជាដើមក្នុងពាងប្រមាណប៉ុណ្ណេះ អាសនៈក្រាលហើយ ។

គរហទិន្នទោះពោលថា សាធុ ហើយក៏ទៅ ។ ក្នុងវេលាដែលគរហទិន្ន ទោះទៅហើយ ពួកនិគ្រន្ថប្រមាណ ៥០០ ក៏មក ។ សិរិគុត្តចេញអំពីផ្ទះថ្វាយបង្គំពួកនិគ្រន្ថដោយបញ្ចង្គប្រតិស្ឋានហើយ ឈរផ្គងអញ្ជលីខាងមុខនៃពួកនិគ្រន្ថទាំងនោះ គិតថា បានឮថា លោកម្ចាស់ទាំងឡាយ រមែងដឹងហេតុសព្វយ៉ាង មានហេតុជាអតីតជាដើម ឧបដ្ឋាករបស់ពួកលោកម្ចាស់ ប្រាប់ដល់ខ្ញុំហើយយ៉ាងនេះ បើលោកម្ចាស់ទាំងឡាយដឹងហេតុទាំងអស់ ពួកលោកម្ចាស់កុំចូលទៅកាន់ផ្ទះរបស់ខ្ញុំ ព្រោះកាលលោកម្ចាស់ចូលទៅកាន់ផ្ទះរបស់ខ្ញុំហើយ បបរមិនមានឡើយ បាយជាដើមក៏មិនមាន បើលោកម្ចាស់មិនដឹង ក៏សូមចូលទៅ ខ្ញុំឲ្យលោកម្ចាស់ទាំងឡាយធ្លាក់ក្នុងរណ្តៅលាមក ហើយនឹងឲ្យវាយ កាលគិតយ៉ាងនោះហើយ ទើបឲ្យសញ្ញាដល់ពួកបុរសថា ពួកអ្នកចូរដឹងការៈគឺការអង្គុយរបស់និគ្រន្ថទាំងនោះហើយ ឈរនៅខាងក្រោយ គប្បីទាំគ្រឿងកម្រាលខាងលើនៃអាសនៈទាំងឡាយចេញហើយ អាសនៈទាំងនោះកុំប្រឡាក់ដោយរបស់មិនស្អាតឡើយ ។ កាលនោះ សិរិគុត្តនិយាយនឹងពួកនិគ្រន្ថថា និមន្តមកខាងនេះចុះលោកម្ចាស់ ពួកនិគ្រន្ថចូលទៅហើយ ក៏ប្រារព្ធដើម្បីអង្គុយលើអាសនៈដែលគេក្រាលហើយ ។ ពេលនោះ មនុស្សទាំងឡាយពោលនឹងនិគ្រន្ថទាំងនោះថា ចូរបង្អង់សិន កុំទាន់អង្គុយលោកម្ចាស់ និគ្រន្ថសួរថា ព្រោះហេតុអ្វី មនុស្សទាំងឡាយពោលថា ការដែលលោកម្ចាស់ទាំងឡាយ ចូលទៅកាន់ផ្ទះរបស់ពួកខ្ញុំ ដឹងទំនៀមហើយ សឹមអង្គុយ រមែងសមគួរ ។ និគ្រន្ថពោលថា ធ្វើដូចម្តេច ទើបសមគួរ មនុស្សទាំងឡាយ

ពោលថា ការដែលលោកម្ចាស់ទាំងឡាយ ឈរក្បែរអាសនៈ រៀងៗ ខ្លួន ហើយអង្គុយព្រមគ្នានោះឯង ទើបគួរ ។

បានឮថា សិរិគុត្តនោះឲ្យធ្វើពិធីនេះដោយគិតថា បើនិគ្រន្ថម្នាក់ធ្លាក់ក្នុងរណ្ដៅហើយ និគ្រន្ថដ៏សេសមិនអង្គុយ ។ និគ្រន្ថទាំងនោះពោលថា ល្អហើយ គិតថា ការដែលពួកយើងធ្វើតាមពាក្យរបស់មនុស្សទាំងនេះ ប្រាប់ហើយ គួរ ។

កាលនោះ និគ្រន្ថទាំងអស់បានឈរនៅក្បែរអាសនៈ ដែលត្រូវបានហើយដល់ខ្លួនដោយលំដាប់ ។ លំដាប់នោះ ពួកមនុស្សពោលនឹងនិគ្រន្ថទាំងនោះថា សូមលោកម្ចាស់ប្រញាប់អង្គុយព្រមគ្នានោះឯង ដឹងការៈ គឺការអង្គុយរបស់និគ្រន្ថទាំងនោះហើយ ទើបនាំគ្រឿងកម្រាលលើអាសនៈទាំងឡាយចេញ ។ ពួកនិគ្រន្ថអង្គុយព្រមគ្នានោះឯង ជើងអាសនៈដែលតាំងនៅលើខ្សែ ក្ដាត់ធ្លាក់ហើយ ពួកនិគ្រន្ថមានក្បាលជាំចុះទៅក្នុងរណ្ដៅ ។ សិរិគុត្តកាលពួកនិគ្រន្ថនោះធ្លាក់ហើយ ទើបបិទទ្វារឲ្យយកដំបងវាយពួកនិគ្រន្ថ ដែលប្រវាឡើងហើយ ដោយពោលថា ពួកលោកម្ចាស់មិនដឹងហេតុដែលជាអតីត អនាគត និងបច្ចុប្បន្ន ព្រោះហេតុអ្វី ហើយប្រាប់ថា ការធ្វើប៉ុណ្ណោះនឹងសមគួរដល់ពួកនិគ្រន្ថទាំងនោះ ដូច្នេះហើយ ទើបបើកទ្វារ ។ ពួកនិគ្រន្ថទាំងនោះចេញហើយ ប្រារព្ធដើម្បីគេចទៅ ឯក្នុងផ្លូវទៅនៃពួកនិគ្រន្ថទាំងនោះ សិរិគុត្តឲ្យមនុស្សធ្វើផែនដី បរិកម្មដោយបាយ-អទុកឲ្យរអិល សិរិគុត្តឲ្យវាយពួកនិគ្រន្ថនោះ ដែលឈរក្នុងទីនោះឲ្យដួលចុះហើយ ទើបបញ្ជូនទៅដោយពាក្យថា ការធ្វើប៉ុណ្ណោះសមគួរដល់លោកម្ចាស់ទាំងឡាយ ។ និគ្រន្ថទាំងនោះកន្ទក់កន្ទេញថា ពួកយើងត្រូវ

អ្នក ធ្វើឲ្យវិនាស ពួកយើង ត្រូវអ្នកធ្វើឲ្យវិនាស បានទៅកាន់ទ្វារផ្ទះរបស់ឧបដ្ឋាកហើយ ។

គរហទិន្នឃើញប្រការចម្លែកនោះ របស់និគ្រន្ថទាំងនោះហើយ ក្រោធគិតថា អញត្រូវសិរិគុត្តឲ្យវិនាសហើយ វាឲ្យវាយលោកម្ចាស់ទាំងឡាយរបស់អញ ដែលជាបុញ្ញក្ខេត្ត ដែលបានឈ្មោះថាអាចឲ្យនូវទេវលោកទាំង ៦ ដល់មនុស្សទាំងឡាយ ដែលបុគ្គលលាដៃចេញថ្វាយបង្គំតាមគាប់ចិត្ត ឲ្យដល់នូវសេចក្តីវិនាសហើយ ទៅកាន់រាជត្រកូលក្រាបទូលឲ្យព្រះរាជា ទ្រង់ធ្វើពិន័យដល់សិរិគុត្តនោះ ១ ពាន់កហាបណៈ ។ គ្រានោះ ព្រះរាជាទ្រង់ព្រះបញ្ជូនសាសន៍ទៅដល់សិរិគុត្តនោះ ។ សិរិគុត្តនោះ ទៅថ្វាយបង្គំព្រះរាជា ហើយក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់សាកសួរហើយ សឹមកាត់សេចក្តី បើទ្រង់មិនបានសាកសួរ កុំកាត់សេចក្តីឡើយ ព្រះរាជាត្រាស់ថា យើងសាកសួរមើលហើយ ទើបកាត់សេចក្តី សិរិគុត្តពោលថា សាធុ ព្រះអង្គ បើដូច្នោះសូមទ្រង់កាត់សេចក្តីចុះ ព្រះរាជាត្រាស់ថា បើដូច្នោះ អ្នកចូរនិយាយចុះ ។ សិរិគុត្តក្រាបទូលការប្រព្រឹត្តទៅនោះទាំងអស់ តាំងអំពីដើម យ៉ាងនេះថា បពិត្រព្រះអង្គ សម្លាញ់របស់ទូលបង្គំ ជាសាវ័ករបស់និគ្រន្ថ ចូលទៅរកខ្ញុំព្រះអង្គហើយ ពោលយ៉ាងនេះរឿយៗ ក្នុងទីឈរ និងទីអង្គុយជាដើមថា នែសម្លាញ់ ប្រយោជន៍អ្វីរបស់អ្នក ដោយព្រះសមណគោតមនោះ អ្នកទៅរកព្រះសមណគោតមនោះនឹងបានអ្វី ដូច្នេះហើយ ក្រាបទូលថា បពិត្រព្រះអង្គ បើការពិន័យព្រោះហេតុនេះគួរហើយ សូមទ្រង់កាត់សេចក្តីចុះ ព្រះរាជា ទត

គរហទិន្ន ត្រាស់ថា បានឮថា អ្នកពោលយ៉ាងនោះពិតឬ គរហទិន្នពោលថា ពិតហើយ ក្រាបទូល ព្រះរាជាត្រាស់ថា អ្នកសេពគប់ពួកនិគ្រន្ថ ដែលមិនដឹងហេតុប៉ុណ្ណេះត្រាច់ទៅ ដោយគិតថា ជាគ្រូ ប្រាប់ដល់សាវករបស់ព្រះតថាគតថា រមែងដឹងសព្វយ៉ាង ព្រោះហេតុអ្វី ពិន័យដែលអ្នកលើកឡើង ចូរមានដល់អ្នកចុះ ។

គរហទិន្ននោះ ត្រូវព្រះរាជាទ្រង់ពិន័យហើយ ដោយអាការយ៉ាងនេះ ពួកនិគ្រន្ថដែលចូលដល់ត្រកូលរបស់គរហទិន្ននោះឯង ត្រូវសិរិគុត្តវាយបណ្តេញចេញហើយ ។

គហរទិន្ន ខឹងនឹងសិរិគុត្តនោះហើយ មិននិយាយជាមួយអស់កាលប្រមាណកន្លះខែ គិតថា ការត្រាច់ទៅដោយអាការយ៉ាងនេះ មិនគួរដល់អញ កាលដែលអញធ្វើសេចក្តីវិនាសដល់ពួកភិក្ខុ ដែលចូលដល់ត្រកូលរបស់សិរិគុត្តនោះ រមែងគួរ ដូច្នេះហើយ ចូលទៅរកសិរិគុត្តពោលថា នែសិរិគុត្តសម្លាញ់ សិរិគុត្តពោលថា មានការអ្វីសម្លាញ់ គរហទិន្នពោលថា ធម្មតាញាតិ និងសម្លាញ់ទាំងឡាយ រមែងមានការឈ្លោះគ្នាខ្លះ វិវាទគ្នាខ្លះ អ្នកមិនពោលពាក្យណាមួយ ព្រោះហេតុអ្វី ទើបធ្វើយ៉ាងនោះ ។

សិរិគុត្តពោលថា នែសម្លាញ់ ខ្ញុំមិននិយាយក៏ព្រោះអ្នកមិននិយាយជាមួយខ្ញុំ កម្មណាដែលខ្ញុំធ្វើហើយ កម្មនោះគ្រាន់តែធ្វើហើយចុះ យើងទាំងពីរមិនទម្លាយមេត្រីដល់គ្នានិងគ្នា ។

ចាប់តាំងអំពីកាលនោះ សម្លាញ់ទាំងពីរឈរ អង្គុយក្នុងទីជាមួយគ្នា ។

ក្នុងកាលថ្ងៃមួយ សិរិគុត្តពោលនឹងគរហទិន្នថា ប្រយោជន៍អ្វីរបស់អ្នកដោយពួកនិគ្រន្ថ អ្នកទៅរកនិគ្រន្ថទាំងនោះនឹងបានអ្វី ការចូលទៅរកព្រះសាស្តារបស់ខ្ញុំក្តី ការថ្វាយទានដល់លោកម្ចាស់ទាំងឡាយក្តី នឹងមិនគួរដល់អ្នកឬ សូម្បីគរហទិន្នទោះរមែងរងចាំហេតុនេះដូចគ្នា ព្រោះដូច្នោះ ពាក្យសម្តីសិរិគុត្តនោះទើបបានហាក់ដូចជាអេះបូសដោយក្រចក ។ គរហទិន្ននោះ សួរសិរិគុត្តថា ព្រះសាស្តារបស់អ្នកដឹងអ្វី សិរិគុត្តពោលថា នែអ្នក អ្នកកុំពោលយ៉ាងនោះ ឈ្មោះថា វត្ថុដែលព្រះសាស្តារបស់យើងមិនដឹង មិនមាន ព្រះសាស្តារបស់យើងនោះ រមែងដឹងហេតុសព្វយ៉ាង មានហេតុជាអតីតជាដើម រមែងកំណត់ចិត្តរបស់សត្វទាំងឡាយ ដោយអាការ ១៦ យ៉ាងបាន ។

គរហទិន្នពោលថា ខ្ញុំមិនជ្រាបយ៉ាងនោះ ព្រោះហេតុអ្វីទើបអ្នកមិនប្រាប់ដល់ខ្ញុំអស់កាលមានប្រមាណប៉ុណ្ណេះ បើដូច្នោះ អ្នកចូរទៅ ចូរទូលនិមន្តព្រះសាស្តាដើម្បីសោយក្នុងថ្ងៃស្អែកនេះ ខ្ញុំនឹងឲ្យសោយ អ្នកចូរក្រាបទូលដើម្បីទ្រង់ទទួលភិក្ខារបស់ខ្ញុំ មួយអន្លើដោយភិក្ខុ ៥០០ រូប ។

សិរិគុត្តចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយ ក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គ គរហទិន្នសម្លាញ់របស់ខ្ញុំព្រះអង្គ ប្រាប់ឲ្យទូលនិមន្តព្រះអង្គ សូមទ្រង់ទទួលភិក្ខារបស់គរហទិន្ននោះ មួយអន្លើដោយភិក្ខុ ៥០០ រូបក្នុងស្អែកនេះ ដ្បិតក្នុងថ្ងៃមុនកម្មឈ្មោះនេះ ខ្ញុំព្រះអង្គធ្វើហើយដល់ពួកនិគ្រន្ថដែលចូលដល់ត្រកូលរបស់គរហទិន្ននោះ ខ្ញុំព្រះអង្គមិនជ្រាបការធ្វើតបដល់កម្មដែលខ្ញុំព្រះអង្គធ្វើហើយ ខ្ញុំព្រះអង្គមិនជ្រាបសូម្បីភាពដែលគរហទិន្ននោះ

ប្រាថ្នានឹងថ្វាយភិក្ខាដល់ព្រះអង្គ ដោយចិត្តដ៏បរិសុទ្ធ ព្រះអង្គទ្រង់ពិចារណាហើយ បើសមគួរសូមទ្រង់ទទួល បើមិនសមគួរទ្រង់កុំទទួលឡើយ ។ ព្រះសាស្តាទ្រង់ពិចារណាថា គរហទិន្នទោះប្រាថ្នានឹងថ្វាយដល់តថាគតឬហ្ន៎ ទ្រង់បានឃើញថា គរហទិន្នទោះបានឲ្យមនុស្សជីករណ្តៅធំ ត្រង់ចន្លោះផ្ទះពីរខ្នងហើយបានឲ្យមនុស្សនាំឈើគគីរមកប្រមាណ ៨០ រទេះ ដុតភ្លើងហើយ ត្រូវការឲ្យតថាគតធ្លាក់ចុះក្នុងរណ្តៅរងើកភ្លើង ហើយសង្កត់សង្កិន ទ្រង់ពិចារណាទៀតថា ព្រោះតថាគតទៅក្នុងទីនោះជាបច្ច័យ ប្រយោជន៍នឹងមាន ឬមិនមានហ្ន៎ លំដាប់នោះ ទ្រង់បានឃើញហេតុនេះថា តថាគតនឹងឈានជើងជាន់លើរណ្តៅរងើកភ្លើង កន្ទេលផែនដែលដាក់បិទបាំងរណ្តៅរងើកភ្លើងនោះនឹងវិនាសទៅ ផ្កាឈូកធំប្រមាណប៉ុនកង់រទេះ នឹងផុសឡើងទម្លាយរណ្តៅរងើកភ្លើង កាលបើដូច្នោះ តថាគតនឹងជាន់ត្របកឈូក ទៅអង្គុយលើអាសនៈភិក្ខុទាំង ៥០០ នឹងទៅអង្គុយយ៉ាងនោះដូចគ្នា មហាជននឹងប្រជុំគ្នា តថាគតនឹងធ្វើអនុមោទនា ដោយគាថា ២ គាថា ក្នុងសមាគមនោះ ក្នុងពេលចប់អនុមោទនា ការត្រាស់ដឹងធម៌ រមែងមានដល់សត្វ ៨៤០០០ ។ សិរិគុត្ត និងគរហទិន្នទឹងបានជាសោតាបន្ន នឹងដាក់គំនរទ្រព្យរៀងៗ ខ្លួនក្នុងសាសនា ។ កាលដែលតថាគតអាស្រ័យកុលបុត្រនេះ ទៅ រមែងសមគួរ ដូច្នេះហើយទើបទ្រង់ទទួលភិក្ខា ។ សិរិគុត្តជ្រាបការទទួលរបស់ព្រះសាស្តាហើយ ទើបប្រាប់ដល់គរហទិន្ន ហើយប្រាប់ថា អ្នកចូរធ្វើសក្ការៈដល់ព្រះលោកជេដ្ឋៈ ។

គរហទិន្នគិតថា ឥឡូវនេះ អញនឹងដឹងកិច្ចដែលគួរធ្វើដល់ព្រះសមណ-

គោតមនោះ ទើបឲ្យជីករណ្ដៅធំក្នុងរវាងផ្ទះពីរខ្នង ឲ្យនាំឈើគគីរប្រមាណ ៨០ រទេះ ឲ្យដុតភ្លើងមួយយប់ទាល់ភ្លឺហើយ ឲ្យធ្វើគំនររងើកភ្លើង ដាក់ឈើដែលរាបស្មើលើមាត់រណ្ដៅ ឲ្យបិទដោយកន្ទេលផែង ឲ្យលាបដោយអាចម៍គោ ក្រាលកំណាត់ឈើពុកត្រង់ចំណែកម្ខាង ហើយឲ្យធ្វើផ្លូវជាទីទៅដោយសម្គាល់ថា ក្នុងពេលដែលពួកសមណៈជាន់ហើយយ៉ាងនេះ កំណាត់ឈើទាំងឡាយបាក់ហើយ ពួកសមណៈនឹងរអិលធ្លាក់ទៅក្នុងរណ្ដៅរងើកភ្លើង ឲ្យតាំងទៀនទទេក្នុងចំណែកខាងក្រោយផ្ទះ ដោយវិធីដែលសិរិគុត្តតាំងហើយដូចគ្នា ។ ឲ្យក្រាលអាសនៈទាំងឡាយយ៉ាងនោះដូចគ្នា ។ សិរិគុត្តទៅផ្ទះរបស់គរហទិន្នទោះអំពីព្រលឹមហើយ ពោលថា សម្លាញ់ អ្នកធ្វើសក្ការៈហើយឬ គរហទិន្នពោលថា អើ ធ្វើហើយសម្លាញ់ សិរិគុត្តពោលថា សក្ការៈនោះនៅឯណា គរហទិន្នឆ្លើយថា ចូរមកមើលចុះ ហើយបង្ហាញរបស់ទាំងអស់ដោយវិធីដែលសិរិគុត្តបង្ហាញហើយដូចគ្នា ។ សិរិគុត្តពោលថា ល្អណាស់ សម្លាញ់ ។ មហាជនប្រជុំហើយ កាលព្រះសាស្ដាដែលបុគ្គលមិច្ឆាទិដ្ឋិនិមន្តហើយ ការប្រជុំធំរមែងមាន ។ ចំណែកពួកមិច្ឆាទិដ្ឋិ រមែងប្រជុំគ្នាដោយគិតថា ពួកយើងនឹងឃើញប្រការដែលប្លែករបស់ព្រះសមណគោតម ចំណែកពួកជនសម្មាទិដ្ឋិរមែងប្រជុំគ្នាដោយគិតថា ថ្ងៃនេះ ព្រះសាស្ដាទ្រង់នឹងសម្ដែងព្រះធម៌ទេសនាយ៉ាងធំ ពួកយើងនឹងកំណត់ពុទ្ធវិស័យ ពុទ្ធលីលា ។ ក្នុងថ្ងៃស្អែកឡើង ព្រះសាស្ដាបានយាងទៅកាន់ទ្វារផ្ទះរបស់គរហទិន្នជាមួយនឹងភិក្ខុ ៥០០ រូប ។ គរហទិន្នទោះចេញអំពីផ្ទះហើយ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ឈរផ្គង

អញ្ជលីខាងមុខព្រះកក្កុគិតថា បពិត្រព្រះអង្គ ឧបដ្ឋាករបស់ព្រះអង្គប្រាប់ដល់ខ្ញុំព្រះអង្គយ៉ាងនេះថា បានឮថា ព្រះអង្គទ្រង់ជ្រាបហេតុសព្វយ៉ាង មានហេតុជាអតីតជាដើម ទ្រង់រមែងកំណត់ចិត្តរបស់សត្វទាំងឡាយដោយអាការ ១៦ យ៉ាងបាន បើទ្រង់ជ្រាប សូមទ្រង់កុំចូលទៅកាន់ផ្ទះរបស់ខ្ញុំព្រះអង្គ ព្រោះកាលទ្រង់ចូលទៅហើយ បបរមិនមានឡើយ កត្តជាដើមក៏មិនមាន ឯខ្ញុំព្រះអង្គនឹងញ៉ាំងលោកម្ចាស់ទាំងអស់ឲ្យធ្លាក់ក្នុងរណ្តៅរងើកភ្លើង ហើយសង្កត់សង្កិន កាលគិតយ៉ាងនោះហើយ ទើបទទួលបាត្ររបស់ព្រះសាស្តាក្រាបទូលថា សូមព្រះដ៏មានព្រះភាគ ទ្រង់យាងមកផ្លូវនេះ ហើយក្រាបទូលថា បពិត្រព្រះអង្គអ្នកមកកាន់ផ្ទះរបស់ខ្ញុំព្រះអង្គ ដឹងទំនៀមហើយសឹមមក ទើបគួរ ព្រះសាស្តាត្រាស់ថា តថាគតធ្វើដូចម្តេច ទើបគួរ គរហទិន្នពោលថា ក្នុងកាលដែលភិក្ខុមួយរូបៗ ចូលទៅខាងមុខអង្គុយហើយ ភិក្ខុដទៃមកក្នុងកាលខាងក្រោយ ទើបគួរ ។

បានឮថា គរហទិន្ននោះមានការគិតយ៉ាងនេះថា ភិក្ខុដ៏សេសឃើញភិក្ខុដែលទៅខាងមុខ ធ្លាក់ចុះក្នុងរណ្តៅភ្លើងហើយ រមែងមិនមក អញនឹងឲ្យភិក្ខុធ្លាក់គ្រប់រូប ហើយសង្កត់សង្កិន ។ ព្រះសាស្តាត្រាស់ថា សាធុ ហើយទ្រង់ចូលទៅតែមួយព្រះអង្គឯង ។ គរហទិន្នដល់រណ្តៅរងើកភ្លើងហើយ ថយចេញទៅឈរក្រាបទូលថា សូមទ្រង់យាងទៅខាងមុខចុះ ។

គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ឈានព្រះបាទចុះលើរណ្តៅរងើកភ្លើង កន្ទេលផែងក៏បាត់ទៅហើយ ផ្កាឈូកប្រមាណប៉ុនកង់រទេះ ផុសឡើងទម្លាយ

រណ្តៅរងើកភ្លើង ។ ព្រះសាស្តាទ្រង់ជាន់ត្របកឈូកយាងទៅប្រថាប់គង់លើពុទ្ធាសនៈដែលគេក្រាលហើយ ។ សូម្បីភិក្ខុទាំងឡាយ ក៏ទៅអង្គុយលើអាសនៈទាំងនោះដូចគ្នា កម្តៅតាំងឡើងអំពីកាយរបស់គរហទិន្នហើយ ។ គាត់ទៅដោយរហ័ស ចូលទៅរកសិរិគុត្ត ប្រាប់ថា សម្លាញ់ សូមអ្នកជាទីពឹងរបស់ខ្ញុំចុះ សិរិគុត្តពោលថា អ្នកកើតអ្វី គរហទិន្នពោលថា បបរឬកត្តជាដើមដើម្បីភិក្ខុ ៥០០ រូបមិនមានក្នុងផ្ទះ ខ្ញុំធ្វើដូចម្តេចហ្ន៎ សិរិគុត្តពោលថា អ្នកធ្វើអ្វី គរហទិន្នពោលថា ខ្ញុំឲ្យគេធ្វើរណ្តៅរងើកភ្លើងធំ ក្នុងរវាងផ្ទះពីរខ្នងពេញដោយរងើកភ្លើង ដោយបំណងថា នឹងឲ្យពួកភិក្ខុធ្លាក់ទៅក្នុងរណ្តៅរងើកភ្លើងនោះហើយសង្កត់សង្កិន ។ ពេលនោះ ផ្កាឈូកធំៗផុសឡើងទម្លាយរណ្តៅរងើកភ្លើងនោះ ភិក្ខុទាំងអស់ជាន់ត្របកឈូក ដើរទៅគង់លើអាសនៈដែលគេក្រាល ឥឡូវនេះខ្ញុំនឹងធ្វើដូចម្តេច សិរិគុត្តពោលថា អ្នកប្រាប់ដល់ខ្ញុំអម្បាញ់មិញនេះឯងថា ពាងបបរប៉ុណ្ណេះ ពាងកត្តជាដើមប៉ុណ្ណេះមិនមែនឬ គរហទិន្នពោលថា ខ្ញុំកុហកទេ ពាងទាំងនោះទទេទាំងអស់ ។ សិរិគុត្តពោលថា ណ្ហើយចុះ អ្នកចូរទៅពិនិត្យមើលបបរជាដើមក្នុងពាងទាំងនោះ ។ ក្នុងខណៈនោះឯងបបរក្នុងពាងទាំងឡាយណា ដែលគរហទិន្ននោះប្រាប់ហើយ ពាងទាំងនោះពេញដោយបបរ កត្តជាដើមក្នុងពាងទាំងឡាយណា ដែលគរហទិន្នប្រាប់ហើយពាងទាំងនោះ បានពេញហើយដោយកត្តជាដើម ព្រោះបានឃើញសម្បត្តិនោះសរីរៈរបស់គរហទិន្នពេញដោយបីតិ និងបាមោជ្ជ មានចិត្តជ្រះថ្លាហើយ គាត់អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយសេចក្តីគោរព ប្រាថ្នាឲ្យទ្រង់

ធ្វើអនុមោទនា ទើបទទួលបាត្ររបស់ព្រះសាស្តា ដែលទ្រង់ធ្វើភត្តកិច្ចហើយ ។

ព្រះសាស្តា កាលទ្រង់ធ្វើអនុមោទនាត្រាស់ថា សត្វទាំងនេះមិនដឹងគុណនៃសាវករបស់តថាគត និងព្រះពុទ្ធសាសនា ព្រោះមិនមានបញ្ញាចក្ខុ ឈ្មោះថា ជាអ្នកងងឹត អ្នកមានបញ្ញា ឈ្មោះថា មានចក្ខុ ដូច្នេះហើយ បានត្រាស់ព្រះគាថាទាំងនេះថា

**យថា សង្ការធានស្មឹ ឧជ្ឈិតស្មឹ មហាបថេ**
**បទុមំ តត្ថ ជាយេថ សុចិគន្ធំ មនោរមំ ។**
**ឯវំ សង្ការភូតេសុ អន្ធភូតេ បុថុជ្ជនេ**
**អតិរោចតិ បញ្ញាយ សម្មាសម្ពុទ្ធសាវកោ ។**

ផ្កាឈូកទុកជាកើតក្នុងគំនរសំរាម ដែលគេចាក់ចោលក្បែរផ្លូវធំនោះ ក៏គង់មានក្លិនក្រអូប ជាទីរីករាយនៃចិត្តបាន ដូចម្តេចមិញ បណ្តាជនដែលដូចជាគំនរសំរាម សាវករបស់ព្រះសម្មាសម្ពុទ្ធ រមែងរុងរឿងកន្លងផុតបុថុជ្ជនទាំងឡាយដែលល្ងិតល្ងង់ដោយប្រាជ្ញា ( របស់ខ្លួន ) ដូច្នោះឯង ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សង្ការធានស្មឹ** គឺក្នុងទីដែលចោលសំរាម អធិប្បាយថា ក្នុងគំនរសំរាម ។ ពីរបទថា **ឧជ្ឈិតស្មឹ មហាបថេ** គឺដែលបុគ្គលចោលហើយក្នុងផ្លូវធំ ។ បទថា **សុចិគន្ធំ** គឺមានក្លិនក្រអូប ។ បទថា **មនោរមំ** មានវិគ្គហៈថា ចិត្តរមែងត្រេកអរក្នុងផ្កាឈូកនេះ ហេតុនោះ ផ្កា

ឈូកនោះ ឈ្មោះថា ជាទីត្រេកអរនៃចិត្ត ។ បទថា **សង្ការភូតេសុ** គឺដូចជាសំរាម ។ បទថា **បុថុជ្ជនេ** សេចក្តីថា ដែលលោកិយមហាជនទាំងឡាយ អ្នកមានឈ្មោះដែលបានហើយយ៉ាងនោះ ព្រោះញ៉ាំងកិលេសក្រាស់ឲ្យកើត ។

ព្រះដ៏មានព្រះភាគត្រាស់ពាក្យនេះថា ផ្កាឈូកមានក្លិនល្អ គប្បីកើតក្នុងគំនរសំរាម ដែលបុគ្គលចោលហើយជិតផ្លូវធំ សូម្បីមិនស្អាត គួរខ្ពើមជារបស់បដិកូល ផ្កាឈូកនោះ គប្បីជាទីគាប់ចិត្ត គឺជារបស់គួរប្រាថ្នា ជាទីត្រេកអរ នៃចិត្ត បានដល់ គប្បីជារបស់គួរប្រតិស្ឋានលើក្បាលនៃឥស្សរជនទាំងឡាយ មានព្រះរាជា និងអមាត្យរបស់ព្រះរាជាជាដើម យ៉ាងណា សាវករបស់ព្រះសម្មាសម្ពុទ្ធ គឺភិក្ខុដែលជាខីណាស្រពក៏ដូច្នោះដូចគ្នា កាលនៅជាបុថុជ្ជន ហាក់ដូចជាគំនរសំរាមកើតហើយ សូម្បីកើតក្នុងរវាងនៃមហាជនដែលមិនមានបញ្ញា មិនមានចក្ខុ រមែងរុងរឿងកន្លងបង់ដោយកម្លាំងនៃបញ្ញារបស់ខ្លួន ឃើញទោសក្នុងកាមទាំងឡាយ និងអានិសង្ស ក្នុងការចេញបួសចេញបួសហើយ រមែងរុងរឿងដោយគុណ ត្រឹមតែការបំពេញបព្វជ្ជា សូម្បីលើកខ្លួនឡើងកាន់សីល សមាធិ បញ្ញា វិមុត្តិ វិមុត្តិញ្ញាណទស្សនៈ ក្រៃលែងជាងគុណត្រឹមតែការបំពេញបព្វជ្ជានោះ រមែងរុងរឿង គឺស្អាតក្រៃលែងជាងបុថុជ្ជនដែលងងឹតទាំងឡាយ ។

ក្នុងវេលាចប់ទេសនា ការត្រាស់ដឹងធម៌មានហើយដល់សត្វ ៨៤០០០ គរហទិន្ន និងសិរិគុត្ត សម្រេចសោតាបត្តិផលហើយ ។ ជនទាំងពីរនាក់នោះសាបព្រោះទ្រព្យរបស់ខ្លួនទាំងអស់ ក្នុងព្រះពុទ្ធសាសនាហើយ ។ ព្រះសាស្តា

បានយាងក្រោកអំពីអាសនៈទៅកាន់វិហារ ។

ភិក្ខុទាំងឡាយញុំាងកថាឲ្យកើតឡើងក្នុងរោងធម្មសភា ក្នុងវេលាល្ងាចថា គួរជ្រះថ្លា ធម្មតាគុណរបស់ព្រះពុទ្ធគួរអស្ចារ្យ ។ ផ្កាឈូកផុសឡើងទម្លាយគំនរវេងើកភ្លើងគគីរបែបនោះហើយ ។ ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះពួកអ្នកអង្គុយប្រជុំគ្នាដោយកថាអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលថា ដោយកថាឈ្មោះនេះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការដែលផ្កាឈូកផុសឡើងអំពីគំនរវេងើកភ្លើងដើម្បីតថាគត ដែលជាព្រះពុទ្ធក្នុងកាលឥឡូវនេះ មិនគួរអស្ចារ្យក្នុងកាលមុន ផ្កាឈូកទាំងនោះក៏ផុសឡើងហើយដើម្បីតថាគត ដែលនៅជាពោធិសត្វ ប្រព្រឹត្តទៅនៅក្នុងបទេសញ្ញាណ កាលភិក្ខុទាំងនោះទូលអារាធនាថា បពិត្រព្រះអង្គ ផ្កាឈូកនោះផុសក្នុងកាលណា សូមទ្រង់ត្រាស់ប្រាប់ដល់យើងខ្ញុំទាំងឡាយ ដូច្នេះហើយ ទើបទ្រង់នាំអតីតនិទានមក ត្រាស់ខទិរង្គារ-ជាតកនេះឲ្យពិស្តារថា

តាមពិត ខ្ញុំព្រះអង្គស៊ូមានជើងឡើងលើ មានក្បាលចុះក្រោម ហើយធ្លាក់ទៅកាន់នរក ខ្ញុំនឹងពុំធ្វើអំពើមិនប្រសើរទេ បើដូច្នោះ សូមព្រះអង្គទទួលនូវចង្ហាន់បិណ្ឌបាតចុះ ដូច្នេះឯង ។៚

**រឿងគហបតិធិន្ន ចប់**

**អធិប្បាយបុប្ផវគ្គ ចប់**

**ចតុត្ថវគ្គ ចប់**

# សុត្តន្តបិដក

## ធម្មបទគាថា ពាលវគ្គទី៥

[ ១៥ ] រាត្រីវែង ចំពោះតែអ្នកភ្ញាក់រឭក ( អ្នកដេកមិនលក់ ) យោជន៍វែង ចំពោះតែអ្នកនឿយហត់ សង្សារវដ្តវែង ចំពោះតែបុគ្គលពាល មិនដឹងច្បាស់នូវព្រះសទ្ធម្ម ។

បុគ្គលកាលស្វះស្វែងរកកល្យាណមិត្ត បើមិនបានមិត្តដ៏ប្រសើរជាងខ្លួន ឬមិត្តដែលស្មើនឹងខ្លួនទេ គប្បីប្រព្រឹត្តនៅតែម្នាក់ឯង ឲ្យខ្ជាប់ខ្ជួនវិញ ព្រោះថា សហាយតាគុណ មិនមានក្នុងបុគ្គលពាលឡើយ ។ ជនពាល តែងព្រួយលំបាក ដោយសេចក្តីសម្គាល់ថា កូនទាំងឡាយរបស់អញមាន ទ្រព្យរបស់អញមាន តាមដែលពិត សូម្បីខ្លួនរបស់ខ្លួនក៏មិនមាន ចំណង់បើកូនទាំងឡាយ នឹងរាប់ថាមានអំពីណាបាន ទ្រព្យនឹងរាប់ថា មានអំពីណាបាន ។

អ្នកណា ជាមនុស្សពាល ហើយដឹងនូវភាពនៃខ្លួនថាជាពាល អ្នកនោះនឹងទៅជាបណ្ឌិតបានខ្លះ ដោយហេតុដែលដឹងខ្លួន ថាជាពាលនោះ ម្យ៉ាងទៀត អ្នកណា ជាមនុស្សពាល មានសេចក្តីប្រកាន់ថា ខ្លួនជាបណ្ឌិត អ្នកនោះ ឈ្មោះថា ជាមនុស្សពាលដោយពិត ។ មនុស្សពាល បើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីអស់មួយជីវិត ក៏ឥតមានដឹងសេចក្តីអ្វីឲ្យច្បាស់លាស់ឡើយ ដូចវែក ដែលមិនដឹងរសសម្ល ។

វិញ្ញូជន បើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីតែមួយរំពេច រមែងយល់សេចក្តី ដោយឆាប់រហ័ស ដូចអណ្តាតដឹងនូវរសសម្ល ។

ពួកជនពាល មិនមានប្រាជ្ញា មានខ្លួនដូចជាសត្រូវ តែងធ្វើកម្មលាមក ដែលជាអំពើមានផលក្តៅក្រហាយ ។

បុគ្គលធ្វើកម្មណាហើយ រមែងក្តៅក្រហាយ ឬមានមុខប្រឡាក់ដោយទឹកភ្នែក ស្រែកយំ ទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះ ឈ្មោះថា ជាកម្មមិនល្អឡើយ ។

បុគ្គលធ្វើកម្មណាហើយ រមែងមិនក្តៅក្រហាយ ឬដល់នូវសេចក្តីពេញចិត្ត មានចិត្តល្អ ទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះឯង ឈ្មោះថា ជាកម្មល្អ ។

បាបមិនទាន់ឲ្យផលត្រឹមណា ជនពាល តែងសម្គាល់នូវបាបនោះថា ដូចទឹកឃ្មុំ លុះតែកាលណាបាបឲ្យផល ជនពាល ទើបប្រទះនូវសេចក្តីទុក្ខ ក្នុងកាលណោះ ។

ជនពាល ទុកជាបរិភោគភោជនដោយចុងស្បូវរាល់ៗ ខែ ជនពាលនោះ ក៏មិនដល់មួយចំណិតនៃចំណែកទី ១៦ៗ លើក របស់បុគ្គលទាំងឡាយ ដែលមានធម៌បានដឹង ឬបានពិចារណាហើយឡើយ ។

កម្មលាមក ដែលជនពាលធ្វើហើយ មិនទាន់ឲ្យផលនោះក៏មាន ដូចទឹកដោះស្រស់ ដែលមិនទាន់ប្រែក្លាយ ( ក្នុងមួយរំពេច ) ដូច្នោះ បាបកម្មនោះ តាមដុតបុគ្គលពាល ដូចរងើកភ្លើងដែលបិទបាំងទុកដោយផេះ ដូច្នោះ ។

ការចេះដឹង កើតឡើងដល់បុគ្គលពាល គ្រាន់តែដើម្បីសេចក្តីវិនាសប៉ុណ្ណោះ រមែងញ៉ាំងបញ្ញាឲ្យធ្លាក់ចុះ បំផ្លេចបំផ្លាញចំណែកធម៌ស គឺកុសល

របស់បុគ្គលពាលនោះ ។ ភិក្ខុពាល រមែងប្រាថ្នានូវសេចក្ដីសរសើរ ដែលមិនមាន ( ក្នុងខ្លួន ) ផង នូវការធ្វើក្នុងខាងមុខ គឺជាប្រមុខ ក្នុងពួកភិក្ខុផង នូវភាពជាឥស្សរៈ ក្នុងអាវាសទាំងឡាយផង នូវការបូជាទាំងឡាយ ក្នុងត្រកូលនៃជនទាំងឡាយដទៃផង ភិក្ខុពាលតែងមានសេចក្ដីត្រិះរិះថា គ្រហស្ថ និងបព្វជិតទាំង ២ ពួក ចូរសម្គាល់នូវកិច្ច ដែលមនុស្សដទៃធ្វើហើយ ថាជាកិច្ចរបស់អញវិញ អំណាចដ៏ក្រៃលែងរបស់អញ ចូរមានក្នុងកិច្ចតូច ធំណាៗមួយ ( កាលបើយ៉ាងនេះ ) ឫស្យា និងមានះ រមែងចម្រើន ។ បដិបទាអាស្រ័យនូវលាភផ្សេង បដិបទាជាដំណើរទៅកាន់ព្រះនិព្វានផ្សេង ភិក្ខុជាសាវករបស់ព្រះពុទ្ធ ដឹងច្បាស់នូវហេតុនោះ យ៉ាងនេះហើយ មិនគួរត្រេកអរចំពោះសក្ការៈឡើយ គប្បីញុំាងវិវេកឲ្យចម្រើន ដោយលំដាប់ ។

## ពាលវគ្គទី ៥ ចប់

# អដ្ឋកថា

# ពាលវគ្គ

## រឿង អញ្ញតរបុរស

### លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះបាទបសេនទិកោសល និងបុរសម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **ទីឃា ជាគរតោ រត្តិ** ជាដើម ។

បានឮថា ក្នុងថ្ងៃមហោស្រពមួយ ព្រះរាជាព្រះនាមបសេនទិកោសល គង់លើដំរីសសុទ្ធមួយឈ្មោះបុណ្ឌរីកៈ ដែលតាក់តែងហើយ ទ្រង់ធ្វើប្រទក្សិណនគរ ដោយអានុភាពនៃព្រះរាជាដ៏ធំ ។ កាលអាជ្ញាជាហេតុឲ្យបុគ្គលក្រោកទៅ គឺទាហានស្តេចដេញបុគ្គលដែលឈរតាមផ្លូវ កំពុងប្រព្រឹត្តទៅ ។ មហាជនត្រូវរាជបុរសវាយដោយវត្ថុ មានដុំដី និងដំបងជាដើមគេចទៅ ក៏នៅឱប-កត្រឡប់សម្លឹងមើលនោះឯង ។ បានឮថា សេចក្តីនេះជាផលនៃទានដែលព្រះរាជាទាំងឡាយ ទ្រង់ថ្វាយល្អហើយ ។

កិរិយារបស់ទុគ្គិតបុរសម្នាក់ ឈរត្រង់ផ្ទៃខាងលើនៃប្រាសាទ ៧ ជាន់ បើកស្លឹកបង្អួចសម្លឹងមើលព្រះរាជា ហើយក៏ត្រឡប់ទៅ ។ ការត្រឡប់ទៅរបស់ ស្រីនោះ ប្រាកដដល់ព្រះរាជាហាក់បីដូចព្រះចន្ទពេញវង់ ចូលកាន់

ស្រទាប់ពពក ។ ព្រះរាជាទ្រង់មានព្រះហឫទ័យប្រតិព័ទ្ធក្នុងស្រីនោះ ហាក់បីដូចដល់នូវអាការធ្លាក់អំពីលើ-កដីរ ទ្រង់ប្រញាប់ប្រញាល់ធ្វើប្រទក្សិណព្រះនគរ ហើយចូលទៅកាន់ខាងក្នុងព្រះរាជវាំង ត្រាស់នឹងអមាត្យស្និទ្ធស្នាលម្នាក់ថា ប្រាសាទដែលខ្ញុំមើលក្នុងទីឈ្មោះនោះ អ្នកឃើញដែរឬទេ ។ អមាត្យទូលថា បពិត្រព្រះអង្គ ទូលបង្គំឃើញ ព្រះរាជាត្រាស់ថា អ្នកបានឃើញស្រីម្នាក់ក្នុងប្រាសាទនោះដែរឬទេ អមាត្យទូលថា បពិត្រព្រះអង្គ ទូលបង្គំបានឃើញ ព្រះរាជាត្រាស់ថា អ្នកចូរទៅ ចូរដឹងថា ស្រីនោះមានប្ដីហើយឬនៅ ។

អមាត្យនោះទៅហើយ ជ្រាបសេចក្ដីដែលស្រីនោះមានប្ដី ទើបមកក្រាបទូលដល់ព្រះរាជាថា បពិត្រព្រះអង្គ ស្រីនោះមានប្ដីហើយ ។ ពេលនោះព្រះរាជាត្រាស់ថា បើដូច្នោះ ចូរអ្នកហៅប្ដីរបស់ស្រីនោះមក អមាត្យនោះទៅពោលថា នែអ្នក ព្រះរាជាត្រាស់ឲ្យហៅ ។ បុរសនោះគិតថា ភ័យគប្បីកើតឡើងដល់អញព្រោះអាស្រ័យភរិយា កាលមិនអាចជំទាស់ព្រះរាជអាជ្ញា ទើបបានទៅថ្វាយបង្គំព្រះរាជាហើយឈរ ។ ខណៈនោះ ព្រះរាជាត្រាស់នឹងបុរសនោះថា អ្នកចូរទំនុកបម្រុងយើង ។ បុរសនោះក្រាបទូលថា បពិត្រព្រះសម្មតិទេព កុំឡើយ ទូលបង្គំធ្វើការងាររបស់ខ្លួន ថ្វាយសួយដល់ព្រះអង្គការចិញ្ចឹមជីវិតនោះ សូមមានដល់ទូលបង្គំចុះ ។ ព្រះរាជាត្រាស់ថា ខ្ញុំមិនត្រូវការដោយសួយរបស់អ្នក ចាប់តាំងអំពីថ្ងៃនេះទៅ អ្នកចូរមប្រើខ្ញុំចុះ ហើយព្រះរាជទានខែល និងអាវុធដល់បុរសនោះ ។

បានឮថា ព្រះរាជាទ្រង់ត្រិះរិះយ៉ាងនេះថា អញនឹងចាប់ទោសណាមួយរបស់បុរសនេះ ហើយសម្លាប់ចោល យកករិយា ។ ពេលនោះ បុរសនោះខ្លាចអំពីមរណភ័យ ជាអ្នកមិនប្រមាទ បម្រើព្រះរាជាហើយ ។ ព្រះរាជាទ្រង់មិនឃើញឱកាសនៃបុរសនោះ កាលទ្រង់ក្តៅក្រហាយ ព្រោះកាមចម្រើនទ្រង់ព្រះតម្រិះថា អញនឹងលើកទោសណាមួយរបស់បុរសនោះឡើង ហើយដាក់រាជអាជ្ញា ទើបបញ្ជាឲ្យហៅបុរសនោះមក ហើយត្រាស់យ៉ាងនេះថា នែអ្នក អ្នកចូរទៅអំពីទីនេះ ទៅកាន់ទីឈ្មោះនោះនៃស្ទឹងក្នុងទីបំផុតប្រមាណ ៥ យោជន៍ នាំយកផ្កាកោមុទ ផ្កាឧប្បល និងដីពណ៌អរុណ ឲ្យទាន់ក្នុងកាលដែលខ្ញុំងូតទឹកក្នុងពេលល្ងាច បើអ្នកមកមិនទាន់ក្នុងខណៈនោះ ខ្ញុំនឹងដាក់អាជ្ញាដល់អ្នក ។

បានឮថា សេវកៈលំបាកជាងទាសា និងទាសី ។ ពិតហើយ ទាសៈទាំងឡាយ មានទាសៈដែលគេលោះមកដោយទ្រព្យជាដើម គង់បានពោលថា ខ្ញុំឈឺក្បាល ខ្ញុំឈឺខ្នង ហើយសម្រាក ។

ពាក្យដែលទាសៈពោលហើយ បានសម្រាកនោះ រមែងមិនមានដល់សេវកៈឡើយ ។ សេវកៈធ្វើការងារតាមបញ្ជាប៉ុណ្ណោះ ព្រោះហេតុនោះ បុរសនោះគិតថា អញត្រូវទៅដោយពិត ឈ្មោះថា ដីពណ៌អរុណ ផ្កាកោមុទ និងផ្កាឧប្បល រមែងកើតក្នុងពិភពនាគ អញនឹងបានអំពីណា ។ ខ្លាចចំពោះមរណភ័យ ទៅផ្ទះហើយ ពោលថា នែនាង កត្តសម្រាប់ខ្ញុំសម្រេចហើយឬ ករិយាពោលថា នែអ្នក កំពុងតាំងនៅលើជើងក្រាន ។ បុរសនោះមិនអាច

វង់ចាំរហូតកិរិយាដាក់កត្តចុះបាន ទើបឲ្យកិរិយាយកបោយជងទឹកបាយ ចាក់បាយដែលជ្រាយនោះឯងចូលក្នុងល្អីតាមតែបានកាន់យកហើយ ធ្វើដំណើរទៅហើយ អស់ចម្ងាយផ្លូវមួយយោជន៍ ។

កាលកំពុងដើរនោះឯង កត្តបានធ្អិនហើយ ។ គាត់បែងចែកកត្តបន្តិចធ្វើមិនឲ្យជាសំណល់ បរិភោគ ជួបអ្នកដំណើរម្នាក់ ទើបពោលថា កត្តបន្តិចប៉ុណ្ណោះខ្ញុំបែងចែកធ្វើមិនឲ្យជារបស់សល់មាន អ្នកចូរទទួលបរិភោគចុះ ។ បុរសនោះទទួលបរិភោគហើយ ។ ទុគ៌តបុរសនោះ ក៏ដាក់កត្តចុះក្នុងទឹកមួយក្តាប់ ខ្ពុរមាត់ហើយប្រកាស ៣ ដងដោយសំឡេងខ្លាំងថា សូមពួកនាគ គ្រុឌ និងទេវតាដែលអាស្រ័យនៅក្នុងស្ទឹងនេះ ស្តាប់ពាក្យរបស់ខ្ញុំ ព្រះរាជាទ្រង់ប្រាថ្នាដាក់អាជ្ញាដល់ខ្ញុំ ទ្រង់បញ្ជាខ្ញុំថា ចូរអ្នកនាំយកដីពណ៌អរុណ ផ្កាកោមុទ និងផ្កាឧប្បលមក កត្តដែលខ្ញុំឲ្យដល់មនុស្សអ្នកធ្វើដំណើរហើយ ទានដែលខ្ញុំឲ្យហើយនោះ មានអានិសង្សរាប់ពាន់ កត្តដែលខ្ញុំឲ្យដល់ត្រីទាំងឡាយក្នុងទឹក ទានដែលខ្ញុំឲ្យនោះមានអានិសង្សរាប់រយ ខ្ញុំនឹងឲ្យផលបុណ្យប្រមាណប៉ុណ្ណោះ ឲ្យជាចំណែកបុណ្យដល់អ្នកទាំងឡាយ សូមលោកទាំងឡាយនាំដីពណ៌អរុណ ផ្កាកោមុទ និងផ្កាឧប្បលមកឲ្យខ្ញុំចុះ ។

ស្តេចនាគអាស្រ័យនៅក្នុងប្រទេសនោះ បានឮសំឡេងនោះ ទើបទៅកាន់សម្នាក់បុរសនោះដោយភេទជាមនុស្សចាស់ពោលថា អ្នកនិយាយអ្វី ទើបបុរសនោះពោលដូចមុននោះឯង ស្តេចនាគពោលថា ចូរអ្នកឲ្យចំណែកបុណ្យនោះដល់ខ្ញុំ ទើបបុរសនោះពោលថា ខ្ញុំឲ្យដល់អ្នក កាលស្តេចនាគពោលទៀត

ថា អ្នកចូរឲ្យ ក៏ពោលថា ខ្ញុំឲ្យដល់អ្នក ស្តេចនាគនោះឲ្យនាំចំណែកបុណ្យមកយ៉ាងនោះអស់ ២-៣ ដងហើយ ទើបឲ្យដីពណ៌អរុណ ផ្កាកោមុទ និងផ្កាឧប្បលដល់បុរសនោះ ។

ចំណែកព្រះរាជាទ្រង់ព្រះតម្រិះថា ធម្មតាមនុស្សទាំងឡាយ មានមន្តច្រើន បើបុរសនោះបានរបស់នោះ ដោយឧបាយណាមួយសោត កិច្ចរបស់អញមិនសម្រេច ទ្រង់បញ្ជាឲ្យបិទទ្វារតាំងអំពីថ្ងៃហើយ ឲ្យនាំកូនសោទៅកាន់សម្នាក់របស់ព្រះអង្គ ។

បុរសនោះ មកទាន់ក្នុងកាលព្រះរាជាទ្រង់ស្រង់ទឹកដូចគ្នា កាលមិនមានទ្វារចូល ទើបហៅអ្នកយាមទ្វារពោលថា សូមអ្នកបើកទ្វារ អ្នកយាមទ្វារពោលថា ខ្ញុំមិនអាចបើកបានទេ ព្រះរាជាបញ្ជាឲ្យនាំកូនសោទៅកាន់ព្រះរាជមន្ទីរតាំងអំពីថ្ងៃនោះឯង ។ បុរសនោះ ទោះបីប្រាប់ថា ខ្ញុំជារាជទូត អ្នកចូរបើកទ្វារ កាលមិនបានទ្វារ ទើបគិតថា ឥឡូវនេះអញនឹងមិនមានជីវិត អញនឹងធ្វើដូចម្តេចហ្ន៎ ហើយបោះដុំដីទៅត្រង់ធរណីទ្វារខាងលើ ព្យួរផ្កាលើធរណីទ្វារនោះ ស្រែកឡើង ៣ ដងថា អ្នកនគរដ៏ចម្រើនទាំងឡាយ សូមអ្នកទាំងឡាយដឹងភាពដែលកិច្ចរបស់ខ្ញុំធ្វើតាមបញ្ជារបស់ព្រះរាជាហើយចុះ ព្រះរាជាទ្រង់ប្រាថ្នាធ្វើខ្ញុំឲ្យវិនាសដោយហេតុមិនសមគួរ ហើយគិតថា អញនឹងទៅទីណាហ្ន៎ បានធ្វើសេចក្តីសន្និដ្ឋានថា ធម្មតាភិក្ខុទាំងឡាយជាអ្នកមានចិត្តទន់ភ្លន់ អញនឹងទៅកាន់វិហារហើយដេក ។ ធម្មតាសត្វទាំងនេះក្នុងវេលាបានទទួលសុខ មិនជ្រាបភាពដែលភិក្ខុទាំងឡាយមាន លុះត្រូវសេចក្តីទុក្ខគ្របសង្កត់ ទើបប្រាថ្នានឹងទៅ

វិហារ ព្រោះហេតុនោះ សូម្បីបុរសនោះ ក៏គិតថា ទីពឹងដទៃរបស់អញមិនមាន ទើបទៅកាន់វិហារ ដេកក្នុងទីសមគួរមួយកន្លែង កាលព្រះរាជាមិនបាននូវការផ្ទំលក់អស់មួយរាត្រី ព្រោះទ្រង់គិតដល់ស្រីនោះ ការពេលវាលព្រោះកាមកើតឡើងហើយ ព្រះរាជាទ្រង់គិតថា ក្នុងខណៈរាត្រីអស់ហើយនោះឯងអញនឹងឲ្យសម្លាប់បុរសនោះ ហើយនាំយកស្រីនោះមក ។

ក្នុងខណៈនោះឯង បុរស ៤ នាក់កើតក្នុងនរកឈ្មោះលោហកុម្ភី ដែលមានជម្រៅ ៦០ យោជន៍ ត្រូវភ្លើងនរកឆេះនទៀលទៅមក ដូចអង្ករក្នុងឆ្នាំងដែលកំពុងពុះកញ្ជ្រោល លិចចុះដល់បាតខាងក្រោម ៣ ម៉ឺនឆ្នាំហើយ អណ្តែតឡើងមកត្រង់មាត់ខាងលើ ៣ ម៉ឺនឆ្នាំទៀត សត្វនរកទាំងនោះងើបក្បាលឡើងសម្លឹងមើលគ្នានិងគ្នាហើយ ប្រាថ្នានឹងពោលម្នាក់មួយគាថា តែមិនអាចពោលបាន ទើបពោលបានតែមួយអក្ខរៈ ហើយវិលចុះទៅកាន់ខាងក្រោមដូចដើម ។

ព្រះរាជា កាលទ្រង់មិនបានការផ្ទំលក់ ក៏ឮសំឡេងនោះ ក្នុងវេលាមជ្ឈិមយាម ទ្រង់តក់ស្លុត មានព្រះហឫទ័យខ្លាច ទ្រង់ត្រិះរិះថា អន្តរាយនៃជីវិតនឹងមានដល់អញឬហ្ន៎ ឬនឹងមានដល់អគ្គមហេសី ឬរាជសម្បត្តិរបស់អញនឹងវិនាស មិនអាចបិទព្រះនេត្រទាំងពីរបានមួយយប់ទាល់ភ្លឺ ។ លុះថ្ងៃរះឡើង ទើបទ្រង់ឲ្យហៅបុរោហិតមកហើយ ត្រាស់ថា លោកអាចារ្យសំឡេងដែលគួរខ្លាចក្រៃលែង ខ្ញុំបានឮក្នុងចន្លោះនៃមជ្ឈិមយាម ខ្ញុំមិនជ្រាបថា អន្តរាយនឹងមានដល់រាជសម្បត្តិ ដល់អគ្គមហេសី ដល់ខ្ញុំ ឬដល់អ្នកណា ព្រោះហេតុនោះ ទើបខ្ញុំអញ្ជើញលោកមក ។

បុរោហិតពោលថា បពិត្រមហារាជ សំឡេងដែលទ្រង់ឮដូចម្តេច ព្រះរាជាត្រាស់ថា លោកអាចារ្យ ខ្ញុំឮសំឡេងទាំងនេះថា ទុ ស ន សោ អ្នកចូរពិចារណាផលសម្រេចនៃសំឡេងទាំងនេះមើល ។

ហេតុណាមួយ រមែងមិនប្រាកដដល់ព្រាហ្មណ៍ ហាក់បីដូចចូលទៅកាន់ទីងងឹតធំ ។ បុរោហិតនោះខ្លាចពោលថា បើអញទូលថា ទូលបង្គំមិនជ្រាបដូច្នេះ លាភសក្ការៈរបស់អញនឹងវិនាស ទើបទូលថា បពិត្រមហារាជ ហេតុនេះធ្ងន់ ព្រះរាជាត្រាស់ថា ហេតុអ្វីលោកអាចារ្យ បុរោហិតទូលថា អន្តរាយនៃជីវិតនឹងប្រាកដដល់ព្រះអង្គ ។

ព្រះរាជាទ្រង់តក់ស្លុតទ្វេគុណត្រាស់ថា លោកអាចារ្យ ហេតុដើម្បីបំបាត់ភាពទាំងនេះណាមួយមានឬ បុរោហិតទូលថា បពិត្រមហារាជ មាន សូមទ្រង់កុំព្រួយព្រះហឫទ័យឡើយ ទូលបង្គំចេះនូវវេទទាំង ៣ ។ ព្រះរាជាត្រាស់ថា ខ្ញុំបានអ្វី ទើបគួរ បុរោហិតទូលថា បពិត្រព្រះអង្គ សូមទ្រង់បូជាយញ្ញ មានសត្វមួយមុខមួយរយ គ្រប់យ៉ាង ហើយនឹងរួចជីវិត ។

ព្រះរាជាត្រាស់ថា បានអ្វី ទើបគួរ ។

បុរោហិតនោះ កាលឲ្យចាប់បាណជាតិប្រភេទនីមួយៗ ឲ្យបានមួយមុខមួយរយ យ៉ាងនេះ គឺដំរី ១០០ សេះ ១០០ គោឧសភៈ ១០០ មេគោទឹកដោះ ១០០ ពពែ ១០០ ចៀម ១០០ មាន់ ១០០ ជ្រូក ១០០ ក្មេងប្រុស ១០០ ក្មេងស្រី ១០០ ទើបគិតថា បើអញចាប់យកតែពួកសត្វប៉ុណ្ណោះ ជនទាំងឡាយក៏ពោលថា បុរោហិតឲ្យចាប់តែរបស់ដែលស៊ីបានសម្រាប់ខ្លួនប៉ុណ្ណោះ

ព្រោះហេតុនោះ ទើបឲ្យចាប់ទាំងដំរី សេះ និងមនុស្សផងដែរ ។ ព្រះរាជាទ្រង់ត្រិះរិះថា ការរស់នៅរបស់យើងនោះឯង ជាលាភរបស់យើង ទើបត្រាស់ថា អ្នកចូរចាប់សត្វគ្រប់ប្រភេទឲ្យរហ័ស ពួកមនុស្សដែលបានទទួលបញ្ជា ក៏ចាប់យកមកច្រើនលើសប្រមាណ ។

ពិតហើយ ព្រះធម្មសង្គាហកាចារ្យពោលពាក្យនេះ ក្នុងកោសលសំយុត្តថា សម័យនោះឯង មហាយញ្ញជាអាការប្រាកដចំពោះដល់ព្រះបាទបសេនទិកោសលហើយ ។

> សម័យនោះ ព្រះបាទបសេនទិកោសល តាំងផ្ដើមធ្វើមហាយញ្ញ ( បូជាធំ ) ។ ពួកគោឧសភៈ ៥០០ កូនគោឈ្មោល ៥០០ កូនគោញី ៥០០ ពពែ ៥០០ ចៀម ៥០០ គេចងភ្ជាប់នឹងសសរយញ្ញ ដើម្បីបូជា ។ ពួកជនណា ដែលជាខ្ញុំប្រុសក្ដី ជាអ្នកបម្រើក្ដី ជាអ្នកធ្វើការងារក្ដី ជនទាំងនោះត្រូវអាជ្ញាគំរាមហើយ ត្រូវភ័យគំរាមហើយ ក៏មានមុខទទឹកដោយទឹកភ្នែក ស្រែកយំ ធ្វើនូវបរិកម្មទាំងឡាយ ( ការរំពឹងគិត ) ។

មហាជនទួញសោក ដើម្បីប្រយោជន៍ដល់ពួកញាតិរៀងៗ ខ្លួន បានធ្វើសំឡេងខ្លាំងហើយ សំឡេងនោះហាក់ដូចជាសំឡេងស្រុតមហាប្រឹថពី ។ គ្រានោះ នាងមល្លិកាទេវីស្ដាប់សំឡេងនោះហើយ យាងចូលទៅកាន់រាជសម្នាក់ទូលសួរថា បពិត្រមហារាជ ព្រោះហេតុអ្វីហ្ន៎ ឥន្ទ្រិយរបស់ព្រះអង្គ មិនជា

ប្រក្រតី ទ្រង់ប្រាកដព្រះរូបស្និតស្រពោន ព្រះរាជាត្រាស់ថា ប្រយោជន៍អ្វី របស់នាង នាងមិនដឹងអាសិរពិសលូនក្បែរត្រចៀករបស់យើងឬ នាងមល្លិកា ទូលថា តើមានហេតុអ្វីព្រះអង្គ ព្រះរាជាត្រាស់ថា ក្នុងចំណែករាត្រី ខ្ញុំបាន ឮសំឡេងបែបនេះ ទើបខ្ញុំសួរបុរោហិត បានឮថា អន្តរាយនៃជីវិត បាន ប្រាកដដល់ព្រះអង្គ ព្រះអង្គទ្រង់បូជាយញ្ញ មានសត្វមួយមុខមួយរយគ្រប់ ប្រភេទ ទើបបាននូវជីវិត ទើបយើងគិតថា ការរស់នៅរបស់យើងនោះឯង ជាលាភរបស់យើង ទើបបញ្ជាឲ្យចាប់សត្វទាំងនោះហើយ ។

ព្រះនាងមល្លិកាទេវីទូលថា បពិត្រមហារាជ ទ្រង់ជាបុគ្គលពាល ទ្រង់ មានកិច្ចច្រើន ទ្រង់រមែងសោយភោជនដែលចម្អិនដោយអង្ករមួយនាឡិ មាន សុបៈ និងព្យញ្ជនៈច្រើនយ៉ាង ព្រះអង្គគ្រងរាជ្យក្នុងដែនទាំងពីរក៏ពិត តែព្រះ បញ្ញារបស់ព្រះអង្គល្ងង់ខ្លៅ ។ ព្រះរាជាត្រាស់ថា ព្រោះហេតុអ្វី ទើបនាង ពោលយ៉ាងនោះ នាងមល្លិកាទូលថា ការបានជីវិតរបស់អ្នកដទៃ ព្រោះការ ស្លាប់របស់អ្នកដទៃ ព្រះអង្គធ្លាប់ឃើញក្នុងទីណា ព្រោះហេតុអ្វី ទើបទ្រង់ ជឿពាក្យសម្តីរបស់ព្រាហ្មណ៍អន្ធពាល ហើយបោះនូវសេចក្តីទុក្ខលើមហាជន ទៅវិញ ព្រះសាស្តាទ្រង់ជាអគ្គបុគ្គលនៃលោក និងទេវលោក មានព្រះ ញាណមិនទើសទាក់ក្នុងកាលទាំងឡាយ មានអតីតកាលជាដើម ប្រថាប់នៅ ក្នុងវិហារជិតបង្កើយ ទ្រង់ទូលសួរព្រះសាស្តានោះហើយ សូមទ្រង់ធ្វើតាម ឱវាទរបស់ព្រះអង្គចុះ ។

គ្រានោះឯង ព្រះរាជាយាងទៅកាន់វិហារជាមួយព្រះនាងមល្លិកា ដោយ

យានដែលស្រោល ត្រូវមរណភ័យគំរាមហើយ មិនអាចទូលពាក្យណាមួយបាន ថ្វាយបង្គំព្រះសាស្តាហើយ ប្រថាប់នៅនាចំណែកម្ខាង ។ លំដាប់នោះព្រះសាស្តាទ្រង់រាក់ទាក់ព្រះរាជានោះមុនថា មហាបពិត្រ ទ្រង់យាងទៅណាទាំងថ្ងៃ ដូច្នេះ ព្រះរាជាក៏ទ្រង់នៅស្ងៀម ។ លំដាប់នោះ ព្រះនាងមល្លិកាក្រាបទូលដល់ព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គ បានឮថា ព្រះរាជាទ្រង់ស្តាប់សំឡេងចម្លែកក្នុងចន្លោះនៃមជ្ឈិមយាម កាលបើដូច្នោះ ទើបទ្រង់ប្រាប់ហេតុនោះដល់បុរោហិត បុរោហិតក្រាបទូលថា អន្តរាយនៃជីវិតនឹងមានដល់ព្រះអង្គ កាលទ្រង់ចាប់សត្វមួយមុខមួយរយ បូជាយញ្ញដោយឈាមបំពង់ករបស់សត្វទាំងនោះ ដើម្បីប្រយោជន៍កម្ចាត់នូវអន្តរាយនោះ ទ្រង់នឹងបានជីវិត ។ ព្រះរាជាឲ្យចាប់សត្វជាច្រើន ព្រោះហេតុនោះ ទើបខ្ញុំម្ចាស់នាំព្រះរាជាមកក្នុងទីនេះ ។ ព្រះសាស្តាត្រាស់ថា មហាបពិត្រ បានឮថា សេចក្តីនោះ យ៉ាងនោះឬ ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ សេចក្តីនោះ យ៉ាងនោះឯង ព្រះសាស្តាត្រាស់ថា សំឡេងដែលទ្រង់ស្តាប់ហើយដូចម្តេច ព្រះរាជាទូលដោយទំនងដែលទ្រង់ស្តាប់ហើយ ។ ពន្លឺតែមួយបានប្រាកដដល់ព្រះតថាគត ព្រោះទ្រង់ស្តាប់សេចក្តីនោះ ។ លំដាប់នោះ ព្រះសាស្តាត្រាស់នឹងព្រះរាជានោះថា សូមទ្រង់កុំតក់ស្លុតឡើយ អន្តរាយមិនមានដល់ព្រះអង្គ សត្វទាំងឡាយដែលមានកម្មលាមក កាលធ្វើទុក្ខរបស់ខ្លួនឲ្យជាក់ច្បាស់ ទើបពោលយ៉ាងនេះ ។ ព្រះរាជាទូលថា បពិត្រព្រះអង្គ កម្មអ្វីដែលសត្វទាំងនោះធ្វើ ។

ព្រះដ៏មានព្រះភាគ កាលទ្រង់សម្ដែងកម្មរបស់សត្វនរកទាំងនោះ ទើបត្រាស់ថា បើដូច្នោះ សូមទ្រង់ស្ដាប់ ហើយទ្រង់នាំអតីតនិទានមកត្រាស់ថា

ក្នុងអតីតកាល កាលមនុស្សមានអាយុ ២ ម៉ឺនឆ្នាំ ព្រះដ៏មានព្រះភាគព្រះនាមកស្សបៈ កើតឡើងក្នុងលោក ទ្រង់ចារិកទៅ មួយអន្លើដោយព្រះខីណាស្រព ២ ម៉ឺនអង្គ ដល់ក្រុងពារាណសី អ្នកក្រុងពារាណសី ២ នាក់ខ្លះ ៣ នាក់ខ្លះ ច្រើនជាងនោះខ្លះ រួមជាពួកតែមួយ ញុំាងអាគន្តុកទានឲ្យប្រព្រឹត្តទៅហើយ ក្នុងកាលនោះ ក្នុងក្រុងពារាណសីមានសេដ្ឋីបុត្រ ៤ នាក់ មានសម្បត្តិ ៤០ កោដិ ជាសម្លាញ់នឹងគ្នា សេដ្ឋីបុត្រទាំងនោះប្រឹក្សាគ្នាថា ក្នុងផ្ទះរបស់ពួកយើងមានទ្រព្យច្រើន ពួកយើងនឹងធ្វើអ្វីដោយទ្រព្យនោះ ។

កាលព្រះសម្ពុទ្ធមានសភាពបែបនោះ ទ្រង់ចារិកទៅ បណ្ដាសេដ្ឋីបុត្រទាំងនោះមិនបានពោលថា ពួកយើងនឹងថ្វាយទាន នឹងធ្វើការបូជា នឹងរក្សាសីល សេដ្ឋីបុត្រម្នាក់ពោលយ៉ាងនេះមុនថា ពួកយើងផឹកសុរាដែលចាស់ ទំពាស៊ីសាច់ដែលមានរសឆ្ងាញ់ នឹងត្រាច់ទៅ ជីវិតរបស់ពួកយើងនឹងមានផល ។

ម្នាក់ទៀត ពោលយ៉ាងនេះថា ពួកយើងនឹងបរិភោគភត្តនៃអង្ករស្រូវសាលី ដែលមានក្លិនក្រអូប ដែលទុកក្នុងជង្រុក ៣ ឆ្នាំ ដោយរសដ៏ប្រសើរផ្សេងៗ ត្រាច់ទៅ ។

ម្នាក់ទៀត ពោលយ៉ាងនេះថា ពួកយើងនឹងឲ្យគេចៀនរបស់គួរទំពាប្លែកៗ មានប្រការផ្សេងៗ ទំពាស៊ី ត្រាច់ទៅ ។

ម្នាក់ទៀត ពោលយ៉ាងនេះថា នៃសម្លាញ់ ពួកយើងមិនធ្វើកិច្ចណាមួយជាទៃឡើយ ស្រីទាំងឡាយ កាលយើងពោលថា នឹងឲ្យទ្រព្យ ឈ្មោះថាមិនប្រាថ្នា មិនមាន ព្រោះហេតុនោះ ពួកយើងប្រមូលទ្រព្យហើយ នឹងលួងលោមស្រីទាំងនោះ ធ្វើបរទារកម្ម គឺការប្រព្រឹត្តខុសក្នុងកិរិយារបស់អ្នកដទៃ ។

សេដ្ឋីបុត្រទាំងអស់ទទួលថា ល្អណាស់ បានតាំងនៅក្នុងពាក្យរបស់ជនទី ៤ នោះ ។ តាំងអំពីនោះមក សេដ្ឋីបុត្រទាំងនោះបញ្ជូនទ្រព្យទៅដើម្បីស្រីដែលមានរូបស្អាត ធ្វើបរទារកម្មអស់ ២ ម៉ឺនឆ្នាំ ធ្វើកាលកិរិយាហើយ កើតក្នុងអវីចិមហានរក ។

សេដ្ឋីបុត្រទាំងនោះ ឆេះហើយក្នុងនរកអស់មួយពុទ្ធន្តរ ធ្វើកាលកិរិយាក្នុងនរកនោះ ដោយសេសសល់ផលកម្ម ក៏កើតក្នុងលោហកុម្ភីនរក ដែលមានជម្រៅ ៦០ យោជន៍ លិចចុះទៅខាងក្រោម ៣ ម៉ឺនឆ្នាំ អណ្តែតមកលើដល់មាត់ឆ្នាំង ៣ ម៉ឺនឆ្នាំទៀត ជាអ្នកប្រាថ្នានឹងពោលគាថាមួយម្នាក់ មិនអាចពោលបាន ពោលបានតែមួយអក្ខរៈ ហើយក៏លិចចុះទៅកាន់បាតខ្ទះដូចមុនទៀត ។ មហាបពិត្រ សូមទ្រង់ប្រាប់ តើទ្រង់បានស្តាប់សំឡេងដូចម្តេច ជាដំបូង ។ ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ គឺសំឡេងថា ទុ ព្រះសាស្តាកាលទ្រង់សម្តែងគាថា ដែលសត្វនរកនោះពោលមិនពេញ ឲ្យពេញ ទើបត្រាស់យ៉ាងនេះថា

**ទុជ្ជីវិតមជីវម្ហា យេសន្តោ ន ទទម្ហសេ**
**សន្តេសុ ទេយ្យធម្មេសុ ទីបំ នាកម្ហ អត្តនោ ។**

*ពួកយើងរស់នៅដោយលំបាក ព្រោះទេយ្យធម៌មាន*

យើងមិនបានឲ្យ កាលទេយ្យធម៌មាន យើងមិនបាន

ធ្វើទីពឹងដល់ខ្លួនសោះ ។

លំដាប់នោះ ព្រះសាស្តាកាលទ្រង់ប្រកាសអត្ថនៃគាថានេះដល់ព្រះរាជាហើយ ទើបត្រាស់សួរថា មហាបពិត្រ សំឡេងទី ២ សំឡេងទី ៣ សំឡេងទី ៤ ទ្រង់បានឮដូចម្តេច កាលព្រះរាជាទូលថា គឺសំឡេងយ៉ាងនេះ ព្រះអង្គ កាលទ្រង់ញុំាងអត្ថដ៏សេសឲ្យបរិបូណ៌ ទើបត្រាស់ថា

**សដ្ឋីវស្សសហស្សានិ បរិបុណ្ណានិ សព្វសោ**

**និរយេ បច្ចមានានំ កទា អន្តោ ភវិស្សតិ។**

ពួកយើងឆេះនៅក្នុងនរកពេញ ប្រាំមួយម៉ឺន

( ៦០០០០ ) ឆ្នាំគ្រាប់គ្រាន់ តើទីបំផុតនឹង

មានក្នុងវេលាណា ។

**នត្ថិ អន្តោ កុតោ អន្តោ ន អន្តោ បដិទិស្សតិ**

**តថា ហិ បកតំ បាបំ មម តុយ្ហញ្ច មារិស។**

ពួកយើងមិនមានទីបំផុតទេ ពួកយើងនឹងមានទីបំផុត

មកពីណា ទីបំផុត នឹងមិនប្រាកដដល់យើងឡើយ

ម្នាលអ្នក ព្រោះតែខ្ញុំក្តី អ្នកក្តី បានធ្វើបាប ។

**សោហំ នូន ឥតោ គន្ត្វា យោនឹ លទ្ធាន មានុសឹ**

**វទញ្ញូ សីលសម្បន្នោ កាហាមិ កុសលំ ពហុំ្ត។**

ប្រសិនបើខ្ញុំ បានរដោះរួចចាកនរកនេះទៅ បានកើត

ជាមនុស្ស សូមជាអ្នកបរិបូណ៌ដោយសីលធ្វើកុសល
ឲ្យច្រើន អំពីកាលដ៏ឯក្តីទៅ ។

ព្រះសាស្តា កាលត្រាស់គាថាទាំងនេះដោយលំដាប់ ប្រកាសអត្ថហើយ ទើបត្រាស់ថា មហាបពិត្រ ជនទាំង ៤ នោះប្រាថ្នានឹងពោលគាថា ម្នាក់មួយគាថា កាលមិនអាចពោលបាន ពោលត្រឹមតែមួយអក្ខរៈប៉ុណ្ណោះ នឹងចុះទៅកាន់លោហកុម្ភីនោះឯងទៀត ដោយប្រការដូច្នេះឯង ។

បានឮថា ចាប់តាំងអំពីកាលនៃសំឡេងនោះ ដែលព្រះបាទបសេនទិកោសលទ្រង់ឮហើយ ជនទាំងនោះលិចចុះទៅខាងក្រោមដូចមុន សូម្បីមកទល់ថ្ងៃនេះ ក៏មិនទាន់កន្លងដល់មួយពាន់ឆ្នាំ ការសង្វេគជំកើតឡើងដល់ព្រះរាជា ព្រោះទ្រង់ស្តាប់ទេសនានោះ ។ ព្រះរាជាទ្រង់ត្រិះរិះថា ឈ្មោះថាបរទារកម្មនេះ ធ្ងន់ហ្ន៎ បានឮថា ជនទាំង ៤ ឆេះហើយក្នុងអវិចីនរកអស់មួយពុទ្ធន្តរ ចុតិអំពីអវិចីនរកនោះហើយ កើតក្នុងលោហកុម្ភីដែលមានជម្រៅ ៦០ យោជន៍ ឆេះហើយក្នុងលោហកុម្ភីនោះអស់ ៦ ម៉ឺនឆ្នាំយ៉ាងនេះ កាលជាទីផុតទុក្ខរបស់ជនទាំងនោះមិនប្រាកដ ឯអញធ្វើនូវការជាប់ជំពាក់ក្នុងកិរិយារបស់បុរសដទៃ មិនបានដេកលក់អស់មួយយប់ ឥឡូវនេះ តាំងអំពីនេះទៅ អញនឹងមិនចងការពេញចិត្ត ក្នុងកិរិយារបស់បុរសដទៃ ទើបក្រាបទូលព្រះតថាគតថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជ្រាបភាពដែលរាត្រីយូរ ក្នុងថ្ងៃនេះ ។

ចំណែកបុរសនោះ អង្គុយក្នុងទីនោះឯង ស្តាប់ពាក្យនោះហើយ គិតថា

បច្ច័យមានកម្លាំងអញបានហើយ ទើបក្រាបទូលព្រះសាស្ដាថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះរាជាទ្រង់ជ្រាបភាពដែលរាត្រីយូរក្នុងថ្ងៃនេះ ចំណែកខ្ញុំព្រះអង្គបានជ្រាបភាពនៃយោជន៍ឆ្ងាយក្នុងកាលម្សិលមិញ ។

ព្រះសាស្ដាទ្រង់ប្រៀបធៀបពាក្យសម្ដីរបស់ជនទាំងពីរហើយ ត្រាស់ថា រាត្រីរបស់បុគ្គលពួកខ្លះរមែងយូរ យោជន៍របស់បុគ្គលពួកខ្លះឆ្ងាយ ចំណែកសង្សាររបស់បុគ្គលពាល រមែងជាសភាវៈវែង កាលទ្រង់សម្ដែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**ទីឃា ជាគរតោ រត្តិ ទីឃំ សន្តស្ស យោជនំ**
**ទីឃោ ពាលាន សំសារោ សទ្ធម្មំ អវិជានតំ ។**

*រាត្រីវែង ចំពោះតែអ្នកភ្ញាក់រឭក ( អ្នកដេកមិនលក់ )*
*យោជន៍វែង ចំពោះតែអ្នកនឿយហត់ សង្សារវដ្ដវែង*
*ចំពោះតែបុគ្គលពាលមិនដឹងច្បាស់នូវព្រះសទ្ធម្ម ។*

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **ទីឃា** ជាដើម សេចក្ដីថា ឈ្មោះថា រាត្រីនេះមានត្រឹម ៣ យាមប៉ុណ្ណោះ តែសម្រាប់បុគ្គលភ្ញាក់ រាត្រីនៅយូរ គឺរមែងប្រាកដហាក់បីដូច ២-៣ ដង បុគ្គលអ្នកខ្ជិលច្រអូសច្រើន ធ្វើខ្លួនឲ្យជាចំណីរបស់សង្កើច ដេកបម្រះនទៀលរហូតព្រះអាទិត្យរះឡើងក្ដី បុគ្គលសេពកាមបរិភោគភោជនដែលល្អហើយ ដេកនៅលើគ្រែដែលជាសិរីក្ដី រមែងមិនដឹងភាពដែលរាត្រីនោះយូរ ចំណែកព្រះយោគាវចរ ដែលជាអ្នកតម្កល់នូវសេចក្ដី

ព្យាយាមមួយយប់ទល់ភ្លឺក្តី ព្រះធម្មកថិក សម្តែងព្រះធម្មកថាមួយយប់ទល់ភ្លឺក្តី បុគ្គលអង្គុយស្តាប់ធម៌ក្នុងទីជិតអាសនៈមួយយប់ទល់ភ្លឺក្តី ដែលត្រូវរោគទាំងឡាយ មានរោគក្បាលជាដើមពាល់ត្រូវហើយ ឬដល់នូវសេចក្តីទុក្ខ មានការកាត់ដៃ និងជើងជាដើម ត្រូវវេទនាគ្របសង្កត់ក្តី អ្នកដើរផ្លូវឆ្ងាយ ដើរផ្លូវ អស់មួយយប់ក្តី រមែងដឹងភាពដែលរាត្រីនោះយូរ ។

បទថា **យោជនំ** ជាដើម សេចក្តីថា ១ យោជន៍មានត្រឹម ៤ គាវុតប៉ុណ្ណោះ ។ សម្រាប់បុគ្គលដែលអស់កម្លាំងហើយ ដែលទន់ខ្សោយហើយនៅឆ្ងាយ គឺរមែងប្រាកដហាក់បីដូច ២-៣ ដង ។ ពិតហើយ អ្នកដើរអស់ ១ ថ្ងៃ នឿយហត់ហើយ ជួបអ្នកធ្វើដំណើរមកសួរថា ស្រុកខាងមុខនៅឆ្ងាយប៉ុនណា កាលគេឆ្លើយថា ចម្ងាយមួយយោជន៍ ទៅបានបន្តិច ក៏សួរមនុស្សដទៃទៀត កាលមនុស្សនោះប្រាប់ថា មួយយោជន៍ ទៅបន្តិចក៏សួរទៀត សូម្បីអ្នកដទៃទៀត គេក៏ពោលថា មួយយោជន៍ ជនទាំងនោះត្រូវអ្នកដំណើរនោះសួរហើយ ក៏ប្រាប់ថា មួយយោជន៍ បុរសនោះគិតថា យោជន៍នេះឆ្ងាយពិតហ្ន៎ រមែងសម្គាល់មួយយោជន៍ហាក់បីដូច ២-៣ យោជន៍ ។

បទថា **ពាលានំ** ជាដើម សេចក្តីថា ចំណែកសង្សាររបស់ជនពាលទាំងឡាយ ដែលមិនដឹងប្រយោជន៍ក្នុងលោកនេះ និងប្រយោជន៍ក្នុងលោកខាងមុខ គឺមិនអាចធ្វើទីបំផុតនៃសង្សារវដ្ត ដែលមិនដឹងច្បាស់នូវព្រះសទ្ធម្ម មានពោធិបក្ខិយធម៌ ៣៧ ប្រការជាដើម ដែលព្រះអរិយៈទាំងឡាយដឹងហើយ ធ្វើទីបំផុតនៃសង្សារបាន ឈ្មោះថា វែង ។ ពិតហើយ សង្សារនោះ ឈ្មោះថា

វែង តាមធម្មតារបស់ខ្លួនឯង ។ សមដូចព្រះពុទ្ធវចនៈដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សង្សារនេះមានទីបំផុត ដែលបុគ្គលដឹងមិនបានខាងដើម និងខាងចុង រមែងមិនប្រាកដ ។ តែសម្រាប់ជនពាលទាំងឡាយ បុគ្គលមិនអាចនឹងធ្វើទីបំផុតបាន រមែងវែងនោះឯង ។

ក្នុងកាលចប់ទេសនា បុរសនោះសម្រេចសោតាបត្តិផលហើយ ជនដទៃជាច្រើន សម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ទេសនាមានប្រយោជន៍ដល់មហាជនហើយ ដូច្នេះឯង ។

ព្រះរាជាថ្វាយបង្គំព្រះសាស្តាហើយ កំពុងយាងទៅ ទ្រង់បញ្ជាឲ្យលែងសត្វទាំងនោះចាកចំណងហើយ ។ បណ្តាមនុស្ស និងសត្វទាំងនោះ ស្រី និងបុរសទាំងឡាយផុតចាកចំណង យកទឹកលាបក្បាលហើយ ទៅកាន់ផ្ទះរៀងៗខ្លួន ពោលសរសើរគុណព្រះនាងមល្លិកាថា យើងទាំងឡាយបានជីវិត ព្រោះអាស្រ័យព្រះទេវីអង្គណា សូមព្រះនាងមល្លិកាទេវីអង្គនោះ ដែលជាម្តាយរបស់យើងទាំងឡាយ សូមព្រះនាងគង់ព្រះជន្មអស់កាលយូរហោង ។

ក្នុងពេលល្ងាច ភិក្ខុទាំងឡាយសន្ទនាក្នុងរោងធម្មសភាថា គួរសរសើរព្រះនាងមល្លិកានេះឈ្លាសវៃហ្ន៎ ព្រះនាងអាស្រ័យបញ្ញារបស់ព្រះនាង បានឲ្យជីវិតទានដល់ជនមានប្រមាណប៉ុណ្ណោះហើយ ។

ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយពាក្យដូចម្តេចហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា ដោយពាក្យឈ្មោះនេះ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំង-

ឡាយ ព្រះនាងមល្លិកាអាស្រ័យបញ្ញារបស់ខ្លួន ឲ្យជីវិតដល់មហាជនក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ព្រះនាងក៏បានឲ្យហើយដូចគ្នា កាលទ្រង់ប្រកាសសេចក្ដីនេះ ទើបទ្រង់នាំអតីតនិទានមកត្រាស់ថា

ក្នុងអតីតកាល ឱរសរបស់ព្រះបាទពារាណសី ចូលទៅកាន់ដើមជ្រៃមួយហើយ ទ្រង់បន់ស្រន់ទេវតាដែលកើតត្រង់ដើមជ្រៃនោះថា បពិត្រទេវរាជ ក្នុងជម្ពូទ្វីបនេះ មានព្រះរាជា ១០១ និងអគ្គមហេសី ១០១ បើខ្ញុំនឹងបានរាជ-សម្បត្តិ ដោយកាលកន្លងទៅនៃបិតាសោត ខ្ញុំនឹងធ្វើពលីដោយឈាម ក្នុងបំពង់ករបស់ស្ដេច និងអគ្គមហេសីទាំងនោះ ។ រាជកុមារនោះ កាលព្រះបិតាសោយទិវង្គតហើយ បានទទួលរាជសម្បត្តិ ទ្រង់ក៏គិតថា អញបានទទួលរាជសម្បត្តិដោយអានុភាពរបស់ទេវតា អញនឹងធ្វើពលីដល់ទេវតានោះ ទើបយាងចេញទៅដោយសេនាធំ ញុំាងព្រះរាជាមួយអង្គឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួនហើយ ធ្វើព្រះរាជាអង្គដទៃ និងដទៃទៀត មួយអន្លើដោយព្រះរាជាអង្គនោះ ឲ្យនៅក្នុងអំណាចរបស់ខ្លួន ធ្វើព្រះរាជាទាំងអស់ឲ្យនៅក្នុងអំណាចរបស់ខ្លួន ដោយប្រការដូច្នេះ ហើយទ្រង់នាំទៅ មួយអន្លើដោយព្រះអគ្គ-មហេសីទាំងឡាយ ទ្រង់ដោះលែងព្រះនាងធម្មទិន្នា ដែលទ្រង់ព្រះគភ៌គ្រប់ខែដែលជាអគ្គមហេសីរបស់ព្រះរាជា ព្រះនាមថា ឧគ្គសេន ដែលជាព្រះរាជាដែលតូចជាង ព្រះរាជាទាំងពួងយាងទៅ ទ្រង់ព្រះតម្រិះថា អញនឹងឲ្យជនទាំងនេះផឹកថ្នាំពិសឲ្យស្លាប់ ទើបឲ្យជនទាំងឡាយ ជម្រះគល់ជ្រៃឲ្យស្អាតហើយ ។

ទេវតាគិតថា ព្រះរាជាអង្គនេះ កាលចាប់ព្រះរាជាប្រមាណប៉ុណ្ណេះ ទ្រង់អាស្រ័យអញ ទើបចាប់ ព្រះរាជាទ្រង់ប្រាថ្នាធ្វើពលីកម្មដល់អញ ដោយឈាមក្នុងបំពង់ករបស់ព្រះរាជាទាំងនោះ បើព្រះរាជានេះទ្រង់សម្រេចទោសព្រះរាជាទាំងនោះសោត ព្រះរាជវង្សក្នុងជម្ពូទ្វីបនឹងដាច់សូន្យ សូម្បីគល់ឈើរបស់អញក៏មិនស្អាត អញអាចឃាត់ព្រះរាជានោះបានដែរឬទេហ្ន៎ ទេវតានោះពិចារណា ក៏ដឹងថា អាត្មាអញមិនអាចឡើយ ទើបចូលទៅរកទេវតាអន្ដដទៃ ប្រាប់សេចក្តីនោះហើយ ពោលថា អ្នកអាចឬ ទេវតានោះ កាលទេវតានោះឃាត់ហើយ ទើបចូលទៅរកទេវតាក្នុងចក្រវាលទាំងមូលយ៉ាងនេះ គឺចូលទៅរកទេវតាអន្ដដទៃ និងអន្ដដទៃ សូម្បីត្រូវទេវតាទាំងនោះឃាត់ហើយ ទើបទៅកាន់សម្នាក់របស់មហារាជទាំង ៤ ក្នុងកាលដែលមហារាជទាំង ៤ នោះឃាត់ហើយដោយពាក្យថា ពួកខ្ញុំមិនអាច តែព្រះរាជារបស់យើងទាំងឡាយ ជាបុគ្គលវិសេសជាងពួកយើងដោយបុណ្យ និងបញ្ញា ចូរអ្នកទូលសួរព្រះរាជានោះចុះ ដូច្នេះហើយ ទើបចូលទៅគាល់សក្កទេវរាជ ក្រាបទូលសេចក្តីនោះហើយ ដោយពាក្យថា បពិត្រតេជះ កាលទ្រង់ដល់នូវការខ្វល់ខ្វាយតិច ខត្តិយវង្សនឹងដាច់សូន្យ សូមទ្រង់ជាទីពឹងពុំនាក់នៃវង្សស្ដេចទាំងនោះចុះ ។

សក្កទេវរាជត្រាស់ថា សូម្បីខ្ញុំក៏មិនអាចឃាត់ព្រះរាជានោះ តែខ្ញុំប្រាប់ឧបាយដល់អ្នក ហើយទ្រង់ប្រាប់ឧបាយថា ទៅចុះអ្នក កាលព្រះរាជាទ្រង់ឃើញនោះឯង អ្នកចូរស្លៀកសំពត់ក្រហម សម្ដែងអាការដូចជាចេញអំពីដើមឈើ

របស់ខ្លួន កាលបើដូច្នោះ ព្រះរាជាទ្រង់ត្រិះរិះថា ទេវតារបស់អញកំពុងទៅអញនឹងឲ្យទេវតានោះត្រឡប់មក ហើយនឹងអង្វរដោយប្រការផ្សេងៗ កាលបើដូច្នោះ អ្នកគប្បីពោលនឹងព្រះរាជានោះថា អ្នកប្រាប់យើងថា នឹងនាំព្រះរាជា ១០១ មួយអន្ទើដោយអគ្គមហេសីទាំងឡាយ ធ្វើពលីដោយឈាមក្នុងបំពង់ករបស់ព្រះរាជាទាំងនោះ ទ្រង់លះបង់ព្រះទេវីរបស់ឧគ្គសេន ហើយយាងមក ខ្ញុំមិនទទួលពលីរបស់អ្នកពោលកុហកដូចទ្រង់ឡើយ ដ្បិតថា កាលបើអ្នកពោលយ៉ាងនេះ ព្រះរាជានឹងនាំព្រះទេវីនោះមក ព្រះទេវីនោះនឹងសម្តែងធម៌ដល់ព្រះរាជា ឲ្យជីវិតទានដល់ជនមានប្រមាណប៉ុណ្ណោះ ។ សក្កទេវរាជប្រាប់ឧបាយនេះដល់ទេវតាដោយហេតុនេះ ទេវតាបានធ្វើតាមនោះហើយ សូម្បីព្រះរាជា ក៏បញ្ជាឲ្យនាំព្រះទេវីនោះមកហើយ ។

ព្រះទេវីនោះ មកថ្វាយបង្គំព្រះរាជាជាស្វាមីរបស់ខ្លួនប៉ុណ្ណោះ ហើយប្រថាប់គង់ក្នុងទីបំផុតនៃព្រះរាជាទាំងនោះ ព្រះរាជាពិរោធចំពោះព្រះទេវីនោះថា កាលអញតាំងនៅក្នុងតំណែងជាធំជាងព្រះរាជាទាំងពួង នាងនៅតែថ្វាយបង្គំប្តីរបស់ខ្លួន ដែលជាអ្នកតូចតាចជាងព្រះរាជាទាំងពួង ។ លំដាប់នោះ ព្រះទេវីទូលព្រះរាជានោះថា រឿងអ្វីរបស់ខ្ញុំម្ចាស់ត្រូវទាក់ទងក្នុងព្រះអង្គ ព្រះរាជាអង្គនេះ ជាស្វាមីឲ្យនូវភាពជាធំដល់ខ្ញុំម្ចាស់ ខ្ញុំម្ចាស់មិនថ្វាយបង្គំព្រះរាជាអង្គនេះហើយ នឹងថ្វាយបង្គំព្រះអង្គព្រោះហេតុអ្វី កាលជនទាំងនោះកំពុងឃើញនុ៎ះឯង រុក្ខទេវតាពោលថា យ៉ាងនោះឯងព្រះទេវីដ៏ចម្រើន យ៉ាងនោះឯងព្រះទេវីដ៏ចម្រើន ហើយបូជាព្រះទេវីនោះដោយផ្កាមួយក្តាប់ ។

ព្រះរាជាត្រាស់ថា បើនាងមិនថ្វាយបង្គំយើងសោត ព្រោះហេតុអ្វី ទើបមិនថ្វាយបង្គំទេវតារបស់យើង ដែលមានអានុភាពច្រើនយ៉ាងនេះ ជាអ្នកឲ្យនូវសិរីនៃភាពជាព្រះរាជា ។ ព្រះទេវីទូលថា បពិត្រមហារាជ ព្រះរាជាទាំងឡាយ ដែលទ្រង់តាំងនៅក្នុងបុណ្យរបស់ខ្លួន ទើបចាប់បាន មិនមែនទេវតាចាប់ថ្វាយឡើយ ។ ទេវតាពោលនឹងព្រះទេវីទៀតថា យ៉ាងនោះឯង ព្រះទេវីដ៏ចម្រើន យ៉ាងនោះឯងព្រះទេវីដ៏ចម្រើន ហើយបូជាយ៉ាងនោះទៀត ។

ព្រះទេវីនោះ ទូលព្រះរាជាទៀតថា ទ្រង់ត្រាស់ថា ព្រះរាជាទាំងឡាយមានប្រមាណប៉ុណ្ណោះ ទេវតាចាប់ឲ្យដល់យើង ឥឡូវនេះដើមជ្រៃត្រូវភ្លើងឆេះខាងត្បូងនៃចំណែកខាងលើរបស់ទេវតារបស់ទ្រង់ ព្រោះហេតុអ្វី ទើបទេវតានោះមិនអាចញ៉ាំងភ្លើងនោះឲ្យរលត់បាន បើទេវតាមានអានុភាពច្រើនយ៉ាងនោះ ។ ទេវតាពោលនឹងព្រះទេវីទៀតថា យ៉ាងនោះឯង ព្រះទេវីដ៏ចម្រើន យ៉ាងនោះឯង ព្រះទេវីដ៏ចម្រើន ហើយបូជាយ៉ាងនោះទៀត ។

ព្រះទេវីឈរទ្រង់ព្រះកន្សែងផង ទ្រង់សើចផង ។ លំដាប់នោះ ព្រះរាជាត្រាស់នឹងព្រះទេវីនោះថា នាងឆ្កួតហើយឬ ព្រះទេវីត្រាស់ថា ព្រោះហេតុអ្វី ទើបទ្រង់ត្រាស់យ៉ាងនោះ ស្រីទាំងឡាយដូចខ្ញុំម្ចាស់ មិនមែនឆ្កួតឡើយ ព្រះរាជាត្រាស់ថា កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបនាងយំហើយសើច ព្រះទេវីទូលថា សូមទ្រង់ស្តាប់ចុះមហារាជ ក្នុងអតីតកាល ខ្ញុំជាកុលធីតា កាលនៅក្នុងត្រកូលប្តី ឃើញភ្ញៀវជាសម្លាញ់របស់ប្តីមកហើយ ប្រាថ្នានឹងធាំស្លដើម្បីភ្ញៀវនោះ ទើបឲ្យកហាបណៈដល់ទាសីដោយប្រាប់ថា ចូរនាង

វិញសាច់មក ទាសីនោះមិនបានសាច់មកហើយពោលថា សាច់មិនមាន ទើបកាត់ក្បាលមេពពែដែលដេកខាងក្រោយផ្ទះ ចាត់ចែងកត្តស្រេច ខ្ញុំនោះឯងកាត់ក្បាលមេពពែមួយក្បាល ឆេះក្នុងនរក ដោយសេសសល់ផលកម្ម ទើបត្រូវគេកាត់ក្បាលអំបាលរាប់ដោយរោមពពែនោះ ទ្រង់សម្រេចទោសជនមានប្រមាណប៉ុណ្ណោះ កាលណានឹងផុតទុក្ខ ខ្ញុំរឭកដល់ទុក្ខដ៏ធំរបស់ព្រះអង្គ ដូច្នេះទើបខ្ញុំយំ ដូច្នេះហើយ ទើបត្រាស់គាថានេះថា

ខ្ញុំកាត់ក្បាលពពែមួយ ឆេះហើយក្នុងនរកដោយការរាប់រោមពពែ
បពិត្រព្រះអង្គដ៏ជាក្សត្រ ទ្រង់កាត់ក្បាលរបស់មនុស្សដ៏ច្រើន
នឹងធ្វើដូចម្តេច ។

ព្រះរាជាត្រាស់ថា បើដូច្នោះ នាងសើចព្រោះហេតុអ្វី ព្រះទេវីត្រាស់ថា បពិត្រមហារាជ ខ្ញុំម្ចាស់ត្រេកអរថា អញនឹងផុតទុក្ខនោះហើយទើបសើច ។

ទេវតាពោលនឹងព្រះទេវីនោះទៀតថា យ៉ាងនោះឯង ព្រះទេវីដ៏ចម្រើន យ៉ាងនោះឯង ព្រះទេវីដ៏ចម្រើន ហើយបូជាផ្កាមួយក្តាប់ ។

ព្រះរាជាទ្រង់ព្រះតម្រិះថា គួរសង្វេគ កម្មរបស់អញធ្ងន់ហ្ន៎ បានឮថា ព្រះទេវីនេះសម្លាប់មេពពែមួយ ឆេះក្នុងនរកហើយ ដោយសេសសល់ផលកម្មត្រូវគេកាត់ក្បាលអំបាលស្មើនឹងរោមពពែនោះ អញសម្លាប់ជនមានប្រមាណប៉ុណ្ណោះ នឹងដល់នូវសួស្តីក្នុងកាលណា ដូច្នេះហើយ ទ្រង់ដោះលែងព្រះរាជាទាំងអស់ ថ្វាយបង្គំព្រះរាជាដែលចាស់ជាង ទ្រង់ផ្គងអញ្ជលីដល់ព្រះរាជាដែលក្មេងជាង ញ៉ាំងព្រះរាជាទាំងអស់ឲ្យអត់ទោស ហើយទ្រង់បញ្ជូនទៅកាន់

ទីលំនៅរបស់ខ្លួន ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយត្រាស់ថា យ៉ាងនោះឯងភិក្ខុទាំងឡាយ ព្រះនាងមល្លិកាអាស្រ័យបញ្ញារបស់ខ្លួន ឲ្យនូវជីវិតទានដល់មហាជន ក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុនព្រះនាងក៏បានប្រទានហើយដូចគ្នា ហើយទ្រង់ប្រជុំរឿងអតីតថា ព្រះបាទពារាណសីក្នុងកាលនោះ បានជាព្រះបាទបសេនទិកោសល ព្រះនាងធម្មទិន្នាទេវី បានជាព្រះនាងមល្លិកា រុក្ខទេវតា គឺតថាគតនេះឯង ។ កាលទ្រង់ប្រជុំអតីតនិទានយ៉ាងនោះហើយ កាលទ្រង់សម្តែងធម៌ទៀត ទើបត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ ឈ្មោះថា បាណាតិបាត ជាទោស មិនសមគួរដែលបុគ្គលគប្បីធ្វើ ព្រោះថា បុគ្គលអ្នកសម្លាប់សត្វជាប្រក្រតី រមែងសោយសោកអស់កាលយូរ ទើបត្រាស់ព្រះគាថានេះថា

បើសត្វទាំងឡាយគប្បីដឹងយ៉ាងនេះថា ជាតិសម្ភវៈនេះ ជាទុក្ខ សត្វមិនគប្បីសម្លាប់សត្វឡើយ ព្រោះថា អ្នកសម្លាប់សត្វជាប្រក្រតី រមែងសោយសោក ។៚

**រឿង អញ្ញតរបុរស ចប់**

# រឿង សទ្ធិវិហារិករបស់ព្រះមហាកស្សបត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធសទ្ធិវិហារិករបស់ព្រះមហាកស្សបៈ ត្រាស់ព្រះធម្មទេសនានេះថា **ចរញ្ចេ នាធិគច្ឆេយ្យ** ជាដើម ។

ទេសនាតាំងឡើងនៅក្នុងក្រុងរាជគ្រឹះ ។ បានឮថា សទ្ធិវិហារិកពីររូបឧបដ្ឋាកព្រះថេរៈ ដែលអាស្រ័យក្រុងរាជគ្រឹះ ក្នុងបិប្ផលិគុហា ។ បណ្តាភិក្ខុពីររូបនោះ មួយរូបធ្វើវត្តដោយគោរព មួយរូបសម្តែងវត្តដែលភិក្ខុនោះធ្វើហើយដូចខ្លួនធ្វើ ដឹងភាពដែលទឹកលប់មុខ និងឈើស្ទន់ដែលភិក្ខុនោះចាត់ចែងហើយ ទើបសួរព្រះថេរៈថា ទឹកលប់មុខ និងឈើស្ទន់ ខ្ញុំចាត់ចែងហើយ សូមលោកម្ចាស់ប្រើប្រាស់ចុះ ។ សូម្បីក្នុងការធ្វើកិច្ច មានការលាងជើង និងស្រង់ទឹកជាដើម ក៏រមែងប្រាប់យ៉ាងនោះដូចគ្នា ។

ភិក្ខុក្រៅអំពីនេះគិតថា ភិក្ខុនេះបង្ហាញវត្តដែលអញធ្វើហើយ ហាក់ដូចជាខ្លួនធ្វើហើយអស់កាលជានិច្ច ណ្ហើយចុះ សេចក្តីនេះអញនឹងធ្វើវត្តដែលគួរធ្វើដល់លោក ។ កាលភិក្ខុនោះឆាន់ហើយសិងលក់នោះឯង ដាំទឹកងូតហើយដួសដាក់ក្នុងឆ្នាំងមួយ តាំងទុកខាងក្រោយទីសម្រាប់ងូត តែបន្សល់ទឹកទុកក្នុងភាជនៈដែលដាំនោះ ប្រមាណមួយត្រឡោក ហើយទុកឲ្យផុតចំហាយ ។

ក្នុងវេលាល្ងាច ភិក្ខុមួយទៀតភ្ញាក់ឡើង ឃើញចំហាយទឹកហុយចេញ គិតថា នឹងជាទឹកដែលភិក្ខុនោះដាំហើយតម្កល់ទុកក្នុងទីសម្រាប់ងូត រួតរះទៅថ្វាយបង្គំព្រះថេរៈហើយប្រាប់ថា ទឹកខ្ញុំតម្កល់ទុកក្នុងទីសម្រាប់ងូត សូមលោក

ម្ចាស់ស្រង់ចុះ ហើយចូលទៅកាន់ទីសម្រាប់ផ្ទុតជាមួយព្រះថេរៈ ព្រះថេរៈ កាលមិនឃើញទឹក ទើបពោលថា នែលោក ទឹកនៅឯណា ភិក្ខុកំលោះទៅកាន់រោងភ្លើង លូកត្រឡោកចូលក្នុងកាជនៈ ដឹងភាពដែលកាជនៈទទេ ទើបពោលទោសថា សូមលោកម្ចាស់មើលកម្មរបស់ភិក្ខុក្បាលរឹង លោកលើកកាជនៈទទេដាក់លើចង្ក្រាន ហើយទៅបាត់ ខ្ញុំប្រាប់ដោយស្មានថាទឹកមានក្នុងទីសម្រាប់ផ្ទុត ដូច្នេះហើយ បានកាន់យកផ្តាំងទៅកាន់កំពង់ទឹក ។

ចំណែកភិក្ខុក្រៅអំពីនេះ នាំយកទឹកខាងក្រោយទីសម្រាប់ផ្ទុត ហើយតាំងទុកក្នុងទីសម្រាប់ផ្ទុត ។ ព្រះថេរៈគិតថា ភិក្ខុកំលោះរូបនេះពោលថា ទឹកខ្ញុំដាំតម្កល់ទុកក្នុងទីសម្រាប់ផ្ទុតហើយ សូមលោកម្ចាស់ស្រង់ចុះ ឥឡូវនេះពោលទោស កាន់យកផ្តាំងទទេទៅកាន់កំពង់ទឹក ហេតុនេះដូចម្តេចហ្ន៎ ពិចារណាមើល ក៏ដឹងថា ភិក្ខុកំលោះរូបនោះ ប្រកាសកិច្ចវត្តដែលភិក្ខុនេះធ្វើហើយ ហាក់ដូចជាខ្លួនធ្វើហើយអស់កាលប៉ុណ្ណេះ បានឲ្យឱវាទដល់លោកដែលមកអង្គុយក្នុងពេលល្ងាចថា លោក ឈ្មោះថាភិក្ខុពោលកិច្ចដែលខ្លួនធ្វើហើយនោះឯងថា ខ្ញុំធ្វើហើយរមែងគួរ នឹងពោលកិច្ចដែលខ្លួនមិនបានធ្វើថាជាកិច្ចដែលខ្លួនធ្វើហើយ មិនគួរឡើយ ឥឡូវនេះ អ្នកពោលថា ទឹកខ្ញុំតម្កល់ទុកក្នុងទីសម្រាប់ផ្ទុត សូមលោកម្ចាស់ស្រង់ចុះ កាលខ្ញុំទៅឈរកាន់ផ្តាំងទឹកពោលទោសអ្នកដទៃ ឈ្មោះថា បព្វជិតធ្វើយ៉ាងនោះ រមែងមិនគួរ ។

ភិក្ខុនោះពោលថា លោកទាំងឡាយ ចូរលោកមើលកម្មរបស់ព្រះថេរៈ ព្រះថេរៈអាស្រ័យហេតុត្រឹមតែទឹក ទើបពោលនឹងខ្ញុំយ៉ាងនេះ ក្រោធហើយ

ក្នុងថ្ងៃស្អែកឡើង មិនចូលទៅបិណ្ឌបាតជាមួយព្រះថេរៈ ។ ព្រះថេរៈទៅកាន់ប្រទេសមួយកន្លែងជាមួយភិក្ខុក្រៅអំពីនេះ ។ កាលព្រះថេរៈទៅហើយ ភិក្ខុនោះទៅកាន់ត្រកូលឧបដ្ឋាករបស់ព្រះថេរៈ ត្រូវឧបដ្ឋាកសួរថា ព្រះថេរៈនិមន្តទៅណា ទើបភិក្ខុនោះប្រាប់ថា ការមិនផាសុកកើតដល់ព្រះថេរៈ លោកគង់ក្នុងវិហារនោះឯង ។ ឧបដ្ឋាកពោលថា បានអ្វីប្រគេនលោក ទើបសមគួរ ភិក្ខុនោះពោលថា អ្នកទាំងឡាយ ចូរឲ្យអាហារឈ្មោះនេះ ។

ឧបដ្ឋាកទាំងឡាយ បានចាត់ចែងតាមទំនង ដែលភិក្ខុពោលនោះឯងប្រគេនហើយ ។ ភិក្ខុនោះ ឆាន់អាហារនោះតាមផ្លូវទៅកាន់វិហារហើយ ។

ចំណែកព្រះថេរៈ បានសំពត់សាច់ល្អិតមួយផ្ទាំងធំក្នុងទីដែលទៅហើយ ក៏បានឲ្យដល់ភិក្ខុកំលោះ ដែលទៅជាមួយលោក ។ ភិក្ខុកំលោះនោះ ជ្រលក់សំពត់នោះហើយ បានធ្វើជាសំពត់សម្រាប់ដណ្តប់របស់ខ្លួន ។ ក្នុងថ្ងៃស្អែកឡើង ព្រះថេរៈទៅកាន់ត្រកូលឧបដ្ឋាកនោះ ។ កាលពួកឧបដ្ឋាកពោលថា បពិត្រលោកម្ចាស់ ពួកខ្ញុំបានឮថា ការមិនផាសុកកើតដល់លោកម្ចាស់ ទើបរៀបចំអាហារផ្ញើទៅ ដោយទំនងដែលភិក្ខុកំលោះពោលហើយនោះឯង ផាសុកកើតដល់លោកម្ចាស់ ព្រោះឆាន់ហើយឬ ព្រះថេរៈក៏ស្ងៀមនៅ ហើយនិមន្តទៅកាន់វិហារ ពោលនឹងភិក្ខុកំលោះនោះ ដែលថ្វាយបង្គំហើយ អង្គុយក្នុងពេលល្ងាចយ៉ាងនេះថា នែលោក បានឮថា ម្សិលមិញនេះ លោកធ្វើកម្មឈ្មោះនេះ កម្មនេះ មិនសមគួរដល់បព្វជិតទាំងឡាយ បព្វជិតធ្វើវិញ្ញត្តិហើយឆាន់ រមែងមិនគួរ ។

ភិក្ខុនោះក្រោធហើយ ចងអាឃាតក្នុងព្រះថេរៈថា ថ្ងៃមុនព្រះថេរៈអាស្រ័យហេតុត្រឹមតែទឹក ធ្វើអញឲ្យជាមនុស្សនិយាយកុហក ក្នុងថ្ងៃនេះ ព្រោះអញបរិភោគភត្តមួយក្តាប់ក្នុងត្រកូលរបស់ខ្ចួន ទើបពោលនឹងអញថា បព្វជិតធ្វើវិញ្ញត្តិបរិភោគមិនគួរ ឯសំពត់ លោកក៏ឲ្យដល់ភិក្ខុដែលបម្រើលោកប៉ុណ្ណោះ ឱ កម្មរបស់ព្រះថេរៈធ្ងន់ អញនឹងដឹងវត្តដែលគួរធ្វើដល់ព្រះថេរៈនោះ ក្នុងថ្ងៃស្អែកឡើង កាលព្រះថេរៈចូលទៅកាន់ស្រុក ខ្ចួនលោកស្នាក់នៅក្នុងវិហារ ចាប់ដំបងវាយវត្ថុទាំងឡាយ មានភាជនៈសម្រាប់ប្រើប្រាស់ជាដើម ហើយដុតភ្លើងត្រង់បណ្ណសាលារបស់ព្រះថេរៈ វត្ថុណាភ្លើងមិនឆេះ យកដំបងវាយបំបែកវត្ថុនោះ ហើយចៀសចេញទៅ ធ្វើកាលកិរិយាហើយកើតក្នុងអវីចិមហានរក ។ មហាជនលើករឿងសន្ទនាគ្នាថា បានឮថា សទ្ធិវិហារិករបស់ព្រះថេរៈ មិនអត់ធន់ហេតុត្រឹមតែការពោលទូន្មាន ខឹងក្រោធ ដុតបណ្ណសាលាហើយចៀសចេញទៅ ។

សម័យក្រោយមក ភិក្ខុមួយរូបចេញអំពីក្រុងរាជគ្រឹះ ប្រាថ្នានឹងគាល់ព្រះសាស្តា ទៅដល់វត្តជេតពន ថ្វាយបង្គំព្រះសាស្តា កាលព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារៈហើយ ត្រាស់សួរថា អ្នកមកអំពីណា ភិក្ខុនោះទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមកអំពីក្រុងរាជគ្រឹះ ព្រះសាស្តាត្រាស់ថា មហាកស្សបៈបុត្រតថាគតនៅដោយសប្បាយឬ ភិក្ខុនោះឆ្លើយថា បពិត្រព្រះអង្គ សប្បាយតែសទ្ធិវិហារិករបស់លោកមួយរូប ក្រោធដោយហេតុត្រឹមតែការប្រៀនប្រដៅដុតបណ្ណសាលា ហើយចៀសចេញទៅ ។

ព្រះសាស្ដាត្រាស់ថា ភិក្ខុនោះស្ដាប់ឱវាទហើយ ទីងក្រោធក្នុងឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ក៏ក្រោធហើយដូចគ្នា ភិក្ខុនោះប្រទូស្ដកុដិក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏មិនមែន ក្នុងកាលមុនក៏ប្រទូស្ដហើយដូចគ្នាដូច្នេះហើយ ទ្រង់នាំអតីតនិទានមកត្រាស់ថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ។ សត្វគ្រលេងគ្រលោងមួយ ធ្វើសម្បុកក្នុងហេមវន្តប្បទេសសម័យមួយ កាលភ្លៀងកំពុងធ្លាក់ ស្វាមួយញ័រចំប្រប់ព្រោះរងា បានទៅកាន់ប្រទេសនោះ ។ គ្រលេងគ្រលោងឃើញស្វានោះ ទើបពោលគាថានេះថា

នែពានរ ក្បាល ដៃ និងជើងរបស់អ្នក ដូចជាមនុស្សដែរ
តែព្រោះហេតុអ្វី បានជាផ្ទះរបស់អ្នកគ្មាន ។

ស្វានោះគិតថា ដៃ និងជើងរបស់អញមានក៏ពិត តែអញពិចារណាហើយ គប្បីធ្វើផ្ទះដោយបញ្ញាណា បញ្ញារបស់អញនោះមិនមាន ប្រាថ្នានឹងប្រកាសសេចក្ដីនោះ ទើបពោលគាថានេះថា

នែគ្រលេងគ្រលោង ក្បាល ដៃ និង ជើងរបស់ខ្ញុំ ដូច
មនុស្សមែនហើយ តែប្រាជ្ញាណាដែលបោរាណាចារ្យពោល
ថា ប្រសើរក្នុងពួកមនុស្ស ប្រាជ្ញានោះរបស់ខ្ញុំមិនមានទេ ។

លំដាប់នោះ គ្រលេងគ្រលោងតិះដៀលស្វានោះថា ការនៅគ្រប់គ្រងផ្ទះ នឹងសម្រេចដល់អ្នកបានដូចម្ដេច ទើបពោលពីរគាថាថា

ធម្មតាអ្នកមានចិត្តមិននឹងនួន មានចិត្តរបិលរប៉ូច ជាអ្នកប្រទូស្ត
ចំពោះមិត្ត មានមារយាទមិនទៀងជានិច្ច តែងមិនមានសេចក្តី
សុខ ។
នែពានរ អ្នកនោះ ចូរធ្វើនូវអានុភាព ( ឲ្យកើតបញ្ញា ) ចូរ
ផ្លាស់មារយាទចេញ ចូរធ្វើខ្លួនជាគ្រឿងការពារនូវត្រជាក់ និង
ខ្យល់ ។

ស្វាគិតថា គ្រលេងគ្រលោងនេះ ធ្វើអញឲ្យជាអ្នកមានចិត្តមិនមាំទាំ មានចិត្តស្រាល ច្រើនដោយការទ្រុស្តមិត្ត មានប្រក្រតីមិនស្ថិតស្ថេរ ។ ឥឡូវនេះ អញនឹងសម្តែងភាពដែលអញ ច្រើនដោយភាពជាអ្នកទ្រុស្តមិត្តចំពោះវា ទើបបោចសម្បុកបោះចោលហើយ ។ គ្រលេងគ្រលោង កាលស្វានោះចាប់បោចសម្បុកនោះឯង គេចទៅដោយចំណែកម្ខាងហើយ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា ស្វាក្នុងកាលនោះបានជាភិក្ខុប្រទូស្តកុដិក្នុងកាលឥឡូវនេះ គ្រលេងគ្រលោងគឺកស្សបៈ ។ កាលទ្រង់សមោធានជាតកហើយ ទើបត្រាស់ថា យ៉ាងនោះឯង ភិក្ខុទាំងឡាយ ភិក្ខុនោះប្រទូស្តកុដិក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏មិនមែនសូម្បីក្នុងកាលមុន ភិក្ខុនោះក្រោធព្រោះឱវាទហើយ ក៏ប្រទូស្តកុដិហើយដូចគ្នា ការនៅរបស់កស្សបៈ បុត្រតថាគតម្នាក់ឯងប៉ុណ្ណោះ ល្អជាងការនៅរួមជាមួយនឹងបុគ្គលពាលបែបនោះ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**ចរញ្ចេ នាធិគច្ឆេយ្យ សេយ្យំ សទិសមត្តនោ**

**ឯកចរិយំ ទឡ្ហំ កយិរា ឧត្ថិ ពាលេ សហាយតា ។**

បុគ្គលកាលស្វែងរកកល្យាណមិត្ត បើមិនបានមិត្តដ៏ប្រសើរជាងខ្លួន ឬមិត្តដែលស្មើនឹងខ្លួនទេ គប្បីប្រព្រឹត្តនៅតែម្នាក់ឯងឲ្យខ្ជាប់ខ្ជួនវិញ ព្រោះថា សហាយតាគុណ មិនមានក្នុងបុគ្គលពាលឡើយ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ចរំ** បណ្ឌិតគប្បីជ្រាបការត្រាច់ទៅដោយចិត្ត មិនទាក់ទងដោយការត្រាច់ទៅដោយឥរិយាបថ អធិប្បាយថា កាលស្វែងរកកល្យាណមិត្ត ។

បាទព្រះគាថាថា **សេយ្យំ សទិសមត្តនោ** សេចក្តីថា បើមិនបានសម្លាញ់ដែលក្រៃលែងជាង ឬស្មើគ្នាដោយគុណ គឺសីល សមាធិ បញ្ញារបស់ខ្លួន ។

បទថា **ឯកចរិយំ** សេចក្តីថា ក្នុងសម្លាញ់ទាំងនោះ បុគ្គលកាលបានសម្លាញ់ដែលល្អជាង រមែងចម្រើនដោយគុណទាំងឡាយ មានសីលគុណជាដើម កាលបានសម្លាញ់ស្មើគ្នា រមែងមិនវិនាសចាកគុណទាំងឡាយ មានសីលជាដើមឡើយ តែកាលនៅដោយរួមគ្នាជាមួយសម្លាញ់ល្អហើយ ធ្វើការសម្ភោគនិងបរិភោគ ដោយភាពជាពួកតែមួយ រមែងវិនាសចាកគុណទាំងឡាយ មានសីលជាដើម ។ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ពាក្យនេះថា បុគ្គលបែបនោះ ដែលបណ្ឌិតមិនគប្បីសេព មិនគប្បីគប់រក មិនគប្បីចូលទៅអង្គុយជិត វៀរតែការអាណិត វៀរតែការអនុគ្រោះ ។

ព្រោះហេតុនោះ បើបុគ្គលអាស្រ័យភាពករុណាគិតថា បុគ្គលនេះអាស្រ័យអញ នឹងចម្រើនដោយគុណទាំងឡាយ មានសីលគុណជាដើម មិនប្រាថ្នាការតបស្នង នៅដោយវត្ថុណាមួយអំពីបុគ្គលនោះ ឈ្មោះថារមែងសង្គ្រោះបុគ្គលនោះបាន ការអាស្រ័យសេចក្ដីករុណា សង្គ្រោះដូច្នេះនោះជាការល្អ បើមិនអាចសង្គ្រោះបាន គប្បីធ្វើការត្រាច់ទៅម្នាក់ឯងឲ្យមាំទាំ គឺធ្វើនូវភាពជាបុគ្គលម្នាក់ឯងប៉ុណ្ណោះឲ្យមាំទាំ នៅតែម្នាក់ឯងក្នុងឥរិយាបថទាំងពួង ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះសហាយតាគុណ រមែងមិនមានក្នុងជនពាល អធិប្បាយថា ចុល្លសីល មជ្ឈិមសីល មហាសីល កថាវត្ថុ ១០ ធុតង្គគុណ ១៣ វិបស្សនាគុណ មគ្គ ៤ ផល ៤ វិជ្ជា ៣ អភិញ្ញា ៦ ឈ្មោះថា សហាយតាគុណ សហាយតាគុណនេះ មិនមានព្រោះអាស្រ័យបុគ្គលពាល ។

ក្នុងកាលចប់ទេសនា អាគន្តុកភិក្ខុសម្រេចសោតាបត្តិផលហើយ ជនដទៃជាច្រើន ក៏សម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ ទេសនាបានប្រព្រឹត្តទៅដោយប្រយោជន៍ដល់មហាជន ដូច្នេះឯង ។៚

**រឿង សទ្ធិវិហារិករបស់ព្រះមហាកស្សបត្ថេរ ចប់**

# រឿង អានន្ទសេដ្ឋី

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធអានន្ទសេដ្ឋី ត្រាស់ព្រះធម្មទេសនានេះថា **បុត្តា មត្ថិ ធនមត្ថិ** ជាដើម ។

បានឮថា ក្នុងក្រុងសាវត្ថី សេដ្ឋីឈ្មោះអានន្ទ មានសម្បត្តិប្រមាណ ៨០ កោដិ ជាបុគ្គលកំណាញ់ច្រើន អានន្ទសេដ្ឋីនោះ ឲ្យញាតិប្រជុំគ្នារៀងរាល់កន្លះខែហើយ ទូន្មានកូនរបស់ខ្លួនឈ្មោះមូលសិរី ក្នុងបីពេលយ៉ាងនេះថា អ្នកកុំធ្វើសេចក្ដីសម្គាល់ថា ទ្រព្យ ៤០ កោដិនេះច្រើន អ្នកមិនគួរឲ្យទ្រព្យដែលមាន គួរញ៉ាំងទ្រព្យថ្មីឲ្យកើតឡើង ព្រោះកាលបុគ្គលធ្វើកហាបណៈមួយឲ្យវិនាសទៅ ទ្រព្យ រមែងអស់ដូចគ្នា ព្រោះហេតុនោះ

បុគ្គលអ្នកឈ្លាស គប្បីឃើញការអស់នៃថ្នាំ សម្រាប់បន្តក់ភ្នែក<br>ការចម្រើននៃដំបូកកណ្ដៀរទាំងឡាយ និងការប្រមូលមកនៃឃ្មុំ<br>ទាំងឡាយ គប្បីនៅគ្រប់គ្រងផ្ទះ ។

សម័យដទៃមកទៀត អានន្ទសេដ្ឋីនោះមិនបានប្រាប់កំណាប់ទ្រព្យធំ ៥ កន្លែងរបស់ខ្លួនដល់កូន អាស្រ័យទ្រព្យ មានការសៅហ្មងព្រោះមន្ទិល គឺសេចក្ដីកំណាញ់ ធ្វើកាលកិរិយាហើយ បដិសន្ធិក្នុងផ្ទៃរបស់ស្រីចណ្ឌាលម្នាក់ ក្នុងពួកចណ្ឌាលមួយពាន់ត្រកូល ដែលនៅអាស្រ័យក្នុងស្រុក ជិតទ្វារនគរមួយកន្លែងនៃនគរនោះឯង ។ ព្រះរាជាទ្រង់ជ្រាបការធ្វើកាលកិរិយារបស់អានន្ទសេដ្ឋីហើយ បញ្ជាឲ្យហៅមូលសិរីដែលជាកូនរបស់គាត់មក ទ្រង់

តែងតាំងក្នុងតំណែងសេដ្ឋី ។

ត្រកូលនៃមនុស្សចណ្ឌាលមួយពាន់នោះ ធ្វើការងារស៊ីឈ្នួលមួយពួក នោះឯងរស់នៅ ចាប់តាំងពីបដិសន្ធិរបស់ទារកនោះ មិនបានឈ្នួល ទាំងមិនបានសូម្បីដុំបាយ ច្រើនជាងអាហារដែលល្មមញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ។ ជនទាំងនោះពោលថា ឥឡូវនេះ យើងទាំងឡាយធ្វើការងារ មិនបានអាហារ ត្រឹមតែដុំបាយ ស្រីកាឡកិណីគប្បីមានក្នុងរវាងពួកយើងទាំងឡាយ ដូច្នេះហើយ ទើបចែកគ្នាជាពីរពួកបន្តៗ រហូតញែកមាតាបិតារបស់ទារកនោះនៅដោយឡែក ដេញមាតារបស់ទារកនោះចេញដោយគិតថា មនុស្សកាឡកិណីកើតក្នុងត្រកូលនេះ ។ ទារកនោះនៅក្នុងផ្ទៃរបស់ស្រីនោះដរាបណា ស្រីនោះបានអាហារ ត្រឹមតែញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយផុតផើយដរាបនោះ រហូតដល់ពេលប្រសូតហើយ ។

ទារកនោះមានដៃនិងជើង ភ្នែក ត្រចៀក ត្រមុះនិងមាត់មិនតាំងនៅក្នុងទីតាមប្រក្រតី ។ ទារកនោះប្រកបដោយការវិកលនៃអាវយវៈបែបនោះ មានរូបគួរខ្ពើមពន់ពេក ដូចបិសាចប្រឡាក់ធូលី ។ កាលបើដូច្នេះ មាតាក៏មិនលះបុត្រនោះ ។ ពិតហើយ ម្តាយ មានការជាប់ជំពាក់ជាកម្លាំងក្នុងបុត្រដែលនៅក្នុងផ្ទៃ នាងចិញ្ចឹមទារកនោះដោយភាពខ្វះខាត ក្នុងថ្ងៃដែលនាំកូននោះទៅមិនបានរបស់អ្វីឡើយ ក្នុងថ្ងៃដែលឲ្យកូននោះនៅផ្ទះ ហើយទៅម្នាក់ឯងនោះឯង ទើបបានថ្ងៃឈ្នួល ។

សម័យតមក ក្នុងកាលទារកនោះអាចដើរទៅដើម្បីដុំបាយចិញ្ចឹមខ្លួនបាន

នាងដាក់អំបែងលើដៃហើយ ពោលនឹងបុត្រនោះថា ពុកម៉ែអាស្រ័យឯង ទើបដល់នូវសេចក្ដីលំបាកខ្លាំង ឥឡូវនេះ ម៉ែមិនអាចចិញ្ចឹមឯងបាន អាហារ-វត្ថុទាំងឡាយ មានបាយជាដើម ដែលគេរៀបចំដើម្បីមនុស្សទាំងឡាយ មានមនុស្សកំព្រា និងមនុស្សដើរផ្លូវជាដើម មាននៅក្នុងនគរនេះ ឯងចូរដើរទៅដើម្បីភិក្ខាក្នុងនគរនោះចិញ្ចឹមជីវិតចុះ ដូច្នេះហើយ លែងបុត្រនោះទៅ ។ ទារកនោះត្រាច់ទៅតាមលំដាប់ផ្ទះ ដល់ទីដែលខ្លួនកើតក្នុងកាលជាអានន្ទសេដ្ឋីហើយ ជាអ្នករឭកជាតិបាន ចូលទៅកាន់ផ្ទះរបស់ខ្លួន ។ បុគ្គលណាម្នាក់មិនបានសង្កេតកុមារនោះក្នុងខ្លោងទ្វារទាំង ៣ ក្នុងខ្លោងទ្វារទី ៤ ពួកកូនរបស់មូលសិរិសេដ្ឋីនោះឃើញ មានចិត្តភ័យខ្លាចស្រែកយំហើយ លំដាប់នោះ ពួកបុរសរបស់សេដ្ឋីពោលនឹងទារកនោះថា ឯងចូរចេញទៅ មនុស្សកាឡកិណីវាយបណ្ដើរ នាំចេញទៅបោះត្រង់គំនរសំរាម ។

ព្រះសាស្ដា មានព្រះអានន្ទត្ថេរជាបច្ឆាសមណៈ ទ្រង់បិណ្ឌបាតដល់ទីនោះហើយ ទតមើលព្រះថេរៈ ព្រះថេរៈទូលសួរហើយ ត្រាស់ប្រាប់ព្រឹត្តិការណ៍នោះ ព្រះថេរៈនោះបានឲ្យមូលសិរិសេដ្ឋីមកហើយ ពួកមហាជនប្រជុំគ្នាហើយ ។ ព្រះសាស្ដាត្រាស់ហៅមូលសិរិសេដ្ឋីមកហើយ ត្រាស់សួរថា អ្នកស្គាល់ទារកនោះដែរឬទេ មូលសិរិសេដ្ឋីទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមិនស្គាល់ទេ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ទារកនោះ គឺអានន្ទសេដ្ឋីបិតារបស់អ្នក ហើយញ៉ាំងទារកនោះឲ្យប្រាប់កំណប់ទ្រព្យ ដោយព្រះតម្រាស់ថា អានន្ទសេដ្ឋី អ្នកចូរប្រាប់កំណប់ទ្រព្យធំ ៥ កន្លែងដល់កូនរបស់អ្នក ទ្រង់

ញ៉ាំងមូលសិរិសេដ្ឋីដែលមិនជឿ ឲ្យជឿហើយ ។ មូលសិរិសេដ្ឋីនោះបានដល់ព្រះសាស្តាជាសរណៈហើយ ។ ព្រះសាស្តា កាលទ្រង់សំដែងធមិដល់មូលសិរិសេដ្ឋីនោះ ទើបត្រាស់ព្រះគាថានេះថា

**បុត្តា មត្ថិ ធនមត្ថិ ឥតិ ពាលោ វិហញ្ញតិ**

**អត្តា ហិ អត្តនោ នត្ថិ កុតោ បុត្តា កុតោធនំ ។**

ជនពាល តែងព្រួយលំបាក ដោយសេចក្តីសម្គាល់ថា កូនទាំងឡាយរបស់អញមាន ទ្រព្យរបស់អញមាន តាមដែលពិត សូម្បីខ្លួនរបស់ខ្លួនក៏មិនមាន ចំណង់បើកូនទាំងឡាយនឹងរកប់ថា មានមកអំពីណាបាន ទ្រព្យ នឹងរកប់ថា មានមកអំពីណាបាន ។

## សេចក្តីអធិប្បាយ

គប្បីជ្រាបអត្ថនៃគាថានោះថា ជនពាលរមែងក្តៅក្រហាយដោយចំណង់ក្នុងបុត្រ និងចំណង់ក្នុងទ្រព្យថា កូនទាំងឡាយរបស់អញមាន ទ្រព្យរបស់អញមាន គឺរមែងលំបាក រមែងដល់នូវទុក្ខ គឺរមែងក្តៅក្រហាយថា កូនទាំង-ឡាយរបស់អញវិនាសហើយ រមែងក្តៅក្រហាយថា កំពុងវិនាស ។ រមែងក្តៅក្រហាយថា នឹងវិនាស សូម្បីក្នុងទ្រព្យក៏មានន័យដូចគ្នា ។ បុគ្គលពាលរមែងក្តៅក្រហាយដោយអាការ ៦ យ៉ាង ដោយប្រការដូច្នេះ បុគ្គលពាល សូម្បីព្យាយាមក្នុងទីទាំងឡាយ មានផ្លូវគោក និងផ្លូវទឹកជាដើម ទាំងពេលយប់ និងពេលថ្ងៃដោយប្រការផ្សេងៗ ដោយគិតថា អញនឹងចិញ្ចឹមកូនទាំងឡាយ ឈ្មោះ

ថា រមែងក្ដៅក្រហាយ សូម្បីធ្វើកម្មទាំងឡាយ មានការធ្វើស្រែ និងការជួញដូរជាដើម ដោយគិតថា អញនឹងញុំាងទ្រព្យឲ្យកើតឡើង ឈ្មោះថា រមែងក្ដៅក្រហាយដូចគ្នា កាលក្ដៅក្រហាយយ៉ាងនេះ ខ្លួនឯងឈ្មោះថា រមែងមិនមានដល់ខ្លួន កាលបុគ្គលមិនអាចធ្វើខ្លួនឲ្យដល់នូវសេចក្ដីទុក្ខ ដោយការចង្អៀតចង្អល់នោះ ឲ្យដល់នូវសុខបានក្នុងបច្ចុប្បន្នកាល ខ្លួនរបស់បុគ្គលនោះឯងឈ្មោះថា រមែងមិនមានដល់ខ្លួន កាលបុគ្គលនោះដេកលើគ្រែសម្រាប់ស្លាប់ត្រូវវេទនាទាំងឡាយ មានការស្លាប់ជាទីបំផុត ដុតរោលហាក់ដូចត្រូវអណ្ដាតភ្លើងឆេះ កាលគ្រឿងត និងគ្រឿងចងដាច់ទៅ កាលសរីរឆ្អឹងបែកទៅ កាលបុគ្គលនោះបិទភ្នែក ឃើញលោកខាងមុខ បើកភ្នែក ឃើញលោកនេះ ខ្លួនឯងសូម្បីគេផ្ចូតឲ្យដោយទឹកមួយថ្ងៃពីរដង ឲ្យបរិភោគមួយថ្ងៃ ៣ ដងប្រដាប់ដោយគ្រឿងក្រអូប និងកម្រងផ្កាជាដើម ចិញ្ចឹមហើយដរាបដល់អស់ជីវិត ឈ្មោះថា រមែងមិនមានដល់ខ្លួន ព្រោះភាពដែលខ្លួនជាអ្នកមិនអាចធ្វើគ្រឿងការពារនូវទុក្ខដោយភាពជាសម្លាញ់បាន កូននឹងមានអំពីទីណា ទ្រព្យនឹងមានអំពីទីណា គឺក្នុងសម័យនោះ កូន ឬទ្រព្យនឹងធ្វើអ្វីបាន ។ កាលអានន្ទសេដ្ឋីមិនឲ្យទ្រព្យអ្វីមួយ ដល់បុគ្គលណាម្នាក់ ប្រមូលទ្រព្យទុកដើម្បីប្រយោជន៍ដល់កូន ដេកលើគ្រែសម្រាប់ស្លាប់ក្នុងកាលមុនក្ដី ដល់នូវទុក្ខនេះក្នុងបច្ចុប្បន្ននេះក្ដី បុត្រអំពីទីណា ទ្រព្យអំពីទីណា គឺបុត្រ ឬទ្រព្យនាំទុក្ខអ្វីទៅបាន ឬឲ្យសុខអ្វីកើតឡើងបាន ។

ក្នុងកាលចប់ទេសនា ការត្រាស់ដឹងធម៌មានដល់សត្វ ៨៤០០០ ទេសនាមានប្រយោជន៍ដល់មហាជនហើយ ដូច្នេះឯង ។ល។

**រឿង អានន្ទសេដ្ឋី ចប់**

# រឿង គណ្ឋិភេទកចោរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធពួកចោរទម្លាយកំណួច ត្រាស់ព្រះធម្មទេសនានេះថា **យោ ពាលោ មញ្ញតី ពាល្យំ** ជាដើម ។

បានឮថា ចោរពីរនាក់នោះជាសម្លាញ់នឹងគ្នា ទៅកាន់វត្តជេតពនជាមួយមហាជនដែលទៅដើម្បីស្តាប់ធម៌ ចោរម្នាក់បានស្តាប់ធម្មកថាហើយ ចោរម្នាក់សម្លឹងមើលរបស់ដែលខ្លួនគួរកាន់យក ។ បណ្តាចោរទាំងពីរនោះ ចោរដែលស្តាប់ធម៌សម្រេចសោតាបត្តិផលហើយ ។ ចោរម្នាក់ទៀត បានទ្រព្យប្រមាណ ៥ មាសក ដែលខ្ចប់ទុកត្រង់ជាយសំពត់របស់ឧបាសកម្នាក់ ទ្រព្យនោះបានជាថ្លៃអាហារក្នុងផ្ទះរបស់ចោរហើយ រមែងមិនសម្រេចផលក្នុងផ្ទះរបស់ចោរដែលជាសោតាបន្នក្រៅអំពីនេះ ។

គ្រានោះ ចោរជាសម្លាញ់ និងកិរិយារបស់ខ្លួន កាលនឹងសើចចំអកចោរដែលជាសោតាបន្ននោះ ទើបពោលថា អ្នកមិនញុំាងសូម្បីត្រឹមតែថ្លៃអាហារឲ្យសម្រេចក្នុងផ្ទះរបស់ខ្លួន ព្រោះភាពដែលខ្លួនឆ្លាតពេក ។ សម្លាញ់ដែលជា

សោតាបន្នក្រៅអំពីនេះគិតថា បុគ្គលនេះរមែងសម្គាល់ភាពដែលខ្លួនជាបណ្ឌិត ដោយភាពជាបុគ្គលពាលហ្ន៎ ដើម្បីក្រាបទូលការប្រព្រឹត្តទៅនោះដល់ព្រះសាស្តា ទើបទៅកាន់វត្តជេតពន មួយអន្លើដោយញាតិទាំងឡាយ ក្រាបទូលហើយ ។

ព្រះសាស្តា កាលទ្រង់សម្តែងធម៌ដល់បុគ្គលនោះ ទើបត្រាស់ព្រះគាថានេះថា

**យោ ពាលោ មញ្ញតី ពាល្យំ បណ្ឌិតោ វាបិ តេន សោ**
**ពាលោ ច បណ្ឌិតមានី ស វេ ពាលោតិ វុច្ចតិ ។**

អ្នកណា ជាមនុស្សពាល ហើយដឹងនូវភាពនៃខ្លួនថាជាពាល អ្នកនោះនឹងទៅជាបណ្ឌិតបានខ្លះ ដោយហេតុដែលដឹងខ្លួនថាជាពាលនោះ ម្យ៉ាងទៀត អ្នកណា ជាមនុស្សពាល មានសេចក្តីប្រកាន់ថា ខ្លួនជាបណ្ឌិត អ្នកនោះឈ្មោះថា ជាមនុស្សពាលដោយពិត ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **យោ ពាលោ** សេចក្តីថា បុគ្គលណាជាមនុស្សល្ងង់ គឺមិនមែនជាបណ្ឌិត រមែងសម្គាល់ថា គឺរមែងដឹងនូវភាពដែលខ្លួនជាមនុស្សល្ងង់ គឺភាពជាបុគ្គលល្ងង់ខ្លៅនោះដោយខ្លួនឯងថា អាត្មាអញជាបុគ្គលល្ងង់ខ្លៅ ។

ពីរបទថា **តេន សោ** សេចក្តីថា ដោយហេតុនោះ បុគ្គលនោះ ជាបណ្ឌិតបានខ្លះ ឬដូចគ្នានឹងបណ្ឌិតបានខ្លះ ។

*បុគ្គលនោះដឹងថា អញជាមនុស្សល្ងង់ ចូលទៅរក ចូលទៅអង្គុយជិតអ្នកដទៃដែលជាបណ្ឌិត ដែលបណ្ឌិតនោះពោលប្រៀនប្រដៅ ទូន្មាន ដើម្បីប្រយោជន៍ដល់ភាពជាបណ្ឌិត រៀនយកឱវាទនោះហើយ រមែងជាបណ្ឌិត ឬជាបណ្ឌិតច្រើនជាង ។*

*ពីរបទថា* **ស វេ ពាលោ** *សេចក្ដីថា ចំណែកបុគ្គលណាជាអ្នកល្ងង់ខ្លៅជាបុគ្គលមានសេចក្ដីសម្គាល់ថា ខ្លួនជាបណ្ឌិតតែម្យ៉ាងយ៉ាងនេះថា បុគ្គលដទៃណា ទោះជាពហុស្សូត ជាធម្មកថិកទ្រទ្រង់វិន័យ មានវាទៈពោលគុណជាគ្រឿងកម្ចាត់កិលេស ដូចគ្នានឹងអាត្មាអញមាន បុគ្គលនោះមិនចូលទៅរក មិនចូលទៅអង្គុយជិតបុគ្គលដទៃដែលជាបណ្ឌិត រមែងមិនរៀនបរិយត្តឡើយ រមែងមិនបំពេញបដិបទា រមែងដល់នូវភាពជាបុគ្គលល្ងង់ដោយចំណែកមួយ បុគ្គលនោះរមែងដូចចោរទម្លាយកំណួចដូច្នោះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យនេះថា* **ស វេ ពាលោតិ វុច្ចតិ ។**

*ក្នុងកាលចប់ទេសនា មហាជនមួយអន្លើដោយញាតិទាំងឡាយរបស់ចោរដែលជាសោតាបន្នក្រៅអំពីនេះ សម្រេចសោតាបត្តិផលហើយដូច្នោះឯង ៕*

**រឿង គណ្ឋិភេទចោរ ចប់**

# រឿង ព្រះឧទាយិត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះឧទាយិត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **យាវជីវម្បិ ចេ ពាលោ** ជាដើម ។

បានឮថា ព្រះឧទាយិត្ថេរនោះ កាលព្រះថេរៈធំចៀសចេញទៅហើយ ទៅកាន់រោងធម្មសភាហើយ អង្គុយលើធម្មាសនៈ ។ ថ្ងៃមួយ ពួកភិក្ខុជាអាគន្តុកៈឃើញព្រះឧទាយិត្ថេរនោះហើយយល់ថា ភិក្ខុនេះប្រហែលជាព្រះមហាថេរៈដែលជាពហូសូត ទើបសួរបញ្ហាទាក់ទងដោយខន្ធជាដើមហើយ តិះដៀលលោកដែលមិនដឹងនូវព្រះពុទ្ធវចនៈណាមួយថា នេះព្រះថេរៈអ្វី នៅក្នុងព្រះវិហារជាមួយនឹងព្រះពុទ្ធ មិនចេះធម៌សូម្បីត្រឹមតែខន្ធ ធាតុ និងអាយតនៈដូច្នេះហើយ ទើបក្រាបទូលការប្រព្រឹត្តទៅនោះដល់ព្រះសាស្តា ។ គ្រានោះព្រះសាស្តាទ្រង់សម្តែងធម្មកថា ដល់អាគន្តុកភិក្ខុនោះ ទើបត្រាស់គាថានេះថា

**យាវជីវម្បិ ចេ ពាលោ បណ្ឌិតំ បយិរុបាសតិ**
**ន សោ ធម្មំ វិជានាតិ ទព្វី សូបរសំ យថា ។**

មនុស្សពាល បើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីអស់មួយជីវិត ក៏ឥតមានដឹងរសធម៌អ្វីឲ្យច្បាស់លាស់ឡើយ ដូចវែកដែលមិនដឹងរសសម្ល ។

## សេចក្តីអធិប្បាយ

គប្បីជ្រាបសេចក្តីនៃព្រះគាថានេះថា ឈ្មោះថា បុគ្គលពាល ចូលទៅ

អន្ធ័យជិតបណ្ឌិតដរាបអស់ជីវិត រមែងមិនដឹងបរិយត្តិធម៌យ៉ាងនេះថា នេះជាព្រះពុទ្ធវចនៈ ព្រះពុទ្ធវចនៈមានប្រមាណប៉ុណ្ណេះ ឬនូវបដិបត្តិធម៌ និងបដិវេធធម៌យ៉ាងនេះថា ធម៌នេះជាគ្រឿងនៅ ធម៌នេះជាមារយាទ នេះជាគោចរកម្ម នេះប្រព្រឹត្តទៅដោយទោស កម្មនេះមិនមានទោស កម្មនេះគួរសេព កម្មនេះមិនគួរសេព វត្ថុនេះគប្បីចាក់ធ្លុះ វត្ថុនេះគួរធ្វើឲ្យជាក់ច្បាស់ ។

សួរថា ដូចអ្វី ឆ្លើយថា ដូចវែកមិនដឹងរសសម្ល ដូច្នោះ អធិប្បាយថា ឧបមាដូចវែក ស្លម្បមនុស្សស្លច្រើនប្រភេទ មានប្រការផ្សេងៗ រហូតសឹករិចរិល រមែងមិនដឹងរសសម្លថា នេះរសប្រៃ នេះរសសាប នេះរសល្វីង នេះរសភ្លាវ នេះរសហឹរ នេះរសជូរ នេះរសចត់ យ៉ាងណា បុគ្គលពាលចូលទៅអន្ធ័យជិតបណ្ឌិតដរាបដល់អស់ជីវិត រមែងមិនដឹងធម៌ មានប្រការដូចពោលហើយ ដូច្នោះដូចគ្នា ។

ក្នុងកាលចប់ទេសនា ចិត្តរបស់អាគន្តុកភិក្ខុ រួចផុតហើយចាកអាសវៈទាំងឡាយ ដូច្នេះឯង ។ល។

**រឿង ព្រះឧទាយិត្ថេរ ចប់**

# រឿង ភិក្ខុអ្នកក្រុងបាវ៉ា

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអ្នកក្រុងបាវ៉ា ប្រមាណ ៣០ រូប ត្រាស់ព្រះធម្មទេសនានេះថា **មុហុត្តម្បិ ចេ វិញ្ញូ** ជាដើម ។

សេចក្តីពិស្តារថា ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងធម៌គ្រាដំបូងក្នុងព្រៃចម្ការកប្បាសដល់សម្លាញ់ ៣០ នាក់នោះ ដែលស្វែងរកស្រី ។ ក្នុងកាលនោះសម្លាញ់ទាំងអស់ដល់នូវភាពជាឯហិភិក្ខុ ជាអ្នកទ្រទ្រង់បាត្រ និងចីវរដែលសម្រេចដោយឫទ្ធិ សមាទានធុតង្គ ១៣ ប្រព្រឹត្តកន្លងទៅនៃកាលយូរ ចូលទៅគាល់ព្រះសាស្តាទៀត ស្តាប់អនមតគ្គធម្មទេសនា សម្រេចអរហត្តលើអាសនៈនោះឯង ។

ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា គួរអស្ចារ្យហ្ន៎ ភិក្ខុទាំងនេះដឹងច្បាស់នូវធម៌ឆាប់រួសរាន់នោះឯង ។ ព្រះសាស្តា ទ្រង់ស្តាប់កថានោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងឥឡូវនេះប៉ុណ្ណោះ សូម្បីក្នុងកាលមុន ភិក្ខុទាំងនេះជាអ្នកលេង ជាសម្លាញ់នឹងគ្នាប្រមាណ ៣០ នាក់ ស្តាប់ធម្មទេសនារបស់ជ្រូក ឈ្មោះមហាតុណ្ឌិលៈ ក្នុងតុណ្ឌិលជាតក ដឹងច្បាស់នូវធម៌បានឆាប់រួសរាន់នោះឯង សមាទានសីល ៥ ហើយ ព្រោះឧបនិស្ស័យនោះឯង ទើបបុគ្គលទាំងនោះសម្រេចអរហត្ត លើអាសនៈដែលខ្លួនអង្គុយហើយនោះឯង ក្នុងកាលឥឡូវនេះ ដូច្នេះហើយ កាលទ្រង់សម្តែងធម៌ ទើបត្រាស់គាថានេះថា

មុហុត្តមបិ ចេ វិញ្ញូ   បណ្ឌិតំ បយិរុបាសតិ
ខិប្បំ ធម្មំ វិជានាតិ   ជិវ្ហា សូបរសំ យថា ។

*វិញ្ញូជន បើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីតែមួយរំពេច រមែងយល់សេចក្ដីធម៌ ដោយឆាប់រហ័ស ដូចអណ្ដាតដឹងនូវរសសម្ល ។*

## សេចក្ដីអធិប្បាយ

*គប្បីជ្រាបអត្ថនៃព្រះគាថានេះថា បើវិញ្ញូជន គឺបុរសដែលជាបណ្ឌិត ចូលទៅអង្គុយជិតបណ្ឌិតដទៃ សូម្បីតែមួយរំពេច បុគ្គលនោះរៀន សាកសួរក្នុងសម្នាក់បណ្ឌិតដទៃនោះ ឈ្មោះថា រមែងដឹងច្បាស់នូវបរិយត្តិធម៌ ដោយឆាប់រួសរាន់នោះឯង បន្ទាប់អំពីនោះ បុគ្គលនោះឲ្យបណ្ឌិតប្រាប់កម្មដ្ឋានហើយ ព្យាយាមក្នុងបដិបទាជាបណ្ឌិត រមែងដឹងច្បាស់នូវលោកុត្តរធម៌ ឆាប់រួសរាន់នោះឯង ។ ដូចបុរសមានជិវ្ហាបសាទ ដែលរោគមិនរារាំងហើយ គ្រាន់តែដាក់អាហារត្រង់ចុងអណ្ដាតដើម្បីដឹងរស រមែងដឹងរស មានរសប្រៃជាដើម ដូច្នោះ ។*

*ក្នុងកាលចប់ទេសនា ភិក្ខុជាច្រើនសម្រេចអរហត្តហើយដូច្នេះឯង ។*

**រឿង ភិក្ខុអ្នកក្រុងបាឋា ចប់**

# រឿង សុប្បពុទ្ធកុដ្ឋិ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធបុរសរោគឃ្លង់ឈ្មោះសុប្បពុទ្ធ ត្រាស់ព្រះធម្មទេសនានេះថា **ចរន្តិ ពាលា ទុម្មេធា** ជាដើម ។

រឿងសុប្បពុទ្ធនេះ មកហើយក្នុងគម្ពីរឧទាននោះឯង ។ ក្នុងកាលនោះ សុប្បពុទ្ធកុដ្ឋិ អង្គុយខាងចុងបរិស័ទ ស្តាប់ធម្មទេសនារបស់ព្រះដ៏មានព្រះភាគ ហើយសម្រេចសោតាបត្តិផល ប្រាថ្នានឹងក្រាបទូលគុណដែលខ្លួនបានហើយ ដល់ព្រះសាស្តា តែមិនអាចឈមចុះក្នុងកណ្តាលបរិស័ទ បានទៅកាន់វិហារ ក្នុងកាលមហាជនថ្វាយបង្គំព្រះសាស្តាត្រឡប់ទៅហើយ ។

ខណៈនោះ សក្កទេវរាជជ្រាបថាសុប្បពុទ្ធកុដ្ឋិនេះ ប្រាថ្នាដើម្បីនឹងធ្វើគុណដែលខ្លួនបានក្នុងសាសនារបស់ព្រះសាស្តាឲ្យប្រាកដ ទ្រង់ព្រះតម្រិះថា អាត្មាអញនឹងសាកល្បងសុប្បពុទ្ធកុដ្ឋិនោះ យាងទៅឈរក្នុងអាកាសហើយ បានត្រាស់ពាក្យនេះថា សុប្បពុទ្ធ អ្នកជាមនុស្សក្រីក្រ ជាមនុស្សទុគ៌ត ខ្ញុំនឹងឲ្យទ្រព្យរាប់មិនអស់ដល់អ្នក អ្នកចូលពោលថា ព្រះពុទ្ធមិនមែនព្រះពុទ្ធ ព្រះធម៌មិនមែនព្រះធម៌ ព្រះសង្ឃមិនមែនព្រះសង្ឃ ខ្ញុំមិនដល់នូវព្រះពុទ្ធ ខ្ញុំមិនដល់នូវព្រះធម៌ ខ្ញុំមិនដល់នូវព្រះសង្ឃ ។ លំដាប់នោះ សុប្បពុទ្ធកុដ្ឋិនោះពោលនឹងសក្កទេវរាជនោះថា អ្នកជានរណា សក្កទេវរាជពោលថា ខ្ញុំជាសក្កទេវរាជ សុប្បពុទ្ធកុដ្ឋិពោលថា អ្នកជាបុគ្គលអន្ធពាលមិនខ្មាស អ្នកជាបុគ្គលមិនសមគួរពោលជាមួយខ្ញុំ អ្នកពោលនឹងខ្ញុំថា ជាមនុស្សក្រីក្រី ជាមនុស្សទុគ៌ត ជា

មនុស្សកំព្រា ខ្ញុំមិនមែនក្រីក្រ មិនមែនទុគ៌ត ខ្ញុំជាអ្នកដល់នូវសេចក្ដីសុខ មានទ្រព្យច្រើន ។

ទ្រព្យ គឺសទ្ធា ទ្រព្យ គឺសីល ទ្រព្យ គឺហិរិ ទ្រព្យ គឺឱត្តប្បៈ ទ្រព្យ គឺសុតៈ ទ្រព្យ គឺចាគៈ ទ្រព្យ គឺបញ្ញា ជាគម្រប់ ៧ ។

បុគ្គលណា ទោះស្ត្រីក្ដី បុរសក្ដី មានទ្រព្យទាំងនេះ អ្នកប្រាជ្ញទាំង-ឡាយ ហៅបុគ្គលនោះថា ជាអ្នកមិនទ័លក្រឡើយ ការរស់នៅរបស់បុគ្គលនោះ មិនសោះសូន្យឡើយ ។

ព្រោះហេតុនោះ អរិយទ្រព្យមាន ៧ យ៉ាងនេះ មានដល់ជនទាំងឡាយណា ជនទាំងនោះ ដែលព្រះពុទ្ធទាំងឡាយ ឬព្រះបច្ចេកពុទ្ធទាំងឡាយ មិនពោលថា ជាអ្នកក្រីក្រឡើយ ។

សក្កទេវរាជ ទ្រង់ស្ដាប់ពាក្យរបស់សុប្បពុទ្ធនោះហើយ ទ្រង់លះបង់សុប្បពុទ្ធកុដ្ឋិក្នុងរវាងផ្លូវ ចូលទៅកាន់សម្នាក់របស់ព្រះសាស្ដា ក្រាបទូលការឆ្លើយតបនូវពាក្យទាំងអស់នោះ ដល់ព្រះសាស្ដាហើយ ។ លំដាប់នោះព្រះដ៏មានព្រះភាគត្រាស់នឹងសក្កៈនោះថា សក្កៈដូចអ្នករាប់រយរាប់ពាន់អង្គ ក៏មិនអាចឲ្យសុប្បពុទ្ធកុដ្ឋិពោលថា ព្រះពុទ្ធមិនមែនព្រះពុទ្ធ ព្រះធម៌មិនមែនព្រះធម៌ ឬព្រះសង្ឃមិនមែនព្រះសង្ឃបានឡើយ ។

ចំណែកសុប្បពុទ្ធ ទៅកាន់សម្នាក់ព្រះសាស្ដា មានការត្រេកអរដែលព្រះសាស្ដាទ្រង់ធ្វើហើយ ក្រាបទូលគុណដែលខ្លួនបានហើយដល់ព្រះសាស្ដា ក្រោកអំពីអាសនៈចៀសទៅហើយ ។ ខណៈនោះ មេគោកូនខ្ចីបុះសុប្បពុទ្ធ

នោះ ដែលចៀសទៅហើយ ក្នុងកាលមិនយូរ ឲ្យអស់ជីវិតហើយ ។

បានឮថា មេគោកូនខ្ចីនោះជាយក្ខិនីម្នាក់ ជាមេគោកាឡាខួន ជនទាំង ៤ គឺកុលបុត្រឈ្មោះបុក្កុសាតិ ១ ពាហិយទារុចីរិយៈ ១ ចោរឃាតកៈឈ្មោះតម្ពទាឋិកៈ ១ សុប្បពុទ្ធកុដ្ឋិ ១ ឲ្យដាច់ជីវិតម្នាក់មួយរយអត្តភាព ។ បានឮថា ក្នុងអតីតកាល ជនទាំងនេះជាកូនសេដ្ឋី ៤ នាក់ នាំស្រីបេស្យា ដែលជានគរសោភិនីម្នាក់ទៅកាន់សួនឧទ្យាន សោយសម្បត្តិ អស់មួយថ្ងៃហើយ ក្នុងវេលាល្ងាច ប្រឹក្សាគ្នាយ៉ាងនេះថា ក្នុងទីនេះមិនមានអ្នកដទៃ យើងទាំងឡាយ នឹងកាន់យកកហាបណៈ ១ ពាន់ និងគ្រឿងអលង្ការទាំងអស់ ដែលយើងឲ្យដល់ស្រីនេះហើយ សម្លាប់ស្រីនេះចោលតែម្តង ។ ស្រីនោះស្តាប់ពាក្យរបស់សេដ្ឋីបុត្រ ទាំងនោះហើយ គិតថា ជនទាំងនេះ មិនមានខ្មាសសប្បាយជាមួយអញហើយ ឥឡូវនេះ ប្រាថ្នានឹងសម្លាប់អញ អញនឹងដឹងកិច្ចដែលគួរធ្វើដល់ជនទាំងនេះ កាលជនទាំងនោះសម្លាប់ បានធ្វើសេចក្តីប្រាថ្នាថា សូមឲ្យខ្ញុំកើតជាយក្ខិនី ដែលអាចសម្លាប់ជនទាំងនោះ ដូចដែលជនទាំងនេះសម្លាប់ខ្ញុំដូច្នោះដូចគ្នា ។

ភិក្ខុច្រើនរូប ក្រាបទូលការធ្វើកាលកិរិយារបស់សុប្បពុទ្ធនោះដល់ព្រះដ៏មានព្រះភាគ ទូលសួរថា គតិរបស់សុប្បពុទ្ធនោះដូចម្តេច ព្រោះហេតុអ្វីទើបគាត់មានរោគឃ្លង់ ។

ព្រះសាស្តាទ្រង់ព្យាករភាពដែលសុប្បពុទ្ធនោះ សម្រេចសោតាបត្តិផលហើយ កើតក្នុងតាវត្តិង្សពិភព និងការឃើញព្រះតគរសិខីបច្ចេកពុទ្ធ ខាកស្តោះ

ទឹកមាត់ ហើយចៀសចេញទៅផ្លូវខាងច្រើន ចេះហើយក្នុងនរកអស់កាលយូរ ដោយវិបាកដ៏សេស ដល់នូវភាពជាបុគ្គលមានរោគឃ្លង់ក្នុងកាលឥឡូវនេះ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សត្វទាំងនេះត្រាច់ធ្វើកម្ម មានផល ក្តៅក្រហាយដល់ខ្លួនឯង ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិ សម្តែងធម៌ឲ្យក្រៃលែងឡើង ទើបត្រាស់ព្រះគាថានេះថា

**ចរន្តិ ពាលា ទុម្មេធា អមិត្តេនេវ អត្តនា**
**ករោន្តា បាបកំ កម្មំ យំ ហោតិ កដុកប្ផលំ ។**

បុគ្គលធ្វើកម្មណាហើយ រមែងក្តៅក្រហាយ ឬមានមុខ
ប្រឡាក់ដោយទឹកភ្នែក ស្រែកយំទទួលផលនៃកម្មណា
កម្មដែលគេធ្វើហើយនោះ ឈ្មោះថា កម្មមិនល្អឡើយ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ចរន្តិ** សេចក្តីថា ត្រាច់ធ្វើអកុសលតែម្យ៉ាង ដោយឥរិយាបថ ៤ ។

ជនទាំងឡាយដែលមិនដឹងប្រយោជន៍ក្នុងលោកនេះ និងប្រយោជន៍ក្នុងលោកខាងមុខ ឈ្មោះថា ពាលក្នុងបទថា **ពាលា** នេះ ។

បទថា **ទុម្មេធា** គឺមិនមានប្រាជ្ញា ។ បទថា **អមិត្តេនេវ** សេចក្តីថា ហាក់បីដូចបុគ្គលមានពៀរ ដែលមិនមែនមិត្រ ។ បទថា **កដុកប្ផលំ** សេចក្តីថា មានផលរីង គឺមានទុក្ខជាផល ។

ក្នុងកាលចប់ទេសនា ជនជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ៗ៙

រឿង សុប្បពុទ្ធកុដ្ឋិ ចប់

# រឿង អ្នកស្រែ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអ្នកស្រែម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **ន តំ កម្មំ កតំ សាធុ** ជាដើម ។

បានឮថា អ្នកស្រែនោះភ្ជួរស្រែមួយកន្លែង ដែលនៅមិនឆ្ងាយអំពីក្រុងសាវត្ថី ពួកចោរចូលទៅកាន់ព្រះនគរតាមលូទឹក ទម្លាយឧម្មង្គក្នុងត្រកូលស្តុកស្តម្ភមួយ ចូលទៅកាន់យកប្រាក់ និងមាសជាច្រើន ហើយចេញទៅតាមលូទឹកនោះឯង ។ ចោរម្នាក់បោកបញ្ឆោតចោរទាំងនោះ ផ្ញើថង់ដែលពេញដោយទ្រព្យមួយពាន់ ទុកត្រង់ជាយសំពត់ហើយទៅដល់ស្រែនោះ ចែកកណ្ឌៈជាមួយនឹងចោរទាំងឡាយហើយ កាន់សំពត់ដើរទៅ មិនបានកំណត់ដល់ថង់ទ្រព្យមួយពាន់ ដែលធ្លាក់អំពីបន្ទេចសំពត់ ។

ក្នុងថ្ងៃនោះពេលទៀបភ្លឺ ព្រះសាស្តាទ្រង់ប្រមើលមើលសត្វលោក ទ្រង់ឃើញអ្នកស្រែនោះ ចូលទៅខាងក្នុងសំណាញ់ គឺព្រះញាណរបស់ព្រះអង្គ ហើយទ្រង់ពិចារណាថា នឹងមានហេតុអ្វីហ្ន៎ ទ្រង់បានឃើញហេតុនេះថា អ្នក

ស្រែនេះនឹងទៅភ្ជួរស្រែអំពីព្រលឹម សូម្បីពួកម្ចាស់ទ្រព្យ ទៅតាមស្នាមជើងរបស់ចោរទាំងឡាយហើយ ឃើញថង់ដែលដាក់ទ្រព្យមួយពាន់ក្នុងស្រែ របស់អ្នកស្រែនោះហើយ នឹងចាប់អ្នកស្រែនោះ វៀរតថាគតហើយ អ្នកដទៃឈ្មោះថាជាបន្ទាល់របស់អ្នកស្រែនោះ មិនមាន សូម្បីឧបនិស្ស័យនៃសោតាបត្តិមគ្គរបស់អ្នកស្រែនោះក៏មាន តថាគតទៅទីនោះ គួរ ។ ចំណែកអ្នកស្រែនោះទៅដើម្បីភ្ជួរស្រែអំពីព្រលឹម ព្រះសាស្តា មានព្រះអានន្ទត្ថេរជាបច្ឆាសមណៈបានយាងទៅក្នុងទីនោះហើយ ។ អ្នកស្រែឃើញព្រះសាស្តាហើយ ទៅថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយផ្តើមភ្ជួរស្រែទៀត ។ ព្រះសាស្តាមិនត្រាស់ពាក្យណាមួយជាមួយគាត់ឡើយ ទ្រង់យាងទៅកាន់ទីដែលថង់ទ្រព្យមួយពាន់ធ្លាក់ចុះ ទតថង់នោះហើយ ទើបត្រាស់នឹងព្រះអានន្ទត្ថេរថា អានន្ទ អ្នកឃើញអាសិរពិសទេ ព្រះអានន្ទត្ថេរទូលថា ឃើញព្រះអង្គ អាសិរពិសកាច អ្នកស្រែបានឮពាក្យនោះហើយ គិតថា ពេលនេះជាកាលទៅ ឬមិនមែនកាលរបស់អញបានឮថា អាសិរពិសមានក្នុងទីនោះ កាលព្រះសាស្តាត្រាស់ពាក្យមានប្រមាណប៉ុណ្ណោះ ទ្រង់យាងទៅហើយ ទើបកាន់យករំពាត់ គឺដងជន្ទ្រញទៅដោយតាំងចិត្តថា អញនឹងសម្លាប់អាសិរពិសនោះ ។ ឃើញថង់ដាក់ទ្រព្យមួយពាន់ គិតថា ពាក្យនោះ ជាពាក្យដែលព្រះសាស្តាត្រាស់សំដៅយកថង់ដាក់ទ្រព្យមួយពាន់នេះ ទើបកាន់យកថង់ដាក់ទ្រព្យមួយពាន់នោះត្រឡប់ទៅ ព្រោះភាពដែលខ្លួនជាអ្នកមិនឈ្លាស ទើបញាត់ទុកក្នុងទីសមគួរមួយកន្លែង លុបដោយធូលីហើយផ្តើមភ្ជួរស្រែទៀត ។

សូម្បីពួកមនុស្ស កាលរាត្រីអស់ហើយ ឃើញកម្មដែលពួកចោរធ្វើក្នុងផ្ទះ ទើបដើរតាមស្នាមជើងទៅដល់ស្រែនោះហើយ ឃើញទីដែលពួកចោរចែកកណ្ឌៈគ្នាក្នុងស្រែនោះ បានឃើញស្នាមជើងរបស់អ្នកស្រែហើយ ។ មនុស្សទាំងនោះទៅតាមស្នាមជើងរបស់អ្នកស្រែនោះ ឃើញថង់ទ្រព្យដែលអ្នកស្រែរក្សាទុក កាយធូលីចេញហើយ កាន់យកថង់ទ្រព្យ គំរាមថា ឯងប្លន់ផ្ទះហើយ ត្រាច់ទៅធ្វើជាភ្ជួរស្រែឬ វាយដោយដំបងនាំទៅបង្ហាញដល់ព្រះរាជាហើយ ។ ព្រះរាជា ទ្រង់ស្តាប់ការប្រព្រឹត្តទៅនោះហើយ ទើបបញ្ជាឲ្យប្រហារជីវិតអ្នកស្រែនោះ ។ ពួករាជបុរសចងស្លាបសេកវាយដោយផ្តៅ នាំទៅកាន់ផ្លូវបែកជា ៤ ហើយ អ្នកស្រែនោះត្រូវរាជបុរសវាយដោយផ្តៅ មិនពោលពាក្យណាដទៃឡើយ ពោលតែពាក្យថា ម្នាលអានន្ទអ្នកឃើញអាសិរពិសទេ បពិត្រព្រះអង្គ ខ្ញុំព្រះអង្គឃើញ អាសិរពិសកាចដើរទៅ ។ គ្រានោះ ពួករាជបុរសសួរថា ឯងពោលពាក្យរបស់ព្រះសាស្តានិងព្រះអានន្ទត្ថេរប៉ុណ្ណោះ តើមានរឿងអ្វី អ្នកស្រែឆ្លើយថា បើខ្ញុំបានគាល់ព្រះរាជា ទើបប្រាប់ ទើបនាំទៅកាន់សម្នាក់របស់ព្រះរាជា ក្រាបទូលការប្រព្រឹត្តទៅនោះដល់ព្រះរាជាហើយ ។

លំដាប់នោះ ព្រះរាជាត្រាស់សួរអ្នកស្រែនោះថា ព្រោះហេតុអ្វី ទើបពោលដូច្នោះ អ្នកស្រែនោះក្រាបទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គមិនមែនចោរទេ ហើយក៏ក្រាបទូលរឿងទាំងអស់នោះដល់ព្រះរាជា តាំងអំពីកាលដែលខ្លួនចេញទៅដើម្បីភ្ជួរស្រែ ។ ព្រះរាជា ទ្រង់ស្តាប់ពាក្យអ្នកស្រែ

នោះហើយ ត្រាស់ថា នែអ្នក អ្នកស្រែនេះយកព្រះសាស្តាដែលជាអគ្គបុគ្គល ក្នុងលោកជាសាក្សី យើងលើកទោសដល់អ្នកស្រែមិនសមគួរ យើងនឹងដឹងវត្ថុដែលគួរធ្វើក្នុងរឿងនេះ ដូច្នេះហើយ ទ្រង់នាំអ្នកស្រែនោះ ទៅកាន់សម្នាក់របស់ព្រះសាស្តាក្នុងពេលល្ងាច ទូលសួរព្រះសាស្តាថា បពិត្រព្រះដ៏មានព្រះភាគ ទ្រង់បានយាងទៅកាន់ទីក្ជួរស្រែរបស់អ្នកស្រែនោះ ជាមួយនឹងព្រះអានន្ទត្ថេរមែនឬ ព្រះសាស្តាត្រាស់ថា សូមថ្វាយព្រះពរ ពិតមែនហើយ ។ ព្រះរាជាត្រាស់ថា ទ្រង់ទតឃើញអ្វីក្នុងស្រែនោះ ព្រះសាស្តាត្រាស់ថា មហាបពិត្រតថាគតឃើញថង់ទ្រព្យមួយពាន់ ព្រះរាជាត្រាស់ថា ទតឃើញហើយត្រាស់ដូចម្តេច ព្រះសាស្តាត្រាស់ថា តថាគតត្រាស់ពាក្យនេះ ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ បើបុរសនេះ មិនបានធ្វើការអាងបុគ្គលដូចគ្នានឹងព្រះអង្គហើយសោត គាត់នឹងមិនបានជីវិត តែគាត់ពោលពាក្យដែលទ្រង់ត្រាស់ហើយ ទើបបានទូវជីវិត ។

ព្រះសាស្តា ទ្រង់ស្តាប់ព្រះរាជតម្រាស់នោះហើយត្រាស់ថា សូមថ្វាយព្រះពរមហាបពិត្រ តថាគតពោលពាក្យមានប្រមាណប៉ុណ្ណោះហើយក៏ទៅ ការតាមក្តៅក្រហាយក្នុងកាលខាងក្រោយរមែងមាន ព្រោះធ្វើកម្មណា កម្មនោះបុគ្គលឈ្មោះថាជាបណ្ឌិតមិនគប្បីធ្វើ ដូច្នេះ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

ន តំ កម្មំ កតំ សាធុ យំ កត្វា អនុតប្បតិ
យស្ស អស្សុមុខោ រោទំ វិបាកំ បដិសេវតិ ។

បុគ្គលធ្វើកម្មណាហើយ រមែងក្ដៅក្រហាយ ឬមានមុខ
ប្រឡាក់ដោយទឹកភ្នែកស្រែកយំ ទទួលផលនៃកម្មណា
កម្មដែលគេធ្វើហើយនោះ ឈ្មោះថា ជាកម្មមិនល្អឡើយ ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ ពីរបទថា **យំ កត្វា** សេចក្ដីថា បុគ្គលធ្វើកម្មណា គឺដែលអាចឲ្យកើតក្នុងអបាយភូមិទាំងឡាយ មាននរកជាដើម បានដល់ មានទុក្ខជាផល កាលតាមរឭកដល់ ឈ្មោះថា ក្ដៅក្រហាយក្នុងកាលជាខាងក្រោយ គឺរមែងសោយសោកក្នុងកាលជាខាងក្រោយ ក្នុងខណៈដែលរឭកដល់ហើយ កម្មនោះដែលបុគ្គលធ្វើហើយមិនល្អ គឺមិនស្អាត បានដល់ មិនស្អាតស្អំ ។

ពីរបទថា **យស្ស អស្សុមុខោ** សេចក្ដីថា មានមុខជោកដោយទឹកភ្នែក រមែងសោយផលកម្មណា ។

ក្នុងកាលចប់ទេសនា ឧបាសកអ្នកស្រែសម្រេចសោតាបត្តិផលហើយ ភិក្ខុដែលប្រជុំគ្នាជាច្រើន ក៏សម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

រឿងអ្នកស្រែ ចប់

# រឿង សុមនមាលាការ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធមាលាការឈ្មោះសុមនៈ ត្រាស់ព្រះធម្មទេសនានេះថា **តញ្ច កម្មំ កតំ សាធុ** ជាដើម ។

បានឮមកថា មាលាការនោះផ្គត់ផ្គង់ព្រះបាទពិម្ពិសារដោយផ្កាម្លិះ ៨ នាឡិ អំពីព្រលឹមរាល់ថ្ងៃ រមែងបានមួយថ្ងៃ ៨ កហាបណៈ ។ សម័យថ្ងៃមួយកាលមាលាការនោះកាន់ផ្កាចូលទៅកាន់ព្រះនគរ ព្រះដ៏មានព្រះភាគ ដែលមហាភិក្ខុសង្ឃចោមរោម ទ្រង់បញ្ចេញព្រះរស្មីមានពណ៌ ៦ ចូលទៅកាន់ព្រះនគរ ដើម្បីបិណ្ឌបាត ដោយពុទ្ធានុភាពដ៏ធំ ដោយព្រះពុទ្ធលីលាដ៏ធំ ។ ពិតហើយ ក្នុងកាលខ្លះ ព្រះដ៏មានព្រះភាគ ទ្រង់បិទព្រះរស្មីដែលមាន ៦ ពណ៌ ដោយចីវរ ហើយយាងទៅ ដូចភិក្ខុអ្នកត្រាច់បិណ្ឌបាតជាវត្ត អង្គណាមួយអង្គ ដូចជាកាលយាងទៅទទួលអង្គុលិមាល៍ អស់ចម្ងាយផ្លូវ ៣០ យោជន៍ ក្នុងកាលខ្លះ ទ្រង់បញ្ចេញឆព្វណ្ណរង្សី ដូចកាលយាងទៅកាន់ក្រុងកបិលវត្ថុជាដើម ក្នុងថ្ងៃនោះ ព្រះដ៏មានព្រះភាគ ទ្រង់បញ្ចេញឆព្វណ្ណរង្សីអំពីព្រះសរីរៈ យាងទៅកាន់ក្រុងរាជគ្រឹះ ដោយពុទ្ធានុភាពធំ ដោយព្រះពុទ្ធលីលាធំ ។

គ្រានោះ មាលាការឃើញអត្តភាពព្រះដ៏មានព្រះភាគ ដូចគ្នានឹងរតនៈដ៏មានតម្លៃ និងមាសដ៏មានតម្លៃ សម្លឹងមើលព្រះសរីរៈដែលប្រដាប់ហើយ ដោយមហាបុរិសលក្ខណៈ ៣២ មានចំណែកលម្អដោយសិរី គឺអនុព្យញ្ជនៈ ៨០ មានចិត្តជ្រះថ្លាហើយ គិតថា អញនឹងធ្វើការបូជាដ៏ក្រៃលែង ដល់ព្រះ

សាស្តា ដូចម្តេចហ្ន៎ កាលមិនឃើញវត្ថុដទៃ ទើបគិតថា អាត្មាអញនឹងបូជាព្រះដ៏មានព្រះភាគដោយផ្កាទាំងនេះ គិតទៀតថា ផ្កាទាំងនេះជាផ្កាសម្រាប់ផ្គត់ផ្គង់ព្រះរាជាជាប្រចាំ បើព្រះរាជាទ្រង់មិនបានផ្កាទាំងនេះ គប្បីចងអញក្តី គប្បីសម្លាប់អញក្តី គប្បីបំបរបង់អញចេញចាកដែនក្តី អញនឹងធ្វើដូចម្តេចហ្ន៎ ។ គ្រានោះ ការគិតយ៉ាងនេះមានដល់មាលាការនោះថា ទោះព្រះរាជាសម្លាប់អញក្តី បណ្តេញអញចេញចាកដែនក្តី ព្រះរាជានោះ ទោះព្រះរាជទានដល់អញ គប្បីព្រះរាជទានទ្រព្យត្រឹមតែចិញ្ចឹមជីវិតក្នុងអត្តភាពនេះ ចំណែកការបូជាព្រះសាស្តា អាចដើម្បីជាប្រយោជន៍ និងសេចក្តីសុខដល់អញ ក្នុងកោដិកប្បជាអនេក លះបង់ជីវិតរបស់ខ្លួនដល់ព្រះសាស្តាហើយ ។ មាលាការនោះ គិតថា ចិត្តជ្រះថ្លារបស់អញមិនប្រែប្រួលដរាបណា អញនឹងធ្វើការបូជាដរាបនោះឯង ជាអ្នកត្រេកអរហើយ មានចិត្តរីករាយ និងផូរផង់ បូជាព្រះសាស្តាហើយ ។

មាលាការនោះបូជាដូចម្តេច ដំបូងមាលាការបាចផ្កាពីរក្តាប់ឡើងទៅខាងលើនៃព្រះតថាគតមុន ។ ផ្កាពីរក្តាប់នោះ បានតាំងជាពិតានខាងលើព្រះសីសៈ គាត់បាចផ្កាពីរក្តាប់ទៀត ផ្កាពីរក្តាប់នោះ បានសំយុងចុះមកតាំងនៅខាងស្តាំព្រះហស្ត ដោយអាការមាលាបាំង ។ គាត់បាចពីរក្តាប់ទៀត ផ្កាពីរក្តាប់នោះសំយុងចុះមកតាំងនៅខាងក្រោយព្រះបិដ្ឋិយ៉ាងនោះដូចគ្នា គាត់បាចពីរក្តាប់ទៀត ផ្កានោះសំយុងចុះតាំងនៅត្រង់ព្រះហស្តឆ្វេងយ៉ាងនោះដូចគ្នា ។ ផ្កា ៨ នាឡិ ជា ៨ ក្តាប់ ចោមរោមព្រះតថាគតក្នុងឋានៈទាំង ៤ ដោយប្រការ

ដូច្នេះ ។ មានផ្លូវល្អមជាទ្វារដើរទៅខាងមុខប៉ុណ្ណោះ ទងផ្កាទាំងឡាយបែរចូលទៅខាងក្នុង ត្របកចេញមកខាងក្រៅ ។ ព្រះដ៏មានព្រះភាគ ហាក់បីដូចចោមរោមដោយបន្ទះប្រាក់ យាងទៅហើយ ។ ផ្កាទាំងឡាយមិនមានចិត្ត អាស្រ័យបុគ្គលដែលមានចិត្ត មិនបែកគ្នា មិនធ្លាក់ចុះ រមែងទៅជាមួយព្រះសាស្ដានោះឯង រមែងឈប់ក្នុងទីដែលទ្រង់ប្រថាប់ឈរ ។ រស្មីដូចផ្លេកបន្ទោររាប់ខ្សែចេញអំពីព្រះសរីរៈរបស់ព្រះសាស្ដា ។ រស្មីដែលចេញអំពីព្រះកាយនោះ ចេញទាំងខាងមុខ ទាំងខាងខ្នង ទាំងខាងស្ដាំ ទាំងខាងឆ្វេង ទាំងខាងលើព្រះសីសៈ ។ ព្រះរស្មីសូម្បីតែមួយខ្សែ មិនបាត់ទៅត្រង់ទីចំពោះព្រះភក្ត្រ រស្មីទាំងអស់ធ្វើប្រទក្សិណព្រះសាស្ដា ៣ ជុំហើយ ផ្គុំជាព្រះរស្មីមានប្រមាណប៉ុនដើមត្នោតជំទង់ បាញ់ត្រង់ទៅខាងមុខតែម្យ៉ាង ។

នគរទាំងមូលភ្ញាក់ផ្អើលហើយ ។ បណ្ដាជន ១៨ កោដិ គឺខាងក្នុងនគរ ៩ កោដិ ខាងក្រៅនគរ ៩ កោដិ ស្ត្រី ឬបុរសសូម្បីតែម្នាក់ ឈ្មោះថា មិនកាន់យកកិក្ខាចេញទៅ មិនមាន ។ មហាជនបន្លឺសីហនាទ ធ្វើការលើកទង់ជ្វាលារាប់ពាន់ខាងមុខព្រះសាស្ដានោះឯង ។ ព្រះសាស្ដា ដើម្បីធ្វើគុណរបស់មាលាការឲ្យប្រាកដ បានយាងទៅក្នុងព្រះនគរប្រមាណ ៣ គាវុត ដោយផ្លូវដែលត្រាច់ទៅដោយស្គរនោះឯង ។ សរីរៈទាំងមូលរបស់មាលាការពេញទៅដោយបីតិទាំង ៥ មាលាការនោះ ត្រាច់ទៅជាមួយព្រះតថាគតបន្តិចប៉ុណ្ណោះ ចូលទៅខាងក្នុងពុទ្ធរស្មី ហាក់បីដូចលិចចុះក្នុងរសនៃមនោសិលា សរសើរថ្វាយបង្គំព្រះសាស្ដាហើយ បានកាន់យកកំប្រោងទទេនោះឯងទៅកាន់ផ្ទះ ។

គ្រានោះ កវិយាសួរថា ផ្កានៅឯណា មាលាការពោលថា ខ្ញុំបូជាព្រះសាស្តាហើយ ។ ភរិយាពោលថា ឥឡូវនេះ អ្នកនឹងធ្វើដូចម្តេចចំពោះព្រះរាជា មាលាការពោលថា ព្រះរាជាសម្លាប់ខ្ញុំក្តី បណ្តេញខ្ញុំចាកដែនក្តី ខ្ញុំលះបង់ជីវិតបូជាព្រះសាស្តាហើយ ផ្កាទាំងអស់មាន ៨ ក្តាប់ បូជា ហេតុបែបនេះកើតឡើងហើយ មហាជនធ្វើការស្រែករបាំពាន់ ត្រាច់ទៅជាមួយព្រះសាស្តានោះ ជាសំឡេងស្រែករបស់មហាជនក្នុងទីនោះ ។

លំដាប់នោះ ភរិយារបស់គាត់ជាស្រីអន្ធពាល មិនញ៉ាំងការជ្រះថ្លាក្នុងបាដិហារ្យបែបនោះឲ្យកើត ជេរហើយពោលថា ធម្មតាព្រះរាជាទាំងឡាយជាអ្នកកាចក្រេវក្រោធហើយ ក៏នឹងធ្វើសេចក្តីវិនាសច្រើន ដោយការកាត់ដៃ និងជើងជាដើម ការវិនាសគប្បីមានដល់ខ្ញុំ ព្រោះកម្មដែលអ្នកធ្វើ នាំកូនទាំងឡាយទៅកាន់រាជត្រកូល ។ កាលព្រះរាជាហៅមកសួរថា តើមានរឿងអ្វី ទើបក្រាបទូលថា ប្តីរបស់ខ្ញុំម្ចាស់យកផ្កាសម្រាប់ទំនុកបម្រុងទ្រង់ បូជាព្រះសាស្តាហើយ មានដៃទទេមកកាន់ផ្ទះ ត្រូវខ្ញុំម្ចាស់សួរថា ផ្កានៅឯណា ក៏ពោលពាក្យឈ្មោះនេះ ខ្ញុំជេរគាត់ហើយថា ធម្មតាព្រះរាជាទាំងឡាយជាអ្នកកាចក្រេវក្រោធតែម្តង ក៏ធ្វើនូវការវិនាសច្រើន ដោយការកាត់ដៃ និងជើងជាដើម ការវិនាសគប្បីមានដល់ខ្ញុំ ព្រោះកម្មដែលអ្នកធ្វើ ដូច្នេះហើយ ក៏ចោលគាត់មកក្នុងទីនេះ កម្មដែលគាត់ធ្វើទោះជាកម្មល្អក្តី កម្មអាក្រក់ក្តី កម្មនោះសូមជារបស់គាត់តែម្នាក់ សូមទ្រង់ជ្រាបភាពដែលគាត់ ត្រូវខ្ញុំម្ចាស់លែងលះចោលហើយ ។

ព្រះរាជាទ្រង់សម្រេចសោតាបត្តិផល ដល់ព្រមដោយសទ្ធា ជាអរិយ-សាវកដោយការជួបជំបូងនោះឯង ទ្រង់ត្រិះរិះថា ឱ ស្រីនេះជាអន្ធពាល មិនញ៉ាំងការជ្រះថ្លាក្នុងគុណបែបនេះឲ្យកើតឡើង ទ្រង់ធ្វើជាក្រោធត្រាស់ថា នាងនិយាយអ្វី មាលាការនោះធ្វើការបូជាដោយផ្កាសម្រាប់ទំនុកបម្រុងយើងឬ ស្រីនោះទូលថា ពិតហើយព្រះអង្គ ។ ព្រះរាជាត្រាស់ថា ល្អណាស់ ដែលនាងលះបង់គេ យើងនឹងដឹងកិច្ចដែលគួរធ្វើដល់មាលាការ ដែលជាអ្នកធ្វើការបូជាដោយផ្កាទាំងឡាយរបស់យើង ។ ទ្រង់បញ្ជូនស្រីនោះទៅហើយ ប្រញាប់យាងទៅកាន់សម្នាក់ព្រះសាស្តា ថ្វាយបង្គំហើយ យាងទៅជាមួយព្រះសាស្តានោះឯង ។ ព្រះសាស្តា ទ្រង់ជ្រាបការជ្រះថ្លានៃព្រះហឫទ័យរបស់ព្រះរាជានោះ ទ្រង់យាងទៅកាន់ព្រះនគរតាមវិថី ដែលត្រាច់ទៅដោយស្គរហើយ បានយាងទៅកាន់ទ្វារនៃព្រះរាជមន្ទីររបស់ព្រះរាជា ។ ព្រះរាជាទទួលបាត្រ ទ្រង់មានបំណងយាងព្រះសាស្តាចូលទៅកាន់ព្រះរាជមន្ទីរ ។ ចំណែកព្រះសាស្តាទ្រង់បានសម្តែងព្រះអាការប្រថាប់គង់ ក្នុងលានព្រះរាជវាំងនោះឯង ។ ព្រះរាជាទ្រង់ជ្រាបព្រះអាការនោះហើយ ត្រាស់ឲ្យធ្វើបុស្បុកក្នុងខណៈនោះឯង ដោយព្រះតម្រាស់ថា អ្នកទាំងឡាយ ចូរធ្វើបុស្បុកដោយរហ័ស ។ ព្រះសាស្តាប្រថាប់គង់ជាមួយនឹងពួកភិក្ខុហើយ ។

សួរថា ព្រោះហេតុអ្វី ទើបព្រះសាស្តាមិនចូលកាន់ព្រះរាជមន្ទីរ ឆ្លើយថា បានឮថា បរិវិតក្កយ៉ាងនេះមានដល់ទ្រង់ថា បើតថាគតចូលទៅខាងក្នុងសោត មហាជនមិនបានឃើញតថាគត គុណរបស់មាលាការនឹងមិនប្រាកដ

តែមហាជន នឹងបានឃើញតថាគតអង្គុយក្នុងលានព្រះរាជវាំង គុណរបស់មាលាការនឹងប្រាកដ ។

មែនពិត ព្រះពុទ្ធនៃយើងប៉ុណ្ណោះ ដែលអាចធ្វើគុណរបស់បុគ្គលដែលមានគុណទាំងឡាយឲ្យប្រាកដ ជនដ៏សេសកាលនឹងពោលគុណរបស់បុគ្គលមានគុណទាំងឡាយ រមែងប្រព្រឹត្តកំណាញ់ គឺដោយអម ។ បន្ទះផ្កា ៤ បន្ទះបានតាំងនៅក្នុងទិសទាំង ៤ ហើយ ។ មហាជនចោមរោមព្រះសាស្ដាហើយ ។ ព្រះរាជាទ្រង់អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយអាហារដ៏ប្រណីត ។ ក្នុងកាលស្រេចភត្តកិច្ច ព្រះសាស្ដាទ្រង់ធ្វើអនុមោទនាហើយ ញ៉ាំងកម្រាលផ្កា ៤ ផ្ទាំង ដែលចោមរោមដោយន័យមុននោះឯង ដែលមហាជនបន្លឺសីហនាទចោមរោម ទ្រង់ទៅកាន់វិហារហើយ ព្រះរាជាជូនដំណើរព្រះសាស្ដា ហើយយាងត្រឡប់ ត្រាស់ឲ្យហៅមាលាការមកហើយ សួរថា ហេតុអ្វី ទើបអ្នកបូជាព្រះសាស្ដាដោយផ្កា ដែលខ្ញុំនតប្បីនាំមកដើម្បីយើង មាលាការក្រាបទូលថា បពិត្រព្រះអង្គ ទូលបង្គំគិតថា ទោះបីព្រះរាជាសម្លាប់អញក្ដី បណ្ដេញអញចេញចាកដែនក្ដី ដូច្នេះហើយ ទើបលះបង់ជីវិតបូជាព្រះសាស្ដា ព្រះរាជាត្រាស់ថា អ្នកជាមហាបុរស ហើយព្រះរាជទានរបស់ដែលគួរឲ្យមួយមុខ ៨ៗ នៃវត្ថុទាំងនេះ គឺដំរី ៨ សេះ ៨ ទាសៈ ៨ ទាសី ៨ គ្រឿងប្រដាប់ធំ ៨ កហាបណៈ ៨ ពាន់ នារី ៨ អង្គ ដែលនាំមកអំពីរាជត្រកូល ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង និងស្រុក ៨ ។

ព្រះអានន្ទត្ថេរគិតថា ថ្ងៃនេះតាំងអំពីព្រលឹម សំឡេងសីហនាទរាប់ពាន់

និងការលើកកំណាត់សំពត់ឡើងរាប់ពាន់ រមែងប្រព្រឹត្តទៅ ។ វិបាករបស់មាលាការដូចម្ដេចហ្ន៎ ។ ព្រះថេរៈនោះទូលសួរព្រះសាស្ដាហើយ ។ លំដាប់នោះ ព្រះសាស្ដាត្រាស់នឹងព្រះថេរៈថា ម្នាលអានន្ទ អ្នកកុំកំណត់ថា កម្មមានប្រមាណតិចដែលមាលាការនោះធ្វើហើយ ឯមាលាការនេះ លះបង់ជីវិតធ្វើការបូជាតថាគតហើយ ញុំាងចិត្តឲ្យជ្រះថ្លាក្នុងតថាគតដោយអាការយ៉ាងនេះ មិនទៅកាន់ទុគ្គតិអស់សែននៃកប្ប ដូច្នេះហើយ ត្រាស់ថា

មាលាការតាំងនៅក្នុងទេវតា និងមនុស្សទាំងឡាយ នឹងមិនទៅ
កាន់ទុគ្គតិ អស់សែនកប្ប នេះជាផលនៃកម្មនោះ ក្នុងកាល
អនាគត នឹងបានជាព្រះបច្ចេក ពុទ្ធនាមថា សុមនៈ ។

ក្នុងកាលព្រះសាស្ដាយាងដល់វិហារ ចូលទៅកាន់ព្រះគន្ធកុដិ ផ្កាទាំងនោះធ្លាក់ចុះត្រង់មាត់ទ្វារហើយ ។

ក្នុងវេលាល្ងាច ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងរោងធម្មសភាថា ឱ កម្មរបស់មាលាការគួរអស្ចារ្យ គាត់លះបង់ជីវិតដើម្បីព្រះសម្ពុទ្ធ ដែលកំពុងគង់ព្រះជន្មនៅ ធ្វើការបូជាដោយផ្កាហើយ បានទទួលរបស់ព្រះរាជទានមួយមុខ ៨ៗ ក្នុងខណៈនោះឯង ។ ព្រះសាស្ដាចេញចាកព្រះគន្ធកុដិហើយ ទៅកាន់រោងធម្មសភា ដោយការយាងទៅ ៣ យ៉ាងណាមួយ ប្រថាប់គង់លើពុទ្ធាសនៈហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយកថាអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា ដោយកថាឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង ការក្ដៅក្រហាយក្នុងកាល

ជាខាងក្រោយ រមែងមិនមាន សោមនស្សប៉ុណ្ណោះ រមែងកើតឡើងក្នុងខណៈដែលរឭកហើយ ព្រោះបុគ្គលធ្វើនូវកម្មណា កម្មបែបនោះ បុគ្គលគួរធ្វើពិត កាលបន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**តញ្ច កម្មំ កតំ សាធុ យំ កត្វា នានុតប្បតិ**
**យស្ស បតីតោ សុមនោ វិបាកំ បដិសេវតិ ។**

បុគ្គលធ្វើកម្មណាហើយ រមែងមិនក្តៅក្រហាយ ឬដល់នូវសេចក្តីពេញចិត្ត មានចិត្តល្អ ទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះឯង ឈ្មោះថា ជាកម្មល្អ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **យំ កត្វា** សេចក្តីថា បុគ្គលធ្វើកម្មណា គឺកម្មដែលអាចញុំាងសម្បត្តិនៃទេវតា សម្បត្តិនៃមនុស្ស និងនិព្វានសម្បត្តិឲ្យកើត គឺមានសុខជាផល រមែងមិនតាមក្តៅក្រហាយដោយពិត បុគ្គលនោះឈ្មោះថា ជាអ្នកត្រេកត្អរហើយ ដោយកម្លាំងនៃបីតិ និងឈ្មោះថា មានចិត្តល្អដោយកម្លាំងនៃសោមនស្ស ក្នុងខណៈដែលរឭកដល់រឿយៗ ជាអ្នកកើតបីតិនិងសោមនស្សក្នុងកាលតទៅ រមែងសោយផលក្នុងទិដ្ឋធម៌នោះឯង កម្មនោះដែលបុគ្គលធ្វើហើយជាកម្មល្អ គឺជាសុចរិតកម្ម បានដល់ កម្មប្រពៃ ។

ក្នុងវេលាចប់ទេសនា ការត្រាស់ដឹងធម៌មានដល់សត្វ ៨៤០០០ ហើយដូច្នេះឯង ។ល។

**រឿង សុមនមាលាការ ចប់**

# រឿង ឧប្បលវណ្ណាថេរី

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះថេរីឈ្មោះឧប្បលវណ្ណា ត្រាស់ព្រះធម្មទេសនានេះថា **មធុវា មញ្ញតី ពាលោ** ជាដើម ។

បានឮមកថា ព្រះថេរីនោះ បានតាំងសេចក្តីប្រាថ្នាទៀបបាទមូលរបស់ព្រះពុទ្ធព្រះនាមបទុមុត្តរៈ ធ្វើបុណ្យទាំងឡាយអស់សែនកប្ប អន្ទោលទៅក្នុងទេវតា និងមនុស្ស ចុតិអំពីទេវលោក បដិសន្ធិក្នុងត្រកូលសេដ្ឋី ក្នុងក្រុងសាវត្ថី ក្នុងពុទ្ធុប្បាទកាលនេះ ។ មាតាបិតាដាក់ឈ្មោះនាងថា ឧប្បលវណ្ណា ព្រោះនាងមានពណ៌ដូចត្របកឧប្បលខៀវ សម័យតមក ក្នុងកាលដែលនាងចម្រើនវ័យហើយ ព្រះរាជា និងសេដ្ឋីទាំងឡាយក្នុងសកលជម្ពូទ្វីប បញ្ជូនបណ្ណាការទៅកាន់សម្នាក់របស់សេដ្ឋីថា សូមលោកសេដ្ឋីឲ្យធីតាដល់ខ្ញុំ ។ ឈ្មោះថា បុគ្គលមិនបញ្ជូនបណ្ណាការទៅមិនមាន ។ លំដាប់នោះ សេដ្ឋីគិតថា អញមិនអាចយកចិត្តមនុស្សទាំងឡាយបាន តែអញនឹងធ្វើឧបាយណាមួយ ។ សេដ្ឋីនោះហៅកូនស្រីមកហើយពោលថា នែនាង នាងអាចបួសដែរឬទេ ។ ពាក្យរបស់បិតាហាក់ដូចជាប្រេង ដែលចម្រាញ់ហើយរាប់រយដង ដែលគេស្រោចលើសីសៈ ព្រោះនាងមានកពជាទីបំផុត ព្រោះដូច្នោះ ទើបនាងឆ្លើយនឹងបិតាថា បពិត្រលោកឪពុក ខ្ញុំនឹងបួស ។ សេដ្ឋីធ្វើសក្ការៈដ៏ច្រើនដល់នាង ហើយនាំទៅកាន់សម្នាក់ភិក្ខុនី ហើយឲ្យបួស ។

កាលនាងបួសហើយមិនយូរ ក្នុងវារៈរក្សាត្រដោកទ្វារក្នុងរោងឧបោសថ

ដល់ហើយ នាងអុជប្រទីប ពោសពេងឧពោសថ ឈរកាន់យកនិមិត្តនៃអណ្តាតប្រទីប សម្លឹងមើលហើយមើលទៀត ញុំាងឈានមានតេជោកសិណជាអារម្មណ៍ឲ្យកើតហើយ ធ្វើឈាននោះឯងឲ្យជាបាទសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា និងអភិញ្ញាទាំងឡាយហើយ ។ ដោយសម័យដទៃ ព្រះថេរីនោះត្រាច់ចារិកទៅក្នុងជនបទ ត្រឡប់មកហើយ ចូលទៅកាន់ព្រៃអន្ធវន ។ ក្នុងកាលនោះ ព្រះសាស្តា ទ្រង់មិនទាន់ហាមការនៅព្រៃរបស់ភិក្ខុនី ។ គ្រានោះពួកមនុស្សធ្វើតូប ដាក់គ្រែ បាំងវាំងននទុកក្នុងព្រៃនោះ ដល់ព្រះថេរីនោះ ។ ព្រះថេរីចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថីចេញមកហើយ ។

ចំណែកនន្ទមាណព ជាកូននៃអ៊ំរបស់ព្រះថេរីនោះ មានចិត្តប្រតិព័ទ្ធតាំងអំពីកាលព្រះថេរីនៅជាគ្រហស្ថ ស្តាប់ភាពដែលព្រះថេរីមក ទើបទៅកាន់ព្រៃអន្ធវនមុនព្រះថេរីមកនោះឯង ចូលទៅកាន់តូប លាក់ខ្លួនក្រោមគ្រែ លុះព្រះថេរីមកហើយ ចូលទៅកាន់តូបបិទទ្វារអង្គុយលើគ្រែ កាលភាពងងឹតក្នុងគន្លងចក្ខុមិនទាន់បាត់ ព្រោះមកអំពីទីភ្លឺ ត្រូវកម្តៅថ្ងៃខាងក្រៅ ទើបនន្ទមាណពចេញអំពីក្រោមគ្រែ ឡើងលើគ្រែហើយ ត្រូវព្រះថេរីឃាត់ថា ជនពាល អ្នកកុំវិនាសឡើយ ជនពាល អ្នកកុំវិនាសឡើយ ចាប់បង្ខំធ្វើកម្មដែលខ្លួនប្រាថ្នាហើយចៀសចេញទៅ ។ កាលនោះ ផែនដីធំ ហាក់ដូចជាមិនអាចទ្រទ្រង់នូវទោសរបស់មាណពបាន ក៏ប្រេះជាពីរចំណែកហើយ មាណពចូលទៅកាន់ផែនដីកើតក្នុងអវីចីមហានរកហើយ ។

ចំណែកព្រះថេរី ប្រាប់សេចក្តីនោះដល់ភិក្ខុនីទាំងឡាយហើយ ពួកភិក្ខុនី

ប្រាប់សេចក្ដីនោះដល់ភិក្ខុទាំងឡាយ ពួកភិក្ខុក្រាបទូលដល់ព្រះសាស្ដា ។

ព្រះសាស្ដា កាលស្ដាប់រឿងនោះហើយ ត្រាស់ហៅភិក្ខុទាំងឡាយមក ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ណាមួយ ជាបុគ្គលពាល កាលធ្វើកម្មលាមក ជាអ្នកត្រេកអរ ហាក់ដូចជាផ្សាយឡើង រមែងធ្វើបាន ដូចបុរសទំពាស៊ីនូវរសផ្អែម មានទឹកឃ្មុំ និងស្ករអំពៅជាដើមណាមួយ ដូច្នេះហើយ កាលទ្រង់បន្ដអនុសន្ធិសម្ដែងធម៌ ត្រាស់ព្រះគាថានេះថា

**មធុវា មញ្ញតី ពាលោ យាវ បាបំ ន បច្ចតិ**
**យទា ច បច្ចតី បាបំ អថ ( ពាលោ ) ទុក្ខំ និគច្ឆតិ ។**

បាបមិនទាន់ឲ្យផលត្រឹមណា ជនពាលតែងសម្គាល់នូវបាបនោះថា ដូចទឹកឃ្មុំ លុះតែកាលណាបាបឲ្យផល ទើបជនពាលប្រទះនូវសេចក្ដីទុក្ខក្នុងកាលណោះ ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **មធុវា** ជាដើម សេចក្ដីថា កាលបុគ្គលពាលធ្វើបាប គឺអកុសលកម្ម កម្មនោះរមែងប្រាកដដូចទឹកឃ្មុំ គឺហាក់ដូចជាផ្អែម បានដល់ ហាក់ដូចគួរប្រាថ្នា គួរពេញចិត្ត បុគ្គលពាលនោះរមែងសម្គាល់នូវបាបនោះដូចទឹកឃ្មុំ ដោយប្រការដូច្នេះ ។

បទថា **យាវ** គឺអស់កាលត្រឹមណា ។

ពីរបទថា **បាបំ ន បច្ចតិ** សេចក្ដីថា បុគ្គលពាលរមែងសម្គាល់នូវបាប

នោះយ៉ាងនោះ ដរាបណាបាបមិនទាន់ឲ្យផលក្នុងទិដ្ឋធម៌ ឬក្នុងសម្បរាយភព ។

បទថា **យទា ច** សេចក្ដីថា ក្នុងកាលណា កាលបុគ្គលពាលនោះត្រូវធ្វើកម្មផ្សេងៗ ក្នុងទិដ្ឋធម៌ ឬសោយទុក្ខធំក្នុងអបាយ មាននរកជាដើមក្នុងសម្បរាយភព បាបនោះ ឈ្មោះថា ឲ្យផលក្នុងកាលនោះ បុគ្គលពាលនោះ រមែងចូលដល់ គឺជួប បានដល់ បាននូវសេចក្ដីទុក្ខ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

សម័យក្រោយមក មហាជនសន្ទនាគ្នាក្នុងធម្មសភាថា ព្រះខីណាស្រពទាំងឡាយ ប្រហែលជានៅត្រេកអរក្នុងកាមសុខ នៅសេពកាម ហេតុអ្វីថាមិនសេព ព្រោះព្រះខីណាស្រពទាំងនោះ មិនមែនឈើពុក មិនមែនដំបូកមានសាច់ស្រស់ ឈាមស្រស់ដូចគ្នា ព្រោះដូច្នោះ សូម្បីព្រះខីណាស្រពទាំងនោះ គង់នៅត្រេកអរក្នុងកាមសុខ នៅសេពកាម ។

ព្រះសាស្ដាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាដោយរឿងអ្វី កាលពួកភិក្ខុក្រាបទូលថា ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រះខីណាស្រពទាំងឡាយ មិនត្រេកអរក្នុងកាមសុខ មិនសេពកាម ដូចតំណក់ទឹកលើស្លឹកឈូក រមែងមិនជាប់ មិនតាំងនៅ រមែងរមៀលធ្លាក់ទៅនោះឯង និងដូចគ្រាប់ស្ពៃមិនជាប់មិនតាំងនៅត្រង់ចុងដែកស្រួច រមែងរអិលធ្លាក់ទៅដោយពិត យ៉ាងណា កាមពីរយ៉ាង រមែងមិនជ្រួតជ្រាប មិនតាំងនៅក្នុងចិត្តរបស់ព្រះខីណាស្រព ដូច្នោះ

ដូច្នេះហើយ កាលនឹងបន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះ ក្នុងព្រាហ្មណវគ្គថា

បុគ្គលណា មានចិត្តមិនបានជាប់នៅក្នុងកាមទាំងឡាយ ដូចទឹកលើស្លឹកឈូក ឬដូចគ្រាប់ស្ពៃលើចុងដែកស្រួច តថាគតហៅបុគ្គលនោះ ថាជាព្រាហ្មណ៍ ។

អត្ថនៃព្រះគាថានេះ នឹងជាក់ច្បាស់ក្នុងព្រាហ្មណវគ្គនោះឯង ។

ព្រះសាស្តា ត្រាស់ឲ្យយាងព្រះបាទបសេនទិកោសលមកហើយ ត្រាស់ថា មហាបពិត្រ កុលធីតាទាំងឡាយក្នុងសាសនានេះ លះពួកញាតិដ៏ធំ និងគំនរនៃភោគៈច្រើនបួសហើយ រមែងនៅក្នុងព្រៃដូចកុលបុត្រទាំងឡាយដូចគ្នា បុគ្គលលាមក ត្រូវរាគៈទទឹកហើយ រមែងបៀតបៀនភិក្ខុនីទាំងនោះ ដែលនៅក្នុងព្រៃ ដោយអំណាចនៃការមើលងាយខ្លះ ដល់នូវអន្តរាយនៃព្រហ្មចរិយៈខ្លះ ព្រោះដូច្នោះ ទ្រង់គួរធ្វើលំនៅខាងក្នុងព្រះនគរដល់ភិក្ខុនីសង្ឃ ព្រះរាជាទ្រង់ទទួលថា សាធុ ដូច្នេះហើយ ឲ្យសាងលំនៅដើម្បីភិក្ខុនីសង្ឃ ត្រង់ចំណែកម្ខាងនៃព្រះនគរ ចាប់តាំងពីកាលនោះមក ពួកភិក្ខុនីរមែងនៅក្នុងចន្លោះស្រុកប៉ុណ្ណោះ ។ល។

## រឿង ឧប្បលវណ្ណាថេរី ចប់

# រឿង ជម្ពុកាជីវក

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធជម្ពុកាជីវក ត្រាស់ព្រះធម្មទេសនានេះថា **មាសេ មាសេ កុសគ្គេន** ជាដើម ។

បានឮថា ក្នុងអតីតកាល ក្នុងកាលព្រះសម្មាសម្ពុទ្ធព្រះនាមកស្សបៈ កុដុម្ពិកៈម្នាក់ សាងវិហារប្រគេនដល់ភិក្ខុមួយរូបហើយ ទំនុកបម្រុងព្រះថេរៈនៅក្នុងវិហារនោះដោយបច្ច័យ ៤ ព្រះថេរៈឆាន់ក្នុងផ្ទះរបស់កុដុម្ពិកៈនោះជានិច្ច ។ កាលនោះ ភិក្ខុខីណាស្រពមួយរូប ត្រាច់បិណ្ឌបាតក្នុងពេលថ្ងៃដល់ទ្វារផ្ទះរបស់កុដុម្ពិកៈនោះៗ ឃើញព្រះខីណាស្រពនោះហើយ ជ្រះថ្លាក្នុងឥរិយាបថរបស់លោក និមន្តឲ្យចូលទៅកាន់ផ្ទះអង្គាសដោយភោជនដ៏ប្រណីត ប្រគេនសំពត់សាដកផ្ទាំងធំដោយពិតថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ជ្រលក់សំពត់សាដកនេះស្លៀកដណ្តប់ចុះ ដូច្នេះហើយ ប្រាប់ថា បពិត្រលោកម្ចាស់ សក់របស់លោកម្ចាស់វែង ខ្ញុំនឹងនាំជាងកោរកាត់មក ដើម្បីប្រយោជន៍ដល់ការកោរសក់របស់លោកម្ចាស់ និងរៀបចំគ្រែដើម្បីប្រយោជន៍ដល់ការសិង កុលុបកភិក្ខុដែលឆាន់ក្នុងផ្ទះជានិច្ច ឃើញសក្ការៈនោះរបស់ព្រះខីណា-ស្រពនោះ មិនអាចញ៉ាំងចិត្តឲ្យជ្រះថ្លាបាន គិតថា កុដុម្ពិកៈនេះធ្វើសក្ការៈបែបនេះ ដល់ភិក្ខុដែលខ្លួនឃើញហើយមួយរំពេច តែមិនធ្វើដល់អញដែលឆាន់ក្នុងផ្ទះជានិច្ច ដូច្នេះហើយ បានទៅកាន់វិហារ ។ សូម្បីភិក្ខុខីណាស្រពទៅជាមួយនឹងភិក្ខុនោះឯង ជ្រលក់សំពត់សាដកដែលកុដុម្ពិកៈប្រគេន ស្លៀក

ដណ្តប់ហើយ សូម្បីកុដុម្ពិកៈនាំជាងកោរកាត់ ទៅឲ្យកោរសក់របស់ព្រះថេរៈ ឲ្យមនុស្សលាតគ្រែហើយ ពិតថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់សិង លើគ្រែនេះឯង និមន្តព្រះថេរៈទាំងពីររូប ដើម្បីឆាន់ក្នុងថ្ងៃស្អែក ក៏ចៀស ចេញទៅ ភិក្ខុម្ចាស់អាវាសមិនអាចអត់ធន់ក្នុងសក្ការៈកុដុម្ពិកៈ ដែលធ្វើដល់ ព្រះទីណាស្រេចនោះបាន ។

លុះដល់ពេលល្ងាច លោកទៅកាន់ទីដែលព្រះថេរៈសិងហើយ ជេរដោយ អាការ ៤ យ៉ាងថា អាវុសោអាគន្តុកៈ លោកទំពាស៊ីលាមក ប្រសើរជាង បរិភោគភត្តក្នុងផ្ទះរបស់កុដុម្ពិកៈ លោកឲ្យដកសក់ដោយធាងត្នោត ប្រសើរ ជាងការកោរសក់ដោយជាងកោរកាត់ ដែលកុដុម្ពិកៈនាំមក លោកអាក្រាត កាយត្រាច់ទៅ ប្រសើរជាងការស្លៀកសំពត់សាដក ដែលកុដុម្ពិកៈឲ្យ លោក ដេកលើផែនដី ប្រសើរជាងការដេកលើគ្រែដែលកុដុម្ពិកៈនាំមក ។ ចំណែក ព្រះថេរៈគិតថា បុគ្គលពាលនេះកុំវិនាសព្រោះអាស្រ័យអាត្មាអញឡើយ ដូច្នេះ ហើយ មិនអើពើដល់ការនិមន្ត ក្រោកឡើងអំពីព្រលឹម បានទៅតាមសប្បាយ ហើយ ។ ចំណែកភិក្ខុម្ចាស់អាវាស ធ្វើវត្តដែលគួរធ្វើក្នុងវិហារ អំពីព្រលឹម ហើយ គោះជួងដោយចុងក្រចកប៉ុណ្ណោះ ដោយសម្គាល់ថា ពេលនេះជាពេល ដែលត្រាច់បិណ្ឌបាត ឥឡូវនេះ អាគន្តុកភិក្ខុកំពុងលក់ លោកគប្បីភ្ញាក់ដោយ សំឡេងជួង ដូច្នេះហើយ ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ។ កុដុម្ពិកៈនោះ ធ្វើសក្ការៈហើយ ទន្ទឹងមើលផ្លូវព្រះថេរៈទាំងពីរ ឃើញភិក្ខុម្ចាស់អាវាសហើយ សួរថា បពិត្រលោកម្ចាស់ ព្រះថេរៈទៅណា ពេលនោះភិក្ខុម្ចាស់អាវាសពោល

នឹងកុដុម្ពិកៈនោះថា អាវុសោកុំពោលដល់ឡើយ កុលុបកភិក្ខុរបស់អ្នកចូលកាន់បន្ទប់តូច ក្នុងពេលដែលអ្នកចេញទៅកាលពីម្សិលមិញ ឈានចុះកាន់និទ្រា កាលអាត្មាធ្វើសំឡេងបោសវិហារក្តី សំឡេងចាក់ទឹកក្នុងក្អមធាន់ និងក្អមសម្រាប់ប្រើក្តី សំឡេងជួងក្តី តាំងអំពីព្រលឹមក៏នៅតែមិនភ្ញាក់ ។ កុដុម្ពិកៈគិតថា ឈ្មោះថាការដេកលក់អស់កាលមានប្រមាណប៉ុណ្ណេះ រមែងមិនមានដល់លោកម្ចាស់របស់អញ ដែលប្រកបដោយឥរិយាបថសម្បត្តិបែបនោះ តែលោកម្ចាស់រូបនេះ ពោលពាក្យណាមួយពិតប្រាកដ ព្រោះឃើញអញធ្វើសក្ការៈដល់លោក ។ ព្រោះភាពដែលខ្លួនជាបណ្ឌិត ទើបកុដុម្ពិកៈនោះនិមន្តឲ្យភិក្ខុឆាន់ដោយគោរព លាងបាត្ររបស់លោកឲ្យល្អហើយ ដាក់ភោជនមានរសប្រសើរផ្សេងៗ ពេញបាត្រ ហើយពោលថា បពិត្រលោកម្ចាស់ បើលោកម្ចាស់ឃើញលោកម្ចាស់របស់ខ្ញុំ សូមលោកម្ចាស់ប្រគេនបិណ្ឌបាតនេះ ដល់លោកម្ចាស់នោះ ។ ភិក្ខុនោះទទួលបិណ្ឌបាតនោះហើយក៏គិតថា បើភិក្ខុនោះឆាន់បិណ្ឌបាតបែបនេះសោត លោកនឹងជាប់ជំពាក់ក្នុងទីនេះប៉ុណ្ណោះ ចោលបិណ្ឌបាតនោះក្នុងរវាងផ្លូវ ទៅកាន់លំនៅរបស់ព្រះថេរៈ សម្លឹងមើលព្រះថេរៈនោះក្នុងទីនោះមិនបានឃើញហើយ ។ ពេលនោះ សមណធម៌ដែលលោកធ្វើអស់ ២ ម៉ឺនឆ្នាំ មិនអាចរក្សាលោកបាន ព្រោះធ្វើកម្មមានប្រមាណប៉ុណ្ណេះ ក្នុងកាលអស់អាយុ លោកកើតក្នុងអវីចិ សោយទុក្ខដ៏ខ្លាំងក្លាអស់មួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទ-កាលនេះ កើតក្នុងផ្ទះនៃត្រកូលដែលមានបាយ និងទឹកច្រើន ក្នុងនគររាជគ្រឹះ ។

ចាប់តាំងអំពីកាលដែលដើរបានដោយជើង កុមារនោះមិនប្រាថ្នាដើម្បី

ដេកលើដំណេក មិនប្រាថ្នាបរិភោគភត្ត បរិភោគតែសរីរវលញ្ជៈរបស់ខ្លួនប៉ុណ្ណោះ ។ មាតាបិតាចិញ្ចឹមទារកនោះដោយសម្គាល់ថា កូនមិនដឹងព្រោះនៅតូច ទើបធ្វើ ។ លុះដល់ធំ បុរសនោះមិនប្រាថ្នាដើម្បីស្លៀកសំពត់ ជាអ្នកអាក្រាតកាយត្រាច់ទៅ ដេកលើផែនដី ទំពាស៊ីតែសរីរវលញ្ជៈរបស់ខ្លួនប៉ុណ្ណោះ ។ លំដាប់នោះ មាតាបិតារបស់គាត់គិតថា ក្មេងនេះមិនសមគួរដល់ផ្ទះនៃត្រកូល ក្មេងនេះសមគួរដល់ពួកអាជីវក ដូច្នេះហើយ ទើបនាំទៅកាន់សម្នាក់នៃអាជីវកទាំងនោះ បានប្រគល់ឲ្យថា សូមលោកម្ចាស់ទាំងឡាយឲ្យក្មេងនេះបួសចុះ ។ លំដាប់នោះ អាជីវកទាំងនោះញ៉ាំងគាត់ឲ្យបួសហើយ កាលឲ្យបួសហើយ អាជីវកទាំងនោះ ដាក់គាត់ក្នុងរណ្តៅប្រមាណត្រឹម-ក ដាក់បន្ទះក្តារលើស្មាទាំងពីរ អង្គុយលើក្តារនោះ ដកសក់ដោយធាងត្នោត ។ លំដាប់នោះ មាតាបិតារបស់គាត់ អញ្ជើញអាជីវកទាំងនោះដើម្បីឆាន់ក្នុងថ្ងៃស្អែក ចៀសចេញទៅ ។ ស្អែកឡើង ពួកអាជីវកពោលនឹងអាជីវកនោះថា ចូរលោកមក ពួកយើងចូលទៅកាន់ស្រុក ។ អាជីវកនោះពោលថា សូមលោកម្ចាស់ទាំងឡាយទៅចុះ ខ្ញុំនឹងនៅក្នុងទីនេះឯង ដូច្នេះហើយ ក៏មិនប្រាថ្នា ។ គ្រានោះ អាជីវកទាំងឡាយបាន លះអាជីវកដែលពោលហើយពោលទៀត មិនប្រាថ្នានឹងទៅ ។ ចំណែកគាត់ជ្រាបភាពដែលអាជីវកទាំងនោះទៅហើយ បើកទ្វារវច្ចកុដិចុះទៅបរិភោគលាមក ពូតឲ្យជាពំនូតដោយដៃទាំងពីរ ពួកអាជីវកបញ្ជូនអាហារទៅអំពីស្រុក ដើម្បីអាជីវកនោះ គាត់មិនប្រាថ្នានូវអាហារនោះ សូម្បីត្រូវពួកអាជីវកពោលរឿយៗ ក៏ពោលថា ខ្ញុំមិនត្រូវការអាហារនេះ អាហារខ្ញុំបាន

ហើយ ។ ពួកអាជីវកសួរថា លោកបានអាហារក្នុងទីណា គាត់ឆ្លើយថា បាន ក្នុងទីនេះឯង ។

ក្នុងថ្ងៃទី ២-៣-៤ ត្រូវពួកអាជីវកនោះពោលច្រើនយ៉ាងនោះ ក៏នៅតែពោលថា ខ្ញុំនៅក្នុងទីនេះឯង មិនប្រាថ្នាទៅស្រុក ។ ពួកអាជីវកគិតថា អាជីវកនេះមិនប្រាថ្នាចូលស្រុករាល់ៗ ថ្ងៃ មិនប្រាថ្នាបរិភោគអាហារ ដែលពួកគេនាំមកឲ្យ ពោលថា អាហារខ្ញុំបានហើយក្នុងទីនេះឯង អាជីវកនេះធ្វើអ្វីហ្ន៎ ពួកយើងនឹងចាប់កំហុសគេ ដូច្នេះហើយ កាលចូលទៅកាន់ស្រុក វៀរអាជីវកម្នាក់ ឬពីរនាក់ ដើម្បីចាំឃ្លាំមើលអាជីវកនោះ ហើយទៅ ។ អាជីវកនោះ ចូលទៅខាងក្រោយ ពួនហើយ ។ អាជីវកនោះ ដឹងភាពដែលអាជីវកទាំងនោះទៅហើយ ចុះកាន់វច្ចកុដិ បរិភោគលាមកដោយន័យមុននោះឯង ។ ពួកអាជីវកក្រៅអំពីនេះ ឃើញកិរិយារបស់គាត់ហើយ ទើបប្រាប់ដល់អាជីវកទាំងឡាយ ពួកអាជីវកស្តាប់ពាក្យនោះហើយ គិតថា ឱ កម្មធ្ងន់ហ្ន៎ បើសាវករបស់ព្រះសមណគោតមដឹងសោត គប្បីប្រកាសការខូចកិត្តិយសរបស់ពួកយើងថា អាជីវកទាំងឡាយស៊ីលាមក អាជីវកនេះមិនសមគួរដល់ពួកយើង ទើបបណ្តេញចេញអំពីសម្នាក់របស់ខ្លួនហើយ អាជីវកនោះ ត្រូវពួកអាជីវកទាំងនោះដេញចេញហើយ ។ មានថ្មដាមួយដុំ ដែលគេតាំងទុកក្នុងទីបន្ទោបង់ឧច្ចារៈរបស់មហាជន មានថ្មកធំលើផ្ទាំងថ្មនោះ មហាជនអាស្រ័យថ្មដាជាទីបន្ទោបង់ឧច្ចារៈ ចូលទៅក្នុងទីនោះ បរិភោគលាមកក្នុងពេលយប់ ក្នុងកាលដែលមហាជនមកបន្ទោបង់ឧច្ចារៈ តោងដុំថ្មដោយដៃម្ខាង លើកជើងម្ខាង

ឡើងដាក់លើក្បាលជង្គង់ ឈរងើយមុខហាមាត់ ។ មហាជនឃើញហើយ ចូលទៅរក ថ្វាយបង្គំហើយ សួរថា បពិត្រលោកម្ចាស់ ព្រោះហេតុអ្វី ទើបលោកម្ចាស់ឈរហាមាត់ អាជីវកពោលថា ព្រោះអាត្មាមានខ្យល់ជាអាហារ អាហារដទៃរបស់អាត្មាមិនមាន ។

មហាជនពោលថា បើដូច្នោះ ព្រោះហេតុអ្វី ទើបលោកម្ចាស់លើកជើងម្ខាងដាក់លើក្បាលជង្គង់ហើយឈរ អាជីវកពោលថា អាត្មាមានតបៈខ្ពស់ មានតបៈខ្លាំងក្លា ផែនដីត្រូវអាត្មាជាន់ដោយជើងទាំងពីរ រមែងញាប់ញ័រ ព្រោះដូច្នោះ ទើបអាត្មាលើកជើងម្ខាងដាក់លើក្បាលជង្គង់ឈរ ឯអាត្មាឈរតែម្យ៉ាង ញ៉ាំងកាលឲ្យកន្លងទៅ មិនអង្គុយ មិនដេក ។

ឈ្មោះថា ពួកមនុស្សដោយច្រើន រមែងជឿត្រឹមតែពាក្យសម្តីប៉ុណ្ណោះ ព្រោះដូច្នោះ ទើបអ្នកដែនអង្គៈ និងដែនមគធៈដោយច្រើនល្បីថា គួរអស្ចារ្យពិត អ្នកមានតបៈបែបនេះមានហ្ន៎ បុគ្គលបែបនេះ ពួកយើងមិនធ្លាប់ឃើញដូច្នេះហើយ រមែងនាំសក្ការៈជាច្រើនទៅរាល់ៗ ខែ ។ អាជីវកនោះពោលថា ខ្ញុំបរិភោគខ្យល់តែម្យ៉ាង មិនបរិភោគអាហារដទៃ ព្រោះកាលយើងបរិភោគអាហារដទៃ តបៈរមែងវិនាសទៅ ដូច្នេះហើយ មិនប្រាថ្នារបស់ណាមួយដែលពួកមនុស្សទាំងនោះនាំមក ។ ពួកមនុស្សអង្វររឿយៗ ថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់កុំឲ្យពួកខ្ញុំវិនាសឡើយ ការបរិភោគដែលបុគ្គលមានតបៈខ្លាំងក្លាដូចលោកម្ចាស់ធ្វើហើយ រមែងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ពួកខ្ញុំអស់កាលយូរ ។ អាជីវកពោលថា អាត្មាមិនគាប់ចិត្ត

ដល់អាហារដទៃ តែត្រូវមហាជនបៀតបៀនដោយការអង្វរ ទើបដាក់កេសជ្ជៈ និងទឹកអំពៅជាដើម ដែលជនទាំងនោះនាំមកត្រង់ចុងអណ្តាត ដោយប្រើចុងស្បូវក្លាំង បញ្ជូនទៅដោយពាក្យថា អ្នកទាំងឡាយ ចូរទៅចុះ ប៉ុណ្ណេះរមែងគ្រប់គ្រាន់ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់អ្នកទាំងឡាយ ។ អាជីវកនោះ ជាបុគ្គលអាក្រាត បរិភោគលាមក ដកសក់ ដេកលើផែនដី ឲ្យកាលកន្លងទៅ ៥៥ ឆ្នាំ ដោយប្រការដូច្នេះ ។

ការប្រមើលមើលសត្វលោក ក្នុងពេលទៀបភ្លឺ ជាពុទ្ធកិច្ចដែលព្រះពុទ្ធទាំងឡាយ ទ្រង់មិនលះបង់ដោយពិត ព្រោះដូច្នោះ កាលព្រះដ៏មានព្រះភាគទ្រង់ពិចារណាមើលសត្វលោកក្នុងពេលទៀបភ្លឺថ្ងៃមួយ ជម្ពុកាជីវកនេះ មកប្រាកដខាងក្នុងសំណាញ់ញាណហើយ ។ ព្រះសាស្តាទ្រង់ពិចារណាថា អ្វីហ្ន៎នឹងមាន ទ្រង់ឃើញឧបនិស្ស័យនៃអរហត្ត មួយអន្លើដោយបដិសម្ភិទារបស់អាជីវកហើយទ្រង់ជ្រាបថា អញនឹងធ្វើជម្ពុកាជីវកនោះឲ្យជាហេតុហើយ ពោលមួយគាថា ក្នុងកាលចប់គាថាសត្វ ៨៤០០០ នឹងត្រាស់ដឹងធម៌ អាស្រ័យកុលបុត្រនេះ មហាជននឹងដល់នូវការសួស្តី ដូច្នេះហើយ ក្នុងថ្ងៃស្អែកឡើងទ្រង់យាងទៅកាន់ក្រុងរាជគ្រឹះដើម្បីបិណ្ឌបាត ទ្រង់ត្រឡប់អំពីបិណ្ឌបាតហើយត្រាស់នឹងអានន្ទត្ថេរថា អានន្ទ យើងនឹងទៅកាន់សម្នាក់របស់ជម្ពុកាជីវក ។ ព្រះអានន្ទទូលថា ទ្រង់តែមួយអង្គប៉ុណ្ណេះយាងទៅឬ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលអានន្ទយ៉ាងនោះឯង តថាគតម្នាក់ឯងនឹងទៅ ។

ព្រះសាស្តា កាលត្រាស់យ៉ាងនោះហើយ ក្នុងពេលរសៀល ទ្រង់យាង

ទៅកាន់សម្នាក់របស់ជម្ពុកាជីវកនោះ ទេវតាទាំងឡាយគិតថា ព្រះសាស្ដាទ្រង់យាងទៅកាន់សម្នាក់របស់ជម្ពុកាជីវកក្នុងពេលល្ងាច ឯជម្ពុកាជីវកនោះនៅលើថ្មដាគួរខ្ពើម ដែលជាទីបន្ទោបង់ឧច្ចារៈ បស្សាវៈ សៅហ្មងដោយឈើស្ទន់ ពួកយើងគួរឲ្យភ្លៀងធ្លាក់ ដូច្នេះហើយ ទើបញុំាងភ្លៀងឲ្យធ្លាក់មួយរំពេចប៉ុណ្ណោះ ដោយអានុភាពរបស់ខ្លួន ថ្មដាបានស្អាតប្រាសចាកមន្ទិលហើយ ។ លំដាប់នោះ ទេវតាទាំងឡាយ ញុំាងភ្លៀងជាវិការនៃផ្កា ៥ ពណ៌ ឲ្យធ្លាក់លើថ្មដានោះ ។ ក្នុងពេលល្ងាចព្រះសាស្ដាយាងទៅកាន់សម្នាក់របស់ជម្ពុកាជីវកហើយ បានបន្លឺព្រះសូរសៀងថា ជម្ពុកៈ ។ ជម្ពុកៈ គិតថា នរណាហ្ន៎ដឹងបានលំបាក ហៅអញដោយពាក្យថាជម្ពុកៈ ទើបគិតថា នុ៎ះជានរណា ។ ព្រះសាស្ដាត្រាស់ថា ម្នាលជម្ពុកៈ គឺតថាគត ជម្ពុកៈពោលថា មានរឿងអ្វីមហាសមណៈ ព្រះសាស្ដាត្រាស់ថា ថ្ងៃនេះ ចូរអ្នកឲ្យទីលំនៅនេះដល់តថាគត ត្រឹមតែមួយយប់ចុះ ជម្ពុកៈពោលថា មហាសមណៈ ទីលំនៅក្នុងទីនេះមិនមានទេ ព្រះសាស្ដាត្រាស់ថា ម្នាលជម្ពុកៈ អ្នកកុំធ្វើយ៉ាងនោះ ចូរអ្នកឲ្យលំនៅដល់តថាគតមួយយប់ចុះ ឈ្មោះថាពួកបព្វជិត រមែងប្រាថ្នាបព្វជិត ពួកមនុស្សរមែងប្រាថ្នាពួកមនុស្ស ពួកបសុសត្វរមែងប្រាថ្នាពួកបសុសត្វ ។ ជម្ពុកៈពោលថា អ្នកជាបព្វជិតឬ ព្រះសាស្ដាត្រាស់ថា អើ តថាគតជាបព្វជិត ជម្ពុកៈពោលថា អើ បើលោកជាបព្វជិត ឃ្លោករបស់លោក នៅឯណា វែកសម្រាប់បក់ផ្សែងរបស់លោកនៅឯណា អំបោះសម្រាប់បូជាយញ្ញរបស់លោក នៅឯណា ។

ព្រះសាស្ដាត្រាស់ថា ឃ្លោកជាដើមនោះរបស់តថាគតមាន តែការកាន់

យកជាផ្នែកៗ ត្រាច់ទៅលំបាក ព្រោះដូច្នោះ ទើបតថាគតទុកខាងក្នុងប៉ុណ្ណោះ ត្រាច់ទៅ ។ អាជីវកនោះក្រោធពោលថា លោកមិនកាន់ឃ្នាកជាដើមនោះ ត្រាច់ទៅបានឬ លំដាប់នោះ ព្រះសាស្ដាត្រាស់នឹងអាជីវកនោះថា ណ្ហើយចុះ ជម្ពុកៈ អ្នកកុំក្រោធឡើយ ចូរអ្នកប្រាប់លំនៅដល់តថាគតចុះ អាជីវកពោលថា មហាសមណៈ ទីលំនៅក្នុងទីនេះមិនមាន ។

ព្រះសាស្ដា កាលទ្រង់ចង្អុលញកមួយកន្លែង ដែលមាននៅក្នុងទីមិនឆ្ងាយអំពីលំនៅរបស់គាត់ ទើបត្រាស់ថា ញកនោះនរណានៅ ជម្ពុកៈ ពោលថា មហាសមណៈ ញកនោះមិនមាននរណានៅឡើយ ។ ព្រះសាស្ដាត្រាស់ថា បើដូច្នោះ ចូរអ្នកឲ្យញកនោះដល់តថាគត ជម្ពុកៈពោលថា មហាសមណៈ ចូរលោកដឹងឯងចុះ ព្រះសាស្ដាទ្រង់ក្រាលនិសីទនៈ ប្រថាប់គង់ត្រង់ញកនោះហើយ ។

គ្រានោះ ទេវរាជទាំង ៤ ធ្វើទិសទាំង ៤ ឲ្យភ្លឺស្វាងក្នុងទិសតែមួយ មកកាន់ទីបម្រើក្នុងបឋមយាម ជម្ពុកៈឃើញពន្លឺហើយ គិតថា នុ៎ះពន្លឺអ្វីហ្ន៎ ក្នុងមជ្ឈិមយាមសក្កទេវរាជយាងមកហើយ ។ ជម្ពុកៈឃើញសក្កទេវរាជនោះ គិតថា នុ៎ះជាអ្នកណាហ្ន៎ ក្នុងបច្ឆិមយាមមហាព្រហ្ម ដែលអាចញុំាងចក្កវាឡមួយឲ្យភ្លឺដោយម្រាមដៃមួយ ញុំាងចក្កវាឡពីរឲ្យភ្លឺដោយម្រាមដៃពីរ ញុំាងចក្កវាឡ ១០ ឲ្យភ្លឺដោយម្រាមដៃ ១០ ធ្វើព្រៃទាំងមូលឲ្យមានពន្លឺតែមួយ យាងមកហើយ ជម្ពុកៈឃើញមហាព្រហ្មនោះគិតថា នុ៎ះជាអ្នកណាហ្ន៎ ដូច្នេះហើយ ទើបទៅកាន់សម្នាក់ព្រះសាស្ដាអំពីព្រលឹម ធ្វើបដិសណ្ឋារៈហើយឈរ

ក្នុងទីសមគួរនាចំណែកម្ខាង ទូលសួរព្រះសាស្តាថា មហាសមណៈ អ្នកណាញ៉ាំងទិសទាំង ៤ ឲ្យភ្លឺស្វាងមកកាន់សម្នាក់របស់លោកក្នុងបឋមយាម ព្រះសាស្តាត្រាស់ថា ស្តេចមហារាជទាំង ៤ ជម្ពុកៈពោលថា មកព្រោះហេតុអ្វី ព្រះសាស្តាត្រាស់ថា មកដើម្បីបម្រើតថាគត ជម្ពុកៈពោលថា លោកជាបុគ្គលប្រសើរជាងស្តេចមហារាជទាំង ៤ ឬ ។

ព្រះសាស្តាត្រាស់ថា អើជម្ពុកៈ តថាគតជាព្រះរាជាប្រសើរជាងព្រះរាជាទាំងឡាយ ជម្ពុកៈសួរថា ចុះអ្នកណាមកក្នុងមជ្ឈិមយាម ព្រះសាស្តាត្រាស់ថា គឺសក្កទេវរាជ ជម្ពុកៈពោលថា មកព្រោះហេតុអ្វី ព្រះសាស្តាត្រាស់ថា ដើម្បីបម្រើតថាគតដូចគ្នា ជម្ពុកៈពោលថា លោកជាបុគ្គលប្រសើរជាងសក្កទេវរាជឬ ព្រះសាស្តាត្រាស់ថា អើជម្ពុកៈ តថាគតជាបុគ្គលប្រសើរជាងសក្កទេវរាជ សក្កទេវរាជនោះជាគិលានុប្បដ្ឋាករបស់តថាគត ដូចគ្នានឹងសាមណេរដែលជាកប្បិយការកៈ ជម្ពុកៈសួរថា ចុះអ្នកណាញ៉ាំងព្រៃទាំងមូលឲ្យភ្លឺស្វាងមកហើយក្នុងបច្ឆិមយាម ព្រះសាស្តាត្រាស់ថា ជនទាំងឡាយមានព្រាហ្មណ៍ជាដើមក្នុងលោក កណ្តាស់ហើយ ភ្ញាក់ហើយរមែងពោលថា ការនមស្ការចូរមានដល់មហាព្រហ្ម អាស្រ័យបុគ្គលណា បុគ្គលនោះឯងជាមហាព្រហ្ម ជម្ពុកៈពោលថា លោកជាបុគ្គលប្រសើរជាងមហាព្រហ្មឬ ព្រះសាស្តាត្រាស់ថា អើជម្ពុកៈ តថាគតជាព្រហ្មក្រៃលែងជាងព្រហ្ម ជម្ពុកៈពោលថា មហាសមណៈ លោកជាបុគ្គលអស្ចារ្យ ខ្ញុំនៅក្នុងទីនេះអស់ ៥៥ ឆ្នាំ បណ្តាទេវតាទាំងនោះសូម្បីមួយអង្គ ក៏មិនធ្លាប់មកដើម្បីបម្រើខ្ញុំ ខ្ញុំជាបុគ្គលមានខ្យល់ជាអាហារឈរ

តែម្យ៉ាង អស់កាលមានប្រមាណប៉ុណ្ណោះកន្លងទៅហើយ ទេវតាទាំងនោះមិនធ្លាប់មកកាន់ទីបម្រើរបស់ខ្ញុំឡើយ ។

គ្រានោះ ព្រះសាស្តាត្រាស់នឹងជម្ពុកៈនោះថា ជម្ពុកៈ អ្នកបោកបញ្ឆោតមហាជនអន្ធពាលក្នុងលោក គង់ប្រាថ្នានឹងបញ្ឆោតតថាគត អ្នកទំពាស៊ីលាមកប៉ុណ្ណោះ ដេកលើផែនដីតែម្យ៉ាង ជាអ្នកអាក្រាតត្រាច់ទៅ ដកសក់ដោយធាងត្នោតអស់ ៥៥ ឆ្នាំមិនមែនឬ កាលបើដូច្នោះ អ្នកបោកបញ្ឆោតសត្វលោកពោលថា ខ្ញុំជាអ្នកមានខ្យល់ជាអាហារ ឈរជើងម្ខាង មិនអង្គុយមិនដេក ជាអ្នកប្រាថ្នានឹងបោកតថាគតផងឬ ក្នុងកាលមុនអ្នកអាស្រ័យទិដ្ឋិដ៏លាមក ជាអ្នកមានលាមកជាអាហារអស់កាលមានប្រមាណប៉ុណ្ណោះ ជាអ្នកដេកលើផែនដីអាក្រាតកាយត្រាច់ទៅ ដល់នូវការដកសក់ដោយធាងត្នោត ក្នុងឥឡូវនេះ អ្នកនៅកាន់យកទិដ្ឋិដ៏អាក្រក់លាមកដូចមុន ជម្ពុកៈពោលថា មហាសមណៈ ខ្ញុំបានធ្វើកម្មអ្វី ។

លំដាប់នោះព្រះសាស្តាត្រាស់ប្រាប់កម្ម ដែលគាត់ធ្វើហើយក្នុងកាលមុនដល់ជម្ពុកៈនោះ ។ កាលព្រះសាស្តាកំពុងត្រាស់នោះឯង សង្វេគកើតឡើងដល់គាត់ហើយ ហិរិឱត្តប្បៈប្រាកដហើយ គាត់អង្គុយច្រហោងហើយ ។ គ្រានោះ ព្រះសាស្តា ទ្រង់បានបោះសំពត់សាដកសម្រាប់ងូតទឹក ទៅឲ្យជម្ពុកៈនោះ ជម្ពុកៈស្លៀកសំពត់នោះហើយ ថ្វាយបង្គំព្រះសាស្តា អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ ចំណែកព្រះសាស្តាត្រាស់អនុបុព្វីកថា សម្តែងធម៌ដល់ជម្ពុកៈ ក្នុងកាលចប់ទេសនា ជម្ពុកៈសម្រេចអរហត្ត មួយអន្លើដោយបដិ-

សម្ពិទា ថ្វាយបង្គំព្រះសាស្តាហើយ ក្រោកឡើងអំពីអាសនៈ ទូលសូមបព្វជ្ជា និងឧបសម្បទា ដោយអាការមានប្រមាណប៉ុណ្ណោះ កម្មក្នុងកាលមុនរបស់ជម្ពុកៈនោះអស់ហើយ ។ ជម្ពុកៈនេះ ជេរព្រះមហាថេរៈដែលជាព្រះខីណាស្រព ដោយអក្កោសវត្ថុ ៤ យ៉ាង ឆេះហើយក្នុងអវិចី ជរាបដល់មហាប្រឹថពីដុះឡើងមួយយោជន៍ និង ៣ គាវុធ ដល់នូវអាការដែលគួរខ្ពើមអស់ ៥៥ ឆ្នាំ ដោយសេសនៃផលកម្ម ព្រោះការជេរនោះ កម្មនោះរបស់លោកអស់ហើយ ព្រោះសម្រេចអរហត្ត កម្មដែលលោកធ្វើហើយនោះ មិនអាចញ៉ាំងផលនៃសមណធម៌ ដែលជម្ពុកៈនេះធ្វើហើយអស់ ២ ម៉ឺនឆ្នាំឲ្យវិនាសបាន ព្រោះដូច្នោះ ទើបព្រះសាស្តាទ្រង់លាព្រះហស្តខាងស្តាំ ត្រាស់នឹងជម្ពុកៈនោះថា ចូរអ្នកជាភិក្ខុចុះ ចូរប្រព្រឹត្តព្រហ្មចរិយៈចុះ ។ ខណៈនោះឯង ភេទគ្រហស្ថរបស់លោកបាត់ទៅហើយ លោកជាអ្នកទ្រទ្រង់បរិក្ខារ ៨ ដូចព្រះថេរៈមានវស្សា ៦០ ហើយ ។

បានឮថា ថ្ងៃនោះ ជាថ្ងៃដែលអ្នកអង្គៈ និងមគធៈកាន់សក្ការៈមកដើម្បីជម្ពុកៈនោះ ព្រោះដូច្នោះ អ្នកដែនទាំងពីរកាន់សក្ការៈមកហើយ ឃើញព្រះតថាគតហើយ ទើបគិតថា ជម្ពុកៈលោកម្ចាស់របស់ពួកយើងជាធំឬហ្ន៎ ឬព្រះសមណគោតមជាធំ គិតថា បើព្រះសមណគោតមគប្បីជាធំ ជម្ពុកៈនេះគប្បីចូលទៅកាន់សម្នាក់របស់ព្រះសមណគោតម តែព្រោះភាពដែលជម្ពុកៈជាធំ ទើបព្រះសមណគោតមយាងមកកាន់សម្នាក់ជម្ពុកាជីវកនេះ ។

ព្រះសាស្តា ទ្រង់ជ្រាបបរិវិតក្ករបស់មហាជន ទើបត្រាស់ថា ជម្ពុកៈ ចូរ

អ្នកដោះសេចក្ដីសង្ស័យរបស់ឧបដ្ឋាកទាំងឡាយរបស់អ្នក លោកក្រាបទូលថា សូម្បីខ្ញុំព្រះអង្គក៏វង់ចាំព្រះពុទ្ធតម្រាស់ មានប្រមាណប៉ុណ្ណេះដូចគ្នា ដូច្នេះហើយ ចូលចតុត្ថជ្ឈាន ក្រោកឡើង ហោះទៅកាន់អាកាសប្រមាណមួយជួរដើមត្នោត ក្រាបទូលថា បពិត្រព្រះអង្គ ទ្រង់ជាសាស្ដារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវក ចុះមកថ្វាយបង្គំ ហោះឡើងទៅកាន់អាកាសប្រមាណ ៧ ជួរដើមត្នោតទៀត ដោយអាការយ៉ាងនេះ គឺប្រមាណ ២ ជួរដើមត្នោត ប្រមាណ ៣ ជួរដើមត្នោត ហើយចុះមកញុំាងមហាជន ឲ្យជ្រាបភាពដែលខ្លួនជាសាវក មហាជនឃើញហេតុនោះហើយ គិតថា ឱ ធម្មតាព្រះពុទ្ធទាំងឡាយជាបុគ្គលគួរអស្ចារ្យ ជាអ្នកមានព្រះគុណមិនថោកថយឡើយ ។

ព្រះសាស្ដា កាលត្រាស់នឹងមហាជន ត្រាស់យ៉ាងនេះថា ជម្ពុកៈនេះដាក់សក្ការៈ ដែលពួកអ្នកនាំមកហើយ ត្រង់ចុងអណ្ដាតដោយចុងស្បូវភ្លាំងអស់កាលមានប្រមាណប៉ុណ្ណេះ នៅក្នុងទីនេះដោយបំណងថា អញបំពេញការប្រព្រឹត្តតបៈ បើអ្នកគប្បីបំពេញតបៈ ១០០ ឆ្នាំដោយឧបាយនេះសោត ឯការបំពេញតបៈនោះ មិនដល់ចំណែកទី ១៦ នៃកុសលចេតនា ជាគ្រឿងកាត់កត្តរបស់អ្នកដែលវៀរសត្រូវកូល ឬកត្ត ហើយមិនបរិភោគក្នុងកាលឥឡូវនេះ ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្ដែងធម៌ ត្រាស់ព្រះគាថានេះថា

**មាសេ មាសេ កុសគ្គេន ពាលោ ភុញ្ជេថ ភោជនំ**
**ន សោ សង្ខាតធម្មានំ កលំ អគ្ឃតិ សោឡសឹ ។**

ជនពាលទុកជាបរិភោគភោជនដោយចុងស្បូវរាល់ៗ ខែ ជន

ពាលនោះ ក៏មិនដល់មួយចំណិតនៃចំណែកទី ១៦ៗ លើក
របស់បុគ្គលទាំងឡាយ ដែលមានធម៌បានដឹង ឬបានពិចា-
រណាហើយឡើយ ។

## សេចក្តីអធិប្បាយ

គប្បីជ្រាបអត្ថនៃគាថានោះថា បើបុគ្គលពាល គឺបុគ្គលមានធម៌មិនទាន់កំណត់ដឹង ឆ្ងាយចាកគុណ មានសីលជាដើម បួសក្នុងលិទ្ធិតិរ្ថិយ បរិភោគភោជនដោយចុងស្បូវក្លាំងរាល់ៗ ខែដែលដល់ហើយ ដោយបំណងថា អញនឹងបំពេញការប្រព្រឹត្តតបៈ ឈ្មោះថា គប្បីបរិភោគភោជនអស់ ១០០ ឆ្នាំ ។

ក្នុងកន្លះគាថាថា **ន សោ សង្ខាតធម្មានំ កលំ អគ្ឃតិ សោឡសឹ** សម្តែងជាបុគ្គលាទិដ្ឋានថា បុគ្គលមានធម៌ដឹងហើយ គឺបុគ្គលមានធម៌ថ្លឹងបានហើយ ហៅថាអ្នកមានធម៌រាប់បានហើយ បណ្តាលោកទាំងនោះ ដោយហោចមានខាងក្រោមព្រះសោតាបន្ន ឈ្មោះថា មានធម៌ដែលរាប់បានហើយ ដោយហោចខាងលើព្រះខីណាស្រព ឈ្មោះថា ជាបុគ្គលមានធម៌រាប់បានហើយ ជនពាលនោះ រមែងមិនដល់ចំណែកទី ១៦ របស់បុគ្គលមានធម៌រាប់បានហើយទាំងនេះ ។

ចំណែកអត្ថក្នុងកន្លះគាថានេះ គប្បីជ្រាបដូច្នេះថា ចេតនារបស់បុគ្គលពាលនោះ ដែលបំពេញការប្រព្រឹត្តតបៈយ៉ាងនោះ អស់មួយរយឆ្នាំ ប្រព្រឹត្តទៅអស់រាត្រីយូរមានប្រមាណប៉ុណ្ណោះ រមែងមិនដល់ចម្រៀកទី ១៦ នៃកុសលចេតនា ជាគ្រឿងកាត់កត្តម្ពង របស់បុគ្គលដែលមានធម៌រាប់បាន

ហើយ រង្កៀសត្រកូល ឬកត្តហើយមិនបរិភោគ ។

ព្រះសាស្តា ត្រាស់អធិប្បាយដូច្នេះថា ផលនៃចំណែកនីមួយៗ ចាកចំណែកទី ១៦ ដែលធ្វើផលនៃចេតនារបស់បុគ្គល ដែលមានធម៌រាប់បានហើយនោះឲ្យជា ១៦ ចំណែកហើយ ធ្វើចំណែកនីមួយៗ អំពីចំណែក ១៦ នោះឲ្យជា ១៦ ចំណែកទៀត គង់ច្រើនជាងការប្រព្រឹត្តតបៈរបស់ជនពាលនោះ ។

ក្នុងកាលចប់ទេសនា ធម្មាភិសម័យ ក៏បានមានដល់សត្វ ៨៤០០០ ហើយដូច្នេះឯង ។

**រឿង ជម្ពុកាជីវក ចប់**

# រឿង អហិប្រេត

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធអហិប្រេត ១ ត្រាស់ព្រះគាថានេះថា **ន ហិ ចាបំ កតំ កម្មំ** ជាដើម ។

សេចក្តីពិស្តារថា ក្នុងថ្ងៃមួយ ព្រះលក្ខណត្ថេរក្នុងចំណោមជដិលទាំងមួយពាន់ និងព្រះមហាមោគ្គល្លានត្ថេរ ចុះអំពីភ្នំគិជ្ឈកូដដោយគិតថា អាត្មាអញនឹងបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ។ បណ្តាព្រះថេរៈពីររូបនោះ ព្រះមហាមោគ្គល្លានឃើញអហិប្រេតមួយ ទើបធ្វើការញញឹមឲ្យប្រាកដ កាលនោះ ព្រះលក្ខណត្ថេរសួរហេតុ អាវុសោ ព្រោះហេតុអ្វី ទើបលោកធ្វើការញញឹមឲ្យប្រាកដ ព្រះ

ថេរៈក៏ឆ្លើយថា អាវុសោនេះ មិនមែនកាលដើម្បីវិសជ្ជនាបញ្ហានេះ លោកម្ចាស់គប្បីសួរខ្ញុំក្នុងសម្នាក់ព្រះដ៏មានព្រះភាគចុះ ។ កាលព្រះថេរៈទាំងពីរនោះ ត្រាច់បិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ទៅកាន់សម្នាក់ព្រះដ៏មានព្រះភាគអង្គុយហើយ ព្រះលក្ខណត្ថេរសួរថា អាវុសោមោគ្គល្លាន លោកចុះអំពីភ្នំគិជ្ឈកូដ ធ្វើការញញឹមឲ្យប្រាកដ ខ្ញុំសួរដល់ហេតុនៃការញញឹមបានពោលថា លោកគប្បីសួរខ្ញុំក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ឥឡូវនេះ សូមលោកម្ចាស់ប្រាប់ហេតុនោះចុះ ។

ព្រះថេរៈពោលថា អាវុសោ ខ្ញុំឃើញអហិប្រេតមួយ ទើបធ្វើការញញឹមឲ្យប្រាកដ អត្តភាពរបស់ប្រេតបែបនេះ ក្បាលរបស់ប្រេតនោះដូចក្បាលមនុស្សអត្តភាពដ៏សេសរបស់ប្រេតនោះដូចពស់ នោះឈ្មោះអហិប្រេត ដោយប្រមាណ ២៥ យោជន៍ ។ អណ្តាតភ្លើងតាំងឡើងអំពីក្បាល រាលទៅដល់ចុងកន្ទុយតាំងឡើងអំពីកន្ទុយរហូតដល់ក្បាល តាំងឡើងត្រង់កណ្តាលឆេះទៅដល់ទាំងសងខាង តាំងឡើងសងខាងរាលមកដល់ត្រង់កណ្តាល ។ បានឮថា អត្តភាពរបស់ប្រេតទាំងពីរនោះឯងប្រមាណ ២៥ យោជន៍ ប្រេតដ៏សេសប្រមាណ ៣ គាវុត ប្រេតនោះ និងកាកប្រេតប្រមាណ ២៥ យោជន៍ បណ្តាប្រេតទាំងពីរនោះ នឹងពោលអហិប្រេតមានប្រមាណប៉ុណ្ណោះសិន ។

ព្រះមហាមោគ្គល្លាន ឃើញកាកប្រេតដែលឆេះនៅត្រង់កំពូលភ្នំគិជ្ឈកូដកាលនឹងសួរបុព្វកម្មរបស់ប្រេតនោះ ទើបពោលគាថានេះថា

អណ្តាតរបស់អ្នកប្រមាណ ៥ យោជន៍ ក្បាលរបស់អ្នកប្រមាណ

៩ យោជន៍ កាយរបស់អ្នកកម្ពស់ប្រមាណ ២៥ យោជន៍ អ្នកធ្វើកម្មអ្វីទុក ទើបដល់នូវទុក្ខដូច្នេះ ។

គ្រានោះ ប្រេតកាលនឹងប្រាប់ដល់ព្រះថេរៈនោះ ទើបពោលគាថានេះថា

ព្រះមោគ្គល្លានដ៏ចម្រើន ខ្ញុំទំពាស៊ីភត្តដែលគេនាំមកដើម្បីសង្ឃ

របស់ព្រះពុទ្ធព្រះនាមថាកស្សបៈ ទ្រង់ស្វែងរកគុណធំ តាម

ប្រាថ្នា ។

ដូច្នោះហើយ ទើបពោលថា បពិត្រលោកម្ចាស់ ក្នុងកាលព្រះពុទ្ធព្រះនាមកស្សបៈ ពួកភិក្ខុច្រើនរូបចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ។ ពួកមនុស្សឃើញព្រះថេរៈទាំងឡាយហើយ ស្រឡាញ់ និមន្តឲ្យគង់ត្រង់រោងធាន់ លាងជើងលាបដោយប្រេង ឲ្យធាន់នូវបបរ ប្រគេនរបស់គួរទំពា រង់ចាំបិណ្ឌបាតកាលអង្គុយស្តាប់ធម៌ ក្នុងកាលចប់ធម្មកថា ពួកមនុស្សទទួលបាត្ររបស់ព្រះថេរៈទាំងឡាយហើយ ញុំាងបាត្រឲ្យពេញដោយភោជនមានរសដ៏ប្រសើរផ្សេងៗ ក្នុងផ្ទះរៀងៗខ្លួនហើយនាំមក ។ ក្នុងគ្រានោះ ខ្ញុំជាអ្នកទំត្រង់ដំបូលនៃរោងធាន់ ឃើញភោជននោះហើយ បានពាំយកដុំបាយ ៣ ដុំពេញមាត់ ៣ ដង អំពីបាត្រដែលមនុស្សម្នាក់កាន់ តែភត្តនោះមិនទាន់ជារបស់សង្ឃឡើយ មិនមែនជាភត្តដែលគេកំណត់ថ្វាយដល់សង្ឃ ជាភត្តដែលសល់អំពីភិក្ខុទាំងឡាយធាន់ ដែលពួកមនុស្សគប្បីនាំទៅកាន់ផ្ទះរបស់ខ្លួនបរិភោគ ក៏មិនមែនត្រឹមតែជាភត្តដែលគេនាំមកចំពោះសង្ឃតែម្យ៉ាងប៉ុណ្ណោះ ខ្ញុំពាំដុំបាយ ៣ ដុំអំពីបាត្រនោះ កម្មមានប្រមាណប៉ុណ្ណោះ ជាបុព្វកម្មរបស់ខ្ញុំ ខ្ញុំនោះ ធ្វើកាល-

កិរិយាហើយ ឆេះក្នុងអវិចី ព្រោះវិបាកនៃកម្មនោះ ក្នុងឥឡូវនេះ កើតជាកាកប្រេត សោយទុក្ខនេះ ត្រង់ភ្នំគិជ្ឈកូដ ដោយផលកម្មដ៏សេស ព្រោះកម្មនោះ ។ រឿងកាកប្រេតមានប្រមាណប៉ុណ្ណេះ ។

តែក្នុងរឿងនេះព្រះថេរៈពោលថា ខ្ញុំឃើញអហិប្រេត ទើបធ្វើការញញឹមឲ្យប្រាកដ ។ លំដាប់នោះ ព្រះសាស្តាទ្រង់ជាសាក្សីរបស់ព្រះថេរៈនោះ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានពោលពិត ឯតថាគតឃើញប្រេតនោះក្នុងថ្ងៃសម្រេចសម្ពោធិញ្ញាណដូចគ្នា តែតថាគតមិនពោល ព្រោះករុណាជនដទៃ ព្រោះជនណាមិនជឿពាក្យរបស់តថាគត ការមិនជឿនោះ គប្បីប្រព្រឹត្តទៅដើម្បីវត្ថុដែលមិនមែនប្រយោជន៍ដល់ជនទាំងនោះ ។ ក្នុងកាលព្រះមោគ្គល្លានឃើញហើយនោះឯង ព្រះសាស្តាទ្រង់ជាសាក្សីរបស់លោក ត្រាស់រឿង ២០ រឿងក្នុងលក្ខណសំយុត្តហើយ សូម្បីរឿងនេះ ព្រះថេរៈក៏ពោលយ៉ាងនេះដូចគ្នា ។ ភិក្ខុទាំងឡាយស្តាប់រឿងនោះហើយ ទើបទូលសួរបុព្វកម្មរបស់ប្រេតនោះ ។ សូម្បីព្រះសាស្តាក៏ត្រាស់ដល់ភិក្ខុទាំងនោះថា

បានឮថា ក្នុងអតីតកាល ពួកជនអាស្រ័យក្រុងពារាណសី សាងបណ្ណ-សាលា ដើម្បីព្រះបច្ចេកពុទ្ធក្បែរឆ្នេរស្ទឹង ។ ព្រះបច្ចេកពុទ្ធនោះ នៅក្នុងបណ្ណសាលានោះ តែងត្រាច់ទៅបិណ្ឌបាតក្នុងក្រុងជានិច្ច ។ សូម្បីពួកអ្នកក្រុងមានដៃកាន់នូវសក្ការៈ គ្រឿងក្រអូប និងផ្កាជាដើម ទៅកាន់ទីបម្រើរបស់ព្រះបច្ចេកពុទ្ធទាំងល្ងាច ទាំងព្រឹក ។ បុរសអ្នកក្រុងពារាណសីម្នាក់ អាស្រ័យផ្លូវនោះ ភ្ជួរស្រែ មហាជនទៅកាន់ទីបម្រើព្រះបច្ចេកពុទ្ធ រមែងជាន់ស្រែនោះ

*ទៅទាំងល្ងាច ទាំងព្រឹក ។ អ្នកស្រែឃាត់ថា សូមអ្នកទាំងឡាយកុំជាន់ស្រែរបស់ខ្ញុំ ក៏មិនអាចឃាត់បាន ។ គ្រានោះ អ្នកស្រែនោះមានគំនិតយ៉ាងនេះថា បើបណ្ណសាលារបស់ព្រះបច្ចេកពុទ្ធមិនមានក្នុងទីនេះសោត ជនទាំងឡាយ ក៏មិនជាន់ស្រែរបស់អញ ក្នុងកាលដែលព្រះបច្ចេកពុទ្ធចូលទៅបិណ្ឌបាត អ្នកស្រែនោះវាយកាជនៈ គ្រឿងប្រើប្រាស់ ហើយដុតបណ្ណសាលាចោល ។ ព្រះបច្ចេកពុទ្ធ ឃើញបណ្ណសាលានោះត្រូវភ្លើងឆេះ ទើបចៀសចេញទៅតាមសប្បាយ ។ មហាជនកាន់យកគ្រឿងក្រអូប និងកម្រងផ្កាមក ឃើញបណ្ណ-សាលាត្រូវភ្លើងឆេះ ទើបពោលថា លោកម្ចាស់របស់ពួកយើងទៅក្នុងទីណាហ្ន៎ អ្នកស្រែនោះក៏មកជាមួយមហាជនដូចគ្នា ឈរត្រង់កណ្តាលមហាជនពោលយ៉ាងនេះថា ខ្ញុំដុតបណ្ណសាលារបស់ព្រះបច្ចេកពុទ្ធ ។ គ្រានោះ ជនទាំងឡាយពោលថា ចូរពួកអ្នកចាប់ ពួកយើងអាស្រ័យបុរសអាក្រក់នេះ ទើបមិនបានឃើញព្រះបច្ចេកពុទ្ធ ដូច្នេះហើយ ក៏វាយអ្នកស្រែនោះ ដោយគ្រឿងប្រហារ មានដំបងជាដើម ឲ្យដល់នូវការអស់ជីវិតហើយ អ្នកស្រែនោះកើតក្នុងអវីចិ ឆេះក្នុងនរកដរាបស្មើនឹងផែនដីនេះ ដែលដុះឡើងប្រមាណមួយយោជន៍ ដោយផលកម្មដែលសេសសល់ ទើបកើតជាអហិប្រេត ត្រង់ភ្នំគិជ្ឈកូដ ។*

*ព្រះសាស្តា កាលត្រាស់បុព្វកម្មនេះ របស់អហិប្រេតនោះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា បាបកម្មនោះ ដូចគ្នានឹងទឹកដោះទឹកដោះដែលបុគ្គលកំពុងរីត រមែងមិនប្រែប្រួលទៅ យ៉ាងណា កម្មដែលបុគ្គល*

កំពុងធ្វើ ដែលមិនទាន់ឲ្យផលក៏ដូច្នោះ តែក្នុងកាលណាកម្មឲ្យផល កាលនោះ បុគ្គលអ្នកធ្វើ រមែងប្រកបដោយទុក្ខបែបនោះ ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**ន ហិ បាបំ កតំ កម្មំ សជ្ជុខីរំវ មុច្ចតិ**
**ឌហន្តំ ពាលមន្វេតិ ភស្មាច្ឆន្នោវ បាវកោ ។**

កម្មលាមក ដែលជនពាលធ្វើហើយ មិនទាន់ឲ្យផលនោះក៏មាន ដូចទឹកដោះស្រស់ដែលមិនទាន់ប្រែក្លាយ ( ក្នុងមួយរំពេច ) ដូច្នោះ បាបកម្មនោះ តាមដុតបុគ្គលពាល ដូចរងើកភ្លើង ដែលបិទបាំងទុកដោយផេះ ដូច្នោះ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សជ្ជុខីរំ** សេចក្តីថា ទឹកដោះដែលហូរចេញអំពីដោះរបស់មេគោក្នុងខណៈនោះឯងនៅក្តៅ រមែងមិនផ្លាស់ប្តូរ គឺរមែងមិនប្រែប្រួលទៅ ។ ព្រះសាស្តាត្រាស់ដូច្នេះថា ទឹកដោះដែលគេរឹតក្នុងខណៈនោះ រមែងមិនផ្លាស់ប្តូរ គឺមិនប្រែប្រួល បានដល់ មិនលះប្រក្រតីក្នុងខណៈនោះឯង តែដែលគេរឹតទុកក្នុងភាជនៈណា រមែងមិនលះប្រក្រតីដរាបប៉ុណ្ណោះ ដែលមិនទាន់បានដាក់របស់ជូរ មានតក្កៈជាដើមចូលក្នុងភាជនៈនោះ គឺដរាបណាមិនដល់ភាជនៈរបស់តក្កៈ មានភាជនៈទឹកដោះជូរជាដើម រមែងលះក្នុងកាលខាងក្រោយ យ៉ាងណា សូម្បីបាបកម្មដែលបុគ្គលកំពុងធ្វើ ក៏រមែងមិនឲ្យផលដូច្នោះដូចគ្នា បើបាបកម្មគប្បីឲ្យផលក្នុងខណៈធ្វើ បុគ្គលណាមួយមិន

អាចធ្វើបាបកម្មបាន ឯខន្ធទាំងឡាយដែលកើតដោយកុសល តាំងនៅជរាប ណា ខន្ធទាំងនោះ រមែងរក្សាបុគ្គលនោះបានជរាបនោះ កាលខន្ធទាំងឡាយ កើតក្នុងអបាយ ព្រោះខន្ធទាំងនោះបែកធ្លាយ បាបកម្មរមែងឲ្យផល កាលឲ្យ ផល ឈ្មោះថា តាមដុតពាលបុគ្គលពាល ។

សួរថា សេចក្តីនេះប្រៀបដូចអ្វី ឆ្លើយថា ប្រៀបដូចភ្លើងដែលផេះបិទ បាំង អធិប្បាយថា ដូចរងើកភ្លើងប្រាសចាកអណ្តាត ដែលផេះបិទបាំង សូម្បី បុគ្គលជាន់ហើយក៏មិនទាន់ឆេះ ព្រោះផេះបិទបាំង តែកាលផេះក្តៅហើយ រមែងឆេះរហូតដល់ខួរដោយអំណាចឆេះអវយវៈ មានស្បែកជាដើម យ៉ាង ណា សូម្បីបាបកម្មក៏ដូច្នោះដូចគ្នា ជាបាបកម្មដែលបុគ្គលធ្វើ រមែងតាមដុត បុគ្គលនោះ ដែលជាបុគ្គលពាលកើតហើយក្នុងអបាយ មាននរកជាដើម ក្នុង អត្តភាពទី ២ ឬទី ៣ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើម ដូច្នេះឯង ៕

**រឿង អហិប្រេត ចប់**

# រឿង សដ្ឋិកូដប្រេត

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធសដ្ឋិកូដប្រេត ត្រាស់ព្រះធម្មទេសនានេះថា **យាវទេវ អនត្ថាយ** ជាដើម ។

សេចក្តីពិស្តារថា ព្រះមហាមោគ្គល្លានត្ថេរចុះអំពីភ្នំគិជ្ឈកូដ មួយអន្លើដោយព្រះលក្ខណត្ថេរ ធ្វើការញញឹមក្នុងបទេសណាមួយ ដោយន័យមុននោះឯង ត្រូវព្រះថេរៈសួរដល់ហេតុនៃការញញឹម ទើបពោលថា លោកម្ចាស់គប្បីសួរខ្ញុំក្នុងសម្នាក់ព្រះដ៏មានព្រះភាគ ក្នុងកាលព្រះមហាមោគ្គល្លានត្ថេរត្រាច់ទៅបិណ្ឌបាត ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំ អង្គុយហើយ ត្រូវព្រះថេរៈសួរទៀត ទើបពោលថា អាវុសោ ខ្ញុំឃើញប្រេតមួយ មានអត្តភាពប្រមាណ ៣ គាវុត ញញួរដែក ៦ ម៉ឺនដែលភ្លើងឆេះសន្ធោសន្ធៅហើយ ធ្លាក់លើអំបែងក្បាលរបស់ប្រេតនោះតាំងឡើង ទម្លាយក្បាលរបស់ប្រេតបែកហើយ រមែងតាំងឡើងទៀតដោយអត្តភាពនេះ អត្តភាពបែបនេះ ខ្ញុំមិនធ្លាប់ឃើញ ខ្ញុំឃើញអត្តភាពនោះ ទើបធ្វើការញញឹមឲ្យប្រាកដ ។ ពិតហើយ ក្នុងរឿងប្រេត ព្រះមហាមោគ្គល្លានត្ថេរសំដៅយកប្រេតនោះឯង ទើបពោលពាក្យជាដើមថា

ញញួរដែកដែលពេញប្រាំមួយម៉ឺន ( ៦០០០០ ) ដ៏គ្រប់គ្រាន់ ធ្លាក់មកលើក្បាលរបស់អ្នក ញញួរដែកទាំងនោះ វាយទម្លាយក្បាល ។

ព្រះសាស្តាទ្រង់ស្តាប់ពាក្យរបស់ព្រះថេរៈហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សត្វនេះតថាគតអង្គុយត្រង់ពោធិមណ្ឌលប្រទេស ក៏ឃើញហើយដូចគ្នា តែតថាគតមិនសម្តែង ដើម្បីអនុគ្រោះដល់ជនដទៃ ព្រោះជនពួកណាមិនជឿពាក្យរបស់តថាគត ការមិនជឿនោះគប្បីមានដើម្បីកម្មមិនជាប្រយោជន៍ដល់បុគ្គលទាំងនោះ តែឥឡូវនេះ តថាគតជាបន្ទាល់របស់មោគ្គល្លាន ទើបប្រាប់បាន ។ ភិក្ខុទាំងឡាយស្តាប់ព្រះតម្រាស់នោះហើយ ទើបសួរដល់បុព្វកម្មរបស់ប្រេតនោះ ។ ព្រះសាស្តាក៏ត្រាស់ដល់ភិក្ខុទាំងនោះថា

បានឮមកថា ក្នុងអតីតកាល ក្នុងក្រុងពារាណសី មានបុរសខ្វិនម្នាក់ដល់នូវសេចក្តីសម្រេចក្នុងសិប្បៈរបស់បុគ្គលដែលផ្ទាត់គ្រាប់ក្រួស ។ បុរសនោះអង្គុយក្រោមដើមជ្រៃមួយដើម ក្បែរទ្វារព្រះនគរ ពួកក្មេងអ្នកស្រុកពោលថា សូមអ្នកផ្ទាត់ជុំក្រួសទម្លុះស្លឹកជ្រៃនោះ ធ្វើជារូបដំរីដល់ពួកខ្ញុំ ធ្វើជារូបសេះដល់ពួកខ្ញុំ ក៏បង្ហាញរូបទាំងឡាយដែលពួកក្មេងប្រាថ្នាហើយ បានវត្ថុមានរបស់ទំពាជាដើមអំពីសម្នាក់ពួកក្មេងទាំងនោះ ។ សម័យមួយ ព្រះរាជាយាងទៅកាន់ព្រះរាជឧទ្យាន ដល់ប្រទេសនោះ ។ ពួកក្មេងញាត់បុរសនោះក្នុងព្រង់ជ្រៃហើយក៏គេចទៅ កាលព្រះរាជាចូលទៅកាន់គល់ជ្រៃ ក្នុងថ្ងៃត្រង់ស្រមោលចាំងចំព្រះសរីរៈ ទ្រង់ត្រិះរិះថា នេះអ្វីហ្ន៎ ទ្រង់ទតមើលខាងលើឃើញរូប មានរូបដំរីជាដើម ត្រង់ស្លឹកឈើទាំងឡាយ ទើបត្រាស់សួរថា នេះជាកម្មរបស់អ្នកណា ទ្រង់បានឮថា របស់មនុស្សខ្វិន ទើបត្រាស់បញ្ជាឲ្យរកបុរសខ្វិននោះមក ហើយត្រាស់ថា បុរោហិតរបស់យើងមាត់រឹងពេក កាល

យើងនិយាយ សូម្បីតិចតួច ក៏ពោលច្រើន រមែងបៀតបៀនយើង តើអ្នកអាចផ្ចាត់អាចម៍ពពែប្រមាណមួយនាឡិ ចូលក្នុងមាត់របស់បុរោហិតនោះបានដែរឬ បុរសខ្វិនទូលថា បពិត្រព្រះអង្គ ទូលបង្គំអាច សូមទ្រង់ឲ្យមនុស្សនាំមូលពពែមក ហើយប្រថាប់គង់ ខាងក្នុងវាំងននជាមួយបុរោហិត ទូលបង្គំដឹងកម្មដែលគួរធ្វើក្នុងរឿងនេះ ។ ព្រះរាជាបានធ្វើយ៉ាងនោះ ។ បុរសខ្វិននេះ ឲ្យធ្វើប្រហោងវាំងននដោយចុងកន្ត្រៃ កាលបុរោហិតនិយាយជាមួយព្រះរាជា គ្រាន់តែហាមាត់ ក៏ផ្ចាត់អាចម៍ពពែទៅម្ដងមួយដុំៗ ។ បុរោហិតលេបអាចម៍ពពែដែលចូលមាត់ហើយ កាលអាចម៍ពពែអស់ ទើបបុរសខ្វិនកន្ត្រាក់វាំងនន ព្រះរាជាទ្រង់ជ្រាបភាពដែលអាចម៍ពពែអស់ ដោយសញ្ញានោះហើយ ទើបត្រាស់ថា លោកអាចារ្យ ខ្ញុំនិយាយជាមួយលោក មិនអាចចាំពាក្យបាន សូម្បីលោកលេបអាចម៍ពពែមួយនាឡិហើយ ក៏មិនដល់នូវភាពជាអ្នកស្ងៀម ព្រោះភាពដែលអ្នកមានមាត់រឹង ។ ព្រាហ្មណ៍ដល់នូវការខ្មាស ចាប់តាំងអំពីនោះមក មិនអាចហាមាត់ជាមួយព្រះរាជាបាន ព្រះរាជាទ្រង់ឲ្យហៅបុរសខ្វិនមកហើយត្រាស់ថា យើងបានសេចក្ដីសុខ ព្រោះអាស្រ័យអ្នក ទ្រង់ពេញព្រះហឫទ័យ ទើបព្រះរាជទានវត្ថុមួយមុខ ៨ ដល់គាត់ បានព្រះរាជទានស្រុកសួយ ៤ ក្នុងទិសទាំង ៤ នៃក្រុង អមាត្យដែលប្រៀនប្រដៅអត្ថ និងធម៌របស់ព្រះរាជា ជ្រាបសេចក្ដីនោះហើយ ទើបពោលគាថានេះថា

ធម្មតាសិល្បសាស្ត្រយ៉ាងណាក៏ដោយ សុទ្ធតែសម្រេចប្រយោជន៍
សូមព្រះអង្គទត ស្រុកសួយទាំង ៤ ទិស ដែលបុរសខ្វិនបាន

ហើយ ដោយការផ្ចាត់ ( អាចម៍ពពែ ) នៃបុរសខ្វិន ។

អមាត្យនោះ ក្នុងកាលនោះបានជាតថាគតនោះឯង ។ គ្រានោះ បុរសម្នាក់ឃើញសម្បត្តិបុរសខ្វិនបានហើយ ទើបគិតថា បុរសជាមនុស្សខ្វិនអាស្រ័យសិប្បៈនេះ ទើបដល់ហើយនូវសម្បត្តិធំ ឯអាត្មាអញសិក្សានូវសិប្បៈនេះក៏គួរ គាត់ចូលទៅរកបុរសខ្វិនថ្វាយបង្គំហើយពោលថា លោកអាចារ្យ សូមលោកឲ្យសិប្បៈនេះដល់ខ្ញុំចុះ ។ បុរសខ្វិនពោលថា នែបា ខ្ញុំមិនអាចឲ្យបានទេ ។ គាត់ត្រូវបុរសខ្វិននោះឃាត់ហើយគិតថា ណ្ហើយចុះ អញនឹងញុំាងបុរសខ្វិននោះឲ្យត្រេកអរ ទើបធ្វើកិច្ចមានការគក់ប្រេបាច់ដៃជើងជាដើម ដល់បុរសខ្វិននោះ ឲ្យបុរសខ្វិននោះ ត្រេកអរហើយអស់កាលយូរ អង្វររឿយៗហើយ ។ បុរសខ្វិនគិតថា ជននេះមានឧបការៈដល់អញពន់ពេក ទើបមិនអាចឃាត់បាន ឲ្យសិក្សាសិប្បៈហើយ ពោលថា នែបា សិប្បៈរបស់អ្នកសម្រេចហើយ ឥឡូវនេះ អ្នកនឹងធ្វើអ្វី បុរសនោះពោលថា ខ្ញុំនឹងទៅសាកល្បងសិប្បៈនៅខាងក្រៅ បុរសខ្វិនពោលថា អ្នកនឹងធ្វើដូចម្ដេច បុរសនោះពោលថា ខ្ញុំនឹងផ្ចាត់មេគោឬ មនុស្សឲ្យស្លាប់ បុរសខ្វិនពោលថា នែបា បើអ្នកសម្លាប់មេគោសំណងនឹងមានមួយរយកហាបណៈ បើសម្លាប់មនុស្សសំណងនឹងមានមួយពាន់កហាបណៈ អ្នកមួយអន្លើដោយបុត្រ និងភរិយាមិនអាចដោះបំណុលនោះបាន ចូរអ្នកកុំវិនាសឡើយ កាលអ្នកប្រហារបុគ្គលណា ដែលមិនមានបំណុល អ្នកចូរពិនិត្យមើលបុគ្គលណាម្នាក់ដែល មិនមានមាតាបិតា ដូច្នោះ ។ បុរសនោះទទួលថា សាធុ ហើយយកដុំក្រួសដាក់

ថ្នក់ ត្រាច់សម្លឹងមើលបុគ្គលដែលមានសភាពដូច្នោះ ឃើញមេគោហើយ មិនអាចផ្ចាត់បាន ដោយគិតថា មេគោនេះមានម្ចាស់ ឃើញមនុស្សហើយមិន អាចផ្ចាត់បាន ដោយគិតថា មនុស្សនេះមានមាតាបិតា ។

ដោយសម័យនោះព្រះបច្ចេកពុទ្ធឈ្មោះសុនេត្តៈ អាស្រ័យព្រះនគរ នៅ ក្នុងបណ្ណសាលា ។ បុរសនោះឃើញព្រះបច្ចេកពុទ្ធនោះ ចូលទៅដើម្បីបិណ្ឌបាត ឈរនៅក្នុងវាំងទ្វារនគរគិតថា ព្រះបច្ចេកពុទ្ធនេះ ជាបុគ្គលមិនមានមាតាបិតា កាលអាត្មាអញផ្ចាត់បុគ្គលនេះ មិនចាំបាច់មានពិន័យ អញនឹងផ្ចាត់ព្រះបច្ចេក-ពុទ្ធនេះ ដើម្បីល្បងសិប្បៈ ដូច្នេះហើយ ទើបផ្ចាត់ដុំក្រួសទៅតម្រង់រន្ធ ត្រចៀកខាងស្តាំរបស់ព្រះបច្ចេកពុទ្ធ ដុំក្រួសចូលទៅតាមរន្ធត្រចៀកខាងស្តាំ ចេញទៅតាមរន្ធត្រចៀកខាងឆ្វេង ទុក្ខវេទនាកើតឡើងហើយ ។ ព្រះបច្ចេក-ពុទ្ធមិនអាចត្រាច់ទៅបិណ្ឌបាតបាន ទើបទៅកាន់បណ្ណសាលាតាមអាកាស បរិនិព្វានហើយ ។ ពួកមនុស្សកាលព្រះបច្ចេកពុទ្ធមិននិមន្តមក គិតថា ការមិន ផាសុកណាមួយនឹងមាន ទើបទៅត្រង់បណ្ណសាលានេះ ឃើញលោកបរិព្វាន ហើយ ទ្រហោយំរៀបរាប់ ។ បុរសនោះឃើញមហាជនទៅត្រង់បណ្ណសាលា នោះហើយ ចាំព្រះបច្ចេកពុទ្ធនោះបាន ទើបពោលថា ព្រះបច្ចេកពុទ្ធអង្គនេះ កាលចូលទៅដើម្បីបិណ្ឌបាត ជួបខ្ញុំត្រង់វាំងទ្វារ កាលខ្ញុំសាកល្បងសិប្បៈ របស់ខ្លួន ទើបប្រហារព្រះបច្ចេកពុទ្ធនេះ ពួកមនុស្សពោលថា បានឮថា មនុស្សអាក្រក់នេះ ប្រហារព្រះបច្ចេកពុទ្ធ ចូរពួកអ្នកចាប់វាយបុរសនោះ ឲ្យ ដល់នូវការអស់ជីវិតក្នុងទីនោះឯង ។ បុរសនោះ កើតក្នុងអវិចី ឆេះហើយ

រហូតផែនដីផុះឡើងបានមួយយោជន៍ ដោយសេសសល់ផលកម្ម កើតជាសដ្ឋិ-កូដប្រេតត្រង់កំពូលភ្នំគិជ្ឈកូដដូច្នេះ ។

ព្រះសាស្តា កាលត្រាស់បុព្វកម្មនេះរបស់ប្រេតនោះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សិប្បៈ ឬឥស្សរៈកើតឡើងដល់បុគ្គលពាល រមែងកើតឡើងដើម្បីសេចក្តីវិនាស ព្រោះថា បុគ្គលពាលបានសិប្បៈ ឬភាពជាឥស្សរៈហើយ រមែងធ្វើសេចក្តីវិនាសដល់ខ្លួនតែម្យ៉ាង ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិនៃធម៌ ទើបត្រាស់ព្រះគាថានេះថា

**យាវទេវ អនត្ថាយ ញត្តំ ពាលស្ស ជាយតិ**
**ហន្តិ ពាលស្ស សុក្កំសំ មុទ្ធំ អស្ស វិបាតយំ ។**

ការចេះដឹងកើតឡើងដល់បុគ្គលពាល គ្រាន់តែដើម្បីសេចក្តីវិនាសប៉ុណ្ណោះ រមែងញ៉ាំងបញ្ញាឲ្យធ្លាក់ចុះ បំផ្លេចបំផ្លាញចំណែកនៃធម៌ស គឺកុសលរបស់បុគ្គលពាលនោះ ។

## សេចក្តីអធិប្បាយ

សព្ទថា **យាវទេវ** ក្នុងគាថានោះ ជានិបាត ចុះក្នុងអត្ថ គឺការកំណត់នូវដែន ។ ការៈ គឺការដឹង ឈ្មោះថា **ញត្តំ** ។ បុគ្គលរមែងដឹងសិប្បៈណា ឬបុគ្គលតាំងនៅក្នុងភាពជាបុគ្គលធំណា ឬដោយការដល់ព្រមដោយយសណា ដែលជនរមែងស្គាល់ គឺប្រាកដ បានដល់ ជាអ្នកខ្ពង់ខ្ពស់ ។ ពាក្យថា **ញត្តំ** នេះ ជាឈ្មោះនៃសិប្បៈភាពជាធំ និងការដល់ព្រមដោយយសនោះ ។ ពិតហើយ សិប្បៈ ឬភាពជាធំជាដើម រមែងកើតដល់បុគ្គលពាល ដើម្បីភាព

*វិនាសតែម្យ៉ាង គឺបុគ្គលពាលនោះអាស្រ័យសិប្បៈជាដើមនោះ រមែងធ្វើនូវការវិនាសដល់ខ្លួនតែម្យ៉ាង ។ បទថា* **ហន្តិ** *បានដល់ ឲ្យវិនាស ។ បទថា* **សុក្កំសំ** *គឺចំណែកនៃកុសល អធិប្បាយថា សិប្បៈ ឬភាពជាធំ កាលកើតឡើងដល់បុគ្គលពាល រមែងកើតឡើងសម្លាប់នូវចំណែកដែលជាកុសលធម៌តែម្យ៉ាង ។ បទថា* **មុទ្ធំ** *នេះ ជាឈ្មោះរបស់បញ្ញា ។ បទថា* **វិបាតយំ** *គឺកម្ចាត់ អធិប្បាយថា ការដឹងនោះ សម្លាប់ចំណែកកុសលរបស់បុគ្គលពាលនោះ ញុំាងមុទ្ធា ពោល គឺបញ្ញាឲ្យធ្លាក់ទៅ គឺកម្ចាត់នោះឯង ឈ្មោះថាសម្លាប់ ។*

*ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមដូច្នេះឯង ។l៚*

**រឿងសដ្ឋិកូដប្រេត ចប់**

# រឿងព្រះសុធម្មត្ថេរ

## លំនាំដើម

*ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសុធម្មត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា* **អសន្តំ ភាវមិច្ឆេយ្យ** *ជាដើម ។*

*ទេសនានេះតាំងឡើងហើយ ក្នុងមច្ឆិកាសណ្ឌនគរ ចប់ហើយក្នុងក្រុងសាវត្ថី ។*

សេចក្ដីពិស្ដារថា ចិត្តគហបតីក្នុងមច្ឆិកាសណ្ឌនគរ ឃើញព្រះមហា-នាមត្ថេរក្នុងពួកបញ្ចវគ្គិយភិក្ខុត្រាច់បិណ្ឌបាត ជ្រះថ្លាក្នុងឥរិយាបថរបស់ព្រះថេរៈហើយ ទើបទទួលបាត្រនិមន្តឲ្យចូលទៅកាន់ផ្ទះ ឲ្យឆាន់ហើយ ក្នុងកាលស្រេចភត្តកិច្ច ស្ដាប់ធម្មកថាសម្រេចសោតាបត្តិផលហើយ ជាអ្នកមានសទ្ធាមិនញាប់ញ័រ ប្រាថ្នាដើម្បីធ្វើឧទ្យានរបស់ខ្លួនដែលមានឈ្មោះថា អម្ពាដកវ័ន គឺចម្ការម្កាក់ឲ្យជាសង្ឃារាម ទើបប្រូចទឹកលើដៃព្រះថេរៈ ប្រគេនហើយ ។ ក្នុងខណៈនោះ មហាប្រឹថពីធ្វើឲ្យទីបំផុតនៃទឹកញាប់ញ័រ ដោយប្រាប់ហេតុថាព្រះពុទ្ធសាសនាតាំងមាំហើយ ។

មហាសេដ្ឋីឲ្យសាងវិហារធំក្នុងឧទ្យាន បានជាបុគ្គលមានទ្វារបើកជានិច្ចដើម្បីពួកភិក្ខុដែលមកអំពីទិសទាំងពួងហើយ ។ ព្រះសុធម្មត្ថេរបានជាម្ចាស់អាវាស នៅក្នុងមច្ឆិកាសណ្ឌៈនោះ ។

សម័យក្រោយតមក អគ្គសាវ័កទាំងពីរ ស្ដាប់កថាពណ៌នាគុណរបស់ចិត្តគហបតីហើយ ប្រាថ្នានឹងធ្វើការសង្គ្រោះដល់គហបតីនោះ ទើបបានទៅកាន់មច្ឆិកាសណ្ឌនគរ ។ ចិត្តគហបតី ជ្រាបការមករបស់អគ្គសាវ័កទាំងពីរនោះ ទើបទៅទទួលអស់ចម្ងាយផ្លូវប្រមាណកន្លះយោជន៍ នាំអគ្គសាវ័កទាំងពីរនោះមកហើយនិមន្តឲ្យចូលទៅកាន់វិហាររបស់ខ្លួន ធ្វើអាគន្តុកវត្តហើយ អារាធនាព្រះធម្មសេនាបតីថា បពិត្រលោកម្ចាស់ ខ្ញុំប្រាថ្នាស្ដាប់ធម្មកថាតិចតួច ។ គ្រានោះ ព្រះថេរៈពោលនឹងគហបតីថា ឧបាសក អាត្មាទាំងឡាយហត់នឿយហើយ ដោយផ្លូវឆ្ងាយ ម្យ៉ាងទៀត ចូរអ្នកស្ដាប់ត្រឹមតែបន្តិចបន្តួចចុះ ដូច្នេះ

ហើយ ពោលធម្មកថាដល់ឧបាសកនោះ ។ គហបតីនោះស្តាប់ធម្មកថារបស់ព្រះថេរៈនោះឯង សម្រេចអនាគាមិផលហើយ ។ ថ្វាយបង្គំអគ្គសាវកទាំងពីរហើយ និមន្តថា បពិត្រលោកម្ចាស់ ស្អែកនេះ សូមលោកម្ចាស់ទាំងពីរជាមួយភិក្ខុ ១ ពាន់រូប ទទួលភិក្ខាត្រង់ផ្ទះខ្ញុំចុះ ហើយនិមន្តព្រះសុធម្មត្ថេរដែលជាម្ចាស់អាវាស តាមក្រោយថា បពិត្រលោកម្ចាស់ ស្អែកនេះ សូមលោកម្ចាស់មកជាមួយព្រះថេរៈទាំងឡាយចុះ ។

ព្រះសុធម្មត្ថេរនោះក្រោធថា ឧបាសកនេះនិមន្តអញក្រោយ ទើបប្រកែកកាលគហបតីអង្វររឿយៗ ក៏ប្រកែកនោះឯង ។ ឧបាសកពោលថា សូមលោកម្ចាស់ពិតប្រាកដចុះ ហើយចៀសចេញទៅ ក្នុងថ្ងៃស្អែកឡើង រៀបចំមហាទានក្នុងលំនៅរបស់ខ្លួន ។ ក្នុងពេលជិតភ្លឺ សូម្បីព្រះសុធម្មត្ថេរគិតថា គហបតីចាត់ចែងសក្ការៈអ្វីហ្ន៎ ដើម្បីអគ្គសាវកទាំងពីរ ស្អែកនេះ អញនឹងទៅមើលហើយបានកាន់បាត្រ និងចីវរ ទៅកាន់ផ្ទះរបស់គហបតីនោះ អំពីព្រលឹម ។ ព្រះសុធម្មត្ថេរនោះ សូម្បីគហបតីពោលថា សូមលោកម្ចាស់និមន្តគង់ចុះ ក៏ពោលថា អាត្មាមិនគង់ អាត្មាត្រាច់បិណ្ឌបាត ហើយពិនិត្យមើលសក្ការៈដែលគហបតីរៀបចំដើម្បីអគ្គសាវកទាំងពីរ ប្រាថ្នានឹងបៀតបៀនគហបតីដោយជាតិ ទើបពោលថា នែគហបតី សក្ការៈរបស់អ្នកគ្រប់គ្រាន់ តែក្នុងសក្ការៈនេះ មិនមានរបស់មួយប៉ុណ្ណោះ គហបតីពោលថា របស់អ្វីលោកម្ចាស់ ព្រះថេរៈឆ្លើយថា គឺនំទ្រាបល្ង ត្រូវគហបតីបៀតបៀនដោយវាចាឧបមាអំពីក្អែក ក្រោធហើយ ពោលថា នែគហបតី នុ៎ះអាវាសរបស់អ្នក

ហើយចៀសចេញទៅ ។ គហបតីឃាត់ដល់ ៣ ដង ក៏ចៀសទៅកាន់សម្នាក់ព្រះសាស្ដា ក្រាបទូលពាក្យដែលចិត្តគហបតីនឹងខ្ទនពោលហើយ ។

ព្រះសាស្ដាត្រាស់ថា ឧបាសកជាអ្នកមានសទ្ធាជ្រះថ្លា ត្រូវអ្នកជេរដោយពាក្យអាក្រក់ ដូច្នេះហើយ ទ្រង់ដាក់ទោសដល់ព្រះសុធម្មត្ថេរនោះឯង ហើយប្រាប់ឲ្យសង្ឃដាក់បដិសារណីយកម្ម ហើយទ្រង់បញ្ជូនទៅថា ចូរអ្នកទៅឲ្យចិត្តគហបតីអត់ទោសឲ្យ ព្រះថេរៈទៅក្នុងទីនោះហើយ ពោលថា គហបតី ទុំះទោសរបស់អាត្មាប៉ុណ្ណោះ ចូរអ្នកអត់ទោសដល់អាត្មាចុះ គហបតីនោះប្រកែកថា ខ្ញុំមិនអត់ទោសឡើយ ក៏ខ្មាសអៀន មិនអាចឲ្យគហបតីទុំះ អត់ទោសបាន ទើបត្រឡប់មកកាន់សម្នាក់ព្រះសាស្ដាទៀត ។ ព្រះសាស្ដាទ្រង់ជ្រាបថា ឧបាសកមិនអត់ទោសដល់ព្រះសុធម្មៈនេះ ទ្រង់ត្រិះរិះថា ភិក្ខុនេះរឹងត្អឹងព្រោះមានះ ចូលទៅកាន់ផ្លូវ ៣ យោជន៍ ហើយត្រឡប់មក ទើបទ្រង់មិនប្រាប់ឧបាយឲ្យអត់ទោសឡើយ ហើយទ្រង់បញ្ជូនទៅ ។

ក្នុងកាលដែលព្រះសុធម្មត្ថេរនោះត្រឡប់មក ព្រះសាស្ដាប្រទានភិក្ខុដែលអនុគ្រោះដល់លោក ដែលនាំមានះចេញហើយត្រាស់ថា ចូរអ្នកទៅចុះ ទៅជាមួយភិក្ខុនេះ ចូរឲ្យឧបាសកអត់ទោស ដូច្នេះហើយ ត្រាស់ថា ធម្មតាសមណៈមិនគួរធ្វើមានះ ប្រណែនថា វិហាររបស់អញ លំនៅរបស់អញ ឧបាសករបស់អញ ឧបាសិការបស់អញ ព្រោះកាលសមណៈធ្វើយ៉ាងនោះ ពួកកិលេស មានឥស្សា និងមានះជាដើម រមែងចម្រើន កាលទ្រង់បន្តអនុសន្ធិ ទើបត្រាស់ព្រះគាថានេះថា

**អសន្តំ ភាវមិច្ឆេយ្យ ពុរេក្ខារញ្ច ភិក្ខុសុ**
**អាវាសេសុ ច ឥស្សរិយំ បូជា បរកុលេសុ ច ។**
**មមេវ កត មញ្ញន្តុ គិហិបព្វជិតា ឧភោ**
**មមេវ អតិវសា អស្សុ កិច្ចាកិច្ចេសុ កិស្មិចិ**
**ឥតិ ពាលស្ស សង្កប្បោ ឥច្ឆា មានោ ច វឌ្ឍតិ ។**

*ភិក្ខុពាល រមែងប្រាថ្នានូវសេចក្ដីសរសើរ ដែលមិនមាន ( ក្នុងខ្លួន ) ផង នូវការធ្វើក្នុងខាងមុខ គឺជាប្រមុខក្នុងពួកភិក្ខុផង នូវភាពជាឥស្សរៈក្នុងអាវាសទាំងឡាយផង នូវការបូជាទាំងឡាយ ក្នុងត្រកូលនៃជនទាំងឡាយដទៃផង ភិក្ខុពាល រមែងមានសេចក្ដីត្រិះរិះថា គ្រហស្ថ និងបព្វជិតទាំងពីរពួក ចូរសម្គាល់នូវកិច្ច ដែលមនុស្សដទៃធ្វើហើយ ថាជាកិច្ចរបស់អញវិញ អំណាចដ៏ក្រៃលែងរបស់អញ ចូរមានក្នុងកិច្ចតូចធំណាៗ មួយ ( កាលបើយ៉ាងនេះ ) ឫស្យា និងមានះ រមែងចម្រើន ។*

## សេចក្ដីអធិប្បាយ

*បណ្ដាបទទាំងនោះ បទថា* **អសន្តំ** *សេចក្ដីថា ភិក្ខុពាល គប្បីប្រាថ្នាសេចក្ដីសរសើរដែលមិនមាន គឺភិក្ខុពាល មិនមានសទ្ធា ជាអ្នកទ្រុស្តសីល ជាអ្នកស្ដាប់តិច មិនស្ងប់ស្ងាត់ ខ្ជិលច្រអូស មានសតិមិនតាំងមាំ មានចិត្តមិន*

មាំទាំ មានបញ្ញាជោកជយ មិនមែនទីណាសវ: រមែងប្រាថ្នាការលើកតម្កើង ដែលមិនមាននេះថា ធ្វើម្តេចហ្ន៎ ជនគប្បីស្គាល់អញថា ភិក្ខុនេះ ជាអ្នកមាន សទ្ធា មានសីល ជាពហូសូត ជាអ្នកស្ងាត់ ប្រារព្ធសេចក្តីព្យាយាម មាន សតិតាំងមាំ មានចិត្តមាំទាំ មានបញ្ញា ជាព្រះទីណាស្រេព ដោយន័យដែល លោកពោលក្នុងបាបិច្ឆតានិទ្ទេសថា ភិក្ខុជាបុគ្គលមិនមានសទ្ធាឡើយ រមែង ប្រាថ្នាថា ចូរជនស្គាល់អញថា ជាអ្នកមានសទ្ធាជាដើម ។

បទថា **បុរេក្ខារំ** គឺនូវបរិក្ខារ អធិប្បាយថា ភិក្ខុពាល តាំងនៅក្នុង ការប្រព្រឹត្តដោយអំណាច គឺការចង់បានយ៉ាងនេះថា ធ្វើម្តេចហ្ន៎ ភិក្ខុក្នុងវិហារ ទាំងមូលគប្បីចោមរោមសួរបញ្ហា ឈ្មោះថា រមែងប្រាថ្នាការចោមរោមក្នុង ភិក្ខុទាំងឡាយ ។

បទថា **អាវាសេសុ** បានដល់ក្នុងអាវាសដែលជារបស់សង្ឃ អធិប្បាយ ថា ភិក្ខុពាលចាត់សេនាសនៈប្រណីត ត្រង់កណ្តាលវិហារ ដើម្បីភិក្ខុទាំងឡាយ មានភិក្ខុដែលជាសម្លាញ់ធ្លាប់ឃើញ និងសម្លាញ់ស្និទ្ធស្នាលជាដើមរបស់ខ្លួន ដោយប្រាប់ថា ចូរពួកលោកនៅក្នុងសេនាសនៈនេះ ចំណែកខ្លួនជ្រៀតបៀត យកសេនាសនៈដែលល្អ រៀបចំសេនាសនៈដែលអាក្រក់ និងសេនាសនៈ ដែលអមនុស្សហួងហែងហើយ តាំងនៅក្នុងទីបំផុត ដើម្បីអាគន្តុកភិក្ខុ ដ៏សេសទាំងឡាយ ដោយប្រាប់ថា ចូរពួកលោកនៅក្នុងសេនាសនៈនេះ ឈ្មោះថា រមែងប្រាថ្នាភាពជាធំក្នុងអាវាស ។

បាទព្រះគាថាថា **បូជា បរកុលេសុ ច** សេចក្តីថា ភិក្ខុពាល រមែងមិន

ប្រាថ្នាការបូជាដោយបច្ច័យ ៤ ក្នុងត្រកូលរបស់មាតា និងបិតាឡើយ និងរបស់ពួកញាតិក៏មិនប្រាថ្នា ។ តែរមែងប្រាថ្នាក្នុងត្រកូលរបស់ជនដទៃប៉ុណ្ណោះ យ៉ាងនេះថា ធ្វើម្តេចហ្ន៎ ជនទាំងនេះគប្បីប្រគេនដល់អញតែម្នាក់ មិនគប្បីឲ្យដល់ភិក្ខុទាំងនោះ ។

បាទព្រះគាថាថា **មមេវ កត មញ្ញន្តុ** សេចក្តីថា ឯការត្រិះរិះរមែងកើតឡើងដល់ភិក្ខុពាលថា ពួកគ្រហស្ថ និងបព្វជិតទាំងពីរ ចូរសម្គាល់កិច្ចដែលខ្ញុំធ្វើហើយ គឺដែលសម្រេចហើយ ព្រោះអាស្រ័យអាត្មាអញប៉ុណ្ណោះ ដោយបំណងយ៉ាងនេះថា នវកម្មណាមួយដែលគេធ្វើហើយក្នុងវិហារ ដោយអំណាចការធ្វើនវកម្ម មានរោងឧបោសថជាដើម នវកម្មទាំងអស់នោះ ដែលព្រះថេរៈរបស់ពួកយើងធ្វើហើយ ។

បាទព្រះគាថាថា **មមេវ អតិវសា អស្សុ** សេចក្តីថា ការត្រិះរិះរមែងកើតឡើងដល់ភិក្ខុដែលជាពាលនោះថា គ្រហស្ថ និងបព្វជិតទាំងអស់ ចូរប្រព្រឹត្តទៅក្នុងអំណាចរបស់អញតែម្នាក់ គឺពាហនៈ និងគ្រឿងឧបករណ៍ទាំងឡាយជាដើមថា រទេះ គោ កាំបិត ពូថៅ ឬដោយហោចកិច្ចទាំងឡាយជាដើម ដូចជាកម្ពោបបរហើយបរិភោគ ដែលគ្រហស្ថ និងបព្វជិតគប្បីបានក៏ដោយចុះ តែបណ្តាកិច្ចតូច និងកិច្ចធំ គឺបណ្តាករណីយកិច្ចទាំងតូចទាំងធំបែបនេះ គ្រហស្ថ ឬបព្វជិតទាំងឡាយ ចូរប្រព្រឹត្តទៅក្នុងអំណាចរបស់អាត្មាអញប៉ុណ្ណោះ ក្នុងកិច្ចណាមួយ គឺក្នុងកិច្ចឯណាមួយ អធិប្បាយថា ចូរសួរអាត្មាអញប៉ុណ្ណោះ ហើយសឹមធ្វើ ។

ពីរបទថា **ឥតិ ពាលស្ស** សេចក្ដីថា ការចង់បាននោះ និងការត្រិះរិះបែបនេះ រមែងកើតឡើងដល់ភិក្ខុពាលណា វិបស្សនា មគ្គ និងផលរមែងមិនចម្រើនដល់ភិក្ខុពាលនោះ ។ តែតណ្ហាដែលកើតឡើងក្នុងទ្វារ ៦ និងមានះ ៩ យ៉ាង រមែងចម្រើនដល់ភិក្ខុពាលនោះតែម្យ៉ាង ដូចទឹកចម្រើនដល់សមុទ្រ ក្នុងកាលព្រះចន្ទរះឡើង ដូច្នោះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមដូច្នេះឯង ។

ព្រះសុធម្មត្ថេរស្ដាប់ឱវាទនេះហើយ ថ្វាយបង្គំព្រះសាស្ដា ក្រោកឡើងអំពីអាសនៈធ្វើប្រទក្សិណហើយ ទៅជាមួយភិក្ខុដែលជាអនុទូតនោះ សម្ដែងអាបត្តិក្នុងគន្លងចក្ខុរបស់ឧបាសក ញ៉ាំងឧបាសកឲ្យអត់ទោសហើយ ។ ព្រះសុធម្មត្ថេរនោះ កាលឧបាសកអត់ទោសដោយពាក្យថា ខ្ញុំអត់ទោសដល់លោកម្ចាស់ បើទោសរបស់ខ្ញុំមាន សូមលោកម្ចាស់អត់ទោសដល់ខ្ញុំ ។ ព្រះថេរៈតាំងនៅក្នុងឱវាទដែលព្រះសាស្ដាប្រទានហើយ ២-៣ ថ្ងៃប៉ុណ្ណោះ ក៏សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា ។

ចំណែកឧបាសកគិតថា អញមិនទាន់បានគាល់ព្រះសាស្ដាឡើយ កាលសម្រេចសោតាបត្តិផលហើយ មិនទាន់បានគាល់ព្រះសាស្ដាដូចគ្នា កាលតាំងនៅក្នុងអនាគាមិផល អញគួរគាល់ព្រះសាស្ដាដោយពិត ។ គហបតីនោះទឹមរទេះ ៥០០ ដាក់ពេញដោយវត្ថុ មានល្ង អង្ករ សប្បិ ទឹកអំពៅ និងសំពត់ដណ្ដប់ជាដើមហើយ ឲ្យពិតដល់ភិក្ខុទាំងឡាយថា លោកម្ចាស់ទាំងឡាយណា

បំណាំងនឹងគាល់ព្រះសាស្តា សូមលោកម្ចាស់ទាំងឡាយនោះនិមន្តទៅ នឹងមិនលំបាកដោយបិណ្ឌបាតជាដើម ដូច្នេះហើយ ក៏ឲ្យពិតដល់ភិក្ខុនីទាំងឡាយ និងប្រាប់ដល់ពួកឧបាសក និងឧបាសិកា ។ ភិក្ខុប្រមាណ ៥០០ រូប ភិក្ខុនីប្រមាណ ៥០០ រូប ពួកឧបាសកប្រមាណ ៥០០ រូប ឧបាសិកាប្រមាណ ៥០០ រូប ចេញទៅជាមួយគហបតីនោះ ។ គាត់ត្រៀមរៀបចំហើយដោយប្រការ ដែលមិនមានការខ្វះខាតសូម្បីតិចតួចដោយបាយ យាគូ និងកត្តជាដើម អស់ចម្ងាយផ្លូវ ៣០ យោជន៍ ដើម្បីជន ៣ ពាន់នាក់ គឺដើម្បីភិក្ខុជាដើមទាំងនោះឯង និងដើម្បីបរិស័ទរបស់ខ្លួន ។ ចំណែកពួកទេវតា ជ្រាបភាពដែលឧបាសកនោះចេញទៅហើយ បោះជំរំស្នាក់នៅរៀងរាល់មួយយោជន៍ ទំនុកបម្រុងជនទាំងនោះដោយអាហារវត្ថុ មានបបរ របស់ទំពា កត្ត និងទឹកជាដើមដែលជាទិព្វ ការខ្វះខាតដោយវត្ថុណាមួយ មិនមានហើយដល់បុគ្គលណាមួយឡើយ មហាជនដែលទេវតាទាំងឡាយ ទំនុកបម្រុងយ៉ាងនោះ ធ្វើដំណើរបានមួយថ្ងៃមួយយោជន៍ៗ មួយខែដល់ក្រុងសាវត្ថី ។ រទេះទាំងឡាយ ៥០០ នៅពេញបរិបូណ៌ដូចដើមនោះឯង ។ គហបតីបានលះបណ្ណាការ ដែលពួកទេវតានោះឯង និងមនុស្សទាំងឡាយនាំមកហើយទៅ ។

ព្រះសាស្តាត្រាស់នឹងព្រះអានន្ទត្ថេរថា អានន្ទ ក្នុងពេលរសៀលថ្ងៃនេះ ចិត្តគហបតីដែលឧបាសក ៥០០ ចោមរោមហើយនឹងមកថ្វាយបង្គំតថាគត ។

ព្រះអានន្ទសួរថា បពិត្រព្រះអង្គ ក្នុងកាលចិត្តគហបតីនោះ ថ្វាយបង្គំព្រះអង្គ បាដិហារ្យណាមួយនឹងមានឬ ។ ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ

មាន អានន្ទសួរថា បពិត្រព្រះអង្គ តើបាដិហារ្យនោះជាអ្វី ព្រះសាស្តាត្រាស់ថា ក្នុងកាលចិត្តគហបតីនោះមកថ្វាយបង្គំតថាគត ភ្លៀងបោក្ខរពស៌ ផ្កាដែលជាទិព្វមាន ៥ ពណ៌ នឹងធ្លាក់ប្រមាណត្រឹមក្បាលជង្គង់ ក្នុងទីប្រមាណ ៨ ករីស ដោយវិធីរបស់ស្ដេច ។

អ្នកក្រុងស្ដាប់ដំណឹងនោះហើយគិតថា បានឮថា ចិត្តគហបតី មានបុណ្យច្រើនយ៉ាងនោះ មកថ្វាយបង្គំព្រះសាស្តាក្នុងថ្ងៃនេះ បានឮថា បាដិហារ្យបែបនេះនឹងមាន ឯពួកយើងនឹងបានឃើញអ្នកមានបុណ្យច្រើននោះ ដូច្នេះហើយ បានកាន់យកគ្រឿងបណ្ណាការទៅឈរសងខាងផ្លូវ ក្នុងកាលដែលចិត្តគហបតីមកជិតវិហារ ភិក្ខុ ៥០០ រូបមកដល់មុន ។ ចិត្តគហបតីពោលនឹងឧបាសិកាថា នែពួកនាងទាំងឡាយ ចូរនាងមកខាងក្រោយ ចំណែកឧបាសក ៥០០ ហោមរោមហើយ បានទៅកាន់សម្នាក់របស់ព្រះសាស្តា ។ ជនទាំងឡាយដែលឈរក្តី អង្គុយក្តី ក្នុងទីចំពោះព្រះភក្ត្ររបស់ព្រះពុទ្ធទាំង-ឡាយ មិនមានខាងនេះ ឬខាងនោះ រមែងឈរណែនណាន់តាន់តាប់ទាំងសងខាងនៃពុទ្ធវិថី ។ ចិត្តគហបតី ចូលកាន់ពុទ្ធវិថីធំហើយ ។ ទីដែលព្រះអរិយ-សាវ័ក អ្នកដល់នូវផល ៣ សម្លឹងមើល ញាប់ញ័រហើយ ។ មហាជនសម្លឹងមើលហើយដោយគិតថា បានឮថា ជននោះ គឺចិត្តគហបតី ។ គហបតីនោះចូលគាល់ព្រះសាស្តា ចូលទៅខាងក្នុងពុទ្ធរស្មីមាន ៦ ពណ៌ ចាប់ព្រះបាទព្រះសាស្តាត្រង់កព្រះបាទទាំងពីរថ្វាយបង្គំហើយ ក្នុងខណៈនោះឯង ភ្លៀងផ្កាមានប្រការដូចពោលមក ធ្លាក់ហើយ សំឡេងសាធុការរាប់ពាន់ ប្រព្រឹត្តទៅ

ហើយ ។

គហបតីនោះ នៅក្នុងសម្នាក់ព្រះសាស្តាអស់កាលមួយខែ បាននិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានឲ្យគង់ក្នុងវិហារនោះឯង ថ្វាយមហាទានហើយ ។ ធ្វើកិក្ខុដែលមកជាមួយខ្លួននៅក្នុងវិហារនោះឯង ទំនុកបម្រុងហើយ មិនចាំបាច់ចាប់យករបស់ណាមួយក្នុងរទេះរបស់ខ្លួន សូម្បីត្រឹមមួយថ្ងៃ ។ បានធ្វើកិច្ចគ្រប់យ៉ាងដោយបណ្ណាការ ដែលទេវតា និងមនុស្សទាំងឡាយនាំមកប៉ុណ្ណោះ ចិត្តគហបតីនោះ ថ្វាយបង្គំព្រះសាស្តាហើយក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមកដោយតាំងចិត្តថា នឹងថ្វាយទានដល់ព្រះអង្គ បានស្នាក់នៅក្នុងរវាងផ្លូវមួយខែ ខ្ញុំព្រះអង្គនៅក្នុងទីនេះកន្លងទៅមួយខែហើយ ខ្ញុំព្រះអង្គមិនបានកាន់យករបស់ណាមួយដែលខ្ញុំព្រះអង្គនាំមកឡើយ បានថ្វាយទានអស់កាលមានប្រមាណប៉ុណ្ណោះ ដោយបណ្ណាការដែលទេវតា និងមនុស្សទាំងឡាយ នាំមកប៉ុណ្ណោះ បើខ្ញុំព្រះអង្គនោះនៅក្នុងទីនេះមួយឆ្នាំ ក៏មិនបានថ្វាយទេយ្យធម៌របស់ខ្ញុំព្រះអង្គពិត ខ្ញុំព្រះអង្គប្រាថ្នាធ្វើរទេះឲ្យស្រាលហើយទៅ សូមទ្រង់មេត្តាប្រាប់ទីសម្រាប់រក្សាដល់ខ្ញុំព្រះអង្គចុះ ។

ព្រះសាស្តាត្រាស់ជាមួយអានន្ទត្ថេរថា ម្នាលអានន្ទ ចូរអ្នកឲ្យទីទំនេរមួយកន្លែងដល់ឧបាសក ព្រះថេរៈឲ្យធ្វើយ៉ាងនោះហើយ ។ បានឮថា ព្រះសាស្តាទ្រង់អនុញ្ញាតកប្បិយភូមិដល់ចិត្តគហបតីហើយ ឯឧបាសក និងជន ៣ ពាន់នាក់ដែលមកជាមួយខ្លួន ធ្វើដំណើរត្រឡប់ដោយរទេះទទេហើយ ។ ពួកទេវតា និងមនុស្សក្រោកឡើងហើយ ពោលថា បពិត្រឧបាសក អ្នកធ្វើកម្ម

គឺការធ្វើដំណើរទៅដោយរទេះទទេ ដូច្នេះហើយ ក៏ដាក់រទេះឲ្យពេញដោយរតនៈ ៧ ប្រការ ។ គហបតីនោះ បានទំនុកបម្រុងមហាជនដោយបណ្ណាការដែលនាំមកដើម្បីខ្លួនទៅហើយ ។

ព្រះអានន្ទត្ថេរ ថ្វាយបង្គំព្រះសាស្តាហើយក្រាបទូលថា បពិត្រព្រះអង្គ ចិត្តគហបតីកាលមកកាន់សម្នាក់របស់ព្រះអង្គ មកហើយដោយខែមួយ នៅក្នុងទីនេះអស់មួយខែដូចគ្នា បានថ្វាយទានដោយបណ្ណាការដែលទេវតា និងមនុស្សនាំមកប៉ុណ្ណោះអស់កាលប៉ុណ្ណោះ ។ បានឮថា ឥឡូវនេះ គហបតីនោះធ្វើរទេះ ៥០០ ឲ្យទទេ នឹងទៅដោយខែមួយដូចគ្នា ទេវតា និងមនុស្សទាំងឡាយ ក្រោកឡើងហើយពោលដល់គហបតីនោះថា បពិត្រឧបាសក អ្នកធ្វើកម្ម គឺការធ្វើដំណើរទៅដោយរទេះទទេ ដូច្នេះហើយ ក៏ផ្ទុករតនៈ ៧ ប្រការពេញក្នុងរទេះ បានឮថា គហបតីទំនុកបម្រុងមហាជនដោយគ្រឿងបណ្ណាការដែលទេវតា និងមនុស្សនាំមកដើម្បីខ្លួននោះឯង និងត្រឡប់ទៅ ។ សក្ការៈនេះកើតឡើងដល់គហបតីនេះ ដែលមកកាន់សម្នាក់របស់ព្រះអង្គប៉ុណ្ណោះឬ ឬក្នុងទីដទៃកើតឡើងដូចគ្នា ។

ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ ចិត្តគហបតីនោះ មកកាន់សម្នាក់តថាគតក្តី ទៅកាន់ទីដទៃក្តី សក្ការៈរមែងកើតឡើងទាំងអស់ ព្រោះឧបាសកនេះ ជាអ្នកមានសទ្ធាជ្រះថ្លា មានសីលបរិបូណ៌ ឧបាសកបែបនេះ រមែងទៅប្រទេសណាមួយ លាភសក្ការៈ រមែងកើតឡើងដល់បុរសនោះ ក្នុងប្រទេសនោះៗ ឯង ដូច្នេះហើយ ត្រាស់ព្រះគាថាក្នុងបកិណ្ណកវគ្គថា

បុគ្គលមានសទ្ធា បរិបូណ៌ដោយសីល ស្កប់ស្កល់
ដោយយស និងភោគសម្បត្តិ គប់រកប្រទេសណាៗ
គេតែងបូជាក្នុងប្រទេសនោះៗ ។

ឯអត្ថនៃព្រះគាថានោះ ជាក់ច្បាស់ក្នុងបកិណ្ណកវគ្គនោះឯង ។

ព្រះសាស្តាត្រាស់យ៉ាងនោះហើយ ទើបព្រះអានន្ទត្ថេរទូលសួរបុព្វកម្ម របស់ចិត្តគហបតី ។ លំដាប់នោះ ព្រះសាស្តាកាលនឹងត្រាស់ដល់ព្រះអានន្ទ ទើបត្រាស់ថា ម្នាលអានន្ទ ចិត្តគហបតីនេះ មានអភិនីហារបានធ្វើហើយ ទៀបបាទមូលរបស់ព្រះដ៏មានព្រះភាគ ព្រះនាមបទុមុត្តរៈ អន្ទោលទៅក្នុងទេវតា និងមនុស្សអស់សែនកប្ប ក្នុងកាលនៃព្រះពុទ្ធព្រះនាមកស្សបៈ កើតក្នុងត្រកូលព្រានម្រឹគ ដល់នូវការចម្រើនហើយ ។ ថ្ងៃមួយ កាលភ្លៀងធ្លាក់ កាន់លំពែងដើរចូលព្រៃ ដើម្បីរកម្រឹគ សម្លឹងមើលពួកម្រឹគ ឃើញភិក្ខុមួយរូបអង្គុយទទូរក្បាល ត្រង់ញកដែលកើតឯងមួយកន្លែង គិតថា លោកម្ចាស់មួយរូប អង្គុយធ្វើសមណធម៌ អញនឹងនាំអាហារមក ដើម្បីលោកម្ចាស់នោះ ដូច្នេះហើយ ប្រញាប់ទៅកាន់ផ្ទះ ឲ្យមនុស្សអាំងសាច់ដែលខ្លួននាំមកកាលពីម្សិលមិញលើចង្ក្រានមួយ ឲ្យដាំបាយលើចង្ក្រានមួយ ឃើញភិក្ខុត្រាច់បិណ្ឌ-បាតពួកដទៃ ទទួលបាត្ររបស់ភិក្ខុទាំងនោះ និមន្តឲ្យគង់លើអាសនៈដែលខ្លួនចាត់ចែង ត្រៀមភិក្ខាហើយ ប្រាប់អ្នកដទៃថា ចូរពួកអ្នកអង្គាសលោកម្ចាស់ទាំងឡាយ ហើយដាក់កត្តនោះក្នុងល្អីកាន់ដើរទៅ បេះផ្កាផ្សេងៗ ក្នុងរវាងផ្លូវខ្ចប់ដោយស្លឹកឈើ ទៅកាន់ទីដែលព្រះថេរៈគង់ ហើយពោលថា បពិត្រ

លោកម្ចាស់ សូមលោកម្ចាស់ធ្វើសេចក្តីសង្គ្រោះដល់ខ្ញុំចុះ ដូច្នេះហើយ ទទួលបាត្រ ឲ្យពេញដោយកក្តួហើយ ដាក់ក្នុងដៃរបស់ព្រះថេរៈ ធ្វើការបូជាដោយផ្កាទាំងនោះ តាំងសេចក្តីប្រាថ្នាថា បិណ្ឌបាតមានរសនេះ ព្រមដោយផ្កាដែលជាគ្រឿងបូជា ញុំាំងចិត្តរបស់ខ្ញុំឲ្យត្រេកអរ យ៉ាងណា សូមបណ្ណាការមួយពាន់ មកញុំាំងចិត្តរបស់ខ្ញុំឲ្យត្រេកអរ ក្នុងទីដែលខ្ញុំកើតហើយយ៉ាងនោះ ។ សូមភ្លៀងផ្កាដែលមានពណ៌ ៥ ធ្លាក់ចុះ ។ បុរសនោះបំពេញកុសលដរាបដល់អស់ជីវិតហើយ កើតក្នុងទេវលោក ។ ភ្លៀងផ្កាទិព្វធ្លាក់ហើយ ប្រមាណត្រឹមជង្គង់ក្នុងទីដែលគាត់កើតហើយ ។ សូម្បីក្នុងកាលនេះ ភ្លៀងផ្កាក៏ធ្លាក់ក្នុងថ្ងៃដែលគាត់កើតហើយ កាលគាត់មកក្នុងទីនេះ ការនាំបណ្ណាការមក និងការដែលរទេះពេញដោយរតនៈ ៧ ប្រការ ក៏ជាផលនៃកម្មនោះឯង ។៚

## រឿងព្រះសុមនត្ថេរ ចប់

# រឿង ព្រះវនវាសីតិស្សត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះតិស្សត្ថេរ ដែលមានប្រក្រតីនៅព្រៃ ត្រាស់ព្រះធម្មទេសនានេះថា **អញ្ញា ហិ លាភូ-បនិសា** ជាដើម ។

ទេសនាតាំងឡើងហើយក្នុងក្រុងរាជគ្រឹះ បានឮថា សម្លាញ់របស់វង្គន្ត-ព្រាហ្មណ៍ដែលជាបិតារបស់ព្រះសារីបុត្តត្ថេរ ឈ្មោះមហាសេនព្រាហ្មណ៍ នៅក្នុងក្រុងរាជគ្រឹះ ។ ថ្ងៃមួយ ព្រះសារីបុត្តត្រាច់បិណ្ឌបាត បានទៅកាន់ទ្វារផ្ទះរបស់ព្រាហ្មណ៍នោះ ដើម្បីអនុគ្រោះដល់គាត់ តែព្រាហ្មណ៍មានសម្បត្តិអស់ហើយ ក្លាយជាមនុស្សក្រីក្រ គិតថា កូនរបស់អញនឹងមកដើម្បីត្រាច់បិណ្ឌ-បាត ត្រង់ទ្វារផ្ទះរបស់អញ តែអញជាមនុស្សក្រីក្រ កូនរបស់អញប្រហែលជាមិនជ្រាបភាពដែលអញជាមនុស្សក្រីក្រ ទេយ្យធម៌ណាមួយ របស់អញមិនមាន កាលមិនអាចជួបព្រះថេរៈនោះបាន ទើបរត់ពួន ។ សូម្បីក្នុងថ្ងៃដទៃ ព្រះថេរៈបានទៅទៀត ។ ព្រាហ្មណ៍បានរត់ពួនយ៉ាងនោះដូចគ្នា ។ គាត់គិតថា អញបានវត្ថុអ្វីមួយដើម្បីប្រគេនហ្ន៎ ក៏មិនបានវត្ថុណាមួយ ។ ថ្ងៃក្រោយមក គាត់បានថាសពេញដោយបាយាស មួយអន្ទើដោយសំពត់សាដកសាច់គ្រោតគ្រាត ក្នុងទីប្រាប់លទ្ធិរបស់ព្រាហ្មណ៍មួយកន្លែង កាន់ទៅដល់ផ្ទះ នឹកដល់ព្រះថេរៈថា កាលដែលអញប្រគេនបិណ្ឌបាតនេះដល់ព្រះថេរៈ គួរ ។

ក្នុងខណៈនោះឯង ព្រះថេរៈចូលឈាន ចេញអំពីឈានសមាបត្តិហើយ

ឃើញព្រាហ្មណ៍នោះគិតថា ព្រាហ្មណ៍បានទេយ្យធម៌ហើយ ទន្ទឹងនូវកម្មរបស់អាត្មាអញ ការដែលអាត្មាអញទៅក្នុងទីនោះគួរ ដូច្នេះហើយ ទើបដណ្តប់សំពត់សង្ឃាដី កាន់បាត្រ បង្ហាញខ្លួនឈរហើយត្រង់ទ្វារផ្ទះរបស់ព្រាហ្មណ៍នោះឯង ។ ព្រោះឃើញព្រះថេរៈប៉ុណ្ណោះ ចិត្តរបស់ព្រាហ្មណ៍ជ្រះថ្លាហើយ ។ លំដាប់នោះ គាត់ចូលទៅរកព្រះថេរៈនោះ ថ្វាយបង្គំហើយ ធ្វើបដិសណ្ឋារៈនិមន្តឲ្យគង់ខាងក្នុងផ្ទះ កាន់ថាសដែលពេញដោយបាយាស កៀរទម្លាក់ទៅក្នុងបាត្រព្រះថេរៈ ។ ព្រះថេរៈទទួលពាក់កណ្តាលហើយ យកដៃបិទបាត្រ ។ ពេលនោះ ព្រាហ្មណ៍ពោលនឹងព្រះថេរៈនោះថា បពិត្រលោកម្ចាស់ បាយាសនេះ ត្រឹមតែជាចំណែករបស់បុគ្គលម្នាក់ប៉ុណ្ណោះ សូមលោកម្ចាស់ធ្វើសេចក្តីសង្គ្រោះក្នុងបរលោកដល់ខ្ញុំចុះ កុំធ្វើសេចក្តីសង្គ្រោះក្នុងលោកនេះឡើយ ខ្ញុំប្រាថ្នាប្រគេន មិនឲ្យសេសសល់ឡើយ ដូច្នេះហើយ ទើបដាក់ទាំងអស់ ។ ព្រះថេរៈឆាន់ក្នុងទីនោះឯង ។ កាលក្នុងវេលាស្រេចភត្តកិច្ច គាត់ថ្វាយសំពត់សាដកនោះដល់ព្រះថេរៈនោះ ថ្វាយបង្គំហើយ ពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ ខ្ញុំគប្បីសម្រេចធម៌ដែលលោកម្ចាស់ឃើញហើយដូចគ្នា ។ ព្រះថេរៈធ្វើអនុមោទនាដល់ព្រាហ្មណ៍នោះថា ចូរសម្រេចយ៉ាងនោះចុះ ក្រោកឡើងចាកអាសនៈចៀសទៅ ត្រាច់ចារិកដោយលំដាប់ ដល់វត្តជេតពនហើយ ។

ទានដែលបុគ្គលឲ្យហើយ ក្នុងគ្រាដែលក្រីក្រ រមែងញុំាងអ្នកឲ្យ ឲ្យត្រេកអរក្រៃលែង ព្រោះដូច្នោះព្រាហ្មណ៍ថ្វាយទាននោះហើយ មានចិត្តជ្រះថ្លាកើតសោមនស្សហើយ បានធ្វើសេចក្តីស្រឡាញ់ក្រៃលែងក្នុងព្រះថេរៈ ដោយ

ការស្រឡាញ់ក្នុងព្រះថេរៈនោះឯង ព្រាហ្មណ៍នោះធ្វើកាលកិរិយាហើយ បដិសន្ធិក្នុងត្រកូលឧបដ្ឋាករបស់ព្រះថេរៈ ក្នុងក្រុងសាវត្ថី ។ ក្នុងខណៈនោះឯង មាតារបស់ទារកប្រាប់ដល់ប្ដីថា សត្វកើតក្នុងគភ៌របស់ខ្ញុំហើយ ។ ប្ដីនោះបានឲ្យគ្រឿងបរិហារគភ៌ដល់មាតារបស់ទារកនោះហើយ ។ កាលនាងវៀរចាកការបរិភោគអាហារវត្ថុមានរបស់ដែលក្ដៅពេក ត្រជាក់ពេក ជូរពេកជាដើម រក្សាគភ៌ដោយសប្បាយ ការចាញ់គភ៌កើតឡើងបែបនេះថា ធ្វើម្ដេចហ្ន៎ អញគប្បីនិមន្តភិក្ខុ ៥០០ រូប មានព្រះសារីបុត្តត្ថេរជាប្រធាន ឲ្យអង្គុយក្នុងផ្ទះប្រគេនបាយាស លាយដោយទឹកដោះ ខ្លួនឯងស្លៀកកាសាវពស្ត្រ កាន់ផ្ដិលមាសអង្គុយខាងចុងនៃអាសនៈ ហើយបរិភោគបាយាសដែលសល់របស់ភិក្ខុប្រមាណប៉ុណ្ណោះ ។ បានឮថា ការចាញ់គភ៌ចង់ស្លៀកកាសាវពស្ត្ររបស់នាងនោះ បានជាបុព្វនិមិត្តនៃការចេញបព្វជ្ជាក្នុងព្រះពុទ្ធសាសនារបស់កូនក្នុងផ្ទៃ ។ លំដាប់នោះ ពួកញាតិរបស់នាងគិតថា ការចាញ់គភ៌របស់កូនស្រីអញប្រកបដោយធម៌ ដូច្នេះហើយ ទើបប្រគេនបាយាស លាយដោយទឹកដោះសុទ្ធដល់ភិក្ខុ ៥០០ រូប ធ្វើព្រះសារីបុត្តត្ថេរឲ្យជាសង្ឃត្ថេរ សូម្បីនាងក៏ស្លៀកកាសាវពស្ត្រមួយផ្ទាំង ដណ្ដប់មួយផ្ទាំង កាន់ផ្ដិលមាស អង្គុយក្នុងទីបំផុតនៃអាសនៈបរិភោគបាយាស ដែលជាសំណល់របស់ភិក្ខុ ។ ការចាញ់គភ៌របស់នាងស្ងប់ហើយ ក្នុងមង្គលដែលគេធ្វើហើយក្នុងចន្លោះៗ ដល់នាងនោះ អស់កាលសត្វកើតក្នុងគភ៌ រហូតប្រសូតក្ដី មង្គលដែលគេធ្វើដល់នាងប្រសូតបុត្រហើយដោយកន្លងទៅ ១០ ខែក្ដី ពួកញាតិក៏បានថ្វាយមធុបាយាស ដែលមានទឹក

តិចដល់ភិក្ខុប្រមាណ ៥០០ រូប មានព្រះសារីបុត្តត្ថេរជាប្រធានដូចគ្នា ។ បាន ឮថា នេះជាផលនៃបាយាស ដែលទារកប្រគេនហើយ ក្នុងកាលដែលខ្លួនជា ព្រាហ្មណ៍ក្នុងកាលមុន ។ ក្នុងថ្ងៃមង្គលដែលពួកញាតិធ្វើក្នុងថ្ងៃដែលទារកកើត ពួកញាតិឲ្យទារកនោះងូតទឹកអំពីព្រលឹម ប្រដាប់ហើយ ឲ្យដេកលើសំពត់ កម្ពលមានតម្លៃមួយសែន ត្រង់ទីដេកដ៏មានសិរី ។

ទារកនោះដេកលើសំពត់កម្ពលនោះឯង សម្លឹងមើលព្រះថេរៈហើយគិត ថា ព្រះថេរៈនេះជាបុព្វាចារ្យរបស់អញ អញបានសម្បត្តិនេះព្រោះអាស្រ័យ ព្រះថេរៈនេះ ការដែលអញធ្វើការបរិច្ចាគវត្ថុអ្វីមួយដល់លោកគួរ កាលញាតិ នាំទៅដើម្បីប្រយោជន៍ ដល់ការទទួលសិក្ខាបទ បានយកដៃខ្ទាំសំពត់កម្ពល នោះ ។ កាលនោះ ញាតិទាំងឡាយរបស់ទារកនោះគិតថា សំពត់កម្ពលជាប់ ត្រង់ដៃហើយ ប្រាថ្នានឹងយកចេញ ។ ទារកនោះស្រែកយំហើយ ពួកញាតិពោល ថា ចូរពួកអ្នកចៀសចេញចុះ អ្នកទាំងឡាយកុំធ្វើទារកឲ្យយំឡើយ ដូច្នេះ ហើយ ទើបនាំទៅ មួយអន្លើដោយសំពត់នោះឯង ។ ក្នុងពេលថ្វាយបង្គំព្រះ ថេរៈ ទារកនោះលាដៃចេញអំពីសំពត់កម្ពល ឲ្យសំពត់ធ្លាក់ចុះទៀបបាទជើង របស់ព្រះថេរៈ ។ លំដាប់នោះ ពួកញាតិមិនពោលថា កុមារមិនដឹងធ្វើហើយ តែបែរជាពោលថា បពិត្រលោកម្ចាស់ សំពត់ដែលកូនរបស់ខ្ញុំប្រគេនហើយ សូមជាការបរិច្ចាគហើយនោះឯង ដូច្នេះហើយ ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ឲ្យសិក្ខាបទ ដល់ទាសៈរបស់លោកម្ចាស់ ដែលធ្វើការបូជា ដោយសំពត់កម្ពលមានតម្លៃមួយសែននោះឯង ព្រះថេរៈសួរថា ទារកនេះ

ឈ្មោះអ្វី ពួកញាតិប្រាប់ថា ឈ្មោះដូចលោកម្ចាស់នោះឯង ព្រះថេរៈពោលថា ឈ្មោះតិស្សៈឬ ។

បានឮថា ព្រះថេរៈកាលនៅជាគ្រហស្ថ មានឈ្មោះថាឧបតិស្សមាណពសូម្បីម្ដាយរបស់ក្មេងនោះក៏គិតថា អញមិនគួរទម្លាយអធ្យាស្រ័យបុត្រ ។ ពួកញាតិកាលធ្វើមង្គល គឺការដាក់ឈ្មោះដល់ក្មេងយ៉ាងនោះហើយ ក្នុងមង្គល គឺការបរិភោគអាហាររបស់ក្មេងនោះក្ដី ក្នុងមង្គល គឺការបោះត្រចៀករបស់ក្មេងនោះក្ដី ក្នុងមង្គល គឺការស្លៀកសំពត់របស់ក្មេងនោះក្ដី ក្នុងមង្គល គឺការកោរជុករបស់ក្មេងនោះក្ដី បានប្រគេនបាយាសដែលមានទឹកតិចដល់ភិក្ខុប្រមាណ ៥០០ រូប មានព្រះសារីបុត្តត្ថេរជាប្រធាន ។ កុមារចម្រើនវ័យហើយ ពោលនឹងម្ដាយក្នុងកាលមានអាយុ ៧ ឆ្នាំថា បពិត្រអ្នកម៉ែ ខ្ញុំនឹងបួសក្នុងសម្នាក់របស់ព្រះថេរៈ ម្ដាយនោះទទួលថា សាធុកូន កាលមុនម៉ែក៏តាំងចិត្តថា អញមិនគួរទម្លាយអធ្យាស្រ័យរបស់កូន ចូរកូនបួសចុះ ដូច្នេះហើយ ឲ្យមនុស្សនិមន្តព្រះថេរៈមក ថ្វាយភិក្ខាដល់ព្រះថេរៈនោះដែលមកហើយ ពោលថាបពិត្រលោកម្ចាស់ ទាសៈរបស់លោកម្ចាស់ពោលថានឹងបួស ខ្ញុំនឹងនាំទាសៈរបស់លោកម្ចាស់នេះ ទៅកាន់វិហារក្នុងពេលល្ងាច បញ្ជូនព្រះថេរៈទៅហើយក្នុងពេលល្ងាចនាំកូនទៅកាន់វិហារដោយសក្ការៈ និងសម្មានៈជាច្រើន ហើយក៏ប្រគល់ដល់ព្រះថេរៈ ។

ព្រះថេរៈពោលនឹងកុមារនោះថា តិស្សៈ ឈ្មោះថា ការបួសជារបស់ដែលធ្វើបានលំបាក កាលសេចក្ដីត្រូវការដោយរបស់ក្ដៅមាន រមែងបាន

របស់ត្រជាក់ កាលសេចក្តីត្រូវការរបស់ត្រជាក់មាន រមែងបានរបស់ក្តៅ ឈ្មោះថា អ្នកបួសទាំងឡាយ រមែងរស់នៅដោយលំបាក ឯអ្នកសោយសុខមកហើយ តិស្សកុមារពោលថា បពិត្រលោកម្ចាស់ ខ្ញុំអាចធ្វើបានគ្រប់យ៉ាងតាមទំនងដែលលោកម្ចាស់ប្រាប់ហើយ ។

ព្រះថេរៈពោលថា សាធុ ហើយប្រាប់តចបញ្ចកកម្មដ្ឋានដោយអំណាចនៃការធ្វើទុកក្នុងចិត្ត ជារបស់បដិកូលដល់កុមារនោះ ឲ្យកុមារបួសហើយ ។ ពិតហើយ ការដែលភិក្ខុប្រាប់អាការ ៣២ ទាំងអស់គួរពិត កាលមិនអាចប្រាប់បានទាំងអស់ គប្បីប្រាប់តចបញ្ចកកម្មដ្ឋានក៏បាន ព្រោះថា កម្មដ្ឋាននេះ ព្រះពុទ្ធគ្រប់អង្គទ្រង់មិនលះដោយពិត ការកំណត់ភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ដែលសម្រេចអរហត្ត ក្នុងបណ្តាអាការទាំងឡាយ មានសក់ជាដើម ចំណែកនីមួយៗ រមែងមិនមាន ។ ភិក្ខុទាំងឡាយដែលមិនឈ្លាសកាលញុំាងកូនឲ្យបួស រមែងញុំាងឧបនិស្ស័យនៃអរហត្តឲ្យវិនាស ព្រោះហេតុនោះ ព្រះថេរៈប្រាប់កម្មដ្ឋានហើយ ទើបឲ្យបួស ឲ្យតាំងនៅក្នុងសីល ១០ ។ មាតាបិតាធ្វើសក្ការៈដល់បុត្រដែលបួសហើយ បានថ្វាយមធុបាយាស ដែលមានទឹកតិចប៉ុណ្ណោះដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ក្នុងវិហារនោះឯងអស់ ៧ ថ្ងៃ ។ ចំណែកភិក្ខុទាំងឡាយពោលទោសថា យើងទាំងឡាយមិនអាចឆាន់មធុបាយាស មានទឹកតិចជានិច្ចបាន ។ មាតាបិតារបស់សាមណេរនោះ បានទៅកាន់ផ្ទះក្នុងពេលល្ងាច ក្នុងថ្ងៃទី ៧ ។ ក្នុងថ្ងៃទី ៨ សាមណេរទៅបិណ្ឌបាតជាមួយភិក្ខុទាំងឡាយ ។

អ្នកក្រុងសាវត្ថីពោលថា បានឮថា សាមណេរចូលទៅបិណ្ឌបាតក្នុងថ្ងៃនេះ ពួកយើងនឹងធ្វើសក្ការៈដល់សាមណេរនោះ ដូច្នេះហើយ ទើបធ្វើឈ្នួតក្បាលដោយសំពត់សាដកប្រមាណ ៥០០ ផ្ទាំង ចាត់ចែងបិណ្ឌបាតប្រមាណ ៥០០ សម្រាប់ បានកាន់ទៅឈរស្ទាក់ផ្លូវប្រគេនហើយ ។ ក្នុងថ្ងៃស្អែកឡើង បានមកកាន់ព្រៃក្បែរវិហារ ប្រគេនហើយ ។ សាមណេរបានបិណ្ឌបាតមួយពាន់ សំពត់សាដកមួយពាន់ផ្ទាំងក្នុង ២ ថ្ងៃប៉ុណ្ណោះ ដោយអាការយ៉ាងនេះ បានឲ្យមនុស្សប្រគេនដល់ភិក្ខុសង្ឃហើយ ។ បានឮថា នុ៎ះជាផលនៃសំពត់សាដកសាច់គ្រោតគ្រាត ដែលសាមណេរប្រគេនហើយ ក្នុងកាលនៅជាព្រាហ្មណ៍ ។ លំដាប់នោះ ភិក្ខុទាំងឡាយដាក់ឈ្មោះឲ្យសាមណេរនោះថា បិណ្ឌបាតទាយកតិស្សៈ ។ ថ្ងៃមួយ ក្នុងរដូវរងា សាមណេរត្រាច់ចារិកទៅក្នុងវិហារ ឃើញភិក្ខុទាំងឡាយអាំងភ្លើងក្នុងរោងភ្លើងជាដើមក្នុងទីនោះៗ ទើបសាកសួរថា បពិត្រលោកម្ចាស់ ហេតុអ្វី ទើបលោកម្ចាស់អង្គុយអាំងភ្លើង ។

ពួកភិក្ខុពោលថា នែសាមណេរ រងាបៀតបៀនពួកយើង សាមណេរពោលថា បពិត្រលោកម្ចាស់ ធម្មតារដូវរងា លោកម្ចាស់ទាំងឡាយ គួរដណ្តប់សំពត់កម្ពល ព្រោះសំពត់កម្ពលនោះ អាចការពាររងាបាន ។

ពួកភិក្ខុពោលថា សាមណេរ ខ្លួនអ្នកមានបុណ្យច្រើន គប្បីបានសំពត់កម្ពល ពួកយើងនឹងបានសំពត់កម្ពលអំពីទីណា សាមណេរពោលថា បពិត្រលោកម្ចាស់ បើដូច្នោះ សូមលោកម្ចាស់ទាំងឡាយដែលត្រូវការសំពត់កម្ពលមកតាមខ្ញុំចុះ ហើយឲ្យប្រាប់ដល់ភិក្ខុក្នុងវិហារទាំងអស់ ។ ភិក្ខុទាំងឡាយគិត

ថា ពួកយើងនឹងទៅជាមួយសាមណេរ ហើយនាំសំពត់កម្ពលមក អាស្រ័យសាមណេរដែលមានអាយុ ៧ ឆ្នាំ ចេញទៅហើយប្រមាណមួយពាន់រូប ។ សាមណេរនោះ មិនឲ្យចិត្តកើតឡើងថា អញនឹងបានសំពត់អំពីណាដើម្បីភិក្ខុប្រមាណប៉ុណ្ណេះ ។ ពួកភិក្ខុទាំងនោះ បែរមុខទៅកាន់ព្រះនគរហើយ មែនពិតទានដែលបុគ្គលឲ្យល្អហើយ រមែងមានអានុភាពបែបនេះ ។ សាមណេរនោះត្រាច់ទៅតាមលំដាប់ផ្ទះ ខាងក្រៅព្រះនគរប៉ុណ្ណោះ បានសំពត់កម្ពលប្រមាណ ៥០០ ហើយនាំចូលទៅខាងក្នុងព្រះនគរ ។ ពួកមនុស្សនាំសំពត់កម្ពលមកអំពីនោះទីនេះ ។ ចំណែកបុរសម្នាក់ដើរទៅតាមផ្លូវក្នុងផ្សារ ឃើញអ្នកលក់សំពត់ម្នាក់អង្គុយអង្អែលសំពត់ ៥០០ ផ្ទាំង ទើបពោលថា នែអ្នក សាមណេរមួយរូបកំពុងប្រមូលសំពត់កម្ពល ចូរអ្នកលាក់សំពត់កម្ពលរបស់អ្នកសិនចុះ អ្នកផ្សារពោលថា សាមណេរនោះកាន់យកតែសំពត់ដែលគេឲ្យហើយ ឬកាន់យកសំពត់ដែលគេមិនបានឲ្យ បុរសនោះពោលថា កាន់យកសំពត់ដែលគេឲ្យហើយ ។ អ្នកផ្សារពោលថា បើដូច្នោះ បើយើងចង់ឲ្យ យើងនឹងឲ្យ បើយើងមិនចង់ឲ្យ ក៏មិនឲ្យចូរអ្នកទៅចុះ ដូច្នេះហើយ ក៏បញ្ជូនទៅ ។

មែនពិត ពួកមនុស្សកំណាញ់ ដែលជាអន្ធពាល កាលជនដទៃឲ្យទានយ៉ាងនេះ ក៏កំណាញ់ហើយ ទើបកើតក្នុងនរក ដូចកាឡអមាត្យឃើញអសទិសទានហើយ កំណាញ់ដូច្នោះ ។ អ្នកលក់គិតថា បុរសនេះមកដោយធម្មតារបស់ខ្លួនពោលនឹងអញថា ចូរលាក់សំពត់កម្ពលរបស់អ្នក អញក៏បានពោលថា សាមណេរនោះ កាន់យកវត្ថុដែលគេឲ្យ បើអញប្រាប្ថា អញនឹងឲ្យរបស់

អញ បើមិនប្រាថ្នា អញក៏មិនឲ្យ កាលអញមិនឲ្យរបស់ដែលសាមណេរឃើញហើយ ការខ្មាសរមែងកើតឡើង បើអញលាក់របស់ខ្លួន រមែងមិនមានទោស បណ្ដាសំពត់កម្ពល ៥០០ នេះ សំពត់កម្ពលពីរផ្ទាំង មានតម្លៃរាប់សែន ការលាក់សំពត់ពីរផ្ទាំងនេះគួរ ដូច្នេះហើយ ទើបបង់សំពត់កម្ពលទាំងពីរផ្ទាំង ធ្វើឲ្យជាជាយដោយជាយ គឺចងភ្ជាប់គ្នា លាក់ក្នុងរវាងសំពត់ទាំងនោះ ។ សាមណេរដល់បទេសនោះ មួយអន្លើដោយភិក្ខុមួយពាន់ ។ ព្រោះឃើញសាមណេរប៉ុណ្ណោះ សេចក្ដីស្រឡាញ់ប្រៀបដូចកូនកើតឡើងដល់អ្នកនោះ សរីរៈទាំងមូលបានពេញហើយដោយសេចក្ដីស្រឡាញ់ គិតថា សំពត់កម្ពលទាំងឡាយ ចូរស្ទេះទុកសិនចុះ អញឃើញសាមណេរនេះហើយ ទោះបីឲ្យបេះដូង ក៏គួរ ។ អ្នកផ្សារនោះ នាំសំពត់ទាំងពីរផ្ទាំងនោះ ចេញមកដាក់ទៀបបាទារបស់សាមណេរ ថ្វាយបង្គំហើយពោលថា បពិត្រលោកម្ចាស់ ខ្ញុំគប្បីមានចំណែកនៃធម៌ដែលលោកម្ចាស់ឃើញហើយ សាមណេរនោះអនុមោទនាថា ចូរសម្រេចយ៉ាងនោះចុះ ។ សាមណេរបានសំពត់កម្ពល ៥០០ ខាងក្នុងព្រះនគរ ក្នុងមួយថ្ងៃប៉ុណ្ណោះ បានសំពត់កម្ពលមួយពាន់ប្រគេនដល់ភិក្ខុមួយពាន់រូប ដោយប្រការដូច្នេះ ។ គ្រានោះ ភិក្ខុទាំងឡាយដាក់ឈ្មោះសាមណេរនោះថា កម្ពលទាយកតិស្សៈ ។ សំពត់កម្ពលដែលសាមណេរប្រគេនក្នុងថ្ងៃដាក់ឈ្មោះ ដល់នូវភាពជាសំពត់កម្ពលមួយពាន់ ក្នុងកាលខ្លួនមានអាយុ ៧ ឆ្នាំ ដោយប្រការដូច្នេះ ។

របស់តិចតួចដែលបុគ្គលឲ្យហើយ ក្នុងឋានៈណា រមែងមានផលច្រើន

របស់ច្រើនបុគ្គលឲ្យហើយក្នុងឋានៈណា រមែងមានផលច្រើនជាង ឋានៈដទៃនោះ វៀរព្រះពុទ្ធសាសនាចេញ រមែងមិនមាន ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ របស់តិចដែលបុគ្គលឲ្យហើយក្នុងពួកភិក្ខុបែបណាមានផលច្រើន របស់ច្រើនដែលបុគ្គលឲ្យហើយ ក្នុងភិក្ខុពួកណាមានផលច្រើនជាង ភិក្ខុទាំងនេះក៏ដូច្នោះ ។ សូម្បីសាមណេរមានអាយុ ៧ ឆ្នាំ បានសំពត់កម្ពលមួយពាន់ដោយផលនៃសំពត់កម្ពលមួយផ្ទាំង ដោយប្រការដូច្នេះ ។

កាលសាមណេរនោះនៅក្នុងវត្តជេតពន ពួកក្មេងដែលជាញាតិមកកាន់សម្នាក់ ពោលចរចាប្រាស្រ័យរឿយៗ ។ សាមណេរនោះគិតថា កាលអញនៅក្នុងទីនេះ កាលក្មេងដែលជាញាតិមកពោល មិនអាចមិនពោលបាន ដោយការយឺតយូរ គឺការសន្ទនាជាមួយក្មេងទាំងនេះ អញមិនអាចធ្វើទីពឹងដល់ខ្លួន បើដូច្នេះ អញនឹងរៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តាហើយ គប្បីចូលព្រៃ ។

តិស្សសាមណេរនោះ ចូលគាល់ព្រះសាស្តា ថ្វាយបង្គំហើយ ទូលសូមឲ្យព្រះសាស្តាត្រាស់ប្រាប់កម្មដ្ឋានអំពីអរហត្ត ថ្វាយបង្គំឧបជ្ឈាយ៍ហើយ កាន់បាត្រ និងចីវរចេញទៅអំពីវិហារហើយគិតថា បើអញនៅក្នុងទីជិតសោត ពួកញាតិនឹងហៅអញទៅ ទើបបានធ្វើដំណើរអស់ចម្ងាយផ្លូវ ១២០ យោជន៍ ។ គ្រានោះ សាមណេរដើរទៅកាត់តាមភូមិមួយ ឃើញបុរសចំណាស់ម្នាក់ សួរថា ឧបាសក វិហារក្នុងព្រៃរបស់ភិក្ខុទាំងឡាយ ដែលនៅក្នុងប្រទេសនេះមានដែរឬទេ ឧបាសកពោលថា មាន លោកម្ចាស់ សាមណេរសួរថា បើដូច្នោះ

សូមអ្នកជួយប្រាប់ផ្លូវដល់អាត្មាចុះ ។

សេចក្ដីស្រឡាញ់ប្រៀបដូចបុត្រ កើតឡើងដល់ឧបាសក ព្រោះឃើញសាមណេរនោះ ។ លំដាប់នោះ ឧបាសកឈរក្នុងទីនោះឯង មិនប្រាប់ដល់សាមណេរនោះពោលថា និមន្តមកចុះ ខ្ញុំនឹងប្រាប់ដល់លោកម្ចាស់ បាននាំសាមណេរទៅហើយ ។ សាមណេរបានទៅជាមួយឧបាសកចាស់នោះ ឃើញបទេស គឺតំបន់ ៦ កន្លែង ៥ កន្លែង ប្រដាប់ហើយដោយផ្កា និងផ្លែផ្សេងៗ ក្នុងរវាងផ្លូវ ទើបសួរថា បទេសនេះឈ្មោះអ្វី ឧបាសកប្រាប់ឈ្មោះបទេសទាំងនោះដល់សាមណេរ ទៅដល់វិហារដែលតាំងនៅក្នុងព្រៃហើយពោលថា បពិត្រលោកម្ចាស់ ទីនេះជាទីសប្បាយ សូមលោកម្ចាស់នៅក្នុងទីនេះចុះ ហើយសួរឈ្មោះថា លោកម្ចាស់ឈ្មោះអ្វី សាមណេរប្រាប់ថា អាត្មាឈ្មោះវនវាសីតិស្សៈ ទើបពោលថា ស្អែកនេះលោកម្ចាស់គួរទៅបិណ្ឌបាតក្នុងស្រុករបស់ពួកខ្ញុំ ហើយត្រឡប់ទៅកាន់ស្រុករបស់ខ្លួននោះឯង ប្រាប់ដល់ពួកមនុស្សថា សាមណេរឈ្មោះវនវាសីតិស្សៈមកកាន់វិហារហើយ ចូរអ្នកទាំងឡាយចាត់ចែងអាហារវត្ថុ មានយាគូ និងភត្តជាដើម ដើម្បីសាមណេរនោះ ។ គ្រាដំបូងនោះឯងសាមណេរឈ្មោះតិស្សៈ បន្ទាប់ពីនោះ បានឈ្មោះបីទៀត គឺបិណ្ឌបាតទាយកតិស្សៈ កម្ពលទាយកតិស្សៈ វនវាសីតិស្សៈ បានឈ្មោះ ៤ ក្នុងអាយុ ៧ ឆ្នាំ ។ ស្អែកឡើងសាមណេរនោះ ចូលទៅបិណ្ឌបាតកាន់ស្រុកនោះអំពីព្រលឹម ពួកមនុស្សប្រគេនភិក្ខា ថ្វាយបង្គំហើយ ។ សាមណេរពោលថា អ្នកទាំងឡាយចូរដល់នូវសេចក្ដីសុខ ចូរផុតចាកទុក្ខចុះ ។ សូម្បីមនុស្សម្នាក់ថ្វាយភិក្ខាដល់

សាមណេរនោះហើយ ក៏មិនអាចត្រឡប់ទៅកាន់ផ្ទះបាន គ្រប់គ្នាបានឈរមើល សាមណេរនោះក៏ទទួលកត្តលួមញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដើម្បីខ្លួន ។ អ្នកស្រុកទាំងអស់ ក្រាបចុះដោយទ្រូង ទៀបបាទារបស់សាមណេរនោះហើយពោលថា បពិត្រលោកម្ចាស់ កាលលោកម្ចាស់នៅក្នុងទីនេះ អស់ត្រីមាសនេះ ពួកខ្ញុំនឹងទទួលសរណៈ ៣ តាំងនៅក្នុងសីល ៥ ធ្វើឧបាសថកម្ម ៨ ដង ក្នុងមួយខែ សូមលោកម្ចាស់ឲ្យប្ដេជ្ញាដល់យើងខ្ញុំទាំងឡាយ ដើម្បីជាប្រយោជន៍នៃការនៅក្នុងទីនេះ ។ សាមណេរនោះកំណត់ឧបការៈ ទើបឲ្យប្ដេជ្ញាដល់មនុស្សប៉ុណ្ណោះ ត្រាច់បិណ្ឌបាតក្នុងស្រុកនោះឯងជាប្រចាំ ។ ក្នុងខណៈដែលគេថ្វាយបង្គំហើយ ពោលចំពោះពីរបទថា ចូរអ្នកទាំងឡាយ ដល់នូវសេចក្ដីសុខ ចូរផុតចាកទុក្ខចុះ ដូច្នេះហើយ ចៀសចេញទៅ ។ សាមណេរនោះឲ្យខែទីមួយ និងខែទីពីរកន្លងទៅហើយ ក្នុងទីនោះ កាលខែទីបីកន្លងទៅក៏សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា ។

កាលបវារណាចេញវស្សាហើយ ឧបជ្ឈាយ៍របស់សាមណេរនោះ ចូលគាល់ព្រះសាស្ដា ថ្វាយបង្គំហើយក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងទៅកាន់សម្នាក់តិស្សសាមណេរ ព្រះសាស្ដាត្រាស់ថា ម្នាលសារីបុត្ត ចូរអ្នកទៅចុះ ព្រះសារីបុត្តត្ថេរនោះ កាលនាំភិក្ខុប្រមាណ ៥០០ រូប ដែលជាបរិវារជនរបស់ខ្លួនចៀសចេញទៅពោលថា អាវុសោមោគ្គល្លាន ខ្ញុំនឹងទៅកាន់សម្នាក់តិស្សសាមណេរ ព្រះមហាមោគ្គល្លានត្ថេរពោលថា អាវុសោ ខ្ញុំក៏ទៅដែរ ដូច្នេះហើយ ចេញទៅព្រមជាមួយភិក្ខុប្រមាណ ៥០០ រូប ។ ព្រះមហាសាវកទាំង

ពួន គឺព្រះមហាកស្សបត្ថេរ ព្រះអនុរុទ្ធត្ថេរ ព្រះឧបាលិត្ថេរ ព្រះបុណ្ណត្ថេរជាដើម ចេញទៅមួយអន្លើដោយភិក្ខុប្រមាណមួយអង្គ ៥០០ រូប ។ ដោយឧបាយនោះឯង បរិវាររបស់សាវកទាំងអស់បានជាភិក្ខុប្រមាណ ៤ ម៉ឺនរូប ។ ឧបាសកដែលទំនុកបម្រុងសាមណេរជាប្រចាំ ឃើញភិក្ខុទាំងនោះធ្វើដំណើរប្រមាណ ១២០ យោជន៍ ដល់គោចរគាមហើយក្នុងទ្វារស្រុកនោះឯង ថ្វាយបង្គំហើយ ។ លំដាប់នោះ ព្រះសារីបុត្តត្ថេរសួរឧបាសកនោះថា ឧបាសក វិហារតាំងនៅក្នុងព្រៃ ក្នុងប្រទេសនេះមានឬ ។

ឧបាសកពោលថា មាន លោកម្ចាស់ ព្រះថេរៈសួរថា តើភិក្ខុមានឬទេ ឧបាសកឆ្លើយថា មាន លោកម្ចាស់ ព្រះថេរៈសួរថា អ្នកណានៅក្នុងទីនោះ ឧបាសកឆ្លើយថា វនវាសីតិស្សសាមណេរ លោកម្ចាស់ ព្រះថេរៈពោលថា បើដូច្នេះ ចូរពួកអ្នកប្រាប់ផ្លូវដល់ពួកអាត្មា ឧបាសកសួរថា លោកម្ចាស់ជាភិក្ខុពួកណា ព្រះថេរៈប្រាប់ថា ពួកអាត្មាមកកាន់សម្នាក់របស់សាមណេរ ។

ឧបាសកសម្លឹងមើលភិក្ខុទាំងនោះ ចាំព្រះមហាសាវកទាំងអស់បាន តាំងអំពីព្រះធម្មសេនាបតីជាដើម ។ អ្នកស្រុកទាំងនោះមានសរីរៈដែលបីតិពាល់ត្រូវហើយ មិនមានចន្លោះពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់បង្អង់សិន ហើយចូលទៅកាន់ស្រុកដោយរហ័សប្រកាសថា ព្រះអសីតិមហាសាវកទាំងឡាយ មានព្រះសារីបុត្តជាដើមមកកាន់សម្នាក់របស់សាមណេរ មួយអន្លើដោយបរិវាររៀងៗខ្លួន អ្នកទាំងឡាយ ចូរកាន់យកគ្រឿងប្រើប្រាស់ មាន

ត្រៃ តាំង កម្រាល ប្រទីប និងប្រេងជាដើម ចេញទៅដោយរហ័សចុះ ។ វេលានោះឯង ពួកមនុស្សជញ្ជូនគ្រៃជាដើម ធ្វើដំណើរតាមស្នាមជើងព្រះថេរៈទៅ ចូលទៅកាន់វិហារ មួយអន្លើដោយព្រះថេរៈនោះឯង ។ សាមណេរចាំកិច្ចបាន ទទួលបាត្រ និងចីវរព្រះមហាថេរៈ ២-៣ អង្គហើយ បានធ្វើវត្ត ។ កាលសាមណេរនោះចាត់ចែងលំនៅដើម្បីព្រះថេរៈទាំងឡាយ ទុកបាត្រ និងចីវរនោះឯង ក៏យប់ងងឹតល្មម ។ ព្រះសារីបុត្តត្ថេរពោលនឹងពួកឧបាសកថា ឧបាសកទាំងឡាយ ពួកអ្នកទៅចុះ ការងងឹត កើតដល់ពួកអ្នក ។

ពួកឧបាសកពោលថា បពិត្រលោកម្ចាស់ ថ្ងៃនេះជាថ្ងៃស្តាប់ធម៌ ពួកខ្ញុំមិនទៅឡើយ នឹងស្តាប់ធម៌ ក្នុងកាលមុនអំពីនេះ សូម្បីការស្តាប់ធម៌ក៏មិនមានដល់យើងខ្ញុំទាំងឡាយ ។ ព្រះថេរៈពោលថា សាមណេរ បើដូច្នេះ ចូរអ្នកអុជប្រទីប ប្រកាសកាលស្តាប់ធម៌ចុះ សាមណេរបានធ្វើយ៉ាងនោះហើយ ។

លំដាប់នោះ ព្រះថេរៈពោលនឹងសាមណេរថា តិស្សៈ ពួកឧបដ្ឋាករបស់អ្នកពោលថា ពួកខ្ញុំទាំងឡាយប្រាថ្នានឹងស្តាប់ធម៌ ចូរអ្នកពោលធម៌ដល់ឧបដ្ឋាកទាំងនោះ ។ ពួកឧបាសកក្រោកឡើងព្រមគ្នានោះឯងពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់របស់ពួកខ្ញុំទាំងឡាយចេះតែ ២ បទ គឺចូរអ្នកទាំងឡាយមានសេចក្តីសុខ ចូរផុតចាកទុក្ខចុះ មិនចេះធម្មកថាដទៃឡើយ សូមលោកម្ចាស់ទាំងឡាយឲ្យធម្មកថឹកដទៃដល់ពួកខ្ញុំចុះ ។ ឯសាមណេរ ទោះបីសម្រេចអរហត្តហើយ ក៏មិនបានពោលធម្មកថាដល់ឧបដ្ឋាកទាំងនោះឡើយ ។

ក្នុងកាលនោះ ព្រះឧបជ្ឈាយ៍ពោលនឹងសាមណេរនោះថា នែសាមណេរ

មនុស្សទាំងឡាយ នឹងមានសេចក្តីសុខបានដូចម្តេច នឹងផុតចាកទុក្ខបានដូចម្តេច ចូរអ្នកពោលអត្ថនៃបទទាំងពីរនេះដល់យើងទាំងឡាយ សាមណេរនោះទទួលថា សាធុ ហើយកាន់យកផ្លិតដ៏វិចិត្រ ឡើងកាន់ធម្មាសនៈ ទាយយកផល និងហេតុមកអំពីនិកាយទាំង ៥ បែកខន្ធ ធាតុ អាយតនៈ និងពោធិបក្ខិយធម៌ ដូចមហាមេឃតាំងឡើងក្នុងទ្វីបទាំង ៤ ញាំងភ្លៀងបោក្ខរពស្សឲ្យធ្លាក់ចុះ ពោលធម្មកថាដោយកំពូល គឺអរហត្ត ហើយពោលថា អ្នកទាំងឡាយសេចក្តីសុខ មានដល់បុគ្គលដែលសម្រេចអរហត្តយ៉ាងនេះ បុគ្គលសម្រេចអរហត្តហើយនោះឯង រមែងផុតចាកទុក្ខ មនុស្សដ៏សេសមិនផុតចាកជាតិទុក្ខជាដើមឡើយ នឹងផុតចាកទុក្ខក្នុងនរកជាដើមបានឡើយ ព្រះថេរៈពោលថា សាធុ សាមណេរ ការពោលដោយបទ អ្នកពោលល្អហើយ ឥឡូវនេះ ចូរពោលសរភញ្ញចុះ ។ សាមណេរនោះ ពោលសរភញ្ញហើយ ។ កាលថ្ងៃរះឡើង ពួកមនុស្សដែលទំនុកបម្រុងសាមណេរ បែកគ្នាជាពីរពួក ។ ពួកខ្លះក្រោធថា ក្នុងកាលមុន ពួកយើងមិនធ្លាប់ជួបមនុស្សអាក្រក់បែបនេះ ហេតុអ្វីសាមណេរចេះធម្មកថាដល់ម៉្លេះ មិនពោលបទធម៌សូម្បីតែមួយបទ ដល់ពួកមនុស្សដែលតាំងនៅក្នុងឋានៈដូចមាតាបិតា ហើយឧបដ្ឋាកអស់កាលមានប្រមាណប៉ុណ្ណោះ ។ ពួកខ្លះត្រេកអរថា ជាលាភរបស់ពួកយើងហ្ន៎ បុគ្គលមិនដឹងគុណ ឬទោស ទំនុកបម្រុងលោកម្ចាស់បែបនេះ តែឥឡូវនេះ ពួកយើងបានស្តាប់ធម៌ក្នុងសម្នាក់របស់លោកដ៏ចម្រើននោះ ។ ក្នុងវេលាជិតភ្លឺថ្ងៃនោះ ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រមើលមើលលោក ទ្រង់ឃើញពួកឧបដ្ឋាករបស់

វនវាសីតិស្សសាមណេរ ចូលទៅខាងក្នុងសំណាញ់ គឺព្រះញាណរបស់ព្រះអង្គ ទ្រង់ពិចារណាថា ហេតុអ្វីនឹងមានហ្ន៎ ទ្រង់ពិចារណាអត្ថនេះថា ពួកឧបដ្ឋាករបស់វនវាសីតិស្សសាមណេរ ពួកខ្លះ ក្រោធ ពួកខ្លះ ត្រេកអរ ពួកដែលក្រោធសាមេណរ ដែលជាបុត្រតថាគតនឹងទៅកាន់នរក តថាគតគួរទៅក្នុងទីនោះចុះ កាលតថាគតទៅ មនុស្សទាំងអស់ នឹងធ្វើមេត្តាចិត្តក្នុងសាមណេរ ហើយផុតចាកទុក្ខ ។ មនុស្សទាំងនោះ និមន្តភិក្ខុសង្ឃហើយក៏ទៅកាន់ស្រុក ឲ្យមនុស្សធ្វើមណ្ឌប រៀបចំអាហារវត្ថុ មានបបរ និងភត្តជាដើម ក្រាលអាសនៈហើយ អង្គុយទន្ទឹងការមករបស់ភិក្ខុសង្ឃ ។ ភិក្ខុទាំងឡាយធ្វើការជម្រះសរីរៈហើយ ចូលទៅកាន់ស្រុក ក្នុងវេលាត្រាច់ភិក្ខា ទើបសួរសាមណេរថា តិស្សៈ អ្នកទៅជាមួយពួកយើង ឬទៅឯក្រោយ សាមណេរពោលថា ខ្ញុំនឹងទៅក្នុងកាលតាមដែលខ្ញុំធ្លាប់ទៅ សូមលោកម្ចាស់ទាំងឡាយ និមន្តទៅចុះ ។ ភិក្ខុទាំងឡាយកាន់បាត្រ និងចីវរចូលទៅហើយ ។

ព្រះសាស្តា ទ្រង់ដណ្តប់ចីវរក្នុងវត្តជេតពននោះឯង ហើយទ្រង់កាន់បាត្រយាងទៅដោយខណៈចិត្តមួយប៉ុណ្ណោះ ទ្រង់សម្តែងព្រះកាយ ប្រថាប់ឈរខាងមុខភិក្ខុទាំងឡាយនោះឯង ។ អ្នកស្រុកទាំងមូល បានត្រេកអរជួចគ្នាថា ព្រះសម្មាសម្ពុទ្ធយាងមក ។ ពួកមនុស្សត្រេកអរ និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានឲ្យគង់ហើយ ថ្វាយបបរ ថ្វាយរបស់ទំពាហើយ ។ កាលភត្តមិនទាន់សម្រេចនោះឯង ។ សាមណេរចូលទៅខាងក្នុងស្រុកហើយ ។ អ្នកស្រុកបាននាំចេញទៅប្រគេនភិក្ខាដល់សាមណេរដោយគោរព សាមណេរនោះទទួលភិក្ខា

ត្រឹមតែញុំាងអត្តភាពឲ្យប្រព្រឹត្តទៅហើយ ទៅកាន់សម្នាក់ព្រះសាស្តា បង្អោន បាត្រចូលទៅហើយ ។ ព្រះសាស្តាត្រាស់ថា នាំមកចុះតិស្សៈ ហើយទ្រង់លា ព្រះហស្តទទួលបាត្រ ទ្រង់សម្តែងដល់ព្រះថេរៈថា សារីបុត្ត ចូរមើលបាត្រ សាមណេររបស់អ្នក ។ ព្រះថេរៈទទួលបាត្រអំពីព្រះហស្តរបស់ព្រះសាស្តា ឲ្យដល់សាមណេរហើយពោលថា ចូរទៅធ្វើភត្តកិច្ចក្នុងទីដែលសមគួរដល់ ខ្លួន ។ អ្នកស្រុកអង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយទូលសូម អនុមោទនានឹងព្រះសាស្តា ។ ព្រះសាស្តា កាលទ្រង់ធ្វើអនុមោទនា ទើប ត្រាស់ពាក្យយ៉ាងនេះថា ឧបាសក និងឧបាសិកាទាំងឡាយ ជាលាភរបស់ អ្នកទាំងឡាយ ដែលបានឃើញអសីតិមហាសាវ័ក គឺសារីបុត្ត មោគ្គល្លាន កស្សបៈជាដើម ព្រោះអាស្រ័យសាមណេរចូលដល់ត្រកូល រៀងៗ ខ្លួន សូម្បី តថាគតក៏មកហើយ ព្រោះអាស្រ័យសាមណេរ ដែលចូលដល់ត្រកូលរបស់ អ្នកទាំងឡាយដូចគ្នា ការឃើញតថាគត ដែលអ្នកទាំងឡាយបានហើយ ព្រោះ អាស្រ័យសាមណេរនេះឯង ជាលាភរបស់អ្នកទាំងឡាយ អ្នកទាំងឡាយ បានល្អហើយ ។ មនុស្សទាំងឡាយគិតថា គួរត្រេកអរហ្ន៎ ជាលាភរបស់ពួក យើង ពួកយើងបានឃើញលោកម្ចាស់របស់ពួកយើង ដែលក្នុងការញុំាង ព្រះពុទ្ធ និងភិក្ខុសង្ឃឲ្យប្រោសប្រាណ រមែងបានថ្វាយទេយ្យធម៌ដល់លោក ម្ចាស់នោះ ។ ពួកមនុស្សដែលក្រោធនឹងសាមណេរ ក៏ត្រេកអរហើយ ។ ពួក ដែលត្រេកអរហើយរឹងរឹតតែជ្រះថ្លាក្រៃលែង ។ ក្នុងកាលចប់អនុមោទនា ជន ជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ ព្រះ

សាស្តាទ្រង់ក្រោកចាកអាសនៈយាងទៅហើយ ។ ពួកមនុស្សទាំងឡាយតាមជូនដំណើរព្រះសាស្តា ថ្វាយបង្គំហើយត្រឡប់ ។ ព្រះសាស្តាយាងទៅដោយព្រះធុរៈដ៏ស្មើជាមួយសាមណេរ ត្រាស់សួរបទេសដែលឧបាសកប្រាប់ហើយដល់សាមណេរនោះ ក្នុងកាលមុនថា សាមណេរ បទេសនេះ ឈ្មោះអ្វី បទេសនេះ ឈ្មោះអ្វី ដូច្នេះហើយ បានយាងទៅ សាមណេរក៏ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បទេសនេះ ឈ្មោះនេះ បទេសនេះ ឈ្មោះនេះ ។

ព្រះសាស្តា យាងដល់លំនៅរបស់សាមណេរនោះហើយ ទ្រង់ឡើងកាន់កំពូលភ្នំ ។ មហាសមុទ្ររមែងប្រាកដដល់បុគ្គលដែលឈរលើកំពូលភ្នំនោះ ព្រះសាស្តាត្រាស់សួរសាមណេរថា តិស្សៈ អ្នកឈរលើកំពូលភ្នំសម្លឹងមើលខាងនោះ និងខាងនេះ ឃើញអ្វី សាមណេរតបថា បពិត្រព្រះអង្គ ឃើញមហាសមុទ្រ ព្រះសាស្តាត្រាស់ថា ឃើញមហាសមុទ្រហើយ គិតដូចម្តេច សាមណេរតបថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គគិតយ៉ាងនេះថា កាលខ្ញុំព្រះអង្គយំក្នុងកាលដែលដល់នូវសេចក្តីទុក្ខ ទឹកភ្នែកគប្បីច្រើនជាងទឹកក្នុងមហាសមុទ្រទាំង ៤ ព្រះសាស្តាត្រាស់ថា សាធុ សាធុ តិស្សៈ សេចក្តីនេះ យ៉ាងនោះឯង ព្រោះទឹកភ្នែកដែលហូរមក ក្នុងពេលដែលសត្វម្នាក់ៗ ដល់នូវសេចក្តីទុក្ខគប្បីជារបស់ច្រើនជាងទឹកក្នុងមហាសមុទ្រទាំង ៤ ដោយពិត កាលត្រាស់ពាក្យនេះហើយ ទើបត្រាស់ព្រះគាថានេះថា

ទឹកក្នុងមហាសមុទ្រទាំង ៤ តិចតួចទេ ទឹក គឺទឹកភ្នែករបស់នរៈ ដែលសេចក្តីទុក្ខពាល់ត្រូវហើយ យំសោកមានប្រមាណមិនតិចឡើយ ច្រើនជាងទឹក

ក្នុងមហាសមុទ្រទាំង ៤ នោះ សម្លាញ់ ព្រោះហេតុអ្វី ទើបអ្នកប្រមាទ ។

លំដាប់នោះ ព្រះសាស្ដាត្រាស់សួរសាមណេរនោះទៀតថា តិស្សៈ អ្នកនៅក្នុងទីណា សាមណេរតបថា បពិត្រព្រះអង្គ នៅត្រង់ញកភ្នំនេះ ព្រះសាស្ដាត្រាស់ថា កាលនៅទីនេះ អ្នកគិតដូចម្ដេច សាមណេរពោលថា ខ្ញុំព្រះអង្គគិតថា ការកំណត់ទីដាក់ចុះនូវសរីរៈ ដែលអាត្មាអញជាអ្នកស្លាប់ ធ្វើហើយក្នុងទីនេះមិនមាន ព្រះសាស្ដាត្រាស់ថា សាធុ សាធុ តិស្សៈ សេចក្ដីនេះយ៉ាងនោះឯង ព្រោះឈ្មោះថា ទីនៃសត្វទាំងនេះ ដែលមិនធ្លាប់ដេកស្លាប់លើផែនដី មិនមាន ដូច្នេះហើយ ទើបត្រាស់ឧបសាឡ្ហកជាតក ក្នុងទុកនិបាតថា

ពួកញាតិឈ្មោះឧបសាឡ្ហក[1] ចំនួន ១៤០០០ នាក់ គេដុតហើយក្នុងប្រទេសនេះ ក្នុងលោក រកទីដែលមិនមានគេស្លាប់មិនមានឡើយ ។

សច្ចៈ ១ ធម្មៈ ១ អហឹសា ១ សញ្ញមៈ ១ ទមៈ ១ មាននៅក្នុងបុគ្គលណា ព្រះអរិយៈទាំងឡាយ រមែងសេពគប់នូវបុគ្គលនុ៎ះ គុណជាតនុ៎ះ ឈ្មោះថា មិនចេះស្លាប់ ក្នុងលោក ។

កាលសត្វទាំងឡាយ ធ្វើការដាក់ចុះនូវសរីរៈលើផែនដី សត្វទាំងឡាយឈ្មោះថា ស្លាប់ក្នុងបទេសដែលមិនធ្លាប់ស្លាប់ រមែងមិនមាន ដោយប្រការដូច្នេះ ។ ចំណែកព្រះថេរៈទាំងឡាយ ដូចគ្នានឹងព្រះអានន្ទត្ថេរ រមែងបរិនិព្វានក្នុងបទេស ដែលសត្វមិនធ្លាប់ស្លាប់ ។

---

១- គួរប្រែថា ព្រាហ្មណ៍ ឈ្មោះឧបសាឡ្ហក ចំនួន ១៤០០០ នាក់ ត្រូវញាតិដុតហើយក្នុងបទេសនេះ ទើបត្រូ តាមន័យរបស់អដ្ឋកថា ។

បានឮមកថា ព្រះអានន្ទត្ថេរ ពិចារណាអាយុសង្ខារក្នុងកាលដែលមានអាយុ ១២០ ឆ្នាំ ជ្រាបភាពដែលអាយុនោះអស់ដោយជុំវិញ ទើបប្រាប់ថា ខ្ញុំនឹងបរិនិព្វានក្នុងថ្ងៃទី ៧ បន្ទាប់អំពីថ្ងៃនេះ ។ បណ្តាមនុស្សដែលនៅត្រង់ច្រាំងទាំងពីរនៃស្ទឹងរោហិណី ជ្រាបដំណឹងនោះហើយ អ្នកដែលនៅត្រើយអាយពោលថា ពួកយើងជាអ្នកមានឧបការៈច្រើនដល់ព្រះថេរៈ ព្រះថេរៈនឹងបរិនិព្វានក្នុងសម្នាក់របស់ពួកយើង ។ អ្នកដែលនៅត្រើយនាយក៏ពោលថា ពួកយើងមានឧបការៈច្រើនដល់ព្រះថេរៈ ព្រះថេរៈនឹងបរិនិព្វានក្នុងសម្នាក់របស់ពួកយើង ។ ព្រះថេរៈស្តាប់ពាក្យរបស់ជនទាំងនោះហើយ គិតថា ពួកជនដែលនៅត្រង់ច្រាំងទាំងពីរ មានឧបការៈដល់អាត្មាអញទាំងអស់ អាត្មាអញមិនអាចពោលថា ជនទាំងនេះមិនមានឧបការៈ បើអញបរិនិព្វានត្រង់ត្រើយអាយ អ្នកនៅត្រើយនាយ នឹងធ្វើការឈ្លោះជាមួយពួកអ្នកត្រើយអាយ ដើម្បីនឹងកាន់យកធាតុ បើអញបរិនិព្វានត្រង់ត្រើយនាយ អ្នកដែលនៅត្រើយអាយ នឹងធ្វើនូវជម្លោះយ៉ាងនោះ ជម្លោះ កាលនឹងកើតឡើង ក៏កើតអាស្រ័យអាត្មាអញពិត កាលស្ងប់ ក៏នឹងស្ងប់អាស្រ័យអញដូចគ្នា ដូច្នេះហើយ ពោលថា អ្នកនៅត្រើយអាយ មានឧបការៈដល់អាត្មា ឯពួកអ្នកដែលនៅត្រើយនាយក៏មានឧបការៈដល់អាត្មា បុគ្គលណាម្នាក់ ឈ្មោះថា មិនមានឧបការៈមិនមាន អ្នកដែលនៅត្រើយអាយ ចូរប្រជុំគ្នាត្រង់ត្រើយអាយនេះឯង អ្នកដែលនៅត្រើយនាយ ក៏ចូរប្រជុំគ្នាត្រង់ត្រើយនាយនោះឯង ។ ក្នុងថ្ងៃទី ៧ បន្ទាប់អំពីថ្ងៃនោះ ព្រះថេរៈអង្គុយពត់ភ្នែនក្នុងអាកាសប្រមាណ ៧ ជួរដើមត្នោត ត្រង់

ពាក់កណ្តាលស្ទឹង ពោលធម្មកថាដល់មហាជនហើយ អធិដ្ឋានថា ចូរសរីរៈ របស់អាត្មាអញបែកពាក់កណ្តាល មួយចំណែក ចូរធ្លាក់ត្រង់ត្រើយអាយ មួយចំណែក ចូរធ្លាក់ត្រង់ត្រើយនាយ ។ គង់តាមប្រក្រតីនោះឯង ចូលសមាបត្តិ មានតេជោធាតុជាអារម្មណ៍ អណ្តាតភ្លើងតាំងឡើងហើយ សរីរៈបែកហើយត្រង់ពាក់កណ្តាល មួយចំណែកធ្លាក់ត្រង់ត្រើយអាយ មួយចំណែកធ្លាក់ត្រង់ត្រើយនាយ មហាជនស្រែកយំហើយ សំឡេងទ្រហោយំហាក់បីដូចសំឡេងផែនដីស្រុត គួរអាណោចអាធ័ម ជាងសំឡេងទ្រហោយំក្នុងថ្ងៃបរិ-និព្វានខែព្រះសាស្តា ។ ពួកមនុស្សទ្រហោយំអស់កាល ៤ ខែ កន្ទក់កន្ទេញថា កាលព្រះថេរៈទទួលបាត្រចីវររបស់ព្រះសាស្តា ឋិតនៅ បានប្រាកដដល់ពួកយើង ដូចការដែលព្រះសាស្តាគង់ព្រះជន្មនៅ ឥឡូវនេះ ព្រះសាស្តារបស់ពួកយើងបរិនិព្វានហើយ ។

ព្រះសាស្តាត្រាស់សួរសាមណេរទៀតថា តិស្សៈ អ្នកមិនខ្លាច ព្រោះសំឡេងនៃសត្វទាំងឡាយ មានសំឡេងខ្លាដំបងជាដើម ក្នុងព្រៃនេះទេឬ សាមណេរក្រាបទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គមិនខ្លាចទេ ម្យ៉ាងទៀត ឈ្មោះថា ការត្រេកអរក្នុងព្រៃ រមែងកើតឡើងដល់ខ្ញុំព្រះអង្គព្រោះស្តាប់សំឡេងសត្វទាំងនោះ ហើយពោលពណ៌នាព្រៃដោយគាថាប្រមាណ ៦០ ។

គ្រានោះ ព្រះសាស្តាត្រាស់ហៅសាមណេរនោះថា តិស្សៈ សាមណេរតបថា ករុណាព្រះអង្គ ព្រះសាស្តាត្រាស់ថា ពួកយើងនឹងទៅ តើអ្នកទៅ ឬមួយក៏ត្រឡប់ សាមណេរទូលថា បើឧបជ្ឈាយ៍របស់ខ្ញុំព្រះអង្គ នាំខ្ញុំព្រះអង្គ

ទៅ ខ្ញុំព្រះអង្គនឹងទៅ បើឲ្យខ្ញុំព្រះអង្គត្រឡប់ ខ្ញុំព្រះអង្គនឹងត្រឡប់ ។

ព្រះសាស្តា ចៀសចេញទៅជាមួយភិក្ខុសង្ឃ តែអធ្យាស្រ័យរបស់សាមណេរត្រឡប់តែម្យ៉ាង ព្រះថេរៈជ្រាបអធ្យាស្រ័យនោះ ទើបពោលថា តិស្សៈ បើអ្នកប្រាថ្នាត្រឡប់ក៏ត្រឡប់ចុះ សាមណេរថ្វាយបង្គំព្រះសាស្តា និងភិក្ខុសង្ឃ ហើយត្រឡប់ ។ ព្រះសាស្តាទ្រង់យាងទៅកាន់វត្តជេតពនហើយ ។

ការសន្ទនារបស់ភិក្ខុទាំងឡាយ កើតឡើងក្នុងធម្មសភាថា គួរអស្ចារ្យហ្ន៎ តិស្សសាមណេរធ្វើកម្មដែលបុគ្គលធ្វើបានលំបាក ចាប់តាំងអំពីបដិសន្ធិពួកញាតិរបស់លោក បានប្រគេនបាយាសមានទឹកតិចដល់ភិក្ខុប្រមាណ ៥០០ ក្នុងថ្ងៃដែលជាមង្គលអស់វារៈ ៧ ដង ក្នុងកាលបួសហើយ ក៏បានប្រគេនមធុបាយាសមានទឹកតិចដូចគ្នាដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ខាងក្នុងវិហារអស់ ៧ ថ្ងៃ កាលបួសហើយ ក្នុងថ្ងៃទី ៨ ចូលទៅកាន់ស្រុកបានបិណ្ឌបាតមួយពាន់ និងសំពត់សាដកមួយពាន់ក្នុងពេលពីរថ្ងៃប៉ុណ្ណោះ ស្អែកឡើងបានសំពត់កម្ពលមួយពាន់ ក្នុងពេលលោកនៅក្នុងទីនេះ លាភ និងសក្ការៈច្រើនកើតឡើងហើយ ដោយប្រការដូច្នេះ ឥឡូវនេះ លោកលះបង់លាភ និងសក្ការៈបែបនេះចោល ហើយទៅកាន់ព្រៃ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយអាហារដែលលាយគ្នា សាមណេរធ្វើកម្មដែលគេធ្វើបានដោយកម្រហ្ន៎ ។

ព្រះសាស្តា យាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង

ឈ្មោះថា បដិបទាដែលចូលទៅអាស្រ័យលាភនោះដទៃ បដិបទាដែលញ៉ាំងសត្វឲ្យដល់ព្រះនិព្វានដទៃ ។ អបាយ ៤ មានទ្វារបើកហើយនោះឯងតាំងនៅ កាលភិក្ខុរក្សាបដិបទា ចូលទៅអាស្រ័យលាភ ដោយអំណាចនៃការសមាទានធុតង្គ មានការនៅព្រៃជាដើម ដោយបំណងថា អញនឹងបានលាភដោយបដិបត្តិយ៉ាងនេះ ចំណែកភិក្ខុដែលលះលាភ និងសក្ការៈដែលកើតឡើងដោយបដិបទាដែលញ៉ាំងសត្វឲ្យដល់នូវព្រះនិព្វាន ហើយចូលទៅកាន់ព្រៃព្យាយាម រមែងកាន់យកអរហត្តបាន ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់គាថានេះថា

**អញ្ញា ហិ លាភូបនិសា អញ្ញា និព្វានគាមិនី**
**ឯវមេតំ អភិញ្ញាយ ភិក្ខុ ពុទ្ធស្ស សាវកោ**
**សក្ការំ នាភិនន្ទេយ្យ វិវេកមនុព្រូហយេ ។**

បដិបទា អាស្រ័យនូវលាភផ្សេង បដិបទាជាដំណើរទៅកាន់ព្រះនិព្វានផ្សេង ភិក្ខុជាសាវករបស់ព្រះពុទ្ធ ដឹងច្បាស់នូវហេតុនុ៎ះ យ៉ាងនេះហើយ មិនគួរត្រេកអរចំពោះសក្ការៈឡើយ គប្បីញ៉ាំងវិវេកឲ្យចម្រើន ដោយលំដាប់ ។

## សេចក្តីអធិប្បាយ

បណ្តាបទថាទាំងនោះ បាទព្រះគាថាថា **អញ្ញា ហិ លាភូបនិសា** សេចក្តីថា ឈ្មោះថាបដិបទាដែលចូលទៅអាស្រ័យលាភនេះយ៉ាងនេះ បដិបទាដែលញ៉ាំងសត្វឲ្យដល់នូវព្រះនិព្វានដោយឡែក ។ ពិតហើយ ភិក្ខុដែលឲ្យលាភ

កើតឡើង គួរធ្វើអកុសលកម្មតិចតួច ។ ការមិនត្រង់នៃកាយជាដើម លោកគប្បីធ្វើ ព្រោះថា ក្នុងកាលណាភិក្ខុធ្វើការវៀចណាមួយ មានការមិនត្រង់នៃកាយជាដើម ក្នុងកាលនោះ លាភរមែងកើតឡើង ។ កាលភិក្ខុសណ្ដូកដៃចុះត្រង់ៗ ក្នុងថាសដែលគេដាក់បាយាស មិនធ្វើឲ្យងហើយលើកឡើង ដៃគ្រាន់តែប្រឡាក់ប៉ុណ្ណោះ តែកាលសណ្ដូកចុះ ធ្វើឲ្យងហើយលើកឡើង ដៃរមែងប្រមូលដុំបាយាសចេញមកបានពិត លាភសក្ការៈ រមែងកើតឡើងក្នុងគ្រាធ្វើការវៀចវេរដោយកាយជាដើមយ៉ាងនេះ នេះចាត់ជាបដិបទា ដែលចូលទៅអាស្រ័យលាភ មិនប្រពៃតាមធម៌ ។ តែលាភដែលកើតឡើងដោយហេតុបែបនេះ គឺការដល់ព្រមដោយឧបធិ ការទ្រទ្រង់ទុកនូវចីវរ គឺការគ្រងចីវរ ភាពជាពហុស្សូត ការមានបរិវារ ការនៅព្រៃ ឈ្មោះថា ប្រកបដោយធម៌ ភិក្ខុកាលបំពេញបដិបទាដែលញ៉ាំងសត្វឲ្យដល់នូវព្រះនិព្វាន គប្បីលះការវៀចដោយកាយជាដើមចេញ កាលភិក្ខុដែលបំពេញបដិបទា ដែលនាំសត្វឲ្យដល់ព្រះនិព្វាន មិនមែនមនុស្សខ្វាក់ តែធ្វើដូចជាមនុស្សខ្វាក់ មិនមែនមនុស្សគរ តែធ្វើដូចជាមនុស្សគរ មិនមែនមនុស្សថ្លង់ ធ្វើដូចជាមនុស្សថ្លង់ ទើបគួរ ។

បទថា **ឯវមេតំ** ជាដើម សេចក្ដីថា ភិក្ខុឈ្មោះថាជាសាវកព្រោះអត្ថថា កើតក្នុងទីបំផុតនៃការស្ដាប់ ឬព្រោះអត្ថថា ស្ដាប់ឱវាទ និងអនុសាសនីរបស់បុគ្គលឈ្មោះថាពុទ្ធ ព្រោះអត្ថថា ត្រាស់ដឹងសង្ខតធម៌ និងអសង្ខតធម៌ទាំងអស់ ជ្រាបបដិបទាជាគ្រឿងញ៉ាំងលាភឲ្យកើតឡើង និងបដិបទាដែលញ៉ាំងសត្វឲ្យដល់ព្រះនិព្វាននោះយ៉ាងនេះហើយ មិនគប្បីត្រេកអរនឹងសក្ការៈ

គឺបច្ច័យ ៤ ដែលមិនប្រកបដោយធម៌ គឺមិនគប្បីហាមឃាត់សក្ការៈដែលប្រកបដោយធម៌នោះឯង គប្បីចម្រើនវិវេក មានកាយវិវេកជាដើម ។

បណ្តាវិវេកទាំងនោះ ភាពជាបុគ្គលមានកាយម្នាក់ឯង ឈ្មោះថា កាយវិវេក សមាបត្តិ ៨ ឈ្មោះថា ចិត្តវិវេក ព្រះនិព្វាន ឈ្មោះថា ឧបធិវិវេក ។

បណ្តាវិវេកទាំងនោះ កាយវិវេក រមែងបន្ទោបង់នូវការច្រឡូកច្រឡំដោយពួកគណៈ ចិត្តវិវេក រមែងបន្ទោបង់ការត្រាំដោយកិលេស ។ ឧបធិវិវេក រមែងបន្ទោបង់នូវការជាប់ជំពាក់ក្នុងសង្ខារ កាយវិវេក រមែងជាបច្ច័យនៃចិត្តវិវេក ។ ចិត្តវិវេក រមែងជាបច្ច័យនៃឧបធិវិវេក ។ សមដូចពាក្យរបស់ព្រះសារីបុត្តត្ថេរពោលថា កាយវិវេក ( កើតមាន ) ដល់ពួកបុគ្គលដែលចេញចាកពួក ត្រេកអរក្នុងការចេញចាកកាមផង ចិត្តវិវេក ( កើតមាន ) ដល់ពួកបុគ្គលដែលមានចិត្តបរិសុទ្ធ ដល់នូវសេចក្តីផូរផង់ក្រៃលែងផង ឧបធិ-វិវេក ( កើតមាន ) ដល់ពួកបុគ្គលដែលមិនមានកិលេស ដល់នូវព្រះនិព្វានដែលប្រាកចាកសង្ខារផង ។ គប្បីចម្រើន គឺគប្បីកើនឡើង អធិប្បាយថាចូលទៅសម្រេចវិវេក ៣ នេះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

**រឿងវនវាសីតិស្សត្ថេរ ចប់**

**ពាលវគ្គទី ៥ ចប់**

# សុត្តន្តបិដក

## ធម្មបទគាថា បណ្ឌិតវគ្គទី ៦

[ ១៦ ] បុគ្គលគួរឃើញនូវអ្នកប្រាជ្ញណា ដែលជាអ្នកពោលសង្កត់សង្កិន ចង្អុលប្រាប់ទោស ថាដូចជាបុគ្គលអ្នកប្រាប់កំណប់ទ្រព្យឲ្យ ដូច្នោះ គួរគប់អ្នកប្រាជ្ញបែបនោះ ( ព្រោះថា ) កាលបុគ្គលគប់អ្នកប្រាជ្ញបែបនោះហើយ រមែងមានសេចក្តីគាប់ប្រសើរ ឥតមានទោសដ៏លាមកឡើយ ។

បណ្ឌិតគួរទូន្មានប្រៀនប្រដៅ គួរហាមឃាត់នូវជនទាំងឡាយ ចាកអំពើអសប្បុរស បណ្ឌិតនោះ រមែងជាទីស្រឡាញ់របស់សប្បុរសតែម្យ៉ាង មិនជាទីស្រឡាញ់នៃអសប្បុរសឡើយ ។

បុគ្គលមិនគួរគប់មិត្តអាក្រក់ មិនគួរគប់បុរសថោកទាប គួរគប់តែមិត្តដែលល្អ គួរគប់តែបុរសជាន់ខ្ពស់ ។

បណ្ឌិតដែលមានសេចក្តីឆ្អែតក្នុងធម៌ មានចិត្តជ្រះថ្លាហើយ រមែងដេកជាសុខ រមែងត្រេកអរ ក្នុងធម៌ដែលព្រះអរិយៈ ប្រកាសទុកហើយគ្រប់ពេល ។

ធម្មតាអ្នកបង្ហូរទឹក តែងបង្ហូរទឹកទៅ អ្នកធ្វើព្រួញតែងពត់ព្រួញ ( ឲ្យត្រង់ ) អ្នកចាំងឈើ តែងចាំងឈើ ឯបណ្ឌិតទាំងឡាយ តែងទូន្មានខ្លួន ( ដូច្នោះដែរ ) ។

ភ្នំថ្មតាន់មិនរំភើបព្រោះខ្យល់ ដូចម្តេចមិញ បណ្ឌិតទាំងឡាយ ក៏មិនរំភើប ព្រោះពាក្យតិះដៀល និងពាក្យសរសើរ ( ជាដើម ) ដូច្នោះឯង ។

អន្លង់ទឹកដែលជ្រៅ រមែងថ្លា មិនល្អក់យ៉ាងណា បណ្ឌិតទាំងឡាយ បើបានស្តាប់ធម៌ទេសនាហើយ រមែងជ្រះថ្លាស៊ប់សួន យ៉ាងនោះ ។

ពួកសប្បុរស តែងលះ ( ឆន្ទរាគ ) ក្នុងធម៌ទាំងពួង ពួកលោកអ្នកស្ងប់ រមែងមិនរអែរអួរ ព្រោះសេចក្តីប្រាថ្នាក្នុងកាម ពួកបណ្ឌិតបើសេចក្តីសុខ ឬទុក្ខពាល់ត្រូវហើយ រមែងមិនសម្តែងអាការឡើងចុះឡើយ ។

បណ្ឌិតមិនគួរធ្វើអាក្រក់ ព្រោះហេតុនៃខ្លួន មិនគួរធ្វើអាក្រក់ ព្រោះហេតុនៃអ្នកដទៃ មិនគួរប្រាថ្នាកូន មិនគួរប្រាថ្នាទ្រព្យ មិនគួរប្រាថ្នារដ្ឋ មិនគួរប្រាថ្នាសិទ្ធិ ដើម្បីខ្លួនដោយហេតុមិនមែនជាធម៌ឡើយ លោកគួរជាអ្នកមានសីល មានប្រាជ្ញាប្រកបដោយធម៌ ។ បណ្តាមនុស្សទាំងឡាយ ពួកជនណា ដែលឆ្លងដល់ត្រើយ គឺព្រះនិព្វាន ពួកជននោះ មានប្រមាណតិច ចំណែកពួកសត្វក្រៅនេះ រមែងស្ទុះទៅកាន់ត្រើយ ( គឺសក្កាយទិដ្ឋិ ) ។

ជនទាំងឡាយណា ប្រព្រឹត្តតាមធម៌ក្នុងធម៌ ដែលព្រះតថាគត ទ្រង់សម្តែងទុកហើយដោយប្រពៃ ជនទាំងនោះនឹងឆ្លងនូវលំនៅនៃមច្ចុ ដែលមិនងាយឆ្លងបាន ហើយដល់នូវព្រះនិព្វាន ។

បណ្ឌិតគួរលះបង់ធម៌ខ្មៅចេញ ញុំាងធម៌សឲ្យចម្រើនឡើង ( ដោយវិធី ) ចេញចាកអាល័យ គឺកាមគុណ ហើយឈមទៅរកព្រះនិព្វាន ជាធម្ម-ជាតមិនមានអាល័យ គប្បីលះបង់កាមទាំងឡាយចេញ ជាអ្នកមិនមានកង្វល់ ប្រាថ្នានូវសេចក្តីត្រេកអរក្នុងវិវេក ដែលពួកសត្វត្រេកអរបានដោយក្រនោះ បណ្ឌិតគួរញុំាងខ្លួនឲ្យផូរផង់ចាកគ្រឿងសៅហ្មងចិត្ត ។ ចិត្តដែលបណ្ឌិតទាំង-

ឡាយណា បានអប់រំល្អហើយ ក្នុងអង្គនៃធម៌ជាគ្រឿងត្រាស់ដឹងទាំងឡាយ ឬបណ្ឌិតទាំងឡាយណា មិនប្រកាន់មាំ ត្រេកអរតែក្នុងការលះនូវសេចក្ដីប្រកាន់មាំ បណ្ឌិតទាំងឡាយនោះៗ រមែងជាអ្នកអស់អាសវៈ មានសេចក្ដីរុងរឿង បរិនិព្វានក្នុងលោក ។

## បណ្ឌិតវគ្គទី ៦ ចប់

# អដ្ឋកថា
# បណ្ឌិតវគ្គទី ៦

## រឿងព្រះរាធត្ថេរ
### លំនាំដើម

*ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះរាធៈ ត្រាស់ព្រះធម្មទេសនានេះថា* **និធីនំវ បវត្តារំ** *ជាដើម ។*

*បានឮថា ព្រះរាធៈនោះក្នុងកាលជាគ្រហស្ថ បានជាព្រាហ្មណ៍ក្រីក្រនៅក្នុងក្រុងសាវត្ថី ។ គាត់គិតថា អញនឹងចិញ្ចឹមជីវិតនៅក្នុងសម្នាក់របស់ភិក្ខុទាំងឡាយ ដូច្នេះហើយ ទៅកាន់វិហារ ធ្វើការស្មៅ បោសបរិវេណ ប្រគេនវត្ថុមានទឹកលប់មុខជាដើម នៅក្នុងវិហារហើយ ។ ភិក្ខុទាំងឡាយបានសង្គ្រោះហើយក៏ដោយ តែក៏មិនប្រាថ្នាឲ្យគាត់បួស ។ គាត់កាលមិនបានបួស ក៏ស្គមស្គាំងហើយ ។*

*ថ្ងៃក្រោយមក ព្រះសាស្ដាទ្រង់ប្រមើលមើលសត្វលោក ក្នុងពេលទៀបភ្លឺ ទតឃើញព្រាហ្មណ៍នោះហើយ ទ្រង់ពិចារណាថា ហេតុអ្វីហ្ន៎ ដូច្នេះហើយ ទ្រង់ជ្រាបថា រាធព្រាហ្មណ៍នឹងបានជាព្រះអរហន្តក្នុងពេលល្ងាច ទ្រង់យាងចារិកទៅក្នុងវិហារ ចូលកាន់សម្នាក់របស់ព្រាហ្មណ៍ហើយត្រាស់សួរថា ម្នាលព្រាហ្មណ៍ អ្នកធ្វើអ្វី ព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គ*

ធ្វើវត្តបដិបត្តិដល់ភិក្ខុទាំងឡាយ ។ ព្រះសាស្ដាត្រាស់ថា អ្នកបានការសង្គ្រោះអំពីសម្នាក់របស់ភិក្ខុទាំងនោះឬ ព្រាហ្មណ៍នោះតបថា បពិត្រព្រះអង្គ បាន ខ្ញុំព្រះអង្គបានត្រឹមតែអាហារ តែលោកមិនឲ្យខ្ញុំព្រះអង្គបួសសោះ ។

ព្រះសាស្ដា ត្រាស់ឲ្យភិក្ខុសង្ឃប្រជុំគ្នាព្រោះរឿងនោះហើយ ត្រាស់សួរសេចក្ដីនោះហើយ ទើបសួរថា ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយរឭកដល់គុណរបស់ព្រាហ្មណ៍នេះបាន មានដែរឬទេ ព្រះសារីបុត្តត្ថេរក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គរឭកបាន កាលខ្ញុំព្រះអង្គត្រាច់បិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ព្រាហ្មណ៍នេះឲ្យមនុស្សប្រគេនភិក្ខាមួយវែក ដែលគេនាំមកដើម្បីខ្លួន ខ្ញុំព្រះអង្គរឭកដល់គុណរបស់ព្រាហ្មណ៍នេះបាន ។ កាលព្រះសាស្ដាត្រាស់ថា ម្នាលសារីបុត្ត ការដែលអ្នកដោះព្រាហ្មណ៍អ្នកមានឧបការៈ ដែលធ្វើហើយយ៉ាងនេះ ឲ្យចាកផុតទុក្ខមិនគួរទេឬ ព្រះសារីបុត្តក្រាបទូលថា សាធុ ព្រះអង្គ ខ្ញុំព្រះអង្គនឹងឲ្យគាត់បួស ទើបឲ្យព្រាហ្មណ៍បួសហើយ ។

អាសនៈចុងក្រោយ នៃអាសនៈក្នុងរោងឆាន់ រមែងដល់លំដាប់របស់លោក លោកលំបាកដោយការរកវត្ថុ មានបបរ និងភត្តជាដើម ព្រះថេរៈនាំលោកចៀសចេញទៅកាន់ទីចារិកហើយ ឲ្យឱវាទទូន្មានរឿយៗ ថា វត្ថុនេះលោកម្ចាស់គួរធ្វើ វត្ថុនេះ មិនគួរធ្វើជាដើម ។ លោកបានជាបុគ្គលប្រដៅងាយ មានប្រក្រតីទទួលយកឱវាទដោយគោរពហើយ ព្រោះដូច្នោះ កាលលោកបដិបត្តិតាមពាក្យដែលព្រះថេរៈទូន្មាន ២-៣ ថ្ងៃប៉ុណ្ណោះ ក៏បានសម្រេចអរហត្ត ហើយព្រះថេរៈនាំលោកទៅកាន់សម្នាក់ព្រះសាស្ដា ថ្វាយបង្គំ

អន្ទុយហើយ ។

លំដាប់នោះ ព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារៈដល់លោក ហើយត្រាស់ថា ម្នាលសារីបុត្ត អន្តេវាសិករបស់អ្នកប្រដៅងាយឬ ព្រះថេរៈទូលថា បពិត្រព្រះអង្គ យ៉ាងនោះឯង លោកជាបុគ្គលប្រដៅងាយពន់ពេក ទោសណាមួយដែលខ្ញុំព្រះអង្គពោលទូន្មានមិនធ្លាប់ខឹងក្រោធឡើយ ។ ព្រះសាស្តាត្រាស់ថា ម្នាលសារីបុត្ត បើអ្នកបានសទ្ធិវិហារិកបែបនេះ គប្បីទទួលបានប្រមាណប៉ុនណា ព្រះថេរៈពោលថា ខ្ញុំព្រះអង្គគប្បីទទួលបានច្រើននោះឯង ។

សម័យក្រោយមក ពួកភិក្ខុសន្ទនាគ្នាក្នុងរោងធម្មសភាថា បានឮថា ព្រះសារីបុត្តត្ថេរ ជាអ្នកកតញ្ញូកតវេទី រឭកដល់ឧបការៈត្រឹមតែបាយមួយវែក ឲ្យព្រាហ្មណ៍បួសហើយ សូម្បីព្រះរាធត្ថេរ ក៏ជាអ្នកអត់ធន់ចំពោះឱវាទរមែងបានបុគ្គលគួរដល់ការឲ្យឱវាទដូចគ្នា ។

ព្រះសាស្តា ទ្រង់ស្តាប់កថារបស់ភិក្ខុទាំងនោះហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ទោះបីក្នុងកាលមុនសារីបុត្តក៏ជាបុគ្គលកតញ្ញូកតវេទីដូចគ្នា ដូច្នេះហើយ ដើម្បីនឹងប្រកាសសេចក្តីនោះ ទើបត្រាស់អលីនចិត្តជាតក ក្នុងទុកនិបាតនេះឲ្យពិស្តារថា

> ព្រះសាស្តាត្រាស់ថា សេនាដ៏ច្រើន មានចិត្តរីករាយ ព្រោះអាស្រ័យនូវអលីនចិត្តកុមារ បានញុំាងដំរីឲ្យចាប់យកព្រះបាទកោសលទាំងរស់ ដែលមិនត្រេកអរហើយ ដោយរាជសម្បត្តិរបស់ខ្លួន យ៉ាងណាមិញ ។

ភិក្ខុអ្នកបរិបូណ៌ដោយនិស្ស័យ មានសេចក្តីព្យាយាមប្រារព្ធហើយ កាលចម្រើននូវកុសលធម៌ ដើម្បីសម្រេចនូវព្រះនិព្វានជាទីក្សេមចាកយោគៈ គប្បីដល់នូវការអស់ទៅនៃសំយោជនៈទាំងពួងដោយលំដាប់ ក៏យ៉ាងនោះដែរ ។

បានឮថា ដំរីមួយត្រាច់ទៅម្នាក់ឯង ដឹងឧបការៈដែលពួកជាងឈើធ្វើហើយដល់ខ្លួនដោយការៈ គឺធ្វើជើងឲ្យជាសះស្បើយ ហើយឲ្យកូនដំរីសសុទ្ធ ដំរីក្នុងកាលនោះ បានជាព្រះសារីបុត្តត្ថេរហើយ ។

ព្រះសាស្តា កាលត្រាស់ជាតកប្រារព្ធព្រះថេរៈយ៉ាងនោះហើយ ទ្រង់ប្រារព្ធព្រះរាធត្ថេរត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុគួរជាអ្នកប្រដៅងាយដូចរាធៈ សូម្បីអាចារ្យចង្អុលទោសប្រៀនប្រដៅក៏មិនខឹងក្រោធ គួរឃើញបុគ្គលអ្នកឲ្យឱវាទ ដូចបុគ្គលអ្នកប្រាប់កំណប់ទ្រព្យដូច្នោះ ដូច្នេះហើយ ទើបទ្រង់បន្តអនុសន្ធិសម្តែងធម៌ បានត្រាស់ព្រះគាថានេះថា

**និធីនំវ បវត្តារំ យំ បស្សេ វជ្ជទស្សិនំ**
**និគ្គយ្ហវាទឹ មេធាវឹ តាទិសំ បណ្ឌិតំ ភជេ**
**តាទិសំ ភជមានស្ស សេយ្យោ ហោតិ ន បាបិយោ ។**

បុគ្គលគួរឃើញនូវអ្នកប្រាជ្ញណា ដែលជាអ្នកពោលសង្កត់សង្កិន ចង្អុលប្រាប់ទោស ដូចជាបុគ្គលអ្នកប្រាប់កំណប់ទ្រព្យឲ្យដូច្នោះ គួរគប់អ្នកប្រាជ្ញបែបនោះ ( ព្រោះថា ) កាលបុគ្គលគប់អ្នកប្រាជ្ញបែបនោះហើយ រមែងមានសេចក្តី

គាប់ប្រសើរ ឥតមានទោសដ៏លាមកឡើយ ។

# សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **និធីនំ** បានដល់ ឆ្នាំងនៃកំណប់ទ្រព្យដែលពេញដោយប្រាក់ មាសជាដើម ដែលគេកប់រក្សាក្នុងទីនោះៗ ។

បទថា **បវត្តារំ** គឺដូចបុគ្គលធ្វើនូវការអនុគ្រោះជនក្រីក្រ ដែលរស់នៅដោយលំបាក ហើយប្រាប់ថា ចូរអ្នកមក ខ្ញុំនឹងចង្អុលឧបាយចិញ្ចឹមជីវិតដោយស្រួលដល់អ្នក ដូច្នេះហើយ នាំទៅកាន់ទីកប់ទ្រព្យហើយ លាដៃចេញប្រាប់ថា ចូរអ្នកកាន់យកទ្រព្យនេះ ចិញ្ចឹមជីវិតតាមសប្បាយចុះ ។

វិនិច្ឆ័យក្នុងបទថា **វជ្ជទស្សិនំ** ភិក្ខុចង្អុលទោស មានពីរពួក គឺភិក្ខុចាំសម្លឹងទោសដោយគិតថា អញនឹងសង្កត់សង្កិនភិក្ខុនោះដោយមារយាទដែលមិនសមគួរ ឬដោយកម្លាំងបែបនេះក្នុងកាលកណ្តាលជំនុំសង្ឃដូច្នេះ ១ ពួកភិក្ខុតាំងនៅហើយតាមសភាវៈ ដោយអំណាចនៃការគាំទ្រ ដោយការសម្លឹងមើលទោសនោះៗ ដើម្បីប្រយោជន៍ឲ្យដឹងវត្ថុដែលមិនទាន់ដឹង ដើម្បីឲ្យបានរឭកដល់វត្ថុដែលដឹងហើយ ព្រោះភាពជាអ្នកប្រាថ្នាការចម្រើននៃគុណ មានសីលជាដើម ដល់បុគ្គលនោះ ១ ពួក ភិក្ខុពួកក្រោយនេះ ព្រះដ៏មានព្រះភាគទ្រង់បំណងយកក្នុងបទថា **វជ្ជទស្សិនំ** នេះ ។ មនុស្សក្រីក្រ ត្រូវអ្នកដទៃគំរាមក្តី វាយក្តី ចង្អុលកំណប់ទ្រព្យឲ្យថា ចូរអ្នកកាន់យកទ្រព្យនេះ រមែងមិនធ្វើការទឹងក្រោធ មានតែត្រេកអរតែម្យ៉ាង យ៉ាងណា កាលបុគ្គលបែបនោះឃើញមារយាទមិនសមគួរក្តី ការភ្លាំងភ្លាត់ក្តី ហើយប្រាប់ អ្នកទទួលនូវការ

ប្រាប់ មិនគួរធ្វើការទទឹងក្រោធ គួរជាអ្នកត្រេកអរតែម្យ៉ាងដូច្នោះ គួរបវារណាថា បពិត្រលោកម្ចាស់ កម្មដ៏ធំដែលលោកម្ចាស់តាំងនៅក្នុងឋានៈជាអាចារ្យជាឧបជ្ឈាយ៍របស់ខ្ញុំហើយ ទូន្មានធ្វើហើយ សូមឱ្យតទៅ សូមលោកម្ចាស់ឲ្យឱវាទដល់ខ្ញុំ ដូច្នេះ ។

បទថា **និគ្គយ្ហវាទី** សេចក្តីថា អាចារ្យខ្លះឃើញមារយាទដែលមិនសមគួរក្តី ការភ្លាំងភ្លាត់ក្តី របស់អន្តេវាសិក មានសទ្ធិវិហារិកជាដើមហើយ មិនអាចនិយាយដោយខ្លាចក្រែងថា សិស្សនេះឧបដ្ឋាកអញដោយកិច្ចវត្ត មានឲ្យទឹកខ្ពុរមាត់ជាដើមដល់អញដោយគោរព បើអញស្តីថាឲ្យលោកសោត លោកនឹងមិនឧបដ្ឋាកអញ ការវិនាសនឹងមានដល់អញដោយអាការយ៉ាងនេះ ដូច្នេះ មិនឈ្មោះថា ជាអ្នកពោលនិគ្គហៈឡើយ បុគ្គលនោះ ឈ្មោះថា ជាអ្នកពង្រាយនូវសំរាមក្នុងសាសនានេះ ។ ចំណែកអាចារ្យណាឃើញទោសបែបនោះហើយ គំរាមបណ្តេញ ដាក់ទណ្ឌកម្ម បណ្តេញចេញអំពីវិហារតាមសមគួរដល់ទោស ឲ្យសិក្សា ។ អាចារ្យនេះ ឈ្មោះថា ពោលនិគ្គហៈ ដូចព្រះសម្មាសម្ពុទ្ធ ។ ពិតហើយ ព្រះដ៏មានព្រះភាគត្រាស់ពាក្យនេះថា ម្នាលអានន្ទ តថាគតនឹងពោលសង្កត់សង្កិន ម្នាលអានន្ទ តថាគតនឹងលើកសរសើរបុគ្គលណាជាសារៈ បុគ្គលនោះ នឹងតាំងនៅបាន ។

បទថា **មេធាវី** គឺប្រកបដោយបញ្ញាដ៏រុងរឿងក្នុងធម៌ ។

បទថា **តាទិសំ** ជាដើម សេចក្តីថា បុគ្គលគប្បីគប់រក គឺគប្បីចូលទៅអង្គុយជិតបណ្ឌិតបែបនោះ ។ ព្រោះកាលអន្តេវាសិក សេពគប់អាចារ្យ

បែបនោះ គុណដ៏ប្រសើររមែងមាន ទោសដ៏លាមករមែងមិនមាន គឺមានតែសេចក្តីចម្រើនតែម្យ៉ាង មិនមានការវិនាសឡើយ ។

ក្នុងទីបំផុតនៃទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។ល។

**រឿងព្រះរាធត្ថេរ ចប់**

# រឿង អស្សជិភិក្ខុ និងបុនព្វសុកៈ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអស្សជិ និងបុនព្វសុកៈ ត្រាស់ព្រះធម្មទេសនានេះថា **ឱវទេយ្យានុសាសេយ្យ** ជាដើម ។ ទេសនានេះតាំងឡើងហើយត្រង់កិដាគិរី ។

បានឮមកថា ភិក្ខុពីររូបនោះ ជាសទ្ធិវិហារិករបស់អគ្គសាវកក៏ពិត តែលោកក៏ក្លាយជាអលជ្ជី ជាភិក្ខុអាក្រក់ ភិក្ខុពីររូបនោះ កាលនៅត្រង់កិដាគិរី ជាមួយភិក្ខុ ៥០០ រូបដែលជាបរិវាររបស់ខ្លួន សុទ្ធសឹងតែជាមនុស្សអាក្រក់ ធ្វើអនាចារច្រើនបែបច្រើនយ៉ាងជាដើម ដាំដើមឈើខ្លួនឯងខ្លះ ប្រើអ្នកដទៃឲ្យដាំខ្លះ ធ្វើកម្មនៃភិក្ខុដែលប្រទូស្តត្រកូល ចិញ្ចឹមជីវិតដោយបច្ច័យដែលកើតអំពីកម្មនោះ បានធ្វើអាវាសនោះមិនឲ្យជាលំនៅនៃពួកភិក្ខុ ដែលមានសីលជាទីស្រឡាញ់ ។ ព្រះសាស្តាទ្រង់ស្តាប់ដំណឹងនោះហើយ ត្រាស់ហៅអគ្គសាវក

ទាំងពីរ មួយអន្លើដោយបរិវារមក ដើម្បីបំណាងធ្វើបព្វាជនីយកម្មដល់ភិក្ខុទាំងនោះ ហើយត្រាស់ថា ម្នាលសារីបុត្ត និងមោគ្គល្លាន ពួកអ្នកទាំងពីរទៅចុះក្នុងភិក្ខុទាំងនោះ ភិក្ខុណាមិនស្តាប់ពាក្យរបស់អ្នក ចូរធ្វើបព្វាជនីយកម្មដល់ភិក្ខុទាំងនោះ ចំណែកភិក្ខុណាស្តាប់ ចូរពោលប្រៀនប្រដៅភិក្ខុទាំងនោះ ធម្មតាការប្រៀនប្រដៅ រមែងមិនជាទីស្រឡាញ់របស់បុគ្គលដែលមិនមែនបណ្ឌិតប៉ុណ្ណោះ តែជាទីស្រឡាញ់ពេញចិត្តរបស់បណ្ឌិតទាំងឡាយ ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**ឱវទេយ្យានុសាសេយ្យ អសព្ភា ច និវារយេ**
**សតំ ហិ សោ បិយោ ហោតិ អសតំ ហោតិ អប្បិយោ ។**

បណ្ឌិតគួរទូន្មានប្រៀនប្រដៅ គួរហាមឃាត់នូវជនទាំងឡាយ
ចាកអំពើអសប្បុរស បណ្ឌិតនោះ រមែងជាទីស្រឡាញ់របស់
សប្បុរសតែម្យ៉ាង មិនជាទីស្រឡាញ់នៃអសប្បុរសឡើយ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ឱវទេយ្យ** សេចក្តីថា កាលកើតរឿងឡើងហើយទើបពោល ឈ្មោះថាឲ្យឱវាទ កាលមិនទាន់កើតរឿង ចង្អុលទោសដែលមិនទាន់មកដល់ ដោយពាក្យជាដើមថា ទោសនឹងគប្បីមានដល់អ្នក ដូច្នេះ ឈ្មោះថា អនុសាសនៈ កាលពោលចំពោះមុខ ឈ្មោះថា ឱវាទ បើបញ្ជូនទូតឬសាសន៍ទៅក្នុងទីកំបាំង ឈ្មោះថា អនុសាសនៈ បើពោលតែម្តង ឈ្មោះថា ឱវាទ បើពោលរឿយៗ ឈ្មោះថាអនុសាសនៈ ម្យ៉ាងទៀត កំពុងឲ្យឱវាទនោះ

ឯង ឈ្មោះថា អនុសាសនៈ គប្បីពោលប្រៀនប្រដៅយ៉ាងនេះ ដោយប្រការដូច្នេះ ។

បទថា **អសព្ភា** សេចក្ដីថា គប្បីហាមចាកអកុសលធម៌ គប្បីឲ្យតាំងនៅក្នុងកុសលធម៌ ។ បទថា **សតំ** សេចក្ដីថា បុគ្គលបែបនេះ រមែងជាទីស្រឡាញ់នៃសប្បុរសទាំងឡាយ មានព្រះពុទ្ធជាដើម តែបុគ្គលពោលប្រៀនប្រដៅនោះ រមែងមិនជាទីស្រឡាញ់នៃពួកបុគ្គលមិនឃើញធម៌ មានបរលោកដែលឆ្ងងហើយ ជាអ្នកឃើញដល់អាមិស បួសដើម្បីប្រយោជន៍ដល់ការចិញ្ចឹមជីវិតទាំងនោះ ឈ្មោះថា អសប្បុរស ជាបុគ្គលចាក់ដោយលំពែង គឺមាត់យ៉ាងនេះថា លោកមិនមែនឧបជ្ឈាយ៍ ឬអាចារ្យរបស់ពួកខ្ញុំទេ ហេតុអ្វីប្រៀនប្រដៅពួកខ្ញុំ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមហើយ ។

ចំណែកព្រះសារីបុត្ត និងព្រះមោគ្គល្លាន ទៅត្រង់កិដាគិរីនោះ ពោលប្រៀនប្រដៅភិក្ខុទាំងនោះហើយ ក្នុងភិក្ខុទាំងនោះ ភិក្ខុពួកខ្លះ ក៏ទទួលឱវាទតាំងចិត្តប្រព្រឹត្តបដិបត្តិ ពួកខ្លះ ក៏សឹកទៅ ភិក្ខុពួកខ្លះ ក៏ត្រូវបញ្ជាជនីយកម្មដូច្នេះឯង ។

**រឿងអស្សជិភិក្ខុ និងបុនព្វសុកៈ ចប់**

# រឿង ព្រះឆន្នត្ថេរ

## លំនាំដើម

*ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះឆន្នត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា* **ន ភជេ បាបកេ មិត្តេ** *ជាដើម ។*

*បានឮមកថា ព្រះឆន្ននោះជេរព្រះអគ្គសាវកទាំងពីរថា ខ្ញុំកាលតាមទ្រង់ចេញមហាភិនេស្ក្រមណ៍ ជាមួយអយ្យបុត្រនៃយើងទាំងឡាយ ក្នុងពេលនោះ មិនបានឃើញអ្នកដទៃ សូម្បីត្រឹមតែម្នាក់ តែឥឡូវនេះ លោកទាំងនេះត្រាច់មកពោលថា ខ្ញុំឈ្មោះសារីបុត្ត ខ្ញុំឈ្មោះមោគ្គល្លាន ពួកខ្ញុំជាអគ្គសាវក ។ ព្រះសាស្តា ទ្រង់ឮដំណឹងនោះអំពីសម្នាក់ភិក្ខុទាំងឡាយហើយ ត្រាស់ឲ្យហៅព្រះឆន្នត្ថេរមកទូន្មានហើយ ។ លោកស្ងៀមក្នុងខណៈនោះប៉ុណ្ណោះ ត្រឡប់ទៅជេរព្រះថេរៈទាំងឡាយយ៉ាងនោះទៀត ។ ព្រះសាស្តា ត្រាស់ឲ្យហៅលោកដែលកំពុងជេរមកហើយ ត្រាស់ប្រៀនប្រដៅយ៉ាងនោះអស់វារៈ ៣ ដងហើយទ្រង់ដាស់តឿនថា ម្នាលឆន្ន ឈ្មោះថា អគ្គសាវកទាំងពីរ ជាកល្យាណមិត្ត ជាបុរសដ៏ឧត្តមរបស់អ្នក ចូរអ្នកសេពគប់កល្យាណមិត្តបែបនេះ ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា*

**ន ភជេ បាបកេ មិត្តេ ន ភជេ បុរិសាធមេ**
**ភជេថ មិត្តេ កល្យាណេ ភជេថ បុរិសុត្តមេ ។**

*បុគ្គលមិនគួរគប់មិត្តអាក្រក់ មិនគួរគប់បុរសថោក*
*ទាប គួរគប់តែមិត្តដែលល្អ គួរគប់តែបុរសជាន់ខ្ពស់។*

# សេចក្ដីអធិប្បាយ

អត្ថនៃព្រះគាថានោះថា បុគ្គលត្រេកអរក្នុងអកុសលកម្ម មានកាយទុច្ចរិតជាដើម ឈ្មោះថាបាបមិត្ត បុគ្គលដឹកនាំក្នុងហេតុដែលមិនសមគួរ មានការកាត់ទី-តជាដើមក្ដី មានការស្វែងរកមិនសមគួរ ២១ យ៉ាងក្ដី ឈ្មោះថា បុរសថោកទាប ។ ម្យ៉ាងទៀត ជនពីរពួកនោះ ឈ្មោះថាជាបាបមិត្តផង ជាបុរសថោកទាបផង បុគ្គលមិនគួរគប់ មិនគួរអង្គុយជិតបុគ្គលទាំងនោះ ចំណែកជនដែលខុសផ្ទុយគ្នា ឈ្មោះថាជាកល្យាណមិត្តផង ជាសប្បុរសផង បុគ្គលគួរគប់ គឺគួរអង្គុយជិតលោកទាំងនោះឯង ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមហើយ ។

ចំណែកព្រះឆន្នត្ថេរ សូម្បីបានស្ដាប់ព្រះឱវាទហើយ ក៏នៅតែជេរពួកភិក្ខុដូចន័យមុននោះឯងទៀត ។ ពួកភិក្ខុក៏ក្រាបទូលដល់ព្រះសាស្ដាទៀត ។ ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលតថាគតនៅមានជីវិត ពួកអ្នកមិនអាចឲ្យឆន្នសិក្សាបានឡើយ តែកាលតថាគតបរិនិព្វានហើយទើបអាច ដូច្នេះហើយ កាលព្រះអានន្ទទូលសួរក្នុងកាលជិតបរិនិព្វានថា បពិត្រព្រះអង្គ ពួកខ្ញុំព្រះអង្គគប្បីបដិបត្តិក្នុងព្រះឆន្នត្ថេរដូចម្ដេច ទើបទ្រង់ត្រាស់ថា ម្នាលអានន្ទ ពួកអ្នកគប្បីដាក់ព្រហ្មទណ្ឌដល់ឆន្នភិក្ខុចុះ ។

ឆន្នភិក្ខុនោះ កាលព្រះសាស្ដាបរិនិព្វានហើយ បានស្ដាប់ព្រហ្មទណ្ឌដែលព្រះអានន្ទត្ថេរលើកឡើងហើយ មានទុក្ខ ខូចចិត្ត ដួលសន្លប់អស់ ៣ ដងហើយអង្វរថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់កុំឲ្យខ្ញុំវិនាសឡើយ ដូច្នេះ

ហើយ បំពេញវត្តដោយប្រពៃ ក្នុងកាលមិនយូរប៉ុន្មានក៏សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយហើយ ដូច្នេះឯង ៚

**រឿង ព្រះឆន្នត្ថេរ ចប់**

# រឿង ព្រះមហាកប្បិនត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះមហាកប្បិនត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **ធម្មបីតិ សុខំ សេតិ** ជាដើម ។ ក្នុងរឿងនោះមានអនុបុព្វីកថាដូចតទៅនេះ

បានឮថា ក្នុងអតីតកាល ព្រះមហាកប្បិន មានអភិនីហារបានធ្វើទៀបបាទមូលរបស់ព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ អន្ទោលទៅក្នុងសង្សារ កើតជាប្រធាននៃជាងតម្បាញ ក្នុងស្រុកជាងតម្បាញមួយកន្លែង មិនឆ្ងាយអំពីក្រុងពារាណសី ។ គ្រានោះ ព្រះបច្ចេកពុទ្ធប្រមាណមួយពាន់អង្គ នៅក្នុងហិមវន្តប្បទេស ៨ ខែ នៅក្នុងជនបទ ៤ ខែ ក្នុងរដូវភ្លៀង ។ គ្រាមួយ ព្រះបច្ចេកពុទ្ធទាំងនោះ ស្នាក់នៅក្នុងទីមិនឆ្ងាយអំពីក្រុងពារាណសី ហើយបញ្ជូនព្រះបច្ចេកពុទ្ធពីររូប ទៅកាន់សម្នាក់របស់ព្រះរាជាដោយពាក្យថា លោកទាំងឡាយ ចូរទូលសុំហត្ថកម្ម ដើម្បីប្រយោជន៍ដល់ការធ្វើសេនាសនៈ ។ ក្នុងកាលនោះ ជាពេលវប្បមង្គល គឺច្រត់ព្រះនង្គ័លរបស់ព្រះរាជា ព្រះរាជា

បានឮថា ព្រះបច្ចេកពុទ្ធទាំងឡាយនិមន្តមក ទើបយាងចេញទៅ ត្រាស់សួរដល់ហេតុដែលមក ហើយត្រាស់ថា បពិត្រលោកម្ចាស់ ថ្ងៃនេះ មិនទាន់មានឱកាស ព្រោះស្អែកនេះ យើងខ្ញុំទាំងឡាយមាននូវវិប្បមង្គល ។ យើងខ្ញុំនឹងធ្វើក្នុងថ្ងៃទី ៣ ទ្រង់មិនអារាធនាព្រះបច្ចេកពុទ្ធទាំងឡាយឡើយ ទ្រង់ចូលទៅហើយ ព្រះបច្ចេកពុទ្ធទាំងឡាយគិតថា ពួកយើងនឹងទៅកាន់ស្រុកដទៃ ហើយចៀសចេញទៅ ។

ខណៈនោះ កិរិយាជាងតម្បាញដែលជាប្រធានទៅកាន់ក្រុងពារាណសី ដោយកិច្ចឯណាទីមួយ ឃើញព្រះបច្ចេកពុទ្ធទាំងនោះ នមស្ការហើយសួរថា បពិត្រលោកម្ចាស់ លោកម្ចាស់មកខុសកាលព្រោះហេតុអ្វី បានជ្រាបការប្រព្រឹត្តទៅនោះតាំងអំពីដើមដល់ចប់ ជាស្រីមានសទ្ធា ដល់ព្រមដោយបញ្ញា និមន្តថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទាំងឡាយ ទទួលភិក្ខារបស់យើងខ្ញុំក្នុងថ្ងៃស្អែកនេះ ។

ព្រះបច្ចេកពុទ្ធត្រាស់ថា ម្នាលប្អូនស្រី ពួកអាត្មាមានច្រើន ស្រីនោះពោលថា មានប្រមាណប៉ុន្មានណាលោកម្ចាស់ ព្រះបច្ចេកពុទ្ធពោលថា ម្នាលប្អូនស្រី មានប្រមាណមួយពាន់រូប ។ ស្រីនោះពោលថា បពិត្រលោកម្ចាស់ ពួកខ្ញុំមានប្រមាណមួយពាន់នាក់នៅក្នុងស្រុកនេះ មនុស្សម្នាក់នឹងប្រគេនភិក្ខាដល់លោកម្ចាស់មួយរូបៗ សូមលោកម្ចាស់ទាំងឡាយទទួលភិក្ខាចុះ ខ្ញុំម្នាក់ឯងនឹងប្រគេនទីលំនៅ ដល់លោកម្ចាស់ទាំងឡាយ ។

ព្រះបច្ចេកពុទ្ធទាំងឡាយទទួលហើយ នាងចូលទៅកាន់ស្រុកប្រកាសថា

ខ្ញុំឃើញព្រះបច្ចេកពុទ្ធប្រមាណមួយពាន់អង្គ ខ្ញុំនិមន្តហើយ អ្នកទាំងឡាយ ចូរចាត់ចែងទីអង្គុយដល់លោកម្ចាស់ទាំងឡាយ ចូររៀបចំអាហារវត្ថុទាំងឡាយ មានបបរ និងបាយជាដើម ដល់លោកម្ចាស់ទាំងឡាយចុះ ហើយឲ្យសាង បុស្បុកត្រង់កណ្តាលស្រុក ក្រាលអាសនៈ ក្នុងថ្ងៃស្អែកឡើង ទើបនិមន្តព្រះ បច្ចេកពុទ្ធទាំងឡាយឲ្យគង់ អង្គាសដោយភោជនដ៏ប្រណីត ក្នុងពេលស្រេច ភត្តកិច្ច ទើបនាំស្រីទាំងអស់ក្នុងស្រុកនោះ មួយអន្លើដោយស្រីទាំងនោះ នមស្ការព្រះបច្ចេកពុទ្ធទាំងឡាយហើយ ទទួលយកបដិញ្ញា ដើម្បីប្រយោជន៍ ដល់ការនៅអស់ត្រីមាស ហើយប្រកាសដល់អ្នកស្រុកទៀតថា នែនាង និង អ្នកទាំងឡាយ បុរសនីមួយៗ អំពីត្រកូលនីមួយៗ ចូរកាន់យកគ្រឿងឧប-ករណ៍ មានកាំបិតជាដើម ចូលទៅកាន់ព្រៃនាំយកទព្វសម្ភារៈ មកធ្វើលំនៅ របស់ព្រះបច្ចេកពុទ្ធទាំងឡាយចុះ ។

ពួកអ្នកស្រុកតាំងនៅក្នុងពាក្យរបស់នាងហើយ មនុស្សម្នាក់ៗ ធ្វើទី កន្លែងនីមួយៗ ហើយសាងសាលាប្រក់ដោយស្លឹកឈើចំនួនមួយពាន់ខ្នង មួយ អន្លើដោយទីសម្រាកពេលយប់ និងពេលថ្ងៃ ហើយឧបដ្ឋាកព្រះបច្ចេកពុទ្ធនៅ ចាំវស្សាក្នុងបណ្ណសាលារៀងៗ ខ្លួន ដោយតាំងចិត្តថា យើងនឹងឧបដ្ឋាក ដោយគោរព យើងនឹងឧបដ្ឋាកដោយគោរព ។

ក្នុងពេលចេញវស្សាហើយនាងបបួលថា អ្នកទាំងឡាយចូរត្រៀមសំពត់ ដើម្បីចីវរ ប្រគេនដល់ព្រះបច្ចេកពុទ្ធទាំងឡាយ ដែលនៅចាំវស្សាក្នុងបណ្ណ-សាលារៀងៗ ខ្លួនចុះ ហើយឲ្យប្រគេនចីវរដែលមានតម្លៃមួយពាន់ ដល់ព្រះ

បច្ចេកពុទ្ធមួយអង្គៗ ។ ព្រះបច្ចេកពុទ្ធទាំងឡាយចេញវស្សាហើយ ធ្វើអនុមោទនាហើយ ក៏ចៀសចេញទៅ ។

ពួកអ្នកស្រុកកាលធ្វើបុណ្យនេះហើយ ចុតិចាកអត្តភាពនោះ កើតក្នុងភពតាវត្តិង្ស មានឈ្មោះថា គណទេវបុត្រ ។ ទេវបុត្រទាំងនោះ សោយទិព្វ-សម្បត្តិក្នុងស្ថានតាវត្តិង្សនោះ ក្នុងកាលព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមកស្សបៈមកកើតក្នុងផ្ទះកុដុម្ពិកៈ ក្នុងក្រុងពារាណសី ។ ប្រធានជាងតម្បាញ បានជាកូនរបស់កុដុម្ពិកៈដែលជាធំ ចំណែកភរិយារបស់គេ បានជាធីតារបស់កុដុម្ពិកៈដែលជាធំដូចគ្នា ។ ស្រីទាំងអស់នោះដល់នូវការចម្រើនវ័យហើយ កាលទៅកាន់ត្រកូលស្វាមី បានទៅកាន់ផ្ទះរបស់បុរសទាំងនោះឯង ។

សម័យមួយ គេប្រកាសការស្តាប់ធម៌ក្នុងវិហារ ។ កុដុម្ពិកៈទាំងអស់នោះបានឮថា ព្រះសាស្តាទ្រង់សម្តែងធម៌ ប្រឹក្សាគ្នាថា យើងទាំងឡាយនឹងស្តាប់ធម៌ ហើយទៅកាន់វិហារជាមួយភរិយា ។ ក្នុងខណៈដែលជនទាំងនោះចូលទៅកាន់វិហារ ភ្លៀងបានធ្លាក់ហើយ ។ បព្វជិតទាំងឡាយ មានសាមណេរជាដើមដែលជាកុលុបកៈ ឬជាញាតិរបស់ជនទាំងឡាយណាមាន ជនទាំងនោះ ក៏ចូលទៅកាន់បរិវេណរបស់បព្វជិតទាំងនោះ តែកុដុម្ពិកៈទាំងនោះ មិនអាចចូលទៅក្នុងទីណាបាន ព្រោះកុលុបកៈ ឬញាតិបែបនោះមិនមាន បានឈរត្រង់កណ្តាលវិហារនោះឯង ។

លំដាប់នោះ ទើបកុដុម្ពិកៈដែលជាប្រធាន ពោលនឹងកុដុម្ពិកៈដែលជាបរិវារទាំងនោះថា អ្នកទាំងឡាយ ចូរមើលអាការគួរខ្មើមរបស់ពួកយើង ធម្មតា

កុលបុត្រទាំងឡាយ ខ្មាសដោយហេតុមានប្រមាណប៉ុណ្ណោះ សមគួរហើយ បរិវារពោលថា បពិត្រលោកម្ចាស់ ពួកយើងនឹងធ្វើដូចម្តេច កុដុម្ពិកៈពោលថា ពួកយើងដល់នូវអាការគួរខ្មាសនេះ ព្រោះមិនមានទីកន្លែងដែលមានមនុស្សស្និទ្ធស្នាលគ្នា យើងទាំងអស់រៃទ្រព្យគ្នាសាងបរិវេណចុះ បរិវារពោលថា សាធុ លោកម្ចាស់ ។

កុដុម្ពិកៈជាប្រធានឲ្យទ្រព្យមួយពាន់ ជនដ៏សេសឲ្យម្នាក់ ៥០០ ពួកស្រីៗឲ្យម្នាក់ ២៥០ ជនទាំងនោះ ប្រមូលទ្រព្យនោះហើយ ផ្តើមសាងបរិវេណធំដើម្បីប្រយោជន៍ជាទីប្រថាប់របស់ព្រះសាស្តា ដែលមានផ្ទះកំពូលមួយពាន់ជាបរិវារ ។ កាលទ្រព្យមិនគ្រប់គ្រាន់ ព្រោះនវកម្មជាការងារធំ ទើបចេញម្នាក់ពាក់កណ្តាល អំពីទ្រព្យដែលខ្លួនឲ្យហើយក្នុងកាលមុន កាលបរិវេណស្រេចហើយ ជនទាំងនោះធ្វើការឆ្លងវិហារ ទើបថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ ហើយចាត់ចែងចីវរដើម្បីភិក្ខុមួយពាន់រូប ។

ចំណែកកិរិយារបស់កុដុម្ពិកៈដែលជាប្រធាន មិនធ្វើឲ្យមានចំណែកស្មើដោយជនទាំងអស់ តាំងនៅដោយបញ្ញារបស់ខ្លួន គិតថា អញនឹងបូជាព្រះ-សាស្តា ធ្វើឲ្យក្រៃលែងជាងគេ ទើបកាន់យកប្រអប់ ដាក់ផ្កានោង និងសំពត់សាដក ដែលមានពណ៌ដូចផ្កានោងតម្លៃមួយពាន់ ក្នុងពេលអនុមោទនាបូជាព្រះសម្ពុទ្ធដោយផ្កានោង ហើយដាក់សំពត់សាដកនោះ ទៀបបាទមូលរបស់ព្រះសាស្តា តាំងសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គ សូមសរីរៈរបស់ខ្ញុំម្ចាស់ដូចផ្កានោងនេះឯង ក្នុងទីដែលខ្ញុំម្ចាស់កើតហើយ ខ្ញុំម្ចាស់សូមមាន

ឈ្មោះថា អនោជាទុំះឯង ។ ព្រះសាស្តាទ្រង់បានធ្វើអនុមោទនាថា ចូរសម្រេចយ៉ាងនេះចុះ ។

ជនទាំងអស់នោះ តាំងនៅដរាបអស់អាយុហើយ ចុតិអំពីអត្តភាពនោះ កើតក្នុងទេវលោក ក្នុងពុទ្ធុប្បាទកាលនេះ ចុតិអំពីទេវលោកហើយ កុដុម្ពិកៈជាប្រធានកើតក្នុងរាជត្រកូល ក្នុងកុក្កុដវតីនគរ ដល់នូវសេចក្តីចម្រើនវ័យហើយ បានជាព្រះរាជាព្រះនាមមហាកប្បិន ជនដ៏សេសកើតក្នុងត្រកូលអមាត្យ ភរិយារបស់កុដុម្ពិកៈជាប្រធាន កើតក្នុងរាជត្រកូល ក្នុងសាគលនគរក្នុងមទ្ទរដ្ឋ ព្រះនាងមានព្រះសរីរៈដូចគ្នានឹងពណ៌នៃផ្កានោងនោះឯង ទើបព្រះញាតិថ្វាយព្រះនាមដល់ព្រះនាងថា អនោជា ទុំះឯង ។ ព្រះនាងដល់នូវការចម្រើនវ័យហើយ ទៅកាន់ព្រះរាជមន្ទីរនៃព្រះបាទកប្បិន បានជាព្រះទេវីមានព្រះនាមអនោជាហើយ ស្ត្រីទាំងឡាយដ៏សេស កើតក្នុងត្រកូលអមាត្យទាំងឡាយ ដល់នូវការចម្រើនវ័យហើយ ក៏បានទៅកាន់ផ្ទះនៃបុត្រអមាត្យទាំងនោះដូចគ្នា ។ ជនទាំងនោះ បានសោយសម្បត្តិដូចគ្នានឹងសម្បត្តិរបស់ព្រះរាជា ។ ក្នុងកាលណាព្រះរាជា ទ្រង់ប្រដាប់គ្រឿងអលង្ការទាំងពួងគង់លើខ្នងដំរីត្រាច់ទៅ ក្នុងកាលនោះ ជនទាំងនោះ ក៏ត្រាច់ទៅយ៉ាងនោះកាលព្រះរាជាយាងទៅដោយសេះ ឬដោយរថ ជនទាំងនោះ ក៏ត្រាច់ទៅយ៉ាងនោះដូចគ្នា ។ ជនទាំងនោះ សោយសម្បត្តិរួមគ្នាដោយអានុភាពនៃបុណ្យដែលធ្វើរួមគ្នា ដោយប្រការដូច្នេះ ។

សេះរបស់ព្រះរាជាមាន ៥ គឺ សេះឈ្មោះពល ១ ពលវាហនៈ ១

បុប្ផៈ ១ បុប្ផវាហនៈ ១ សុបត្តៈ ១ ។ បណ្ដាសេះទាំងនោះ សេះឈ្មោះសុបត្តៈ ព្រះរាជាគង់ដោយព្រះអង្គឯង សេះ ៤ ក្រៅអំពីនេះ ទ្រង់ព្រះរាជទានជាសេះបម្រើ ដើម្បីប្រយោជន៍ក្នុងការនាំសារទៅមក ។

ព្រះរាជា ឲ្យសេះបម្រើទាំងនោះស៊ីអំពីព្រលឹមហើយ ទ្រង់បញ្ជូនទៅដោយព្រះតម្រាស់ថា ចូរពួកអ្នកទៅចុះ ត្រាច់ទៅ ២-៣ យោជន៍ ហើយចូរជ្រាបថា ព្រះពុទ្ធ ព្រះធម៌ ឬព្រះសង្ឃកើតហើយ ចូរនាំដំណឹងដែលនាំឲ្យកើតសុខមកដល់ខ្ញុំ ។ សេះបម្រើទាំងនោះ ចេញដោយទ្វារទាំង ៤ ត្រាច់ទៅបាន ២-៣ យោជន៍ មិនបានដំណឹងក៏ត្រឡប់មក ។

សម័យថ្ងៃមួយ ព្រះរាជាគង់លើសេះឈ្មោះសុបត្តៈ ដែលអមាត្យមួយពាន់ចោមរោម យាងទៅកាន់ព្រះរាជឧទ្យាន ទតឃើញពួកឈ្មួញប្រមាណ ៥០០ មានរាងកាយទន់ខ្សោយកម្លាំង ចូលកាន់ព្រះនគរ ហើយទ្រង់ព្រះតម្រិះថា ជនទាំងនេះ លំបាកក្នុងការធ្វើដំណើរផ្លូវឆ្ងាយ អញនឹងបានស្ដាប់ដំណឹងល្អណាមួយ អំពីសម្នាក់នៃជនទាំងនេះឯងដោយពិត ទើបឲ្យហៅឈ្មួញទាំងនោះមកត្រាស់សួរថា អ្នកទាំងឡាយមកអំពីស្រុកណា ឈ្មួញទូលថា បពិត្រព្រះអង្គ ពួកទូលបង្គំមកអំពីនគរឈ្មោះសាវត្ថី មាននៅក្នុងទីបំផុតប្រមាណ ១២០ យោជន៍អំពីនគរនេះ ។ ព្រះរាជាត្រាស់ថា ដំណឹងណាមួយកើតឡើងក្នុងបទេសរបស់ពួកអ្នកមានដែរឬ ឈ្មួញទូលថា បពិត្រព្រះអង្គ ដំណឹងដទៃណាមួយមិនមានទេ តែព្រះសម្មាសម្ពុទ្ធ ទ្រង់កើតឡើងហើយ ។

ព្រះរាជាមានព្រះសរីរៈ ដែលបីតិទាំង ៥ ពាល់ត្រូវហើយ ក្នុងរំពេច

នោះឯង មិនអាចកំណត់អ្វីមួយបាន ទ្រង់ទ្រឹងមួយស្របក់ហើយត្រាស់សួរថា នែបា ពួកអ្នកពោលអ្វី ពួកឈ្នួញក្រាបទូលថា បពិត្រព្រះអង្គ ព្រះពុទ្ធទ្រង់កើតឡើងហើយ សូម្បីលើកទី ២ លើកទី ៣ ព្រះរាជាក៏ទ្រង់ទ្រឹងនៅដូចគ្នា ក្នុងវារៈទី ៤ ទ្រង់ត្រាស់សួរថា នែបា ពួកអ្នកពោលដូចម្តេច កាលឈ្នួញទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ ព្រះពុទ្ធទ្រង់កើតឡើងហើយ ទើបត្រាស់ថា នែបាទាំងឡាយ ខ្ញុំឲ្យទ្រព្យដល់ពួកអ្នកមួយសែន ហើយត្រាស់សួរថា នែបា ដំណឹងណាមួយ ដទៃទៀតមានដែរឬទេ ពួកឈ្នួញក្រាបទូលថា បពិត្រព្រះអង្គ មាន ព្រះធម៌កើតឡើងហើយ ព្រះរាជាទ្រង់ស្តាប់ពាក្យនោះហើយ ទ្រង់ទ្រឹងនៅអស់កាល ៣ ដងដោយន័យមុននោះឯង ក្នុងវារៈទី ៤ កាលពួកឈ្នួញក្រាបទូលថា **ធម្មោ** ទើបត្រាស់ថា ក្នុងបទនេះ ខ្ញុំឲ្យទ្រព្យដល់ពួកអ្នកមួយសែន ហើយត្រាស់សួរថា នែបា ដំណឹងដទៃទៀត មានដែរឬទេ ។ ពួកឈ្នួញក្រាបទូលថា បពិត្រព្រះអង្គ មាន ព្រះសង្ឃរតនៈកើតឡើងហើយ ព្រះរាជាទ្រង់ស្តាប់ពាក្យនោះហើយ ទ្រង់ទ្រឹងអស់ ៣ ដងដូចគ្នា ក្នុងវារៈទី ៤ កាលពួកឈ្នួញក្រាបទូលថា **សង្ឃោ** ទើបត្រាស់ថា ព្រោះបទនេះ ខ្ញុំឲ្យទ្រព្យដល់ពួកអ្នកមួយសែន ហើយទ្រង់សម្លឹងមើលអមាត្យមួយពាន់ ត្រាស់សួរថា បាទាំងឡាយ ពួកអ្នកនឹងធ្វើដូចម្តេច អមាត្យទូលថា បពិត្រព្រះអង្គ ចុះព្រះអង្គគិតធ្វើដូចម្តេច ព្រះរាជាត្រាស់ថា នែបាទាំងឡាយ ខ្ញុំបានឮថា ព្រះពុទ្ធកើតឡើងហើយ ព្រះធម៌កើតឡើងហើយ ព្រះសង្ឃកើតឡើងហើយ ខ្ញុំមិនត្រឡប់វិញឡើយ ខ្ញុំនឹងឧទ្ទិសចំពោះព្រះសាស្តា ទៅកាន់

សម្នាក់របស់ព្រះអង្គ ។ អមាត្យទូលថា ទូលបង្គំទាំងឡាយ ក៏នឹងបួសជាមួយព្រះអង្គដែរ ។

ព្រះរាជាត្រាស់ឲ្យក្នាក់ងារយកល័ក្ខចារឹកអក្សរ ដាក់ក្នុងជំបារមាស ហើយត្រាស់នឹងពួកឈ្មួញថា ព្រះទេវីឈ្មោះអនោជា នឹងព្រះរាជទានទ្រព្យ ៣ សែនដល់ពួកអ្នក ពួកអ្នកគប្បីពោលយ៉ាងនេះថា បានឮថា ព្រះរាជាទ្រង់លះភាពជាធំថ្វាយដល់ព្រះនាងហើយ ព្រះនាងសោយរាជសម្បត្តិតាមសប្បាយចុះ បើព្រះទេវីសួរពួកអ្នកថា តើព្រះរាជាយាងទៅឯណា ពួកអ្នកគប្បីប្រាប់ថា ព្រះរាជាត្រាស់ថា នឹងបួសឧទ្ទិសព្រះសាស្តាយាងទៅហើយ ។

អមាត្យទាំងឡាយ ក៏បញ្ជូនដំណឹងដល់កិរិយាវៀងៗ ខ្លួនយ៉ាងនោះដូចគ្នា ។ ព្រះរាជាទ្រង់បញ្ជូនពួកឈ្មួញទៅហើយ មានអមាត្យមួយពាន់ចោមរោមយាងចេញទៅក្នុងខណៈនោះឯង ។

ក្នុងថ្ងៃនោះ ព្រះសាស្តាទ្រង់ប្រមើលមើលសត្វលោកក្នុងពេលទៀបភ្លឺ បានទតឃើញព្រះបាទមហាកប្បិន មួយអន្លើដោយបរិវារ ទ្រង់ព្រះតម្រិះថា ព្រះបាទមហាកប្បិននេះ ទ្រង់បានស្តាប់ភាពដែលរតនៈ ៣ កើតឡើងអំពីសម្នាក់របស់ពួកឈ្មួញហើយ ទ្រង់បូជាពាក្យរបស់ឈ្មួញទាំងនោះ ដោយទ្រព្យ ៣ សែន ទ្រង់លះរាជសម្បត្តិដែលអមាត្យមួយពាន់ចោមរោម ទ្រង់បំណាងដើម្បីនឹងបួសឧទ្ទិសចំពោះតថាគត ទ្រង់ចេញទៅក្នុងថ្ងៃស្អែកនេះ ព្រះរាជា មួយអន្លើដោយបរិវារនឹងសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ តថាគតនឹងធ្វើការទទួលទ្រង់ ដូច្នេះហើយ ក្នុងថ្ងៃស្អែកឡើង ព្រះ

សាស្តាទ្រង់បាត្រ និងចីវរដោយព្រះអង្គឯងនោះឯង ទ្រង់ចេញទៅទទួលអស់ចម្ងាយផ្លូវ ១២០ យោជន៍ ដូចស្តេចចក្រពត្តិ ទ្រង់ទទួលសេនាបតី ដូច្នោះ ទ្រង់ប្រថាប់គង់បញ្ចេញព្រះរស្មី មាន ៦ ពណ៌ ខាងក្រោមគល់និគ្រោធត្រង់ឆ្នេរស្ទឹងចន្ទភាគានទី ។

ចំណែកព្រះរាជា យាងមកដល់ច្រាំងមួយកន្លែងហើយ ត្រាស់សួរថា នេះឈ្មោះថា ស្ទឹងអ្វី អមាត្យទូលថា បពិត្រព្រះអង្គ ឈ្មោះអារវបច្ឆានទី ព្រះរាជាត្រាស់ថា នែបាទាំងឡាយ ស្ទឹងនេះមានប្រមាណប៉ុនណា អមាត្យទូលថា បពិត្រព្រះអង្គ ដោយជម្រៅ ១ គាវុត ដោយទទឹង ២ គាវុត ព្រះរាជាត្រាស់ថា ក្នុងស្ទឹងនេះ ទូក ឬក្បូនមានដែរឬទេ អមាត្យទូលថា មិនមានទេ ព្រះអង្គ ព្រះរាជាត្រាស់ថា កាលយើងទាំងឡាយរវល់តែរកយាន មានទូកជាដើម ជាតិរមែងនាំទៅកាន់ជរា ជរារមែងនាំទៅកាន់មរណៈ ខ្ញុំមិនមានសេចក្តីសង្ស័យ ចេញបួសឧទ្ទិសចំពោះព្រះរតនត្រ័យ ដោយអានុភាពនៃព្រះរតនត្រ័យនោះ ទឹកនេះ កុំបីដូចជាទឹកឡើយ ដូច្នេះហើយ ទ្រង់រឭកដល់គុណព្រះរតនត្រ័យ រឭកដល់ពុទ្ធានុស្សតិថា ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ជាព្រះអរហត្តសម្មាសម្ពុទ្ធ ដោយហេតុឈ្មោះនេះជាដើម មួយអន្លើដោយបរិវារ យាងទៅលើផ្ទៃទឹកដោយសេះមួយពាន់ ។ សេះសន្ធពទាំងឡាយ ក៏រត់ទៅដូចរត់លើផែនថ្ម ចុងក្រចក ក៏មិនសើម ។

ព្រះរាជាឆ្លងស្ទឹងហើយ យាងទៅខាងមុខទតឃើញស្ទឹងដទៃទៀត ទើបត្រាស់សួថា ស្ទឹងនេះឈ្មោះអ្វី អមាត្យទូលថា បពិត្រព្រះអង្គ ស្ទឹងនេះឈ្មោះ

នីលវាហនាទទី ព្រះរាជាត្រាស់ថា ស្ទឹងនេះមានប្រមាណប៉ុន្មាន អមាត្យទូលថា បពិត្រព្រះអង្គ ជម្រៅក្តី ទទឹងក្តី ប្រមាណកន្លះយោជន៍ ។ ពាក្យដ៏សេស ដូចគ្នានឹងពាក្យមុននោះឯង ។

ព្រះរាជាទតឃើញទឹកនោះហើយ ទ្រង់រឭកដល់ធម្មានុស្សតិថា ព្រះធម៌ដែលព្រះដ៏មានព្រះភាគត្រាស់ល្អហើយជាដើម ទ្រង់យាងទៅហើយ ។ កាលទ្រង់ឆ្លងស្ទឹងនោះទៅបានហើយ ទតឃើញស្ទឹងដទៃទៀត ទើបត្រាស់សួរថា ស្ទឹងនេះឈ្មោះអ្វី អមាត្យទូលថា បពិត្រព្រះអង្គ ស្ទឹងនេះឈ្មោះចន្ទភាគានទី ព្រះរាជាត្រាស់ថា ស្ទឹងនេះមានប្រមាណប៉ុន្មាន អមាត្យទូលថា បពិត្រព្រះអង្គ ជម្រៅក្តី ទទឹងក្តី ប្រមាណមួយយោជន៍ ពាក្យដ៏សេសដូចគ្នានឹងពាក្យមុននោះឯង ។

ព្រះរាជាទ្រង់ទតឃើញស្ទឹងនេះហើយ ទ្រង់រឭកដល់សង្ឃានុស្សតិថា ព្រះសង្ឃជាសាវ័ករបស់ព្រះដ៏មានព្រះភាគ ជាអ្នកបដិបត្តិល្អហើយជាដើម យាងទៅហើយ ។ កាលទ្រង់ឆ្លងទឹកនោះទៅ បានទតឃើញឆព្វណ្ណរង្សីដែលផ្សាយចេញអំពីសរីរៈរបស់ព្រះសាស្តា មែកឈើក្តី ប្រគាបក្តី ស្លឹកក្តីនៃដើមនិគ្រោធ ហាក់បីដូចជាវិចិត្រដោយមាស ។

ព្រះរាជាទ្រង់ព្រះតម្រិះថា ពន្លឺនេះមិនមែនពន្លឺព្រះចន្ទ មិនមែនពន្លឺព្រះអាទិត្យ មិនមែនពន្លឺនៃទេវតា មារ ព្រហ្ម នាគ គ្រុឌជាដើមណាមួយឡើយ អញឧទ្ទិសចំពោះព្រះសាស្តាហើយមក នេះពិតជាព្រះមហាគោតមសម្ពុទ្ធ ទ្រង់ឃើញហើយដោយពិត ។ ក្នុងរំពេចនោះឯង ទ្រង់ចុះអំពីខ្នងសេះ ឱនព្រះសរីរៈ

ចូលទៅគាល់ព្រះសាស្តាតាមខ្សែព្រះរស្មី ស្តេចចូលទៅខាងក្នុងនៃព្រះពុទ្ធរស្មី ហាក់បីដូចមុជចុះទៅក្នុងមនោសិលារស ថ្វាយបង្គំព្រះសាស្តាហើយ ប្រថាប់គង់ក្នុងចំណែកម្ខាង មួយអន្លើដោយអមាត្យមួយពាន់ ។

ព្រះសាស្តា ទ្រង់សម្តែងអនុបុព្វីកថាហើយ ក្នុងកាលចប់ទេសនា ព្រះរាជា មួយអន្លើដោយបរិវារ តាំងនៅហើយក្នុងសោតាបត្តិផល ។ លំដាប់នោះ ជនទាំងអស់នោះក្រោកឡើង ទូលសូមបព្វជ្ជាហើយ ។

ព្រះសាស្តាទ្រង់ពិចារណាថា បាត្រ ចីវរ សម្រេចដោយឫទ្ធិរបស់កុលបុត្រទាំងនេះនឹងមកឬហ្ន៎ ទ្រង់ជ្រាបថា កុលបុត្រទាំងនេះបានឲ្យចីវរមួយពាន់ផ្ទាំង ដល់ព្រះបច្ចេកពុទ្ធមួយពាន់អង្គ ក្នុងកាលព្រះពុទ្ធព្រះនាមកស្សបៈ បានថ្វាយចីវរ ២ ម៉ឺន ដល់ភិក្ខុ ២ ម៉ឺនរូប ការមកនៃបាត្រ និងចីវរដែលសម្រេចដោយឫទ្ធិរបស់កុលបុត្រទាំងនេះ មិនគួរអស្ចារ្យឡើយ ដូច្នេះហើយ ទ្រង់លាព្រះហស្តស្តាំត្រាស់ថា ចូរអ្នកទាំងឡាយមកជាភិក្ខុចុះ ចូរអ្នកទាំងឡាយប្រព្រឹត្តព្រហ្មចរិយៈ ដើម្បីធ្វើទីបំផុតទុក្ខដោយប្រពៃចុះ ។ រំពេចនោះឯងកុលបុត្រទាំងនោះហាក់បីដូចជាព្រះថេរៈមានវស្សាមួយរយ ទ្រទ្រង់នូវបរិក្ខារ ៨ ហោះ ឡើងកាន់វេហាស៍ ត្រឡប់មកថ្វាយបង្គំព្រះសាស្តា គង់នៅហើយ ។

ចំណែកឈ្នួញទាំងនោះ ទៅកាន់រាជត្រកូលហើយ ឲ្យភ្នាក់ងារក្រាបទូលដំណឹងដែលព្រះរាជាបញ្ជូនទៅ កាលព្រះទេវីប្រាប់ថា ចូលមកចុះ ក៏ចូលទៅថ្វាយបង្គំហើយ បានឈរនៅក្នុងចំណែកម្ខាង ។ គ្រានោះ ព្រះទេវីត្រាស់សួរឈ្នួញទាំងនោះថា នែបាទាំងឡាយ ពួកអ្នកមកព្រោះហេតុអ្វី ឈ្នួញទូល

ថា ព្រះរាជាទ្រង់បញ្ជូនពួកទូលបង្គំដោយន័យថា សូមព្រះរាជទានទ្រព្យ ៣ សែន ដល់ពួកទូលបង្គំ ។

ព្រះទេវីពោលថា នែបាទាំងឡាយ ពួកអ្នកពោលច្រើនពេក ពួកអ្នកបានធ្វើអ្វីដល់ព្រះរាជា ព្រះរាជាជ្រះថ្លាក្នុងអ្វីរបស់ពួកអ្នក ទើបបញ្ជាឲ្យព្រះរាជទានទ្រព្យមានប្រមាណដល់ម៉្លេះ ឈ្មួញទូលថា បពិត្រព្រះនាង អ្វីដទៃពួកទូលបង្គំមិនបានធ្វើទេ តែពួកទូលបង្គំបានក្រាបទូលដំណឹងដល់ព្រះរាជា ។ ព្រះទេវីពោលថា នែបាទាំងឡាយ ពួកអ្នកអាចប្រាប់ដល់យើងបានដែរឬទេ ឈ្មួញពោលថា បពិត្រព្រះនាង បាន ព្រះទេវីពោលថា នែបាទាំងឡាយ បើដូច្នោះចូរពួកអ្នកប្រាប់មកចុះ ។ ឈ្មួញទូលថា បពិត្រព្រះនាង ព្រះពុទ្ធកើតឡើងហើយក្នុងលោក ។

សុម្បីព្រះទេវី ព្រះនាងស្តាប់ពាក្យនោះហើយ មានព្រះសរីរៈដែលបីតិពាល់ត្រូវហើយ ដោយន័យមុននោះឯង ព្រះនាងកំណត់អ្វីមួយមិនបាន អស់វារៈ ៣ ដង ក្នុងវារៈទី ៤ ព្រះនាងស្តាប់បទថា **ពុទ្ធោ** ហើយ ទើបត្រាស់ថា នែបាទាំងឡាយ ព្រោះបទនេះព្រះរាជាព្រះរាជទានអ្វី ឈ្មួញទូលថា បពិត្រព្រះនាង ទ្រព្យមួយសែន ព្រះទេវីពោលថា នែបាទាំងឡាយ ព្រះរាជាទ្រង់ស្តាប់ដំណឹងបែបនេះហើយ ព្រះរាជទានទ្រព្យមួយសែន ដល់ពួកអ្នកទាំង-ឡាយ ឈ្មោះថា ធ្វើមិនសមគ្នាសោះ តែខ្ញុំនឹងឲ្យពួកអ្នក ៣ សែន ចាត់ជារង្វាន់តិចតួចរបស់ខ្ញុំ ដំណឹងអ្វីទៀតដែលអ្នកទាំងឡាយទូលហើយ ។ ឈ្មួញទាំងនោះក្រាបទូលដំណឹងពីរយ៉ាងដទៃទៀតថា ដំណឹងយ៉ាងនេះ ដំណឹង

យ៉ាងនេះ ។

ព្រះទេវីមានព្រះសរីរៈ ដែលបីតិពាល់ត្រូវហើយដោយន័យមុននោះឯង ព្រះនាងកំណត់អ្វីមួយមិនបាន អស់កាល ៣ ដង ក្នុងគ្រាទី ៤ ទ្រង់ស្តាប់យ៉ាងនោះដូចគ្នាហើយ ព្រះនាងបញ្ជាឲ្យព្រះរាជទានទ្រព្យម្តង ៣ សែន ។ ឈ្មួញទាំងនោះ បានទ្រព្យទាំងអស់ ១២ សែន ដោយប្រការដូច្នេះ ។

លំដាប់នោះ ព្រះទេវីត្រាស់សួរឈ្មួញទាំងនោះថា នែបាទាំងឡាយ ព្រះរាជាយាងទៅណា ឈ្មួញពោលថា បពិត្រព្រះនាង ព្រះរាជាទ្រង់ត្រាស់ថា ខ្ញុំនឹងបួសឧទ្ទិសចំពោះព្រះសាស្តាយាងទៅហើយ ព្រះទេវីត្រាស់ថា ដំណឹងអ្វីដែលទ្រង់ព្រះរាជទានដល់ខ្ញុំ ឈ្មួញទូលថា ព្រះរាជាទ្រង់លះភាពជាធំថ្វាយដល់ព្រះនាង សូមព្រះនាងសោយសម្បត្តិតាមបំណងចុះ ។

ព្រះទេវីត្រាស់ថា នែបា ពួកអមាត្យទៅណា ឈ្មួញទូលថា បពិត្រព្រះនាង អមាត្យទាំងនោះពោលថា ខ្ញុំនឹងបួសជាមួយព្រះរាជាដូចគ្នា ហើយក៏ទៅ ។ ព្រះនាងត្រាស់ឲ្យហៅភរិយារបស់អមាត្យទាំងនោះមកហើយ ត្រាស់ថា នែនាងទាំងឡាយ ប្តីរបស់ពួកនាងពោលថា អញនឹងបួសជាមួយព្រះរាជាហើយ ក៏ទៅ ពួកនាងនឹងធ្វើដូចម្តេច ស្រីទាំងនោះទូលថា បពិត្រព្រះនាង ដំណឹងអ្វី ដែលពួកគេបញ្ជូនមកដើម្បីពួកខ្ញុំម្ចាស់ ព្រះទេវីត្រាស់ថា បានឮថា អមាត្យទាំងនោះ លះបង់សម្បត្តិរៀងៗ ខ្លួនដល់ពួកនាងហើយ បានឮថា ចូរពួកនាងបរិភោគសម្បត្តិនោះតាមគាប់ចិត្តចុះ ។ ស្រីទាំងនោះទូលថា ព្រះនាងគិតធ្វើដូចម្តេច ព្រះទេវីពោលថា នែនាងទាំងឡាយ ដំបូង ព្រះរាជា

ទ្រង់ស្តាប់ដំណឹងហើយ ប្រថាប់ឈរក្នុងវាំងផ្លូវនោះឯង ទ្រង់បូជាព្រះរតន-ត្រ័យដោយទ្រព្យ ៣ សែន ទ្រង់លះបង់សម្បត្តិដូចដុំទឹកមាត់ ត្រាស់ថា ខ្ញុំនឹងបួស ហើយយាងចេញទៅ ចំណែកខ្ញុំបានស្តាប់ដំណឹងព្រះរតនត្រ័យហើយ បូជាព្រះរតនត្រ័យ ដោយទ្រព្យ ៩ សែន ឈ្មោះថា សម្បត្តិនេះមិនបាននាំទុក្ខមកដល់ព្រះរាជាប៉ុណ្ណោះ រមែងជាហេតុនាំទុក្ខមកដល់ខ្ញុំដូចគ្នា បុគ្គលណានឹងលុតជង្គង់ទទួលយកដុំទឹកមាត់ដែលព្រះរាជា ទ្រង់ស្តោះហើយដោយមាត់នោះ ខ្ញុំមិនត្រូវការដោយសម្បត្តិ ឯខ្ញុំក៏នឹងទៅបួសឧទ្ទិសព្រះសាស្តាដែរ ។

ស្រីទាំងនោះទូលថា បពិត្រព្រះនាង សូម្បីពួកខ្ញុំម្ចាស់ក៏នឹងបួសជាមួយព្រះនាងដូចគ្នា ព្រះទេវីត្រាស់ថា នែនាង បើពួកនាងអាចក៏ជាការល្អ ស្រីទាំងនោះទូលថា បពិត្រព្រះនាង ខ្ញុំម្ចាស់អាច ព្រះទេវីត្រាស់ថា បើដូច្នោះ ចូរនាងមក ដូច្នេះហើយ បញ្ជាឲ្យទឹមរថមួយពាន់ ព្រះនាងឡើងរថចេញទៅជាមួយស្រីទាំងនោះ ទតឃើញស្តេចខ្សែទីមួយក្នុងវាំងផ្លូវ ត្រាស់សួរដូចព្រះរាជាត្រាស់សួរហើយដូចគ្នា ព្រះនាងស្តាប់ការប្រព្រឹត្តទៅទាំងអស់ហើយត្រាស់ថា ចូរពួកនាងមើលផ្លូវដែលយាងទៅរបស់ព្រះរាជា ស្រីទាំងនោះក្រាបទូលថា ពួកខ្ញុំម្ចាស់មិនឃើញស្នាមជើងសេះសន្ធពទេព្រះនាង នាងក៏ត្រិះរិះថា ព្រះរាជាទ្រង់ពិតជាធ្វើសច្ចកិរិយាថា ខ្ញុំចេញបួសឧទ្ទិសព្រះរតនត្រ័យ ហើយយាងទៅសូម្បីខ្ញុំក៏ចេញបួសឧទ្ទិសព្រះរតនត្រ័យ ដោយអានុភាពនៃព្រះរតនៈទាំងនោះឯង សូមទឹកនេះកុំដូចជាទឹកឡើយ ដូច្នេះហើយ ព្រះនាងរឭកដល់គុណព្រះ

វតនត្រ័យ បញ្ជូនវេជមួយពាន់ទៅ ទឹកក៏ហាក់ដូចជាផ្ទាំងថ្ម ចុងនៃក្លៅរទេះ និងខ្នងកង់នៃរថក៏មិនសើមឡើយ ។ ព្រះនាងឆ្លងស្ទឹងទាំងពីរក្រៅអំពីនេះទៅបាន ដោយឧបាយនោះដូចគ្នា ។

ព្រះសាស្តាទ្រង់ជ្រាបការយាងមករបស់ព្រះទេវី ទ្រង់បានធ្វើដោយប្រការដែលភិក្ខុទាំងឡាយ អង្គុយក្នុងសម្នាក់របស់ព្រះអង្គមិនឲ្យប្រាកដ ។ ព្រះទេវីកំពុងយាងទៅ ទតឃើញព្រះរស្មី ផ្សាយចេញអំពីព្រះសរីរៈរបស់ព្រះសាស្តា ព្រះនាងត្រិះរិះយ៉ាងនោះដូចគ្នា ហើយយាងចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយ ប្រថាប់ឈរក្នុងចំណែកម្ខាង ទូលសួរថា បពិត្រព្រះអង្គ ព្រះមហាកប្បិនយាងចេញបួសឧទ្ទិសចំពោះព្រះអង្គ ទ្រង់ប្រហែលជាយាងមកក្នុងទីនេះហើយ ព្រះរាជាប្រថាប់នៅឯណា ទ្រង់មិនបង្ហាញដល់ពួកខ្ញុំម្ចាស់ទេឬ ។

ព្រះសាស្តាត្រាស់ថា ចូរនាងទាំងឡាយអង្គុយសិន នឹងឃើញព្រះរាជាក្នុងទីនេះឯង ។ ស្រីទាំងអស់នោះ មានចិត្តត្រេកអរហើយ អង្គុយដោយគិតថា ពួកយើងអង្គុយក្នុងទីនោះឯង នឹងឃើញពួកស្វាមី ។

ព្រះសាស្តា ត្រាស់អនុបុព្វីកថាហើយ ក្នុងពេលចប់ទេសនា ព្រះនាងអនោជាទេវី មួយអន្លើដោយបរិវារ សម្រេចសោតាបត្តិផលហើយ ។

ព្រះមហាកប្បិនត្ថេរ មួយអន្លើដោយបរិវារស្តាប់ព្រះធម្មទេសនា ដែលព្រះសាស្តាទ្រង់ពន្រឹកដល់ស្រីទាំងនោះហើយ ក៏បានសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ ។ ក្នុងខណៈនោះ ព្រះសាស្តាទ្រង់បង្ហាញភិក្ខុទាំងនោះ ដែលសម្រេចអរហត្តហើយ ដល់ស្រីទាំងនោះ ។

បានឮថា ក្នុងខណៈដែលស្រីទាំងនោះមកអង្គុយនោះឯង ចិត្តរបស់នាង មិនមានអារម្មណ៍តែមួយ ព្រោះឃើញប្តីរៀងៗខ្លួន ដែលទ្រទ្រង់សំពត់ជ្រលក់ ដោយទឹកអម្ចត់ មានក្បាលត្រងោល ព្រោះហេតុនោះ ស្រីទាំងនោះមិនអាច សម្រេចមគ្គផលបាន ព្រោះដូច្នោះ ក្នុងពេលស្រីទាំងនោះតាំងមាំនៅក្នុងសទ្ធា ដែលមិនញាប់ញ័រហើយ ទើបព្រះសាស្តាទ្រង់បង្ហាញភិក្ខុទាំងនោះដែលសម្រេច ព្រះអរហត្តហើយ ដល់ស្រីទាំងនោះ ។ ស្រីទាំងនោះ ឃើញភិក្ខុទាំងនោះ ហើយ នមស្ការដោយបញ្ចង្គប្រតិស្ឋានហើយពោលថា បពិត្រលោកម្ចាស់ កិច្ច បព្វជិតរបស់លោកម្ចាស់ទាំងឡាយ ដល់ទីបំផុតមុន ដូច្នេះហើយ ថ្វាយបង្គំ ព្រះសាស្តា ឈរនៅក្នុងចំណែកម្ខាង ហើយទូលសូមបព្វជ្ជា ។

អាចារ្យពួកខ្លះពោលថា បានឮថា កាលស្រីទាំងនោះក្រាបទូលយ៉ាងនោះ ហើយ ព្រះសាស្តាទ្រង់ត្រិះរិះឲ្យព្រះនាងឧប្បលវណ្ណាថេរីនិមន្តមក ។

ព្រះសាស្តាត្រាស់នឹងឧបាសិកាទាំងនោះថា នាងទាំងឡាយគប្បីទៅកាន់ ក្រុងសាវត្ថី បព្វជ្ជាក្នុងសម្នាក់នៃពួកភិក្ខុនីចុះ ។ ឧបាសិកាទាំងនោះ ត្រាច់ចារិក ទៅដោយលំដាប់ មានសក្ការៈ និងការគោរពរាប់អាន ដែលមហាជននាំមក ក្នុងរវាងផ្លូវ ធ្វើដំណើរទៅដោយជើងអស់ចម្ងាយផ្លូវ ១២០ យោជន៍ បួស ក្នុងសម្នាក់នៃភិក្ខុនី បានសម្រេចអរហត្តហើយ ។ ព្រះសាស្តា ទ្រង់ក៏បាននាំ ភិក្ខុមួយពាន់រូប យាងទៅកាន់វត្តជេតពនតាមអាកាសនោះឯង ។

បានឮថា ក្នុងភិក្ខុទាំងនោះ ព្រះមហាកប្បិនត្រាច់បន្លឺឧទានក្នុងទីទាំង-ឡាយ មានទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃថា សុខហ្ន៎ សុខហ្ន៎

ភិក្ខុទាំងឡាយក្រាបទូលដល់ព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គ ព្រះមហាកប្បិនបន្លឺឧទានថា សុខំ សុខំ លោកប្រហែលជាប្រារព្ធសុខក្នុងរាជ-សម្បត្តិរបស់ខ្លួន ។

ព្រះសាស្តា ត្រាស់ឲ្យហៅព្រះមហាកប្បិននោះមកហើយ ត្រាស់សួរថា ម្នាលកប្បិន បានឮថា អ្នកបន្លឺឧទានប្រារព្ធសុខក្នុងកាម សុខក្នុងរាជសម្បត្តិ ពិតឬ ព្រះមហាកប្បិនទូលថា បពិត្រព្រះអង្គ ព្រះអង្គក៏ទ្រង់ជ្រាបការបន្លឺ ឬមិនបន្លឺប្រារព្ធកាមសុខ ក្នុងរាជសុខនោះ របស់ខ្ញុំព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុត្ររបស់តថាគត រមែងបន្លឺឧទានប្រារព្ធសុខក្នុងកាម សុខក្នុងរាជសម្បត្តិក៏មិនមែន តែការឆ្អែតក្នុងធម៌ រមែងកើតឡើងដល់បុត្ររបស់តថាគត បុត្ររបស់តថាគតនោះ រមែងបន្លឺឧទានយ៉ាងនោះ ព្រោះប្រារព្ធអមតមហានិព្វាន ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**ធម្មប្បីតិ សុខំ សេតិ    វិប្បសន្នេន ចេតសា**
**អរិយប្បវេទិតេ ធម្មេ    សទា រមតិ បណ្ឌិតោ ។**

បណ្ឌិត ដែលមានសេចក្តីឆ្អែតក្នុងធម៌ មានចិត្តជ្រះថ្លា
ហើយ រមែងដេកជាសុខ រមែងត្រេកអរក្នុងធម៌ ដែល
ព្រះអរិយៈប្រកាសទុកហើយគ្រប់ពេល ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ធម្មប្បីតិ** សេចក្តីថា ជាអ្នកឆ្អែតក្នុងធម៌

អធិប្បាយថា ជាអ្នកផឹកនូវធម៌ ។ ឈ្មោះថា ព្រះធម៌នេះ បុគ្គលណាម្នាក់ មិនអាចនឹងផឹកបានដូចទឹក ឬបបរជាដើមដោយភាជនៈ ដូច្នោះ បុគ្គលពាល់ត្រូវលោកុត្តរធម៌ ៩ យ៉ាងដោយនាមកាយ ធ្វើឲ្យជាក់ច្បាស់ដោយភាពជាអារម្មណ៍ ចាក់ធ្លុះនូវអរិយសច្ច មានទុក្ខជាដើមដោយកិច្ច មានការសម្រេចធម៌ដោយការកំណត់ដឹងជាដើម ឈ្មោះថា រមែងផឹកនូវធម៌ ។

ពាក្យថា **សុខំ សេតិ** នេះ ត្រឹមតែជាមាតិកានៃទេសនា អធិប្បាយថា រមែងនៅជាសុខដោយឥរិយាបថ ៤ ។ បទថា **វិប្បសន្នេន** គឺមិនល្អក់កករ បានដល់ មិនមានឧបក្កិលេស ។

បទថា **អរិយប្បវេទិតេ** សេចក្តីថា ក្នុងពោធិបក្ខិយធម៌ មានសតិប្បដ្ឋានជាដើម ដែលព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើមប្រកាសហើយ ។

ពីរបទថា **សទា រមតិ** សេចក្តីថា បណ្ឌិតដែលល្អក្នុងធម៌បែបនោះ មានចិត្តផូរផង់មកតាមព្រមហើយ ដោយភាពជាបណ្ឌិត រមែងត្រេកអរ គឺរមែងសរសើរគ្រប់កាល ។

ក្នុងកាលចប់ទេសនា មហាជនបានជាព្រះអរិយបុគ្គល មានព្រះសោតាបន្នជាដើមហើយ ដូច្នេះឯង ។ល។

**រឿង ព្រះមហាកប្បិនត្ថេរ ចប់**

# រឿង បណ្ឌិតសាមណេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបណ្ឌិតសាមណេរ ត្រាស់ព្រះធម្មទេសនានេះថា **ឧទកំ ហិ នយន្តិ** ជាដើម ។

បានឮមកថា ក្នុងអតីតកាល ព្រះសម្មាសម្ពុទ្ធព្រះនាមកស្សបៈ មានព្រះខីណាស្រព ២ ម៉ឺនរូបជាបរិវារ បានយាងទៅកាន់ក្រុងពារាណសី មនុស្សទាំងឡាយកំណត់កម្លាំងរៀងៗ ខ្លួនហើយ រួមគ្នា ៨ នាក់ខ្លះ ១០ នាក់ខ្លះ បានថ្វាយអាគន្តុកទានហើយ ។

តមកថ្ងៃមួយ ក្នុងកាលដែលស្រេចភត្តកិច្ច ព្រះសាស្តាទ្រង់បានធ្វើអនុមោទនាយ៉ាងនេះថា ឧបាសក ឧបាសិកាទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ គិតថា អញឲ្យរបស់ខ្លួនប៉ុណ្ណោះគួរ ប្រយោជន៍អ្វីដោយការបបួលអ្នកដទៃ ដូច្នេះហើយ ទើបឲ្យទានដោយខ្លួនឯងប៉ុណ្ណោះ មិនបបួលអ្នកដទៃ បុគ្គលនោះ រមែងបានភោគសម្បត្តិ មិនបានបរិវារសម្បត្តិក្នុងទីដែលខ្លួនកើតហើយ បុគ្គលខ្លះ បបួលអ្នកដទៃ ខ្លួនឯងមិនឲ្យ រមែងបានបរិវារសម្បត្តិ មិនបានភោគសម្បត្តិ ក្នុងទីដែលខ្លួនកើតហើយ ។ បុគ្គលខ្លះមិនបានឲ្យដោយខ្លួនឯង មិនបានបបួលអ្នកដទៃ បុគ្គលនោះរមែងមិនបានភោគសម្បត្តិ មិនបានបរិវារសម្បត្តិ ជាអ្នកស៊ីដែល ញ៉ាំងជីវិតឲ្យរស់នៅក្នុងទីដែលខ្លួនកើតហើយ ។ បុគ្គលខ្លះ ខ្លួនឯងឲ្យទានផង បបួលអ្នកដទៃផង បុគ្គលនោះ រមែងបាននូវភោគសម្បត្តិផង បាននូវបរិវារសម្បត្តិផង ក្នុងទីដែលខ្លួនកើតហើយ ។

បុរសបណ្ឌិតម្នាក់ឈរក្នុងទីជិត បានស្តាប់អនុមោទនាកថានោះហើយ គិតថា ឥឡូវនេះ អញនឹងធ្វើឲ្យសម្បត្តិទាំងពីរមានដល់អញ អញនឹងថ្វាយបង្គំព្រះសាស្តាហើយក្រាបទូលថា ស្អែកនេះ សូមទ្រង់ទទួលភិក្ខារបស់ខ្ញុំព្រះអង្គ ។

ព្រះសាស្តាទ្រង់ត្រាស់ថា តើអ្នកត្រូវការភិក្ខុប៉ុន្មាន បណ្ឌិតបុរសទូលថា បរិវាររបស់ព្រះអង្គមានប៉ុន្មាន ព្រះសាស្តាត្រាស់ថា មានភិក្ខុ ២ ម៉ឺនរូប ។ បណ្ឌិតបុរសពោលថា បពិត្រព្រះអង្គ ស្អែកនេះ សូមទ្រង់ មួយអន្លើដោយភិក្ខុទាំងអស់ ទ្រង់ទទួលភិក្ខារបស់ខ្ញុំព្រះអង្គ ។

ព្រះសាស្តា ទ្រង់ទទួលនិមន្តហើយ បុរសនោះចូលទៅកាន់ស្រុកហើយដើរប្រាប់បុណ្យថា បពិត្រអ្នកម៉ែ និងលោកឪពុកទាំងឡាយ ស្អែកនេះ ខ្ញុំនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដើម្បីទទួលភិក្ខា អ្នកទាំងឡាយ ចូរប្រគេនដល់ភិក្ខុតាមចំនួនដែលអាច ។ កាលជនទាំងឡាយ កំណត់កម្លាំង រៀងៗ ខ្លួនហើយពោលថា ពួកយើងនឹងប្រគេន ១០ រូប ពួកយើងនឹងប្រគេន ២០ រូប ពួកយើងនឹងប្រគេន ១០០ រូប ពួកយើងនឹងប្រគេន ៥០០ រូប ដូច្នេះហើយ ទើបកត់ពាក្យរបស់ជនទាំងឡាយក្នុងបញ្ជី តាំងពីដើមមក ។

សម័យនោះ ក្នុងនគរនោះ មានបុរសម្នាក់ប្រាកដឈ្មោះថា មហាទុគ្គតៈ ព្រោះជាអ្នកក្រីក្រពន់ពេក ។ បុរសបណ្ឌិតនោះ ឃើញជនក្រីក្រនោះមកចំពោះមុខ ទើបប្រាប់ថា នែទុគ្គតៈសម្លាញ់ ខ្ញុំបាននិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដើម្បីឆាន់ក្នុងថ្ងៃស្អែកនេះ ស្អែកនេះ អ្នកស្រុកនឹងថ្វាយ

ទាន អ្នកអង្គាសភិក្ខុប៉ុន្មានរូប មហាទុគ្គតៈពោលថា ឱ ! អ្នក ខ្ញុំត្រូវការអ្វី ដោយភិក្ខុទាំងនោះ ឈ្មោះថា ការត្រូវការភិក្ខុ ជារបស់អ្នកមានទ្រព្យ ឯខ្ញុំ គ្រាន់តែអង្ករមួយនាឡិ ដើម្បីប្រយោជន៍ដល់បបរក្នុងស្អែកនេះក៏មិនមាន ខ្ញុំ ធ្វើការងារស៊ីឈ្នួលចិញ្ចឹមជីវិត ខ្ញុំត្រូវការអ្វីដោយភិក្ខុ ។

ធម្មតាអ្នកបបួល គប្បីជាអ្នកឈ្លាស ព្រោះដូច្នោះ បុរសបណ្ឌិតនោះ កាលមហាទុគ្គតៈពោលថា មិនមាន ក៏មិនស្ងៀម នៅតែពោលយ៉ាងនេះថា មហាទុគ្គតៈសម្លាញ់ មនុស្សជាច្រើនក្នុងក្រុងនេះ បរិភោគភោជនយ៉ាងល្អ ស្លៀកសំពត់សាច់ម៉ដ្ឋ តែងខ្លួនដោយគ្រឿងអាភរណៈផ្សេងៗ ដេកលើដំណេក ដ៏ប្រសើរ រមែងសោយសម្បត្តិ ចំណែកអ្នកធ្វើការស៊ីឈ្នួលអស់ថ្ងៃ ក៏មិន បានអាហារពេញពោះ កាលបើដូច្នេះ អ្នកនៅមិនដឹងថា អញមិនបានអ្វីមួយ ព្រោះមិនបានធ្វើបុណ្យណាមួយក្នុងកាលមុន មហាទុគ្គតៈពោលថា ខ្ញុំដឹង ហើយអ្នក បណ្ឌិតបុរសពោលថា បើដូច្នោះ ហេតុអ្វី ឥឡូវនេះ ទើបអ្នកមិន ធ្វើបុណ្យ អ្នកនៅជាកំលោះ មានកម្លាំងកំហែងបរិបូណ៌ អ្នកធ្វើការស៊ីឈ្នួល ហើយ ឲ្យទានតាមកម្លាំងមិនគួរឬ ។ មហាទុគ្គតៈនោះ កាលបណ្ឌិតបុរស កំពុងពោលដល់នូវសេចក្តីសង្វេគ ទើបពោលថា ចូរអ្នកចុះបញ្ជីភិក្ខុឲ្យខ្ញុំបាន មួយរូប ខ្ញុំនឹងធ្វើការងារស៊ីឈ្នួលណាមួយ ហើយនឹងប្រគេនភិក្ខាដល់ភិក្ខុ មួយរូប ។ បុរសបណ្ឌិតនោះគិតថា ភិក្ខុមួយរូប នឹងកត់ចូលក្នុងបញ្ជីធ្វើអ្វី ដូច្នេះហើយ ទើបមិនកត់ចូល ។

ចំណែកមហាទុគ្គតៈ ទៅកាន់ផ្ទះហើយ និយាយនឹងភរិយាថា នែនាង

ស្អែកនេះ អ្នកស្រុកគេរៀបចំភត្តដើម្បីសង្ឃ ខ្ញុំត្រូវគេបបួលថា ចូរថ្វាយភិក្ខាដល់ភិក្ខុមួយរូប ពួកយើងនឹងថ្វាយភិក្ខាដល់ភិក្ខុមួយរូបក្នុងថ្ងៃស្អែកនេះ លំដាប់នោះ ភរិយារបស់គាត់មិនពោលថា ពួកយើងជាអ្នកក្រ អ្នកទទួលពាក្យគេធ្វើអ្វី តែពោលថា នែអ្នក អ្នកធ្វើល្អហើយ កាលមុនយើងមិនឲ្យវត្ថុណាមួយ ទើបជាតិនេះកើតជាមនុស្សក្រីក្រ យើងទាំងពីរនាក់ធ្វើការស៊ីឈ្នួលហើយ នឹងប្រគេនដល់ភិក្ខុមួយរូប ។ ទាំងពីរនាក់បានទៅកាន់ទីស៊ីឈ្នួល ។ មហាសេដ្ឋីឃើញមហាទុគ្គតៈ ទើបសួរថា មហាទុគ្គតៈសម្លាញ់ អ្នកនឹងធ្វើការងារស៊ីឈ្នួលឬ មហាទុគ្គតៈពោលថា បាទ លោកម្ចាស់ មហាសេដ្ឋីពោលថា អ្នកនឹងធ្វើអ្វី មហាទុគ្គតៈពោលថា ស្រេចតែលោកម្ចាស់ឲ្យធ្វើ មហាសេដ្ឋីពោលថា បើយ៉ាងនោះ ស្អែកនេះ ខ្ញុំអង្គាសភិក្ខុ ២-៣ រយរូប ចូរអ្នកពុះអុសចុះ ហើយឲ្យយកកាំបិត និងពូថៅមកឲ្យ ។ មហាទុគ្គតៈពួយយ៉ាងពេញកម្លាំងដល់នូវភាពឧស្សាហ៍ ដាក់កាំបិត ចាប់ពូថៅ បោះពូថៅចាប់កាំបិត ពុះអុសរឿយៗ ទៅ ។

លំដាប់នោះ សេដ្ឋីពោលនឹងមហាទុគ្គតៈថា នែសម្លាញ់ ថ្ងៃនេះ អ្នកខ្នះខ្នែងធ្វើការពន់ពេក មានរឿងអ្វីឬ មហាទុគ្គតៈពោលថា បាទ លោកម្ចាស់ ខ្ញុំអង្គាសភិក្ខុមួយរូប ។

សេដ្ឋីស្តាប់ពាក្យនោះហើយ មានចិត្តជ្រះថ្លា គិតថា គួរជ្រះថ្លាពិតហ្ន៎ មហាទុគ្គតៈនេះ ធ្វើកម្មដែលគេធ្វើបានដោយក្រ បុរសនេះមិនព្រងើយកន្តើយដោយគិតថា អញក្រីក្រ ពោលថា នឹងធ្វើការស៊ីឈ្នួល ហើយអង្គាសភិក្ខុ

មួយរូប ។

ចំណែកកិរិយាសេដ្ឋីឃើញប្រពន្ធរបស់មហាទុគ្គតៈនោះហើយ ក៏សួរថា នែនាង នាងធ្វើការងារអ្វី នាងក៏ឆ្លើយថា ស្រេចតែអ្នកស្រីប្រើឲ្យធ្វើ ទើបចូលទៅកាន់រោងត្បាល់ក្លឿង ហើយប្រគល់គ្រឿងឧបករណ៍ មានចង្អេរ និងអង្រែជាដើមឲ្យហើយ ។ នាងត្រេកអររីករាយ បុកផង ផាត់អង្ករផង ដូចគេរាំល្ខោន ។

លំដាប់នោះ កិរិយាសេដ្ឋីសួរថា នែនាង នាងត្រេកអរក្នុងការងារពន់ពេក មានហេតុអ្វីឬ នាងពោលថា បពិត្រអ្នកស្រី ពួកខ្ញុំធ្វើការស៊ីឈ្នួលហើយ នឹងអង្គាសភិក្ខុមួយរូប ។

ចំណែកកិរិយាសេដ្ឋីស្ដាប់ពាក្យនោះហើយ ជ្រះថ្លាក្នុងនាងថា គួរជ្រះថ្លាហ្ន៎ ស្រីនេះ ធ្វើកម្មដែលគេធ្វើបានដោយក្រ ។

ក្នុងពេលដែលមហាទុគ្គតៈពុះអុសស្រេច សេដ្ឋីប្រើឲ្យគេយកអង្ករស្រូវសាលី ៤ នាឡិមកឲ្យដោយពោលថា នេះថ្លៃឈ្នួលរបស់អ្នក ហើយប្រាប់ឲ្យគេយក ៤ នាឡិមកឲ្យទៀតពោលថា នេះជាចំណែកបន្ថែមព្រោះខ្ញុំត្រេកអរនឹងអ្នក ។

គាត់ទៅកាន់ផ្ទះប្រាប់កិរិយាថា ខ្ញុំស៊ីឈ្នួលបានអង្ករស្រូវសាលីមកចំណែកនេះ នឹងបានជាម្ហូប ចូរនាងកាន់យករបស់ គឺទឹកដោះជូរ ប្រេង និងគ្រឿងទេសដោយតម្លៃ ដែលនាងបានហើយ ។

ចំណែកកិរិយាសេដ្ឋី បានឲ្យសប្បិមួយជប ទឹកដោះជូរមួយក្រឡតូច

មួយអន្ទើដោយគ្រឿងទេស និងអង្ករស្រូវសាលីមួយនាឡិដល់នាង ជនទាំង ពីរមានអង្ករ ៥ នាឡិ ដោយប្រការដូច្នេះ ។

ជនពីរនាក់ប្តីប្រពន្ធត្រេកអរថា យើងបានទេយ្យធម៌ហើយ ក្រោកឡើង អំពីព្រលឹម ភរិយាពោលនឹងមហាទុគ្គតៈថា សូមអ្នកទៅរកបន្លែមកចុះ គាត់ មិនឃើញបន្លែក្នុងផ្សារ ទើបទៅកាន់មាត់ស្ទឹង មានចិត្តត្រេកអរថា នឹងបាន ប្រគេនភោជនដល់លោកម្ចាស់ ស្រែកច្រៀងបណ្តើរ បេះបន្លែបណ្តើរ ។ អ្នក ប្រមង់ឈរបង់សំណាញ់ធំ ដឹងថា ជាសំឡេងរបស់មហាទុគ្គតៈ ទើបហៅ មកសួរថា អ្នកមានចិត្តសប្បាយពន់ពេក ស្រែកច្រៀង មានហេតុអ្វីហ្ន៎ មហា ទុគ្គតៈពោលថា នែសម្លាញ់ ខ្ញុំបេះបន្លែ អ្នកប្រមង់ពោលថា អ្នកបេះបន្លែ ធ្វើអ្វី មហាទុគ្គតៈប្រាប់ថា ខ្ញុំអង្គាសភិក្ខុមួយរូប អ្នកប្រមង់ពោលថា ឱ ! ឆ្អែតឬ ភិក្ខុដែលឆាន់បន្លែរបស់អ្នក មហាទុគ្គតៈពោលថា នែសម្លាញ់ អ្នក ធ្វើអ្វីបាន ខ្ញុំត្រូវអង្គាសភិក្ខុដោយបន្លែដែលបាន អ្នកប្រមង់ពោលថា បើ ដូច្នោះ ចូរអ្នកមកណេះចុះ មហាទុគ្គតៈពោលថា អ្នកនឹងធ្វើអ្វីសម្លាញ់ អ្នក ប្រមង់ពោលថា ចូរកាន់យកត្រីទាំងនេះដោតឲ្យជាចង្កោម ដែលមានតម្លៃ មួយបាតខ្វះ កន្លះបាតខ្វះ មួយកហាបណៈខ្វះ គាត់បានធ្វើយ៉ាងនោះ ។

អ្នកស្រុកទិញត្រីដែលមហាទុគ្គតៈដោតយកទៅ ដើម្បីប្រយោជន៍ដល់ ភិក្ខុដែលខ្លួននិមន្តហើយ កាលគាត់កំពុងដោតត្រីនោះឯង ក៏ដល់ពេលភិក្ខាចារ ហើយ គាត់កំណត់កាលហើយពោលថា នែសម្លាញ់ ខ្ញុំត្រូវទៅហើយ នេះជា ពេលដែលភិក្ខុនិមន្តមក អ្នកប្រមង់ពោលថា ចង្កោមត្រីទាំងនោះនៅមានដែរ

ឬទេ មហាទុគ្គតៈពោលថា មិនមានទេ អស់ហើយសម្លាញ់ អ្នកប្រមង់ពោលថា បើដូច្នោះ ត្រីផ្ចិត ៤ ខ្ញុំកប់ក្នុងខ្សាច់ដើម្បីប្រយោជន៍ដល់ខ្លួន បើអ្នកត្រូវការអង្គាសភិក្ខុ ចូរយកត្រីទាំងនេះទៅចុះ ដូច្នេះហើយ ក៏បានឲ្យត្រីផ្ចិតទាំងនោះដល់មហាទុគ្គតៈ ។

ថ្ងៃនោះ ព្រះសាស្តា ទ្រង់ប្រមើលមើលសត្វលោកក្នុងពោលទៀបភ្លឺ ទ្រង់ឃើញមហាទុគ្គតៈចូលទៅខាងក្នុងសំណាញ់ គឺព្រះញាណរបស់ព្រះអង្គ ទ្រង់អាវជ្ជនៈថា មានហេតុអ្វីហ្ន៎ ទ្រង់ត្រិះរិះថា មហាទុគ្គតៈគិតថា នឹងអង្គាសភិក្ខុមួយរូប ទើបបានធ្វើការស៊ីឈ្នួលជាមួយភរិយាហើយ កាលពីម្សិលមិញ បុរសនេះនឹងបានភិក្ខុរូបណាហ្ន៎ ទ្រង់ពិចារណាថា មនុស្សទាំងឡាយនឹងនាំភិក្ខុទៅតាមឈ្មោះ ដែលខ្លួនកត់ក្នុងបញ្ជីហើយ ឲ្យអង្គុយក្នុងផ្ទះ រៀងៗ ខ្លួន មហាទុគ្គតៈវៀរតជាគតហើយ នឹងមិនបានភិក្ខុដទៃ ។

បានឮថា ព្រះពុទ្ធទាំងឡាយ ទ្រង់រមែងធ្វើសេចក្តីអនុគ្រោះក្នុងពួកមនុស្សក្រីក្រ ព្រោះដូច្នោះ ព្រះសាស្តា ទ្រង់ធ្វើសរីរៈកិច្ចអំពីព្រលឹមហើយ យាងចូលកាន់ព្រះគន្ធកុដិ ប្រថាប់គង់ដោយទ្រង់ព្រះតម្រិះថា នឹងសង្គ្រោះមហាទុគ្គតៈ កាលមហាទុគ្គតៈកំពុងកាន់យកត្រីចូលទៅកាន់ផ្ទះ បណ្ឌុកម្ពលសិលាអាសនៈរបស់សក្កទេវរាជសម្តែងអាការក្តៅ ទ្រង់ពិចារណាថា មានហេតុអ្វីហ្ន៎ ទ្រង់ត្រិះរិះថា ម្សិលមិញនេះ មហាទុគ្គតៈ បានធ្វើការងារស៊ីឈ្នួលជាមួយភរិយារបស់ខ្លួនដោយតាំងចិត្តថា នឹងថ្វាយភិក្ខាដល់ភិក្ខុមួយរូប មហាទុគ្គតៈនឹងបានភិក្ខុរូបណាហ្ន៎ ទ្រង់ជ្រាបថា ភិក្ខុដទៃមិនមានសម្រាប់គេ

តែព្រះសាស្តាប្រថាប់គង់ក្នុងព្រះគន្ធកុដិនោះឯង ដោយតាំងព្រះហឫទ័យថា នឹងសង្គ្រោះមហាទុគ្គតៈ ។ មហាទុគ្គតៈគប្បីថ្វាយបបរ បាយ អន្លក់ និងសម្ល ដូចដែលខ្លួនបរិភោគឯងដល់ព្រះតថាគត បើដូច្នោះ អាត្មាអញ គួរទៅកាន់ផ្ទះ របស់មហាទុគ្គតៈ ធ្វើនាទីជាចុងភៅ ដូច្នេះហើយ ទើបទ្រង់កាឡាខ្លួនមិនឲ្យ អ្នកណាស្គាល់ យាងទៅជិតផ្ទះរបស់មហាទុគ្គតៈនោះ ហើយត្រាស់សួរថា បុគ្គលណាមួយ មានការងារស៊ីឈ្នួលអ្វីខ្លះឬ មហាទុគ្គតៈឃើញសក្កទេវរាជ ហើយ ទើបពោលថា នែសម្លាញ់ អ្នកនឹងធ្វើការអ្វី សក្កៈពោលថា ខ្ញុំចេះ វិជ្ជាការគ្រប់យ៉ាង ឈ្មោះថា អ្វីដែលខ្ញុំមិនចេះ មិនយល់ មិនមានឡើយ ចេះទាំងការចម្អិនបបរ បាយជាដើម ។ មហាទុគ្គតៈពោលថា នែសម្លាញ់ ខ្ញុំត្រូវការដោយការងាររបស់អ្នក តែមិនមានតម្លៃ ដែលគួរឲ្យដល់អ្នក សក្កៈ ពោលថា អ្នកត្រូវការឲ្យខ្ញុំធ្វើអ្វី មហាទុគ្គតៈពោលថា ខ្ញុំបំណងនឹងប្រគេន ភិក្ខាដល់ភិក្ខុមួយរូប បំណងនឹងរៀបចំបបរ បាយ ប្រគេនភិក្ខុនោះ ។ សក្កៈ ពោលថា បើអ្នកប្រគេនដល់ភិក្ខុ ខ្ញុំមិនត្រូវការថ្លៃឈ្នួល មិនគួរឬ មហា-ទុគ្គតៈពោលថា នែសម្លាញ់ បើដូច្នោះ ក៏ជាការល្អ សូមអ្នកចូលមកចុះ ។

សក្កៈនោះ ចូលទៅក្នុងផ្ទះរបស់មហាទុគ្គតៈនោះហើយ ឲ្យយកអង្ករជា ដើមមក ហើយទ្រង់បញ្ជូនមហាទុគ្គតៈនោះទៅដោយពាក្យថា ទៅចុះអ្នក ចូរ នាំភិក្ខុដែលដល់លំដាប់ខ្លួនមក ។

ចំណែកអ្នកចាត់ការទាន បានចែកភិក្ខុទៅកាន់ផ្ទះរបស់ពួកជនទាំងនោះ តាមបញ្ជីដែលកត់នោះឯង ។ មហាទុគ្គតៈទៅកាន់សម្នាក់របស់បុរសនោះ

ហើយពោលថា ចូរឲ្យភិក្ខុដល់ខ្ញុំចុះ គាត់មានស្មារតីឡើងក្នុងខណៈនោះ ទើបពោលថា ខ្ញុំភ្លេចភិក្ខុសម្រាប់អ្នកទៅហើយ មហាទុគ្គតៈហាក់បីដូចត្រូវប្រហារត្រង់ពោះដោយលំពែងដ៏មុត ផ្គងដើមដៃទ្រហោយំថា ហេតុអ្វី ទើបឲ្យខ្ញុំវិនាស ខ្ញុំត្រូវអ្នកបបួលហើយ កាលពីម្សិលមិញ ខ្ញុំ និងភរិយាធ្វើការស៊ីឈ្នួលអស់មួយថ្ងៃ ថ្ងៃនេះ តាំងអំពីព្រលឹម ត្រាច់ទៅត្រង់ប្រាំងស្ងួង ដើម្បីបន្ទៃហើយ ទើបមក សូមអ្នកឲ្យភិក្ខុដល់ខ្ញុំមួយរូបចុះ ។

មនុស្សទាំងឡាយប្រជុំគ្នាហើយសួរថា មហាទុគ្គតៈ តើអ្នកកើតអ្វី ។ គាត់ប្រាប់សេចក្តីនោះ មនុស្សទាំងនោះសួរអ្នកចាត់ការថា នែសម្លាញ់ ពិតឬបានឮថា មហាទុគ្គតៈនេះ អ្នកបបួលថា ចូរធ្វើការស៊ីឈ្នួល ហើយប្រគេនភិក្ខាដល់ភិក្ខុមួយរូប ។

អ្នកចាត់ការពោលថា ត្រូវហើយអ្នក មនុស្សទាំងនោះពោលថា អ្នកចាត់ការភិក្ខុមានប្រមាណប៉ុណ្ណោះ មិនបានឲ្យដល់មហាទុគ្គតៈនេះត្រឹមតែមួយរូប អ្នកធ្វើកម្មធ្ងន់ហើយ ។

បុរសនោះខ្មាសក្នុងចិត្តដោយវាចារបស់មនុស្សទាំងនោះ ទើបនិយាយនឹងមហាទុគ្គតៈនោះថា មហាទុគ្គតៈសម្លាញ់ កុំឲ្យខ្ញុំវិនាសឡើយ ខ្ញុំដល់នូវសេចក្តីលំបាកធំ ព្រោះហេតុនៃអ្នក មនុស្សទាំងឡាយ នាំភិក្ខុដែលដល់លំដាប់ខ្លួនទៅតាមបញ្ជីដែលកត់ ឈ្មោះថា បុគ្គលនឹងដកភិក្ខុដែលអង្គុយក្នុងផ្ទះរបស់ខ្លួនឲ្យ មិនមាន ។ ចំណែកព្រះសាស្តា ទ្រង់ស្រេពព្រះភក្ត្រហើយប្រថាប់គង់នៅក្នុងព្រះគន្ធកុដិនោះឯង ស្តេចផែនដី យុវរាជ និងបុគ្គលធំៗ

មានសេនាបតីជាដើម អន្ទយរង់ចាំការយាងចេញអំពីព្រះគន្ធកុដិនៃព្រះសាស្តា គិតថា នឹងទទួលបាត្ររបស់ព្រះសាស្តាទៅ ធម្មតាព្រះពុទ្ធទាំងឡាយ ទ្រង់រមែងធ្វើសេចក្តីអនុគ្រោះក្នុងមនុស្សក្រីក្រ ចូរអ្នកទៅវិហារក្រាបទូលព្រះសាស្តាថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គជាមនុស្សក្រីក្រ សូមទ្រង់ធ្វើសេចក្តីសង្គ្រោះដល់ខ្ញុំព្រះអង្គចុះ បើអ្នកមានបុណ្យ អ្នកនឹងបានពិត មហាទុគ្គតៈទៅកាន់វិហារហើយ ។

លំដាប់នោះ ស្តេចផែនដី និងយុវរាជជាដើម ត្រាស់នឹងបុរសនោះថា មហាទុគ្គតៈ មិនមែនជាពេលភត្ត អ្នកមកធ្វើអ្វី ព្រោះធ្លាប់ឃើញគាត់ដោយភាពជាអ្នកស៊ីដែលក្នុងវិហារ ក្នុងថ្ងៃដទៃៗ ។ មហាទុគ្គតៈក្រាបទូលថា ទូលបង្គំជ្រាបថា មិនមែនភត្តកាល តែខ្ញុំព្រះអង្គមកដើម្បីថ្វាយបង្គំព្រះសាស្តាដូច្នេះហើយ ទើបឱនក្បាលចុះត្រង់ធរណីទ្វារព្រះគន្ធកុដិ ថ្វាយបង្គំដោយបញ្ចង្គ-ប្រដិស្ឋាន ក្រាបទូលថា អ្នកដែលក្រីក្រជាងខ្ញុំក្នុងនគរនេះ មិនមាន សូមទ្រង់ជាទីពឹងដល់ខ្ញុំព្រះអង្គចុះ សូមទ្រង់ធ្វើសេចក្តីសង្គ្រោះដល់ខ្ញុំព្រះអង្គចុះ ។ ព្រះសាស្តា ទ្រង់បើកទ្វារព្រះគន្ធកុដិ ទ្រង់នាំបាត្រប្រទានក្នុងដៃរបស់មហា-ទុគ្គតៈ គាត់ហាក់ដូចបានជាស្តេចចក្រពត្តិដ៏មានសិរី ស្តេចផែនដី និងយុវរាជជាដើម ទ្រង់សម្លឹងមើលព្រះភក្ត្រគ្នានិងគ្នា ។

ពិតហើយ បុគ្គលណាម្នាក់ ឈ្មោះថា អាចទទួលបាត្រដែលព្រះសាស្តាប្រទានដល់មហាទុគ្គតៈដោយអំណាចភាពជាធំ មិនមាន តែការពោលយ៉ាងនេះថា មហាទុគ្គតៈសម្លាញ់ ចូរអ្នកឲ្យបាត្ររបស់ព្រះសាស្តាដល់ពួកយើង ពួក

យើងនឹងឲ្យទ្រព្យមានប្រមាណប៉ុណ្ណេះ គឺមួយពាន់ ឬមួយសែនដល់អ្នក អ្នកជាបុគ្គលក្រីក្រ ចូរយកទ្រព្យចុះ ប្រយោជន៍អ្វីរបស់អ្នក ដោយបាត្រនោះ មហាទុគ្គតៈឆ្លើយថា ខ្ញុំមិនឲ្យដល់អ្នកណាឡើយ ខ្ញុំមិនត្រូវការដោយទ្រព្យ នឹងឲ្យព្រះសាស្ដាប៉ុណ្ណោះសោយ ។ ជនទាំងឡាយដ៏សេស អង្វរមហាទុគ្គតៈមិនបានបាត្រហើយ ទើបត្រឡប់ទៅ ។

ចំណែកស្ដេចផែនដីទ្រង់ព្រះតម្រិះថា មហាទុគ្គតៈ សូម្បីគេលួងលោមដោយទ្រព្យក៏មិនឲ្យបាត្រព្រះសាស្ដា បុគ្គលណាម្នាក់មិនអាចទទួលបាត្រដែលព្រះសាស្ដាប្រទានហើយដោយព្រះអង្គឯងបាន ទេយ្យធម៌របស់មហាទុគ្គតៈនេះ នឹងមានប្រមាណប៉ុនណា ក្នុងពេលមហាទុគ្គតៈនេះ ថ្វាយទេយ្យធម៌ស្រេច យើងនឹងនាំព្រះសាស្ដាទៅកាន់ព្រះរាជវាំង ថ្វាយអាហារដែលគេរៀបចំសម្រាប់យើង ដូច្នេះហើយ ទើបយាងទៅជាមួយព្រះសាស្ដានោះឯង ។

ចំណែកសក្កទេវរាជរៀបចំភត្តាហារ មានបបរ បាយ និងបន្លែជាដើម ក្រាលអាសនៈដែលសមគួរ ជាទីប្រថាប់នៃព្រះសាស្ដាហើយ ប្រថាប់គង់ ។ មហាទុគ្គតៈនាំព្រះសាស្ដាទៅហើយក្រាបទូលថា សូមទ្រង់យាងចូលព្រះអង្គ ។ ឯផ្ទះដែលជាលំនៅរបស់គាត់ទៀត បុគ្គលដែលមិនឱន មិនអាចចូលទៅបាន តែធម្មតាព្រះពុទ្ធទាំងឡាយ កាលយាងចូលកាន់ផ្ទះ មិនចាំបាច់ទ្រង់ឱនចូលទៅ ព្រោះថា ក្នុងពេលទ្រង់យាងចូលកាន់ផ្ទះ មហាប្រឹថពីរមែងស្រុតចុះក្រោម ឬផ្ទះខ្ពស់ឡើង នេះជាផលនៃទាន ដែលព្រះពុទ្ធទាំងឡាយថ្វាយល្អហើយ ។ ក្នុងពេលដែលទ្រង់យាងចេញទៅហើយ វត្ថុជាប្រក្រតីក៏ដូចដើម

វិញ ព្រោះដូច្នោះ ព្រះសាស្តា ប្រថាប់ឈរនោះឯង ទ្រង់យាងចូលកាន់ផ្ទះហើយ ប្រថាប់គង់លើអាសនៈដែលសក្កៈក្រាលហើយ ។ កាលព្រះសាស្តាប្រថាប់គង់ហើយ ព្រះរាជាត្រាស់ថា មហាទុគ្គតៈសម្លាញ់ អ្នកមិនឲ្យបាត្ររបស់ព្រះសាស្តា ដល់ពួកយើងដែលខំអង្វរ ពួកយើងនឹងមើលសិន សក្ការៈដែលអ្នករៀបចំថ្វាយព្រះសាស្តាដូចម្តេច ។ លំដាប់នោះ សក្កទេវរាជបើកផ្ទាំងបបរ និងកត្តចេញ ក្លិនអប់កត្តាហារទាំងនោះ បានក្រអូបពេញព្រះនគរ ។ ព្រះរាជាទ្រង់ទតបបរជាដើមហើយ ក្រាបទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គគិតថា ទេយ្យធម៌របស់មហាទុគ្គតៈមានត្រឹមប៉ុនណា កាលមហាទុគ្គតៈនេះថ្វាយទេយ្យធម៌ហើយ នឹងនាំព្រះសាស្តាទៅកាន់ព្រះរាជវាំងថ្វាយអាហារដែលគេរៀបចំសម្រាប់ខ្លួន ដូច្នេះ ទើបមកហើយ អាហារបែបនេះ ខ្ញុំព្រះអង្គមិនធ្លាប់ឃើញឡើយ កាលខ្ញុំព្រះអង្គនៅក្នុងទីនេះ មហាទុគ្គតៈត្រូវលំបាកពន់ពេក ខ្ញុំព្រះអង្គនឹងត្រឡប់ ថ្វាយបង្គំព្រះសាស្តាហើយ ទ្រង់ចៀសចេញទៅ ។

ចំណែកសក្កទេវរាជ ថ្វាយយាគូជាដើម ទ្រង់អង្គាសព្រះសាស្តាដោយគោរព ព្រះសាស្តាទ្រង់ធ្វើភត្តកិច្ចហើយ ទ្រង់ធ្វើអនុមោទនាក្រោកចាកអាសនៈយាងទៅហើយ ។ សក្កទេវរាជ បានឲ្យសញ្ញាដល់មហាទុគ្គតៈ ។ គាត់ទទួលបាត្រធ្វើដំណើរតាមព្រះសាស្តា ។ សក្កទេវរាជយាងត្រឡប់ ប្រថាប់ឈរត្រង់ផ្ទះរបស់មហាទុគ្គតៈ ទ្រង់សម្លឹងអាកាសហើយ ភ្លៀងកែវ ៧ ប្រការ ធ្លាក់ចុះមកអំពីអាកាស ពេញភាជនៈទាំងអស់ក្នុងផ្ទះរបស់គាត់ហើយ ហៀរទៅពេញ

ផ្ទះ ។ ក្នុងផ្ទះរបស់គាត់មិនមានចន្លោះ ភរិយារបស់គាត់បានដឹកដៃកូននាំចេញទៅឈរខាងក្រៅ ។ មហាទុគ្គតៈតាមព្រះសាស្ដាទៅហើយត្រឡប់មក ឃើញកូននៅត្រង់ផ្លូវ ទើបសួរថា តើមានរឿងអ្វី ភរិយាឆ្លើយថា នែអ្នក ផ្ទះរបស់យើងពេញទៅដោយកែវ ៧ ប្រការ មិនមានចន្លោះដែលចូលទៅបាន ។ គាត់គិតថា ទានរបស់គាត់ឲ្យផលក្នុងថ្ងៃនេះឯង ដូច្នេះហើយ ទើបទៅកាន់ព្រះរាជសម្នាក់ ថ្វាយបង្គំព្រះរាជាហើយ កាលព្រះរាជាត្រាស់សួរថា តើអ្នកមកធ្វើអ្វី ទើបក្រាបទូលថា បពិត្រព្រះអង្គ ផ្ទះរបស់ទូលបង្គំពេញទៅដោយកែវ ៧ ប្រការ សូមទ្រង់កាន់យកទ្រព្យនោះចុះ ព្រះរាជាទ្រង់ត្រិះរិះថា គួរអស្ចារ្យទានដែលបុរសនេះថ្វាយដល់ព្រះពុទ្ធទាំងឡាយ ដល់ទីបំផុតថ្ងៃនេះឯង ដូច្នេះហើយ ទើបត្រាស់នឹងមហាទុគ្គតៈថា អ្នកគួរនឹងបានអ្វី មហាទុគ្គតៈពោលថា សូមទ្រង់ព្រះរាជទានរទេះមួយពាន់ ដើម្បីនាំទ្រព្យមក ។

ព្រះរាជាទ្រង់បញ្ជូនរទេះមួយពាន់ទៅ ឲ្យនាំទ្រព្យមកគរត្រង់លានព្រះរាជវាំង គំនរទ្រព្យកម្ពស់ប្រមាណស្មើដើមត្នោត ។ ព្រះរាជាទ្រង់បញ្ជាឲ្យអ្នកនគរប្រជុំគ្នាហើយត្រាស់សួរថា ក្នុងនគរនេះ អ្នកមានទ្រព្យប្រមាណប៉ុណ្ណេះមានដែរឬទេ អ្នកនគរទូលថា បពិត្រព្រះអង្គ មិនមានទេ ព្រះរាជាត្រាស់ថា តើគួរធ្វើដូចម្ដេចដល់បុគ្គល ដែលមានទ្រព្យច្រើនដល់ម៉្លេះ អ្នកនគរទូលថា បពិត្រព្រះអង្គ គួរលើកជាសេដ្ឋី ។

ព្រះរាជាទ្រង់ធ្វើសក្ការៈជាច្រើន ដល់មហាទុគ្គតៈហើយ ត្រាស់ឲ្យព្រះរាជទានតំណែងសេដ្ឋី ។ លំដាប់នោះ ព្រះរាជាត្រាស់ប្រាប់ត្រង់ផ្ទះរបស់សេដ្ឋី

ម្នាក់ក្នុងកាលមុន ដល់មហាទុគ្គតៈហើយ ត្រាស់ថា អ្នកចូរភ្ជួរគុម្ពឈើដែលកើតក្នុងទីនេះ ហើយសង់ផ្ទះនៅចុះ កាលគាត់ភ្ជួរទីនោះ ជីកដីធ្វើឲ្យរាបធ្នាំងទ្រព្យបានផុសឡើងតម្រៀបលើគ្នា ។ គាត់ក៏ក្រាបទូលដល់ព្រះរាជា ទើបព្រះរាជាត្រាស់ថា ធ្នាំងទ្រព្យនោះ កើតព្រោះបុណ្យរបស់អ្នកនោះឯង ចូរអ្នកកាន់យកចុះ ។

គាត់បានសង់ផ្ទះហើយ បានថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ ខាងមុខអំពីនោះ គាត់បានបំពេញបុណ្យដរាបដល់អស់អាយុ ក្នុងទីបំផុតអាយុ បានទៅកើតក្នុងទេវលោក សោយទិព្វសម្បត្តិអស់មួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទកាលនេះ ចុតិអំពីនោះហើយ បដិសន្ធិក្នុងផ្ទៃធីតាច្បង ក្នុងត្រកូលឧបដ្ឋាករបស់ព្រះសារីបុត្តត្ថេរ ក្នុងក្រុងសាវត្ថី ។ គ្រានោះ មាតាបិតារបស់នាង ដឹងថា នាងមានគភ៌ ទើបឲ្យគ្រឿងបរិហារគភ៌ ។ ដោយសម័យដទៃ នាងចាញ់គភ៌ដូច្នេះថា ឱ អញគប្បីឲ្យទានដល់ភិក្ខុ ៥០០ រូប ចាប់តាំងអំពីព្រះធម្មសេនាបតី ដោយសេត្រីច្ឆិនហើយ ស្លៀកសំពត់ជ្រលក់ទឹកម្ចត់ អង្គុយក្នុងទីបំផុតអាសនៈ បរិភោគភត្តដែលសល់អំពីភិក្ខុទាំងនោះ នាងប្រាប់ដល់មាតាបិតាហើយ ក៏បានធ្វើតាមបំណង ។ ការចាញ់គភ៌ក៏រម្ងាប់ទៅហើយ ។ តមក ក្នុងការឆ្លងមង្គល ៧ ដងដទៃអំពីនោះ ។ មាតាបិតារបស់នាងអង្គាសភិក្ខុ ៥០០ រូប មានព្រះធម្មសេនាបតីសារីបុត្តជាប្រធាន ដោយសេត្រីច្ឆិនដូចគ្នា ។

គប្បីជ្រាបរឿងទាំងអស់ ដោយន័យដែលពោលហើយ ក្នុងរឿងតិស្ស-

កុមារនោះឯង ។ តែនេះជាផលនៃការថ្វាយសេត្រីច្ឆិន ក្នុងកាលដែលនៅជាទុគ្គតៈនោះឯង ។

ក្នុងថ្ងៃដាក់ឈ្មោះ កាលមាតារបស់ក្មេងនោះពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ឲ្យសិក្ខាបទទាំងឡាយដល់ទាសៈរបស់លោកម្ចាស់ចុះ ទើបព្រះថេរៈពោលថា កុមារនេះឈ្មោះអ្វី ម្តាយរបស់កុមារឆ្លើយថា បពិត្រលោកម្ចាស់ បុគ្គលល្ងង់ខ្លៅក្នុងផ្ទះនេះ ក៏ត្រឡប់ទៅជាមនុស្សឈ្លាស តាំងអំពីកាលដែលកុមារនេះបដិសន្ធិក្នុងផ្ទៃ ព្រោះដូច្នោះ កូនរបស់ខ្ញុំ នឹងមានឈ្មោះថា បណ្ឌិត ចុះ ។ ព្រះថេរៈឲ្យសិក្ខាបទទាំងឡាយហើយ ។ តាំងអំពីថ្ងៃបណ្ឌិតកុមារកើតមក ការគិតកើតឡើងដល់មាតារបស់កុមារថា អាត្មាអញនឹងមិនទម្លាយអធ្យាស្រ័យរបស់កូនអញឡើយ ក្នុងកាលដែលកុមារមានអាយុបាន ៧ ឆ្នាំ ក៏ពោលនឹងមាតាថា ខ្ញុំចង់បួសក្នុងសម្នាក់ព្រះថេរៈ នាងពោលថា នែបា បាន ម៉ែបានគិតហើយយ៉ាងនេះថា នឹងមិនទម្លាយអធ្យាស្រ័យរបស់អ្នក ដូច្នេះហើយ ទើបនិមន្តព្រះថេរៈឲ្យឆាន់ ហើយពោលថា បពិត្រលោកម្ចាស់ ទាសៈរបស់លោកម្ចាស់ចង់បួស ខ្ញុំនឹងនាំកុមារនេះទៅវិហារក្នុងពេលល្ងាច ជូនដំណើរព្រះថេរៈទៅហើយ ឲ្យពួកញាតិប្រជុំគ្នា ពោលថា ខ្ញុំនឹងធ្វើសក្ការៈ ដែលគួរធ្វើដល់កូនរបស់ខ្ញុំក្នុងពេលជាគ្រហស្ថក្នុងថ្ងៃនេះឯង ដូច្នេះហើយ ក៏ឲ្យធ្វើសក្ការៈយ៉ាងច្រើន នាំបណ្ឌិតកុមារនោះទៅកាន់វិហារបានប្រគល់ដល់ព្រះថេរៈថា សូមលោកម្ចាស់ឲ្យកុមារនេះបួសចុះ ។ ព្រះថេរៈប្រាប់គាពដែលបួស ជាកិច្ចដែលធ្វើបានលំបាកហើយ កាលកុមារទទួល

ថា ខ្ញុំនឹងធ្វើតាមឱវាទរបស់លោកម្ចាស់ ទើបពោលថា បើដូច្នោះ ចូរមកចុះ លាបសក់ឲ្យសើមហើយ ប្រាប់តចបញ្ចកកម្មដ្ឋានឲ្យបួសហើយ ។ សូម្បីមាតាបិតារបស់បណ្ឌិតសាមណេរនោះ ក៏នៅក្នុងវិហារនោះឯងអស់ ៧ ថ្ងៃ ថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយរសគ្រឿងទិន្នន័យតែម្យ៉ាង ក្នុងថ្ងៃទី ៧ ពេលល្ងាច ទើបបានទៅកាន់ផ្ទះ ។

ក្នុងថ្ងៃទី ៨ ព្រះថេរៈកាលទៅខាងក្នុងស្រុក នាំសាមណេរនោះទៅ មិនបានទៅជាមួយពួកភិក្ខុ ព្រោះហេតុអ្វី ព្រោះថា ការដណ្តប់ចីវរ និងកាន់បាត្រ ឬឥរិយាបថរបស់លោក មិនទាន់គួរឲ្យជ្រះថ្លានៅឡើយ ម្យ៉ាងទៀត វត្តដែលគប្បីធ្វើក្នុងវិហាររបស់ព្រះថេរៈនៅមាន ម្យ៉ាងទៀត ព្រះថេរៈកាលភិក្ខុសង្ឃចូលទៅខាងក្នុងស្រុកហើយ ត្រាច់ទៅពេញវិហារ បោសទីដែលមិនទាន់បានបោស តម្កល់ទឹកឆាន់ ទឹកប្រើប្រាស់ទុកក្នុងភាជនៈដែលទទេ ទុកដាក់គ្រែ និងតាំងជាដើម ដែលមិនទាន់បានទុកដាក់រៀបរយ ទើបចូលទៅកាន់ស្រុកជាក្រោយ ។ ម្យ៉ាងទៀត លោកគិតថា ពួកតិរ្ថិយចូលទៅកាន់វិហារទទេហើយ កុំបីពោលថា មើលចុះអាសនៈពួកសាវកព្រះគោតម ដូច្នេះហើយ ទើបបានចាត់ចែងវិហារទាំងមូល ហើយចូលទៅកាន់ស្រុកឯក្រោយ ព្រោះដូច្នោះ ក្នុងថ្ងៃនោះ ព្រះថេរៈឲ្យសាមណេរនោះឯង កាន់បាត្រ ចីវរចូលទៅកាន់ស្រុកយឺតយូរបន្តិច ។

សាមណេរទៅជាមួយព្រះឧបជ្ឈាយ៍ ឃើញប្រឡាយក្នុងរវាងផ្លូវ ទើបសាកសួរថា បពិត្រលោកម្ចាស់ នេះ គេហៅថា អ្វី ព្រះថេរៈពោលថា អើ

សាមណេរ នេះ គេហៅថា ប្រឡាយ សាមណេរពោលថា គេធ្វើអ្វីដោយប្រឡាយនេះ ព្រះថេរៈពោលថា គេបង្ហូរទឹក ហើយធ្វើការងារទាក់ទងដោយសម្បូររបស់ខ្លួន សាមណេរពោលថា បពិត្រលោកម្ចាស់ ទឹកនេះ មានចិត្តដែលឬទេ ព្រះថេរៈពោលថា មិនមានទេ សាមណេរពោលថា ជនទាំងឡាយ រមែងបង្ហូរទឹកដែលមិនមានចិត្តបែបនេះ ទៅកាន់ទីដែលខ្លួនប្រាថ្នា ហើយបានឬ ព្រះថេរៈពោលថា អើ សាមណេរ បាន ។

សាមណេរនោះគិតថា បើមនុស្សទាំងឡាយ បង្ហូរទឹកដែលមិនមានចិត្តបែបនេះ ទៅកាន់ទីដែលខ្លួនប្រាថ្នា ហើយធ្វើការងារបាន ហេតុអ្វី មនុស្សមានចិត្តពិតៗ មិនអាចធ្វើចិត្តរបស់ខ្លួនឲ្យប្រព្រឹត្តទៅក្នុងអំណាចហើយ បំពេញសមណធម៌ ។ លោកដើរបន្តទៅទៀត ឃើញពួកជាងព្រួញ កំពុងយកព្រួញរោលភ្លើង សម្លឹងដោយកន្ទុយភ្នែកពត់ឲ្យត្រង់ ទើបសាកសួរថា បពិត្រលោកម្ចាស់ ជនទាំងនេះ ឈ្មោះអ្វី ព្រះថេរៈពោលថា ឈ្មោះជាងព្រួញ សាមណេរៗ ពោលថា តើពួកគេធ្វើអ្វី ព្រះថេរៈពោលថា គេរោលត្រង់ភ្លើង ហើយពត់ព្រួញឲ្យត្រង់ ។ សាមណេរពោលថា ព្រួញនោះ មានចិត្តដែរឬទេ ព្រះថេរៈពោលថា មិនមានចិត្តទេ សាមណេរគិតថា បើមនុស្សទាំងឡាយកាន់យកព្រួញដែលមិនមានចិត្តរោលភ្លើង ហើយពត់ឲ្យត្រង់បាន ព្រោះហេតុអ្វី ទើបមនុស្សមានចិត្ត មិនអាចធ្វើចិត្តរបស់ខ្លួនឲ្យប្រព្រឹត្តទៅក្នុងអំណាច ហើយបំពេញសមណធម៌ ។

កាលសាមណេរនិមន្តទៅទៀត ឃើញជាងឈើធ្វើគ្រឿងទព្វសម្ភារៈ មាន

កាំ ខ្នងកង់ និងដុំជាដើម ទើបសាកសួរថា បពិត្រលោកម្ចាស់ ជនទាំងនេះឈ្មោះអ្វី ព្រះថេរៈប្រាប់ថា នែសាមណេរ ឈ្មោះជាងឈើ សាមណេរសួរថា ពួកគេធ្វើអ្វី ព្រះថេរៈប្រាប់ថា គេកាន់យកឈើហើយ ធ្វើកង់នៃយានតូចជាដើម សាមណេរសួរថា ឈើនោះ មានចិត្តដែរឬទេ ព្រះថេរៈប្រាប់ថា មិនមានទេ ។

ពេលនោះ សាមណេរគិតយ៉ាងនេះថា បើមនុស្សទាំងឡាយ កាន់យកកំណាត់ឈើដែលមិនមានចិត្ត ធ្វើជាកង់រទេះជាដើមបាន ហេតុអ្វី ទើបបុគ្គលមានចិត្តមិនអាចធ្វើចិត្តរបស់ខ្លួន ឲ្យប្រព្រឹត្តទៅក្នុងអំណាច ហើយបំពេញសមណធម៌បាន ។ លោកឃើញហេតុទាំងនេះហើយ ទើបពិតព្រះថេរៈថា បពិត្រលោកម្ចាស់ បើលោកម្ចាស់អាចកាន់បាត្រ និងចីវររបស់លោកម្ចាស់បាន ខ្ញុំនឹងត្រឡប់ ព្រះថេរៈមិនបានកើតគំនិតថា សាមណេរតូចនេះបួសថ្មីៗដើរតាមអញមក ហើយពោលយ៉ាងនេះ បែរជាពោលថា នែសាមណេរចូរអ្នកយកមកចុះ ហើយទទួលបាត្រ និងចីវររបស់ខ្លួន ។

ចំណែកសាមណេរ ថ្វាយបង្គំឧបជ្ឈាយ៍ហើយ កាលនឹងត្រឡប់ ទើបពិតថា បពិត្រលោកម្ចាស់ បើលោកម្ចាស់នាំអាហារមកដើម្បីខ្ញុំ សូមនាំយករសត្រីឆ្អិនមកចុះ ព្រះថេរៈពោលថា អើសាមណេរ ខ្ញុំនឹងបានអំពីណា សាមណេរពិតថា បើមិនបានដោយបុណ្យរបស់លោកម្ចាស់ គង់បានដោយបុណ្យរបស់ខ្ញុំ ។ ព្រះថេរៈគិតថា អន្តរាយគប្បីមានដល់សាមណេរតូច ដែលអង្គុយខាងក្រៅ ទើបឲ្យកូនសោទៅ ហើយប្រាប់ថា គួរបើកទ្វារបន្ទប់របស់

ខ្ញុំ ហើយចូលទៅអគ្គិយខាងក្នុង ។ លោកបានធ្វើយ៉ាងនោះហើយ អង្គុយ ញ៉ាំងចិត្តឲ្យឈមចុះក្នុងករជកាយ ពិចារណាអត្តភាពរបស់ខ្លួន ។

គ្រានោះ ទីប្រថាប់របស់សក្កទេវរាជ សម្តែងអាការក្តៅដោយតេជះនៃគុណរបស់សាមណេរនោះ ទ្រង់ពិចារណាថា នឹងមានហេតុអ្វីហ្ន៎ ទ្រង់ត្រិះរិះបានថា បណ្ឌិតសាមណេរឲ្យបាត្រ និងចីវរដល់ឧបជ្ឈាយ៍ ហើយត្រឡប់ដោយតាំងចិត្តថា នឹងធ្វើសមណធម៌ សូម្បីអាត្មាអញក៏គួរទៅក្នុងទីនោះ ដូច្នេះហើយ ទើបហៅមហារាជទាំង ៤ មកត្រាស់ថា ចូរអ្នកទៅដេញបក្សាបក្សីដែលស្រែកយំខ្សៀវខ្សារក្នុងព្រៃ ក្បែរវិហារឲ្យគេចទៅ ហើយធ្វើការរក្សាដោយជុំវិញ ត្រាស់នឹងចន្ទទេវបុត្រថា ចូរអ្នកទាញមណ្ឌលព្រះចន្ទ ត្រាស់នឹងសុរិយទេវបុត្រថា ចូរអ្នកទាញមណ្ឌលព្រះអាទិត្យ ដូច្នេះហើយ ព្រះអង្គឯងបានយាងទៅប្រថាប់ឈរធ្វើការរក្សា ។ ក្នុងវិហារ សូម្បីត្រឹមតែសំឡេងស្លឹកឈើចាស់ក៏មិនមាន ។ ចិត្តរបស់សាមណេរ មានអារម្មណ៍ជាឯកគ្គតាហើយ ។ លោកពិចារណាអត្តភាពហើយ សម្រេចផល ៣ ក្នុងរវាងកត្តនោះឯង ។

ចំណែកព្រះថេរៈគិតថា សាមណេរអង្គុយហើយក្នុងវិហារ អាត្មាអញអាចបានភោជន ដែលសមបំណងដល់លោក ក្នុងត្រកូលឈ្មោះនោះ ដូច្នេះហើយ ទៅកាន់ត្រកូលឧបដ្ឋាកមួយ ដែលប្រកបដោយសេចក្តីស្រឡាញ់ និងគោរព ។ ក្នុងថ្ងៃនោះ មនុស្សទាំងឡាយក្នុងត្រកូលនោះ បានត្រីត្អិនជាច្រើនអង្គុយទន្ទឹងការមករបស់ព្រះថេរៈ ។ មនុស្សទាំងនោះ ឃើញព្រះថេរៈកំពុង

និមន្តមក ទើបពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់មកទីនេះធ្វើកម្មចម្រើនហើយ ហើយនិមន្តឲ្យចូលទៅខាងក្នុង ប្រគេនបបរ និងរបស់គួរទំពាជាដើមហើយ បានថ្វាយបិណ្ឌបាតដោយសេត្រីធ្អិន ព្រះថេរៈសម្តែងអាការនាំទៅ ។ ពួកមនុស្សប្រាប់ថា និមន្តឆាន់ចុះលោកម្ចាស់ លោកម្ចាស់នឹងបានកត្តសម្រាប់នាំទៅ ។ ក្នុងពេលស្រេចភត្តកិច្ចរបស់ព្រះថេរៈ បានយកកោជនប្រកបដោយសេត្រីធ្អិន ដាក់ពេញបាត្រប្រគេនហើយ ។ ព្រះថេរៈគិតថា សាមណេររបស់អាត្មាអញឃ្លានហើយ ទើបរួតរះទៅ ។

ក្នុងថ្ងៃនោះ ព្រះសាស្តាសោយអំពីព្រឹកហើយយាងទៅកាន់វិហារ ទ្រង់ពិចារណាថា បណ្ឌិតសាមណេរឲ្យបាត្រ និងចីវរដល់ឧបជ្ឈាយ៍ ហើយត្រឡប់ទៅដោយតាំងចិត្តថា នឹងធ្វើសមណធម៌ កិច្ចនៃបព្វជិតរបស់សាមណេរ នឹងសម្រេចដែរឬទេ ទ្រង់ជ្រាបថា សាមណេរសម្រេចផល ៣ ហើយ ទ្រង់ពិចារណាថា ឧបនិស្ស័យនៃអរហត្តមាន ឬមិនមានហ្ន៎ ទ្រង់ឃើញថា មានហើយទ្រង់ពិចារណាថា សាមណេរអាចសម្រេចអរហត្តមុនកត្ត ឬក៏មិនអាចហ្ន៎ ទ្រង់បានជ្រាបថា នឹងអាច ។ លំដាប់នោះ ទ្រង់មានបរិវិតក្កយ៉ាងនេះថា សារីបុត្រកាន់កត្តដើម្បីសាមណេរ រួតរះមក សារីបុត្តគប្បីធ្វើអន្តរាយដល់សាមណេរនោះក៏បាន តថាគតនឹងអង្គុយកាន់យកការរក្សាត្រង់ខ្លោងទ្វារ រួចសួរបញ្ហា ៤ យ៉ាងដល់សារីបុត្ត កាលសារីបុត្តកំពុងឆ្លើយ សាមណេរនឹងសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា ដូច្នេះហើយ ទើបទ្រង់យាងទៅអំពីវិហារ ប្រថាប់ឈរត្រង់ខ្លោងទ្វារ ត្រាស់សួរបញ្ហា ៤ យ៉ាងជាមួយនឹង

ព្រះថេរៈៗ មកដល់ហើយ ក៏ឆ្លើយបញ្ហាដែលព្រះសាស្ដាត្រាស់សួរ ។

ក្នុងបញ្ហានោះ មានបុច្ឆា និងវិសជ្ជនាដូចតទៅនេះ បានឮថា ព្រះសាស្ដាត្រាស់នឹងព្រះថេរៈថា សារីបុត្ត អ្នកបានអ្វីមក ព្រះថេរៈទូលថា បពិត្រព្រះអង្គ បានអាហារ ព្រះសាស្ដាត្រាស់សួរថា ម្នាលសារីបុត្ត ឈ្មោះថា អាហាររមែងនាំអ្វីមក ព្រះថេរៈទូលថា បពិត្រព្រះអង្គ វេទនា ព្រះសាស្ដាត្រាស់ថា ម្នាលសារីបុត្ត វេទនារមែងនាំអ្វីមក ព្រះថេរៈទូលថា បពិត្រព្រះអង្គ រូប ព្រះសាស្ដាត្រាស់ថា ម្នាលសារីបុត្ត ចុះរូបរមែងនាំអ្វីមក ព្រះថេរៈទូលថា បពិត្រព្រះអង្គ ផស្សៈ ។

ក្នុងបញ្ហានោះ មានអធិប្បាយថា ពិតហើយ អាហារដែលមនុស្សស្រេកឃ្លានបរិភោគហើយ កម្ចាត់នូវការស្រេកឃ្លានរបស់បុគ្គលនោះ ហើយនាំសុខវេទនាមកឲ្យ កាលសុខវេទនាកើតឡើងដល់បុគ្គលដែលមានសុខព្រោះការបរិភោគអាហារ វណ្ណសម្បត្តិរមែងមានក្នុងសរីរៈ ទើបវេទនាឈ្មោះថានាំរូបមកដោយប្រការយ៉ាងនេះ ឯបុគ្គលដែលមានសុខសោមនស្សដោយអំណាចរូបដែលកើតអំពីអាហារ ដេកក្ដី អង្គុយក្ដី ដោយគិតថា ឥឡូវនេះ អស្សាទៈកើតឡើងដល់អញហើយ រមែងបាននូវសុខផស្សៈ ។

ព្រះថេរៈឆ្លើយបញ្ហា ៤ យ៉ាងនេះហើយ សាមណេរក៏បានសម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទា ។ ចំណែកព្រះសាស្ដា ត្រាស់នឹងព្រះថេរៈថា ទៅចុះសារីបុត្ត ចូរអ្នកឲ្យភត្តដល់សាមណេររបស់អ្នក ។ ព្រះថេរៈគោះទ្វារហើយ សាមណេរចេញមកទទួលបាត្រអំពីដៃព្រះថេរៈ ទុកក្នុងចំណែកម្ខាងហើយ ទើប

យកផ្ចិតស្ទឹកឆ្នោតបក់ព្រះថេរៈ ព្រះថេរៈពោលដល់លោកថា សាមណេរ ចូរអ្នកធ្វើកត្តកិច្ចចុះ ។ សាមណេរពិតថា បពិត្រលោកម្ចាស់ ចុះលោកម្ចាស់វិញ ព្រះថេរៈពោលថា ខ្ញុំធ្វើកត្តកិច្ចស្រេចហើយ ចូរអ្នកធ្វើចុះ ។

កុមារអាយុ ៧ ឆ្នាំបួសហើយ ក្នុងថ្ងៃទី ៨ សម្រេចអរហត្ត ហាក់ដូចជាផ្កាឈូករីកហើយ ក្នុងខណៈនោះ បានគន់ពិចារណាត្រង់ទីដាក់កត្ត ធ្វើកត្តកិច្ចហើយ ក្នុងខណៈដែលលោកលាងបាត្រទុកដាក់ហើយ ចន្ទទេវបុត្រក៏លែងចន្ទមណ្ឌល សុរិយទេវបុត្រក៏លែងសុរិយមណ្ឌល មហារាជទាំង ៤ រក្សាទិសទាំង ៤ សក្កទេវរាជ ក៏វៀរការរក្សាត្រង់សន្ទះទ្វារ ព្រះអាទិត្យលយលឿន ជ្រេទៅហើយអំពីថ្ងៃត្រង់ ។

ភិក្ខុទាំងឡាយពោលទោសថា ស្រមោលជ្រេហួសប្រមាណហើយ ព្រះអាទិត្យគោចរទៅអំពីថ្ងៃត្រង់ សាមណេរចាន់ស្រេចអម្បាញ់មិញនេះឯង តើមានរឿងអ្វីហ្ន៎ ព្រះសាស្តាទ្រង់ជ្រាបការប្រព្រឹត្តទៅនោះហើយ ទ្រង់យាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកសន្ទនាគ្នាអំពីរឿងអ្វី ភិក្ខុទាំងឡាយទូលថា បពិត្រព្រះអង្គ រឿងឈ្មោះនេះ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង ក្នុងពេលបុគ្គលមានបុណ្យធ្វើសមណធម៌ ចន្ទទេវបុត្រ បញ្ឈប់មណ្ឌលព្រះចន្ទ សុរិយទេវបុត្រ បញ្ឈប់មណ្ឌលព្រះអាទិត្យ មហារាជទាំង ៤ រក្សាក្នុងទិសទាំង ៤ ក្នុងព្រៃជិតវិហារ សក្កទេវរាជមកឈររក្សាត្រង់សន្ទះទ្វារ តថាគតមានការខ្វល់ខ្វាយតិច ដោយគិតថា ជាព្រះពុទ្ធក៏មិនបានអង្គុយនៅ គង់ទៅឈររក្សាបុត្ររបស់តថាគតត្រង់ខ្លោងទ្វារ

ពួកបណ្ឌិតឃើញមនុស្សបង្ហូរទឹក បង្ហូរទឹកទៅអំពីប្រឡាយ ជាងព្រួញកំពុងពត់ព្រួញឲ្យត្រង់ ជាងឈើកំពុងថាំងឈើ កាន់យកហេតុប៉ុណ្ណោះ ឲ្យជាអារម្មណ៍ទូន្មានខ្លួនហើយ រមែងទាញយកបាននូវអរហត្តនោះឯង ដូច្នេះហើយ កាលនឹងបន្តអនុសន្ធិសម្តែងធម៌ ត្រាស់ព្រះគាថានេះថា

**ឧទកញ្ហិ នយន្តិ នេត្តិកា ឧសុការា នមយន្តិ តេជនំ**
**ទារុំ នមយន្តិ តច្ឆកា អត្តានំ ទមយន្តិ បណ្ឌិតា ។**

ធម្មតា អ្នកបង្ហូរទឹក តែងបង្ហូរទឹកទៅ អ្នកធ្វើព្រួញ តែងពត់ព្រួញ (ឲ្យត្រង់) អ្នកថាំងឈើ តែងថាំងឈើ ឯបណ្ឌិតទាំងឡាយ តែងទូន្មានខ្លួន (ដូច្នោះដែរ) ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ឧទកំ** ជាដើម សេចក្តីថា ជនទាំងឡាយជីកត្រង់ទួលលើផែនដី បំពេញត្រង់ទំនាប ហើយធ្វើប្រឡាយ ឬដាក់រហាត់ រមែងបង្ហូរទឹកទៅកាន់ទីដែលខ្លួនត្រូវការ ព្រោះដូច្នោះ ទើបឈ្មោះថា បង្ហូរទឹក ។ បទថា **តេជនំ** បានដល់ ព្រួញ ។

មានព្រះពុទ្ធាធិប្បាយត្រាស់ដូច្នេះថា

ពួកអ្នកបង្ហូរទឹក រមែងបង្ហូរទឹកទៅតាមគាប់ចិត្តរបស់ខ្លួនបាន សូម្បីជាងព្រួញ រមែងរោលពត់នូវព្រួញ គឺធ្វើឲ្យត្រង់ សូម្បីជាងឈើ កាលនឹងថាំងដើម្បីប្រយោជន៍ដល់ទព្វសម្ភារៈ មានខ្នងកង់ជាដើម រមែងពត់ឈើ គឺធ្វើឲ្យត្រង់ ឬកោងតាមគាប់ចិត្តរបស់ខ្លួន បណ្ឌិតទាំងឡាយ ធ្វើហេតុមានប្រមាណ

ប៉ុណ្ណោះឲ្យជាអារម្មណ៍យ៉ាងនោះហើយ ញ៉ាំងមគ្គ មានសោតាបត្តិមគ្គជាដើម ឲ្យកើតឡើង ឈ្មោះថា ទូន្មានខ្លួន តែកាលសម្រេចអរហត្តហើយ រមែង ឈ្មោះថា ទូន្មានដោយចំណែកមួយ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើម ដូច្នេះឯង ។៙

រឿង បណ្ឌិតសាមណេរ ចប់

# រឿង ព្រះលកុណ្ឋកភទ្ទិយត្ថេរ

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធលកុណ្ឋកភទ្ទិយត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **សេលោ យថា** ជាដើម ។

បានឮថា សហធម្មិក មានសាមណេរជាដើមដែលជាបុថុជ្ជន ឃើញ ព្រះថេរៈហើយ ចាប់ត្រង់ក្បាលខ្លះ ត្រង់ត្រចៀកខ្លះ ច្រមុះខ្លះពោលថា បពិត្រ លោកម្ចាស់ៗ មិនអផ្សុក នៅត្រេកអរមាំទាំ ក្នុងព្រះសាសនាឬ ព្រះថេរៈ មិនក្រោធ មិនប្រទូស្តក្នុងសហធម្មិកទាំងនោះឡើយ ។

ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងរោងធម្មសភាថា អាវុសោទាំងឡាយ ចូរ ពួកអ្នកមើលចុះ សហធម្មិក មានសាមណេរជាដើម ឃើញព្រះលកុណ្ឋកភទ្ទិ- យត្ថេរហើយ រមែងលេងយ៉ាងនេះ តែលោកមិនក្រោធ មិនប្រទូស្តក្នុង

សហធម្មិកទាំងនោះឡើយ ។

ព្រះសាស្ដាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកនិយាយអ្វី កាលភិក្ខុទាំងនោះក្រាបទូលថា រឿងឈ្មោះនេះព្រះអង្គ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង ធម្មតាព្រះខីណាស្រព រមែងមិនក្រោធមិនប្រទូស្តឡើយ ព្រោះលោកទាំងនោះមិនញាប់ញ័រ មិនកម្រើក ដូចគ្នានឹងថ្មភ្នំតាន់ ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ត្រាស់ព្រះគាថានេះថា

**សេលោ យថា ឯកឃនោ វាតេន ន សមីរតិ**

**ឯវំ និន្ទាបសំសាសុ ន សមិញ្ជន្តិ បណ្ឌិតា ។**

ថ្មភ្នំតាន់ មិនរំភើបព្រោះខ្យល់ ដូចម្តេចមិញ បណ្ឌិតទាំងឡាយ ក៏មិនរំភើប ព្រោះពាក្យតិះដៀល និងពាក្យសរសើរ ( ជាដើម ) ដូច្នោះឯង ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ក្នុងបទថា **និន្ទាបសំសាសុ** នេះ ព្រះដ៏មានព្រះភាគត្រាស់លោកធម៌ពីរក៏ពិត តែគប្បីជ្រាបដោយអំណាចនៃលោកធម៌ទាំង ៨ អធិប្បាយថា ដូចថ្មភ្នំសុទ្ធជាដុំតែមួយ គឺមិនមានប្រហោង រមែងមិនញាប់ញ័រ គឺមិនទោរទន់ មិនកម្រើកដោយខ្យល់ មានខ្យល់ដែលបក់មកអំពីទិសខាងកើតជាដើម យ៉ាងណា កាលលោកធម៌ទាំង ៨ គ្របសង្កត់ បណ្ឌិតទាំងឡាយ រមែងមិនទោរទន់ គឺមិនញាប់ញ័រ មិនកម្រើក ដោយអំណាចការប្រទូស្ត ឬត្រេកអរ ដូច្នោះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមដូច្នេះឯង ។l៚

**រឿង ព្រះលកុណ្ឌកភទ្ទិយត្ថេរ ចប់**

# រឿង មាតារបស់នាងកាណា

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធមាយរបស់នាងកាណា ត្រាស់ព្រះធម្មទេសនានេះថា **យថាបិ រហាទោ គម្ភីរោ** ជាដើម ។

រឿងនេះមកហើយ ក្នុងវិន័យនោះឯង ។

គ្រានោះ ក្នុងកាលមាតារបស់នាងកាណាចៀននំដើម្បីបញ្ជូនកូនស្រីឲ្យជាបុគ្គលមិនមានដៃទទេ ទៅកាន់ត្រកូលស្វាមីហើយ ប្រគេនដល់ភិក្ខុ ៤ រូប អស់វារៈ ៤ ដង ។ ព្រះសាស្តា ទ្រង់បញ្ញត្តសិក្ខាបទព្រោះរឿងនោះ កាលស្វាមីរបស់នាងកាណានាំកិរិយាថ្មីមកហើយ នាងកាណា បានស្តាប់រឿងនោះ ទើបជេរបរិភាសពួកភិក្ខុ ដែលខ្លួនបានឃើញហើយថា ការគ្រប់គ្រងផ្ទះរបស់ខ្ញុំ ភិក្ខុទាំងនេះឲ្យវិនាសហើយ ។ ភិក្ខុទាំងឡាយមិនអាចដើរទៅកាន់ផ្លូវនោះបាន ។

ព្រះសាស្តា ទ្រង់ជ្រាបរឿងនោះហើយ ទើបយាងទៅក្នុងទីនោះ មាតារបស់នាងកាណា ថ្វាយបង្គំព្រះសាស្តាហើយ និមន្តឲ្យប្រថាប់គង់លើអាសនៈ

ដែលខ្លួនរៀបចំ បានថ្វាយបបរ និងរបស់គួរទំពាហើយ ។

ព្រះសាស្តា សោយព្រះក្រយាហារព្រឹកហើយ ត្រាស់សួរថា កាណា ទៅណា កាណាមាតាពោលថា បពិត្រព្រះអង្គ នាងឃើញព្រះអង្គហើយ ជាអ្នកខ្មាសអៀន ឈរយំ ព្រះសាស្តាត្រាស់ថា ព្រោះហេតុដូចម្តេច កាណាមាតាទូលថា នាងជេរបរិភាសពួកភិក្ខុ ព្រោះដូច្នោះ នាងឃើញព្រះអង្គហើយ ទើបជាអ្នកខ្មាសអៀន ហើយឈរយំ ។

លំដាប់នោះ ព្រះសាស្តា ត្រាស់ឲ្យហៅនាងកាណាមកហើយ សួរថា នែកាណា នាងឃើញតថាគតហើយ ខ្មាសអៀន ពួនយំធ្វើអ្វី គ្រានោះ មាតារបស់នាងក្រាបទូលកិរិយាដែលនាងធ្វើហើយឲ្យទ្រង់ជ្រាប ។ ពេលនោះ ព្រះសាស្តា ត្រាស់នឹងមាតារបស់នាងកាណាថា កាណាមាតា សាវកទាំងឡាយរបស់តថាគត កាន់យករបស់ដែលនាងឲ្យហើយ ឬមិនទាន់បានឲ្យ កាណាមាតាពោលថា បពិត្រព្រះអង្គ កាន់វត្ថុដែលខ្ញុំម្ចាស់ឲ្យហើយ ព្រះសាស្តាត្រាស់ថា សាវករបស់តថាគតត្រាច់បិណ្ឌបាតដល់ទ្វារផ្ទះរបស់នាងហើយ កាន់យករបស់ដែលនាងឲ្យហើយ នឹងមានទោសអ្វី កើតដល់សាវកទាំងនោះ កាណាមាតាពោលថា បពិត្រព្រះអង្គ ទោសរបស់លោកម្ចាស់ទាំងឡាយមិនមានទេ ទោសរបស់កូនស្រីរបស់ខ្ញុំម្ចាស់ប៉ុណ្ណោះមាន ព្រះសាស្តាត្រាស់នឹងនាងកាណាថា នែកាណា បានឮថា សាវករបស់តថាគតត្រាច់បិណ្ឌបាត មកដល់ទ្វារផ្ទះនេះហើយ កាលបើដូច្នេះ មាតារបស់នាងបានឲ្យនំដល់សាវកទាំងនោះ ក្នុងរឿងនេះ ឈ្មោះថា ទោសនឹងមានដល់ពួកសាវកទាំងឡាយរបស់

តថាគតឬ នាងកាណាទូលថា បពិត្រព្រះអង្គ ទោសរបស់លោកម្ចាស់ទាំង-ឡាយ មិនមានទេ ខ្ញុំម្ចាស់ប៉ុណ្ណោះ ជាអ្នកមានទោស ។ នាងថ្វាយបង្គំព្រះសាស្តា សូមឲ្យទ្រង់អត់ទោសឲ្យហើយ ។ គ្រានោះ ព្រះសាស្តា បានត្រាស់អនុបុព្វីកថាដល់នាង នាងសម្រេចសោតាបត្តិផលហើយ ។

ព្រះសាស្តា ទ្រង់ក្រោកចាកអាសនៈហើយ កាលនឹងយាងទៅកាន់វិហារ បានយាងទៅតាមលានព្រះរាជវាំង ។ ព្រះរាជាទតឃើញហើយត្រាស់សួរថា នែអ្នក មើលទុំះ ដូចព្រះសាស្តា រាជបុរសក៏ទូលថា បពិត្រព្រះអង្គ ពិតមែនហើយ ដូច្នេះហើយ ទើបបញ្ជូនទៅដោយព្រះតម្រាស់ថា ចូរអ្នកទៅក្រាបទូលភាពដែលខ្ញុំថ្វាយបង្គំ ហើយបានចូលទៅគាល់ព្រះសាស្តា ដែលប្រថាប់ឈរក្នុងលានព្រះរាជវាំង ថ្វាយបង្គំដោយបញ្ចង្គប្រដិស្ឋានហើយ ទូលសួរថា បពិត្រព្រះអង្គ ទ្រង់យាងទៅណា ព្រះសាស្តាត្រាស់ថា មហាបពិត្រ តថាគតទៅកាន់ផ្ទះកាណាមាតា ព្រះរាជាទូលថា បពិត្រព្រះអង្គ ទ្រង់យាងទៅព្រោះហេតុអ្វី ព្រះសាស្តាត្រាស់ថា បានឮថា នាងកាណាជេរបរិភាសភិក្ខុ តថាគតទៅ ព្រោះហេតុនោះ ព្រះរាជាទូលថា បពិត្រព្រះអង្គ ទ្រង់ធ្វើភាពដែលនាងមិនជេរហើយឬ ព្រះសាស្តាត្រាស់ថា មហាបពិត្រ តថាគតធ្វើនាងមិនឲ្យជាអ្នកជេរភិក្ខុហើយ នឹងឲ្យជាម្ចាស់របស់ទ្រព្យដែលជាលោកុត្តរហើយ ព្រះរាជាទូលថា ទ្រង់ធ្វើនាងឲ្យជាម្ចាស់ទ្រព្យ ដែលជាលោកុត្តរក៏ធ្វើទៅចុះ ឯខ្ញុំព្រះអង្គ នឹងធ្វើនាងឲ្យជាម្ចាស់របស់ទ្រព្យ ដែលជាលោកិយ ដូច្នេះហើយថ្វាយបង្គំព្រះសាស្តាយាងត្រឡប់ហើយ ទ្រង់បញ្ជូនយានធំដែលបិទបាំងទៅ

ត្រាស់ឲ្យហៅនាងកាណាមកហើយ តាក់តែងគ្រឿងអាភរណៈគ្រប់យ៉ាង ទ្រង់តាំងនាងក្នុងតំណែងជាធីតាច្បង ត្រាស់ថា អ្នកណាអាចចិញ្ចឹមកូនស្រីរបស់ខ្ញុំបាន បុគ្គលនោះ ចូរទទួលយកនាងចុះ ។

គ្រានោះ អមាត្យម្នាក់ ដែលជាអ្នកសម្រេចរាជកិច្ចគ្រប់យ៉ាងក្រាបទូលថា ទូលបង្គំនឹងចិញ្ចឹមធីតារបស់ទ្រង់ ដូច្នេះហើយ នាំនាងទៅកាន់ផ្ទះរបស់ខ្លួនប្រគល់ភាពជាធំគ្រប់យ៉ាងឲ្យហើយ ពោលថា ចូរនាងធ្វើបុណ្យតាមគាប់ចិត្តចុះ ។

ចាប់តាំងអំពីកាលនោះមក នាងកាណាឲ្យបុរស ៤ នាក់យាមត្រង់ទ្វារ ក៏មិនបានភិក្ខុ និងភិក្ខុនីដែលខ្លួនគប្បីទំនុកបម្រុង ។ របស់គួរទំពា និងរបស់គួរបរិភោគ ដែលនាងកាណាត្រៀមត្រង់ទ្វារផ្ទះ ប្រៀបដូចជំនន់ទឹកធំ ។

ពួកភិក្ខុសន្ទនាគ្នាក្នុងរោងធម្មសភាថា អាវុសោ ក្នុងកាលមុនព្រះថេរៈ ៤ រូប ធ្វើការក្តៅក្រហាយឲ្យដល់នាងកាណា នាងជាអ្នកក្តៅក្រហាយយ៉ាងនោះ អាស្រ័យព្រះសាស្តា បានទូវការដល់ព្រមដោយសទ្ធាហើយ ព្រះសាស្តាទ្រង់ធ្វើផ្ទះរបស់នាង ឲ្យជាទីដែលគួរចូលទៅរបស់ពួកភិក្ខុទៀត ឥឡូវនេះ សូម្បីនាងស្វែងរកភិក្ខុ ឬភិក្ខុនីទាំងឡាយ ដែលខ្លួនគប្បីទំនុកបម្រុងក៏មិនបានឱ ! ធម្មតាព្រះពុទ្ធទាំងឡាយ មានគុណអស្ចារ្យពិតហ្ន៎ ។

ព្រះសាស្តា យាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយកថាដូចម្តេចហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ កថាឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុ

ចាស់ទាំងនោះ ធ្វើការក្ដៅក្រហាយដល់នាងកាណា មិនមែនតែក្នុងឥឡូវនេះ ប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនក៏ពួកលោកធ្វើហើយដូចគ្នា ម្យ៉ាងទៀត តថាគត ធ្វើឲ្យនាងកាណា ធ្វើតាមពាក្យរបស់តថាគត មិនមែនតែក្នុងកាលឥឡូវនេះ ប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនតថាគតក៏ធ្វើហើយដូចគ្នា កាលពួកភិក្ខុប្រាថ្នានឹង ស្ដាប់សេចក្ដីនោះ ទូលអារាធនាហើយ ទើបត្រាស់ពព្ពុជាតកដោយពិស្ដារថា

ព្រះសាស្ដា ត្រាស់ថា ឆ្មាមួយ បានកណ្ដុរក្នុងទីណា ឆ្មាជា គម្រប់ពីរ គម្រប់បី គម្រប់បួន រមែងកើតក្នុងទីនោះ ឆ្មាទាំង នោះ ( ប្រហារ ) នូវវន្ទនេះ ហើយដល់នូវសេចក្ដីស្លាប់ ។

ហើយទ្រង់ប្រជុំជាតកថា ភិក្ខុចាស់ ៤ រូបក្នុងឥឡូវនេះ គឺជាឆ្មា ៤ ក្នុង កាលនោះ កណ្ដុរជានាងកាណា ជាងកែវ គឺតថាគតនោះឯង ដូច្នេះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នាងកាណា បានជាអ្នកមានចិត្តក្ដៅក្រហាយ មានចិត្តល្អក់កករយ៉ាងនេះ តែបានជាអ្នកមានចិត្តផូរផង់ ដូចអន្លង់ទឹកដែល មានទឹកថ្លា ព្រោះពាក្យរបស់តថាគត កាលទ្រង់បន្តអនុសន្ធិសម្ដែងធម៌ ទើប ត្រាស់ព្រះគាថានេះថា

**យថាបិ រហទោ គម្ភីរោ វិប្បសន្នោ អនាវិលោ**
**ឯវំ ធម្មានិ សុត្វាន វិប្បសីទន្តិ បណ្ឌិតា ។**

អន្លង់ទឹកដែលជ្រៅ រមែងថ្លា មិនល្អក់យ៉ាងណា បណ្ឌិត ទាំងឡាយ បើបានស្ដាប់ធម៌ទេសនាហើយ រមែងជ្រះថ្លា ស៊ប់សួនយ៉ាងនោះ ។

# សេចក្តីអធិប្បាយ

អន្ទង់ទឹកណា កាលចតុរង្គសេនាកំពុងឆ្លង រមែងមិនល្អក់កករ អន្ទង់ទឹកបែបនេះ ឈ្មោះថា **រហទោ** ក្នុងព្រះគាថានោះ ។

នីលមហាសមុទ្រ ដែលមានជម្រៅ ៨៤០០០ យោជន៍ ដោយអាការទាំងពួង ឈ្មោះថា អន្ទង់ទឹក ពិតហើយ ទឹកក្នុងទីប្រមាណ ៤ ពាន់យោជន៍ខាងក្រោមមហាសមុទ្រនោះ រមែងញាប់ញ័រព្រោះហ្វូងត្រី ទឹកក្នុងទីមានប្រមាណប៉ុណ្ណោះ គឺខាងលើ រមែងញាប់ញ័រព្រោះខ្យល់ ចំណែកទឹកដែលមានប្រមាណ ៤ ពាន់យោជន៍ត្រង់កណ្តាល មិនញាប់ញ័រតាំងនៅ នេះឈ្មោះថា អន្ទង់ទឹកជ្រៅ ។

បទថា **ធម្មានិ** បានដល់ ធម្មទេសនាទាំងឡាយ ។ ព្រះដ៏មានព្រះភាគត្រាស់ពាក្យអធិប្បាយនេះថា អន្ទង់ទឹកនោះ ឈ្មោះថា ថ្លា ព្រោះជាទឹកមិនគួរឲ្យខ្ពើម ឈ្មោះថា មិនល្អក់ ព្រោះជាទឹកមិនញាប់ញ័រ យ៉ាងណា បណ្ឌិតទាំងឡាយ ស្តាប់ធម្មទេសនារបស់តថាគតហើយ ដល់នូវភាពជាបុគ្គលមានចិត្តប្រាសចាកឧបក្កិលេស ដោយអំណាចនៃមគ្គ មានសោតាបត្តិមគ្គជាដើម ឈ្មោះថា រមែងផូរផង់ ដូច្នោះ ចំណែកបុគ្គលដែលសម្រេចអរហត្តហើយ រមែងជាអ្នកផូរផង់ ដោយចំណែកមួយ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

## រឿងមាតារបស់នាងកាណា ចប់

# រឿង ភិក្ខុ ៥០០ រូប

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុ ៥០០ រូប ត្រាស់ធម្មទេសនានេះថា **សព្វត្ថ វេ សប្បុរិសា វជន្តិ** ជាដើម ។

ធម្មទេសនាតាំងឡើងក្នុងក្រុងវេរញ្ជា ។

សេចក្តីពិស្តារថា ក្នុងបឋមពោធិកាល ព្រះដ៏មានព្រះភាគយាងទៅកាន់ក្រុងវេរញ្ជា ដែលព្រាហ្មណ៍ឈ្មោះវេរញ្ជៈទូលនិមន្តហើយ ទើបទ្រង់ចាំវស្សាមួយអន្លើដោយភិក្ខុ ៥០០ រូប ។ វេរញ្ជព្រាហ្មណ៍ត្រូវមារបណ្តាលចិត្តមិនឲ្យកើតសតិ ប្រារព្ធដល់ព្រះសាស្តាត្រឹមតែមួយថ្ងៃ ។ កាលវេរញ្ជា ក្លាយជាស្រុកដែលមានអន្តរថ្ងៃហើយ ។ ពួកភិក្ខុត្រាច់ទៅបិណ្ឌបាតពេញក្រុងវេរញ្ជាទាំងខាងក្នុងទាំងខាងក្រៅ កាលមិនបានបិណ្ឌបាត ទើបដល់នូវសេចក្តីលំបាក ។

ពួកឈ្មួញសេះមករៀបចំភិក្ខា មានអង្ករក្រហមប្រហែលមួយទូកដៃៗដើម្បីភិក្ខុទាំងនោះ ។ ព្រះមហាមោគ្គល្លាន ឃើញភិក្ខុទាំងនោះលំបាក មានបំណងនឹងឲ្យភិក្ខុធាន់ក្រមរផែនដី និងបំណងឲ្យពួកភិក្ខុចូលទៅកាន់ឧត្តរកុរុទ្វីបដើម្បីបិណ្ឌបាត ព្រះសាស្តាទ្រង់ហាមហើយ ។ ក្នុងមួយថ្ងៃ ពួកភិក្ខុមិនបានមានសេចក្តីតក់ស្លុតព្រោះប្រារព្ធបិណ្ឌបាត ។ ភិក្ខុទាំងឡាយ វៀរការប្រព្រឹត្តដោយអំណាចការចង់បានហើយ ។

ព្រះសាស្តា ប្រថាប់ក្នុងក្រុងវេរញ្ជានោះ អស់ត្រីមាសហើយ ទ្រង់លាវេរញ្ជព្រាហ្មណ៍ មានសក្ការៈ និងការរាប់អានដែលព្រាហ្មណ៍នោះធ្វើហើយ

ទ្រង់ឲ្យព្រាហ្មណ៍តាំងនៅក្នុងសរណៈហើយ យាងចេញចាកក្រុងវេរញ្ជានោះ ចារិកទៅដោយលំដាប់ ។ សម័យមួយ ទ្រង់យាងដល់ក្រុងសាវត្ថី ប្រថាប់នៅក្នុងវត្តជេតពន អ្នកក្រុងសាវត្ថីធ្វើអាគន្តុកកត្តដល់ព្រះសាស្តាហើយ ។

ក្នុងកាលនោះ ពួកអ្នកស៊ីដែលប្រមាណ ៥០០ នាក់ អាស្រ័យពួកភិក្ខុដែលនៅខាងក្នុងវិហារនោះឯង ។ ពួកគេបរិភោគភោជនដ៏ប្រណីត ដែលសល់អំពីពួកភិក្ខុទាំងឡាយឆាន់ហើយ ក៏ដេកលក់ ក្រោកឡើងហើយទៅកាន់ប្រាំងស៊ីង ស្រែកហ៊ោកញ្ជៀវ ឈោតលេងប្រលែងគ្នា ប្រព្រឹត្តអនាចារប៉ុណ្ណោះទាំងខាងក្នុងវិហារ ទាំងខាងក្រៅវិហារ ។

ពួកភិក្ខុសន្ទនាគ្នាក្នុងរោងធម្មសភាថា អាវុសោទាំងឡាយ មើលចុះ ក្នុងពេលកើតទុព្ភិក្ខភ័យ ពួកអ្នកស៊ីដែលទាំងនេះ មិនបានសម្តែងវិការណាមួយក្នុងក្រុងវេរញ្ជា តែឥឡូវនេះ បរិភោគភោជនដ៏ប្រណីតបែបនេះហើយ សម្តែងអាការប្លែកៗ ជាអនេក ចំណែកពួកភិក្ខុជាអ្នកនៅស្ងៀមក្នុងក្រុងវេរញ្ជា ទោះក្នុងឥឡូវនេះ ក៏នាំគ្នានៅស្ងប់ស្ងៀមដូចគ្នា ។

ព្រះសាស្តាយាងទៅកាន់រោងធម្មសភាហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកសន្ទនាគ្នាអំពីរឿងអ្វី កាលពួកភិក្ខុក្រាបទូលថា បពិត្រព្រះអង្គ រឿងឈ្មោះនេះ ដូច្នេះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងកាលមុន អ្នកស៊ីដែលទាំងនេះ កើតក្នុងកំណើតលា ជាលា ៥០០ បានផឹកទឹកមានរសតិច ជាទឹកអាក្រក់ ដែលដល់នូវការរាប់ថា ទឹកចុង ព្រោះគេយកទឹកដែលប្រេបាច់ពីកាក ដែលត្រាំធ្វើទឹកចណ្ឌមានរសឆ្ងាញ់ ដែលសេះសន្ធពជាតិ

អាជានេយ្យ ៥០០ ផឹកហើយ ទើបត្រងដោយសំពត់សម្បកធ្មៃចាស់ៗ ជារបស់ស្រវឹង ផ្អែម ក៏ស្រែកហ៊ោកញ្ជ្រៀវ កាលទ្រង់សម្ដែងកិរិយារបស់លាទាំងនោះ ដែលព្រះពោធិសត្វជាព្រះរាជា ទ្រង់ស្ដាប់សំឡេងរបស់លាទាំងនោះ ត្រាស់សួរហើយ បានក្រាបទូលព្រះរាជា ត្រាស់វាលោទកជាតកនេះដោយពិស្ដារថា

ព្រះរាជាពារាណសីត្រាស់ថា សេចក្ដីស្រវឹងកើតឡើងដល់ពួកលា ព្រោះផឹកទឹកដែលច្រោះដោយសម្បកក្រចៅ មានរសតិច ជារបស់ថោកទាប សេចក្ដីស្រវឹងមិនកើតដល់ពួកសេះសិន្ធវៈ ព្រោះផឹកទឹកមានរសដ៏ឧត្ដមនេះទេ ។

អមាត្យពោធិសត្វក្រាបទូលថា បពិត្រព្រះអង្គជាធំជាងជនសត្វដែលមានជាតិថោកទាប ផឹកទឹកមានរសតិចហើយ សត្វនោះ ត្រូវទឹកមានរសតិចពាល់ត្រូវហើយ រមែងស្រវឹង ចំណែកសត្វអ្នកនាំនូវធុរៈ នឹងមានមារយាទ កើតក្នុងត្រកូល ( ដ៏ខ្ពស់ ) បានផឹកទឹកមានរសដ៏ប្រសើរ រមែងមិនស្រវឹងទេ ។

ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សប្បុរសវៀរសេចក្ដីលោភហើយ រមែងជាអ្នកមិនមានវិការឡើយ ទាំងក្នុងពេលដល់នូវសេចក្ដីសុខ ទាំងក្នុងពេលដល់នូវសេចក្ដីទុក្ខយ៉ាងនេះ កាលទ្រង់បន្តអនុសន្ធិ បានត្រាស់ព្រះគាថានេះថា

**សព្វត្ថ វេ សប្បុរិសា វជន្តិ ន កាមកាមា លបយន្តិ សន្តោ**

**សុខេន ផុដ្ឋា អថ វា ទុខេន ន ឧច្ចាវចំ បណ្ឌិតា ទស្សយន្តិ ។**

ពួកសប្បុរស តែងលះ ( ឆន្ទរាគៈ ) ក្នុងធម៌ទាំងពួង ពួកលោកអ្នកស្ងប់ រមែងមិនរអែរអួរ ព្រោះសេចក្តីប្រាថ្នាក្នុងកាម ពួកបណ្ឌិត បើសេចក្តីសុខ ឬទុក្ខពាល់ត្រូវហើយ រមែងមិនសម្តែងអាការឡើងចុះឡើយ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សព្វត្ថ** បានដល់ ក្នុងធម៌ទាំងអស់ ដោយធម៌ មានខន្ធជាដើម ។ បុរសល្អឈ្មោះថា **សប្បុរិសា** ។

បទថា **វជន្តិ** សេចក្តីថា សប្បុរស កាលទាញឆន្ទរាគៈចេញហើយ អរហត្តមគ្គញាណ ឈ្មោះថា រមែងវៀរឆន្ទរាគៈ ។

បទថា **ន កាមកាមា** បានដល់ ដែលប្រាថ្នាកាម ម្យ៉ាងទៀត បានដល់ ព្រោះហេតុនៃកាម គឺព្រោះកាមជាហេតុ ។

ពីរបទថា **លបយន្តិ សន្តោ** សេចក្តីថា សប្បុរសទាំងឡាយ មានព្រះសម្ពុទ្ធជាដើម រមែងមិនរអែរអួរដោយខ្លួនឯងឡើយ ទាំងមិនញុំាងអ្នកដទៃឲ្យរអែរអួរព្រោះហេតុនៃកាម ។ ពិតហើយ ភិក្ខុពួកណាចូលទៅដើម្បីភិក្ខា តាំងនៅក្នុងឥដ្ឋាចារ ពោលពាក្យជាដើមថា ឧបាសក បុត្រកិរិយារបស់អ្នកសុខសប្បាយដែរឬទេ ឧបទ្រវៈណាមួយ ដោយអំណាចនៃរាជភ័យ និងចោរភ័យជាដើម មិនមានក្នុងសត្វជើង ២ និងជើង ៤ ទេឬ ភិក្ខុទាំងនោះ ឈ្មោះថារមែងរអែរអួរឯង ។ កាលពោលយ៉ាងនោះហើយ និយាយឲ្យគេនិមន្តខ្លួនថា

យ៉ាងនោះឯង ពួកខ្ញុំគ្រប់គ្នាមានសេចក្ដីសុខសប្បាយ ឧបទ្រវៈណាមួយមិនមាន ឥឡូវនេះ ផ្ទះរបស់ពួកខ្ញុំមានបាយ និងទឹកពោរពាស សូមនិមន្តលោកម្ចាស់នៅក្នុងទីនេះឯង ដូច្នេះ ឈ្មោះថា ឲ្យបុគ្គលដទៃរអែរអូរ ។ ចំណែកសប្បុរសទាំងឡាយ រមែងមិនធ្វើការនិយាយរអែរអូរទាំងពីរយ៉ាងនេះ ។

ពាក្យថា **សុខេន ផុដ្ឋា អថ វា ទុខេន** នេះ ឈ្មោះថា ជាទេសនាអធិប្បាយថា បណ្ឌិតទាំងឡាយដែលលោកធម៌ ៨ ពាល់ត្រូវហើយ រមែងមិនសម្ដែងអាការឡើងចុះ ដោយអំណាចនៃភាពជាបុគ្គលត្រេកអរ និងភាពជាបុគ្គលខ្មាសអៀន ឬដោយអំណាចនៃការពោលគុណ និងទោស ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។ល។

**រឿង ភិក្ខុ ៥០០ រូប ចប់**

# រឿង ព្រះថេរៈតាំងនៅក្នុងធម៌

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះធម្មិកត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **ន អត្តហេតុ** ជាដើម ។

បានឮថា ឧបាសកម្នាក់ ក្នុងក្រុងសាវត្ថី គ្រប់គ្រងផ្ទះដោយធម៌ ។ ឧបាសកនោះ ជាអ្នកប្រាថ្នានឹងបួស ថ្ងៃមួយ អង្គុយសន្ទនាជលំពាក្យប្រារព្ធ

សុខជាមួយភរិយា ទើបពោលថា នែនាង ខ្ញុំប្រាថ្នានឹងបួស ភរិយាអង្វរថា នែអ្នក បើដូច្នោះ សូមអ្នកបង្អង់សិន ទម្រាំខ្ញុំប្រសូតបុត្រក្នុងផ្ទៃសិនចុះ ។ គាត់រង់ចាំហើយ ក្នុងកាលដែលទារកដើរបាន ទើបលានាងម្តងទៀត កាលនាងអង្វរថា នែអ្នក សូមអ្នកបង្អង់សិន ទម្រាំក្មេងនេះចម្រើនវ័យចុះ ។ ទើបគាត់គិតថា ប្រយោជន៍អ្វីរបស់អញដោយស្រីនេះ ដែលអញលាហើយ ឬមិនលា អញនឹងធ្វើការរលាស់ចេញចាកទុក្ខដល់ខ្លួន ដូច្នេះហើយ ចេញទៅបួស ។ លោករៀនកម្មដ្ឋាន ព្យាយាមញ៉ាំងកិច្ចរបស់បព្វជិត របស់ខ្លួនឲ្យសម្រេចហើយ ទើបត្រឡប់មកក្រុងសាវត្ថីវិញ ដើម្បីសួរសុខទុក្ខបុត្រ និងភរិយាទាំងនោះ ហើយបានសម្តែងធម្មកថាដល់បុត្រ ។

សូម្បីកូននោះក៏ចេញបួសហើយ កាលបួសហើយមិនយូរប៉ុន្មានក៏សម្រេចអរហត្ត ។ ភរិយាអំពីមុនរបស់ភិក្ខុគិតថា អញនៅគ្រប់គ្រងផ្ទះដើម្បីប្រយោជន៍ដល់អ្នកណា ជនទាំងពីរនាក់នោះក៏បួសហើយ ឥឡូវនេះ ប្រយោជន៍អ្វីរបស់អញដោយការគ្រប់គ្រងផ្ទះ អញនឹងបួស ហើយទើបចេញទៅបួសក្នុងសម្នាក់ភិក្ខុនី កាលបួសហើយ មិនយូរប៉ុន្មានក៏បានសម្រេចអរហត្ត ។

ថ្ងៃមួយ ពួកភិក្ខុសន្ទនាគ្នាក្នុងធម្មសភាថា អាវុសោទាំងឡាយ ធម្មិក-ឧបាសកចេញបួសសម្រេចអរហត្តហើយ បានជាទីពឹងដល់កូនផង ភរិយាផងក៏ព្រោះភាពដែលខ្លួនតាំងនៅក្នុងធម៌ ។

ព្រះសាស្តាយាងមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយរឿងអ្វីហ្ន៎ កាលពួកភិក្ខុក្រាបទូលថា

ដោយរឿងឈ្មោះនេះ ព្រះអង្គ ហើយទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាបណ្ឌិត មិនគប្បីប្រាថ្នាសេចក្ដីសម្រេចព្រោះហេតុនៃខ្លួន និងមិនគប្បីប្រាថ្នាការសម្រេច ព្រោះហេតុនៃអ្នកដទៃឡើយ តែគប្បីជាអ្នកតាំងនៅក្នុងធម៌ មានធម៌ជាទីពឹងដោយពិត កាលទ្រង់បន្តអនុសន្ធិ ទើបត្រាស់ព្រះគាថានេះថា

**ន អត្តហេតុ ន បរស្ស ហេតុ ន បុត្តមិច្ឆេ ន ធនំ ន រដ្ឋំ**
**ន ឥច្ឆេយ្យ អធម្មេន សមិទ្ធិមត្តនោ ស សីលវា បញ្ញវា ធម្មិកោ សិយា ។**

បណ្ឌិត មិនគួរធ្វើអាក្រក់ ព្រោះហេតុនៃខ្លួន មិនគួរធ្វើអាក្រក់ ព្រោះហេតុនៃអ្នកដទៃ មិនគួរប្រាថ្នាកូន មិនគួរប្រាថ្នាទ្រព្យ មិនគួរប្រាថ្នារដ្ឋ មិនគួរប្រាថ្នាសមិទ្ធិដើម្បីខ្លួន ដោយហេតុមិនមែនជាធម៌ឡើយ លោកគួរជាអ្នកមានសីល មានប្រាជ្ញាប្រកបដោយធម៌ ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **ន អត្តហេតុ** សេចក្ដីថា ធម្មតាបណ្ឌិតរមែងមិនធ្វើបាប ព្រោះហេតុនៃខ្លួន ឬព្រោះហេតុនៃបុគ្គលដទៃ ។

បទថា **ន បុត្តមិច្ឆេ** សេចក្ដីថា បណ្ឌិតមិនគប្បីប្រាថ្នាកូន ឬទ្រព្យ ឬដែនដោយកម្មដ៏លាមក បណ្ឌិតកាលប្រាថ្នាវត្ថុទាំងនោះ រមែងមិនធ្វើកម្មលាមកឡើយ ។

បទថា **សមិទ្ធិមត្តនោ** សេចក្ដីថា បណ្ឌិត មិនគប្បីប្រាថ្នាសម្បត្តិការសម្រេចដើម្បីខ្លួនដោយមិនជាធម៌ អធិប្បាយថា បណ្ឌិត រមែងមិនធ្វើបាប

ព្រោះហេតុនៃសេចក្ដីសម្រេច ។

បទថា **ស សីលវា** សេចក្ដីថា បុគ្គលបែបនេះ គប្បីជាអ្នកមានសីល មានបញ្ញា តាំងនៅក្នុងធម៌ អធិប្បាយថា មិនគប្បីជាបុគ្គលដទៃ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

**រឿង ព្រះថេរៈតាំងនៅក្នុងធម៌ ចប់**

# រឿង ការស្ដាប់ធម៌

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការស្ដាប់ធម៌ ត្រាស់ព្រះធម្មទេសនានេះថា **អប្បកា តេ មនុស្សេសុ** ជាដើម ។

បានឮមកថា ពួកមនុស្សដែលនៅតាមវិថីមួយជាមួយគ្នា ក្នុងក្រុងសាវត្ថី ជាអ្នកព្រមព្រៀងគ្នា ថ្វាយទានរួមគ្នាជាគណៈហើយ ក៏ឲ្យធ្វើការស្ដាប់ធម៌មួយយប់ទល់ភ្លឺ តែមិនអាចស្ដាប់ធម៌ទល់ភ្លឺ បុគ្គលពួកខ្លះ ជាអ្នកអាស្រ័យការត្រេកអរក្នុងកាម ក៏ត្រឡប់ទៅផ្ទះមុនគេ ពួកខ្លះ ជាអ្នកអាស្រ័យទោសៈទៅហើយ ។ តែពួកខ្លះ ដែលងោកងុយពេញទំហឹង អង្គុយងក់ក្នុងទីនោះឯង មិនអាចស្ដាប់បាន ស្អែកឡើង ពួកភិក្ខុញ៉ាំងពាក្យឲ្យតាំងឡើងក្នុងរោងធម្មសភា ដល់រឿងនោះ ។ ព្រះសាស្ដាទ្រង់យាងមក ត្រាស់សួរថា ម្នាលភិក្ខុ

*ទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាល ភិក្ខុទាំងឡាយក្រាបទូលថា ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុ ទាំងឡាយ ធម្មតាសត្វទាំងនេះអាស្រ័យភពហើយ ជាប់ជំពាក់ក្នុងភពនោះ ឯង ដោយច្រើន បុគ្គលដែលស្តាប់មានចំនួនតិច កាលទ្រង់បន្តអនុសន្ធិ បានត្រាស់ព្រះគាថានេះថា*

**អប្បកា តេ មនុស្សេសុ　　យេ ជនា បារគាមិនោ**
**អថាយំ ឥតរា បជា　　តីរមេវានុធាវតិ ។**
**យេ ច ខោ សម្មទក្ខាតេ　　ធម្មេ ធម្មានុវត្តិនោ**
**តេ ជនា បារមេស្សន្តិ　　មច្ចុធេយ្យំ សុទុត្តរំ ។**

*បណ្តាមនុស្សទាំងឡាយ ពួកជនណាដែលឆ្លងដល់ត្រើយ គឺព្រះនិព្វាន ពួកជននោះ មានប្រមាណតិច ចំណែកពួក សត្វក្រៅនេះ រមែងស្ទុះទៅកាន់ត្រើយ ( គឺសក្កាយទិដ្ឋិ )។ ជនទាំងឡាយណា ប្រព្រឹត្តតាមធម៌ក្នុងធម៌ ដែលព្រះ តថាគត ទ្រង់សម្តែងទុកហើយដោយប្រពៃ ជនទាំងនោះ នឹងឆ្លងនូវលំនៅនៃមច្ចុ ដែលមិនងាយឆ្លងបាន ហើយ ដល់នូវព្រះនិព្វាន ។*

## សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ បទថា* **អប្បកា** *គឺបន្តិចបន្តួច បានដល់ មិនច្រើន ។ បទថា* **បារគាមិនោ** *គឺសម្រេចព្រះនិព្វាន ។ បាទព្រះគាថាថា* **អថាយំ ឥតរា**

**បជា** សេចក្ដីថា ចំណែកប្រជាដ៏សេសនេះ រមែងស្ទុះទៅកាន់ត្រើយ គឺសក្កាយទិដ្ឋិនេះមានច្រើន ។

បទថា **សម្មទក្ខាតេ** គឺត្រាស់ដោយប្រពៃ បានដល់ ត្រាស់ត្រឹមត្រូវ ។ បទថា **ធម្មេ** គឺក្នុងធម្មទេសនា ។ បទថា **ធម្មានុវត្តិនោ** សេចក្ដីថា ប្រព្រឹត្តសមគួរដល់ធម៌ ដោយអំណាចនៃការស្ដាប់ធម៌នោះហើយ បំពេញបដិបទាសមគួរដល់ធម៌នោះហើយ ធ្វើមគ្គផលឲ្យជាក់ច្បាស់ ។

បទថា **ចារមេស្សន្តិ** សេចក្ដីថា ជនទាំងនោះ គឺបែបនោះ នឹងដល់នូវត្រើយ គឺព្រះនិព្វាន ។ បទថា **មច្ចុធេយ្យំ** បានដល់ វដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិ ដែលជាទីនៅអាស្រ័យរបស់មច្ចុ ពោល គឺកិលេសមារ ។

បទថា **សុទុត្តរំ** សេចក្ដីថា ជនទាំងឡាយណាប្រព្រឹត្តធម៌សមគួរដល់ធម៌ ជនទាំងនោះ កន្លង គឺរំលងអន្ទាក់មារដែលឆ្លងបានលំបាក គឺឈានកន្លងបានលំបាកហើយនោះ នឹងដល់នូវត្រើយ គឺព្រះនិព្វាន ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

## រឿង ការស្ដាប់ធម៌ ចប់

# រឿង អាគន្តុកភិក្ខុ

## លំនាំដើម

*ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអាគន្តុកភិក្ខុ ត្រាស់ព្រះធម្មទេសនានេះថា* **កណ្ហំ ធម្មំ វិប្បហាយ** *ជាដើម ។*

*បានឮមកថា ភិក្ខុប្រមាណ ៥០០ រូប ចាំវស្សានៅក្នុងដែនកោសល ចេញវស្សាហើយ ប្រឹក្សាគ្នាថានឹងគាល់ព្រះសាស្ដា ទើបទៅកាន់វត្តជេតពន ថ្វាយបង្គំព្រះសាស្ដាហើយ គង់នៅក្នុងទីបំផុតក្នុងទីមួយកន្លែង ព្រះសាស្ដាទ្រង់ពិចារណាធម៌ ដែលជាបដិបក្ខដល់ចរិយារបស់ពួកលោក កាលទ្រង់សម្ដែងធម៌ បានត្រាស់គាថាទាំងនេះថា*

**កណ្ហំ ធម្មំ វិប្បហាយ សុក្កំ ភាវេថ បណ្ឌិតោ**
**ឱកា អនោកមាគម្ម វិវេកេ យត្ថ ទូរមំ ។**
**តត្រាភិរតិមិច្ឆេយ្យ ហិត្វា កាមេ អកិញ្ចនោ**
**បរិយោទបេយ្យ អត្តានំ ចិត្តក្លេសេហិ បណ្ឌិតោ ។**
**យេសំ សម្ពោធិយង្គេសុ សម្មា ចិត្តំ សុភាវិតំ**
**អាទានបដិនិស្សគ្គេ អនុបាទាយ យេ រតា**
**ខីណាសវា ជុតិមន្តោ តេ លោកេ បរិនិព្វុតា ។**

*ជនទាំងឡាយណា ប្រព្រឹត្តក្នុងធម៌ ដែលព្រះតថាគតទ្រង់សម្ដែងទុកហើយដោយប្រពៃ ជនទាំងនោះ នឹងឆ្លងនូវលំនៅនៃមច្ចុ ដែលមិនងាយឆ្លងបាន ហើយដល់នូវព្រះនិព្វាន ។ បណ្ឌិតគួរលះបង់ធម៌ខ្មៅចេញ ញ៉ាំងធម៌ស*

ឲ្យចម្រើនឡើង ( ដោយវិធី ) ចេញចាកអាល័យ គឺ
កាមគុណ ហើយឈមទៅរកព្រះនិព្វាន ជាធម្មជាតមិន
មានអាល័យ គប្បីលះបង់កាមទាំងឡាយចេញ ជាអ្នក
មិនមានកង្វល់ ប្រាថ្នានូវសេចក្តីត្រេកអរក្នុងវិវេក ដែល
ពួកសត្វត្រេកអរបានដោយក្រនោះ បណ្ឌិតគួរញុំាងខ្លួន
ឲ្យផូរផង់ចាកគ្រឿងសៅហ្មងចិត្ត ។ ចិត្តដែលបណ្ឌិត
ទាំងឡាយបានអប់រំល្អហើយ ជាអង្គនៃធម៌ ជាគ្រឿង
ត្រាស់ដឹងទាំងឡាយ ឬបណ្ឌិតទាំងឡាយណា មិន
ប្រកាន់មាំ ត្រេកអរតែក្នុងការលះនូវសេចក្តីប្រកាន់មាំ
បណ្ឌិតទាំងឡាយនោះ រមែងជាអ្នកអស់អាសវៈ មាន
សេចក្តីរុងរឿង បរិនិព្វានក្នុងលោក ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **កណ្ហំ ធម្មំ** សេចក្តីថា លះ គឺលះ អកុសលធម៌ មានកាយទុច្ចរិតជាដើម ។

ពីរបទថា **សុក្កំ ភាវេថ** សេចក្តីថា កិច្ចដែលជាបណ្ឌិតគួរចម្រើនធម៌ស មានកាយសុចរិតជាដើម តាំងអំពីចេញបួស រហូតដល់អរហត្តមគ្គ ។ ចម្រើនដូចម្តេច គឺចេញចាកអាល័យ ប្រារព្ធធម៌ដែលមិនមានអាល័យ ។

អធិប្បាយថា ធម៌ជាហេតុឲ្យអាល័យ ត្រាស់ហៅថា **ឱក** ធម៌ជាហេតុឲ្យមិនមានអាល័យ ត្រាស់ហៅថា **អនោក** បណ្ឌិតចេញចាកធម៌ ជាហេតុ

ឲ្យអាល័យហើយ ឧទ្ទិស គឺប្រារព្ធព្រះនិព្វាន ពោល គឺធម៌ជាហេតុមិនមាន អាល័យ កាលប្រាថ្នាព្រះនិព្វាននោះ គួរចម្រើនធម៌ស ។

បាទព្រះគាថាថា **តត្រាភិរតិមិច្ឆេយ្យ** សេចក្ដីថា គប្បីប្រាថ្នាសេចក្ដីត្រេកអរក្រៃលែងក្នុងវិវេក ដែលរាប់ថា ជាធម៌មិនមានអាល័យ គឺព្រះនិព្វាន ដែលសត្វទាំងនោះ អភិរម្យបានដោយលំបាក ។

ពីរបទថា **ហិត្វា កាមេ** សេចក្ដីថា លះវត្ថុកាម និងកិលេសកាម ហើយ ជាអ្នកអស់កង្វល់ គប្បីប្រាថ្នាសេចក្ដីត្រេកអរក្រៃលែងក្នុងវិវេក ។

បទថា **ចិត្តក្លេសេហិ** សេចក្ដីថា គប្បីធ្វើខ្លួនឲ្យស្អាតផង់ គឺឲ្យបរិសុទ្ធចាកនីវរណៈ ៥ ។

បទថា **សម្ពោធិយង្គេសុ** បានដល់ ក្នុងធម៌ជាគ្រឿងត្រាស់ដឹង ។

បាទព្រះគាថាថា **សម្មា ចិត្តំ សុភាវិតំ** សេចក្ដីថា ជនទាំងឡាយណាអប់រំ គឺចម្រើនចិត្តដោយល្អហើយ តាមហេតុ គឺតាមន័យ ។

បាទព្រះគាថាថា **អាទានបដិនិស្សគ្គេ** សេចក្ដីថា ការប្រកាន់ ត្រាស់ហៅថា ការប្រកាន់មាំ ជនទាំងឡាយណា មិនប្រកាន់មាំនូវវត្ថុណាមួយ ដោយឧបាទាន ៤ ត្រេកអរហើយក្នុងការមិនប្រកាន់មាំ ពោល គឺការលះបង់នូវការប្រកាន់នោះ ។

បទថា **ជុតិមន្តោ** សេចក្ដីថា ជាអ្នកមានអានុភាព គឺជាអ្នកញុំាំងធម៌មានខន្ធជាដើមឲ្យរុងរឿង ហើយតាំងមាំ ដោយការរុងរឿង គឺញាណដែលទាក់ទងដោយអរហត្តមគ្គ ។ ពីរបទថា **តេ លោកេ** ជាដើម សេចក្ដីថា ជន

ទាំងនោះ ឈ្មោះថា រលត់ឥតសេសសល់ហើយ ក្នុងខន្ធាទិលោកនេះ គឺបរិនិព្វានហើយ ដោយបរិនិព្វាន ២ យ៉ាង គឺដោយសឧបាទិសេសបរិនិព្វាន ព្រោះកិលេសវដ្តដែលខ្ជូនឲ្យអស់ទៅហើយ តាំងអំពីពេលសម្រេចអរហត្ត និងដោយអនុបាទិសេសបរិនិព្វាន ព្រោះខន្ធវដ្តដែលខ្ជូនឲ្យអស់ទៅហើយ ដោយរម្ងត់ចរិមចិត្ត គឺដល់នូវការមិនមានបញ្ញត្តិ ដូចប្រទីបមិនមានកំញម ដូច្នោះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើម ដូច្នេះឯង ។៚

**រឿងអាគន្តុកភិក្ខុ ចប់**

**បណ្ឌិតវគ្គ ចប់**

**វគ្គទី ៦ ចប់**

# សុត្តន្តបិដក

## ធម្មបទគាថា អរហន្តវគ្គទី ៧

[ ១៧ ] សេចក្តីក្តៅក្រហាយ រមែងមិនមានដល់លោកអ្នក មានផ្លូវឆ្ងាយដើរដល់ហើយ មិនមានសេចក្តីសោក រួចស្រឡះចាកធម៌ទាំងពួង ( មានខន្ធជាដើម ) មានកិលេសជាគ្រឿងចាក់ស្រេះទាំងពួង លះបង់ហើយ ។

ព្រះខីណាស្រពទាំងឡាយ មានស្មារតី រមែងខ្វល់ខ្វាយ រមែងត្រេកអរក្នុងទីនៅអាស្រ័យ លោកលះបង់ចោលស្រឡះ នូវអាល័យទាំងអស់ ដូចហង្សលះបង់ពួកហើរទៅ ដូច្នោះ ។ ពួកជនណា មិនមានសេចក្តីសន្សំ ពួកជនណា កំណត់ដឹងភោជនហើយ ជនណាមានសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ និងអប្បណិហិតវិមោក្ខ ជាគោចរ គតិ គឺដំណើររបស់ពួកជននោះៗ គេកម្រដឹងបាន ដូចដំណើរនៃពួកសត្វស្លាបឰដ៏អាកាស ដូច្នោះ ។

ជនណា អស់អាសវៈហើយ ទាំងមិនអាស្រ័យ ( តណ្ហា និងទិដ្ឋិ ) ក្នុងអាហារ ជនណា មានសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ និងអប្បណិហិត-វិមោក្ខ ជាគោចរ ដំណើររបស់ជននោះ គេកម្រដឹងបាន ដូចដំណើរនៃពួកសត្វស្លាបឰដ៏អាកាស ដូច្នោះ ។

ឥន្ទ្រិយទាំងឡាយ របស់អ្នកណា ដល់នូវការស្ងប់រម្ងាប់ ដូចសេះដែលនាយសារថី ហ្វឹកហ្វឺនរាបហើយ សូម្បីទេវតា និងមនុស្សទាំងឡាយក៏ស្រឡាញ់អ្នកនោះឯង ដែលមានមានះលះបង់ហើយ មិនមានអាសវៈ ជាបុគ្គលមានចិត្តនឹងធឹង មិនញាប់ញ័រ ។

ភិក្ខុមានចិត្តដូចផែនដី មិនក្រោធ មានវត្តល្អ មានចិត្តនឹងធឹងដូចសសរគោល មានចិត្តថ្លា ដូចអន្លង់ប្រាសចាកភក់ សង្សារទាំងឡាយ របស់ភិក្ខុបែបនោះ រមែងមិនមាន ។

ចិត្តស្ងប់ វាចាស្ងប់ និងកាយកម្មស្ងប់ រមែងមានដល់លោក ដែលដឹងដោយប្រពៃ ផុតស្រឡះ ( ចាករាគាទិក្កិលេស ) ជាអ្នកស្ងប់រម្ងាប់ដូច្នោះ ។

នរជនណា មិនជឿអ្នកដទៃផង ស្គាល់ព្រះនិព្វានផង កាត់នូវគ្រឿងតគឺវដ្តៈផង មានឱកាសកម្ចាត់បង់ហើយផង មានសេចក្តីប្រាថ្នាខ្ជាក់ចោលហើយផង នរជននោះ ជាឧត្តមបុរស ។

ព្រះអរហន្តទាំងឡាយ នៅក្នុងទីណា ទោះជាស្រុកក្តី ព្រៃក្តី ទីទាបក្តី ទីទួលក្តី ទីនោះឯង ជាភូមិគួរត្រេកអរ ។

ជន ( អ្នកស្វែងរកកាម ) រមែងមិនត្រេកអរ ក្នុងព្រៃដែលគួររីករាយទេ ព្រះខីណាស្រពដែលមានរាគៈទៅប្រាសហើយ ទើបត្រេកអរក្នុងព្រៃនោះ ព្រោះលោកជាអ្នកមិនស្វែងរកកាម ។

**អរហន្តវគ្គទី ៧ ចប់**

# អដ្ឋកថា

# អរហន្តវគ្គទី ៧

## រឿង ពេទ្យជីវក

### លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងចម្ការស្វាយរបស់ពេទ្យជីវក ទ្រង់ប្រារព្ធបញ្ហាដែលពេទ្យជីវកទូលសួរហើយ ត្រាស់ព្រះធម្មទេសនានេះថា **គតទ្ធិនោ** ជាដើម ។ រឿងពេទ្យជីវក លោកឲ្យពិស្តារក្នុងខន្ធកៈហើយ ។

សេចក្តីពិស្តារថា សម័យមួយ ទេវទត្តជាអ្នករួមគំនិតនឹងព្រះបាទអជាតសត្តុ ឡើងកាន់ភ្នំគិជ្ឈកូដ មានចិត្តប្រទូស្ត គិតថា អញនឹងផ្តាច់ព្រះជន្មព្រះសាស្តា ទើបប្រមៀលថ្មចុះ កំពូលភ្នំពីរទទួលថ្មនោះ ។ បំណែកថ្មបែកចេញអំពីថ្មនោះ ខ្ទាតទៅចំព្រះបាទារបស់ព្រះដ៏មានព្រះភាគ ញ៉ាំងព្រះលោហិតឲ្យពុះពងហើយ ។ វេទនាដ៏ខ្លាំងក្លាប្រព្រឹត្តទៅហើយ ។

ភិក្ខុទាំងឡាយ នាំព្រះសាស្តាទៅកាន់ឧទ្យានមទ្ទកុច្ឆិ[១] ។ ព្រះសាស្តាមានបំណងនឹងយាងចេញអំពីឧទ្យានមទ្ទកុច្ឆិនោះ ទៅកាន់ចម្ការស្វាយរបស់ពេទ្យជីវក ទើបត្រាស់ថា អ្នកទាំងឡាយ ចូរនាំតថាគតទៅកាន់ចម្ការស្វាយ

---

១- ឧទ្យានរំលូតកូន បានឮថា ព្រះនាងវេទេហីព្យាយាមរំលូតព្រះបាទអជាតសត្តុក្នុងឧទ្យាននេះ ។

របស់ពេទ្យជីវកនោះ ។ ពួកភិក្ខុបាននាំព្រះដ៏មានព្រះភាគ ទៅកាន់ចម្ការស្វាយរបស់ពេទ្យជីវកហើយ ។

ពេទ្យជីវកជ្រាបរឿងនោះ ទៅកាន់សម្នាក់ព្រះសាស្ដា ថ្វាយភេសជ្ជៈដើម្បីប្រយោជន៍ដល់ការផ្សះដំបៅ រុំមុខរបួសស្រេចហើយ បានក្រាបទូលពាក្យនេះដល់ព្រះសាស្ដាថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គធ្វើភេសជ្ជៈដល់មនុស្សម្នាក់ខាងក្នុងព្រះនគរ ខ្ញុំព្រះអង្គនឹងទៅកាន់សម្នាក់របស់មនុស្សនោះហើយនឹងត្រឡប់មកគាល់វិញ សូមទ្រង់តាំងនៅដោយនិយាម ដែលខ្ញុំព្រះអង្គរុំនោះឯង ទម្រាំខ្ញុំព្រះអង្គត្រឡប់មក ។

ពេទ្យជីវក ទៅធ្វើកិច្ចដែលគួរធ្វើដល់បុរសនោះហើយ ត្រឡប់មកក្នុងកាលដែលគេបិទទ្វារ ។ ពេលនោះ គាត់មានបរិវិតក្កយ៉ាងនេះថា ស៊ិយហ្ន៎ អញធ្វើកម្មធ្ងន់ហើយ ដែលអញថ្វាយភេសជ្ជៈដ៏ចាស់ រុំរបួសត្រង់ព្រះបាទរបស់ព្រះតថាគតដូចមនុស្សសាមញ្ញ ពេលនេះ ជាពេលដែលត្រូវស្រាយរបួសនោះ បើរបួសនោះមិនបានស្រាយ ការក្ដៅក្នុងព្រះសរីរៈរបស់ព្រះដ៏មានព្រះភាគ នឹងតាំងឡើងមួយយប់ទល់ភ្លឺ ។

ខណៈនោះ ព្រះសាស្ដា ត្រាស់ហៅព្រះអានន្ទត្ថេរមកគាល់ ត្រាស់ថា ម្នាលអានន្ទ ពេទ្យជីវកមកក្នុងពេលល្ងាចមិនទាន់ទ្វារ ជីវកគិតថា ពេលនេះជាពេលស្រាយរបួស ចូរអ្នកស្រាយរបួសនោះ ព្រះថេរៈស្រាយហើយ ដំបៅក៏ជាដូចដើម ដូចក្រមរឈើជ្រុះអំពីដើមឈើ ។

ពេទ្យជីវក រួតរះមកកាន់សម្នាក់ព្រះសាស្ដា ខាងក្នុងអរុណនោះឯង

ទូលសួរថា បពិត្រព្រះអង្គ ការក្តៅក្រហាយកើតក្នុងព្រះសរីរៈរបស់ព្រះអង្គ ដែរឬ ព្រះសាស្តាត្រាស់ថា ជីវក ការក្តៅក្រហាយទាំងពួងរបស់តថាគត ស្ងប់រម្ងាប់ហើយ តាំងពីទទួលនូវពុទ្ធភូមិនោះឯង ដូច្នេះហើយ កាលទ្រង់បន្ត អនុសន្ធិ ទើបត្រាស់ព្រះគាថានេះថា

**គតទ្ធិនោ វិសោកស្ស   វិប្បមុត្តស្ស សព្វធិ**

**សព្វគន្ថប្បហីនស្ស   បរិឡាហោ ន វិជ្ជតិ ។**

សេចក្តីក្តៅក្រហាយ រមែងមិនមានដល់លោកអ្នកមាន ផ្លូវឆ្ងាយដើរដល់ហើយ មិនមានសេចក្តីសោក រួច ស្រឡះចាកធម៌ទាំងពួង ( មានខន្ធជាដើម ) មាន កិលេសជាគ្រឿងចាក់ស្រែះទាំងពួង លះបង់ហើយ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **គតទ្ធិនោ** បានដល់ ដែលមានផ្លូវឆ្ងាយ ដល់ហើយ ។ ផ្លូវឆ្ងាយមានពីរយ៉ាង ផ្លូវឆ្ងាយ គឺកន្តារ ១ ផ្លូវឆ្ងាយ គឺវដ្តៈ ១ ។ បណ្តាផ្លូវឆ្ងាយពីរយ៉ាងនោះ បុគ្គលដើរផ្លូវកន្តារ មិនទាន់ដល់ទីដែលខ្លួន ប្រាថ្នាដរាបណា ក៏ឈ្មោះថា ជាអ្នកដើរផ្លូវឆ្ងាយរឿយៗ ដរាបនោះ តែកាលផ្លូវ ឆ្ងាយនោះ ដែលបុគ្គលនោះចូលដល់ហើយ រមែងជាបុគ្គល ឈ្មោះថា មាន ផ្លូវឆ្ងាយដល់ហើយ ចំណែកសត្វទាំងឡាយ ដែលដើរក្នុងផ្លូវវដ្តៈ ខ្លួននៅក្នុង វដ្តៈដរាបណា ក៏ឈ្មោះថា ជាអ្នកដើរផ្លូវឆ្ងាយរឿយៗ ទៅដរាបនោះ ។ មាន ពាក្យសួរជ្រៀតចូលមកថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះភាពដែលវដ្តៈ

ដែលខ្លួនមិនទាន់លះបាន ។ ព្រះអរិយបុគ្គលទាំងឡាយ មានព្រះសោតាបន្ន ជាដើម ក៏ឈ្មោះថា ដើរផ្លូវឆ្ងាយដូចគ្នា ចំណែកព្រះខីណាស្រព ញ៉ាំងវដ្ដៈ ឲ្យអស់ទៅបានហើយ តាំងនៅ រមែងជាបុគ្គល ឈ្មោះថា មានផ្លូវឆ្ងាយដល់ ហើយ ។ ដល់ព្រះខីណាស្រពដែលមានផ្លូវឆ្ងាយ ដល់ហើយនោះ ។

បទថា **វិសោកស្ស** គឺឈ្មោះថាជាអ្នកមិនមានសេចក្ដីសោក ព្រោះភាព ដែលសេចក្ដីសោក មានវដ្ដៈជាមូលទៅប្រាសហើយ ។

បាទព្រះគាថាថា **វិប្បមុត្តស្ស សព្វធិ** គឺរួចផុតហើយក្នុងធម៌ មានខន្ធ ទាំងពួងជាដើម ។

បាទព្រះគាថាថា **សព្វគន្ថប្បហីនស្ស** គឺឈ្មោះថា ជាអ្នកលះកិលេស ជាគ្រឿងរួបរឹតទាំងពួងបាន ព្រោះភាពដែលកិលេសជាគ្រឿងរួបរឹត ៤ យ៉ាង ដែលខ្លួនលះបានហើយ ។

បាទព្រះគាថាថា **បរិឡាហោ ន វិជ្ជតិ** សេចក្ដីថា ការក្ដៅក្រហាយ មានពីរយ៉ាង គឺក្ដៅក្រហាយប្រព្រឹត្តទៅតាមកាយ ១ ក្ដៅក្រហាយប្រព្រឹត្តទៅ ផ្លូវចិត្ត ១ ។ បណ្ដាការក្ដៅក្រហាយពីរយ៉ាងនោះ ការក្ដៅក្រហាយប្រព្រឹត្ត ទៅតាមកាយ ដែលកើតឡើងដល់ព្រះខីណាស្រព ដោយអំណាចនៃផស្សៈ មានរងា និងក្ដៅជាដើម មិនទាន់រលត់ឡើយ ពេទ្យជីវកទូលសួរសំដៅដល់ ការក្ដៅក្រហាយ ដែលប្រព្រឹត្តទៅតាមកាយនោះ ។ តែព្រះសាស្ដា ទ្រង់ បង្ហួសព្រះធម្មទេសនា ដោយអំណាចនៃការក្ដៅក្រហាយ ដែលប្រព្រឹត្តទៅ តាមផ្លូវចិត្ត ព្រោះភាពដែលទ្រង់ជាអ្នកឈ្លាសក្នុងទេសនាវិធី ព្រោះភាពដែល

ទ្រង់ជាព្រះធម្មរាជា ទើបត្រាស់ថា ជីវក ដោយបរមត្ថ ការក្តៅក្រហាយ រមែងមិនមានដល់ព្រះខីណាស្រព ដែលជាអ្នកឃើញបែបនោះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើម ដូច្នេះឯង ។ល។

**រឿង ពេទ្យជីវក ចប់**

# រឿង ព្រះមហាកស្សបត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រះមហាកស្សបត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **ឧយ្យុញ្ជន្តិ** ជាដើម ។

សេចក្តីពិស្តារថា សម័យមួយ ព្រះសាស្តាទ្រង់ចាំវស្សានៅក្នុងក្រុងរាជគ្រឹះ ទ្រង់ត្រាស់ដល់ភិក្ខុទាំងឡាយថា ក្នុងកាលកន្លងទៅកន្លះខែ តថាគតនឹងទៅកាន់ទីចារិក ។

បានឮថា ការត្រាស់ដល់ភិក្ខុទាំងឡាយថា ឥឡូវនេះ នឹងចៀសទៅកាន់ទីចារិក ដោយកាលកន្លងទៅកន្លះខែដូច្នេះ ដោយទ្រង់បំណងថា ភិក្ខុទាំងឡាយនឹងធ្វើកិច្ចផ្សេងៗ មានការអប់បាត្រ និងជ្រលក់ចីវរជាដើមរបស់ខ្លួនហើយ នឹងទៅតាមសប្បាយដោយអាការយ៉ាងនេះ នេះជាទំនៀមរបស់ព្រះពុទ្ធទាំងឡាយ ដែលមានបំណងចារិកទៅ មួយអន្លើដោយពួកភិក្ខុ ។ កាលភិក្ខុទាំង-

ឡាយកំពុងធ្វើកិច្ចផ្សេងៗ មានការអប់បាត្រជាដើម ព្រះមហាកស្សបត្ថេរ ក៏បោកចីវរទាំងឡាយហើយ ។

ពួកភិក្ខុលើកទោសថា ព្រោះហេតុអ្វី ទើបព្រះថេរៈបោកចីវរក្នុងព្រះនគរនេះ ទាំងខាងក្នុង និងខាងក្រៅ មានមនុស្សអាស្រ័យនៅ ១៨ កោដិ បណ្ដាមនុស្សទាំងនោះ ពួកណាមិនជាញាតិរបស់ព្រះថេរៈ មនុស្សពួកនោះជាឧបដ្ឋាក មនុស្សពួកណាមិនជាឧបដ្ឋាក មនុស្សពួកនោះជាញាតិ ជនទាំងនោះ រមែងធ្វើការរាប់អាន និងធ្វើសក្ការៈដល់ព្រះថេរៈដោយបច្ច័យទាំង ៤ ព្រះថេរៈនោះ នឹងលះឧបការៈមានប្រមាណប៉ុណ្ណោះ ទៅក្នុងទីណាបាន បើគប្បីទៅបាន ក៏មិនទៅហួសអំពីញកឈ្មោះមាបមាទ ។

បានឮមកថា ព្រះសាស្ដាយាងដល់ញកណាហើយ រមែងត្រាស់ប្រាប់ភិក្ខុទាំងឡាយដែលគួរទ្រង់ឲ្យត្រឡប់ថា ចូរអ្នកទាំងឡាយត្រឡប់ត្រឹមនេះ កុំប្រមាទ ញកនោះសត្វលោកហៅថា ញកមាបមាទៈ ពាក្យនុ៎ះ ភិក្ខុទាំងឡាយពោលសំដៅយកញកមាបមាទៈនោះ ។

ព្រះសាស្ដាទ្រង់យាងចៀសចេញទៅកាន់ទីចារិក ទ្រង់ត្រិះរិះបណ្ដើរថា ក្នុងនគរទាំងខាងក្នុងទាំងខាងក្រៅ មានមនុស្ស ១៨ កោដិ ដែលភិក្ខុនឹងទៅក្នុងទីដែលធ្វើការមង្គល និងអវមង្គលរបស់មនុស្សទាំងឡាយមាន តថាគតមិនអាចធ្វើវិហារឲ្យទទេបាន តថាគតនឹងឲ្យនណាហ្ន៎ត្រឡប់ ។

លំដាប់នោះ ទ្រង់មានបរិវិតក្កយ៉ាងនេះថា ពួកមនុស្សទាំងនោះជាញាតិផង ឧបដ្ឋាកផងរបស់កស្សបៈ តថាគតគួរឲ្យកស្សបៈត្រឡប់ចុះ ។ ទ្រង់ត្រាស់

នឹងព្រះថេរៈថា ម្នាលកស្សបៈ តថាគតមិនអាចធ្វើវិហារឲ្យទទេបាន សេចក្តីត្រូវការដោយភិក្ខុក្នុងទីដែលធ្វើមង្គល និងអវមង្គលទាំងឡាយរបស់ពួកមនុស្សមាន អ្នក មួយអន្ទើដោយបរិស័ទរបស់ខ្លួនចូរត្រឡប់ចុះ ។ ព្រះថេរៈទូលថា សាធុ ព្រះអង្គ ហើយនាំបរិស័ទត្រឡប់ ។ ភិក្ខុទាំងឡាយពោលទោសថា អាវុសោទាំងឡាយ ពួកអ្នកឃើញដែរឬទេ ពួកយើងពោលអម្បាញ់មិញនេះឯង មិនមែនឬ ពាក្យដែលពួកយើងពោលថា ព្រោះហេតុអ្វី ទើបព្រះមហាកស្សបៈបោកចីវរ លោកនឹងមិនទៅជាមួយព្រះសាស្តា ដូច្នេះនោះឯង ក្លាយជាការពិតហើយ ។

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់ភិក្ខុទាំងឡាយហើយ ទ្រង់យាងត្រឡប់ ប្រថាប់ឈរត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកពោលអ្វីហ្ន៎ ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ ពួកខ្ញុំព្រះអង្គពោលប្រារព្ធព្រះមហាកស្សបត្ថេរ ដូច្នេះហើយ ក្រាបទូលរឿងរ៉ាវទាំងអស់ តាមទំនងដែលខ្លួនពោលហើយនោះឯង ។

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យនោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកពោលទោសកស្សបៈថា ជាប់ជំពាក់ហើយក្នុងត្រកូល និងក្នុងបច្ច័យទាំងឡាយ តែសេចក្តីពិត កស្សបៈត្រឡប់ដោយធ្វើទុកក្នុងចិត្តថា អញនឹងធ្វើតាមពាក្យរបស់ព្រះតថាគត ។ កស្សបៈនោះ សូម្បីក្នុងកាលមុន កាលធ្វើសេចក្តីប្រាថ្នានោះឯង ក៏បានធ្វើសេចក្តីប្រាថ្នាថា អាត្មាអញមិនគប្បីជាអ្នកជាប់ជំពាក់ក្នុងបច្ច័យទាំង ៤ មានឧបមាដូចព្រះចន្ទ អាចចូលទៅកាន់ត្រកូល

ទាំងឡាយបាន កស្សបៈនោះ មិនមានការជាប់ជំពាក់ក្នុងត្រកូល ឬក្នុងបច្ច័យទាំងឡាយ តថាគតកាលពោលបដិបទា ដែលឧបមាដូចព្រះចន្ទ និងបដិបទានៃអរិយវង្ស ក៏ពោលអាងកស្សបៈឲ្យជាដើម ។

ភិក្ខុទាំងឡាយទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គ ព្រះថេរៈតាំងសេចក្តីប្រាថ្នាពីអង្កាល់ណា ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកបំណងនឹងស្តាប់ឬ ភិក្ខុទាំងឡាយក្រាបទូលថា ករុណាព្រះអង្គ ។

ព្រះសាស្តាត្រាស់ដល់ភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ ក្នុងទីបំផុតនៃសែនកប្បអំពីកប្បនេះ ព្រះពុទ្ធព្រះនាមបទុមុត្តរៈ ទ្រង់កើតហើយក្នុងលោកដូច្នេះហើយ ត្រាស់ការប្រព្រឹត្តក្នុងកាលមុនរបស់ព្រះថេរៈ តាំងអំពីដើម លោកតាំងសេចក្តីប្រាថ្នាក្នុងកាលនៃព្រះពុទ្ធ ព្រះនាមបទុមុត្តរៈ ។ បុព្វចរិតនោះព្រះធម្មសង្គាហកាចារ្យឲ្យពិស្តារហើយក្នុងព្រះបាលី ដែលសម្តែងប្រវត្តិរបស់ព្រះថេរៈនោះឯង ។

ព្រះសាស្តា កាលត្រាស់បុព្វចរិតរបស់ព្រះថេរៈឲ្យពិស្តាហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រោះយ៉ាងនេះឯង ទើបតថាគតពោលបដិបទាដែលប្រៀបដូចព្រះចន្ទ និងបដិបទានៃអរិយវង្ស ដោយលើកយកកស្សបបុត្តរបស់តថាគតឲ្យជាគំរូ ។ ឈ្មោះថា ការជាប់ជំពាក់ក្នុងបច្ច័យក្តី ត្រកូលក្តីវិហារក្តី បរិវេណក្តី រមែងមិនមានដល់បុត្ររបស់តថាគត ។ បុត្ររបស់តថាគត មិនជាប់ជំពាក់ក្នុងរបស់ណាមួយឡើយ ដូចស្តេចហង្សចុះក្នុងភក់ត្រាច់ទៅក្នុងភក់នោះហើយ ក៏ហើរទៅដូច្នោះ ដូច្នេះហើយ កាលទ្រង់បន្ត

អនុសន្ធិសម្ដែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**ឧយ្យុញ្ជន្តិ សតីមន្តោ ន និកេតេ រមន្តិ តេ**
**ហំសាវ បល្លលំ ហិត្វា ឱកមោកំ ជហន្តិ តេ ។**

ព្រះខីណាស្រពទាំងឡាយ មានស្មារតី រមែងខ្វល់ខ្វាយ រមែងត្រេកអរក្នុងទីនៅអាស្រ័យ លោកលះបង់ចោលស្រឡះ នូវអាល័យទាំងអស់ ដូចហង្សលះបង់កក់ ហើរទៅ ដូច្នោះ ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បាទព្រះគាថាថា **ឧយ្យុញ្ជន្តិ សតីមន្តោ** សេចក្ដីថា បុគ្គលដែលដល់នូវភាពបរិបូណ៌នៃសតិ ឈ្មោះថា មានអាសវៈអស់ហើយ រមែងខ្វល់ខ្វាយរឿយៗ ក្នុងគុណដែលខ្លួនចាក់ធ្លុះហើយ មានឈាន និងវិបស្សនាជាដើម ដោយអាវជ្ជនៈ ដោយចូលសមាបត្តិ ដោយចេញចាកសមាបត្តិ ដោយការតាំងចិត្តនៅក្នុងសមាបត្តិ និងដោយការពិចារណា ។

បាទព្រះគាថាថា **ន និកេតេ រមន្តិ តេ** គឺឈ្មោះថា ការត្រេកអរក្នុងទីហួងហែងរបស់លោក រមែងមិនមាន ។

បទថា **ហំសាវ** នេះ ជាចំណុចនៃទេសនា ។ នេះការអធិប្បាយក្នុងពាក្យនេះថា ហ្វូងបក្សី គឺយកចំណីរបស់ខ្លួនក្នុងកក់ដែលបរិសុទ្ធដោយចំណីហើយក្នុងកាលទៅ មិនធ្វើការហួងហែងតិចតួចក្នុងទីនោះថា ទឹករបស់អញ ផ្កាឈូករបស់អញ ផ្កាឧប្បលរបស់អញ ផ្កាបុណ្ឌរិករបស់អញ ស្មៅរបស់អញ មិនមានការស្ដាយឡើយ លះបទេសនោះស្មុះហើរទៅក្នុងអាកាស យ៉ាង

ណា ព្រះខីណាស្រពទាំងឡាយនោះក៏ដូច្នោះឯង សូម្បីនៅក្នុងទីណាមួយ មិនជាប់ជំពាក់ហើយក្នុងត្រកូលជាដើម ក្នុងគ្រាទៅ លះទីនោះទៅ មិនមានការសោកស្តាយថា វិហាររបស់អញ បរិវេណរបស់អញ ឧបដ្ឋាករបស់អញត្រាច់ទៅ ។

បទថា **ឱកមោកំ** គឺអាល័យ សេចក្តីថា លះនូវការហួងហែងទាំងពួង ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

**រឿង ព្រះមហាកស្សបត្ថេរ ចប់**

# រឿង ព្រះវេឡដ្ឋសីសត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះវេឡដ្ឋសីសៈត្រាស់ព្រះធម្មទេសនានេះថា **យេសំ សន្និចយោ នត្ថិ** ជាដើម ។

បានឮមកថា ព្រះថេរៈនោះត្រាច់បិណ្ឌបាតក្នុងវិថីមួយខាងក្នុងស្រុក ធ្វើភត្តកិច្ចហើយ ត្រាច់បិណ្ឌបាតក្នុងវិថីមួយទៀត កាន់យកបាយក្រៀមទៅក្នុងវិហាររក្សាទុក គិតឃើញថា ឈ្មោះថា ការត្រាច់ស្វែងរកបិណ្ឌបាតរឿយៗទៅ ជាទុក្ខ ញុំាងថ្ងៃតិចតួចឲ្យកន្លងទៅដោយសុខក្នុងឈានហើយ កាលត្រូវការដោយអាហារ រមែងឆាន់បាយក្រៀមនោះ ។ ពួកភិក្ខុដែលដឹងតិះដៀល

ហើយ ទូលសេចក្តីនោះដល់ព្រះដ៏មានព្រះភាគ ព្រះសាស្តាសូម្បីទ្រង់បញ្ញត្តិសិក្ខាបទដល់ភិក្ខុទាំងឡាយ ដើម្បីប្រយោជន៍វៀរការសន្សំតទៅ ព្រោះហេតុនោះហើយ កាលទ្រង់ប្រកាសការមិនមានទោសរបស់ព្រះថេរៈ ព្រោះការទុកដាក់អាហារនោះ ព្រោះព្រះថេរៈអាស្រ័យការប្រាថ្នាតិច ធ្វើក្នុងកាលដែលទ្រង់មិនទាន់បញ្ញត្តសិក្ខាបទ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ បានត្រាស់ព្រះគាថានេះថា

**យេសំ សន្និចយោ នត្ថិ យេ បរិញ្ញាតភោជនា**
**សុញ្ញតោ អនិមិត្តោ ច វិមោក្ខោ យេស គោចរោ**
**អាកាសេវ សកុន្តានំ គតិ តេសំ ទុរន្នយា ។**

ពួកជនណា មិនមានសេចក្តីសន្សំ ពួកជនណា កំណត់ដឹងភោជនហើយ ជនណា មានសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ និងអប្បណិហិតវិមោក្ខ ជាគោចរ គតិ គឺដំណើររបស់ពួកជននោះៗ គេកម្រដឹងបាន ដូចដំណើរនៃពួកសត្វស្លាបពួដ៏អាកាសដូច្នោះ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ក្នុងបទថា **សន្និចយោ** សន្សំមាន ២ យ៉ាង គឺ សន្សំកម្ម ១ សន្សំបច្ច័យ ១ ក្នុងការសន្សំ ២ យ៉ាងនោះ កម្មដែលជាកុសល និងអកុសល ឈ្មោះថា សន្សំកម្ម ។ បច្ច័យ ៤ ឈ្មោះថា សន្សំបច្ច័យ ក្នុងការសន្សំ ២ យ៉ាងនោះ សន្សំបច្ច័យ រមែងមិនមានដល់ភិក្ខុដែលនៅក្នុង

វិហារ ទុកដាក់ទឹកស្ករអំពៅមួយដុំ សប្បិត្រឹមតែចំណែកទី ៤ និងអង្ករត្រឹមមួយនាឡិ រមែងមិនមានដល់ភិក្ខុដែលទុកដាក់ច្រើនជាងនោះ សន្សំ ២ យ៉ាងនេះរបស់ជនពួកណា មិនមាន ។

បទថា **បរិញ្ញាតភោជនា** គឺកំណត់ដឹងភោជនដោយបរិញ្ញា ៣ ការដឹងភោជនមានបបរជាដើម ដោយភាពជាបបរជាដើម ឈ្មោះថា ញាតបរិញ្ញា កំណត់ដឹងដោយការដឹងហើយ ។ ឯការកំណត់ដឹងភោជន ដោយអំណាចសម្គាល់ឃើញក្នុងអាហារបដិកូល ឈ្មោះថា តីរណបរិញ្ញា ។ ញាណជាហេតុដកនូវតម្រេក ដោយអំណាចការពេញចិត្តក្នុងភោជនាហារចេញ ឈ្មោះថា បហានបរិញ្ញា ជនពួកណា កំណត់ដឹងភោជនដោយបរិញ្ញា ៣ នេះ ។

ក្នុងបាទព្រះគាថាថា **សុញ្ញតោ អនិមិត្តោ ច** នេះ សូម្បីអប្បណិហិតវិមោក្ខ ក៏ទ្រង់កាន់យកដោយពិត ។ ព្រោះថា បទទាំង ៣ នោះ ជាឈ្មោះនៃព្រះនិព្វាននោះឯង ។ ពិតហើយ ព្រះនិព្វាន លោកពោលថា សុញ្ញតវិមោក្ខ ព្រោះថា ទទេ ព្រោះមិនមានរាគៈ ទោសៈ និងមោហៈ និងផុតចាករាគៈ ទោសៈ មោហៈនោះ ព្រះនិព្វាននោះ លោកពោលថា ជាអនិមិត្តវិមោក្ខ ព្រោះថា មិនមាននិមិត្ត ព្រោះមិនមាននៃនិមិត្ត មានរាគៈជាដើម និងផុតហើយចាកនិមិត្តទាំងនោះម្យ៉ាងទៀត លោកពោលថា អប្បណិហិតវិមោក្ខ ព្រោះមិនបានតាំងនៅ ព្រោះមិនមានបណិធិ គឺកិលេសជាហេតុតាំងនៅ មានរាគៈជាដើម និងរួចផុតហើយចាកបណិធិទាំងនោះ ។ វិមោក្ខ ៣ យ៉ាងនេះជាអារម្មណ៍របស់ជនពួកណា បុគ្គលធ្វើព្រះនិព្វាននោះឲ្យជាអារម្មណ៍ ដោយ

អំណាចចូលសមាបត្តិ សម្បយុត្តដោយផលចិត្ត ។

បាទព្រះគាថាថា **គតិ តេសំ ទុរន្នយា** សេចក្តីថា ដូចផ្លូវទៅរបស់ហ្វូងបក្សីដែលទៅហើយដោយអាកាស ទៅតាមលំបាក គឺមិនអាចដឹង ព្រោះមិនឃើញគន្លង យ៉ាងណា គតិរបស់ជនទាំងឡាយ ដែលជាអ្នកសន្សំពីរយ៉ាងនេះ មិនបានកំណត់ដឹងកោជនដោយបរិញ្ញា ៣ នេះ និងជាបុគ្គលមានវិមោក្ខមានប្រការដែលពោលហើយនេះជាអារម្មណ៍ ក៏ទៅតាមលំបាក គឺមិនអាចបញ្ញត្តិ ព្រោះមិនប្រាកដនៃការទៅថា ទៅហើយក្នុងចំណែក ៥ នេះ គឺភព ៣ កំណើត ៤ គតិ ៥ វិញ្ញាណដ្ឋិតិ ៧ សត្តាវាស ៩ ដោយចំណែកឈ្មោះនេះៗ ដូច្នោះឯង ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

**រឿង ព្រះវេឡដ្ឋសីសត្ថេរ ចប់**

# រឿង ព្រះអនុរុទ្ធត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រះអនុរុទ្ធត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **យស្សាសវា បរិក្ខីណា** ជាដើម ។

សេចក្តីពិស្តារថា ក្នុងថ្ងៃមួយ ព្រះថេរៈមានចីវរចាស់ហើយ ស្វែងរក

ចីវរ ក្នុងទីទាំងឡាយ មានគំនរសំរាមជាដើម ស្រីករិយាចាស់របស់ព្រះថេរៈ នោះ ក្នុងអត្តភាពទី ៣ បន្ទាប់អំពីអត្តភាពនេះ បានកើតជាទេពធីតាឈ្មោះ ជាលិនី ក្នុងស្ថានតាវត្តិង្ស នាងជាលិនីទេពធីតានោះ ឃើញព្រះថេរៈស្វែង រកកំណាត់សំពត់ កាន់សំពត់ទិព្វ ៣ ផ្ទាំង បណ្តោយ ១៣ ហត្ថ ទទឹង ៤ ហត្ថ ហើយគិតថា បើអញប្រគេនដោយទំនងនេះ ព្រះថេរៈនឹងមិនទទួល ទើបដាក់លើគំនរសំរាមមួយកន្លែងខាងមុខព្រះថេរៈនោះ ដែលកំពុងស្វែងរកសំពត់ទាំងឡាយ ដោយអាការត្រឹមតែជាយសំពត់នោះ ប្រាកដបាន ។ ព្រះថេរៈស្វែងរកកំណាត់សំពត់ដោយផ្លូវនោះ ឃើញជាយ សំពត់នោះហើយ ទើបចាប់ត្រង់ជាយសំពត់នោះទាញមក ឃើញសំពត់ទិព្វ មានប្រមាណដូចពោលហើយ កាន់យកដោយគិតថា សំពត់នេះ ជាសំពត់ បង្សុកូលយ៉ាងឧក្រិដ្ឋហ្ន៎ ដូច្នេះហើយ ចៀសចេញទៅ ។

ក្នុងថ្ងៃធ្វើចីវររបស់ព្រះថេរៈ ព្រះសាស្តាមានភិក្ខុ ៥០០ រូបជាបរិវារ យាងទៅវិហារប្រថាប់គង់ហើយ ។ អសីតិមហាសាវកក៏អង្គុយហើយយ៉ាង នោះដូចគ្នា ។ ព្រះមហាកស្សបត្ថេរ អង្គុយហើយខាងដើម ដើម្បីដេរចីវរ ព្រះសារីបុត្តអង្គុយត្រង់កណ្តាល ព្រះអានន្ទត្ថេរអង្គុយក្នុងទីបំផុត ភិក្ខុសង្ឃរុំ អំបោះ ។ ព្រះសាស្តាទ្រង់ដោតអំបោះក្នុងគូថម្ជុល ព្រះមហាមោគ្គល្លានត្ថេរ សេចក្តីត្រូវការដោយវត្ថុណាមាន ជាអ្នកនាំវត្ថុនោះៗ មកហើយ ។ ទេពធីតា ចូលទៅខាងក្នុងស្រុកហើយ ដឹកនាំឲ្យទទួលភិក្ខាថា នែអ្នកទាំងឡាយ ព្រះ សាស្តាទ្រង់ធ្វើចីវរដល់ព្រះអនុរុទ្ធត្ថេរ លោកម្ចាស់របស់យើងទាំងឡាយ ក្នុង

ថ្ងៃនេះ ដែលព្រះអសីតិមហាសាវកចោមរោម ប្រថាប់គង់នៅក្នុងវិហារជាមួយភិក្ខុ ៥០០ រូប ចូរពួកអ្នកកាន់យកបបរជាដើមទៅកាន់វិហារ សូម្បីព្រះមហាមោគ្គល្លានត្ថេរ នាំចំណិតព្រីងធំមកហើយក្នុងរវាងកត្ត ។ ភិក្ខុ ៥០០ រូបមិនអាចទំពាឆាន់ឲ្យអស់បាន សក្កៈបានធ្វើការប្រោះព្រំក្នុងទីដែលធ្វើចីវរ ។ ផ្ទៃផែនដីហាក់បីដូចជ្រលក់ដោយទឹកល័ក្ត ។ គំនរធំនៃបបរ របស់ទំពា និងកត្តដែលភិក្ខុទាំងឡាយឆាន់សល់មានហើយ ។

ភិក្ខុទាំងឡាយពោលទោសថា ប្រយោជន៍អ្វីរបស់ភិក្ខុ មានប្រមាណប៉ុណ្ណេះ ដោយបបរជាដើមដ៏ច្រើនយ៉ាងនេះ ញាតិ និងឧបដ្ឋាកដែលភិក្ខុទាំង-ឡាយកំណត់ប្រមាណហើយ គប្បីពោលថា ចូរពួកអ្នកនាំវត្ថុមានប្រមាណប៉ុណ្ណេះមក មិនមែនឬ ព្រះអនុរុទ្ធត្ថេរប្រហែលបំណងឲ្យគេដឹងភាពនៃញាតិនិងឧបដ្ឋាករបស់ខ្លួនមានច្រើន ។ លំដាប់នោះ ព្រះសាស្តា ត្រាស់សួរភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកនិយាយអ្វី ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ និយាយរឿងឈ្មោះនេះ ទើបត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកសម្គាល់ថា សេចក្តីនេះ អនុរុទ្ធឲ្យនាំមកហើយឬ ភិក្ខុទាំងឡាយក្រាបទូលថា យ៉ាងនោះឯងព្រះអង្គ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អនុរុទ្ធបុត្រតថាគត មិនពោលពាក្យបែបនោះឡើយ ។ ពិតហើយ ព្រះខីណាស្រពទាំងឡាយ រមែងមិនពោលកថាបដិសំយុត្តដោយបច្ច័យ ។ បិណ្ឌបាតនេះកើតហើយដោយអានុភាពរបស់ទេវតា កាលទ្រង់បន្តអនុសន្ធិ ទើបត្រាស់គាថានេះថា

**យស្សាសវា បរិក្ខីណា អាហារេ ច អនិស្សិតោ**
**សុញ្ញតោ អនិមិត្តោ ច វិមោក្ខោ យស្ស គោចរោ**
**អាកាសេវ សកុន្តានំ បទន្តស្ស ទុរន្នយំ ។**

ជនណាអស់អាសវៈហើយ ទាំងមិនអាស្រ័យ ( តណ្ហា និង ទិដ្ឋិ ) ក្នុងអាហារ ជនណា មានសុញ្ញតវិមោក្ខ អនិមិត្ត-វិមោក្ខ និងអប្បណិហិតវិមោក្ខជាគោចរ ដំណើររបស់ជននោះ គេកម្រដឹងបាន ដូចដំណើរនៃពួកសត្វស្លាប ពួដ៏អាកាស ដូច្នោះ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **យស្សាសវា** សេចក្តីថា អាសវៈ ៤ របស់បុគ្គលណាអស់ហើយ ។ បាទព្រះគាថាថា **អាហារេ ច អនិស្សិតោ** សេចក្តីថា ដែលតណ្ហានិស្ស័យ និងទិដ្ឋិនិស្ស័យមិនអាស្រ័យហើយក្នុងអាហារ ។

បាទព្រះគាថាថា **បទន្តស្ស ទុរន្នយំ** សេចក្តីថា ដែលបុគ្គលមិនអាចនឹងដឹងស្នាមរបស់បក្សីទាំងឡាយ ដែលទៅក្នុងអាកាសថា បក្សីទាំងឡាយជាន់ដោយជើងក្នុងទីនេះហើរទៅហើយ ទង្គិចទីនេះដោយទ្រូងហើរទៅហើយ ប៉ះទីនេះដោយក្បាល ដោយស្លាបទាំង ២ យ៉ាងណា បុគ្គលណាមួយ ក៏មិនអាចបញ្ញត្តិនូវស្នាមរបស់ភិក្ខុបែបនេះដោយន័យជាដើមថា ភិក្ខុនេះទៅហើយដោយផ្លូវនរក ឬទៅហើយដោយផ្លូវតិរច្ឆានដូច្នោះដូចគ្នា ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមដូច្នេះឯង ។

រឿង ព្រះអនុរុទ្ធត្ថេរ ចប់

# រឿង ព្រះមហាកច្ចាយនត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តបុព្វារាម ទ្រង់ប្រារព្ធព្រះមហាកច្ចា-យនត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **យស្សិន្ទ្រិយានិ** ជាដើម ។

សេចក្តីពិស្តារថា ក្នុងសម័យមួយ ព្រះសាស្តាដែលព្រះមហាសាវកចោមរោមហើយ ប្រថាប់គង់ខាងក្រោមប្រាសាទរបស់មិគារមាតា ក្នុងថ្ងៃមហាបវារណា ។ ក្នុងសម័យនោះ ព្រះមហាកច្ចាយនត្ថេរ នៅក្នុងអវន្តីជនបទ មកហើយអំពីចម្ងាយ រមែងសរសើរការស្តាប់ធម៌នោះឯង ព្រោះដូច្នោះព្រះថេរៈធំៗ ទាំងឡាយ កាលអង្គុយ ក៏អង្គុយវៀរអាសនៈដើម្បីព្រះមហាកច្ចាយ-នត្ថេរ ។ សក្កទេវរាជ យាងមកអំពីទេវលោកទាំងពីរ មួយអន្លើដោយទេវ-បរិស័ទ ទ្រង់បូជាព្រះដ៏មានព្រះភាគដោយគ្រឿងក្រអូប និងកម្រងផ្កាដែលជាទិព្វជាដើមហើយ ប្រថាប់ឈរ មិនបានឃើញព្រះមហាកច្ចាយនត្ថេរ ទើបទ្រង់ពិចារណាថា ព្រោះហេតុអ្វីហ្ន៎ ទើបលោកម្ចាស់របស់យើងមិនប្រាកដបើលោកម្ចាស់របស់យើងមក ការមករបស់ពួកលោកជាការល្អ ។ ព្រះថេរៈ

មកហើយក្នុងខណៈនោះឯង បង្ហាញខ្លួន អង្គុយហើយលើអាសនៈរបស់ខ្លួននោះឯង ។ សក្កទេវរាជទតឃើញព្រះថេរៈហើយ ទ្រង់ចាប់កជើងទាំងពីរយ៉ាងមាំ ហើយត្រាស់ថា លោកម្ចាស់របស់យើងមកហើយហ្ន៎ ខ្ញុំទន្ទឹងការមករបស់លោកម្ចាស់នោះឯង ដូច្នេះហើយ ទ្រង់ប្របាច់ជើងទាំងពីររបស់ព្រះថេរៈ ដោយដៃទាំងពីរ បូជាដោយគ្រឿងក្រអូប និងកម្រងផ្កាជាដើម ថ្វាយបង្គំហើយ បានប្រថាប់ឈរក្នុងចំណែកម្ខាង ។

ភិក្ខុទាំងឡាយពោលទោសថា សក្កទេវរាជទ្រង់យល់មុខ ទើបធ្វើសក្ការៈ មិនធ្វើសក្ការៈបែបនេះដល់មហាសាវកដ៏សេស ឃើញព្រះមហាកច្ចាយនត្ថេរហើយ ចាប់កជើងទាំងពីរដោយរហ័សត្រាស់ថា លោកម្ចាស់របស់យើងមកល្អហ្ន៎ ខ្ញុំទន្ទឹងការមករបស់លោកម្ចាស់នោះឯង ដូច្នេះហើយ ទ្រង់ប្របាច់ជើងទាំងពីរដោយដៃទាំងពីរបូជាហើយ ថ្វាយបង្គំហើយ ប្រថាប់ឈរក្នុងចំណែកម្ខាង ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់ភិក្ខុទាំងឡាយនោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានទ្វារដែលខ្លួនគ្រប់គ្រងហើយក្នុងឥន្ទ្រិយទាំងឡាយដូចគ្នានឹងមហាកច្ចាយនៈ បុត្រតថាគត រមែងជាទីស្រឡាញ់របស់ពួកទេវតានោះឯង កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**យស្សិន្ទ្រិយានិ សមថង្គតានិ អស្សា យថា សារថិនា សុទន្តា**
**បហីនមានស្ស អនាសវស្ស ទេវាបិ តស្ស បិហយន្តិ តាទិនោ ។**

ឥន្ទ្រិយទាំងឡាយ របស់អ្នកណា ដល់នូវការស្ងប់រម្ងាប់ ដូចសេះដែលនាយសារថីហ្វឹកហ្វឺនរាបហើយ សូម្បីទេវតា និងមនុស្សទាំង-

ឡាយ ក៏ស្រឡាញ់អ្នកនោះឯង ដែលមានមានះលះបង់ហើយ មិនមានអាសវៈ ជាបុគ្គលមានចិត្តនឹងធឹង មិនញាប់ញ័រ ។

## សេចក្ដីអធិប្បាយ

អត្ថនៃព្រះគាថានោះដូច្នេះថា ឥន្ទ្រិយ ៦ របស់ភិក្ខុណាដល់នូវការស្ងប់ គឺភាពជាឥន្ទ្រិយដែលខ្លួនទូន្មានហើយ បានដល់ ភាពជាឥន្ទ្រិយអស់នូវព្យសន៍កំណាច ដូចសេះដែលនាយសារថីអ្នកឈ្លាស បង្ហឹកល្អហើយ ដូច្នោះ ។ ចំពោះភិក្ខុនោះ ដែលឈ្មោះថាមានមានះលះបង់ហើយ ព្រោះលះមានះមាន ៩ យ៉ាង តាំងទៅ ឈ្មោះថា មិនមានអាសវៈ ព្រោះមិនមានអាសវៈ ៤ ។ បទថា **តាទិនោ** សេចក្ដីថា ទាំងពួកទេវតា ទាំងពួកមនុស្សរមែងស្រឡាញ់ គឺរមែងប្រាថ្នាការឃើញ និងការមករបស់ភិក្ខុបែបនោះ ដែលតាំងនៅដោយភាវៈនៃតាទិបុគ្គល ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

**រឿង ព្រះមហាកច្ចាយនត្ថេរ ចប់**

# រឿង ព្រះសារីបុត្តត្ថេរ

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសារីបុត្តត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **បឋវីសមោ** ជាដើម ។

សេចក្ដីពិស្ដារថា សម័យមួយ ព្រះសារីបុត្តចេញវស្សាហើយ ប្រាថ្នានឹងចៀសទៅកាន់ទីចារិក ទើបទូលលាព្រះដ៏មានព្រះភាគ ថ្វាយបង្គំហើយចេញទៅ មួយអន្លើដោយបរិវាររបស់ខ្លួន ។ ភិក្ខុទាំងឡាយដទៃ តាមជូនព្រះថេរៈហើយ ។ ព្រះថេរៈប្រាស្រ័យនឹងភិក្ខុទាំងឡាយ ដែលប្រាកដដោយអំណាចឈ្មោះ និងគោត្រ តាមឈ្មោះ និងគោត្រហើយ ទើបប្រាប់ឲ្យត្រឡប់ ។ ភិក្ខុដែលមិនប្រាកដ ដោយអំណាចឈ្មោះ និងគោត្ររូបណាមួយគិតថា ឱហ្ន៎ ព្រះថេរៈ គួរសរសើរប្រាស្រ័យនឹងយើងខ្លះ ដោយអំណាចឈ្មោះ និងគោត្រ ហើយគប្បីឲ្យត្រឡប់ ព្រះថេរៈមិនទាន់កំណត់ដល់លោកក្នុងរវាងនៃភិក្ខុសង្ឃជាច្រើន ភិក្ខុនោះអាឃាតក្នុងព្រះថេរៈថា ព្រះថេរៈមិនសរសើរអញដូចភិក្ខុដទៃទាំងឡាយ ។ រមួរសង្ឃាដីរបស់ព្រះថេរៈ ត្រូវសរីរៈរបស់ភិក្ខុនោះហើយ ដោយហេតុនោះ ភិក្ខុនោះក៏ត្រូវអាឃាតហើយដូចគ្នា ។ ភិក្ខុនោះដឹងថា ឥឡូវនេះ ព្រះថេរៈនឹងកន្លងឧបចារវិហារ ទើបចូលទៅគាល់ព្រះសាស្ដា ក្រាបទូលថា បពិត្រព្រះអង្គ ព្រះសារីបុត្តប្រហារខ្ញុំព្រះអង្គ ដូចទម្លាយគុម្ពត្រចៀក មិនញុំាងខ្ញុំព្រះអង្គឲ្យអត់ទោស ចៀសទៅកាន់ទីចារិក ដោយសម្គាល់ថា ជាអគ្គសាវករបស់ព្រះអង្គ ។ ព្រះសាស្ដា ត្រាស់ឲ្យហៅ

ព្រះថេរៈមកហើយ ។

ក្នុងខណៈនោះ ព្រះមហាមោគ្គល្លាន និងព្រះអានន្ទគិតហើយថា ព្រះសាស្តាទ្រង់មិនជ្រាបភាពដែលភិក្ខុនេះ ដែលបងប្រុសរបស់ពួកយើងមិនប្រហារហើយក៏មិនមែន តែទ្រង់បំណងឲ្យលោកបន្លឺសីហនាទ អញនឹងឲ្យបរិស័ទប្រជុំគ្នា ព្រះថេរៈទាំងពីរមានកូនសោនៅក្នុងដៃ បើកទ្វារបរិវេណហើយ ពោលថា ចូរអាវុសោទាំងឡាយចេញ ចូរអាវុសោទាំងឡាយចេញ ឥឡូវនេះ ព្រះសារីបុត្តនឹងបន្លឺសីហនាទ ក្នុងទីចំពោះព្រះភក្ត្រព្រះសាស្តា ឲ្យមហាភិក្ខុសង្ឃប្រជុំគ្នាហើយ ។ ចំណែកព្រះថេរៈមកថ្វាយបង្គំព្រះសាស្តា អង្គុយហើយ ។ លំដាប់នោះ ព្រះសាស្តាត្រាស់សួរសេចក្តីនោះជាមួយព្រះថេរៈហើយ ។ ព្រះថេរៈមិនក្រាបទូលភ្លាមថា ភិក្ខុនេះ ខ្ញុំព្រះអង្គមិនប្រហារហើយ កាលនឹងពោលគុណកថារបស់ខ្លួន ទើបក្រាបទូលថា បពិត្រព្រះអង្គ សតិប្រព្រឹត្តទៅក្នុងកាយ ដែលភិក្ខុណាមិនគប្បីចូលទៅតាំងទុកហើយក្នុងកាយ ភិក្ខុនោះប៉ះពាល់សព្រហ្មចារីរូបណាមួយក្នុងសាសនានេះ មិនសុំទោសហើយ គប្បីចៀសទៅកាន់ទីចារិកពិត ដូច្នេះហើយ ប្រកាសភាពដែលខ្លួនមានចិត្តស្មើដោយផែនដី ស្មើដោយទឹក ភ្លើង ខ្យល់ សំពត់ជូតធូលី ក្មេងចណ្ឌាល គោឧសភៈបាក់ស្នែង ការខ្ពើមរអើមដោយកាយរបស់ខ្លួន ដូចសាកសពពស់ជាដើម និងការបរិហារកាយរបស់ខ្លួន ដូចភាជនៈខ្លាញ់ខាប់ ដោយន័យជាដើមថា បុគ្គលរមែងចោលរបស់ស្អាតខ្លះ រមែងចោលរបស់មិនស្អាតខ្លះ លើផែនដី យ៉ាងណា ។ កាលព្រះថេរៈពោលគុណរបស់ខ្លួន ដោយឧបមា ៩ យ៉ាងនេះ មហាប្រឹថពី

*កម្រើករហូតដល់ទីបំផុតទឹក ក្នុងវារៈទាំង ៩ ហើយ ។ ក្នុងវេលានាំឧបមាដោយសំពត់ជូតធូលី ក្មេងចណ្ឌាល និងកាជនៈខ្ទាញ់ខាប់មក ភិក្ខុដែលជាបុថុជ្ជនមិនអាចទប់ទឹកភ្នែកបាន ធម្មសង្វេគកើតដល់ភិក្ខុដែលជាខីណាស្រពទាំងឡាយហើយ ។ កាលព្រះថេរៈពោលគុណរបស់ខ្លួននោះឯង ការក្តៅក្រហាយ កើតឡើងក្នុងសរីរៈទាំងមូល របស់ភិក្ខុដែលពោលបង្កាច់ហើយ រំពេចនោះឯង ភិក្ខុនោះ ក្រាបចុះទៀបបាទាទាំងទ្វេ របស់ព្រះដ៏មានព្រះភាគប្រកាសទោស ព្រោះការពោលទោសដោយពាក្យដែលមិនពិត សម្តែងទោស ដែលប្រព្រឹត្តកន្លងហើយ ។*

*ព្រះសាស្តាត្រាស់ហៅព្រះថេរៈមកហើយត្រាស់ថា ម្នាលសារីបុត្ត ចូរអ្នកអត់ទោសឲ្យមោឃបុរសនេះចុះ ទាន់សីសៈរបស់ភិក្ខុនេះមិនទាន់បែកជា ៧ ភាគ ព្រះថេរៈអង្គុយប្រហោងផ្គងអញ្ជលី ក្រាបទូលថា បពិត្រព្រះអង្គខ្ញុំព្រះអង្គ អត់ទោសចំពោះអាវុសោនុ៎ះហើយ សូម្បីអាវុសោនុ៎ះ ក៏សូមអត់ទោសចំពោះខ្ញុំព្រះអង្គ បើទោសរបស់ខ្ញុំព្រះអង្គមាន ភិក្ខុទាំងឡាយពោលថាអាវុសោទាំងឡាយ ចូរអ្នកទាំងឡាយមើលព្រះថេរៈមានគុណមិនថោកថយ ព្រះថេរៈមិនធ្វើសេចក្តីក្រោធ ឬការប្រទូស្តសូម្បីមានប្រមាណតិចតួច ចំពោះភិក្ខុដែលពោលទោសដោយមុសាវាទបែបនេះ ខ្លួនឯងអង្គុយប្រហោង ផ្គងអញ្ជលីឲ្យភិក្ខុនោះអត់ទោស ។*

*ព្រះសាស្តាទ្រង់ស្តាប់កថានោះហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយពួកអ្នកនិយាយអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា កថាឈ្មោះនេះ ព្រះអង្គ*

ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយមិនអាចឲ្យសេចក្តីក្រោធ ឬការប្រទូស្តកើតឡើងដល់ភិក្ខុដូចសារីបុត្តបានឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តរបស់សារីបុត្តដូចគ្នានឹងមហាប្រឹថពី ដូចគ្នានឹងសសរខឿន ដូចគ្នានឹងអន្លង់ទឹកថ្លា កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**បឋវីសមោ នោ វិរុជ្ឈតិ ឥន្ទខីលូបមោ តាទិ សុព្វតោ**
**រហទោវ អបេតកទ្ទមោ សំសារា ន ភវន្តិ តាទិនោ ។**

ភិក្ខុមានចិត្តដូចផែនដី មិនក្រោធ មានវត្តល្អ មានចិត្តនឹងធឹងដូចសសរគោល មានចិត្តថ្លា ដូចអន្លង់ប្រាសចាកភក់ សង្សារទាំងឡាយរបស់ភិក្ខុបែបនោះ រមែងមិនមាន ។

## សេចក្តីអធិប្បាយ

អត្ថនៃព្រះគាថានោះដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ជនទាំងឡាយរមែងចោលរបស់ស្អាត មានរបស់ក្រអូប និងកម្រងផ្កាជាដើមខ្លះ រមែងចោលរបស់មិនស្អាត មានមូត្រ និងលាមកជាដើមខ្លះលើផែនដី ។ ម្យ៉ាងទៀត ក្មេងជាដើមរមែងបន្ទោបង់បស្សាវៈខ្លះ រមែងបន្ទោបង់ឧច្ចារៈខ្លះ ស្រោចសសរខឿនដែលគេកប់ក្បែរទ្វារក្រុង តែជនទាំងឡាយដទៃ រមែងធ្វើសក្ការៈសសរខឿននោះដោយវត្ថុ មានគ្រឿងក្រអូប និងកម្រងផ្កាជាដើម ព្រោះការធ្វើនោះ សេចក្តីត្រេកអរ ឬការអាក់អន់រមែងមិនកើតដល់ផែនដី ឬសសរខឿននោះ យ៉ាងណា ភិក្ខុដែលជាខីណាស្រពនេះ ឈ្មោះថា ជាតាទិបុគ្គល ព្រោះភាពជាអ្នកមិនញាប់ញ័រដោយលោកធម៌ទាំង ៨ ឈ្មោះថា ជាអ្នកមានវត្តល្អ ព្រោះភាពនៃ

វត្ថុទាំងឡាយស្អាត ភិក្ខុទាំងនោះក៏ដូច្នោះដូចគ្នា កាលជនទាំងឡាយធ្វើសក្ការៈនិងអសក្ការៈ រមែងមិនត្រេកអរ រមែងមិនអាក់អន់ថា ជនទាំងនេះ រមែងធ្វើសក្ការៈអញដោយបច្ច័យ ៤ តែជនទាំងនេះមិនធ្វើសក្ការៈដោយពិត ភិក្ខុដែលជាព្រះខីណាស្រពនោះ រមែងជាអ្នកស្មើដោយផែនដី និងជាអ្នកប្រៀបដូចសសរខឿននោះឯង ។ អន្លង់ទឹកដែលមានកក់ទៅប្រាសហើយ ជាអន្លង់ទឹកថ្លា យ៉ាងណា ភិក្ខុដែលជាព្រះខីណាស្រពនោះ ឈ្មោះថា មានកក់ទៅប្រាសហើយ ដោយកក់ទាំងឡាយ មានរាគៈជាដើម ព្រោះភាពជាបុគ្គលមានកិលេសទៅប្រាសហើយ រមែងជាអ្នកផូរផង់នោះឯងដូច្នោះ ។

បទថា **សំសារា** សេចក្តីថា ឈ្មោះថា សង្សារទាំងឡាយ ដោយអំណាចនៃការអន្ទោលទៅក្នុងសុគតិ និងទុគ្គតិទាំងឡាយ រមែងមិនមានដល់ភិក្ខុនោះ គឺដល់ភិក្ខុបែបនោះ ។

ក្នុងកាលចប់ទេសនា ភិក្ខុ ៩ ពាន់រូបបានសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ ដូច្នេះឯង ៕

**រឿងព្រះសារីបុត្តត្ថេរ ចប់**

# រឿង ព្រះតិស្សត្ថេរអ្នកក្រុងកោសម្ពី

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសាមណេររបស់ព្រះតិស្សត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **សន្តំ តស្ស មនំ ហោតិ** ជាដើម ។

បានឮមកថា កុលបុត្រអ្នកក្រុងកោសម្ពីម្នាក់ បួសក្នុងព្រះសាសនា បានឧបសម្បទាហើយ ប្រាកដឈ្មោះថា កោសម្ពិវាសីតិស្សត្ថេរ ។ កាលព្រះថេរៈនោះចាំវស្សានៅក្នុងក្រុងកោសម្ពី ឧបដ្ឋាកនាំត្រៃចីវរ សប្បិ ទឹកអំពៅមកដាក់ក្បែរបាទា កាលនោះ ព្រះថេរៈពោលនឹងឧបដ្ឋាកនោះថា ឧបាសក នុ៎ះអ្វី ឧបដ្ឋាកពោលថា ខ្ញុំនិមន្តលោកម្ចាស់ឲ្យនៅចាំវស្សាមិនមែនឬ ពួកភិក្ខុដែលនៅចាំវស្សាក្នុងវិហាររបស់ពួកខ្ញុំ រមែងបានលាភនោះ សូមលោកម្ចាស់ទទួលចុះ ព្រះថេរៈពោលថា ណ្ហើយចុះ ឧបាសក សេចក្តីត្រូវការដោយវត្ថុនេះរបស់អាត្មា មិនមាន ឧបដ្ឋាកពោលថា បពិត្រលោកម្ចាស់ តើព្រោះហេតុអ្វី ព្រះថេរៈពោលថា សាមណេរជាកប្បិយការិកក្នុងសម្នាក់របស់អាត្មាក៏មិនមាន ឧបដ្ឋាកពោលថា បពិត្រលោកម្ចាស់ បើកប្បិយការិកមិនមាន កូនរបស់ខ្ញុំ នឹងជាសាមណេរក្នុងសម្នាក់របស់លោកម្ចាស់ ព្រះថេរៈទទួលហើយ ឧបាសកនាំកូនរបស់ខ្លួន មានអាយុ ៧ ឆ្នាំ ទៅកាន់សម្នាក់របស់ព្រះថេរៈហើយ បានប្រគេនថា សូមលោកម្ចាស់ឲ្យក្មេងនេះបួសចុះ ។ គ្រានោះ ព្រះថេរៈលាបសក់របស់ក្មេងនោះឲ្យសើម ហើយកោរ ឲ្យតចបញ្ចកកម្មដ្ឋាន ឲ្យបួសហើយ ។ ក្នុងវេលាកោរសក់ស្រេចនោះឯង កុមារនោះ ក៏

សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា ។ ព្រះថេរៈ កាលឲ្យកុមារនោះបួសហើយ នៅក្នុងទីនោះអស់កន្លះខែហើយ គិតថា នឹងគាល់ព្រះសាស្តា ទើបឲ្យសាមណេរវេចខ្ចប់កណ្ឌៈ ធ្វើដំណើរទៅកាន់វិហារមួយកន្លែង ក្នុងរវាងផ្លូវ ។ សាមណេរកាន់យកសេនាសនៈដែលចាត់ចែង ដើម្បីព្រះឧបជ្ឈាយ៍ហើយ ។ កាលសាមណេរនោះ រៀបចំសេនាសនៈនោះឯង ក៏អស់ពេល ។ ព្រោះហេតុនោះ ទើបសាមណេរមិនអាចរៀបចំសេនាសនៈ ដើម្បីខ្លួនបាន ។

គ្រានោះ ព្រះថេរៈសួរសាមណេរដែលមកកាន់ទីបម្រើ កំពុងអង្គុយហើយ សួរថា សាមណេរ អ្នករៀបចំទីលំនៅរបស់ខ្លួនហើយឬ សាមណេរឆ្លើយថា ខ្ញុំមិនបានឱកាសដើម្បីរៀបចំទេ លោកម្ចាស់ ។

ព្រះថេរៈពោលថា បើដូច្នោះ អ្នកចូរនៅក្នុងលំនៅរបស់ខ្ញុំចុះ ការនៅក្នុងទីអាគន្តុកៈលំបាក ។ នាំសាមណេរនោះឯងចូលទៅកាន់សេនាសនៈហើយ ។ ឯព្រះថេរៈជាបុថុជ្ជន គ្រាន់តែសិងប៉ុណ្ណោះ ក៏ឈមចុះកាន់ការនិទ្រា ។ សាមណេរគិតថា ថ្ងៃនេះ ជាថ្ងៃទី ៣ របស់អញ ដែលនៅក្នុងសេនាសនៈជាមួយព្រះឧបជ្ឈាយ៍ បើអាត្មាអញដេកលក់ ព្រះថេរៈគប្បីត្រូវសហសេយ្យាបត្តិ អញនឹងអង្គុយតែម្យ៉ាង ញុំាងកាលឲ្យកន្លងទៅ ។ សាមណេរអង្គុយពត់ភ្នែន ក្បែរគ្រែរបស់ឧបជ្ឈាយ៍នោះឯង ញុំាងរាត្រីឲ្យកន្លងទៅហើយ ។ ព្រះថេរៈក្រោកឡើងក្នុងវេលាទៀបភ្លឺ គិតថា គួរឲ្យសាមណេរចេញ ទើបចាប់ផ្លិតដែលនៅក្បែរគ្រែ យកចុងផ្លិតវាយកន្ទេលផែងរបស់សាមណេរហើយ លើកផ្លិតឡើងលើ ពោលថា សាមណេរ ចូរចេញទៅខាងក្រៅ ចុងផ្លិតក៏ចាក់ភ្នែក

បែកហើយ មួយរំពេចនោះឯង សាមណេរពោលថា មានការអ្វីលោកម្ចាស់ ព្រះថេរៈពោលថា ចូរអ្នកក្រោកឡើងចេញទៅខាងក្រៅចុះ សាមណេរក៏មិនពោលថា ក្អែករបស់ខ្ញុំបែកហើយ បិទក្អែកដោយដៃម្ខាងចេញទៅ ។ ក្នុងពេលធ្វើវត្ត សាមណេរមិនអង្គុយស្ងៀម ដោយគិតថា ក្អែករបស់អាត្មាអញបែកហើយ ខ្ទប់ក្អែកដោយដៃម្ខាង កាន់អំបោសដោយដៃម្ខាង បោសវច្ចកុដិនិងទីលុបមុខ តម្កល់ទឹកលុបមុខទុកហើយ បោសបរិវេណ ប្រគេនឈើស្ទន់ដល់ព្រះឧបជ្ឈាយ៍ ក៏ប្រគេនដោយដៃម្ខាង ។

គ្រានោះ ឧបជ្ឈាយ៍ពោលនឹងសាមណេរនោះថា សាមណេរនេះមិនបានសិក្សាហ្ន៎ ទើបប្រគេនឈើស្ទន់ដល់អាចារ្យ និងឧបជ្ឈាយ៍ដោយដៃម្ខាង ។ សាមណេរពោលថា បពិត្រលោកម្ចាស់ ខ្ញុំជ្រាបថា នុ៎ះមិនមែនជាវត្ត តែដៃម្ខាងរបស់ខ្ញុំមិនទំនេរ ព្រះថេរៈសួរថា នែសាមណេរ តើមានរឿងអ្វី ។

សាមណេរប្រាប់ការប្រព្រឹត្តទៅនោះតាំងពីដើមដល់ចប់ហើយ ព្រះថេរៈស្តាប់ហើយ មានចិត្តសង្វេគពោលថា ឱកម្មធ្ងន់អាត្មាអញធ្វើហើយ ពោលថា សូមអត់ទោសដល់ខ្ញុំចុះសប្បុរស ខ្ញុំមិនដឹងសេចក្តីនោះ សូមអ្នកជាទីពឹងរបស់ខ្ញុំ ដូច្នេះហើយ ផ្គងអញ្ជលី អង្គុយច្រហោងទៀបបាទារបស់សាមណេរអាយុ ៧ ឆ្នាំ ។ លំដាប់នោះ សាមណេរប្រាប់ព្រះថេរៈនោះថា ខ្ញុំមិនបានពោលដើម្បីហេតុនោះទេ ខ្ញុំកាលតាមរក្សាចិត្តរបស់លោកម្ចាស់ ទើបបានពោលហើយយ៉ាងនេះ ។ ក្នុងសេចក្តីនេះ ទោសរបស់លោកម្ចាស់ក៏មិនមាន ទោសរបស់ខ្ញុំក៏មិនមាន នុ៎ះជាទោសរបស់វដ្តៈប៉ុណ្ណោះ សូមលោកម្ចាស់កុំគិតឡើយ ខ្ញុំ

រក្សាការក្តៅក្រហាយរបស់លោកម្ចាស់នោះឯង ទើបមិនប្រាប់ ។ ព្រះថេរៈ កាលសាមណេរឲ្យធូរស្រាលចិត្ត ក៏មិនធូរស្រាលចិត្ត មានសេចក្តីសង្វេគកើតឡើងហើយ កាន់កណ្ឌៈរបស់សាមណេរ ទៅកាន់សម្នាក់ព្រះសាស្តាហើយ ។ ព្រះសាស្តា ប្រថាប់គង់ទតការមករបស់ព្រះថេរៈនោះដូចគ្នា ព្រះថេរៈនោះទៅថ្វាយបង្គំព្រះសាស្តា ធ្វើសេចក្តីត្រេកអរជាមួយនឹងព្រះសាស្តាហើយ កាលព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុ អ្នកល្មមអត់ធន់បានដែរឬ ការមិនផាសុកដ៏ខ្លាំងក្លាណាមួយ មិនមានទេឬ ទើបក្រាបទូលថា បពិត្រព្រះអង្គ ល្មមអត់ធន់បាន ការមិនផាសុកដ៏ខ្លាំងក្លាណាមួយរបស់ខ្ញុំព្រះអង្គ មិនមាន ។ម្យ៉ាងទៀត អ្នកដទៃដែលមានគុណយ៉ាងក្រៃលែង ដូចសាមណេរតូចនេះ ខ្ញុំព្រះអង្គមិនធ្លាប់ឃើញឡើយ ព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុ កម្មអ្វីដែលសាមណេរធ្វើហើយ ព្រះថេរៈក្រាបទូលការប្រព្រឹត្តទៅទាំងអស់នោះ តាំងអំពីដើមដល់ចប់ ដល់ព្រះដ៏មានព្រះភាគ ហើយក្រាបទូលថា បពិត្រព្រះអង្គ សាមណេរនេះ កាលខ្ញុំព្រះអង្គឲ្យអត់ទោសយ៉ាងនេះ ពោលនឹងខ្ញុំព្រះអង្គយ៉ាងនេះថា ក្នុងសេចក្តីនេះ ទោសរបស់លោកម្ចាស់មិនមានឡើយ ទោសរបស់ខ្ញុំក៏មិនមាន នុ៎ះជាទោសរបស់វដ្តៈប៉ុណ្ណោះ សូមលោកម្ចាស់កុំគិតឡើយ ។ សាមណេរ ញ៉ាំងខ្ញុំព្រះអង្គឲ្យធូរស្បើយហើយនោះឯង ដោយប្រការដូច្នេះ មិនធ្វើសេចក្តីក្រោធ មិនធ្វើសេចក្តីប្រទូស្តក្នុងខ្ញុំព្រះអង្គឡើយ បពិត្រព្រះអង្គ បុគ្គលសម្បូរដោយគុណបែបនេះ ខ្ញុំព្រះអង្គ ពុំធ្លាប់ឃើញឡើយ ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងព្រះថេរៈថា ម្នាលភិក្ខុ ធម្មតា ព្រះខីណាស្រពទាំងឡាយ មិនក្រោធ មិនប្រទូស្តចំពោះបុគ្គលណា ជាអ្នកមានឥន្រ្ទិយស្ងប់ហើយ ជាអ្នកមានចិត្តស្ងប់ហើយនោះឯង ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**សន្តំ តស្ស មនំ ហោតិ សន្តា វាចា ច កម្ម ច**
**សម្មទញ្ញា វិមុត្តស្ស ឧបសន្តស្ស តាទិនោ ។**

ចិត្តស្ងប់ វាចាស្ងប់ និងកាយកម្មស្ងប់ រមែងមានដល់
លោកដែលដឹងដោយប្រពៃ ផុតស្រឡះ ( ចាកភគា-
ទិក្កិលេស ) ជាអ្នកស្ងប់រម្ងាប់ដូច្នោះ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **សន្តំ** សេចក្តីថា ចិត្តរបស់សមណៈដែលជាខីណាស្រពនោះ ឈ្មោះថា ស្ងប់ហើយពិត គឺរម្ងាប់ បានដល់ រលត់ព្រោះការមិនមាននៃមនោទុច្ចរិតទាំងឡាយ មានអភិជ្ឈាជាដើម មួយ៉ាងទៀត វាចា ឈ្មោះថា ស្ងប់ហើយ ព្រោះការមិនមាននៃវចីទុច្ចរិតទាំងឡាយ មានមុសាវាទជាដើម និងកាយកម្ម ឈ្មោះថា ស្ងប់ហើយនោះឯង ព្រោះការមិនមាននៃកាយទុច្ចរិត មានបាណាតិបាតជាដើម ។

បាទព្រះគាថាថា **សម្មទញ្ញា វិមុត្តស្ស** សេចក្តីថា បុគ្គលរួចផុតវិសេសហើយដោយវិមុត្តិ ៥ ព្រោះដឹងដោយន័យ ដោយហេតុ ។

បទថា **ឧបសន្តស្ស** សេចក្តីថា ឈ្មោះថា ជាអ្នកស្ងប់រម្ងាប់ហើយ

ព្រោះការស្ងប់រម្ងាប់នៃកិលេស មានរាគៈជាដើមខាងក្នុង ។

បទថា **តាទិនោ** គឺជាអ្នកសម្បូរដោយគុណបែបនោះ ។

ក្នុងកាលចប់ទេសនា ព្រះតិស្សត្ថេរអ្នកក្រុងកោសម្ពី បានសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ ធម្មទេសនាបានជាប្រយោជន៍ដល់មហាជនដ៏សេសផ្សេងទៀត ។

**រឿង ព្រះតិស្សត្ថេរអ្នកក្រុងកោសម្ពី ចប់**

# រឿង ព្រះសារីបុត្តត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសារីបុត្តត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **អស្សទ្ធោ** ជាដើម ។

សេចក្តីពិស្តារថា ភិក្ខុអ្នកនៅព្រៃជាវត្តប្រមាណ ៣០ រូប ថ្ងៃមួយចូលទៅកាន់សម្នាក់ព្រះសាស្តា ថ្វាយបង្គំអង្គុយហើយ ។ ព្រះសាស្តាទ្រង់ជ្រាបឧបនិស្ស័យនៃអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយរបស់ភិក្ខុទាំងនោះហើយ ត្រាស់ហៅព្រះសារីបុត្តត្ថេរមក ត្រាស់សួរបញ្ហាប្រារព្ធឥន្ទ្រិយ ៥ យ៉ាងនេះថា ម្នាលសារីបុត្ត អ្នកជឿឬ ឥន្ទ្រិយ គឺសទ្ធាដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងឈមចុះដល់អមតៈ មានអមតៈជាទីបំផុត ។ ព្រះថេរៈទូលដោះស្រាយបញ្ហានោះយ៉ាងនេះថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គ

រមែងមិនដល់នូវការជឿចំពោះព្រះដ៏មានព្រះភាគក្នុងឥន្ទ្រិយ ៥ នេះឯងថា ឥន្ទ្រិយ គឺសទ្ធា ។បេ។ មានអមតៈជាទីបំផុត ខ្ញុំព្រះអង្គចម្រើនឥន្ទ្រិយ គឺសទ្ធា នោះ ដែលជនទាំងឡាយណាមិនដឹងហើយ មិនស្តាប់ហើយ មិនឃើញហើយ មិនជ្រាបហើយ មិនធ្វើឲ្យជាក់ច្បាស់ហើយ មិនពាល់ត្រូវហើយដោយបញ្ញា ជនទាំងនោះគប្បីដល់ដោយការជឿចំពោះជនដទៃក្នុងឥន្ទ្រិយ ៥ នោះថា ឥន្ទ្រិយ គឺសទ្ធា ។បេ។ មានអមតៈជាទីបំផុត ។ ភិក្ខុទាំងឡាយស្តាប់ពាក្យនោះហើយ ញុំាងកថាឲ្យតាំងឡើងថា ព្រះសារីបុត្តត្រេរច្ឆើយហើយ ដោយការយល់ខុស នោះឯង ក្នុងថ្ងៃនេះ ព្រះថេរៈមិនជឿចំពោះព្រះសម្មាសម្ពុទ្ធនោះឯង ។

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យនោះហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកពោលពាក្យដូចម្តេច តថាគតសួរថា ម្នាលសារីបុត្ត អ្នកជឿឬទេថា ឈ្មោះថា បុគ្គលមិនអប់រំឥន្ទ្រិយ ៥ មិនចម្រើនសមថៈ និងវិបស្សនា អាច ធ្វើមគ្គ និងផលឲ្យជាក់ច្បាស់មាន សារីបុត្តពោលថា បពិត្រព្រះអង្គ ខ្ញុំព្រះ អង្គមិនជឿថា បុគ្គលធ្វើឲ្យជាក់ច្បាស់យ៉ាងនោះ ឈ្មោះថា មាន សារីបុត្តមិន ជឿផលវិបាកនៃទានដែលបុគ្គលឲ្យហើយ ឬនៃកម្មដែលបុគ្គលធ្វើហើយ ក៏ មិនមែន ម្យ៉ាងទៀត សារីបុត្តមិនជឿគុណរបស់ព្រះរតនត្រ័យរបស់ព្រះពុទ្ធ ជាដើម ក៏មិនមែន តែសារីបុត្តនោះ មិនដល់នូវការជឿចំពោះបុគ្គលដទៃក្នុង ធម៌ គឺឈាន វិបស្សនា មគ្គ និងផលដែលខ្លួនបានចំពោះហើយ ព្រោះដូច្នោះ ទើបសារីបុត្ត ជាបុគ្គលដែលបុគ្គលណាម្នាក់មិនគួរតិះដៀល ។ កាលទ្រង់ បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថាថា

**អស្សទ្ធោ អកតញ្ញូ ច សន្ធិច្ឆេទោ ច យោ នរោ**
**ហតាវកាសោ វន្តាសោ ស វេ ឧត្តមបោរិសោ ។**

នរជនណាមិនជឿអ្នកដទៃផង ស្គាល់ព្រះនិព្វានផង កាត់នូវគ្រឿងត គឺវដ្ដៈផង មានឱកាសកម្ចាត់បង់ហើយផង មានសេចក្ដីប្រាថ្នាខ្ជាក់ចោលហើយផង នរជននោះជាឧត្តមបុរស ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **អស្សទ្ធោ** ជាដើម គប្បីជ្រាបវិគ្គហៈដូច្នេះថា នរៈ ឈ្មោះថា អស្សទ្ធោ ព្រោះអត្ថថា មិនជឿគុណដែលខ្លួនចាក់ធ្លុះហើយដោយពាក្យរបស់ជនដទៃ ឈ្មោះថា អកតញ្ញូ ព្រោះអត្ថថា ដឹងព្រះនិព្វានដែលបច្ច័យធ្វើមិនបានហើយ អធិប្បាយថា មានព្រះនិព្វានដែលខ្លួនធ្វើឲ្យជាក់ច្បាស់ហើយ ។ ឈ្មោះថា **សន្ធិច្ឆេទោ** ព្រោះអត្ថថា កាត់នូវទី-ត គឺវដ្ដៈ ទី-ត គឺសង្សារ តាំងនៅ ។ ឈ្មោះថា **ហតាវកាសោ** ព្រោះអត្ថថា ឱកាសនៃការកើតឡើង ឈ្មោះថា ដែលនរៈកម្ចាត់ហើយ ព្រោះភាពដែលពូជ គឺកុសលកម្មនិងអកុសលកម្មអស់ហើយ ។ ឈ្មោះថា **វន្តាសោ** ព្រោះអត្ថថា ការប្រាថ្នាទាំងពួង ឈ្មោះថា នរៈនេះខ្ជាក់ចោលហើយ ព្រោះភាពដែលកិច្ចដែលខ្លួនគួរធ្វើដោយមគ្គ ៤ ដែលខ្លួនធ្វើហើយ ។ នរៈបែបនេះណា នរៈនោះឯងឈ្មោះថា ឧត្តមបុរស ព្រោះអត្ថថា ដល់នូវភាពខ្ពង់ខ្ពស់ក្នុងបុរសទាំងឡាយដោយភាពដែលលោកុត្តរធម៌ ខ្លួនចាក់ធ្លុះហើយ ។

ក្នុងកាលចប់ព្រះគាថា ភិក្ខុ ៣០ រូប ដែលនៅព្រៃទាំងនោះ សម្រេច

អរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយហើយ ។

ព្រះធម្មទេសនា មានប្រយោជន៍ដល់មហាជនដ៏សេស ដូច្នេះឯង ។៚

**រឿង ព្រះសារីបុត្តត្ថេរ ចប់**

# រឿង ព្រះខទិរវនិយរេវតត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះរេវតត្ថេរ ដែលនៅក្នុងព្រៃគគីរ ត្រាស់ព្រះធម្មទេសនានេះថា **គាមេ វា** ជាដើម ។

សេចក្តីពិស្តារថា ព្រះសារីបុត្តលះទ្រព្យ ៨៧ កោដិបួសហើយ បបួលប្អូនស្រី ៣ នាក់ គឺនាងចាលា នាងឧបចាលា នាងសីសុបចាលា និងប្អូនប្រុស ២ នាក់ គឺចុន្ទ និងឧបសេន ឲ្យបួសហើយ ។ រេវតកុមារម្នាក់ប៉ុណ្ណោះដែលនៅសល់ក្នុងផ្ទះ ។ លំដាប់នោះ ម្តាយលោកគិតថា ឧបតិស្សៈកូនរបស់អញ លះទ្រព្យប្រមាណប៉ុណ្ណោះបួសហើយ បបួលប្អូនស្រី ៣ នាក់ ប្អូនប្រុស ២ នាក់ឲ្យបួសផង រេវតៈម្នាក់ប៉ុណ្ណោះនៅសល់ បើលោកបបួលរេវតៈនេះឲ្យបួសសោត ទ្រព្យរបស់អញមានប្រមាណប៉ុណ្ណោះក៏នឹងវិនាស វង្សត្រកូលនឹងដាច់សូន្យ អញនឹងចងរេវតៈនោះ ដោយការនៅគ្រប់គ្រងផ្ទះ ក្នុងកាលដែលនៅជាកុមារចុះ ។

ចំណែកព្រះសារីបុត្ត ផ្តាំភិក្ខុទាំងឡាយមុនថា អាវុសោ បើរេវតៈចង់

បួស មកសោត លោកគប្បីឲ្យគេបួសដោយគ្រាន់តែមកដល់ប៉ុណ្ណោះ ព្រោះញោមស្រីញោមប្រុសរបស់ខ្ញុំជាមនុស្សមិច្ឆាទិដ្ឋិ ។ ប្រយោជន៍អ្វីដោយលោកទាំងពីរនោះ ដែលរេវតៈលាមកបួស ខ្ញុំនេះឯងជាមាតា និងបិតារបស់រេវតៈនោះ ។

មាតារបស់ព្រះសារីបុត្តនោះ បំណងនឹងចងរេវតកុមារ ដែលមានអាយុ ៧ ឆ្នាំប៉ុណ្ណោះ ដោយគ្រឿងចង គឺផ្ទះ ទើបនាំក្មេងស្រីក្នុងត្រកូលដែលមានជាតិស្មើគ្នា កំណត់ថ្ងៃហើយ ប្រដាប់តាក់តែងកុមារហើយ បាននាំទៅកាន់ផ្ទះរបស់ញាតិខាងស្រី មួយអន្លើដោយបរិវារជាច្រើន ។ លំដាប់នោះ កាលពួកញាតិរបស់គេទាំងពីរធ្វើការមង្គល ប្រជុំគ្នាហើយ ពួកញាតិឲ្យគេទាំងពីរជ្រលក់ដៃក្នុងថាសទឹកហើយ ពោលមង្គលទាំងឡាយ ប្រាថ្នាសេចក្ដីចម្រើនដល់ក្មេងស្រី ទើបពោលថា ចូរនាងឃើញធម៌ដែលយាយរបស់នាងឃើញហើយ ចូរនាងរស់នៅអស់កាលយឺនយូរដូចយាយ ។ រេវតកុមារក៏បានគិតថា នេះអ្វីហ្ន៎ ឈ្មោះថា ធម៌ដែលយាយឃើញហើយ ទើបសួរថា អ្នកណាជាយាយរបស់ទារិកា ។ លំដាប់នោះ ពួកញាតិប្រាប់រេវតៈថា នែបា លោកយាយនេះមានអាយុ ១២០ ឆ្នាំ មានធ្មេញបាក់ សក់ស្កូវ ស្បែកជ្រីវជ្រួញ ខ្នួនញ័រទទ្រើក ខ្នងកោងដូចបង្កង់ផ្ទះ អ្នកមិនឃើញទេឬ ទុំះជាជីដូនរបស់ទារិកានោះ រេវតៈសួរថា ទារិកានេះនឹងទៅជាយ៉ាងនោះឬ ពួកញាតិពោលថា បើនាងរស់នៅ សោត ក៏នឹងទៅជាយ៉ាងនោះ ។

រេវតៈនោះគិតថា ឈ្មោះថា សរីរៈបែបនេះ នឹងដល់នូវប្រការប្រែប្រួល

នេះព្រោះជរា ឧបតិស្សៈបងប្រុសអញឃើញហេតុនេះហើយ អញគួរតែគេច ចេញទៅបួសក្នុងថ្ងៃនេះឯង ពេលនោះ ពួកញាតិពឡើងកាន់យានតែមួយ ជាមួយទារិកានាំចេញទៅហើយ រេវតៈទៅបានបន្តិច អាងដល់ការបន្ទោបង់ ឧច្ចារៈ ពោលថា ចូរអ្នកទាំងឡាយបញ្ឈប់យានសិន ខ្ញុំចុះទៅហើយនឹង ត្រឡប់មក ដូច្នោះហើយ ចុះអំពីយានបង្អែបង្អង់បន្តិចត្រង់គុម្ពឈើមួយ ហើយទើបទៅ ។ ទៅបានបន្តិចហើយ ចុះទៅដោយការអាងនោះឯងទៀត ឡើងហើយ ក៏បានធ្វើយ៉ាងនោះដូចគ្នាទៀត ។

លំដាប់នោះ ពួកញាតិកំណត់ថា រេវតៈនេះបំណងទៅពិតៗ ទើបមិន បានធ្វើការរក្សាឲ្យតឹងរ៉ឹង ។ រេវតៈទៅបានបន្តិច ក៏ចុះទៅដោយការអាងនោះ ឯងទៀត ពោលថា សូមពួកលោកបរទៅខាងមុខ ខ្ញុំនឹងដើរសន្សឹមៗ អំពីក្រោយ ទើបចុះទៅហើយ បែរមុខទៅកាន់គុម្ពោតព្រៃ ។

ពួកញាតិរបស់រេវតៈ បរយានទៅដោយសម្គាល់ថា រេវតៈនឹងមកតាម ក្រោយ ចំណែករេវតៈនោះគេចទៅអំពីទីនោះហើយ ទៅកាន់សម្នាក់របស់ ភិក្ខុប្រមាណ ៣០ រូប ដែលនៅក្នុងប្រទេសមួយកន្លែង ថ្វាយបង្គំហើយ ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទាំងឡាយឲ្យខ្ញុំបួសចុះ ភិក្ខុ ទាំងឡាយសួរថា អាវុសោ អ្នកប្រដាប់ដោយគ្រឿងអលង្ការសព្វយ៉ាង ពួក អាត្មាមិនស្គាល់ថា អ្នកជាព្រះរាជឱរស ឬជាកូនរបស់អមាត្យ នឹងឲ្យបួស ដូចម្ដេចបាន រេវតៈពោលថា លោកម្ចាស់មិនស្គាល់ខ្ញុំឬ ពួកភិក្ខុពោលថា អើ អាវុសោ រេវតៈពោលថា ខ្ញុំជាប្អូនប្រុសរបស់ឧបតិស្សៈ ពួកភិក្ខុពោលថា

ឈ្មោះឧបតិស្សៈនោះជាអ្នកណា រេវតៈពោលថា លោកម្ចាស់ទាំងឡាយហៅបងប្រុសខ្ញុំថា សារីបុត្ត ព្រោះដូច្នោះ កាលខ្ញុំប្រាប់ថាឧបតិស្សៈ ទើបលោកម្ចាស់ទាំងឡាយមិនស្គាល់ ។ ពួកភិក្ខុពោលថា អ្នកជាប្អូនប្រុសរបស់ព្រះសារីបុត្តឬ រេវតៈពោលថា យ៉ាងនោះឯង លោកម្ចាស់ ។

ភិក្ខុទាំងនោះពោលថា បើដូច្នោះ មកចុះ បងប្រុសរបស់អ្នកអនុញ្ញាតហើយផងដែរ ដូច្នេះហើយ ឲ្យដោះគ្រឿងអាភរណៈចេញ ព្យួរក្នុងទីបំផុតនាចំណែកម្ខាង ឲ្យបួសហើយ ទើបបញ្ជូនដំណឹងដល់ព្រះថេរៈ ។

ព្រះថេរៈស្តាប់ដំណឹងនោះហើយ ក៏ក្រាបទូលដល់ព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គ ភិក្ខុទាំងឡាយឲ្យដំណឹងមកថា ពួកភិក្ខុដែលនៅព្រៃឲ្យរេវតៈបួស ខ្ញុំព្រះអង្គទៅសួរសុខទុក្ខលោកហើយ នឹងត្រឡប់មក ។

ព្រះសាស្តា ទ្រង់មិនព្រមឲ្យទៅ ដោយព្រះតម្រាស់ថា សារីបុត្ត ចូរអ្នកបង្អង់សិន ។ ដោយកាលកន្លងទៅ ២-៣ ថ្ងៃ ព្រះថេរៈក៏ទូលលាព្រះសាស្តាម្តងទៀត ។ ព្រះសាស្តាទ្រង់មិនអនុញ្ញាតឲ្យទៅ ដោយព្រះតម្រាស់ថា សារីបុត្ត ចូរបង្អង់សិន ព្រោះតថាគតក៏នឹងទៅ ។

ចំណែកសាមណេរគិតថា បើអញនៅក្នុងទីនេះសោត ពួកញាតិនឹងឲ្យមនុស្សតាមហៅអញត្រឡប់ ទើបរៀនកម្មដ្ឋានរហូតអរហត្ត អំពីសម្នាក់របស់ភិក្ខុទាំងនោះ កាន់បាត្រ និងចីវរ ត្រាច់ទៅដល់ព្រៃគគីរ ក្នុងទីប្រមាណ ៣០ យោជន៍អំពីទីនោះ ។ ក្នុងរវាង ៣ ខែ ខាងក្នុងវស្សានោះឯង សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ ។

ព្រះថេរៈបវារណាហើយ ទូលលាព្រះសាស្តាដើម្បីទៅក្នុងទីនោះទៀត ព្រះសាស្តាត្រាស់ថា សារីបុត្ត ឯតថាគតក៏ទៅ ទ្រង់យាងទៅមួយអន្លើដោយភិក្ខុ ៥០០ រូប ។ ក្នុងពេលយាងទៅបានបន្តិច ព្រះអានន្ទត្ថេរឈរត្រង់ផ្លូវបែកជាពីរ ក្រាបទូលព្រះសាស្តាថា បពិត្រព្រះអង្គ បណ្តាផ្លូវដែលទៅកាន់សម្នាក់របស់រេវតៈ ផ្លូវនេះជាផ្លូវអមប្រមាណ ៦០ យោជន៍ ជាទីនៅរបស់មនុស្ស ផ្លូវនេះជាផ្លូវត្រង់ប្រមាណ ៣០ យោជន៍ ដែលអមនុស្សគ្រប់គ្រង ពួកយើងទៅដោយផ្លូវណា ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ សីវលីមកជាមួយពួកយើងដែរឬទេ ព្រះអានន្ទទូលថា បពិត្រព្រះអង្គ សីវលីមកដែរ ព្រះសាស្តាត្រាស់ថា បើសីវលីមក ចូរអ្នកកាន់យកផ្លូវត្រង់នោះឯង ។

បានឮថា ព្រះសាស្តាមិនបានត្រាស់ថា តថាគតនឹងញ៉ាំងបបរ បាយឲ្យកើតឡើងដល់ពួកអ្នក ចូរពួកអ្នកកាន់យកផ្លូវត្រង់ ទ្រង់ជ្រាបថា ទីនោះ ជាទីឲ្យផលនៃបុណ្យដល់ជននោះៗ ទើបត្រាស់ថា បើសីវលីមក ចូរអ្នកកាន់យកផ្លូវត្រង់ ។ កាលព្រះសាស្តាទ្រង់យាងទៅផ្លូវនោះ ពួកទេវតាគិតថា ពួកយើងនឹងធ្វើសក្ការៈដល់ព្រះសីវលិត្ថេរ លោកម្ចាស់របស់យើង បាននិម្មិតវិហារក្នុងទីមួយយោជន៍ ១ មួយយោជន៍ ១ មិនឲ្យឆ្ងាយជាងមួយយោជន៍ ក្រោកឡើងអំពីព្រលឹមកាន់យកវត្ថុ មានបបរជាដើមដែលជាទិព្វ ហើយដើរទៅដោយតាំងចិត្តថា ព្រះសីវលិត្ថេរ លោកម្ចាស់របស់យើង គង់ក្នុងទីណា ។

ព្រះថេរៈឲ្យទេវតាប្រគេនភត្ត ដែលនាំមកដើម្បីខ្លួនដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ព្រះសាស្តា មួយអន្លើដោយបរិវារ សោយផលបុណ្យរបស់

ព្រះសីវលិត្ថេរតែមួយអង្គ បានយាងកាត់ផ្លូវកន្តារប្រមាណ ៣០ យោជន៍ ។

ចំណែកព្រះរេវតត្ថេរ ជ្រាបការយាងមករបស់ព្រះសាស្តា ទើបនិម្មិតព្រះគន្ធកុដិដើម្បីព្រះដ៏មានព្រះភាគ និម្មិតផ្ទះកំពូល ៥០០ ទីចង្ក្រម ៥០០ ទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃ ៥០០ ។ ព្រះសាស្តា ប្រថាប់នៅក្នុងសម្នាក់របស់ព្រះរេវតៈនោះអស់កាលប្រមាណ ១ ខែដូច្នេះ សូម្បីប្រថាប់នៅក្នុងទីនោះ ក៏ដោយផលបុណ្យរបស់ព្រះសីវលិត្ថេរនោះឯង ។

បណ្តាភិក្ខុទាំងនោះ ភិក្ខុចាស់ពីររូប ក្នុងពេលព្រះសាស្តាយាងចូលទៅកាន់ព្រៃគគីរ គិតហើយយ៉ាងនេះថា ភិក្ខុនេះធ្វើនវកម្ម គឺកសាងប្រមាណប៉ុណ្ណេះ នឹងអាចធ្វើសមណធម៌បានដូចម្តេច ព្រះសាស្តាទ្រង់ធ្វើកិច្ច គឺការយល់មុខដោយទ្រង់ព្រះតម្រិះថា ជាប្អូនប្រុសរបស់ព្រះសារីបុត្ត ទើបយាងមកកាន់សម្នាក់របស់លោក ដែលប្រកបនវកម្មបែបនេះ ។

ក្នុងថ្ងៃនោះ ព្រះសាស្តាទ្រង់ប្រមើលមើលសត្វលោកក្នុងពេលទៀបភ្លឺ ទ្រង់ឃើញភិក្ខុទាំងនោះហើយ ទ្រង់ជ្រាបវារៈចិត្តរបស់ភិក្ខុទាំងនោះហើយ ព្រោះហេតុនោះ ប្រថាប់នៅក្នុងទីនោះអស់កាលប្រមាណ ១ ខែហើយ ក្នុងថ្ងៃយាងចេញទៅ ទ្រង់អធិដ្ឋានឲ្យភិក្ខុទាំងនោះភ្លេចបំពង់ប្រេង បំពង់ទឹក តម្រងទឹក និងស្បែកជើងរបស់ខ្លួនយាងចេញទៅ ក្នុងពេលយាងចេញទៅខាងក្រៅឧបចារវិហារ ទើបព្រះថេរៈរំសាយឫទ្ធិ ។

គ្រានោះ ភិក្ខុទាំងនោះពោលថា ខ្ញុំភ្លេចរបស់នេះ និងរបស់នេះ ខ្ញុំក៏ភ្លេច

ដូច្នេះហើយ ទាំងពីររូបក៏ត្រឡប់ទៅ មិនកំណត់ទីនោះ ត្រូវបន្ទាគគីរ[១] មុត ត្រាច់ទៅ ជួបរបស់ដែលខ្ទួនក្មេច ព្យួរត្រង់ដើមគគីរមួយដើម កាន់យក ហើយ ក៏ចៀសចេញទៅ ។

ព្រះសាស្តា ទ្រង់នាំភិក្ខុសង្ឃទៅ សោយផលបុណ្យរបស់ព្រះសីវលី អស់កាលប្រមាណ ១ ខែនោះឯងទៀត យាងចូលទៅកាន់បុព្វារាម ។ គ្រា នោះ ភិក្ខុចាស់ទាំងនោះលុបមុខអំពីព្រលឹម ដើរទៅដោយតាំងចិត្តថា ពួក យើងនឹងបាន់បបរក្នុងផ្ទះរបស់នាងវិសាខា ដែលថ្វាយអាគន្តុកភត្ត ឆាន់បបរ ហើយ ឆាន់របស់ទំពាអគ្គ័យនៅ ។

លំដាប់នោះ នាងវិសាខាសួរភិក្ខុចាស់ទាំងនោះថា បពិត្រលោកម្ចាស់ លោកម្ចាស់ទាំងឡាយ បានទៅលំនៅរបស់ព្រះរេវតត្ថេរជាមួយព្រះសាស្តាឬ ភិក្ខុចាស់ពោលថា អើ ឧបាសិកា នាងវិសាខាពោលថា បពិត្រលោកម្ចាស់ លំនៅរបស់ព្រះថេរៈគួរជាទីត្រេកអរឬ ។ ភិក្ខុចាស់ពោលថា លំនៅរបស់ ព្រះថេរៈនោះ ជាទីត្រេកអរមកអំពីណា ទីនោះប្រេងេងប្រងាងដោយដើមគគីរ មានបន្លាពណាស ដូចគ្នានឹងលំនៅរបស់ពួកប្រេត ។

គ្រានោះ ភិក្ខុកំលោះពីររូបដទៃមកហើយ ។ ឧបាសិកាប្រគេនបបរ និង របស់គួរទំពាទាំងឡាយ ដល់ភិក្ខុកំលោះទាំងនោះហើយ សួរយ៉ាងនោះដូចគ្នា ភិក្ខុទាំងនោះពោលថា ឧបាសិកា ពួកអាត្មាមិនអាចពណ៌នាបាន លំនៅរបស់

---

១- ដើមគគីរមិនមានបន្លាទេ តែដោយបាលី លោកពោលថា ខទិរគុម្ពកណ្តកេហិ ទើបយើងប្រែថា បន្លាគគីរ ។

ព្រះថេរៈដូចគ្នានឹងទេវសកា ឈ្មោះសុធម្មា គាក់តែងដោយឫទ្ធិ ។

ឧបាសិកាគិតថា ភិក្ខុដែលមកមុនពោលមួយបែប ភិក្ខុពួកនេះពោលមួយបែប ភិក្ខុដែលមកមុនភ្លេចរបស់អ្វីមួយពិត ត្រឡប់ទៅក្នុងកាលដែលឫទ្ធិរំសាយហើយ ចំណែកភិក្ខុទាំងនេះ នឹងទៅក្នុងពេលដែលព្រះថេរៈនិម្មិតទីកន្លែងដោយឫទ្ធិ ព្រោះភាពដែលខ្លួនជាបណ្ឌិតទើបជ្រាបសេចក្តីនោះ បានឈរហើយបំណងថា នឹងទូលសួរក្នុងកាលដែលព្រះសាស្តាយាងមក មួយរំពេចនោះឯង ព្រះសាស្តាដែលភិក្ខុសង្ឃចោមរោម យាងទៅកាន់ផ្ទះរបស់នាងវិសាខា ប្រថាប់គង់លើអាសនៈដែលគេរៀបចំហើយ នាងអង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានដោយគោរព ក្នុងពេលស្រេចភត្តកិច្ច ថ្វាយបង្គំព្រះសាស្តាហើយទូលសួរចំពោះថា បពិត្រព្រះអង្គ បណ្តាភិក្ខុដែលទៅជាមួយព្រះអង្គ ភិក្ខុពួកខ្លះ ពោលថា លំនៅរបស់ព្រះរេវតៈ ជាព្រៃស្អុកដោយដើមគគីរ ពួកខ្លះពោលថា ជាទីគួរត្រេកអរ តើលំនៅរបស់ព្រះថេរៈនោះ ដូចម្តេចហ្ន៎ ។

ព្រះសាស្តា ស្តាប់ពាក្យនោះហើយ ត្រាស់ថា ឧបាសិកា ស្រុកក្តី ព្រៃក្តី ព្រះអរហន្តទាំងឡាយនៅក្នុងទីណា ទីនោះ គួរត្រេកអរពិត ដូច្នេះហើយកាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**គាមេ វា យទិ វា រញ្ញេ  និន្នេ វា យទិ វា ថលេ**
**យត្ថ អរហន្តោ វិហរន្តិ  តំ ភូមិរាមណេយ្យកំ ។**

ព្រះអរហន្តទាំងឡាយ នៅក្នុងទីណា ទោះជាស្រុកក្តី
ព្រៃក្តី ទីទាបក្តី ទីទួលក្តី ទីនោះឯងជាភូមិគួរត្រេកអរ ។

# សេចក្តីអធិប្បាយ

ក្នុងព្រះគាថានោះ សេចក្តីថា ព្រះអរហន្តទាំងឡាយរមែងមិនបានកាយវិវេកខាងក្នុងស្រុកក៏ពិត តែរមែងបានចិត្តវិវេកយ៉ាងពិតប្រាកដ ព្រោះអារម្មណ៍ទាំងឡាយប្រៀបដូចរបស់ទិព្វ រមែងមិនអាចធ្វើចិត្តរបស់ព្រះអរហន្តទាំងនោះឲ្យញាប់ញ័របាន ព្រោះហេតុនោះ ទោះជាស្រុក ឬជាទីណាមួយ មានព្រៃជាដើម ព្រះអរហន្តទាំងឡាយ រមែងនៅក្នុងទីណា ។ បាទព្រះគាថាថា **តំ ភូមិរាមណេយ្យកំ** សេចក្តីថា ភូមិស្ថាននោះ ជាទីគួរត្រេកអរពិត ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ក្នុងសម័យដទៃទៀត ភិក្ខុទាំងឡាយសន្ទនាគ្នាថា អាវុសោទាំងឡាយ ព្រោះហេតុអ្វីហ្ន៎ ទើបព្រះសីវលិត្ថេរនៅក្នុងផ្ទៃមាតារហូត ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ ព្រោះកម្មអ្វី ទើបឆេះហើយក្នុងនរក ព្រោះកម្មអ្វី ទើបជាអ្នកមានលាភដ៏ក្រៃលែង និងមានយសដ៏ក្រៃលែងយ៉ាងនេះ ។

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យនោះហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំង-ឡាយ ពួកអ្នកសន្ទនាអំពីរឿងអ្វី កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ កថាឈ្មោះនេះ ដូច្នេះហើយ កាលនឹងត្រាស់បុព្វកម្មរបស់ព្រះសីវលិត្ថេរនោះ ទើបត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រះដ៏មានព្រះភាគព្រះនាមវិបស្សី ទ្រង់កើតឡើងក្នុងលោកហើយ សម័យមួយ ទ្រង់យាងចារិកទៅក្នុងជនបទ ត្រឡប់មកកាន់នគររបស់ព្រះបិតា ។ ព្រះរាជាទ្រង់ត្រៀម

អាគន្តុកទានដើម្បីភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ទ្រង់បញ្ជូនដំណឹងដល់អ្នកនគរថា ចូរជនទាំងឡាយ មកជាសម្លាញ់របស់យើង ។ ជនទាំងនោះធ្វើយ៉ាងនោះហើយគិតថា ពួកយើងនឹងថ្វាយទាន ឲ្យក្រៃលែងជាងទានដែលព្រះរាជាថ្វាយហើយ ទើបទូលនិមន្តព្រះសាស្តា ក្នុងថ្ងៃស្អែកឡើង តាក់តែងទានហើយបញ្ជូនដំណឹងទៅទូលដល់ព្រះរាជា ។ ព្រះរាជាយាងមកទតឃើញទានរបស់ជនទាំងនោះហើយ ទ្រង់ព្រះតម្រិះថា អញនឹងថ្វាយទានឲ្យក្រៃលែងជាងទាននេះ ក្នុងថ្ងៃស្អែកឡើង ទ្រង់និមន្តព្រះសាស្តាហើយ ។ ព្រះរាជាទ្រង់មិនអាចឲ្យអ្នកនគរចុះចាញ់បាន សូម្បីអ្នកនគរក៏មិនអាចឲ្យព្រះរាជាចាញ់បាន ។ ក្នុងគ្រាទី ៦ អ្នកនគរគិតថា ឥឡូវនេះ ពួកយើងនឹងថ្វាយទានក្នុងថ្ងៃស្អែកនេះ ដោយប្រការដែលបុគ្គលណាម្នាក់មិនអាចពោលបានថា មិនមានវត្ថុឈ្មោះនេះក្នុងទានរបស់ជនទាំងនោះ ដូច្នេះហើយ ក្នុងថ្ងៃស្អែកឡើង ចាត់ចែងរបស់ថ្វាយស្រេចហើយ ពិនិត្យមើលថា អ្វីហ្ន៎ មិនទាន់មានក្នុងទាននេះ ក៏មិនបានឃើញទឹកឃ្មុំឆៅ ចំណែកទឹកឃ្មុំផ្អែមមានច្រើន ។ ជនទាំងនោះ បានកាន់យកទ្រព្យ ៤ ពាន់ហើយ បញ្ជូនទៅក្នុងទ្វារនៃព្រះនគរទាំង ៤ ដើម្បីទឹកឃ្មុំឆៅ ។

គ្រានោះ អ្នកស្រុកក្រៅម្នាក់ មកសួរសុខទុក្ខមេស្រុក ឃើញសម្បុកឃ្មុំក្នុងរវាងផ្លូវ ដេញមេឃ្មុំឲ្យហើរទៅហើយ កាប់មែកឈើត្រង់បន្តង មួយអន្ទើដោយក្បាលទឹកនោះឯង ចូលទៅកាន់ព្រះនគរដោយតាំងចិត្តថា អញនឹងឲ្យដល់មេស្រុក ។ បុរសដែលទៅដើម្បីរកទឹកឃ្មុំ ជួបបុរសស្រុកក្រៅនោះហើយ សួរថា នែអ្នក ទឹកឃ្មុំរបស់អ្នកលក់ដែរឬទេ អ្នកស្រុកក្រៅពោលថា

មិនលក់ទេ បុរសនោះពោលថា សូមអ្នកទទួលយកកហាបណៈនេះ ហើយឲ្យឃ្មុំដល់ខ្ញុំចុះ អ្នកស្រុកក្រៅនោះគិតថា ឃ្មុំនេះមានតម្លៃត្រឹមតែមួយបាទ តែបុរសនេះឲ្យមួយកហាបណៈ ប្រហែលជាមានកហាបណៈច្រើន អញគួរដំឡើងតម្លៃ ។ លំដាប់នោះ ទើបគាត់ឆ្លើយនឹងបុរសនោះថា ខ្ញុំឲ្យមិនបានទេ បុរសនោះពោលថា បើដូច្នេះ សូមអ្នកទទួលយក ២ កហាបណៈចុះ អ្នកស្រុកក្រៅពោលថា សូម្បី ២ កហាបណៈក៏ខ្ញុំឲ្យមិនបាន ។

គេដំឡើងតម្លៃដោយអាការយ៉ាងនោះ រហូតដល់បុរសនោះពោលថា បើដូច្នោះ សូមអ្នកទទួលយកទ្រព្យមួយពាន់កហាបណៈនេះ ដូច្នេះហើយ ហុចកញ្ចប់កណ្ដុះទៅ ។ ពេលនោះ អ្នកស្រុកក្រៅពោលនឹងបុរសនោះថា អ្នកឆ្កួតឬហ្ន៎ ឬមិនបានឱកាសជាទីទុកកហាបណៈ ទឹកឃ្មុំនេះតម្លៃមិនដល់មួយបាទ អ្នកនៅតែពោលថា សូមយកកហាបណៈមួយពាន់ ហើយឲ្យឃ្មុំដល់ខ្ញុំ ឈ្មោះថាមានហេតុដូចម្ដេច បុរសនោះពោលថា នែអ្នក ខ្ញុំដឹងកម្មរបស់ខ្ញុំដោយទឹកឃ្មុំនេះមាន ព្រោះហេតុនោះ ទើបខ្ញុំពោលយ៉ាងនោះ អ្នកស្រុកក្រៅពោលថា តើកម្មនោះជាកម្មអ្វី បុរសនោះពោលថា ពួកខ្ញុំត្រៀមធ្វើមហាទានដើម្បីព្រះវិបស្សីសម្មាសម្ពុទ្ធ ដែលមានសមណៈ ៦ លាន ៨ សែនជាបរិវារ ក្នុងមហាទាននោះ ខ្វះតែទឹកឃ្មុំឆៅប៉ុណ្ណោះ ព្រោះដូច្នោះ ទើបខ្ញុំសុំទិញដោយអាការយ៉ាងនោះ អ្នកស្រុកក្រៅពោលថា បើយ៉ាងនោះ ខ្ញុំឲ្យដោយមិនគិតថ្លៃ បើខ្ញុំបានចំណែកបុណ្យខ្លះ ក្នុងទាននោះសោត ។

បុរសនោះ ទៅប្រាប់សេចក្ដីនោះដល់អ្នកនគរ អ្នកនគរកោលជ្រាបភាព

ដែលសទ្ធារបស់គាត់មានកម្លាំង ទើបទទួលថា សាធុ សូមបុរសនោះបាន ចំណែកបុណ្យចុះ ។ ពួកអ្នកនគរនោះនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យគង់ហើយ ថ្វាយបបរ និងរបស់ទំពា ឲ្យមនុស្សនាំថាសមាសយ៉ាងធំ មក ប្របាច់សម្បុកឃ្មុំហើយ សូម្បីបំពង់ទឹកដោះដែលមនុស្សនោះនាំមក ដើម្បីជា រង្វាន់មាន ។ គេចាក់ទឹកដោះនោះចូលក្នុងថាសហើយ លាយជាមួយទឹកឃ្មុំ នោះ ប្រគេនដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ចាប់តាំងអំពីដើមអាសនៈ ។ ទឹកឃ្មុំនោះទូទៅដល់ភិក្ខុគ្រប់រូប ដែលទទួលយករហូតគ្រប់គ្រាន់ តាមសេចក្តី ត្រូវការបានសល់ហូរហៀរ ។ បុគ្គលណាម្នាក់មិនគួរគិតថា ទឹកឃ្មុំតិចយ៉ាង នោះ គ្រប់គ្រាន់ដល់ភិក្ខុច្រើនដល់ម៉្លោះបានដូចម្តេច ពិតហើយ ទឹកឃ្មុំនោះ គ្រប់គ្រាន់ បានដោយអានុភាពនៃព្រះសម្ពុទ្ធ ។ ពុទ្ធវិស័យ បុគ្គលមិនគួរគិត ។ ពិតហើយ ហេតុ ៤ យ៉ាង ដែលព្រះដ៏មានព្រះភាគត្រាស់ថា ជារឿងដែល មិនគួរគិត ។ បុគ្គលណាម្នាក់គិតហេតុទាំងនោះ រមែងជាអ្នកមានចំណែកនៃ មនុស្សឆ្កួតនោះឯង ដោយប្រការដូច្នេះ ។

បុរសនោះ ធ្វើកម្មប្រមាណប៉ុណ្ណោះហើយ ក្នុងកាលជាទីបំផុតនៃអាយុ កើតក្នុងទេវលោក អន្ទោលទៅមកអស់កាលមានប្រមាណប៉ុណ្ណោះ ក្នុងសម័យ មួយ ចុតិអំពីទេវលោកមកកើតក្នុងរាជត្រកូល ក្នុងនគរពារាណសី ដោយ កាលដែលព្រះជនកសោទិវង្គត ដល់នូវភាពជាព្រះរាជាហើយ ។ ទ្រង់ព្រះ តម្រិះថា នឹងដណ្តើមយកនគរមួយ ទើបយាងទៅព័ទ្ធនគរនោះ ហើយទ្រង់ បញ្ជូនសាសន៍ទៅដល់អ្នកនគរថា ឲ្យរាជសម្បត្តិ ឬក៏ច្បាំង អ្នកនគរទាំងនោះ

ធ្វើយថា នឹងមិនឲ្យទាំងរាជសម្បត្តិ នឹងមិនឲ្យទាំងការច្បាំង ដូច្នេះហើយ ក៏ចេញទៅនាំឧស និងទឹកជាដើមមកតាមទ្វារតូចៗ ធ្វើកិច្ចគ្រប់យ៉ាង ។

ចំណែកព្រះរាជា រក្សាទ្វារធំទាំង ៤ ព័ទ្ធព្រះនគរអស់ ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ ។ ក្នុងកាលតមក ព្រះជននីរបស់ព្រះរាជានោះត្រាស់សួរថា បុត្ររបស់យើងធ្វើដូចម្ដេច ព្រះនាងស្ដាប់រឿងនោះថា ទ្រង់ធ្វើកម្មឈ្មោះនេះ ទើបត្រាស់ថា បុត្ររបស់ខ្ញុំល្ងង់ ចូរពួកអ្នកទៅទូលដល់បុត្ររបស់យើងនោះថា ចូរបិទទ្វារតូចៗ ព័ទ្ធព្រះនគរ ។ ព្រះរាជាទ្រង់ស្ដាប់ពាក្យប្រៀនប្រដៅរបស់ព្រះជននីហើយ ក៏បានធ្វើយ៉ាងនោះ ។

ចំណែកអ្នកក្រុង កាលមិនបានចេញទៅខាងក្រៅ ក្នុងថ្ងៃទី ៧ ទើបផ្ដាច់ព្រះជន្មព្រះរាជារបស់ខ្លួន ថ្វាយរាជសម្បត្តិដល់ព្រះរាជានោះ ។ ទ្រង់ធ្វើកម្មនេះហើយ ក្នុងទីបំផុតនៃអាយុទៅកើតក្នុងអវិចី ឆេះហើយក្នុងនរកដរាបដល់ផែនដីដុះឡើងប្រមាណមួយយោជន៍ ចុតិអំពីអត្តភាពនោះហើយ បដិសន្ធិក្នុងផ្ទៃរបស់មាតានោះឯង នៅក្នុងផ្ទៃអស់ ៧ ឆ្នាំ ៧ ខែ នៅទទឹងទ្វារមាសអស់ ៧ ថ្ងៃ ព្រោះភាពដែលខ្លួនបិទទ្វារតូចៗ ទាំង ៤ ។

ម្នាលភិក្ខុទាំងឡាយ សីវលីឆេះហើយក្នុងនរកអស់កាលប្រមាណប៉ុណ្ណោះ ព្រោះកម្មដែលព័ទ្ធព្រះនគរ ដណ្ដើមយកក្នុងកាលនោះ បដិសន្ធិក្នុងផ្ទៃរបស់មាតានោះឯង នៅក្នុងផ្ទៃអស់កាលប្រមាណប៉ុណ្ណោះ ព្រោះសីវលីបិទទ្វារតូចៗ ទាំង ៤ ជាអ្នកដល់នូវភាពជាបុគ្គលមានលាភដ៏កំពូល មានយសដ៏កំពូល ព្រោះសីវលីបានថ្វាយទឹកឃ្មុំស្រស់ ដោយប្រការយ៉ាងនេះ ។

ក្នុងថ្ងៃស្អែកឡើង ភិក្ខុទាំងឡាយសន្ទនាគ្នាថា សាមណេរតែមួយរូប និម្មិតផ្ទះកំពូល ៥០០ ដើម្បីភិក្ខុ ៥០០ រូប មានលាភ មានបុណ្យគួរសរសើរពិតហ្ន៎ ព្រះសាស្ដាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញពួកអ្នកអង្គុយប្រជុំគ្នាដោយកថាដូចម្ដេចហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ ដោយកថាឈ្មោះនេះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុត្ររបស់តថាគតមិនមានបុណ្យ មិនមានបាប ព្រោះបុណ្យនិងបាបទាំងពីរ បុត្រតថាគតលះហើយ បានត្រាស់ព្រះគាថានេះនៅក្នុងព្រាហ្មណវគ្គថា

> បុគ្គលណា ក្នុងលោកនេះ លះបង់បុណ្យ និងបាបទាំង ២ និង
> កិលេសជាគ្រឿងជំពាក់ ( មានរាគៈជាដើម ) ចេញហើយ
> តថាគតហៅបុគ្គលនោះ ដែលជាអ្នកមិនមានសេចក្ដីសោក
> មានធូលី គឺកិលេសអស់ហើយ ជាអ្នកបរិសុទ្ធថាជាព្រាហ្មណ៍ ។

**រឿង ព្រះខទិរវនិយរេវតត្ថេរ ចប់**

# រឿង អញ្ញតរិត្ថី

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធស្រីម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **រមណីយានិ** ជាដើម ។

បានឮមកថា ភិក្ខុសមាទានបិណ្ឌបាតមួយរូប រៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះសាស្ដាហើយ ចូលទៅកាន់ឧទ្យានដែលគេបោះបង់មួយ ធ្វើសមណធម៌ ។ គ្រានោះ ស្រីដែលធ្វើឲ្យនគរស្អាតម្នាក់ ធ្វើការណាត់ជាមួយបុរសថា ខ្ញុំនឹងទៅកាន់ទីឈ្មោះនោះ អ្នកគប្បីមកក្នុងទីនោះ បានទៅហើយ ។ បុរសនោះមិនមក នាងចាំមើលផ្លូវបុរសនោះមិនឃើញ អផ្សុកកើតឡើង ទើបត្រាច់ទៅខាងនោះខាងនេះ ចូលទៅកាន់ឧទ្យាននោះ ជួបព្រះថេរៈកំពុងអង្គុយពត់ភ្នែន សម្លឹងមើលឆ្វេងស្ដាំមិនឃើញអ្នកដទៃ គិតថា បុគ្គលនេះក៏ជាប្រុសដូចគ្នា អញនឹងញុំាងចិត្តរបស់បុគ្គលនេះឲ្យវង្វេង ឈរខាងមុខរបស់ព្រះថេរៈនោះ ដោះសំពត់ស្លៀកហើយ ធ្វើជាស្លៀកវិញរឿយៗ រំសាយសក់ហើយចងវិញ ទះដៃ ហើយសើច ។

ការសង្វេគកើតឡើងដល់ព្រះថេរៈ ផ្សាយជ្រួតជ្រាបពេញសរីរៈ លោកគិតថា មានរឿយអ្វីហ្ន៎ ។

ចំណែកព្រះសាស្ដាទ្រង់ពិចារណាថា ការប្រព្រឹត្តទៅរបស់ភិក្ខុដែលរៀនកម្មដ្ឋានអំពីសម្នាក់របស់តថាគត ទៅហើយ ដោយតាំងចិត្តថា នឹងធ្វើសមណធម៌ យ៉ាងណាហើយហ្ន៎ ទ្រង់ឃើញស្រីនោះហើយ ទ្រង់ជ្រាបកិរិយា

*អនាចាររបស់ស្រីនោះ នឹងការកើតឡើងនៃសេចក្តីសង្វេគរបស់ព្រះថេរៈ ប្រថាប់គង់ក្នុងព្រះគន្ធកុដិនោះឯង ត្រាស់នឹងព្រះថេរៈថា ម្នាលភិក្ខុ ទីដែលមិនត្រេកអររបស់ពួកបុគ្គលអ្នកស្វែងរកកាមនោះឯង ជាទីត្រេកអររបស់បុគ្គលដែលមានរាគៈទៅប្រាសហើយ ។ កាលទ្រង់ត្រាស់យ៉ាងនោះហើយ ទ្រង់បញ្ចេញឱភាសទៅ កាលទ្រង់សម្តែងធម៌ដល់ភិក្ខុនោះ ត្រាស់ព្រះគាថានេះថា*

**រមណីយានិ អរញ្ញានិ យត្ថ ន រមតី ជនោ**
**វីតរាគា រមេស្សន្តិ ន តេ កាមគវេសិនោ ។**

*ជន ( អ្នកស្វែងរកកាម ) រមែងមិនត្រេកអរក្នុងព្រៃដែលគួររីករាយទេ ព្រះខីណាស្រពដែលមានរាគៈ ទៅប្រាសហើយ ទើបត្រេកអរក្នុងព្រៃនោះ ព្រោះលោកជាអ្នកមិនស្វែងរកកាម ។*

## សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ បទថា* **អរញ្ញានិ** *សេចក្តីថា ធម្មតាព្រៃទាំងឡាយដែលប្រដាប់ដោយដងព្រៃ មានដើមឈើជំទង់ៗ មានផ្ការីកហើយ សម្បូរដោយទឹកថ្លាស្អាត ជាទីគួរត្រេកអរ ។ បទថា* **យត្ថ** *ជាដើម សេចក្តីថា ជនអ្នកស្វែងរកកាម រមែងមិនត្រេកអរក្នុងព្រៃទាំងឡាយណា ដូចសត្វរុយស្រុកមិនត្រេកអរក្នុងគុម្ពឈូក ដែលមានផ្ការីកហើយ ដូច្នោះ ។*

*បទថា* **វីតរាគា** *ជាដើម សេចក្តីថា បុគ្គលដែលមានរាគៈទៅប្រាស*

ហើយទាំងឡាយ គឺព្រះវីណាស្រេត នឹងត្រេកអរក្នុងព្រៃទាំងឡាយបែបនោះ ដូចកន្ទន់ និងឃ្មុំត្រេកអរក្នុងគុម្ពឈូក ដូច្នោះ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះលោកមានរាគៈទៅប្រាសហើយទាំងនោះ ជាអ្នកមានប្រក្រតីមិនស្វែងរកកាម អធិប្បាយថា ព្រោះលោកទាំងនោះ មិនជាអ្នកមានប្រក្រតីស្វែងរកកាមឡើយ ទើបត្រេកអរក្នុងព្រៃទាំងឡាយ ។

ក្នុងកាលចប់ព្រះធម៌ទេសនា ព្រះថេរៈនោះ អង្គុយតាមប្រក្រតីនោះឯង សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ មកតាមអាកាស ធ្វើនូវការសរសើរ ថ្វាយបង្គំបាទាទាំងទ្វេរបស់ព្រះតថាគត បានទៅហើយដូច្នេះឯង ។៚

**រឿងអញ្ញតរិត្ថី ចប់**

**អរហន្តវគ្គ ចប់**

**វគ្គទី ៧ ចប់**

# សុត្តន្តបិដក

## ធម្មបទគាថា សហស្សវគ្គទី ៨

[ ១៨ ] បើវាចា សូម្បី ១ ពាន់ម៉ាត់ ជាវាចាប្រកបដោយបទឥតប្រយោជន៍ វាចានោះ ពុំប្រសើរឡើយ អ្នកណា ស្តាប់បទមានប្រយោជន៍ណាហើយ រមែងស្ងប់រម្ងាប់បាន បទមានប្រយោជន៍នោះ សូម្បីតែមួយបទ ក៏ឈ្មោះថា ប្រសើរជាង ។

បើគាថា សូម្បី ១ ពាន់ ជាគាថាប្រកបដោយបទឥតប្រយោជន៍ គាថានោះ ពុំប្រសើរឡើយ អ្នកណា ស្តាប់បទនៃគាថាណាហើយ រមែងស្ងប់រម្ងាប់បាន បទនៃគាថានោះ សូម្បីតែមួយបទ ក៏ឈ្មោះថា ប្រសើរជាង ។

អ្នកណា គប្បីពោលគាថា មួយរយ ជាគាថាប្រកបដោយបទឥតប្រយោជន៍ គាថាដែលអ្នកនោះពោលហើយនោះ ពុំប្រសើរឡើយ អ្នកណា ស្តាប់បទនៃធម៌ហើយ រមែងស្ងប់រម្ងាប់បាន បទនៃធម៌នោះ សូម្បីតែមួយបទ ក៏ឈ្មោះថា ប្រសើរជាង ។

អ្នកណា គប្បីឈ្នះពួកមនុស្ស ក្នុងសង្គ្រាមអស់ ១ ពាន់ៗ ដង គឺ ១ លាន ចំណែកអ្នកណា ឈ្នះខ្លួនឯងម្នាក់ឯងបាន អ្នកនោះ ឈ្មោះថា ជាមនុស្សខ្ពង់ខ្ពស់ ជាងអ្នកដែលឈ្នះក្នុងសង្គ្រាមនោះ ។

ខ្លួនឯងដែលឈ្នះហើយ ប្រសើរជាង ចំណែកពួកសត្វក្រៅពីនេះ ដែលគេឈ្នះហើយ មិនប្រសើរឡើយ កាលបើបុរសមានខ្លួនទូន្មានហើយ ជាអ្នកប្រព្រឹត្តសង្រួមជានិច្ច ទេវតា គន្ធព្វ មារ ព្រមទាំងព្រហ្ម មិនគប្បីធ្វើ

នូវជម្ពុះ របស់សត្វមានសភាពដូច្នោះ ឲ្យត្រឡប់ចាញ់វិញបានឡើយ ។

អ្នកណា បូជា ( លោកិយមហាជន ) ដោយទ្រព្យមួយពាន់រាល់ខែៗ អស់ ១ រយឆ្នាំគត់ ចំណែកអ្នកណា គប្បីបូជាចំពោះបុគ្គលដែលមានខ្លួនអប់រំហើយ តែមួយនាក់ សូម្បីតែមួយរំពេច ការបូជានោះឯង ប្រសើរជាង ការបូជារបស់អ្នកដែលបូជាអស់ ១ រយឆ្នាំនោះ ការបូជាអស់ ១០០ ឆ្នាំ មិនប្រសើរឡើយ ។

ជនណា បម្រើភ្លើងក្នុងព្រៃអស់ ១០០ ឆ្នាំ ចំណែកអ្នកណាបូជាលោកដែលមានខ្លួនអប់រំហើយ តែ ១ នាក់ សូម្បីមួយរំពេច ការបូជានោះឯងប្រសើរជាងការបូជារបស់ជននោះ ការបូជាអស់ ១០០ ឆ្នាំ មិនប្រសើរឡើយ ។

បុគ្គលអ្នកប្រាថ្នាបុណ្យ គប្បីបូជាគ្រឿងសក្ការបូជា ធំ តូចណាមួយក្នុងលោកអស់ ១ ឆ្នាំ ការបូជាទាំងអស់នោះឯង រមែងមិនដល់នូវចំណែកទី ៤ នៃការអភិវាទន៍ ចំពោះលោកទាំងឡាយ ដែលប្រព្រឹត្តត្រង់ហើយប្រសើរជាង ។

ធម៌ ៤ ប្រការ គឺអាយុ ១ វណ្ណៈ ១ សុខ ១ ពល ១ រមែងចម្រើនដល់អ្នកដែលមានសេចក្តីឱនកាយថ្វាយបង្គំជាប្រក្រតី មានសេចក្តីក្រោតក្រែង ដល់បុគ្គលដែលចម្រើនជាងខ្លួន អស់កាលជានិច្ច ។

បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សទ្រុស្តសីល មានចិត្តមិនបានតម្កល់ខ្ជាប់ ការរស់នៅតែមួយថ្ងៃ របស់លោកដែលមានសីល មានការពិនិត្យពិចារណាជាប្រក្រតី ប្រសើរជាង ។

បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សមិនមានប្រាជ្ញា មានចិត្តមិនបានតម្កល់ខ្ជាប់ ការរស់នៅតែមួយថ្ងៃ របស់លោកដែលមានប្រាជ្ញា មានការពិនិត្យពិចារណាជាប្រក្រតី ប្រសើរជាង ។

បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សមានចិត្តជ្រុលធ្លាក់ក្នុងអកុសលវិតក្ក មានព្យាយាមថោកថយ ការរស់នៅសូម្បីតែមួយថ្ងៃ របស់លោកដែលប្រារព្ធសេចក្ដីព្យាយាមមាំមួន ប្រសើរជាង ។

បុគ្គលណា រស់នៅមួយរយឆ្នាំ មិនឃើញការកើតឡើង និងការវិនាសទៅ ការរស់នៅសូម្បីតែមួយថ្ងៃ របស់លោកដែលឃើញការកើតឡើង និងការវិនាសទៅ ប្រសើរជាង ។

បុគ្គលណា រស់នៅមួយរយឆ្នាំ មិនឃើញផ្លូវព្រះនិព្វាន ការរស់នៅសូម្បីតែ ១ ថ្ងៃ របស់លោកអ្នកឃើញផ្លូវព្រះនិព្វាន ប្រសើរជាង ។

បុគ្គលណា រស់នៅមួយរយឆ្នាំ មិនឃើញធម៌ដ៏ខ្ពង់ខ្ពស់ ការរស់នៅសូម្បីតែ ១ ថ្ងៃ របស់លោកអ្នកឃើញធម៌ដ៏ខ្ពង់ខ្ពស់ ប្រសើរជាង ។

**សហស្សវគ្គទី ៨ ចប់**

# អដ្ឋកថា
# សហស្សវគ្គ

## រឿង តម្ពទាឋិកចោរឃាតក
### លំនាំដើម

*ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធពេជ្ឈឃាតមានពុកមាត់ក្រហម ត្រាស់ព្រះធម្មទេសនានេះថា* **សហស្សមបិ ចេ វាចា** *ជាដើម ។*

*បានឮមកថា ចោរ ៤៩៩ នាក់ ធ្វើកម្មមានការប្លន់ស្រុកជាដើម សម្រេចការរស់នៅហើយ ។ គ្រានោះ បុរសម្នាក់មានភ្នែកក្រហម មានពុកមាត់ក្រហម ទៅកាន់សម្នាក់របស់ចោរទាំងនោះពោលថា ខ្ញុំនឹងនៅជាមួយពួកអ្នក ។ ពេលនោះពួកចោរ បង្ហាញបុរសនោះដល់មេចោរ ហើយពោលថា បុរសនេះចង់នៅក្នុងសម្នាក់របស់ពួកយើង ។ គ្រានោះ មេចោរសម្លឹងមើលបុរសនោះហើយគិតថា បុរសនេះរឹងត្អឹងពន់ពេក អាចកាត់ដោះរបស់ម្តាយ ឬឈាមក្នុងបំពង់ករបស់ឪពុក ហើយបរិភោគបាន ។ ទើបឃាត់ថា កិច្ច គឺការនៅក្នុងសម្នាក់របស់ពួកយើងសម្រាប់បុរសនេះមិនមាន ។ បុរសនោះត្រូវមេចោរឃាត់យ៉ាងនោះក៏មិនទៅ ទំនុកបម្រុងសិស្សម្នាក់របស់មេចោរនោះឯងឲ្យពេញចិត្តហើយ ចោរនោះនាំបុរសនោះ ចូលទៅរកមេចោរហើយអង្វរថា លោកនាយ បុគ្គល*

នេះជាមនុស្សល្អ មានឧបការៈដល់ពួកយើង សូមលោកនាយសង្គ្រោះគេផង ចុះ មេចោរនោះទទួលហើយ ។ ថ្ងៃក្រោយមក ពួកអ្នកស្រុករួមគ្នាជាមួយ ពួករាជបុរស ចាប់ចោរទាំងនោះបាន នាំទៅកាន់សម្នាក់របស់ពួកអមាត្យដែល ជាអ្នកវិនិច្ឆ័យក្តីទាំងឡាយ ។ ពួកអមាត្យបញ្ជាឲ្យកាត់ក្បាលរបស់ចោរទាំង នោះដោយពូថៅ ។ លំដាប់នោះ អ្នកស្រុកប្រឹក្សាគ្នាថា អ្នកណាហ្ន៎ហ៊ាន សម្លាប់ចោរទាំងនេះ ស្វែងរកក៏មិនឃើញអ្នកណាម្នាក់ ហ៊ានសម្លាប់ចោរទាំង នោះ ទើបនិយាយនឹងមេចោរថា អ្នកសម្លាប់ចោរទាំងនេះហើយ អ្នកនឹងបាន រួចជីវិត បានទូវការរាប់អានទៀតផង ចូរអ្នកសម្លាប់ចោរទាំងនោះ ។ សូម្បី មេចោរនោះ ក៏មិនប្រាថ្នាសម្លាប់ ព្រោះភាពដែលពួកចោរនោះ អាស្រ័យខ្លួន រស់នៅហើយ ពួកអ្នកស្រុកសួរចោរ ៤៩៩ ដោយឧបាយនោះ ។ ចោរទាំង អស់ក៏មិនប្រាថ្នាហើយ ។ ពួកអ្នកស្រុកសួរនាយតម្ពទាឋិកៈ គឺបុរសពុកមាត់ ក្រហម ភ្នែកក្រហមនោះក្រោយគេបង្អស់ ។ នាយតម្ពទាឋិកៈនោះទទួលថា សាធុ ហើយសម្លាប់ចោរទាំងអស់នោះ បានទូវជីវិតផង បានទូវការរាប់អាន ផង ។

ពួកអ្នកស្រុកនាំចោរ ៥០០ មកអំពីទិសខាងត្បូងនៃក្រុងហើយ បង្ហាញ ដល់ពួកអមាត្យដោយឧបាយនោះ កាលពួកអមាត្យនោះបញ្ជាឲ្យកាត់ក្បាល ចោរទាំងនោះ ទើបសួរតាំងអំពីមេចោរជាដើមទៅ មិនឃើញអ្នកណាហ៊ាន សម្លាប់ ទើបសួរថា ក្នុងថ្ងៃមុនបុរសម្នាក់សម្លាប់ចោរ ៥០០ នាក់ហើយ បុរសនោះនៅឯណាហ្ន៎ កាលជនទាំងឡាយឆ្លើយថា ពួកខ្ញុំឃើញគាត់ក្នុងទី

ឈ្មោះនោះ ទើបឲ្យហៅគាត់មកហើយ ប្រាប់ថា ចូរអ្នកសម្លាប់ចោរទាំងនេះ អ្នកនឹងបាននូវការរាប់អាន ។ តម្ពទាឋិកៈនោះទទួលថា សាធុ ហើយសម្លាប់ចោរទាំងនោះ បាននូវការរាប់អានហើយ ។

កាលនោះ អ្នកនគរទាំងនោះពិភាក្សាគ្នាថា បុរសនេះល្អ ពួកយើងនឹងធ្វើគាត់ឲ្យជាអ្នកសម្លាប់ចោរជាប្រចាំនោះឯង ដូច្នេះហើយ ទើបឲ្យតំណែងនោះដល់គាត់ ធ្វើនូវការរាប់អានហើយ ។

នាយតម្ពទាឋិកៈនោះ សម្លាប់ចោរ ម្តង ៥០០ៗ ដែលគេនាំមកពីទិសខាងលិចខ្លះ ទិសឧត្តរខ្លះ ។ គាត់សម្លាប់ចោរអស់ ២ ពាន់នាក់ ដែលនាំមកអំពីទិសទាំង ៤ ដោយឧបាយយ៉ាងនោះ ។ ចាប់តាំងអំពីនោះ កាលសម្លាប់មនុស្សដែលគេនាំមក ម្នាក់ ឬពីរនាក់រាល់ៗ ថ្ងៃ បានធ្វើការសម្លាប់ចោរអស់ ៥៥ ឆ្នាំ ក្នុងពេលគាត់ចាស់ មិនអាចកាត់ក្បាលចោរត្រឹមតែម្តងបាន ត្រូវកាប់ពីរ ឬបីដង ធ្វើឲ្យអ្នកស្លាប់ទាំងឡាយលំបាក ។ ពួកអ្នកស្រុកគិតគ្នាថា អ្នកសម្លាប់ចោរដទៃនឹងកើតឡើង បុគ្គលនេះ ធ្វើមនុស្សទាំងឡាយឲ្យលំបាកពន់ពេក តើត្រូវការអ្វីដោយបុគ្គលនេះ ទើបដកតំណែងរបស់គាត់នោះ ។

នាយតម្ពទាឋិកៈនោះ សម្លាប់ចោរក្នុងកាលមុន មិនបានកិច្ច ៤ យ៉ាង គឺស្លៀកសំពត់ថ្មី ១ ពិសាបបរលាយដោយទឹកដោះថ្មរំដោយសប្បិ ១ ប្រដាប់នូវផ្កាម្លិះ ១ លាបនូវគ្រឿងក្រអូប ១ ។ ក្នុងថ្ងៃដែលត្រូវចេញពីតំណែង គាត់ពោលថា ចូរអ្នកទាំងឡាយដាំបបរលាយទឹកដោះដល់ខ្ញុំ ហើយឲ្យមនុស្សកាន់យកសំពត់ថ្មី កម្រងផ្កាម្លិះ និងគ្រឿងលាប ទៅកាន់ស្ទឹងងូតទឹក ហើយស្លៀក

សំពត់ថ្មី ប្រដាប់ផ្កា មានខ្លួនលាបដោយគ្រឿងក្រអូប មកកាន់ផ្ទះអន្ទយហើយ ។ ពេលនោះ ជនទាំងឡាយ ដាក់បបរលាយដោយទឹកដោះ ផ្សំដោយសប្បិអំពីខាងមុខគាត់ហើយ នាំទឹកសម្រាប់លាងដៃមក ។

ក្នុងខណៈនោះ ព្រះសារីបុត្តត្ថេរចេញអំពីសមាបត្តិ ពិចារណាផ្លូវបិណ្ឌបាតរបស់ខ្លួនថា ថ្ងៃនេះ អាត្មាអញគួរទៅបិណ្ឌបាតទីណាហ្ន៎ ឃើញបបរទឹកដោះក្នុងផ្ទះរបស់តម្ពទាឋិកៈនោះ ពិចារណាថា បុរសនេះ គួរធ្វើការសង្គ្រោះឬហ្ន៎ ដឹងថា បុរសនេះឃើញអាត្មាអញហើយ នឹងធ្វើការសង្គ្រោះដល់អញ កុលបុត្រនេះ កាលធ្វើហើយ នឹងបានសម្បត្តិធំ ទើបដណ្តប់ចីវរកាន់បាត្របង្ហាញខ្លួន ត្រង់ទ្វារផ្ទះរបស់តម្ពទាឋិកៈនោះឯង ។

តម្ពទាឋិកៈនោះគ្រាន់តែឃើញព្រះថេរៈ ក៏មានចិត្តជ្រះថ្លាគិតថា អញធ្វើចោរឃាតកម្មមកអស់កាលដ៏យូរ អញសម្លាប់មនុស្សជាច្រើន ឥឡូវនេះ ក្នុងផ្ទះរបស់អញតាក់តែងបបរ លាយដោយទឹកដោះ ។ ឯព្រះថេរៈក៏មកឈរត្រង់ទ្វារផ្ទះរបស់អញ អញនឹងប្រគេនទេយ្យធម៌ដល់លោកម្ចាស់ក្នុងកាលនេះក៏គួរដូច្នេះហើយ ទើបនាំយកបបរដែលគេដាក់ចំពោះមុខចេញទៅ ចូលទៅរកព្រះថេរៈ ថ្វាយបង្គំហើយ និមន្តឲ្យគង់ខាងក្នុងផ្ទះ ដួសយាគូដែលផ្សំដោយទឹកដោះដាក់ក្នុងបាត្រ រោយដោយទឹកដោះស្រស់ ឈរបក់ព្រះថេរៈ ។ ពេលនោះអធ្យាស្រ័យដើម្បីបរិភោគបបរលាយទឹកដោះមានកម្លាំង ព្រោះគាត់មិនធ្លាប់បានហើយអស់កាលយូរ ព្រះថេរៈដឹងអធ្យាស្រ័យរបស់តម្ពទាឋិកៈនោះ ទើបនិយាយនឹងគាត់ថា ឧបាសក ចូរអ្នកបរិភោគបបររបស់ខ្លួនចុះ ។ គាត់ឲ្យផ្ចិត

ក្នុងដៃដល់អ្នកដទៃ ហើយបរិភោគខ្លួនឯង ។ ព្រះថេរៈនិយាយនឹងបុរសដែលបក់ផ្លិតថា ចូរអ្នកបក់ឲ្យឧបាសកចុះ ។ គាត់កាលបុរសនោះបក់ បរិភាគបបរពេញពោះហើយ មកឈរបក់ព្រះថេរៈ បានទទួលបាត្ររបស់ព្រះថេរៈដែលធ្វើភត្តកិច្ចស្រេចហើយ ។ ព្រះថេរៈក៏ផ្តើមអនុមោទនាដល់បុរសនោះ ។ គាត់មិនអាចធ្វើចិត្តរបស់ខ្លួន ឲ្យទៅតាមធម្មទេសនារបស់ព្រះថេរៈបាន ព្រះថេរៈសង្កេតបាន ទើបសួរថា ឧបាសក ហេតុអ្វី ទើបអ្នកមិនអាចធ្វើចិត្តឲ្យទៅតាមធម្មទេសនាបាន ។ តម្ពទាឋិកៈពោលថា បពិត្រលោកម្ចាស់ ខ្ញុំធ្វើកម្មថោកទាបមកអស់កាលដ៏យូរ មនុស្សជាច្រើនត្រូវខ្ញុំសម្លាប់ឲ្យស្លាប់ ខ្ញុំរឭកដល់កម្មរបស់ខ្លួននោះ ទើបមិនអាចធ្វើចិត្ត ឲ្យទៅតាមទេសនារបស់លោកម្ចាស់បាន ។ ព្រះថេរៈគិតថា អាត្មាអញនឹងបញ្ឆោតបុរសនេះ ទើបពោលថា អ្នកបានធ្វើតាមពេញចិត្តរបស់ខ្លួន ឬត្រូវអ្នកដទៃឲ្យធ្វើ តម្ពទាឋិកៈពោលថា បពិត្រលោកម្ចាស់ ព្រះរាជាឲ្យខ្ញុំធ្វើ ព្រះថេរៈពោលថា ឧបាសក បើដូច្នោះ អកុសលនឹងមានដល់អ្នកបានដូចម្តេចហ្ន៎ ។

ឧបាសកជាមនុស្សមានធាតុក្រាស់ ត្រូវព្រះថេរៈពោលយ៉ាងនោះ មានសេចក្តីសម្គាល់ថាអកុសលមិនមានដល់ខ្លួន ទើបពោលថា បពិត្រលោកម្ចាស់ បើដូច្នោះ សូមលោកម្ចាស់ពោលធម៌ចុះ ឧបាសកនោះ កាលព្រះថេរៈធ្វើអនុមោទនា មានចិត្តជាឯកគ្គតាស្តាប់ធម៌ ញ៉ាំងខន្តីឲ្យប្រព្រឹត្តទៅក្នុងអនុលោម ( ដល់អរិយសច្ច ) ខាងក្នុងនៃសោតាបត្តិមគ្គឲ្យកើតឡើងហើយ ។ ព្រះថេរៈធ្វើអនុមោទនាហើយ ក៏ចៀសចេញទៅ ។

យក្ខិនីម្នាក់ មកហើយដោយភេទនៃមេគោកូនខ្ចី ប៉ុះត្រង់ទ្រូងឧបាសកដែលតាមជូនដំណើរព្រះថេរៈបន្តិចហើយត្រឡប់ឲ្យស្លាប់ ឧបាសកនោះ ធ្វើកាលកិរិយាហើយ កើតក្នុងតុសិតបុរី ។

ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងរោងធម្មសភាថា បុរសសម្លាប់ចោរ ធ្វើកម្មគ្រោតគ្រាតអស់ ៥៥ ឆ្នាំ ផុតចាកកម្មនោះក្នុងថ្ងៃនេះឯង ថ្វាយភិក្ខាដល់ព្រះថេរៈក្នុងថ្ងៃនេះដូចគ្នា ធ្វើកាលកិរិយាក្នុងថ្ងៃនេះឯង គាត់កើតក្នុងទីណាហ្ន៎ ។

ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកសន្ទនាគ្នាដោយពាក្យអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថាដោយពាក្យឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុរសនោះកើតក្នុងតុសិតបុរី ភិក្ខុទាំងឡាយទូលសួរថា បពិត្រព្រះអង្គ ទ្រង់ត្រាស់អ្វី បុរសនោះសម្លាប់មនុស្សប៉ុណ្ណោះ អស់កាលប៉ុណ្ណោះ ហើយកើតក្នុងតុសិតវិមាន ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង បុរសនោះបានកល្យាណមិត្តធំ ព្រោះស្តាប់ធម្មទេសនារបស់សារីបុត្ត ញ៉ាំងអនុលោមញ្ញាណឲ្យកើតហើយ ឃ្លាតចាកលោកនេះហើយ កើតក្នុងតុសិតវិមានដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

បុរសសម្លាប់ចោរក្នុងក្រុង ស្តាប់ពាក្យជាសុភាសិតហើយ បាន
នូវអនុលោមខន្តី ទៅកាន់ទេវលោកដ៏ជាទិព្វ រមែងត្រេកអរ ។

ភិក្ខុទាំងឡាយទូលថា បពិត្រព្រះអង្គ ធម្មតាអនុមោទនាកថាមានកម្លាំងបុរសនោះធ្វើអកុសលច្រើន ញ៉ាំងគុណវិសេសឲ្យកើត ដោយហេតុប៉ុណ្ណោះ

បានដូចម្ដេច ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំកាន់យកប្រមាណនៃធម៌ ដែលតថាគតសម្ដែងហើយថា មានប្រមាណតិច ឬច្រើន ព្រោះថា វាចាមួយម៉ាត់ ដែលអាស្រ័យប្រយោជន៍ប្រសើរដោយពិត កាលទ្រង់បន្តអនុសន្ធិសម្ដែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**សហស្សមបិ ចេ វាចា អនត្ថបទសញ្ហិតា**
**ឯកំ អត្ថបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។**

បើវាចាសូម្បីមួយពាន់ម៉ាត់ ជាវាចាប្រកបដោយបទឥតប្រយោជន៍ វាចានោះពុំប្រសើរឡើយ អ្នកណាស្ដាប់បទមានប្រយោជន៍ណាហើយ រមែងស្ងប់រម្ងាប់បាន បទមានប្រយោជន៍នោះ សូម្បីតែមួយបទក៏ឈ្មោះថាប្រសើរជាង ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **សហស្សមបិ** ជាពាក្យសម្រាប់កំណត់អធិប្បាយថា បើវាចាដែលគេកំណត់ដោយពាន់យ៉ាងនេះ គឺមួយពាន់ ពីរពាន់សោត វាចាទាំងនោះមិនប្រកបដោយបទដែលជាប្រយោជន៍ គឺប្រកបដោយបទទាំងឡាយដែលមិនជាប្រយោជន៍ ដែលប្រកាសតែរឿងពណ៌នាអាកាស ពណ៌នាភ្នំ ពណ៌នាព្រៃជាដើម មិនសម្ដែងព្រះនិព្វាន មានច្រើនដរាបណា ក៏ជាវាចាអាក្រក់នោះឯងដរាបនោះ ។

ពីរបទថា **ឯកំ អត្ថបទំ** សេចក្ដីថា ចំណែកបុគ្គលស្ដាប់បទណាដែលជាប្រយោជន៍ សូម្បីតែមួយបទបែបនេះថា នេះកាយ នេះសតិក្នុងកាយ វិជ្ជា

៣ អាត្មាអញតាមសម្រេចហើយ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ អាត្មាអញធ្វើហើយ ។ រមែងស្ងប់រម្ងាប់ ដោយការស្ងប់រម្ងាប់កិលេស មានរាគៈជាដើមបាន បទនោះសម្រេចប្រយោជន៍ ប្រកបដោយនិព្វាន គឺសម្ដែងខន្ធ ធាតុ អាយតនៈ ឥន្ទ្រិយ ពល ពោជ្ឈង្គ និងសតិប្បដ្ឋានសូម្បីតែមួយបទ គង់ប្រសើរជាងដោយពិត ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

**រឿង តម្ពទាឋិកចោរឃាតក ចប់**

# រឿង ព្រះទារុចីរិយត្ថេរ

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះទារុចីរិយត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **សហស្សមបិ ចេ គាថា** ជាដើម ។

សេចក្ដីពិស្ដារថា ក្នុងកាលមួយមនុស្សជាច្រើន ចេញសំពៅទៅកាន់មហាសមុទ្រ កាលសំពៅលិចក្នុងមហាសមុទ្រ ក៏បានជាចំណីអណ្ដើក និងត្រីហើយ ។ បណ្ដាមនុស្សទាំងនោះ បុរសម្នាក់តោងបន្ទះក្ដារបានមួយបន្ទះ ព្យាយាមហែលទៅកាន់ត្រើយនៃកំពង់ឈ្មោះសុប្បារកៈ ។ គាត់មិនមានសំពត់ដណ្ដប់ ។ បុរសនោះ មិនឃើញអ្វីដទៃ ទើបយកធ្មេចងកំណាត់ឈើស្ងួតធ្វើ

ជាសំពត់ស្លៀក កាន់យកអំបែងអំពីទេវស្ថាន បានទៅកាន់កំពង់ ឈ្មោះសុប្បារកៈ ។ មនុស្សទាំងឡាយឃើញគាត់ហើយ ឲ្យបបរ និងភត្តជាដើម ហើយសរសើរថា បុគ្គលនេះ ជាព្រះអរហន្តមួយអង្គ ។ បុរសនោះ កាលមនុស្សទាំងឡាយនាំសំពត់ទៅឲ្យ គិតថា បើអញស្លៀក និងដណ្តប់ លាភសក្ការៈរបស់អញនឹងវិនាស ទើបឃាត់សំពត់ដែលគេនាំមក ស្លៀកដណ្តប់តែសម្បកឈើប៉ុណ្ណោះ ។

គ្រានោះ កាលគាត់ត្រូវមនុស្សជាច្រើនពោលថាជាព្រះអរហន្ត ការបរិវិតក្កនៃចិត្ត ទើបកើតឡើងយ៉ាងនេះថា ព្រះអរហន្ត ឬអ្នកសម្រេចអរហត្ត-មគ្គណាមួយក្នុងលោក បណ្តាព្រះអរហន្តទាំងនោះ អញក៏ជាព្រះអរហន្តមួយអង្គដែរ ។ ពេលនោះ ទេវតាជាសាលោហិតក្នុងកាលមុននៃបុរសនោះ ក៏គិតហើយយ៉ាងនោះ ។

ពាក្យថា ជាសាលោហិតក្នុងកាលមុន គឺធ្វើសមណធម៌រួមគ្នាក្នុងកាលមុន បានឮថា ក្នុងកាលមុន កាលសាសនារបស់ព្រះទសពល ព្រះនាមកស្សបៈសាបសូន្យទៅ ភិក្ខុ ៧ រូបឃើញអាការប្លែកនៃបព្វជិតទាំងឡាយ មានសាមណេរជាដើមហើយ ដល់នូវការសង្វេគ គិតថា ការអន្តរធាននៃព្រះសាសនា មិនមានដរាបណា ពួកយើងនឹងធ្វើទីពឹងដល់ខ្លួនដរាបនោះ ថ្វាយបង្គំសុវណ្ណចេតិយ ហើយចូលទៅកាន់ព្រៃ ឃើញភ្នំមួយ ទើបពោលថា អ្នកណាមានអាល័យក្នុងជីវិត ចូរត្រឡប់ទៅវិញចុះ អ្នកណាមិនមានអាល័យ ចូរឡើងភ្នំនេះ ប្រានជណ្តើរចោលហើយ ជនទាំងនោះ ឡើងភ្នំនោះ ប្រាន

ជណ្តើរចោល ហើយធ្វើសមណធម៌ ។ បណ្តាភិក្ខុទាំងនោះ ព្រះសង្ឃត្ថេរសម្រេចអរហត្ត ដោយកន្លងទៅត្រឹមមួយរាត្រីប៉ុណ្ណោះ ព្រះថេរៈនោះទំពាឈើស្ទន់ឈ្មោះនាគលតា ក្នុងអនោតត្តស្រះ នាំបិណ្ឌបាតមកអំពីឧត្តរកុរុទ្វីប ហើយពោលនឹងភិក្ខុទាំងនោះថា អាវុសោទាំងឡាយ ពួកអ្នកទំពាឈើស្ទន់នេះ ខ្ពុរមាត់ហើយ ចូរឆាន់បិណ្ឌបាតនេះ ភិក្ខុទាំងនោះពោលថា បពិត្រលោកម្ចាស់ ពួកយើងធ្វើកតិកាគ្នាយ៉ាងនេះថា ភិក្ខុណាសម្រេចអរហត្តមុនភិក្ខុទាំងឡាយដ៏សេស នឹងឆាន់បិណ្ឌបាតដែលភិក្ខុនោះនាំមកឬ ព្រះថេរៈពោលថា អាវុសោ សេចក្តីនោះ មិនមានឡើយ ភិក្ខុទាំងឡាយពោលថា បើដូច្នោះ ពួកខ្ញុំគប្បីញ៉ាំងគុណវិសេសឲ្យកើតដូចលោកម្ចាស់ ពួកខ្ញុំនឹងនាំមកបរិភោគឯង ដូច្នេះហើយ ក៏មិនប្រាថ្នា ។ ក្នុងថ្ងៃទីពីរ ព្រះថេរៈអន្តទីពីរសម្រេចអនាគាមិផលហើយ ។ សូម្បីព្រះថេរៈនោះនាំបិណ្ឌបាតមកហើយ ក៏និមន្តភិក្ខុក្រៅអំពីនេះយ៉ាងនោះដូចគ្នា ភិក្ខុទាំងនោះពោលយ៉ាងនេះថា បពិត្រលោកម្ចាស់ ពួកយើងធ្វើកតិកាគ្នាយ៉ាងនេះថា ពួកយើងមិនបរិភោគបិណ្ឌបាតដែលមហាថេរៈនាំមក តែនឹងបរិភោគបិណ្ឌបាត ដែលព្រះអនុថេរៈនាំមកឬព្រះថេរៈអន្តទីពីរពោលថា អាវុសោ សេចក្តីនោះមិនមានឡើយ ។ ភិក្ខុទាំងនោះពោលថា កាលបើដូច្នោះ ពួកខ្ញុំនឹងញ៉ាំងគុណវិសេសឲ្យកើតដូចលោកម្ចាស់ហើយ អាចបរិភោគដោយសេចក្តីព្យាយាមនៃកម្លាំងបុរសរបស់ខ្លួនបាន ទើបបរិភោគ ដូច្នេះហើយ ក៏មិនប្រាថ្នា ។

បណ្តាភិក្ខុទាំងនោះ ភិក្ខុសម្រេចអរហត្តបរិនិព្វានហើយ ភិក្ខុដែលជា

អនាគាមីកើតក្នុងព្រហ្មលោក ភិក្ខុ ៥ រូបក្រៅអំពីនេះ មិនអាចញ៉ាំងគុណវិសេសឲ្យកើតបាន ស្លាំងស្លូមហើយ ធ្វើកាលកិរិយាក្នុងថ្ងៃទី ៧ កើតក្នុងទេវលោក ក្នុងពុទ្ធុប្បាទកាលនេះ ចុតិអំពីទេវលោកនោះហើយ កើតក្នុងផ្ទះនៃត្រកូលនោះៗ ។

បណ្ដាជនទាំងនោះ បុគ្គលម្នាក់បានជាព្រះរាជា ឈ្មោះបុក្កុសាតិ ម្នាក់ទៀតបានជាកុមារកស្សបៈ ម្នាក់ទៀតបានជាទារុចីរិយៈ ម្នាក់ទៀតបានជាទព្វមល្លបុត្រ ម្នាក់ទៀតបានជាបរិព្វាជកឈ្មោះសភិយៈ ។ ពាក្យថា ទេវតាដែលជាសាលោហិតក្នុងកាលមុននេះ លោកពោលសំដៅយកភិក្ខុ ដែលកើតក្នុងព្រហ្មលោកនោះ ។

ព្រហ្មនោះ មានបរិវិតក្កយ៉ាងនេះថា បុរសនេះ ដាក់ជណ្ដើរហើយ ឡើងភ្នំ បានធ្វើសមណធម៌ជាមួយអញ ឥឡូវនេះ កាន់លទ្ធិនេះ ត្រាច់ទៅដើម្បីសេចក្ដីវិនាស អញនឹងញ៉ាំងបុរសនេះឲ្យសង្វេគ ។ ពេលនោះ ព្រហ្មនោះចូលទៅរកបុរសនោះហើយ ពោលយ៉ាងនេះថា ពាហិយៈ អ្នកមិនមែនជាព្រះអរហន្តទេ អ្នកមិនទាន់បានសម្រេចអរហត្តមគ្គឡើយ សូម្បីបដិបទារបស់អ្នកជាហេតុឲ្យបានជាព្រះអរហន្ត ឬជាអ្នកសម្រេចអរហត្តមគ្គ ក៏មិនមាន ។ ពាហិយៈសម្លឹងមើលមហាព្រហ្ម ដែលកំពុងឈរក្នុងអាកាស ទើបគិតថា ឱ អញធ្វើកម្មធ្ងន់ហ្ន៎ អញគិតថា ខ្លួនអញជាព្រះអរហន្ត ឯមហាព្រហ្មនេះនិយាយនឹងអញថា អ្នកមិនមែនព្រះអរហន្ត អ្នកមិនទាន់បានសម្រេចអរហត្តមគ្គឡើយ ព្រះអរហន្តដទៃ មាននៅក្នុងលោកនេះឬ ពេលនោះ គាត់សួរ

មហាព្រហ្មនោះថា អ្នកជាទេវតា ឥឡូវនេះ ព្រះអរហន្ត ឬអ្នកសម្រេចអរ-ហត្តមគ្គ មាននៅក្នុងលោកឬ ។ គ្រានោះ ទេវតាប្រាប់ពាហិយៈនោះថា ពាហិយៈ នគរឈ្មោះសាវត្ថី មាននៅក្នុងជនបទទិសឧត្តរ ឥឡូវនេះ ព្រះដ៏មានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធនោះ ប្រថាប់នៅក្នុងព្រះនគរនោះ ពាហិយៈ ព្រះដ៏មានព្រះភាគអង្គនោះ ជាព្រះអរហន្តផង ទ្រង់សម្តែងធម៌ដើម្បីភាពជាព្រះអរហន្តផង ។

ពាហិយៈស្តាប់ពាក្យរបស់ទេវតាក្នុងចំណែករាត្រីហើយ មានចិត្តសង្វេគក្នុងរំពេចនោះឯង ចេញអំពីកំពង់សុប្បារកៈ ទៅដល់ក្រុងសាវត្ថី ដោយការស្នាក់នៅមួយរាត្រី គាត់បានធ្វើដំណើរប្រមាណ ១២០ យោជន៍ ដោយការស្នាក់នៅមួយរាត្រីប៉ុណ្ណោះ កាលទៅ ទៅហើយដោយអានុភាពរបស់ទេវតា អាចារ្យពួកខ្លះពោលថា ទៅដោយអានុភាពរបស់ព្រះសម្ពុទ្ធក៏មាន ។

ក្នុងខណៈនោះ ព្រះសាស្តាយាងទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត ពាហិយៈនោះ សួរភិក្ខុទាំងឡាយដែលឆាន់អាហារព្រឹកហើយ ដើរចង្ក្រមក្នុងទីវាល ដើម្បីដោះនូវភាពធ្ងន់នៃកាយ ដោយពាក្យថា ឥឡូវនេះ ព្រះសាស្តាប្រថាប់នៅក្នុងទីណា ។ ភិក្ខុទាំងឡាយក៏ឆ្លើយថា យាងចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត ហើយសួរបុរសនោះថា អ្នកមកអំពីណា ទារុចិរិយៈពោលថា ខ្ញុំមកអំពីកំពង់សុប្បារកៈ ភិក្ខុទាំងឡាយពោលថា អ្នកចេញមកក្នុងកាលណា ទារុចិរិយៈពោលថា ខ្ញុំចេញមកក្នុងពេលល្ងាចម្សិលមិញនេះ ភិក្ខុទាំងឡាយពោលថា អ្នកមកអំពីទីឆ្ងាយ ចូរអ្នកអង្គុយសិនចុះ លាងជើងហើយ លាប

ដោយប្រេង ចូរសម្រាកឲ្យបាត់នឿយហត់សិនចុះ អ្នកនឹងឃើញព្រះសាស្តា ក្នុងកាលដែលទ្រង់យាងមក ទារុចីរិយៈពោលថា បពិត្រលោកម្ចាស់ ខ្ញុំមិនដឹងអន្តរាយនៃជីវិតរបស់ព្រះសាស្តា ឬជីវិតរបស់ខ្ញុំ ខ្ញុំមិនបានឈប់ មិនបានអង្គុយក្នុងទីណា ដើរមកអស់ផ្លូវ ១២០ យោជន៍ មួយយប់ប៉ុណ្ណោះ ទាល់តែខ្ញុំឃើញព្រះសាស្តាហើយ ទើបសម្រាក ។

ពាហិយៈនោះ ពោលយ៉ាងនោះហើយ មានអាកប្បកិរិយារួសរាន់ចូលទៅកាន់ក្រុងសាវត្ថី ឃើញព្រះដ៏មានព្រះភាគកំពុងត្រាច់បិណ្ឌបាត ដោយពុទ្ធសិរីប្រៀបមិនបាន គិតថា យូរហើយហ្ន៎ អញឃើញព្រះគោតមសម្មាសម្ពុទ្ធ ដូច្នេះហើយ ក៏បន្ទន់ខ្លួនដើរចូលទៅតាំងអំពីទីដែលខ្លួនឃើញ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋានក្នុងរវាងផ្លូវ ចាប់ត្រង់កព្រះបាទទាំងគូ ហើយក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គ សូមទ្រង់សម្តែងធម៌ដល់ខ្ញុំព្រះអង្គ សូមព្រះសុគត ទ្រង់សម្តែងធម៌ ដែលគប្បីប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ និងសេចក្តីសុខដល់ខ្ញុំព្រះអង្គ អស់កាលយូរចុះ ។

លំដាប់នោះ ព្រះសាស្តាត្រាស់ឃាត់ថា ពាហិយៈ មិនមែនជាកាលតថាគតចូលទៅកាន់ចន្លោះផ្លូវដើម្បីបិណ្ឌបាត ។ ពាហិយៈ ស្តាប់ពុទ្ធតម្រាស់នោះហើយ ក្រាបទូលថា បពិត្រព្រះអង្គ បុគ្គលអន្ទោលទៅក្នុងសង្សារ មិនធ្លាប់បានអាហារ គឺដុំបាយឬ ខ្ញុំព្រះអង្គមិនដឹងអន្តរាយនៃជីវិតរបស់ទ្រង់ ឬរបស់ខ្ញុំព្រះអង្គឡើយ សូមទ្រង់សម្តែងធម៌ដល់ខ្ញុំព្រះអង្គចុះ ។ លើកទី ២ ព្រះសាស្តាក៏ត្រាស់ហាមហើយដូចគ្នា ។ បានឮថា ព្រះសាស្តាទ្រង់បរិវិតក្ក

យ៉ាងនេះថា ចាប់តាំងអំពីពាហិយៈឃើញតថាគតហើយ សរីរៈទាំងមូលជោរជន់ដោយបីតិមិនមានចន្លោះ ជាអ្នកមានបីតិជាកម្លាំង សូម្បីស្តាប់ធម៌ហើយក៏មិនអាចចាក់ចុះបាន បុគ្គលនេះ ចូរតាំងនៅក្នុងឧបេក្ខា គឺការមធ្យស្ថជាមុនសិន សូម្បីភាពក្រវល់ក្រវាយរបស់សត្វនេះមានកម្លាំង ព្រោះធ្វើដំណើរមកអស់ផ្លូវ ១២០ យោជន៍ ដោយមួយរាត្រីប៉ុណ្ណោះ សូម្បីការក្រវល់ក្រវាយនោះ ក៏ចូររម្ងាប់សិន ។ ព្រោះដូច្នោះ ទើបព្រះសាស្តាហាមអស់វារៈពីរដង ត្រូវគាត់អារាធនាលើកទី ៣ ប្រថាប់ឈរក្នុងរវាងផ្លូវនោះឯង ទ្រង់សម្តែងធម៌ ដោយន័យជាដើមថា ពាហិយៈ ព្រោះហេតុនោះ អ្នកគប្បីសិក្សាក្នុងសាសនានេះយ៉ាងនេះថា រូបដែលអញបានឃើញហើយ រូប ត្រឹមតែអញឃើញ ។ ពាហិយៈនោះ កំពុងស្តាប់ធម៌របស់ព្រះសាស្តានោះឯង ញ៉ាំងអាសវៈឲ្យអស់ទៅ សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា ៤ ហើយខណៈនោះឯង គាត់ទូលសូមបព្វជ្ជានឹងព្រះសាស្តា ទ្រង់ត្រាស់សួរថា បាត្រចីវររបស់អ្នកគ្រប់គ្រាន់ហើយឬ ពាហិយៈទូលតបថា មិនគ្រប់គ្រាន់ទេព្រះអង្គ ពេលនោះ ព្រះសាស្តាត្រាស់ថា បើយ៉ាងនោះ ចូរអ្នកស្វែងរកបាត្រចីវរហើយចៀសចេញទៅ ។

បានឮថា ពាហិយៈនោះធ្វើសមណធម៌អស់ ២ ម៉ឺនឆ្នាំ គិតថា ធម្មតាភិក្ខុបានបច្ច័យដោយខ្លួនហើយ មិនសម្លឹងមើលអ្នកដទៃ បរិភោគឯងប៉ុណ្ណោះទើបគួរ ដូច្នេះហើយ មិនបានធ្វើការសង្គ្រោះដោយបាត្រ ឬចីវរ សូម្បីដល់ភិក្ខុមួយរូប ។ ព្រោះដូច្នោះ ព្រះសាស្តាទ្រង់ជ្រាបថា បាត្រចីវរដែលសម្រេចដោយ

ឫទ្ធិមិនកើតឡើង ទើបមិនបានប្រទានបព្វជ្ជាដោយឯហិភិក្ខុដល់គាត់ ។ ពាហិយៈនោះ កំពុងស្វែងរកបាត្រ និងចីវរនោះឯង យក្ខិនីម្នាក់ មកដោយរូបជាមេគោកូនខ្ចី បុះត្រង់ក្លៀកខាងឆ្វេង ឲ្យដល់នូវការអស់ជីវិត ។

ព្រះសាស្តាត្រាច់បិណ្ឌបាត ធ្វើភត្តកិច្ចស្រេចហើយ យាងចេញទៅព្រមជាមួយភិក្ខុដ៏ច្រើន ទ្រង់ឃើញសរីរៈរបស់ពាហិយៈ ស្តូកស្តឹងក្នុងគំនរសំរាម ទើបទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរឈរក្បែរទ្វារផ្ទះណាមួយ យកគ្រែមកហើយ នាំសរីរៈនេះចេញអំពីក្រុងបូជាហើយ សាងព្រះស្តូប ភិក្ខុទាំងឡាយធ្វើយ៉ាងនោះហើយ កាលធ្វើហើយទៅកាន់វិហារ ចូលគាល់ព្រះសាស្តា ទូលកិច្ចដែលខ្លួនធ្វើហើយ សួរអំពីអភិសម្បរាយភពរបស់ពាហិយៈនោះ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ ត្រាស់ប្រាប់ភាពដែលពាហិយៈនោះបរិនិព្វានដល់ភិក្ខុទាំងនោះ ទ្រង់តែងតាំងក្នុងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ ពាហិយទារុចីរិយៈ ជាកំពូលជាងភិក្ខុសាវករបស់តថាគត ខាងត្រាស់ដឹងរហ័ស លំដាប់នោះ ភិក្ខុទាំងឡាយទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គទ្រង់ត្រាស់ថា ពាហិយទារុចីរិយៈសម្រេចអរហត្ត តើសម្រេចអរហត្តក្នុងកាលណា ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលដែលគេស្តាប់ធម៌របស់តថាគត ភិក្ខុទាំងឡាយទូលសួរថា តើទ្រង់ត្រាស់ធម៌ដល់ពាហិយៈពីអង្កាល់ណា ព្រះសាស្តាត្រាស់ថា តថាគតកំពុងត្រាច់បិណ្ឌបាតឈរក្នុងរវាងផ្លូវសម្តែងធម៌ដល់ពាហិយៈ ភិក្ខុទាំងឡាយពោលថា បពិត្រ

ព្រះអង្គ ធម៌ដែលទ្រង់ប្រថាប់ឈរក្នុងរវាងផ្លូវ ត្រាស់ហើយ មានប្រមាណតិចតួច តើនឹងញ៉ាំងគុណវិសេសឲ្យកើតដោយធម៌ មានប្រមាណដល់ម៉្លោះដូចម្ដេច ។

លំដាប់នោះ ព្រះសាស្ដាត្រាស់នឹងភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំរាប់ធម៌របស់តថាគតថា តិច ឬច្រើន ព្រោះថាគាថាមួយពាន់ជាអនេក ដែលមិនអាស្រ័យប្រយោជន៍ មិនប្រសើរឡើយ ចំណែកបទនៃគាថា សូម្បីមួយ អាស្រ័យប្រយោជន៍ ប្រសើរជាង ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្ដែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**សហស្សមបិ ចេ គាថា អនត្ថបទសញ្ហិតា**
**ឯកំ គាថាបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។**

បើគាថាសូម្បីមួយពាន់ ជាគាថាប្រកបដោយបទឥតប្រយោជន៍ គាថានោះ ពុំប្រសើរឡើយ អ្នកណាស្ដាប់បទនៃគាថាណាហើយ រមែងស្ងប់រម្ងាប់បាន បទនៃគាថានោះ សូម្បីតែមួយបទ ក៏ឈ្មោះថា ប្រសើរជាង ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ ពីរបទថា **ឯកំ គាថាបទំ** សេចក្ដីថា សូម្បីគាថាមួយបែបនេះថា សេចក្ដីមិនប្រមាទជាផ្លូវនៃសេចក្ដីមិនស្លាប់ ។បេ។ ជនទាំងឡាយដែលប្រមាទហើយ ទុកដូចជាមនុស្សស្លាប់ទៅហើយ ប្រសើរជាង ។ បទដ៏សេសគប្បីជ្រាបតាមន័យមុននោះឯង ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿង ព្រះធារុចីរិយត្ថេរ ចប់

# រឿង ព្រះនាងកុណ្ឌលកេសីថេរី

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងកុណ្ឌលកេសី ត្រាស់ព្រះធម្មទេសនានេះថា **យោ ច គាថា សតំ ភាសេ** ជាដើម ។

បានឮមកថា កូនស្រីសេដ្ឋីម្នាក់ក្នុងក្រុងរាជគ្រឹះ អាយុ ១៦ ឆ្នាំ មានរូបស្អាតគួរគយគន់ នារីទាំងឡាយតាំងនៅក្នុងវ័យនោះ រមែងមានការចាប់ចិត្តក្នុងបុរស ឡេះឡោះក្នុងបុរស ។ គ្រានោះ មាតាបិតាឲ្យធីតានោះនៅក្នុងបន្ទប់ដ៏មានសិរី លើផ្ទៃប្រាសាទជាន់ទី ៧ បានធ្វើទាសីម្នាក់ប៉ុណ្ណោះឲ្យជាអ្នកបម្រើ ។

គ្រានោះ ពួករាជបុរសចាប់កុលបុត្រម្នាក់ដែលធ្វើចោរកម្ម ចងស្លាបសេក វាយដោយផ្ដៅម្ដង ៤ សរសៃ ហើយនាំទៅកាន់ទីសម្រាប់ពិឃាដ កូនស្រីសេដ្ឋីបានឮសំឡេងមហាជន គិតថា នេះអ្វីហ្ន៎ ឈរសម្លឹងមើលលើផ្ទៃប្រាសាទ ឃើញចោរនោះហើយ មានចិត្តប្រតិព័ទ្ធ ហាមអាហារហើយដេកលើគ្រែ ។ លំដាប់នោះ មាតាសួរនាងថា នែនាង តើនាងកើតអ្វី ធីតាសេដ្ឋីពោលថា

បើខ្ញុំបានបុរសដែលគេចាប់នាំទៅថាជាចោរនោះសោត ខ្ញុំនឹងរស់នៅ បើមិនបាន ជីវិតខ្ញុំក៏មិនមាន ខ្ញុំនឹងស្លាប់ក្នុងទីនេះឯង ។ មាតាពោលថា នែនាង នាងកុំធ្វើយ៉ាងនេះឡើយ នាងនឹងបានប្តីដទៃដែលស្មើគ្នាដោយជាតិ និងភោគៈរបស់យើង ធីតាសេដ្ឋីពោលថា កិច្ចដោយបុរសដទៃសម្រាប់ខ្ញុំមិនមាន បើខ្ញុំមិនបានបុរសនេះ ខ្ញុំនឹងស្លាប់ ។

មាតា កាលមិនអាចញ៉ាំងធីតាឲ្យយល់ព្រមបាន ទើបប្រាប់ដល់បិតា សូម្បីបិតានោះក៏មិនអាចញ៉ាំងធីតានោះឲ្យយល់ព្រមបាន គិតថា យើងអាចធ្វើអ្វីបាន បញ្ជូនកញ្ចប់កហាបណៈមួយពាន់ដល់រាជបុរស ដែលចាប់ចោរនោះហើយដើរទៅដោយពាក្យថា ចូរអ្នកទទួលកហាបណៈនេះហើយ ឲ្យបុរសនោះដល់ខ្ញុំ ។ រាជបុរសនោះទទួលថា សាធុ ហើយទទួលកហាបណៈ លែងចោរនោះទៅ សម្លាប់បុរសដទៃហើយ ក្រាបទូលដល់ព្រះរាជាថា បពិត្រព្រះអង្គ ទូលបង្គំសម្លាប់ចោរហើយ ។

សេដ្ឋីបានឲ្យធីតាដល់ចោរនោះហើយ នាងគិតថា នឹងញ៉ាំងស្វាមីឲ្យត្រេកអរ ទើបតាក់តែងគ្រឿងអលង្ការទាំងពួង រៀបចំយាគូជាដើមដល់ចោរនោះឯង ។

ក្នុងកាលកន្លងទៅបាន ២-៣ ថ្ងៃ ចោរគិតថា ក្នុងកាលណាហ្ន៎ អញនឹងបានសម្លាប់ស្រីនេះ កាន់យកគ្រឿងអលង្ការរបស់ស្រីនេះ ស៊ីផឹកក្នុងរោងសុរាមួយ ចោរនោះគិតថា ឧបាយនេះមាន ទើបហាមអាហារ ហើយដេកលើគ្រែ ពេលនោះ ធីតាសេដ្ឋីចូលទៅរកចោរនោះហើយ សួរថា នែអ្នក អ្វី

ចាក់ដោតអ្នកឬ ចោរពោលថា អ្វីមិនបានចាក់ដោតខ្ញុំទេ ធីតាសេដ្ឋីពោលថា មាតាបិតារបស់ខ្ញុំខឹងក្រោធនឹងអ្នកឬ ចោរពោលថា មិនខឹងក្រោធទេ ធីតាសេដ្ឋីពោលថា បើដូច្នោះ តើអ្នកកើតអ្វី ចោរពោលថា នែនាង ខ្ញុំត្រូវចាប់នាំទៅក្នុងថ្ងៃនោះ ខ្ញុំបានបន់ស្រន់ទេវតា ដែលស្ថិតនៅត្រង់ភ្នំទម្លាក់ចោរ បាននូវជីវិតហើយ សូម្បីនាង ខ្ញុំក៏បានដោយអានុភាពនៃទេវតានោះដូចគ្នា នែនាង ខ្ញុំគិតថា នឹងធ្វើពលីកម្មនោះចំពោះទេវតា ។ ធីតាសេដ្ឋីពោលថា នែអ្នក អ្នកកុំគិតថ្វីឡើយ ខ្ញុំនឹងធ្វើពលីកម្ម សូមអ្នកប្រាប់ តើត្រូវការអ្វីខ្លះ ចោរពោលថា ត្រូវធ្វើមធុបាយាស ដែលមានទឹកតិច និងផ្កាមានលាជជាគម្រប់ ៥ ។ ធីតាសេដ្ឋីពោលថា សាធុ ខ្ញុំនឹងរៀបចំ ។

ធីតាសេដ្ឋីនោះរៀបចំពលីកម្មគ្រប់យ៉ាងហើយ ទើបពោលថា មកចុះអ្នក យើងនឹងទៅទាំងអស់គ្នា ។ ចោរពោលថា នែនាង បើដូច្នោះ សូមនាងឲ្យពួកញាតិត្រឡប់ចុះ កាន់យកសំពត់និងគ្រឿងអលង្ការដែលមានតម្លៃច្រើនហើយតែងខ្លួន យើងនឹងសើចលេងបណ្តើរ ដើរទៅបណ្តើរយ៉ាងសប្បាយ ។

នាងបានធ្វើយ៉ាងនោះហើយ ។ ពេលនោះ ក្នុងវេលាដល់ជើងភ្នំ ចោរនោះពោលនឹងនាងថា នែនាង ខាងមុខអំពីនេះ យើងនឹងទៅពីរនាក់ ចូរនាងឲ្យមនុស្សដ៏សេសត្រឡប់ មួយអន្លើដោយយាន លើកកាជនៈពលីកម្មដើរទៅឯង នាងបានធ្វើយ៉ាងនោះ ចោរនាំនាងឡើងកាន់ភ្នំសម្រាប់ទម្លាក់ចោរ ។

មនុស្សទាំងឡាយ ឡើងទៅក្នុងចំណែកម្ខាងនៃភ្នំនោះ ចំណែកម្ខាងទៀតជាជ្រោះ មនុស្សទាំងឡាយឈរលើកំពូលភ្នំហើយ រមែងទម្លាក់ចោរទាំងឡាយ

ក្នុងទីម្នាងនោះ ចោរទាំងនោះដាច់ជាកំណាត់តូចធំ ធ្លាក់ទៅត្រង់ផែនដី ព្រោះដូច្នោះ ទើបគេហៅថា ភ្នំចោលចោរ ។ នាងឈរលើកំពូលភ្នំនោះ ពោលថា នែអ្នក សូមអ្នកធ្វើពលីកម្មរបស់អ្នក ចោរនោះបាននៅស្ងៀមហើយ ។ កាលនាងពោលទៀតថា នែអ្នក ហេតុអ្វី ទើបអ្នកនៅស្ងៀម ក៏ប្រាប់ថា ខ្ញុំមិនត្រូវការពលីកម្មទេ តែខ្ញុំបោកបញ្ឆោតដើម្បីនាំនាងមក ធីតាសេដ្ឋីពោលថា ព្រោះហេតុអ្វី ចោរពោលថា ដើម្បីសម្លាប់នាង ហើយកាន់យកគ្រឿងអលង្ការរបស់នាង គេចទៅ ។

នាងត្រូវមរណភ័យគំរាមហើយ ពោលថា នែអ្នក ខ្ញុំក្តី គ្រឿងអលង្ការក្តី ជារបស់អ្នកប៉ុណ្ណោះ ហេតុអ្វី ទើបអ្នកពោលយ៉ាងនេះ ចោរនោះត្រូវនាងអង្វររឿយៗ ថា សូមអ្នកកុំធ្វើយ៉ាងនេះ ក៏ពោលថា ខ្ញុំនឹងសម្លាប់ឲ្យបាន នាងពោលថា បើដូច្នោះ អ្នកត្រូវការអ្វីដោយការស្លាប់របស់ខ្ញុំ អ្នកកាន់យកគ្រឿងអលង្ការទាំងនេះ ហើយឲ្យជីវិតដល់ខ្ញុំចុះ ចាប់តាំងអំពីនេះ អ្នកចូរចាំខ្ញុំថា ស្លាប់ហើយ ឬថា ទុកខ្ញុំជាទាសីរបស់អ្នកធ្វើហត្ថកម្ម ដូច្នេះហើយ ពោលគាថានេះថា

ខ្សែមាសទាំងនេះ សុទ្ធតែសម្រេចដោយកែវពិទូរ្យ នែអ្នក សូមអ្នកកាន់យកទាំងអស់ ហើយចូរប្រកាសថា ខ្ញុំជាទាសីចុះ ។

ចោរស្តាប់ពាក្យនោះហើយ ពោលថា បើយើងធ្វើយ៉ាងនោះ នាងទៅហើយ នឹងប្រាប់ដល់ឪពុកម្តាយឲ្យសម្លាប់យើងបាន នាងកុំសោយសោកឡើយ ដូច្នេះហើយ ពោលគាថាថា

នាងកុំសោយសោកឡើយ ចូរប្រញាប់ខ្ចប់របស់របរចុះ ជីវិតរបស់នាងមិនមានទេ យើងនឹងកាន់យករបស់ទាំងអស់នេះ ។

នាងគិតថា ឱ ! កម្មនេះធ្ងន់ ឈ្មោះថា បញ្ញា ជាធម្មតាមិនមែនសាងមក ទុកស្ងួស៊ីឡើយ ដែលពិត សាងមកដើម្បីប្រយោជន៍ពិចារណា អញនឹងដឹងវត្ថុដែលគួរធ្វើដល់ចោរនេះ ។

លំដាប់នោះ នាងពោលនឹងចោរនោះថា នៃអ្នក អ្នកត្រូវចាប់នាំទៅថាជាចោរក្នុងកាលណា ក្នុងកាលនោះ ខ្ញុំប្រាប់ដល់ឪពុកម្តាយ លោកទាំងពីរលះទ្រព្យមួយពាន់ឲ្យនាំអ្នកមក ចាប់តាំងអំពីនោះ ខ្ញុំក៏ឧបការៈអ្នក ថ្ងៃនេះសូមអ្នកឲ្យខ្ញុំធ្វើខ្ទនអ្នកឲ្យឃើញច្បាស់ ហើយថ្វាយបង្គំ ។

ចោរនោះពោលថា សាធុ ចូរនាងធ្វើខ្ទនខ្ញុំឲ្យឃើញច្បាស់ ហើយថ្វាយបង្គំចុះ ដូច្នេះហើយ ក៏ឈរលើកំពូលភ្នំ ពេលនោះ នាងធ្វើប្រទក្សិណ ៣ ជុំថ្វាយបង្គំចោរនោះក្នុងទី ៤ ស្ថាន ហើយពោលថា នៃអ្នក នេះជាការឃើញចុងក្រោយរបស់ខ្ញុំ ឥឡូវនេះ ការដែលអ្នកឃើញខ្ញុំ ឬការដែលខ្ញុំឃើញអ្នកមិនមានឡើយ ហើយឱបខាងមុខ ខាងក្រោយ ឈរអំពីខាងខ្នង យកដៃម្ខាងចាប់ចោរដែលជាអ្នកប្រមាទ ឈរលើកំពូលភ្នំត្រង់ក យកដៃម្ខាងចាប់ត្រង់ក្លៀកខាងក្រោយ ប្រានចោរទម្លាក់ទៅក្នុងជ្រោះ ចោរនោះត្រូវប៉ះទង្គិចត្រង់ថ្មភ្នំ ដាច់ជាចម្រៀកតូចធំ ធ្លាក់ចុះទៅហើយ ត្រង់ផែនដី ។

ទេវតាដែលស្ថិតនៅលើកំពូលភ្នំជាទីទម្លាក់ចោរ ឃើញកិរិយារបស់ជនទាំងពីរនោះ ទើបឲ្យសាធុការដល់ស្រីនោះ ហើយពោលគាថានេះថា

បុរសនោះ ជាបណ្ឌិតក្នុងទីគ្រប់ស្ថាន ក៏មិនមែន សូម្បីស្ត្រីជាអ្នកមានបញ្ញា ឃើញប្រចក្ស ក៏ជាបណ្ឌិតបានក្នុងទីនោះៗ ។

ធីតាសេដ្ឋីនោះ កាលប្រានចោរធ្លាក់ទៅក្នុងជ្រោះហើយ គិតថា បើអញទៅផ្ទះ ឪពុកម្តាយនឹងសួរថា ប្តីរបស់នាងទៅណា បើអញត្រូវសួរយ៉ាងនោះ នឹងឆ្លើយថា ខ្ញុំសម្លាប់ហើយ លោកនឹងចាក់ដោតអញដោយលំពែង គឺមាត់ថា កូនក្បាលរឹង នាងឲ្យទ្រព្យមួយពាន់ ឲ្យនាំប្តីមក ឥឡូវនេះ ក៏សម្លាប់គេចោល កាលអញប្រាប់ថា ចោរនោះប្រាថ្នានឹងសម្លាប់ខ្ញុំ ដើម្បីគ្រឿងអលង្ការ លោកក៏មិនជឿ ណ្ហើយចុះ មានប្រយោជន៍អ្វីដោយផ្ទះរបស់អញ ដូច្នេះហើយ បោះគ្រឿងអលង្ការចោលក្នុងទីនោះឯង ចូលទៅកាន់ព្រៃត្រាច់ទៅដោយលំដាប់ ដល់អាស្រមរបស់ពួកបរិព្វាជកមួយកន្លែង ថ្វាយបង្គំហើយ ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទាំងឡាយ ឲ្យខ្ញុំបព្វជ្ជាក្នុងសម្នាក់របស់លោកម្ចាស់ផងចុះ លំដាប់នោះ បរិព្វាជកទាំងឡាយ ឲ្យនាងបព្វជ្ជាហើយ ។

ធីតាសេដ្ឋីនោះ បួសហើយសួរថា បពិត្រលោកម្ចាស់ អ្វីជាទីបំផុតនៃបព្វជ្ជារបស់លោកម្ចាស់ បរិព្វាជកពោលថា នៃនាង បុគ្គលធ្វើបរិកម្មក្នុងកសិណ ១០ ហើយ គប្បីញុំាងឈានឲ្យកើតខ្លះ គប្បីរៀនវាទៈមួយពាន់ខ្លះ នេះជាប្រយោជន៍ដ៏ឧត្តមនៃបព្វជ្ជារបស់ពួកយើង ធីតាសេដ្ឋីពោលថា ខ្ញុំមិនអាចញុំាងឈានឲ្យកើតឡើងបាន តែនឹងរៀនវាទៈមួយពាន់ ។ គ្រានោះ បរិព្វាជកទាំងនោះ ញុំាងនាងឲ្យរៀននូវវាទៈមួយពាន់ហើយ ពោលថា សិប្បៈ នាងរៀនហើយ ឥឡូវនេះ ចូរនាងត្រាច់ទៅលើផ្ទៃជម្ពូទ្វីប ពិនិត្យមើលបុគ្គលណា

អាចពោលបញ្ហាជាមួយនាង ហើយឲ្យមែកព្រីងក្នុងដៃដល់នាង បញ្ជូនទៅថា ទៅចុះនាង បើបុគ្គលណាជាគ្រហស្ថ អាចពោលបញ្ហាជាមួយនាងបាន នាងចូរជាបាទបរិចារិការបស់បុគ្គលនោះឯង បើជាបព្វជិត ចូរនាងបួសក្នុងសម្នាក់បុគ្គលនោះចុះ ។ នាងមានឈ្មោះថា ជម្ពុបរិព្វាជិកា តាមឈ្មោះឈើ ចេញអំពីទីនោះ ត្រាច់សួរបញ្ហានឹងអ្នកដែលខ្លួនជួបប្រទះហើយ ជនដែលឈ្មោះថាអាចឆ្លើយនឹងនាងបាន មិនមានឡើយ ។ មនុស្សទាំងឡាយគ្រាន់តែឮថា នាងជម្ពុបរិព្វាជិកាមកក្នុងទីនេះ រមែងគេចទៅ ។ នាងចូលទៅកាន់ស្រុក ឬតំបន់ដើម្បីភិក្ខា គរដីខ្សាច់ជាពំនូក ត្រង់ទ្វារស្រុក ដោតមែកព្រីងលើគំនរខ្សាច់នោះ ពោលថា អ្នកណាអាចពោលជាមួយខ្ញុំ ចូរជាន់មែកព្រីងចុះ ហើយក៏ចូលទៅកាន់ស្រុក ។ បុគ្គលណាម្នាក់ ឈ្មោះថា ចូលទៅកាន់ទីនោះមិនមានសូម្បីនាងកាន់មែកឈើដទៃ ក្នុងកាលមែកព្រីងចាស់ក្រៀមស្វិត ។ ត្រាច់ទៅដោយទំនងនេះដល់ក្រុងសាវត្ថី ដោតមែកព្រីងក្បែរទ្វារស្រុក ពោលដោយន័យដូចពោលមកហើយនោះ ចូលទៅដើម្បីភិក្ខា ក្មេងជាច្រើន បានឈរចោមរោមមែកឈើហើយ ។

ក្នុងកាលនោះ ព្រះសារីបុត្តត្រាច់ទៅដើម្បីបិណ្ឌបាត ធ្វើភត្តកិច្ចហើយ ចេញទៅអំពីក្រុង ឃើញក្មេងទាំងនោះចោមរោមមែកព្រីងទើបសួរថា នេះជាអ្វី ក្មេងទាំងឡាយប្រាប់រឿងនោះដល់ព្រះថេរៈហើយ ។ ព្រះថេរៈពោលថា នែកុមារទាំងឡាយ បើយ៉ាងនោះពួកអ្នកចូរជាន់មែកព្រីងនេះ កុមារទទួលថា បពិត្រលោកម្ចាស់ ពួកខ្ញុំខ្លាច ព្រះថេរៈពោលថា អាត្មានឹងពោលបញ្ហា ចូរ

ពួកអ្នកជាន់ចុះ ។ ក្មេងទាំងនោះ កើតឧស្សាហ៍ដោយពាក្យរបស់ព្រះថេរៈ ធ្វើយ៉ាងនោះ ស្រែកហ៊ោ បាចធូលីឡើងហើយ ។

បរិព្វាជិកាមកហើយ សម្លុតក្មេងទាំងនោះ ពោលថា កិច្ចដោយបញ្ហារបស់យើងនឹងពួកអ្នកមិនមាន ហេតុអ្វី ទើបពួកអ្នកនាំគ្នាជាន់មែកឈើរបស់យើង កុមារទាំងឡាយពោលថា ពួកខ្ញុំត្រូវលោកម្ចាស់ឲ្យជាន់ បរិព្វាជិកាពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់ឲ្យពួកក្មេងជាន់មែកឈើរបស់ខ្ញុំឬ ព្រះថេរៈពោលថា អើ ប្អូនស្រី បរិព្វាជិកាពោលថា បើយ៉ាងនោះ លោកម្ចាស់ពោលបញ្ហាជាមួយខ្ញុំ ព្រះថេរៈពោលថា សាធុ អាត្មានឹងពោល ។

បរិព្វាជិកានោះ បានទៅកាន់សម្នាក់របស់ព្រះថេរៈ ដើម្បីសួរបញ្ហាក្នុងវេលាម្លប់ឈើមិនចម្រើន គឺពេលរសៀល ។ មនុស្សក្នុងក្រុងតោឡោថា ពួកយើងនឹងស្តាប់វាទៈ របស់បណ្ឌិតទាំងពីរ ។ ពួកអ្នកក្រុងបានទៅជាមួយនឹងបរិព្វាជិកានោះដូចគ្នា ថ្វាយបង្គំព្រះថេរៈហើយ បានអង្គុយក្នុងចំណែកម្ខាង ។

បរិព្វាជិកាពោលនឹងព្រះថេរៈថា បពិត្រលោកម្ចាស់ ខ្ញុំនឹងសួរបញ្ហាជាមួយលោកម្ចាស់ ព្រះថេរៈពោលថា សួរចុះប្អូនស្រី ។

នាងសួរវាទៈមួយពាន់ហើយ ព្រះថេរៈឆ្លើយបញ្ហាដែលនាងសួរហើយលំដាប់នោះ ព្រះថេរៈពោលនឹងនាងថា បញ្ហារបស់នាងមានប៉ុណ្ណេះ បញ្ហាដទៃមានទៀតឬ បរិព្វាជិកាពោលថា បពិត្រលោកម្ចាស់ មានប៉ុណ្ណេះឯង ព្រះថេរៈពោលថា នាងសួរបញ្ហាជាច្រើន អាត្មានឹងសួរបញ្ហាត្រឹមតែមួយ នាងឆ្លើយបានដែរឬទេ បរិព្វាជិកាពោលថា បើខ្ញុំដឹង ខ្ញុំនឹងឆ្លើយ សូមលោកម្ចាស់សួរ

ចុះ ព្រះថេរៈសួរបញ្ហាថា អ្វីមានតែមួយ បរិព្វាជិកានោះ មិនដឹងថា បញ្ហានេះ គួរឆ្លើយយ៉ាងនេះ ទើបសួរថា តើនុ៎ះជាអ្វីលោកម្ចាស់ ព្រះថេរៈពោលថា ម្នាលប្អូនស្រី នុ៎ះឈ្មោះថា ពុទ្ធមន្ត បរិព្វាជិកាពោលថា សូមលោកម្ចាស់ឲ្យពុទ្ធមន្តនោះដល់ខ្ញុំខ្លះ ព្រះថេរៈពោលថា បើនាងដូចអាត្មា អាត្មានឹងឲ្យ បរិព្វាជិកាពោលថា បើដូច្នោះ សូមលោកម្ចាស់ញ៉ាំងខ្ញុំឲ្យបព្វជ្ជាចុះ ។

ព្រះថេរៈ ប្រាប់ដល់ភិក្ខុនីទាំងឡាយឲ្យបព្វជ្ជាហើយ នាងកាលបាននូវបព្វជ្ជាឧបសម្បទាហើយ មានឈ្មោះថាកុណ្ឌលកេសីថេរី សម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទាទាំងឡាយ ក្នុងកាល ២-៣ ថ្ងៃប៉ុណ្ណោះ ។

ភិក្ខុទាំងឡាយ សន្ទនាគ្នាក្នុងរោងធម្មសភាថា ការស្តាប់ធម៌របស់នាងកុណ្ឌលកេសីថេរីមិនច្រើន កិច្ចនៃបព្វជិតរបស់នាងដល់ទីបំផុតហើយ បានឮថា នាងធ្វើមហាសង្គ្រាមជាមួយចោរម្នាក់ឈ្នះហើយមក ។

ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយកថាដូចម្តេច កាលភិក្ខុទាំងឡាយនោះក្រាបទូលថា ពាក្យសម្តីឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកកុំរាប់ធម៌ដែលតថាគតសម្តែងហើយថា តិច ឬច្រើន បទដែលមិនជាប្រយោជន៍មួយរយបទ មិនប្រសើរឡើយ ចំណែកបទនៃធម៌ សូម្បីតែមួយបទ ប្រសើរជាង ម្យ៉ាងទៀត កាលបុគ្គលឈ្នះចោរដ៏សេស មិនឈ្មោះថាឈ្នះឡើយ ចំណែកបុគ្គលឈ្នះចោរ គឺកិលេសដែលប្រព្រឹត្តទៅខាងក្នុងនោះឯង ទើបឈ្មោះថា ឈ្នះ កាលទ្រង់បន្តអនុសន្ធិ ទើបត្រាស់ព្រះគាថាទាំងនេះ

**យោ ច គាថាសតំ ភាសេ អនត្ថបទសញ្ហិតា**
**ឯកំ ធម្មបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។**
**យោ សហស្សំ សហស្សេន សង្គាមេ មានុសេ ជិនេ**
**ឯកញ្ច ជេយ្យមត្តានំ ស វេ សង្គាមជុត្តមោ ។**

*អ្នកណា គប្បីពោលគាថាមួយរយ ជាគាថាប្រកបដោយបទឥតប្រយោជន៍ គាថាដែលអ្នកនោះពោលហើយ ពុំប្រសើរឡើយ អ្នកណាស្តាប់បទនៃធម៌ហើយ រមែងស្ងប់រម្ងាប់បាន បទនៃធម៌នោះសូម្បីតែមួយបទ ក៏ឈ្មោះថា ប្រសើរជាង ។ អ្នកណា គប្បីឈ្នះពួកមនុស្សក្នុងសង្គ្រាម អស់មួយពាន់ៗដង គឺមួយលាន ចំណែកអ្នកណា ឈ្នះខ្លួនឯងម្នាក់ឯងបាន អ្នកនោះ ឈ្មោះថា ជាមនុស្សខ្ពង់ខ្ពស់ជាងអ្នកដែលឈ្នះក្នុងសង្គ្រាមនោះ ។*

## សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ ពីរបទថា* **គាថាសតំ** *សេចក្តីថា បុគ្គលណាគប្បីពោលគាថាមួយរយ គឺច្រើនគាថា ។ បាទព្រះគាថាថា* **អនត្ថបទសញ្ហិតា** *សេចក្តីថា ប្រកបដោយបទទាំងឡាយដែលមិនមានប្រយោជន៍ ដោយអំណាចពណ៌នាអាកាសជាដើម ។*

*បទដែលបដិសំយុត្តដោយធម៌ មានខន្ធជាដើម សម្រេចប្រយោជន៍ ឈ្មោះថា បទធម៌ ។ បណ្តាធម៌ ៤ ដែលព្រះសាស្តាត្រាស់យ៉ាងនេះថា បរិព្វាជកទាំងឡាយ បទធម៌មាន ៤ បទធម៌ ៤ គឺអ្វីខ្លះ បរិព្វាជកទាំងឡាយ*

បទធម៌ គឺការមិនសម្ងឹង បទធម៌ គឺការមិនប្រទូស្ត បទធម៌ គឺការរឭកត្រូវ បទធម៌ គឺការតាំងចិត្តប្រពៃ បទធម៌ សូម្បីតែមួយប្រសើរជាង ។

បាទព្រះគាថាថា **យោ សហស្សំ សហស្សេន** សេចក្តីថា បុគ្គលណា គឺអ្នកច្បាំងក្នុងសង្គ្រាម គប្បីឈ្នះមនុស្សមួយពាន់ៗ ដង ក្នុងសង្គ្រាមម្តង បានដល់ ឈ្នះមនុស្ស ១០ សែន ហើយនាំជ័យជម្នះមក បុគ្គលនេះ មិនឈ្មោះថា ជាកំពូលនៃជនទាំងឡាយ ដែលឈ្នះក្នុងសង្គ្រាមឡើយ ។

បាទព្រះគាថាថា **ឯកញ្ច ជេយ្យមត្តានំ** សេចក្តីថា ចំណែកបុគ្គលណា ពិចារណាកម្មដ្ឋាន ដែលប្រព្រឹត្តទៅខាងក្នុង ក្នុងទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃ គប្បីឈ្នះខ្លួនដោយការឈ្នះកិលេស មានលោភៈជាដើមរបស់ខ្លួនបាន ។

បាទព្រះគាថាថា **ស វេ សង្គាមជុត្តមោ** សេចក្តីថា បុគ្គលនោះ ឈ្មោះថា ជាកំពូល គឺប្រសើរនៃជនទាំងឡាយដែលឈ្នះក្នុងសង្គ្រាម បានដល់ ជាអ្នកចម្បាំងដ៏កំពូល ក្នុងសង្គ្រាម ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។ល។

**រឿងកុណ្ឌលកេសីថេរី ចប់**

# រឿង អនត្ថបុច្ឆកព្រាហ្មណ៍

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអនត្ថបុច្ឆកព្រាហ្មណ៍ ត្រាស់ព្រះគាថានេះថា **អត្ថា ហាវេ** ជាដើម ។

បានឮថា ព្រាហ្មណ៍នោះគិតថា ព្រះសម្មាសម្ពុទ្ធ ទ្រង់ជ្រាបវត្ថុដែលជាប្រយោជន៍តែម្យ៉ាងឬហ្ន៎ ឬទ្រង់ជ្រាបវត្ថុដែលមិនជាប្រយោជន៍ដែរ អញនឹងទូលសួរទ្រង់ ដូច្នេះហើយ ទើបចូលទៅគាល់ព្រះសាស្តា ទូលសួរថា បពិត្រព្រះអង្គ ទ្រង់ឃើញ ទ្រង់ជ្រាបវត្ថុដែលជាប្រយោជន៍តែម្យ៉ាង មិនជ្រាបវត្ថុដែលមិនមែនប្រយោជន៍ទេឬ ព្រះសាស្តាត្រាស់ថា ម្នាលព្រាហ្មណ៍ តថាគតដឹងវត្ថុដែលជាប្រយោជន៍ផង វត្ថុដែលមិនជាប្រយោជន៍ផង ។ ព្រាហ្មណ៍ពោលថា បើយ៉ាងនោះ សូមទ្រង់ត្រាស់ប្រាប់វត្ថុដែលមិនជាប្រយោជន៍ដល់ខ្ញុំព្រះអង្គចុះ ។ លំដាប់នោះ ព្រះសាស្តាត្រាស់ព្រះគាថានេះ ដល់ព្រាហ្មណ៍នោះថា

ការដេករហូតដល់ថ្ងៃរះ ការខ្ជិលច្រអូស ការកាច ការពន្យាពេល
ការធ្វើដំណើរឆ្ងាយរបស់បុគ្គលម្នាក់ឯង ការចូលទៅសេពកិរិយា
របស់អ្នកដទៃ ម្នាលព្រាហ្មណ៍ អ្នកចូរសេពកម្ម ៦ យ៉ាងនេះចុះ
វត្ថុមិនមែនជាប្រយោជន៍ នឹងមានដល់អ្នក ។

ព្រាហ្មណ៍ស្តាប់ព្រះពុទ្ធតម្រាស់នោះហើយ បានឲ្យសាធុការថា សាធុ សាធុ ទ្រង់ជាអាចារ្យរបស់គណៈ ទ្រង់ជាធំក្នុងគណៈ ទ្រង់រមែងជ្រាបវត្ថុដែល

ជាប្រយោជន៍ផង វត្ថុដែលមិនជាប្រយោជន៍ផង ។

ព្រះសាស្តាត្រាស់ថា ម្នាលព្រាហ្មណ៍ យ៉ាងនោះឯង ឈ្មោះថា បុគ្គលដឹងវត្ថុដែលជាប្រយោជន៍ និងវត្ថុមិនជាប្រយោជន៍ដូចតថាគតរមែងមិនមាន ។

លំដាប់នោះ ព្រះសាស្តាទ្រង់ប្រមើលមើលអធ្យាស្រ័យរបស់ព្រាហ្មណ៍នោះហើយ ទើបត្រាស់សួរថា ម្នាលព្រាហ្មណ៍ អ្នករស់នៅចិញ្ចឹមជីវិតដោយការងារអ្វី ព្រាហ្មណ៍ទូលថា បពិត្រព្រះគោតម ដោយការងារ គឺលេងបាស្កា ព្រះសាស្តាត្រាស់ថា អ្នកឈ្នះ ឬចាញ់ ។ កាលព្រាហ្មណ៍នោះទូលថា ឈ្នះខ្លះ ចាញ់ខ្លះ ដូច្នេះហើយ ទើបទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ នុ៎ះនៅមានប្រមាណតិច ឈ្មោះថា ការឈ្នះរបស់បុគ្គលដែលឈ្នះអ្នកដទៃ មិនប្រសើរឡើយ ចំណែកបុគ្គលណាឈ្នះខ្លួនបាន ដោយឈ្នះកិលេស ការឈ្នះរបស់បុគ្គលនោះប្រសើរ ព្រោះថាបុគ្គលណាម្នាក់មិនអាចធ្វើជ័យជម្នះនោះ ឲ្យត្រឡប់ចាញ់បាន កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថាទាំងនេះថា

**អត្តា ហវេ ជិតំ សេយ្យោ　　យា ចាយំ ឥតរា បជា**
**អត្តទន្តស្ស បោសស្ស　　និច្ចំ សញ្ញតចារិនោ ។**
**នេវ ទេវោ ន គន្ធព្វោ　　ន មារោ សហ ព្រហ្មុនា**
**ជិតំ អបជិតំ កយិរា　　តថារូបស្ស ជន្តុនោ ។**

ខ្លួនឯងដែលឈ្នះហើយប្រសើរជាង ចំណែកពួកសត្វក្រៅពីនេះ ដែលគេឈ្នះហើយ មិនប្រសើរឡើយ កាលបើបុរសមានខ្លួនទូន្មានហើយ ជាអ្នកប្រព្រឹត្តសង្រួមជានិច្ច ទេវតា

គន្ធព្វ មារ ព្រមទាំងព្រហ្ម មិនគប្បីធ្វើនូវជម្នះរបស់សត្វ
មានសភាពដូច្នោះ ឲ្យត្រឡប់ចាញ់វិញបានឡើយ ។

## សេចក្ដីអធិប្បាយ

ក្នុងព្រះគាថានោះ សព្ទថា **ហវេ** ត្រឹមតែជានិបាត ។

សព្ទថា **ជិតំ** ជាលិង្គវិបល្លាស សេចក្ដីថា ខ្លួនដែលបុគ្គលឈ្នះហើយ ដោយការឈ្នះកិលេសរបស់ខ្លួន ប្រសើរ ។

បាទព្រះគាថាថា **យា ចាយំ ឥតរា បជា** សេចក្ដីថា ចំណែកពួកសត្វនេះ គឺសត្វដ៏សេស គប្បីជាបុគ្គលដែលគេឈ្នះដោយការលេងបាស្កាក្ដី ដោយការធបោកទ្រព្យក្ដី ដោយការគ្របសង្កត់ដោយកម្លាំងក្នុងសង្គ្រាមក្ដី ការឈ្នះដែលបុគ្គលឈ្នះពួកសត្វនោះ ឈ្នះហើយ មិនប្រសើរសោះឡើយ ។

សួរថា ហេតុអ្វី ការឈ្នះនោះប៉ុណ្ណោះប្រសើរ ការឈ្នះនេះមិនប្រសើរ ឆ្លើយថា ព្រោះកាលបុរសទូន្មានខ្លួនហើយ ។បេ។ របស់សត្វបែបនោះឲ្យត្រឡប់ចាញ់មិនបាន ។

ព្រះសាស្ដា ត្រាស់ពាក្យនេះថា ព្រោះថា កាលបុរស ឈ្មោះថាទូន្មានខ្លួនហើយ ព្រោះជាអ្នកដែលឥតកិលេស មិនមានកិលេសដូចទីទួល មានប្រក្រតីប្រព្រឹត្តសង្រួមតាមផ្លូវកាយជាដើមជានិច្ច ទេវតាក្ដី គន្ធព្វក្ដី មារ ព្រមទាំងព្រហ្មក្ដី សូម្បីព្យាយាមថា អញនឹងធ្វើជ័យជម្នះរបស់បុគ្គលនោះឲ្យត្រឡប់ចាញ់ នឹងធ្វើកិលេសទាំងឡាយ ដែលគេលះបានដោយមគ្គភាវនាឲ្យកើតទៀត ក៏មិនអាចធ្វើការឈ្នះរបស់សត្វនោះ គឺជាអ្នកសង្រួមហើយ

ដោយការសន្រ្ទមតាមផ្លូវកាយជាដើមនេះ ឲ្យត្រឡប់ចាញ់ ដូចអ្នកចាញ់ដោយទ្រព្យដែលជាបរបក្ខឡើយ ជ័យជម្នះដែលបុគ្គលក្រៅពីនេះឈ្នះហើយ គប្បីធ្វើឲ្យត្រឡប់ចាញ់ទៀត ដូច្នោះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

**រឿង អនត្ថបុច្ឆកព្រាហ្មណ៍ ចប់**

# រឿង ព្រាហ្មណ៍ជាអាំរបស់ព្រះសារីបុត្តត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រាហ្មណ៍ជាអាំរបស់ព្រះសារីបុត្តត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **មាសេ មាសេ** ជាដើម ។

បានឮថា ព្រះថេរៈទៅកាន់សម្នាក់របស់ព្រាហ្មណ៍នោះហើយសួរថា នែព្រាហ្មណ៍ អ្នកធ្វើកុសលណាមួយខ្លះដែរឬទេ ព្រាហ្មណ៍ឆ្លើយថា ធ្វើលោកម្ចាស់ ព្រះថេរៈសួរថា ធ្វើកុសលអ្វី ព្រាហ្មណ៍ឆ្លើយថា ខ្ញុំឲ្យទាន ដោយបរិច្ចាគទ្រព្យមួយពាន់រៀងរាល់ខែ ព្រះថេរៈសួរថា ឲ្យដល់អ្នកណា ព្រាហ្មណ៍ឆ្លើយថា ឲ្យដល់ពួកនិគ្រន្ថ លោកម្ចាស់ ព្រះថេរៈសួរថា តើអ្នកប្រាថ្នាអ្វី ព្រាហ្មណ៍ឆ្លើយថា ខ្ញុំប្រាថ្នាព្រហ្មលោក ព្រះថេរៈសួរថា នេះជាផ្លូវនៃព្រហ្មលោកឬ ព្រាហ្មណ៍ឆ្លើយថា យ៉ាងនោះឯងលោកម្ចាស់ ព្រះថេរៈសួរថា អ្នកណាពោល

យ៉ាងនេះ ព្រាហ្មណ៍ឆ្លើយថា អាចារ្យទាំងឡាយរបស់ខ្ញុំជាអ្នកពោល ។

ព្រះថេរៈពោលថា អ្នកមិនដឹងផ្លូវនៃព្រហ្មលោកឡើយ សូម្បីអាចារ្យទាំងឡាយរបស់អ្នកក៏មិនដឹង ព្រះសាស្តាមួយអង្គប៉ុណ្ណោះទ្រង់ដឹង នៃព្រាហ្មណ៍ ចូរមកចុះ អាត្មានឹងទូលអារាធនា ឲ្យទ្រង់ត្រាស់ប្រាប់ផ្លូវទៅកាន់ព្រហ្មលោកដល់អ្នក ដូច្នេះហើយ នាំព្រាហ្មណ៍នោះទៅកាន់សម្នាក់របស់ព្រះសាស្តា ក្រាបទូលរឿងនោះថា បពិត្រព្រះអង្គ ព្រាហ្មណ៍នេះពោលយ៉ាងនេះ ហើយក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់ត្រាស់ប្រាប់ផ្លូវនៃព្រហ្មលោកដល់ព្រាហ្មណ៍នេះ ។

ព្រះសាស្តាត្រាស់សួរថា ម្នាលព្រាហ្មណ៍ បានឮថា សេចក្តីនោះ យ៉ាងនេះឬ កាលព្រាហ្មណ៍នោះទូលថា បពិត្រព្រះគោតម យ៉ាងនោះឯង ទើបត្រាស់ថា ម្នាលព្រាហ្មណ៍ ការសម្លឹងមើលសាវ័ករបស់តថាគត ដោយចិត្តជ្រះថ្លា ត្រឹមតែមួយរំពេច ឬការឲ្យអាហារវត្ថុត្រឹមតែបាយមួយវែក មានផលច្រើនជាងទាន ដែលអ្នកឲ្យយ៉ាងនោះ អស់រយឆ្នាំ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**មាសេ មាសេ សហស្សេន យោ យជេថ សតំ សមំ**
**ឯកញ្ច ភាវិតត្តានំ មុហុត្តមបិ បូជយេ**
**សា យេវ បូជនា សេយ្យោ យញ្ចេ វស្សសតំ ហុតំ ។**

អ្នកណា បូជា ( លោកិយមហាជន ) ដោយទ្រព្យមួយពាន់រាល់ខែៗ អស់មួយរយឆ្នាំគត់ ចំណែកអ្នកណា គប្បីបូជាចំពោះ

បុគ្គលដែលមានខ្លួនអប់រំហើយ តែមួយនាក់ សូម្បីតែមួយរំពេច ការបូជានោះឯង ប្រសើរជាងការបូជា របស់អ្នកដែលបូជាអស់មួយរយឆ្នាំនោះ ការបូជាអស់មួយរយឆ្នាំ មិនប្រសើរឡើយ ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **សហស្សេន** សេចក្ដីថា ដោយបរិច្ចាគទ្រព្យមួយពាន់ ។

បាទព្រះគាថាថា **យោ យជេថ សតំ សមំ** សេចក្ដីថា បុគ្គលណាកាលបរិច្ចាគទ្រព្យមួយពាន់ រៀងរាល់ខែ គប្បីឲ្យទានដល់លោកិយមហាជន អស់មួយរយឆ្នាំ ។

បាទព្រះគាថាថា **ឯកញ្ច ភាវិតត្តានំ** សេចក្ដីថា ចំណែកបុគ្គលណាគប្បីបូជាបុគ្គល ដែលមានខ្លួនអប់រំហើយ ដោយអំណាចនៃគុណតែម្នាក់ ដោយហោចត្រឹមតែបុគ្គលថ្នាក់ទាប ជាព្រះសោតាបន្ន ដោយហោចត្រឹមតែបុគ្គលថ្នាក់ខ្ពស់ ជាព្រះខីណាស្រព ដែលមកដល់ទៀបទ្វារផ្ទះ ដោយអំណាចភិក្ខាមួយវែក ដោយអំណាចអាហារល្មមញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបាន ឬដោយត្រឹមតែប្រគេនសំពត់សាច់គ្រោតគ្រាត ការបូជារបស់បុគ្គលនោះឯងប្រសើរ គឺកំពូល បានដល់ ឧត្ដមជាងការបូជា ដែលបុគ្គលក្រៅអំពីនេះបូជាហើយ អស់មួយរយឆ្នាំ ។

ក្នុងកាលចប់ទេសនា ព្រាហ្មណ៍នោះសម្រេចសោតាបត្តិផលហើយ ជន

ដទៃជាច្រើន សម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

**រឿង ព្រាហ្មណ៍ជាអាំរបស់ព្រះសារីបុត្តត្ថេរ ចប់**

# រឿង ព្រាហ្មណ៍ជាក្មួយរបស់ព្រះសារីបុត្តត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធក្មួយរបស់ព្រះសារីបុត្តត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **យោ ច វស្សសតំ ជន្តុ** ជាដើម ។

សេចក្តីពិស្តារថា ព្រះថេរៈចូលទៅរកក្មួយនោះហើយសួរថា នែព្រាហ្មណ៍ អ្នកធ្វើកុសលឬ ព្រាហ្មណ៍ឆ្លើយថា បពិត្រលោកម្ចាស់ យ៉ាងនោះឯង ព្រះថេរៈសួរថា អ្នកធ្វើកុសលអ្វី ព្រាហ្មណ៍នោះឆ្លើយថា សម្លាប់សត្វចិញ្ចឹមមួយ ហើយបម្រើភ្លើងរៀងរាល់ខែ ព្រះថេរៈសួរថា ធ្វើយ៉ាងនោះដើម្បីអ្វី ព្រាហ្មណ៍ឆ្លើយថា បានឮថា នុ៎ះជាផ្លូវទៅព្រហ្មលោក ព្រះថេរៈសួរថា អ្នកណាពោលយ៉ាងនោះ ព្រាហ្មណ៍ឆ្លើយថា ពួកអាចារ្យរបស់ខ្ញុំ ព្រះថេរៈពោលថា អ្នកមិនដឹងផ្លូវនៃព្រហ្មលោក សូម្បីពួកអាចារ្យរបស់អ្នកក៏មិនដឹង មកចុះយើងនឹងទៅកាន់សម្នាក់ព្រះសាស្តា ដូច្នេះហើយ នាំក្មួយនោះទៅកាន់សម្នាក់របស់ព្រះសាស្តា ទូលរឿងនោះហើយ ក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់ប្រាប់ផ្លូវនៃព្រហ្មលោក ដល់ព្រាហ្មណ៍នេះ ។ ព្រះសាស្តា ត្រាស់សួរថា

*បានឮថា សេចក្តីនោះ យ៉ាងនេះឬ កាលព្រាហ្មណ៍ទូលថា បពិត្រព្រះគោតម យ៉ាងនោះឯង ទើបត្រាស់ថា ម្នាលព្រាហ្មណ៍ ការបម្រើភ្លើងរបស់អ្នក ដែលអ្នកបម្រើយ៉ាងនោះ អស់មួយរយឆ្នាំ រមែងមិនដល់សូម្បីត្រឹមការបូជាសាវករបស់តថាគតត្រឹមតែមួយខណៈឡើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា*

**យោ ច វស្សសតំ ជន្តុ អគ្គឹ បរិចរេ វនេ**
**ឯកញ្ច ភាវិតត្តានំ មុហុត្តមបិ បូជយេ**
**សាយេវ បូជនា សេយ្យោ យញ្ចេ វស្សសតំ ហុតំ ។**

*ជនណា បម្រើភ្លើងក្នុងព្រៃ អស់មួយរយឆ្នាំ ចំណែកអ្នកណា បូជាលោកដែលមានខ្លួនអប់រំហើយតែមួយនាក់ សូម្បីមួយរំពេច ការបូជានោះឯង ប្រសើរជាងការបូជា របស់ជននោះ ការបូជាអស់មួយរយឆ្នាំ មិនប្រសើរឡើយ ។*

## សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ បទថា* **ជន្តុ** *នេះ ត្រឹមតែជាឈ្មោះរបស់សត្វ ។ បាទព្រះគាថាថា* **អគ្គឹ បរិចរេ វនេ** *សេចក្តីថា សូម្បីចូលទៅកាន់ព្រៃដោយប្រាថ្នាភាពជាបុគ្គលមិនមានធម៌ជាគ្រឿងយឺតយូរ គប្បីបម្រើភ្លើងក្នុងព្រៃនោះ ។ ពាក្យដ៏សេស ដូចគ្នានឹងពាក្យដែលមានក្នុងកាលមុននោះឯង ។*

*ក្នុងកាលចប់ទេសនា ព្រាហ្មណ៍សម្រេចសោតាបត្តិផល ជនដទៃជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។*

# រឿង ព្រាហ្មណ៍ជាសម្លាញ់របស់ព្រះសារីបុត្តត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រាហ្មណ៍ដែលជាសម្លាញ់ព្រះសារីបុត្តត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **យង្កិញ្ចិ យិដ្ឋញ្ច** ជាដើម ។

សេចក្តីពិស្តារថា ព្រះថេរៈចូលទៅរកព្រាហ្មណ៍នោះហើយ សួរថា នែព្រាហ្មណ៍ អ្នកធ្វើកុសលខ្លះដែរឬទេ ព្រាហ្មណ៍ឆ្លើយថា បពិត្រលោកម្ចាស់ ធ្វើដែរ ព្រះថេរៈសួរថា ធ្វើកុសលអ្វី ព្រាហ្មណ៍ឆ្លើយថា បូជាយញ្ញដូចដែលគេបូជា ។

បានឮថា កាលណោះ ជនទាំងឡាយរមែងបូជាយញ្ញនោះ ដោយបរិច្ចាគដ៏ច្រើន ។ បន្ទាប់អំពីនេះ ព្រះថេរៈសួរដោយន័យមុននោះឯង រួចនាំព្រាហ្មណ៍នោះ ទៅកាន់សម្នាក់របស់ព្រះសាស្តា ទូលរឿងនោះហើយ ក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់ត្រាស់ប្រាប់ផ្លូវនៃព្រហ្មលោកដល់ព្រាហ្មណ៍នេះ ។

ព្រះសាស្តាត្រាស់សួរថា ម្នាលព្រាហ្មណ៍ បានឮថា សេចក្តីនេះយ៉ាងនោះឬ កាលព្រាហ្មណ៍ទូលថា យ៉ាងនោះឯង ព្រះអង្គ ទើបត្រាស់ថា ម្នាលព្រាហ្មណ៍ ទានដែលអ្នកបូជាយញ្ញ ដូចដែលគេធ្លាប់បូជា ឲ្យដល់លោកិយមហាជនរាប់ឆ្នាំ រមែងមិនដល់ចំណែកទី ៤ នៃកុសលចេតនាដែលកើតឡើងដល់មនុស្សទាំងឡាយ ដែលថ្វាយបង្គំសាវ័ករបស់តថាគត ដោយចិត្តជ្រះថ្លា កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**យង្កិញ្ចិ យិដ្ឋំ វ ហុតំ វ លោកេ សំវច្ឆរំ យជេថ បុញ្ញបេក្ខោ**
**សព្វំបិ តំ ន ចតុភាគមេតិ អភិវាទនា ឧជ្ជុគតេសុ សេយ្យោ។**

*បុគ្គលអ្នកប្រាថ្នាបុណ្យ គប្បីបូជាគ្រឿងសក្ការបូជាធំតូចណាមួយ ក្នុងលោកអស់មួយឆ្នាំ ការបូជាទាំងអស់នោះឯង រមែងមិនដល់នូវចំណែកទី ៤ នៃការអភិវាទន៍ចំពោះលោកទាំងឡាយ ដែលប្រព្រឹត្តត្រង់ហើយ ប្រសើរជាង ។*

## សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ បទថា* **យំកិញ្ចិ** *នេះ ជាពាក្យសរុប កាន់យកមិនមានចំណែកសល់ ។ បទថា* **យិដ្ឋំ** *បានដល់ ទានដែលគេឲ្យ ដោយអំណាចការធ្វើមង្គលជាដើមដោយច្រើន ។ បទថា* **ហុតំ** *បានដល់ ទានដើម្បីភ្ញៀវ ដែលគេរៀបចំធ្វើ និងទានដែលបុគ្គលជឿកម្ម និងផលនៃកម្មធ្វើ ។*

*ពីរបទថា* **សំវច្ឆរំ យជេថ** *សេចក្តីថា គប្បីឲ្យទានមានប្រការដូចពោលហើយ ដល់លោកិយមហាជនក្នុងចក្កវាឡទាំងមូល អស់មួយឆ្នាំមិនមានរវាងចន្លោះ ។ បទថា* **បុញ្ញបេក្ខោ** *បានដល់ អ្នកប្រាថ្នាបុណ្យ ។ បទថា* **ឧជ្ជុគតេសុ** *សេចក្តីថា ដោយហោចយ៉ាងទាបក្នុងព្រះសោតាបន្ន ដោយហោចយ៉ាងខ្ពស់ ក្នុងព្រះខីណាស្រព ។*

*ពាក្យនេះ ជាពាក្យដែលព្រះសាស្តាត្រាស់ថា ទានទាំងអស់ មិនដល់ត្រឹមចំណែកទី ៤ អំពីផលនៃកុសលចេតនារបស់បុគ្គល ដែលបង្អោនសរីរៈថ្វាយបង្គំដោយចិត្តជ្រះថ្លាបែបនោះ ព្រោះដូច្នោះ ការអភិវាទន៍ក្នុងបុគ្គល*

ដែលប្រព្រឹត្តត្រង់ប៉ុណ្ណោះ ប្រសើរបំផុត ។

ក្នុងកាលចប់ទេសនា ព្រាហ្មណ៍សម្រេចសោតាបត្តិផលហើយ ជនដទៃជាច្រើន សម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ៕៚

**រឿង ព្រាហ្មណ៍ជាសម្លាញ់របស់ព្រះសារីបុត្តត្ថេរ ចប់**

# រឿង អាយុវឌ្ឍនកុមារ

## លំនាំដើម

ព្រះសាស្តា កាលទ្រង់អាស្រ័យទីឃលម្ពិកនគរ ប្រថាប់នៅក្នុងកុដិក្នុងព្រៃ ទ្រង់ប្រារព្ធកុមារដែលអាយុវែង ត្រាស់ព្រះធម្មទេសនានេះថា **អភិវាទនសីលិស្ស** ជាដើម ។

បានឮថា ព្រាហ្មណ៍ពីរនាក់ រស់នៅក្នុងទីឃលម្ពិកនគរ បួសក្នុងលទ្ធិខាងក្រៅ បំពេញតបៈអស់ ៤៨ ឆ្នាំ បណ្តាព្រាហ្មណ៍ពីរនាក់នោះ ព្រាហ្មណ៍ម្នាក់ គិតថា បវេណីរបស់អញនឹងបាត់បង់ អញនឹងសឹក ដូច្នេះហើយ ទើបលក់បរិក្ខារតបៈដែលខ្លួនធ្វើដល់អ្នកដទៃ បានភរិយា មួយអន្ទើដោយគោមួយរយក្បាល និងទ្រព្យមួយរយកហាបណៈ បានជាដើមទុន ។ គ្រានោះភរិយារបស់គាត់ប្រសូតបុត្រ ។

ចំណែកសម្លាញ់របស់គាត់ ចេញអំពីទីនោះទៅកាន់ទឹកដីដទៃ ត្រឡប់

មកកាន់នគរនោះទៀត ។ គាត់បានឮដំណឹងសម្លាញ់នោះមក ទើបនាំបុត្រ និង កិរិយាទៅដើម្បីសួរសុខទុក្ខសម្លាញ់ កាលដល់ហើយ ឲ្យបុត្រក្នុងដៃរបស់មាតាហើយ ក៏ថ្វាយបង្គំឯងមុន មាតាឲ្យបុត្រក្នុងដៃបិតាហើយក៏ថ្វាយបង្គំ សម្លាញ់នោះពោលថា សូមអ្នកអាយុវែង តែកាលមាតាឲ្យបុត្រថ្វាយបង្គំហើយ សម្លាញ់នោះក៏នៅស្ងៀម ។

លំដាប់នោះ ព្រាហ្មណ៍ពោលនឹងសម្លាញ់នោះថា បពិត្រលោកម្ចាស់ ព្រោះហេតុអ្វី កាលខ្ញុំថ្វាយបង្គំ លោកម្ចាស់ពោលថា សូមអ្នកមានអាយុវែង ក្នុងកាលដែលកុមារនេះថ្វាយបង្គំ មិនពោលពាក្យអ្វីសោះ សម្លាញ់នោះពោលថា នែព្រាហ្មណ៍ អន្តរាយមួយរបស់ក្មេងនេះមាន ព្រាហ្មណ៍ពោលថា ក្មេងរស់នៅអស់កាលមានប្រមាណប៉ុនណា សម្លាញ់នោះពោលថា នែព្រាហ្មណ៍ ៧ ថ្ងៃទៀតប៉ុណ្ណោះ ព្រាហ្មណ៍សួរថា មានវិធីការពារដែរឬទេ សម្លាញ់នោះពោលថា ខ្ញុំមិនដឹងហេតុជាគ្រឿងការពារ ។ ព្រាហ្មណ៍ពោលថា អ្នកណាគប្បីដឹង លោកម្ចាស់ សម្លាញ់នោះឆ្លើយថា ព្រះសមណគោតម ចូរអ្នកទៅកាន់សម្នាក់របស់ទ្រង់ហើយ សួរចុះ ព្រាហ្មណ៍ពោលថា ខ្ញុំទៅក្នុងទីនោះខ្លាចអំពីការវិនាសនៃតបៈ សម្លាញ់នោះពោលថា បើការស្រឡាញ់ក្នុងបុត្ររបស់អ្នកមាន កុំគិតដល់ការវិនាសនៃតបៈឡើយ ចូរទៅកាន់សម្នាក់របស់ព្រះគោតមនោះសួរចុះ ។

ព្រាហ្មណ៍នោះ ទៅកាន់សម្នាក់របស់ព្រះសាស្តា ថ្វាយបង្គំឯងជាបឋម ព្រះសាស្តាត្រាស់ថា ចូរអ្នកមានអាយុវែង សូម្បីក្នុងពេលដែលបជាបតីថ្វាយ

បន្តំ ក៏ត្រាស់ដល់នាងយ៉ាងនោះដូចគ្នា ក្នុងកាលដែលព្រាហ្មណ៍ឲ្យបុត្រថ្វាយបង្គំ ទ្រង់ក៏នៅស្ងៀម ។ គាត់ទូលសួរព្រះសាស្ដាដោយន័យមុននោះឯង សូម្បីព្រះសាស្ដា ក៏ទ្រង់ព្យាករដល់គាត់យ៉ាងនោះដូចគ្នា ។

បានឮថា ព្រាហ្មណ៍នោះមិនចាក់ធ្លុះសព្វញ្ញុតញ្ញាណ ទើបប្រៀបធៀបមន្តរបស់ខ្លួនជាមួយសព្វញ្ញុតញ្ញាណ តែមិនដឹងឧបាយជាគ្រឿងការពារ ។

ព្រាហ្មណ៍ទូលសួរព្រះសាស្ដាថា បពិត្រព្រះអង្គ ឧបាយជាគ្រឿងការពារមានដែរឬទេ ព្រះសាស្ដាត្រាស់ថា ម្នាលព្រាហ្មណ៍ មាន ព្រាហ្មណ៍ទូលថា គប្បីមានដូចម្ដេច ព្រះសាស្ដាត្រាស់ថា បើអ្នកអាចធ្វើមណ្ឌបក្បែរទ្វារផ្ទះរបស់ខ្លួន ធ្វើតាំងត្រង់កណ្ដាលមណ្ឌបនោះ ហើយក្រាលអាសនៈ ៨ ឬ ១៦ ព័ទ្ធជុំវិញតាំងនោះ ឲ្យសាវ័ករបស់តថាគតអង្គុយលើអាសនៈទាំងនោះ ធ្វើព្រះបរិត្ត ៧ ថ្ងៃ មិនមានចន្លោះ អន្តរាយរបស់ក្មេងនោះ គប្បីវិនាសទៅដោយឧបាយយ៉ាងនេះ ។

ព្រាហ្មណ៍ពោលថា បពិត្រព្រះគោតម ខ្ញុំព្រះអង្គអាចធ្វើមណ្ឌបជាដើមបាន តែនឹងបានសាវ័ករបស់ទ្រង់ដូចម្ដេច ព្រះសាស្ដាត្រាស់ថា បើអ្នកធ្វើកិច្ចប៉ុណ្ណោះហើយ តថាគតនឹងឲ្យសាវ័ករបស់តថាគតទៅ ព្រាហ្មណ៍ទទួលថា សាធុព្រះគោតម ហើយធ្វើកិច្ចទាំងអស់នោះជិតទ្វារផ្ទះរបស់ខ្លួនហើយ បានទៅកាន់សម្នាក់របស់ព្រះសាស្ដា ។

ព្រះសាស្ដាទ្រង់បញ្ជូនភិក្ខុទាំងឡាយទៅ ភិក្ខុទាំងនោះអង្គុយក្នុងមណ្ឌបនោះ ព្រាហ្មណ៍ស្វាមីភរិយាឲ្យកុមារដេកលើតាំងហើយ ភិក្ខុទាំងឡាយសូធ្យ

ព្រះបរិត្ត ៧ យប់ ៧ ថ្ងៃមិនមានចន្លោះ ។ ក្នុងថ្ងៃទី ៧ ព្រះសាស្តាយាងមក ឯង កាលព្រះសាស្តាយាងទៅហើយ ពួកទេវតាក្នុងចក្កវាឡទាំងមូលប្រជុំគ្នាហើយ ។

ឯអវរុទ្ធកយក្ខ បម្រើព្រះបាទវេស្សវណ ១២ ឆ្នាំ កាលបានពរអំពីសម្នាក់ព្រះបាទវេស្សវណនោះ បានពោលថា ក្នុងថ្ងៃទី ៧ បន្ទាប់អំពីថ្ងៃនេះ អ្នកគប្បីចាប់យកទារកនេះ ព្រោះដូច្នោះ ទើបយក្ខនោះមកឈរ កាលព្រះសាស្តាយាងទៅក្នុងមណ្ឌបនោះ ពួកទេវតាមានសក្តិធំប្រជុំគ្នា ពួកទេវតាមានសក្តិតូច ក៏ថយទៅ មិនបានឱកាស ចៀសចេញទៅអស់ ១២ យោជន៍ សូម្បីអវរុទ្ធកយក្ខ ក៏បានចៀសទៅឈរយ៉ាងនោះដូចគ្នា ។

ព្រះសាស្តា ទ្រង់បានធ្វើព្រះបរិត្តមួយយប់ទល់ភ្លឺ កាលថ្ងៃទី ៧ កន្លងហើយ អវរុទ្ធកយក្ខមិនបានទារក ក្នុងថ្ងៃទី ៨ គ្រាន់តែអារុណរះឡើងប៉ុណ្ណោះ ស្វាមីភរិយា នាំកុមារឲ្យថ្វាយបង្គំព្រះសាស្តា ព្រះសាស្តាត្រាស់ថា ចូរអ្នកមានអាយុវែងចុះ ព្រាហ្មណ៍ទូលថា បពិត្រព្រះគោតម កុមារនេះតាំងនៅយូរប៉ុនណា ព្រះសាស្តាត្រាស់ថា ម្នាលព្រាហ្មណ៍ ១២០ ឆ្នាំ ។

លំដាប់នោះ ស្វាមីភរិយាទាំងពីរ ដាក់ឈ្មោះក្មេងនោះថា អាយុវឌ្ឍនកុមារ ។ អាយុវឌ្ឍនកុមារនោះ ចម្រើនធំធាត់ហើយ មានឧបាសក ៥០០ ចោមរោមត្រាច់ទៅ ។

ថ្ងៃមួយ ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងរោងធម្មសភាថា អាវុសោទាំងឡាយ ចូរអ្នកទាំងឡាយមើល បានឮថា អាយុវឌ្ឍនកុមារគប្បីស្លាប់ក្នុងថ្ងៃទី ៧ ឥឡូវ

នេះ អាយុវឌ្ឍនកុមារនោះ មានឧបាសក ៥០០ ហោមរោម ត្រាច់ទៅ ហេតុជាគ្រឿងចម្រើនអាយុរបស់សត្វទាំងនេះ ប្រហែលជាមាន ។

ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងឡាយក្រាបទូលថា ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាយុចម្រើនតែម្យ៉ាងប៉ុណ្ណោះក៏មិនមែន សត្វទាំងនេះថ្វាយបង្គំបុគ្គលដែលមានគុណ រមែងចម្រើនដោយហេតុ ៤ ប្រការ ផុតចាកអន្តរាយ តាំងនៅដរាបដល់អាយុនោះឯង ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**អភិវាទនសីលិស្ស និច្ចំ វុឌ្ឍាបចាយិនោ**
**ចត្តារោ ធម្មា វឌ្ឍន្តិ អាយុវណ្ណោ សុខំ ពលំ ។**

ធម៌ ៤ ប្រការ គឺអាយុ ១ វណ្ណៈ ១ សុខ ១ ពល ១ រមែងចម្រើន ដល់អ្នកដែលមានសេចក្តីឱនកាយ ថ្វាយបង្គំជាប្រក្រតី មានសេចក្តីកោតក្រែង ដល់បុគ្គលដែលចម្រើនជាន់ខ្ពស់អស់កាលជានិច្ច ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អភិវាទនសីលិស្ស** គឺដែលថ្វាយបង្គំជាប្រក្រតី បានដល់ ជាអ្នកខ្វល់ខ្វាយដោយកិច្ច គឺការថ្វាយបង្គំរឿយៗ ។ បទថា **វុឌ្ឍាបចាយិនោ** សេចក្តីថា ដល់គ្រហស្ថដែលឱនលំទោន ឬដែលបូជា

ជានិច្ច ដោយការថ្វាយបង្គំ សូម្បីក្នុងភិក្ខុកំលោះ និងសាមណេរដែលបួសក្នុងថ្ងៃនោះ ឬដល់បព្វជិតជាអ្នកឱនលំទោន ឬបូជាជានិច្ច ដោយការក្រាបថ្វាយបង្គំក្នុងបុគ្គលដែលចាស់ជាងដោយបព្វជ្ជា ឬដោយឧបសម្បទា ឬក្នុងបុគ្គលដែលចម្រើនដោយគុណ ។

ពីរបទថា **ចត្តារោ ធម្មា** សេចក្តីថា កាលអាយុចម្រើន អាយុនោះរមែងចម្រើនអស់កាលប៉ុនណា ធម៌ទាំងឡាយក្រៅអំពីនេះ ក៏ចម្រើនអស់កាលប៉ុណ្ណោះដូចគ្នា ព្រោះថា បុគ្គលណាធ្វើកុសលដែលញុំាងអាយុ ៥០ ឆ្នាំឲ្យប្រព្រឹត្តទៅ អន្តរាយនៃជីវិតរបស់បុគ្គលនោះ គប្បីកើតឡើងក្នុងកាលមានអាយុ២៥ ឆ្នាំ អន្តរាយនោះ រមែងរម្ងាប់បាន ដោយភាពជាអ្នកថ្វាយបង្គំជាប្រក្រតី ។ បុគ្គលនោះ រមែងតាំងនៅបានដរាបដល់អស់អាយុនោះឯង ។ សូម្បីពណ៌សម្បុរជាដើមរបស់បុគ្គលនោះ រមែងចម្រើនព្រមជាមួយអាយុនោះឯង ។

ន័យក្រៅលែងជាងនេះ ក៏យ៉ាងនេះឯង ។ ឈ្មោះថា ការចម្រើននៃអាយុ ដែលប្រព្រឹត្តទៅ ដោយមិនមានអន្តរាយ ក៏មិនមែន ។

ក្នុងកាលចប់ទេសនា អាយុវឌ្ឍនកុមារតាំងនៅក្នុងសោតាបត្តិផល មួយអន្លើដោយឧបាសក ៥០០ ហើយ សូម្បីជនដទៃជាច្រើន ក៏សម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

**រឿង អាយុវឌ្ឍនកុមារ ចប់**

# រឿង សង្កិច្ចសាមណេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសង្កិច្ចសាមណេរ ត្រាស់ព្រះធម្មទេសនានេះថា **យោ ច វស្សសតំ ជីវេ** ជាដើម ។

បានឮថា កុលបុត្រប្រមាណ ៣០ នាក់ ក្នុងក្រុងសាវត្ថី ស្តាប់ធម្មកថាហើយ បួសថ្វាយជីវិតក្នុងសាសនារបស់ព្រះសាស្តា ភិក្ខុទាំងនោះឧបសម្បទាបាន ៥ វស្សា ចូលគាល់ព្រះសាស្តា ស្តាប់ធុរៈពីរប្រការ គឺគន្ថធុរៈ និងវិបស្សនាធុរៈ មិនធ្វើឧស្សាហ៍ក្នុងគន្ថធុរៈ ព្រោះជាអ្នកបួសឯចាស់ កាលបំណងនឹងបំពេញវិបស្សនាធុរៈ ទូលសូមព្រះសាស្តា ឲ្យត្រាស់ប្រាប់កម្មដ្ឋានអំពីអរហត្ត ទើបទូលលាព្រះសាស្តាថា ខ្ញុំព្រះអង្គនឹងទៅកាន់ព្រៃមួយកន្លែង ។

ព្រះសាស្តាត្រាស់សួរថា ពួកអ្នកនឹងទៅក្នុងទីណា កាលភិក្ខុទាំងនោះក្រាបទូលថា ក្នុងទីឈ្មោះនោះ ទ្រង់បានជ្រាបថា ភ័យនឹងកើតឡើងក្នុងទីនោះដល់ភិក្ខុទាំងនោះ ព្រោះអាស្រ័យមនុស្សស៊ីដែលម្នាក់ តែបើសង្កិច្ចសាមណេរទៅហើយ ភ័យនឹងរម្ងាប់ កាលបើដូច្នោះ កិច្ចបព្វជិតរបស់ភិក្ខុទាំងនោះនឹងដល់នូវភាពបរិបូណ៌ ។

សាមណេររបស់ព្រះសារីបុត្ត ឈ្មោះសង្កិច្ចសាមណេរ មានអាយុ ៧ ឆ្នាំអំពីកំណើត ។ បានឮថា មាតារបស់សង្កិច្ចសាមណេរនោះ ជាកូនស្រីរបស់ត្រកូលស្តុកស្តម្ភ ក្នុងក្រុងសាវត្ថី ។ កាលសាមណេរនោះ នៅក្នុងផ្ទៃមាតានោះ បានធ្វើកាលកិរិយាក្នុងខណៈនោះឯង ដោយជំងឺឯណានីមួយ ។

កាលមាតា នោះត្រូវដុត សាច់ចំណែកដ៏សេសឆេះទៅ វៀរតែសាច់ផ្ទៃពោះ ។ លំដាប់នោះ ពួកពុកលើកសាច់ពោះរបស់នាងចុះអំពីជើងថ្ករ ចាក់ដោយដែកស្រួច ក្នុងទីពីរបីកន្លែង ចុងដែកក៏ចាក់ត្រង់កន្ទុយភ្នែករបស់ទារក ពួកអ្នកពុកចាក់សាច់ពោះយ៉ាងនោះហើយ ទើបបោះទៅលើគំនររងើកភ្លើង លុបដោយរងើកភ្លើងនោះឯង ហើយចៀសចេញទៅ សាច់ពោះឆេះហើយ ។ ចំណែកទារកហាក់ដូចជាដុំមាសលើគំនររងើកភ្លើង ដូចដេកនៅក្នុងត្របកផ្កាឈូក ។ ពិតហើយ សត្វដែលមានភពចុងក្រោយ សូម្បីត្រូវភ្នំសិនេរុសង្កត់ បើមិនទាន់សម្រេចអរហត្ត ជីវិតមិនអស់ឡើយ ។ ក្នុងថ្ងៃស្អែកឡើង ពួកអ្នកពុកមកដោយគិតថា នឹងពន្លត់ជើងថ្ករ ឃើញទារកដេកយ៉ាងនោះ កើតអស្ចារ្យចម្លែកក្នុងចិត្ត គិតថា មានរឿងអ្វីកើតឡើងហ្ន៎ សរីរៈទាំងមូលដុតលើឧសប៉ុណ្ណេះ ទារកមិនឆេះហើយ នឹងមានហេតុអ្វីហ្ន៎ ទើបពទារកនោះនាំទៅក្នុងស្រុកហើយ សាកសួរពួកហោរាទាយនិមិត្ត ។ ពួកហោរាទាយនិមិត្តពោលថា ទារកនេះ បើនៅគ្រប់គ្រងផ្ទះ ពួកញាតិ ៧ តំណាត្រកូលនឹងមិនធ្លាក់ក្រីក្រ បើចេញបួស នឹងជាបុគ្គលមានសមណៈ ៥០០ ចោមរោម ត្រាច់ទៅ ។ ពួកញាតិដាក់ឈ្មោះថា សង្កិច្ចៈ ព្រោះកន្ទុយភ្នែករបស់ទារកមុតដោយដែកស្រួច ។

គ្រាក្រោយមក កុមារនោះប្រាកដថា សង្កិច្ចៈ ។ គ្រានោះ ពួកញាតិចិញ្ចឹមទារក ដោយគិតគ្នាថា ណ្ហើយចុះ ក្នុងកាលដែលទារកធំហើយ ពួកយើងនឹងឲ្យបួសក្នុងសម្នាក់ព្រះសារីបុត្ត លោកម្ចាស់របស់យើង ។ ក្នុងពេល

ដែលកុមារបានអាយុ ៧ ឆ្នាំ សង្កិច្ចៈនោះបានឮពាក្យរបស់ក្មេងៗ ថា ក្នុងកាលដែលឯងនៅក្នុងពោះ ម៉ែរបស់ឯងធ្វើកាលកិរិយាហើយ កាលសរីរៈម៉ែរបស់ឯងនោះត្រូវដុត ឯងក៏មិនឆេះ ទើបប្រាប់ដល់ពួកញាតិថា បានឮថា ខ្ញុំរួចផុតអំពីភ័យបែបនោះ ប្រយោជន៍អ្វីរបស់ខ្ញុំដោយផ្ទះ ខ្ញុំនឹងបួស ។ ញាតិទាំងនោះទទួលថា សាធុ ហើយនាំទៅកាន់សម្នាក់ព្រះសារីបុត្តត្ថេរ ប្រគេនដោយពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ឲ្យក្មេងនេះ បួសចុះ ។ ព្រះថេរៈឲ្យតចបញ្ចកកម្មដ្ឋានហើយឲ្យបួស ។ សាមណេរនោះ សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា ក្នុងពេលកោរសក់ស្រេចនោះឯង ឈ្មោះថា សង្កិច្ចសាមណេរ មានប្រមាណប៉ុណ្ណេះ ។

ព្រះសាស្តាទ្រង់ជ្រាបថា កាលសាមណេរនេះទៅហើយ ភ័យនឹងរម្ងាប់កាលបើដូច្នោះ កិច្ចនៃបព្វជិតរបស់ភិក្ខុទាំងនោះនឹងដល់នូវភាពបរិបូណ៌ ដូច្នេះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចូរពួកអ្នកលាសារីបុត្តបងប្រុសរបស់អ្នកហើយសឹមទៅ ។ ភិក្ខុទាំងនោះទទួលថា សាធុ ហើយទៅកាន់សម្នាក់របស់ព្រះថេរៈ កាលព្រះថេរៈសួរថា ពួកលោកមានការអ្វី ទើបពោលថា ខ្ញុំរៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តាហើយ មានបំណងនឹងចូលទៅកាន់ព្រៃ ទើបទូលលា កាលបើដូច្នោះ ទើបព្រះសាស្តាត្រាស់យ៉ាងនេះដល់ពួកខ្ញុំថា ពួកអ្នកលាបងប្រុសរបស់ពួកអ្នកហើយសឹមទៅ ដោយហេតុនោះ ទើបពួកខ្ញុំមកទីនេះ ។

ព្រះថេរៈគិតថា ភិក្ខុទាំងនេះ ប្រហែលជាព្រះសាស្តាទ្រង់ឃើញហេតុណាមួយហើយបញ្ជូនមកទីនេះ តើមានរឿងអ្វីហ្ន៎ ដឹងរឿងនោះហើយ ទើប

ពោលថា អាវុសោ សាមណេររបស់ពួកអ្នកមានដែរឬទេ ភិក្ខុឆ្លើយថា មិនមានទេ អាវុសោ ព្រះថេរៈពោលថា បើមិនមាន ចូរពួកលោកនាំសាមណេរនេះទៅ ពួកភិក្ខុពោលថា កុំឡើយអាវុសោ ព្រោះអាស្រ័យសាមណេរ ការកន្ទល់នឹងមានដល់ពួកខ្ញុំ ប្រយោជន៍អ្វីដោយសាមណេរ សម្រាប់ពួកភិក្ខុដែលនៅក្នុងព្រៃ ។ ព្រះថេរៈពោលថា អាវុសោ ព្រោះអាស្រ័យសាមណេរនេះ ការកន្ទល់មិនមានដល់ពួកលោកឡើយ តែព្រោះអាស្រ័យពួកលោក កន្ទល់នឹងមានដល់សាមណេរនេះ សូម្បីព្រះសាស្តា កាលទ្រង់បញ្ជូនពួកអ្នកមកកាន់សម្នាក់ខ្ញុំ ទ្រង់ចង់ឲ្យសាមណេរទៅជាមួយពួកលោក ទើបទ្រង់បញ្ជូនមក ចូរពួកលោកនាំសាមណេរនេះទៅចុះ ។

ភិក្ខុទាំងនោះទទួលថា សាធុ មានគ្នាគម្រប់ ៣១ រូប ទាំងសាមណេរ លាព្រះថេរៈចេញអំពីវិហារ ត្រាច់ទៅដល់ស្រុកមួយ មានត្រកូល ១០០០ ក្នុងចម្ងាយ ១២០ យោជន៍ ។ ពួកមនុស្សឃើញភិក្ខុទាំងនោះ មានចិត្តជ្រះថ្លា អង្គាសដោយគោរពហើយ សួរថា បពិត្រលោកម្ចាស់ លោកម្ចាស់ទាំងឡាយនិមន្តទៅណា កាលភិក្ខុទាំងនោះឆ្លើយថា ទៅរកទីស្ថានដែលជាផាសុក ទើបក្រាបចុះទៀបបាទដើងនិមន្តថា បពិត្រលោកម្ចាស់ បើលោកម្ចាស់អាស្រ័យស្រុកនេះ អស់កាលខាងក្នុងវស្សា ពួកខ្ញុំនឹងសមាទានសីល ៥ និងរក្សាឧបោសថ ព្រះថេរៈទាំងឡាយទទួលហើយ ។ គ្រានោះ ពួកភិក្ខុរៀបចំទីសម្រាកពេលយប់ ទីសម្រាកពេលថ្ងៃ ទីចង្ក្រម និងបណ្ណសាលា ដល់នូវភាពឧស្សាហ៍ថា ថ្ងៃនេះ ពួកយើង ស្អែកនេះ ពួកយើងបានធ្វើការទំនុក

បម្រើភិក្ខុទាំងនោះ ។

ក្នុងថ្ងៃចាំវស្សា ព្រះថេរៈទាំងឡាយធ្វើកតិកាគ្នាថា អាវុសោ ពួកយើង រៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះសម្ពុទ្ធ ដែលទ្រង់គង់ព្រះជន្មនៅឡើយ តែ វៀរការដល់ព្រមដោយបដិបទា ពួកយើងមិនអាចញុំាងព្រះពុទ្ធទាំងឡាយឲ្យ ត្រេកអរបាន ។ ម្យ៉ាងទៀត ទ្វារអបាយក៏បើកហើយ សម្រាប់ពួកយើងនោះ ឯង ព្រោះដូច្នោះ វៀរពេលភិក្ខាចារក្នុងពេលព្រឹក និងពេលទំនុកបម្រើព្រះ ថេរៈពេលល្ងាច ក្នុងកាលដ៏សេស ពួកយើងនឹងមិននៅក្នុងទីតែមួយពីររូប ឡើយ ការមិនផាសុកមានដល់លោកម្ចាស់អង្គណា លោកម្ចាស់អង្គនោះត្រូវ វាយជួង ពួកយើងនឹងទៅកាន់សម្នាក់លោកម្ចាស់អង្គនោះ ដើម្បីធ្វើថ្នាំ ក្នុង ចំណែកពេលយប់ ឬក្នុងចំណែកពេលថ្ងៃ ដទៃក្រៅអំពីនេះ ពួកយើងកុំប្រមាទ ប្រកបកម្មដ្ឋានរឿយៗ ។

កាលភិក្ខុទាំងនោះធ្វើកតិកាយ៉ាងនោះ បុរសទុគ៌តម្នាក់ អាស្រ័យកូនស្រី រស់នៅ កាលទុព្ភិក្ខភ័យកើតឡើងក្នុងទីនោះ មានបំណងនឹងអាស្រ័យកូន ដទៃរស់នៅ ទើបធ្វើដំណើរទៅ សូម្បីព្រះថេរៈទាំងឡាយត្រាច់ទៅបិណ្ឌបាត ក្នុងស្រុក មកដល់លំនៅ ផ្ទូតទឹកក្នុងស្ទឹងមួយកន្លែងក្នុងរវាងផ្លូវនោះ អង្គុយ លើឆ្នេរខ្សាច់ធ្វើភត្តកិច្ច ។ ក្នុងខណៈនោះ បុរសនោះដល់ទីនោះហើយ បាន ឈរនៅក្នុងទីបំផុតនាចំណែកម្ខាង ។ លំដាប់នោះ ព្រះថេរៈទាំងឡាយសួរថា តើអ្នកទៅណា បុរសនោះប្រាប់សេចក្ដីនោះហើយ ។ ព្រះថេរៈទាំងឡាយកើត សេចក្ដីករុណាក្នុងបុរសនោះ ទើបពោលថា ឧបាសក អ្នកឃ្លានខ្លាំង ចូរទៅ

នាំស្លឹកឈើមក ពួកអាត្មានឹងឲ្យដុំភត្តដល់អ្នកមួយរូបមួយដុំ កាលគាត់នាំស្លឹកឈើមកហើយ ទើបប្រឡប់ដោយសម្ល និងម្ហូប ដោយទំនងដែលធាន់រៀងៗខ្លួន បានឲ្យដុំភត្តមួយរូបមួយដុំ ។ បានឮថា ទំនៀមមានដូច្នោះ ភិក្ខុបើឲ្យភត្តដល់អ្នកមកដល់ក្នុងពេលធាន់ មិនឲ្យអនាមដ្ឋភត្ត គប្បីឲ្យតិចតួចខ្លះ ច្រើនខ្លះ ដោយទំនងដែលធាន់ដោយខ្លួននោះឯង ព្រោះដូច្នោះ ទើបភិក្ខុទាំងនោះមិនបានឲ្យយ៉ាងនោះ ។ បុរសនោះធ្វើភត្តកិច្ចហើយ ថ្វាយបង្គំព្រះថេរៈទាំង-ឡាយ សួរថា បពិត្រលោកម្ចាស់ លោកម្ចាស់ទាំងឡាយ បុគ្គលណាមួយនិមន្តទុកឬ ភិក្ខុទាំងនោះ ពោលថា ឧបាសក មិនមានការនិមន្តទេ ពួកមនុស្សឲ្យអាហារបែបនេះរៀងរាល់ថ្ងៃ ។

ទុគ្គតបុរសគិតថា អញសូម្បីប្រឹងប្រែងធ្វើការងារអស់កាលជានិច្ច ក៏មិនអាចបានអាហារបែបនោះ ប្រយោជន៍អ្វីរបស់អញដោយការទៅកាន់ទីដទៃ អញនឹងនៅក្នុងសម្នាក់របស់ភិក្ខុទាំងនេះឯង ។ លំដាប់នោះ ទើបពោលនឹងភិក្ខុទាំងនោះថា ខ្ញុំប្រាថ្នានឹងធ្វើវត្តបដិបត្តិក្នុងសម្នាក់របស់ពួកលោកម្ចាស់ ភិក្ខុទាំងនោះពោលថា សាធុ ឧបាសក ។

គាត់ចូលទៅត្រង់លំនៅរបស់ភិក្ខុទាំងនោះ ជាមួយភិក្ខុទាំងនោះ ធ្វើវត្តបដិបត្តិដ៏ល្អ ញ៉ាំងពួកភិក្ខុឲ្យស្រឡាញ់ក្រៃលែងអស់ ២ ខែ ប្រាថ្នាទៅសួរសុខទុក្ខកូនស្រី គិតថា បើអញលាលោកម្ចាស់ទាំងឡាយ លោកម្ចាស់ទាំងឡាយ នឹងមិនឲ្យអញទៅ ដូច្នេះ អញមិនលាឡើយ ដូច្នេះហើយ ក៏មិនប្រាប់ដល់ភិក្ខុទាំងនោះ លួចចេញទៅហើយ ។ បានឮថា ការដែលបុរសនោះ

មិនលាពួកភិក្ខុចៀសចេញទៅប៉ុណ្ណោះ ក៏មានអន្តរាយជាំក្នុងផ្លូវទៅរបស់បុរសនោះ មានព្រៃមួយកន្លែង ។ ថ្ងៃទី ៧ ជាថ្ងៃរបស់ចោរ ៥០០ ធ្វើការបន់ស្រន់ទេវតាថា អ្នកណាចូលកាន់ព្រៃនេះ ពួកយើងនឹងសម្លាប់អ្នកនោះ ហើយធ្វើពលីកម្មដល់លោក ដោយសាច់ និងឈាមរបស់បុគ្គលនោះឯង ហើយនៅក្នុងព្រៃនោះ ។

ព្រោះដូច្នោះ ក្នុងថ្ងៃទី ៧ មេចោរឡើងដើមឈើ ពិនិត្យមើលពួកមនុស្ស ឃើញបុរសនោះដើរមក ទើបឲ្យសញ្ញាដល់ពួកចោរ ។ ចោរទាំងនោះដឹងភាពដែលបុរសនោះចូលកាន់ព្រៃ ទើបព័ទ្ធចាប់ ធ្វើការចងយ៉ាងមាំទាំ កួតភ្លើងដោយឈើកួតភ្លើង ជញ្ជូនឧសមកគរជាគំនរធំ សម្រួចលំពែង ។ បុរសនោះឃើញកិរិយារបស់ចោរទាំងនោះ សួរថា នែអ្នក ក្នុងទីនេះ ខ្ញុំមិនឃើញជ្រូក និងម្រឹគជាដើមឡើយ ហេតុអ្វី ទើបពួកអ្នកធ្វើលំពែងនេះ ពួកចោរឆ្លើយថា ពួកយើងនឹងសម្លាប់ឯង ធ្វើពលីកម្មដល់ទេវតាដោយសាច់ និងឈាមរបស់ឯង ។

បុរសនោះត្រូវមរណភ័យគ្របសង្កត់ មិនបានគិតដល់ឧបការៈរបស់ពួកភិក្ខុ គិតរក្សាជីវិតរបស់ខ្លួនតែម្យ៉ាងប៉ុណ្ណោះ ទើបពោលយ៉ាងនេះថា នែអ្នក ខ្ញុំជាមនុស្សស៊ីដែល បរិភោគកត្តដែលជាសំណល់ធំធាត់ ឈ្មោះថា បុគ្គលស៊ីដែល ជាមនុស្សកាឡកិណី ឯពួកព្រះថេរៈចេញបួសអំពីត្រកូលណាមួយជាក្សត្រនោះឯង ភិក្ខុ ៣១ រូបនៅក្នុងទីឈ្មោះនោះ ពួកអ្នកចូរសម្លាប់ភិក្ខុទាំងនោះ ហើយធ្វើកម្ម ទេវតារបស់ពួកអ្នកនឹងត្រេកអរយ៉ាងក្រៃលែង ។

ពួកចោរស្តាប់ពាក្យនោះហើយគិតថា បុគ្គលនេះនិយាយត្រូវ ប្រយោជន៍អ្វីដោយមនុស្សក្រាឡកិណីនេះ ពួកយើងនឹងសម្លាប់ពួកក្សត្រធ្វើពលីកម្ម ដូច្នេះហើយ ទើបពោលថា មកចុះ ចូរអ្នកបង្ហាញលំនៅរបស់ភិក្ខុទាំងនោះ ហើយឲ្យបុរសនោះឯងធ្វើជាអ្នកនាំផ្លូវ ដល់ទីនោះហើយ មិនឃើញពួកភិក្ខុក្នុងវិហារ ទើបសួរថា ពួកភិក្ខុទៅណា បុរសនោះដឹងកតិកាវត្តរបស់ភិក្ខុទាំងនោះ ព្រោះនៅបាន ២ ខែ ទើបពោលយ៉ាងនេះថា ពួកភិក្ខុអង្គុយក្នុងទីសម្រាកពេលយប់និងពេលថ្ងៃរបស់ខ្លួន ចូរវាយជួងនោះ ពួកភិក្ខុនឹងប្រជុំគ្នាដោយសំឡេងជួង ។ មេចោរវាយជួងហើយ ពួកភិក្ខុបានឮសំឡេងជួងគិតថា អ្នកណាវាយជួងខុសកាល ការមិនផាសុកនឹងមានដល់អ្នកណា ដូច្នេះហើយ ទើបមកអង្គុយលើផ្ទាំងថ្ម ដែលគេរៀបចំដោយលំដាប់ត្រង់កណ្តាលវិហារ ព្រះសង្ឃត្ថេរសម្លឹងមើលពួកចោរហើយ សួរថា ឧបាសក អ្នកណាវាយជួង មេចោរឆ្លើយថា ខ្ញុំលោកម្ចាស់ ព្រះសង្ឃត្ថេរសួរថា ព្រោះហេតុអ្វី មេចោរឆ្លើយថា ពួកខ្ញុំបន់ស្រន់ទេវតាប្រចាំព្រៃថា នឹងចាប់ភិក្ខុមួយរូបទៅ ដើម្បីធ្វើពលីកម្មដល់ទេវតានោះ ។

ព្រះមហាថេរៈស្តាប់ពាក្យនោះហើយ ទើបពោលនឹងពួកភិក្ខុនោះថា អាវុសោ ធម្មតាកិច្ចកើតដល់ពួកប្អូនៗ បងត្រូវជួយស្រោចស្រង់ ខ្ញុំនឹងលះបង់ជីវិតរបស់ខ្លួនដើម្បីពួកលោក ទៅជាមួយចោរទាំងនេះ សូមអន្តរាយកុំបីមានដល់លោកគ្រប់រូប សូមពួកលោកជាអ្នកមិនប្រមាទ ធ្វើសមណធម៌ចុះ ។ ព្រះអនុត្ថេរពោលថា បពិត្រលោកម្ចាស់ ធម្មតាកិច្ចរបស់បងប្រុស រមែងជាភារៈរបស់ប្អូនប្រុស ខ្ញុំនឹងទៅ សូមលោកទាំងឡាយជាអ្នកមិនប្រមាទចុះ ។ ដោយឧបាយ

នេះ ភិក្ខុទាំង ៣០ ក្រោកឡើងនិយាយជាលំដាប់ថា ខ្ញុំឯង ខ្ញុំឯង ដោយប្រការដូច្នេះ ។ ភិក្ខុទាំងអស់មិនមែនជាបុត្ររួមមាតាជាមួយគ្នាឡើយ មិនជាបុត្ររបស់បិតាជាមួយគ្នាឡើយ ទាំងមិនទាន់អស់រាគៈ តែរមែងលះបង់ជីវិតតាមលំដាប់ ដើម្បីប្រយោជន៍ដល់ភិក្ខុដ៏សេស បណ្ដាភិក្ខុទាំងនោះ សូម្បីភិក្ខុមួយរូប ឈ្មោះថា អាចពោលថា សូមលោកទៅចុះ មិនមានឡើយ ។

សង្កិច្ចសាមណេរបានស្ដាប់ពាក្យរបស់ភិក្ខុទាំងនោះ ទើបពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ឈប់ចុះ ខ្ញុំនឹងលះបង់ជីវិតដើម្បីលោកម្ចាស់ទាំងឡាយ ពួកភិក្ខុពោលថា អាវុសោ យើងទាំងអស់សូម្បីត្រូវស្លាប់រួមគ្នា ក៏មិនព្រមលះបង់រូបលោកតែមួយរូប សាមណេរពោលថា ព្រោះហេតុអ្វី ពួកភិក្ខុពោលថា អាវុសោ ព្រោះលោកជាសាមណេររបស់ព្រះធម្មសេនាបតីសារីបុត្តត្ថេរ បើខ្ញុំលះបង់លោក ព្រះថេរៈនឹងតិះដៀលថា ពួកភិក្ខុនាំសាមណេររបស់ខ្ញុំទៅ ប្រគល់ឲ្យដល់ពួកចោរ ខ្ញុំមិនអាចរលាស់ចោលនូវពាក្យតិះដៀលទាំងនោះបានឡើយ ដោយហេតុនោះ ខ្ញុំមិនលះបង់លោកឡើយ សាមណេរពោលថា បពិត្រលោកម្ចាស់ ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ជូនពួកលោកម្ចាស់ទៅកាន់សម្នាក់ឧបជ្ឈាយ៍របស់ខ្ញុំក្ដី ព្រះឧបជ្ឈាយ៍របស់ខ្ញុំក្ដី បញ្ជូនខ្ញុំមកជាមួយលោកម្ចាស់ទាំងឡាយ ទ្រង់បានឃើញហេតុទាំងអស់នេះហើយ ទើបបញ្ជូនមក ឈប់ចុះ ខ្ញុំនេះឯងនឹងទៅ ។

សាមណេរនោះថ្វាយបង្គំភិក្ខុទាំង ៣០ រូបហើយពោលថា បពិត្រលោកម្ចាស់ បើទោសរបស់ខ្ញុំមាន សូមលោកម្ចាស់អត់ទោស ដូច្នេះហើយ ចេញ

ទៅ ការសង្វេគយ៉ាងធំ កើតឡើងដល់ពួកភិក្ខុហើយ ភ្នែកពេញទៅដោយទឹកភ្នែក ហទយៈញាប់ញ័រហើយ ។ ព្រះមហាថេរៈពោលនឹងពួកចោរថា ឧបាសក កុមារនេះ ឃើញអ្នកបង្កាត់ភ្លើង សម្រួចលំពែង ក្រាលស្លឹកឈើ នឹងខ្លាច អ្នកទាំងឡាយដាក់សាមណេរនេះក្នុងចំណែកមួយ គប្បីធ្វើកិច្ចទាំងនោះ ។ ពួកចោរនាំសាមណេរទៅក្នុងទីមួយកន្លែង ហើយធ្វើកិច្ចទាំងពួង ។

ក្នុងពេលស្រេចកិច្ច មេចោរបានហូតដាវ ដើរតម្រង់ទៅរកសាមណេរ កាលសាមណេរអង្គុយ ក៏អង្គុយចូលឈាន ។ មេចោរគ្រវីដាវតម្រង់កសាមណេរ ដាវបត់មុខទាល់នឹងមុខ ។ មេចោរនោះសម្គាល់ថា អញប្រហារមិនល្អ ទើបពត់ដាវនោះឲ្យត្រង់ហើយប្រហារទៀត ។ ដាវក៏រមូរដូចស្លឹកត្នោតរហូតដល់គល់ដាវ ។ ពិតហើយ បុគ្គលយកភ្នំសិនេរុសង្កត់សាមណេរនោះឈ្មោះថា អាចឲ្យសាមណេរស្លាប់មិនមានឡើយ នឹងពោលថ្វី ត្រឹមតែយកដាវកាប់ឲ្យស្លាប់ ។ មេចោរឃើញបាដិហារ្យនោះហើយ គិតថា កាលមុនដាវរបស់អញ រមែងកាត់សសរថ្ម ឬដង្គត់គគីរផុយដូចដើមចេក ឥឡូវនេះដាវរបស់អញម្តង ម្តងទៀតក៏រមួលដូចស្លឹកត្នោត ដាវនេះមិនមានចេតនាគង់ដឹងគុណសាមណេរនេះ ឯអញមានចេតនា ហេតុអ្វី មិនដឹង ។

មេចោរនោះបោះដាវចោលលើផែនដី យកលំពែងចាក់ក្បែរជើងរបស់សាមណេរហើយសួរថា បពិត្រលោកម្ចាស់ ខ្ញុំចូលមកក្នុងព្រៃនេះព្រោះត្រូវការទ្រព្យ បុរសមានប្រមាណមួយពាន់នាក់ឃើញពួកខ្ញុំអំពីចម្ងាយ ញាប់ញ័រ ចំប្រប់ មិនអាចនិយាយពីរបីមាត់បាន សម្រាប់លោកម្ចាស់ ត្រឹមតែការតក់

ស្មុតនៃចិត្តក៏មិនមាន មុខរបស់លោកម្ចាស់ផូរផង់ដូចមាសក្នុងស្នប់ និងដូចផ្កាកណិការដែលរីកល្អ ហេតុអ្វីហ្ន៎ ទើបពោលគាថានេះថា

ការតក់ស្លុតមិនមានដល់លោកម្ចាស់ ការខ្លាចក៏មិនមាន ពណ៌សម្បុរ ផូរផង់ក្រៃពេក ហេតុអ្វី ទើបលោកម្ចាស់ មិនសោយសោក ព្រោះភ័យធំ ដែលមានសភាពបែបនេះ ។

សាមណេរចេញអំពីឈាន កាលនឹងសម្តែងធម៌ដល់មេចោរនោះ ទើបពោលថា នែអ្នក ឈ្មោះថា អត្តភាពរបស់ព្រះខីណាស្រព រមែងដូចភារៈគឺរបស់ធ្ងន់ដែលដាក់លើក្បាល ព្រះខីណាស្រពនោះ កាលអត្តភាពនោះបែកធ្លាយទៅ រមែងត្រេកអរនោះឯង រមែងមិនខ្លាចឡើយ ដូច្នេះហើយ ក៏បានពោលគាថានេះថា

នែអ្នក ទុក្ខផ្លូវចិត្ត រមែងមិនមានដល់បុគ្គល ដែលមិនមានការជាប់ជំពាក់ លោកអ្នកដែលស្វែងរកគុណ អស់សំយោជនៈហើយ ឈានកន្លងភ័យគ្រប់យ៉ាងបាន តណ្ហាដែលនាំទៅកាន់ភពរបស់ព្រះខីណាស្រពនោះ អស់ហើយ លោកឃើញធម៌ហើយ តាមសេចក្តីពិត ឬដោយពិត ការស្លាប់របស់លោកអស់ភ័យ ដូចដាក់ភារៈចុះ ដូច្នោះ ។

មេចោរនោះស្តាប់សាមណេរនោះហើយ សម្លឹងមើលចោរ ៥០០ ពោលថា ពួកអ្នកនឹងធ្វើអ្វី ពួកចោរពោលថា ចុះលោកនាយវិញ មេចោរពោលថា កិច្ចក្នុងការគ្រប់គ្រងផ្ទះរបស់ខ្ញុំមិនមាន ព្រោះឃើញបាដិហារ្យបែបនេះ ខ្ញុំនឹង

បួសក្នុងសម្នាក់លោកម្ចាស់ ពួកចោរពោលថា ខ្ញុំក៏យ៉ាងនោះដូចគ្នា មេចោរពោលថា សាធុ លំដាប់នោះ ចោរទាំង ៥០០ ថ្វាយបង្គំសាមណេរហើយទើបសូមបព្វជ្ជា សាមណេរនោះកាត់សក់ និងសំពត់ដោយដាវរបស់ចោរទាំងនោះឯង ជ្រលក់ដោយដីក្រហម ឲ្យគ្រងកាសាវពស្ត្រទាំងនោះ ឲ្យតាំងនៅក្នុងសីល ១០ កាលនាំសាមណេរទាំងនោះទៅគិតថា បើអញមិនសួរសុខទុក្ខព្រះថេរៈទាំងឡាយ ព្រះថេរៈទាំងនោះនឹងមិនអាចធ្វើសមណធម៌បាន ចាប់តាំងពីពួកចោរចាប់អាត្មាអញមក ព្រះថេរៈទាំងនោះ សូម្បីត្រឹមតែមួយរូបក៏មិនអាចទប់ទឹកភ្នែកបាន បើព្រះថេរៈទាំងនោះគិតថា សាមណេរត្រូវចោរសម្លាប់ហើយឬនៅហ្ន៎ កម្មដ្ឋាននឹងមិនបាន ព្រោះដូច្នោះ អញសួរសុខទុក្ខលោកហើយនោះឯង សឹមទៅ ។

សាមណេរនោះមានសាមណេរ ៥០០ រូបជាបរិវារទៅក្នុងទីនោះ កាលភិក្ខុទាំងនោះ បាននូវការធូរស្បើយចិត្ត ព្រោះឃើញលោកហើយ ពោលថា សង្កិច្ចសប្បុរស លោកបានជីវិតហើយឬ ទើបឆ្លើយថា យ៉ាងនោះឯងលោកម្ចាស់ ចោរទាំងនេះប្រាថ្នាសម្លាប់ខ្ញុំឲ្យស្លាប់ ក៏មិនអាចសម្លាប់បាន ជ្រះថ្លាក្នុងគុណធម៌របស់ខ្ញុំ ស្តាប់ធម៌ហើយបួស ខ្ញុំមកដោយបំណងថាសួរសុខទុក្ខលោកម្ចាស់ហើយនឹងទៅ សូមលោកម្ចាស់ជាបុគ្គលមិនប្រមាទ ធ្វើសមណធម៌ចុះខ្ញុំនឹងទៅកាន់សម្នាក់ព្រះសាស្តា ហើយថ្វាយបង្គំភិក្ខុទាំងនោះ នាំសាមណេរក្រៅអំពីនោះទៅកាន់សម្នាក់ព្រះឧបជ្ឈាយ៍ កាលលោកសួរថា សង្កិច្ចៈ អ្នកបានអន្តេវាសិកហើយឬ ទើបឆ្លើយថា ពិតហើយ លោកម្ចាស់ ដូច្នេះហើយ

ក៏តំណាលរឿងនោះ កាលព្រះថេរៈពោលថា សង្កិច្ច: ចូរអ្នកទៅគាល់ព្រះសាស្តា លោកក៏ទទួលថា សាធុ ហើយថ្វាយបង្គំព្រះថេរ: នាំសាមណេរទាំងនោះទៅកាន់សម្នាក់ព្រះសាស្តា កាលព្រះសាស្តាត្រាស់សួរថា ម្នាលសង្កិច្ច: អ្នកបានអន្តេវាសិកហើយឬ ទើបក្រាបទូលរឿងនោះ ។

ព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា សេចក្តីនេះយ៉ាងនោះឬ កាលពួកភិក្ខុទទួលថា យ៉ាងនោះឯងព្រះអង្គ ទើបត្រាស់ថា ការតាំងនៅក្នុងសីលហើយ សូម្បីរស់នៅមួយថ្ងៃក្នុងឥឡូវនេះ ប្រសើរជាងការដែលបុគ្គលធ្វើចោរកម្ម តាំងនៅក្នុងភាពទ្រុស្តសីលអស់មួយរយឆ្នាំ ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**យោ ច វស្សសតំ ជីវេ ទុស្សីលោ អសមាហិតោ**
**ឯកាហំ ជីវិតំ សេយ្យោ សីលវន្តស្ស ឈាយិនោ ។**

បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សទ្រុស្តសីល មានចិត្តមិនបានតម្កល់ខ្ជាប់ ការរស់នៅតែមួយថ្ងៃ របស់លោកដែលមានសីល មានការពិនិត្យ ពិចារណាជាប្រក្រតីប្រសើរជាង ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ទុស្សីលោ** គឺមិនមានសីល ។ បទថា **សីលវន្តស្ស** សេចក្តីថា ការរស់នៅត្រឹមតែមួយថ្ងៃ គឺត្រឹមតែមួយរំពេចរបស់អ្នកមានសីល មានឈាន ដោយឈាន ២ ប្រការ ប្រសើរ គឺឧត្តមជាង

ការរស់នៅមួយរយឆ្នាំរបស់បុគ្គលទ្រុស្តសីល ។

ក្នុងកាលចប់ទេសនា ភិក្ខុ ៥០០ នោះសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ ធម្មទេសនាមានប្រយោជន៍ដល់មហាជន ដែលប្រជុំគ្នាហើយ ។

ដោយសម័យដទៃទៀត សង្កិច្ចៈបានឧបសម្បទាហើយ មានវស្សា ១០ ទើបទទួលសាមណេរ សាមណេរនោះជាក្មួយរបស់លោក ឈ្មោះអធិមុត្តកសាមណេរ ។ គ្រានោះ ព្រះថេរៈហៅសាមណេរនោះមកក្នុងកាលមានអាយុគ្រប់ បញ្ជូនទៅដោយពាក្យថា ខ្ញុំនឹងធ្វើការឧបសម្បទាលោក ចូរលោកទៅសួរចំនួនអាយុក្នុងសម្នាក់ពួកញាតិហើយ ចូរមក ។ អធិមុត្តកសាមេណរនោះកាលទៅកាន់សម្នាក់របស់មាតាបិតា ត្រូវពួកចោរ ៥០០ បំណងនឹងសម្លាប់ឲ្យស្លាប់ ដើម្បីធ្វើពលីកម្មក្នុងរវាងផ្លូវ សម្តែងធម៌ដល់ចោរទាំងនោះ កាលពួកចោរមានចិត្តជ្រះថ្លា ដោះលែងទៅហើយដោយពាក្យថា សូមលោកម្ចាស់កុំប្រាប់ភាពដែលពួកខ្ញុំមាននៅក្នុងទីនេះ ដល់បុគ្គលណាម្នាក់ឡើយ ឃើញមាតាបិតា ដើរបញ្ច្រាស់ផ្លូវមក រក្សាសច្ចៈ មិនប្រាប់ដល់មាតាបិតាទាំងនោះដើរទៅផ្លូវនោះឯង កាលមាតាបិតានោះ ត្រូវពួកចោរបៀតបៀន ពោលថា ប្រហែលជាលោក ក៏ជាបក្សពួកតែមួយជាមួយពួកចោរ ទើបមិនប្រាប់ដល់យើង ចោរទាំងនោះ បានឮសំឡេងហើយ ដឹងភាពដែលសាមណេរមិនប្រាប់ដល់មាតាបិតា ក៏មានចិត្តជ្រះថ្លាសូមបព្វជ្ជា ។ សូម្បីអធិមុត្តកសាមណេរនោះ ក៏ញុំាងចោរទាំងអស់នោះឲ្យបួសហើយ ដូចសង្កិច្ចសាមណេរ នាំមក

កាន់សម្នាក់ព្រះឧបជ្ឈាយ៍ ដែលព្រះឧបជ្ឈាយ៍នោះ បញ្ជូនទៅកាន់សម្នាក់ព្រះសាស្តា នាំភិក្ខុទាំងនោះ ទៅក្រាបទូលរឿងនោះដល់ព្រះសាស្តាហើយ ។ ព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា សេចក្តីនោះ យ៉ាងនេះឬ កាលពួកភិក្ខុក្រាបទូលថា ករុណា ព្រះអង្គ កាលទ្រង់បន្តអនុសន្ធិដោយន័យមុននោះឯង ទើបត្រាស់ព្រះគាថានេះថា

បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សទ្រុស្តសីល
មានចិត្តមិនបានតម្កល់ខ្ជាប់ ការរស់នៅតែមួយថ្ងៃ
របស់លោក ដែលមានសីល មានការពិនិត្យពិចារណា
ជាប្រក្រតី ប្រសើរជាង រឿងអធិមុត្តកសាមណេរ ខ្ញុំ
ក៏ពោលហើយ ដោយគាថានេះដូចគ្នា ។

**រឿង សង្កិច្ចសាមណេរ ចប់**

# រឿង ព្រះខាណុកោណ្ឌញ្ញត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះខានុកោណ្ឌញ្ញៈ ត្រាស់ព្រះគាថានេះថា **យោ ច វស្សសតំ ជីវេ** ជាដើម ។

បានឮថា ព្រះថេរៈនោះ រៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តាក្នុងព្រៃ សម្រេចអរហត្តហើយ គិតថា និងទូលលាព្រះសាស្តា កាលមកអំពីទីនោះ

ហត់នឿយក្នុងវវាងផ្លូវ គេចចេញអំពីផ្លូវ អង្គុយចូលឈានលើថ្មដាមួយកន្លែង ។ គ្រានោះ ចោរ ៥០០ ប្លន់ស្រុកមួយកន្លែងហើយ វេចទ្រព្យរបស់តាមសមគួរដល់កម្លាំងរបស់ខ្លួន យកក្បាលទូល ដើរទៅ កាលដើរទៅឆ្ងាយនឿយហត់គិតថា អញមកឆ្ងាយហើយ នឹងសម្រាកលើថ្មដានេះ គេចចេញអំពីផ្លូវទៅកាន់ទីជិតថ្មដា លុះឃើញព្រះថេរៈ ក៏មានសេចក្តីសម្គាល់ថា នេះជាដង្កត់ឈើ លំដាប់នោះ ចោរម្នាក់ដាក់បង្វេចទ្រព្យ លើសីសៈព្រះថេរៈ ។ ចោរដទៃៗ ក៏ដាក់បង្វេចទ្រព្យលើព្រះថេរៈនោះ ។ ដោយប្រការដូច្នេះ ចោរទាំង ៥០០ នាក់យកបង្វេច ៥០០ ដាក់លើព្រះថេរៈ លុះខ្លួនឯងក៏ដេកលក់ភ្ញាក់ឡើងក្នុងពេលថ្ងៃរះ ទាញបង្វេចរៀងៗ ខ្លួន បានឃើញព្រះថេរៈ ក៏ផ្តើមគេចទៅដោយសម្គាល់ថា ជាអមនុស្ស ។

វំពេចនោះ ព្រះថេរៈពោលនឹងចោរទាំងនោះថា កុំខ្លាចឡើយឧបាសកអាត្មាជាបព្វជិត ។ ចោរទាំងនោះក្រាបចុះទៀបបាទជើងព្រះថេរៈ ឲ្យព្រះថេរៈអត់ទោសដោយពាក្យថា សូមលោកម្ចាស់អត់ទោសចុះ ពួកខ្ញុំសម្គាល់ថាដង្កត់ឈើ កាលមេចោរប្រាប់ថា ខ្ញុំនឹងបួសក្នុងសម្នាក់លោកម្ចាស់ ពួកចោរដ៏សេសក៏ពោលថា ពួកខ្ញុំក៏នឹងបួស មានធន្ទៈតែមួយសូមបព្វជ្ជានឹងព្រះថេរៈ ។ ព្រះថេរៈបានឲ្យចោរទាំងអស់នោះបួស ដូចសន្និចូសាមណេរដែរ ។ ចាប់តាំងអំពីនោះ ព្រះថេរៈប្រាកដឈ្មោះថា ខានុកោណ្ឌញ្ញៈ ។ លោកទៅកាន់សម្នាក់ព្រះសាស្តា មួយអន្លើដោយភិក្ខុទាំងនោះ ។ កាលព្រះសាស្តាត្រាស់សួរថា ម្នាលកោណ្ឌញ្ញៈ អ្នកបានអន្តេវាសិកហើយឬ ទើបក្រាបទូលរឿងនោះ ។

ព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា សេចក្តីនេះយ៉ាង នោះឬ កាលភិក្ខុទាំងនោះទទួលថា ករុណាព្រះអង្គ ពួកខ្ញុំព្រះអង្គមិនធ្លាប់ឃើញ អានុភាពបែបនោះរបស់បុគ្គលដទៃឡើយ ដោយហេតុនោះ ទើបពួកខ្ញុំព្រះអង្គ បួស ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការរស់នៅមួយថ្ងៃរបស់ពួក អ្នក ប្រព្រឹត្តក្នុងបញ្ញាសម្បទាក្នុងឥឡូវនេះ ប្រសើរជាងការតាំងនៅក្នុងកម្ម របស់បុគ្គលដែលមានបញ្ញាថោកថយបែបនោះ ដែលរស់នៅអស់មួយរយឆ្នាំ ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**យោ ច វស្សសតំ ជីវេ ទុប្បញ្ញោ អសមាហិតោ**
**ឯកាហំ ជីវិតំ សេយ្យោ បញ្ញវន្តស្ស ឈាយិនោ ។**

បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សមិនមានប្រាជ្ញា មាន ចិត្តមិនបានតម្កល់ខ្ជាប់ ការរស់នៅតែមួយថ្ងៃរបស់លោកដែល មានប្រាជ្ញា មានការពិនិត្យពិចារណាជាប្រក្រតី ប្រសើរជាង ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ទុប្បញ្ញោ** សេចក្តីថា ជាអ្នកឥតបញ្ញា ។ បទថា **បញ្ញវន្តស្ស** សេចក្តីថា ដែលប្រព្រឹត្តទៅដោយបញ្ញា ។ ពាក្យ ដ៏សេស ដូចគ្នានឹងពាក្យដែលមានក្នុងកាលមុននោះឯង ។

ក្នុងកាលចប់ទេសនា ភិក្ខុ ៥០០ រូប សម្រេចអរហត្ត មួយអន្លើដោយ បដិសម្ភិទាហើយ ។ ព្រះធម្មទេសនាមានប្រយោជន៍ដល់មហាជនដែលប្រជុំ គ្នាហើយដូច្នេះឯង ។៚

# រឿង ព្រះសប្បទាសត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសប្បទាសត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **យោ ច វស្សសតំ ជីវេ** ជាដើម ។

បានឮមកថា កុលបុត្រម្នាក់ក្នុងក្រុងសាវត្ថី ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយ បព្វជ្ជា បានឧបសម្បទាហើយ ដោយសម័យដទៃទៀត ក៏អផ្សុកឡើង ទើបគិតថា ឈ្មោះថា ភាវៈនៃគ្រហស្ថ មិនគួរដល់កុលបុត្រដូចអញ សូម្បីការតាំងនៅក្នុងបព្វជ្ជាហើយស្លាប់ទៅ ជាការល្អរបស់អញ ដូច្នេះហើយ ក៏ត្រាច់រកឧបាយដើម្បីការស្លាប់របស់ខ្លួន ។

ថ្ងៃមួយ ភិក្ខុទាំងឡាយស្រង់ទឹកអំពីព្រលឹម ធ្វើភត្តកិច្ចស្រេចហើយ ទៅកាន់វិហារ ឃើញពស់ត្រង់រោងភ្លើង ទើបដាក់ពស់នោះក្នុងថ្នាំងមួយ បិទគម្របហើយ កាន់ចេញអំពីវិហារ ។ ចំណែកភិក្ខុដែលអផ្សុកធ្វើភត្តកិច្ចហើយ ដើរមកឃើញភិក្ខុទាំងនោះ ទើបសួរថា អាវុសោ នេះជាអ្វី កាលពួកភិក្ខុប្រាប់ថា អាវុសោ គឺពស់ ទើបសួរថា តើធ្វើអ្វីដល់ពស់នេះ ភិក្ខុទាំងនោះប្រាប់ថា យកវាទៅចោល ទើបភិក្ខុនោះគិតថា អញនឹងឲ្យពស់នេះចឹកស្លាប់ ទើបពោលថា យកមកចុះខ្ញុំនឹងចោលឲ្យ ទទួលថ្នាំងអំពីដៃរបស់ភិក្ខុទាំងនោះហើយ អង្គុយក្នុងទីមួយ ក៏ឲ្យពស់នោះចឹក ។ ពស់មិនប្រាថ្នានឹងចឹក ភិក្ខុនោះយកដៃលូកចូលក្នុងថ្នាំងហើយ ត្រឡប់ខាងនោះខាងនេះ ហែកមាត់ពស់ហើយ ស៊កម្រាមដៃចូលទៅ ពស់ក៏មិនចឹកលោកឡើយ ។ លោកគិតថា

ពស់នេះមិនមែនពស់ពិស ជាពស់ផ្ទះ ទើបលែងពស់នោះ ហើយទៅកាន់វិហារ ។

លំដាប់នោះ ភិក្ខុទាំងឡាយពោលនឹងលោកថា អាវុសោ លោកលែងពស់ហើយឬ ភិក្ខុអផ្សុកពោលថា អាវុសោ នុ៎ះមិនមែនពស់ពិស ជាពស់ផ្ទះ ភិក្ខុពោលថា អាវុសោ ពស់នោះជាពស់ពិសនោះឯង បើកពពារធំបញ្ចេញសំឡេងស៊ូតៗ ខ្ញុំចាប់បានដោយលំបាក ព្រោះហេតុអ្វី ទើបលោកពោលយ៉ាងនេះ ភិក្ខុអផ្សុកពោលថា អាវុសោ ខ្ញុំឲ្យពស់នោះចឹកអាវយវៈខ្លះ ស៊កដៃចូលក្នុងមាត់ខ្លះ ក៏មិនអាចឲ្យវាចឹកបាន ។

ពួកភិក្ខុស្ដាប់ពាក្យនោះហើយ ក៏អង្គុយស្ងៀម ។ ថ្ងៃក្រោយមក ខ្ទាន់ព្រះកេសកាន់កាំបិតកោរ ២-៣ ដើមទៅវិហារ ដាក់កាំបិតកោរមួយនៅត្រង់ផែនដី យកកាំបិតកោរមួយកោរសក់របស់ភិក្ខុទាំងឡាយ ។ ទើបភិក្ខុអផ្សុកនោះចាប់កាំបិតកោរដែលនៅត្រង់ផែនដី ហើយគិតថា អញអារ-កដោយកាំបិតកោរនេះ ទើបឈរផ្អែកត្រង់ដើមឈើមួយដើម ហើយដាក់កាំបិតត្រង់បំពង់ក ពិចារណាដល់សីលរបស់ខ្លួន តាំងអំពីកាលឧបសម្បទា បានឃើញសីលមិនមានមន្ទិល ដូចព្រះចន្ទប្រាសចាកមន្ទិល និងដូចមណ្ឌលនៃកែវមណីដែលគេខាត់ល្អហើយ កាលលោកពិចារណាមើលសីលនោះ បីតិកើតផ្សាយទៅពេញសរីរៈ ។ លោកសង្កត់បីតិបានហើយ ចម្រើនវិបស្សនា សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ ទើបកាន់កាំបិតកោរចូលទៅកណ្ដាលវិហារ ។ លំដាប់នោះ ភិក្ខុទាំងឡាយសួរលោកថា អាវុសោ លោក

ទៅណា ភិក្ខុអផ្សុកពោលថា អាវុសោ ខ្ញុំទៅដោយគិតថា នឹងយកកាំបិតកោរនេះអារបំពង់ក ភិក្ខុទាំងនោះពោលថា បើដូច្នោះ ហេតុអ្វីក៏មិនស្លាប់ ភិក្ខុអផ្សុកពោលថា ឥឡូវនេះ ខ្ញុំជាបុគ្គលមិនគួរនាំសស្ត្រាមក ព្រោះខ្ញុំគិតថា នឹងកាត់បំពង់កដោយកាំបិតកោរនេះ តែបែរជាកាត់កិលេសអស់ ដោយកាំបិតកោរ គឺញាណ ។ ពួកភិក្ខុក្រាបទូលដល់ព្រះដ៏មានព្រះភាគថា ភិក្ខុនេះព្យាករអរហត្ត ដោយពាក្យមិនពិត ព្រះដ៏មានព្រះភាគ ទ្រង់ស្តាប់ពាក្យរបស់ភិក្ខុទាំងនោះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាព្រះខីណាស្រព មិនផ្តាច់ជីវិតដោយដៃរបស់ខ្លួនឡើយ ពួកភិក្ខុទូលថា បពិត្រព្រះអង្គ ទ្រង់ត្រាស់ថា ភិក្ខុនេះជាព្រះខីណាស្រព ភិក្ខុនេះសម្បូរដោយឧបនិស្ស័យនៃព្រះអរហត្តយ៉ាងនេះ ហេតុអ្វី ទើបអផ្សុក អ្វីជាហេតុនៃឧបនិស្ស័យនៃអរហត្តរបស់ភិក្ខុនោះ ហេតុអ្វី ទើបពស់មិនចឹកភិក្ខុនោះ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ ពស់នោះ ជាខ្ញុំប្រុសរបស់ភិក្ខុនេះក្នុងអត្តភាពទី ៣ បន្ទាប់អំពីអត្តភាពនេះ ពស់នោះ មិនអាចខាំសរីរៈរបស់បុគ្គលដែលជាចៅហ្វាយបាន ។

ព្រះសាស្តាទ្រង់ត្រាស់ប្រាប់ហេតុមួយ ដល់ភិក្ខុទាំងនោះ ដោយប្រការដូច្នេះ តាំងអំពីនោះមក ភិក្ខុនោះ បានឈ្មោះថា សប្បទាសៈ ។

បានឮមកថា ក្នុងកាលនៃព្រះកស្សបសម្ពុទ្ធ បុត្រនៃគហបតីម្នាក់ស្តាប់ធម៌របស់ព្រះសាស្តាហើយ កើតការសង្វេគ ទើបបព្វជ្ជា បានឧបសម្បទាហើយ ។ សម័យក្រោយមកទៀត កាលការនឿយណាយកើតឡើង ទើបប្រាប់ដល់ភិក្ខុដែលជាសម្លាញ់មួយរូប ។ សម្លាញ់នោះ ពោលទោសក្នុងការៈ

នៃគ្រហស្ថ ដល់លោករឿយៗ ភិក្ខុនោះស្ដាប់ពាក្យនោះហើយ ក៏ត្រេកអរក្នុងព្រះសាសនា អង្គុយជុសសមណបរិក្ខារទាំងឡាយ ដែលមានប្រេះចាប់ក្នុងកាលដែលលោកនៅឿយណាយអំពីមុន ឲ្យអស់មន្ទិលក្បែរមាត់ស្រះមួយកន្លែង ចំណែកសម្លាញ់របស់ភិក្ខុនោះ អង្គុយក្នុងទីជិតនោះឯង ។ គ្រានោះភិក្ខុនោះពោលនឹងសម្លាញ់នោះយ៉ាងនេះថា អាវុសោ បើខ្ញុំសឹក នឹងឲ្យបរិក្ខារទាំងនេះដល់លោក ។ សម្លាញ់នោះ មានការចង់បានកើតឡើង គិតថា អញត្រូវការអ្វីដោយភិក្ខុនេះ ដែលនៅបួស ឬសឹក ឥឡូវនេះ អញនឹងញ៉ាំងបរិក្ខារទាំងឡាយឲ្យវិនាស ។ តាំងអំពីនោះមក សម្លាញ់នោះនិយាយពាក្យជាដើមថា អាវុសោ ឥឡូវនេះ ប្រយោជន៍អ្វីដល់ជីវិតរបស់ពួកយើង ដែលមានដៃកាន់អំបែង ត្រាច់ទៅដើម្បីដុំបាយក្នុងត្រកូលដទៃ ថែមទាំងមិនបានសន្ទនាប្រាស្រ័យនឹងបុត្រភរិយា ដូច្នេះហើយ ក៏ពោលគុណនៃភាវៈរបស់គ្រហស្ថ ។ ភិក្ខុនោះស្ដាប់ពាក្យសម្លាញ់នោះហើយ ក៏អផ្សុកម្ដងទៀត គិតថា សម្លាញ់នេះ កាលអញពោលថា ខ្ញុំអផ្សុក ក៏ពោលទោសក្នុងភាវៈនៃគ្រហស្ថ ឥឡូវនេះ ពោលដល់គុណរឿយៗ សេចក្ដីនេះដូចម្ដេចហ្ន៎ ក៏ដឹងថា ព្រោះចង់បានក្នុងសមណបរិក្ខារទាំងនេះ ទើបត្រឡប់ចិត្តរបស់ខ្លួន ដោយខ្លួនឯងនោះឯង ព្រោះភាពដែលភិក្ខុមួយរូប ត្រូវខ្លួនធ្វើឲ្យអផ្សុកហើយ ក្នុងកាលនៃព្រះកស្សបសម្ពុទ្ធ ឥឡូវនេះ ទើបការអផ្សុកកើតឡើងដល់ភិក្ខុនោះ ដោយប្រការដូច្នេះ ។ សមណធម៌ណា ដែលភិក្ខុនោះបំពេញមកពីរម៉ឺនឆ្នាំ សមណធម៌នោះ បានជាឧបនិស្ស័យនៃអរហត្តរបស់ភិក្ខុនោះក្នុងកាលឥឡូវនេះឯង ។

ភិក្ខុទាំងនោះ ស្តាប់សេចក្តីនេះអំពីសម្នាក់ព្រះដ៏មានព្រះភាគ ទើបទូលសួរក្រៃលែងឡើងថា បពិត្រព្រះអង្គ បានឮថា ភិក្ខុនេះ ឈរយកកាំបិតកោរផ្គងត្រង់បំពង់ករ ហើយសម្រេចអរហត្ត អរហត្តមគ្គកើតឡើងបាន ដោយខណៈមានប្រមាណប៉ុណ្ណោះឬ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង កាលភិក្ខុប្រារព្ធព្យាយាម លើកជើងឡើង ដាក់លើផែនដី កាលជើងមិនទាន់ដល់ផែនដី អរហត្តមគ្គក៏បានកើតឡើង ពិតណាស់ ការរស់នៅត្រឹមមួយជួរខណៈរបស់បុគ្គល ដែលប្រារព្ធព្យាយាម ប្រសើរជាងការរស់នៅមួយរយឆ្នាំ របស់បុគ្គលខ្ជិលច្រអូស ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**យោ ច វស្សសតំ ជីវេ កុសីតោ ហីនវីរិយោ**
**ឯកាហំ ជីវិតំ សេយ្យោ វីរិយំ អារភតោ ទឡ្ហំ ។**

បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សមានចិត្តនុំរង់ក្នុងអកុសលវិតក្ក មានព្យាយាមថោកថយ ការរស់នៅសូម្បីតែមួយថ្ងៃ របស់លោកដែលប្រារព្ធសេចក្តីព្យាយាមមាំមួន ប្រសើរជាង ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **កុសីតោ** បានដល់ បុគ្គលដែលញ៉ាំងកាលឲ្យកន្លងទៅដោយវិតក្ក ៣ មានកាមវិតក្កជាដើម ។ បទថា **ហីនវីរិយោ** គឺ មិនមានសេចក្តីព្យាយាម ។

*បាទព្រះគាថាថា* **វីរិយំ អារភតោ ទឡ្ហំ** *សេចក្តីថា បុគ្គលប្រារព្ធ សេចក្តីព្យាយាមមាំទាំ ឈ្មោះថា អាចញុំាងឈាន ២ ប្រការឲ្យកើត ។ ពាក្យដ៏សេស ដូចគ្នានឹងពាក្យដែលមានក្នុងកាលមុននោះឯង ។*

*ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើម ដូច្នេះឯង ។ល។*

រឿង ព្រះសប្បទាសត្ថេរ ចប់

# រឿង នាងបដាចារា

## លំនាំដើម

*ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះនាងបដាចា-ថេរី ត្រាស់ព្រះធម្មទេសនានេះថា* **យោ ច វស្សសតំ ជីវេ** *ជាដើម ។*

*បានឮមកថា នាងបដាចារានោះ ជាធីតារបស់សេដ្ឋីអ្នកមានទ្រព្យ ៤០ កោដិ ក្នុងក្រុងសាវត្ថី មានរូបស្រស់ត្រកាល ពេលមានអាយុ ១៦ ឆ្នាំ ម្តាយ ឪពុកកាលរក្សា ទើបឲ្យនាងនៅលើប្រាសាទជាន់ទី ៧ ។ កាលបើដូច្នោះ នាង ក៏នៅតែសមាគមជាមួយបុរសអ្នកបម្រើរបស់ខ្លួន ។ កាលនោះមាតាបិតារបស់ នាង លើកឲ្យដល់បុរសកំលោះម្នាក់ ក្នុងត្រកូលដែលមានជាតិស្មើគ្នា ហើយ កំណត់ថ្ងៃវិវាហៈ ។ កាលថ្ងៃវិវាហៈនោះជិតចូលមកដល់ នាងក៏ពោលនឹងអ្នក បម្រើប្រុសនោះថា បានឮថា ឪពុកម្តាយខ្ញុំ លើកខ្ញុំឲ្យដល់ត្រកូលឈ្មោះនោះ*

ក្នុងកាលដែលខ្ញុំទៅកាន់ត្រកូលប្តី អ្នក សូម្បីកាន់បណ្ណាការដើម្បីខ្ញុំមកហើយ ក៏នឹងមិនបានចូលទៅក្នុងទីនោះ បើអ្នកស្រឡាញ់ខ្ញុំ សូមនាំខ្ញុំគេចទៅដោយផ្លូវណាមួយក្នុងកាលឥឡូវនេះឯង ។ អ្នកបម្រើនោះទទួលថា សាធុនាង ហើយពោលថា បើយ៉ាងនោះ ខ្ញុំនឹងឈរក្នុងទីឈ្មោះនោះនៃទ្វារក្រុងអំពីព្រលឹមស្អែកនេះ នាងគប្បីចេញទៅដោយឧបាយណាមួយហើយ មកក្នុងទីនោះ ក្នុងថ្ងៃទី ២ ក៏ឈរក្នុងទីដែលបានមត់គ្នា ។

ចំណែកធីតាសេដ្ឋីនោះ ស្លៀកសំពត់ចាស់ៗ រំសាយសក់ យកកន្ទក់លាបខ្លួន កាន់ក្អមទឹកចេញអំពីផ្ទះ ដើរទៅជាមួយពួកទាសី បានទៅកាន់ទីនោះអំពីព្រលឹម អ្នកបម្រើនោះ នាំនាងទៅឆ្ងាយហើយ សម្រេចការអាស្រ័យនៅក្នុងស្រុកមួយកន្លែង ភ្ជួរស្រែក្នុងព្រៃហើយ បាននាំឧស និងបន្លែជាដើមមក ។ ធីតាសេដ្ឋីនាំយកក្អមទឹកមកហើយ ធ្វើកិច្ច មានការបុកអង្ករ និងចម្អិនជាដើមដោយដៃខ្លួនឯង សោយផលនៃអំពើអាក្រក់របស់ខ្លួន ។ គ្រានោះ សត្វកើតក្នុងគភ៌តាំងឡើងក្នុងផ្ទៃរបស់នាងហើយ នាងមានគភ៌ចាស់ហើយ អង្វរប្តីថា ជនឯណានីមួយជាអ្នកឧបការៈរបស់យើងមិនមានក្នុងទីនេះ ធម្មតាមាតាបិតាជាអ្នកមានចិត្តទន់ភ្លន់ក្នុងបុត្រទាំងឡាយ ចូរអ្នកនាំខ្ញុំទៅកាន់សម្នាក់របស់លោកចុះ ខ្ញុំនឹងប្រសូតបុត្រក្នុងទីនោះ ។ ស្វាមីនោះជំទាស់ថា នែនាង នាងនិយាយអ្វី មាតាបិតារបស់នាងឃើញខ្ញុំហើយ គប្បីធ្វើទណ្ឌកម្មផ្សេងៗ ខ្ញុំមិនអាចទៅក្នុងទីនោះបានទេ ។ សូម្បីនាងអង្វរហើយអង្វរទៀត ក៏មិនបានទូវការយល់ព្រម ក្នុងកាលដែលប្តីនោះទៅព្រៃ ទើបហៅមនុស្សដែលស្និទ្ធស្នាលមកផ្តាំថា

បើប្តីខ្ញុំមកមិនឃើញខ្ញុំ បើគាត់សួរថា ខ្ញុំទៅណា សូមអ្នកប្រាប់គាត់ដែលខ្ញុំទៅកាន់ផ្ទះនៃត្រកូលរបស់ខ្លួន ដូច្នេះហើយ ក៏បិទទ្វារផ្ទះចៀសចេញទៅ ។

ចំណែកស្វាមីនោះមកហើយ មិនឃើញភរិយានោះ ទើបសួរអ្នកស្និទ្ធស្នាល ស្តាប់រឿងនោះហើយ ក៏រត់តាមទៅ ដោយគិតថា នឹងឲ្យនាងត្រឡប់ ជួបនាងហើយ អង្វរដោយប្រការផ្សេងៗ ក៏មិនអាចឲ្យនាងត្រឡប់បាន ។ ពេលនោះ ខ្យល់កម្មជ្ជវាតរបស់នាងក៏កម្រើកហើយក្នុងទីមួយកន្លែង នាងចូលទៅក្នុងរវាងគុម្ពឈើមួយ ពោលថា នែអ្នក ខ្យល់កម្មជ្ជវាតរបស់ខ្ញុំកម្រើកហើយ ដេកបម្រះនទៀលលើផែនដី ប្រសូតទារកដោយលំបាក ហើយគិតថា អញគប្បីទៅកាន់ផ្ទះនៃត្រកូលដើម្បីប្រយោជន៍ណា ប្រយោជន៍នោះសម្រេចហើយ ទើបត្រឡប់មកកាន់ផ្ទះជាមួយស្វាមី សម្រេចការនៅជាមួយគ្នាទៀត ។

សម័យក្រោយមក គភ៌របស់នាងក៏មានទៀត ។ នាងមានគភ៌ចាស់ហើយ ទើបអង្វរប្តីដោយន័យមុននោះឯង កាលមិនបាននូវការយល់ព្រម ទើបពកូនដោយចង្កេះចៀសចេញទៅយ៉ាងនោះឯង ត្រូវប្តីនោះរត់តាមទៅទាន់ហើយ ក៏មិនប្រាថ្នានឹងត្រឡប់ ។

គ្រានោះ កាលជនទាំងនោះដើរទៅ មហាមេឃពុំជូកាលកើតឡើង ។ ផ្ទៃលម្ហមានផ្គរទឹកធ្លាក់ចុះមិនមានចន្លោះ ផ្លេកបន្ទោរវាសធ្លៀលធ្លាត់ដោយជុំវិញ ហាក់ដូចទម្លាយចុះនូវសំឡេងគ្រហឹមនៃមេឃ ។ ខណៈនោះ ខ្យល់កម្មជ្ជវាតរបស់នាងកម្រើកហើយ នាងហៅស្វាមីមកពោលថា នែអ្នក ខ្យល់

កម្មជវាតរបស់ខ្ញុំកម្រើកហើយ ខ្ញុំមិនអាចអត់ធន់បាន សូមអ្នកដឹងទីដែលភ្លៀងមិនប៉ះពាល់ខ្ញុំចុះ ។ ប្តីនោះមានកាំបិតនៅក្នុងដៃ ក្រឡេកមើលឆ្វេងស្តាំឃើញគុម្ពឈើដែលកើតនៅលើដំបូកមួយកន្លែងហើយផ្តើមនឹងកាប់ ។ លំដាប់នោះអាសិរពិសកាច លូនចេញមកអំពីដំបូក ចឹកបុរសនោះក្នុងខណៈនោះឯង ។ សរីរៈរបស់បុរសនោះ មានពណ៌ខៀវដូចត្រូវភ្លើងឆេះ តាំងឡើងខាងក្នុងដួលចុះក្នុងទីនោះឯង ចំណែកកកិរិយាសោយទុក្ខមហន្ត ចាំមើលផ្លូវរបស់ប្តីមិនបានឃើញ ទើបប្រសូតបុត្រម្នាក់ឯងទៀត ។ ទារកទាំង ២ អត់ធន់នឹងកម្លាំងខ្យល់ និងភ្លៀងមិនបាន ក៏យំរំពង ។ នាងយកទារកទាំង ២ ដាក់ក្រោមដើមទ្រូង លត់ជង្គង់លើផែនដី ដៃទាំងពីរប្រចត់ទប់ខ្លួន ឲ្យរាត្រីកន្លងទៅហើយ សរីរៈទាំងមូលដូចគ្នានឹងស្លឹកឈើពណ៌លឿង ហាក់ដូចមិនមានឈាម ។ កាលថ្ងៃរះឡើង នាងបីបុត្រម្នាក់ ដែលមានពណ៌ដូចដុំសាច់ត្រង់ចង្កេះ ដៃម្ខាងដឹកដៃកូនច្បង ពោលថា មកចុះបា ឪពុករបស់អ្នកទៅដោយផ្លូវនេះ ដូច្នេះហើយ ក៏ដើរតាមផ្លូវដែលប្តីទៅ ឃើញប្តីនោះដួលស្លាប់លើដំបូក មានពណ៌ខៀវ ខ្លួនរឹងក្រញាង ទ្រហោយំរៀបរាប់ថា ព្រោះអាស្រ័យខ្ញុំ ទើបអ្នកស្លាប់ក្នុងផ្លូវនេះ ដូច្នេះហើយ ធ្វើដំណើរទៅ ។

នាងឃើញស្ទឹងអចិរវតី ពេញប្រៀបដោយទឹកត្រឹមក្បាលជង្គង់ ត្រឹមដោះ ព្រោះភ្លៀងធ្លាក់មួយយប់ទល់ភ្លឺ មិនអាចចុះទឹកមួយអន្លើដោយទារកពីរនាក់បាន ព្រោះខ្លួនមិនសូវចេះហែលទឹក ទើបដាក់បុត្រច្បងនៅត្រង់ត្រើយអាយ បីកូនប្អូន ទៅកាន់ត្រើយនាយ ក្រាលមែកឈើឲ្យទារកដេកហើយ

គិតថា នឹងទៅនាំបុត្រក្រៅអំពីនេះ មិនអាចលះបង់កូនតូចបាន ត្រឡប់មកមើលហើយមើលទៀតដើរទៅ ។ ក្នុងកាលដែលនាងដល់កណ្តាលស្ទឹង ខ្លែងមួយឃើញក្មេងនោះ ទើបបោះពួយចុះមកអំពីអាកាស ដោយសម្គាល់ថាជាដុំសាច់ នាងឃើញខ្លែងបោះពួយចុះមកដើម្បីបុត្រ ទើបលើកដៃទាំងពីរឡើងស្រែកដោយសំឡេងខ្លាំង ៣ ដងថា សូក ! សូក ! ខ្លែងមិនបានឮសំឡេងនោះ ព្រោះនៅឆ្ងាយ ទើបខ្វាំទារកហើរឡើងទៅកាន់អាកាសហើយ ។ បុត្រដែលឈរត្រើយអាយ ឃើញមាតាលើកដៃទាំងពីរឡើង ស្រែកដោយសំឡេងខ្លាំង កណ្តាលស្ទឹង ទើបលោតចុះទៅក្នុងស្ទឹងដោយរហ័ស ដោយសម្គាល់ថា ម្តាយហៅ ។ ខ្លែងចាបកូនខ្ចីរបស់នាងទៅ កូនច្បងត្រូវទឹកកួចទៅ ដោយប្រការដូច្នេះ ។

នាងដើរយំរៀបរាប់ថា កូនរបស់ខ្ញុំម្នាក់ត្រូវខ្លែងចាបទៅ កូនម្នាក់ត្រូវទឹកកួចទៅ ប្តីក៏ស្លាប់ក្នុងអធ្វា ជួបបុរសម្នាក់ដើរមកអំពីក្រុងសាវត្ថី ទើបសួរថា នែអ្នក អ្នកនៅទីណា បុរសនោះឆ្លើយថា ខ្ញុំនៅក្នុងក្រុងសាវត្ថី ធីតាសេដ្ឋីពោលថា ត្រកូលឈ្មោះនោះនៅក្បែរផ្លូវឈ្មោះនោះក្នុងក្រុងសាវត្ថីមាន តើអ្នកជ្រាបឬទេ បុរសនោះពោលថា នែនាង ខ្ញុំជ្រាប តែកុំសួរដល់ត្រកូលនោះអី បើនាងស្គាល់ត្រកូលដទៃ ក៏ចូរសួរចុះ ។

ធីតាសេដ្ឋីពោលថា កម្មដោយត្រកូលដទៃរបស់ខ្ញុំមិនមាន ខ្ញុំសួរដល់ត្រកូលនោះប៉ុណ្ណោះឯង បុរសនោះពោលថា នែនាង បើខ្ញុំប្រាប់ក៏មិនគួរ ធីតាសេដ្ឋីពោលថា សូមប្រាប់ខ្ញុំមកចុះ បុរសនោះពោលថា ថ្ងៃនេះ នាងឃើញ

ភ្លៀងធ្លាក់មួយយប់ទល់ភ្លឺដែរឬទេ ធីតាសេដ្ឋីពោលថា ខ្ញុំឃើញ ភ្លៀងនោះធ្លាក់មួយយប់ទល់ភ្លឺ ដើម្បីខ្ញុំប៉ុណ្ណោះ មិនមែនធ្លាក់ដើម្បីអ្នកដទៃឡើយ តែខ្ញុំនឹងប្រាប់ហេតុដែលភ្លៀងធ្លាក់ដើម្បីខ្ញុំដល់អ្នក ក្នុងកាលជាក្រោយ សូមអ្នកប្រាប់ការប្រព្រឹត្តទៅក្នុងផ្ទះរបស់សេដ្ឋីនោះដល់ខ្ញុំមុន ។ បុរសនោះ ពោលថា នែនាង ថ្ងៃនេះ ក្នុងកណ្តាលយប់ ផ្ទះរលំសង្កត់ជនទាំង ៣ គឺសេដ្ឋី ១ ភរិយាសេដ្ឋី ១ បុត្រសេដ្ឋី ១ ជនទាំង ៣ នោះ ត្រូវដុតលើជើងថ្ករតែមួយ នែនាង នុ៎ះផ្សែង កំពុងប្រាកដនៅឡើយ ។

ក្នុងខណៈនោះ នាងមិនដឹងសំពត់របូត ដល់នូវភាពជាមនុស្សវិកលចរិតហើយឈរផ្អឹង ទ្រហោយំរៀបរាប់ថា កូនពីរនាក់ស្លាប់ហើយ ប្តីរបស់ខ្ញុំក៏ស្លាប់ត្រង់អធ្វា មាតាបិតា និងបងប្រុស ក៏ត្រូវដុតលើជើងថ្ករតែមួយ ។

មនុស្សទាំងឡាយឃើញនាងហើយ សម្គាល់ថា ជាស្រីឆ្កួត ទើបកាន់យកសំរាម ធូលីរោយលើក្បាល គ្រវែងដោយដុំដី ។

ព្រះសាស្តា ប្រថាប់គង់សម្តែងធម៌ក្នុងកណ្តាលបរិស័ទ ៤ ក្នុងជេតពនមហាវិហារ បានទតឃើញនាងដែលបំពេញបារមីមកមួយសែនកប្ប សម្បូរដោយអភិនីហារដើរមក ។

បានឮថា ក្នុងកាលនៃព្រះពុទ្ធព្រះនាមបទុមុត្តរៈ នាងបដាចារានេះ ឃើញព្រះថេរី អ្នកទ្រទ្រង់វិន័យមួយរូប ដែលព្រះបទុមុត្តរសាស្តា ស្ថាបនាក្នុងតំណែងឯតទគ្គៈ ដូចសក្កទេវរាជ ចាប់ត្រង់ដើមដៃ យកទៅដាក់ទុកក្នុងឧទ្យាននន្ទនវ័ន ទើបធ្វើគុណ គឺសេចក្តីល្អហើយ តាំងសេចក្តីប្រាថ្នាថា ខ្ញុំម្ចាស់

គប្បីបានតំណែងកំពូលជាងព្រះថេរី ខាងទ្រទ្រង់វិន័យទាំងឡាយ ក្នុងសម្នាក់ព្រះពុទ្ធដូចព្រះអង្គ ។ ព្រះបទុមុត្តរៈ ទ្រង់ទតអនាគតដោយអនាគតំសញ្ញាណ ក៏ទ្រង់ជ្រាបថា ការប្រាថ្នានឹងសម្រេច ទើបទ្រង់ព្យាករថា ក្នុងអនាគត ស្រីនេះ នឹងបានជាកំពូលជាងព្រះថេរី ខាងទ្រទ្រង់វិន័យទាំងឡាយ មានឈ្មោះថា បដាចារា ក្នុងសាសនារបស់ព្រះគោតមសម្ពុទ្ធ ។

ព្រះសាស្តា ទ្រង់ឃើញនាងមានសេចក្តីប្រាថ្នាតាំងទុកហើយយ៉ាងនោះ ជាអ្នកសម្បូរដោយអភិនីហារ កំពុងដើរមកអំពីចម្ងាយ ទ្រង់ព្រះតម្រិះថា លើកលែងតថាគតចេញហើយ អ្នកដទៃឈ្មោះថា អាចជាទីពឹងរបស់ស្រីនេះ មិនមាន ទើបទ្រង់ធ្វើនាងដោយប្រការ ដែលនាងបែរមុខមកកាន់វិហារដើរមក ។

បរិស័ទឃើញនាងហើយ ទើបពោលថា អ្នកទាំងឡាយ កុំឲ្យស្រីឆ្កួតនេះ មកទីនេះ ។ ព្រះសាស្តាត្រាស់ថា ចូរពួកអ្នកចៀសចេញ ទៅកុំឃាត់នាងឡើយ ក្នុងពេលនាងចូលមកជិត ទើបត្រាស់ថា ម្នាលប្អូនស្រី ចូរនាងបាននូវស្មារតីចុះ ។ នាងត្រឡប់បានសតិដោយពុទ្ធានុភាពក្នុងខណៈនោះឯង ។ ក្នុងពេលនោះ នាងកំណត់ភាពដែលសំពត់ របូតបានហើយ កើតនូវហិរិ-ឱត្តប្បៈឡើង ទើបអង្គុយចុះ ។

គ្រានោះ បុរសម្នាក់ បោះសំពត់ដណ្តប់ឲ្យនាង នាងស្លៀកសំពត់នោះ ហើយចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំដោយបញ្ចង្គប្រដិស្ឋានទៀបបាទមូលទាំងទ្វេ ដែលមានពណ៌ដូចមាស ហើយទូលថា បពិត្រព្រះអង្គ សូមទ្រង់

ជាទីពឹងរបស់ខ្ញុំម្ចាស់ចុះ ព្រោះថា ខ្លែងឆាបកូនម្នាក់របស់ខ្ញុំម្ចាស់ទៅ កូនម្នាក់ ត្រូវទឹកបន្សាត់ទៅ ប្ដីស្លាប់កណ្ដាលអធ្វា មាតាបិតា និងបងប្រុសត្រូវផ្ទះសង្កត់ស្លាប់ ដុតលើជើងថ្ករតែមួយ ។

ព្រះសាស្ដា ទ្រង់ស្ដាប់ពាក្យរបស់នាង ទើបត្រាស់ថា កុំគិតឡើយបដាចារា នាងមកកាន់សម្នាក់របស់បុគ្គល ដែលអាចជាទីពឹងរបស់នាងបានហើយ ឥឡូវនេះ ទោះជាកូនម្នាក់របស់នាងត្រូវខ្លែងឆាបទៅ កូនម្នាក់ត្រូវទឹកកួចទៅ ប្ដីស្លាប់ហើយត្រង់អធ្វន មាតាបិតា និងបងប្រុសត្រូវផ្ទះបាក់សង្កត់យ៉ាងណា ទឹកភ្នែកដែលហូររបស់នាង ដែលយំក្នុងសង្សារនេះ ក្នុងកាលដែលបិយជន មានកូនជាដើមស្លាប់ គង់ច្រើនជាងទឹកក្នុងមហាសមុទ្រទាំង ៤ ក៏ដូច្នោះដូចគ្នា ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

ទឹកក្នុងមហាសមុទ្រទាំង ៤ មានប្រមាណតិច ទឹក
ភ្នែករបស់បុគ្គល ដែលត្រូវសេចក្ដីទុក្ខពាល់ត្រូវ
ហើយ សោយសោកមិនមែនតិច ច្រើនជាងទឹកក្នុង
មហាសមុទ្រនោះ ហេតុអ្វី ទើបនាងប្រមាទ ។

កាលព្រះសាស្ដា ត្រាស់អនមតគ្គបរិយាយសូត្រយ៉ាងនោះ សេចក្ដីសោកក្នុងសរីរៈរបស់នាង បានដល់នូវការស្រាកស្រាន្តហើយ ។ លំដាប់នោះ ព្រះសាស្ដាទ្រង់ជ្រាបភាពដែលនាងមានសេចក្ដីសោក ស្រាកស្រាន្តហើយ ទ្រង់ដាស់តឿនទៀត ដោយព្រះតម្រាស់ថា បដាចារា ឈ្មោះថា បិយជន មានកូនជាដើម មិនអាចជាទីជ្រកកោន ជាទីពឹង ឬជាទីការពាររបស់នាង ទៅកាន់

បរលោកឡើយ ព្រោះដូច្នោះ កូនជាដើមនោះ ទោះបីមាន ក៏ឈ្មោះមិនមាន នោះឯង ចំណែកបណ្ឌិតជម្រះសីលហើយ គួរជម្រះផ្លូវដែលញ៉ាំងសត្វឲ្យដល់នូវព្រះនិព្វានរបស់ខ្លួនប៉ុណ្ណោះ កាលទ្រង់សម្ដែងធម៌ បានត្រាស់ព្រះគាថាទាំងនេះថា

កាលបុគ្គលត្រូវមច្ចុគ្របសង្កត់ហើយ កូនទាំងឡាយ មិន
មានដើម្បីជាទីពឹង បិតា ក៏មិនមាន ទាំងផៅពង្ស ក៏មិន
មានដើម្បីជាទីពឹងឡើយ សេចក្ដីទីពឹងក្នុងញាតិទាំង-
ឡាយ ក៏មិនមាន បណ្ឌិតដឹងអំណាចប្រយោជន៍នេះ
ហើយគួរជាអ្នកសង្រួមក្នុងសីល គួរប្រញាប់ប្រញាល់
ជម្រះផ្លូវជាទីទៅកាន់ព្រះនិព្វានឲ្យបាន ។

ក្នុងកាលចប់ទេសនា នាងបដាចារាជុតកិលេស មានប្រមាណប៉ុនធូលីក្នុងមហាប្រឹថពីហើយ តាំងនៅក្នុងសោតាបត្តិផល មហាជនដទៃសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមដូច្នេះឯង ។

ចំណែកនាងបដាចារានោះ បានជាព្រះសោតាបន្នហើយ ទូលសូមបព្វជ្ជានឹងព្រះសាស្ដា ។ ព្រះសាស្ដា ទ្រង់បញ្ជូននាងទៅកាន់សម្នាក់របស់ពួកភិក្ខុនីឲ្យបព្វជ្ជាហើយ ។ នាងបានឧបសម្បទាហើយ ប្រាកដឈ្មោះថាបដាចារា ព្រោះនាងត្រឡប់ការប្រព្រឹត្តបាន ។ ថ្ងៃមួយ នាងកំពុងយកក្អមដងទឹកលាងជើង ចាក់ទឹកចុះ ទឹកនោះហូរទៅបន្តិចហើយ ក៏រីងស្ងួត លើកទីពីរទឹកដែលនាងចាក់ បានហូរទៅឆ្ងាយជាងនោះ លើកទីបីទឹកដែលនាងចាក់ បានហូរទៅ

ឆ្ងាយជាងនោះទៀត ដោយប្រការដូច្នេះ នាងកាន់យកទឹកនោះឯងជាអារម្មណ៍ កំណត់វ័យទាំងបីហើយ គិតថា សត្វទាំងនេះ ស្លាប់ក្នុងបឋមវ័យក៏មាន ដូចទឹកដែលអញចាក់ដំបូង ស្លាប់ក្នុងមជ្ឈិមវ័យក៏មាន ដូចទឹកដែលអញចាក់លើកទីពីរហូរទៅឆ្ងាយជាងនោះ ស្លាប់ក្នុងបច្ឆិមវ័យក៏មាន ដូចទឹកដែលអញចាក់លើកទីបី ហូរទៅឆ្ងាយជាងនោះទៀត ។

ព្រះសាស្តា ប្រថាប់គង់នៅក្នុងព្រះគន្ធកុដិ ទ្រង់ផ្សាយព្រះរស្មីទៅ ហាក់ដូចប្រថាប់ឈរចំពោះមុខរបស់នាង ត្រាស់ថា បដាចារា សេចក្តីនោះយ៉ាងនោះឯង ព្រោះថា ការរស់នៅមួយថ្ងៃក្តី មួយខណៈក្តីរបស់បុគ្គលដែលឃើញការកើតឡើង និងការវិនាសនៃបញ្ចក្ខន្ធទាំងនោះ ប្រសើរជាងការរស់នៅមួយរយឆ្នាំរបស់អ្នកមិនឃើញការកើត និងការវិនាសនៃបញ្ចក្ខន្ធ ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**យោ ច វស្សសតំ ជីវេ អបស្សំ ឧទយព្វយំ**
**ឯកាហំ ជីវិតំ សេយ្យោ បស្សតោ ឧទយព្វយំ ។**

បុគ្គលណា រស់នៅមួយរយឆ្នាំ មិនឃើញការកើតឡើង និង
ការវិនាសទៅ ការរស់នៅសូម្បីតែមួយថ្ងៃ របស់លោកដែល
ឃើញការកើតឡើង និងការវិនាសទៅ ប្រសើរជាង ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បាទព្រះគាថាថា **អបស្សំ ឧទយព្វយំ** សេចក្តីថា មិនឃើញការកើតឡើង និងការសូន្យទៅដោយលក្ខណៈ ២៥ នៃបញ្ចក្ខន្ធ ។

បាទព្រះគាថាថា **បស្សតោ ឧទយព្វយំ** សេចក្ដីថា ការរស់នៅសូម្បីត្រឹមតែមួយថ្ងៃ របស់អ្នកឃើញការកើតឡើង និងការវិនាសនៃបញ្ចក្ខន្ធទាំងនោះ ប្រសើរជាងការរស់នៅរបស់បុគ្គលនេះ ។

ក្នុងកាលចប់ទេសនា នាងបដាចារាសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ ដូច្នេះឯង ។l៙

**រឿង នាងបដាចារា ចប់**

# រឿង កិសាគោតមី

## លំនាំដើម

ព្រះសាស្ដា កាលគង់ក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងកិសាគោតមី ត្រាស់ព្រះធម្មទេសនានេះថា **យោ ច វស្សសតំ ជីវេ** ជាដើម ។

បានឮថា ទ្រព្យ ៤០ កោដិក្នុងផ្ទះរបស់សេដ្ឋីម្នាក់ក្នុងក្រុងសាវត្ថី បានក្លាយជាធ្យូងទាំងអស់ តាំងនៅ ។ សេដ្ឋីឃើញហេតុនោះ កើតសេចក្ដីសោកដេកអត់អាហារលើគ្រែតូច សម្លាញ់ម្នាក់របស់សេដ្ឋីនោះ សួរថា នែសម្លាញ់ ហេតុអ្វីទើបអ្នកសោកសៅ ស្ដាប់ការប្រព្រឹត្តទៅនោះហើយ ពោលថា នែសម្លាញ់ សូមអ្នកកុំសោកឡើយ ខ្ញុំដឹងឧបាយមួយ ចូរធ្វើឧបាយនោះចុះ សេដ្ឋីសួរថា នែសម្លាញ់ តើធ្វើដូចម្ដេច សេដ្ឋីម្នាក់ទៀតពោលថា សូមសម្លាញ់ក្រាលកន្ទេលផែនត្រង់ផ្សារ ធ្វើធ្យូងឲ្យជាគំនរ ចូរអង្គុយដូចអ្នកលក់ បណ្ដា

មនុស្សដែលមកហើយ បុគ្គលណានិយាយយ៉ាងនេះថា ជនដ៏សេសលក់សំពត់ ប្រេង ទឹកឃ្មុំ និងទឹកអំពៅជាដើម ចំណែកអ្នកអង្គុយលក់ធ្យូង អ្នកគប្បីពោលនឹងមនុស្សទាំងនោះថា ខ្ញុំមិនលក់របស់ខ្លួន តើនឹងធ្វើអ្វី ចំណែកបុគ្គលណាពោលនឹងអ្នក យ៉ាងនេះថា ជនដ៏សេសលក់សំពត់ ប្រេង ទឹកឃ្មុំ និងទឹកអំពៅជាដើម ចំណែកអ្នកអង្គុយលក់ប្រាក់ និងមាស អ្នកគប្បីនិយាយនឹងជននោះថា ឯណាមាស និងប្រាក់ កាលគេពោលថា នេះ អ្នកគប្បីពោលថា សូមនាំប្រាក់មាសនោះមក ហើយទទួលដោយដៃទាំងពីររបស់ដែលជននោះឲ្យក្នុងដៃរបស់អ្នកយ៉ាងនោះ នឹងក្លាយជាប្រាក់ និងមាស បុគ្គលនោះ បើជាស្រីក្រមុំ ចូរនាំនាង មកដើម្បីបុត្រក្នុងផ្ទះរបស់អ្នក ប្រគល់ទ្រព្យ ៤០ កោដិឲ្យដល់នាង គប្បីប្រើប្រាស់ ប្រាក់មាសដែលនាងឲ្យ បើជាបុរស អ្នកគប្បីឲ្យកូន ស្រីដែលចម្រើនវ័យហើយ ក្នុងផ្ទះរបស់អ្នកដល់បុគ្គលនោះ ហើយប្រគល់ទ្រព្យ ៤០ កោដិឲ្យដល់បុរសនោះ ប្រើប្រាស់ទ្រព្យដែលគេឲ្យ ។ សេដ្ឋីពោលថា ឧបាយនេះល្អ ទើបដញ្ញូនធ្យូងឲ្យជាគំនរក្នុងផ្សាររបស់ខ្លួន អង្គុយធ្វើដូចអ្នកលក់ មនុស្សពួកណា ពោលនឹងសេដ្ឋីនោះយ៉ាងនេះថា ជនដ៏សេសទាំងឡាយលក់សំពត់ ប្រេង ទឹកឃ្មុំ និងទឹកអំពៅជាដើម អ្នកអង្គុយលក់ធ្យូង ក៏ឲ្យចម្លើយដល់មនុស្សទាំងនោះថា ខ្ញុំមិនលក់របស់ខ្លួន តើនឹងធ្វើអ្វី ។

គ្រានោះ ទារិកាម្នាក់ឈ្មោះគោតមី ប្រាកដឈ្មោះថា កិសាគោតមី ព្រោះមានរាងស្តើង ជាធីតារបស់ត្រកូលបុរាណ ទៅកាន់ផ្សារដោយកិច្ចឯណា

ទីមួយរបស់ខ្លួន ឃើញសេដ្ឋីនោះ ទើបពោលយ៉ាងនេះថា នែលោកឪពុក ជនដ៏សេសលក់សំពត់ ប្រេង ទឹកឃ្មុំ និងទឹកអំពៅជាដើម ហេតុអ្វី ទើបលោកអង្គុយលក់ប្រាក់ និងមាស សេដ្ឋីសួរថា ឯណាប្រាក់ និងមាស នាងគោតមីពោលថា លោកអង្គុយចាប់ប្រាក់មាសនោះឯង មិនមែនឬ សេដ្ឋីពោលថា ចូរនាំប្រាក់មាសនោះមកសិន ។

នាងកើបពេញដៃហើយ ដាក់ត្រង់ដៃសេដ្ឋីនោះ ធ្យូងនោះក៏ក្លាយជាប្រាក់ និងមាសទាំងអស់ ។ លំដាប់នោះ សេដ្ឋីសួរនាងថា នែនាង ផ្ទះរបស់នាងនៅឯណា កាលនាងប្រាប់ថា ក្នុងទីឈ្មោះនោះ ដឹងភាពដែលនាងមិនទាន់មានប្តីហើយ ទើបរក្សាទ្រព្យ នាំនាងមកដើម្បីកូនរបស់ខ្លួន ឲ្យរក្សាទ្រព្យ ៤០ កោដិ ។ ទ្រព្យទាំងអស់បានក្លាយជាប្រាក់ និងមាសដូចដើម ។

សម័យដទៃ នាងតាំងគភ៌កន្លងទៅ ១០ ខែ ប្រសូតបុត្រហើយ បុត្រនោះធ្វើកាលកិរិយាហើយ ក្នុងកាលដែលចេះដើរ ។ នាងឃាត់ពួកជនដែលនាំកូននោះទៅដុត ព្រោះនាងមិនធ្លាប់ឃើញការស្លាប់ ពសាកសពបុត្រដែលស្លាប់ហើយដោយចង្កេះ ដោយបំណងថា នឹងសួរដល់ថ្នាំដើម្បីកូនខ្លួន ដើរសួរទៅតាមលំដាប់ផ្ទះថា អ្នកទាំងឡាយ ស្គាល់ថ្នាំដើម្បីកូនរបស់ខ្ញុំដែរឬទេ ពេលនោះ មនុស្សទាំងឡាយនិយាយនឹងនាងថា នែនាង នាងឆ្កួតហើយឬ នាងសួរដល់ថ្នាំដើម្បីកូនដែលស្លាប់ហើយ នាងសម្គាល់ថា នឹងបានមនុស្សដែលចេះថ្នាំ ដើម្បីកូនរបស់នាងពិត ទើបត្រាច់ទៅ ។

ពេលនោះ បុរសដែលជាបណ្ឌិតម្នាក់ ឃើញនាងហើយគិតថា កូនស្រី

របស់អញនេះប្រសូតបុត្រដំបូង មិនធ្លាប់ឃើញការស្លាប់ អញជាទីពឹងរបស់ស្រីនេះ ទើបគួរ ទើបពោលថា នែនាង ខ្ញុំមិនចេះថ្នាំ តែខ្ញុំស្គាល់អ្នកដែលចេះថ្នាំ នាងគោតមីពោលថា បពិត្រលោកឪពុក អ្នកណាចេះ បណ្ឌិតនោះពោលថា នែនាង ព្រះសាស្តាទ្រង់ជ្រាប ចូរនាងទៅទូលសួរព្រះអង្គចុះ ។ នាងពោលថា បពិត្រលោកឪពុក ខ្ញុំនឹងទៅ នឹងទូលសួរ ដូច្នោះហើយ ចូលទៅរកព្រះសាស្តា ថ្វាយបង្គំហើយ ឈរក្នុងទីបំផុតនាចំណែកម្ខាង ទូលសួរថា បានឮថា ព្រះអង្គទ្រង់ចេះថ្នាំដើម្បីកូនរបស់ខ្ញុំម្ចាស់ឬ ព្រះសាស្តាត្រាស់ថា អើ នាង តថាគតដឹង នាងគោតមីទូលថា បានអ្វី ទើបគួរព្រះអង្គ ព្រះសាស្តាត្រាស់ថា បានគ្រាប់ស្ពៃត្រឹមមួយចិប គួរនាងគោតមីទូលថា នឹងបានព្រះអង្គ តែបានក្នុងផ្ទះអ្នកណា ទើបគួរ ព្រះសាស្តាត្រាស់ថា បុត្រ ឬធីតាណាម្នាក់ក្នុងផ្ទះរបស់បុគ្គលណា មិនធ្លាប់ស្លាប់ បានក្នុងផ្ទះរបស់បុគ្គលនោះ ទើបគួរ នាងទទួលថា ករុណា ព្រះអង្គ ហើយថ្វាយបង្គំព្រះសាស្តា ពកូនដែលស្លាប់ហើយដោយចង្កេះ ចូលទៅខាងក្នុងស្រុក ឈរត្រង់ទ្វារផ្ទះទីមួយ ពោលថា គ្រាប់ស្ពៃខាងក្នុងផ្ទះនេះមានខ្លះឬទេ ព្រោះថា គ្រាប់ស្ពៃនោះជាថ្នាំដើម្បីកូនរបស់ខ្ញុំ កាលគេឆ្លើយថា មាន ទើបពោលថា បើយ៉ាងនោះសូមឲ្យខ្ញុំចុះ ។ កាលមនុស្សទាំងនោះ នាំគ្រាប់ស្ពៃមកឲ្យ ទើបសួរថា ក្នុងផ្ទះនេះ កូនប្រុស ឬកូនស្រីធ្លាប់ស្លាប់ មានដែរឬទេ កាលគេឆ្លើយថា នាងនិយាយអ្វី ព្រោះមនុស្សដែលរស់មានតិចតួច មនុស្សដែលស្លាប់នោះឯងមានច្រើន ទើបពោលថា បើយ៉ាងនោះ សូមទទួលគ្រាប់ស្ពៃរបស់អ្នកវិញចុះ

នោះមិនមែនជាថ្នាំសម្រាប់កូនខ្ញុំឡើយ ហើយបានឲ្យទៅវិញ ដើរសួរដោយទំនងនេះ តាំងអំពីផ្ទះទីមួយជាដើមទៅ ។ នាងមិនទទួលគ្រាប់ស្ពៃក្នុងផ្ទះមួយក្នុងពេលល្ងាច គិតថា ឱ ! កម្មធ្ងន់ហ្ន៎ អញធ្វើសេចក្ដីសម្គាល់ថា កូនរបស់អញប៉ុណ្ណោះស្លាប់ ក្នុងស្រុកទាំងមូល មនុស្សដែលស្លាប់ប៉ុណ្ណោះច្រើនជាងអ្នករស់ ។ កាលនាងកំពុងគិតយ៉ាងនេះ ហទយៈដែលទន់ដោយការស្រឡាញ់បុត្រ បានដល់នូវការរឹងហើយ ។ នាងដាក់កូននោះក្នុងព្រៃ ទៅកាន់សម្នាក់ព្រះសាស្ដា ថ្វាយបង្គំហើយ ឈរក្នុងទីបំផុត នាចំណែកម្ខាង ។

គ្រានោះ ព្រះសាស្ដាត្រាស់នឹងនាងថា នាងបានគ្រាប់ស្ពៃប្រមាណមួយចិបហើយឬ នាងគោតមីទូលថា មិនបានទេព្រះអង្គ ព្រោះក្នុងស្រុកទាំងមូលអ្នកស្លាប់នោះឯងច្រើនជាងអ្នករស់ ។

លំដាប់នោះ ព្រះសាស្ដាត្រាស់នឹងនាងថា នាងយល់ថា កូនរបស់អញប៉ុណ្ណោះស្លាប់ ការស្លាប់នោះ ជាធម៌ស្ថិតស្ថេរសម្រាប់សត្វទាំងឡាយ ព្រោះថា មច្ចុរាជអូសទាញសត្វទាំងអស់ ដែលមានអធ្យាស្រ័យមិនពេញលេញនោះឯង ឲ្យធ្លាក់ក្នុងសមុទ្រ គឺអបាយ ដូចអន្លង់ទឹកធំ ដូច្នោះ កាលទ្រង់សម្ដែងធម៌ ទើបត្រាស់ព្រះគាថានេះថា

មច្ចុ គឺសេចក្ដីស្លាប់ តែងនាំយកនរជនអ្នកស្រវឹង
ជ្រប់ក្នុងកូន និងសត្វចិញ្ចឹម មានចិត្តជាប់ជំពាក់ក្នុង
អារម្មណ៍ផ្សេងៗ នោះ ដូចជំនន់ទឹកធំ នាំយកអ្នក
ស្រុកកំពុងដេកលក់ ។

ក្នុងកាលចប់ទេសនា នាងកិសាគោតមី តាំងនៅក្នុងសោតាបត្តិផល សូម្បីមហាជនដទៃ ក៏សម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផល ជាដើម ដូច្នេះឯង ។

ចំណែកនាងកិសាគោតមីនោះ ទូលសូមបព្វជ្ជានឹងព្រះសាស្តាហើយ ព្រះសាស្តាទ្រង់បញ្ជូនទៅកាន់សម្នាក់ភិក្ខុនី ឲ្យបព្វជ្ជាហើយ ។ នាងបាន ឧបសម្បទាហើយ ប្រាកដឈ្មោះថា កិសាគោតមីថេរី ។

ថ្ងៃមួយ នាងដល់វារៈក្នុងរោងឧបោសថ អន្ទុយអុជប្រទីប ឃើញ អណ្តាតប្រទីបឆេះឡើង និងថយចុះ បានកាន់យកជាអារម្មណ៍ថា សត្វទាំង នេះ ក៏យ៉ាងនោះដូចគ្នា កើតឡើង និងរលត់ទៅដូចអណ្តាតប្រទីប បុគ្គល ដល់ព្រះនិព្វាន មិនប្រាកដយ៉ាងនោះ ។

ព្រះសាស្តា ប្រថាប់គង់ក្នុងព្រះគន្ធកុដិនោះឯង ទ្រង់ផ្សាយព្រះរស្មីទៅ ដូចគង់ត្រាស់ចំពោះមុខ ត្រាស់ថា យ៉ាងនោះឯងគោតមី សត្វទាំងនោះ រមែង កើត និងរលត់ដូចអណ្តាតប្រទីប ដល់នូវព្រះនិព្វានហើយ រមែងមិនប្រាកដ យ៉ាងនោះ ភាពជាអ្នករស់នៅត្រឹមមួយខណៈ របស់អ្នកឃើញព្រះនិព្វាន ប្រសើរជាងការរស់នៅមួយរយឆ្នាំ របស់អ្នកមិនឃើញព្រះនិព្វានយ៉ាងនោះ ដូច្នោះហើយ ទើបទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**យោ ច វស្សសតំ ជីវេ  អបស្សំ អមតំ បទំ**
**ឯកាហំ ជីវិតំ សេយ្យោ  បស្សតោ អមតំ បទំ ។**

បុគ្គលណា រស់នៅមួយរយឆ្នាំ មិនឃើញផ្លូវព្រះនិព្វាន

ការរស់នៅសូម្បីមួយថ្ងៃ របស់លោកអ្នកឃើញផ្លូវព្រះ
និព្វាន ប្រសើរជាង ។

បណ្ដាបទទាំងនោះ ពីរបទថា **អមតំ បទំ** សេចក្ដីថា អមតមហានិព្វាន ដែលជាចំណែកវៀរចាកនូវមរណៈ ។

ពាក្យដ៏សេស ដូចគ្នានឹងពាក្យដែលមានក្នុងកាលមុននោះឯង ។

ក្នុងកាលចប់ទេសនា នាងកិសាគោតមីអង្គុយនៅតាមប្រក្រតីនោះឯង តាំងនៅក្នុងអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ ដូច្នេះឯង ។

**រឿង កិសាគោតមី ចប់**

# រឿង ពហុបុត្តិកាថេរី

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងពហុបុត្តិកា-ថេរី ត្រាស់ព្រះធម្មទេសនានេះថា **យោ ច វស្សសតំ ជីវេ** ជាដើម ។

បានឮថា ក្នុងត្រកូលមួយ នាក្រុងសាវត្ថី ស្ត្រីម្នាក់មានកូនប្រុស ៧ និង កូនស្រី ៧ កូនប្រុស និងកូនស្រីទាំងអស់នោះចម្រើនវ័យហើយ តាំងនៅក្នុង ផ្ទះបានដល់នូវសេចក្ដីសុខ តាមធម្មតារបស់ខ្លួន ។ សម័យដទៃមក ឪពុក របស់ជនទាំងនោះ បានធ្វើកាលកិរិយាហើយ ។

មហាឧបាសិកា សូម្បីស្វាមីអនិច្ចកម្មទៅហើយ ក៏មិនបែងចែកទ្រព្យឲ្យកូនទាំងឡាយ ។ កាលនោះ កូនទាំងឡាយពោលនឹងមាតានោះថា កាលបិតារបស់ខ្ញុំស្លាប់ទៅហើយ ប្រយោជន៍អ្វីរបស់ម៉ែដោយគំនរទ្រព្យ ពួកខ្ញុំមិនអាចចិញ្ចឹមម៉ែបានឬ នាងស្តាប់ពាក្យរបស់កូនទាំងនោះហើយ ក៏អង្គុយស្ងៀម ត្រូវកូនទាំងនោះពោលរឿយៗ ទើបគិតថា ពួកកូនៗ នឹងទំនុកបម្រុងអញ ប្រយោជន៍អ្វីរបស់អញ ដោយគំនរទ្រព្យមួយចំណែក បានបែងចែកទ្រព្យសម្បត្តិទាំងអស់ ពាក់កណ្តាលឲ្យទៅ ។

ក្នុងកាលកន្លងទៅ ២-៣ ថ្ងៃ ភរិយារបស់បុត្រច្បងពោលនឹងម៉ែក្មេកនោះថា ឱ អ្នកម៉ែពួកយើង មកផ្ទះនេះប៉ុណ្ណោះ ដូចនឹងឲ្យពីរចំណែក ដល់កូនប្រុសច្បង ។ ភរិយារបស់កូនដ៏សេស ក៏ពោលយ៉ាងនោះដូចគ្នា ។

ចាប់តាំងអំពីកូនស្រីច្បង ក៏ពោលនឹងនាងដូចគ្នា ក្នុងវេលាដែលនាងទៅកាន់ផ្ទះរបស់ធីតានោះៗ ។ នាងត្រូវមើលងាយ គិតថា ប្រយោជន៍អ្វីដោយការនៅក្នុងសម្នាក់របស់មនុស្សទាំងនេះ អញនឹងបួសជាភិក្ខុនី ហើយទៅកាន់សម្នាក់របស់ភិក្ខុនី សូមបព្វជ្ជាហើយ ។ ភិក្ខុនីទាំងនោះឲ្យនាងបព្វជ្ជាហើយ នាងបានឧបសម្បទាហើយ ប្រាកដឈ្មោះថា ពហុបុត្តិកាថេរី ។ នាងគិតថា អញបួសក្នុងកាលឯចាស់ អញមិនគួរជាបុគ្គលប្រមាទ ទើបធ្វើវត្ត

បដិបត្តិដល់ភិក្ខុនីទាំងឡាយ គិតថា នឹងធ្វើសមណធម៌មួយយប់ទល់ភ្លឺ ទើបយកដៃចាប់សសរមួយដើម ខាងក្រោមប្រាសាទ ដើរវៀលសសរនោះធ្វើសមណធម៌ កាលដើរចង្រ្កម ក៏យកដៃចាប់ដើមឈើ ដោយគិតថា ក្បាលរបស់អញគប្បីទង្គិចដើមឈើ ឬទីណាមួយក្នុងទីងងឹត ដូច្នេះហើយ ដើរវៀលដើមឈើនោះ ធ្វើសមណធម៌ ពិចារណាដល់ធម៌ ដោយគិតថា នឹងធ្វើតាមធម៌ដែលព្រះសាស្តាទ្រង់សម្តែង តាមរឭកដល់ធម៌ ត្រាច់ធ្វើសមណធម៌ ។

កាលនោះ ព្រះសាស្តាទ្រង់ប្រថាប់គង់ក្នុងព្រះគន្ធកុដិហើយ ទ្រង់ផ្សាយព្រះរស្មីទៅ ហាក់ដូចប្រថាប់គង់ចំពោះមុខដោយព្រះតម្រាស់ថា ពហុបុត្តិកា ការរស់នៅ សូម្បីត្រឹមមួយរំពេចរបស់អ្នកឃើញធម៌ ដែលតថាគតសម្តែង ប្រសើរជាងការរស់នៅមួយរយឆ្នាំ របស់បុគ្គលមិនពិចារណា មិនឃើញធម៌ដែលតថាគតសម្តែង កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះដូច្នេះថា

**យោ ច វស្សសតំ ជីវេ អបស្សំ ធម្មមុត្តមំ**
**ឯកាហំ ជីវិតំ សេយ្យោ បស្សតោ ធម្មមុត្តមំ ។**

បុគ្គលណា រស់នៅមួយរយឆ្នាំ មិនឃើញធម៌ដ៏ខ្ពង់ខ្ពស់
ការរស់នៅ សូម្បីតែមួយថ្ងៃ របស់លោកអ្នកឃើញធម៌
ដ៏ខ្ពង់ខ្ពស់ ប្រសើរជាង ។

# សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ បទថា* **ធម្មមុត្តមំ** *បានដល់លោកុត្តរធម៌ ៩ យ៉ាង ។ លោកុត្តរធម៌នោះ ឈ្មោះថា ជាធម៌ដ៏ឧត្តម បុគ្គលណាមិនឃើញធម៌ដ៏កំពូលនោះ កាលជាអ្នករស់នៅ សូម្បីតែមួយរំពេច គឺសូម្បីតែមួយខណៈរបស់អ្នកឃើញ គឺចាក់ធ្លុះនូវធម៌នោះ ប្រសើរជាងការរស់នៅមួយរយឆ្នាំរបស់បុគ្គលនោះ ។*

*ក្នុងកាលចប់ទេសនា ព្រះនាងពហុបុត្តិកាថេរីតាំងនៅក្នុងអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ ដូច្នេះឯង ។ល។*

**រឿងពហុបុត្តិកាថេរី ចប់**

**សហស្សវគ្គ ចប់**

**វគ្គទី ៨ ចប់**

# សុត្តន្តបិដក

## ធម្មបទគាថា ចាបវគ្គទី ៩

[ ១៩ ] បុគ្គលគួរប្រញាប់ប្រញាល់ធ្វើអំពើល្អ គួរឃាត់ចិត្តចាកបាប ព្រោះថា កាលបើបុគ្គលធ្វើបុណ្យយឺតយូរ ចិត្តរមែងត្រេកអរក្នុងបាប ។ បើបុរសធ្វើបាប កុំធ្វើបាបនោះរឿយៗ ឡើយ កុំគប្បីធ្វើសេចក្តីពេញចិត្តក្នុងបាបនោះ ( ព្រោះថា ) ការសន្សំបាប តែងនាំសេចក្តីទុក្ខមកឲ្យ ។

បើបុរសធ្វើបុណ្យ គួរធ្វើបុណ្យនោះឲ្យរឿយៗ គួរធ្វើសេចក្តីពេញចិត្តក្នុងបុណ្យនោះ ( ព្រោះថា ) ការសន្សំបុណ្យ តែងនាំសេចក្តីសុខមកឲ្យ ។

បាប មិនទាន់ឲ្យផលត្រឹមណា មនុស្សបាប ក៏នៅឃើញតែសេចក្តីចម្រើនត្រឹមនោះ លុះកាលណា បាបឲ្យផល មនុស្សបាប ទើបឃើញបាបក្នុងកាលនោះ ។

អំពើល្អ មិនទាន់ឲ្យផលត្រឹមណា មនុស្សល្អ នៅឃើញតែបាបត្រឹមនោះ លុះកាលណា អំពើល្អឲ្យផល មនុស្សល្អ ទើបឃើញល្អក្នុងកាលនោះ ។

បុគ្គលមិនគួរមើលងាយបាបថា មានប្រមាណតិច នឹងមិនឲ្យផលដូច្នេះឡើយ ប្រៀបដូចក្អមទឹក រមែងពេញដោយតំណក់ទឹក ដែលធ្លាក់ចុះ

*យ៉ាងណា បុគ្គលពាល កាលសន្សំបាប សូម្បីបន្តិចម្តងៗ គង់ពេញបាន ដោយបាប យ៉ាងនោះដែរ ។*

*បុគ្គលមិនគួរមើលងាយបុណ្យថា មានប្រមាណតិច នឹងមិនឲ្យផល ដូច្នេះឡើយ ប្រៀបដូចក្អមទឹក រមែងពេញបានដោយតំណក់ទឹកដែលធ្លាក់ចុះ យ៉ាងណា អ្នកមានប្រាជ្ញា កាលសន្សំបុណ្យបន្តិចម្តងៗ គង់ពេញបានដោយ បុណ្យយ៉ាងនោះ ។*

*បុគ្គលគួរចៀសវាងបាបទាំងឡាយ ឲ្យដូចពាណិជដែលមានទ្រព្យ ច្រើន តែមានគ្នាតិច ចៀសវាងផ្លូវគួរខ្លាច ឬដូចជាបុរសប្រាថ្នារស់នៅ ចៀសវាងថ្នាំពិស ដូច្នោះដែរ ។*

*បើដំបៅមិនមានក្នុងបាតដៃទេ បុគ្គលគប្បីនាំយកថ្នាំពិសដោយបាតដៃ ថ្នាំពិសតែងមិនជ្រាបចូលទៅកាន់បាតដៃដែលគ្មានដំបៅ យ៉ាងណា បាបរមែង មិនមានដល់បុគ្គលអ្នកមិនធ្វើ យ៉ាងនោះដែរ ។ បុគ្គលណា ប្រទូស្តអ្នកមិន ប្រទូស្តតប ជាសត្វស្អាត មិនមានកិលេសដូចជាទីទួល បាបរមែងត្រឡប់ មករកបុគ្គលពាលនោះវិញ ដូចធូលីល្អិតដែលបុគ្គលបាចសាចទៅកាន់ទី ប្រាសខ្យល់ ។*

*ជនពួកខ្លះ កើតក្នុងគភ៌មនុស្ស ពួកអ្នកមានអំពើអាក្រក់ទៅកាន់នរក*

ពួកអ្នកមានគតិល្អ ទៅកាន់ស្ថានសួគ៌ ពួកអ្នកមិនមានអាសវៈបរិនិព្វាន ។

បុគ្គលអ្នកធ្វើបាបកម្មហើយ ទោះបីចូលទៅព្ធដ៏អាកាស ក្នុងកណ្ដាលសមុទ្រ កាន់ចន្លោះភ្នំទាំងឡាយ ក៏មិនគប្បីរួចចាកបាបកម្ម ព្រោះប្រទេសលើផែនដី ដែលបុគ្គលស្ថិតនៅហើយ គប្បីរួចចាកបាបកម្មបាននោះ មិនដែលមានឡើយ ។

បុគ្គលទៅព្ធដ៏អាកាស ក្នុងកណ្ដាលសមុទ្រ កាន់ចន្លោះនៃភ្នំទាំងឡាយ ក៏មិនរួចចាកសេចក្ដីស្លាប់បាន ព្រោះប្រទេសលើផែនដីដែលបុគ្គលឋិតនៅហើយ សេចក្ដីស្លាប់គ្របសង្កត់មិនបាននោះ មិនដែលមានឡើយ ។

**បាបវគ្គទី ៩ ចប់**

# អដ្ឋកថា

# ធម្មបទដ្ឋកថា

## ខុទ្ទកនិកាយ គាថាធម្មបទ

## ពាលវគ្គទី ៩

## រឿង ព្រាហ្មណ៍ ឈ្មោះ ចូឡេកសាដក

### លំនាំដើម

*ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធចូឡេកសាដក-ព្រាហ្មណ៍ ត្រាស់ព្រះធម្មទេសនានេះថា* **អភិត្ថរេថ កល្យាណេ** *ជាដើម ។*

*សេចក្តីពិស្តារថា ក្នុងកាលនៃព្រះវិបស្សីទសពល មានព្រាហ្មណ៍ម្នាក់ឈ្មោះមហាឯកសាដក ។ តែក្នុងកាលនោះ ព្រាហ្មណ៍នេះជាព្រាហ្មណ៍ឈ្មោះចូឡេកសាដកក្នុងក្រុងសាវត្ថី ។ សំពត់សាដកសម្រាប់ស្លៀករបស់ព្រាហ្មណ៍នោះមានតែមួយផ្ទាំង សូម្បីរបស់នាងព្រាហ្មណីក៏មានតែមួយផ្ទាំង ទាំងពីរនាក់ប្តីប្រពន្ធ មានសំពត់ដណ្តប់មួយផ្ទាំងប៉ុណ្ណោះ ។ ក្នុងពេលចេញទៅខាងក្រៅ ព្រាហ្មណ៍ ឬព្រាហ្មណី រមែងដណ្តប់សំពត់មួយផ្ទាំងនោះ ។ ក្រោយមក កាលគេប្រកាសការស្តាប់ធម៌ក្នុងវិហារ ព្រាហ្មណ៍ពោលថា នែនាង គេប្រកាសការស្តាប់ធម៌ នាងនឹងទៅទីស្តាប់ធម៌ក្នុងពេលថ្ងៃ ឬពេលយប់ ព្រោះ*

យើងទាំងពីរមិនអាចទៅព្រមគ្នាបាន ព្រោះមិនមានសំពត់ដណ្តប់ ព្រាហ្មណី ឆ្លើយថា នែអ្នក ខ្ញុំនឹងទៅពេលថ្ងៃ ហើយនឹងដណ្តប់សំពត់សាដកទៅ ។

ព្រាហ្មណ៍សម្ងំនៅក្នុងផ្ទះអស់មួយថ្ងៃ លុះពេលយប់ ទើបបានទៅអង្គុយស្តាប់ធម៌ ចំពោះព្រះភក្ត្រព្រះសាស្តា ។ គ្រានោះ បីតិ ៥ យ៉ាងជ្រួតជ្រាបពេញសរីរៈរបស់ព្រាហ្មណ៍នោះកើតឡើងហើយ ។ គាត់ជាបុគ្គលប្រាថ្នានឹងបូជាព្រះសាស្តា គិតថា បើអញថ្វាយសំពត់សាដកនេះសោត សំពត់ដណ្តប់របស់នាងព្រាហ្មណីនឹងមិនមាន របស់អញក៏មិនមាន ខណៈនោះ ចិត្តប្រកបដោយសេចក្តីកំណាញ់រាប់ពាន់កើតឡើងហើយដល់គាត់ ចិត្តប្រកបដោយសទ្ធាមួយដួងកើតឡើងទៀត ចិត្តប្រកបដោយសេចក្តីកំណាញ់រាប់ពាន់ កើតឡើងគ្របសង្កត់ចិត្តសទ្ធានោះទៀត ។ សេចក្តីកំណាញ់របស់គាត់មានកម្លាំង ចាំតែគ្របសង្កត់ចិត្តដែលជាសទ្ធា ដូចត្រូវចាប់ចងនោះឯង ដោយប្រការដូច្នេះ ។

កាលព្រាហ្មណ៍កំពុងគិតថា តើថ្វាយ ឬមិនថ្វាយ ដូច្នោះនោះឯង បឋមយាមកន្លងទៅហើយ បន្ទាប់អំពីនោះ ក៏ដល់មជ្ឈិមយាម ព្រាហ្មណ៍មិនអាចថ្វាយក្នុងមជ្ឈិមយាមនោះបាន លុះដល់បច្ឆិមយាម គាត់គិតថា កាលអញច្បាំងជាមួយសទ្ធាចិត្ត និងមច្ឆរិយចិត្តនោះឯង ពីរយាមកន្លងទៅហើយ មច្ឆរិយចិត្តរបស់អញមានប្រមាណប៉ុណ្ណេះចម្រើន នឹងមិនឲ្យងើបក្បាលឡើងអំពីអបាយ ៤ អញនឹងថ្វាយសំពត់សាដកនេះ ព្រាហ្មណ៍សង្កត់សេចក្តីកំណាញ់រាប់ពាន់បានហើយ ដោយធ្វើសទ្ធាចិត្តឲ្យជាបុរេចារិក កាន់សំពត់សាដកទៅដាក់ទៀបបាទមូលព្រះសាស្តា បានបន្លឺសំឡេងខ្លាំង ៣ ដងថា ខ្ញុំ

ឈ្នះហើយ ខ្ញុំឈ្នះហើយជាដើម ។

ព្រះបាទបសេនទិកោសលកំពុងស្តាប់ធម៌ បានស្តាប់សំឡេងនោះហើយ ត្រាស់ថា ពួកអ្នកចូរសួរព្រាហ្មណ៍នោះមើល បានឮថា គេឈ្នះអ្វី ។

ព្រាហ្មណ៍នោះ ត្រូវពួករាជបុរសសួរ បានប្រាប់សេចក្តីនោះ ព្រះរាជាបានស្តាប់សេចក្តីនោះហើយ ទ្រង់ត្រិះរិះថា ព្រាហ្មណ៍ធ្វើវត្ថុដែលបុគ្គលធ្វើបានលំបាក អញនឹងធ្វើការសង្គ្រោះដល់ព្រាហ្មណ៍ ទើបទ្រង់ព្រះរាជទានសំពត់សាដកមួយគូ ។

គាត់បានថ្វាយសំពត់នោះដល់ព្រះសាស្តាដូចគ្នា ទើបព្រះរាជា បញ្ជាឲ្យព្រះរាជទានធ្វើឲ្យជាទ្វេគុណ គឺ ២ គូ ៤ គូ ៨ គូ ១៦ គូ គាត់បានថ្វាយសំពត់នោះ ដល់ព្រះសាស្តានោះឯង ។ បន្ទាប់មកព្រះរាជាត្រាស់ឲ្យព្រះរាជទានសំពត់ សាដក ៣២ គូដល់ព្រាហ្មណ៍ ។

ព្រាហ្មណ៍កាលការពារវាទៈថា ព្រាហ្មណ៍មិនកាន់យកដើម្បីខ្លួន លះបង់សំពត់ដែលបានហើយទាំងអស់ ទើបកាន់យកសំពត់សាដកពីរគូ អំពីសំពត់សាដក ៣២ គូនោះ គឺដើម្បីខ្លួនមួយគូ ដើម្បីនាងព្រាហ្មណីមួយគូ បានថ្វាយសំពត់សាដក ៣០ គូដល់ព្រះសាស្តានោះឯង ។ ចំណែកព្រះរាជា កាលព្រាហ្មណ៍នោះថ្វាយដល់ ៧ ដង មានព្រះរាជបំណងនឹងព្រះរាជទានទៀត ។ ព្រាហ្មណ៍ឈ្មោះមហាឯកសាដកក្នុងកាលមុន កាន់យកសំពត់សាដកពីរគូក្នុងចំនួនសំពត់សាដក ៦៤ គូ ។ ចំណែកព្រាហ្មណ៍ឈ្មោះចូឡេកសាដកនេះ បានកាន់យកសំពត់សាដកពីរគូ ក្នុងពេលដែលខ្លួនបានសំពត់សាដក ៣២ គូ ។

ព្រះរាជាទ្រង់បង្គាប់ពួករាជបុរសថា នែអ្នក ព្រាហ្មណ៍ធ្វើវត្តដែលធ្វើបានកម្រ អ្នកទាំងឡាយគប្បីនាំយកសំពត់កម្ពលពីរផ្ទាំង ក្នុងវាំងរបស់យើងមក ពួករាជបុរសបានធ្វើយ៉ាងនោះ ។ ព្រះរាជាត្រាស់ឲ្យព្រះរាជទានសំពត់កម្ពលពីរផ្ទាំង ដែលមានតម្លៃមួយសែនដល់ព្រាហ្មណ៍ ។ ព្រាហ្មណ៍គិតថា សំពត់កម្ពលទាំងនេះ មិនសមគួរពាល់ត្រូវត្រង់សរីរៈរបស់អញ សំពត់ទាំងនោះសមគួរដល់ព្រះពុទ្ធសាសនាប៉ុណ្ណោះ ទើបបានចងសន្ទឹងសំពត់កម្ពលមួយផ្ទាំង ធ្វើជាពិដានខាងលើទីបន្ទំរបស់ព្រះសាស្តា ខាងក្នុងព្រះគន្ធកុដិ ចងសន្ទឹងមួយផ្ទាំង ធ្វើជាពិដាន ក្នុងទីធ្វើភត្តកិច្ចរបស់ភិក្ខុដែលឆាន់ជានិច្ចក្នុងផ្ទះរបស់ខ្លួន ក្នុងពេលល្ងាច ព្រះរាជាយាងចូលទៅកាន់សម្នាក់របស់ព្រះសាស្តា ទ្រង់ចាំសំពត់កម្ពលនោះបានហើយ ទូលសួរថា បពិត្រព្រះអង្គ អ្នកណាធ្វើការបូជា កាលព្រះសាស្តាត្រាស់ថា ព្រាហ្មណ៍ឈ្មោះឯកសាដក ដូច្នេះហើយ ទ្រង់ព្រះតម្រិះថា ព្រាហ្មណ៍ជ្រះថ្លាក្នុងឋានៈដែលអញជ្រះថ្លាដូចគ្នា ត្រាស់ឲ្យព្រះរាជទានវត្ថុគ្រប់យ៉ាង ១ មុខ ៤ៗ រហូតដល់មួយរយនៃវត្ថុទាំងអស់ដល់ព្រាហ្មណ៍នោះយ៉ាងនេះ គឺដំរី ៤ សេះ ៤ កហាបណៈ ៤ ពាន់ ស្ត្រី ៤ ទាសី ៤ បុរស ៤ ស្រុកសួយ ៤ ។

ភិក្ខុទាំងឡាយ សន្ទនាគ្នាក្នុងរោងធម្មសភាថា ឱកម្មរបស់ព្រាហ្មណ៍ឈ្មោះ ចូឡេកសាដកគួរអស្ចារ្យ មួយរំពេចប៉ុណ្ណោះគាត់បានវត្ថុសព្វយ៉ាងមួយមុខ៤ៗ សុចរិតកម្មដែលគាត់ធ្វើក្នុងស្រែឥឡូវនេះឯងឲ្យផលក្នុងថ្ងៃនេះ ។

ព្រះសាស្តា យាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញ

នេះ ពួកអ្នកទាំងឡាយ អង្គុយសន្ទនាគ្នា ដោយកថាដូចម្ដេច កាលពួកភិក្ខុក្រាបទូលថា បពិត្រព្រះអង្គ ដោយកថាឈ្មោះនេះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើឯកសាដកនេះ ឲ្យដល់តថាគតក្នុងបឋមយាមសោត នឹងបានវត្ថុសព្វយ៉ាង មួយមុខ ១៦ បើឲ្យក្នុងមជ្ឈិមយាមសោត នឹងបានវត្ថុសព្វយ៉ាង មួយមុខ ៨ តែព្រោះឲ្យក្នុងកាលទៀបភ្លឺ ទើបព្រាហ្មណ៍បានវត្ថុមួយមុខ ៤ ពិតហើយ សុចរិតកម្មដែលបុគ្គលគប្បីធ្វើ មិនញុំាងចិត្តកើត ក៏ដល់នូវសេចក្ដីវិនាស គួរធ្វើភ្លាមៗនោះឯង ព្រោះថា កុសលដែលបុគ្គលធ្វើយឺតយូរ កាលឲ្យសម្បត្តិ រមែងឲ្យយឺតយូរដូចគ្នា ព្រោះដូច្នោះ គប្បីធ្វើសុចរិតកម្មក្នុងលំដាប់នៃចិត្តុប្បាទនោះឯង កាលទ្រង់បន្តអនុសន្ធិសម្ដែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**អភិត្ថរេថ កល្យាណេ ចាចា ចិត្តំ និវារយេ**
**ទន្ធំ ហិ ករតោ បុញ្ញំ ចាបស្មឹ រមតី មនោ ។**

បុគ្គលគួរប្រញាប់ធ្វើអំពើល្អ គួរឃាត់ចិត្តចាកបាប ព្រោះថា កាលបើបុគ្គលធ្វើបុណ្យយឺតយូរ ចិត្តរមែងត្រេកអរក្នុងបាប ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **អភិត្ថរេថ** សេចក្ដីថា គប្បីធ្វើដោយប្រញាប់ គឺរហ័ស ។ ពិតហើយ គ្រហស្ថ កាលចិត្តកើតឡើងថា នឹងធ្វើកុសលឯណានីមួយ ក្នុងទានកុសលទាំងឡាយ មានសលាកភត្តជាដើម គួរធ្វើរំពេចនោះ

ឯង ដោយគិតថា អញនឹងធ្វើ អញនឹងធ្វើ ដោយប្រការដែលជនដទៃមិនបាន ឱកាស ដូច្នោះ ។ ឬបព្វជិត កាលធ្វើវត្តទាំងឡាយ មានឧបជ្ឈាយវត្តជាដើម មិនឲ្យឱកាសដល់អ្នកដទៃ គួរធ្វើដោយរហ័សនោះឯង ដោយគិតថា អញនឹងធ្វើអញ នឹងធ្វើ ។

ពីរបទថា **បាបា ចិត្តំ** សេចក្តីថា បុគ្គលគប្បីហាមចិត្តចាកបាបកម្ម មានកាយទុច្ចរិតជាដើម ឬចាកអកុសលចិត្តប្បាទក្នុងទីគ្រប់អន្លើ ។

ពីរបទថា **ទន្ធំ ហិ ករតោ** សេចក្តីថា បុគ្គលណាគិតយ៉ាងនេះថា អញនឹងឲ្យ នឹងធ្វើ ផលនេះនឹងសម្រេចដល់អញឬទេ ឈ្មោះថា ធ្វើបុណ្យយឺតយូរ ដូចបុគ្គលដើរផ្លូវរអិល សេចក្តីអាក្រក់របស់បុគ្គលនោះរមែងបានឱកាស ដូចជាមច្ឆរិយចិត្តមួយពាន់ របស់ព្រាហ្មណ៍ឈ្មោះឯកសាដក ដូច្នោះ ។ កាលបើដូច្នោះ ចិត្តរបស់បុគ្គលនោះ រមែងត្រេកអរក្នុងបាប ព្រោះថា ក្នុងកាលដែលធ្វើកុសលកម្មប៉ុណ្ណោះ ចិត្តរមែងត្រេកអរក្នុងកុសលកម្ម ផុតអំពីនោះរមែងបង្អោនទៅកាន់សេចក្តីអាក្រក់បានពិត ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

**រឿង ព្រាហ្មណ៍ចូឡេកសាដក ចប់**

# រឿង ព្រះសេយ្យសកត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសេយ្យសកត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **បាបញ្ចេ បុរិសោ កយិរា** ជាដើម ។

បានឮមកថា ព្រះសេយ្យសកត្ថេរនោះ ជាសទ្ធិវិហារិករបស់ព្រះលោឡុទាយិត្ថេរ ប្រាប់ការមិនត្រេកអររបស់ខ្លួន ដល់ព្រះលោឡុទាយីនោះ ត្រូវលោកដឹកនាំក្នុងការធ្វើបឋមសង្ឃាទិសេស កាលការមិនត្រេកអរកើតទៀងឡើង បានធ្វើកម្មនោះហើយ ។

ព្រះសាស្តា បានស្តាប់កិរិយារបស់លោក ទ្រង់ត្រាស់ឲ្យហៅមកហើយ សួរថា បានឮថា អ្នកធ្វើយ៉ាងនោះពិតឬ កាលលោកទូលថា យ៉ាងនោះឯងព្រះអង្គ ទើបត្រាស់ថា នែមោឃបុរស ហេតុអ្វី ទើបអ្នកធ្វើកម្មធ្ងន់ដែលមិនសមគួរ ទ្រង់តិះដៀលដោយប្រការផ្សេងៗ ទ្រង់បញ្ញត្តសិក្ខាបទហើយ ត្រាស់ថា កម្មបែបនេះ ជាកម្មញុំាងសត្វឲ្យប្រព្រឹត្តទៅដើម្បីទុក្ខតែម្យ៉ាង ទាំងក្នុងភពនេះ ទាំងក្នុងភពខាងមុខ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**បាបញ្ចេ បុរិសោ កយិរា ន នំ កយិរា បុនប្បុនំ**
**ន តម្ហិ ឆន្ទំ កយិរាថ ទុក្ខោ បាបស្ស ឧច្ចយោ ។**

បើបុរសធ្វើបាប កុំធ្វើបាបនោះរឿយៗ ឡើយ កុំធ្វើសេចក្តីពេញចិត្តក្នុងបាបនោះ ( ព្រោះថា ) ការសន្សំបាប តែងនាំសេចក្តីទុក្ខមកឲ្យ ។

## សេចក្ដីអធិប្បាយ

អត្ថនៃព្រះគាថានេះថា បើបុគ្គលធ្វើនូវកម្មលាមកម្ដង គួរពិចារណាក្នុងខណៈនោះឯង សិក្សាថា កម្មនេះមិនសមគួរ ជាកម្មគ្រោតគ្រាត មិនគួរធ្វើកម្មនោះរឿយៗ គប្បីបន្ទោរបង់ មិនគួរធ្វើនូវការពេញចិត្ត ឬការគាប់ចិត្តក្នុងបាបនោះ ដែលគប្បីកើតឡើងឡើយ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះថា ការសន្សំ គឺការសន្សំនូវបាបជាហេតុឲ្យកើតទុក្ខ គឺរមែងនាំតែទុក្ខមកឲ្យទាំងក្នុងលោកនេះ ទាំងក្នុងលោកខាងមុខ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

**រឿង ព្រះសេយ្យសកត្ថេរ ចប់**

# រឿង នាងលាជទេពធីតា

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងលាជទេព-ធីតា ត្រាស់ព្រះធម្មទេសនានេះថា **បុញ្ញញ្ចេ បុរិសោ កយិរា** ជាដើម រឿងកើតឡើងហើយ ក្នុងនគររាជគ្រឹះ ។

សេចក្ដីពិស្ដារថា ព្រះមហាកស្សបដែលនៅត្រង់បិប្ផលិគុហា ចូលឈានហើយ ចេញក្នុងថ្ងៃទី ៧ ប្រមើលមើលទីដែលត្រូវទៅដើម្បីបិណ្ឌបាតដោយទិព្វចក្ខុ ឃើញស្រីចាំស្រូវសាលីម្នាក់ក្ដិចក្តួរស្រូវធ្វើលាជ ពិចារណាថា ស្រី

នេះមានសទ្ធាដែរឬហ្ន៎ ដឹងថា មានសទ្ធា ពិចារណាថា នាងនឹងអាចធ្វើការសង្គ្រោះដល់អាត្មាអញបានឬហ្ន៎ ដឹងថា កុលធីតាជាស្រីក្លាហាន នឹងធ្វើការសង្គ្រោះដល់អញ កាលធ្វើហើយនឹងបានសម្បត្តិដ៏ច្រើន ទើបឃ្លុំចីវរ កាន់បាត្រ បានឈរនៅទីជិតស្រែស្រូវសាលី ។ កុលធីតាឃើញព្រះថេរៈ មានចិត្តជ្រះថ្លា មានសរីរៈដែលបីតិទាំង ៥ ពាល់ត្រូវហើយ ពោលថា សូមលោកម្ចាស់និមន្តរង់ចាំសិន កាន់លាជទៅដោយរហ័ស កៀរទម្លាក់ក្នុងបាត្ររបស់ព្រះថេរៈហើយ ថ្វាយបង្គំដោយបញ្ចង្គប្រដិស្ឋាន បានធ្វើសេចក្ដីប្រាថ្នាថា បពិត្រលោកម្ចាស់ ខ្ញុំគប្បីជាអ្នកមានចំណែកនៃធម៌ដែលលោកម្ចាស់ឃើញហើយ ។

ព្រះថេរៈបានធ្វើអនុមោទនាថា សេចក្ដីប្រាថ្នាយ៉ាងនោះ ចូរសម្រេចចុះ ចំណែកនាងថ្វាយបង្គំព្រះថេរៈហើយ គិតដល់ទានដែលខ្លួនឲ្យហើយ ត្រឡប់ទៅ ។ ក្នុងផ្លូវដែលនាងដើរទៅលើភ្លឺស្រែ មានពស់កាចដេកក្នុងរន្ធមួយកន្លែង ពស់មិនអាចចឹកស្មងព្រះថេរៈ ដែលបិទបាំងដោយកាសាវពស្ត្របាន ។ នាងវព្រកដល់ទានត្រឡប់ទៅដល់ទីនោះ ពស់លូនចេញអំពីរន្ធ ចឹកនាងឲ្យដួលចុះក្នុងទីនោះឯង នាងមានចិត្តជ្រះថ្លាធ្វើកាលកិរិយាហើយ ទៅកើតក្នុងវិមានមាសប្រមាណ ៣០ យោជន៍ ក្នុងតាវត្តិង្សពិភព មានអត្តភាពប្រមាណ ៣ គាវុតប្រដាប់ដោយគ្រឿងអលង្ការគ្រប់យ៉ាង ដូចដេកលក់ ហើយភ្ញាក់ឡើង ។

នាងស្លៀកសំពត់ទិព្វប្រមាណ ១២ ហត្ថ មួយផ្ទាំង ដណ្ដប់មួយផ្ទាំង ចោមរោមដោយទេពអប្សរមួយពាន់ ដើម្បីប្រកាសបុព្វកម្ម ទើបឈរត្រង់ទ្វារ

វិមាន ដែលប្រដាប់ដោយផ្ដិលមាស ពេញដោយលាជមាសសំយុងនៅ សម្លឹង មើលទិព្វសម្បត្តិរបស់ខ្លួន ពិចារណាដោយទិព្វចក្ខុថា អញធ្វើកម្មអ្វីហ្ន៎ ទើប បានសម្បត្តិនេះ បានដឹងថា សម្បត្តិនេះ អញបានហើយ ព្រោះផលនៃលាជ ដែលអញប្រគេនដល់លោកម្ចាស់កស្សបត្ថេរ នាងគិតថា អញបានសម្បត្តិ បែបនេះ ព្រោះកម្មតិចតួចយ៉ាងនេះ ឥឡូវនេះ អញមិនគួរប្រមាទ អញនឹង ធ្វើវត្តបដិបត្តិដល់លោកម្ចាស់ ធ្វើសម្បត្តិនេះឲ្យស្ថិតស្ថេរ ទើបកាន់អំបោស និងកំប្រោង សម្រាប់ចាក់សំរាម សម្រេចដោយមាស ទៅបោសបរិវេណ របស់ព្រះថេរៈ ហើយដងទឹកឆាន់ ទឹកប្រើប្រាស់អំពីព្រលឹម ។

ព្រះថេរៈឃើញដូច្នោះ សម្គាល់ថាជាវត្តដែលភិក្ខុ ឬសាមណេររូបខ្លះ ធ្វើ ។ ក្នុងថ្ងៃទី ២ នាងក៏បានធ្វើយ៉ាងនោះ ចំណែកព្រះថេរៈក៏សម្គាល់ដូច្នោះ ដូចគ្នា ។ តែក្នុងថ្ងៃទី ៣ ព្រះថេរៈបានឮសំឡេងអំបោសរបស់នាង និងឃើញ ពន្លឺអំពីសរីរៈចាំងចូលទៅតាមរន្ធទ្វារ ទើបបើកទ្វារចេញមកសួរថា អ្នកណា បោស នាងឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំជាឧបដ្ឋាយិការបស់លោកម្ចាស់ ឈ្មោះលាជទេពធីតា ព្រះថេរៈឆ្លើយថា ឧបដ្ឋាយិការបស់អាត្មាឈ្មោះយ៉ាង នេះដូចជាមិនមាន ។ នាងឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំយាមស្រូវប្រគេន លាជហើយ មានចិត្តជ្រះថ្លា កំពុងត្រឡប់ទៅត្រូវពស់ចឹក ធ្វើកាលកិរិយាហើយ កើតក្នុងទេវលោកជាន់តាវត្តិង្ស ខ្ញុំគិតថា សម្បត្តិដែលអញបានព្រោះអាស្រ័យ លោកម្ចាស់ ឥឡូវនេះ អញនឹងធ្វើវត្តដល់លោក ធ្វើសម្បត្តិឲ្យស្ថិតស្ថេរ ទើបមក ព្រះថេរៈពោលថា ម្សិលមិញក្ដី ម្សិលម្ង៉ៃក្ដី នាងបោសទីនេះ ហើយ

តម្កល់ទឹកឆាន់ ទឹកប្រើប្រាស់ឬ នាងពោលថា បពិត្រលោកម្ចាស់ យ៉ាងនោះឯង ព្រះថេរៈពោលថា នែទេពធីតា ចូរចៀសចេញទៅ វត្តដែលនាងធ្វើហើយ ក៏ធ្វើហើយចុះ តាំងអំពីនេះទៅ នាងកុំមកទីនេះ ទេពធីតាពោលថា បពិត្រលោកម្ចាស់ កុំឲ្យខ្ញុំវិនាសឡើយ សូមលោកម្ចាស់ឲ្យខ្ញុំធ្វើវត្តដល់លោកម្ចាស់ ធ្វើសម្បត្តិរបស់ខ្ញុំឲ្យមាំទាំចុះ ព្រះថេរៈពោលថា នែទេពធីតា ចូរចៀសចេញទៅ នាងកុំធ្វើឲ្យអាត្មាត្រូវធម្មកថិកទាំងឡាយ អង្គុយចាប់ផ្ចិតដ៏វិចិត្រ ពោលក្នុងអនាគតថា បានឮថា ទេពធីតាមួយរូប មកធ្វើវត្តបដិបត្តិចូលទៅតម្កល់ទឹកឆាន់ ទឹកប្រើប្រាស់ដើម្បីព្រះមហាកស្សបត្ថេរ តាំងអំពីនេះទៅ នាងកុំមកក្នុងទីនេះឡើយ ចូរត្រឡប់ទៅចុះ ទើបនាងអង្វរដដែលទៀតថា សូមលោកម្ចាស់ កុំឲ្យខ្ញុំវិនាសឡើយ ។

ព្រះថេរៈគិតថា ទេពធីតានេះមិនស្តាប់ពាក្យរបស់អញ ទើបទះដៃដោយពោលថា នាងមិនស្គាល់ប្រមាណ ។ នាងមិនអាចតាំងនៅក្នុងទីនោះបាន ខ្ទាតឡើងទៅក្នុងអាកាស ផ្គងអញ្ជលីទ្រហោយំក្នុងអាកាសថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់កុំឲ្យសម្បត្តិរបស់ខ្ញុំវិនាសឡើយ សូមឲ្យខ្ញុំធ្វើឲ្យមាំទាំចុះ ។

ព្រះសាស្តាប្រថាប់គង់ក្នុងព្រះគន្ធកុដិនោះឯង ទ្រង់ស្តាប់សំឡេងទេពធីតានោះយំ ទ្រង់ផ្សាយព្រះរស្មីដូចប្រថាប់គង់ក្នុងទីចំពោះមុខទេពធីតានោះ ត្រាស់ថា ម្នាលទេពធីតា ការធ្វើសំវរៈនោះឯង ជាការៈរបស់កស្សបបុត្រតថាគត តែការកំណត់ថា នេះជាប្រយោជន៍របស់អញ ហើយបំណងធ្វើតែបុណ្យ រមែងជាការៈរបស់អ្នកមានសេចក្តីត្រូវការដោយបុណ្យ ព្រោះថា ការធ្វើបុណ្យ ជា

ហេតុឲ្យកើតសុខតែម្យ៉ាង ទាំងក្នុងភពនេះ ទាំងក្នុងភពខាងមុខ ដូច្នេះ កាល ទ្រង់បន្តអនុសន្ធិសម្ដែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**បុញ្ញញ្ចេ បុរិសោ កយិរា    កយិរាថេនំ បុនប្បុនំ**
**តម្ហិ ឆន្ទំ កយិរាថ    សុខោ បុញ្ញស្ស ឧច្ចយោ ។**

បើបុរសធ្វើបុណ្យ គួរធ្វើបុណ្យនោះឲ្យរឿយៗ គួរធ្វើសេចក្ដីពេញចិត្តក្នុងបុណ្យនោះ ( ព្រោះថា ) ការសន្សំបុណ្យតែងនាំសេចក្ដីសុខមកឲ្យ ។

## សេចក្ដីអធិប្បាយ

អត្ថនៃព្រះគាថានោះថា បើបុរសគប្បីធ្វើបុណ្យសោត មិនគប្បីវៀរដោយយល់ថា អញធ្វើបុណ្យម្ដងហើយ គ្រប់គ្រាន់ដោយបុណ្យត្រឹមប៉ុណ្ណេះ គប្បីធ្វើរឿយៗ ក្នុងខណៈធ្វើបុណ្យនោះ គប្បីធ្វើការពេញចិត្ត គឺការគាប់ចិត្តបានដល់ ការឧស្សាហ៍ក្នុងបុណ្យនោះឯង សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះការសន្សំបុណ្យនាំឲ្យកើតសុខ អធិប្បាយថា ព្រោះការសន្សំ គឺការប្រមូលនូវបុណ្យ ឈ្មោះថា ញ៉ាំងសេចក្ដីសុខឲ្យកើត ព្រោះជាហេតុនាំសេចក្ដីសុខមកឲ្យ ក្នុងលោកនេះ និងលោកខាងមុខ ។

ក្នុងកាលចប់ទេសនា នាងលាជទេវធីតានោះឈរក្នុងទីបំផុត ៤៥ យោជន៍នោះឯង បានសម្រេចសោតាបត្តិផលហើយដូច្នេះឯង ។ល។

**រឿង នាងលាជទេវធីតា ចប់**

# រឿង អនាថបិណ្ឌិកសេដ្ឋី

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសេដ្ឋីឈ្មោះអនាថបិណ្ឌិក ត្រាស់ព្រះធម្មទេសនានេះថា **បាបោបិ បស្សតិ ភទ្រំ** ជាដើម ។

សេចក្តីពិស្តារថា អនាថបិណ្ឌិកសេដ្ឋីចំណាយទ្រព្យ ៥៤ កោដិក្នុងព្រះពុទ្ធសាសនាចំពោះវិហារប៉ុណ្ណោះ កាលព្រះសាស្តាប្រថាប់នៅក្នុងវត្តជេតពន ទៅកាន់ទីទំនុកបម្រុងធំ ៣ កន្លែងរាល់ថ្ងៃ កាលទឹងទៅ គិតថា សាមណេរក្តី ភិក្ខុកំលោះក្តី គប្បីសម្លឹងមើលដៃរបស់អញដោយការទឹកថា សេដ្ឋីនោះកាន់អ្វីមកខ្លះដូច្នេះ មិនធ្លាប់ជាអ្នកមានដៃទទេទៅឡើយ ទៅក្នុងពេលព្រឹកឲ្យមនុស្សកាន់បបរទៅ បរិភោគអាហារព្រឹកហើយ ឲ្យមនុស្សកាន់ភេសជ្ជៈទាំងឡាយ មានសប្បិ នវនីតជាដើមទៅ ក្នុងពេលល្ងាច បានកាន់វត្ថុផ្សេងៗ មានកម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប និងសំពត់ជាដើមទៅកាន់វិហារ ថ្វាយទាន រក្សាសីលយ៉ាងនេះ រាល់ៗ ថ្ងៃអ ស់កាលជានិច្ច ។

សម័យតមក សេដ្ឋីដល់នូវការអស់ទៅនៃទ្រព្យ ទាំងពួកពាណិជ ក៏ខ្ចីទ្រព្យ ១៨ កោដិ អំពីដៃសេដ្ឋីនោះ ។ ប្រាក់ ១៨ កោដិ ជាសម្បត្តិនៃត្រកូលរបស់សេដ្ឋី ដែលកប់ក្បែរមាត់ស្ទឹង កាលច្រាំងបាក់ព្រោះទឹកច្រោះ ក៏ហូរទៅកាន់មហាសមុទ្រ ទ្រព្យរបស់សេដ្ឋីនោះ ដល់នូវការអស់ទៅដោយលំដាប់ ដោយប្រការយ៉ាងនេះ ។

សេដ្ឋីសូម្បីខ្វនយ៉ាងនោះហើយ ក៏នៅតែថ្វាយទាន ដល់សង្ឃរឿយៗ

ទៅ តែមិនអាចធ្វើឲ្យប្រណីតបាន ។ ក្នុងថ្ងៃមួយ សេដ្ឋី កាលព្រះសាស្តា ត្រាស់ថា ម្នាលគហបតី ទានក្នុងត្រកូលអ្នកនៅតែឲ្យឬ ក៏ក្រាបទូលថា បពិត្រព្រះអង្គ ទានក្នុងត្រកូលខ្ញុំព្រះអង្គ នៅតែឲ្យ តែទាននោះ ជាបាយចុង អង្ករ មានទឹកជ្រក់ជាគម្រប់ពីរ ។

ពេលនោះ ព្រះសាស្តាត្រាស់នឹងសេដ្ឋីនោះថា ម្នាលគហបតី អ្នកកុំគិតថា អញឲ្យទានសៅហ្មងឡើយ ព្រោះថា កាលចិត្តប្រណីតហើយ ទានដែលបុគ្គលថ្វាយដល់ព្រះអរហន្តទាំងឡាយ មានព្រះពុទ្ធជាដើម ឈ្មោះថា សៅហ្មង រមែងមិនមាន ម្នាលគហបតី មួយវិញទៀត អ្នកបានថ្វាយទានដល់ព្រះអរិយបុគ្គលទាំង ៨ ហើយ ចំណែកតថាគត ក្នុងកាលនៅជាវេលាម-ព្រាហ្មណ៍នោះ ធ្វើអ្នកជម្ពូទ្វីបទាំងមូលឲ្យឈប់ភ្ជួរស្រែ ញ៉ាំងមហាទានឲ្យប្រព្រឹត្តទៅមិនបានទក្ខិណេយ្យបុគ្គលណាម្នាក់ សូម្បីជាអ្នកដល់នូវត្រៃសរណៈ ឈ្មោះថា ទក្ខិណេយ្យបុគ្គលទាំងឡាយ លំបាកដែលបុគ្គលបាន ដោយប្រការដូច្នេះ ព្រោះហេតុនោះ អ្នកកុំគិតឡើយថា ទានរបស់អញសៅហ្មង ដូច្នេះ ហើយត្រាស់វេលាមសូត្រ ដល់សេដ្ឋីនោះ ។

គ្រានោះ ទេវតាដែលស្ថិតនៅត្រង់ខ្លោងទ្វាររបស់សេដ្ឋី កាលព្រះសាស្តា និងសាវកទាំងឡាយចូលទៅកាន់ផ្ទះ មិនអាចតាំងនៅបាន ព្រោះតេជះព្រះដ៏មានព្រះភាគ និងសាវកទាំងនោះ គិតថា ព្រះសាស្តា និងសាវកទាំងនេះ មិនចូលទៅកាន់ផ្ទះដោយប្រការណា អញនឹងញុះញង់គហបតីដោយប្រការនោះ ប្រាថ្នានឹងពោលជាមួយសេដ្ឋីនោះ ក៏មិនបានដើម្បីពោលនូវពាក្យ

ណាមួយ ក្នុងកាលដែលសេដ្ឋីជាឥស្សរៈ គិតថា ឥឡូវនេះ សេដ្ឋីនេះក្រីក្រ ហើយ គង់នឹងជឿពាក្យរបស់អញ ក្នុងពេលរាត្រី ចូលទៅកាន់បន្ទប់ដែលជាសិរីរបស់សេដ្ឋី ឈរនៅក្នុងអាកាស ។ ខណៈនោះ សេដ្ឋីឃើញទេវតានោះហើយ សួរថា នុ៎ះជាអ្នកណា ទេវតាពោលថា លោកមហាសេដ្ឋី ខ្ញុំជាទេវតាអាស្រ័យនៅត្រង់ខ្លោងទ្វារទី ៤ របស់អ្នក មកដើម្បីដាស់តឿនអ្នក សេដ្ឋីពោលថា បើដូច្នោះ សូមអ្នកនិយាយចុះ ទេវតាពោលថា លោកសេដ្ឋី លោកមិនសម្លឹងមើលដល់កាលខាងក្រោយឡើយ ចាយទ្រព្យជាច្រើន ក្នុងសាសនារបស់ព្រះសមណគោតម ឥឡូវនេះ លោកជាអ្នកក្រីក្រហើយ ក៏នៅតែមិនលះបង់ការចាយទ្រព្យទៀត កាលលោកប្រព្រឹត្តយ៉ាងនេះ នឹងមិនបានវត្ថុត្រឹមតែអាហារ និងគ្រឿងស្លៀកដណ្តប់ត្រឹម ២-៣ ថ្ងៃពិត លោកត្រូវការអ្វី ដោយព្រះសមណគោតម សូមលោកឈប់បរិច្ចាគហួសកម្លាំង ហើយប្រកបការងារទាំងឡាយ ប្រមូលសម្បត្តិចុះ សេដ្ឋីពោលថា នេះជាឱវាទដែលអ្នកឲ្យដល់ខ្ញុំឬ ទេវតាពោលថា អើ លោកមហាសេដ្ឋី សេដ្ឋីពោលថា សូមអ្នកទៅចុះ បុគ្គលដូចអ្នករាប់រយ រាប់ពាន់ រាប់សែន ក៏មិនអាចធ្វើខ្ញុំឲ្យញាប់ញ័របាន អ្នកពោលពាក្យមិនសមគួរ នឹងត្រូវការអ្វី ដោយអ្នកដែលនៅក្នុងផ្ទះរបស់ខ្ញុំ ចូរអ្នកចេញអំពីផ្ទះរបស់ខ្ញុំឲ្យរហ័ស ។

ទេវតានោះ ស្តាប់ពាក្យរបស់សេដ្ឋី ដែលជាសោតាបន្នអរិយសាវក ហើយ មិនអាចស្ថិតនៅបាន ទើបនាំទារកទាំងឡាយចេញទៅ កាលចេញទៅហើយ មិនបានទីលំនៅក្នុងទីដទៃ ទើបគិតថា អញនឹងឲ្យលោកសេដ្ឋីអត់ទោស

ហើយនៅក្នុងកន្លែងដើមនោះឯង ចូលទៅរកទេវបុត្រអ្នករក្សាព្រះនគរ ប្រាប់នូវកំហុស ដែលខ្លួនធ្វើហើយ ពោលថា សូមអ្នកមកចុះ សូមអ្នកនាំខ្ញុំទៅកាន់សម្នាក់របស់សេដ្ឋី ឲ្យលោកសេដ្ឋីអត់ទោស ហើយឲ្យទីលំនៅដល់ខ្ញុំ ទេវបុត្រឃាត់ទេវតានោះថា អ្នកធ្វើមិនសមគួរ ខ្ញុំមិនអាចទៅកាន់សម្នាក់របស់សេដ្ឋីនោះបាន ។ ទើបទេវតានោះចូលទៅកាន់សម្នាក់របស់មហារាជទាំង ៤ ក៏ត្រូវមហារាជទាំងនោះឃាត់ ទើបចូលទៅកាន់សម្នាក់សក្កទេវរាជ ក្រាបទូលរឿងនោះឲ្យទ្រង់ជ្រាបហើយ ទូលអង្វរដ៏គួរឲ្យអាណិតថា បពិត្រព្រះអង្គ ទូលបង្គំមិនបានទីលំនៅ ត្រូវដឹកដៃទារកទាំងឡាយ ដើរក្នុងទីផ្សេងៗ រកទីពឹងមិនបាន សូមទ្រង់ឲ្យសេដ្ឋីឲ្យនូវទីលំនៅ ដល់ទូលបង្គំចុះ ។

គ្រានោះ សក្កទេវរាជត្រាស់នឹងទេវតានោះថា ខ្ញុំមិនអាចពោលនឹងសេដ្ឋី ព្រោះហេតុនៃអ្នកបាន តែនឹងប្រាប់ឧបាយមួយដល់អ្នក ទេវតាពោលថា សាធុ ព្រះអង្គ សូមទ្រង់មេត្តាប្រាប់ចុះ សក្កទេវរាជពោលថា ចូរអ្នកទៅចុះ កាឡាខ្លួនជាស្មៀនរបស់សេដ្ឋី ឲ្យបុគ្គលណាម្នាក់នាំបញ្ជីអំពីដៃសេដ្ឋីមកហើយ នាំទៅឲ្យអ្នកជំពាក់បំណុលសងទ្រព្យ ១៨ កោដិ ដែលពួកឈ្មួញកាន់យកទៅ ដោយអានុភាពរបស់ខ្លួនហើយ ដាក់ឲ្យពេញក្នុងបន្ទប់ទទេ ទ្រព្យ ១៨ កោដិ ដែលហូរទៅកាន់មហាសមុទ្រក្តី ទ្រព្យ ១៨ កោដិដទៃដែលមិនមានម្ចាស់ នៅក្នុងទីឈ្មោះនោះក្តី ចូរប្រមូលទ្រព្យទាំងអស់នោះ ដាក់ឲ្យពេញក្នុងបន្ទប់ទទេរបស់សេដ្ឋី កាលធ្វើកម្មឈ្មោះនេះ ឲ្យជាទណ្ឌកម្មហើយ សឹមសូមខមាទោសនឹងលោកសេដ្ឋី ។

ទេវតានោះទទួលថា សាធុព្រះអង្គ ហើយធ្វើកម្មគ្រប់យ៉ាងតាមន័យដែលសក្កទេវរាជប្រាប់ហើយនោះឯង ញ៉ាំងបន្ទប់ដែលជាសិរីរបស់សេដ្ឋីឲ្យភ្លឺ តាំងនៅក្នុងអាកាស កាលលោកសេដ្ឋីពោលថា នុ៎ះជាអ្នកណា ទើបឆ្លើយថា ខ្ញុំជាទេវតាអន្ធពាល ស្ថិតនៅត្រង់ខ្លោងទ្វារទី ៤ របស់លោក ពាក្យណាដែលខ្ញុំពោលហើយ ក្នុងសម្នាក់របស់លោក ដោយភាពជាអន្ធពាល សូមលោកអត់ទោសនោះដល់ខ្ញុំចុះ ខ្ញុំបានធ្វើទណ្ឌកម្មដោយការប្រមូលទ្រព្យ ៥៤ កោដិមកដាក់ពេញបន្ទប់ទទេ តាមបញ្ជារបស់សក្កទេវរាជ ខ្ញុំមិនមានទីលំនៅរមែងលំបាក ។

អនាថបិណ្ឌិកសេដ្ឋី ចិន្តនាការថា ទេវតានេះពោលថា ទណ្ឌកម្មខ្ញុំបានធ្វើហើយដូច្នេះ នឹងដឹងនូវទោសរបស់ខ្លួន អញនឹងបង្ហាញទេវតានោះដល់ព្រះសម្មាសម្ពុទ្ធ លោកសេដ្ឋីនាំទេវតានោះទៅកាន់សម្នាក់របស់ព្រះសាស្តា ក្រាបទូលកម្មដែលទេវតានោះធ្វើហើយទាំងអស់ ទេវតាក្រាបចុះដោយសិរសា គឺត្បូង ទៀបព្រះយុគលបាទនៃព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមិនជ្រាបព្រះគុណទាំងឡាយរបស់ទ្រង់ បានពោលពាក្យថោកទាបព្រោះភាពជាអន្ធពាល សូមទ្រង់អត់ទោសនូវពាក្យនោះដល់ខ្ញុំព្រះអង្គ បានឲ្យព្រះសាស្តាអត់ទោសហើយ ទើបឲ្យមហាសេដ្ឋីអត់ទោសឲ្យ ក្នុងកាលជាក្រោយ ។

ព្រះសាស្តា កាលទ្រង់ទូន្មានសេដ្ឋី និងទេវតា ដោយអំណាចវិបាកនៃកម្មល្អ និងកម្មអាក្រក់នោះឯង ទើបត្រាស់ថា ម្នាលគហបតី បុគ្គលអ្នកធ្វើ

បាប ក្នុងលោកនេះ រមែងឃើញបាប ថាល្អ អស់កាលដែលបាបមិនទាន់ឲ្យផល តែកាលណា បាបរបស់បុគ្គលនោះឲ្យផល កាលនោះ បុគ្គលនោះឃើញនូវបាបថា អាក្រក់ពិតៗ ចំណែកបគ្គលអ្នកធ្វើកម្មល្អ រមែងឃើញកម្មល្អថា អាក្រក់ ដរាបណាដែលកម្មល្អមិនទាន់ឲ្យផល តែកាលណា កម្មល្អរបស់បុគ្គលនោះឲ្យផល កាលនោះ បុគ្គលនោះ រមែងឃើញកម្មល្អថា ល្អពិតៗ ដូច្នេះហើយ កាលទ្រង់បន្តអានុសន្ធិសម្តែងធម៌ ទើបភាសិតព្រះគាថានេះថាទុកថា

**បាបោបិ បស្សតី ភទ្រំ យាវ បាបំ ន បច្ចតិ**
**យទា ច បច្ចតី បាបំ អថ (បាបោ) បាបានិ បស្សតិ ។**
**ភទ្រោបិ បស្សតី បាបំ យាវ ភទ្រំ ន បច្ចតិ**
**យទា ច បច្ចតី ភទ្រំ អថ (ភទ្រោ) ភទ្រានិ បស្សតិ ។**

បាបមិនទាន់ឲ្យផលត្រឹមណា មនុស្សបាប ក៏នៅឃើញតែ
សេចក្តីចម្រើនត្រឹមណោះ លុះកាលណា បាបឲ្យផល
មនុស្សបាប ទើបឃើញបាបក្នុងកាលនោះ ។
អំពើល្អ មិនទាន់ឲ្យផលត្រឹមណា មនុស្សល្អ នៅឃើញ
តែបាបត្រឹមណោះ លុះកាលណា អំពើល្អឲ្យផល មនុស្ស
ល្អ ទើបឃើញល្អ ក្នុងកាលនោះ ។

## សេចក្តីអធិប្បាយ

បុគ្គលដែលប្រកបបាបកម្ម មានកាយទុច្ចរិតជាដើម ឈ្មោះថា បុគ្គល

បាប ក្នុងព្រះគាថានេះ ។

បុគ្គលនោះ កាលសោយសុខ ដែលកើតឡើងដោយអានុភាពនៃសុចរិតកម្មក្នុងកាលមុន រមែងឃើញបាបកម្មថា ល្អ ។

បាទព្រះគាថាថា **យាវ ចាបំ ន បច្ចតិ** ជាដើម សេចក្តីថា បាបកម្មរបស់បុគ្គលនោះ មិនទាន់ឲ្យផលក្នុងបច្ចុប្បន្នភព ឬសម្បរាយភពដរាបណា បុគ្គលធ្វើបាប រមែងឃើញបាបថាល្អដរាបនោះ តែកាលបាបកម្មរបស់បុគ្គលនោះឲ្យផលក្នុងបច្ចុប្បន្នភព ឬក្នុងសម្បរាយភព កាលនោះ អ្នកធ្វើបាបនោះ កាលសោយកម្មករណៈផ្សេងៗ ក្នុងបច្ចុប្បន្នភព និងទុក្ខក្នុងអបាយ ក្នុងសម្បរាយភព រមែងឃើញបាបថា អាក្រក់ ដោយចំណែកមួយ ។

ក្នុងព្រះគាថាទី ២ គប្បីជ្រាបសេចក្តីដូចតទៅនេះ បុគ្គលដែលប្រកបកម្ម ដែលមានកាយសុចរិតជាដើម ឈ្មោះថា អ្នកធ្វើកម្មល្អ បុគ្គលធ្វើកម្មល្អនោះ កាលសោយទុក្ខដែលកើតឡើង ដោយអានុភាពនៃទុច្ចរិតក្នុងកាលមុន រមែងឃើញកម្មល្អថា អាក្រក់ ។

បាទព្រះគាថាថា **យាវ ភទ្រំ ន បច្ចតិ** ជាដើម សេចក្តីថា កម្មល្អរបស់បុគ្គលនោះ មិនទាន់ឲ្យផលក្នុងបច្ចុប្បន្នភព ឬក្នុងសម្បរាយភពដរាបណា ។ បុគ្គលធ្វើកម្មល្អ រមែងឃើញល្អថា អាក្រក់ដរាបនោះ តែកាលណាកម្មល្អនោះឲ្យផល កាលនោះ អ្នកធ្វើកម្មល្អនោះ កាលសោយសុខដែលអាស្រ័យអាមិស មានលាភ និងសក្ការៈជាដើមក្នុងបច្ចុប្បន្នភព និងសុខដែលអាស្រ័យសម្បត្តិ ដែលជាទិព្វក្នុងសម្បរាយភព រមែងឃើញកម្មល្អ ថាល្អ

ពិតៗ ដូច្នេះ ។

ក្នុងកាលចប់ទេសនា ទេវតានោះ តាំងនៅក្នុងសោតាបត្តិផល ព្រះធម្មទេសនា មានប្រយោជន៍ដល់បរិស័ទដែលមកប្រជុំគ្នា ដូច្នេះឯង ។

**រឿង អនាថបិណ្ឌិកសេដ្ឋី ចប់**

# រឿង ភិក្ខុមិនទុកដាក់បរិក្ខារ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមួយរូប ដែលមិនទុកដាក់បរិក្ខារ ត្រាស់ព្រះធម្មទេសនានេះថា **មាវមញ្ញេថ បាបស្ស** ជាដើម ។

បានឮថា ភិក្ខុនោះប្រើប្រាស់បរិក្ខារ មានគ្រែ និងតាំងជាដើមឯណានីមួយខាងក្រៅហើយ ទុកចោលក្នុងទីនោះឯង បរិក្ខាររមែងវិនាសទៅ ព្រោះភ្លៀងខ្លះ កម្តៅថ្ងៃខ្លះ ពួកសត្វ មានកណ្តៀរជាដើមខ្លះ ។ ភិក្ខុនោះ កាលពួកភិក្ខុពោលដាស់តឿនថា អាវុសោ ធម្មតាបរិក្ខារ ភិក្ខុគួរទុកដាក់ មិនមែនឬ បែរជាពោលថា អាវុសោ កម្មដែលខ្ញុំធ្វើនោះតូចតាច បរិក្ខារនោះមិនមានចិត្ត ការវិចិត្រក៏មិនមាន ដូច្នេះហើយ នៅតែធ្វើយ៉ាងនោះដដែល ។ ភិក្ខុទាំងឡាយក្រាបទូលកិរិយារបស់លោកដល់ព្រះសាស្តា ។

ព្រះសាស្តាត្រាស់ឲ្យហៅភិក្ខុនោះមកហើយ ត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកធ្វើយ៉ាងនោះពិតឬ ភិក្ខុនោះត្រូវព្រះសាស្តាត្រាស់សួរហើយ ក៏ក្រាបទូលបែបមើលងាយយ៉ាងនោះឯងថា បពិត្រព្រះមានព្រះភាគ សេចក្តីនោះមានជាការអ្វី ខ្ញុំព្រះអង្គធ្វើកម្មតិចតួច បរិក្ខារនោះមិនមានចិត្ត ការវិចិត្រក៏មិនមាន ។

គ្រានោះ ព្រះសាស្តាត្រាស់នឹងភិក្ខុនោះថា ម្នាលភិក្ខុ អ្នកធ្វើយ៉ាងនោះមិនគួរ ឈ្មោះថា បាបកម្ម បុគ្គលមិនគួរមើលងាយថា តិចតួច ឧបមាដូចភាជនៈ ដែលគេបើកគម្របទុកក្នុងទីវាល កាលភ្លៀងធ្លាក់ចុះ មិនពេញដោយតំណក់ទឹកដោយពិត តែកាលភ្លៀងធ្លាក់រឿយៗ ភាជនៈនោះរមែងពេញបានពិត យ៉ាងណា បុគ្គលដែលធ្វើបាបកម្ម រមែងធ្វើគំនរបាបឲ្យធំឡើងដោយលំដាប់បានដោយពិត ក៏ដូច្នោះដូចគ្នា ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**មាវមញ្ញេថ បាបស្ស　　ន មន្តំ អាគមិស្សតិ**
**ឧទពិន្ទុនិបាតេន　　ឧទកុម្ភោបិ បូរតិ**
**អាបូរតិ ពាលោ បាបស្ស　　ថោកំ ថោកំបិ អាចិនំ ។**

បុគ្គល មិនគួរមើលងាយបាប ថាមានប្រមាណតិច នឹងមិនឲ្យផលដូច្នេះឡើយ ប្រៀបដូចក្អមទឹក រមែងពេញបានដោយតំណក់ទឹកដែលធ្លាក់ចុះ យ៉ាងណា បុគ្គលពាលកាលសន្សំបាប សូម្បីបន្តិចម្តងៗ គង់ពេញបានដោយបាប យ៉ាងនោះដែរ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **មាវមញ្ញេថ** សេចក្តីថា បុគ្គលមិនគួរមើលងាយ ។ បទថា **បាបស្ស** ប្រែថា នូវបាប ។ បាទព្រះគាថាថា **ន មន្តំ អាគមិស្សតិ** សេចក្តីថា បុគ្គលមិនគួរមើលងាយបាបយ៉ាងនេះថា អញធ្វើបាបមានប្រមាណតិច ធ្វើម្តេចបាបនោះនឹងឲ្យផល ។

បទថា **ឧទកុម្ភោបិ** សេចក្តីថា ភាជនៈដីប្រភេទណាមួយ ដែលគេបើកមាត់ដាក់ក្នុងទីដែលភ្លៀងធ្លាក់ រមែងពេញដោយតំណក់ទឹក ដែលធ្លាក់ចុះម្តងមួយតំណក់ៗ ដោយលំដាប់បាន យ៉ាងណា ។ បុគ្គលល្ងង់ខ្លៅ កាលសន្សំ គឺចម្រើននូវបាបសូម្បីតិចតួច តែងពេញដោយបាបបានដូច្នោះដូចគ្នា ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ភិក្ខុណាមួយ លាត ឬសន្ធឹងខ្លួនឯងក្តី ឲ្យគេលាតក្តី នូវគ្រែក្តី តាំងក្តី ពូកក្តី កៅអីក្តី ដែលជារបស់សង្ឃក្នុងទីវាល ហើយកាលនឹងដើរចេញទៅ មិនបានរើយកគ្រឿងសេនាសនៈ មានគ្រែជាដើមនោះ មកទុកដាក់ឯង មិនបានប្រើគេឲ្យរើសយកមកទុកដាក់ ហើយឥតបានប្រាប់ ( អ្នកដទៃ ) ស្រាប់តែដើរចេញទៅ ត្រូវអាបត្តិបាចិត្តិយៈ ។៚

**រឿង ភិក្ខុមិនទុកដាក់បរិក្ខារ ចប់**

# រឿង សេដ្ឋី ឈ្មោះ ពិឡាលបទកៈ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសេដ្ឋីឈ្មោះ ពិឡាលបទកៈ គឺសេដ្ឋីជើងឆ្មា ត្រាស់ព្រះធម្មទេសនានេះថា **មាវមញ្ញេថ បុញ្ញស្ស** ជាដើម ។

សេចក្តីពិស្តារថា សម័យមួយ អ្នកក្រុងសាវត្ថីនាំគ្នាថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយទាក់ទងជាពួកតែមួយ ។ ថ្ងៃមួយ ព្រះសាស្តា កាលទ្រង់ធ្វើអនុមោទនាត្រាស់យ៉ាងនេះថា ម្នាលឧបាសក ឧបាសិកាទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ឲ្យទានដោយខ្លួនឯង តែមិនដឹកនាំអ្នកដទៃ បុគ្គលនោះ រមែងបាននូវភោគសម្បត្តិ តែមិនបានបរិវារសម្បត្តិ ក្នុងទីដែលខ្លួនកើតហើយ បុគ្គលពួកខ្លះ មិនឲ្យទានដោយខ្លួនឯង បបួលតែអ្នកដទៃ បុគ្គលនោះ រមែងបានបរិវារសម្បត្តិ តែមិនបានភោគសម្បត្តិ ក្នុងទីដែលខ្លួនកើតហើយ បុគ្គលពួកខ្លះ មិនឲ្យទានដោយខ្លួនឯងផង មិនបបួលអ្នកដទៃផង បុគ្គលនោះ រមែងមិនបានភោគសម្បត្តិ មិនបានបរិវារសម្បត្តិ ក្នុងទីដែលខ្លួនកើតហើយ ក្លាយជាបុគ្គលស៊ីដែល ។ បុគ្គលពួកខ្លះ ឲ្យទានដោយខ្លួនឯងផង បបួលអ្នកដទៃផង បុគ្គលនោះ រមែងបាននូវភោគសម្បត្តិផង បរិវារសម្បត្តិផង ក្នុងទីដែលខ្លួនកើតហើយ ។

គ្រានោះ បណ្ឌិតបុរសម្នាក់ស្តាប់ធម៌ទេសនានោះហើយគិតថា ឱ ហេតុនេះគួរអស្ចារ្យ ឥឡូវនេះ អញនឹងធ្វើកម្មដែលប្រព្រឹត្តទៅដើម្បីសម្បត្តិទាំងពីរ

ទើបក្រាបទូលព្រះសាស្តាក្នុងកាលទ្រង់ក្រោកទៅថា បពិត្រព្រះអង្គ ស្អែកនេះ សូមទ្រង់ទទួលភិក្ខារបស់ខ្ញុំព្រះអង្គ ព្រះសាស្តាត្រាស់ថា អ្នកត្រូវការភិក្ខុប៉ុន្មាន បុរសនោះទូលថា បពិត្រព្រះអង្គ ភិក្ខុទាំងអស់ ។

ព្រះសាស្តាទ្រង់ទទួលហើយ បុរសនោះក៏ទៅកាន់ផ្ទះ ត្រាច់ប្រកាសថា បពិត្រអ្នកម្តាយ និងលោកឪពុកទាំងឡាយ ខ្ញុំនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានដើម្បីឆាន់ភត្តាហារក្នុងថ្ងៃស្អែក ។ បុគ្គលណាអាចប្រគេនដល់ភិក្ខុទាំងឡាយមានប្រមាណប៉ុនណា បុគ្គលនោះ ចូរឲ្យវត្ថុផ្សេងៗ មានអង្ករជាដើម ដើម្បីជាប្រយោជន៍ដល់អាហារ មានយាគូជាដើម ដើម្បីភិក្ខុទាំងឡាយ មានប្រមាណប៉ុណ្ណោះ ពួកយើងនឹងឲ្យចម្អិនក្នុងទីតែមួយ ហើយថ្វាយទាន ។

ពេលនោះ សេដ្ឋីម្នាក់ ឃើញបុរសនោះមកដល់រានផ្សាររបស់ខ្លួន ក៏ខឹងសម្បាថា បុរសនេះមិននិមន្តភិក្ខុឲ្យល្មមកម្លាំងរបស់ខ្លួន ចាំបាច់ដើរមកបបួលអ្នកស្រុកទាំងអស់ទៀត ទើបប្រាប់ថា ឯងចូរនាំយកភាជនៈដែលឯងកាន់មកដូច្នេះហើយ យកម្រាមដៃ ៣ ច្បិចអង្ករបន្តិច សណ្តែកបាយបន្តិច សណ្តែករាជមាសក៏ដូចគ្នាហើយឲ្យ ។ តាំងអំពីនោះ ទើបសេដ្ឋីនោះឈ្មោះថា ពិឡាលបទកសេដ្ឋី កាលឲ្យភេសជ្ជៈ មានសប្បិ និងទឹកអំពៅជាដើម ក៏ផ្អៀងមាត់ដបចូលត្រង់ផ្ទាំង ធ្វើឲ្យមាត់ដបនោះជាប់ជាមួយគ្នា ឲ្យភេសជ្ជៈ មានសប្បិ និងទឹកអំពៅជាដើម ហូរចូលមួយតំណក់ៗ បានឲ្យបន្តិចប៉ុណ្ណោះ ។

ឧបាសកធ្វើវត្ថុទាន ដែលអ្នកដទៃឲ្យរួមគ្នា តែបានកាន់យកវត្ថុដែលសេដ្ឋីនេះឲ្យទុកដោយឡែក ។ សេដ្ឋីនោះ ឃើញកិរិយារបស់បុរសនោះហើយ

គិតថា ហេតុអ្វីហ្ន៎ ទើបបុរសនេះទទួលរបស់អញឲ្យ ទុកដោយឡែក ទើបបញ្ជូនចូឡុបដ្ឋាកម្នាក់ ទៅអំពីក្រោយប្រាប់ថា ចូរអ្នកទៅ ចូរដឹងកម្មដែលបុរសនោះធ្វើ ។ ឧបាសកនោះទៅហើយពោលថា សូមឲ្យផលធំមានដល់សេដ្ឋីដូច្នេះហើយ ដាក់អង្ករមួយ ឬពីរគ្រាប់ ដើម្បីប្រយោជន៍ដល់បបរ កត្តូ និងនំដាក់សណ្ដែកបាយ សណ្ដែកកពជមាសខ្លះ បន្ទក់ប្រេង និងទឹកអំពៅជាដើមខ្លះ ចូលក្នុងភាជនៈ គ្រប់ៗ ភាជនៈ ចូឡុបដ្ឋាកទៅប្រាប់ដល់សេដ្ឋីនោះហើយ សេដ្ឋីស្ដាប់ពាក្យនោះហើយ គិតថា បើបុរសនោះ ពោលទោសរបស់អញក្នុងបរិស័ទសោត គ្រាន់តែវាចេញឈ្មោះអញប៉ុណ្ណោះ អញនឹងប្រហារវាឲ្យស្លាប់ ។ ក្នុងថ្ងៃស្អែកឡើង ទើបលាក់អាវុធក្នុងរវាងសំពត់ស្លៀក បានទៅឈរត្រង់រោងចុងភៅ ។ បុរសនោះអង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានហើយក្រាបទូលដល់ព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គបបួលមហាជនថ្វាយទាននេះ ពួកមនុស្សដែលខ្ញុំព្រះអង្គបបួលហើយក្នុងទីនោះ បានឲ្យអង្ករជាដើមច្រើនខ្លះ តិចខ្លះ តាមកម្លាំងរបស់ខ្លួន សូមផលដ៏វិសាលមានដល់មហាជនទាំងអស់នោះ ។

សេដ្ឋីបានឮពាក្យនោះហើយគិតថា អញមកដោយតាំងចិត្តថា គ្រាន់តែវាចេញឈ្មោះរបស់អញឡើងថា សេដ្ឋីឈ្មោះនោះ យកអង្ករជាដើមច្បិចដោយម្រាមដៃឲ្យ អញនឹងសម្លាប់បុរសនេះឲ្យស្លាប់ តែបុរសនេះធ្វើទានឲ្យរួមគ្នាទាំងអស់ ហើយពោលថា ទានដែលជនពួកណាវាល់ដោយនាឡិជាដើមហើយឲ្យក្ដី ទានដែលជនពួកណា កាន់យកដោយច្បិចដោយម្រាមដៃហើយឲ្យក្ដី សូម

ផលដ៏វិសាលមានដល់ជនទាំងអស់នោះ បើអញមិនឲ្យបុរសបែបនេះអត់ទោស សោត អាជ្ញារបស់ព្រះម្ចាស់សួគ៌ នឹងធ្លាក់លើអំបែងក្បាលអញ សេដ្ឋីនោះ ក្រាបចុះទៀបបាតជើងរបស់ឧបាសកនោះហើយ ពោលថា នែអ្នក សូមអ្នក អត់ទោសឲ្យខ្ញុំផង ត្រូវឧបាសកនោះសួរថា តើមានរឿងអ្វី ទើបប្រាប់រឿង ទាំងអស់នោះ ។

ព្រះសាស្តាទ្រង់ឃើញកិរិយានោះហើយ ត្រាស់សួរបុរសដែលខ្វល់ខ្វាយ ក្នុងទានថា តើមានរឿងអ្វី ទើបបុរសនោះក្រាបទូលរឿងទាំងអស់ ដែលកើត ឡើងហើយ ។

ពេលនោះ ព្រះសាស្តាត្រាស់សួរសេដ្ឋីនោះថា បានឮថា សេចក្តីនោះ យ៉ាងនេះឬ កាលសេដ្ឋីក្រាបទូលថា បពិត្រព្រះអង្គយ៉ាងនោះឯង ទើបទ្រង់ ត្រាស់ថា ម្នាលឧបាសក ឈ្មោះថា បុណ្យបុគ្គលណាម្នាក់ មិនគួរមើលងាយ ថា មានប្រមាណតិចតួច កាលបុគ្គលថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធ ជាប្រធានហើយ មិនគួរមើលងាយថាជារបស់តិចតួច ដ្បិតថា បុរសដែលជាបណ្ឌិតធ្វើបុណ្យ រមែងពេញទៅដោយបុណ្យដោយលំដាប់ពិត ប្រៀបដូចភាជនៈដែលបើកមាត់ រមែងពេញទៅដោយទឹក ដូច្នោះ ដូច្នេះ ហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

មាវមញ្ញេថ បុញ្ញស្ស ន មត្តំ អាគមិស្សតិ
ឧទពិន្ទុនិបាតេន ឧទកុម្ភោបិ បូរតិ
អាបូរតិ ធីរោ បុញ្ញស្ស ថោកំ ថោកំបិ អាចិនំ ។

បុគ្គល មិនគួរមើលងាយបុណ្យ ថាមានប្រមាណតិច នឹង
មិនឲ្យផល ដូច្នេះឡើយ ប្រៀបដូចក្អមទឹក រមែងពេញបាន
ដោយតំណក់ទឹកដែលធ្លាក់ចុះ យ៉ាងណា អ្នកមានប្រាជ្ញា
កាលសន្សំបុណ្យបន្តិចម្តងៗ គង់ពេញបានដោយបុណ្យ
យ៉ាងនោះ ។

## សេចក្តីអធិប្បាយ

អត្ថនៃព្រះគាថានោះថា មនុស្សដែលជាបណ្ឌិតធ្វើបុណ្យហើយ កុំមើលងាយ គឺមិនគួរមើលស្រាលបុណ្យយ៉ាងនេះថា អញធ្វើបុណ្យមានប្រមាណតិច បុណ្យមានប្រមាណតិចនឹងមកដល់ ដោយអំណាចនៃវិបាកឡើយ បើយ៉ាងនេះ កម្មតិចតួចនឹងឃើញអញអំពីណា ឬថា អញនឹងឃើញកម្មនោះអំពីណា កាលណាបុណ្យនោះនឹងឲ្យផល ដូចភាជនៈដីដែលបុគ្គលបើកគម្របតម្កល់ទុកចោល រមែងពេញដោយតំណក់ទឹក ដែលស្រក់ចុះមកមិនដាច់ខ្សែបាន យ៉ាងណា ធីរជន គឺបុរសដែលជាបណ្ឌិតកាលសន្សំបុណ្យម្តងបន្តិចៗ ឈ្មោះថា ពេញដោយបុណ្យបាន ដូច្នោះ ។

ក្នុងកាលចប់ទេសនា សេដ្ឋីនោះ បានសម្រេចសោតាបត្តិផលហើយ ព្រះធម្មទេសនាមានប្រយោជន៍ដល់បរិស័ទដែលមកប្រជុំគ្នា ដូច្នេះឯង ។ល។

**រឿង សេដ្ឋីឈ្មោះពិឡាលបទកៈ ចប់**

# រឿង មហាធនពាណិជ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឈ្មួញមានទ្រព្យច្រើន ត្រាស់ព្រះធម្មទេសនានេះថា **វាណិជោវ ភយំ មគ្គំ** ជាដើម ។

បានឮមកថា ពួកចោរ ៥០០ នាក់ ស្វែងរកឱកាសក្នុងផ្ទះរបស់ឈ្មួញនោះមិនបានហើយ ។ សម័យដទៃ ឈ្មួញនោះ ផ្ទុកទំនិញក្នុងរទេះ ៥០០ ហើយឲ្យប្រាប់ដល់ភិក្ខុទាំងឡាយថា ខ្ញុំនឹងទៅកាន់ទីឈ្មោះនោះ ដើម្បីលក់ដូរ លោកម្ចាស់ទាំងឡាយណាចង់ទៅក្នុងទីនោះ សូមនិមន្តលោកម្ចាស់ទាំង-ឡាយនោះទៅចុះ នឹងមិនលំបាកដោយភិក្ខាតាមផ្លូវ ភិក្ខុ ៥០០ រូបស្តាប់ពាក្យនោះហើយ បានធ្វើដំណើរទៅជាមួយឈ្មួញនោះ ។ សូម្បីចោរទាំងនោះ ក៏បានដំណឹងថា បានឮថា ឈ្មួញនោះចេញទៅហើយ បានបោះជំរំក្នុងព្រៃ ។

ចំណែកឈ្មួញទៅហើយ កាន់យកទីសម្រាកក្បែរភូមិមួយកន្លែង ត្រង់មាត់ព្រៃ រៀបចំគោ និងរទេះជាដើមអស់ ២-៣ ថ្ងៃ និងប្រគេនភិក្ខា ដល់ភិក្ខុទាំងនោះជានិច្ច ។ ពួកចោរ កាលឈ្មួញនោះយឺតយូរ ទើបបញ្ជូនបុរសម្នាក់ទៅ ដោយប្រាប់ថា ចូរអ្នកទៅ ចូរដឹងថ្ងៃចេញដំណើរ របស់ឈ្មួញនោះហើយ ចូរមក ។ បុរសនោះ ទៅដល់ស្រុកនោះហើយ សួរសម្លាញ់ម្នាក់ថា ឈ្មួញចេញទៅអង្កាល់ សម្លាញ់នោះឆ្លើយថា កន្លងទៅ ២-៣ ថ្ងៃទៀត ដូច្នេះហើយ ពោលថា ចុះអ្នកសួរដើម្បីអ្វី ពេលនោះ បុរសនោះប្រាប់ថា ពួកខ្ញុំជាចោរ ៥០០ ពួននៅក្នុងព្រៃដើម្បីប្លន់ឈ្មួញនោះ ។ ចំណែកសម្លាញ់នោះ

ពោលថា បើដូច្នោះ សូមអ្នកទៅចុះ ឈ្មួញនឹងចេញទៅឆាប់ៗ បញ្ជូនបុរសនោះទៅហើយ គិតថា អញនឹងឃាត់ពួកចោរ ឬឃាត់ឈ្មួញហ្ន៎ ក៏សម្រេចចិត្តថា ប្រយោជន៍អ្វីរបស់អញដោយពួកចោរ ភិក្ខុ ៥០០ រូប អាស្រ័យឈ្មួញរស់នៅ អញនឹងឲ្យសញ្ញាដល់ឈ្មួញ ហើយបានទៅកាន់សម្នាក់របស់ឈ្មួញនោះ សួរថា អ្នកទៅអង្កាល់ ឈ្មួញឆ្លើយថា ក្នុងថ្ងៃទី ៣ ក៏ពោលថា សូមអ្នកធ្វើតាមពាក្យរបស់ខ្ញុំ បានឮថា ពួកចោរ ៥០០ ស្កាត់នៅត្រង់ព្រៃដើម្បីអ្នក អ្នកកុំប្រញាប់ទៅធ្វើអ្វី ឈ្មួញសួរថា អ្នកដឹងដូចម្ដេច បុរសនោះប្រាប់ថា សម្លាញ់របស់ខ្ញុំមាននៅក្នុងពួកចោរទាំងនោះ ខ្ញុំដឹង ព្រោះការប្រាប់របស់គេ ឈ្មួញពោលថា បើយ៉ាងនោះ ប្រយោជន៍អ្វីរបស់ខ្ញុំដោយការទៅអំពីទីនេះ ខ្ញុំនឹងត្រឡប់ទៅផ្ទះ ។

កាលឈ្មួញនោះយឺតយូរ ពួកចោរក៏បញ្ជូនបុរសនោះមកទៀត មកដល់ហើយសួរសម្លាញ់នោះ បានស្ដាប់ការប្រព្រឹត្តទៅនោះហើយ ទៅប្រាប់ដល់ពួកចោរថា បានឮថា ឈ្មួញនឹងត្រឡប់ គឺទៅផ្ទះនោះឯង ។ ពួកចោរស្ដាប់ពាក្យនោះហើយ បានចេញអំពីព្រៃនោះ ទៅស្កាត់ត្រង់មាត់ផ្លូវក្រៅអំពីនេះ កាលឈ្មួញនោះយឺតយូរ ចោរទាំងនោះ ក៏បញ្ជូនបុរសនោះ ទៅកាន់សម្នាក់របស់សម្លាញ់នោះទៀត សម្លាញ់នោះ ដឹងភាពដែលពួកចោរស្កាត់ក្នុងទីនោះហើយ ក៏ប្រាប់ដល់ឈ្មួញទៀត ឈ្មួញគិតថា ក្នុងទីនេះ ការអត្តខាត់របស់អញ មិនមាន បើដូច្នេះ អញមិនទៅខាងនោះ មិនទៅខាងនេះ នឹងនៅទីនេះឯង ដូច្នេះហើយ ទៅកាន់សម្នាក់ភិក្ខុទាំងឡាយ ប្រាប់ថា បពិត្រលោកម្ចាស់

ពួកចោរបំណាចប្អូនខ្ញុំ នៅត្រង់មាត់ផ្លូវ បានឮថា ឥឡូវនេះ ឈ្មួញនឹងត្រឡប់មកទៀត ទើបទៅស្កាត់ត្រង់មាត់ផ្លូវក្រៅអំពីនេះ ខ្ញុំនឹងមិនទៅខាងនោះ ខាងនេះ នឹងស្នាក់នៅក្នុងទីនេះឯងមួយរយៈ បើលោកម្ចាស់ទាំងឡាយ បំណងនៅក្នុងទីនេះក៏នៅចុះ បើបំណងទៅ សូមនិមន្តតាមគាប់ចិត្តចុះ ។

ភិក្ខុទាំងឡាយពោលថា បើដូច្នោះ ពួកអាត្មានឹងត្រឡប់ លាឈ្មួញហើយ ក្នុងថ្ងៃស្អែកឡើង ទៅកាន់ក្រុងសាវត្ថី ថ្វាយបង្គំព្រះសាស្តា អង្គុយក្នុងទីសមគួរហើយ ។

ព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកមិនទៅជាមួយឈ្មួញមានទ្រព្យច្រើនទេឬ កាលពួកភិក្ខុនោះក្រាបទូលថា យ៉ាងនោះឯងព្រះអង្គ ពួកចោរស្កាត់ត្រង់មាត់ផ្លូវទាំងសងខាង ដើម្បីប្លន់ឈ្មួញដែលមានទ្រព្យច្រើន ព្រោះហេតុនោះ ទើបគាត់ស្នាក់នៅក្នុងទីនោះឯង ឯពួកខ្ញុំព្រះអង្គ លាគាត់ត្រឡប់មក ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មួញមានទ្រព្យច្រើន រមែងវៀរផ្លូវដែលមានភ័យ ព្រោះភាពដែលពួកចោរមាន បុរសសូម្បីប្រាថ្នានឹងរស់នៅ រមែងវៀរចាកថ្នាំពិសដ៏ពន្លឹក សូម្បីភិក្ខុជ្រាបថា ភព ៣ ដូចគ្នានឹងផ្លូវដែលពួកចោរស្កាត់ ហើយវៀរកម្មអាក្រក់ចេញ គួរ ដូច្នេះហើយ ដើម្បីទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

វាណិជោវ ភយំ មគ្គំ អប្បសត្ថោ មហទ្ធនោ
វិសំ ជីវិតុកាមោវ បាបានិ បរិវជ្ជយេ ។

បុគ្គល គួរវៀសវាងបាបទាំងឡាយ ឲ្យដូចពាណិជដែល
មានទ្រព្យច្រើន តែមានគ្នាតិច វៀសវាងផ្លូវគួរខ្លាច ឬដូច
បុរសប្រាថ្នារស់ វៀសវាងថ្នាំពិស ដូច្នោះដែរ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **ភយំ** បានដល់ ដែលគួរខ្លាច អធិប្បាយថា ដែលមានភ័យចំពោះមុខ ព្រោះជាផ្លូវដែលពួកចោរស្ទាក់ផ្លូវ ។ លោកបានអធិប្បាយពាក្យនេះថា ឈ្មួញមានទ្រព្យច្រើន មានគ្នាតិច វៀរផ្លូវដែលមានភ័យចំពោះមុខ យ៉ាងណា បុគ្គលត្រូវការរស់នៅ រមែងវៀរថ្នាំពិសដែលមានពិសដ៏ពន្លឹក យ៉ាងណា ភិក្ខុដែលជាបណ្ឌិត គួរវៀរបាបទាំងឡាយសូម្បីមានប្រមាណតិចក៏ដូច្នោះ ។

ក្នុងកាលចប់ទេសនា ភិក្ខុទាំងនោះសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ ព្រះធម្មទេសនាបានជាប្រយោជន៍ដល់មហាជន ដែលមកប្រជុំគ្នាហើយ ដូច្នោះឯង ។ល។

**រឿងមហាធនពាណិជ ចប់**

# រឿង កុក្កុដមិត្ត

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រានឈ្មោះកុក្កុដ-មិត្ត ត្រាស់ព្រះធម្មទេសនានេះថា **ទាណិម្ហិ ចេ វណោ ឆាស្ស** ជាដើម ។

បានឮថា ធីតាសេដ្ឋីម្នាក់ ក្នុងក្រុងរាជគ្រឹះ ចម្រើនវ័យហើយ ដើម្បីជាប្រយោជន៍ក្នុងការរក្សា ទើបមាតាបិតាប្រគល់ស្រីបម្រើម្នាក់ ឲ្យនៅក្នុងបន្ទប់លើប្រាសាទ ៧ ជាន់ ។ ល្ងាចថ្ងៃមួយ ក្រឡេកទៅចន្លោះផ្លូវតាមមាត់បង្អួចឃើញព្រានម្នាក់ ឈ្មោះកុក្កុដមិត្តកាន់អន្ទាក់ ៥០០ ចម្រូង ៥០០ សម្លាប់ម្រឹគទាំងឡាយចិញ្ចឹមជីវិត បានម្រឹគ ៥០០ ហើយ ដាក់ពេញរទេះធំ លក់ម្រឹគទាំងនោះ អង្គុយលើទូករទេះ ចូលទៅកាន់ព្រះនគរដើម្បីលក់សាច់ ជាអ្នកមានចិត្តប្រតិព័ទ្ធក្នុងព្រាននោះ ឲ្យបណ្ណាការក្នុងដៃស្រីបម្រើ បញ្ជូនទៅថា ចូរនាងទៅ ចូរឲ្យបណ្ណាការដល់បុរសនោះ ចូរដឹងពេលទៅរបស់គាត់ រួចហើយសឹមត្រឡប់មក ។

ស្រីបម្រើទៅហើយ ឲ្យបណ្ណាការដល់ព្រាននោះហើយ សួរថា អ្នកទៅវិញអង្កាល់ ព្រានឆ្លើយថា ថ្ងៃនេះ ខ្ញុំលក់សាច់ហើយ នឹងចេញទៅដោយទ្វារឈ្មោះនោះ អំពីព្រលឹមនោះឯង ។ ស្រីបម្រើស្ដាប់ពាក្យព្រាននោះប្រាប់ហើយ ត្រឡប់មកប្រាប់ដល់នាង ។

ធីតាសេដ្ឋីប្រមូលសំពត់ និងអាភរណៈ ដែលគួរដល់ភារៈជារបស់ខ្លួន ដែលគួរកាន់យក ស្លៀកសំពត់ចាស់ កាន់ក្អមទឹកចេញទៅអំពីព្រលឹម ដូច

ទៅកាន់កំពង់ទឹកជាមួយពួកនាងទាសី ដល់ទីនោះហើយ បានឃើញទនឹងការមករបស់ព្រាន ។ ព្រានក៏បររទេះចេញទៅអំពីព្រលឹម ចំណែកនាងក៏ដើរតាមក្រោយរទេះនោះទៅ បុរសនោះឃើញ ទើបពោលថា ខ្ញុំមិនស្គាល់នាងថាជាកូនស្រីរបស់បុគ្គលឈ្មោះនោះ នែនាង នាងកុំដើរតាមខ្ញុំឡើយ ។ នាងឆ្លើយថា លោកមិនបានហៅខ្ញុំមក ខ្ញុំមកតាមធម្មតារបស់ខ្ញុំ សូមលោកនៅស្ងៀម បររទេះរបស់ខ្លួនចុះ ។ បុរសនោះហាមហើយ ហាមទៀតនោះឯង ។ នាងក៏ពោលថា ការហាមឃាត់សិរី ដែលមកកាន់សម្នាក់ខ្លួន មិនគួរ ព្រានជ្រាបការមករបស់នាងដើម្បីខ្លួនដោយឥតសង្ស័យហើយ បានបីនាងដាក់លើរទេះទៅ ។

មាតាបិតារបស់នាងឲ្យមនុស្សរកក្នុងទីផ្សេងៗ ក៏មិនជួប សម្គាល់ថានាងស្លាប់ហើយ ទើបធ្វើមត្តកភត្ត ។ នាងអាស្រ័យការនៅរួមជាមួយព្រាននោះ បានកូន ៧ នាក់ដោយលំដាប់ ចងបុត្រទាំងនោះដែលចម្រើនវ័យហើយដោយគ្រឿងចង គឺផ្ទះ បានដល់ ឲ្យមានប្រពន្ធ ។

ថ្ងៃមួយ ព្រះសាស្តា ទ្រង់ប្រមើលមើលលោកក្នុងពេលទៀបភ្លឺ ទ្រង់ឃើញព្រានកុក្កុដមិត្ត កូនប្រុស និងកូនប្រសា ចូលទៅខាងក្នុងសំណាញ់ គឺព្រះញាណរបស់ព្រះអង្គ ទ្រង់ពិចារណាថា ហេតុនោះដូចម្តេចហ្ន៎ ទ្រង់ឃើញឧបនិស្ស័យនៃសោតាបត្តិមគ្គរបស់ជនទាំងនោះហើយ ទ្រង់កាន់បាត្រ និងចីវរ បានយាងទៅកាន់ទីដាក់អន្ទាក់របស់ព្រាននោះអំពីព្រលឹម ។ ថ្ងៃនោះម្រឹគ សូម្បីតែមួយ ក៏មិនបានជាប់អន្ទាក់ ។

ព្រះសាស្ដា ទ្រង់ប្រតិស្ឋានស្នាមព្រះបាទ ក្នុងទីជិតអន្ទាក់របស់ព្រាន ហើយប្រថាប់គង់ក្រោមម្លប់ឈើមួយគុម្ពខាងមុខ ។ ព្រានកុក្កុដមិត្តកាន់ធ្នូទៅមើលអន្ទាក់តាំងពីព្រលឹម ពិនិត្យមើលអន្ទាក់តាំងពីដើមរហូតដល់អស់ មិនបានសត្វសូម្បីតែមួយក្បាលដែលជាប់អន្ទាក់ បានឃើញស្នាមព្រះបាទរបស់ព្រះសាស្ដាហើយ ត្រិះរិះថា អ្នកណាដើរដោះសត្វជាប់អន្ទាក់របស់អញ ។ គាត់ចងអាឃាតក្នុងព្រះសាស្ដា កាលដើរទៅ ក៏ជួបព្រះសាស្ដាប្រថាប់គង់ត្រង់គុម្ពឈើ គិតថា សមណៈនេះដោះសត្វរបស់អញ អញនឹងសម្លាប់សមណៈនេះបង់ម្យ៉ៀត ដូច្នេះហើយ ក៏យឹតធ្នូ ។

ព្រះសាស្ដាឲ្យធ្នូកោងបាន តែមិនឲ្យព្រួញចេញ គាត់មិនអាចលែងព្រួញទៅផង មិនអាចដាក់ចុះ មានឆ្អឹងជំនីរទាំងពីរហាក់បែក មានទឹកមាត់ហូរចេញអំពីមាត់ ជាអ្នកអស់កម្លាំង បានឈរហើយ ។ គ្រានោះ កូនប្រុសរបស់គាត់ចូលទៅផ្ទះនិយាយគ្នាថា ឪពុករបស់យើងយឺតយូរ តើមានហេតុអ្វីហ្ន៎ ទើបម្ដាយបញ្ជូនទៅថា នែបាទាំងឡាយ ចូរពួកអ្នកទៅកាន់សម្នាក់របស់ឪពុក ក៏នាំគ្នាកាន់ធ្នូទៅ ឃើញឪពុកឈរបែបនោះ គិតថា បុគ្គលនេះ ពិតជាបច្ចាមិត្តរបស់ឪពុកពួកយើង ទាំង ៧ នាក់ យឹតធ្នូហើយ បានឈរនៅដូចឪពុករបស់ពួកខ្លួនហើយ ដោយអានុភាពនៃព្រះសម្មាសម្ពុទ្ធ ។

លំដាប់នោះ ម្ដាយរបស់ជនទាំងនោះ គិតថា ហេតុអ្វីហ្ន៎ ទើបឪពុកនិងកូនយឺតយូរ បានទៅជាមួយកូនប្រសា ៧ នាក់ ឃើញជនទាំងនោះឈរយ៉ាងនោះ គិតថា ជនទាំងនេះបាញ់អ្នកណាហ្ន៎ ក្រឡេកទៅឃើញព្រះសាស្ដា

ទើបផ្តងដើមដៃទាំងពីរស្រែកខ្លាំងៗ ថា ពួកអ្នក កុំធ្វើឪពុករបស់ខ្ញុំឲ្យវិនាស ពួកអ្នក កុំធ្វើឪពុករបស់ខ្ញុំឲ្យវិនាសឡើយ ។

ព្រានកុក្កុដមិត្តបានឮសំឡេងនោះហើយ គិតថា អញវិនាសហើយហ្ន៎ បានឮថា បុគ្គលនេះ ជាឪពុករបស់អញ ឱហ្ន៎ ! អញធ្វើកម្មធ្ងន់ ។ សូម្បីកូនប្រុសរបស់គាត់ក៏គិតថា បានឮថា ជននេះ ជាជីតារបស់អញ ឱហ្ន៎ ! អញធ្វើកម្មធ្ងន់ ។ ព្រានកុក្កុដមិត្តតាំងនូវមេត្តាចិត្តថា បុគ្គលនេះជាឪពុករបស់អញ សូម្បីពួកកូនប្រុសរបស់គាត់ ក៏ចូលទៅតាំងមេត្តាចិត្តថា បុគ្គលនេះជាជីតារបស់ពួកយើង ។ ខណៈនោះ ធីតាសេដ្ឋីដែលជាម្តាយពោលថា ចូរពួកអ្នកដាក់ធ្នូចុះឲ្យរហ័ស ឲ្យឪពុករបស់ខ្ញុំអត់ទោស ។

ព្រះសាស្តា កាលទ្រង់ជ្រាបចិត្តរបស់ជនទាំងនោះទន់ភ្លន់ហើយ ទើបឲ្យដាក់ធ្នូចុះបាន ។ ជនទាំងអស់ថ្វាយបង្គំព្រះសាស្តាហើយ ឲ្យទ្រង់អត់ទោសថា បពិត្រព្រះអង្គ សូមទ្រង់អត់ទោសដល់ខ្ញុំព្រះអង្គ ដូច្នេះហើយ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ លំដាប់នោះ ព្រះសាស្តាត្រាស់អនុបុព្វីកថាដល់ពួកជនទាំងនោះ ក្នុងកាលចប់ទេសនា ព្រានកុក្កុដមិត្ត កូនប្រុស និងកូនប្រសាទាំង ១៥ នាក់ តាំងនៅក្នុងសោតាបត្តិផលហើយ ព្រះសាស្តាយាងទៅបិណ្ឌបាតបានទៅកាន់វិហារខាងក្រោយភត្ត ។ លំដាប់នោះ ព្រះអានន្ទត្ថេរទូលសួរថា បពិត្រព្រះអង្គ ថ្ងៃនេះទ្រង់យាងទៅទីណា ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ តថាគតទៅកាន់សម្នាក់របស់កុក្កុដមិត្ត ព្រះអានន្ទទូលថា បពិត្រព្រះអង្គ កុក្កុដ-មិត្ត ទ្រង់ធ្វើឲ្យជាបុគ្គលមិនធ្វើកម្ម គឺបាណាតិបាតហើយឬ ព្រះសាស្តាត្រាស់

ថា អើអានន្ទ ព្រានកុក្កុដមិត្តនោះមានខ្ទួនជាគម្រប់ ១៥ តាំងនៅក្នុងសទ្ធាមិនញាប់ញ័រ ជាអ្នកអស់នូវសេចក្តីសង្ស័យក្នុងរតនៈ ៣ ជាអ្នកមិនធ្វើកម្ម គឺបាណាតិបាតឡើយ ។

ពួកភិក្ខុក្រាបទូលថា បពិត្រព្រះអង្គ កិរិយារបស់គាត់មាន មិនមែនឬ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង នាងជាកុមារិកាក្នុងផ្ទះរបស់អ្នកមានត្រកូល សម្រេចសោតាបត្តិផលហើយ ។

ពួកភិក្ខុសន្ទនាគ្នាថា បានឮថា កិរិយារបស់ព្រានកុក្កុមិត្ត សម្រេចនូវសោតាបត្តិផល ក្នុងកាលជាកុមារីនោះឯង ហើយទៅកាន់ផ្ទះរបស់ព្រាននោះ បានកូន ៧ នាក់ នាងកាលស្វាមីប្រើអស់កាលប៉ុណ្ណោះថា ចូរនាងយកធ្នូមក យកព្រួញមក យកលំពែងមក យកចម្រូងមក យកអន្ទាក់មក បានឲ្យវត្ថុទាំងនោះហើយ ព្រាននោះកាន់គ្រឿងប្រហារដែលនាងឲ្យ ទៅធ្វើបាណាតិបាត សូម្បីព្រះសោតាបន្នទាំងឡាយ នៅធ្វើបាណាតិបាតឬ ។

ព្រះសាស្តាយាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយរឿងអ្វី កាលភិក្ខុទាំងនោះក្រាបទូលថា ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សោតាបន្ន មិនធ្វើបាណាតិបាត តែនាងធ្វើយ៉ាងនោះ ដោយគិតថា អញនឹងធ្វើតាមពាក្យប្តី ចិត្តរបស់នាងមិនមានឡើយថា ចូរប្តីនោះកាន់យកគ្រឿងប្រហារនេះ ទៅធ្វើបាណាតិបាត ពិតហើយ កាលដំបៅក្នុងបាតដៃមិនមាន ថ្នាំពិសនោះ ក៏មិនអាចឲ្យទោសដល់អ្នកកាន់ថ្នាំពិសបាន យ៉ាងណា ឈ្មោះថា បាប មិនមាន

*ដល់អ្នកមិនធ្វើបាប សូម្បីនាំគ្រឿងប្រហារទាំងឡាយ មានធ្នូជាដើមហុចឲ្យ ព្រោះមិនមានអកុសលចេតនាដូច្នោះដូចគ្នា ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា*

**បាណម្ហិ ចេ វណោ នាស្ស ហរេយ្យ បាណិនា វិសំ**
**នាព្វណំ វិសមន្វេតិ នត្ថិ បាបំ អកុព្វតោ ។**

*បើដំបៅមិនមានក្នុងបាតដៃទេ បុគ្គលគប្បីកាន់នាំយកថ្នាំពិសដោយបាតដៃ ថ្នាំពិសតែងមិនជ្រាបចូលទៅកាន់បាតដៃដែលគ្មានដំបៅ យ៉ាងណា បាប រមែងមិនមានដល់បុគ្គល អ្នកមិនធ្វើយ៉ាងនោះដែរ ។*

## សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ បទថា* **នាស្ស** *ប្រែថា មិនគប្បីមាន ។ បទថា* **ហរេយ្យ** *ប្រែថា គប្បីអាចនាំទៅបាន ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះថ្នាំពិសមិនជ្រាបទៅកាន់បាតដៃដែលមិនមានដំបៅ ។ ពិតហើយ ថ្នាំពិសរមែងមិនអាចជ្រាបចូលកាន់បាតដៃដែលមិនមានដំបៅ យ៉ាងណា ឈ្មោះថាបាប រមែងមិនមានដល់បុគ្គលដែលមិនធ្វើបាប នាំគ្រឿងប្រហារទាំងឡាយមានធ្នូជាដើមមកឲ្យ ព្រោះមិនមានអកុសលចេតនាដូច្នោះដូចគ្នា ។ មែនពិត បាប រមែងមិនជាប់តាមចិត្តរបស់បុគ្គលនោះ ដូចថ្នាំពិសមិនជ្រាបចូលទៅក្នុងបាតដៃដែលមិនមានដំបៅ ដូច្នោះ ដូច្នេះឯង ។*

*ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មាន*

សោតាបត្តិផលជាដើម ដូច្នេះឯង ។

សម័យមួយ ពួកភិក្ខុសន្ទនាគ្នាថា អ្វីហ្ន៎ ជាឧបនិស្ស័យនៃសោតាបត្តិ-មគ្គរបស់ព្រានកុក្កុដមិត្ត កូនប្រុស និងកូនប្រសាស្រី ។ ព្រានកុក្កុដមិត្តនេះកើតក្នុងត្រកូលរបស់ព្រានម្រឹគ ព្រោះហេតុអ្វី ។

ព្រះសាស្តាយាងមក ហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នា ដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា ដោយរឿងឈ្មោះនេះ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងអតីតកាល ពួកជនរៀបចំធ្វើព្រះចេតិយ បញ្ចុះព្រះធាតុរបស់ព្រះកស្សប-ទសពល និយាយគ្នាយ៉ាងនេះថា អ្វីហ្ន៎ជាដីឥដ្ឋ អ្វីហ្ន៎ ជាទឹកបន្សំនៃចេតិយនេះ ។

ពេលនោះ ពួកជនទាំងនោះត្រិះរិះថា ហរតាល និងមនោសិលាជាដីឥដ្ឋ ប្រេងល្ងជាទឹកបន្សំ ។ ពួកជនទាំងនោះបុកហរតាល និងមនោសិលាហើយលាយនឹងប្រេងល្ង កដោយឥដ្ឋ បិទដោយមាស គូរក្បាច់ក្បូរខាងក្នុង ។ ត្រង់ខាងមុខផ្នែកខាងក្រៅ មានឥដ្ឋជាដុំមាស ឥដ្ឋនីមួយៗ មានតម្លៃមួយសែន ។ ពួកជនទាំងនោះ កាលធ្វើចេតិយស្រេចហើយ រហូតដល់កាលបញ្ចុះព្រះធាតុគិតគ្នាថា ក្នុងកាលបញ្ចុះព្រះធាតុ ត្រូវការទ្រព្យច្រើន ពួកយើងនឹងធ្វើអ្នកណាហ្ន៎ ឲ្យជាប្រធាន ។

ខណៈនោះ សេដ្ឋីស្រុកក្រៅម្នាក់ពោលថា ខ្ញុំនឹងជាប្រធាន បានដាក់ប្រាក់មួយកោដិក្នុងទីបញ្ចុះព្រះធាតុ អ្នកដែនឃើញកិរិយានោះ តិះដៀលថា

សេដ្ឋីក្រុងនេះ ប្រមូលទ្រព្យទុកដាក់តែម្យ៉ាង មិនអាចជាប្រធាន ក្នុងចេតិយ បែបនេះ បានចំណែកសេដ្ឋីស្រុកក្រៅដាក់ទ្រព្យមួយកោដិ ធ្វើជាប្រធាន ។

សេដ្ឋីក្នុងក្រុងនោះ បានឮពាក្យរបស់ជនទាំងនោះហើយពោលថា អញនឹងឲ្យទ្រព្យពីរកោដិ ហើយធ្វើជាប្រធាន បានដាក់ទ្រព្យពីរកោដិហើយ ។ សេដ្ឋីស្រុកក្រៅគិតថា អញនេះឯងនឹងជាប្រធាន បានឲ្យទ្រព្យ ៣ កោដិ ។ សេដ្ឋីទាំងពីរបន្ថែមទ្រព្យដោយអាការយ៉ាងនោះ សេដ្ឋីក្នុងក្រុងបានឲ្យទ្រព្យ ៨ កោដិហើយ ។

ចំណែកសេដ្ឋីស្រុកក្រៅ មានទ្រព្យ ៩ កោដិប៉ុណ្ណោះក្នុងផ្ទះ សេដ្ឋីក្នុងក្រុងមានទ្រព្យ ៤០ កោដិ ។ ព្រោះដូច្នោះ សេដ្ឋីស្រុកក្រៅគិតថា បើអញដាក់ទ្រព្យ ៩ កោដិសោត សេដ្ឋីនេះនឹងពោលថា ខ្ញុំដាក់ ១០ កោដិ កាលបើដូច្នោះ ការអស់ទ្រព្យរបស់អញនឹងប្រាកដ ទើបគាត់ពោលយ៉ាងនេះថា ខ្ញុំនឹងឲ្យទ្រព្យប្រមាណប៉ុណ្ណោះ ហើយខ្ញុំ កូន និងប្រពន្ធ នឹងធ្វើជាទាសៈរបស់ចេតិយ ដូច្នេះហើយ នាំកូនទាំង ៧ កូនប្រសាទាំង ៧ និងភរិយា ប្រគល់ដល់ចេតិយ មួយអន្លើដោយខ្លួនឯង ។

អ្នកដែនធ្វើសេដ្ឋីស្រុកក្រៅនោះឲ្យជាប្រធាន ដោយអាងថា ឈ្មោះថាទ្រព្យអ្នកណាក៏អាចឲ្យកើតឡើងបាន តែសេដ្ឋីស្រុកក្រៅ មួយអន្លើដោយបុត្រនិងភរិយា ប្រគល់ខ្លួនចំពោះចេតិយ សេដ្ឋីនេះឯងនឹងជាប្រធាន ។ ជនទាំង ១៦ នាក់ បានជាទាសៈរបស់ចេតិយដោយប្រការដូច្នេះ តែអ្នកដែនបានធ្វើពួកគាត់ឲ្យជាអ្នកជា ។ កាលបើដូច្នោះ ពួកគាត់ក៏បដិបត្តិចេតិយនោះឯង ដរាប

ដល់អស់ជីវិត ។ ចុតិអំពីអត្តភាពនោះហើយ កើតក្នុងទេវលោក កាលជនទាំងនោះនៅក្នុងទេវលោកអស់មួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទកាលនេះ កិរិយាចុតិអំពីទេវលោកនោះ កើតជាធីតាសេដ្ឋីក្នុងក្រុងរាជគ្រឹះ ។

នាងនៅជាកុមារីនោះឯង សម្រេចសោតាបត្តិផលហើយ ។ ឈ្មោះថាបដិសន្ធិរបស់សត្វដែលមិនទាន់ឃើញសច្ចៈ ជាការៈធ្ងន់ ព្រោះដូច្នោះ ស្វាមីរបស់នាងវិលទៅកើតក្នុងត្រកូលព្រានម្រឹគ សេចក្តីស្រឡាញ់ក្នុងកាលមុនបានគ្របសង្កត់ចិត្តធីតាសេដ្ឋី ដោយគ្រាន់តែឃើញព្រានកុក្កុដមិត្តនោះឯង ។ ពិតហើយ ព្រះដ៏មានព្រះភាគ ក៏បានត្រាស់ពាក្យនេះថា

សេចក្តីស្រឡាញ់នោះ រមែងកើតដោយហេតុ ២ យ៉ាង
គឺដោយធ្លាប់នៅរួមគ្នាក្នុងកាលមុន ១ ដោយការទំនុក
បម្រុងគ្នាក្នុងបច្ចុប្បន្ននេះ ១ ដូចជាឧប្បលដែលដុះក្នុង
ទឹកដោយហេតុ ២ យ៉ាង គឺទឹក ១ ភក់ ១ ។

ធីតាសេដ្ឋីនោះ បានទៅកាន់ត្រកូលរបស់ព្រានម្រឹគ ព្រោះសេចក្តីស្នេហាក្នុងកាលមុន ។ សូម្បីពួកកូនប្រុសរបស់នាង ក៏ចុតិអំពីទេវលោក បដិសន្ធិក្នុងផ្ទៃរបស់នាងនោះឯង ។ សូម្បីកូនប្រសារបស់នាង កើតឡើងក្នុងទីនោះៗ ចម្រើនវ័យហើយ បានទៅកាន់ផ្ទះរបស់ជនទាំងនោះឯង ។ ជនទាំងនោះបដិបត្តិចេតិយក្នុងកាលនោះហើយ ទើបបានសម្រេចសោតាបត្តិផល ដោយអានុភាពនៃកម្មនោះ ដូច្នេះឯង ។

## រឿង កុក្កុដមិត្ត ចប់

# រឿង ព្រានសុនខ ឈ្មោះ កោកៈ

## លំនាំដើម

*ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រានឆ្កែឈ្មោះកោកៈ ត្រាស់ព្រះធម្មទេសនានេះថា* **យោ អប្បទុដ្ឋស្ស នរស្ស ទុស្សតិ** *ជាដើម ។*

*បានឮថា ព្រឹកថ្ងៃមួយ ព្រាននោះកាន់ធ្នូ មានឆ្កែចោមរោមចេញទៅព្រៃ ជួបភិក្ខុសមាទានបិណ្ឌបាតជាវត្តមួយរូប កំពុងត្រាច់បិណ្ឌបាតក្នុងរវាងផ្លូវ ខឹងក្រោធហើយ គិតបណ្ដើរថា អញជួបមនុស្សកាឡកិណី ថ្ងៃនេះ នឹងមិនបានវត្ថុណាមួយឡើយ ដូច្នេះ ទើបចៀសចេញទៅ ។ ចំណែកព្រះថេរៈត្រាច់បិណ្ឌបាតក្នុងស្រុក ធ្វើភត្តកិច្ចហើយ ទើបត្រឡប់ទៅកាន់វិហារវិញ ។*

*ឯព្រានត្រាច់ទៅក្នុងព្រៃ មិនបានសត្វសោះ កាលត្រឡប់មក ក៏ជួបព្រះថេរៈទៀត ទើបគិតថា ថ្ងៃនេះ អញជួបមនុស្សកាឡកិណី ហើយទៅព្រៃមិនបានសត្វណាមួយ ឥឡូវនេះ លោកបានមកជួបមុខអញទៀត អញនឹងឲ្យឆ្កែទាំងឡាយខាំភិក្ខុរូបនេះ ដូច្នេះហើយ ទើបឲ្យសញ្ញាលែងឆ្កែទៅ ។*

*ព្រះថេរៈឃាត់ថា ឧបាសក អ្នកកុំធ្វើយ៉ាងនោះឡើយ ។ គាត់ស្រែកប្រាប់ថា ថ្ងៃនេះ អញមិនបានសត្វណាមួយ ព្រោះជួបឯង ឯងមកជួបអញទៀត អញនឹងឲ្យឆ្កែខាំឯង ដូច្នេះហើយ ទើបឲ្យឆ្កែខាំ ព្រះថេរៈប្រញាប់ឡើងដើមឈើមួយដើមដោយរហ័ស អង្គុយក្នុងទីកម្ពស់មួយជួរបុរស ឆ្កែ ទាំងឡាយ ក៏នាំគ្នាចោមរោមដើមឈើនោះ ។*

ព្រានក្រោធហើយ ស្រែកប្រាប់ថា ឯងឡើងដើមឈើ ក៏មិនអាចរួចខ្លួនបាន ដូច្នេះហើយ ទើបចាក់បាតជើងព្រះថេរៈដោយព្រួញ ព្រះថេរៈបានតែឃាត់ថា អ្នកកុំធ្វើដូច្នោះឡើយ នាយកោកៈនេះមិនពិចារណាដល់ពាក្យរបស់លោក ចាក់កាន់តែខ្លាំង ព្រះថេរៈកាលបាតជើងម្ខាងត្រូវចាក់ ទើបលើកជើងនោះឡើង ដាក់ជើងទីពីរចុះ កាលជើងទីពីរនោះត្រូវចាក់ ទើបលើកជើងនោះឡើង នាយកោកៈ មិនពិចារណាដល់ពាក្យឃាត់របស់ព្រះថេរៈ ចាក់ជើងទាំងពីរដោយអាការយ៉ាងនេះ សរីរៈរបស់ព្រះថេរៈ ហាក់ដូចជារោលដោយគប់ភ្លើង ។ លោកសោយវេទនា មិនអាចគ្រប់គ្រងសតិបាន ចីវរដែលលោកឃ្លុំ សូម្បីរបូតចុះ ក៏កំណត់មិនបាន ។ ចីវរនោះកាលធ្លាក់ចុះ ក៏ធ្លាក់គ្របនាយកោកៈតាំងអំពីក្បាលនោះឯង ។

ចំណែកឆ្កែស្ទុះចូលទៅក្នុងវាំងចីវរ ដោយសម្គាល់ថា ព្រះថេរៈធ្លាក់ចុះមក ដូច្នេះហើយ ចោមរោមខាំស៊ីម្ចាស់របស់ខ្លួន ធ្វើឲ្យសល់ត្រឹមតែឆ្អឹង ឆ្កែទាំងឡាយចេញមកពីក្នុងចីវរហើយ បានឈរខាងក្រៅ ពេលនោះ ទើបព្រះថេរៈកាច់មែកឈើងាប់មួយមែក គ្រវែងឆ្កែទាំងនោះ ឆ្កែឃើញព្រះថេរៈនោះដឹងថា ពួកខ្លួនខាំស៊ីម្ចាស់របស់ខ្លួនឯង ទើបគេចចូលព្រៃ ។

ព្រះថេរៈកើតការសង្ស័យថា បុរសនោះ ចូលក្នុងចីវររបស់អាត្មាអញវិនាសហើយ សីលរបស់អាត្មាអញមិនពន្រាស ពពាលទេឬហ្ន៎ ចុះអំពីដើមឈើហើយ ទៅកាន់សម្នាក់ព្រះសាស្តា ក្រាបទូលរឿងនោះតាំងអំពីដើមរហូតដល់ចប់ហើយ ទូលសួរថា បពិត្រព្រះអង្គ ឧបាសកនោះ អាស្រ័យចីវររបស់

ខ្ញុំព្រះអង្គ វិនាសហើយ សីលរបស់ខ្ញុំព្រះអង្គ ពព្រុស ពពាលដែរឬ សមណភាពរបស់ខ្ញុំព្រះអង្គ នៅមានដែរឬ ។

ព្រះសាស្តាទ្រង់ស្តាប់វាចារបស់ព្រះថេរៈនោះហើយត្រាស់ថា ម្នាលភិក្ខុ សីលរបស់អ្នកមិនពព្រុស មិនពពាល សមណភាពរបស់អ្នកនៅមាន ព្រាន ប្រទូស្តចំពោះអ្នកមិនប្រទូស្ត ដល់នូវការវិនាស មិនមែនតែក្នុងកាលឥឡូវ នេះប៉ុណ្ណោះទេ សូម្បីក្នុងអតីតកាល ក៏ប្រទូស្តចំពោះអ្នកមិនប្រទូស្ត ដល់នូវ សេចក្តីវិនាសហើយដូចគ្នា ដូច្នេះហើយ កាលទ្រង់ប្រកាសសេចក្តីនោះ ទ្រង់ នាំអតីតនិទានមកត្រាស់ថា

រឿងមានមកថា ក្នុងអតីតកាល គ្រូម្នាក់ត្រាច់ទៅដល់ភូមិមួយ ដើម្បី ធ្វើវេជ្ជកម្ម មិនបានកម្មណាមួយ ត្រូវសេចក្តីស្រេកឃ្លានបៀតបៀនហើយ ចេញទៅឃើញក្មេងៗ ជាច្រើន កំពុងលេងត្រង់ទ្វារស្រុក ទើបគិតថា អញ នឹងឲ្យពស់ចឹកក្មេងទាំងនេះ ហើយព្យាបាល នឹងបានអាហារ ដូច្នេះហើយ ទើបបង្ហាញពស់ដេកអើតក្បាល ក្នុងព្រង់ឈើមួយកន្លែង ប្រាប់ថា នែកុមារ ទាំងឡាយ នុ៎ះ កូនសត្វសាលិកា ចូរពួកអ្នកចាប់វា ។

រំពេចនោះ ក្មេងតូចម្នាក់ចាប់ពស់ត្រង់កយ៉ាងតឹងទាញចេញមក ដឹងថា ជាពស់ ទើបស្រែកឡើង រលាស់ទៅលើក្បាលរបស់គ្រូនោះ ដែលកំពុងឈរ មិនឆ្ងាយ ពស់រុំត្រង់ករបស់គ្រូ ចឹកយ៉ាងខ្លាំងឲ្យដល់នូវការអស់ជីវិត ក្នុងទី នោះឯង នាយកោកៈព្រានឆ្កែនេះ ក្នុងកាលមុន ក៏ប្រទូស្តអ្នកមិនប្រទូស្ត ដល់ នូវសេចក្តីវិនាសហើយយ៉ាងនេះដូចគ្នា ។

ព្រះសាស្តា កាលទ្រង់នាំអតីតនិទាននេះមកហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**យោ អប្បទុដ្ឋស្ស នរស្ស ទុស្សតិ សុទ្ធស្ស ពោសស្ស អនង្គណស្ស**
**តមេវ ពាលំ បច្ចេតិ បាបំ សុខុមោ រជោ បដិវាតំវ ខិត្តោ ។**

បុគ្គលណា ប្រទូស្តចំពោះអ្នកមិនប្រទូស្តតប ជាសត្វស្អាត មិនមានកិលេសដូចជាទីទួល បាប រមែងត្រឡប់មករកបុគ្គលពាលនោះវិញ ដូចធូលីល្អិត ដែលបុគ្គលបាចសាចទៅកាន់ទីច្រាស់ខ្យល់ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អប្បទុដ្ឋស្ស** គឺបុគ្គលមិនប្រទូស្តចំពោះខ្លួន ឬចំពោះសព្វសត្វ ។ បទថា **នរស្ស** បានដល់ សត្វ ។ បទថា **ទុស្សតិ** ប្រែថា រមែងប្រព្រឹត្តខុស ។ បទថា **សុទ្ធស្ស** គឺជាអ្នកមិនមានកំហុស ។ ពាក្យថា **ពោសស្ស** នេះ ជាឈ្មោះរបស់សត្វនោះឯង ដោយអាការដទៃ ។

បទថា **អនង្គណស្ស** គឺមិនមានកិលេស ។ ពាក្យថា **បច្ចេតិ** កាត់បទជា **បដិ ឯតិ** ប្រែថា រមែងត្រឡប់ដល់ ។ បទថា **បដិវាតំ** ជាដើម សេចក្តីថា ធូលីដែលល្អិត ដែលបុរសម្នាក់បាចទៅ ដោយភាពជាអ្នកប្រាថ្នាប្រហារអ្នកដទៃ ដែលឈរលើខ្យល់ រមែងត្រឡប់ដល់បុរសនោះឯង គឺធ្លាក់ចុះខាងលើរបស់អ្នកបាចទៅនោះឯង យ៉ាងណា បុគ្គលណា កាលឲ្យនូវការប្រហារដោយដៃជាដើម ឈ្មោះថា រមែងប្រទូស្តចំពោះបុរសដែលមិនប្រទូស្ត បាបនោះឲ្យផលក្នុងបច្ចុប្បន្ននេះ ឬក្នុងអបាយទាំងឡាយ មាននរកជាដើម ក្នុងភព

ខាងមុខ ឈ្មោះថា រមែងត្រឡប់ដល់បុគ្គលនោះឯង ដែលជាបុគ្គលពាល ដោយអំណាចវិបាកទុក្ខ ដូច្នោះដូចគ្នា ។

ក្នុងកាលចប់ទេសនា ភិក្ខុនោះ តាំងនៅក្នុងអរហត្តផល ។ ព្រះធម្មទេសនា មានប្រយោជន៍ដល់បរិស័ទ ដែលប្រជុំគ្នាហើយដូច្នោះឯង ។\

**រឿង ព្រានសុនខ១ ឈ្មោះ កោកៈ ចប់**

# រឿង ព្រះតិស្សត្ថេរកុលុបកៈរបស់ជាងកែវ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះថេរៈឈ្មោះ តិស្សៈ ដែលជាអ្នកចូលទៅកាន់ត្រកូលជាងកែវ ត្រាស់ព្រះធម្មទេសនានេះ ថា **គព្ភមេកេ ឧបជ្ជន្តិ** ជាដើម ។

បានឮថា ព្រះថេរៈនោះ ឆាន់ភត្តនៅក្នុងត្រកូលរបស់មណិការម្នាក់ អស់ ១២ ឆ្នាំ ។ ភរិយា និងស្វាមីក្នុងត្រកូលនោះ តាំងនៅក្នុងឋានៈដូចមាតាបិតា បដិបត្តិព្រះថេរៈហើយ ។

សម័យថ្ងៃមួយ មណិការកំពុងហាន់សាច់ខាងមុខព្រះថេរៈ ក្នុងខណៈនោះ ព្រះបាទបសេនទិកោសល ទ្រង់បញ្ជូនកែវមណីមួយទៅ ដោយត្រាស់ថា ចូរជាងកែវជុសខាត់ និងថ្នៃកែវមណីនេះ ហើយបញ្ជូនទៅ ។ មណិការទទួលកែវនោះដោយដៃទាំងប្រឡាក់ឈាម ដាក់លើជ្រញ់ ហើយចូលទៅ

ខាងក្នុងដើម្បីលាងដៃ ។

ក្នុងផ្ទះនោះ សត្វក្រៀលដែលគាត់ចិញ្ចឹមមាន ក្រៀលនោះលេបកែវមណីនោះដោយសម្គាល់ថាសាច់ ព្រោះក្លិនឈាម កាលព្រះថេរៈកំពុងឃើញនោះឯង មណីការមកហើយមិនឃើញកែវមណី ទើបសួរភរិយា ធីតា និងបុត្រ ដោយលំដាប់ថា ពួកអ្នកយកកែវមណីទៅឬ កាលជនទាំងនោះពោលថា មិនបានយកទេ ទើបគិតថា ប្រហែលជាព្រះថេរៈយក ទើបប្រឹក្សានឹងភរិយាថា កែវមណីប្រហែលព្រះថេរៈយក ភរិយាប្រាប់ថា នៃអ្នក អ្នកកុំពោលយ៉ាងនោះ ខ្ញុំមិនធ្លាប់ឃើញទោសណាមួយរបស់ព្រះថេរៈ អស់កាលប្រមាណប៉ុណ្ណោះ លោកមិនកាន់យកកែវនោះឡើយ ។ មណីការសួរព្រះថេរៈថា បពិត្រលោកម្ចាស់ លោកម្ចាស់យកកែវមណីក្នុងទីនេះឬ ព្រះថេរៈឆ្លើយថា ឧបាសកអាត្មាមិនបានកាន់យកទេ មណីការពោលថា ក្នុងទីនេះ មិនមានអ្នកដទៃទេលោកម្ចាស់យកទៅដោយពិតប្រាកដ សូមលោកម្ចាស់ឲ្យកែវមណីដល់ខ្ញុំចុះ ។

កាលព្រះថេរៈមិនទទួល ទើបនិយាយនឹងភរិយាថា ព្រះថេរៈយកកែវមណីពិត ខ្ញុំនឹងជំរិតសួរលោក ភរិយាឆ្លើយថា នៃអ្នក អ្នកកុំឲ្យពួកយើងវិនាសឡើយ ពួកយើងចូលដល់ភាពជាទាសៈប្រសើរជាង ការចាប់ទោសព្រះថេរៈបែបនេះ មិនប្រសើរឡើយ ។

ជាងកែវនោះពោលថា ពួកយើងទាំងអស់គ្នាចូលដល់នូវភាពជាទាសៈក៏មិនស្មើនឹងតម្លៃកែវមណី ដូច្នេះហើយ ទើបកាន់យកខ្សែ រុំក្បាលព្រះថេរៈមួលដោយកូនកំព្រា ។ ឈាមហូរចេញអំពីក្បាល ត្រចៀក និងច្រមុះរបស់

ព្រះថេរៈ ភ្នែកទាំងពីរដល់នូវអាការល្វៀនចេញ លោកឈឺចាប់ខ្លាំង ក៏រលំចុះត្រង់ផែនដី សត្វក្រៀលមកដោយកុិនឈាម បរិភោគឈាម ។

ខណៈនោះ ទើបមណីការទាត់ក្រៀលដោយជើងបណ្តើរ ពោលបណ្តើរថា អាមកធ្វើអ្វី ដោយកម្លាំងសេចក្តីក្រោធដែលកើតឡើងក្នុងព្រះថេរៈ សត្វក្រៀលនោះដួលស្លាប់ ដោយការទាត់ត្រឹមមួយជើងប៉ុណ្ណោះ ។ ព្រះថេរៈឃើញក្រៀលនោះ ទើបពោលថា ឧបាសក ចូរអ្នកបន្ធូរខ្សែ ត្រង់ក្បាលរបស់អាត្មាសិន ហើយពិចារណាមើលក្រៀលនេះថា ស្លាប់ហើយ ឬទៅ លំដាប់នោះទើបជាងកែវពោលថា លោកក៏នឹងស្លាប់ដូចក្រៀលនោះ ព្រះថេរៈពោលថា ឧបាសក កែវមណីនោះ ក្រៀលនេះលេបហើយ បើក្រៀលនេះមិនទាន់ស្លាប់សោត ទោះបីអាត្មាស្លាប់ ក៏មិនប្រាប់កែវមណីដល់អ្នក ។

គាត់វះពោះក្រៀលនោះ ឃើញកែវមណីហើយ មានចិត្តរន្ធត់ក្រាបចុះទៀបបាតជើងរបស់ព្រះថេរៈពោលថា សូមលោកម្ចាស់អត់ទោសដល់ខ្ញុំ ខ្ញុំមិនដឹង ទើបធ្វើហើយ ។ ព្រះថេរៈពោលថា ឧបាសក ទោសរបស់អ្នកមិនមាន របស់អាត្មាក៏មិនមាន នេះជាទោសរបស់វដ្តៈប៉ុណ្ណោះ អាត្មាអត់ទោសដល់អ្នក មណីការពោលថា បើលោកម្ចាស់អត់ទោសឲ្យខ្ញុំសោត សូមលោកម្ចាស់ ទទួលភិក្ខាក្នុងផ្ទះរបស់ខ្ញុំដូចសព្វមួយដងចុះ ព្រះថេរៈពោលថា ឧបាសក តាំងអំពីថ្ងៃនេះទៅ អាត្មាមិនចូលក្នុងសំយាបផ្ទះរបស់អ្នកដទៃឡើយ ព្រោះថា នេះជាទោសនៃការចូលទៅខាងក្នុងផ្ទះដោយត្រង់ តាំងអំពីនេះទៅ កាលជើងទាំងពីរនៅដើរបាន អាត្មានឹងឈរត្រង់ទ្វារផ្ទះប៉ុណ្ណោះ ទទួលភិក្ខា

ដូច្នេះហើយ សមាទានធុតង្គ ពោលគាថានេះថា

កត្តក្នុងត្រកូលទាំងឡាយតិចតួច ដែលគេចម្អិនទុកដើម្បីមុនី អាត្មានឹងត្រាច់ទៅដោយកម្លាំងស្មងរបស់អាត្មាដែលមាន ។

កាលព្រះថេរៈពោលគាថានេះហើយ ក្នុងកាលមិនយូរ ក៏បរិនិព្វានដោយព្យាធិនោះឯង ។

សត្វក្រៀល បានបដិសន្ធិក្នុងផ្ទៃនៃភរិយារបស់ជាងកែវនោះ ។ ជាងកែវធ្វើកាលកិរិយាហើយកើតក្នុងនរក ភរិយារបស់ជាងកែវ ធ្វើកាលកិរិយាហើយកើតក្នុងទេវលោក ព្រោះអ្នកមានចិត្តទន់ក្នុងព្រះថេរៈ ។ ភិក្ខុទាំងឡាយទូលសួរអភិសម្បរាយភពរបស់ជនទាំងនោះនឹងព្រះសាស្តា ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សត្វពួកខ្លះក្នុងលោកនេះ រមែងកើតក្នុងគភ៌ ពួកខ្លះធ្វើកម្មលាមក រមែងកើតក្នុងនរក សត្វពួកខ្លះធ្វើកម្មល្អហើយ រមែងកើតក្នុងទេវលោក ចំណែកអ្នកមិនមានអាសវៈ រមែងបរិនិព្វាន ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**គព្ភមេកេ ឧប្បជ្ជន្តិ និរយំ បាបកម្មិនោ**
**សគ្គំ សុគតិនោ យន្តិ បរិនិព្វន្តិ អនាសវា ។**

ជនពួកខ្លះ កើតក្នុងគភ៌មនុស្ស ពួកអ្នកមានអំពើអាក្រក់ទៅកាន់នរក ពួកអ្នកមានគតិល្អ ទៅកាន់ស្ថានសួគ៌ ពួកអ្នកមិនមានអាសវៈ បរិនិព្វាន ។

## សេចក្ដីអធិប្បាយ

*ក្នុងបទទាំងនោះ គភ៌មនុស្ស ព្រះសាស្ដាទ្រង់បំណាងយកក្នុងបទថា* **គភ៌** *នេះ ពាក្យដ៏សេសក្នុងគាថានេះ មានអត្ថងាយយល់ទាំងអស់ហើយ ។*

*ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។*

**រឿងព្រះតិស្សត្ថេរកុលុបកៈរបស់ជាងកែវ ចប់**

# រឿងជន ៣ ពួក

## លំនាំដើម

*ព្រះសាស្ដា កាលគង់ក្នុងវត្តជេតពន ទ្រង់ប្រារព្ធជន ៣ ពួក ត្រាស់ព្រះធម្មទេសនានេះថា* **ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ** *ជាដើម ។*

*បានឮថា កាលព្រះសាស្ដា គង់នៅក្នុងវត្តជេតពន ភិក្ខុច្រើនរូបមកបំណាងដើម្បីគាល់ព្រះសាស្ដា ចូលទៅកាន់ភូមិមួយ ដើម្បីបិណ្ឌបាត អ្នកស្រុកទទួលបាត្ររបស់ភិក្ខុទាំងនោះហើយ និមន្តឲ្យគង់ក្នុងរោងឆាន់ ប្រគេនបបរ និងរបស់ទំពា កាលរង់ចាំពេលបិណ្ឌបាត អង្គុយស្ដាប់ធម៌ហើយ ។ ខណៈនោះ អណ្ដាតភ្លើងឆេះឡើងអំពីជើងក្រានរបស់ស្រីម្នាក់ដែលចម្អិនបាយហើយចម្អិនស្ងោរ និងព្យញ្ជនៈដល់ដំបូល រង្វេលស្មៅមួយហោះឡើងអំពីដំបូលនោះ ដែលភ្លើងឆេះ ទៅកាន់អាកាស ។ ក្នុងខណៈនោះ ក្អែកមួយហើរមកតាមអាកាស ស៊កកចូលទៅក្នុងរង្វេលស្មៅនោះ ត្រូវរង្វេលស្មៅរុំហើយ*

ឆេះធ្លាក់ស្លាប់ត្រង់កណ្តាលស្រុក ។ ពួកភិក្ខុឃើញហេតុនោះ គិតថា ឱកម្មធ្ងន់ អាវុសោអ្នកទាំងឡាយ ចូរមើលអាការប្លែក ដែលក្អែកដល់ហើយ បើវៀរ ព្រះសាស្តា អ្នកណានឹងដឹងកម្មដែលក្អែកនេះធ្វើហើយ ពួកយើងនឹងទូលសួរ កម្មរបស់ក្អែកនោះនឹងព្រះសាស្តា ដូច្នេះហើយ ក៏នាំគ្នាចៀសចេញទៅ ។

ភិក្ខុមួយពួកទៀត ធ្វើដំណើរតាមសំពៅទៅដើម្បីគាល់ព្រះសាស្តា សំពៅ បានកឿងកណ្តាលសមុទ្រ ។ ពួកមនុស្សនាំគ្នាគិតថា មនុស្សកាឡកិណីគប្បី មានក្នុងសំពៅនេះ ដូច្នេះហើយ ទើបឲ្យចាប់ស្លាក ។ ភរិយានាយសំពៅតាំង នៅក្នុងបឋមវ័យគួរមើល ស្លាកក៏ដល់នាងនោះ ។ ពួកមនុស្សនាំគ្នាពោលថា ចូរចែកស្លាកសាជាថ្មី ហើយឲ្យចាប់ដល់ ៣ ដង ស្លាកត្រូវនាងនោះដល់ទៅ ៣ ដង ពួកមនុស្សមើលមកនាយសំពៅពោលថា ធ្វើយ៉ាងណាលោក នាយ សំពៅពោលថា ខ្ញុំមិនអាចឲ្យមហាជនវិនាសដើម្បីប្រយោជន៍ដល់នាងនេះ ចូរ ពួកអ្នកបោះនាងទៅក្នុងទឹកចុះ ។ ស្រីនោះ កាលពួកមនុស្សចាប់បោះទៅក្នុង ទឹក ខ្លាចចំពោះមរណភ័យ បានស្រែយំហើយ ។ នាយសំពៅបានឮសម្រែក នោះ ទើបពោលថា ប្រយោជន៍អ្វីដោយអាភរណៈ ដែលដល់នូវសេចក្តីវិនាស ទទេៗ ចូរពួកអ្នកដោះគ្រឿងអាភរណៈទាំងអស់ ឲ្យស្លៀកសំពត់ចាស់មួយ ផ្ទាំង ហើយបោះស្រីនោះ ឯខ្ញុំមិនអាចមើលស្រីនោះ ដែលអណ្តែតលើផ្ទៃ ទឹកបាន ព្រោះដូច្នោះ ចូរពួកអ្នកយកក្អម ដែលពេញដោយដីខ្សាច់ ចងត្រង់ កហើយ បោះទៅក្នុងមហាសមុទ្រចុះ ដោយប្រការដែលខ្ញុំមិនឃើញនាង ។ មនុស្សទាំងនោះ បានធ្វើតាមនោះហើយ ។ ត្រី និងអណ្តើក ចោមរោមស៊ី

ស្រីនោះក្នុងទីដែលធ្លាក់នោះឯង ។ ពួកភិក្ខុឃើញរឿងនោះហើយក៏គិតថា ជនដទៃវៀរព្រះសាស្តាហើយ នឹងដឹងកម្មរបស់ស្រីនោះមិនមាន ពួកយើងនឹងទូលសួរកម្មរបស់ស្រីនោះនឹងព្រះសាស្តា ដល់ទីដែលប្រាថ្នាហើយ ទើបនាំគ្នាចុះអំពីសំពៅចៀសចេញទៅ ។

ភិក្ខុ ៧ រូបមួយពួកទៀត ទៅអំពីបច្ចន្តជនបទដើម្បីគាល់ព្រះសាស្តាក្នុងពេលល្ងាចចូលទៅកាន់វត្តមួយ ហើយសួរដល់ទីសម្រាក ក្នុងគុហាមួយកន្លែងមានគ្រែ ៧ កាលភិក្ខុទាំងនោះបានគុហានោះឯង សិងលើគ្រែនោះហើយលុះដល់ពេលយប់ ផ្ទាំងថ្មប៉ុនផ្ទះកំពូលរមៀលចុះមកបិទទ្វារគុហា ។ ពួកភិក្ខុពោលថា ពួកយើងឲ្យគុហានេះដល់អាគន្តុកភិក្ខុ ផ្ទាំងថ្មធំនេះបានបិទទ្វារគុហាហើយ ។ ពួកយើងនឹងប្រមៀលផ្ទាំងថ្មនោះចេញ ហើយឲ្យប្រជុំពួកមនុស្ស ៧ ស្រុកដោយជុំវិញ កាលព្យាយាមក៏មិនអាចធ្វើផ្ទាំងថ្មនោះឲ្យឃ្លាតចាកទី ។

សូម្បីពួកភិក្ខុដែលចូលទៅខាងក្នុង ក៏ព្យាយាមដូចគ្នា កាលបើដូច្នោះក៏នៅតែមិនអាចធ្វើផ្ទាំងថ្មនោះឲ្យឃ្លាតចាកទីបាន រហូត ៧ ថ្ងៃ ពួកអាគន្តុកភិក្ខុត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់ អស់ ៧ ថ្ងៃ សោយទុក្ខធំហើយ ។ ក្នុងថ្ងៃទី ៧ ផ្ទាំងថ្មក៏បានរមៀលទៅឯង ពួកភិក្ខុចេញទៅហើយគិតថា បាបរបស់ពួកយើងនេះ វៀរព្រះសាស្តាចេញហើយ អ្នកណានឹងដឹងបាន ពួកយើងនឹងទូលសួរព្រះសាស្តា ដូច្នេះហើយ នាំគ្នាចៀសចេញទៅ ។

ភិក្ខុទាំងនោះ មកជួបគ្នាជាមួយពួកភិក្ខុពួកមុនក្នុងរវាងផ្លូវ រួមគ្នាជាពួកតែមួយ ចូលគាល់ព្រះសាស្តា ថ្វាយបង្គំហើយ អង្គុយនាចំណែកម្ខាង មាន

បដិសណ្ឋារៈ ដែលព្រះសាស្តាទ្រង់ធ្វើហើយ ទើបទូលសួរដល់ហេតុដែលខ្លួនឃើញ និងដែលខ្លួនសោយមកហើយតាមលំដាប់ សូម្បីព្រះសាស្តាក៏ត្រាស់ព្យាករដល់ភិក្ខុទាំងនោះដោយលំដាប់យ៉ាងនេះ ។

ម្នាលភិក្ខុទាំងឡាយ ក្អែកនោះបានសោយកម្មដែលខ្លួនធ្វើហើយនោះឯងដោយពិត ។ ក្នុងអតីតកាល អ្នកស្រែម្នាក់ក្នុងក្រុងពារាណសី បង្ហឹកគោរបស់ខ្លួន មិនអាចបង្ហឹកបាន ដ្បិតថា គោរបស់គាត់នោះ ដើរទៅបានបន្តិចហើយក៏ដេក សូម្បីបុរសនោះវាយឲ្យក្រោកឡើងហើយ ដើរទៅបានបន្តិចក៏ដេកដូចមុននោះឯង ។ អ្នកស្រែនោះព្យាយាមហើយ ក៏មិនអាចបង្ហឹកគោនោះបាន ជាបុគ្គលត្រូវសេចក្តីក្រោធគ្របសង្កត់ហើយ ទើបពោលថា ឥឡូវនេះ ឯងដេកឲ្យស្រុខតាំងអំពីនេះទៅ ដូច្នេះហើយ យកចំបើងរុំកគោនោះ ហើយដុតដោយភ្លើង ។ គោត្រូវភ្លើងឆេះស្លាប់ក្នុងទីនោះឯង ម្នាលភិក្ខុទាំងឡាយ បាបកម្មនោះ ដែលក្អែកនោះធ្វើហើយក្នុងកាលនោះ ។ បុរសនោះ ឆេះក្នុងនរកអស់កាលយូរ ដោយផលនៃវិបាកដែលសេសសល់នៃបាបកម្មនោះ កើតហើយក្នុងកំណើតក្អែក ៧ ដង ត្រូវភ្លើងឆេះស្លាប់ក្នុងអាកាស យ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ស្រីនោះសោយផលកម្មដែលខ្លួនធ្វើហើយដូចគ្នា ។ ក្នុងអតីតកាល ស្រីនោះជាភរិយារបស់គហបតីម្នាក់ ក្នុងក្រុងពារាណសី បានធ្វើកិច្ចគ្រប់យ៉ាង មានរែកទឹក បុកអង្ករ ចម្អិនអាហារជាដើមដោយដៃរបស់ខ្លួន ឆ្កែមួយរបស់នាងអង្គុយមើលនាងនោះ ដែលធ្វើកិច្ចគ្រប់យ៉ាងក្នុងផ្ទះ ។ កាលស្រីនោះនាំភត្តទៅស្រែក្តី ទៅព្រៃដើម្បីរកវត្ថុផ្សេងៗ មានឧស និងបន្លែ

ជាដើមក្តី ឆ្កែនោះរមែងទៅជាមួយនាងនោះឯងជានិច្ច ។ ពួកកំលោះឃើញដូច្នោះ រមែងចំអន់ថា នែបា ព្រានឆ្កែចេញដំណើរហើយ ថ្ងៃនេះពួកយើងនឹងស៊ីបាយជាមួយសាច់ នាងខ្មាសព្រោះពាក្យនិយាយរបស់ពួកមនុស្សទាំងនោះ ទើបប្រហារឆ្កែនោះដោយដុំដី និងអន្ទត់ឧសជាដើមឲ្យគេចចេញទៅ ។ ឆ្កែត្រឡប់ហើយក៏តាមទៅទៀត ។ បានឮថា ឆ្កែនោះ ត្រូវជាប្តីរបស់នាងក្នុងអត្តភាពទី ៣ ហេតុនោះ ទើបឆ្កែនោះមិនអាចកាត់សេចក្តីស្នេហាបាន មែនពិត បុគ្គលណាម្នាក់ ឈ្មោះថាមិនធ្លាប់ជាប្រពន្ធ ឬជាប្តីគ្នានិងគ្នា ក្នុងសង្សារ ដែលមិនមានទីបំផុត មិនមានដោយពិត តែសេចក្តីស្រឡាញ់មានប្រមាណក្រៃលែងរមែងមានក្នុងបុគ្គលដែលជាញាតិនឹងគ្នាក្នុងអត្តភាពមិនឆ្ងាយ ហេតុនោះ ទើបឆ្កែនោះមិនអាចលះស្រីនោះបាន ។ នាងក្រោធនឹងឆ្កែនោះ កាលនាំបបរទៅដើម្បីប្តីឯស្រែ ទើបយកខ្សែដាក់ក្នុងជាយថ្នក់ហើយទៅ ឆ្កែទៅជាមួយនាងដូចគ្នា ។ នាងឲ្យបបរដល់ប្តីហើយ កាន់ក្អមទទេទៅកាន់កំពង់ទឹកមួយកន្លែង ដាក់ខ្សាច់ពេញក្អមហើយ ធ្វើសំឡេងដល់ឆ្កែដែលឈរមើលក្នុងទីជិត ។ ឆ្កែសប្បាយថា យូរហើយហ្ន៎ អញបានពាក្យពីរោះក្នុងថ្ងៃនេះ ទើបបក់កន្ទុយចូលទៅរក ។ នាងចាប់ឆ្កែនោះយ៉ាងមាំត្រង់កហើយ ទើបយកចុងខ្សែម្ខាងចងក្អមចុងម្ខាង ចងត្រង់កឆ្កែ ប្រមៀលក្អមចូលទៅក្នុងទឹក ឆ្កែក៏ដោយតាមក្អមទៅធ្លាក់ក្នុងទឹក ស្លាប់ក្នុងទឹកនោះឯង ។ ស្រីនោះ ឆេះក្នុងនរកអស់កាលយូរ ព្រោះវិបាករបស់កម្មនោះ ។ ដោយវិបាកដ៏សេស ទើបនាងត្រូវគេយកក្អមពេញដោយដីខ្សាច់ ចងត្រង់កបោះទៅក្នុងទឹក ធ្វើកាលកិរិយាយ៉ាងនេះ

អស់មួយរយអត្តភាព ។

ម្នាលភិក្ខុទាំងឡាយ ពួកអ្នកក៏មានការសោយកម្ម ដែលខ្លួនធ្វើហើយដូចគ្នា ។ ក្នុងអតីតកាល ក្នុងក្រុងពារាណសី ក្មេងគង្វាលគោ ៧ នាក់ ត្រាច់ឃ្វាលគោមួយកន្លែង ៧ ថ្ងៃ ក្នុងទីជិតព្រៃមួយកន្លែង ។ ថ្ងៃមួយ ឃ្វាលគោហើយ ត្រឡប់មកជួបទន្សងធំមួយ ទើបដេញតាម ទន្សងគេចចូលទៅកាន់ដំបូកមួយ ឯរន្ធនៃដំបូកនោះមាន ៧ ពួកក្មេងប្រឹក្សាគ្នាថា ឥឡូវនេះ ពួកយើងមិនអាចចាប់បាន ស្អែកនេះ សឹមនាំគ្នាមកចាប់ ដូច្នេះហើយ ម្នាក់ៗកាន់យកមែកឈើដែលកាច់ ម្នាក់មួយក្តាប់ៗ ទាំង ៧ នាក់ នាំគ្នាចុករន្ធទាំង ៧ ហើយចៀសចេញទៅ ។ ក្នុងថ្ងៃស្អែកឡើង ក្មេងទាំងនោះមិនបាននឹកដល់ទន្សងនោះ ឃ្វាលគោក្នុងទីដទៃ លុះគ្រប់ ៧ ថ្ងៃ នាំគ្នាត្រឡប់មក ជួបដំបូកនោះ ក៏បាននូវស្មារតីគិតគ្នាថា ទន្សងនោះដូចម្តេចទៅហើយហ្ន៎ ទើបដកធ្នុកដែលបិទហើយ ។ ទន្សងអស់អាល័យក្នុងជីវិត សល់តែស្បែកដណ្តប់ឆ្អឹងលូនចេញមក ក្មេងទាំងនោះឃើញដូច្នេះហើយ កើតនូវការអាណិត ពោលថា ពួកយើងកុំសម្លាប់វាឡើយ គ្នាអត់អាហារអស់ ៧ ថ្ងៃ ទើបស្ទាបខ្នងទន្សងនោះហើយលែងទៅដោយពោលថា ចូរឯងទៅតាមសប្បាយចុះ ក្មេងទាំងនោះមិនឆេះក្នុងនរក ព្រោះមិនបានសម្លាប់ទន្សង តែជនទាំង ៧ នោះ បានជាអ្នកអត់បាយរួមគ្នា ៧ ថ្ងៃៗ អស់ ១៤ អត្តភាព ។ ម្នាលភិក្ខុទាំងឡាយ កម្មនោះ ពួកអ្នកជាក្មេងឃ្វាលគោ ៧ នាក់ ធ្វើហើយ ក្នុងកាលនោះ ។

ព្រះសាស្តា ទ្រង់ព្យាករបញ្ហាដែលភិក្ខុនោះទូលសួរហើយ ដោយប្រការ

ដូច្នេះ ។

គ្រានោះ ភិក្ខុមួយរូប ទូលព្រះសាស្តាថា បពិត្រព្រះអង្គ ការរួចផុតរមែងមិនមានដល់សត្វដែលធ្វើបាបកម្មហើយ ទោះហោះទៅក្នុងអាកាសក្តី នៅក្នុងមហាសមុទ្រក្តី ចូលកាន់រូងភ្នំក្តី ដូច្នេះឬ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង ក្នុងទីទាំងឡាយ មានអាកាសជាដើម ប្រទេសត្រឹមតែមួយដែលបុគ្គលនៅហើយ គប្បីផុតចាកបាបកម្ម មិនមាន កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ ន បព្វតានំ វិវរំ បវិសំ**
**ន វិជ្ជតី សោ ជគតិប្បទេសោ យត្រដ្ឋិតោ មុញ្ចេយ្យ បាបកម្មា ។**

បុគ្គលអ្នកធ្វើបាបកម្មហើយ ទោះបីចូលទៅឰដ៏អាកាស ក្នុងកណ្តាលសមុទ្រ កាន់ចន្លោះភ្នំទាំងឡាយ ក៏មិនគប្បីរួចចាកបាបកម្ម ព្រោះប្រទេសលើផែនដី ដែលបុគ្គលស្ថិតនៅហើយ គប្បីរួចចាកបាបកម្មបាននោះ មិនដែលមានឡើយ ។

## សេចក្តីអធិប្បាយ

សេចក្តីនៃព្រះគាថានោះថា បើបុគ្គលខ្លះគិតថា អញនឹងផុតចាកបាបកម្មដោយឧបាយនេះ គប្បីអង្គុយក្នុងអាកាសក្តី គប្បីចូលទៅមហាសមុទ្រ ដែលមានជម្រៅ ៨៤០០០ យោជន៍ក្តី គប្បីអង្គុយក្នុងញកភ្នំក្តី បុគ្គលនោះ មិនគប្បីផុតចាកកម្មអាក្រក់បានឡើយ ព្រោះថា ក្នុងចំណែកនៃផែនដី គឺភាគនៃប្រឹថពី មានទិសខាងកើតជាដើម ឱកាសប្រមាណប៉ុនចុងរោមទ្រាយ ដែល

បុគ្គលនៅហើយ គប្បីអាចរួចផុតចាកបាបកម្មបានមិនមាន ។

ក្នុងកាលចប់ទេសនា ភិក្ខុទាំងនោះសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ព្រះធម្មទេសនាជាកថាមានប្រយោជន៍ ដល់មហាជនដែលប្រជុំគ្នាហើយ ដូច្នេះឯង ។ល៕

**រឿង ជន ៣ ពួក ចប់**

# រឿង ព្រះបាទសុប្បពុទ្ធសក្យៈ

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងនិគ្រោធារាម ទ្រង់ប្រារព្ធសក្យរាជព្រះនាមសុប្បពុទ្ធ ត្រាស់ព្រះធម្មទេសនានេះថា **ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ** ជាដើម ។

បានឮមកថា ព្រះបាទសុប្បពុទ្ធអង្គនោះ ចងអាឃាតព្រះសាស្ដាដោយហេតុ ២ យ៉ាង គឺព្រះសមណគោតមនេះ បោលកូនស្រីរបស់អញចេញបួស ១ ឲ្យកូនប្រុសរបស់អញបួសហើយ តាំងនៅក្នុងឋានៈជាសត្រូវចំពោះកូនប្រុសអញ ១ ។ ថ្ងៃមួយ ទ្រង់ព្រះតម្រិះថា ឥឡូវនេះ អញនឹងមិនឲ្យព្រះសមណគោតមនោះ ទៅឆាន់ក្នុងទីដែលនិមន្តដូច្នេះ ទើបបិទផ្លូវដែលយាង ទៅអង្គុយសោយទឹកចណ្ឌក្នុងរវាងចន្លោះផ្លូវ ។

លំដាប់នោះ កាលព្រះសាស្ដា មានភិក្ខុសង្ឃចោមរោមយាងមកទីនោះ

ពួកមហាតលិកក្រាបទូលថា ព្រះសាស្តាយាងមកហើយ ព្រះរាជាត្រាស់ថា ចូរពួកអ្នកទៅមុន ប្រាប់សមណៈនោះថា ព្រះសមណគោតម មិនជាធំជាង យើងឡើយ យើងនឹងមិនឲ្យផ្លូវដល់សមណគោតមនោះ សូម្បីពួកមហា-តលិកទូលជាស់តឿនហើយ ក៏នៅប្រថាប់គង់ត្រាស់យ៉ាងនោះហើយ ។

ព្រះសាស្តា មិនបានផ្លូវអំពីសម្នាក់របស់ព្រះមាតុលៈហើយ ទើបយាង ត្រឡប់អំពីទីនោះ ។ សូម្បីព្រះរាជាក៏ទ្រង់បញ្ជូនចារបុរសម្នាក់ទៅដោយត្រាស់ ថា ចូរអ្នកទៅស្តាប់ពាក្យរបស់សមណគោតមនោះ ហើយត្រឡប់មក ។

ព្រះសាស្តាយាងត្រឡប់មក ទ្រង់ធ្វើការញញឹម ព្រះអានន្ទត្ថេរទូលថា បពិត្រព្រះអង្គ អ្វីហ្ន៎ជាបច្ច័យនៃកម្ម គឺការញញឹមឲ្យប្រាកដ ទើបព្រះសាស្តា ត្រាស់ថា ម្នាលអានន្ទ អ្នកឃើញព្រះបាទសុប្បពុទ្ធដែរឬទេ ព្រះថេរៈទូលថា បពិត្រព្រះអង្គ ឃើញ ព្រះសាស្តាត្រាស់ថា ព្រះបាទសុប្បពុទ្ធនោះមិនឲ្យផ្លូវ ដល់ព្រះពុទ្ធដូចតថាគត ធ្វើកម្មធ្ងន់ហើយ ក្នុងថ្ងៃទី ៧ បន្ទាប់អំពីថ្ងៃនេះ ទ្រង់ នឹងចូលទៅកាន់ផែនដី ក្នុងទីជិតជណ្តើរ ខាងក្រោមប្រាសាទ ។

ចារបុរសបានស្តាប់ព្រះតម្រាស់នោះហើយ ទៅកាន់សម្នាក់របស់ព្រះបាទ សុប្បពុទ្ធ ព្រះរាជាត្រាស់សួរថា ក្មួយរបស់យើងកាលត្រឡប់ទៅនិយាយអ្វី ខ្លះ ទើបក្រាបទូលតាមដែលខ្លួនបានឮ ។

ព្រះរាជាបានស្តាប់ពាក្យរបស់ចារបុរសនោះហើយ ត្រាស់ថា ឥឡូវនេះ ក្នុងការនិយាយខុសនៃក្មួយរបស់យើងមិនមាន ទ្រង់ត្រាស់ពាក្យណា ពាក្យ នោះ ត្រូវពិតដូច្នោះឯង កាលបើដូច្នេះ ឥឡូវនេះ យើងនឹងចាប់កំហុសរបស់

ទ្រង់ ដោយការនិយាយកុហក ព្រោះទ្រង់មិនត្រាស់ជាមួយយើងដោយចំពោះថា ព្រះបាទសុប្បពុទ្ធនឹងត្រូវធរណីស្រូបក្នុងថ្ងៃទី ៧ តែត្រាស់ថា យើងនឹងត្រូវធរណីស្រូបក្នុងទីជិតជណ្ដើរខាងក្រោមប្រាសាទ តាំងអំពីថ្ងៃនេះទៅ យើងនឹងមិនទៅកាន់ទីនោះ កាលបើដូច្នោះ យើងមិនត្រូវធរណីស្រូបក្នុងទីនោះ ហើយនឹងសង្កត់សង្កិនទ្រង់ដោយការពោលកុហក ។

ព្រះរាជាត្រាស់ឲ្យពួកមហាតលិកជញ្ជូនគ្រឿងប្រើប្រាស់របស់ទ្រង់ចេញទាំងអស់ទុកលើប្រាសាទ ៧ ជាន់ ឲ្យដកជណ្ដើរ បិទទ្វារ តាំងមនុស្សដែលមានកម្លាំងទុកត្រង់ទ្វារ មួយទ្វារពីរនាក់ ត្រាស់ថា បើយើងចុះទៅខាងក្រោមដោយប្រមាទសោត ពួកអ្នកត្រូវឃាត់យើង ដូច្នេះហើយ ប្រថាប់គង់ក្នុងបន្ទប់ដ៏មានសិរី លើផ្ទៃប្រាសាទជាន់ទី ៧ ។

ព្រះសាស្ដា ទ្រង់ស្ដាប់រឿងនោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រះបាទសុប្បពុទ្ធ មិនមែនគង់លើផ្ទៃប្រាសាទតែម្យ៉ាង ទោះបីហោះឡើងទៅកាន់អាកាស អង្គុយលើអាកាសក្ដី ទៅកាន់សមុទ្រដោយទូកក្ដី ចូលញកភ្នំក្ដី ធម្មតាព្រះតម្រាស់របស់ព្រះពុទ្ធទាំងឡាយ មិនបែកជាពីរឡើយ ព្រះរាជានឹងត្រូវធរណីស្រូប ក្នុងទីដែលតថាគតពោលនោះឯង កាលទ្រង់បន្តអនុសន្ធិសម្ដែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ ន បព្វតានំ វិវរំ បវិស្ស**

**ន វិជ្ជតី សោ ជគតិប្បទេសោ យត្រដ្ឋិតំ នប្បសហេយ្យ មច្ចុ ។**

*បុគ្គលទៅឰដ៏អាកាស ក្នុងកណ្តាលសមុទ្រ កាន់ចន្លោះនៃភ្នំទាំង-ឡាយ ក៏មិនរួចចាកសេចក្តីស្លាប់បាន ព្រោះប្រទេសលើផែនដី ដែលបុគ្គលស្ថិតនៅហើយ សេចក្តីស្លាប់គ្របសង្កត់មិនបាននោះ មិនដែលមានឡើយ ។*

## សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ ពីរបទថា* **នប្បសហេយ្យ មច្ចុ** *សេចក្តីថា ប្រទេស គឺផែនដី សូម្បីត្រឹមប៉ុនចុងសក់ ដែលមរណៈមិនគប្បីញាំញី គឺមិនគប្បីគ្រប សង្កត់បុគ្គលស្ថិតនៅរមែងមិនមាន ពាក្យដ៏សេស ក៏ដូចគ្នានឹងពាក្យមុននោះឯង ។ ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមដូច្នេះឯង ។*

*ក្នុងថ្ងៃទី ៧ ក្នុងពេលដែលព្រះបាទសុប្បពុទ្ធបិទផ្លូវកិក្ខាចាររបស់ព្រះ សាស្តា សេះមង្គលរបស់ព្រះបាទសុប្បពុទ្ធ នៅខាងក្រោមប្រាសាទស្រែក កញ្ជ្រៀវ ទន្ទិចទន្ទូវជញ្ជាំងនោះ ។*

*ព្រះរាជាប្រថាប់គង់លើប្រាសាទនោះឯង បានស្តាប់សំឡេងរបស់សេះ នោះត្រាស់សួរថា នុ៎ះជាសំឡេងអ្វី មហាតលិកទូលថា សេះមង្គលកញ្ជ្រៀវ ចំណែកសេះនោះ គ្រាន់តែឃើញព្រះបាទសុប្បពុទ្ធ ក៏នៅស្ងៀម ។*

ខណៈនោះ ព្រះរាជាមានបំណងនឹងចាប់សេះនោះ បានចុះអំពីទីប្រថាប់ បែរមុខមកកាន់ទ្វារ ទ្វារទាំងឡាយបើកឯងនោះឯង ជណ្ដើរតាំងនៅក្នុងទីរបស់ខ្លួនដូចមុន បុរសមានកម្លាំងឈរត្រង់ទ្វារ ចាប់ព្រះរាជាត្រង់ក រុញឲ្យមានមុខចុះមកខាងក្រោម ។ ដោយឧបាយនោះ ទ្វារត្រង់ផ្ទៃប្រាសាទទាំង ៧ ក៏បើកឯងនោះឯង ជណ្ដើរទាំងឡាយក៏តាំងនៅដូចដើម ពួកបុរសដែលមានកម្លាំងចាំយាមក្នុងទីនោះៗ ចាប់ព្រះរាជាត្រង់កហើយ ច្រានព្រះរាជាឲ្យមានមុខចុះមក ។

ខណៈនោះ មហាប្រឹថពីប្រេះវង់ចាំព្រះបាទសុប្បពុទ្ធនោះ ដែលដល់ត្រង់ទីជិតជណ្ដើរខាងក្រោមប្រាសាទនោះឯង ព្រះរាជាទៅកើតក្នុងអវីចិនរកហើយ ៕ល៕

## រឿងព្រះបាទសុប្បពុទ្ធសក្យៈ ចប់

## បាបវគ្គ ចប់

## វគ្គទី ៩ ចប់

# សុត្តន្តបិដក

## ធម្មបទគាថា ទណ្ឌវគ្គទី ១០

[ ២០ ] សត្វទាំងឡាយគ្រប់ប្រាណ តែងតក់ស្លុតនឹងអាជ្ញា សត្វទាំង-ឡាយ តែងខ្លាចចំពោះសេចក្តីស្លាប់គ្រប់ៗ រូប បុគ្គលគួរធ្វើខ្លួនឲ្យជាឧបមាហើយ មិនគួរប្រហារដោយខ្លួនឯង មិនគួរប្រើគេឲ្យប្រហារឡើយ ។

សត្វទាំងឡាយគ្រប់ប្រាណ តែងតក់ស្លុតនឹងអាជ្ញា ( ព្រោះថា ) ជីវិតជាទីស្រឡាញ់របស់សត្វទាំងពួង បុគ្គលគួរធ្វើខ្លួនឲ្យជាឧបមាហើយ មិនគួរប្រហារដោយខ្លួនឯង មិនគួរប្រើគេឲ្យប្រហារឡើយ ។ ជនណា ស្វែងរកសេចក្តីសុខ ដើម្បីខ្លួន តែបៀតបៀនសត្វទាំងឡាយ ដែលប្រាថ្នាសេចក្តីសុខដោយអាជ្ញា ជននោះលះលោកនេះទៅហើយ នឹងមិនបានសេចក្តីសុខឡើយ។ ជនណា ស្វែងរកសេចក្តីសុខ ដើម្បីខ្លួន តែមិនបៀតបៀនសត្វទាំងឡាយអ្នកដែលប្រាថ្នាសេចក្តីសុខ ដោយអាជ្ញា ជននោះ លះលោកនេះទៅហើយរមែងបានសេចក្តីសុខ ។

អ្នកកុំនិយាយពាក្យអាក្រក់នឹងអ្នកណាមួយឡើយ ជនទាំងឡាយដែលអ្នកស្តីថាឲ្យហើយ គេគប្បីស្តីថាតបមកអ្នកវិញ ព្រោះថា ការពោលពាក្យប្រណាំងប្រជែង ជាហេតុនាំឲ្យកើតទុក្ខ ការតស៊ូទាំងឡាយ គប្បីប៉ះពាល់នូវអ្នក ។ បើអ្នកធ្វើខ្លួនមិនឲ្យញាប់ញ័រ ដូចគាំងដែលចៀរមាត់ចេញហើយ ( រមែងមិនលាន់ឮសូរ ) ដូច្នោះ អ្នកនុ៎ះ ជាបុគ្គលដល់នូវព្រះនិព្វានការប្រណាំងប្រជែង មិនមានដល់អ្នក ។

គង្វាលគោ រមែងកៀងគោទៅកាន់ទីគោចរ ដោយអាជ្ញា ដូចម្តេចមិញ ជរា និងមច្ចុ តែងកៀងអាយុរបស់សត្វទាំងឡាយ ដូច្នោះឯង ។

បុគ្គលមិនមានប្រាជ្ញា កាលធ្វើអំពើអាក្រក់ រមែងមិនភ្ញាក់ខ្លួន លុះកាលជាខាងក្រោយ ទើបក្តៅក្រហាយ ដោយសារកម្មរបស់ខ្លួន ដូចត្រូវភ្លើងឆេះ ។

បុគ្គលណា ប្រទូស្តដោយអាជ្ញា ចំពោះបុគ្គលទាំងឡាយ ដែលមិនមានអាជ្ញា មិនប្រទូស្ត បុគ្គលនោះ រមែងដល់នូវហេតុនៃសេចក្តីទុក្ខណាមួយ ក្នុងហេតុ ១០ យ៉ាង ដោយទាន់ហន់ គឺគប្បីដល់នូវវេទនាដ៏អាក្រក់ ១ សេចក្តីវិនាសទ្រព្យ ១ បែកធ្លាយសរីរៈ ១ អាពាធជាទម្ងន់ ១ ក្រឡកចិត្ត ( ឆ្កួត ) ១ រឹបជាន់អំពីស្តេច ១ ពោលពាក្យបង្កាច់ដ៏អាក្រក់ ១ អស់ពួកញាតិរលីង ១ ពុកផុយភោគសម្បត្តិទាំងឡាយ ១ ទាំងភ្លើងនឹងឆេះបំផ្លាញនូវផ្ទះរបស់បុគ្គលនោះ ១ បុគ្គលមិនមានប្រាជ្ញានោះ លុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងនរក ។ ការប្រព្រឹត្តអាក្រាតកាយ ទុកសក់ ដេកលើភក់ មិនបរិភោគបាយ ដេកលើផែនដី ប្រឡាក់ខ្លួនដោយធូលី ព្យាយាមអង្គុយប្រហោង មិនជម្រះសត្វដែលមិនទាន់ឆ្លងផុតសេចក្តីសង្ស័យបានទេ ។

បើបុគ្គលណា មានខ្លួនប្រដាប់ស្អិតស្អាងហើយ ( ដោយគ្រឿងអម្ពរ ) តែគប្បីប្រព្រឹត្តស្មើ អ្នកស្ងប់រម្ងាប់ ទូន្មាន ( ឥន្ទ្រិយ ) ជាបុគ្គលទៀង ( ចំពោះមគ្គផល ) អ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ទម្លាក់ចោលនូវអាជ្ញា ក្នុងសត្វទាំងពួងចេញហើយ បុគ្គលនោះ ហៅថា ព្រាហ្មណ៍ក៏បាន ថាសមណៈក៏បាន ថាភិក្ខុក៏បាន ។

បុរសអ្នកកម្ចាត់បង់នូវអកុសលវិតក្ក ដោយសេចក្ដីខ្មាសបាប មានតិចក្នុងលោក បុគ្គលណាបន្ទោបង់ នូវការដេកលក់ ដូចសេះល្អខ្លាចព្រោះរំពាត់ បុរសនោះ រកបានដោយក្រក្នុងលោក ។

សេះល្អ ដែលនាយសារថីទូន្មាន ដោយរំពាត់ តក់ស្លុត យ៉ាងណា អ្នកទាំងឡាយ ចូរជាបុគ្គលមានព្យាយាម មានសេចក្ដីតក់ស្លុតយ៉ាងនោះឯង បើអ្នកទាំងឡាយ ប្រកបព្រមដោយសទ្ធាផង សីលផង ព្យាយាមផង សមាធិផង ធម្មវិនិច្ឆ័យផង ជាអ្នកមានវិជ្ជា និងចរណៈដ៏បរិបូណ៌ មានស្មារតីតម្កល់មាំ រមែងលះបង់ទុក្ខ មានប្រមាណច្រើននេះមិនខាន ។

ធម្មតាអ្នកបង្ហូរ តែងបង្ហូរទឹក អ្នកធ្វើព្រួញ តែងពត់ព្រួញ ( ឲ្យត្រង់ ) អ្នកចាំង តែងចាំងឈើ អ្នកមានវត្តល្អ តែងទូន្មានខ្លួន ។

**ទណ្ឌវគ្គទី ១០ ចប់**

# អដ្ឋកថា
# ធណ្ឌវគ្គទី ១០

## រឿង ឆព្វគ្គិយភិក្ខុ
### លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឆព្វគ្គិយភិក្ខុ ត្រាស់ព្រះធម្មទេសនានេះថា **សព្វេ តសន្តិ** ជាដើម ។

សេចក្ដីពិស្ដារថា សម័យមួយ កាលសេនាសនៈដែលសត្តរសវគ្គិយភិក្ខុជួសជុលហើយ ឆព្វគ្គិយភិក្ខុពោលថា ចូរពួកលោកចេញទៅ ពួកខ្ញុំចាស់ជាងសេនាសនៈនោះដល់លំដាប់ពួកខ្ញុំ កាលសត្តរសវគ្គិយភិក្ខុទាំងនោះពោលថា ពួកខ្ញុំមិនឲ្យ ព្រោះពួកខ្ញុំជួសជុលមុន ដូច្នេះហើយ ទើបប្រហារភិក្ខុទាំងនោះ ។ សត្តរសវគ្គិយភិក្ខុត្រូវមរណភ័យគំរាមហើយ ទើបយំទ្រហឹង ។

ព្រះសាស្តា ទ្រង់ស្ដាប់សំឡេងរបស់ភិក្ខុទាំងនោះ ទើបត្រាស់សួរថា តើមានរឿងអ្វី កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ រឿងឈ្មោះនេះ ដូច្នេះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចាប់តាំងអំពីនេះទៅ ធម្មតាភិក្ខុមិនគួរធ្វើយ៉ាងនោះ ភិក្ខុណាធ្វើ ភិក្ខុនោះត្រូវអាបត្តិឈ្មោះនេះ ដូច្នេះហើយ ទ្រង់បញ្ញត្តបហារទានសិក្ខាបទ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុដឹងថា អាត្មាអញរមែងតក់ស្លុតចំពោះអាជ្ញា ខ្លាចចំពោះសេចក្ដីស្លាប់ យ៉ាងណា

សូម្បីសត្វដទៃ ក៏រមែងតក់ស្លុតចំពោះអាជ្ញា ខ្លាចចំពោះសេចក្តីស្លាប់ដូច្នោះ ដូចគ្នា មិនគួរប្រហារឯង មិនគួរប្រើឲ្យសម្លាប់អ្នកដទៃ ដូច្នេះហើយ កាល ទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**សព្វេ តសន្តិ ទណ្ឌស្ស សព្វេ ភាយន្តិ មច្ចុនោ**
**អត្តានំ ឧបមំ កត្វា ន ហនេយ្យ ន ឃាតយេ ។**

សត្វទាំងឡាយ គ្រប់ប្រាណ តែងតក់ស្លុតនឹងអាជ្ញា សត្វទាំង-ឡាយ តែងខ្លាចចំពោះសេចក្តីស្លាប់គ្រប់ៗ រូប បុគ្គលគួរធ្វើ ខ្លួនឲ្យជាឧបមាហើយ មិនគួរប្រហារដោយខ្លួនឯង មិនគួរ ប្រើគេឲ្យប្រហារឡើយ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **សព្វេ តសន្តិ** សេចក្តីថា សត្វទាំងអស់ កាលអាជ្ញាធ្លាក់ដល់ខ្លួន រមែងតក់ស្លុតចំពោះអាជ្ញានោះ ។

បទថា **មច្ចុនោ** បានដល់ រមែងខ្លាចចំពោះសេចក្តីស្លាប់ពិត ។

ព្យញ្ជនៈនៃទេសនានេះមិនមានសល់ ចំណែកអត្ថនៅមានសល់ ឧបមា ដូចកាលព្រះរាជាប្រើឲ្យពួករាជបុរសវាយស្គរប្រកាសថា ជនទាំងអស់ ចូរ ប្រជុំគ្នា ជនទាំងឡាយដ៏សេស វៀរព្រះរាជា និងអមាត្យ រមែងប្រជុំគ្នា យ៉ាងណា កាលព្រះសាស្តាត្រាស់ថា សត្វទាំងអស់ រមែងតក់ស្លុត ដូច្នេះ សត្វទាំងឡាយដ៏សេស វៀរសត្វពិសេស ៤ ពួក គឺដំរីអាជានេយ្យ សេះ អាជានេយ្យ គោឧសភអាជានេយ្យ និងព្រះខីណាស្រព បណ្ឌិតគប្បីជ្រាបថា

រមែងតក់ស្លុតដូច្នោះដូចគ្នា ។ ពិតហើយ បណ្ដាសត្វវិសេសទាំងនេះ ព្រះខីណាស្រពមិនឃើញសត្វដែលស្លាប់ ព្រោះលោកលះសក្កាយទិដ្ឋិចេញបានហើយ ទើបមិនខ្លាច សត្វវិសេស ៣ ពួកក្រៅអំពីនេះ មិនឃើញសត្វដែលជាបដិបក្ខចំពោះខ្លួន ព្រោះសក្កាយទិដ្ឋិមានកម្លាំង ទើបមិនខ្លាច ។

ព្រះគាថាថា **ន ហនេយ្យ ន ឃាតយេ** សេចក្ដីថា បុគ្គលដឹងថា អាត្មាអញ យ៉ាងណា សត្វដទៃក៏ដូច្នោះ ដូច្នេះហើយ ក៏មិនសម្លាប់ឯង មិនគួរឲ្យអ្នកដទៃសម្លាប់ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

**រឿង ឆព្វគ្គិយភិក្ខុ ចប់**

# រឿង ឆព្វគ្គិយភិក្ខុ

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធពួកឆព្វគ្គិយភិក្ខុ ត្រាស់ព្រះធម្មទេសនានេះថា **សព្វេ តសន្តិ** ជាដើម ។

សេចក្ដីពិស្ដារថា សម័យមួយ ពួកឆព្វគ្គិយភិក្ខុនាំនូវលំពែង គឺបាតដៃ ដល់ពួកសត្តរសវគ្គិយភិក្ខុទាំងនោះ ដោយហេតុដែលខ្លួនប្រហារពួកសត្តរស-

វគ្គិយភិក្ខុក្នុងសិក្ខាបទមុននោះឯង តែក្នុងរឿងនេះ ព្រះសាស្តាទ្រង់ស្តាប់សំឡេងរបស់ភិក្ខុទាំងនោះហើយ ត្រាស់សួរថា តើមានរឿងអ្វី ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ រឿងឈ្មោះនេះ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចាប់តាំងអំពីនេះទៅ ធម្មតាភិក្ខុមិនគួរធ្វើយ៉ាងនេះ ភិក្ខុណាធ្វើ ភិក្ខុនោះ ត្រូវអាបត្តិឈ្មោះនេះ ដូច្នេះហើយ ទ្រង់បញ្ញត្តតលសត្តិកសិក្ខាបទ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុដឹងថា សូម្បីសត្វពួកដទៃ រមែងតក់ស្លុតចំពោះអាជ្ញាតែម្យ៉ាង ដូចអាត្មាអញដូចគ្នា ម្យ៉ាងទៀត ជីវិតក៏រមែងជាទីស្រឡាញ់របស់សត្វទាំងនោះ ដូចអាត្មាអញដោយពិត មិនគួរប្រហារឯង មិនគួរប្រើអ្នកដទៃឲ្យសម្លាប់ ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**សព្វេ តសន្តិ ទណ្ឌស្ស សព្វេសំ ជីវិតំ បិយំ**
**អត្តានំ ឧបមំ កត្វា ន ហនេយ្យ ន ឃាតយេ ។**

សត្វទាំងឡាយគ្រប់ប្រាណ តែងតក់ស្លុតនឹងអាជ្ញា ( ព្រោះថា ) ជីវិត ជាទីស្រឡាញ់របស់សត្វទាំងពួង បុគ្គលគួរធ្វើខ្លួនឲ្យជាឧបមាហើយ មិនគួរប្រហារដោយខ្លួនឯង មិនគួរប្រើគេឲ្យប្រហារឡើយ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បាទព្រះគាថាថា **សព្វេសំ ជីវិតំ បិយំ** សេចក្តីថា ជីវិតរមែងជាទីស្រឡាញ់ក្រៃលែងរបស់ពួកសត្វដ៏សេស វៀរព្រះខីណាស្រព

ចេញ ឯព្រះខីណាស្រព ជាអ្នកព្រងើយក្នុងជីវិត ឬក្នុងមរណៈដោយពិត ។ ពាក្យដ៏សេស ដូចគ្នានឹងពាក្យដែលមានអំពីមុននោះឯង ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើម ដូច្នេះឯង ។៚

**រឿង ឆព្វគ្គិយភិក្ខុ ចប់**

# រឿង កុមារច្រើននាក់

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុមារជាច្រើន ត្រាស់ព្រះធម្មទេសនានេះថា **សុខកាមានិ ភូតានិ** ជាដើម ។

សេចក្តីពិស្តារថា ថ្ងៃមួយ ព្រះសាស្តាទ្រង់កាន់បាត្រ ចូលទៅកាន់ក្រុង សាវត្ថី ទ្រង់ឃើញក្មេងជាច្រើន យកដំបងវាយពស់ផុះមួយ ក្នុងចន្លោះផ្លូវ ត្រាស់សួរថា នែកុមារទាំងឡាយ ពួកអ្នកធ្វើអ្វី ក្មេងទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ ពួកខ្ញុំយកដំបងវាយពស់ ទើបត្រាស់ទៀតថា ព្រោះហេតុអ្វី ទើបពួកក្មេងក្រាបទូលថា បពិត្រព្រះអង្គ ព្រោះខ្លាចវាចឹក ទើបត្រាស់ថា ពួក អ្នកវាយពស់នេះដោយគិតថា អ្នកនឹងធ្វើសេចក្តីសុខដល់ខ្លួន នឹងជាបុគ្គលមិន បានទទួលសេចក្តីសុខក្នុងទីដែលខ្លួនកើតហើយ ពិតហើយ បុគ្គល កាល ប្រាថ្នាសុខដល់ខ្លួន តែប្រហារសត្វដទៃ រមែងមិនគួរ ដូច្នេះហើយ កាល

*ទ្រង់បន្តអនុសន្ធិសម្ដែងធម៌ ទើបទ្រង់ភាសិតព្រះគាថានេះថា*

**សុខកាមានិ ភូតានិ យោ ទណ្ឌេន វិហឹសតិ**
**អត្តនោ សុខមេសានោ បេច្ច សោ ន លភតេ សុខំ ។**
**សុខកាមានិ ភូតានិ យោ ទណ្ឌេន ន ហឹសតិ**
**អត្តនោ សុខមេសានោ បេច្ច សោ លភតេ សុខំ ។**

*ជនណា ស្វែងរកសេចក្ដីសុខដើម្បីខ្លួន តែបៀតបៀនសត្វទាំងឡាយ ដែលប្រាថ្នាសេចក្ដីសុខដោយអាជ្ញា ជននោះ លះលោកនេះទៅហើយ នឹងមិនបានសេចក្ដីសុខឡើយ ។*

*ជនណា ស្វែងរកសេចក្ដីសុខដើម្បីខ្លួន តែមិនបៀតបៀនសត្វទាំងឡាយ អ្នកដែលប្រាថ្នាសេចក្ដីសុខដោយអាជ្ញា ជននោះ លះលោកនេះទៅហើយ រមែងបានសេចក្ដីសុខ ។*

## សេចក្ដីអធិប្បាយ

*បណ្ដាបទទាំងនោះ ពីរបទថា* **យោ ទណ្ឌេន** *សេចក្ដីថា បុគ្គលណា បៀតបៀនអ្នកដទៃដោយដំបង ឬវត្ថុទាំងឡាយ មានដុំដីជាដើម ។*

*បាទព្រះគាថា* **បេច្ច សោ ន លភតេ សុខំ** *សេចក្ដីថា បុគ្គលនោះ រមែងមិនបានសុខសម្រាប់មនុស្ស សុខដែលជាទិព្វ ឬសុខ គឺព្រះនិព្វានដែលជាបរមត្ថសុខ ក្នុងលោកខាងមុខ ។ ក្នុងគាថាទីពីរ បទជាច្រើនថា* **បេច្ច សោ លភតេ សុខំ** *សេចក្ដីថា បុគ្គលនោះ រមែងបានសុខទាំង ៣ យ៉ាង មានប្រការដូចពោលហើយ ក្នុងបរលោក ។*

ក្នុងកាលចប់ទេសនា ក្មេងទាំង ៥០០ តាំងនៅក្នុងសោតាបត្តិផល ដូច្នេះឯង ។ល។

**រឿង កុមារច្រើននាក់ ចប់**

# រឿង ព្រះកោណ្ឌធានត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះថេរៈឈ្មោះកោណ្ឌធាន ត្រាស់ព្រះធម្មទេសនានេះថា **មាវោច ផរុសំ កញ្ចិ** ជាដើម ។

បានឮមកថា ចាប់តាំងអំពីថ្ងៃដែលព្រះថេរៈនោះបួសហើយ រូបស្ត្រីម្នាក់ត្រាច់ទៅជាមួយព្រះថេរៈ តែព្រះថេរៈមិនឃើញរូបស្ត្រីនោះ ។ ចំណែកមហាជនឃើញ កាលលោកត្រាច់បិណ្ឌបាតខាងក្នុងស្រុក ពួកមនុស្សប្រគេនភិក្ខាមួយវែក ហើយពោលថា បពិត្រលោកម្ចាស់ នេះជាចំណែកសម្រាប់លោកម្ចាស់ តែចំណែកនេះសម្រាប់ស្ត្រី ដែលជាសម្លាញ់របស់លោកម្ចាស់ ដូច្នេះហើយ ក៏ប្រគេនភិក្ខាពីរវែក ។

សួរថា បុព្វកម្មរបស់លោកដូចម្តេច ឆ្លើយថា បានឮថា ក្នុងកាលនៃព្រះពុទ្ធព្រះនាមកស្សបៈ ភិក្ខុពីររូបជាសម្លាញ់នឹងគ្នា ជាអ្នកស្រឡាញ់គ្នាយ៉ាងក្រៃលែង ដូចកើតអំពីផ្ទៃម្តាយតែមួយ ។

ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធដែលមានព្រះជន្មវែង ភិក្ខុទាំងឡាយរមែងប្រជុំគ្នា ដើម្បីប្រយោជន៍ដោយការធ្វើឧបោសថរៀងរាល់មួយឆ្នាំម្តង ឬ ៦ ខែម្តង ព្រោះដូច្នោះ ព្រះថេរៈទាំងពីររូបនោះ ក៏ចេញអំពីលំនៅដោយគិតថា នឹងទៅកាន់រោងឧបោសថ ។

ទេវតាកើតក្នុងជាន់តាវត្តិង្សមួយរូប ឃើញព្រះថេរៈទាំងពីរ គិតថា ភិក្ខុនេះស្រឡាញ់គ្នាពន់ពេក អញអាចបំបែកភិក្ខុទាំងនេះបានឬហ្ន៎ ដូច្នេះហើយបានមកក្នុងលំដាប់ដែលខ្លួនគិតហើយនោះឯង ព្រោះភាពដែលខ្លួនជាបុគ្គលក្អេងក្អាង ។ ក្នុងភិក្ខុពីររូបនោះ កាលមួយរូបពោលថា អាវុសោ សូមរង់ចាំមួយភ្លែត ខ្ញុំបន្ទោបង់ឧច្ចារៈ ទើបនិម្មិតភេទជាស្រីមនុស្សម្នាក់ កាលដែលព្រះថេរៈចូលទៅក្នុងរវាងគុម្ពឈើ ហើយចេញមក យកដៃម្ខាងប្រមូលសក់ ដៃម្ខាងស្លៀកសំពត់ដើរចេញមកតាមក្រោយព្រះថេរៈនោះ ។ លោកមិនឃើញស្រីនោះ ។ តែភិក្ខុមួយរូបដែលឈរខាងមុខដែលរង់ចាំលោក ក្រឡេកមកឃើញស្រីនោះ ធ្វើយ៉ាងនោះ ដើរតាមក្រោយមក ។

ទេវតានោះដឹងភាវៈនៃខ្លួនដែលភិក្ខុនោះឃើញហើយ ក៏អន្តរធានទៅ ។ ភិក្ខុដែលរង់ចាំនោះ និយាយនឹងភិក្ខុនោះក្នុងកាលដែលមកជិតខ្លួនថា អាវុសោ សីលរបស់លោកបែកធ្លាយហើយ ភិក្ខុពោលថា អាវុសោ កម្មបែបនោះរបស់ខ្ញុំមិនមាន ភិក្ខុរង់ចាំពោលថា អម្បាញ់មិញនេះ ស្រីវ័យក្មេងដើរតាម ចេញមកខាងក្រោយលោក លោកធ្វើកម្មឈ្មោះនេះ ខ្ញុំឃើញហើយ លោកហ៊ាននិយាយបដិសេធថា កម្មបែបនេះរបស់ខ្ញុំមិនមានឬ ។

ភិក្ខុនោះ ហាក់បីដូចត្រូវរន្ទះធ្លាក់ចុះត្រង់អំបែងក្បាល ពោលអង្វរថា អាវុសោ សូមកុំឲ្យខ្ញុំវិនាសឡើយ កម្មបែបនោះរបស់ខ្ញុំមិនមានពិត ។

ភិក្ខុមួយរូបទៀតពោលថា ខ្ញុំឃើញដោយភ្នែកទាំងពីរ នឹងជឿលោកដូចម្ដេចបាន ដូច្នេះហើយ ក៏បែកគ្នាដូចកំណាត់ឈើ ហើយចៀសទៅ ។ ក្នុងវេនឧបោសថ ក៏អង្គុយដោយតាំងចិត្តថា អញនឹងមិនធ្វើឧបោសថជាមួយភិក្ខុនេះ ។

ភិក្ខុដែលត្រូវចោទប្រាប់ដល់ភិក្ខុទាំងឡាយថា បពិត្រលោកម្ចាស់ ចំណុចខ្មៅសូម្បីប៉ុនគ្រាប់ល្ង រមែងមិនមានក្នុងសីលរបស់ខ្ញុំ ភិក្ខុមួយរូបទៀតក៏ពោលអះអាងថា កម្មលាមកនោះ ខ្ញុំឃើញឯង ។

ទេវតាឃើញភិក្ខុរូបដែលរង់ចាំនោះ មិនប្រាថ្នាធ្វើឧបោសថ ជាមួយភិក្ខុមួយរូបទៀត គិតថា អញធ្វើកម្មធ្ងន់ហើយដូច្នេះ ទើបប្រាប់ថា ការបែកធ្លាយសីលរបស់លោកម្ចាស់មិនមាន តែខ្ញុំធ្វើកម្មលាមកនោះ ដោយអំណាចការសាកល្បងមើល សូមលោកម្ចាស់ធ្វើឧបោសថជាមួយលោកម្ចាស់ចុះ ភិក្ខុដែលរង់ចាំនោះ កាលទេវតានោះតាំងនៅក្នុងអាកាស ចន្លុលបង្ហាញ ទើបជឿ ហើយធ្វើឧបោសថរួមគ្នា តែមិនបានជិតស្និទ្ធក្នុងព្រះថេរៈដូចកាលមុនឡើយ ។

បុព្វកម្មរបស់ទេវតាមានប្រមាណប៉ុណ្ណេះ ក្នុងកាលអស់អាយុ ព្រះថេរៈទាំងនោះ កើតក្នុងទេវលោក ។ ចំណែកទេវតា កើតក្នុងអវីចីហើយ ឆេះក្នុងអវីចីនោះអស់មួយពុទ្ធន្តរ ។ ក្នុងពុទ្ធុប្បាទកាលនេះ បានកើតក្នុងក្រុងសាវត្ថី ដល់នូវការចម្រើនវ័យហើយ បានបព្វជ្ជាឧបសម្បទាក្នុងព្រះសាសនា តាំងអំពីថ្ងៃដែលបួសហើយ រូបស្រីនោះ ក៏បានប្រាកដយ៉ាងនោះឯង ដោយហេតុនោះ

ឯង ទើបភិក្ខុទាំងឡាយដាក់ឈ្មោះថា កោណ្ឌធាន ។

ភិក្ខុទាំងឡាយ ឃើញលោកត្រាច់ទៅយ៉ាងនោះ ទើបប្រាប់អនាថបិណ្ឌិកសេដ្ឋីថា លោកសេដ្ឋី សូមលោកបណ្តេញភិក្ខុទ្រុស្តសីលនេះចេញអំពីវិហាររបស់លោកចុះ ព្រោះថា ការវិនាសនឹងកើតឡើងដល់ភិក្ខុដ៏សេស ។ សេដ្ឋីពោលថា បពិត្រលោកម្ចាស់ ព្រះសាស្តាមិនមានក្នុងវិហារឬ ភិក្ខុប្រាប់ថា មានលោកសេដ្ឋី ។ សេដ្ឋីពោលថា បពិត្រលោកម្ចាស់ បើដូច្នោះ ព្រះសាស្តាគង់នឹងជ្រាប ។ ភិក្ខុទាំងឡាយ ក៏ទៅប្រាប់នាងវិសាខាយ៉ាងនោះដូចគ្នា សូម្បីនាងវិសាខាក៏បានឆ្លើយដល់ភិក្ខុទាំងនោះដូចគ្នា ។

ចំណែកភិក្ខុទាំងឡាយ កាលជនទាំងនោះមិនទទួលពាក្យរបស់ខ្លួន ទើបទូលដល់ព្រះរាជាថា មហាបពិត្រ ភិក្ខុឈ្មោះកោណ្ឌធាន នាំស្រីម្នាក់ដើរទៅនឹងញុំាងសេចក្តីវិនាសឲ្យកើតដល់ភិក្ខុគ្រប់រូប សូមមហាបពិត្របណ្តេញភិក្ខុរូបនោះចេញអំពីដែនរបស់ព្រះអង្គចុះ ព្រះរាជាត្រាស់ថា ភិក្ខុនោះនៅឯណា ពួកភិក្ខុប្រាប់ថា មហាបពិត្រ នៅក្នុងវិហារ ។ ព្រះរាជាត្រាស់ថា នៅក្នុងសេនាសនៈមួយណា ភិក្ខុពោលថា ក្នុងសេនាសនៈឈ្មោះនោះ ព្រះរាជាត្រាស់ថា បើដូច្នោះ សូមលោកម្ចាស់និមន្តទៅចុះ ខ្ញុំនឹងបញ្ជាឲ្យរាជបុរសចាប់ភិក្ខុរូបនោះ ។

ក្នុងពេលល្ងាច ព្រះរាជាយាងទៅកាន់វិហារ បញ្ជាឲ្យពួករាជបុរសព័ទ្ធសេនាសនៈនោះហើយ បានបែរព្រះភក្ត្រទៅកាន់លំនៅរបស់ព្រះថេរៈៗ បានឮសំឡេងកោកកាក ទើបចេញអំពីវិហារឈរត្រង់យ៉មុខ ។ ព្រះរាជាបានទត

ឃើញស្ត្រីនោះឈរខាងក្រោយខ្នងព្រះថេរៈនោះ ។ ព្រះថេរៈដឹងថា ព្រះរាជាយាងមក ទើបឡើងទៅកាន់វិហារអង្គុយហើយ ។ ព្រះរាជាមិនថ្វាយបង្គំព្រះថេរៈ ព្រោះបានទតឃើញស្ត្រីនោះ ទ្រង់រកមើលតាមជ្រុងទ្វារខ្លះ ក្រោមគ្រែខ្លះ ក៏មិនបានជួប ទើបត្រាស់នឹងព្រះថេរៈថា បពិត្រលោកម្ចាស់ ខ្ញុំបានឃើញស្រីម្នាក់ក្នុងទីនេះ តើស្រីនោះទៅណា ព្រះថេរៈទូលថា មហាបពិត្រ អាត្មាមិនឃើញ កាលព្រះរាជាត្រាស់ថា អម្បាញ់មិញ ខ្ញុំឃើញស្ត្រីឈរខាងក្រោយខ្នង ក៏ទូលបដិសេធថា មហាបពិត្រ អាត្មាមិនឃើញទេ ។

ព្រះរាជាទ្រង់ព្រះតម្រិះថា តើមានរឿងអ្វីហ្ន៎ ហើយត្រាស់ថា សូមនិមន្តលោកម្ចាស់ចេញអំពីទីនេះសិន កាលព្រះថេរៈចេញទៅអំពីទីនោះ ឈរត្រង់យ៉មុខ ស្ត្រីនោះក៏បានឈរខាងក្រោយខ្នងព្រះថេរៈទៀត ព្រះរាជាទតឃើញស្រីនោះហើយ ទើបយាងឡើងទៅជាន់លើទៀត ។ ព្រះថេរៈជ្រាបកាលដែលព្រះរាជាយាងមកហើយ ទើបអង្គុយ ។ ព្រះរាជាទ្រង់ពិនិត្យមើលស្ត្រីនោះក្នុងទីគ្រប់កន្លែងទៀត ក៏មិនបានជួប ទើបត្រាស់សួរព្រះថេរៈដដែលទៀតថា ស្រីនោះនៅឯណា ព្រះថេរៈឆ្លើយថា មហាបពិត្រ អាត្មាមិនឃើញស្ត្រីនោះទេ ព្រះរាជាត្រាស់ថា សូមលោកម្ចាស់ប្រាប់ចុះ ខ្ញុំឃើញស្ត្រីឈរខាងក្រោយខ្នងលោកម្ចាស់អម្បាញ់មិញនេះឯង ព្រះថេរៈពោលថា សូមថ្វាយព្រះពរមហាបពិត្រ សូម្បីមហាជនក៏ពោលថា ស្ត្រីត្រាច់ទៅខាងក្រោយខ្នងអាត្មាភាព ឯអាត្មាភាពមិនឃើញស្រីនោះឡើយ ។

ព្រះរាជាទ្រង់កំណត់ថា នុ៎ះគប្បីជារូបសិប្បនិមិត្ត ហើយត្រាស់នឹងព្រះ

ថេរៈទៀតថា សូមលោកម្ចាស់ចុះអំពីទីនេះសាកមើល កាលព្រះថេរៈចុះទៅ ឈរត្រង់យ៉មុខ ក៏បានទតឃើញស្រីនោះ ឈរខាងក្រោយខ្នងរបស់ព្រះថេរៈ នោះទៀត កាលយាងឡើងទៅខាងលើ ក៏មិនបានទតឃើញ ។ ព្រះរាជាទ្រង់ សាកសួរព្រះថេរៈទៀត កាលព្រះថេរៈទូលថា អាត្មាមិនឃើញ ក៏ទ្រង់សន្និដ្ឋាន បានថា នុ៎ះជារូបសិប្បនិមិត្តដោយពិត ទើបត្រាស់នឹងព្រះថេរៈថា បពិត្រលោក ម្ចាស់ កាលសត្តិលេសបែបនោះ ជាប់តាមពីខាងក្រោយលោកម្ចាស់ បុគ្គល ដទៃៗ នឹងមិនប្រគេនភិក្ខាដល់លោកម្ចាស់ សូមលោកម្ចាស់និមន្តទៅវាំង របស់ខ្ញុំជានិច្ចចុះ ខ្ញុំនឹងទំនុកបម្រុងលោកម្ចាស់ដោយបច្ច័យ ៤ ទ្រង់និមន្តព្រះ ថេរៈហើយ ក៏ចៀសចេញទៅ ។ ភិក្ខុទាំងឡាយលើកទោសថា អាវុសោ ទាំងឡាយ លោកទាំងឡាយ ចូរមើលកិរិយារបស់ព្រះរាជាលាមក កាល ពួកយើងទូលថា សូមទ្រង់បណ្តេញភិក្ខុនោះចេញអំពីវិហារ ក៏យាងមក បែរ ជានិមន្តភិក្ខុនោះដោយបច្ច័យ ៤ ហើយយាងត្រឡប់ ។

ភិក្ខុទាំងឡាយក៏ពោលនឹងព្រះថេរៈនោះថា រ៉ឺយបុគ្គលទ្រុស្តសីល ឥឡូវ នេះ ព្រះរាជាក្លាយជាមនុស្សអាក្រក់ហើយ ។ ព្រះថេរៈនោះ ក្នុងកាលមុន មិនអាចពោលអ្វីជាមួយភិក្ខុទាំងឡាយបាន ឥឡូវនេះ ពោលបានរហ័សថា ពួក លោក ជាមនុស្សទ្រុស្តសីល ជាមនុស្សអាក្រក់ ពួកលោកនាំស្រីដើរទៅ ។

ភិក្ខុទាំងនោះទៅក្រាបទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គ កោណ្ឌធាន កាលខ្ញុំព្រះអង្គពោលហើយ បែរជាពោលជេរដោយពាក្យផ្សេងៗ ជាដើមថា ពួកលោកក៏ជាបុគ្គលទ្រុស្តសីល ។

ព្រះសាស្តា ឲ្យត្រាស់ហៅព្រះកោណ្ឌធានទោះមកហើយ ត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកពោលយ៉ាងនោះពិតឬ ព្រះថេរៈទូលថា ករុណាព្រះអង្គ ព្រះសាស្តាត្រាស់ថា ហេតុអ្វីទើបអ្នកពោលយ៉ាងនោះ ព្រះថេរៈទូលថា ព្រោះភិក្ខុទាំងនោះពោលនឹងខ្ញុំព្រះអង្គ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុអ្វី ទើបពួកអ្នកពោលនឹងភិក្ខុនេះយ៉ាងនោះ ។

ពួកភិក្ខុទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គឃើញស្រីដើរទៅខាងក្រោយភិក្ខុនេះ ទើបពោលយ៉ាងនោះ ព្រះសាស្តាត្រាស់ថា បានឮថា ភិក្ខុទាំងនេះឃើញស្រីត្រាច់ទៅជាមួយអ្នក ទើបពោលយ៉ាងនោះ ចំណែកខ្លួនអ្នកមិនបានឃើញឡើយ ព្រោះហេតុអ្វី ទើបអ្នកពោលនឹងភិក្ខុទាំងនេះយ៉ាងនោះ ផលនេះកើតឡើងព្រោះអាស្រ័យទិដ្ឋិលាមករបស់អ្នក ក្នុងកាលមុនមិនមែនឬ ហេតុអ្វី ឥឡូវនេះ ទើបអ្នកប្រកាន់នូវទិដ្ឋិលាមកនោះទៀត ។ ពួកភិក្ខុទូលសួរថា បពិត្រព្រះអង្គ ភិក្ខុនេះធ្វើកម្មដូចម្តេចក្នុងកាលមុន ។

ពេលនោះ ព្រះសាស្តា ត្រាស់បុព្វកម្មរបស់លោកដល់ភិក្ខុទាំងនោះហើយ ត្រាស់ថា ម្នាលភិក្ខុ អ្នកអាស្រ័យកម្មលាមកនេះ ទើបដល់នូវប្រការប្លែកបែបនេះហើយ ឥឡូវនេះ អ្នកប្រកាន់នូវទិដ្ឋិដ៏លាមកបែបនោះទៀត មិនគួរ អ្នកកុំពោលពាក្យណាមួយជាមួយភិក្ខុទាំងឡាយទៀត ចូរជាអ្នកមិនមានសំឡេង ដូចគ្នាទីងជួងដែលគេកាត់កណ្តាប់មាត់ហើយ កាលធ្វើយ៉ាងនោះនឹងជាបុគ្គល ឈ្មោះថា សម្រេចព្រះនិព្វាន ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបទ្រង់ភាសិតព្រះគាថាទាំងនេះថា

**មាវោច ផរុសំ កញ្ចិ វុត្តា បដិវទេយ្យុ តំ**
**ទុក្ខា ហិ សារម្ភកថា បដិទណ្ឌា ផុសេយ្យុ តំ ។**
**សចេ នេរេសិ អត្តានំ កំសោ ឧបហតោ យថា**
**ឯស បត្តោសិ និព្វានំ សារម្ភោ តេ ន វិជ្ជតិ ។**

*អ្នកកុំនិយាយពាក្យអាក្រក់ នឹងអ្នកណាមួយឡើយ ជនទាំងឡាយដែលអ្នកស្តីថាឲ្យហើយ គេគប្បីស្តីថាតបមកអ្នកវិញ ព្រោះថា ការពោលពាក្យប្រណាំងប្រជែង ជាហេតុនាំឲ្យកើតទុក្ខ ការតស៊ូទាំងឡាយគប្បីប៉ះពាល់នូវអ្នក ។ បើអ្នកធ្វើខ្លួនមិនឲ្យញាប់ញ័រ ដូចគាំងដែលចៀរមាត់ចេញហើយ ( រមែងមិនលាន់ឮសូរ ) ដូច្នោះ អ្នកនុ៎ះជាបុគ្គលដល់នូវព្រះនិព្វាន ការប្រណាំងប្រជែង មិនមានដល់អ្នក ។*

## សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ បទថា* **កញ្ចិ** *សេចក្តីថា កុំពោលពាក្យគ្រោតគ្រាតដល់បុគ្គលណាម្នាក់ គឺសូម្បីជាមួយបុគ្គលម្នាក់ ។*

*បទថា* **វុត្តា** *សេចក្តីថា ជនដទៃត្រូវអ្នកពោលថា ពួកអ្នកទ្រុស្តសីល គប្បីពោលឆ្លើយឆ្លងជាមួយអ្នកខ្លះ នូវពាក្យយ៉ាងនោះដូចគ្នា ។*

*បទថា* **សារម្ភកថា** *ឈ្មោះថា ការពោលប្រណាំងប្រជែង ហេតុនោះនាំឲ្យកើតទុក្ខ ។*

*បទថា* **បដិទណ្ឌា** *សេចក្តីថា កាលអ្នកប្រហារអ្នកដទៃដោយអាជ្ញាទាំង*

ឡាយ មានកាយអាជ្ញាជាដើម អាជ្ញាត្រឡប់បែបនោះឯង គប្បីធ្លាក់លើអំបែងក្បាលរបស់អ្នក ។

បទថា **សចេ នេរេសិ** សេចក្តីថា បើអ្នកអាចធ្វើខ្លួនមិនឲ្យញាប់ញ័របានសោត ។

បាទព្រះគាថាថា **កំសោ ឧបហតោ យថា** សេចក្តីថា ដូចជួងដែលគេចៀរមាត់ ធ្វើឲ្យសល់តែខ្លួន ។ ពិតហើយ ជួងបែបនោះ សូម្បីបុគ្គលវាយហើយដោយដៃ ជើង ឬដោយដំបង ក៏មិនឮខ្លាំង ។

ពីរបទថា **ឯស បត្តោសិ** សេចក្តីថា បើអ្នកអាចជាបុគ្គលបែបនោះបានសោត អ្នកនោះបំពេញបដិបទានេះ ជាអ្នកមិនប្រមាទហើយក្នុងឥឡូវនេះឈ្មោះថា សម្រេចព្រះនិព្វាន ។

បាទព្រះគាថាថា **សារម្ភោ តេ ន វិជ្ជតិ** សេចក្តីថា កាលបើយ៉ាងនោះសូម្បីការប្រណាំងប្រជែងគ្នា មានការពោលធ្វើឲ្យក្រៃលែងជាងគ្នាជាលក្ខណៈជាដើមយ៉ាងនេះថា អ្នកជាអ្នកទ្រុស្តសីល ឬថា ពួកអ្នកជាអ្នកទ្រុស្តសីលដូច្នេះ រមែងមិនមាន គឺនឹងមិនមានដល់អ្នកឡើយ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមហើយ ។ ព្រះកោណ្ឌធានត្ថេរ តាំងនៅក្នុងព្រះឱវាទដែលព្រះសាស្តាប្រទានហើយ បានសម្រេចអរហត្តផល ក្នុងកាលមិនយូរប៉ុន្មានឡើយ លោកបានហោះឡើងទៅក្នុងអាកាស ចាប់ស្លាកគ្រាដំបូងដូច្នេះឯង ។

# រឿង ឧបោសថកម្ម

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តបុព្វារាម ទ្រង់ប្រារព្ធឧបោសថកម្ម របស់ឧបាសិកាទាំងឡាយ មាននាងវិសាខាជាដើម ត្រាស់ព្រះធម្មទេសនា នេះថា **យថាទណ្ឌេន គោបាលោ** ជាដើម ។

បានឮមកថា ក្នុងថ្ងៃឧបោសថមួយ ស្ត្រីប្រមាណ ៥០០ ក្នុងនគរសាវត្ថី ជាអ្នករក្សាឧបោសថ បានទៅកាន់វិហារ ។ នាងវិសាខាចូលទៅរកស្រីចាស់ៗ ក្នុងចំនួនស្រី ៥០០ នោះហើយសួរថា នែនាងទាំងឡាយ ពួកនាងរក្សាឧបោសថ ដើម្បីអ្វី កាលស្រីទាំងនោះឆ្លើយថា ពួកខ្ញុំប្រាថ្នាទិព្វសម្បត្តិ ទើបរក្សាឧបោសថ ។ សួរពួកស្រីវ័យកណ្តាល កាលពួកស្រីទាំងនោះប្រាប់ថា ពួកខ្ញុំរក្សាឧបោសថ ដើម្បីរួចផុតអំពីការនៅជាមួយស្រីរួមប្តី ។ សួរពួកស្រីក្មេងៗ កាលពួកគេ ប្រាប់ថា ពួកខ្ញុំរក្សាឧបោសថដើម្បីបានកូនប្រុស ក្នុងការមានគភ៌ដំបូង សួរស្រីវ័យក្រមុំ កាលពួកគេប្រាប់ថា ពួកខ្ញុំរក្សាឧបោសថដើម្បីទៅកាន់ត្រកូលប្តី ក្នុងវ័យស្រករៗ គ្នា ។ នាងបានស្តាប់ពាក្យទាំងអស់របស់ស្រីទាំងនោះហើយ ក៏នាំពួកស្រីទាំងនោះទៅកាន់សម្នាក់ព្រះសាស្តា ក្រាបទូលតាមលំដាប់ ។

ព្រះសាស្តា ទ្រង់ស្តាប់ពាក្យនោះហើយ ត្រាស់ថា ម្នាលនាងវិសាខា ធម្មតាសភាវធម៌ទាំងឡាយ មានជាតិជាដើមរបស់សត្វទាំងនេះ ដូចគ្នានឹង គោបាលដែលមានដំបងក្នុងដៃ ជាតិបញ្ជូនសត្វទៅកាន់សម្នាក់ជរា ជរាបញ្ជូន ទៅកាន់សម្នាក់ព្យាធិ ព្យាធិបញ្ជូនទៅកាន់សម្នាក់មរណៈ មរណៈរមែងកាត់

*បង់នូវជីវិត ដូចបុគ្គលកាប់នូវដើមឈើដោយពូថៅ កាលបើយ៉ាងនោះ ពួកសត្វ ឈ្មោះថា ប្រាថ្នាវិវដ្ដៈរមែងមិនមាន ប្រាថ្នាតែវដ្ដៈប៉ុណ្ណោះ ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្ដែងធម៌ ទើបត្រាស់ព្រះគាថានេះថា*

**យថា ទណ្ឌេន គោបាលោ គាវោ បាជេតិ គោចរំ**

**ឯវំ ជរា ច មច្ចុ ច អាយុំ បាជេន្តិ បាណិនំ ។**

*គង្វាលគោ រមែងកៀងគោទៅកាន់ទីគោចរ ដោយអាជ្ញា ដូចម្ដេចមិញ ជរា និងមច្ចុ តែងកៀងអាយុរបស់សត្វទាំងឡាយ ដូច្នោះឯង ។*

## សេចក្ដីអធិប្បាយ

*បណ្ដាបទទាំងនោះ បទថា* **បាជេតិ** *សេចក្ដីថា គោបាលដ៏ឈ្លាសកៀងគោទាំងឡាយ ដែលចូលទៅកាន់រវាងក្ដីស្រែដោយដំបង វាយដោយដំបងនោះឯងនាំទៅ ឈ្មោះថា រមែងកៀងនូវគោទាំងឡាយទៅកាន់ទីគោចរ ដែលមានស្មៅ និងទឹករកបានងាយ ។*

*ពីរបទថា* **អាយុំ បាជេន្តិ** *សេចក្ដីថា រមែងកាត់នូវឥន្ទ្រិយ គឺជីវិត គឺរមែងញ៉ាំងជីវិតិន្ទ្រិយឲ្យអស់ទៅ ។ ក្នុងព្រះគាថានេះ មានពាក្យឧបមាឧបមេយ្យដូច្នេះថា ជរា និងមច្ចុ ប្រៀបដូចគោបាល ជីវិតិន្ទ្រិយប្រៀបដូចហ្វូងគោ មរណៈ ប្រៀបដូចទីគោចរ ។ បណ្ដាសភាវធម៌ទាំងនោះ ជាតិបញ្ជូនឥន្ទ្រិយ គឺជីវិតរបស់សត្វទាំងឡាយទៅកាន់សម្នាក់ជរា ជរាបញ្ជូនទៅកាន់សម្នាក់ព្យាធិ ព្យាធិបញ្ជូនទៅកាន់សម្នាក់មរណៈ មរណៈនោះឯង កាត់នូវជីវិតិន្ទ្រិយរបស់*

សត្វទាំងឡាយ ដូចបុគ្គលកាត់ដើមឈើដោយពូថៅ ដូច្នោះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

**រឿង ឧទោសថកម្ម ចប់**

# រឿង អជគរប្រេត

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធអជគរប្រេត ត្រាស់ព្រះធម្មទេសនានេះថា **អថ ចាចានិ កម្មានិ** ជាដើម ។

សេចក្តីពិស្តារថា សម័យមួយព្រះមហាមោគ្គល្លាន និងព្រះលក្ខណៈ ចុះអំពីភ្នំគិជ្ឈកូដ បានឃើញសត្វឈ្មោះអជគរប្រេត ប្រមាណ ២៥ យោជន៍ ដោយទិព្វចក្ខុ ។ អណ្តាតភ្លើងឆេះឡើងអំពីក្បាលរបស់ប្រេតនោះ រហូតដល់កន្ទុយ ឆេះឡើងអំពីកន្ទុយរហូតដល់ក្បាល ឆេះឡើងទាំងសងខាង ទៅប្រជុំត្រង់កណ្តាលខ្លួន ។

ព្រះថេរៈកាលឃើញប្រេតនោះហើយទើបញញឹម កាលព្រះលក្ខណត្ថេរសួរហេតុនៃការញញឹមហើយ ក៏ឆ្លើយថា អាវុសោ កាលនេះ មិនមែនកាលព្យាករបញ្ហានេះ លោកចាំសួរក្នុងសម្នាក់ព្រះសាស្តាចុះ កាលត្រាច់បិណ្ឌបាតក្នុងក្រុងរាជគ្រឹះស្រេចហើយ ចូលទៅកាន់សម្នាក់ព្រះសាស្តា ព្រះលក្ខណត្ថេរ

សួរហើយ ទើបឆ្លើយថា អាវុសោ ខ្ញុំបានឃើញប្រេតមួយក្នុងទីនោះ អត្តភាពរបស់ប្រេតនោះ មានសភាពយ៉ាងនេះ ខ្ញុំឃើញហើយ ទើបធ្វើការញញឹមឲ្យប្រាកដ ព្រោះគិតថា អត្តភាពបែបនេះ ខ្ញុំមិនធ្លាប់ឃើញឡើយ ។

ព្រះសាស្តា កាលត្រាស់ពាក្យជាដើមថា ម្នាលភិក្ខុទាំងឡាយ សាវករបស់តថាគត ជាអ្នកមានចក្ខុហ្ន៎ ទ្រង់ទទួលពាក្យរបស់ព្រះថេរៈហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ប្រេតនោះ តថាគតក៏បានឃើញហើយត្រង់ពោធិមណ្ឌលដ្ឋានដូចគ្នា តែតថាគតមិនពោល ព្រោះថា ជនទាំងឡាយណាមិនជឿពាក្យរបស់តថាគត ការមិនជឿនោះ របស់បុគ្គលទាំងនោះ គប្បីប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ឥឡូវនេះ តថាគតបានមោគ្គល្លានជាបន្ទាល់ហើយ ទើបនិយាយបាន ។ កាលភិក្ខុទាំងឡាយ ទូលសួរបុព្វកម្មរបស់ប្រេតនោះហើយ ទើបទ្រង់ព្យាករថា

បានឮថា ក្នុងកាលនៃព្រះពុទ្ធព្រះនាមកស្សបៈ សេដ្ឋីឈ្មោះសុមង្គលក្រាលផ្ទៃដីដោយឥដ្ឋមាស សាងវិហារក្នុងទីប្រមាណ ២០ ឧសភៈ ដោយទ្រព្យប្រមាណប៉ុណ្ណោះហើយ បានធ្វើការឆ្លងដោយទ្រព្យប្រមាណប៉ុណ្ណោះទៀត ។ ថ្ងៃមួយ លោកសេដ្ឋីទៅកាន់សម្នាក់ព្រះសាស្តាអំពីព្រលឹម ឃើញចោរម្នាក់ដេកយកសំពត់កាសាវពស្ត្រដណ្តប់រហូតដល់ក្បាល មានជើងប្រឡាក់ភក់នៅក្នុងសាលាមួយជិតទ្វារនគរ ទើបពោលថា បុរសនេះ មានជើងប្រឡាក់ភក់ប្រហែលជាអ្នកដើរយប់ហើយ ទើបមកដេក ។

ចោរបើកមុខឡើងឃើញសេដ្ឋីហើយគិតក្នុងចិត្តថា ណ្ហើយចុះ អញនឹង

ដីឯកម្មដែលគួរធ្វើដល់វា ដូច្នេះហើយ ក៏ចងនូវអាឃាត បានដុតស្រែរបស់សេដ្ឋី ៧ ដង កាត់ជើងគោទាំងឡាយក្នុងក្រោល ៧ ដង ដុតផ្ទះ ៧ ដង ចោរនោះមិនអាចធ្វើនូវការអាក់អន់ឲ្យរលត់បាន សូម្បីដោយទារុណកម្ម មានប្រមាណប៉ុណ្ណោះ ទើបធ្វើការជិតស្និទ្ធជាមួយអ្នកបម្រើរបស់សេដ្ឋីនោះ ហើយសួរថា អ្វីជាទីស្រឡាញ់របស់លោកសេដ្ឋីរបស់អ្នក បុរសនោះប្រាប់ថា បានឮថា វត្ថុជាស្រឡាញ់ក្រៃលែងរបស់សេដ្ឋី ក្រៅអំពីព្រះគន្ធកុដិមិនមាន ទើបគិតថា ណ្ហើយចុះ អញនឹងដុតព្រះគន្ធកុដិ ញុំាងការខឹងក្រោធឲ្យរលត់ ។ កាលព្រះសាស្តាចូលទៅបិណ្ឌបាត ទើបវាយក្អមទឹកសម្រាប់ផឹក និងសម្រាប់ប្រើប្រាស់ បានដុតព្រះគន្ធកុដិហើយ ។

សេដ្ឋីបានឮថា ព្រះគន្ធកុដិត្រូវភ្លើងឆេះ ដើរមកក្នុងកាលដែលព្រះគន្ធកុដិត្រូវភ្លើងឆេះហើយទើបមកដល់ សម្លឹងព្រះគន្ធកុដិដែលត្រូវភ្លើងឆេះ មិនបានធ្វើការអាក់អន់សូម្បីប៉ុនចុងរោមទ្រាយ លើកដៃខាងឆ្វេង ទះដៃខាងស្តាំយ៉ាងខ្លាំង ។ ខណៈនោះ មហាជនដែលឈរក្នុងទីជិតសួរលោកសេដ្ឋីថា បពិត្រលោកសេដ្ឋី ព្រោះហេតុអ្វី ទើបលោកទះដៃក្នុងកាលដែលព្រះគន្ធកុដិ ដែលលះទ្រព្យប្រមាណប៉ុណ្ណោះសាងត្រូវភ្លើងឆេះ ។ សេដ្ឋីឆ្លើយថា អ្នកទាំងឡាយខ្ញុំធ្វើកម្មប្រមាណប៉ុណ្ណោះ ឈ្មោះថា បានកប់ទ្រព្យក្នុងព្រះសាសនា ដែលមិនសាធារណៈដល់អន្តរាយ មានភ្លើងជាដើម ទើបខ្ញុំមានចិត្តត្រេកអរ ទះដៃដោយគិតថា អញនឹងបានចំណាយទ្រព្យប្រមាណប៉ុណ្ណោះ សាងព្រះគន្ធកុដិថ្វាយព្រះសាស្តាទៀត ។

លោកសេដ្ឋីលះទ្រព្យប្រមាណប៉ុណ្ណោះ សាងព្រះគន្ធកុដិទៀត បានថ្វាយដល់ព្រះសាស្តា ដែលមានភិក្ខុ ២ ម៉ឺនរូបជាបរិវារ ។ ចោរឃើញកិរិយានោះហើយគិតថា អញមិនសម្លាប់សេដ្ឋីនេះ នឹងមិនអាចធ្វើឲ្យបាត់ខ្មាសអៀនបានឡើយចុះ អញនឹងសម្លាប់វាចោល ដូច្នេះហើយ ទើបសៀតកាំបិតស្នៀតក្នុងសំពត់ស្លៀក ដើរវេរវង់ក្នុងវិហារអស់ ៧ ថ្ងៃ ក៏មិនបានឱកាស ។

ចំណែកមហាសេដ្ឋី ថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ ថ្វាយបង្គំព្រះសាស្តាហើយក្រាបទូលថា បពិត្រព្រះអង្គ បុរសម្នាក់ដុតស្រែខ្ញុំព្រះអង្គអស់ ៧ ដង កាត់ជើងគោក្នុងក្រោលអស់ ៧ ដង ដុតផ្ទះ ៧ ដង ឥឡូវនេះ សូម្បីព្រះគន្ធកុដិ ប្រហែលជាបុរសនោះឯងដុត ខ្ញុំព្រះអង្គសូមឲ្យចំណែកបុណ្យក្នុងទាននេះ ដល់បុរសនោះមុនគេ ។

ចោរបានឮពាក្យនោះ មានការក្តៅក្រហាយកើតឡើងថា អញធ្វើកម្មធ្ងន់ហ្ន៎ កាលបើយ៉ាងនោះ បុរសនេះក៏មិនមានត្រឹមតែការអាក់អន់ក្នុងអញដែលធ្វើខុស ឲ្យចំណែកបុណ្យក្នុងទាននេះដល់អញមុនទៀតផង អញប្រទូស្តក្នុងបុរសនេះមិនគួរឡើយ ទេវទណ្ឌគប្បីធ្លាក់លើអំបែងក្បាលរបស់អញ ដែលមិនឲ្យបុរសបែបនេះអត់ទោសឲ្យ ដូច្នេះហើយ ទើបទៅក្រាបចុះទៀបបាតជើងរបស់សេដ្ឋីពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់មេត្តាអត់ទោសដល់ខ្ញុំចុះ កាលសេដ្ឋីពោលថា មានរឿងអ្វី ទើបប្រាប់ថា ខ្ញុំបានធ្វើកម្មប្រមាណប៉ុណ្ណោះ សូមលោកម្ចាស់អត់ទោសនោះដល់ខ្ញុំចុះ ។

ពេលនោះ សេដ្ឋីសួរកម្មគ្រប់យ៉ាងថា អ្នកធ្វើកម្មនេះផងៗ ប្រមាណ

ប៉ុណ្ណោះដល់ខ្ញុំឬ កាលចោរសារភាពថា បាទ ខ្ញុំធ្វើ ទើបសួរថា ខ្ញុំមិនធ្លាប់ឃើញអ្នកឡើយ ហេតុអ្វី ទើបខឹងក្រោធ បានធ្វើយ៉ាងនោះដល់ខ្ញុំ ។

ចោរនោះដាស់តឿនឲ្យសេដ្ឋីរឭកដល់ពាក្យ ដែលគាត់ចេញអំពីព្រះនគរក្នុងថ្ងៃមួយពោលហើយ បានប្រាប់ថា ខ្ញុំកើតនូវការអាក់អន់ព្រោះហេតុនេះ ។

សេដ្ឋីរឭកដល់ការៈនៃពាក្យដែលខ្លួនពោលបានហើយ ឲ្យចោរអត់ទោសឲ្យដោយពាក្យថា អើបាខ្ញុំពោលពិត សូមបាអត់ទោសដល់ខ្ញុំចុះ ហើយពោលថា ក្រោកឡើងចុះ ខ្ញុំអត់ទោសឲ្យដល់អ្នក ចូរអ្នកទៅចុះ ចោរពោលថា បពិត្រលោកម្ចាស់ បើលោកម្ចាស់អត់ទោសដល់ខ្ញុំសោត សូមធ្វើខ្ញុំ មួយអន្លើដោយកូនប្រពន្ធឲ្យជាទាសៈក្នុងផ្ទះរបស់លោកម្ចាស់ចុះ សេដ្ឋីពោលថា នែបា កាលខ្ញុំពោលពាក្យមានប្រមាណប៉ុណ្ណោះ អ្នកក៏បានធ្វើការកាត់បែបនេះ ខ្ញុំមិនអាចពោលពាក្យណាមួយជាមួយអ្នកដែលនៅក្នុងផ្ទះបានឡើយ ។ ខ្ញុំមិនមានកិច្ចទាក់ទងដោយអ្នកនៅក្នុងផ្ទះ ខ្ញុំអត់ទោសឲ្យដល់អ្នក ចូរអ្នកទៅចុះ ។

កាលចោរធ្វើកម្មនោះហើយ ក្នុងកាលអស់អាយុ កើតឡើងហើយក្នុងអវិចី ឆេះក្នុងអវិចីអស់កាលយូរ ក្នុងកាលឥឡូវនេះ កើតជាអជគរប្រេតត្រូវភ្លើងឆេះត្រង់ភ្នំគិជ្ឈកូដ ដោយវិបាកនៃកម្មដែលសេសសល់ ។

ព្រះសាស្តា កាលត្រាស់បុព្វកម្មរបស់ប្រេតនោះ យ៉ាងនេះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាបុគ្គលពាលធ្វើកម្មដ៏លាមក រមែងមិនដឹង តែខាងក្រោយក្តៅក្រហាយ ព្រោះកម្មដែលខ្លួនធ្វើហើយ រមែងដូចគ្នានឹងភ្លើងឆេះព្រៃ ដោយខ្លួនរបស់ខ្លួនឯង ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិ

សម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**អថ បាបានិ កម្មានិ ករំ ពាលោ ន ពុជ្ឈតិ**
**សេហិ កម្មេហិ ទុម្មេធោ អគ្គិទឌ្ឍោវ តប្បតិ ។**

បុគ្គលមិនមានប្រាជ្ញា កាលធ្វើអំពើអាក្រក់ រមែងមិនភ្ញាក់ខ្លួន លុះកាលជាខាងក្រោយ ទើបក្តៅក្រហាយដោយសារកម្មរបស់ខ្លួន ដូចត្រូវភ្លើងឆេះ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អថ បាបានិ** សេចក្តីថា បុគ្គលពាលមិនមែនធ្វើបាបទាំងឡាយ ដោយអំណាចនៃសេចក្តីក្រោធតែម្យ៉ាងប៉ុណ្ណោះឡើយ ។ សូម្បីធ្វើ ក៏មិនដឹង តែកាលធ្វើបាប ឈ្មោះថា មិនដឹងថា អញធ្វើបាប រមែងមិនមាន ។

ព្រះដ៏មានព្រះភាគត្រាស់ថា រមែងមិនដឹង ព្រោះការមិនដឹងថា ផលរបស់កម្មនេះ មានឈ្មោះបែបនេះ ។

បទថា **សេហិ** សេចក្តីថា ព្រោះកម្មដែលជារបស់ខ្លួនទាំងនោះ ។

បទថា **ទុម្មេធោ** សេចក្តីថា បុគ្គលអ្នកមានបញ្ញាថោកថយ កើតក្នុងនរក រមែងក្តៅក្រហាយ ដូចត្រូវភ្លើងឆេះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។ល។

**រឿង អជគរប្រេត ចប់**

# រឿង ព្រះមហាមោគ្គល្លានត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រះមហាមោគ្គ-ល្លានត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **យោ ទណ្ឌេន អទណ្ឌេសុ** ជាដើម ។

សេចក្តីពិស្តារថា ក្នុងសម័យមួយ ពួកតិរ្ថិយប្រជុំគ្នា គិតថា អាវុសោ លោកទាំងឡាយជ្រាបឬ ហេតុអ្វីទើបលាភសក្ការៈកើតឡើងជាច្រើនដល់ព្រះសមណគោតម តិរ្ថិយម្នាក់ពោលថា ពួកខ្ញុំមិនដឹង ចំណែកពួកលោកដឹងឬ តិរ្ថិយដែលដឹងរឿង ក៏នាំគ្នាឆ្លើយថា ពួកខ្ញុំដឹង លាភសក្ការៈកើតឡើង ព្រោះអាស្រ័យព្រះថេរៈមួយរូប ឈ្មោះមហាមោគ្គល្លាន ព្រោះព្រះថេរៈនោះទៅទេវ-លោក សួរកម្មដែលពួកទេវតាធ្វើហើយ ត្រឡប់មកប្រាប់ពួកមនុស្សថា ទេវតាធ្វើកម្មឈ្មោះនេះ រមែងបានសម្បត្តិបែបនេះ សូម្បីទៅនរក ក៏សួរកម្មរបស់ពួកសត្វដែលកើតក្នុងនរកហើយ ត្រឡប់មកប្រាប់ពួកមនុស្សថា ពួកនេរយិក-សត្វធ្វើកម្មឈ្មោះនេះ រមែងសោយទុក្ខបែបនេះ ពួកមនុស្សបានស្តាប់ពាក្យព្រះថេរៈនោះហើយ រមែងនាំលាភសក្ការៈជាច្រើនទៅប្រគេន ។ បើពួកយើងអាចសម្លាប់ព្រះថេរៈនោះបានសោត លាភសក្ការៈនោះនឹងកើតឡើងដល់ពួកយើង ។

តិរ្ថិយទាំងនោះទទួលថា ឧបាយនេះប្រើបាន ជនទាំងអស់ជាអ្នកមានឆន្ទៈតែមួយសម្រេចថា ពួកយើងនឹងធ្វើកម្មណាមួយ សម្លាប់ព្រះថេរៈនោះចោល ដូច្នេះហើយ បបួលឧបដ្ឋាករបស់ខ្លួនបានទ្រព្យ ១ ពាន់កហាបណៈ ឲ្យហៅ

ពួកចោរអ្នកត្រាច់ធ្វើកម្ម គឺសម្លាប់ មកហើយ ប្រាប់ថា ព្រះថេរៈឈ្មោះមហាមោគ្គល្លាន នៅត្រង់កាឡសិលា ចូរពួកអ្នកទៅក្នុងទីនោះហើយ សម្លាប់ព្រះថេរៈនោះ ដូច្នេះហើយ ក៏បានឲ្យកហាបណៈដល់ពួកចោរ ។

ពួកចោរទទួលពាក្យ ព្រោះចំណង់ក្នុងទ្រព្យ តាំងចិត្តថា ពួកយើងនឹងសម្លាប់ព្រះថេរៈ ដូច្នេះហើយ បានព័ទ្ធលំនៅរបស់ព្រះមហាមោគ្គល្លានត្ថេរ ។

ព្រះថេរៈជ្រាបភាពដែលខ្លួនត្រូវពួកចោរទាំងនោះ ព័ទ្ធចាប់ហើយ ទើបចេញតាមប្រហោងសោចៀសចេញទៅ ។ ក្នុងថ្ងៃនោះ ពួកចោរមិនឃើញព្រះថេរៈ ស្អែកឡើងទើបទៅព័ទ្ធទៀត ។ ព្រះថេរៈជ្រាបហើយ ក៏ទម្លាយមណ្ឌលហោជាង ហោះទៅកាន់អាកាស កាលបើដូច្នេះ ក្នុងខែដំបូងក្តី ខែកណ្តាលក្តី ពួកតិរ្ថិយនោះក៏មិនអាចចាប់ព្រះថេរៈបាន លុះដល់ខែចុងក្រោយ ព្រះថេរៈជ្រាបករៈ គឺការទាញមកនៃកម្មដែលខ្លួនបានធ្វើហើយ ទើបមិនបានគេច ។

ពួកចោរចាប់ព្រះថេរៈបានហើយ វាយរហូតឆ្អឹងទាំងឡាយរបស់ព្រះថេរៈបែកជាបំណែកតូចៗ ប៉ុនគ្រាប់អង្ករដែលបាក់ ពេលនោះ ពួកចោរបោះលោកទៅកាន់គុម្ពឈើមួយកន្លែង ដោយសម្គាល់ថាស្លាប់ហើយ ក៏ចៀសចេញទៅ ។

ព្រះថេរៈគិតថា អញគាល់ព្រះសាស្តាសិនសឹមបរិនិព្វាន ដូច្នេះហើយ ទើបសមោធានអត្តភាពដោយឈាន គឺឲ្យមាំទាំហើយ ទៅកាន់សម្នាក់ព្រះសាស្តាតាមអាកាស ថ្វាយបង្គំព្រះសាស្តាហើយក្រាបទូលថា បពិត្រព្រះអង្គខ្ញុំព្រះអង្គនឹងបរិនិព្វាន ព្រះសាស្តាត្រាស់ថា ម្នាលមោគ្គល្លាន អ្នកនឹងបរិនិព្វានឬ ព្រះថេរៈទូលថា ករុណាព្រះអង្គ ព្រះសាស្តាត្រាស់សួរថា អ្នកនឹង

បរិនិព្វានក្នុងទីណា ព្រះថេរៈទូលថា ខ្ញុំព្រះអង្គនឹងទៅកាន់ទីឈ្មោះកាឡសិលា ហើយបរិនិព្វាន ព្រះសាស្តាត្រាស់ថា ម្នាលមោគ្គល្លាន បើដូច្នេះ ចូរអ្នកសម្តែងធម៌ដល់តថាគត ហើយសឹមទៅ ព្រោះឥឡូវនេះ តថាគតលែងបានឃើញសាវកដូចអ្នកទៀតហើយ ។

ព្រះថេរៈក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងធ្វើយ៉ាងនោះ ដូច្នេះ ថ្វាយបង្គំព្រះសាស្តា ហោះឡើងទៅកាន់អាកាស សម្តែងឫទ្ធិមានប្រការផ្សេងៗ ដូចព្រះសារីបុត្តសម្តែងឫទ្ធិក្នុងថ្ងៃបរិនិព្វាន ហើយសម្តែងធម៌ ថ្វាយបង្គំព្រះសាស្តា ទៅកាន់ព្រៃក្បែរកាឡសិលាបទេស បរិនិព្វានហើយ ។

ពាក្យល្បីខ្ចរខ្ចាយថា បានឮថា ពួកចោរបានសម្លាប់ព្រះថេរៈហើយ ដូច្នេះ បានឮសុះសាយទៅពេញជម្ពូទ្វីប ។ ព្រះបាទអជាសត្រូវ ទ្រង់រៀបចំចារបុរសទៅ ដើម្បីស៊ើបអង្កេតពួកចោរ កាលពួកចោរទាំងនោះកំពុងផឹកស្រាក្នុងរោងស្រា ចោរម្នាក់កែងខ្នងចោរម្នាក់ឲ្យដួលចុះ ចោរដែលដួលនោះគំហកចោរនោះ ហើយនិយាយថា វ៉ឺយ អាក្បាលរឹង ហេតុអ្វី ទើបអាវាយខ្នងអញ ចោរម្នាក់ពោលថា វ៉ឺយ អាចោរកាច ព្រះមោគ្គល្លាន អាជាអ្នកដៃដល់មុនឬ ចោរនោះពោលថា ឯងមិនដឹងថា ព្រះមោគ្គល្លាន ត្រូវអញវាយទេឬ ។

កាលពួកចោរទាំងនោះ នាំគ្នាអួតក្អេងក្អាងថា ព្រះមោគ្គល្លានខ្លួនជាអ្នកវាយហើយ ។ ចារបុរសទាំងនោះបានឮហើយ ទើបចាប់ចោរទាំងនោះចងទាំងអស់ហើយ ក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាទ្រង់ត្រាស់ឲ្យហៅពួកចោរមក

ហើយសួរថា ពួកឯងសម្លាប់ព្រះថេរៈឬ ពួកចោរទូលថា យ៉ាងនោះឯងព្រះអង្គ ព្រះរាជាត្រាស់ថា អ្នកណាឲ្យពួកអ្នកធ្វើ ចោរទូលថា ពួកសមណៈអាក្រាតព្រះអង្គ ។

ព្រះរាជាទ្រង់ឲ្យចាប់សមណៈអាក្រាតប្រមាណ ៥០០ កប់ក្នុងរណ្តៅប្រមាណត្រឹមផ្ចិត ត្រង់លានព្រះរាជវាំង ប្រមូលចោរ ៥០០ លុបដោយចំបើងហើយដុត ។ កាលទ្រង់ជ្រាបថា ជនទាំងនោះត្រូវភ្លើងឆេះហើយ ទើបបញ្ជាឲ្យភ្ជួរដោយនង្គ័លដែក ធ្វើជនទាំងអស់ឲ្យជាកំណាត់តូចកំណាត់ធំ ហើយឲ្យដោតចោរ ៤ នាក់ដោយលំពែង ។

ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងរោងធម្មសភាថា គួរសង្វេគហ្ន៎ ព្រះមហាមោគ្គល្លានមរណភាពមិនសមគួរដល់ខ្លួន ។ ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយកថាដូចម្តេចហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ ដោយកថាឈ្មោះនេះ ដូច្នេះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានមរណភាពមិនសមគួរដល់អត្តភាពនេះប៉ុណ្ណោះ តែមោគ្គល្លានដល់នូវមរណភាពសមគួរដល់កម្មដែលធ្វើក្នុងកាលមុន ។ កាលភិក្ខុទាំងឡាយទូលសួរថា បពិត្រព្រះអង្គបុព្វកម្មរបស់លោកដូចម្តេច ទើបទ្រង់ត្រាស់អតីតនិទានយ៉ាងពិស្តារ ដូចតទៅនេះ ។

បានឮមកថា ក្នុងអតីតកាល កុលបុត្រម្នាក់ជាអ្នកក្រុងពារាណសី ធ្វើកិច្ចផ្សេងៗ មានបុកអង្ករ និងដាំបាយជាដើម ដោយខ្លួនឯង ប្រតិបត្តិមាតា

បិតា ។ តមក មាតាបិតានិយាយនឹងកុលបុត្រនោះថា នែបា បាម្នាក់ឯង ប៉ុណ្ណោះធ្វើការទាំងក្នុងផ្ទះ ទាំងក្នុងព្រៃ រមែងលំបាក ពុកម៉ែនឹងនាំស្រីក្រមុំម្នាក់មកឲ្យដល់កូន កុលបុត្រនោះហាមថា ខ្ញុំមិនត្រូវការប្រពន្ធឡើយ ខ្ញុំនឹងទំនុកបម្រុងលោកទាំងពីរដោយដៃខ្ញុំឯង ដរាបណាលោកទាំងពីរនៅមានជីវិត ក៏អង្វរកូនរឿយៗ ហើយ នាំទារិកាមក ។

ស្រីនោះទំនុកបម្រុងឪពុកក្មេក ម្ដាយក្មេកបានត្រឹម ២-៣ ថ្ងៃប៉ុណ្ណោះ ក្រោយមកមិនចង់ឃើញលោកទាំងពីរនោះឡើយ ទើបប្រាប់ស្វាមីថា ខ្ញុំមិនអាចនៅក្នុងទីជាមួយឪពុកម្ដាយរបស់អ្នកបានទេ ដូច្នេះហើយ តិះដៀលដោយប្រការផ្សេងៗ កាលប្ដីនោះមិនជឿពាក្យរបស់ខ្លួន ក្នុងពេលប្ដីចេញទៅក្រៅ កាន់យកសម្បកផ្ចិត ធ្នឹងផ្ចិត និងពពុះបបររោយរាយក្នុងទីនោះៗ ឲ្យស្មោកគ្រោក ប្ដីមកហើយសួរថា នេះជាអ្វី ក៏ប្រាប់ថា នេះជាកម្មរបស់មនុស្សចាស់ខ្វាក់ភ្នែកទាំងនេះ មនុស្សចាស់ទាំងពីរធ្វើផ្ទះគ្រប់កន្លែងឲ្យស្មោកគ្រោក ខ្ញុំមិនអាចនៅជាមួយមនុស្សចាស់ទាំងពីរនោះបានទេ ។

កាលស្រីនោះរំអុកយ៉ាងនោះ សត្វដែលមានបារមីបានបំពេញហើយបែបនោះ ក៏បែកអំពីមាតាបិតាបាន គាត់ពោលថា ណ្ហើយចុះ ខ្ញុំនឹងដឹងកម្មដែលគួរធ្វើដល់លោកទាំងពីរ ដូច្នេះហើយ ឲ្យមាតាបិតាបរិភោគហើយ បបួលថា បពិត្រលោកឪពុកអ្នកម្ដាយ ពួកញាតិក្នុងទីឈ្មោះនោះ ទន្ទឹងការមករបស់លោកទាំងពីរ ខ្ញុំនឹងនាំលោកទៅក្នុងទីនោះ ដូច្នេះហើយ ឲ្យលោកទាំងពីរឡើងយានតូច ហើយបរទៅ ក្នុងកាលដល់កណ្ដាលព្រៃ ក៏បញ្ឆោតថា សូម

លោកឪពុកកាន់ខ្សែ គោទាំងពីរនឹងទៅដោយសញ្ញានៃជន្ទញ ក្នុងទីនេះ ពួកចោរចាំស្កាត់ ខ្ញុំនឹងចុះទៅ ដូច្នេះហើយ ដាក់ខ្សែក្នុងដៃរបស់ឪពុក ចុះទៅហើយ បានក្លែងសំឡេង ធ្វើឲ្យដូចសំឡេងពួកចោរ ។

មាតាបិតាបានឮសំឡេងនោះដោយសម្គាល់ថា ពួកចោរ ទើបពោលថា ឱកូន ពុក និងម៉ែចាស់ហើយ ចូរកូនរក្សាខ្លួនឲ្យផុតភ័យចុះ ។ កុលបុត្រធ្វើសំឡេងដូចចោរ វាយមាតាបិតាដែលកំពុងស្រែកយ៉ាងនោះ ឲ្យស្លាប់ហើយបោះចោលក្នុងព្រៃហើយត្រឡប់ទៅ ។

ព្រះសាស្តាកាលត្រាស់បុព្វកម្មនេះរបស់ព្រះមហាមោគ្គល្លាននោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានធ្វើកម្មប្រមាណប៉ុណ្ណោះ ឆេះក្នុងនរកច្រើនសែនឆ្នាំ ដោយសេសសល់ផលកម្ម ទើបត្រូវវាយយ៉ាងនោះឯង ល្អិតខ្ទិចខ្ទីដល់នូវការស្លាប់អស់មួយរយអត្តភាព មោគ្គល្លានបានមរណៈយ៉ាងនេះក៏សមគួរដល់កម្មរបស់ខ្លួនពិត ។ ពួកតិរ្ថិយ ៥០០ និងចោរ ៥០០ ប្រទូស្តចំពោះបុត្រតថាគត ដែលមិនប្រទូស្តក៏បានស្លាប់ សមគួរដល់កម្មរបស់ខ្លួនដូចគ្នា ព្រោះថា បុគ្គលដែលប្រទូស្តចំពោះបុគ្គលដែលមិនប្រទូស្ត រមែងដល់នូវការវិនាសដោយហេតុ ១០ ប្រការពិត ដូច្នេះហើយ កាលនឹងបន្តអនុសន្ធិសម្តែងធម៌ ទើបបានភាសិតព្រះគាថាទាំងនេះថា

**យោ ទណ្ឌេន អទណ្ឌេសុ អប្បទុដ្ឋេសុ ទុស្សតិ**
**ទសន្នមញ្ញតរំ ឋានំ ខិប្បមេវ និគច្ឆតិ**
**វេទនំ ផរុសំ ជានឹ សរីរស្ស ច ភេទនំ**

**គរុកំ វាបិ អាពាធំ ចិត្តក្ខេបំ វ បាបុណេ**

**រាជតោ វា ឧបសគ្គំ អព្ភក្ខានំ វ ទារុណំ**

**បរិក្ខយំ វ ញាតីនំ ភោគានំ វ បភង្គុណំ**

**អថវស្ស អគារានិ អគ្គិ ឌហាតិ បាវកោ**

**កាយស្ស ភេទា ទុប្បញ្ញោ និរយំ សោ ឧបបជ្ជតិ ។**

*បុគ្គលណាប្រទូស្តដោយអាជ្ញា ចំពោះបុគ្គលទាំងឡាយ ដែលមិនមានអាជ្ញា មិនប្រទូស្ត បុគ្គលនោះ រមែងដល់នូវហេតុនៃសេចក្តីទុក្ខណាមួយ ក្នុងហេតុ ១០ យ៉ាង ដោយទាន់ហន់ គឺគប្បីដល់នូវវេទនាដ៏អាក្រក់ ១ សេចក្តីវិនាសទ្រព្យ ១ បែកធ្លាយសរីរៈ ១ អាពាធជាទម្ងន់ ១ ក្រឡកចិត្ត ( ឆ្កួត ) ១ រឹបជាន់អំពីស្តេច ១ ពោលពាក្យបង្កាច់ដ៏អាក្រក់ ១ អស់ពួកញាតិរលីង ១ ពុកផុយភោគសម្បត្តិទាំងឡាយ ១ ភ្លើងនឹងឆេះបំផ្លាញនូវផ្ទះរបស់បុគ្គលនោះ ១ បុគ្គលមិនមានប្រាជ្ញានោះ លុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងនរក ។*

## សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ បទថា* **អទណ្ឌេសុ** *សេចក្តីថា ក្នុងព្រះខីណាស្រពទាំងឡាយ ដែលវៀរចាកអាជ្ញា មានកាយអាជ្ញាជាដើម ។*

*បទថា* **អប្បទុដ្ឋេសុ** *សេចក្តីថា បុគ្គលមិនមានការខុសក្នុងជនដទៃ ឬក្នុងខ្លួន ។*

បាទព្រះគាថាថា **ទសន្នមញ្ញតរំ ឋានំ** សេចក្តីថា ក្នុងហេតុនៃទុក្ខ ១០ យ៉ាង នូវហេតុណាមួយ ។

បទថា **វេទនំ** បានដល់ វេទនាដ៏ខ្លាំងក្លា មានរោគក្នុងក្បាលជាដើម ។

បទថា **ជានឹ** បានដល់ ការវិនាសទ្រព្យ ដែលបានដោយលំបាក ។

បទថា **ភេទនំ** បានដល់ ការបែកធ្លាយនៃសរីរៈ មានការកាត់ដៃជាដើម ។

បទថា **គរុកំ** បានដល់ អាពាធធ្ងន់ដោយរោគ មានរោគស្លាប់មួយចំហៀងខ្លួន ពិការបក្ខុម្ខាង រោគស្លាប់ដៃជើង ខ្វិន និងរោគឃ្លង់ជាដើម ។

បទថា **ចិត្តក្ខេបំ** បានដល់ ជាមនុស្សឆ្កួត ។

បទថា **ឧបសគ្គំ** បានដល់ មានការរារាំងអំពីព្រះរាជាជាដើមថា ចូរដកតំណែងសេនាបតីជាដើម ។

បទថា **អព្ភក្ខានំ** សេចក្តីថា កាលត្រូវពោលចោទយ៉ាងខ្លាំងក្លាបែបនេះថា កម្ម មានការកាត់ទីតជាដើមនេះក្តី កម្ម គឺការប្រព្រឹត្តខុសក្នុងព្រះរាជានេះក្តី អ្នកធ្វើហើយដែលខ្លួនមិនធ្លាប់ឃើញ មិនធ្លាប់បានឮ និងមិនធ្លាប់គិតឡើយ ។

បាទព្រះគាថាថា **បរិក្ខយំ វ ញាតីនំ** បានដល់ ការវិនាសនៃពួកញាតិដែលអាចជាទីពឹងពំនាក់របស់ខ្លួន ។

បទថា **បភង្គុណំ** គឺសេចក្តីវិនាស បានដល់ ការពុកផុយទៅ ឯស្រូវក្នុងជង្រុករបស់បុគ្គលនោះ រមែងដល់នូវការពុកផុយ ។ មាសដល់នូវភាពជាធ្យូង កែវមុក្តាដល់នូវភាពជាគ្រាប់កប្បាស កហាបណៈដល់នូវភាពជាអំបែងជាដើម ។ សត្វជើងពីរ ជើងបួន ដល់នូវភាពជាសត្វខ្វាក់ខ្នែកជាដើម ។

ពីរបទថា **អគ្គិ ឌហតិ** សេចក្ដីថា ក្នុងមួយឆ្នាំ កាលភ្លើងដទៃមិនមានភ្លើង គឺរន្ទះរមែងធ្លាក់ចុះដុតបំផ្លាញ ២-៣ ដង គឺភ្លើងព្រៃតាំងឡើងតាមធម្មតារបស់វា រមែងឆេះ ។

បទថា **និរយំ** ជាដើម សេចក្ដីថា ព្រះដ៏មានព្រះភាគត្រាស់ថា បុគ្គលនោះរមែងចូលដល់នរក ក៏ដើម្បីសម្ដែងឋានៈ ដែលការកបុគ្គលដល់នូវឋានៈ ១០ យ៉ាង ណាមួយក្នុងបច្ចុប្បន្ននេះហើយ ក៏គប្បីដល់ក្នុងសម្បរាយកពដូចគ្នា ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

រឿង ព្រះមហាមោគ្គល្លានត្ថេរ ចប់

# រឿង ភិក្ខុមានភណ្ឌៈច្រើន

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុមានភណ្ឌៈច្រើន ត្រាស់ព្រះធម្មទេសនានេះថា **ន នគ្គចរិយា** ជាដើម ។

បានឮថា កុដុម្ពិកៈអ្នកក្រុងសាវត្ថីម្នាក់ មានប្រពន្ធស្លាប់ហើយទើបបួស ។ កាលគាត់បួស ឲ្យគេសាងបរិវេណ រោងភ្លើង ឃ្លាំងដាក់ភណ្ឌៈដើម្បីខ្លួន ដាក់ភណ្ឌៈពេញបន្ទប់ទាំងអស់ដោយវត្ថុទាំងឡាយ មានសប្បិ និងប្រេងជាដើម

ហើយទើបបួស ។ កាលបួសហើយ ឲ្យហៅពួកទាសៈរបស់ខ្លួនមកចម្អិនអាហារ តាមដែលគាប់ចិត្តហើយបរិភោគ ។ បានជាអ្នកមានភណ្ឌៈច្រើន និងមានបរិក្ខារច្រើន សំពត់ស្លៀក សំពត់ដណ្តប់ក្នុងរាត្រីមួយសម្រាប់ក្នុងពេលថ្ងៃមួយសម្រាប់ នៅត្រង់ចុងវិហារ ។

ថ្ងៃមួយ កាលភិក្ខុនោះហាលចីវរ និងកម្រាលសិងរបស់ខ្លួន ភិក្ខុទាំងឡាយ ត្រាច់ចារិកទៅតាមសេនាសនៈ ឃើញហើយសួរថា អាវុសោ ចីវរ និងកម្រាលដេកនេះ ជារបស់អ្នកណា កាលភិក្ខុនោះឆ្លើយថា របស់ខ្ញុំ ដូច្នេះហើយ ទើបពោលថា អាវុសោ ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតចីវរត្រឹមតែ ៣ ឯលោក បួសក្នុងសាសនារបស់ព្រះសាស្តា ដែលជាអ្នកមានសេចក្តីប្រាថ្នាតិចយ៉ាងនេះ ហេតុអ្វីទើបជាអ្នកមានបរិក្ខារច្រើនយ៉ាងនេះ ដូច្នេះហើយ បាននាំភិក្ខុនោះទៅកាន់សម្នាក់ព្រះសាស្តាក្រាបទូលថា បពិត្រព្រះអង្គ ភិក្ខុរូបនេះជាអ្នកមានភណ្ឌៈច្រើនពន់ពេក ។ ព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា សេចក្តីនេះយ៉ាងនោះឬ កាលភិក្ខុនោះក្រាបទូលថា ករុណាព្រះអង្គ ទើបត្រាស់ថា ម្នាលភិក្ខុ ហេតុអ្វីអ្នកកាលតថាគតសម្តែងធម៌ដើម្បីភាពជាបុគ្គលមានសេចក្តីប្រាថ្នាតិចហើយ បែរជាអ្នកមានភណ្ឌៈច្រើនយ៉ាងនេះទៅវិញ ។

ភិក្ខុនោះក្រោធហើយ ដោយហេតុត្រឹមប៉ុណ្ណោះឯង គិតថា ឥឡូវនេះ អញនឹងដើរទៅដោយទំនងនេះ ដូច្នេះហើយ ដោះសំពត់ដណ្តប់ មានចីវរមួយគឺស្បង់ បានឈរត្រង់កណ្តាលបរិស័ទ ។ គ្រានោះ ព្រះសាស្តា កាលទ្រង់

អបស្សុបភិក្ខុនោះ ទើបត្រាស់ថា ម្នាលភិក្ខុ ក្នុងកាលមុនអ្នកស្វែងរកហិរិ និងឱត្តប្បៈ ក្នុងកាលជាអារក្សទឹក ក៏ស្វែងរកហិរិឱត្តប្បៈអស់ ១២ ឆ្នាំមិនមែនឬ តែឥឡូវនេះ អ្នកបួសក្នុងព្រះពុទ្ធសាសនា ដ៏គួរគោរពយ៉ាងនេះហើយ ដោះសំពត់ដណ្ដប់ លះបង់នូវហិរិ និងឱត្តប្បៈឈរត្រង់កណ្ដាលបរិស័ទ ៤ ព្រោះហេតុអ្វី ។

ភិក្ខុនោះបានស្ដាប់ព្រះតម្រាស់របស់ព្រះសាស្ដាហើយ បាននូវហិរិឱត្តប្បៈ ដណ្ដប់ចីវរនោះ ថ្វាយបង្គំព្រះសាស្ដាហើយ អង្គុយក្នុងទីសមគួរ នាចំណែកម្ខាង ។ ភិក្ខុទាំងឡាយទូលអារាធនាព្រះសាស្ដា ដើម្បីឲ្យទ្រង់ប្រកាសសេចក្ដីនោះ ទើបព្រះដ៏មានព្រះភាគ នាំអតីតនិទានមកត្រាស់ ដូច្នេះ ។

បានឮថា ក្នុងអតីតកាល ព្រះពោធិសត្វបដិសន្ធិក្នុងព្រះគភ៌របស់ព្រះអគ្គមហេសីព្រះបាទពារាណសី ក្នុងថ្ងៃដាក់ឈ្មោះ ជនទាំងឡាយបានថ្វាយព្រះនាមរបស់ព្រះអង្គថា មហិសាសកុមារ ។ ព្រះកនិដ្ឋភាតា គឺប្អូនប្រុសរបស់ព្រះអង្គមានឈ្មោះថាចន្ទកុមារ កាលព្រះជននីនៃព្រះរាជកុមារទាំងពីរនោះអស់ព្រះជន្មហើយ ព្រះរាជាទ្រង់ស្ថាបនាស្ត្រីដទៃទុកក្នុងតំណែងជាអគ្គមហេសី ។

ព្រះនាងប្រសូតព្រះឱរសមួយអង្គ ។ ជនទាំងឡាយថ្វាយព្រះនាមរបស់ឱរសនោះថា សុរិយកុមារ ។ ព្រះរាជាទតឃើញសុរិយកុមារនោះហើយ ទ្រង់ពេញព្រះហឫទ័យប្រទានពរថា យើងឲ្យពរដល់បុត្ររបស់នាង ។ ឯព្រះទេវីនោះឯងក្រាបទូលថា ខ្ញុំម្ចាស់នឹងទទួលយកក្នុងពេលដែលត្រូវការ ដូច្នេះហើយ

ក្នុងកាលដែលព្រះរាជឱរសចម្រើនវ័យហើយ ទើបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព ទ្រង់បានប្រទានពរហើយ ក្នុងកាលកូនរបស់ខ្ញុំម្ចាស់ប្រសូត សូមទ្រង់ព្រះរាជទានរាជសម្បត្តិដល់បុត្រខ្ញុំម្ចាស់ចុះ ។

ព្រះរាជាទ្រង់ឃាត់ថា កូនទាំងពីររបស់យើងកំពុងរុងរឿងដូចគំនរភ្លើងត្រាច់ទៅ យើងមិនអាចឲ្យរាជសម្បត្តិដល់សុរិយកុមារនោះបានទេ តែទ្រង់ឃើញព្រះនាងអង្វររឿយៗ ទើបព្រះតម្រិះថា ស្រីនេះធ្វើសេចក្តីវិនាសដល់កូនរបស់អញ ដូច្នេះហើយ ទើបត្រាស់ឲ្យហៅព្រះរាជឱរសទាំងពីរមកត្រាស់ថា បាទាំងពីរ បិតាបានឲ្យពរក្នុងកាលដែលសុរិយកុមារប្រសូត ឥឡូវនេះ មាតារបស់សុរិយកុមារទូលសូមរាជសម្បត្តិ បិតាមិនអាចមិនឲ្យដល់នាងឡើយ មាតារបស់សុរិយកុមារ ធ្វើនូវសេចក្តីវិនាសដល់បុត្រទាំងពីរ ចូរបាទៅនៅក្នុងព្រៃ ហើយសឹមត្រឡប់មកទទួលរាជសម្បត្តិ ក្នុងកាលដែលបិតាសោយទិវង្គតទៅ ដូច្នេះហើយ ទ្រង់បញ្ជូនទៅ ។

សុរិយកុមារលេងត្រង់លានព្រះរាជវាំង ឃើញព្រះរាជកុមារទាំងពីរនោះថ្វាយបង្គំព្រះបិតា ហើយចុះអំពីប្រាសាទ ជ្រាបហេតុនោះហើយ ទើបចេញទៅជាមួយព្រះរាជកុមារទាំងនោះដែរ ។ ក្នុងកាលដែលព្រះរាជកុមារនោះចូលទៅកាន់ហិមវន្តប្បទេស ព្រះពោធិសត្វយាងចេញអំពីផ្លូវ គង់ត្រង់ម្លប់ឈើមួយដើម ហើយត្រាស់នឹងសុរិយកុមារថា នែបា ចូរបាទៅកាន់ស្រះនោះងូតទឹក និងសោយទឹក ហើយយកស្លឹកឈូកនាំទឹកមកដើម្បីបងទាំងពីរផង ។ ស្រះនោះជាស្រះដែលអារក្សទឹកម្នាក់ បានអំពីសម្នាក់នៃស្តេចវេស្សវ័ណ ព្រះបាទ

វេស្សវ័ណ ត្រាស់នឹងអារក្សទឹកនោះថា វៀរតែជនដែលចេះទេវធម៌ប៉ុណ្ណោះ ជនដទៃដែលចុះក្នុងស្រះនេះ អ្នកគប្បីបានទំពាស៊ីនូវជនទាំងនោះ ។ តាំងអំពីនោះមក អារក្សទឹកនោះ សួរទេវធម៌នឹងបុគ្គលដែលចុះហើយកាន់ស្រះនោះ រមែងទំពាស៊ីបុគ្គលដែលមិនចេះ ។

ចំណែកសុរិយកុមារ មិនបានពិចារណាស្រះនោះចុះទៅ ត្រូវអារក្សទឹកនោះសួរថា អ្នកចេះទេវធម៌ឬ ក៏ឆ្លើយថា ព្រះចន្ទ និងព្រះអាទិត្យ ឈ្មោះថាទេវធម៌ ។ លំដាប់នោះ អារក្សទឹកពោលនឹងសុរិយកុមារនោះថា អ្នកមិនចេះទេវធម៌ ហើយក៏ទាញចុះក្នុងទឹក នាំទៅទុកក្នុងកពរបស់ខ្លួន ។ ចំណែកព្រះពោធិសត្វ ឃើញសុរិយកុមារនោះយឺតយូរ ទើបបញ្ជូនចន្ទកុមារទៅ ចន្ទកុមារនោះ ត្រូវអារក្សនោះសួរថា អ្នកចេះទេវធម៌ឬ ក៏ឆ្លើយថា ទិសទាំង ៤ ឈ្មោះថា ទេវធម៌ អារក្សក៏ទាញចន្ទកុមារនោះចុះទឹក ទៅទុកយ៉ាងនោះដូចគ្នា ។

ព្រះពោធិសត្វ កាលចន្ទកុមារនោះយឺតយូរ ទើបគិតថា អន្តរាយគប្បីមាន ដូច្នេះហើយ ទើបទៅឯង ឃើញស្នាមជើងចុះនៃកុមារទាំងពីរហើយ ក៏ដឹងថា ស្រះនេះមានអារក្សទឹករក្សា ទើបស៊កព្រះខ័ន កាន់ធ្នូឈរហើយ ។ អារក្សទឹកឃើញព្រះពោធិសត្វមិនចុះ ទើបកាឡាខ្លួនជាជ្មើរព្រៃមកពោលប្រាស្រ័យថា នៃបុរស អ្នកធ្វើដំណើរហត់នឿយ ហេតុអ្វី មិនចុះកាន់ស្រះនេះងូតទឹក ផឹកទឹក បរិភោគក្រអៅឈូក ប្រដាប់នូវផ្កាហើយ សឹមទៅ ។

ព្រះពោធិសត្វឃើញបុរសនោះជ្រាបបានថា បុរសនេះជាយក្ខ ទើបពោល

ថា អ្នកចាប់ប្អូនប្រុសទាំងពីររបស់ខ្ញុំឬ យក្ខពោលថា អើខ្ញុំចាប់ ព្រះពោធិ-សត្វពោលថា ចាប់ធ្វើអ្វី យក្ខពោលថា ខ្ញុំតែងបាន គឺទំពាស៊ីបុគ្គលដែលចុះកាន់ស្រះនេះ ព្រះពោធិសត្វសួរថា អ្នករមែងបានគ្រប់គ្នាឬ យក្ខពោលថា វៀរអ្នកចេះទេវធម៌ ជនដ៏សេសខ្ញុំរមែងបាន ព្រះពោធិសត្វពោលថា អ្នកត្រូវការដោយទេវធម៌ឬ យក្ខពោលថា ខ្ញុំត្រូវការ ព្រះពោធិសត្វពោលថា ខ្ញុំនឹងពោល យក្ខពោលថា បើដូច្នោះ ចូរអ្នកពោលចុះ ព្រះពោធិសត្វពោលថា ខ្ញុំមានខ្លួនកខ្វក់មិនអាចពោលបានទេ ។

យក្ខឲ្យព្រះពោធិសត្វងូតទឹក ឲ្យផឹកទឹកដែលគួរផឹក តាក់តែងកាយឡើងកាន់បល្ល័ង្ក ត្រង់កណ្ដាលមណ្ឌប ដែលរៀបចំដោយខ្លួនឯង អង្គុយទៀបបាទមូលរបស់ព្រះពោធិសត្វនោះ ។

លំដាប់នោះ ព្រះពោធិសត្វប្រាប់យក្ខនោះថា ចូរអ្នកស្ដាប់ដោយគោរពចុះ ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

ពួកសប្បុរស អ្នកមានចិត្តស្ងប់រម្ងាប់ បរិបូណ៌ដោយហិរិ និងឱត្តប្បៈ តាំងមាំហើយក្នុងធម៌ស លោកពោលថា មានទេវធម៌ក្នុងលោក ។

យក្ខស្ដាប់ទេសនានេះហើយជ្រះថ្លា ពោលនឹងព្រះពោធិសត្វថា លោកជាបណ្ឌិត ខ្ញុំជ្រះថ្លាចំពោះលោកហើយ នឹងឲ្យប្អូនប្រុសម្នាក់ តើនាំអ្នកណាមក ព្រះពោធិសត្វពោលថា ចូរនាំប្អូនពៅមកចុះ យក្ខពោលថា លោកជាបណ្ឌិត លោកចេះទេវធម៌តែម្យ៉ាងប៉ុណ្ណោះ តែលោកមិនប្រព្រឹត្តក្នុងទេវធម៌ទាំងនោះ

ព្រះពោធិសត្វសួរថា ព្រោះហេតុអ្វី យក្ខឆ្លើយថា ព្រោះលោកឲ្យនាំប្អូនពៅមក វៀរកូនច្បង រមែងមិនឈ្មោះថាធ្វើអបចាយិកកម្មចំពោះអ្នកមានសេចក្តីចម្រើន ។ ព្រះពោធិសត្វពោលថា នែយក្ខ ខ្ញុំចេះទេវធម៌ផង ប្រព្រឹត្តនៅក្នុងទេវធម៌នោះផង ព្រោះខ្ញុំអាស្រ័យប្អូនប្រុសពៅនោះ ទើបពួកខ្ញុំចូលព្រៃនេះ ព្រោះថា មាតារបស់ប្អូនប្រុសពៅនោះ ទូលសូមរាជសម្បត្តិនឹងបិតារបស់យើងទាំងពីរ ដើម្បីប្រយោជន៍ដល់ប្អូនពៅនោះ បិតារបស់ខ្ញុំមិនព្រះរាជទានពរនោះ ទ្រង់អនុញ្ញាតការនៅព្រៃ ដើម្បីប្រយោជន៍ដល់ការតាមរក្សាយើងទាំងពីរ កុមារនោះ មិនឃើញទៅ ឃើញតែពួកយើង កាលបើខ្ញុំពោលថា យក្ខក្នុងព្រៃទំពាស៊ីប្អូនប្រុសពៅនោះ ដូច្នេះ បុគ្គលណាក៏មិនជឿ ព្រោះហេតុនោះ ខ្ញុំភ័យចំពោះការនិន្ទា ទើបឲ្យនាំប្អូនប្រុសពៅនោះតែម្នាក់មក ។

យក្ខជ្រះថ្លាចំពោះព្រះពោធិសត្វ សរសើរថា សាធុ លោកបណ្ឌិត លោកចេះទេវធម៌ផង ប្រព្រឹត្តក្នុងទេវធម៌ផង ដូច្នេះហើយ ទើបនាំប្អូនទាំងពីរមកឲ្យលំដាប់នោះ ព្រះពោធិសត្វពណ៌នាទោសក្នុងកំណើតយក្ខហើយ ឲ្យយក្ខនោះតាំងនៅក្នុងសីល ៥ ។ ព្រះពោធិសត្វនោះ ជាអ្នកមានការរក្សាដែលយក្ខនោះធ្វើដោយល្អហើយនៅក្នុងព្រៃនោះ កាលព្រះរាជបិតាសោយទិវង្គតហើយ នាំយក្ខទៅកាន់ក្រុងពារាណសី គ្រប់គ្រងរាជសម្បត្តិហើយ ព្រះរាជទានតំណែងឧបរាជដល់ចន្ទកុមារ ព្រះរាជទានតំណែងសេនាបតីដល់សុរិយកុមារ ឲ្យធ្វើលំនៅក្នុងរមណីយដ្ឋានដល់យក្ខ នឹងបានធ្វើដោយប្រការដែលយក្ខនោះដល់នូវភាពជាបុគ្គលដ៏ប្រសើរដោយលាភ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា អារក្សទឹកក្នុងកាលនោះ បានជាភិក្ខុដែលមានភណ្ឌៈច្រើន សុរិយ-កុមារបានជាអានន្ទ ចន្ទកុមារបានជាសារីបុត្រ មហិសាសកុមារ បានមកជាតថាគតនេះឯង ។

ព្រះសាស្តា កាលត្រាស់ជាតកយ៉ាងនេះហើយ ទើបត្រាស់ថា ម្នាលភិក្ខុ ក្នុងកាលមុន អ្នកស្វែងរកទេវធម៌ ដល់ព្រមដោយហិរិ និងឱត្តប្បៈត្រាច់ទៅយ៉ាងនោះ ។ ឥឡូវនេះ អ្នកឈរដោយទំនងនេះ ក្នុងកណ្តាលនៃបរិស័ទ ៤ ពោលចំពោះមុខតថាគតថា ខ្ញុំមានសេចក្តីប្រាថ្នាតិចដូច្នេះ ឈ្មោះថា បានធ្វើកម្មដែលមិនសមគួរហើយ ព្រោះថា បុគ្គលឈ្មោះថាជាសមណៈដោយគ្រាន់តែហាមសំពត់សាដកជាដើមក៏មិនមែន ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**ន នគ្គចរិយា ន ជដា ន បង្កា នានាសកា ថណ្ឌិលសាយិកា វា**
**រជោជល្លំ ឧក្កុដិកប្បធានំ សោធេន្តិ មច្ចំ អវិតិណ្ណកង្ខំ ។**

ការប្រព្រឹត្តអាក្រាតកាយ ទុកសក់ ដេកលើភក់ មិនបរិភោគបាយ ដេកលើផែនដី ប្រឡាក់ខ្លួនដោយធូលី ព្យាយាមអង្គុយប្រហោង មិនជម្រះសត្វ ដែលមិនទាន់ឆ្លងផុតសេចក្តីសង្ស័យបានទេ ។

## សេចក្តីអធិប្បាយ

បណ្តាបទថាទាំងនោះ បទថា **នានាសកា** កាត់បទជា **ន អនាសកា**

សេចក្ដីថា ការហាមកត្ត ។ ការដេកលើផែនដី ឈ្មោះថា **ថណ្ឌិល-សាយិកា** ។ គឺធូលីដែលប្រឡាក់ក្នុងសរីរៈ ដោយអាការ គឺដូចលាបដោយភក់ ឈ្មោះថា **រជោជល្លំ** ។ សេចក្ដីព្យាយាមដែលប្រារព្ធហើយ ដោយភាពជាអ្នកអង្គុយប្រហោង ឈ្មោះថា **ឧក្កុដិកប្បធានំ** ។ ព្រះដ៏មានព្រះភាគត្រាស់អធិប្បាយពាក្យនេះថា សត្វណាយល់ថា អញនឹងសម្រេចសេចក្ដីបរិសុទ្ធពោល គឺការចេញចាកលោក ដោយបដិបត្តិយ៉ាងនេះ ដូច្នេះហើយ គប្បីសមាទាន ប្រព្រឹត្តវត្តឯណាមួយ ក្នុងវត្ត មានការប្រព្រឹត្តជាបុគ្គលជាអាក្រាតទាំងនេះជាដើម សត្វនោះគប្បីឈ្មោះថា ចម្រើនដោយការឃើញ និងគប្បីជាអ្នកមានចំណែកនៃសេចក្ដីលំបាកដោយចំណែកមួយ ។ ព្រោះថា វត្តទាំងនោះ ដែលសត្វសមាទានល្អហើយ រមែងញុំាងសត្វដែលឈ្មោះថា មិនទាន់កន្លងនូវសេចក្ដីសង្ស័យ មានវត្ថុ ៥ ដែលខ្លួនមិនទាន់បានឈានកន្លងហើយឲ្យបរិសុទ្ធបានឡើយ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។៚

## រឿង ភិក្ខុមានភណ្ឌៈច្រើន ចប់

# រឿង សន្តតិមហាមាត្យ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសន្តតិមហាមាត្យ ត្រាស់ព្រះធម្មទេសនានេះថា **អលង្កតោ ចេបិ សមញ្ចរេយ្យ** ជាដើម ។

សេចក្តីពិស្តារថា សម័យមួយ សន្តតិមហាមាត្យនោះ បង្ក្រាបជនបទក្នុងដែនរបស់ព្រះបាទបសេនទិកោសល ដែលបះបោរឲ្យស្ងប់រម្ងាប់ហើយត្រឡប់មក គ្រានោះ ព្រះរាជាទ្រង់ពេញព្រះហឫទ័យ ប្រទានរាជសម្បត្តិឲ្យ ៧ ថ្ងៃ បានប្រទានស្ត្រីឈ្លាសក្នុងការរាំ និងច្រៀងម្នាក់ដល់គាត់ ។ គាត់ជាបុគ្គលស្រវឹងស្រាអស់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ ប្រដាប់ដោយគ្រឿងអលង្ការគ្រប់យ៉ាងហើយ ឡើងកាន់កដំរីដ៏ប្រសើរទៅកាន់កំពង់ទឹក ឃើញព្រះសាស្តាកំពុងយាងចូលទៅបិណ្ឌបាតត្រង់រវាងទ្វារ នៅលើកដំរីដ៏ប្រសើរនោះឯងងក់ក្បាលថ្វាយបង្គំហើយ ។ ព្រះសាស្តាទ្រង់ធ្វើការញញឹម ព្រះអានន្ទទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ជាហេតុឲ្យទ្រង់ធ្វើការញញឹមឲ្យប្រាកដកាលត្រាស់ប្រាប់ហេតុនៃការញញឹម ទើបត្រាស់ថា ម្នាលអានន្ទ ចូរអ្នកមើលសន្តតិមហាមាត្យ ក្នុងថ្ងៃនេះឯង គេប្រដាប់ដោយអាភរណៈគ្រប់យ៉ាងមកកាន់សម្នាក់តថាគត នឹងសម្រេចអរហត្តក្នុងកាលចប់គាថា ដែលប្រកបដោយ ៤ បទ អង្គុយលើអាកាស ៧ ដូរដើមត្នោត នឹងបរិនិព្វាន ។ មហាជនបានស្តាប់ព្រះតម្រាស់របស់ព្រះសាស្តា ដែលកំពុងត្រាស់ជាមួយព្រះថេរៈ ។

បណ្តាជនទាំងនោះ ពួកមិច្ឆាទិដ្ឋិគិតថា ចូរអ្នកទាំងឡាយមើលកិរិយា

របស់ព្រះសមណគោតម ទ្រង់ពោលតែមាត់ប៉ុណ្ណោះ បានឮថា ក្នុងថ្ងៃនេះ សន្តតិមហាមាត្យនោះ ស្រវឹងស្រាយ៉ាងនោះ តែងខ្លួនតាមប្រក្រតី ស្តាប់ធម៌ ក្នុងសម្នាក់របស់ព្រះសមណគោតមនោះហើយ នឹងបរិនិព្វានក្នុងថ្ងៃនេះ ពួកយើងនឹងចាប់កំហុសព្រះសមណគោតមនោះ ដោយមុសាវាទ ។

ពួកជនសម្មាទិដ្ឋិគិតគ្នាថា គួរអស្ចារ្យហ្ន៎ ព្រះពុទ្ធទាំងឡាយទ្រង់មានអានុភាពច្រើន ក្នុងថ្ងៃនេះ យើងទាំងឡាយ នឹងបានមើលភាពអង់អាចរបស់ព្រះពុទ្ធ និងការអង់អាចរបស់សន្តតិមហាមាត្យ ។

ឯសន្តតិមហាមាត្យ លេងទឹកអស់មួយថ្ងៃ ត្រង់កំពង់ហើយ ទៅកាន់ឧទ្យាន អង្គុយត្រង់រោងផឹកសុរា ។ ចំណែកស្រីនោះ ចុះទៅក្នុងកណ្តាលទីសម្រាប់រាំ ផ្តើមសម្តែងការរាំ និងការច្រៀង កាលនាងសម្តែងការរាំ និងការច្រៀងក្នុងថ្ងៃនោះ ខ្យល់មានពិសដូចសស្ត្រាកើតឡើងហើយខាងក្នុងផ្ទៃកាត់នូវហទយៈហើយ ព្រោះភាពដែលនាងមានអាហារតិចអស់ ៧ ថ្ងៃ ដើម្បីសម្តែងការទន់ល្វតល្វៃនៃសរីរៈ ក្នុងវេលានោះឯង នាងមានមាត់ហា និងបើកភ្នែក បានធ្វើកាលកិរិយាហើយ ។

សន្តតិមហាមាត្យពោលថា ចូរអ្នកទាំងឡាយមើលស្រីនោះ គ្រាន់តែពាក្យដែលជនទាំងឡាយពោលថា ស្រីនោះស្លាប់ហើយដូច្នេះ ត្រូវសេចក្តីសោកដ៏ខ្លាំងក្លាគ្របសង្កត់ហើយ ។ ក្នុងខណៈនោះឯង ស្រាដែលគាត់ផឹកអស់ ៧ ថ្ងៃ ក៏ស្វាងហើយ ប្រៀបដូចតំណក់ទឹកលើអំបែងក្តៅ ដូច្នោះ ។ គាត់គិតថា អ្នកដទៃវៀរព្រះតថាគតចេញ មិនអាចញ៉ាំងសេចក្តីសោករបស់អញឲ្យរលត់

បានឡើយ មានសេនាហែហម ទៅកាន់សម្នាក់ព្រះសាស្ដាក្នុងពេលល្ងាច ថ្វាយបង្គំហើយ ក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សេចក្ដីសោក បែបនេះកើតឡើងដល់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គមកហើយដោយបំណងថា ទ្រង់នឹង អាចលត់នូវសោករបស់ខ្ញុំព្រះអង្គបាន សូមទ្រង់ជាទីពឹងរបស់ខ្ញុំព្រះអង្គចុះ ។

គ្រានោះ ព្រះសាស្ដាត្រាស់ថា អ្នកមកកាន់សម្នាក់របស់បុគ្គលដែល អាចលត់នូវសេចក្ដីសោកបានពិតប្រាកដ ពិតហើយ ទឹកភ្នែកដែលហូររបស់ អ្នក ដែលយំក្នុងកាលស្រីនេះស្លាប់ ដោយហេតុនេះឯង ច្រើនជាងទឹករបស់ ទឹកក្នុងមហាសមុទ្រទាំង ៤ ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

> កិលេសជាគ្រឿងកង្វល់ណាមានក្នុងកាលមុន ចូរអ្នកញុំាងកិលេស
> គ្រឿងកង្វល់នោះឲ្យរីងស្ងួតទៅ កិលេសជាគ្រឿងកង្វល់ កុំមាន
> ដល់អ្នកក្នុងកាលខាងក្រោយឡើយ បើអ្នកមិនប្រកាន់ខន្ធក្នុង
> កណ្ដាល នឹងជាអ្នកស្ងប់រម្ងាប់ត្រាច់ទៅ ។

ក្នុងកាលចប់ព្រះគាថា សន្តតិមហាមាត្យសម្រេចអរហត្តហើយ ពិចារណា មើលនូវអាយុសង្ខាររបស់ខ្លួន ជ្រាបការប្រព្រឹត្តទៅមិនបាននៃអាយុសង្ខារនោះ ហើយ ទើបក្រាបទូលព្រះសាស្ដាថា បពិត្រព្រះអង្គ សូមទ្រង់អនុញ្ញាត បរិនិព្វានដល់ខ្ញុំព្រះអង្គចុះ ។

ព្រះសាស្ដាទ្រង់ជ្រាបកម្មដែលសន្តតិមហាមាត្យធ្វើហើយ ក៏ទ្រង់កំណត់ ថា ពួកជនមិច្ឆាទិដ្ឋិប្រជុំគ្នា ដើម្បីសង្កត់សង្កិនតថាគតដោយមុសាវាទ នឹងមិន បានឱកាស ពួកសម្មាទិដ្ឋិប្រជុំគ្នាដោយបំណងថា ពួកយើងនឹងមើលនូវកាត

អង់អាចរបស់ព្រះពុទ្ធ និងភាពអង់អាចរបស់សន្តតិមហាមាត្យ ស្តាប់កម្ម ដែលសន្តតិមហាមាត្យនេះធ្វើហើយ នឹងធ្វើនូវការអើពើក្នុងបុណ្យទាំងឡាយ ដូច្នេះហើយ ទើបត្រាស់ថា បើដូច្នោះ ចូរអ្នកប្រាប់កម្មដែលអ្នកធ្វើហើយដល់ ជនទាំងនេះ កាលប្រាប់ កុំឈរលើផែនដី ចូរឈរលើអាកាស ៧ ជួរត្នោត ហើយប្រាប់ចុះ ។

សន្តតិមហាមាត្យនោះទូលថា សាធុ ដូច្នេះហើយ ទើបថ្វាយបង្គំព្រះ សាស្តា ហោះឡើងទៅកាន់អាកាសមួយជួរត្នោត ចុះមកថ្វាយបង្គំម្តងទៀត ហោះឡើងទៅអង្គុយពត់ភ្នែនលើអាកាស ៧ ជួរដើមត្នោតតាមលំដាប់ហើយ ទូលថា បពិត្រព្រះអង្គ សូមទ្រង់ស្តាប់បុព្វកម្មរបស់ខ្ញុំចុះ ។

ក្នុងកប្បទី ៩១ អំពីកប្បនេះ ក្នុងកាលព្រះពុទ្ធព្រះនាមវិបស្សី ខ្ញុំព្រះ អង្គកើតក្នុងត្រកូលមួយ ក្នុងពន្ធុមតីនគរ គិតហើយថា អ្វីហ្ន៎ជាកម្មដែលមិន ធ្វើនូវការកាត់ផ្តាច់ ឬបៀតបៀននូវជនដទៃ ដូច្នេះហើយ កាលពិចារណា ទើបឃើញកម្ម គឺការប្រកាសក្នុងបុណ្យទាំងឡាយ ចាប់តាំងអំពីកាលនោះ ធ្វើកម្មនោះ បបួលមហាជនដើរប្រកាសថា ចូរពួកអ្នកធ្វើបុណ្យទាំងឡាយ ចូរ សមាទានឧបោសថក្នុងថ្ងៃឧបោសថទាំងឡាយ ចូរស្តាប់ធម៌ ឈ្មោះថា រតនៈ ដទៃ ស្មើនឹងពុទ្ធរតនៈមិនមាន ចូរពួកអ្នកធ្វើសក្ការៈរតនៈទាំង ៣ ចុះ ។

ព្រះរាជាជាធំ ព្រះនាមពន្ធុមៈ ជាពុទ្ធបិតា ទ្រង់ស្តាប់សំឡេងរបស់ខ្ញុំ ព្រះអង្គ ត្រាស់ឲ្យហៅខ្ញុំព្រះអង្គចូលគាល់ហើយត្រាស់សួរថា នែបា បាត្រាច់ ធ្វើអ្វី កាលខ្ញុំព្រះអង្គទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំដើរប្រកាសគុណ

រតនៈទាំង ៣ បបួលមហាជនក្នុងការធ្វើបុណ្យទាំងឡាយ ទើបត្រាស់សួរថា អ្នកអង្គុយលើអ្វីត្រាច់ទៅ កាលខ្ញុំព្រះអង្គទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំដើរទៅដោយជើង ទើបត្រាស់ថា នែបា បាមិនគួរដើរទៅយ៉ាងនោះ ចូរប្រដាប់នូវកម្រងផ្កានេះហើយ អង្គុយលើខ្នងសេះត្រាច់ទៅចុះ ដូច្នេះហើយព្រះរាជាព្រះរាជទានកម្រងផ្កា ដូចគ្នានឹងកម្រងកែវមុក្តា និងបានព្រះរាជទានសេះដែលបង្ហឹកហើយដល់ខ្ញុំព្រះអង្គ ។

សម័យក្រោយមកទៀត ព្រះរាជាត្រាស់ឲ្យខ្ញុំព្រះអង្គ ដែលកំពុងត្រាច់ប្រកាសយ៉ាងនោះឯង ដោយគ្រឿងបរិហារដែលព្រះរាជាប្រទាន ចូលគាល់ហើយត្រាស់សួរថា នែបា បាត្រាច់ធ្វើអ្វី កាលខ្ញុំព្រះអង្គទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំធ្វើកម្មឈ្មោះនោះ ទើបត្រាស់ថា នែបា សូម្បីសេះក៏មិនគួរដល់បា ចូរបាអង្គុយលើរថត្រាច់ទៅចុះ ហើយបានព្រះរាជទានរថ ដែលទឹមដោយសេះ សិន្ធព ៤ ។ ក្នុងគ្រាទី ៣ ព្រះរាជាស្តាប់សំឡេងរបស់ខ្ញុំព្រះអង្គហើយ ត្រាស់ឲ្យចូលគាល់ សួរថា នែបា បាត្រាច់ធ្វើអ្វី កាលខ្ញុំព្រះអង្គទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គធ្វើកម្មឈ្មោះនោះ ទើបត្រាស់ថា នែបា សូម្បីរថក៏មិនគួរដល់បា ហើយព្រះរាជទានភោគៈជាច្រើន និងគ្រឿងប្រដាប់ធំ មួយអន្លើដោយដំរី ១ ដល់ខ្ញុំព្រះអង្គ ។ ខ្ញុំព្រះអង្គនោះ ប្រដាប់ដោយអាភរណៈគ្រប់យ៉ាង អង្គុយលើ-កដំរី បានធ្វើកម្មរបស់អ្នកប្រកាសធម៌អស់ ៨ ម៉ឺនឆ្នាំ ក្លិនខ្លឹមចន្ទន៍ផ្សាយចេញអំពីកាយរបស់ខ្ញុំព្រះអង្គ ក្លិនឧប្បលផ្សាយចេញអំពីមាត់អស់កាលមានប្រមាណប៉ុណ្ណោះ នេះជាកម្មដែលខ្ញុំព្រះអង្គ

ធ្វើហើយ ។

សន្តតិមហាមាត្យនោះ កាលទូលបុព្វកម្មរបស់ខ្លួនយ៉ាងនោះហើយ អង្គុយលើអាកាសនោះឯង ចូលតេជោកសិណបរិនិព្វានហើយ ។ អណ្តាតភ្លើងកើតឡើងក្នុងសរីរៈ ឆេះសាច់ និងឈាមហើយ ធាតុទាំងឡាយដូចផ្កាម្លិះនៅសល់ ។

ព្រះសាស្តាទ្រង់លាតសំពត់ស ធាតុទាំងឡាយក៏ធ្លាក់ចុះលើសំពត់នោះ ទ្រង់បញ្ចុះធាតុទាំងនោះហើយ ត្រាស់ឲ្យសាងស្តូបត្រង់ផ្លូវធំ ដែលមានទម្រុំ ៤ ដោយបំណងថា មហាជនថ្វាយបង្គំហើយ នឹងមានចំណែកនៃបុណ្យ ។

ពួកភិក្ខុសន្ទនាគ្នាក្នុងរោងធម្មសភាថា អាវុសោ សន្តតិមហាមាត្យសម្រេចអរហត្តក្នុងកាលចប់មួយព្រះគាថា ទាំងមានគ្រឿងប្រដាប់នោះឯង អង្គុយលើអាកាសបរិនិព្វានហើយ ការហៅលោកថា សមណៈគួរឬហ្ន៎ ឬហៅថា ព្រាហ្មណ៍ ទើបគួរ ។

ព្រះសាស្តាទ្រង់យាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយកថាអ្វីហ្ន៎ កាលភិក្ខុទាំងឡាយទូលថា ពួកខ្ញុំព្រះអង្គ អង្គុយប្រជុំគ្នាដោយកថាឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការហៅបុត្ររបស់តថាគតថាសមណៈក៏គួរ ហៅថា ព្រាហ្មណ៍ក៏គួរដូចគ្នា ដូច្នេះ កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា

**អលង្កតោ ចេបិ សមំ ចរេយ្យ**
**សន្តោ ទន្តោ និយតោ ព្រហ្មចារី**

**សន្តោ ទន្តោ និយតោ ព្រហ្មចារី**
**សព្វេសុ ភូតេសុ និធាយ ទណ្ឌំ**
**សោ ព្រាហ្មណោ សោ សមណោ ស ភិក្ខុ ។**

បើបុគ្គលណា មានខ្លួនប្រដាប់ស្អិតស្អាងហើយ ( ដោយគ្រឿងអម្ពរ ) តែគប្បីប្រព្រឹត្តស្មើ អ្នកស្ងប់រម្ងាប់ ទូន្មាន ( ឥន្ទ្រិយ ) ជាបុគ្គលពាល ( ចំពោះមគ្គផល ) អ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ទម្លាក់ចោលនូវអាជ្ញាក្នុងសត្វទាំងពួង ចេញហើយ បុគ្គលនោះ ហៅថា ព្រាហ្មណ៍ក៏បាន ថាសមណៈក៏បាន ថាភិក្ខុក៏បាន ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អលង្កតោ** បានដល់ ប្រដាប់ដោយសំពត់ និងអាភរណៈ ។ បណ្ឌិតគប្បីជ្រាបអត្ថនៃព្រះគាថានេះថា បើបុគ្គលប្រកប ដោយគ្រឿងអលង្ការ មានសំពត់ជាដើម គប្បីប្រព្រឹត្តស្មើដោយកាយជាដើម ឈ្មោះថាជាអ្នកស្ងប់ ព្រោះការស្ងប់រម្ងាប់នៃរាគៈជាដើម ឈ្មោះថាជាបុគ្គល ទូន្មាន ព្រោះទូន្មានឥន្ទ្រិយ ឈ្មោះថាជាបុគ្គលទៀង ព្រោះទៀងក្នុងមគ្គទាំង ៤ ឈ្មោះថាព្រហ្មចារី ព្រោះប្រព្រឹត្តប្រសើរ ឈ្មោះថាដកនូវអាជ្ញាក្នុងសត្វគ្រប់ពួក ព្រោះជាអ្នកដាក់ចុះនូវអាជ្ញាតាមកាយជាដើមហើយ បុគ្គលនោះ គឺបុគ្គលបែបនោះ ដែលបុគ្គលគួរហៅថាព្រាហ្មណ៍ ព្រោះជាអ្នកមានបាបបន្សាត់ហើយក៏បាន ថាសមណៈ ព្រោះជាអ្នកមានបាបស្ងប់ហើយក៏បាន ។ ថាភិក្ខុ ព្រោះជាអ្នកមានកិលេសដែលទម្លាយហើយក៏បាន ដោយពិត ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មាន

សោតាបត្តិផលជាដើម ដូច្នេះឯង ។

**រឿង សន្តតិមហាមាត្យ ចប់**

# រឿង ព្រះបិលោតិកត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះបិលោតិកត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **ហិរិនិសេធោ បុរិសោ** ជាដើម ។

សេចក្តីពិស្តារថា ថ្ងៃមួយ ព្រះអានន្ទត្ថេរឃើញទារកម្នាក់ស្លៀកសំពត់ចាស់ កាន់អំបែងដើរសូមទាន ទើបពោលថា អ្នកបួសមិនល្អជាងការដើរទៅយ៉ាងនេះឬ កាលកុមារតបថា បពិត្រលោកម្ចាស់ អ្នកណានឹងឲ្យខ្ញុំបួស ទើបធានាថា អាត្មានឹងឲ្យបួស ហើយនាំទៅកាន់វិហារ បានងូតទឹកដោយដៃរបស់ខ្លួន ឲ្យកម្មដ្ឋានហើយក៏ឲ្យបួស ។

ព្រះអានន្ទនោះ បោកសំពត់ចាស់ដែលទារកនោះស្លៀកហើយ ពិនិត្យមិនឃើញចំណែកណាមួយល្មមប្រើប្រាស់បាន សូម្បីត្រឹមតែធ្វើសំពត់តម្រងទឹក ទើបពាក់ត្រង់មែកឈើជាមួយអំបែង ។

គាត់បានបព្វជ្ជាឧបសម្បទាហើយ បរិភោគលាភសក្ការៈដែលកើតឡើងដើម្បីព្រះពុទ្ធទាំងឡាយ ដណ្តប់ចីវរដែលមានតម្លៃច្រើនត្រាច់ទៅ ជាអ្នកមានសរីរៈធាត់ អផ្សុកហើយគិតថា ប្រយោជន៍អ្វីរបស់អញដោយការដណ្តប់ចីវរ

ដែលជនឲ្យដោយសទ្ធាត្រាច់ទៅ ។ អញនឹងស្លៀកដណ្ដប់សំពត់ចាស់របស់ខ្លួននេះឯង ដូច្នេះហើយ ក៏ទៅកាន់ទីនោះ ចាប់យកសំពត់ចាស់នោះឲ្យជាអារម្មណ៍ហើយ ទើបទូន្មានខ្លួនដោយខ្លួនឯងថា អ្នកមិនមានហិរិ អស់ទូវខ្មាស អ្នកប្រាថ្នាដើម្បីលះឋានៈ គឺការស្លៀកដណ្ដប់សំពត់ទាំងឡាយបែបនោះ ត្រឡប់ទៅស្លៀកសំពត់ចាស់នេះ មានដៃកាន់អំបែងដើរសូមទានទៀតឬ ។

កាលលោកទូន្មានខ្លួននោះឯង ចិត្តជូរផង់ហើយ លោកក៏ទុកសំពត់ចាស់នោះត្រង់ទីដើមនោះឯង ត្រឡប់ទៅកាន់វិហារវិញ ។ ២-៣ ថ្ងៃកន្លងទៅ លោកអផ្សុកឡើងទៀត ទៅពោលយ៉ាងនោះឯងហើយក៏ត្រឡប់ អផ្សុកឡើងទៀត ក៏ទៅពោលយ៉ាងនោះដូចគ្នា ហើយក៏ត្រឡប់ ដោយប្រការដូច្នេះ ។

ភិក្ខុទាំងឡាយ ឃើញលោកទៅមកៗយ៉ាងនោះហើយទើបសួរថា អាវុសោ អ្នកទៅណា លោកប្រាប់ថា អាវុសោ ខ្ញុំនឹងទៅសម្នាក់អាចារ្យ ដូច្នេះហើយ ក៏ធ្វើសំពត់ចាស់របស់ខ្លួនឯងឲ្យជាអារម្មណ៍ដោយទំនងនោះឯង ហាមខ្លួនបាន ២-៣ ថ្ងៃប៉ុណ្ណោះ ក៏សម្រេចអរហត្តផល ។

ភិក្ខុទាំងឡាយពោលថា អាវុសោ លោកមិនទៅសម្នាក់អាចារ្យទៀតទេឬ ផ្លូវនេះជាផ្លូវត្រាច់ទៅរបស់លោកមិនមែនឬ ព្រះថេរៈឆ្លើយថា អាវុសោ កាលការទាក់ទងដោយអាចារ្យមាន ទើបខ្ញុំទៅ តែឥឡូវនេះ ខ្ញុំកាត់ផ្ដាច់នូវការជាប់ជំពាក់បានហើយ ព្រោះដូច្នោះ ទើបខ្ញុំមិនទៅកាន់សម្នាក់អាចារ្យ ។

ពួកភិក្ខុក្រាបទូលរឿងរ៉ាវដល់ព្រះសាស្ដាថា បពិត្រព្រះអង្គ ព្រះបិលោតិកត្ថេរអួតអរហត្តផល ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បិលោតិកៈ

ពោលដូចម្ដេច ភិក្ខុទាំងឡាយទូលថា បពិត្រព្រះអង្គ លោកពោលពាក្យឈ្មោះនេះ ព្រះសាស្ដាទ្រង់ស្ដាប់ពាក្យនោះហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ បុត្ររបស់តថាគត កាលការជាប់ជំពាក់មាន ទើបទៅកាន់សម្នាក់អាចារ្យ តែឥឡូវនេះ ការជាប់ជំពាក់របស់បិលោតិកៈ កាត់បានហើយ លោកហាមខ្លួនដោយខ្លួនឯង សម្រេចអរហត្តហើយ ដូច្នេះហើយ ទ្រង់បានភាសិតព្រះគាថាទាំងនេះថា

ហិរិនិសេធោ បុរិសោ កោចិ លោកស្មិ វិជ្ជតិ
យោ និន្ទំ អបពោធេតិ អស្សោ ភទ្រោ កសាមិវ
អស្សោ យថា ភទ្រោ កសានិវិដ្ឋោ អាតាបិនោ សំវេគិនោ ភវាថ
សទ្ធាយ សីលេន ច វីរិយេន ច សមាធិនា ធម្មវិនិច្ឆយេន ច
សម្បន្នវិជ្ជាចរណា បតិស្សតា បហស្សថ ទុក្ខមិទំ អនប្បកំ។

បុរសអ្នកកម្ចាត់បង់នូវអកុសលវិតក្ក ដោយសេចក្ដីខ្មាសបាបមានតិចក្នុងលោក បុគ្គលណាបន្ទោបង់នូវការដេកលក់ ដូចសេះល្អខ្លាចព្រោះរំពាត់ បុរសនោះរកបានដោយកម្រក្នុងលោក សេះល្អដែលនាយសារថីទូន្មានដោយរំពាត់ តក់ស្លុត យ៉ាងណា អ្នកទាំងឡាយចូរជាបុគ្គលមានព្យាយាម មានសេចក្ដីតក់ស្លុតយ៉ាងនោះឯង បើអ្នកទាំងឡាយ ប្រកបព្រមដោយសទ្ធាផង សីលផង ព្យាយាមផង សមាធិផង ធម្មវិនិច្ឆ័យផង ជាអ្នកមានវិជ្ជា និងចរណៈដ៏បរិបូណ៌ មានស្មារតីតម្កល់មាំ រមែងលះបង់ទុក្ខមានប្រមាណច្រើននេះមិនខាន ។

# សេចក្តីអធិប្បាយ

បុគ្គល ឈ្មោះថា ហិរិនិសេធបុគ្គល ក្នុងព្រះគាថានោះ ក៏ព្រោះអត្ថថា ហាមអកុសលវិតក្ក ដែលកើតក្នុងខាងក្នុងដោយហិរិបាន ។

ពីរបទថា **កោចិ លោកស្មិំ** សេចក្តីថា បុគ្គលបែបនោះរកបានលំបាក ទើបឈ្មោះថា តិចណាស់ដែលមានក្នុងលោក ។

ពីរបទថា **យោ និទ្ទំ** សេចក្តីថា បុគ្គលណាមិនប្រមាទហើយ ធ្វើសមណធម៌ ឃ្លាំចាំបណ្តេញនូវការដេកលក់ដែលកើតហើយ ខ្លួនជាអ្នកភ្ញាក់រឭក ព្រោះដូច្នោះ ទើបបុគ្គលនោះ ឈ្មោះថា បន្ទោបង់នូវការដេកលក់ ជាអ្នកភ្ញាក់រឭក ។

បទថា **កសាមិវ** ជាដើម សេចក្តីថា បុគ្គលណាកម្ចាត់ការដេកលក់ ជាអ្នកភ្ញាក់ ដូចសេះល្អរវាងប្រយ័ត្ននូវខ្សែតី គឺមិនឲ្យធ្លាក់ដល់ខ្លួនបាន ដូច្នោះ បុគ្គលនោះ រកបានលំបាក ។

ក្នុងគាថាទី ២ មានសេចក្តីសង្ខេបដូចតទៅនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរជាអ្នកមានព្យាយាម មានការសង្វេគ ដូចសេះល្អអាស្រ័យសេចក្តីប្រមាទ ត្រូវគេវាយដោយខ្សែតីហើយ ដឹងខ្លួនថា សូម្បីខ្លួនអញ ត្រូវគេវាយដោយខ្សែតីហើយ ក្នុងកាលតមករមែងធ្វើសេចក្តីព្យាយាម ដូច្នោះ ។ អ្នកទាំងឡាយជាបុគ្គលយ៉ាងនោះហើយ ប្រកបដោយសទ្ធាពីរយ៉ាង ដែលជាលោកិយ និងលោកុត្តរ ដោយបារិសុទ្ធិសីល ៤ ដោយសេចក្តីព្យាយាមប្រព្រឹត្តទៅតាមផ្លូវកាយ និងចិត្ត ដោយសមាធិដែលសម្បយុត្តដោយសមាបត្តិ ៨ និងដោយគុណជាគ្រឿងវិនិច្ឆ័យធម៌ មានការដឹងហេតុ និងមិនមែនហេតុ

ជាលក្ខណៈ ឈ្មោះថា មានវិជ្ជា និងចរណៈដល់ព្រម ព្រោះការដល់ព្រម នៃវិជ្ជា ៣ ឬវិជ្ជា ៨ និងចរណៈ ១៥ ឈ្មោះថា ជាអ្នកមានសតិមាំទាំ ព្រោះជាអ្នកមានសតិតាំងមាំហើយ នឹងលះនូវទុក្ខក្នុងវដ្តៈដែលមានប្រមាណ មិនតិចនេះបាន ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មាន សោតាបត្តិផលជាដើម ដូច្នេះឯង ។៚

**រឿង ព្រះបិលោតិកត្ថេរ ចប់**

# រឿង សុខសាមណេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសុខសាមណេរ ត្រាស់ព្រះធម្មទេសនានេះថា **ឧទកំ ហិ នយន្តិ នេត្តិកា** ជាដើម ។

សេចក្តីពិស្តារ ក្នុងអតីតកាល មានបុត្ររបស់សេដ្ឋីអ្នកក្រុងពារាណសី ម្នាក់ ឈ្មោះគន្ធកុមារ កាលបិតារបស់គាត់អនិច្ចកម្មហើយ ព្រះរាជាត្រាស់ ឲ្យហៅគាត់មកចូលគាល់ ទ្រង់លួងលោមហើយ បានព្រះរាជទានតំណែង សេដ្ឋីដល់គាត់នោះឯងដោយសក្ការៈដ៏ច្រើន ចាប់តាំងអំពីកាលនោះមក គន្ធ-កុមារនោះ ក៏បានប្រាកដឈ្មោះថា គន្ធសេដ្ឋី ។ គ្រានោះ អ្នករក្សាឃ្លាំងរបស់ សេដ្ឋីនោះ បានបើកទ្វារបន្ទប់សម្រាប់ដាក់ទ្រព្យ ជញ្ជូនចេញមកហើយ ចន្ទុល

បង្ហាញថា បពិត្រលោកសេដ្ឋី ទ្រព្យរបស់បិតាលោកមានប្រមាណប៉ុណ្ណេះ ទ្រព្យបុព្វបុរស មានជីតាជាដើមមានចំនួនប៉ុណ្ណេះ ។ សេដ្ឋីនោះសម្លឹងមើលគំនរទ្រព្យហើយពោលថា ហេតុអ្វីបុព្វបុរសទាំងនោះមិនបានកាន់យកទ្រព្យទាំងនេះទៅផង អ្នករក្សាឃ្លាំងឆ្លើយថា បពិត្រលោកម្ចាស់ ឈ្មោះថា បុគ្គលដែលកាន់យកទ្រព្យទៅផង មិនមានដោយពិត សត្វទាំងឡាយ នាំយកតែកុសលអកុសល ដែលខ្លួនបានធ្វើប៉ុណ្ណោះទៅ ។

សេដ្ឋីនោះគិតថា បុព្វបុរសទាំងនោះ នាំគ្នាសន្សំទ្រព្យហើយ ក៏លះបង់ចោលទៅ ព្រោះភាពដែលខ្លួនជាមនុស្សល្ងង់ ។ ចំណែកអញ នឹងកាន់យកទ្រព្យនោះទៅផង កាលគន្ធសេដ្ឋីគិតយ៉ាងនោះ មិនបានគិតថា អញនឹងឲ្យទានឬនឹងធ្វើការបូជា តែគិតថា អញនឹងបរិភោគទ្រព្យនេះឲ្យអស់ ហើយសឹមទៅ សេដ្ឋីនោះបានចំណាយទ្រព្យមួយសែន ធ្វើទីសម្រាប់ងូតទឹកសម្រេចដោយកែវផលិក ចំណាយទ្រព្យមួយសែនឲ្យធ្វើគ្រាសម្រាប់ងូតទឹក ដែលវិចិត្រដោយកែវផលិកដូចគ្នា ចំណាយទ្រព្យមួយសែនឲ្យធ្វើបល្ល័ង្កសម្រាប់អង្គុយ ចំណាយទ្រព្យមួយសែនឲ្យធ្វើថាសសម្រាប់ដាក់ភោជន ចំណាយទ្រព្យមួយសែនឲ្យធ្វើមណ្ឌបក្នុងទីបរិភោគ ចំណាយទ្រព្យមួយសែន ឲ្យធ្វើគ្រែសម្រាប់ដាក់ថាសភោជន ឲ្យសាងសីហបញ្ជរក្នុងផ្ទះដោយទ្រព្យមួយសែនដូចគ្នា បានចំណាយទ្រព្យមួយពាន់ ដើម្បីប្រយោជន៍ដល់អាហារព្រឹករបស់ខ្លួន ចំណាយទ្រព្យមួយពាន់ ដើម្បីជាប្រយោជន៍ដល់អាហារល្ងាច តែក្នុងថ្ងៃពេញបូណ៌មី បានចំណាយទ្រព្យមួយសែន ដើម្បីជាប្រយោជន៍ដល់ភោជន ក្នុងថ្ងៃបរិភោគ

ភត្តនោះ លោកសេដ្ឋីបានចំណាយទ្រព្យមួយសែន គាក់តែងព្រះនគរ ប្រើមនុស្សឲ្យវាយស្គរ ប្រកាសថា សូមមហាជន មើលការបរិភោគភត្តរបស់គន្ធសេដ្ឋី មហាជនបានចងគ្រែត្រួតលើគ្រែ ប្រជុំគ្នា ។

ចំណែកគន្ធសេដ្ឋីនោះ អង្គុយលើបន្ទះក្ដារដែលមានតម្លៃមួយសែន ក្នុងទីងូតទឹកដែលមានតម្លៃមួយសែន ងូតទឹកដោយក្អមទឹក ១៦ ក្អម បើកសីហបញ្ជរនោះហើយ អង្គុយលើបល្ល័ង្កនោះ កាលនោះពួកអ្នកបម្រើដាក់ថាសនោះលើគ្រែសម្រាប់ទ្រនោះហើយ ដួសភោជនដែលមានតម្លៃមួយសែន ដើម្បីសេដ្ឋីនោះ ។ សេដ្ឋីកាលអ្នករបាំចោមរោមហើយ បរិភោគភោជននោះដោយសម្បត្តិបែបនេះ ។

សម័យដទៃមក អ្នកស្រុកក្រៅម្នាក់ ដាក់ឧសជាដើមក្នុងយាន ដើម្បីដូរស្បៀងអាហារសម្រាប់ខ្លួន ទៅដល់ព្រះនគរហើយ ក៏ស្នាក់នៅក្នុងផ្ទះរបស់សម្លាញ់ ។ កាលនោះជាថ្ងៃពេញបូណ៌មី ជនទាំងឡាយវាយស្គរប្រកាសក្នុងព្រះនគរថា ចូរមហាជនមើលការបរិភោគរបស់គន្ធសេដ្ឋី ។ កាលនោះទើបសម្លាញ់ពោលនឹងសម្លាញ់ស្រុកក្រៅនោះថា នែសម្លាញ់ ការបរិភោគភត្តរបស់គន្ធសេដ្ឋី អ្នកធ្លាប់ឃើញឬ បុរសស្រុកក្រៅពោលថា ខ្ញុំមិនធ្លាប់ឃើញឡើយ សម្លាញ់នោះពោលថា បើដូច្នោះ មកចុះសម្លាញ់ យើងនឹងទៅជាមួយគ្នា អ្នកវាយស្គរនេះត្រាច់ទៅពេញនគរ យើងនឹងមើលមហាសម្បត្តិ ។

សម្លាញ់ក្នុងក្រុង បាននាំសម្លាញ់ស្រុកក្រៅចេញទៅហើយ ។ មហាជនក៏បាននាំគ្នាឡើងគ្រែដែលត្រួតលើគ្នានោះ ។ សម្លាញ់ស្រុកក្រៅបានហិតក្លិន

កត្ត ក៏ពោលនឹងសម្លាញ់ក្នុងក្រុងថា ខ្ញុំកើតការឃ្លានក្នុងកត្តដែលនៅក្នុងថាស នោះហើយ សម្លាញ់ក្នុងក្រុងពោលថា នែសម្លាញ់ អ្នកកុំប្រាថ្នាដុំកត្តនោះឡើយ ខ្ញុំមិនអាចយកឲ្យបានទេ សម្លាញ់ស្រុកក្រៅពោលថា ឱសម្លាញ់ បើមិនបាន ខ្ញុំក៏មិនអាចរស់ ។

សម្លាញ់ក្នុងក្រុងនោះ កាលមិនអាចឃាត់សម្លាញ់ស្រុកក្រៅនោះបាន ឈរខាងចុងបរិស័ទ ស្រែកដោយសំឡេងខ្លាំង ៣ ដងថា បពិត្រលោកម្ចាស់ ខ្ញុំថ្វាយបង្គំលោក កាលគន្ធសេដ្ឋីសួរថា អ្នកជានរណា ទើបឆ្លើយថា គឺខ្ញុំ លោកម្ចាស់ សេដ្ឋីសួរថា តើមានរឿងអ្វី គាត់ក៏ឆ្លើយថា បុរសស្រុកក្រៅម្នាក់នេះ មានចំណង់ក្នុងដុំកត្តដែលនៅក្នុងថាសរបស់លោក សូមលោកមេត្តាឲ្យដុំកត្តមួយដុំចុះ សេដ្ឋីពោលថា មិនអាចទេ សម្លាញ់នោះពោលថា នែសម្លាញ់ ពាក្យរបស់សេដ្ឋី សម្លាញ់បានឮឬទេ បុរសស្រុកក្រៅពោលថា អើ ខ្ញុំបានឮហើយសម្លាញ់ តែបើមិនបាន ខ្ញុំនឹងមិនអាចរស់នៅបាន ការស្លាប់នឹងមានពិត ។ សម្លាញ់នោះស្រែកទៀតថា បពិត្រលោកម្ចាស់ បានឮថា បុរសនេះបើមិនបាន នឹងស្លាប់ សូមលោកឲ្យជីវិតដល់គេផងចុះ គន្ធ-សេដ្ឋីពោលថា នែអ្នក ដុំកត្តនេះ រមែងដល់តម្លៃមួយរយក៏មាន ពីររយក៏មាន បុគ្គលណាម្នាក់សូម កាលឲ្យដល់បុគ្គលនោះ ខ្ញុំនឹងបរិភោគអ្វី សម្លាញ់ក្នុងក្រុងពោលថា បពិត្រលោកម្ចាស់ បុរសនេះ បើមិនបាននឹងស្លាប់ សូមលោកម្ចាស់ឲ្យជីវិតដល់គេផងចុះ គន្ធសេដ្ឋីពោលថា ខ្ញុំមិនអាចឲ្យទទេៗ បានឡើយ បើបុរសនោះមិនអាចរស់នៅបានសោត បុរសនោះ ចូរធ្វើការស៊ីឈ្នួលក្នុងផ្ទះ

របស់ខ្ញុំ ៣ ឆ្នាំចុះ ខ្ញុំនឹងឲ្យកត្តមួយថាសដល់គេ ។

បុរសស្រុកក្រៅស្តាប់ពាក្យនោះហើយ ក៏ពោលនឹងសម្លាញ់នោះថា ល្អហើយចុះ សម្លាញ់ ខ្ញុំយល់ព្រម ដូច្នេះហើយ បានលាបុត្រ និងភរិយា ចូលទៅកាន់ផ្ទះរបស់សេដ្ឋី ដោយបំណងថា នឹងធ្វើការស៊ីឈ្នួលរយៈពេល ៣ ដើម្បីប្រយោជន៍ដល់កត្តមួយថាស ។ បុរសនោះធ្វើការស៊ីឈ្នួល ទទួលធ្វើកិច្ចគ្រប់យ៉ាងដោយល្អ ការងារដែលគួរធ្វើក្នុងស្រុក ក្នុងព្រៃ ពេលថ្ងៃ ពេលយប់ បានប្រាកដថា គាត់ធ្វើបានល្អ ។ មហាជនហៅគាត់ថា ភត្តភតិកបុរស ពាក្យនោះ បានប្រាកដទៅពេញព្រះនគរ ។

ក្នុងកាលតមក កាលថ្ងៃស៊ីឈ្នួលរបស់ភត្តភតិកៈ គ្រប់បរិបូណ៌ហើយ អ្នករៀបចំភត្តប្រាប់ថា បពិត្រលោកម្ចាស់ ថ្ងៃស៊ីឈ្នួលរបស់ភត្តភតិកបុរស គ្រប់បរិបូណ៌ហើយ គាត់ធ្វើការស៊ីឈ្នួលគ្រប់ ៣ ឆ្នាំ ធ្វើកម្មកម្រដែលអ្នកដទៃធ្វើបាន ការងារណាមួយក៏មិនធ្លាប់ខូចខាត ។ គ្រានោះ លោកសេដ្ឋីបានប្រាប់ឲ្យគេចំណាយទ្រព្យ ៣ ពាន់ ដល់អ្នករៀបចំភត្តនោះ គឺ ២ ពាន់ដើម្បីប្រយោជន៍អាហារល្ងាច និងអាហារព្រឹករបស់ខ្លួន មួយពាន់ដើម្បីប្រយោជន៍ដល់អាហារព្រឹករបស់ភត្តភតិកបុរសនោះ ហើយប្រាប់អ្នកបម្រើថា ថ្ងៃនេះ ចូរពួកអ្នកធ្វើការបរិហារ ដែលគប្បីធ្វើដល់ខ្ញុំ ដល់នាយភត្តភតិកៈនោះចុះ កាលប្រាប់ហើយ ទើបប្រាប់នឹងជនដ៏សេស វៀរភរិយាជាទីស្រឡាញ់ ឈ្មោះចិន្តាមណីម្នាក់ថា ថ្ងៃនេះ ចូរពួកអ្នកចោមរោមភត្តភតិកបុរសនោះចុះ ដូច្នេះហើយ ក៏ប្រគល់សម្បត្តិទាំងអស់ ឲ្យដល់ភត្តភតិកបុរសនោះ ។

កត្តកតិកបុរសនោះ អង្គុយលើបទុះក្តារនោះ ក្នុងទីសម្រាប់ងូតនោះឯង ងូតទឹកសម្រាប់ងូតរបស់សេដ្ឋី ស្លៀកសំពត់សាដកសម្រាប់ស្លៀករបស់សេដ្ឋីនោះឯង ហើយអង្គុយលើបល្ល័ង្ករបស់សេដ្ឋីនោះដូចគ្នា ។ លោកសេដ្ឋីក៏ប្រើឲ្យមនុស្សយកស្គរវាយប្រកាសក្នុងព្រះនគរថា នាយកត្តកតិកៈ ធ្វើការងារស៊ីឈ្នួលអស់ ៣ ឆ្នាំក្នុងផ្ទះរបស់គន្ធសេដ្ឋីបានកត្តមួយថាស សូមជនទាំងឡាយមើលសម្បត្តិនៃការបរិភោគរបស់គាត់ មហាជនបានដាក់គ្រែត្រួតលើគ្នាដើម្បីមើល ។ ទីដែលបុរសស្រុកក្រៅសម្ងឹងមើលហើយ ក៏ដល់នូវអាការញាប់ញ័រ ពួកអ្នករបាំបានឈរចោមរោមកត្តកតិកបុរសនោះ ពួកអ្នកបម្រើលើកថាសកត្តមួយដាក់ខាងមុខរបស់កត្តកតិកបុរសនោះហើយ ។

គ្រានោះ ក្នុងកាលដែលកត្តកតិកៈនោះលាងដៃ ព្រះបច្ចេកពុទ្ធមួយអង្គនៅត្រង់ភ្នំគន្ធមាទន៍ ចេញអំពីសមាបត្តិក្នុងថ្ងៃទី ៧ ហើយពិចារណាថា ថ្ងៃនេះអាត្មាអញនឹងទៅដើម្បីប្រយោជន៍ដល់ភិក្ខាចារក្នុងទីណាហ្ន៎ ក៏បានឃើញកត្តកតិកបុរសហើយ គ្រានោះ លោកពិចារណាតទៅទៀតថា កត្តកតិកបុរសនេះធ្វើការស៊ីឈ្នួលអស់ ៣ ឆ្នាំ ទើបបានថាសកត្ត ។ សទ្ធារបស់បុរសនេះមានឬមិនមានហ្ន៎ ពិចារណាទៅ ក៏ជ្រាបបានថា សទ្ធារបស់បុរសនេះមាន គិតទៀតថា ជនពួកខ្លះទោះមានសទ្ធា ក៏មិនអាចធ្វើការសង្គ្រោះបាន កត្តកតិកបុរសនេះតើអាច ឬមិនអាចហ្ន៎ ដើម្បីធ្វើការសង្គ្រោះដល់អាត្មាអញ ក៏ដឹងថា កត្តកតិកៈនឹងអាចនោះឯង ព្រមទាំងបានមហាសម្បត្តិព្រោះអាស្រ័យហេតុគឺការសង្គ្រោះដល់អាត្មាអញទៀតផង ដូច្នេះហើយ ទើបដណ្តប់ចីវរ កាន់បាត្រ ហោះឡើង

កាន់វេហាស៍ ទៅដោយរវាងបរិស័ទ បង្ហាញខ្លួនឈរខាងមុខកត្តកតិកបុរស នោះឯង កត្តកតិកបុរសនោះ ឃើញព្រះបច្ចេកពុទ្ធហើយ គិតថា អញបាន ស៊ីឈ្នួលក្នុងផ្ទះអ្នកដទៃអស់ ៣ ឆ្នាំ ដើម្បីប្រយោជន៍ដល់ថាសមួយ ព្រោះ តែអញមិនបានឲ្យទានក្នុងកាលមុន ឥឡូវនេះ កត្តនេះរបស់អញ គប្បីរក្សា អញត្រឹមតែមួយថ្ងៃមួយយប់ បើអញប្រគេនកត្តនោះដល់ព្រះបច្ចេកពុទ្ធ កត្ត នឹងរក្សាអញ មិនមែនពាន់កោដិកប្ប អញនឹងប្រគេនកត្តនោះដល់លោកម្ចាស់ ចុះ ។ កត្តកតិកបុរសនោះ ធ្វើការស៊ីឈ្នួលអស់ ៣ ឆ្នាំ បានថាសកត្តហើយ មិនទាន់ដាក់កត្តមួយដុំក្នុងមាត់ បន្ទោបង់នូវចំណង់បាន លើកថាសកត្តឡើង ទៅកាន់សម្នាក់ព្រះបច្ចេកពុទ្ធ ឲ្យថាសក្នុងដៃរបស់អ្នកដទៃហើយ ថ្វាយបង្គំ ដោយបញ្ចង្គប្រតិស្ឋាន យកដៃឆ្វេងចាប់ថាសកត្ត យកដៃស្តាំជួសកត្តដាក់ ក្នុងបាត្ររបស់ព្រះបច្ចេកពុទ្ធអង្គនោះ ។ ព្រះបច្ចេកពុទ្ធ បានយកដៃបិទបាត្រ ក្នុងកាលដែលកត្តនៅសល់ពាក់កណ្តាល ។

គ្រានោះ កត្តកតិកៈនោះពិតលោកថា បពិត្រលោកម្ចាស់ កត្តចំណែក មួយប៉ុណ្ណោះ ខ្ញុំមិនអាចចែកជាពីរបាន សូមលោកម្ចាស់កុំសង្គ្រោះខ្ញុំក្នុងលោក នេះឡើយ សូមធ្វើការសង្គ្រោះក្នុងបរលោកចុះ ខ្ញុំនឹងប្រគេនទាំងអស់នោះឯង មិនឲ្យសេសសល់ឡើយ ។ ពិតហើយ ទានដែលបុគ្គលឲ្យមិនបន្សល់ទុក ដើម្បីខ្លួនសូម្បីតិចតួច ឈ្មោះថា ទានមិនមានចំណែកសេសសល់ ទាននោះ រមែងមានផលច្រើន ។ កត្តកតិកបុរសនោះ កាលធ្វើយ៉ាងនោះ ទើបបាន ប្រគេនទាំងអស់ ថ្វាយបង្គំម្តងទៀតហើយពោលថា បពិត្រលោកម្ចាស់ ខ្ញុំ

អាស្រ័យកត្តមួយថាស ត្រូវធ្វើការស៊ីឈ្នួលក្នុងផ្ទះអ្នកដទៃអស់ ៣ ឆ្នាំ បាន សោយទុក្ខហើយ ។ ឥឡូវនេះ សូមសេចក្ដីសុខមានដល់ខ្ញុំ ក្នុងទីដែលខ្ញុំ កើតហើយចុះ ខ្ញុំសូមមានចំណែកនៃធម៌ដែលលោកម្ចាស់ឃើញហើយចុះ ។ ព្រះបច្ចេកពុទ្ធពោលថា

សូមតម្រិះត្រូវទាំងពួង ចូរពេញដល់អ្នក ដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើត ដូច្នោះ ។ កាលធ្វើអនុមោទនា ទើបពោលថា

សូមឥដ្ឋផល គឺផលជាទីគាប់ចិត្តដែលអ្នកប្រាថ្នាហើយ តាំងចិត្ត ហើយ ចូរមានដល់អ្នកឲ្យបានឆាប់រួសរាន់ទាន់ចិត្ត សូមតម្រិះ ត្រូវទាំងពួង ចូរពេញដល់អ្នក ដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើត សូមឥដ្ឋផល គឺផលជាទីគាប់ចិត្តដែលអ្នកប្រាថ្នាហើយ តាំង ចិត្តហើយ ចូរមានដល់អ្នកឲ្យបានឆាប់រួសរាន់ទាន់ចិត្ត សូមតម្រិះ ត្រូវទាំងពួង ចូរពេញដល់អ្នក ដូចកែវមណីមានរស្មីដ៏រុងរឿង ជាកែវវិសេស អាចញុំាងសេចក្ដីប្រាថ្នាទាំងពួង ឲ្យសម្រេចបាន ដូច្នោះ ។

ពិតហើយ អធិដ្ឋានថា សូមមហាជនដែលឈរ ឃើញអាត្មាអញ ហោះដល់ភ្នំគន្ធមាទន៍ចុះ ។ បានទៅកាន់ភ្នំគន្ធមាទន៍ដោយអាកាសហើយ សូម្បីមហាជន ក៏បានឃើញនោះឯង ព្រះបច្ចេកពុទ្ធទៅកាន់ភ្នំគន្ធមាទន៍ហើយ បានរំលែកបិណ្ឌបាតនោះប្រគេនដល់ព្រះបច្ចេកពុទ្ធ ៥០០ អង្គ ព្រះបច្ចេក-ពុទ្ធគ្រប់រូប បានទទួលយកកត្តល្មមសមគួរដល់ខ្លួនហើយ បុគ្គលមិនគួរគិត

ថា បិណ្ឌបាតបន្តិចបន្តួចនឹងគ្រប់គ្រាន់បានដូចម្តេច ព្រោះថា អចិន្តេយ្យ ៤ យ៉ាង ព្រះដ៏មានព្រះភាគត្រាស់ហើយ ក្នុងអចិន្តេយ្យ ៤ យ៉ាងនោះ នេះក៏ជាបច្ចេកពុទ្ធវិស័យ ។

មហាជនក៏ឃើញបិណ្ឌបាត ដែលព្រះបច្ចេកពុទ្ធចែករំលែកដល់ព្រះបច្ចេកពុទ្ធទាំងឡាយ បាននាំគ្នាញ៉ាំងសាធុការរាប់ពាន់ ឲ្យប្រព្រឹត្តទៅហើយ ។ សំឡេងសាធុការ ហាក់បីដូចសំឡេងអសនីបាត ។ គន្ធសេដ្ឋីបានឮសំឡេងនោះហើយ ទើបគិតថា កត្តកតិកបុរស ប្រហែលជាមិនអាចទ្រទ្រង់សម្បត្តិដែលអញឲ្យហើយបាន ព្រោះហេតុនោះ មហាជននេះ កាលធ្វើការសើចចំអក ទើបស្រែកឡើង ។ លោកសេដ្ឋីនោះ បញ្ជូនមនុស្សទៅដើម្បីដឹងរឿងរ៉ាវដែលប្រព្រឹត្តទៅហើយ ។ មនុស្សទាំងនោះមកហើយ ប្រាប់ថា បពិត្រលោកម្ចាស់ ធម្មតាអ្នកទ្រទ្រង់សម្បត្តិរមែងបែបនេះ ដូច្នេះហើយ ទើបប្រាប់រឿងរ៉ាវដែលប្រព្រឹត្តទៅហើយនោះ ។

សេដ្ឋីស្តាប់រឿងនោះហើយ ជាអ្នកមានសរីរៈដែលបីតិទាំង ៥ ពាល់ត្រូវហើយទើបពោលថា គួរអស្ចារ្យហ្ន៎ កត្តកតិកបុរសនេះ ធ្វើវត្ថុដែលគេធ្វើបានដោយលំបាក អញតាំងនៅក្នុងសម្បត្តិបែបនេះ អស់កាលមានប្រមាណប៉ុណ្ណោះ គង់មិនអាចឲ្យវត្ថុណាមួយបាន ដូច្នេះហើយ ទើបហៅកត្តកតិកបុរសនោះមកហើយ សួរថា បានឮថា អ្នកធ្វើកម្មឈ្មោះនេះពិតឬ កាលបុរសនោះឆ្លើយថា ពិតហើយលោកម្ចាស់ ទើបពោលថា ណ្ហើយចុះ ចូរអ្នកកាន់យកទ្រព្យមួយពាន់ ហើយចែកចំណែកបុណ្យក្នុងទានរបស់អ្នកឲ្យខ្ញុំខ្លះ កត្តកតិកបុរសនោះ

បានធ្វើតាមនោះហើយ សេដ្ឋីក៏បានចែកនូវទ្រព្យពាក់កណ្តាលនៃសម្បត្តិរបស់ខ្លួន ឲ្យដល់កត្តកតិកបុរសនោះ ។

ពិតហើយ ឈ្មោះថា សម្បទា មាន ៤ យ៉ាង គឺវត្ថុសម្បទា ១ បច្ចយសម្បទា ១ ចេតនាសម្បទា ១ គុណាតិរេកសម្បទា ១ ក្នុងសម្បទា ៤ នោះ ព្រះអរហន្ត ឬព្រះអនាគាមី គួរដល់និរោធសមាបត្តិ ជាទក្ខិណេយ្យ-បុគ្គល ឈ្មោះថា វត្ថុសម្បទា កាលកើតឡើងនៃបច្ច័យទាំងឡាយ ដោយធម៌ស្មើ ឈ្មោះថា បច្ចយសម្បទា ភាពដែលចេតនាក្នុងកាល ៣ គឺមុនឲ្យ ១ កំពុងឲ្យ ១ ក្រោយឲ្យ ១ សម្បយុត្តដោយញាណ ប្រកបព្រមដោយសោមនស្ស ឈ្មោះថា ចេតនាសម្បទា ចំណែកទក្ខិណេយ្យបុគ្គលចេញអំពីសមាបត្តិ ឈ្មោះថា គុណាតិរេកសម្បទា ។ សម្បទា ៤ យ៉ាង គឺព្រះបច្ចេក-ពុទ្ធ ព្រះវីណាស្រេពជាទក្ខិណេយ្យបុគ្គល បច្ច័យដែលកើតហើយដោយធម៌ ដោយការដែលធ្វើការស៊ីឈ្នួលបានហើយ ចេតនាបរិសុទ្ធក្នុងកាលទាំង ៣ ព្រះបច្ចេកពុទ្ធដែលចេញអំពីសមាបត្តិ ជាអ្នកក្រៃលែងដោយគុណ សម្រេចហើយដល់កត្តកតិកបុរសនេះ ដោយអានុភាពនៃសម្បទា ៤ នេះ ទើបកត្ត-កតិកៈសម្រេចមហាសម្បត្តិទាន់ភ្នែកនោះឯង ព្រោះដូច្នោះ កត្តកតិកបុរសនោះ ទើបបានសម្បត្តិក្នុងសម្នាក់របស់សេដ្ឋី ។

ក្នុងកាលតមក ព្រះរាជាទ្រង់ស្តាប់កម្មដែលកត្តកតិកបុរសនោះធ្វើហើយ ទើបត្រាស់ឲ្យហៅមកចូលគាល់ ហើយព្រះរាជទានទ្រព្យមួយពាន់ ទ្រង់ទទួលចំណែកបុណ្យ ទ្រង់ពេញព្រះហឫទ័យ ព្រះរាជទានភោគៈច្រើន ហើយបាន

ព្រះរាជទានតំណែងសេដ្ឋីឲ្យ ។ គាត់មានឈ្មោះថា កត្តកតិកសេដ្ឋី ។ កត្ត-កតិកសេដ្ឋីនោះ ជាសម្លាញ់នឹងគន្ធសេដ្ឋី បរិភោគផឹករួមគ្នា តាំងនៅជរាបអស់អាយុ ចុតិអំពីអត្តភាពនោះហើយ កើតក្នុងទេវលោកសោយសម្បត្តិជាទិព្វមួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទកាលនេះ បានបដិសន្ធិក្នុងត្រកូលឧបដ្ឋាករបស់ព្រះសារីបុត្តត្ថេរ ក្នុងក្រុងសាវត្ថី ។

គ្រានោះ មាតារបស់ទារកនោះ បានទូវគព្ភបរិហារហើយ ដោយកន្លងទៅ ២-៣ ថ្ងៃ ក៏កើតចាញ់គភ៌ថា ឱហ្ន៎ អញប្រគេនភោជនមានរសមួយរយប្រភេទដល់ព្រះសារីបុត្តត្ថេរ មួយអន្លើដោយភិក្ខុ ៥០០ រូប ស្លៀកសំពត់ជ្រលក់ដោយទឹកម្ចត់ហើយ កាន់នូវផ្តិលមាស អង្គុយខាងចុងអាសនៈ គប្បីបរិភោគភត្តដែលសល់របស់ភិក្ខុទាំងឡាយនោះ ដូច្នេះហើយ ធ្វើតាមការគិតនោះឯង បន្ទោបង់នូវការចាញ់គភ៌ហើយ ។ នាងនៅក្នុងកាលមង្គលដទៃៗថ្វាយទានយ៉ាងនោះដូចគ្នា ប្រសូតបុត្រហើយ ក្នុងថ្ងៃដាក់ឈ្មោះ ទើបពិតព្រះថេរៈថា សូមលោកម្ចាស់ឲ្យនូវសិក្ខាបទដល់កូនប្រុសរបស់ខ្ញុំចុះ ព្រះថេរៈសួរថា កុមារនេះឈ្មោះអ្វី កាលមាតារបស់ទារកពិតថា បពិត្រលោកម្ចាស់តាំងអំពីកូនប្រុសរបស់ខ្ញុំបដិសន្ធិ ឈ្មោះថា ទុក្ខ មិនធ្លាប់មានដល់បុគ្គលណាក្នុងផ្ទះនេះឡើយ ព្រោះដូច្នោះ ពាក្យថា សុខកុមារនេះឯង ជាឈ្មោះរបស់កុមារនេះ ទើបកាន់យកពាក្យនោះឯង ជាឈ្មោះរបស់ទារកនោះ បានឲ្យសិក្ខាបទហើយ ក្នុងកាលនោះ ការគិតបានកើតដល់មាតារបស់ទារកនោះយ៉ាងនេះថា អញនឹងមិនទម្លាយអាធ្យាស្រ័យរបស់កូនប្រុសអញឡើយ សូម្បី

ក្នុងកាលមង្គលទាំងឡាយ មានពិធីចោះត្រចៀកជាដើម នាងក៏បានថ្វាយទាន យ៉ាងនោះដូចគ្នា ។

ចំណែកកុមារ ក្នុងកាលមានអាយុ ៧ ឆ្នាំ ក៏ពោលថា បពិត្រអ្នកម៉ែ ខ្ញុំចង់បួសក្នុងសម្នាក់ព្រះថេរៈ ។ នាងឆ្លើយថា សាធុ បា ម៉ែមិនទម្លាយអធ្យា-ស្រ័យរបស់បាទេ ដូច្នេះហើយ ទើបនិមន្តព្រះថេរៈឲ្យឆាន់ហើយ ពិតថា បពិត្រលោកម្ចាស់ កូនប្រុសរបស់ខ្ញុំចង់បួស ក្នុងពេលល្ងាច សូមនាំកុមារនេះទៅកាន់វិហារផងចុះ ហើយក៏បញ្ជូនព្រះថេរៈទៅ ឲ្យប្រជុំពួកញាតិពោលថា ក្នុងកាលដែលកូនប្រុសរបស់ខ្ញុំជាគ្រហស្ថ ពួកយើងនឹងធ្វើកិច្ចដែលគួរធ្វើក្នុងថ្ងៃនេះឯង ដូច្នេះហើយ ទើបតែងខ្លួនកូនប្រុស នាំទៅកាន់វិហារដោយសិរីដ៏ធំ ហើយប្រគល់ដល់ព្រះថេរៈ ចំណែកព្រះថេរៈពោលនឹងសុខកុមារនោះថា នែបា ធម្មតាបព្វជ្ជាធ្វើបានលំបាក អ្នកអាចអភិរម្យឬ កាលឆ្លើយថា ខ្ញុំអាចធ្វើតាមឱវាទរបស់លោកម្ចាស់ ទើបឲ្យកម្មដ្ឋានបំបួសហើយ ។ មាតាបិតារបស់សុខកុមារនោះ កាលធ្វើសក្ការៈក្នុងកិច្ចបំបួស ក៏ប្រគេនភោជន មានរសមួយរយដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន នៅក្នុងវិហារនោះឯងអស់ ៧ ថ្ងៃ ក្នុងពេលល្ងាច ទើបបានទៅកាន់ផ្ទះរបស់ខ្លួន ។ ក្នុងថ្ងៃទី ៣ ព្រះសារីបុត្តកាលភិក្ខុសង្ឃចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ធ្វើកិច្ចដែលគួរធ្វើក្នុងវិហារហើយ ទើបឲ្យសាមណេរកាន់បាត្រ និងចីវរ ចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាត ។

សាមណេរឃើញប្រឡាយទឹកជាដើមក្នុងរវាងផ្លូវ ទើបសួរព្រះថេរៈដូច

បណ្ឌិតសាមណេរដែរ ។ ព្រះថេរៈក៏ព្យាករដល់សាមណេរនោះយ៉ាងនោះដូចគ្នា ។ សាមណេរស្តាប់ហេតុនោះហើយ ទើបសួរព្រះថេរៈថា បើលោកម្ចាស់អាចទទួលបាត្រ និងចីវររបស់លោកម្ចាស់សោត ខ្ញុំគប្បីត្រឡប់ ព្រះថេរៈមិនទម្លាយអាធ្យាស្រ័យរបស់សាមេណរនោះ ពោលថា ចូរយកបាត្រ និងចីវររបស់ខ្ញុំមកចុះ ទទួលបាត្រ និងចីវរទៅហើយ សាមណេរថ្វាយបង្គំព្រះថេរៈកាលនឹងត្រឡប់ ទើបប្រាប់ព្រះថេរៈថា បពិត្រលោកម្ចាស់ បើនាំអាហារមកដើម្បីខ្ញុំ គប្បីនាំយកភោជនមានរសមួយរយប្រភេទមក ព្រះថេរៈពោលថា តើបានភោជននោះមកអំពីណា សាមណេរពោលថា បើមិនបានដោយបុណ្យរបស់លោកម្ចាស់ គង់នឹងបានដោយបុណ្យរបស់ខ្ញុំ ។

គ្រានោះ ព្រះថេរៈឲ្យកូនសោដល់សាមណេរនោះហើយ ក៏ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត សាមណេរនោះទៅវិហារហើយ បើកបន្ទប់របស់ព្រះថេរៈចូលទៅហើយបិទទ្វារ អង្គុយញ៉ាំងញាណឲ្យឈមចុះក្នុងកាយរបស់ខ្លួនហើយដោយតេជះនៃគុណរបស់សាមណេរនោះ អាសនៈរបស់សក្កទេវរាជសម្ដែងអាការក្តៅហើយ សក្កៈពិចារណាមើលថា នេះហេតុអ្វីហ្ន៎ ឃើញសាមណេរហើយ ទ្រង់ព្រះតម្រិះថា សុខសាមណេរឲ្យចីវរដល់ឧបជ្ឈាយ៍ហើយ ត្រឡប់មកវិហារ ដោយគិតថា នឹងធ្វើសមណធម៌ គួរអញទៅក្នុងទីនោះ ទើបហៅមហារាជទាំង ៤ ហើយបញ្ជូនទៅដោយពាក្យថា នែបាទាំងឡាយ ចូរពួកអ្នកទៅ ចូរដេញបក្សីដែលមានសំឡេងជាទោសក្បែរព្រៃ នៃវិហារឲ្យគេចទៅមហារាជទាំងឡាយនោះ ធ្វើតាមនោះហើយ ក៏នាំគ្នារក្សាដោយជុំវិញ ។ សក្ក-

ទេវរាជទ្រង់ប្រាប់ចន្ទទេវបុត្រ និងសុរិយទេវបុត្រថា ចូរពួកអ្នកបញ្ឈប់វិមានរបស់ខ្លួនសិន ចន្ទទេវបុត្រ និងសុរិយទេវបុត្រក៏ធ្វើតាមនោះហើយ សក្កៈខ្លួនឯងក៏ទ្រង់រក្សាត្រង់សន្ទះទ្វារ វិហារស្ងប់ស្ងាត់ប្រាសចាកសំឡេង ។ សាមណេរចម្រើនវិបស្សនាដោយចិត្តមានអារម្មណ៍មួយ សម្រេចមគ្គ និងផល ៣ ។

ព្រះថេរៈ កាលសាមណេរពោលថា សូមលោកម្ចាស់នាំភោជនមានរសមួយរយមក ដូច្នេះហើយ ក៏គិតថា អាត្មាអញអាចបានក្នុងត្រកូលរបស់អ្នកណាហ្ន៎ ពិចារណាក៏ឃើញត្រកូលឧបដ្ឋាកសម្បូរដោយអាធ្យាស្រ័យមួយ ទើបទៅក្នុងត្រកូលនោះ កាលជនទាំងនោះមានចិត្តត្រេកអរថា បពិត្រលោកម្ចាស់ជាការល្អណាស់ដែលលោកម្ចាស់មកក្នុងទីនេះ ក្នុងថ្ងៃនេះ ទទួលបាត្រ និមន្តឲ្យគង់ប្រគេនយាគូ និងរបស់ទំពាហើយ គេអារាធនាឲ្យធ្វើភត្តាហារ ទើបពោលសារាណីយធម្មកថាដល់ជនទាំងនោះ កំណត់កាលញុំាងធម្មទេសនាឲ្យចប់ហើយ។ ពេលនោះ ទើបជនទាំងឡាយប្រគេនភោជន មានរសមួយរយដល់ព្រះថេរៈនោះ ឃើញព្រះថេរៈទទួលភោជននោះហើយ បំណងត្រឡប់ ទើបប្រាប់ថា សូមនិមន្តឆាន់ចុះ ពួកខ្ញុំប្រគេនភោជនបែបនេះទៀត ឲ្យព្រះថេរៈឆាន់ហើយ ក៏ប្រគេនដកាបពេញបាត្រទៀត ។ ព្រះថេរៈទទួលភោជននោះហើយ ក៏ប្រញាប់ទៅវិហារដោយគិតថា សាមណេររបស់អញឃ្លានហើយ ។ ថ្ងៃនោះ ព្រះសាស្ដា យាងចេញប្រថាប់គង់ក្នុងព្រះគន្ធកុដិអំពីព្រលឹម ទ្រង់អាវជ្ជនៈថា ថ្ងៃនេះ សុខសាមណេរ ឲ្យបាត្រ និងចីវរដល់ឧបជ្ឈាយ៍ហើយ ត្រឡប់មក ដោយតាំងចិត្តថា នឹងធ្វើសមណធម៌ កិច្ចរបស់សាមណេរសម្រេច

ហើយឬហ្ន៎ ទ្រង់ឃើញត្រឹមតែមគ្គ និងផលទាំង ៣ ដែលសាមណេរសម្រេចហើយ ទើបទ្រង់ពិចារណាក្រៃលែងឡើងថា សុខសាមណេរនេះ អាចសម្រេចអរហត្តក្នុងថ្ងៃនេះដែរឬហ្ន៎ ចំណែកសារីបុត្តនាំកត្តហើយ ក៏រូតរះដោយគិតថា សាមណេររបស់អញឃ្លានហើយ បើសាមណេរនេះមិនទាន់សម្រេចអរហត្ត សារីបុត្តនាំកត្តមកមុន អន្តរាយនឹងមានដល់សាមណេរនេះតថាគតគួរទៅរក្សាត្រង់ខ្លោងទ្វារ ។ កាលទ្រង់ព្រះតម្រិះហើយ ទើបយាងចេញអំពីគន្ធកុដិ ប្រថាប់ឈរធ្វើការរក្សាត្រង់ខ្លោងទ្វារ ។ ចំណែកព្រះថេរៈនាំកត្តមក ។ គ្រានោះ ព្រះសាស្តាត្រាស់សួរប្រស្នា ៤ នឹងព្រះថេរៈនោះដោយន័យដែលពោលហើយខាងដើមនោះឯង ។ ក្នុងទីបំផុតនៃការវិសជ្ជនាបញ្ហា សាមណេរក៏សម្រេចអរហត្តហើយ ។

ព្រះសាស្តាត្រាស់ហៅព្រះថេរៈមកហើយ ត្រាស់ថា សារីបុត្ត ចូរអ្នកទៅចុះ ចូរឲ្យកត្តដល់សាមណេររបស់អ្នក ។ ព្រះថេរៈទៅដល់ហើយ គោះទ្វារ សាមណេរចេញមកធ្វើវត្តដល់ឧបជ្ឈាយ៍ហើយ កាលព្រះថេរៈប្រាប់ថា ចូរធ្វើភត្តកិច្ចចុះ ក៏ដឹងថា ព្រះថេរៈមិនត្រូវការដោយកត្ត កុមារអាយុ ៧ ឆ្នាំសម្រេចអរហត្តក្នុងខណៈនោះឯង ពិនិត្យមើលទីអង្គុយទាបជាង ធ្វើភត្តកិច្ចហើយ ក៏លាងបាត្រ ។ ក្នុងកាលនោះ មហារាជទាំង ៤ នាំគ្នាលើកការរក្សាសូម្បីចន្ទទេវបុត្រ និងសុរិយទេវបុត្រ ក៏លែងនូវវិមានរបស់ខ្លួន សូម្បីសក្កៈក៏ទ្រង់លើកការរក្សាត្រង់សន្ទះទ្វារ ព្រះអាទិត្យប្រាកដអណ្តែតលយលឿនជ្រេទៅហើយ ។

ភិក្ខុទាំងឡាយនាំគ្នាពោលថា កាលល្ងាចប្រាកដ សាមណេរធ្វើកត្តកិច្ច អម្បាញ់មិញនេះឯង ហេតុអ្វីហ្ន៎ ទើបថ្ងៃនេះ ពេលព្រឹកមានច្រើន ពេលល្ងាចមានតិច ។ ព្រះសាស្តាយាងមក សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយកថាអ្វីហ្ន៎ កាលភិក្ខុទាំងឡាយទូលថា បពិត្រព្រះអង្គ ថ្ងៃនេះ ពេលព្រឹកមានច្រើន ពេលល្ងាចមានតិច សាមណេរទើបតែធាន់អម្បាញ់មិញនេះឯង ហេតុអ្វី ទើបព្រះអាទិត្យអណ្តែតលយលឿនជ្រេទៅ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងពេលធ្វើសមណធម៌របស់អ្នកមានបុណ្យទាំងឡាយ រមែងដូច្នោះឯង ក្នុងថ្ងៃនេះ មហារាជទាំង ៤ រក្សាដោយជុំវិញ ចន្ទទេវបុត្រ និងសុរិយទេវបុត្រ បញ្ឈប់វិមានរបស់ខ្លួន សក្កទេវរាជរក្សាត្រង់សន្ទះទ្វារ តថាគតរក្សាត្រង់ខ្លោងទ្វារ ថ្ងៃនេះ សុខ-សាមណេរឃើញមនុស្សបង្ហូរទឹកចូលប្រឡាយ ជាងព្រួញពត់ព្រួញឲ្យត្រង់ ជាងឈើចាំងនូវទព្វសម្ភារៈទាំងឡាយ មានកង់រថជាដើមហើយ ក៏ទូន្មានខ្លួនសម្រេចអរហត្តហើយ ទើបត្រាស់ព្រះគាថានេះថា

**ឧទកំ ហិ នយន្តិ នេត្តិកា ឧសុការា នមយន្តិ តេជនំ**
**ទារុំ នមយន្តិ តច្ឆកា អត្តានំ ទមយន្តិ សុព្វតា ។**

ធម្មតាអ្នកបង្ហូរ តែងបង្ហូរទឹក អ្នកធ្វើព្រួញ តែងពត់ព្រួញ (ឲ្យត្រង់) អ្នកចាំង តែងចាំងឈើ អ្នកមានវត្តល្អ តែងទូន្មានខ្លួន ។

# សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **សុព្វតា** សេចក្ដីថា ប្រដៅងាយ គឺគប្បីទូន្មាន គប្បីអនុសាសន៍ដោយស្រួល ។ ពាក្យដ៏សេស មានន័យដូចពោលហើយខាងដើមនោះឯង ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ៕

**រឿងសុខសាមណេរ ចប់**

**ទណ្ឌវគ្គ ចប់**

**វគ្គទី ១០ ចប់**

# សុត្តន្តបិដក

## ធម្មបទគាថា ជរាវគ្គទី ១១

[ ២១ ] កាលបើលោកសន្និវាស ត្រូវភ្លើង មានរាគៈជាដើម ឆេះទ្រលោមជានិច្ច ម្តេចក៏សើច ម្តេចក៏ត្រេកត្រអាល អ្នកទាំងឡាយ ត្រូវងងឹតគឺអវិជ្ជារួបរឹតហើយ ( ម្តេចឡើយ ) ក៏មិនស្វែងរកប្រទីប គឺប្រាជ្ញា ។

អត្តភាពណា មិនទៀងទាត់ ស្ថិតស្ថេរ អ្នកចូរមើលអត្តភាព ( នោះ ) ដែលកុសលាកុសលកម្ម ធ្វើវិចិត្រហើយ ជាកាយពាសពេញ ដោយដំបៅដែលឆ្អឹង ៣០០ កំណាត់ ផ្គុំគ្នាហើយ ជាអត្តភាពក្តៅក្រហាយជានិច្ច ជាទីពឹងត្រិះរិះរបស់ជនច្រើនគ្នា ។

រូបនេះ គ្រាំគ្រាអស់ហើយ ជាទីសម្នាក់នៃរោគ ជារបស់ពុកផុយ រាងកាយជារបស់ស្អុយ ( នេះ ) តែងបែកធ្លាយទៅវិញ ព្រោះថា ជីវិតមានសេចក្តីស្លាប់ជាទីបំផុត ។

ឆ្អឹងទាំងឡាយណា មានសម្បុរដូចសត្វព្រាប ដែលគេចោលហើយ ដូចផ្លែឃ្លោកក្នុងសរទកាល សេចក្តីត្រេកអរអ្វីហ្ន៎ ( របស់អ្នកទាំងឡាយ ) ព្រោះតែឃើញឆ្អឹងទាំងឡាយនោះ ។

សេចក្តីគ្រាំគ្រា សេចក្តីស្លាប់ សេចក្តីប្រកាន់ខ្លួន និងសេចក្តីលុបគុណប្រជុំចុះក្នុងសរីរៈណា ( សរីរៈនោះ ) ដែលកុសលាកុសលកម្ម ធ្វើហើយឲ្យជានគររបស់ឆ្អឹងទាំងឡាយ ជាគ្រឿងប្រឡាក់ដោយសាច់ និងឈាម ។ រាជរថទាំងឡាយ ដ៏វិចិត្រល្អ រមែងគ្រាំគ្រា សូម្បីសរីរៈ ក៏ដល់នូវសេចក្តី

គ្រាំគ្រាដូចគ្នា ទើបឯធម៌របស់សប្បុរសទាំងឡាយ មិនដល់នូវសេចក្តីគ្រាំគ្រា ( ដូច្នោះ ) ទេ សប្បុរសទាំងឡាយ តែងនិយាយឲ្យពួកសប្បុរសផងគ្នាដឹងបាន ។ បុរសអ្នកមិនមានការចេះដឹងនេះ តែងចាស់ ( ឥតអំពើ ) ដូចគោបម្រើ សាច់របស់វា តែងចម្រើនឡើង តែប្រាជ្ញារបស់វា មិនចម្រើនឡើយ ។ កាលតថាគតមិនទាន់ជួបប្រទះ ( ពោធិញ្ញាណ វល់តែ ) ស្វះស្វែងរកជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្តភាព ក៏អន្ទោលទៅកាន់សង្សារវដ្តមានជាតិដ៏ច្រើន សេចក្តីកើត ជាទុក្ខរឿយៗ ។

នែជាងផ្ទះ អ្នកឯងធ្វើផ្ទះ គឺអត្តភាព តថាគតឃើញហើយ អ្នកនឹងធ្វើផ្ទះ ( របស់តថាគត ) ទៀត មិនបានឡើយ ឆ្អឹងជំនីរ គឺកិលេសរបស់អ្នកទាំងអស់ តថាគតកាច់បំបាក់អស់ហើយ ដំបូលផ្ទះ គឺអវិជ្ជា តថាគតកម្ចាត់ចោលហើយ ចិត្តរបស់តថាគត ដល់ព្រះនិព្វានដែលមានសង្ខារប្រាសហើយ តថាគតបានដល់ធម៌ ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ។

ជនពាលទាំងឡាយ មិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានទ្រព្យ ក្នុងកាលខ្លួននៅជាកំលោះក្រមុំ រមែងសញ្ជប់សញ្ជឹង ដូចសត្វក្រៀលចាស់សំកុកនៅក្នុងកក់ ដែលអស់ត្រីហើយ ។

ជនពាលទាំងឡាយ មិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានទ្រព្យក្នុងកាលខ្លួននៅកំលោះក្រមុំ រមែងដេកថ្ងូរ សោកស្តាយទ្រព្យចាស់ទាំងឡាយ ដូចព្រួញដែលផុតចាកខ្សែធ្នូ ដូច្នោះ ។

**ជរាវគ្គទី ១១ ចប់**

# អដ្ឋកថា
# ជរាវគ្គទី ១១

## រឿង ស្រីសម្លាញ់របស់នាងវិសាខា
### លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធពួកស្រីដែលជាសម្លាញ់របស់នាងវិសាខា ត្រាស់ព្រះធម្មទេសនានេះថា **កោ នុ ហាសោ កិមានន្ទោ** ជាដើម ។

បានឮថា កុលបុត្រ ៥០០ នាក់ ក្នុងនគរសាវត្ថី បានប្រគល់ភរិយារបស់ខ្លួននឹងនាងវិសាខាឧបាសិកា ដោយបំណងថា ដោយឧបាយយ៉ាងនេះ ភរិយាទាំងនេះ នឹងជាបុគ្គលនៅដោយសេចក្តីមិនប្រមាទ ។ ស្រីទាំងនោះ កាលទៅឧទ្យានក្តី ទៅវិហារក្តី រមែងទៅជាមួយនាងវិសាខានោះឯង ។

សម័យមួយ កាលគេឃោសនាមហោស្រពថា នឹងមានការលេងមហោស្រព ទាក់ទងដោយសុរា ៧ ថ្ងៃ ស្រីទាំងនោះក៏ត្រៀមសុរាដើម្បីប្តីរៀងៗ ខ្លួន ប្តីទាំងនោះលេងមហោស្រព ដែលទាក់ទងនឹងស្រាអស់ ៧ ថ្ងៃហើយ ក្នុងថ្ងៃទី ៨ បានចេញទៅដើម្បីធ្វើការងារ ។

ស្រីទាំងនោះបបួលគ្នាថា ពួកយើងមិនបានផឹកស្រាចំពោះមុខប្តី ឯស្រាដែលសល់នៅមាន យើងទាំងឡាយនឹងផឹកស្រានេះដោយវិធីដែលប្តីទាំងនោះ

មិនដឹង ដូច្នេះហើយ ទើបទៅក្នុងសម្នាក់របស់នាងវិសាខាពោលថា បពិត្រអ្នកនាង យើងទាំងឡាយចង់លេងក្នុងឧទ្យាន កាលនាងវិសាខាឆ្លើយថា ប្រពៃណាស់អ្នកទាំងឡាយ បើដូច្នោះ ចូរធ្វើកិច្ចដែលគួរធ្វើស្រេចហើយសឹមទៅ ។ បានទៅជាមួយនាងវិសាខានោះ លាក់ស្រាដោយអាការមិនឲ្យអ្នកដទៃឃើញ ផឹករហូតស្រវឹងហើយ ដើរទៅក្នុងឧទ្យាន ។ នាងវិសាខាគិតថា ស្រីទាំងនេះធ្វើកម្មមិនសមគួរ ពេលនេះ សូម្បីពួកតិត្ថិយក៏នឹងតិះដៀលបានថា សាវិកាទាំងឡាយរបស់ព្រះគោតមផឹកស្រាដើរទៅ ទើបពោលនឹងស្រីទាំងនោះថា នែនាង នាងទាំងឡាយធ្វើកម្មមិនសមគួរ នាំឲ្យកើតអាប់យសដល់ខ្ញុំផង សូម្បីប្តីរបស់នាងក៏ខឹងនឹងពួកនាង ឥឡូវនេះ ពួកនាងនឹងធ្វើដូចម្តេច ស្រីទាំងនោះឆ្លើយថា បពិត្រអ្នកនាង ខ្ញុំនឹងពុតធ្វើជាឈឺ ទើបនាងវិសាខាពោលថា បើដូច្នោះ ពួកនាងក៏នឹងប្រាកដដោយកម្មរបស់ខ្លួន ។ ស្រីទាំងនោះ ទៅដល់ផ្ទះហើយ ពុតជាឈឺ ពេលនោះ ប្តីរបស់ស្រីទាំងនោះសួរថា ស្រីឈ្មោះនេះៗ ទៅណា បានឮថា ឈឺ ក៏កំណត់សេចក្តីបានថា ស្រីទាំងនេះ ផឹកស្រាដែលសល់ពិត ទើបវាយស្រីទាំងនោះឲ្យដល់នូវការវិនាស ។ ក្នុងកាលមហោស្រពក្រោយមកទៀត ស្រីទាំងនោះចង់ផឹកស្រាយ៉ាងនោះទៀត ទើបចូលទៅរកនាងវិសាខា ពោលថា បពិត្រអ្នកនាង សូមនាំខ្ញុំទៅលេងឧទ្យានចុះ ត្រូវនាងវិសាខាឃាត់ថា ក្នុងកាលមុន នាងទាំងឡាយ ធ្វើឲ្យអាប់មុខមាត់ដល់ខ្ញុំ ចូរនាងទៅឯងចុះ ខ្ញុំមិននាំទៅឡើយ បាននិយាយយកចិត្តថា ពេលនេះ ពួកខ្ញុំមិនធ្វើយ៉ាងនោះឡើយ ហើយចូលទៅរកនាងវិសាខា ពោលជាថ្មីថា

យើងទាំងឡាយបំណាននឹងធ្វើពុទ្ធបូជា សូមនាំយើងទាំងឡាយ ទៅវិហារចុះ ទើបនាងពោលថា នែនាង ឥឡូវនេះ សមគួរពិត នាងទាំងឡាយ ចូរទៅរៀបចំត្រៀមខ្លួនចុះ ។ ស្រីទាំងនោះ ឲ្យមនុស្សកាន់គ្រឿងក្រអូប និងកម្រងផ្កាជាដើម ដោយប្រអប់ដាក់ដបមានសណ្ឋានដូចដៃដែលក្តាប់ ពេញដោយសុរាដោយដៃទាំងពីរ ដណ្តប់សំពត់ផ្ទាំងធំ ចូលទៅរកនាងវិសាខា ហើយចូលទៅកាន់វិហារ មួយអន្លើដោយនាងវិសាខានោះ អង្គុយក្នុងចំណែកម្ខាង ផឹកស្រាដោយដប ដែលមានសណ្ឋានដូចដៃដែលក្តាប់នោះឯង ហើយគ្រវែងដបចោល អង្គុយត្ពោះព្រះភក្ត្រព្រះសាស្តា ក្នុងរោងធម្មសភា ។ នាងវិសាខាក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់សម្តែងធម៌ដល់ស្រីទាំងនេះ ។ ឯស្រីទាំងនោះ មានខ្លួនញ័រដោយអំណាចស្រវឹង កើតគំនិតឡើងថា យើងទាំង-ឡាយ នឹងរាំ នឹងច្រៀង ។

លំដាប់នោះ ទេវតាមួយអង្គដែលទាក់ទងក្នុងពួកមារ គិតថា ឥឡូវនេះ អញនឹងសណ្ឋិតក្នុងសរីរៈរបស់ស្រីទាំងនេះហើយ នឹងសម្តែងប្រការដែលប្លែកចំពោះព្រះភក្ត្រព្រះសមណគោតម ហើយចូលសណ្ឋិតក្នុងសរីរៈរបស់ស្រីទាំងនោះ បណ្តាស្រីទាំងនោះ ពួកខ្លះផ្តើមទះដៃសើច ពួកខ្លះដើររាំចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគ ។ ព្រះសាស្តាទ្រង់អាវជ្ជនៈថា តើមានរឿងអ្វីហ្ន៎ ទ្រង់ជ្រាបហេតុនោះហើយ ទ្រង់ព្រះតម្រិះថា ឥឡូវនេះ តថាគតនឹងមិនឲ្យទេវតាដែលទាក់ទងក្នុងពួកមារបានឱកាស ព្រោះតថាគត កាលបំពេញបារមីអស់កាលប៉ុណ្ណោះ មិនមែនដើម្បីឲ្យពួកទេវតា ដែលជាបក្ខពួករបស់មារបាន

ឱកាសឡើយ ដើម្បីឲ្យស្រីទាំងនោះសង្វេគ ទើបទ្រង់បញ្ចេញព្រះរស្មីអំពីព្រះលោមា ក្នុងវេលាងចនោះចិញ្ចើម រំពេចនោះឯង ងងឹតអន្ធការមានហើយ ។ ស្រីទាំងនោះភ័យខ្លាច កាលមរណភ័យគំរាមហើយ ដោយហេតុនោះ ទើបស្រាក្នុងពោះរបស់ស្រីទាំងនោះស្វាងទៅ ។ ព្រះសាស្តាទ្រង់បាត់ទៅ ត្រង់បល្ល័ង្កដែលប្រថាប់គង់ ទ្រង់ប្រថាប់ឈរលើកំពូលភ្នំសិនេរុ ទ្រង់បញ្ចេញព្រះរស្មីអំពីព្រះឧណ្ណាលោម ។ ខណៈនោះ ពន្លឺ មានដូចព្រះចន្ទមួយពាន់ដួង ។ ព្រះសាស្តាត្រាស់ហៅស្រីទាំងនោះមកហើយ ត្រាស់ថា ពួកនាងកាលមកកាន់សម្នាក់របស់តថាគត ប្រមាទហើយ មក មិនគួរ ព្រោះការប្រមាទរបស់ពួកនាងនោះឯង ទើបទេវតាដែលជាបក្សពួកនៃមារបានឱកាសឲ្យពួកនាងធ្វើកាយវិការ មានសើចជាដើមក្នុងទីដែលមិនគួរធ្វើកាយវិការ មានសើចជាដើម ឥឡូវនេះ ពួកនាងធ្វើសេចក្តីឧស្សាហ៍ ដើម្បីប្រាជ្ញាឲ្យភ្លើងរាគៈជាដើមរលត់ទៅ ទើបគួរ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**កោ នុ ហាសោ កិមានន្ទោ និច្ចំ បជ្ជលិតេ សតិ**
**អន្ធការេន ឱនទ្ធា បទីបំ ន គវេសថ ។**

កាលបើលោកសន្និវាស ត្រូវភ្លើង មានរាគៈជាដើម
ឆេះទ្រលោមជានិច្ច ម្តេចក៏សើច ម្តេចក៏ត្រេក-
ត្រអាល អ្នកទាំងឡាយត្រូវងងឹត គឺអវិជ្ជារួបរឹតហើយ
( ម្តេចឡើយ ) ក៏មិនស្វែងរកប្រទីប គឺប្រាជ្ញា ។

# សេចក្តីអធិប្បាយ

ការត្រេកអរ ឈ្មោះថា **អានន្ទោ** ក្នុងព្រះគាថានោះ ។ ព្រះដ៏មានព្រះភាគ ត្រាស់អធិប្បាយដូច្នេះថា កាលលោកសន្និវាសនេះ ដែលភ្លើង ១១ យ៉ាង មានរាគៈជាដើមឆេះសន្ធោសន្ធៅហើយជានិច្ច អ្នកទាំងឡាយ រវល់តែត្រេកអរ ឬរីករាយអ្វីហ្ន៎ នុ៎ះមិនសមគួរធ្វើឡើយ មិនមែនឬ អ្នកទាំងឡាយដែលងងឹត គឺអវិជ្ជាដែលមានវត្ថុ ៨ គ្របដណ្តប់ ហេតុអ្វី ទើបមិនស្វែងរក គឺមិនធ្វើប្រទីប គឺញាណ ដើម្បីប្រយោជន៍ដល់ការកម្ចាត់ងងឹតនោះ ។

ក្នុងកាលចប់ទេសនា ស្រី ៥០០ តាំងនៅក្នុងសោតាបត្តិផលហើយ ព្រះសាស្តា ទ្រង់ជ្រាបសេចក្តីដែលស្រីទាំងនោះជាអ្នកតាំងមាំនៅក្នុងអចល-សទ្ធាហើយ ទ្រង់ចុះអំពីកំពូលភ្នំសិនេរុ ប្រថាប់គង់លើពុទ្ធាសនៈ ។

លំដាប់នោះ នាងវិសាខាបានក្រាបទូលព្រះពុទ្ធអង្គថា បពិត្រព្រះអង្គ ឈ្មោះថា សុរានេះ អាក្រក់ថោកទាប ព្រោះថា ស្រីទាំងនេះ មានសភាពបែបនេះ អង្គុយត្រង់ព្រះភក្ត្រព្រះសម្ពុទ្ធដូចទ្រង់ គង់មិនអាចញុំាងត្រឹមតែឥរិយាបថឲ្យរៀបរយបាន ក្រោកឡើងទះដៃ ធ្វើការសើច ច្រៀង និងរាំជាដើម ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលនាងវិសាខា យ៉ាងនោះឯងឈ្មោះថា សុរានេះ អាក្រក់ពិត ព្រោះមហាជនអាស្រ័យសុរានេះ ដល់នូវសេចក្តីវិនាសច្រើនរយ កាលនាងវិសាខាក្រាបទូលថា បពិត្រព្រះអង្គ សុរានេះ កើតឡើងក្នុងកាលណា ដើម្បីនឹងត្រាស់ឧប្បត្តិហេតុនៃសុរានោះដល់នាងវិសាខាដោយពិស្តារ ទើបទ្រង់នាំអតីតនិទានមក ហើយត្រាស់កុម្ភជាតក ដូច្នេះឯង ។៚

# រឿង នាងសិរិមា

## លំនាំដើម

*ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធនាងសិរិមា ត្រាស់ព្រះធម្មទេសនានេះថា* **បស្ស ចិត្តកតំ ពិម្ពំ** *ជាដើម ។*

*បានឮថា នាងសិរិមានោះ មានរូបស្អាត ជាស្រីនគរសោភិនីក្នុងក្រុងរាជគ្រឹះ ខាងក្នុងវស្សាមួយ បានប្រទូស្តចំពោះឧបាសិកាឈ្មោះឧត្តរា ដែលជាធីតារបស់បុណ្ណកសេដ្ឋី ដែលជាភរិយារបស់សុមនសេដ្ឋីបុត្រ បំណាច់នឹងឲ្យនាងឧត្តរានោះជ្រះថ្លា ទើបទូលសូមខមាទោសជាមួយព្រះសាស្តា ទ្រង់ធ្វើភត្តកិច្ច ជាមួយភិក្ខុសង្ឃស្រេចហើយ ក្នុងផ្ទះរបស់នាងឧត្តរានោះ ក្នុងថ្ងៃនោះ បានស្តាប់ភត្តានុមោទនារបស់ព្រះទសពល សម្រេចសោតាបត្តិផល ហើយក្នុងកាលចប់ព្រះគាថា ដែលទ្រង់សម្តែងថា*

> *បុគ្គលគប្បីផ្ចាញ់ មនុស្សក្រោធ ដោយសេចក្តីមិនក្រោធ គប្បីផ្ចាញ់មនុស្សអសប្បុរស ដោយសប្បុរស គប្បីផ្ចាញ់មនុស្សកំណាញ់ ដោយការឲ្យ គប្បីផ្ចាញ់មនុស្សនិយាយពាក្យមិនពិត ដោយពាក្យពិត ។*

*នេះជាសេចក្តីសង្ខេបក្នុងរឿងនេះ ចំណែកសេចក្តីពិស្តារមានច្បាស់ក្នុងគាថាអនុមោទនានៃកោធវគ្គនោះឯង ។ នាងសិរិមានោះ កាលសម្រេចសោតាបត្តិផលយ៉ាងនោះហើយ និមន្តព្រះទសពល ស្អែកឡើង ថ្វាយទានជាច្រើន ហើយបានតាំងអដ្ឋកភត្ត គឺសលាកភត្តសម្រាប់ភិក្ខុ ៨ អង្គជាប្រចាំ ។ តាំង*

អំពីថ្ងៃដំបូងមក ភិក្ខុ ៨ រូប ទៅកាន់ផ្ទះនាងជានិច្ច ។ នាងពោលថា និមន្ត លោកម្ចាស់ទាំងឡាយទទួលសប្បិ សូមលោកម្ចាស់ទទួលទឹកដោះ ដូច្នេះជាដើម ហើយ ដាក់កត្តពេញបាត្ររបស់ភិក្ខុទាំងនោះ ។ អាហារបិណ្ឌបាត ដែលភិក្ខុ មួយរូបបានហើយ រមែងគ្រប់គ្រាន់ដល់ភិក្ខុ ៣ រូបខ្លះ ៤ រូបខ្លះ ។ នាង ថ្វាយបិណ្ឌបាតដោយការចំណាយទ្រព្យ ១៦ កហាបណៈរាល់ថ្ងៃ ។ ថ្ងៃមួយ ភិក្ខុមួយរូបបានឆាន់អដ្ឋកកត្តក្នុងផ្ទះរបស់នាងហើយ បានទៅវិហារមួយកន្លែង ក្នុង ទីចម្ងាយ ៣ យោជន៍ ។ គ្រានោះ ពួកភិក្ខុសួរលោក ដែលអង្គុយក្នុងទី បម្រើព្រះថេរៈក្នុងពេលល្ងាចថា អាវុសោ ទៅទទួលភិក្ខាក្នុងទីណា លោក ឆ្លើយថា ខ្ញុំទៅឆាន់អដ្ឋកកត្តរបស់នាងសិរិមា ។ ពួកភិក្ខុសួរទៀតថា នាងធ្វើ របស់គួរពេញចិត្តប្រគេនដែរឬ ។

ទើបភិក្ខុនោះពោលគុណរបស់នាងថា ខ្ញុំមិនអាចពណ៌នាកត្តរបស់នាង បានទេ នាងធ្វើប្រគេនដ៏ប្រណីត កត្តដែលភិក្ខុមួយរូបបានទទួល រមែងគ្រប់ គ្រាន់ដល់ភិក្ខុ ៣ រូបខ្លះ ៤ រូបខ្លះ តែការបានឃើញនាងនោះឯងល្អក្រៃលែង ជាងទេយ្យធម៌របស់នាងទៅទៀត ព្រោះនាងស្អាតបែបនេះៗ គ្រានោះ ភិក្ខុមួយ រូប បានស្តាប់ពាក្យដែលពណ៌នាគុណរបស់នាង កើតសេចក្តីស្រឡាញ់ឡើង ហើយ ដោយមិនទាន់បានឃើញផង គិតថា គួរតែអញទៅមើលនាង ហើយ ប្រាប់ចំនួនវស្សារបស់ខ្លួនហើយ សួរលំដាប់ជាមួយភិក្ខុនោះហើយ បានឮថា អាវុសោ ស្អែកនេះ លោកជាព្រះសង្ឃត្ថេរ នឹងបានអដ្ឋកកត្តក្នុងផ្ទះនោះ ទើបទាញបាត្រ និងចីវរ ចៀសចេញទៅក្នុងខណៈនោះឯង ។ កាលអរុណរះ

ឡើងអំពីព្រលឹម ចូលទៅកាន់រោងកត្តុរង់ចាំហើយ ជាព្រះសង្ឃត្ថេរ បាន អង្គុកកត្តក្នុងផ្ទះរបស់នាង ។

ក្នុងកាលដែលភិក្ខុនោះឆាន់ហើយ ចៀសចេញទៅកាលពីម្សិលមិញនោះឯង រោគបានកើតឡើងក្នុងសរីរៈរបស់នាង ដូច្នោះ ទើបនាងដោះគ្រឿងអាករណៈចេញហើយដេក ។ ពួកទាសីរបស់នាង ឃើញភិក្ខុទាំងឡាយបានអង្គុកកត្តមកហើយ ទើបប្រាប់ដល់នាង នាងមិនអាចទទួលបាត្រ ហើយនិមន្តឲ្យគង់ ឬអង្គាសដោយដៃរបស់ខ្លួនបាន ទើបប្រាប់ពួកទាសីថា នែនាងទាំង-ឡាយ ពួកនាងទទួលបាត្រហើយ និមន្តលោកម្ចាស់ឲ្យគង់ ឲ្យឆាន់បបរប្រគេនរបស់ទំពាក្នុងកាលឆាន់កត្ត ចូរដាក់កត្តឲ្យពេញបាត្រ ហើយប្រគេនចុះ ទាសីទាំងនោះទទួលថា សាធុ អ្នកនាង ហើយនិមន្តភិក្ខុទាំងឡាយឲ្យចូលមក ឲ្យឆាន់បបរ ប្រគេនខាទនីយៈ ក្នុងពេលឆាន់កត្ត ដាក់កត្តពេញបាត្រហើយ ប្រាប់ដល់នាង នាងពោលថា ចូរជួយគ្រាហ៍ខ្ញុំទៅកាន់ទីនោះ ខ្ញុំនឹងថ្វាយបង្គំលោកម្ចាស់ទាំងឡាយ ។ ទាសីទាំងនោះ គ្រាហ៍ទៅកាន់ទីជិតភិក្ខុទាំងឡាយហើយ បានថ្វាយបង្គំភិក្ខុទាំងឡាយ ទាំងមានខ្លួនញ័រ ភិក្ខុនោះសម្លឹងមើលនាងហើយ គិតថា ការស្អាតនៃរូបរបស់ស្រីដែលមានជំងឺនេះ គង់ស្អាតដល់ម្ល៉េះ ក្នុងកាលមិនទាន់ឈឺ រូបសម្បត្តិរបស់នាងដែលតាក់តែងហើយ ដោយអាករណៈគ្រប់យ៉ាង នឹងស្អាតប៉ុនណាហ្ន៎ ។ កាលនោះ កិលេសដែលលោកសន្សំច្រើនកោដិឆ្នាំកម្រើកហើយ ។ ភិក្ខុនោះ មិនមានចិត្តទៅកាន់ទីដទៃ គឺមានចិត្តបាញ់ឆ្ពោះនាងប៉ុណ្ណោះ មិនអាចឆាន់អាហារបាន

ទើបកាន់បាត្រត្រឡប់ទៅវិហារ បិទបាត្រទុកក្នុងចំណែកម្ខាង ក្រាលចីវរសិង ហើយ ។ លំដាប់នោះ ភិក្ខុជាសម្លាញ់របស់លោកមួយរូប សូម្បីអង្វរ ក៏មិនអាចឲ្យលោកឆាន់បាន ភិក្ខុនោះបានអត់អាហារហើយ ។

ក្នុងពេលល្ងាចនោះឯង នាងសិរិមាបានធ្វើកាលកិរិយាហើយ ។ ព្រះរាជាទ្រង់បញ្ជូនព្រះរាជសាសន៍ទៅថ្វាយព្រះសាស្តាថា បពិត្រព្រះអង្គ នាងសិរិមាប្អូនស្រីរបស់ពេទ្យជីវក បានធ្វើកាលកិរិយាហើយ ។ ព្រះសាស្តាទ្រង់ស្តាប់រឿងនោះ ទើបបញ្ជូនដំណឹងទៅកាន់ព្រះរាជាថា កិច្ច គឺការបូជាសពនាងសិរិមា កុំទាន់មានឡើយ ព្រះសាស្តាទ្រង់ត្រាស់ឲ្យយកសពនាងសិរិមានោះដាក់ក្នុងព្រៃខ្មោចស្រស់ហើយ ឲ្យរក្សា ដោយក្អែក និងឆ្កែជាដើមស៊ីមិនបាន ។ ព្រះរាជាទ្រង់បានធ្វើតាមព្រះតម្រាស់ហើយ ។ ៣ ថ្ងៃកន្លងទៅហើយដោយលំដាប់ ក្នុងថ្ងៃទី ៤ សរីរៈហើមប៉ោងហើយ ។ ពួកដង្កូវហូរចេញអំពីទ្វារទាំង ៩ ។ សរីរៈទាំងមូល បានបែកធ្លាយដូចថាសស្រូវសាលី ដូច្នោះព្រះរាជាឲ្យពួករាជបុរស វាយស្គរឃោសនាក្នុងព្រះនគរថា វៀរកុមារតូចៗ និងអ្នកចាំផ្ទះ អ្នកណាមិនមកមើលនាងសិរិមា ត្រូវពិន័យ ៨ កហាបណៈ ។ ហើយបានបញ្ជូនព្រះរាជសាសន៍ទៅកាន់សម្នាក់ព្រះសាស្តាថា សូមភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន និមន្តមកមើលនាងសិរិមា ព្រះសាស្តាត្រាស់ឲ្យផ្តៀងដល់ភិក្ខុទាំងឡាយថា យើងទាំងឡាយនឹងទៅមើលនាងសិរិមា ។ ភិក្ខុកំលោះរូបនោះ មិនស្តាប់ពាក្យរបស់បុគ្គលណាឡើយអស់ ៤ ថ្ងៃ អត់អាហារ សិងទទូរហើយ បាយក្នុងបាត្រផ្អូម ប្រែះក៏តាំងឡើងក្នុងបាត្រ ។ លំដាប់នោះ

ភិក្ខុសម្លាញ់នោះ ទើបចូលទៅរកលោកហើយ ប្រាប់ថា អាវុសោ ព្រះសាស្តា យាងទៅទតនាងសិរិមា ។ ភិក្ខុនោះ សូម្បីត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់យ៉ាងនោះ ក៏ក្រោកឡើងដោយប្រញាប់ ព្រោះបានឮពាក្យថា សិរិមានោះឯងសួរថា លោកពោលដូចម្តេច កាលភិក្ខុសម្លាញ់ឆ្លើយថា ព្រះសាស្តាយាងទៅទតនាងសិរិមា លោកទៅដែរឬទេ ទើបទទួលយ៉ាងប្រញាប់ថា ខ្ញុំទៅ ហើយចាក់បាយលាងបាត្រដាក់ក្នុងស្ពាយ បានទៅជាមួយពួកភិក្ខុ ។ ព្រះសាស្តា មានភិក្ខុចោមរោមហើយ បានប្រថាប់នាចំណែកម្ខាង ។ ភិក្ខុនីសង្ឃក្តី រាជបរិស័ទក្តី ឧបាសកបរិស័ទក្តី ឧបាសិកាបរិស័ទក្តី បានឈរម្ខាងមួយពួក ។

ព្រះសាស្តាត្រាស់សួរព្រះរាជាថា មហាបពិត្រ នេះជាអ្នកណា ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ នេះជាប្អូនស្រីរបស់ពេទ្យជីវកឈ្មោះសិរិមា ព្រះដ៏មានព្រះភាគត្រាស់ថា នេះនាងសិរិមាឬ ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ គឺនាងសិរិមា ព្រះសាស្តាត្រាស់ថា បើដូច្នោះ សូមមហាបពិត្រឲ្យរាជបុរសវាយស្គរឃោសនាក្នុងព្រះនគរថា អ្នកណាឲ្យទ្រព្យមួយពាន់ ចូរយកនាងសិរិមាទៅចុះ ។ ព្រះរាជាបានធ្វើយ៉ាងនោះហើយ បុគ្គលដែលហាមាត់ថា ខ្ញុំឬថា យើង សូម្បីតែម្នាក់ក៏មិនមាន ។ ព្រះរាជាទូលដល់ព្រះសាស្តាថា បពិត្រព្រះអង្គ ជនទាំងឡាយមិនទទួល ។ ព្រះសាស្តាត្រាស់ថា មហាបពិត្រ បើដូច្នោះ សូមទ្រង់បន្ថយតម្លៃចុះទៀត ។ ព្រះរាជាត្រាស់ឲ្យវាយស្គរឃោសនាថា អ្នកណាឲ្យទ្រព្យ ៥០០ ចូរយកទៅ មិនឃើញមានបុគ្គលណាម្នាក់ទទួលយក ទើបត្រាស់ឲ្យវាយស្គរឃោសនាថា អ្នកណាឲ្យទ្រព្យ ២៥០-២០០-

១០០-៥០-២៥ កហាបណៈ ១០ កហាបណៈ ៥ កហាបណៈ ១ កហាបណៈ កន្លះកហាបណៈ ១ បាទ ១ មាសក ១ កាកណិក ហើយយកនាងសិរិមាទៅចុះ ក៏មិនឃើញអ្នកណាទទួលយកទៅ ទើបឲ្យវាយស្គរឃោសនាថា ចូរយកទទេចុះ បុគ្គលដែលហាមាត់ថា ខ្ញុំ ឬថាយើង សូម្បីតែម្នាក់ក៏មិនមាន ។ ព្រះរាជាទូលថា បពិត្រព្រះអង្គ ឈ្មោះថា បុគ្គលដែលទទួលយកទៅ សូម្បីទទេក៏មិនមាន ។ ទើបព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយមើល មាតុគ្រាមដែលជាទីស្រឡាញ់ របស់មហាជនក្នុងកាលមុន ជនទាំងឡាយក្នុងនគរនេះ ឲ្យទ្រព្យមួយពាន់ ហើយបានអភិរម្យមួយថ្ងៃ ឥឡូវនេះ សូម្បីបុគ្គលដែលទទួលយកទទេៗ ក៏មិនមាន រូបបែបនេះ ដល់នូវការអស់ទៅ និងការសូន្យទៅហើយ ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយ មើលអត្តភាពដែលគួរខ្ពើមរអើម ដូច្នេះហើយ ត្រាស់គាថានេះថា

**បស្ស ចិត្តកតំ ពិម្ពំ អរុកាយំ សមុស្សិតំ**
**អាតុរំ ពហុសង្កប្បំ យស្ស នត្ថិ ធុវំ ឋិតិ ។**

អត្តភាពណា មិនទៀងទាត់ ស្ថិតស្ថេរ ចូរអ្នកមើលអត្តភាព ( នោះ ) ដែលកុសលាកុសលកម្មធ្វើវិចិត្រ ហើយ ជាកាយពាសពេញដោយដំបៅ ដែលឆ្អឹង ៣០០ កំណាត់ផ្គុំគ្នាហើយ ជាអត្តភាពក្តៅក្រហាយជានិច្ច ជាទីរំពឹងត្រិះរិះរបស់ជនច្រើនគ្នា ។

# សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **ចិត្តកតំ** សេចក្ដីថា មានការវិចិត្រដែលកម្មធ្វើហើយ គឺដែលកម្មធ្វើឲ្យវិចិត្រដោយវត្ថុផ្សេងៗ មានអាករណៈ គឺសំពត់ និងគ្រឿងប្រដាប់ គឺកម្រងផ្កាជាដើម ។ បទថា **ពិម្ពំ** បានដល់ នូវអត្តភាព ដែលតាំងនៅ ត្រូវបែកដោយអវយវៈទាំងឡាយតូចធំ មានចំណែកបណ្ដោយជាដើម ក្នុងឋានៈដែលសមគួរដល់ភាពជាអវយវៈបណ្ដោយជាដើម ។ បទថា **អរុកាយំ** គឺមានកាយជាមុខដំបៅ ដោយអំណាចទ្វារទាំង ៩ ។ បទថា **សមុស្សិតំ** គឺឆ្អឹង ៣០០ កំណាត់លើកឡើងហើយ ។ បទថា **អាតុរំ** សេចក្ដីថា ឈ្មោះថា មានជំងឺជាប្រចាំ ព្រោះជាទីដែលត្រូវបរិហារដោយឥរិយាបថជាដើម សព្វកាល ។ បទថា **ពហុសង្កប្បំ** បានដល់ ដែលមហាជនត្រិះរិះគិតហើយ ដោយច្រើន ។ បាទព្រះគាថាថា **យស្ស នត្ថិ ធុវំ ឋិតិ** សេចក្ដីថា ចូរអ្នកទាំងឡាយមើលអត្តភាពនេះ ដែលមិនមានការស្ថិតស្ថេរ ឬការមាំទាំ មានការបែករាត់រាយ និងខ្ចាត់ខ្ចាយទៅជាធម្មតាដោយចំណែកមួយ ។

ក្នុងកាលចប់ទេសនា ធម្មាភិសម័យមានហើយ ដល់សត្វ ៨៤០០០ សូម្បី ភិក្ខុនោះ ក៏បានតាំងនៅក្នុងសោតាបត្តិផលដូច្នោះឯង ៚

**រឿង ឆាងសិរិមា ចប់**

# រឿង នាងឧត្តរាថេរី

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងឧត្តរាថេរី ត្រាស់ព្រះធម្មទេសនានេះថា **បរិជិណ្ណមិទំ រូបំ** ជាដើម ។

បានឮមកថា ព្រះថេរីមានអាយុ ១២០ ឆ្នាំអំពីកំណើត ត្រាច់បិណ្ឌបាត បានបិណ្ឌបាតហើយ ឃើញភិក្ខុមួយរូបក្នុងចន្លោះផ្លូវ បានសួរដោយអើពើដោយបិណ្ឌបាត កាលភិក្ខុមិនឃាត់ ទទួលយក ក៏ប្រគេនទាំងអស់ ខ្លួននាងបានអត់អាហារហើយ សូម្បីក្នុងថ្ងៃទី ២-៣ ក៏បានប្រគេនកត្តដល់ភិក្ខុនោះឯង ក្នុងទីនោះដូចគ្នា បានអត់អាហារហើយយ៉ាងនោះ ។

ក្នុងថ្ងៃទី ៤ ព្រះថេរីត្រាច់បិណ្ឌបាត ជួបព្រះសាស្ដាក្នុងទីចង្អៀតមួយកន្លែង កាលថយក្រោយ ជាន់ជាយចីវររបស់ខ្លួន ទើបដួលចុះ មិនអាចទប់ខ្លួនបាន ដួលចុះហើយ ។ ព្រះសាស្ដាយាងទៅជិតហើយ ត្រាស់ថា ម្នាលប្អូនស្រី អត្តភាពរបស់នាងចាស់ហើយ ក្នុងកាលមិនយូរ ក៏នឹងបែកធ្លាយទៅដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**បរិជិណ្ណមិទំ រូបំ ‌ ‌ ‌ ‌ ‌ ‌ ‌ ‌ ‌ ‌ ‌ ‌ ‌ ‌ ‌ ‌ ‌ ‌ រោគនិឌ្ឌំ បភង្គុណំ**
**ភិជ្ជតិ បូតិ សន្ទេហោ ‌ ‌ ‌ ‌ ‌ ‌ ‌ ‌ ‌ ‌ ‌ ‌ ‌ ‌ ‌ ‌ មរណន្តំ ហិ ជីវិតំ ។**

រូបនេះគ្រាំគ្រាអស់ហើយ ជាទីសម្នាក់នៃរោគ ជារបស់
ពុកផុយ រាងកាយជារបស់ស្អុយ (នេះ) តែងបែកធ្លាយ
ទៅវិញ ព្រោះថា ជីវិតមានសេចក្ដីស្លាប់ជាទីបំផុត ។

# សេចក្តីអធិប្បាយ

អត្ថនៃព្រះគាថានោះថា ម្នាលប្អូនស្រី រូបនេះ គឺដែលរាប់ថា សរីរៈរបស់នាង ឈ្មោះថា ចាស់ហើយ ព្រោះជាមនុស្សចាស់ រូបនោះឯង ឈ្មោះថាជាសម្បុករបស់រោគ ព្រោះអត្ថថា ជាទីនៅអាស្រ័យរបស់រោគគ្រប់ប្រភេទ ប្រៀបដូចខ្មែចចក សូម្បីនៅក្មេង ក៏គេហៅថា ចចកចាស់ ។ វល្លិ៍ផោម សូម្បីនៅខ្ចី ក៏គេហៅថា វល្លិ៍ស្អុយ យ៉ាងណា រូបនេះ ក៏ដូច្នោះ កើតក្នុងថ្ងៃនោះ សូម្បីជារូបមានពណ៌ដូចមាស ក៏ឈ្មោះថា កាយស្អុយ បែកធ្លាយ ព្រោះអត្ថថា ហូរចេញជានិច្ច ។ កាយរបស់នាងជារបស់ស្អុយ គប្បីជ្រាបចុះថា នឹងបែក គឺនឹងបែកធ្លាយក្នុងកាលមិនយូរឡើយ ព្រោះហេតុអ្វី ព្រោះជីវិត មានការស្លាប់ជាទីបំផុត ។ ព្រះសាស្តាត្រាស់អធិប្បាយថា ព្រោះជីវិតរបស់សព្វសត្វ មានការស្លាប់ជាទីបំផុតទាំងអស់ ។

ក្នុងកាលចប់ទេសនា ព្រះថេរីសម្រេចសោតាបត្តិផលហើយ ។ ទេសនាបានជាកថាមានប្រយោជន៍ដល់មហាជនហើយ ដូច្នេះឯង ។៚

**រឿង ឧត្តរាថេរី ចប់**

# រឿង ព្រះអធិមានិកភិក្ខុ

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធពួកភិក្ខុដែលមានការសម្គាល់ថា ខ្លួនបានសម្រេចអរហត្តផលច្រើនរូប ត្រាស់ព្រះធម្មទេសនានេះថា **យានិមានិ** ជាដើម ។

បានឮថា ភិក្ខុ ៥០០ រូប រៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្ដាហើយ ចូលកាន់ព្រៃ ព្យាយាមញ៉ាំងឈានឲ្យកើតឡើងហើយ សម្គាល់ថា កិច្ចបព្វ-ជិតរបស់ពួកយើងសម្រេចហើយ ព្រោះកិលេសទាំងឡាយមិនផ្សាយឡើង ទើបត្រឡប់មកដោយបំណងថា នឹងក្រាបទូលគុណដែលខ្លួនបានហើយ ដល់ព្រះសាស្ដា ។

ក្នុងពេលដែលពួកភិក្ខុដល់ខ្លោងទ្វារខាងក្រៅប៉ុណ្ណោះ ព្រះសាស្ដាត្រាស់នឹងព្រះអានន្ទត្ថេរថា អានន្ទ ការងារទាក់ទងដោយតថាគត ដែលភិក្ខុទាំងនោះ ចូលមកគាល់មិនមាន ភិក្ខុទាំងនោះ ចូលទៅកាន់ព្រៃខ្មោចស្រស់ជាមុនសិន ត្រឡប់អំពីទីនោះហើយ សឹមគាល់តថាគត ។ ព្រះថេរៈទៅប្រាប់សេចក្ដីនោះដល់ពួកលោកហើយ ។ ពួកលោកមិនពោលថា ពួកយើងនឹងបានប្រយោជន៍អ្វីដោយព្រៃខ្មោចស្រស់ គិតថា ព្រះពុទ្ធទ្រង់ឃើញហេតុឆ្ងាយទ្រង់នឹងឃើញហេតុ ដូច្នេះហើយ ទៅកាន់ព្រៃខ្មោចស្រស់ កាលឃើញសពក្នុងទីនោះ ក៏បាននូវការខ្ពើមក្នុងសាកសពដែលចោល ១ ថ្ងៃ ២ ថ្ងៃ ញ៉ាំងតម្រេកឲ្យកើតក្នុងសរីរៈស្រស់ ដែលគេទើបតែចោលក្នុងខណៈនោះ ។ ក្នុង

រំពេចនោះ ក៏ដឹងថា ខ្លួននៅមានកិលេស ។ ព្រះសាស្តា ប្រថាប់គង់ក្នុងព្រះគន្ធកុដិនោះឯង ទ្រង់ផ្សាយព្រះរស្មីទៅ ដូចត្រាស់ចំពោះមុខរបស់ភិក្ខុទាំងនោះ ដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ឃើញរាងឆ្អឹងដូច្នោះ ញុំាងសេចក្តីត្រេកអរដោយអំណាចរាគៈឲ្យកើត គួរឬ ដូច្នេះ ហើយ ត្រាស់ព្រះគាថានេះថា

**យានិមានិ អបត្ថានិ អលាពូនេវ សារទេ**
**កាបោតកានិ អដ្ឋីនិ តានិ ទិស្វាន កា រតិ ។**

ឆ្អឹងទាំងឡាយណា មានសម្បុរដូចសត្វព្រាប ដែលគេបោលហើយ ដូចផ្លែឃ្លោកក្នុងសរទកាល សេចក្តីត្រេកអរអ្វីហ្ន៎ ( របស់អ្នកទាំងឡាយ ) ព្រោះតែឃើញឆ្អឹងទាំងឡាយនោះ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អបត្ថានិ** បានដល់ ដែលគេបោលហើយ ។ បទថា **សារទេ** សេចក្តីថា ដូចឃ្លោកដែលខ្យល់ និងកម្តៅថ្ងៃប៉ះខ្ទប់ ជ្រុះរបេកក្នុងទីនោះៗ ក្នុងសរទកាល ។ បទថា **កាបោតកានិ** ប្រែថា មានពណ៌ដូចសត្វព្រាប ។ ពីរបទថា **តានិ ទិស្វាន** សេចក្តីថា ការត្រេកអរអ្វីរបស់ពួកអ្នក ព្រោះឃើញឆ្អឹងទាំងនោះ គឺបែបនោះ ការធ្វើសេចក្តីត្រេកអរក្នុងកាម សូម្បីត្រឹមតែតិចតួច រមែងមិនគួរឡើយ មិនមែនឬ ។

ក្នុងកាលចប់ទេសនា ភិក្ខុទាំងនោះបានសម្រេចអរហត្តផលហើយ តាម

ដែលឈរនៅនោះឯង សរសើរព្រះដ៏មានព្រះភាគ មកថ្វាយបង្គំហើយ ដូច្នេះឯង ។ល។

**រឿង ព្រះអធិមានិកភិក្ខុ ចប់**

# រឿង នាងរូបនន្ទាថេរី

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងរូបនន្ទាថេរី ដែលជាស្រីស្អាតក្នុងជនបទ ត្រាស់ព្រះធម្មទេសនានេះថា **អដ្ឋីនំ នគរំ កតំ** ជាដើម ។

បានឮថា ព្រះនាងរូបនន្ទានោះព្រះតម្រិះថា បងប្រុសរបស់អញលះសិរីរាជសម្បត្តិចេញបួស បានជាព្រះពុទ្ធ ជាអគ្គបុគ្គលក្នុងលោក សូម្បីឱរសរបស់ទ្រង់ ព្រះនាមរាហុលកុមារ ក៏បួសហើយ សូម្បីបងរបស់អញ គឺព្រះនន្ទ ក៏បួសហើយ ព្រះមាតារបស់អញ ក៏បួសហើយ កាលគណញាតិមានប្រមាណប៉ុណ្ណោះបួសហើយ អញនឹងធ្វើអ្វីក្នុងផ្ទះ នឹងបួសដែរ ព្រះនាងយាងចូលទៅកាន់សម្នាក់ភិក្ខុនីទាំងឡាយ ហើយបួស ព្រះនាងបួសព្រោះស្រឡាញ់ក្នុងព្រះញាតិប៉ុណ្ណោះ មិនមែនបួសដោយសទ្ធាឡើយ តែព្រោះព្រះនាងជាអ្នកមានព្រះរូបល្អ ទើបប្រាកដឈ្មោះថា រូបនន្ទា ។

ព្រះនាងបានឮថា ព្រះសាស្ដាត្រាស់ថា រូបមិនទៀង ជាទុក្ខ ជាអនត្តា

វេទនា សញ្ញា សង្ខារ វិញ្ញាណមិនទៀង ជាទុក្ខ ជាអនត្តា ទើបមិនយាងទៅជួបព្រះភក្ត្រព្រះសាស្តា ដោយព្រះនាងខ្លាចព្រះសាស្តាត្រាស់ទោសក្នុងរូបរបស់ខ្លួនដែលគួរមើល គួរជ្រះថ្លាយ៉ាងនេះ ។

អ្នកនគរសាវត្ថីថ្វាយទានអំពីព្រលឹម សមាទានឧបោសថហើយ ដណ្តប់សំពត់ស្អាត មានដៃកាន់គ្រឿងក្រអូប និងកម្រងផ្កាជាដើម ក្នុងពេលល្ងាចប្រជុំគ្នាស្តាប់ធម៌ក្នុងវត្តជេតពន ។ សូម្បីភិក្ខុនីសង្ឃដែលកើតឆន្ទៈក្នុងព្រះធម្មទេសនារបស់ព្រះសាស្តា ក៏រមែងទៅវិហារស្តាប់ធម៌ ។ អ្នកនគរសាវត្ថីទាំងនោះ កាលស្តាប់ធម៌ហើយ ចូលទៅកាន់ព្រះនគរ ក៏ពោលតែគុណកថារបស់ព្រះសាស្តាប៉ុណ្ណោះចូលទៅ ។

ពិតហើយ ពួកសត្វក្នុងលោកសន្និវាស ដែលមានប្រមាណ ៤ ពួក ឃើញព្រះសាស្តា មិនកើតសេចក្តីជ្រះថ្លា មានចំនួនតិច ។ ពោលដោយចំនួនសត្វដែលជារូបប្បមាណិកា គឺកាន់យករូបជាប្រមាណ ឃើញព្រះសរីរៈរបស់ព្រះដ៏មានព្រះភាគ ដែលប្រដាប់ដោយព្រះលក្ខណៈ និងអនុព្យញ្ជនៈ មានព្រះឆវីវណ្ណដូចមាស រមែងជ្រះថ្លា ។ ពួកសត្វដែលជាឃោសប្បមាណិកា គឺកាន់យកសំឡេងជាប្រមាណ ស្តាប់សំឡេងប្រកាសគុណរបស់ព្រះសាស្តាដែលអាស្រ័យប្រព្រឹត្តទៅហើយរាប់រយជាតិ និងសំឡេងប្រកាសធម្មទេសនាដែលប្រកបដោយអង្គ ៨ រមែងជ្រះថ្លា ។ ពួកសត្វដែលជាលូខប្បមាណិកា គឺកាន់យកការបដិបត្តិសៅហ្មងជាប្រមាណ អាស្រ័យភាពដែលព្រះអង្គជាអ្នកសៅហ្មងដោយបច្ច័យទាំងឡាយ មានចីវរជាដើម រមែងជ្រះថ្លា ។ ពួកសត្វ

ដែលជាធម្មប្បមាណិកា គឺកាន់យកធម៌ជាប្រមាណ រមែងជ្រះថ្លាថា សីលរបស់ព្រះទសពលបែបនេះ សមាធិបែបនេះ បញ្ញាបែបនេះ ព្រះដ៏មានព្រះភាគទ្រង់មិនមានបុគ្គលស្មើ មិនមានបុគ្គលផ្ទឹម មិនមានបុគ្គលក្រៃលែងជាង មិនមានបុគ្គលប្រៀបផ្ទឹមដោយគុណទាំងឡាយ មានសីលជាដើម ។ កាលជនទាំងនោះពណ៌នាគុណរបស់ព្រះតថាគត មាត់ក៏មិនគ្រប់គ្រាន់ ។

ព្រះនាងរូបនន្ទាបានស្តាប់នូវគុណកថា អំពីសម្នាក់ពួកភិក្ខុនី និងពួកឧបាសិកា ទើបទ្រង់ព្រះតម្រិះថា ជនទាំងឡាយរមែងពោលសរសើរបងរបស់អញច្រើននោះឯង ក្នុងថ្ងៃមួយ ទ្រង់នឹងត្រាស់ទោសរូបរបស់អញ នឹងត្រាស់បានត្រឹមប៉ុនណា បើដូច្នោះ អញគប្បីទៅជាមួយពួកភិក្ខុនី មិនបង្ហាញខ្លួនឡើយ គាល់ព្រះតថាគតស្តាប់ធម៌ហើយ គប្បីមក ។ ព្រះនាងត្រាស់ប្រាប់ដល់ពួកភិក្ខុនីថា ថ្ងៃនេះ ខ្ញុំនឹងទៅស្តាប់ធម៌ ពួកភិក្ខុនីត្រេកអរថា យូរណាស់ហើយ កាលដែលព្រះនាងរូបនន្ទា ទ្រង់មានបំណងចូលទៅកាន់ទីបម្រើព្រះសាស្តា កើតឡើងហើយ ថ្ងៃនេះ ព្រះសាស្តា ទ្រង់អាស្រ័យព្រះនាងរូបនន្ទានេះហើយ ទ្រង់នឹងសម្តែងព្រះធម្មទេសនាដ៏វិចិត្រ ដូច្នេះហើយ នាំព្រះនាងចេញទៅហើយ ។ ចាប់តាំងអំពីចេញទៅ ព្រះនាងត្រិះរិះថា អញមិនបង្ហាញខ្លួនឡើយ ។

ព្រះសាស្តាទ្រង់ព្រះតម្រិះថា ថ្ងៃនេះ រូបនន្ទានឹងមកកាន់ទីបម្រើរបស់តថាគត ធម្មទេសនាដូចម្តេចហ្ន៎ទើបជាទីសប្បាយរបស់នាង ទ្រង់ដាក់ព្រះហឫទ័យថា រូបនន្ទានោះ ធ្ងន់ក្នុងរូប ជាប់ជំពាក់ក្នុងអត្តភាពដ៏ខ្លាំងក្លា ការ

បន្ទោបង់សេចក្ដីស្រវឹងក្នុងរូបដោយរូបនោះឯង ជាទីសប្បាយរបស់នាង ដូចការយកបន្លាដោះបន្លា ដូច្នោះ ។ ក្នុងកាលដែលព្រះនាងចូលទៅកាន់វិហារ ទ្រង់និម្មិតស្រីម្នាក់ អាយុ ១៦ ឆ្នាំ ស្លៀកសំពត់ក្រហម ប្រដាប់ហើយដោយអាភរណៈគ្រប់យ៉ាង កាន់ផ្លិត ឈរបក់ក្នុងទីជិតព្រះអង្គដោយកម្លាំងឫទ្ធិព្រះសាស្ដា និងព្រះនាងរូបនន្ទាប៉ុណ្ណោះ ឃើញរូបស្ត្រីនោះ ។ ព្រះនាងយាងចូលទៅកាន់វិហារជាមួយភិក្ខុនីទាំងឡាយ ឈរខាងក្រោយភិក្ខុនី ថ្វាយបង្គំព្រះសាស្ដាដោយបញ្ចង្គប្រតិស្ឋាន អង្គុយក្នុងចន្លោះពួកភិក្ខុនី ឆ្មៀងមើលព្រះសាស្ដាតាំងអំពីព្រះបាទ នាងឃើញព្រះសរីរៈរបស់ព្រះសាស្ដា វិចិត្រដោយព្រះលក្ខណៈ រុងរឿងដោយអនុព្យញ្ជនៈ មានព្រះរស្មីមួយព្យាមចោមរោមហើយ ព្រះនាងគយគន់ព្រះភក្ត្រដ៏មានសិរី ដូចព្រះចន្ទ្រពេញវង់ បានឃើញរូបស្រីឈរក្នុងទីជិតហើយ ។ ព្រះនាងមើលស្រីនោះហើយ សម្លឹងមើលអត្តភាពរបស់ខ្លួន ដឹងថា ខ្លួនដូចក្អែកញីនៅក្បែរហង្សមាសញីដូច្នោះ ។ ចាប់តាំងអំពីកាលនាងឃើញរូប ដែលសម្រេចដោយឫទ្ធិនោះឯង ព្រះនេត្រទាំងពីររបស់ព្រះនាង ក៏គយគន់មិនដាក់ ។ ព្រះនាងមានចិត្តដែលសិរីរូបនៃសរីរប្បទេសទាំងអស់ ស្រូបចូលទៅហើយថា ឱ សក់របស់ស្រីនេះក៏ស្អាត ឱ ថ្ងាសក៏ស្អាត ដូច្នេះ មានចិត្តស្រឡាញ់ក្នុងរូបនោះដ៏ខ្លាំងក្លា ។ ព្រះសាស្ដាទ្រង់ជ្រាបការត្រេកអរបំផុត ក្នុងរូបនោះរបស់ព្រះនាង កាលទ្រង់សម្ដែងធម៌ ទើបទ្រង់សម្ដែងរូបនោះ ឲ្យកន្លងភាវៈបុគ្គលមានអាយុ ១៦ មានអាយុ ២០ ឆ្នាំ ។ ព្រះនាងរូបនន្ទាបានទត មានចិត្តនឿយណាយបន្តិចម្ដងថា រូបនេះមិន

ដូចរូបមុនហ្ន៎ ។ ព្រះសាស្តាទ្រង់សម្តែងរូបស្រីនោះ ឲ្យប្រែប្រួលតាមលំដាប់ គឺស្រីស្រករប្រសូតបុត្រម្តង ស្រីកណ្តាលមនុស្ស ស្រីចាស់ ស្រីចាស់គ្រាំគ្រា ព្រោះជរា សូម្បីព្រះនាងក៏នឿយណាយក្នុងរូបនោះ ក្នុងកាលដែលទ្រុឌទ្រោម ព្រោះជរាដោយលំដាប់ដូចគ្នាថា ឱ រូបនេះ វិនាសទៅហើយហ្ន៎ កាលនាង ឃើញរូបនោះមានធ្មេញបាក់ សក់ស្កូវ ខ្នងកោង មានថ្ពឹងផុសឡើង ដូចបង្កង់ ផ្ទះ មានឈើច្រត់ទ្រខាងមុខ ដើរទ្រេតៗ ក៏នឿយណាយពន់ពេក ។ គ្រានោះ ព្រះសាស្តាទ្រង់និម្មិតរូបស្រីនោះ ឲ្យជារូបដែលព្យាធិគ្របសង្កត់ក្នុងខណៈ នោះឯង ស្រីនោះក៏បោះឈើច្រត់ និងផ្ទិតស្ទឹកត្នោត ស្រែកថ្ងូរ ដួលចុះត្រង់ ផែនដី ដេកក្នុងមូត្រ និងលាមករបស់ខ្លួន បម្រះនទៀលទៅមក ព្រះនាង រូបនន្ទាឃើញស្រីនោះហើយ នឿយណាយពន់ពេក ។ ព្រះសាស្តា ទ្រង់ សម្តែងមរណៈរបស់ស្រីនោះហើយ ស្រីនោះដល់នូវសភាពជាសពហើមប៉ោង ក្នុងខណៈនោះឯង ។ ខ្សែនៃខ្ទុះ និងពួកដង្កូវហូរចេញអំពីមុខដំបៅទាំង ៩ ហ្វូងសត្វមានក្អែកជាដើម ប្រជែងគ្នាស៊ីហើយ ។ ព្រះនាងរូបនន្ទា ពិចារណា សាកសពនោះហើយ នាងឃើញអត្តភាពជាសភាវៈមិនទៀងថា ស្រីនេះដល់ នូវការចាស់ ដល់នូវការឈឺ ដល់នូវការស្លាប់ក្នុងទីនេះឯង ការចាស់ ការឈឺ និងការស្លាប់ នឹងមកដល់អត្តភាពនេះយ៉ាងនោះដូចគ្នា ។ និងព្រោះការដែល អត្តភាពជាសភាវៈ ដែលព្រះនាងឃើញហើយដោយសភាពមិនទៀងនោះឯង ទើបអត្តភាពនោះ ព្រះនាងឃើញថាជាទុក្ខ ដោយភាពជាអនត្តានោះឯង ។ លំដាប់នោះ ភពទាំង ៣ ប្រាកដដល់ព្រះនាងដូចត្រូវភ្លើងឆេះហើយ និងដូច

សាកសពដែលគេចងព្យួរត្រង់ព្រះសូរង ចិត្តបាញ់ចំពោះកម្មដ្ឋានហើយ ។ ព្រះសាស្តាទ្រង់ជ្រាបថា ព្រះនាងគិតឃើញអត្តភាព ដោយភាពជារបស់មិនទៀងហើយ ទើបទ្រង់ពិចារណាមើលថា នាងអាចធ្វើទីពឹងដល់ខ្លួនឯងបានដែរឬហ្ន៎ ទ្រង់ឃើញថា មិនអាច ទាល់តែព្រះនាងបានបច្ច័យខាងក្រៅជាមុនសិន ទើបសមគួរ ដូច្នេះហើយ កាលទ្រង់សម្តែងធម៌ដោយអំណាចធម្មសប្បាយដល់ព្រះនាង បានត្រាស់ព្រះគាថានេះថា

> នន្ទា ចូរនាងមើលកាយ ដែលកម្មលើកឡើង គួរខ្ពើម មិនស្អាត ជាកាយស្អុយ ហូរចេញខាងលើ ហូរចេញខាងក្រោម ដែលពាលជនទាំងឡាយ ប្រាថ្នាពន់ពេក សរីរៈរបស់នាង យ៉ាងណា សរីរៈរបស់ស្រីនោះក៏យ៉ាងនោះ សរីរៈរបស់ស្រីនោះ យ៉ាងណា សរីរៈរបស់នាង ក៏យ៉ាងនោះ ចូរនាងឃើញធាតុទាំងឡាយ ជារបស់សោះសូន្យ កុំត្រឡប់មកកាន់លោកនេះទៀតឡើយ ចូរនាងប្រាសចាកតម្រេក គឺការពេញចិត្តក្នុងភពហើយ នឹងជាបុគ្គលស្ងប់ត្រាច់ទៅ ។

បានឮថា ព្រះដ៏មានព្រះភាគ ទ្រង់ប្រារព្ធព្រះនាងនន្ទាភិក្ខុនី បានត្រាស់ព្រះគាថាទាំងនេះ ដោយប្រការដូច្នេះឯង ។ ព្រះនាងនន្ទាបញ្ជូនញាណទៅតាមក្រសែទេសនា សម្រេចសោតាបត្តិផលហើយ ។

កាលនោះ ព្រះសាស្តា កាលទ្រង់ត្រាស់សុញ្ញតកម្មដ្ឋាន ដើម្បីអប់រំវិបស្សនា ដើម្បីមគ្គផលទាំង ៣ ក្រៃលែងឡើងដល់ព្រះនាង ទើបត្រាស់ថា

នទ្ធា នាងកុំធ្វើការយល់ថា សារៈក្នុងសរីរៈនេះមាន ព្រោះសារៈក្នុងសរីរៈនេះ សូម្បីតិចតួចក៏មិនមាន សរីរៈនេះ ដែលកម្មលើកឆ្អឹង ៣០០ កំណាត់ឡើង សាងឲ្យជានគរឆ្អឹងទាំងឡាយ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**អដ្ឋីនំ នគរំ កតំ មំសលោហិតលេបនំ**

**យត្ថ ជរា ច មច្ចុ ច មានោ មក្ខោ ច ឱហិតោ ។**

សេចក្តីគ្រាំគ្រា សេចក្តីស្លាប់ សេចក្តីប្រកាន់ខ្លួន និងសេចក្តីលុបគុណ ប្រជុំចុះក្នុងសរីរៈណា ( សរីរៈនោះ ) ដែលកុសលាកុសលកម្មធ្វើហើយ ឲ្យជានគររបស់ឆ្អឹងទាំងឡាយ ជាគ្រឿងប្រឡាក់ដោយសាច់ និងឈាម ។

## សេចក្តីអធិប្បាយ

អត្ថនៃព្រះគាថានោះថា ដូចជនទាំងឡាយ លើកឈើទាំងឡាយឡើងយកវល្លិ៍ចងហើយ បូកដោយដីឥដ្ឋ ធ្វើឲ្យជាផ្ទះខាងក្រៅ ពោល គឺនគរដើម្បីប្រយោជន៍ដល់ការតាំងបុព្វណ្ណជាតិ និងអបរណ្ណជាតិជាដើម យ៉ាងណា សរីរៈដែលប្រព្រឹត្តទៅខាងក្នុងក៏ដូច្នោះ ដែលកម្មញ៉ាំងឆ្អឹង ៣០០ កំណាត់ឲ្យ លើកឡើងហើយ ធ្វើឲ្យជានគរដែលសសៃរចង លាបដោយសាច់ និងឈាម ខ្ទប់ដោយស្បែក ដើម្បីប្រយោជន៍នៃការធ្លាក់ចុះនៃជរា ដែលមានការទ្រុឌទ្រោមជាលក្ខណៈនៃមច្ចុ ដែលមានការស្លាប់ជាលក្ខណៈ នៃមានៈ ដែលមានការស្រវឹង ព្រោះអាស្រ័យការដល់ព្រមដោយការលើកខ្លួនជាដើមជាលក្ខណៈ និងនៃមក្ខៈ មានការធ្វើកម្មដែលគេធ្វើល្អហើយឲ្យវិនាសជាលក្ខណៈ ព្រោះអាពាធ

ដែលប្រព្រឹត្តទៅតាមកាយ និងចិត្តបែបនេះនោះឯង តាំងចុះហើយ ក្នុងសរីរៈនេះ ក្រៅអំពីនេះ ក៏មិនមានអ្វីដែលចូលដល់នូវភាពជារបស់គប្បីកាន់យក ។

ក្នុងកាលចប់ទេសនា ព្រះនាងរូបនន្ទាថេរីបានសម្រេចអរហត្តផល ។ ព្រះធម្មទេសនា បានជាកថាមានប្រយោជន៍ដល់មហាជនហើយ ដូច្នោះឯង ។៙

**រឿង នាងរូបនន្ទាថេរី ចប់**

# រឿង ព្រះនាងមល្លិកាទេវី

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះនាងមល្លិកាទេវី ត្រាស់ព្រះធម្មទេសនានេះថា **ជីរន្តិ វេ រាជរថា សុចិត្តា** ជាដើម ។

បានឮថា ថ្ងៃមួយ ព្រះនាងមល្លិកាទេវីនោះ យាងចូលទៅកាន់ទីសម្រាប់ស្រង់ទឹក ព្រះនាងជម្រះព្រះឱស្ឋហើយ បន្ទោនព្រះសរីរៈចុះដើម្បីជម្រះស្មងមានសុនខដែលព្រះនាងប្រោសប្រាណមួយ ចូលទៅជាមួយព្រះនាងនោះឯង សុនខឃើញព្រះនាងឱនដូច្នោះ ទើបផ្តើមធ្វើអសទ្ធម្ម ព្រះនាងទ្រង់ត្រេកអរនឹងសម្ផស្សនោះ ទើបប្រថាប់ឈរ ព្រះរាជាទតតាមបង្អួចក្នុងប្រាសាទជាន់លើ ទ្រង់ឃើញកិរិយានោះ ក្នុងកាលព្រះនាងយាងមកវិញ ទើបត្រាស់ថា ស្រីថោកទាប ចូរនាងវិនាស ព្រោះហេតុអ្វី ទើបធ្វើកម្មបែបនេះ ព្រះនាងទូលថា ខ្ញុំម្ចាស់ធ្វើអ្វីខុស ព្រះរាជាត្រាស់ថា នាងធ្វើសន្ថវៈជាមួយសុនខ ព្រះនាងទូលថា

បពិត្រព្រះអង្គ រឿងនេះ មិនពិតទេ ព្រះរាជាត្រាស់ថា យើងឃើញឯង យើងមិនមែនជឿអ្នកដទៃ ស្រីថោកទាប ចូរវិនាស ព្រះនាងទូលថា បពិត្រព្រះអង្គ បុគ្គលណាម្នាក់ចូលទៅកាន់បន្ទប់ទឹកនេះ តែម្នាក់ប៉ុណ្ណោះក៏ប្រាកដជាពីរនាក់ដល់អ្នកដែលមើលតាមបង្អួចនេះ ព្រះរាជាត្រាស់ថា ស្រីអាក្រក់ នាងពោលមិនពិត ព្រះនាងត្រាស់ថា បពិត្រព្រះអង្គ បើទ្រង់មិនជឿខ្ញុំម្ចាស់ សូមយាងទៅកាន់បន្ទប់ទឹកនោះ ខ្ញុំនឹងមើលទ្រង់តាមបង្អួចនេះ ។

ព្រះរាជា មានជាតិជាបុគ្គលល្ងង់ខ្លៅ ទើបទ្រង់ជឿពាក្យរបស់ព្រះនាង ហើយចូលទៅកាន់បន្ទប់ទឹក ចំណែកព្រះទេវីនោះឯង ទ្រង់ឈរទតត្រង់បង្អួច ទូលថា មហារាជល្ងង់ខ្លៅ រឿងអ្វីទ្រង់ធ្វើសន្ថវៈជាមួយពពែ កាលព្រះរាជាត្រាស់ថា នែនាង ខ្ញុំមិនបានធ្វើកម្មបែបនោះ ក៏ទូលថា ខ្ញុំម្ចាស់ឃើញឯង ខ្ញុំម្ចាស់មិនជឿព្រះអង្គឡើយ ព្រះរាជាទ្រង់ស្តាប់ពាក្យនោះហើយទ្រង់ជឿថា បុគ្គលចូលទៅកាន់បន្ទប់ទឹកនេះម្នាក់ឯងប៉ុណ្ណោះ ក៏រមែងប្រាកដជាពីរនាក់ ។ ព្រះនាងមល្លិកាព្រះតម្រិះថា ព្រះរាជានេះអញបញ្ឆោតបានហើយ ព្រោះទ្រង់ល្ងង់ខ្លៅ អញធ្វើកម្មអាក្រក់ហើយ ព្រះរាជានេះ អញពោលទោសដោយពាក្យមិនពិត សូម្បីព្រះសាស្តាទ្រង់ក៏ជ្រាបកម្មនេះរបស់អញ អគ្គសាវកទាំងពីរក្តី អសីតិមហាសាវកក្តី នឹងជ្រាប ឱហ្ន៎ អញធ្វើកម្មធ្ងន់ហើយ ។ បានឮថា ព្រះនាងមល្លិកានោះ ជាសម្លាញ់ក្នុងអសទិសទានរបស់ព្រះរាជា ។

ក្នុងអសទិសទាននោះ កិច្ចបរិច្ចាគដែលទ្រង់ធ្វើមួយថ្ងៃ មានតម្លៃដល់ ១៤ កោដិ ស្វេតច្ឆត្រ បល្ល័ង្កប្រថាប់គង់ ជើងបាត្រ តាំងសម្រាប់ទព្រះបាទ

ព្រះតថាគត របស់ ៤ យ៉ាងនេះ មានតម្លៃកាត់ថ្លៃមិនបាន ។ ក្នុងកាលអស់ព្រះជន្ម ព្រះនាងមល្លិកា មិនបាននឹកដល់មហាបរិច្ចាគបែបនោះ នាងរឭកដល់កម្មលាមកតែម្យ៉ាង អស់ព្រះជន្មហើយ កើតក្នុងអវិចី ព្រះនាងមល្លិកានោះជាអ្នកប្រោសប្រាណរបស់ព្រះរាជាក្រៃលែង ។

ព្រះរាជាត្រូវសេចក្ដីសោកមានកម្លាំងគ្របសង្កត់ បញ្ជាឲ្យធ្វើឈាបនកិច្ចព្រះសរីរៈរបស់ព្រះនាងហើយ ទ្រង់ព្រះតម្រិះថា អញនឹងទូលសួរទីកើតរបស់ព្រះនាង ទើបទៅកាន់សម្នាក់ព្រះសាស្ដា ។ ព្រះសាស្ដាទ្រង់បានធ្វើឲ្យព្រះរាជារឭកមិនបាន ។ ទ្រង់ស្ដាប់ព្រះធម្មកថា ក្នុងសម្នាក់ព្រះសាស្ដាហើយក៏ភ្លេចក្នុងកាលយាងទៅកាន់ព្រះរាជនិវេសន៍ ទ្រង់រឭកបាន ទើបត្រាស់ថា នែអ្នក ខ្ញុំតាំងចិត្តថានឹងទូលសួរទីដែលព្រះនាងមល្លិកាកើត ទៅកាន់សម្នាក់ព្រះសាស្ដាក៏ភ្លេចឈឹង ស្អែកនេះខ្ញុំនឹងទូលសួរទៀត ដូច្នេះហើយ ក៏យាងទៅ សូម្បីក្នុងថ្ងៃស្អែកឡើង ព្រះសាស្ដាក៏បានធ្វើឲ្យព្រះរាជារឭកមិនបានរហូត ៧ ថ្ងៃតាមលំដាប់ ។ ចំណែកព្រះនាងមល្លិកានោះ ឆេះក្នុងនរកអស់ ៧ ថ្ងៃប៉ុណ្ណោះ ក្នុងថ្ងៃ ទី ៨ ចុតិអំពីទីនោះហើយ កើតក្នុងតុសិត ។

សួរថា ព្រោះហេតុអ្វីទើបព្រះសាស្ដា បានធ្វើភាពដែលព្រះរាជានោះឲ្យទ្រង់រឭកមិនបាន ឆ្លើយថា បានឮថា ព្រះនាងមល្លិកានោះជាទីពេញព្រះហឫទ័យរបស់ព្រះរាជាបំផុត ព្រោះដូច្នោះ បើទ្រង់ជ្រាបថា ព្រះនាងកើតក្នុងនរកហើយ ក៏កើតមិច្ឆាទិដ្ឋិថា បើស្រីសម្បូរដោយសទ្ធាបែបនេះ កើតក្នុងនរកសោត អញនឹងថ្វាយទានធ្វើអ្វី ដូច្នេះហើយ នឹងផ្ដាច់និច្ចភត្តដែលប្រព្រឹត្ត

ទៅក្នុងព្រះរាជនិវេសន៍ សម្រាប់ភិក្ខុ ៥០០ ហើយ គប្បីកើតក្នុងនរក ។ ព្រោះដូច្នោះ ទើបព្រះសាស្តា ទ្រង់ធ្វើកាលដែលព្រះរាជានោះ មិនឲ្យរឭកបាន អស់ ៧ ថ្ងៃ ។ ក្នុងថ្ងៃទី ៨ ទ្រង់យាងទៅដើម្បីបិណ្ឌបាត ចូលទៅកាន់ទ្វារ ព្រះរាជវាំងដោយព្រះអង្គឯង ។ ព្រះរាជាជ្រាបថា ព្រះសាស្តាយាងមកហើយ ទើបចេញទៅទទួលបាត្រ បម្រុងនិមន្តឡើងកាន់ប្រាសាទ តែព្រះសាស្តាទ្រង់ សម្តែងអាការដើម្បីប្រថាប់គង់ត្រង់រោងរថ ។ ទើបព្រះរាជានិមន្តព្រះសាស្តា ឲ្យប្រថាប់គង់ក្នុងទីនោះ ទ្រង់ទទួលដោយបបរ និងរបស់ទំពាហើយ ទើប ថ្វាយបង្គំ លុះប្រថាប់គង់ ក៏ក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមកដោយ បំណងថា នឹងទូលសួរទីកើតរបស់ព្រះនាងមល្លិកាទេវី ហើយបេះតែភ្លេច ព្រះ នាងកើតក្នុងទីណាហ្ន៎ ព្រះសាស្តាត្រាស់ថា មហាបពិត្រ នាងកើតក្នុងតុសិត-ភព ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ បើនាងមិនកើតក្នុងតុសិតភព អ្នកដទៃ ណានឹងកើត ស្រីដូចព្រះនាងមល្លិកានោះ មិនមាន ព្រោះក្នុងទីដែលព្រះនាង អង្គុយជាដើម កិច្ចដទៃវៀរការចាត់ចែងទាន ដោយគិតថា ស្អែកនេះ នឹង ថ្វាយវត្ថុនេះ នឹងធ្វើវត្ថុនេះដល់ព្រះតថាគត ដូច្នេះ មិនមានឡើយ បពិត្រ ព្រះអង្គ តាំងអំពីនាងទៅកាន់បរលោកហើយ សរីរៈរបស់ខ្ញុំព្រះអង្គ មិន ស្រួលរីករាយឡើយ ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងព្រះរាជាថា មហាបពិត្រ កុំគិតឡើយ នេះជាធម៌ដែលពិតប្រាកដរបស់សត្វគ្រប់ជំពូក ហើយត្រាស់សួរថា មហាបពិត្រ នេះរថរបស់អ្នកណា ។ ព្រះរាជាទ្រង់ប្រតិស្ឋានអញ្ជលីលើត្បូងទូលថា បពិត្រ

ព្រះអង្គ របស់ជីតាខ្ញុំព្រះអង្គ ព្រះសាស្តាត្រាស់ថា នេះជារបស់អ្នកណា ព្រះរាជាត្រាស់ថា របស់បិតាខ្ញុំព្រះអង្គ ។

កាលព្រះរាជាក្រាបទូលយ៉ាងនោះហើយ ព្រះសាស្តាត្រាស់ថា មហាបពិត្រ រថរបស់ជីតា ហេតុអ្វី មិនដូចរថរបស់ព្រះបិតា រថរបស់ព្រះបិតាមិនដូចរថរបស់មហាបពិត្រ ការគ្រាំគ្រា រមែងមកដល់ សូម្បីតែកំណាត់ឈើបែបនេះ នឹងពោលទៅថ្វីការគ្រាំគ្រាថា មិនមកដល់អត្តភាពនេះ មហាបពិត្រ សេចក្តីពិត ធម៌របស់សប្បុរសប៉ុណ្ណោះ មិនមានសេចក្តីជរា ចំណែកសត្វទាំងឡាយ ឈ្មោះថា មិនជរាមិនមាន ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**ជីរន្តិ វេ រាជរថា សុចិត្តា អថោ សរីរម្បិ ជរំ ឧបេតិ**
**សតញ្ច ធម្មោ ន ជរំ ឧបេតិ សន្តោ ហវេ សព្ភិ បវេទយន្តិ ។**

រាជរថទាំងឡាយ ដ៏វិចិត្រល្អ រមែងគ្រាំគ្រា សូម្បីសរីរៈក៏ដល់នូវសេចក្តីគ្រាំគ្រាដូចគ្នា ទើបឯធម៌របស់សប្បុរសទាំងឡាយ មិនដល់នូវសេចក្តីគ្រាំគ្រា ( ដូច្នោះ ) ទេ សប្បុរសទាំងឡាយ តែងនិយាយឲ្យពួកសប្បុរសផងគ្នាដឹងបាន ។

## សេចក្តីអធិប្បាយ

គប្បីជ្រាបថា វេ ក្នុងព្រះគាថានោះ ជានិបាត បទថា **សុចិត្តា** សេចក្តីថា រថទាំងឡាយរបស់ព្រះរាជាទាំងឡាយ ដ៏វិចិត្រល្អហើយ ដោយរតនៈ ៧ និងដោយគ្រឿងប្រដាប់រថដទៃ រមែងគ្រាំគ្រាបាន ។

បទថា **សរីរម្បិ** សេចក្តីថា មិនមែនរថតែម្យ៉ាងប៉ុណ្ណោះ សរីរៈដែល

ផ្សំផ្គុំគ្នាយ៉ាងល្អនេះ ក៏រមែងដល់នូវការទ្រុឌទ្រោម មានភាពជាបុគ្គលធ្មេញបាក់ជាដើម ឈ្មោះថា ចូលដល់នូវការគ្រាំគ្រា ។

បទថា **សតញ្ច** សេចក្តីថា តែលោកុត្តរធម៌ ៩ របស់សប្បុរសទាំង-ឡាយ មានព្រះពុទ្ធជាដើម រមែងមិនធ្វើនូវការប៉ះទង្គិចក្នុងទីណាឡើយ ឈ្មោះថា មិនចូលដល់នូវភាពទ្រុឌទ្រោម ។

បទថា **បវេទយន្តិ** សេចក្តីថា សប្បុរសទាំងឡាយ មានព្រះពុទ្ធជាដើម ប្រាស្រ័យជាមួយសប្បុរស គឺដោយបណ្ឌិតទាំងឡាយយ៉ាងនេះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ៕

**រឿង ព្រះនាងមល្លិកាទេវី ចប់**

# រឿង ព្រះលោឡុទាយិត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធលោឡុទាយិត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **អប្បស្សុតាយំ បុរិសោ** ជាដើម ។

បានឮមកថា ព្រះលោឡុទាយិត្ថេរនោះ ទៅកាន់ផ្ទះរបស់បុគ្គលដែលធ្វើនូវមង្គល ក៏សូត្រនូវអវមង្គលដោយន័យជាដើមថា **តិរោកុឌ្ឌេសុ តិដ្ឋន្តិ** បើទៅផ្ទះរបស់អ្នកធ្វើការអវមង្គល ដែលគួរពោលតិរោកុឌ្ឌសូត្រជាដើម ក៏ពោល

មង្គលកថា ដោយន័យជាដើមថា **ឆានញ្ច ធម្មចរិយា ច** ឬរតនសូត្រជាដើមថា **យំកិញ្ចិ វិត្តំ ឥធ វា ហុរំ វា** ។ លោកគិតថា អញនឹងពោលសូត្រដទៃ សូម្បីពោលសូត្រដទៃក្នុងទីនោះៗ យ៉ាងនោះ ក៏មិនដឹងថាអញពោលសូត្រដទៃ ។

ភិក្ខុទាំងឡាយស្តាប់កថារបស់លោកហើយ ទើបក្រាបទូលព្រះសាស្តាថា បពិត្រព្រះអង្គ ហេតុអ្វីលោឡុទាយី ក្នុងទីគេធ្វើមង្គល និងអវមង្គល គួរពោលសូត្រដទៃ ក៏បែរជាទៅពោលសូត្រដទៃ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លោឡុទាយីនោះពោលយ៉ាងនោះ ក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន លោឡុទាយី កាលសូត្រដទៃដែលខ្លួនគួរពោល ក៏បែរជាពោលសូត្រដទៃ កាលភិក្ខុទាំងនោះទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកថា

ក្នុងអតីតកាល បុត្ររបស់ព្រាហ្មណ៍ឈ្មោះអគ្គិទត្ត ក្នុងក្រុងពារាណសី ឈ្មោះសោមទត្តកុមារ បម្រើព្រះរាជាហើយ ។ កុលបុត្រនោះ បានជាទីប្រោសប្រាណពេញព្រះហឫទ័យរបស់ព្រះរាជា ។ ចំណែកព្រាហ្មណ៍ អាស្រ័យកសិកម្មចិញ្ចឹមជីវិត ។ ព្រាហ្មណ៍នោះ មានគោពីរ ក្នុងគោពីរនោះ គោមួយក្បាលស្លាប់ហើយ ។ ទើបព្រាហ្មណ៍និយាយនឹងកូនប្រុសថា នែបា សោមទត្ត ចូរបាសូមព្រះរាជា នាំគោមកឲ្យឪពុកមួយក្បាល ។

មហាតលិកសោមទត្តគិតថា បើអញសូមព្រះរាជទាន ជាមួយព្រះរាជា សោត ភាពជាបុគ្គលរឹកររនឹងប្រាកដដល់អញ ទើបពោលថា បពិត្រលោក

ឪពុក សូមលោកឪពុក សូមនឹងព្រះរាជាចុះ កាលព្រាហ្មណ៍ពោលថា នែកូន បើដូច្នោះ ចូរនាំឪពុកទៅចុះ ទើបគិតថា ព្រាហ្មណ៍នេះ មានបញ្ញាទន់ខ្សោយ មិនចេះសូម្បីត្រឹមតែពាក្យជាដើមថា ចូរទៅខាងមុខ ចូរថយមកក្រោយ កាលពាក្យដទៃដែលគួរពោលថា ក៏បែរជាពោលពាក្យដទៃទៀត អញនឹងឲ្យសិក្សាហើយសឹមនាំទៅ ។ សោមទត្តនាំឪពុកទៅកាន់ព្រៃខ្មោច ឈ្មោះវីរណត្ថម្ភកៈហើយ ចងស្នោប្រើនបាច់សន្មតថា បាច់នេះជាព្រះរាជា បាច់នេះជាឧបរាជ បាច់នេះជាសេនាបតីដូច្នេះជាដើម បង្ហាញដល់បិតាតាមលំដាប់ហើយ ប្រាប់ថា ពេលដែលលោកឪពុកចូលទៅកាន់រាជត្រកូល ត្រូវដើរយ៉ាងនេះ ត្រូវថយយ៉ាងនេះ និយាយនឹងព្រះរាជា ត្រូវក្រាបទូលយ៉ាងនេះ ឧបរាជ ត្រូវនិយាយយ៉ាងនេះ លោកឪពុកគាល់ព្រះរាជាហើយ ត្រូវថ្វាយជ័យមង្គលយ៉ាងនេះថា សូមទ្រង់មានជ័យជម្នះចុះ ដូច្នេះ គប្បីពោលគាថានេះហើយ សូមគោចុះ ទើបឲ្យបិតារៀនគាថាថា

> បពិត្រមហារាជ គោសម្រាប់ភ្ជួរស្រែរបស់ទូលបង្គំមានពីរ ក្នុងគោពីរនោះ គោមួយស្លាប់ហើយ សូមទ្រង់ព្រះរាជទានគោទីពីរចុះ ។

ព្រាហ្មណ៍នោះ ទន្ទេញគាថានោះយ៉ាងស្ទាត់អស់មួយឆ្នាំ ទើបប្រាប់ភាពដែលគាថានោះស្ទាត់ជំនាញហើយដល់បុត្រ កាលសោមទត្តពោលថា បពិត្រលោកឪពុក បើដូច្នោះ សូមលោកឪពុកកាន់គ្រឿងបណ្ណាការបន្តិចបន្តួចនោះឯងមកចុះ ខ្ញុំទៅមុន ហើយឈរត្រង់ព្រះរាជសម្នាក់ ទើបពោលថា ប្រពៃណាស់ កូន ហើយកាន់គ្រឿងបណ្ណាការទៅ ជាអ្នកដល់នូវភាពឧស្សាហ៍

ទៅកាន់រាជត្រកូល ក្នុងកាលដែលសោមទត្តឈរក្នុងរាជសម្នាក់ ជាអ្នកមានព្រះរាជបដិសណ្ឋារៈ ដែលព្រះរាជាមានព្រះហឫទ័យត្រេកអរ ទ្រង់ធ្វើហើយ កាលទ្រង់ត្រាស់ថា នែអ្នក អ្នកខានមកយូរហើយ នេះទីអង្គុយ ចូរអង្គុយហើយនិយាយចុះ អ្នកត្រូវការវត្ថុណា ទើបសូធ្យគាថានេះថា បពិត្រមហារាជ គោសម្រាប់ភ្ជួរស្រែរបស់ទូលបង្គំមានពីរ គោមួយស្លាប់ហើយ សូមទ្រង់កាន់យកគោទីពីរវិញចុះ ។ កាលព្រះរាជាត្រាស់ថា នែអ្នក អ្នកពោលដូចម្តេច ចូរពោលម្តងទៀត ព្រាហ្មណ៍នោះ ក៏ពោលគាថានោះឯង ព្រះរាជាទ្រង់ជ្រាបភាពដែលគាថានោះ ព្រាហ្មណ៍ពោលខុស ទ្រង់ញញឹមហើយ ត្រាស់ថា សោមទត្ត គោក្នុងផ្ទះរបស់អ្នក មានច្រើនឬ កាលសោមទត្តក្រាបទូលថា បពិត្រព្រះអង្គ គោទូលបង្គំ បើទ្រង់ព្រះរាជទានហើយ ទើបមានច្រើន ដូច្នេះហើយ ទ្រង់ប្រោសប្រាណសោមទត្តពោធិសត្វ ទើបព្រះរាជទានគោ ១៦ ដល់ព្រាហ្មណ៍ ទ្រព្យសម្បត្តិ គ្រឿងអលង្ការ និងផ្ទះដល់ពោធិសត្វនោះ ឲ្យជាព្រហ្មទេយ្យហើយ ទើបបញ្ជូនព្រាហ្មណ៍ទៅ ដោយយសធំ ។

ព្រះសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ប្រជុំជាតកថា ស្តេចផែនដីក្នុងកាលនោះ បានជាអានន្ទ ព្រាហ្មណ៍ក្នុងកាលនោះ បានជាលោឡុទាយី មហាតលិកសោមទត្តក្នុងកាលនោះ ជាតថាគតនេះឯង ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លោឡុទាយីនេះ កាលពាក្យដទៃដែលខ្លួនគួរពោល ក៏បែរជាពោលពាក្យដទៃទៅវិញ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន លោឡុទាយីក៏ពោលហើយ ព្រោះភាពដែល

ខ្លួនមានធម៌បានស្តាប់តិច ព្រោះថា បុគ្គលមានសុតៈតិច ដូចគោបម្រើ ទើបត្រាស់ព្រះគាថាថា

**អប្បស្សុតាយំ បុរិសោ ពលិពទ្ទោវ ជីរតិ**
**មំសានិ តស្ស វឌ្ឍន្តិ បញ្ញា តស្ស ន វឌ្ឍតិ ។**

*បុរសអ្នកមិនមានការចេះដឹងនេះ តែងចាស់ ( ឥតអំពើ ) ដូចគោបម្រើ សាច់របស់វា តែងចម្រើនឡើង តែប្រាជ្ញារបស់វាមិនចម្រើនឡើយ ។*

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អប្បស្សុតាយំ** បុគ្គលឈ្មោះថា អប្បស្សុតៈ ព្រោះមានពួកសូត្រ ៥០ មួយពួក ឬពីរពួក ឬព្រោះមិនមានវគ្គនៃសូត្រមួយវគ្គ ឬពីរវគ្គ ដោយកំណត់តិចបំផុត ព្រោះមិនមានសូត្រមួយ ឬពីរសូត្រ តែបានរៀនកម្មដ្ឋានតិចតួច ប្រកបព្យាយាមរឿយៗ ក៏ជាពហូសូតបាននោះឯង ។

ពីរបទថា **ពលិពទ្ទោវ ជីរតិ** សេចក្តីថា ដូចគោបម្រើ កាលចាស់ គឺកាលជរា រមែងធំឡើងដើម្បីប្រយោជន៍ដល់គោមេ មិនជាប្រយោជន៍ដល់គោឈ្មោលឡើយ គោដែលជាបងប្អូនដ៏សេស ក៏មិនមានប្រយោជន៍ដូចគ្នាដោយពិត ចាស់មិនមានប្រយោជន៍ឡើយ យ៉ាងណា សូម្បីអប្បស្សុតជននេះ មិនធ្វើឧបជ្ឈាយវត្ត មិនធ្វើអាចរិយវត្ត មិនធ្វើវត្តដទៃ មានអាគន្តុកវត្តជាដើម មិនប្រកបព្យាយាម សូម្បីត្រឹមតែភាវនា ឈ្មោះថា រមែងចាស់មិនមានប្រយោជន៍ ដូច្នោះឯង ។

បាទព្រះគាថាថា **មំសានិ តស្ស វឌ្ឍន្តិ** អធិប្បាយថា សាច់របស់គោបម្រើដែលម្ចាស់គិតថា អានេះ មិនអាចអូសនឹមជាដើមបាន លែងឲ្យស៊ីក្នុងព្រៃ ដើរស៊ី ដើរផឹកក្នុងព្រៃនោះឯង រមែងចម្រើនយ៉ាងណា សាច់របស់អ្នកចេះដឹងតិចនេះដែលព្រះគរុដ្ឋានិយៈ មានឧបជ្ឈាយ៍ជាដើមបោះបង់ចោលហើយ អាស្រ័យសង្ឃបានបច្ច័យ ៤ ធ្វើសរីរកិច្ចមានបញ្ចុះផ្ទៃជាដើម ចិញ្ចឹមកាយ រមែងចម្រើន គឺរមែងមានរាងកាយធាត់ត្រាច់ទៅ ដូច្នោះ ។

ពីរបទថា **បញ្ញា តស្ស** សេចក្តីថា ចំណែកបញ្ញា ដែលជាលោកិយ និងលោកុត្តររបស់អប្បស្សុតជននោះ សូម្បីមានប្រមាណមួយអង្គុលី ក៏មិនចម្រើន តែតណ្ហា និងមានៈ ៩ យ៉ាង រមែងចម្រើន ព្រោះអាស្រ័យទ្វារ ៦ ដូចគុម្ពស្មៅ លតាវល្លិ៍ជាដើម ចម្រើនក្នុងព្រៃ ដូច្នោះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ៕៚

**រឿងព្រះលោឡុទាយិត្ថេរ ចប់**

# រឿង បឋមពោធិកាល

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងមណ្ឌលពោធិព្រឹក្ស ទ្រង់បន្លឺឧទាន ដោយអំណាចសោមនស្ស ក្នុងសម័យដទៃ ព្រះអានន្ទទូលសួរ ទើបត្រាស់ព្រះធម្មទេសនានេះថា **អនេកជាតិសង្សារំ** ជាដើម ។

ព្រះសម្មាសម្ពុទ្ធអង្គនោះឯង ប្រថាប់គង់ក្នុងមណ្ឌលពោធិព្រឹក្ស កាលព្រះអាទិត្យមិនទាន់អស្តង្គត ទ្រង់កម្ចាត់មារ និងពលហើយ ក្នុងបឋមយាម ទ្រង់ទម្លាយងងឹតដែលបិទបាំងបុព្វេនិវាសញ្ញាណ ។ ក្នុងមជ្ឈិមយាម ទ្រង់ជម្រះទិព្វចក្ខុឲ្យបរិសុទ្ធហើយ ក្នុងបច្ឆិមយាម ទ្រង់អាស្រ័យសេចក្តីករុណាក្នុងពួកសត្វ ទ្រង់ញ៉ាំងព្រះញាណឲ្យចុះក្នុងបច្ចយាការហើយ ទ្រង់ពិចារណាបច្ចយាការនោះដោយអំណាចនៃអនុលោម បដិលោម ។ ក្នុងវេលាអរុណរះ ទ្រង់សម្រេចព្រះសម្មាសម្ពោធិញ្ញាណ មួយអន្លើដោយភាពអស្ចារ្យច្រើនយ៉ាង កាលទ្រង់បន្លឺឧទាន ដែលព្រះពុទ្ធមិនមែនមួយសែន ទ្រង់មិនលះបង់ហើយ ទើបត្រាស់ព្រះគាថាទាំងនេះថា

**អនេកជាតិសង្សារំ សន្ធាវិស្សំ អនិព្វិសំ**
**គហការកំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ**
**គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ**
**សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ**
**វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា ។**

កាលតថាគត មិនទាន់បានជួបប្រទះ ( ពោធិញ្ញាណ វល់តែ ) ស្វះស្វែងរកជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្តភាព ក៏អន្ទោល ទៅកាន់សង្សារវដ្ត មានជាតិដ៏ច្រើន សេចក្តីកើតជាទុក្ខរឿយៗ ។ នែជាងផ្ទះ អ្នកឯងធ្វើផ្ទះ គឺអត្តភាព តថាគតឃើញហើយ អ្នកនឹងធ្វើផ្ទះ ( របស់តថាគត ) ទៀត មិនបានឡើយ ឆ្អឹងជំនីរ គឺកិលេសរបស់អ្នកទាំងអស់ តថាគតកាច់បំបាក់អស់ហើយ ដំបូលផ្ទះ គឺអវិជ្ជា តថាគតកម្ចាត់ចោលហើយ ចិត្តរបស់តថាគតដល់ព្រះនិព្វាន ដែលមានសង្ខារប្រាសហើយ តថាគតបានដល់ធម៌ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ ពីរបទថា **គហការំ គវេសន្តោ** សេចក្តីថា តថាគតកាលស្វែងរកជាង គឺតណ្ហាអ្នកធ្វើផ្ទះ ពោល គឺអត្តភាពនេះ កាលអភិនីហារដែលធ្វើហើយ ទៀបបាទមូលនៃព្រះសម្ពុទ្ធព្រះនាមទីបង្ករ ដើម្បីជាប្រយោជន៍ដល់ព្រះញាណ ដែលជាធម្មជាតអាចឃើញនាយជាងនោះបាន គឺព្រះពោ-ធិញ្ញាណ កាលមិនប្រសព្វ មិនជួប គឺមិនបាននូវព្រះញាណនោះឯង ទើបអន្ទោល គឺស្ទុះ បានដល់ វិលវល់ទៅមកកាន់សង្សារ មានជាតិមិនតែមួយ គឺកាន់សង្សារវដ្តនេះ ដែលរាប់បានច្រើនសែនជាតិ អស់កាល មានប្រមាណប៉ុណ្ណោះ ។

ពាក្យថា **ទុក្ខា ជាតិ បុនប្បុនំ** នេះ ជាពាក្យសម្តែងហេតុនៃការស្វែងរកជាងដែលធ្វើផ្ទះ ។ ព្រោះ ឈ្មោះថា ជាតិនេះ គឺការចូលដល់រឿយៗ ឈ្មោះថា ជាទុក្ខ ព្រោះភាវៈដែលលាយឡំដោយជរា ព្យាធិ និងមរណៈ ជាតិនោះ កាលនាយជាងដែលធ្វើផ្ទះនោះ ដែលបុគ្គលណាម្នាក់មិនជួបហើយ រមែងមិនត្រឡប់ ដូច្នោះ កាលតថាគតស្វែងរកជាងធ្វើផ្ទះ ទើបអន្ទោលទៅ ។

បទថា **ទិដ្ឋោសិ** សេចក្តីថា ឥឡូវនេះ តថាគតត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណ ជួបអ្នកពិតប្រាកដ ។ បទថា **បុន គេហំ** សេចក្តីថា អ្នកនឹងធ្វើផ្ទះរបស់តថាគត ពោល គឺអត្តភាពក្នុងសង្សារវដ្តនេះទៀត មិនបានឡើយ ។

បាទព្រះគាថាថា **សព្វា តេ ផាសុកា ភគ្គា** សេចក្តីថា ឆ្អឹងជំនីរ ពោល គឺកិលេសដ៏សេសទាំងអស់របស់អ្នក តថាគតបានកាច់ចោលហើយ ។

បាទព្រះគាថាថា **គហាកូដំ វិសង្ខតំ** សេចក្តីថា សូម្បីមណ្ឌលមេដំបូល ពោល គឺអវិជ្ជានៃផ្ទះ គឺអត្តភាព ដែលអ្នកសាងហើយនេះ តថាគតក៏រើចេញហើយ ។

បាទព្រះគាថាថា **វិសង្ខារគតំ ចិត្តំ** សេចក្តីថា ឥឡូវនេះ ចិត្តរបស់តថាគតចូលដល់ គឺចូលទៅដល់ធម៌ប្រាសចាកគ្រឿងតាក់តែងហើយ គឺព្រះនិព្វាន ដោយអំណាចធ្វើឲ្យជាអារម្មណ៍ ។

បាទព្រះគាថាថា **តណ្ហានំ ខយមជ្ឈគា** សេចក្តីថា តថាគតសម្រេចអរហត្ត ពោល គឺធម៌ជាទីអស់ទៅនៃតណ្ហាហើយ ។៚

**រឿង បឋមពោធិកាល ចប់**

# រឿង សេដ្ឋីបុត្រមានទ្រព្យច្រើន

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងព្រៃឥសិបតនមិគទាយវ័ន ទ្រង់ប្រារព្ធសេដ្ឋីបុត្រអ្នកមានទ្រព្យច្រើន ត្រាស់ព្រះធម្មទេសនានេះថា **អចរិត្វា ព្រហ្មចរិយំ** ជាដើម ។

បានឮមកថា សេដ្ឋីបុត្រនោះកើតហើយក្នុងត្រកូលមានសម្បត្តិ ៨០ កោដិ ក្នុងក្រុងពារាណសី កាលនោះ មាតាបិតារបស់សេដ្ឋីបុត្រនោះ គិតថា ក្នុងត្រកូលរបស់យើង មានគំនរភោគៈច្រើន យើងនឹងប្រគល់គំនរភោគៈនោះក្នុងដៃកូនរបស់យើង ធ្វើឲ្យប្រើប្រាស់យ៉ាងសប្បាយ កិច្ចដោយការងារដទៃមិនចាំបាច់មាន ដូច្នេះហើយ ទើបឲ្យកូនសិក្សាសិប្បៈត្រឹមតែការរាំច្រៀង និងប្រគំតែម្យ៉ាង ។ ក្នុងនគរនោះឯង មានធីតាសេដ្ឋីម្នាក់ កើតហើយក្នុងត្រកូលដទៃ មានសម្បត្តិ ៨០ កោដិ មាតាបិតារបស់នាងក៏គិតហើយយ៉ាងនោះដូចគ្នា ហើយក៏ឲ្យនាងសិក្សាត្រឹមតែសិប្បៈរាំ ច្រៀង និងប្រគំតែម្យ៉ាង កាលជនទាំងពីរចម្រើនវ័យហើយ បានធ្វើអាវាហវិវាហមង្គលជាមួយគ្នា ក្នុងកាលក្រោយមក ឪពុកម្តាយជនទាំងពីរនោះអនិច្ចកម្មហើយ ទ្រព្យ ១៦០ កោដិ ក៏បានរួមគ្នាក្នុងផ្ទះតែមួយ ។ សេដ្ឋីនោះទៅកាន់ទីបម្រើព្រះរាជាមួយថ្ងៃ ៣ ដង កាលនោះពួកអ្នកលេងក្នុងព្រះនគរនោះគិតគ្នាថា បើសេដ្ឋីបុត្រនេះក្លាយជាអ្នកលេងសុរា ផាសុកនឹងមានដល់ពួកយើង យើងនឹងបង្រៀនបុរសនេះឲ្យក្លាយជាអ្នកលេងសុរា ។ ទើបពួកអ្នកលេងនោះកាន់យកសុរា ចង្កាច់សម្រាប់ក្លែម និង

ដុំអំបិលត្រង់ជាយថ្នក់ កាន់មើមស្ពៃ អង្គុយមើលផ្លូវសេដ្ឋីបុត្រនោះ ដែលមកអំពីរាជត្រកូល ឃើញបុរសនោះដើរមក ទើបផឹកសុរា យកដុំអំបិលដាក់ក្នុងមាត់ ទំពាមើមស្ពៃ ពោលថា លោកសេដ្ឋី ចូររស់នៅមួយរយឆ្នាំចុះ ពួកខ្ញុំអាស្រ័យលោក ទើបអាចក្នុងការទំពា និងការផឹក ។

សេដ្ឋីបុត្រ ស្ដាប់ពាក្យអ្នកលេងនោះហើយ ទើបសួរអ្នកបម្រើជិតស្និទ្ធដែលមកតាមក្រោយថា ជនទាំងនោះផឹកអ្វី អ្នកបម្រើប្រាប់ថា ផឹកទឹកប្រភេទម្យ៉ាង សេដ្ឋីបុត្រសួរថា មានរសជាតិឆ្ងាញ់ឬ អ្នកបម្រើប្រាប់ថា បពិត្រលោកម្ចាស់ ធម្មតាទឹកដែលគួរផឹកដូចគ្នានឹងទឹកនេះ មិនមានក្នុងលោកដែលរស់នៅនេះ ។ សេដ្ឋីបុត្រនោះពោលថា បើដូច្នេះ ខ្ញុំផឹកក៏គួរ ដូច្នេះហើយ ទើបឲ្យយកមកបន្តិចហើយក៏ផឹក តមកមិនយូរប៉ុន្មាន អ្នកលេងទាំងនោះដឹងថា សេដ្ឋីនោះផឹក ទើបនាំគ្នាចោមរោមសេដ្ឋីបុត្រនោះ ក្នុងកាលកន្លងទៅ ក៏មានបរិវារធំ ។ សេដ្ឋីបុត្រនោះឲ្យនាំសុរាមកដោយទ្រព្យ ១០០ ខ្លះ ២០០ ខ្លះផឹក តាំងគំនរកហាបណៈក្នុងទីអង្គុយជាដើមដោយលំដាប់ ផឹកសុរា ពោលថា ចូរនាំយកផ្កាមកដោយកហាបណៈនេះ ចូរនាំយកគ្រឿងក្រអូបមកដោយកហាបណៈនេះ បុគ្គលនេះឈ្លាសក្នុងការច្រៀង បុគ្គលនេះឈ្លាសក្នុងការរាំ បុគ្គលនេះឈ្លាសក្នុងការប្រគំ ចូរឲ្យទ្រព្យមួយពាន់ដល់បុគ្គលនេះ ចូរឲ្យទ្រព្យពីរពាន់ដល់បុគ្គលនេះ ។ កាលខ្ជះខ្ជាយយ៉ាងនោះ ក្នុងកាលមិនយូរប៉ុន្មាន ក៏ញុំាងទ្រព្យ ៨០ កោដិ ដែលជារបស់ខ្លួនឲ្យអស់ទៅហើយ កាលហិរញ្ញិកប្រាប់ថា បពិត្រលោកម្ចាស់ ទ្រព្យរបស់លោកម្ចាស់អស់ហើយ ទើបពោលថា ទ្រព្យរបស់ភរិយាខ្ញុំ

នៅមានឬ កាលគេប្រាប់ថា នៅមាន ទើបប្រាប់ថា បើដូច្នោះ ចូរយកទ្រព្យនោះមក បានញ៉ាំងទ្រព្យនោះឲ្យអស់ទៅហើយយ៉ាងនោះដូចគ្នា ហើយលក់សម្បត្តិរបស់ខ្លួនទាំងអស់ គឺស្រែ សួនផ្កា ចម្ការ យានពាហនៈជាដើម ដោយហោច ភាជនៈជាគ្រឿងប្រើប្រាស់ កម្រាល សំពត់ដណ្តប់ និងសំពត់ក្រាលអង្គុយ ដោយលំដាប់ ហើយទំពាស៊ី ។

ក្នុងកាលដែលគាត់ចាស់ ទើបម្ចាស់ផ្ទះដេញចេញអំពីផ្ទះ ដែលបុរសនោះមានភោគៈអស់ហើយ លក់ផ្ទះរបស់ខ្លួនដែលធ្លាប់អាស្រ័យនៅ នាំកិរិយាទៅអាស្រ័យសំយាបផ្ទះរបស់អ្នកដទៃ កាន់អំបែងត្រាច់ទៅសូមទាន ប្រារព្ធនឹងបរិភោគភត្ត ដែលជាសំណល់របស់ពួកជនហើយ ។ កាលនោះ ព្រះសាស្តាទតឃើញបុរសនោះឈរត្រង់ទ្វាររោងធាន់ រង់ចាំទទួលភោជនដែលសល់អំពីភិក្ខុកំលោះ និងសាមណេរឲ្យក្នុងថ្ងៃមួយ ទើបទ្រង់ញញឹម ។ លំដាប់នោះព្រះអានន្ទទូលសួរដល់ហេតុដែលទ្រង់ញញឹម ។ ព្រះសាស្តា កាលនឹងត្រាស់ប្រាប់ហេតុដែលទ្រង់ញញឹម ទើបត្រាស់ថា ម្នាលអានន្ទ ចូរអ្នកមើលបុត្រសេដ្ឋីដែលមានទ្រព្យច្រើននេះ បំផ្លាញទ្រព្យអស់ ១៦០ កោដិ នាំកិរិយាដើរសូមទាន នៅក្នុងនគរនេះឯង បើសេដ្ឋីបុត្រនេះមិនបំផ្លាញទ្រព្យអស់ ប្រកបការងារក្នុងបឋមវ័យ ក៏នឹងបានជាសេដ្ឋីដ៏កំពូលក្នុងនគរនេះឯង បើចេញបួសនឹងសម្រេចអរហត្ត កិរិយារបស់បុរសនេះ នឹងតាំងនៅក្នុងអនាគាមិផល បើមិនបំផ្លាញទ្រព្យឲ្យអស់ទៅ នឹងប្រកបការងារក្នុងមជ្ឈិមវ័យ នឹងបានជាសេដ្ឋីលំដាប់ទីពីរ ចេញបួស នឹងបានជាអនាគាមី កិរិយានឹងតាំងនៅក្នុងសកទា-

គាមិផល បើមិនបំផ្លាញទ្រព្យឲ្យអស់ទៅ ប្រកបការងារក្នុងបច្ឆិមវ័យ នឹងបាន ជាសេដ្ឋីលំដាប់ទីបី បេញបួស នឹងបានសកទាគាមី កិរិយារបស់គេនឹងតាំង នៅក្នុងសោតាបត្តិផល តែឥឡូវនេះ កូនសេដ្ឋីនោះ វិនាសហើយចាកភោគៈ របស់គ្រហស្ថ វិនាសហើយចាកសាមញ្ញផល កាលវិនាសហើយ ទើបដូចជា ក្រៀលក្នុងកក់ស្ងួត ដូច្នេះហើយ ទើបទ្រង់ត្រាស់ព្រះគាថានេះថា

**អចរិត្វា ព្រហ្មចរិយំ អលទ្ធា យោព្វនេ ធនំ**
**ជិណ្ណកោញ្ចាវ ឈាយន្តិ ខីណមច្ឆេវ បល្លលេ ។**
**អចរិត្វា ព្រហ្មចរិយំ អលទ្ធា យោព្វនេ ធនំ**
**សេន្តិ ចាបាតិខីណាវ បុរាណានិ អនុត្ថុនំ ។**

ជនពាលទាំងឡាយ មិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបាន ទ្រព្យ ក្នុងកាលខ្លួននៅជាកំលោះក្រមុំ រមែងសញ្ជប់សញ្ជឹង ដូចសត្វក្រៀលចាស់សំកុកនៅក្នុងកក់ដែលអស់ត្រីហើយ ។ ជនពាលទាំងឡាយ មិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានទ្រព្យ ក្នុងកាលខ្លួននៅកំលោះក្រមុំ រមែងដេកថ្ងូរសោកស្តាយទ្រព្យ ចាស់ទាំងឡាយ ដូចព្រួញដែលផុតចាកខ្សែធ្នូនោះ ដូច្នោះ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **អចរិត្វា** សេចក្តីថា មិននៅក្នុងព្រហ្មចរិយាវាស ។ បទថា **យោព្វនេ** សេចក្តីថា មិនបានសូម្បីទ្រព្យក្នុងកាលដែលខ្លួន អាចញុំាងភោគៈដែលមិនកើតឲ្យកើតឡើង ឬដើម្បីតាមរក្សាភោគៈដែលកើត

ឡើងហើយ ។ បទថា **ឈាមច្ចេ** សេចក្តីថា បុគ្គលល្ងង់ខ្លៅបែបនោះ តែង សោកសៅដូចសត្វក្រៀលចាស់ មានរោមជ្រុះអស់ សោកសៅនៅក្នុងកក់ដែល ឈ្មោះថាអស់ត្រីហើយ ព្រោះមិនមានទឹក អធិប្បាយថា លោកពោលដូច្នេះ ថា ឯការមិនមានលំនៅរបស់បុគ្គលល្ងង់ខ្លៅទាំងនេះ ដូចការមិនមានទឹកក្នុងកក់ ព្រោះមិនមានភោគៈរបស់បុគ្គលល្ងង់ខ្លៅទាំងនេះ ដូចការអស់ត្រី ការមិនអាច រួបរួមភោគៈបានដោយផ្លូវគោក ឬផ្លូវទឹកជាដើម ក្នុងកាលឥឡូវនេះឯងរបស់ បុគ្គលល្ងង់ខ្លៅទាំងនេះ ដូចការមិនមានការផុសឡើង ហើយហើរទៅនៃសត្វ ក្រៀលដែលមានរោមស្វាបជ្រុះ ព្រោះដូច្នោះ បុគ្គលល្ងង់ខ្លៅទាំងនេះ ទើប ដេកសោកសៅក្នុងទីនេះឯង ដូចសត្វក្រៀលមានរោមស្វាបជ្រុះហើយដូច្នោះ ។

បទថា **ចាបាតិខីណាវ** សេចក្តីថា របូតចាកបន្ទោះ គឺផុតចាកបន្ទោះ មានពាក្យអធិប្បាយដូច្នេះថា ព្រួញផុតចាកបន្ទោះ ទៅតាមកម្លាំងធ្លាក់ហើយ កាលមិនមានបុគ្គលណាចាប់លើកឡើង ព្រួញនោះក៏ត្រូវក្លាយជាអាហាររបស់ កណ្តៀរក្នុងទីនោះឯង យ៉ាងណា បុគ្គលល្ងង់ខ្លៅទាំងនេះ ក៏ដូច្នោះ កន្លងវ័យ ទាំង ៣ ទៅហើយ ក៏នឹងចូលដល់មរណៈ ព្រោះការមិនអាចលើកខ្លួនឡើង បានក្នុងកាលឥឡូវនេះ ព្រោះដូច្នោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា **សេន្តិ ចាបាតិខីណាវ** ។

បាទព្រះគាថាថា **បុរាណានិ អនុត្ថុនំ** សេចក្តីថា រមែងដេកសំកុក គឺ

សោកសៅដល់ការបរិភោគ ការផឹក ការរាំ ការច្រៀង និងការប្រគំជាដើម ដែលខ្លួនធ្វើហើយក្នុងកាលមុនថា ពួកយើងស៊ីហើយយ៉ាងនេះ ផឹកហើយយ៉ាងនេះ ៗ

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ៕

**រឿងសេដ្ឋីបុត្រមានទ្រព្យច្រើន ចប់**

**ជរាវគ្គ ចប់**

**វគ្គទី ១១ ចប់**

# សុត្តន្តបិដក

## ធម្មបទគាថា អត្តវគ្គទី ១២

[ ២២ ] បើបណ្ឌិតដឹងថា ខ្លួនជាទីស្រឡាញ់ គួររក្សាខ្លួននោះឲ្យល្អ គួរស្ងួនគ្រងខ្លួនទុកក្នុងវ័យទាំង ៣ វ័យណាមួយ ។

បណ្ឌិត គួរតម្កល់ខ្លួនទុកក្នុងគុណ ដ៏សមគួរជាមុនសិន ហើយសឹមប្រៀនប្រដៅអ្នកដទៃ ជាខាងក្រោយ ( ធ្វើយ៉ាងនេះ ) នឹងមិនលំបាកឡើយ ។

បុគ្គលប្រៀនប្រដៅអ្នកដទៃ យ៉ាងណា ត្រូវធ្វើខ្លួនឲ្យបានយ៉ាងនោះដែរ អ្នកដែលទូន្មានខ្លួនល្អហើយ ទើបគួរទូន្មានអ្នកដទៃបាន ព្រោះថា ខ្លួនកម្រទូន្មានបានពេកណាស់ ។

ខ្លួនជាទីពឹងរបស់ខ្លួន អ្នកដទៃជាទីពឹងដូចម្តេចបាន ព្រោះបុគ្គលអ្នកមានខ្លួនហ្វឹកហ្វឺនល្អហើយ រមែងបាននូវទីពឹង ដែលគេបានដោយកម្រ ។

បាប កើតអំពីខ្លួន មានខ្លួនជាដែនកើត ដែលខ្លួនធ្វើហើយ តែងញាំញីមនុស្សឥតប្រាជ្ញា ដូចពេជ្រសម្រាប់កែវមណី ដែលកើតអំពីថ្ម ដូច្នោះឯង ។

ភាពជាអ្នកទ្រុស្តសីលហួសហេតុ គ្របសង្កត់ ( នូវអត្តភាព ) របស់បុគ្គលណា ដូចវល្លិ៍ដែលរួបរឹតដើមឈើ បុគ្គលនោះ ឈ្មោះថា ធ្វើខ្លួនឯងឲ្យវិនាស ដូចជាចោរអ្នកប្រាថ្នាធ្វើបុគ្គលនោះឲ្យវិនាស ដូច្នោះ ។

កម្មទាំងឡាយណា មិនល្អផង មិនជាប្រយោជន៍ដល់ខ្លួនផង កម្មទាំងនោះ ដែលជនពាលធ្វើបានដោយងាយ កម្មណាជាប្រយោជន៍ផង ល្អផង កម្មនោះឯង ដែលជនពាលធ្វើបានដោយលំបាក ។

បុគ្គលណា អប្បប្រាជ្ញា អាស្រ័យទិដ្ឋិដ៏លាមក ហាមឃាត់សាសនារបស់ព្រះអរហន្តទាំងឡាយដ៏ប្រសើរ រស់នៅដោយធម៌ ការហាមឃាត់របស់បុគ្គលនោះ រមែងចេញផល ដើម្បីសម្លាប់ខ្លួន ដូចផ្លែឫស្សី ដូច្នោះ ។

អ្នកធ្វើបាបខ្លួនឯង នឹងសៅហ្មងខ្លួនឯង អ្នកមិនធ្វើបាបខ្លួនឯង តែងបរិសុទ្ធស្អាតខ្លួនឯង សេចក្ដីបរិសុទ្ធ និងមិនបរិសុទ្ធ មានចំពោះខ្លួន អ្នកដទៃនឹងធ្វើអ្នកដទៃ ឲ្យបរិសុទ្ធពុំបានទេ ។

បុគ្គល កុំគប្បីធ្វើប្រយោជន៍ខ្លួនឲ្យវិនាស ព្រោះប្រយោជន៍របស់អ្នកដទៃ សូម្បីច្រើន បើដឹងច្បាស់នូវប្រយោជន៍របស់ខ្លួនហើយ គប្បីខ្វល់ខ្វាយក្នុងប្រយោជន៍របស់ខ្លួន ( នោះ ) ។

**អត្តវគ្គទី ១២ ចប់**

# អដ្ឋកថា
# អត្តវគ្គទី ១២

## រឿង ពោធិរាជកុមារ
### លំនាំដើម

*ព្រះសាស្តា កាលគង់នៅក្នុងភេសកឡាវ័ន ទ្រង់ប្រារព្ធពោធិរាជកុមារ ត្រាស់ព្រះធម្មទេសនានេះថា* **អត្តានញ្ចេ** *ជាដើម ។*

*បានឮមកថា ពោធិរាជកុមារឲ្យសាងប្រាសាទ ឈ្មោះកោកនទៈ មានទ្រង់ទ្រាយមិនដូចប្រាសាទដទៃៗ លើផែនដី តែមានរាងដូចអណ្តែតនៅក្នុងអាកាសហើយ ត្រាស់សួរជាងថា ប្រាសាទដែលមានរូបរាងយ៉ាងនេះ អ្នកធ្លាប់សាងក្នុងទីដទៃខ្លះហើយឬ ឬថា នេះជាសិប្បៈដំបូងរបស់អ្នក កាលមេជាងទូលថា បពិត្រព្រះសម្មតិទេព នេះជាសិប្បៈដំបូងនោះឯង ព្រះរាជាទ្រង់ព្រះតម្រិះថា បើមេជាងនេះសាងប្រាសាទ ដែលមានទ្រង់ទ្រាយបែបនេះដល់អ្នកដទៃសោត ប្រាសាទនេះក៏មិនគួរអស្ចារ្យ កាលដែលអញសម្លាប់មេជាងនេះចោល កាត់ដៃកាត់ជើង ឬខ្វេះភ្នែកទាំងពីរ រមែងគួរ កាលបើដូច្នោះ មេជាងនេះសាងប្រាសាទដល់អ្នកដទៃមិនបាន ព្រះរាជាប្រាប់សេចក្តីនោះដល់មាណពតូច កូនរបស់សញ្ជីវកៈ ដែលជាសម្លាញ់ជិតស្និទ្ធរបស់ខ្លួន ។*

*មាណពតូចនោះ គិតថា ព្រះរាជកុមារអង្គនេះ បំផ្លាញមេជាងឲ្យវិនាស*

ដោយឥតសង្ស័យ មនុស្សដែលមានសិប្បៈកាត់ថ្លៃមិនបាន បើអញនៅមានចូរបុគ្គលនោះកុំវិនាសឡើយ អញនឹងឲ្យសញ្ញាដល់មេជាងនេះ ។ មាណពតូចចូលទៅរកមេជាងហើយសួរថា ការងាររបស់អ្នកឯប្រាសាទ សម្រេចហើយឬនៅ កាលមេជាងប្រាប់ថា សម្រេចហើយ ទើបពោលថា ព្រះរាជកុមារមានបំណងនឹងបំផ្លាញអ្នកឲ្យវិនាស ព្រោះដូច្នោះ អ្នកគប្បីរក្សាខ្លួនឲ្យល្អ ។

មេជាងពោលថា នែអ្នក អ្នកប្រាប់សេចក្តីនោះដល់ខ្ញុំ ធ្វើសុចរិតកម្មហើយ ខ្ញុំនឹងដឹងកិច្ចដែលគួរធ្វើក្នុងរឿងនេះ ដូច្នេះហើយ កាលព្រះរាជកុមារត្រាស់សួរថា សម្លាញ់ ការងាររបស់អ្នកត្រង់ប្រាសាទរបស់យើង សម្រេចហើយឬ ទើបទូលថា បពិត្រព្រះសម្មតិទេព ការងារត្រង់ប្រាសាទមិនទាន់សម្រេចនៅឡើយ នៅសល់ច្រើនទៀត ។ ព្រះរាជកុមារសួរថា ការងារអ្វីដែលនៅសល់ ជាងទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គនឹងទូលក្នុងកាលជាក្រោយ សូមទ្រង់ត្រាស់ឲ្យបុគ្គលណាម្នាក់ ជញ្ជូនឈើមកសិនចុះ ព្រះរាជកុមារត្រាស់សួរថា នឹងឲ្យជញ្ជូនឈើប្រភេទណាមក មេជាងទូលថា បពិត្រព្រះអង្គ ឈើស្ងួតមិនមានខ្លឹម ។

ព្រះរាជាបានឲ្យជញ្ជូនមកហើយ ។ លំដាប់នោះ មេជាងទូលព្រះរាជ-កុមារនោះថា បពិត្រព្រះសម្មតិទេព ចាប់តាំងអំពីនេះទៅ ទ្រង់មិនចាំបាច់យាងមកកាន់សម្នាក់របស់ទូលបង្គំឡើយ ព្រោះកាលទូលបង្គំធ្វើការងារល្អិតល្អន់ បើមានការសន្ទនានឹងអ្នកដទៃ ការរាយមាយក៏គប្បីមានម្យ៉ាងទៀតពេលទទួលទានអាហារ ភរិយាទូលបង្គំប៉ុណ្ណោះនឹងនាំអាហារមក ។ ព្រះរាជ-

កុមារទ្រង់ទទួលថា សាធុ ចំណែកជាងនោះ ចាំងឈើទាំងនោះក្នុងបន្ទប់មួយ ធ្វើជាសត្វគ្រុឌ គួរដល់បុត្រកិរិយារបស់ខ្លួនអង្គុយខាងក្នុងបាន ក្នុងពេលទទួលទានអាហារ ប្រាប់កិរិយាថា ចូរនាងលក់របស់គ្រប់យ៉ាងក្នុងផ្ទះហើយទទួលយកប្រាក់ និងមាស ។

ចំណែកព្រះរាជកុមារត្រាស់ឲ្យព័ទ្ធផ្ទះ ទ្រង់រៀបចំការរក្សា ដើម្បីជាប្រយោជន៍កុំឲ្យមេជាងចេញទៅបាន ។ មេជាង ក្នុងកាលដែលបក្សីសម្រេចហើយ ប្រាប់កិរិយាថា ថ្ងៃនេះនាងគប្បីនាំកូនទាំងអស់មក ទទួលទានអាហារព្រឹកស្រេចហើយ ឲ្យបុត្រ និងកិរិយាអង្គុយក្នុងពោះគ្រុឌ បេញតាមបង្អួចលួចគេចទៅហើយ កាលអ្នករក្សាទាំងនោះទូលរៀបរាប់ថា បពិត្រព្រះសម្មតិទេព មេជាងលបគេចទៅបាន ដូច្នេះនោះឯង ជាងនោះក៏ទៅចុះត្រង់ហិមវន្តប្រទេស សាងនគរមួយបានជាព្រះរាជា ព្រះនាមកដ្ឋវាហនៈក្នុងនគរនោះ ។

ចំណែកព្រះរាជកុមារ ទ្រង់ព្រះតម្រិះថា អញធ្វើការឆ្លងប្រាសាទ ទើបឲ្យនិមន្តព្រះសាស្ដា ទ្រង់ធ្វើការប្រោះព្រំក្នុងប្រាសាទ ដោយគ្រឿងគន្ធជាតិ ៤ យ៉ាង ទ្រង់ក្រាលកម្រាលតូចតាំងអំពីធរណីទ្វារទីមួយ បានឮថា ព្រះរាជាមិនមានព្រះឱរស ព្រោះដូច្នោះ ទើបទ្រង់ព្រះតម្រិះថា បើអញបានបុត្រ ឬធីតាសោត ព្រះសាស្ដានឹងជាន់សំពត់តូចនេះ ហើយទើបទ្រង់ក្រាល ។ ព្រះរាជា កាលព្រះសាស្ដាយាងមក ថ្វាយបង្គំហើយ ដោយបញ្ចង្គប្រតិស្ឋានទទួលបាត្រ ក្រាបទូលថា សូមនិមន្តទ្រង់យាងចូលចុះ ព្រះសាស្ដាមិនយាងចូល ព្រះរាជាទ្រង់និមន្តអស់វារៈ ២-៣ ដង ព្រះសាស្ដាក៏មិនយាងចូលទៅ

ទ្រង់មើលព្រះអានន្ទ ។

ព្រះថេរៈ ជ្រាបការដែលទ្រង់មិនជាន់សំពត់ទាំងឡាយ ដោយសញ្ញាដែលទ្រង់ទតនោះឯង ទើបទូលឲ្យព្រះរាជកុមារដកសំពត់ទាំងឡាយចេញដោយពាក្យថា មហាបពិត្រ សូមទ្រង់សាសំពត់ទាំងឡាយចេញចុះ ព្រះសាស្តាទ្រង់មិនជាន់សំពត់នេះឡើយ ព្រោះព្រះតថាគតទ្រង់សម្លឹងមើលមហាជនដែលកើតឯក្រោយ ។

ព្រះរាជាទ្រង់ដកសំពត់ទាំងឡាយហើយ ទូលអារាធនាឲ្យទ្រង់ចូលទៅខាងក្នុង ទ្រង់អង្គាសឲ្យឆ្អែតស្កប់ស្កល់ដោយបបរ និងរបស់ទំពា ហើយគង់ក្នុងទីសមគួរនាចំណែកម្ខាង ថ្វាយបង្គំហើយទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គជាឧបដ្ឋាករបស់ទ្រង់ ដល់នូវទ្រង់ថាជាទីពឹងអស់វារៈ ៣ ដងហើយ បានឮថាព្រះរាជាកាលនៅក្នុងផ្ទៃ ដល់នូវសរណៈជាទីពឹងទីរឭកលើកទី ១ ក្នុងលើកទី ២ ក្នុងកាលដែលខ្ញុំព្រះអង្គជាកុមារ ក្នុងលើកទី ៣ ក្នុងកាលដែលខ្ញុំព្រះអង្គ ដល់នូវភាពជាអ្នកដឹងក្តី ទ្រង់មិនជាន់ផ្ទាំងសំពត់តូចរបស់ខ្ញុំព្រះអង្គនោះព្រោះហេតុអ្វី ។ ព្រះសាស្តាត្រាស់ថា ព្រះរាជកុមារ ទ្រង់ត្រិះរិះដូចម្តេចទើបក្រាលផ្ទាំងសំពត់តូច ព្រះរាជកុមារត្រាស់ថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គគិតថា បើបានបុត្រ ឬធីតាសោត ព្រះសាស្តាទ្រង់នឹងជាន់ផ្ទាំងសំពត់តូចរបស់អញ ហើយទើបក្រាលផ្ទាំងសំពត់តូច ព្រះសាស្តាត្រាស់ថា ព្រះរាជ-កុមារ ព្រោះហេតុនោះ ទើបតថាគតមិនជាន់ ព្រះរាជកុមារទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គមិនបានបុត្រ ឬធីតាទេឬ ព្រះសាស្តាត្រាស់ថា ព្រះរាជកុមារ

យ៉ាងនោះឯង ព្រះរាជកុមារត្រាស់ថា បពិត្រព្រះអង្គ ព្រោះហេតុអ្វី ព្រះសាស្ដាត្រាស់ថា ព្រោះទ្រង់ និងព្រះជាយា ជាអ្នកដល់នូវសេចក្ដីប្រមាទហើយ ក្នុងអត្តភាពមុន ព្រះរាជកុមារត្រាស់ថា បពិត្រព្រះអង្គ ក្នុងកាលណា ។ លំដាប់នោះ ព្រះសាស្ដា ទ្រង់នាំអតីតនិទានមកសម្ដែងដល់ព្រះរាជកុមារនោះថា

បានឮមកថា ក្នុងអតីតកាល មនុស្សច្រើនរយនាក់ធ្វើដំណើរតាមទូកធំទៅកាន់សមុទ្រ ទូកក៏លិចកណ្ដាលសមុទ្រ ស្វាមីភរិយាស្រវាបានបន្ទះក្ដារមួយ ហែលទៅកាន់កោះតូចដែលមានក្នុងចន្លោះ មនុស្សដ៏សេសស្លាប់ទាំងអស់ ក្នុងមហាសមុទ្រនោះឯង ។ ពួកបក្សីជាច្រើននៅត្រង់កោះនោះឯង ជនទាំងពីរមិនឃើញវត្ថុដទៃដែលគួរបរិភោគបាន ត្រូវសេចក្ដីឃ្លានគ្របសង្កត់ហើយ ទើបដុតស៊ុតបក្សីទាំងឡាយត្រង់រងើកភ្លើង ហើយបរិភោគ កាលស៊ុតបក្សីទាំងនោះ មិនគ្រប់គ្រាន់ ក៏ចាប់កូនបក្សីទាំងឡាយអាំងបរិភោគ កាលកូនបក្សីទាំងនោះ មិនគ្រប់គ្រាន់ ក៏ចាប់មេបក្សីទាំងឡាយបរិភោគ ក្នុងបឋមវ័យក្ដី មជ្ឈិមវ័យក្ដី បច្ឆិមវ័យក្ដី បានទំពាស៊ីយ៉ាងនោះឯង ក្នុងថ្ងៃមួយ ក៏មិនបានដល់នូវការមិនប្រមាទម្យ៉ាងទៀត បណ្ដាជនទាំងពីរនោះ សូម្បីបុគ្គលម្នាក់ ក៏មិនបានដល់នូវសេចក្ដីមិនប្រមាទ ។

ព្រះសាស្ដា កាលទ្រង់សម្ដែងបុព្វកម្មនេះរបស់ពោធិរាជកុមារនោះហើយត្រាស់ថា ព្រះរាជកុមារ ក្នុងកាលនោះ បើទ្រង់ និងមហេសីដល់នូវការមិនប្រមាទ សូម្បីក្នុងវ័យមួយសោត បុត្រ ឬធីតាគប្បីកើតឡើង ក្នុងវ័យណា

មួយ បើបណ្ដាអ្នកទាំងពីរ អ្នកណាម្នាក់បានជាអ្នកមិនប្រមាទហើយសោត បុត្រ ឬធីតា នឹងអាស្រ័យបុគ្គលមិនប្រមាទនោះកើតឡើង ម្នាលព្រះរាជកុមារ បុគ្គល កាលសម្គាល់ខ្លួនថាជាទីស្រឡាញ់ គប្បីមិនប្រមាទ រក្សាខ្លួនក្នុងវ័យទាំង ៣ បើមិនអាចយ៉ាងនោះ គប្បីរក្សាឲ្យបានក្នុងវ័យណាមួយ ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

**អត្តានញ្ចេ បិយំ ជញ្ញា រក្ខេយ្យ នំ សុរក្ខិតំ**
**តិណ្ណំ អញ្ញតរំ យាមំ បដិជគ្គេយ្យ បណ្ឌិតោ ។**

បើបណ្ឌិតដឹងថា ខ្លួនជាទីស្រឡាញ់ គួររក្សាខ្លួននោះឲ្យល្អ
គួរស្ងួនគ្រងខ្លួនទុកក្នុងវ័យទាំង ៣ វ័យណាមួយ ។

## សេចក្ដីអធិប្បាយ

បណ្ដាបទទាំងនោះ បទថា **យាមំ** នេះ ព្រះសាស្ដាទ្រង់សម្ដែងធ្វើវ័យទាំង ៣ វ័យណាមួយ ឲ្យឈ្មោះថា ជាយាម ព្រោះភាពដែលទ្រង់ជាធំក្នុងធម៌ និងព្រោះភាពដែលទ្រង់ឈ្លាសក្នុងទេសនាវិធី ព្រោះហេតុនោះ ក្នុងព្រះគាថានេះ បណ្ឌិតគប្បីជ្រាបសេចក្ដីយ៉ាងនេះថា បើបុគ្គលដឹងថា ខ្លួនជាទីស្រឡាញ់ គប្បីរក្សាខ្លួននោះឲ្យជាការរក្សាល្អហើយ គឺគប្បីរក្សាខ្លួននោះដោយប្រការដែលខ្លួនរក្សាល្អហើយ ។

បណ្ដាជនដែលរក្សាខ្លួនទាំងនោះ បើបុគ្គលជាគ្រហស្ថគិតថា នឹងរក្សាខ្លួន ដូច្នេះហើយ ចូលទៅកាន់បន្ទប់ដែលគេបិទឲ្យរៀបរយ ជាបុគ្គលមានការរក្សាបរិបូណ៌ ឡើងលើផ្ទៃប្រាសាទជាន់លើក្ដី បុគ្គលជាបព្វជិត នៅក្នុង

គុហាដែលបិទល្អល្អិត មានទ្វារ និងបង្អួចបិទល្អហើយក្តី មិនឈ្មោះថា រក្សាខ្លួនឡើយ តែបុគ្គលជាគ្រហស្ថធ្វើបុណ្យទាំងឡាយ មានឲ្យទាន រក្សាសីលជាដើមតាមកម្លាំង ឬដែលជាបព្វជិត ដល់នូវការខ្វល់ខ្វាយក្នុងវត្ត បដិវត្ត បរិយត្តិ និងការធ្វើទុកក្នុងចិត្ត ឈ្មោះថា រមែងរក្សាខ្លួន ។

បុរសដែលជាបណ្ឌិត កាលមិនអាចធ្វើយ៉ាងនោះបានក្នុងវ័យទាំង ៣ ត្រូវស្ងួនគ្រងខ្លួនក្នុងវ័យណាមួយ ក៏បានដូចគ្នា បើបុគ្គលជាគ្រហស្ថ មិនអាចធ្វើកុសលបានក្នុងបឋមវ័យ ព្រោះជាអ្នកជាប់ជំពាក់ក្នុងការលេងសោត ក្នុងមជ្ឈិមវ័យ គប្បីជាអ្នកមិនប្រមាទ បំពេញកុសល បើក្នុងមជ្ឈិមវ័យ ចាំបាច់ចិញ្ចឹមបុត្រ និងភរិយា មិនអាចបំពេញកុសលបានសោត ក្នុងបច្ឆិមវ័យ គប្បីបំពេញកុសល ឲ្យបានដោយអាការយ៉ាងនេះ ខ្លួនត្រូវជាបុគ្គលស្ងួនគ្រងខ្លួនឯងនោះឯង តែកាលមិនអាចធ្វើយ៉ាងនោះ ខ្លួន ឈ្មោះថា មិនជាទីស្រឡាញ់ ។ បុគ្គលនោះ ធ្វើខ្លួននោះឲ្យមានអបាយជាទីទៅខាងមុខនោះឯង ។

បើបព្វជិត ក្នុងបឋមវ័យ ធ្វើការស្វាធ្យាយ ទ្រទ្រង់ចាំ ប្រាប់ ធ្វើវត្ត និងបដិវត្ត ឈ្មោះថា ដល់នូវសេចក្តីប្រមាទ ក្នុងមជ្ឈិមវ័យ គប្បីជាបុគ្គលមិនប្រមាទ បំពេញសមណធម៌ ។

ម្យ៉ាងទៀត បើរវល់តែសាកសួរអដ្ឋកថា និងវិនិច្ឆ័យ និងហេតុនៃព្រះបរិយត្តិ ដែលខ្លួនរៀនហើយក្នុងបឋមវ័យ ឈ្មោះថា ដល់នូវសេចក្តីប្រមាទក្នុងមជ្ឈិមវ័យ ក្នុងបច្ឆិមវ័យ គប្បីជាអ្នកមិនប្រមាទ បំពេញសមណធម៌ដោយអាការយ៉ាងនេះ ខ្លួន ឈ្មោះថា បព្វជិតនោះស្ងួនគ្រងហើយនោះឯង ។

តែកាលមិនធ្វើយ៉ាងនោះ ខ្លួន ឈ្មោះថា មិនជាទីស្រឡាញ់ បព្វជិតនោះស្មើ គ្នានឹងធ្វើខ្លួននោះឲ្យក្តៅក្រហាយ ដោយការតាមក្តៅក្រហាយក្នុងកាលខាង ក្រោយពិត ។

កាលចប់ទេសនា ពោធិរាជកុមារតាំងនៅក្នុងសោតាបត្តិផលហើយ ព្រះ ធម្មទេសនាបានជាប្រយោជន៍ដល់បរិស័ទ ដែលប្រជុំគ្នាហើយដូច្នេះឯង ។ល។

**រឿង ពោធិរាជកុមារ ចប់**

# រឿង ព្រះឧបនន្ទសក្យបុត្រ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះឧបនន្ទសក្យ-បុត្រ ត្រាស់ព្រះធម្មទេសនានេះថា **អត្តានមេវ បឋមំ** ជាដើម ។

បានឮមកថា ព្រះថេរៈនោះឈ្លាសក្នុងការពោលធម្មកថា ភិក្ខុជាច្រើន ស្តាប់ធម្មកថា ដែលបដិសំយុត្តដោយភាពជាបុគ្គល មានសេចក្តីប្រាថ្នាតិចជា ដើមរបស់លោកហើយ ទើបបូជាដោយចីវរទាំងឡាយ សមាទានធុតង្គ ព្រះ ឧបនន្ទនោះមួយរូប ទទួលយកបរិក្ខារដែលភិក្ខុទាំងនោះលះបង់ហើយ ។

លុះក្នុងរដូវវស្សាជិតចូលមកដល់ ព្រះឧបនន្ទនោះបានទៅកាន់ជនបទ ហើយ ។ លំដាប់នោះ ភិក្ខុកំលោះ និងសាមណេរក្នុងវិហារពោលនឹងលោក ដោយសេចក្តីស្រឡាញ់ក្នុងធម្មកថិកថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់

ចូលវស្សាក្នុងទីនេះចុះ ព្រះឧបនន្ទសួរថា ក្នុងវិហារនេះបានសំពត់ចំណាំវស្សាប៉ុន្មានផ្ទាំង កាលភិក្ខុទាំងនោះឆ្លើយថា បានមួយអន្ថ ១ ផ្ទាំង ទើបទុកស្បែកជើងក្នុងវិហារនោះ បានទៅវិហារដទៃ ដល់វិហារទីពីរហើយសួរថា ក្នុងវិហារនេះភិក្ខុទាំងឡាយបានអ្វី កាលភិក្ខុឆ្លើយថា បានសាដកពីរផ្ទាំង ទើបទុកឈើប្រត់ក្នុងទីនោះ ដល់វិហារទី ៣ សួរថា ក្នុងវិហារនេះភិក្ខុទាំងឡាយបានអ្វី កាលភិក្ខុឆ្លើយថា បានសំពត់សាដក ៣ ផ្ទាំង ទើបទុកធម្មក្រកក្នុងទីនោះ ដល់វិហារទី ៤ សួរថា ក្នុងវិហារនេះភិក្ខុទាំងឡាយបានអ្វី កាលពួកភិក្ខុឆ្លើយថា បានសាដក ៤ ផ្ទាំង ពោលថា សាធុ ខ្ញុំនឹងនៅទីនេះ ដូច្នេះហើយ ចាំវស្សាក្នុងវិហារនោះ ពោលធម្មកថាដល់គ្រហស្ថ និងភិក្ខុទាំងឡាយនោះឯង គ្រហស្ថនិងភិក្ខុទាំងឡាយនោះ បូជាព្រះឧបនន្ទនោះដោយសំពត់ និងចីវរជាច្រើន ។ ព្រះឧបនន្ទនោះ ចេញវស្សាហើយ ឲ្យដំណឹងទៅវិហារក្រៅអំពីនេះថា ខ្ញុំគួរបានសំពត់ចំណាំវស្សា ព្រោះខ្ញុំទុកបរិក្ខារ ចូរភិក្ខុទាំងឡាយបញ្ជូនសំពត់ចំណាំវស្សាឲ្យខ្ញុំ ឲ្យនាំសំពត់ចំណាំវស្សាទាំងអស់មកហើយ ដាក់ពេញរទេះតូចបរទៅ ។

កាលនោះភិក្ខុពីររូប នៅក្នុងវិហារមួយកន្លែង បានសំពត់សាដកពីរផ្ទាំង សំពត់កម្ពលមួយផ្ទាំង មិនអាចចែកគ្នាបានថា សំពត់សាដកចូរជារបស់លោក សំពត់កម្ពលនឹងជារបស់ខ្ញុំ អង្គុយប្រកែកគ្នាត្រង់កណ្តាលផ្លូវ ភិក្ខុពីររូបនោះឃើញព្រះថេរៈដើរមក ទើបពោលថា សូមលោកម្ចាស់ជួយចែកឲ្យដល់ខ្ញុំផងចុះ ព្រះថេរៈពោលថា ចូរពួកលោកចែកគ្នាដោយខ្លួនឯងចុះ ភិក្ខុទាំងនោះ

ពោលថា ពួកខ្ញុំមិនអាច សូមលោកម្ចាស់ចែកឲ្យពួកខ្ញុំចុះ ព្រះថេរៈសួរថា ពួកលោកតាំងនៅក្នុងពាក្យរបស់ខ្ញុំឬ ពួកភិក្ខុពោលថា បពិត្រលោកម្ចាស់ ពួកខ្ញុំនឹងតាំងនៅ ព្រះថេរៈនោះពោលថា សាធុ បើដូច្នោះ ខ្ញុំនឹងចែក ហើយឲ្យសំពត់សាដកពីរផ្ទាំង ដល់ភិក្ខុពីររូបនោះឯង ពោលថា សំពត់កម្ពលនេះ ចូរជាសំពត់ដណ្តប់របស់ខ្ញុំដែលពោលធម្មកថា ដូច្នេះហើយ ក៏កាន់យកសំពត់កម្ពលដែលមានតម្លៃច្រើន ចៀសចេញទៅ ។ ពួកភិក្ខុកំលោះ ជាអ្នកដល់នូវសេចក្តីក្តៅក្រហាយ ទៅកាន់សម្នាក់ព្រះសាស្តា ក្រាបទូលសេចក្តីនោះហើយ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឧបនន្ទនេះកាន់យកទ្រព្យរបស់ពួកអ្នក ធ្វើឲ្យពួកអ្នកក្តៅក្រហាយតែក្នុងឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ក៏ធ្វើហើយដូចគ្នា ដូច្នេះហើយ ទ្រង់នាំអតីតនិទានមកត្រាស់ថា

ក្នុងអតីតកាល ភេពីរ ភេមួយរកស៊ីទឹករាក់ ភេមួយរកស៊ីទឹកជ្រៅ ចាប់បានត្រីធ្មិនធំមួយ ដល់នូវការឈ្លោះគ្នាថា ក្បាលជារបស់ខ្ញុំ កន្ទុយជារបស់អ្នក មិនអាចចែកគ្នាបាន ឃើញឆ្កែចចកមួយ ទើបពោលថា បពិត្រលោកអ៊ំ សូមអ៊ំជួយចែកត្រីនេះឲ្យដល់ពួកខ្ញុំ ឆ្កែចចកពោលថា យើង គឺព្រះរាជាតាំងទុកក្នុងតំណែងចៅក្រម យើងអង្គុយត្រង់ទីវិនិច្ឆ័យនោះយូរហើយ ទើបមកដើម្បីដើរលេង ឥឡូវនេះ ឱកាសរបស់យើងមិនមាន ភេពោលថា សូមអ៊ំកុំធ្វើយ៉ាងនោះឡើយ មេត្តាជួយចែកឲ្យពួកខ្ញុំផងចុះ ចចកពោលថា ពួកអ្នកតាំងនៅក្នុងពាក្យរបស់យើងឬ ភេពោលថា ខ្ញុំនឹងតាំងនៅ ។

ចចកនោះពោលថា សាធុ បើដូច្នោះ ខ្ញុំនឹងចែក ទើបការក្បាលទុក ម្ខាង កន្ទុយទុកម្ខាង កាលធ្វើហើយ ទើបពោលថា នែបាទាំងពីរ បណ្ដាពួក បាទាំងពីរ មួយណារកស៊ីទឹករាក់ មួយនោះត្រូវបានកន្ទុយ មួយណារកស៊ីទឹក ជ្រៅ មួយនោះត្រូវបានក្បាល ចំណែកកំណាត់កណ្ដាលនេះជារបស់ខ្ញុំ ដែល តាំងនៅក្នុងវិនិច្ឆ័យធម៌ កាលឲ្យភេទាំងនោះយល់ព្រម ទើបពោលគាថាថា

ម្នាលភេ អ្នកត្រាច់ទៅតាមឆ្នេរ ( អ្នកត្រូវបាន ) កន្ទុយ
ភេដែលត្រាច់ទៅក្នុងទឹកជ្រៅ ( ត្រូវបាន ) ក្បាល ដុំជា
កណ្ដាល ក្រៅអំពីចំណែកពីរនេះ ត្រូវបាន ( យើង ) អ្នកស្ថិត
នៅក្នុងតំណែងជម្រះក្ដី ។

ដូច្នេះហើយ ពាំកំណាត់កណ្ដាល ចៀសចេញទៅ ភេទាំងពីរនោះ ក្ដៅក្រហាយ បានឈរមើលចចកនោះហើយ ។

ព្រះសាស្ដា កាលទ្រង់នាំអតីតនិទាននេះមកហើយ ត្រាស់ថា ក្នុង អតីតកាល ឧបនន្ទនេះ បានធ្វើពួកអ្នកឲ្យក្ដៅក្រហាយយ៉ាងនេះដូចគ្នា ឲ្យភិក្ខុ ទាំងនោះយល់ព្រមហើយ កាលនឹងតិះដៀលព្រះឧបនន្ទ ទើបត្រាស់ថា

**អត្តានមេវ បឋមំ បដិរូបេ និវេសយេ**
**អថញ្ញមនុសាសេយ្យ ន កិលិស្សេយ្យ បណ្ឌិតោ ។**

បណ្ឌិត គួរតម្កល់ខ្លួនទុកក្នុងគុណដ៏សមគួរជាមុនសិន
ហើយសឹមប្រៀនប្រដៅអ្នកដទៃជាខាងក្រោយ ( ធ្វើ
យ៉ាងនេះ ) នឹងមិនលំបាកឡើយ ។

# សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បាទព្រះគាថាថា **បដិរូបេ និវេសយេ** បានដល់ គប្បីញុំាងខ្លួនឲ្យតាំងនៅក្នុងគុណដ៏សមគួរ ព្រះសាស្តាត្រាស់ពាក្យនេះថា បុគ្គលណាបំណងប្រៀនប្រដៅអ្នកដទៃដោយគុណ មានការប្រាថ្នាតិចជាដើម ឬដោយបដិបទារបស់អរិយវង្សជាដើម បុគ្គលនោះគប្បីញុំាងខ្លួននោះឯងឲ្យតាំងនៅក្នុងគុណនោះមុន កាលតាំងខ្លួនទុកយ៉ាងនោះហើយ គប្បីប្រៀនប្រដៅអ្នកដទៃដោយគុណនោះ ក្នុងកាលខាងក្រោយ ព្រោះថា បុគ្គលកាលមិនញុំាងខ្លួនឲ្យតាំងនៅក្នុងគុណនោះ ទូន្មានអ្នកដទៃតែម្យ៉ាងប៉ុណ្ណោះ បាននូវការនិន្ទាអំពីអ្នកដទៃហើយ ឈ្មោះថា រមែងសៅហ្មង ។ បុគ្គលកាលញុំាងខ្លួនឲ្យតាំងនៅក្នុងគុណនោះហើយ ទូន្មានអ្នកដទៃ រមែងបានទទួលនូវសេចក្តីសរសើរអំពីអ្នកដទៃ ព្រោះដូច្នោះ ទើបឈ្មោះថា រមែងមិនសៅហ្មង បណ្ឌិតកាលធ្វើយ៉ាងនេះ ឈ្មោះថា មិនគប្បីសៅហ្មង ។

ក្នុងកាលចប់ទេសនា ភិក្ខុពីររូបនោះតាំងនៅក្នុងសោតាបត្តិផល ទេសនាបានប្រព្រឹត្តទៅដោយប្រយោជន៍ដល់មហាជនដូច្នេះឯង ។៚

**រឿង ព្រះឧបនន្ទសក្យបុត្រ ចប់**

# រឿង ព្រះបធានិកតិស្សត្ថេរ

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះបធានិកតិស្សត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **អត្តានញ្ចេ** ជាដើម ។

បានឮមកថា ព្រះថេរៈនោះរៀនព្រះកម្មដ្ឋានក្នុងសម្នាក់របស់ព្រះសាស្ដាហើយ ពួកភិក្ខុប្រមាណ ៥០០ រូបទៅចាំវស្សាក្នុងព្រៃ ពោលទូន្មានថា អាវុសោទាំងឡាយ ពួកលោករៀនកម្មដ្ឋានក្នុងសម្នាក់ព្រះពុទ្ធដែលគង់ព្រះជន្មនៅ ចូរជាអ្នកមិនប្រមាទ ធ្វើសមណធម៌ចុះ ដូច្នេះហើយ ខ្លួនឯងក៏ទៅសិងលក់ ភិក្ខុទាំងនោះចង្ក្រមក្នុងបឋមយាមហើយ ចូលទៅកាន់វិហារក្នុងមជ្ឈិមយាម ព្រះថេរៈនោះទៅកាន់សម្នាក់របស់ភិក្ខុទាំងនោះ ក្នុងពេលដែលខ្លួនសិងលក់ហើយភ្ញាក់ឡើងពោលថា ពួកលោកមកដោយបំណងថា នឹងដេកលក់ដូច្នេះឬ ចូរប្រញាប់ចេញទៅធ្វើសមណធម៌ចុះ ដូច្នេះហើយ ខ្លួនឯងក៏ទៅសិងយ៉ាងនោះឯង ។ ពួកភិក្ខុក្រៅអំពីនេះ ចង្ក្រមខាងក្រៅ ក្នុងមជ្ឈិមយាមហើយ ទៅកាន់វិហារក្នុងបច្ឆិមយាម ព្រះថេរៈនោះភ្ញាក់ឡើងហើយ ទៅកាន់សម្នាក់របស់ភិក្ខុទាំងនោះ នាំភិក្ខុទាំងនោះចេញអំពីវិហារហើយ ខ្លួនឯងក៏ទៅសិងលក់យ៉ាងនោះទៀត កាលព្រះថេរៈធ្វើយ៉ាងនោះអស់កាលជានិច្ច ភិក្ខុទាំងនោះមិនអាចធ្វើការស្វាធ្យាយ ឬធ្វើព្រះកម្មដ្ឋានក្នុងចិត្តបាន ទើបដល់នូវការរាយមាយហើយ ។ ភិក្ខុទាំងនោះប្រឹក្សាគ្នាថា អាចារ្យរបស់ពួកយើងប្រារព្ធព្យាយាមពន់ពេក ពួកយើងនឹងឃ្លាំមើលលោក កាលឃ្លាំមើលឃើញកិរិយា

របស់ព្រះថេរៈនោះហើយ ពោលថា អាវុសោទាំងឡាយ ពួកយើងវិនាស អាចារ្យរបស់ពួកយើង ស្រែកទទេៗ បណ្ដាភិក្ខុទាំងនោះលំបាកពន់ពេក សូម្បីភិក្ខុមួយរូប ក៏មិនអាចញុំាំងគុណវិសេសឲ្យកើតបាន ភិក្ខុទាំងនោះចេញវស្សាហើយ ទៅកាន់សម្នាក់របស់ព្រះសាស្ដា មានបដិសណ្ឋារៈដែលព្រះសាស្ដាទ្រង់ធ្វើហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកជាអ្នកមិនប្រមាទ ធ្វើសមណធម៌ឬ ទើបក្រាបទូលសេចក្ដីនោះ ។

ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះបានធ្វើអន្តរាយដល់ពួកអ្នកមិនមែនតែក្នុងឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ភិក្ខុនោះក៏បានធ្វើអន្តរាយដល់ពួកអ្នកដូចគ្នា កាលភិក្ខុទាំងនោះទូលអារាធនាហើយ ទើបទ្រង់ញុំាំងអកាលរាវិកុក្កុដជាតកឲ្យពិស្ដារ តែក្នុងទីនេះមានសេចក្ដីសង្ខេបថា[១]

-១ បិដកខ្មែរអកាលរាវិជាតក ។

មាន់នេះ ចម្រើននៅក្នុងសម្នាក់នៃបុគ្គល មិនមែនជាមាតាបិតា កាលនៅក្នុងត្រកូល នៃបុគ្គលមិនមែនជាអាចារ្យ រមែងមិនដឹងច្បាស់នូវកាលគួររងាវ ឬកាលមិនគួររងាវ ។

ដូច្នេះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុកាលពោលប្រៀនប្រដៅអ្នកដទៃ គប្បីធ្វើខ្លួនដែលទូន្មានល្អហើយ ព្រោះបុគ្គលកាលប្រៀនប្រដៅយ៉ាងនោះ ជាបុគ្គលមានខ្លួនទូន្មានហើយ ឈ្មោះថា រមែងទូន្មានបាន ហើយត្រាស់ព្រះគាថានេះថា

**អត្តានញ្ចេ តថា កយិរា យថញ្ញមនុសាសតិ**

**សុទន្តោ វត ទមេថ　　　　អត្តា ហិ កិរ ទុទ្ទមោ ។**

បុគ្គលប្រៀនប្រដៅអ្នកដទៃយ៉ាងណា ត្រូវធ្វើខ្លួនឲ្យបាន
យ៉ាងនោះដែរ អ្នកដែលទូន្មានខ្លួនល្អហើយ ទើបគួរទូន្មាន
អ្នកដទៃបាន ព្រោះថា ខ្លួនកម្រទូន្មានបានពេកណាស់ ។

## សេចក្តីអធិប្បាយ

គប្បីជ្រាបអត្ថនៃព្រះគាថានោះថា ភិក្ខុពោលហើយថា គប្បីចង្ក្រមក្នុងបឋមយាមជាដើម ឈ្មោះថា ទូន្មានអ្នកដទៃយ៉ាងណា ខ្លួនឯងក៏ដូច្នោះ អធិដ្ឋានកិច្ច មានចង្ក្រមជាដើម ឈ្មោះថា គប្បីធ្វើខ្លួនដូចទូន្មានអ្នកដទៃ កាលបើដូច្នេះ ភិក្ខុនោះជាបុគ្គលមានខ្លួនទូន្មានល្អហើយហ្ន៎ គួរទូន្មានអ្នកដទៃ ។

បាទព្រះគាថាថា **សុទន្តោ វត ទមេថ** សេចក្តីថា ភិក្ខុរមែងប្រៀនប្រដៅអ្នកដទៃដោយហេតុណា ជាបុគ្គលទូន្មានខ្លួនល្អហើយ ដោយខ្លួនដោយគុណនោះ គួរទូន្មានអ្នកដទៃ ។

បាទព្រះគាថាថា **អត្តា ហិ កិរ ទុទ្ទមោ** សេចក្តីថា ព្រោះថា ឈ្មោះថា ខ្លួននេះ ជាសភាវៈដែលបុគ្គលទូន្មានបានលំបាក ព្រោះហេតុនោះ បុគ្គលនោះរមែងជាសភាវៈ ដែលបុគ្គលទូន្មានល្អហើយដោយប្រការណា គួរទូន្មានខ្លួនដោយប្រការនោះ ។

ក្នុងកាលចប់ទេសនា ភិក្ខុប្រមាណ ៥០០ រូបនោះសម្រេចអរហត្តផលហើយ ដូច្នោះឯង ។ល។

**រឿង ព្រះបធានិកតិស្សត្ថេរ ចប់**

# រឿង មាតាព្រះកុមារកស្សបត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធមាតារបស់ព្រះកុមារកស្សបត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **អត្តា ហិ អត្តនោ នាថោ** ជាដើម ។

បានឮមកថា មាតារបស់ព្រះថេរៈនោះ ជាកូនស្រីសេដ្ឋីក្នុងក្រុងរាជគ្រឹះ សូមបព្វជ្ជាហើយ ចាប់តាំងអំពីកាលដែលខ្លួនដឹងក្តី សូម្បីអង្វររឿយៗ ក៏មិនបានបួសអំពីសម្នាក់មាតា និងបិតា ចម្រើនវ័យហើយ ទៅកាន់ត្រកូលប្តី ជាអ្នកមានប្តីដូចទេវតានៅគ្រប់គ្រងផ្ទះហើយ ។ ក្នុងកាលមិនយូរ សត្វកើតក្នុងគភ៌តាំងឡើងហើយ ក្នុងផ្ទៃរបស់នាង តែនាងមិនជ្រាបភាពដែលគភ៌នោះតាំងឡើងឡើយ ញុំាងស្វាមីឲ្យត្រេកអរហើយ ទើបសូមបួស ។ គ្រានោះស្វាមីនាំនាងទៅកាន់សម្នាក់របស់ភិក្ខុនីដោយសក្ការៈធំ មិនជ្រាបថាមានផ្ទៃពោះ ឲ្យបួសក្នុងសម្នាក់របស់ភិក្ខុនី ដែលជាបក្ខពួករបស់ទេវទត្តហើយ ។

សម័យក្រោយមក នាងត្រូវភិក្ខុនីទាំងនោះដឹងថាមានគភ៌ហើយ សួរថានេះអ្វីហ្ន៎ ទើបឆ្លើយថា បពិត្រអ្នកនាងម្ចាស់ ខ្ញុំមិនជ្រាបថានេះជាអ្វី តែសីលរបស់ខ្ញុំមិនពព្រុស មិនពពាលឡើយ ។ ពួកភិក្ខុនីនាំនាងទៅកាន់សម្នាក់របស់ទេវទត្តហើយសួរថា ភិក្ខុនីនេះបួសដោយសទ្ធា ពួកខ្ញុំមិនដឹងកាលនៃគភ៌របស់នាងតាំងឡើង ឥឡូវនេះ ពួកខ្ញុំនឹងធ្វើដូចម្តេច ទេវទត្តគិតឃើញត្រឹមតែហេតុប៉ុណ្ណេះថា ការវិនាសកេរ្តិ៍ឈ្មោះ ចូរកុំកើតឡើងដល់ពួកភិក្ខុនី ដែលធ្វើតាម

ឱរសរបស់យើង ទើបពោលថា ចូរពួកនាងឲ្យស្រីនោះសឹក ភិក្ខុនីនោះស្តាប់ពាក្យនោះហើយ ពោលថា បពិត្រអ្នកនាងម្ចាស់ សូមកុំធ្វើឲ្យខ្ញុំវិនាសឡើយ ខ្ញុំមិនបានបួសឧទ្ទិសចំពោះលោកម្ចាស់ទេវទត្តឡើយ សូមនាងម្ចាស់ទាំង-ឡាយ នាំខ្ញុំទៅកាន់វត្តជេតពន ដែលជាសម្នាក់របស់ព្រះសាស្តា ភិក្ខុនីទាំងនោះនាំនាងទៅកាន់វត្តជេតពន ក្រាបទូលដល់ព្រះសាស្តាហើយ ។

ព្រះសាស្តាទ្រង់ជ្រាបថា គភ៌តាំងឡើងហើយ ក្នុងកាលនាងជាគ្រហស្ថ កាលនឹងដោះពាក្យរបស់អ្នកដទៃ ទើបត្រាស់ឲ្យយាងព្រះបាទបសេនទិកោសល អនាថបិណ្ឌិកសេដ្ឋី ចូឡអនាថបិណ្ឌិកសេដ្ឋី វិសាខាឧបាសិកា និងត្រកូលធំៗ មកហើយ ទ្រង់ត្រាស់នឹងព្រះឧបាលិត្ថេរថា ចូរអ្នកទៅជម្រះកម្មរបស់ភិក្ខុនីនេះឲ្យបរិសុទ្ធក្នុងកណ្តាលបរិស័ទ ៤ ។ ព្រះថេរៈ ឲ្យហៅនាងវិសាខាមកចំពោះព្រះភក្ត្រព្រះរាជាហើយ ឲ្យពិនិត្យអធិករណ៍នោះ នាងវិសាខាឲ្យមនុស្សព័ទ្ធដោយគ្រឿងព័ទ្ធ គឺរាំងនន ពិនិត្យមើលដៃ ជើង ផ្ចិត និងទីបំផុតនៃពោះរបស់ភិក្ខុនីនោះ ខាងក្នុងរាំងនន ហើយរាប់ខែថ្ងៃមើល ដឹងថា នាងមានគភ៌ក្នុងកាលនៅជាគ្រហស្ថ ទើបប្រាប់សេចក្តីនោះដល់ព្រះថេរៈ គ្រានោះ ព្រះថេរៈញុំាងភាពដែលនាងជាបុគ្គលបរិសុទ្ធ ឲ្យត្រឡប់តាំងឡើងក្នុងកណ្តាលបរិស័ទហើយ ។ ដោយសម័យដទៃ នាងប្រសូតបុត្រមានអានុភាពច្រើន ដែលមានសេចក្តីប្រាថ្នា តាំងទុកទៀបបាទមូលរបស់ព្រះពុទ្ធព្រះនាមបទុមុត្តរៈ ។

ថ្ងៃមួយ ព្រះរាជាយាងទៅក្នុងទីជិតសម្នាក់របស់ភិក្ខុនី ទ្រង់ឮសំឡេងទារក ទើបត្រាស់សួរថា នេះសំឡេងអ្វី កាលអមាត្យក្រាបទូលថា បពិត្រ

ព្រះអង្គ កូនរបស់ភិក្ខុនីនោះកើតហើយ ទុំជាសំឡេងបុត្ររបស់ភិក្ខុនីនោះ ។ ទ្រង់នាំកុមារនោះទៅកាន់ព្រះរាជមន្ទីររបស់ទ្រង់ បានប្រទានឲ្យដល់មេដោះទាំងឡាយ ។ ក្នុងថ្ងៃដាក់ឈ្មោះ ជនទាំងឡាយដាក់ឈ្មោះកុមារនោះថា កស្សបៈ ព្រោះកុមារនោះជាបុគ្គលដែលព្រះរាជាទ្រង់ឲ្យចម្រើនហើយ ដោយគ្រឿងរក្សារបស់ព្រះកុមារ ទើបគេហៅថា កុមារកស្សបៈ ។ កុមារនោះវាយក្មេងក្នុងទីលេងកីឡាហើយ កាលពួកក្មេងពោលថា ពួកយើងត្រូវមនុស្សមិនមានម៉ែ មិនមានឪវាយហើយ ។ ទើបចូលទៅគាល់ព្រះរាជាទូលសួរថា បពិត្រព្រះសម្មតិទេព ពួកក្មេងរមែងជេរទូលបង្គំថា មិនមានមាតា និងបិតា សូមទ្រង់ត្រាស់ប្រាប់មាតាដល់ទូលបង្គំចុះ កាលទ្រង់បង្ហាញមេដោះទាំងឡាយ ត្រាស់ថា ស្រីទាំងនេះជាមាតារបស់បា ទើបក្រាបទូលថា មាតារបស់ទូលបង្គំមិនមានប៉ុណ្ណោះឡើយ មាតារបស់ទូលបង្គំ មានតែមួយ សូមទ្រង់ប្រាប់មាតានោះដល់ទូលបង្គំចុះ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា អញមិនអាចបញ្ឆោតកុមារនេះបាន ទើបត្រាស់ថា នែបា មាតារបស់បាជាភិក្ខុនី អ្នក គឺយើងនាំមកអំពីសម្នាក់របស់ភិក្ខុនី ។

កុមារនោះ មានសេចក្តីសង្វេគកើតឡើងព្រមហើយ ដោយហេតុមានប្រមាណប៉ុណ្ណោះនោះឯង ក្រាបទូលថា បពិត្របិតា សូមទ្រង់ឲ្យទូលបង្គំបួសចុះ ព្រះរាជាទទួលថា សាធុ ហើយញុំាងកុមារនោះឲ្យបួសក្នុងសម្នាក់របស់ព្រះសាស្តា ដោយសក្ការៈដ៏ច្រើន ។

កុមារកស្សបៈនោះបានឧបសម្បទាហើយ ប្រាកដឈ្មោះថា កុមារកស្ស-

បត្តរ លោករៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តា ចូលទៅកាន់ព្រៃ ព្យាយាម ហើយ មិនអាចញុំាងគុណវិសេសឲ្យកើតបាន ទើបគិតថា អញនឹងរៀន កម្មដ្ឋានឲ្យវិសេសទៀត មកកាន់សម្នាក់ព្រះសាស្តា នៅក្នុងព្រៃអន្ធវនហើយ កាលនោះ ភិក្ខុធ្វើសមណធម៌រួមគ្នា ក្នុងកាលព្រះកស្សបសម្ពុទ្ធ សម្រេច អនាគាមិផល ហើយកើតក្នុងព្រហ្មលោក មកអំពីព្រហ្មលោក សួរបញ្ហា ១៥ ជាមួយកុមារកស្សបៈនោះហើយ បញ្ជូនទៅដោយពាក្យថា អ្នកដទៃវៀរ ព្រះ សាស្តា បុគ្គលដែលអាចព្យាករបញ្ហាទាំងនេះមិនមាន សូមលោកម្ចាស់ ទៅ សាកសួរអត្ថរបស់បញ្ហាទាំងនេះ ក្នុងសម្នាក់របស់ព្រះសាស្តាចុះ ។ លោក ធ្វើយ៉ាងនោះ សម្រេចអរហត្តផល ក្នុងកាលដែលព្រះសាស្តា ទ្រង់ឆ្លើយ បញ្ហាចប់ ។

តាំងអំពីថ្ងៃដែលព្រះថេរៈនោះចេញទៅហើយ ទឹកភ្នែកហូរចេញអំពីរន្ធន៍ ភ្នែកទាំងគូរបស់ភិក្ខុនីជាមាតាអស់កាល ១២ ឆ្នាំ នាងមានទុក្ខ ព្រោះព្រាត់ ប្រាសចាកបុត្រ មានមុខជោកដោយទឹកភ្នែកនោះឯង ត្រាច់ទៅដើម្បីភិក្ខា ឃើញ ព្រះថេរៈក្នុងចន្លោះផ្លូវ ទើបស្រែកថា កូន កូន រត់ចូលទៅដើម្បីចាប់ព្រះថេរៈ ក៏ដួលហើយ នាងមានទឹកដោះហូរក្រោកឡើង មានចីវរសើមចាប់ព្រះថេរៈ ហើយ ព្រះថេរៈគិតថា បើម្តាយអញបានឮពាក្យពីរោះអំពីសម្នាក់អញ នាង នឹងវិនាស អញនឹងនិយាយជាមួយមាតានេះ ធ្វើឲ្យគ្រោតគ្រាតហើយ ។ ពេល នោះ ព្រះថេរៈពោលនឹងភិក្ខុនីដែលជាមាតានោះថា នាងត្រាច់ធ្វើអ្វី ទើបមិន អាចកាត់ គ្រាន់តែសេចក្តីស្រឡាញ់បាន នាងគិតថា ឱ ពាក្យរបស់ព្រះថេរៈ

គ្រោតគ្រាត ទើបពោលថា នែបា បានិយាយអ្វី ត្រូវព្រះថេរៈពោលយ៉ាងនោះឯងទៀត ទើបគិតថា អញមិនអាចទប់ទឹកភ្នែកបានអស់ ១២ ឆ្នាំ ព្រោះហេតុនៃកូននេះ តែកូនរបស់អញនេះ មានចិត្តរឹងត្អឹង ប្រយោជន៍អ្វីរបស់អញដោយកូននេះ កាត់សេចក្តីស្រឡាញ់ក្នុងបុត្រហើយ សម្រេចអរហត្តផលក្នុងថ្ងៃនោះឯង ។

ក្នុងសម័យដទៃ ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងរោងធម្មសភាថា អាវុសោទាំងឡាយ កុមារកស្សបៈ និងព្រះថេរី សម្បូរដោយឧបនិស្ស័យយ៉ាងនេះត្រូវទេវទត្តឲ្យវិនាសហើយ ចំណែកព្រះសាស្តា បានជាទីពឹងរបស់លោកទាំងពីរនោះ ឱ គួរអស្ចារ្យ ធម្មតាព្រះពុទ្ធទាំងឡាយ រមែងជាអ្នកអនុគ្រោះ ( សត្វ ) លោក ។

ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា ដោយរឿងឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតជាបច្ច័យ ជាទីពំនាក់អាស្រ័យរបស់ជនទាំងពីរនេះ ក្នុងឥឡូវនេះប៉ុណ្ណោះ ក៏មិនមែន សូម្បីក្នុងកាលមុន តថាគតក៏បានជាទីពឹងរបស់ជនទាំងនេះដូចគ្នា ដូច្នេះហើយទើបត្រាស់និគ្រោធជាតកដោយពិស្តារ ( តែក្នុងទីនេះមានសេចក្តីសង្ខេប ) ថា

បុគ្គល គប្បីសេពនូវម្រឹគ ឈ្មោះនិគ្រោធតែម្យ៉ាង កុំគប្បីសេពនូវម្រឹគឈ្មោះសាខៈឡើយ កាលស្លាប់ក្នុងសម្នាក់នៃម្រឹគឈ្មោះនិគ្រោធ ជាការប្រសើរ ការរស់នៅក្នុងសម្នាក់នៃម្រឹគ

ឈ្មោះសាខៈ ពុំប្រសើរឡើយ ។

ទ្រង់ប្រជុំជាតកថា ម្រឹគឈ្មោះសាខៈក្នុងកាលនោះ បានជាទេវទត្តក្នុងកាលឥឡូវនេះ បរិស័ទរបស់ម្រឹគឈ្មោះសាខៈនោះ ក៏ជាបរិស័ទរបស់ទេវទត្តនោះឯង ម្រឹគដែលដល់វេណ បានជាព្រះថេរី កូនម្រឹគ បានជាកុមារកស្សបៈ ចំណែកស្តេចម្រឹគឈ្មោះនិគ្រោធ ដែលទៅលះជីវិតដល់មេម្រឹគ ដែលមានគភ៌ គឺតថាគតនេះឯង ។ កាលទ្រង់ប្រកាសភាពដែលព្រះថេរី កាត់សេចក្តីស្រឡាញ់ក្នុងបុត្រហើយ ធ្វើទីពឹងដល់ខ្លួនឯង ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រោះបុគ្គលអាស្រ័យអ្នកដទៃ មិនអាចមានសួគ៌ ឬមគ្គជាទីទៅខាងមុខបានឡើយ ដូច្នោះ ខ្លួននោះឯងជាទីពឹងរបស់ខ្លួន អ្នកដទៃ នឹងធ្វើអ្វីបាន ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**អត្តា ហិ អត្តនោ នាថោ  កោ ហិ នាថោ បរោ សិយា**
**អត្តនា ហិ សុទន្តេន  នាថំ លភតិ ទុល្លភំ ។**

ខ្លួនជាទីពឹងរបស់ខ្លួន អ្នកដទៃជាទីពឹងដូចម្តេចបាន ព្រោះបុគ្គលអ្នកមានខ្លួនហ្វឹកហ្វឺនល្អហើយ រមែងបាននូវទីពឹង ដែលគេបានដោយកម្រ ។

## សេចក្តីអធិប្បាយ

បណ្តាបទទាំងនោះ បទថា **នាថោ** គឺជាទីពឹង ព្រះដ៏មានព្រះភាគត្រាស់ពាក្យនេះថា បុគ្គលតាំងនៅក្នុងខ្លួន គឺសម្បូរហើយដោយខ្លួន អាចធ្វើកុសលហើយដល់នូវសួគ៌ ឬដើម្បីញ៉ាំងមគ្គឲ្យចម្រើន ឬធ្វើឲ្យជាក់ច្បាស់នូវផលបាន

ព្រោះហេតុនោះឯង ខ្លួនគប្បីជាទីពឹងរបស់ខ្លួន ។ អ្នកដទៃណា គប្បីជាទីពឹងរបស់បុគ្គលណាបាន ព្រោះបុគ្គលមានខ្លួនទូន្មានល្អហើយ គឺមានការសេពខុសទៅប្រាសហើយ រមែងបានទីពឹងដែលបុគ្គលបានដោយកម្រ ពោល គឺអរហត្តផល ។ ពាក្យថា **នាថំ លភតិ ទុល្លភំ** នេះ ព្រះដ៏មានព្រះភាគ ត្រាស់សម្តៅយកអរហត្ត ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ៕

**រឿង មាតាព្រះកុមារកស្សបត្ថេរ ចប់**

# រឿង ឧបាសក ឈ្មោះ មហាកាល

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសកដែលជាសោតាបន្នម្នាក់ ឈ្មោះមហាកាល ត្រាស់ព្រះធម្មទេសនានេះថា **អត្តនា ហិ កតំ បាបំ** ជាដើម ។

បានឮថា មហាកាលនោះជាអ្នករក្សាឧបោសថ ៨ ថ្ងៃក្នុងមួយខែ ស្តាប់ធម្មកថាមួយយប់ទល់ភ្លឺក្នុងវិហារ កាលពួកចោរកាត់ទី-តក្នុងផ្ទះមួយខ្នង ក្នុងពេលយប់ កាន់បង្វេចកណ្ឌះទៅ ត្រូវពួកម្ចាស់ផ្ទះភ្ញាក់ឡើង ព្រោះភាជនៈលោហៈទង្គិចគ្នា ដេញតាមហើយ ចោលទ្រព្យដែលខ្លួនកាន់យកហើយ

ចៀសចេញទៅ ។

ចំណែកម្ចាស់ទ្រព្យ ដេញតាមចោរនោះរឿយៗ មក ពួកចោរទាំងនោះខ្ចាត់ខ្ចាយគេចទៅក្នុងទិសផ្សេងៗ ចំណែកចោរម្នាក់កាន់យកផ្លូវដែលទៅកាន់វិហារ ចោលកញ្ចប់កណ្ឌៈខាងមុខមហាកាល ដែលស្ដាប់ធម្មកថាមួយយប់ទល់ភ្លឺ លុបមុខត្រង់មាត់ស្រះបោក្ខរណីអំពីព្រលឹម ហើយគេចទៅ ។

ពួកមនុស្សដេញតាមពួកចោរមក ជួបកញ្ចប់កណ្ឌៈហើយ ទើបចាប់មហាកាលនោះ ដោយពោលថា ឯងកាត់ទី-តក្នុងផ្ទះរបស់ពួកយើង លួចកញ្ចប់កណ្ឌៈមកហើយ ធ្វើដូចជាស្ដាប់ធម៌ វាយឲ្យស្លាប់ហើយទុកចោល ។

គ្រានោះ ភិក្ខុកំលោះ និងសាមណេរទាំងឡាយ កាន់ក្អមទឹកផឹកទៅអំពីព្រលឹម ជួបមហាកាលនោះ ពោលថា ឧបាសកស្ដាប់ធម្មកថានៅវិហារ បានមរណៈមិនសមគួរ ដូច្នេះហើយ ទើបក្រាបទូលដល់ព្រះសាស្ដា ។ ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង កាលឧបាសក បានមរណៈមិនសមគួរក្នុងអត្តភាពនេះ តែសមគួរដល់កម្មដែលបានធ្វើហើយក្នុងកាលមុននោះឯង កាលភិក្ខុកំលោះ និងសាមណេរទាំងនោះទូលអារាធនា ទើបត្រាស់បុព្វកម្មរបស់មហាកាលនោះ

បានឮមកថា ក្នុងអតីតកាល ពួកចោរស្កាត់ផ្លូវត្រង់មាត់ព្រៃមួយកន្លែងនាបច្ចន្តគាម ក្នុងដែនរបស់ព្រះបាទពារាណសី ។ ព្រះរាជាទ្រង់តាំងរាជភដៈម្នាក់ត្រង់មាត់ផ្លូវ ។ រាជភដៈនោះ ទទួលថ្លៃឈ្នួលហើយ ក៏នាំមនុស្សអំពីខាងនេះ ទៅកាន់ខាងនោះ នាំមនុស្សអំពីខាងនោះ មកខាងនេះ ។

គ្រាមួយ បុរសម្នាក់ នាំកិរិយាឡើងកាន់យានតូចហើយ បានទៅដល់ទីនោះ ។ រាជភដៈឃើញស្រីនោះ ក៏កើតសេចក្ដីស្រឡាញ់ កាលបុរសនោះពោលថា សូមលោកជូនខ្ញុំទាំងពីរឲ្យឆ្លងព្រៃចុះ ក៏ឆ្លើយថា ឥឡូវនេះ យប់ព្រលប់ហើយ ចាំព្រឹកខ្ញុំនឹងជូនឲ្យឆ្លងផុតទៅ បុរសនោះពោលថា ពេលនៅមាន សូមនាំខ្ញុំទាំងពីរទៅឥឡូវនេះចុះ រាជភដៈពោលថា ត្រឡប់សិនចុះអ្នក អាហារ និងទីស្នាក់អាស្រ័យ មានក្នុងផ្ទះរបស់ខ្ញុំ ។

បុរសនោះមិនប្រាថ្នានឹងត្រឡប់ឡើយ ចំណែករាជភដៈនេះឲ្យសញ្ញាដល់ពួកបុរស ញុំាងយានតូចឲ្យត្រឡប់ហើយ ឲ្យស្នាក់នៅត្រង់ខ្លោងទ្វារ ឲ្យចាត់ចែងអាហារដល់បុរសនោះ ដែលមិនប្រាថ្នាឡើយ ។ ក្នុងផ្ទះរាជភដៈនោះមានកែវមណីមួយ គាត់ឲ្យយកកែវមណីនោះ លាក់ក្នុងជ្រុងនៃយានតូចរបស់បុរសនោះហើយ លុះពេលទៀបភ្លឺឲ្យធ្វើសំឡេងជាពួកចោរចូលទៅក្នុងផ្ទះ ។

លំដាប់នោះ ពួកបុរសប្រាប់ដល់គាត់ថា លោកម្ចាស់ កែវមណីត្រូវចោរលួចយកទៅហើយ គាត់បញ្ជាថា ចូរពួកអ្នកតាំងកម្លាំងរក្សាត្រង់ទ្វារស្រុកទាំងឡាយ ចែកឆែរមើលមនុស្សដែលចេញទៅអំពីក្នុងស្រុក ចំណែកមនុស្សក្រៅអំពីនេះ រៀបចំយានតូចស្រេចហើយ ក៏បរទៅអំពីព្រលឹម ។ ពេលនោះពួកអ្នកបម្រើរបស់រាជភដៈ ទើបឆែកឆេរយានតូចរបស់បុរសនោះ ឃើញកែវមណីដែលខ្លួនលាក់ ទើបពោលថា ឯងលួចយកកែវមណីទៅ ដូច្នេះហើយក៏វាយបង្ហាញដល់មេស្រុកថា ពួកខ្ញុំចាប់ចោរបានហើយ រាជភដៈពោលថា ខ្ញុំជារាជភដៈ ឲ្យស្នាក់អាស្រ័យក្នុងផ្ទះឲ្យកត្តហើយ ឯងគង់លួចកែវមណីទៅ

*បាន ចូរពួកអ្នកចាប់បុរសអាក្រក់នេះ ដូច្នេះហើយ ឲ្យវាយសម្លាប់ហើយបោះចោល នេះជាបុព្វកម្មរបស់មហាកាលនោះ ។ រាជកជៈនោះ ចុតិចាកអត្តភាពនោះហើយ កើតក្នុងអវីចិ ឆេះក្នុងអវីចិនោះអស់កាលយូរ ដោយសេសសល់ផលកម្ម ត្រូវគេវាយឲ្យស្លាប់យ៉ាងនោះឯងអស់ ១០០ អត្តភាព ។*

*ព្រះសាស្តា កាលទ្រង់សម្តែងបុព្វកម្មរបស់មហាកាលយ៉ាងនោះហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បាបកម្មដែលខ្លួនបានធ្វើហើយនោះឯង រមែងបៀតបៀនសត្វទាំងនោះ ដោយអបាយ ៤ យ៉ាងនេះ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា*

**អត្តនា វ កតំ បាបំ អត្តជំ អត្តសម្ភវំ**
**អភិមត្ថតិ ទុម្មេធំ វជិរំវម្ហយំ មណឹ ។**

*បាបកើតអំពីខ្លួន មានខ្លួនជាដែនកើត ដែលខ្លួនធ្វើហើយ តែងញាំញី មនុស្សឥតប្រាជ្ញា ដូចពេជ្រសម្រាប់កាត់កែវមណីដែលកើតអំពីថ្ម ដូច្នោះឯង ។*

## សេចក្តីអធិប្បាយ

*បណ្តាបទទាំងនោះ បាទព្រះគាថាថា* **វជិរំវម្ហយំ មណឹ** *សេចក្តីថា ប្រៀបដូចពេជ្រ ញាំញីកែវមណីដែលកើតអំពីថ្ម លោកអធិប្បាយពាក្យនេះថា ពេជ្រដែលសម្រេចអំពីថ្ម មានថ្មជាដែនកើត កាត់កែវមណីដែលកើតអំពីថ្ម គឺកែវមណីដែលសម្រេចអំពីថ្ម ដែលរាប់ថាជាទីតាំងឡើងរបស់ខ្លួននោះឯង គឺធ្វើឲ្យជាប្រហោងតូច ប្រហោងធំ ឲ្យជាកំណាត់តូចកំណាត់ធំ ធ្វើឲ្យ*

ប្រើប្រាស់មិនបាន យ៉ាងណា បាបដែលធ្វើហើយ កើតក្នុងខ្លួន មានខ្លួនជាដែនកើត រមែងញាំញី គឺកម្ចាត់បុគ្គលដែលមានបញ្ញាថោកថយ គឺបុគ្គលឥតបញ្ញាក្នុងអបាយ ៤ ដូច្នោះដូចគ្នា ។

ក្នុងកាលចប់ទេសនា ភិក្ខុដែលមកប្រជុំ សម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

**រឿង ឧបាសក ឈ្មោះ មហាកាល ចប់**

# រឿង ទេវទត្តភិក្ខុ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធទេវទត្តភិក្ខុ ទ្រង់ត្រាស់ធម្មទេសនានេះថា **យស្ស អច្ចន្តទុស្សីល្យំ** ជាដើម ។

សេចក្តីពិស្តារ ថ្ងៃមួយ ពួកភិក្ខុសន្ទនាគ្នាក្នុងរោងធម្មសភាថា អាវុសោទាំងឡាយ ទេវទត្តជាអ្នកទ្រុស្តសីល មានធមិដ៏លាមក អែបអបព្រះបាទអជាតសត្តុ ញុំាងលាភសក្ការៈដ៏ច្រើនឲ្យកើតឡើង បបួលព្រះបាទអជាតសត្តុ ក្នុងកាលសម្លាប់បិតា ជាអ្នករួមគំនិតជាមួយព្រះបាទអជាតសត្តុនោះ ដើម្បីសម្លាប់ព្រះតថាគត ដោយប្រការផ្សេងៗ ព្រោះតណ្ហាដែលចម្រើនឡើងហើយ ដោយហេតុ គឺភាពជាបុគ្គលទ្រុស្តសីលនោះឯង ព្រះសាស្តាយាងមកត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយ

សន្ទនាគ្នាដោយកថាដូចម្ដេចហ្ន៎ កាលភិក្ខុទាំងនោះក្រាបទូលថា ដោយកថាឈ្មោះនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ទេវទត្តក៏ព្យាយាមដើម្បីសម្លាប់តថាគត ដោយប្រការផ្សេងៗ ដូចគ្នា ដូច្នេះហើយ ទើបត្រាស់ជាតកទាំងឡាយ មានកុរុង្គ-ជាតកជាដើម ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តណ្ហាដែលកើតឡើងព្រោះហេតុ គឺជាអ្នកទ្រុស្តសីល ស្រោបរួបរឹតនូវបុគ្គលដែលទ្រុស្តសីល ឲ្យធ្លាក់ទៅក្នុងអបាយទាំងឡាយ មាននរកជាដើម ដូចដើមជ្រៃរួបរឹតដើមសាល-ព្រឹក្ស រហូតបាក់ចុះដូច្នោះ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**យស្ស អច្ចន្តទុស្សីល្យំ មាលុវា សាលមិវោត្ថតំ**
**ករោតិ សោ តថត្តានំ យថា នំ ឥច្ឆតី ទិសោ ។**

*កាពជាអ្នកទ្រុស្តសីលហួសហេតុ គ្របសង្កត់ ( នូវអត្តភាព ) របស់បុគ្គលណា ដូចវល្លិ៍ដែលរួបរឹតដើមឈើ បុគ្គលនោះ ឈ្មោះថាធ្វើខ្លួនឯងឲ្យវិនាស ដូចជាចោរអ្នកប្រាថ្នាធ្វើបុគ្គលនោះឲ្យវិនាស ដូច្នោះ ។*

# សេចក្ដីអធិប្បាយ

កាពជាអ្នកទ្រុស្តសីលដោយចំណែកមួយ ឈ្មោះថា **អច្ចន្តទុស្សីល្យំ** ក្នុងព្រះគាថានោះ ។ បុគ្គលជាគ្រហស្ថ ធ្វើអកុសលកម្មបថ ១០ តាំងអំពីកើតក្ដី បព្វជិតត្រូវគរុកាបត្តិតាំងអំពីថ្ងៃឧបសម្បទាក្ដី ឈ្មោះថាជាអ្នកទ្រុស្តសីលហួសហេតុ ។

តែបទថា **អច្ចន្តទុស្សីល្យំ** នេះ ព្រះដ៏មានព្រះភាគត្រាស់ក្នុងព្រះគាថានេះ ទ្រង់សំដៅយកភាពជាអ្នកទ្រុស្តសីលដែលមកហើយតាមគតិរបស់បុគ្គលដែលទ្រុស្តសីលក្នុង ២-៣ អត្តភាព ។

ម្យ៉ាងទៀត តណ្ហាដែលអាស្រ័យទ្វារ ៦ របស់បុគ្គលទ្រុស្តសីលកើតឡើង បណ្ឌិតគប្បីជ្រាបថា ភាពជាអ្នកទ្រុស្តសីលក្នុងព្រះគាថានេះ ។

បាទព្រះគាថាថា **មាលុវា សាលមិវោត្ថតំ** សេចក្តីថា ភាពជាអ្នកទ្រុស្តសីល ពោល គឺតណ្ហារួបរឹត គឺហ៊ុមព័ទ្ធអត្តភាពរបស់បុគ្គលណាតាំងនៅ ដូចដើមជ្រៃ រួបរឹតដើមសាលព្រឹក្ស គឺគ្របដណ្តប់ទូទៅទាំងអស់នោះឯង ដោយអំណាចទទួលទឹកដោយស្លឹកក្នុងកាលភ្លៀងធ្លាក់ ហើយកាច់បំបាក់ដូច្នោះឯង ។ បុគ្គលនោះ គឺបុគ្គលត្រូវតណ្ហា ពោល គឺភាពទ្រុស្តសីលនោះកាច់បំបាក់ឲ្យធ្លាក់ទៅក្នុងអបាយទាំងឡាយ ដូចដើមឈើត្រូវពួរជ្រៃកាច់បំបាក់ឲ្យរលំចុះលើផែនដី ដូច្នោះ ឈ្មោះថា រមែងធ្វើខ្លួនតែម្យ៉ាងជាមួយចោរ ដែលប្រាថ្នាសេចក្តីវិនាស ប្រាថ្នាធ្វើឲ្យ ដូច្នោះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមដូច្នេះឯង ។

**រឿង ឧទេវទត្តភិក្ខុ ចប់**

# រឿង ទេវទត្តបំបែកសង្ឃ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធការព្យាយាមដើម្បីបំបែកសង្ឃ ត្រាស់ព្រះធម្មទេសនានេះថា **សុករានិ** ជាដើម ។

សេចក្តីពិស្តារថា ទេវទត្តកិក្ខុខ្នះខ្នែងដើម្បីបំបែកសង្ឃ ថ្ងៃមួយ ឃើញព្រះអានន្ទកំពុងត្រាច់បិណ្ឌបាត ប្រាប់នូវបំណងរបស់ខ្លួនហើយ ។ ព្រះថេរៈស្តាប់ហើយ ទៅកាន់សម្នាក់របស់ព្រះសាស្តា បានទូលពាក្យនេះ នឹងព្រះសាស្តាថា បពិត្រព្រះអង្គ ព្រឹកមិញ ខ្ញុំព្រះអង្គស្លៀកស្បង់ត្រង់ព្រៃឫស្សីនេះហើយ កាន់បាត្រ និងចីវរ ចូលទៅកាន់ក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត ទេវទត្តឃើញខ្ញុំព្រះអង្គត្រាច់បិណ្ឌបាតក្នុងក្រុងរាជគ្រឹះហើយ ចូលទៅរកខ្ញុំព្រះអង្គ បានពោលពាក្យនេះថា អាវុសោអានន្ទ ចាប់តាំងអំពីថ្ងៃនេះទៅ ខ្ញុំនឹងធ្វើឧបោសថ និងសង្ឃកម្មបែកអំពីព្រះដ៏មានព្រះភាគ បែកអំពីកិក្ខុសង្ឃ បពិត្រព្រះសាស្តា ថ្ងៃនេះ ទេវទត្តនឹងបំបែកសង្ឃ ធ្វើឧបោសថ និងសង្ឃកម្ម ។

កាលព្រះអានន្ទក្រាបទូលយ៉ាងនោះហើយ ព្រះសាស្តាទ្រង់បន្លឺនូវព្រះឧទានថា

អំពើល្អ មនុស្សល្អ ធ្វើបានដោយងាយ អំពើល្អ មនុស្សអាក្រក់ធ្វើ
បានដោយកម្រ អំពើអាក្រក់ មនុស្សអាក្រក់ ធ្វើបានដោយងាយ
អំពើអាក្រក់ ពួកព្រះអរិយៈ ធ្វើបានដោយកម្រ ។

ហើយត្រាស់ថា ម្នាលអានន្ទ ឈ្មោះថាកម្មដែលមិនជាប្រយោជន៍ដល់

ខ្លួនធ្វើបានងាយ កម្មដែលជាប្រយោជន៍ដល់ខ្លួន ធ្វើលំបាកពន់ពេក ហើយត្រាស់ព្រះគាថានេះថា

**សុករានិ អសាធូនិ អត្តនោ អហិតានិ ច**
**យំ វេ ហិតញ្ច សាធុញ្ច តំ វេ បរមទុក្ករំ ។**

កម្មទាំងឡាយណា មិនល្អផង មិនជាប្រយោជន៍ដល់ខ្លួនផង កម្មទាំងនោះ ដែលជនពាលធ្វើបានដោយងាយ កម្មណាជាប្រយោជន៍ផង ល្អផង កម្មនោះឯងដែលជនពាលធ្វើបានដោយលំបាក ។

## សេចក្តីអធិប្បាយ

អត្ថនៃព្រះគាថានោះថា កម្មទាំងឡាយណាមិនល្អ គឺមានទោស និងប្រព្រឹត្តទៅដើម្បីអបាយ ឈ្មោះថាមិនជាប្រយោជន៍ដល់ខ្លួនព្រោះធ្វើនោះឯងកម្មទាំងនោះ ធ្វើបានដោយងាយ ចំណែកកម្មណា ឈ្មោះថាជាប្រយោជន៍ដល់ខ្លួន ព្រោះធ្វើ និងឈ្មោះថាល្អដោយអត្ថថា មិនមានទោស គឺប្រព្រឹត្តទៅដើម្បីសុគតិ និងប្រព្រឹត្តទៅដើម្បីព្រះនិព្វាន កម្មនោះសែនលំបាក ប្រៀបដូចទប់ទឹកទន្លេគង្គា ហូរទៅទិសខាងកើត ធ្វើឲ្យហូរត្រឡប់ ដូច្នោះ ។

ក្នុងកាលចប់ទេសនា មហាជនបានសម្រេចលោកុត្តរផល មានសោតាបត្តិផលជាដើម ដូច្នេះឯង ៕

**រឿងទេវទត្តបំបែកសង្ឃ ចប់**

# រឿង ព្រះកាលត្ថេរ

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះកាលត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **យោ សាសនំ** ជាដើម ។

បានឮមកថា ស្រីម្នាក់ក្នុងក្រុងសាវត្ថី តាំងនៅក្នុងនាទីជាមាតា ទំនុកបម្រុងព្រះថេរៈ ។ ពួកមនុស្សក្នុងផ្ទះនៃបុគ្គលស្និទ្ធស្នាលរបស់ស្រីនោះ ស្តាប់ធម៌ក្នុងសម្នាក់ព្រះសាស្តាហើយ ត្រឡប់មកកាន់ផ្ទះសរសើរថា ឱ ឈ្មោះថាព្រះពុទ្ធទាំងឡាយអស្ចារ្យ ឱ ព្រះធម្មទេសនាក៏ពីរោះ ។ ស្រីនោះស្តាប់ពាក្យរបស់មនុស្សទាំងនោះហើយ ទើបប្រាប់ដល់ព្រះកាលៈថា បពិត្រលោកម្ចាស់ ខ្ញុំចង់ស្តាប់ធម៌របស់ព្រះសាស្តា ។ ព្រះថេរៈឃាត់ថា កុំទៅទីនេះឡើយ ។ ស្រីនោះក្នុងថ្ងៃស្អែកឡើងក៏សូមទៀត សូម្បីព្រះកាលៈនោះឃាត់អស់ ៣ ដងក៏នៅតែចង់ស្តាប់នោះឯង ។ មានពាក្យសួរជ្រៀតចូលមកថា ហេតុអ្វី ទើបព្រះថេរៈហាម ឆ្លើយថា បានឮថា លោកយល់ឃើញដូច្នេះថា ឧបាសិកានេះបានស្តាប់ធម៌ក្នុងសម្នាក់ព្រះសាស្តាហើយ នឹងបែកអំពីអញ ហេតុនោះទើបឃាត់ ។

ថ្ងៃមួយ ស្រីនោះបរិភោគអាហារស្រេច សមាទានឧបោសថហើយ ប្រាប់កូនស្រីថា ចូរនាងអង្គាសលោកម្ចាស់ឲ្យល្អ ហើយបានទៅកាន់វិហារអំពីព្រលឹម ចំណែកកូនស្រី ក៏អង្គាសព្រះកាលៈដោយផ្ចិតផ្ចង់ ក្នុងកាលព្រះថេរៈមកក៏សួរថា ឧបាសិកាធំទៅណា ទារិកាឆ្លើយថា ទៅវិហារដើម្បីស្តាប់ធម៌ ។ គ្រាន់តែ

បានឮពាក្យនោះ ញាប់ញ័រព្រោះការតានតឹងតាំងឡើងខាងក្នុង គិតថា ឥឡូវនេះ ឧបាសិកានោះបែកអំពីអញហើយ ម្ចីម្នាទៅ ឃើញស្រីនោះស្តាប់ធម៌ក្នុងសម្នាក់ព្រះសាស្តា ទើបទូលព្រះសាស្តាថា បពិត្រព្រះអង្គ ស្រីនេះល្ងង់ខ្លៅមិនយល់ធម្មកថាដែលល្អិតជ្រាលជ្រៅទេ សូមទ្រង់កុំត្រាស់ធម្មកថាដែលជាបរមត្ថដោយសភាវធម៌ មានខន្ធជាដើមឡើយ ត្រាស់ត្រឹមតែទានកថា និងសីលកថាក៏គ្រប់គ្រាន់ ។

ព្រះសាស្តា ទ្រង់ជ្រាបអធ្យាស្រ័យរបស់ព្រះថេរៈហើយ ត្រាស់ថា អ្នកជាបុគ្គលអប្បឥតប្រាជ្ញា អាស្រ័យទិដ្ឋិដ៏លាមក ឃាត់នូវពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ អ្នកព្យាយាមដើម្បីសម្លាប់ខ្លួនឯង ហើយត្រាស់ព្រះគាថានេះថា

**យោ សាសនំ អរហតំ អរិយានំ ធម្មជីវិនំ**
**បដិក្កោសតិ ទុម្មេធោ ទិដ្ឋឹ និស្សាយ បាបិកំ**
**ផលានិ កដ្ឋកស្សេវ អត្តឃញ្ញាយ ផល្លតិ ។**

បុគ្គលណាអប្បប្រាជ្ញា អាស្រ័យទិដ្ឋិដ៏លាមក ហាមឃាត់
សាសនារបស់ព្រះអរហន្តទាំងឡាយដ៏ប្រសើរ រស់នៅ
ដោយធម៌ ការហាមឃាត់របស់បុគ្គលនោះ រមែងចេញ
ផលដើម្បីសម្លាប់ខ្លួន ដូចផ្លៃឫស្សី ដូច្នោះ ។

## សេចក្តីអធិប្បាយ

អត្ថនៃព្រះគាថានោះថា បុគ្គលណាអប្បប្រាជ្ញា អាស្រ័យទិដ្ឋិដ៏លាមក ឃាត់នូវពួកជនដែលពោលថា ខ្ញុំនឹងស្តាប់ធម៌ក្តី ខ្ញុំនឹងថ្វាយទានក្តី ព្រោះខ្លាច

សាបសូន្យសក្ការៈរបស់ខ្លួន ឈ្មោះថាជំទាស់នឹងពាក្យប្រៀនប្រដៅរបស់ព្រះអរិយបុគ្គលដែលជាអរហន្ត មានប្រក្រតីរស់នៅដោយធម៌ គឺព្រះពុទ្ធ ការជំទាស់ក្តី ទិដ្ឋិដ៏ថោកទាបក្តីរបស់បុគ្គលនោះ រមែងដូចជាផ្លែរបស់ឈើមានបន្ទា ពោលគឺឫស្សី ហេតុនោះ ឫស្សីកាលចេញផ្លែ រមែងចេញដើម្បីសម្លាប់ខ្លួនប៉ុណ្ណោះយ៉ាងណា បុគ្គលនោះរមែងកើតមកដើម្បីសម្លាប់ខ្លួន គឺកើតមកដើម្បីបំផ្លាញខ្លួនឯង ដូច្នោះ ។ សមដូចប្រពន្ធគាថា ដែលព្រះដ៏មានព្រះភាគត្រាស់ថា

ផ្លែចេក តែងសម្លាប់ដើមចេក ផ្លែឫស្សី តែងសម្លាប់ដើមឫស្សី
ផ្លែបបុស តែងសម្លាប់ដើមបបុស សក្ការៈ តែងសម្លាប់បុរស
អាក្រក់ ដូចជាគភ៌តែងសម្លាប់មេសេះអស្សតរ ។

ក្នុងកាលចប់ទេសនា ឧបាសិកាតាំងនៅក្នុងសោតាបត្តិផល ទេសនាមានប្រយោជន៍ដល់បរិស័ទ ដែលប្រជុំគ្នាហើយ ដូច្នោះឯង ។

**រឿង ព្រះកាលត្ថេរ ចប់**

# រឿង ឧបាសក ឈ្មោះ ចុល្លកាល

## លំនាំដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធឧបាសកឈ្មោះចុល្លកាល ត្រាស់ព្រះធម្មទេសនានេះថា **អត្តនាវ កតំ បាបំ** ជាដើម ។

សេចក្តីពិស្តារ ថ្ងៃមួយ ពួកចោរជីកឧម្មង្គដែលម្ចាស់ទ្រព្យទាំងឡាយ

ដេញតាមហើយ ទើបចោលបង្វេចកណ្ដៈខាងមុខឧបាសក ដែលស្ដាប់ធម៌ក្នុងវិហារអស់រាត្រី ដើរចេញអំពីវិហារអំពីព្រលឹម មកកាន់ក្រុងសាវត្ថីហើយ ពួកចោរក៏ចៀសចេញទៅ ដោយន័យដែលពោលហើយ ក្នុងរឿងមហាកាលនោះឯង ពួកមនុស្សឃើញហើយ ពោលថា បុគ្គលនេះធ្វើចោរកម្មក្នុងរាត្រីហើយ ធ្វើនូវអាកប្បកិរិយាដូចស្ដាប់ធម៌ត្រាច់ទៅ ចូរអ្នកទាំងឡាយ នាំគ្នាចាប់វាដូច្នេះហើយ វាយឧបាសកនោះ ។

ពួកនាងកុម្ភទាសីដើរទៅកំពង់ទឹក ជួបនូវហេតុនោះទើបពោលថា នែអ្នកទាំងឡាយ ចូរចៀសចេញទៅ បុរសនេះមិនធ្វើកម្មបែបនោះឡើយ ដូច្នេះហើយ ឲ្យមនុស្សទាំងនោះដោះលែងហើយ ចូលទៅកាន់វិហារ ប្រាប់ដល់ភិក្ខុទាំងឡាយថា បពិត្រលោកម្ចាស់ ខ្ញុំត្រូវពួកមនុស្សទាំងឡាយឲ្យវិនាសហើយ ខ្ញុំបានជីវិត ព្រោះអាស្រ័យពួកនាងកុម្ភទាសី ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនោះ ដល់ព្រះតថាគត ។

ព្រះសាស្ដា ទ្រង់ស្ដាប់ពាក្យរបស់ភិក្ខុទាំងនោះហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចុល្លកាលឧបាសកបានជីវិត ព្រោះអាស្រ័យនាងកុម្ភទាសីផង ភាពដែលខ្លួនមិនបានធ្វើផង ព្រោះថា ធម្មតាសត្វទាំងនេះ ធ្វើបាបកម្មដោយខ្លួនឯងហើយ រមែងសៅហ្មងដោយខ្លួនឯងក្នុងអបាយ មាននរកជាដើម ។ ចំណែកសត្វទាំងឡាយ ធ្វើកុសលហើយ ទៅកាន់សុគតិ និងនិព្វាន រមែងឈ្មោះថា បរិសុទ្ធបានដោយខ្លួនឯង ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**អត្តនា វ កតំ បាបំ អត្តនា សង្កិលិស្សតិ**

**អត្តនា អកតំ បាបំ អត្តនា វ វិសុជ្ឈតិ**
**សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ ។**

អ្នកធ្វើបាបខ្លួនឯង នឹងសៅហ្មងខ្លួនឯង អ្នកមិនធ្វើបាបខ្លួនឯង តែងបរិសុទ្ធស្អាតខ្លួនឯង សេចក្តីបរិសុទ្ធ និងមិនបរិសុទ្ធមានចំពោះខ្លួន អ្នកដទៃនឹងធ្វើអ្នកដទៃឲ្យបរិសុទ្ធពុំបានទេ ។

## សេចក្តីអធិប្បាយ

អត្ថនៃព្រះគាថានោះថា អកុសលកម្ម ជាកម្មដែលបុគ្គលណាធ្វើហើយដោយខ្លួន បុគ្គលនោះកាលសោយទុក្ខក្នុងអបាយ ៤ ឈ្មោះថា សៅហ្មងដោយខ្លួនឯង ចំណែកបាបដែលបុគ្គលណាមិនបានធ្វើដោយខ្លួនឯង បុគ្គលនោះ កាលទៅកាន់សុគតិ និងនិព្វាន ឈ្មោះថា បរិសុទ្ធដោយខ្លួនឯង ។ សេចក្តីបរិសុទ្ធ ពោល គឺកុសលកម្ម និងការមិនបរិសុទ្ធ ពោល គឺអកុសលកម្មជារបស់ចំពោះខ្លួន គឺរមែងឲ្យផលចំពោះខ្លួនរបស់សត្វអ្នកធ្វើទាំងឡាយ បុគ្គលដទៃធ្វើបុគ្គលដទៃឲ្យបរិសុទ្ធមិនបាន គឺឲ្យបរិសុទ្ធមិនបានឡើយ ឲ្យសៅហ្មងមិនបានដូចគ្នា ។

ក្នុងកាលចប់ទេសនា ចុល្លកាលតាំងនៅហើយក្នុងសោតាបត្តិផល ព្រះធម្មទេសនាមានប្រយោជន៍ដល់បរិស័ទដែលប្រជុំគ្នា ដូច្នោះឯង ។៚

**រឿង ឧបាសក ឈ្មោះ ចុល្លកាល ចប់**

# រឿង ព្រះអត្តទត្ថត្ថេរ

## លំនាំដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះអត្តទត្ថត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **អត្តទត្ថំ បរត្ថេន** ជាដើម ។

សេចក្ដីពិស្ដារថា កាលព្រះសាស្ដាត្រាស់ក្នុងកាលដែលទៀបបរិនិព្វាន ថា ម្នាលភិក្ខុទាំងឡាយ ដោយកាលកន្លងទៅ ៤ ខែបន្ទាប់អំពីថ្ងៃនេះ តថាគត នឹងបរិនិព្វាន ភិក្ខុប្រមាណ ៧០០ រូបដែលនៅជាបុថុជ្ជន កើតនូវសេចក្ដីសង្វេគ មិនលះសម្នាក់ព្រះសាស្ដាឡើយ ប្រឹក្សាគ្នាថា អាវុសោ ពួកយើងធ្វើអ្វីហ្ន៎ ។

ចំណែកព្រះអត្តទត្ថត្ថេរគិតថា បានឮថា ព្រះសាស្ដានឹងបរិនិព្វានដោយ កាលកន្លងទៅ ៤ ខែ ឯពួកយើងជាអ្នកមានរាគៈមិនទាន់ទៅប្រាស កាលព្រះ សាស្ដាគង់ព្រះជន្មនៅ ព្យាយាមដើម្បីប្រយោជន៍ដល់អរហត្ត ព្រះថេរៈនោះមិន ទៅសម្នាក់របស់ភិក្ខុទាំងឡាយ ។ លំដាប់នោះ ភិក្ខុទាំងឡាយពោលនឹងលោក ថា អាវុសោ ហេតុអ្វី ទើបមិនមកកាន់សម្នាក់របស់ខ្ញុំ លោកមិនប្រឹក្សារឿង អ្វីមួយ ដូច្នេះហើយ នាំទៅកាន់សម្នាក់ព្រះសាស្ដា ក្រាបទូលថា បពិត្រ ព្រះអង្គ ភិក្ខុរូបនេះ រមែងធ្វើវត្តឈ្មោះនេះ ។

ព្រះអត្តទត្ថត្ថេរនោះ សូម្បីព្រះសាស្ដាត្រាស់ថា ហេតុអ្វី ទើបអ្នកធ្វើ យ៉ាងនោះ ទើបក្រាបទូលថា បពិត្រព្រះអង្គ បានឮថា ទ្រង់នឹងបរិនិព្វាន ដោយកាលកន្លងទៅ ៤ ខែ ខ្ញុំព្រះអង្គព្យាយាមដើម្បីសម្រេចអរហត្តក្នុងកាល ទ្រង់គង់ព្រះជន្មនៅនេះឯង ។

ព្រះសាស្តា ប្រទានសាធុការដល់ព្រះថេរៈនោះហើយ ត្រាស់ថា ម្នាល ភិក្ខុទាំងឡាយ បុគ្គលណាមានសេចក្តីស្នេហាក្នុងតថាគត បុគ្គលនោះ គួរជាបុគ្គលដូចអត្ថទត្ថភិក្ខុនេះ ព្រោះថា ជនទាំងឡាយបូជាដោយវត្ថុផ្សេងៗ មានគ្រឿងក្រអូបជាដើម រមែងមិនឈ្មោះថាបូជាតថាគត ឯបុគ្គលបូជាដោយការបដិបត្តិធម៌សមគួរដល់ធម៌ ឈ្មោះថា បូជាតថាគត ព្រោះដូច្នោះ ភិក្ខុរូបដទៃក៏គប្បីដូចអត្ថទត្ថៈ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**អត្តទត្ថំ បរត្ថេន ពហុនាបិ ន ហាបយេ**

**អត្តទត្ថមភិញ្ញាយ សទត្ថបសុតោ សិយា ។**

បុគ្គល កុំគប្បីធ្វើប្រយោជន៍ខ្លួនឲ្យវិនាស ព្រោះប្រយោជន៍របស់ជនដទៃសូម្បីច្រើន បើដឹងច្បាស់នូវប្រយោជន៍របស់ខ្លួនហើយ គប្បីខ្វល់ខ្វាយក្នុងប្រយោជន៍របស់ខ្លួន ( នោះ ) ។

## សេចក្តីអធិប្បាយ

អត្ថនៃព្រះគាថានោះថា បុគ្គលជាគ្រហស្ថ មិនគប្បីញុំាងប្រយោជន៍របស់ខ្លួន សូម្បីប្រមាណមួយកាកណិកឲ្យវិនាស ព្រោះប្រយោជន៍អ្នកដទៃ សូម្បីមានតម្លៃរាប់ពាន់ ព្រោះថា ប្រយោជន៍របស់ខ្លួននៃបុគ្គលនោះឯង សូម្បីប្រមាណមួយកាកណិក ក៏គង់ញុំាងរបស់ទំពា ឬរបស់គួរបរិភោគឲ្យសម្រេចបាន ប្រយោជន៍របស់អ្នកដទៃមិនសម្រេចឡើយ ។ ចំណែកពីរបាទព្រះគាថាទាំងនេះ ព្រះដ៏មានព្រះភាគទ្រង់មិនត្រាស់យ៉ាងនោះ ត្រាស់ដោយមាតិកានៃកម្មដ្ឋាន ព្រោះដូច្នោះ ភិក្ខុតាំងចិត្តថា អញនឹងមិនញុំាងប្រយោជន៍របស់ខ្លួន

ឲ្យវិនាស ដូច្នេះហើយ មិនគប្បីញ៉ាំងកិច្ចមានការជួសជុលព្រះចេតិយជាដើម ដែលកើតឡើងដល់សង្ឃ ឬវត្ថុ មានឧបជ្ឈាយវត្តជាដើមឲ្យវិនាស ព្រោះថា ភិក្ខុបំពេញអភិសមាចារិកវត្តឲ្យសម្បូរនោះឯង រមែងធ្វើឲ្យជាក់ច្បាស់នូវផល ទាំងឡាយ មានអរិយផលជាដើម ព្រោះដូច្នោះ ការបំពេញវត្តឲ្យបរិបូណ៌នេះ ទើបឈ្មោះថា ជាប្រយោជន៍ដល់ខ្លួនពិត ។

ម្យ៉ាងទៀត ភិក្ខុណាមានវិបស្សនាដែលប្រារព្ធក្រៃលែងហើយ ប្រាថ្នាការ ចាក់ធ្លុះថា អាត្មាទឹងត្រាស់ដឹងក្នុងថ្ងៃនេះៗ ឯង ដូច្នេះហើយ ប្រព្រឹត្ត ភិក្ខុ នោះញ៉ាំងវត្ត មានឧបជ្ឈាយវត្តជាដើមឲ្យវិនាសហើយ ក៏គប្បីធ្វើកិច្ចរបស់ខ្លួន ឲ្យបាន ។ ភិក្ខុដឹងប្រយោជន៍របស់ខ្លួនបែបនោះ គឺកំណត់បានថា នេះជាប្រ-យោជន៍របស់អាត្មា គប្បីជាអ្នកខ្វល់ខ្វាយប្រកបក្នុងប្រយោជន៍របស់ខ្លួននោះ ។

ក្នុងកាលចប់ទេសនា ព្រះថេរៈនោះបានតាំងនៅក្នុងអរហត្តផល ទេសនា បានជាប្រយោជន៍ដល់ភិក្ខុដែលប្រជុំគ្នាទាំងឡាយ ដូច្នោះឯង ។៚

## រឿង ព្រះអត្តទត្ថត្ថេរ ចប់

## អត្តវគ្គទី១២ ចប់

# ក្បាលទី –៣៣

# សុត្តន្តបិដក ចាលីប្រែ –៥២

## ចិត្តវគ្គទី ៣


រឿងមេឃិយត្ថេរ ...... ...... ...... ...... ៤

រឿងអញ្ញត្រភិក្ខុ ...... ...... ...... ...... ៨

រឿងឧក្កណ្ឋិតភិក្ខុ ...... ...... ...... ...... ២១

រឿងក្មួយរបស់ព្រះសង្ឃរក្ខិតត្ថេរ ...... ...... ...... ...... ២៥

រឿងព្រះចិត្តហត្ថត្ថេរ ...... ...... ...... ...... ៣១

រឿងភិក្ខុប្រារព្ធវិបស្សនា ...... ...... ...... ...... ៤១

រឿងបូតិគត្តិស្សត្ថេរ ...... ...... ...... ...... ៤៨

រឿងនន្ទគោបាលកៈ ...... ...... ...... ...... ៥៣

រឿងសោរេយ្យត្ថេរ ...... ...... ...... ...... ៥៧


## បុប្ផវគ្គទី ៤ ( ៦៧ )


រឿងភិក្ខុ ៥០០ ដែលខ្វល់ខ្វាយក្នុងបឋវីកថា ...... ...... ៧០

រឿងព្រះថេរៈចម្រើនមរីចិកម្មដ្ឋាន ...... ...... ...... ...... ៧៣

រឿងព្រះបាទវិឌូឌកៈ ...... ...... ...... ...... ៧៦

រឿងនាងបតិបូជិកា ...... ...... ...... ...... ១០៧

រឿងកោសិយសេដ្ឋី ...... ...... ...... ...... ១១២

រឿងបាជិកាជីវក ...... ...... ...... ...... ១២៣

រឿងឆត្តបាណិឧបាសក ...... ...... ...... ...... ១២៨

រឿងនាងវិសាខា ...... ...... ...... ...... ១៧៤
រឿងបញ្ហារបស់ព្រះអានន្ទត្ថេរ ...... ...... ...... ...... ១៧៨
រឿងប្រគេនបិណ្ឌបាតដល់ព្រះមហាកស្សបត្ថេរ ...... ...... ១៨២
រឿងបរិព្វានរបស់ព្រះគោធិកត្ថេរ ...... ...... ...... ...... ១៩០
រឿងគរហទិន្ន ...... ...... ...... ...... ១៩៥

## ពាលវគ្គទី ៥ ( ២១០ )

រឿងអញ្ញត្របុរស ...... ...... ...... ...... ២១៣
រឿងសទ្ធិវិហារិករបស់ព្រះមហាកស្សបត្ថេរ ...... ....... ២៣៦
រឿងអានន្ទសេដ្ឋី ...... ...... ...... ...... ២៤៤
រឿងគណ្ឋិភេទកចោរ ...... ...... ...... ...... ២៤៩
រឿងព្រះឧទាយិត្ថេរ ...... ...... ...... ...... ២៥២
រឿងភិក្ខុអ្នកក្រុងបាវា ...... ...... ...... ...... ២៥៤
រឿងសុប្បពុទ្ធកុដ្ឋិ ...... ...... ...... ...... ២៥៦
រឿងអ្នកស្រែ ...... ...... ...... ...... ២៦០
រឿងសុមនមាលាការ ...... ...... ...... ...... ២៦៥
រឿងឧប្បលវណ្ណាថេរី ...... ...... ...... ...... ២៧៣
រឿងជម្ពុកាជីវក ...... ...... ...... ...... ២៧៨
រឿងអហិប្រេត ...... ...... ...... ...... ២៩២
រឿងសដ្ឋិកូដប្រេត ...... ...... ...... ...... ២៩៩
រឿងព្រះសុធម្មត្ថេរ ...... ...... ...... ...... ៣០៥

រឿងព្រះវនវាសីតិស្សត្ថេរ ...... ...... ...... ...... ៣១៩

បណ្ឌិតវគ្គទី ៦ ( ៣៤៤ )

រឿងព្រះរាធត្ថេរ ...... ...... ...... ...... ៣៤៧

រឿងអស្សជិភិក្ខុ និងបុនព្វសុកៈ ...... ...... ...... ...... ៣៥៣

រឿងព្រះឆន្នត្ថេរ ...... ...... ...... ...... ៣៥៦

រឿងព្រះមហាកប្បិនត្ថេរ ...... ...... ...... ...... ៣៥៨

រឿងបណ្ឌិតសាមណេរ ...... ...... ...... ...... ៣៧៧

រឿងព្រះលកុណ្ឌកភទ្ទិយត្ថេរ ...... ...... ...... ...... ៤០០

រឿងមាតារបស់នាងកាណា ...... ...... ...... ...... ៤០២

រឿងភិក្ខុ ៥០០ រូប ...... ...... ...... ...... ៤០៨

រឿងព្រះថេរៈតាំងនៅក្នុងធម៌ ...... ...... ...... ...... ៤១២

រឿងការស្តាប់ធម៌ ...... ...... ...... ...... ៤១៥

រឿងអាគន្តុកភិក្ខុ ...... ...... ...... ...... ៤១៨

អរហន្តវគ្គទី ៧ ( ៤២២ )

រឿងពេទ្យជីវក ...... ...... ...... ...... ៤២៤

រឿងព្រះមហាកស្សបត្ថេរ ...... ...... ...... ...... ៤២៨

រឿងព្រះវេឡដ្ឋសីសត្ថេរ ...... ...... ...... ...... ៤៣៣

រឿងព្រះអនុរុទ្ធត្ថេរ ...... ...... ...... ...... ៤៣៦

រឿងមហាកច្ចាយនត្ថេរ ...... ...... ...... ...... ៤៤០

រឿងព្រះសារីបុត្តត្ថេរ ...... ...... ...... ...... ៤៤៣

រឿងព្រះតិស្សត្ថេរអ្នកក្រុងកោសម្ពី ...... ...... ...... ...... ៤៤៨
រឿងព្រះសារីបុត្តត្ថេរ ...... ...... ...... ...... ៤៥៣
រឿងព្រះខទិរវនិយរេវតត្ថេរ ...... ...... ...... ...... ៤៥៦
រឿងអញ្ញតរិត្ថី ...... ...... ...... ...... ៤៧០

សហស្សវគ្គទី ៨ ( ៤៧០ )

រឿងតម្ពទាឋិកចោរឃាតក ...... ...... ...... ...... ៤៧៦
រឿងព្រះទារុចីរិយត្ថេរ ...... ...... ...... ...... ៤៨៣
រឿងព្រះនាងកុណ្ឌលកេសីថេរី ...... ...... ...... ...... ៤៩២
រឿងអនត្ថបុច្ឆកព្រាហ្មណ៍ ...... ...... ...... ...... ៥០៣
រឿងព្រាហ្មណ៍ជាអ៊ំរបស់ព្រះសារីបុត្តត្ថេរ ... ...... ...... ៥០៦
រឿងព្រាហ្មណ៍ជាក្មួយរបស់ព្រះសារីបុត្តត្ថេរ ... ...... ...... ៥០៩
រឿងព្រាហ្មណ៍ជាសម្លាញ់របស់ព្រះសារីបុត្តត្ថេរ ... ....... ៥១១
រឿងអាយុវឌ្ឍនកុមារ ...... ...... ...... ...... ៥១៣
រឿងសង្កិច្ចសាមណេរ ...... ...... ...... ...... ៥១៩
រឿងព្រះខាណុកោណ្ឌញ្ញត្ថេរ ...... ...... ...... ...... ៥៣៣
រឿងព្រះសប្បទាសត្ថេរ ...... ...... ...... ...... ៥៣៦
រឿងនាងបដាចារា ...... ...... ...... ...... ៥៤១
រឿងកិសាគោតមី ...... ...... ...... ...... ៥៥១
រឿងពហុបុត្តកាថេរី ...... ...... ...... ...... ៥៥៧

បាបវគ្គទី ៩ ( ៥៦១ )

រឿងព្រាហ្មណ៍ឈ្មោះចូឡេកសាដក ...... ...... ...... ...... ៥៦៤
រឿងព្រះសេយ្យសកត្ថេរ ...... ...... ...... ...... ៥៧០
រឿងនាងលាជទេពធីតា ...... ...... ...... ...... ៥៧១
រឿងអនាថបិណ្ឌិកសេដ្ឋី ...... ...... ...... ...... ៥៧៦
រឿងភិក្ខុមិនទុកដាក់បរិក្ខារ ...... ...... ...... ...... ៥៨៣
រឿងសេដ្ឋីឈ្មោះវិឡាលបទក: ...... ...... ...... ...... ៥៨៦
រឿងមហាធនពាណិជ្ជ ...... ...... ...... ...... ៥៩១
រឿងកុក្កុដមិត្ត ...... ...... ...... ...... ៥៩៥
រឿងព្រានសុនខឈ្មោះកោក: ...... ...... ...... ...... ៦០៤
រឿងព្រះតិស្សត្ថេរកុលុបក:របស់ជាងកែវ .... ...... ...... ៦០៨
រឿងជន ៣ ពួក ...... ...... ...... ...... ៦១២
រឿងព្រះបាទសុប្បពុទ្ធសក្យ: ...... ...... ...... ...... ៦១៩

ទណ្ឌវគ្គទី ១០ ( ៦២៤ )

រឿងឆព្វគ្គិយភិក្ខុ ...... ...... ...... ...... ៦២៧
រឿងឆព្វគ្គិយភិក្ខុ ...... ...... ...... ...... ៦២៩
រឿងកុមារច្រើននាក់ ...... ...... ...... ...... ៦៣១
រឿងព្រះកោណ្ឌធានត្ថេរ ...... ...... ...... ...... ៦៣៣
រឿងឧបោសថកម្ម ...... ...... ...... ...... ៦៤២
រឿងអជគរប្រេត ...... ...... ...... ...... ៦៤៤
រឿងព្រះមហាមោគ្គល្លានត្ថេរ ...... ...... ...... ...... ៦៥០

រឿងភិក្ខុមានកណ្ឋៈច្រើន ...... ...... ...... ...... ៦៥៨

រឿងសន្តតិមហាមាត្យ ...... ...... ...... ...... ៦៦៧

រឿងព្រះបិលោតិកត្ថេរ ...... ...... ...... ...... ៦៧៤

រឿងសុខសាមណេរ ...... ...... ...... ...... ៦៧៨

ជរាវគ្គទី ១១ ( ៦៩៥ )

រឿងស្រីសម្លាញ់របស់នាងវិសាខា ...... ...... ...... ...... ៦៩៧

រឿងនាងសិរិមា ...... ...... ...... ...... ៧០២

រឿងនាងឧត្តរាថេរី ...... ...... ...... ...... ៧០៩

រឿងព្រះអធិមានិកភិក្ខុ ...... ...... ...... ...... ៧១១

រឿងនាងរូបនន្ទាថេរី ...... ...... ...... ...... ៧១៣

រឿងព្រះនាងមល្លិកាទេវី ...... ...... ...... ...... ៧២០

រឿងព្រះលោឡុទាយិត្ថេរ ...... ...... ...... ...... ៧២៥

រឿងបឋមពោធិកាល ...... ...... ...... ...... ៧៣១

រឿងសេដ្ឋីបុត្រមានទ្រព្យច្រើន ...... ...... ...... ...... ៧៣៤

អត្តវគ្គទី ១២ ( ៧៤០ )

រឿងពោធិរាជកុមារ ...... ...... ...... ...... ៧៤២

រឿងព្រះឧបនន្ទសក្យបុត្រ ...... ...... ...... ...... ៧៤៩

រឿងព្រះបធានិកតិស្សត្ថេរ ...... ...... ...... ...... ៧៥៤

រឿងមាតាព្រះកុមារកស្សបត្ថេរ ...... ...... ...... ...... ៧៥៧

រឿងឧបាសកឈ្មោះមហាកាល ...... ...... ...... ...... ៧៦៣

រឿងទេវទត្តភិក្ខុ ...... ...... ...... ...... ៧៦៧

រឿងទេវទត្តបំបែកសង្ឃ ...... ...... ...... ...... ៧៧០

រឿងព្រះកាលត្ថេរ ...... ...... ...... ...... ៧៧២

រឿងឧបាសកឈ្មោះចុល្លកាល ...... ...... ...... ...... ៧៧៤

រឿងព្រះអត្តទត្ថត្ថេរ ...... ...... ...... ...... ៧៧៧